# ព្រះ ត្រៃបិដក

## ប្រែរួមនឹង ព្រះអដ្ឋកថា

## ភាគ៣៤

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# សុត្តន្តបិដក

## និង

# បរមត្ថជោតិកា អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ

# ខុទ្ទកបាឋ ធម្មបទគាថា ឧទាន

# បឋមភាគ

# ៣៤

# បាលីប្រែ ៥២

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ភាគទី ៣៤

# សុត្តន្តបិដក ខុទ្ទកនិកាយ

## ធម្មបទគាថា លោកវគ្គទី ១៣

[ ២៣ ] បុគ្គល មិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចម្រើនលោក ។

បុគ្គល មិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បុគ្គល គួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បុគ្គល ឃើញពពុះទឹក យ៉ាងណា ឃើញព្រេញថ្ងៃ យ៉ាងណា ស្តេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

អ្នកទាំងឡាយ ចូរមកមើលលោកនេះ ដ៏ត្រកាល ដូចរាជរថ ជនពាលទាំងឡាយ រមែងលិចលង់ ក្នុងលោកណា សេចក្តីជាប់ជំពាក់ ក្នុងលោកនោះ រមែងមិនមាន ដល់ជនជាបណ្ឌិតទាំងឡាយដែលដឹងច្បាស់ទេ ។

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយគេមិនប្រមាទវិញ បុគ្គលនោះ ឈ្មោះថា ញុំាងខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រដែលរួចផុតចាកពពក ។

បុគ្គលណា ធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះដោយកុសល គឺអរហត្តមគ្គបាន បុគ្គលនោះឈ្មោះថា ញ៉ាំងខន្ធាទិលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្ររះផុតចាកពពក ។

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជនតិចគ្នា ដែលឃើញច្បាស់ ( នូវខន្ធាទិលោកនេះ ដោយអំណាចអនិច្ចលក្ខណៈជាដើម ) ជនតិចគ្នា ដែលទៅកាន់ស្ថានសួគ៌ ដូចសត្វស្លាប ( ដែលជាប់សំណាញ់របស់ព្រានហើយ ) តិចណាស់ ដែលរួចអំពីសំណាញ់ ដូច្នោះ ។

ពួកហង្ស តែងហើរទៅក្នុងគន្លងផ្លូវព្រះអាទិត្យ អ្នកមានឫទ្ធិ តែងហោះទៅក្នុងអាកាស ដោយឫទ្ធិ អ្នកប្រាជ្ញផ្ចាញ់កិលេសមារ ព្រមទាំងវាហនៈ គឺតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញចាកលោកបាន ។ បុគ្គលប្រព្រឹត្តកន្លង ( ពាក្យសច្ចៈ ) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោក លះចោលហើយ ឈ្មោះថា មិនធ្វើអំពើបាប មិនមែនឡើយ ។

បុគ្គល កំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានឡើយ ចំណែកអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបានសេចក្តីសុខ ក្នុងលោកខាងមុខ ។ សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ស្ថានសួគ៌ផង ជាងភាពជាធំ ក្នុងលោកទាំងមូលផង ។

**លោកវគ្គទី ១៣ ចប់**

# អដ្ឋកថា
# លោកវគ្គទី ១៣

## រឿង ភិក្ខុកំលោះ
### លំនាំដើម

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះមួយរូប ត្រាស់ព្រះធម្មទេសនានេះថា* **ហីនំ ធម្មំ** *ជាដើម ។*

*បានឮថា ព្រះថេរៈមួយរូប មួយអន្លើដោយភិក្ខុកំលោះ ទៅកាន់ផ្ទះរបស់នាងវិសាខាអំពីព្រលឹម បបរប្រចាំ រមែងជារបស់ដែលគេរៀបចំជានិច្ចដើម្បីភិក្ខុប្រមាណ ៥០០ រូប ក្នុងផ្ទះរបស់នាងវិសាខា ព្រះថេរៈឆាន់បបរហើយ ឲ្យភិក្ខុកំលោះអង្គុយលើផ្ទះរបស់នាងវិសាខានោះ ចំណែកខ្លួនបានទៅកាន់ផ្ទះមួយខ្នងដទៃទៀត ។ សម័យនោះ កូនស្រីរបស់កូននាងវិសាខាតាំងនៅក្នុងឋានៈរបស់យាយ ធ្វើការខ្វល់ខ្វាយដល់ភិក្ខុទាំងឡាយ ។ នាងត្រងទឹកដើម្បីភិក្ខុកំលោះនោះ ឃើញស្រមោលមុខរបស់ខ្លួនក្នុងថ្លាង ទើបសើច ភិក្ខុកំលោះសម្លឹងមើលនាងក៏សើច នាងឃើញភិក្ខុកំលោះនោះសើច ទើបពោលថា បុគ្គលដាច់ក្បាលរមែងសើច លំដាប់នោះ ភិក្ខុកំលោះជេរនាងថា នាងក៏ដាច់ក្បាល ម៉ែ និងឪរបស់នាង ក៏ដាច់ក្បាល នាងយំទៅកាន់សម្នាក់របស់ជីដូនក្នុងរោងបាយ កាលនាងវិសាខាពោលថា នែនាង តើនាងកើតអ្វី ទើប*

ប្រាប់សេចក្ដីនោះ ។ នាងវិសាខាមកកាន់សម្នាក់របស់ភិក្ខុកំលោះហើយ ពោលថា បពិត្រលោកម្ចាស់ កុំក្រោធឡើយ ពាក្យនោះ មិនជាពាក្យជូនសម្រាប់លោកម្ចាស់ទេ បុគ្គលមានសក់ និងក្រចកកាត់ហើយ មានសំពត់ដណ្ដប់កាត់ដាច់ហើយ កាន់អំបែងដែលកាត់ត្រង់កណ្ដាល ត្រាច់ទៅដើម្បីភិក្ខា ។ ភិក្ខុកំលោះពោលថា អើ ឧបាសិកា នាងរមែងដឹងភាពដែលអាត្មាជាអ្នកមានសក់កាត់ដាច់ហើយជាដើម ការដែលចៅរបស់នាងជេរអាត្មាថា មនុស្សដាច់ក្បាលដូច្នេះ គួរឬ នាងវិសាខាមិនអាចឲ្យភិក្ខុកំលោះយល់ព្រមផង មិនអាចឲ្យនាងទារិកាយល់ព្រមផង ខណៈនោះ ព្រះថេរៈមកហើយ សួរថា តើមានរឿងអ្វី ឧបាសិកា ស្ដាប់សេចក្ដីនោះហើយ កាលពោលប្រៀនប្រដៅភិក្ខុកំលោះ ទើបពោលថា អាវុសោ ចូរលោកចៀសចេញទៅ ស្រីនេះ មិនបានជេរចំពោះលោក ដែលមានសក់ ក្រចក និងសំពត់កាត់ដាច់ហើយ ជាអ្នកមានអំបែងកាត់ត្រង់កណ្ដាល ត្រាច់ទៅដើម្បីភិក្ខា ចូរលោកនៅស្ងៀម ភិក្ខុកំលោះពោលថា យ៉ាងនោះឯង លោកម្ចាស់ លោកម្ចាស់មិនគំរាមឧបដ្ឋាយិការបស់ខ្លួន គំរាមខ្ញុំតែម្យ៉ាង ការដែលនាងជេរខ្ញុំថា មនុស្សដាច់ក្បាល គួរឬ ។ ខណៈនោះ ព្រះសាស្ដាយាងមក ត្រាស់សួរថា ម្នាលនាងវិសាខា តើមានរឿងអ្វី នាងវិសាខាក្រាបទូលព្រឹត្តិហេតុនោះ តាំងអំពីដើមដល់ចប់ ។

ព្រះសាស្ដា ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់ភិក្ខុកំលោះនោះហើយ ទើបទ្រង់ព្រះតម្រិះថា តថាគតអនុលោមតាមភិក្ខុកំលោះនេះគួរដូច្នេះហើយ ទើបត្រាស់នឹងនាងវិសាខាថា ម្នាលនាងវិសាខា ទារិការបស់នាង

ដេរ ធ្វើសាវ័កទាំងឡាយរបស់តថាគតឲ្យជាអ្នកមានក្បាលដាច់ ដោយហេតុត្រឹមតែមានសក់កោរហើយជាដើមនោះឯង គួរឬ ភិក្ខុកំលោះក្រោកឡើង ផ្គងអញ្ជលីក្នុងវេលានោះឯង ក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់រមែងជ្រាបបញ្ហានោះដោយល្អ ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ និងមហាឧបាសិកា មិនជ្រាបដោយល្អឡើយ ។ ព្រះសាស្តា ទ្រង់ជ្រាបភាពដែលទ្រង់ជាអ្នកអនុគ្រោះដល់ភិក្ខុកំលោះហើយ ត្រាស់ថា ឈ្មោះថា ការកើត គឺការសើច ប្រារព្ធកាមគុណជាធម៌ដ៏លាមក ម្យ៉ាងទៀត ការសេពធម៌ដែលឈ្មោះថាលាមក និងការនៅរួមជាមួយសេចក្តីប្រមាទ មិនគួរ ទើបត្រាស់ព្រះគាថាថា

**ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ**
**មិច្ឆាទិដ្ឋឹ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ ។**

បុគ្គល មិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្អៀតលោក ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ហីនំ ធម្មំ** បានដល់ ធម៌ គឺបញ្ចកាមគុណ ។ ពិតហើយ ធម៌ គឺបញ្ចកាមគុណនោះ ដែលជនថោកទាប ដោយហោចសត្វឱដ្ឋ និងសត្វគោជាដើមគប្បីសេព ធម៌ គឺបញ្ចកាមគុណ រមែងឲ្យសត្វអ្នកសេពកើតក្នុងឋានៈទាំងឡាយ មាននរកជាដើមដ៏ថោកទាប ព្រោះហេតុនោះ ធម៌ គឺបញ្ចកាមគុណនោះ ទើបឈ្មោះថា ជាធម៌ថោកទាប បុគ្គលមិន

គប្បីសេពធម៌ដ៏ថោកទាបនោះ ។ បទថា **បមាទេន** សេចក្ដីថា មិនគប្បីនៅរួមដោយសេចក្ដីប្រមាទ មានការបណ្ដែតបណ្ដោយសតិជាលក្ខណៈ ។ បទថា **ន សេវេយ្យ** បានដល់ មិនគប្បីកាន់យកនូវមិច្ឆាទិដ្ឋិ ។ បទថា **លោកវឌ្ឍនោ** សេចក្ដីថា បុគ្គលណាធ្វើយ៉ាងនេះ បុគ្គលនោះ រមែងឈ្មោះថា ជាមនុស្សបង្អៀតលោក ព្រោះហេតុនោះ មិនគប្បីជាមនុស្សបង្អៀតលោកឡើយ ព្រោះមិនធ្វើយ៉ាងនោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុកំលោះនោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាបានជាប្រយោជន៍ដល់ជនទាំងឡាយ ដែលប្រជុំគ្នាដូច្នេះឯង ។ល។

**រឿង ភិក្ខុកំលោះ ចប់**

# រឿង ព្រះបាទសុទ្ធោទនៈ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធព្រះបិតា ត្រាស់ព្រះធម្មទេសនានេះថា **ឧត្តិដ្ឋេ នប្បមជ្ជេយ្យ** ជាដើម ។

សេចក្ដីពិស្ដារថា សម័យមួយ ព្រះសាស្ដាយាងទៅកាន់ក្រុងកបិលវត្ថុជាលើកទីមួយ មានការទទួលដែលព្រះញាតិទាំងឡាយធ្វើហើយ ។ ទ្រង់ទៅកាន់និគ្រោធារាម ទ្រង់និម្មិតខ្នងចង្ក្រមក្នុងអាកាស ចង្ក្រមលើរតនចង្ក្រមនោះ ទ្រង់សម្ដែងធម៌ដើម្បីទម្លាយមានះ របស់ពួកញាតិទាំងឡាយហើយ ព្រះញាតិ

ទាំងឡាយមានចិត្តជ្រះថ្លាហើយ ថ្វាយបង្គំ ចាប់តាំងអំពីព្រាទសុទ្ធោទនមហារាជ ។ ភ្លៀងបោក្ខរព័ស្សិធ្លាក់ក្នុងសមាគមនៃព្រះញាតិនោះ ។ កាលមហាជនប្រារព្ធភ្លៀងនោះ សន្ទនាគ្នាហើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភ្លៀងបោក្ខរព័ស្សិក៏ធ្លាក់ក្នុងសមាគមនៃញាតិរបស់តថាគតដូចគ្នា ដូច្នេះហើយ ទើបត្រាស់វេស្សន្តរជាតក ។ បណ្តាព្រះញាតិដែលស្តាប់ព្រះធម្មទេសនាហើយ ចៀសចេញទៅ សូម្បីមួយអង្គ ក៏មិននិមន្តព្រះសាស្តា សូម្បីព្រះរាជាក៏ទ្រង់មិននិមន្តឡើយ ដោយទ្រង់ព្រះតម្រិះថា បុត្ររបស់អញ បើមិនមកកាន់ផ្ទះ តើនឹងទៅណា ដូច្នេះហើយ ក៏យាងទៅ ។ កាលទ្រង់យាងទៅហើយ ឲ្យមនុស្សតាក់តែងបបរជាដើម ឲ្យក្រាលអាសនៈទាំងឡាយ ដើម្បីភិក្ខុប្រមាណ ២ ម៉ឺនរូប ក្នុងព្រះរាជមន្ទីរ ។

ស្អែកឡើង ព្រះសាស្តាយាងចូលទៅកាន់ព្រះនគរដើម្បីបិណ្ឌបាត ទ្រង់ពិចារណាថា ព្រះពុទ្ធក្នុងអតីតទាំងឡាយ យាងដល់ព្រះនគរព្រះបិតាហើយ យាងទៅកាន់ត្រកូលនៃព្រះញាតិតែម្តងឬហ្ន៎ ឬទៅដើម្បីបិណ្ឌបាតដោយលំដាប់ ទ្រង់ឃើញថា ទៅបិណ្ឌបាតដោយលំដាប់ ដូច្នេះហើយ ទើបយាងទៅដើម្បីបិណ្ឌបាតតាំងអំពីផ្ទះទីមួយ ។ រាហុលមាតា ប្រថាប់គង់លើប្រាសាទឃើញហើយ ទើបក្រាបទូលបវត្តិហេតុនោះដល់ព្រះរាជា ព្រះរាជាទ្រង់រៀបចំសំពត់សាដក ម្ទីម្នាយាងចេញទៅ ថ្វាយបង្គំព្រះសាស្តាហើយ ត្រាស់ថា បពិត្រអយ្យបុត្រ ព្រោះហេតុអ្វី ទើបបុត្រធ្វើឲ្យបិតាវិនាស បុត្រត្រាច់ទៅដើម្បីភិក្ខា

ឲ្យនូវការខ្មាសកើតឡើងហើយដល់បិតាពន់ពេក ឈ្មោះថា កម្មមិនគួរធ្វើ បុត្រធ្វើបានហើយ ការដែលបុត្រត្រាច់ទៅដោយវមាសជាដើម ត្រាច់ទៅដើម្បីភិក្ខាក្នុងនគរនេះឯង ទើបគួរ កូនកុំធ្វើឲ្យបិតាខ្មាសធ្វើឡើយ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ តថាគតមិនមែនឲ្យទ្រង់ខ្មាសឡើយ តែតថាគតប្រព្រឹត្តតាមវង្សត្រកូលរបស់ខ្លួន ព្រះរាជាត្រាស់ថា បពិត្រអយ្យបុត្រ ការត្រាច់ទៅដើម្បីភិក្ខារស់នៅ ជាវង្សរបស់ខ្ញុំឬ ព្រះសាស្តាត្រាស់ថា មហាបពិត្រ នុ៎ះមិនមែនជាវង្សរបស់ទ្រង់ទេ តែជាវង្សរបស់តថាគត ព្រោះព្រះពុទ្ធមិនមែនមួយពាន់អង្គ ទ្រង់យាងទៅដើម្បីបិណ្ឌបាតហើយ រស់នៅដូចគ្នាដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានភាសិតគាថាទាំងនេះថា

**ឧត្តិដ្ឋេ នប្បមជ្ជេយ្យ ធម្មំ សុចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។**
**ធម្មំ ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។**

បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេក

ជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧត្តិដ្ឋេ** សេចក្តីថា ក្នុងដុំបាយដែលខ្លួនគប្បីក្រោកឡើងទទួលត្រង់ទ្វារផ្ទះរបស់ជនដទៃ ។ បទថា **នប្បមជ្ជេយ្យ** សេចក្តីថា ភិក្ខុកាលឲ្យទំនៀមរបស់អ្នកត្រាច់បិណ្ឌបាតជាប្រក្រតីវិនាសហើយ រមែងស្វែងរកភោជនដ៏ប្រណីត ឈ្មោះថា រមែងប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីទទួលជាដើម តែបើត្រាច់ទៅតាមលំដាប់ច្រកដើម្បីបិណ្ឌបាត ឈ្មោះថា មិនប្រមាទ ។ ធ្វើយ៉ាងនេះ ឈ្មោះថា មិនប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល ។

បទថា **ធម្មំ** សេចក្តីថា កាលលះការស្វែងរកដែលមិនគួរហើយត្រាច់ទៅតាមលំដាប់ច្រក ឈ្មោះថាគប្បីប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខានោះឯងឲ្យជាសុចរិត ។ ពាក្យថា **សុខំ សេតិ** នោះ ត្រឹមតែជាទេសនា អធិប្បាយថា កាលប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខា ឈ្មោះថាប្រព្រឹត្តធម៌ជាប្រក្រតីរមែងនៅជាសុខដោយឥរិយាបថទាំង ៤ ក្នុងលោកនេះ និងលោកខាងមុខ ។

ពីរបទថា **ន តំ ទុច្ចរិតំ** សេចក្តីថា កាលត្រាច់ទៅក្នុងអគោចរ មានកន្លែងស្រីបេស្យាជាដើម ឈ្មោះថា រមែងប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខាឲ្យជាទុច្ចរិត មិនប្រព្រឹត្តយ៉ាងនោះ គប្បីប្រព្រឹត្តធម៌នោះ ឲ្យជាសុចរិត មិនគប្បីប្រព្រឹត្តធម៌នោះ ឲ្យជាទុច្ចរិតឡើយ ។ ពាក្យដ៏សេស មានអត្ថដូចពោលហើយ ។

ក្នុងកាលចប់ទេសនា ព្រះរាជាតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់ជនទាំងឡាយដែលប្រជុំគ្នា ដូច្នេះឯង ។

**រឿង ព្រះចាទសុទ្ធោទនៈ ចប់**

# រឿង ភិក្ខុចម្រើនវិបស្សនា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចម្រើនវិបស្សនាមានប្រមាណ ៥០០ រូប ត្រាស់ព្រះធម្មទេសនានេះថា **យថា បុព្វុឡកំ បស្សេ** ជាដើម ។

បានឮថា ភិក្ខុទាំងនោះ រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយ ចូលទៅកាន់ព្រៃដើម្បីព្យាយាម ក៏មិនបានសម្រេចគុណវិសេស ទើបគិតថា ពួកយើងនឹងរៀនកម្មដ្ឋានឲ្យវិសេស កំពុងត្រឡប់មកកាន់សម្នាក់របស់ព្រះដ៏មានព្រះភាគ ឃើញថ្ងៃបណ្តើរកូនក្នុងវាលផ្លូវ ចម្រើនកម្មដ្ឋាន មានថ្ងៃបណ្តើរកូនជាអារម្មណ៍នោះឯងមកហើយ ។ ភ្លៀងធ្លាក់ក្នុងខណៈនៃភិក្ខុទាំងនោះចូលទៅកាន់វិហារនោះឯង ។ ភិក្ខុទាំងនោះ ឈរត្រង់យ៉មុខនោះ ឃើញពពុះទឹកទាំងឡាយតាំងឡើងហើយ បែកទៅដោយរហ័សដោយកម្លាំងខ្សែទឹក កាន់យកជាអារម្មណ៍ថា អត្តភាពនេះដូចគ្នានឹងដុំពពុះទឹក ព្រោះអត្ថថា កើតឡើងហើយបែកទៅដូចគ្នា ។ ព្រះសាស្តា ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់សម្លឹង

មើលភិក្ខុទាំងនោះហើយ ទ្រង់ផ្សាយព្រះឱភាស ត្រាស់ជាមួយភិក្ខុទាំងនោះហើយ ដោយព្រះគាថានេះថា

**យថា បុព្វុឡកំ បស្សេ យថា បស្សេ មរីចិកំ**
**ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។**

បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រេញថ្ងៃយ៉ាងណា ស្តេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើមយ៉ាងនោះទេ ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មរីចិកំ** គឺថ្ងៃបណ្តើរកូន ពិតហើយ ថ្ងៃបណ្តើរកូន សូម្បីប្រាកដឡើងអំពីចម្ងាយ ដោយអំណាចមានសណ្ឋានដូចផ្ទះជាដើម ជារបស់បុគ្គលនោះ ដល់នូវភាពជារូបដែលកាន់យកមិនបាន ជារបស់ទទេពិត គឺរមែងប្រាកដដល់ជនទាំងឡាយដែលចូលទៅជិត ព្រោះហេតុនោះ ទើបមានអធិប្បាយថា ស្តេចមច្ចុ រមែងមិនឃើញបុគ្គលដែលពិចារណាឃើញនូវលោក មានខន្ធជាដើម ដូចបុគ្គលគប្បីឃើញពពុះទឹក ព្រោះអត្ថថា កើតឡើងហើយបែកទៅ និងដូចបុគ្គលឃើញថ្ងៃបណ្តើរកូន ព្រោះជាធម្មជាតិទទេជាដើមដូច្នោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះសម្រេចអរហត្តហើយ ក្នុងទីដែលខ្លួនឈរនោះ ដូច្នេះឯង ។ល។

**រឿង ភិក្ខុចម្រើនវិបស្សនា ចប់**

# រឿង អភយរាជកុមារ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអភយរាជកុមារ ត្រាស់ព្រះធម្មទេសនានេះថា **ឯថ បស្សថិមំ លោកំ** ជាដើម ។

បានឮថា កាលអភយរាជកុមារនោះ បង្ក្រាបបច្ចន្តជនបទឲ្យស្ងប់រម្ងាប់ហើយ ព្រះបាទពិម្ពិសារដែលជាព្រះបិតា ទ្រង់ពេញព្រះហឫទ័យហើយ ព្រះរាជទានអ្នករបាំម្នាក់ ដែលឈ្លាសក្នុងការរាំ និងច្រៀងហើយ បានព្រះរាជ-ទានរាជសម្បត្តិ ៧ ថ្ងៃ ។ អភយរាជកុមារនោះ មិនយាងចេញខាងក្រៅព្រះរាជដំណាក់ឡើយ សោយសិរីនៃភាពជាព្រះរាជាអស់ ៧ ថ្ងៃ យាងទៅកាន់កំពង់ទឹកក្នុងថ្ងៃទី ៨ ទ្រង់ស្រង់ហើយ ចូលទៅកាន់ព្រះរាជឧទ្យាន គង់ប្រថាប់ទតការរាំ និងការច្រៀងរបស់ស្រីនោះ ដូចសន្តតិមហាមាត្យដែរ ។ ក្នុងខណៈនោះឯង ស្ត្រីនោះក៏បានធ្វើកាលកិរិយា ដោយអំណាចគំនរខ្យល់ដ៏មុតដូចសស្ត្រា ដូចអ្នករបាំរបស់សន្តតិមហាមាត្យដែរ ព្រះរាជកុមារមានសេចក្តីសោកកើតឡើងហើយ ព្រោះកាលកិរិយារបស់ស្រីរបាំនោះ ទ្រង់ព្រះតម្រិះថា អ្នកដទៃវៀរព្រះសាស្តាចេញ មិនអាចឲ្យសេចក្តីសោករបស់អញនេះ រម្ងាប់បានឡើយ ដូច្នេះហើយ ទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ឲ្យសេចក្តីសោករបស់ខ្ញុំព្រះអង្គរលត់ចុះ ។

ព្រះសាស្តា ទ្រង់លួងលោមព្រះរាជកុមារនោះហើយ ត្រាស់ថា កុមារ ប្រមាណនៃទឹកភ្នែកទាំងឡាយដែលអ្នកយំ ក្នុងកាលដែលស្រីនេះស្លាប់ហើយ

យ៉ាងនេះ ឲ្យប្រព្រឹត្តទៅហើយ រមែងមិនមានក្នុងសង្សារ ដែលមិនមានទីបំផុតខាងដើម ទ្រង់ជ្រាបភាពដែលសេចក្តីសោក មានសភាពធូរស្រាលព្រោះទេសនានោះហើយ ទើបត្រាស់ថា ម្នាលកុមារ អ្នកកុំសោកឡើយ សេចក្តីនោះ ជាឋានៈដែលលិចចុះរបស់ជនពាលទាំងឡាយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ**
**យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។**

អ្នកទាំងឡាយ ចូរមកមើលលោកនេះដ៏ត្រកាល ដូចរាជរថ ជនពាលទាំងឡាយ រមែងលិចលង់ក្នុងលោកណា សេចក្តីជាប់ជំពាក់ក្នុងលោកនោះ រមែងមិនមានដល់ជនជាបណ្ឌិតទាំងឡាយ ដែលដឹងច្បាស់ទេ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ឯថ បស្សថ** ព្រះសាស្តាត្រាស់សំដៅយកព្រះរាជកុមារនោះឯង ។ ពីរបទថា **ឥមំ លោកំ** បានដល់ អត្តភាពពោល គឺខន្ធលោកជាដើមនេះ ។ បទថា **ចិត្តំ** សេចក្តីថា ដែលវិចិត្រដោយគ្រឿងប្រដាប់ មានគ្រឿងប្រដាប់ គឺសំពត់ជាដើម ដូចរាជរថដែលវិចិត្រដោយគ្រឿងប្រដាប់ មានកែវ ៧ ប្រការជាដើម ។ ពីរបទថា **យត្ថ ពាលា** សេចក្តីថា បុគ្គលពាលល្ងង់ខ្លៅប៉ុណ្ណោះ លិចលង់ក្នុងអត្តភាពណា ។ បទថា **វិជានតំ** សេចក្តីថា តែសម្រាប់ពួកអ្នកប្រាជ្ញ គឺបណ្ឌិតទាំងឡាយ មិនមាន

ការជាប់ជំពាក់ក្នុងកិលេសជាគ្រឿងជាប់ជំពាក់ មានរាគៈជាដើមណាមួយក្នុងអត្តភាពនេះឡើយ ។

ក្នុងកាលចប់ទេសនា ព្រះរាជកុមារ តាំងនៅក្នុងសោតាបត្តិផលហើយ ព្រះធម្មទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នា ដូច្នេះឯង ។៚

**រឿង អភយរាជកុមារ ចប់**

# រឿង ព្រះសម្មជ្ជនត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសម្មជ្ជនត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ច បុព្វេ បមជ្ជិត្វា** ជាដើម ។

បានឮថា ព្រះថេរៈនោះមិនធ្វើកាលឲ្យជាប្រមាណថា ព្រឹក ឬល្ងាច រមែងបោសប្រាសរឿយៗ ។ ថ្ងៃមួយ ព្រះថេរៈនោះកាន់អំបោសទៅកាន់សម្នាក់ព្រះរេវតៈ ដែលអង្គុយទីសម្រាកពេលថ្ងៃ ហើយពោលថា ព្រះថេរៈនេះ ជាអ្នកខ្ជិលច្រអូសច្រើន បរិភោគរបស់ដែលជនឲ្យដោយសទ្ធា ហើយមកអង្គុយ ការដែលព្រះថេរៈនោះកាន់យកអំបោសហើយ បោសទីមួយកន្លែងមិនគួរឬ ព្រះថេរៈគិតថា អញនឹងឲ្យឱវាទលោក ដូច្នេះហើយ ទើបពោលថា មកនេះចុះ អាវុសោ ព្រះសម្មជ្ជនត្ថេរពោលថា មានការអ្វីលោកម្ចាស់ ព្រះរេវតត្ថេរពោលថា សូមលោកទៅងូតទឹកហើយ សឹមមក ។ ព្រះសម្មជ្ជនត្ថេរ

*នោះ បានធ្វើយ៉ាងនោះហើយ លំដាប់នោះ ព្រះថេរៈឲ្យលោកអង្គុយក្នុងទីបំផុតនាចំណែកម្ខាង ហើយកាលពោលទូន្មាន ទើបពោលថា អាវុសោ ធម្មតាភិក្ខុដែលបោសសព្វកាលមិនគួរ ការដែលភិក្ខុបោសតែពេលព្រឹកហើយ ត្រាច់បិណ្ឌបាត ត្រឡប់អំពីបិណ្ឌបាតហើយ មកអង្គុយក្នុងទីសម្រាកពេលយប់ ឬទីសម្រាកពេលថ្ងៃ ស្វាធ្យាយអាការ ៣២ ផ្ដើមចម្រើននូវការអស់ទៅ សូន្យទៅក្នុងអត្តភាពហើយ ក្រោកឡើង បោសក្នុងពេលល្ងាច ទើបគួរ ភិក្ខុមិនបោសអស់កាលជានិច្ច ហើយគប្បីធ្វើឱកាសដល់ខ្លួន ។ ព្រះសម្មជ្ជនត្ថេរនោះតាំងនៅក្នុងឱវាទរបស់ព្រះថេរៈហើយ មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត ។ ក្នុងទីនោះៗបានស្អុកហើយ ។*

*លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងព្រះសម្មជ្ជនត្ថេរនោះថា អាវុសោសម្មជ្ជនៈ ក្នុងទីនោះៗ រាត់រាយ ព្រោះហេតុអ្វីទើបលោកមិនបោស ព្រះសម្មជ្ជនៈពោលថា អាវុសោ ខ្ញុំធ្វើហើយយ៉ាងនោះ ក្នុងកាលប្រមាទ ឥឡូវនេះ ខ្ញុំមិនប្រមាទហើយ ។*

*ភិក្ខុទាំងឡាយ ក្រាបទូលដល់ព្រះសាស្ដាថា ព្រះថេរៈនេះព្យាករនូវអរហត្តផល ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង បុត្ររបស់តថាគតបោសក្នុងកាលប្រមាទក្នុងកាលមុន តែឥឡូវនេះ បុត្ររបស់តថាគត សម្ងំនៅដោយសេចក្ដីសុខដែលកើតអំពីមគ្គផល ទើបមិនបោសដូច្នេះហើយ ត្រាស់ព្រះគាថានេះថា*

**យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ**
**សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។**

*បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះ ឈ្មោះថាញុំាងខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទរះផុតចាកពពក ។*

## សេចក្តីអធិប្បាយ

បណ្ឌិតគប្បីជ្រាបអត្ថនៃព្រះគាថានោះថា បុគ្គលណាប្រមាទហើយក្នុងកាលមុន ដោយការធ្វើវត្ត និងបដិវត្ត ដោយការស្វាធ្យាយជាដើម ក្រោយមក សម្ញុំទៅដោយសុខដែលកើតអំពីមគ្គផល ឈ្មោះថា រមែងមិនប្រមាទបុគ្គលនោះ រមែងញុំាងលោក មានខន្ធជាដើមនេះឲ្យភ្លឺស្វាង គឺរមែងធ្វើឲ្យភ្លឺស្វាង ដូចគ្នាដោយមគ្គញាណ ដូចព្រះចន្ទផុតហើយចាកពពកជាដើមញុំាងឱកាសលោកឲ្យភ្លឺស្វាង ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង ព្រះសម្មុជ្ជនត្ថេរ ចប់**

# រឿង អង្គុលិមាលត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអង្គុលិមាលត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យស្ស បាបំ កតំ កម្មំ** ជាដើម ។

រឿងនេះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃអង្គុលិមាលសូត្រនោះឯង ។ កាលព្រះថេរៈបួសក្នុងសម្នាក់របស់ព្រះសាស្តា សម្រេចអរហត្តហើយ ។ កាលនោះឯង ព្រះអង្គុលិមាលទៅហើយក្នុងទីស្ងាត់ សម្ងំនៅសោយវិមុត្តិសុខហើយ បន្លឺឧទាននេះ ក្នុងកាលមុនថា

បុគ្គលណាប្រមាទហើយ ក្នុងកាលមុន ខាងក្រោយ មិនប្រមាទ
បុគ្គលនោះ រមែងញ៉ាំងលោកឲ្យភ្លឺស្វាង ដូចព្រះចន្ទរួចហើយ
អំពីពពក ដូច្នោះ ។

កាលបន្លឺឧទានហើយ ក៏បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោ ព្រះថេរៈកើតហើយក្នុងទីណាហ្ន៎ ព្រះសាស្តាយាងមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យសម្តីដូចម្តេចហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយពាក្យប្រារព្ធដល់ទីដែលកើតរបស់អង្គុលិមាលត្ថេរ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតបរិនិព្វានហើយ កាលភិក្ខុទាំងឡាយក្រាបទូលថា ព្រះអង្គុលិមាលត្ថេរ សម្លាប់មនុស្សមានប្រមាណប៉ុណ្ណោះ បរិនិព្វានហើយឬ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង

*ព្រោះអង្គុលិមាលនោះ បានទូវបាបមិត្រ ទើបធ្វើនូវបាបមានប្រមាណប៉ុណ្ណេះក្នុងកាលមុន តែខាងក្រោយ អង្គុលិមាលបាននូវកល្យាណមិត្រជាបច្ច័យ ទើបជាបុគ្គលមិនប្រមាទ ហេតុនោះ បាបកម្មនោះ ដែលបុត្ររបស់តថាគតលះបានហើយ ដោយកុសល ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា*

**យស្ស បាបំ កតំ កម្មំ កុសលេន បិធីយតិ**
**សោ មំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។**

*បុគ្គលណាធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះ*
*ដោយកុសល គឺអរហត្តមគ្គបាន បុគ្គលនោះ ឈ្មោះថា*
*ញុំាងខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទរះផុតចាក*
*ពពក ។*

# សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **កុសលេន** *ព្រះសាស្តាត្រាស់សំដៅយកអរហត្តមគ្គ ពាក្យដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕*

**រឿង អង្គុលិមាលត្ថេរ ចប់**

# រឿង កូនស្រីជាងតម្បាញ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងចេតិយឈ្មោះអគ្គាឡវៈ ទ្រង់ប្រារព្ធធីតារបស់ជាងតម្បាញម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **អន្ធភូតោ អយំ លោកោ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ពួកអ្នកក្រុងអាឡវី កាលព្រះសាស្តាយាងដល់ក្រុងអាឡវីហើយ បានទូលនិមន្តថ្វាយទានហើយ ។ ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនាក្នុងពេលស្រេចភត្តកិច្ច ទើបត្រាស់ថា អ្នកទាំងឡាយ ចូរចម្រើនមរណស្សតិយ៉ាងនេះថា ជីវិតរបស់យើងមិនស្ថិតស្ថេរ ការស្លាប់របស់យើងទៀង យើងគប្បីស្លាប់ពិត ជីវិតរបស់យើងមានសេចក្តីស្លាប់ជាទីបំផុត ជីវិតរបស់យើងមិនទៀង ការស្លាប់ទៀង ។ មរណៈដែលជនទាំងឡាយណាមិនចម្រើនហើយ ក្នុងកាលទីបំផុត ជនទាំងឡាយនោះ ដល់នូវការតក់ស្លុតស្រែកគួរឲ្យខ្លាច ធ្វើនូវកាលកិរិយា ដូចបុរសឃើញអាសិរពិសហើយ ភ័យខ្លាច ដូច្នោះ ចំណែកមរណៈដែលជនទាំងឡាយណាបានចម្រើនហើយ ជនទាំងឡាយនោះ រមែងមិនតក់ស្លុត ក្នុងកាលជាទីបំផុត ដូចបុរសឃើញអាសិរពិសអំពីចម្ងាយ ហើយយកកំណាត់ឈើគ្រឹះចោល ហើយឈរ ដូច្នោះ ព្រោះដូច្នោះ មរណស្សតិ អ្នកទាំងឡាយ គប្បីចម្រើន ។

ពួកជនដ៏សេសស្តាប់ធម្មទេសនានោះហើយ បានជាអ្នកខ្វល់ខ្វាយក្នុងកិច្ចរបស់ខ្លួនតែម្យ៉ាង ចំណែកធីតារបស់ជាងតម្បាញ អាយុ ១៦ ឆ្នាំម្នាក់គិតថា ឱ ធម្មតាវាចារបស់ព្រះពុទ្ធទាំងឡាយអស្ចារ្យ អញចម្រើនមរណស្សតិ ទើប

គួរ ដូច្នេះហើយ ក៏ចម្រើនមរណស្សតិតែម្យ៉ាង អស់ថ្ងៃ និងយប់ ។ ចំណែកព្រះសាស្តា យាងចេញអំពីក្រុងអាឡវីហើយ ដល់វត្តជេតពន កុមារិកានោះចម្រើនមរណស្សតិអស់ ៣ ឆ្នាំនោះឯង ។ សម័យមួយ ព្រះសាស្តាប្រមើលមើលលោកក្នុងពេលជិតភ្លឺ ទ្រង់ឃើញនាងកុមារិកានោះ ចូលក្នុងសំណាញ់គឺព្រះញាណ ទ្រង់ពិចារណាថា តើមានហេតុអ្វីហ្ន៎ ជ្រាបថា កុមារិកានេះចម្រើនមរណស្សតិអស់ ៣ ឆ្នាំហើយ តាំងអំពីថ្ងៃដែលបានស្តាប់ធម៌របស់តថាគត ។ ឥឡូវនេះ តថាគតនឹងទៅក្នុងទីនោះ ហើយសួរបញ្ហា ៤ ដល់កុមារិកានេះ កាលនាងឆ្លើយបញ្ហា នឹងឲ្យសាធុការក្នុងឋានៈ ៤ ហើយភាសិតគាថា ក្នុងកាលចប់គាថា កុមារិកានោះតាំងនៅក្នុងសោតាបត្តិផល ព្រោះអាស្រ័យកុមារិកានោះ ទេសនានឹងមានប្រយោជន៍ដល់មហាជន ដូច្នេះហើយ មានភិក្ខុប្រមាណ ៥០០ រូបជាបរិវារ ចេញអំពីវត្តជេតពន ទៅកាន់អគ្គាឡវិហារដោយលំដាប់ ។ អ្នកក្រុងអាឡវីជ្រាបថា ព្រះសាស្តាយាងមកហើយ ទើបទៅវិហារទូលនិមន្តហើយ សូម្បីកុមារិកានោះ ជ្រាបដំណើរយាងមករបស់ព្រះសាស្តា មានចិត្តត្រេកអរថា ព្រះមហាសមណគោតមសម្ពុទ្ធជាបិតា ជាធំ ជាអាចារ្យ ជាបុគ្គលមានព្រះភក្ត្រដូចព្រះចន្ទពេញវង់របស់អញយាងមកហើយ ទើបគិតថា ព្រះសាស្តា ទ្រង់មានពណ៌ដូចមាស ដែលអញធ្លាប់ឃើញកន្លងទៅ ៣ ឆ្នាំអំពីថ្ងៃនេះ ។ ឥឡូវនេះ អញនឹងបានឃើញព្រះសរីរៈដែលមានពណ៌ដូចមាស នឹងស្តាប់ធម៌ដែលជាឱវាទ ដែលមានឱជៈដ៏ពីរោះនៃព្រះសាស្តាអង្គនោះ ។

ចំណែកឪពុករបស់នាង កាលទៅកាន់រោងតម្បាញបានប្រាប់ថា នែនាង សំពត់សាដកដែលជារបស់អ្នកដទៃ អញលើកឡើង សំពត់នោះប្រមាណ ១ ចំអាមមិនទាន់ស្រេច អញនឹងឲ្យសំពត់នោះស្រេចក្នុងថ្ងៃនេះ នាងត្បាញឲ្យរួច ហើយគប្បីនាំមកឲ្យដល់អញដោយរហ័ស ។ កុមារិកានោះគិតថា អញប្រាថ្នានឹងស្ដាប់ធម៌របស់ព្រះសាស្ដា បិតាប្រើអញយ៉ាងនេះ អញស្ដាប់ធម៌របស់ព្រះសាស្ដា ឬក៏ត្បាញឲ្យស្រេចហើយ នាំទៅឲ្យដល់បិតា កាលនោះកុមារិកានោះ មានបរិវិតក្កថា កាលអញមិននាំអំបោះទៅឲ្យបិតា គប្បីទាត់អញខ្លះ វាយអញខ្លះ ព្រោះដូច្នោះ អញត្បាញឲ្យស្រេចឲ្យដល់លោកហើយ សឹមទៅស្ដាប់ធម៌ឯក្រោយ ដូច្នេះហើយ ទើបអង្គុយត្បាញលើតាំង ។ ពួកអ្នកក្រុងអាឡវីអង្គាសព្រះសាស្ដាហើយ បានទទួលបាត្រឈរដើម្បីអនុមោទនា ។ ព្រះសាស្ដាប្រថាប់គង់ហើយដោយព្រះតម្រិះថា តថាគតអាស្រ័យកុលធីតាមកហើយ អស់ចម្ងាយផ្លូវ ៣០ យោជន៍ កុលធីតានោះមិនមានឱកាសក្នុងថ្ងៃនេះ បើកុលធីតានោះបានឱកាស តថាគតនឹងធ្វើអនុមោទនា ។ បុគ្គលណាម្នាក់ក្នុងលោក ព្រមទាំងទេវលោក មិនអាចទូលពាក្យណាមួយនឹងព្រះសាស្ដាដែលទ្រង់ស្ងៀមយ៉ាងនោះបាន ។ កុមារិកានោះ ត្បាញហើយ ដាក់ក្នុងកំប្រោង ដើរទៅកាន់សម្នាក់របស់ឪពុក ដល់ទីបំផុតរបស់បរិស័ទហើយ ដើរបណ្ដើរ សម្លឹងមើលព្រះសាស្ដាបណ្ដើរ ហួសទៅ ។ សូម្បីព្រះសាស្ដា ក៏ទ្រង់ងើបព្រះនេត្រទតកុមារិកានោះ កុមារិកានោះបានជ្រាបហើយដោយអាការ ដែលព្រះសាស្ដាទតដូចគ្នាថា ព្រះសាស្ដាប្រថាប់គង់ក្នុងកណ្ដាលបរិស័ទបែបនោះទតអញ ទ្រង់

ទន្ទឹងការមករបស់អញ ទ្រង់បំណងការមកកាន់សម្នាក់របស់ទ្រង់នោះឯង នាងដាក់កំប្រោងហើយ បានទៅកាន់សម្នាក់របស់ព្រះសាស្តា សួរថា ព្រោះហេតុអ្វី ទើបព្រះសាស្តាទតកុមារិកានោះ ឆ្លើយថា បានឮថា ទ្រង់បរិវិតក្ក យ៉ាងនេះថា កុមារិកានោះ កាលទៅអំពីទីនេះ ធ្វើកាលកិរិយាទាំងបុថុជ្ជន ជាអ្នកមានគតិមិនពិតប្រាកដ តែបើមកកាន់សម្នាក់តថាគតហើយសឹមទៅ សម្រេចសោតាបត្តិផលហើយ នឹងមានគតិពិតប្រាកដ កើតក្នុងតុសិតវិមាន ។ បានឮថា ថ្ងៃនោះ ឈ្មោះថា ការរួចផុតអំពីសេចក្តីស្លាប់ មិនមានដល់កុមារិកានោះ ។

កុមារិកានោះ ចូលទៅគាល់ព្រះសាស្តាហើយ ដោយសញ្ញាដែលព្រះសាស្តាទតនោះឯង នាងចូលទៅកាន់ចន្លោះនៃរស្មី ដែលមានពណ៌ ៦ ថ្វាយបង្គំហើយ ឈរនៅក្នុងទីសមគួរ នាចំណែកម្ខាង ។

ក្នុងខណៈដែលកុមារិកានោះ ថ្វាយបង្គំព្រះសាស្តា ដែលប្រថាប់គង់ស្ងៀមកណ្តាលបរិស័ទបែបនោះហើយកំពុងឈរ ព្រះសាស្តាត្រាស់ថា កុមារិកា នាងមកអំពីណា កុមារិកាទូលថា មិនដឹងទេព្រះអង្គ ព្រះសាស្តាសួរថា នាងនឹងទៅក្នុងទីណា កុមារិកាទូលថា មិនដឹងទេព្រះអង្គ ព្រះសាស្តាត្រាស់ថា នាងមិនដឹងឬ កុមារិកាទូលថា ដឹងព្រះអង្គ ព្រះសាស្តាត្រាស់សួរថា នាងដឹងឬ កុមារិកាទូលថា មិនដឹងទេព្រះអង្គ ។ ព្រះសាស្តាត្រាស់សួរបញ្ហា ៤ នឹងកុមារិកានោះ ដោយប្រការដូច្នេះ ។

មហាជនពោលទោសថា អ្នកនិរទុក្ខទាំងឡាយ ចូរអ្នកទាំងឡាយមើលកូនស្រីជាងតម្បាញនេះ និយាយពាក្យដែលខ្លួនប្រាថ្នាហើយ ជាមួយព្រះសម្ពុទ្ធ

កាលព្រះសម្មាសម្ពុទ្ធត្រាស់ថា នាងមកអំពីណា កូនស្រីជាងតម្បាញនេះគួរពោលថា មកអំពីផ្ទះរបស់ជាងតម្បាញ កាលត្រាស់សួរថា នាងនឹងទៅណា គួរពោលថា ទៅរោងជាងតម្បាញ មិនមែនឬ ព្រះសាស្តាទ្រង់ធ្វើមហាជនឲ្យស្ងាត់ហើយ ត្រាស់សួរថា កុមារិកា នាង កាលតថាគតពោលថា មកអំពីណា ហេតុអ្វី ទើបនាងឆ្លើយថា មិនដឹង កុមារិកាទូលថា បពិត្រព្រះអង្គ ទ្រង់ជ្រាបដែលខ្ញុំម្ចាស់មកអំពីផ្ទះជាងតម្បាញ តែទ្រង់កាលត្រាស់សួរថា នាងមកអំពីណា ទ្រង់ចង់សួរថា នាងមកអំពីណា កើតក្នុងទីនេះ តែខ្ញុំម្ចាស់មិនជ្រាបថា អាត្មាអញមកអំពីណា ទើបកើតក្នុងទីនេះ ។

លំដាប់នោះ ព្រះសាស្តា ប្រទានសាធុការទីមួយ ដល់កុមារិកានោះថា សាធុ សាធុ កុមារិកា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបានហើយ ហើយត្រាស់សួរតទៅថា កាលតថាគតសួរហើយថា នាងនឹងទៅក្នុងទីណា ព្រោះហេតុអ្វី ទើបពោលថាមិនដឹង កុមារិកាទូលថា បពិត្រព្រះអង្គទ្រង់ជ្រាបខ្ញុំម្ចាស់ ដែលកាន់កំប្រោងដើរទៅកាន់រោងជាងតម្បាញ ទ្រង់មានបំណងសួរថា នាងទៅអំពីលោកនេះហើយ នឹងកើតក្នុងទីណា ខ្ញុំម្ចាស់ចុតិអំពីលោកនេះហើយ មិនដឹងថា នឹងទៅកើតក្នុងទីណាទេ ។

លំដាប់នោះ ព្រះសាស្តាប្រទានសាធុការដល់នាងជាលើកទីពីរថា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបានហើយ ហើយត្រាស់សួរក្នុងបទតទៅថា បើដូច្នោះ កាលតថាគតសួរថា មិនដឹងឬ ព្រោះហេតុអ្វី ទើបពោលថា ដឹង កុមារិកាទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់រមែងដឹងនូវភាវៈ គឺការស្លាប់

របស់ខ្ញុំម្ចាស់ប៉ុណ្ណោះ ហេតុនោះ ទើបក្រាបទូលយ៉ាងនោះ ។

លំដាប់នោះ ព្រះសាស្ដាប្រទានសាធុការដល់នាងលើកទី ៣ ថា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបានហើយ ហើយត្រាស់សួរសេចក្ដីតទៅថា កាលបើដូច្នោះ កាលតថាគតសួរថា នាងរមែងដឹងឬ ព្រោះហេតុអ្វីទើបពោលថា មិនដឹង កុមារិកាទូលថា ខ្ញុំម្ចាស់រមែងដឹងតែការ: គឺការស្លាប់របស់ខ្ញុំម្ចាស់ប៉ុណ្ណោះ តែមិនដឹងថា ស្លាប់ក្នុងពេលយប់ ពេលថ្ងៃ ឬពេលព្រឹកជាដើម ក្នុងកាលឈ្មោះនោះ ព្រោះហេតុនោះ ទើបពោលយ៉ាងនោះ ។

លំដាប់នោះ ព្រះសាស្ដាប្រទានសាធុការលើកទី ៤ ដល់នាងថា បញ្ហាដែលតថាគតសួរហើយ នាងឆ្លើយបានហើយ ទើបត្រាស់ដាស់តឿនបរិស័ទថា ពួកអ្នកមិនដឹងពាក្យប្រមាណប៉ុណ្ណេះ ដែលកុមារិកានេះពោលហើយ រមែងពោលទោសតែម្យ៉ាងប៉ុណ្ណោះ ព្រោះចក្ខុ គឺបញ្ញារបស់ជនទាំងឡាយណាមិនមាន ជនទាំងឡាយនោះ ដូចជាខ្វាក់នោះឯង ចក្ខុ គឺបញ្ញារបស់ជនណាមាន ជនទាំងនោះឯង ដូចជាអ្នកមានភ្នែកក្ដី ដូច្នេះហើយត្រាស់ព្រះគាថានេះថា

**អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ**
**សកុណ្ដោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។**

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្ដាជនទាំងនេះ
ជនតិចគ្នា ដែលឃើញច្បាស់ ( នូវខន្ធាទិលោកនេះ
ដោយអំណាចអនិច្ចលក្ខណៈជាដើម ) ជនតិចគ្នា ដែល

*ទៅកាន់ស្ថានសួគ៌ ដូចសត្វស្ទាប ( ដែលជាប់សំណាញ់ របស់ព្រានហើយ ) តិចណាស់ ដែលរួចអំពីសំណាញ់ ដូច្នោះ ។*

# សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ ពីរបទថា* **អយំ លោកោ** *សេចក្តីថា លោកិយ-មហាជន ឈ្មោះថា ដូចមនុស្សភ្នែកខ្វាក់ ព្រោះមិនមានចក្ខុ គឺបញ្ញា ។ ពីរបទថា* **តនុកេត្ថ** *សេចក្តីថា ជនក្នុងលោកនេះ តិចគ្នា គឺមិនច្រើន ដែលឃើញច្បាស់ដោយអំណាចនៃត្រៃលក្ខណ៍ មានមិនទៀងជាដើម ។ បទថា* **ជាលមុត្តោវ** *សេចក្តីថា បណ្តាហ្វូងបក្សី គឺចាប ដែលនាយព្រានអ្នកឈ្លាសវាយដោយសំណាញ់ចាប់យក សត្វចាបតិចតួចប៉ុណ្ណោះ រមែងរួចផុតសំណាញ់បាន ចាបដ៏សេស រមែងចូលទៅខាងក្នុងសំណាញ់ទាំងអស់ យ៉ាងណា បណ្តាសត្វដែលសំណាញ់ គឺមាររួបរួមហើយ សត្វជាច្រើន រមែងទៅកាន់អបាយ តិចគ្នា គឺបុគ្គលខ្លះប៉ុណ្ណោះ ទៅក្នុងស្ថានសួគ៌ គឺដល់សុគតិ ឬព្រះនិព្វាន ដូច្នោះ ។*

*ក្នុងកាលចប់ទេសនា កុមារិកានោះ បានតាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នោះ ។*

*កុមារិកានោះ កាន់កំប្រោងអំបោះទៅកាន់សម្នាក់របស់បិតាហើយ បិតានោះអង្គុយនិទ្រាហើយ កាលនឹងទៅមិនកំណត់ បង្អោនកំប្រោងចូលទៅ កំប្រោងប៉ះត្រង់ទីបំផុតត្រល់ ឮសំឡេងធ្លាក់ទៅ បិតានោះភ្ញាក់ឡើង*

ហើយ ទាញទីបំផុតត្រល់ ដោយនិមិត្តដែលខ្លួនចាប់យកនោះឯង ទីបំផុតត្រល់ទៅប្រហារកុមារិកានោះត្រង់ដើមទ្រូង នាងធ្វើកាលកិរិយាក្នុងទីនោះឯង កើតហើយក្នុងទីបំផុតកព លំដាប់នោះ បិតារបស់នាង សម្លឹងមើលឃើញកូនស្រីខ្លួនមានសរីរៈប្រឡាក់ដោយឈាមដួលស្លាប់ហើយ ។ លំដាប់នោះ សេចក្តីសោកដ៏ធំកើតឡើងដល់បិតានោះ ។ គាត់ទ្រហោយំ គិតថា បុគ្គលដទៃមិនអាចញ៉ាំងសេចក្តីសោករបស់អញ ឲ្យរលត់បានឡើយ ទើបទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលសេចក្តីនោះថា បពិត្រព្រះអង្គ សូមទ្រង់ញ៉ាំងសេចក្តីសោករបស់ខ្ញុំព្រះអង្គឲ្យរលត់ផងចុះ ។ ព្រះសាស្តា ទ្រង់លួងលោមបុរសនោះហើយ ត្រាស់ថា អ្នកកុំសោកឡើយ ព្រោះទឹកភ្នែកដែលហូរចេញហើយ ក្នុងកាលដែលស្លាប់នៃកូនស្រីរបស់អ្នក ដោយអាការយ៉ាងនេះ ក្នុងសង្សារដែលមិនមានទីបំផុតខាងដើម ទឹកភ្នែកនោះ ច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ ដូច្នេះហើយ ទើបត្រាស់អនមតគ្គសូត្រ ។ បុរសនោះមានសេចក្តីសោកស្រាកស្បើយ ទូលសូមបព្វជ្ជានឹងព្រះសាស្តា បានឧបសម្បទាហើយ ក្នុងកាលមិនយូរប៉ុន្មានសម្រេចអរហត្តហើយ ដោយប្រការដូច្នេះ ៕

**រឿង កូនស្រីជាងតម្បាញ ចប់**

# រឿងភិក្ខុ ៣០ រូប

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ៣០ រូប ត្រាស់ព្រះធម្មទេសនានេះថា **ហំសា អាទិច្ចបថេ យន្តិ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងថ្ងៃមួយ ភិក្ខុមានប្រក្រតីនៅក្នុងទិសប្រមាណ ៣០ រូបចូលទៅគាល់ព្រះសាស្តា ។ ព្រះអានន្ទត្ថេរ មកក្នុងកាលដែលធ្វើវត្តដល់ព្រះសាស្តា ឃើញភិក្ខុទាំងនោះហើយគិតថា កាលព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងនេះហើយអញនឹងធ្វើវត្ត ដូច្នេះហើយ បានឈរត្រង់ខ្លោងទ្វារ ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងនោះហើយ ក៏ត្រាស់កថាដែលប្រារព្ធធម៌ ជាគ្រឿងឲ្យរឭកដល់គ្នានិងគ្នាដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះស្តាប់ធម្មកថានោះហើយ សម្រេចអរហត្ត ហោះទៅតាមអាកាស ព្រះអានន្ទកាលភិក្ខុនោះយឺតយូរ ចូលទៅគាល់ព្រះសាស្តា ទូលសួរថា បពិត្រព្រះអង្គភិក្ខុប្រមាណ ៣០ រូបមកហើយក្នុងទីនេះ ភិក្ខុទាំងនោះទៅណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ទៅហើយ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅដោយផ្លូវណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ទៅតាមអាកាស ព្រះអានន្ទសួរថា បពិត្រព្រះអង្គ ភិក្ខុទាំងនោះជាព្រះខីណាស្រពឬ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ យ៉ាងនោះឯង ភិក្ខុទាំងនោះ ស្តាប់ធម៌ក្នុងសម្នាក់តថាគតសម្រេចអរហត្តហើយ ។

ក្នុងខណៈនោះ ហង្សទាំងឡាយទៅដោយអាកាសហើយ ។ ព្រះសាស្តា

ត្រាស់ថា អានន្ទ ឥទ្ធិបាទ ៤ ដែលបុគ្គលណាចម្រើនល្អហើយ បុគ្គលនោះរមែងទៅដោយអាកាសដូចហង្សដូច្នោះ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**ហំសា ធិច្ចបថេ យន្តិ អាកាសេ យន្តិ ឥទ្ធិយា**
**នីយន្តិ ធីរា លោកម្ហា ជេត្វា មារំ សវាហនំ ។**

ពួកហង្ស តែងហើរទៅក្នុងគន្លងផ្លូវព្រះអាទិត្យ អ្នកមានឫទ្ធិ តែងហោះទៅក្នុងអាកាសដោយឫទ្ធិ អ្នកប្រាជ្ញផ្ចាញ់កិលេសមារ ព្រមទាំងវាហនៈ គឺតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញចាកលោកបាន ។

## សេចក្តីអធិប្បាយ

បណ្ឌិតគប្បីជ្រាបអត្ថនៃព្រះគាថានោះថា ហង្សទាំងនេះ រមែងទៅក្នុងផ្លូវនៃព្រះអាទិត្យ គឺក្នុងអាកាស ។ ឥទ្ធិបាទដែលជនណាចម្រើនល្អហើយ ជនទាំងនោះ រមែងទៅក្នុងអាកាសដោយឫទ្ធិ ។ ធីរជនទាំងឡាយ គឺបណ្ឌិតឈ្នះមារ មួយអន្លើដោយវាហនៈហើយ រមែងចេញទៅ គឺរមែងរលាស់ចេញចាកលោក គឺវដ្តៈនេះ បានដល់ ដល់នូវព្រះនិព្វាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ភិក្ខុ ៣០ រូប ចប់**

# រឿង ចិញ្ចមាណវិកា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងចិញ្ចមាណវិកា ត្រាស់ព្រះធម្មទេសនានេះថា **ឯកំ ធម្មំ អតីតស្ស** ជាដើម ។

សេចក្តីពិស្តារថា ក្នុងបឋមពោធិកាល កាលសាវករបស់ព្រះទសពល មានច្រើន មិនមានប្រមាណ កាលពួកទេវតា និងមនុស្សឈមចុះកាន់អរិយភូមិ កាលការកើតឡើងនៃព្រះគុណរបស់ព្រះសាស្តាផ្សាយទៅហើយ លាភសក្ការៈ ជាច្រើនកើតឡើងហើយ ។ ពួកតិរ្ថិយ ជាបុគ្គលដូចគ្នានឹងពន្លឺអំពិលអំពែក ក្នុងកាលដែលព្រះអាទិត្យរះឡើង ជាអ្នកសាបសូន្យលាភសក្ការៈ ។ ពួកតិរ្ថិយ ទាំងនោះឈរត្រង់ចន្លោះផ្លូវ ប្រកាសឲ្យពួកមនុស្សដឹងច្បាស់យ៉ាងនេះថា ព្រះ សមណគោតមប៉ុណ្ណោះឬជាព្រះពុទ្ធ ពួកយើងក៏ជាព្រះពុទ្ធ ទានដែលគេឲ្យហើយ ដល់ព្រះសមណគោតមនោះប៉ុណ្ណោះឬ មានផលច្រើន ទានដែលគេឲ្យហើយ ដល់ពួកយើងទាំងឡាយ ក៏មានផលច្រើនដូចគ្នា អ្នកទាំងឡាយចូរឲ្យ ចូរធ្វើ ដល់យើងទាំងឡាយខ្លះ ដូច្នេះហើយ បានលាភសក្ការៈហើយ ប្រជុំគ្នាក្នុងទី ស្ងាត់ថា ពួកយើងគប្បីញ៉ាំងទោសឲ្យកើតឡើងដល់ព្រះសមណគោតម ក្នុង រវាងមនុស្សទាំងឡាយ គប្បីញ៉ាំងលាភសក្ការៈឲ្យវិនាសដោយឧបាយដូចម្តេច ហ្ន៎ កាលនោះ ក្នុងក្រុងសាវត្ថី មានបរិព្វាជិកាម្នាក់ ឈ្មោះចិញ្ចមាណវិកាជា អ្នកទ្រទ្រង់នូវរូបឆោម ដល់នូវការក្រៃលែងដោយសម្រស់ ដូចទេពអប្សរ ដូច្នោះ រស្មីរមែងផ្សាយចេញអំពីសរីរៈរបស់ស្ត្រីនោះ ។

លំដាប់នោះ តិរ្ថិយដែលជាអ្នកឈ្លាសវៃម្នាក់ពោលយ៉ាងនេះថា យើង

ទាំងឡាយ អាស្រ័យនាងចិញ្ចមាណវិកា គប្បីញ៉ាំងទោសឲ្យកើតឡើងដល់ព្រះសមណគោតម ញ៉ាំងលាភសក្ការៈឲ្យវិនាសបាន ។ តិរ្ថិយទាំងនោះទទួលថា ឧបាយនេះមាន ។ បន្ទាប់មក នាងចិញ្ចមាណវិកានោះទៅកាន់អារាមរបស់តិរ្ថិយ ថ្វាយបង្គំហើយឈរ ពួកតិរ្ថិយមិនពោលជាមួយនាងសោះ ទើបគិតថា អញមានទោសអ្វីហ្ន៎ សូម្បីពោលអស់វារៈ ៣ ដងថា លោកម្ចាស់ទាំងឡាយ ខ្ញុំថ្វាយបង្គំ ដូច្នេះហើយ ទើបពោលថា លោកម្ចាស់ទាំងឡាយ ខ្ញុំមានទោសអ្វីឬ ព្រោះហេតុអ្វី ទើបលោកម្ចាស់ទាំងឡាយមិននិយាយជាមួយខ្ញុំ ។

តិរ្ថិយពោលថា នែប្អូនស្រី នាងមិនជ្រាបទេឬ សមណគោតមបៀតបៀនយើងទាំងឡាយ ធ្វើយើងទាំងឡាយឲ្យវិនាសលាភសក្ការៈទាំងឡាយទេឬ ។ នាងចិញ្ចមាណវិកាពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនដឹងទេ ក្នុងរឿងនេះ ខ្ញុំគួរធ្វើដូចម្តេច តិរ្ថិយពោលថា នែប្អូនស្រី បើនាងប្រាថ្នាសេចក្តីសុខដល់យើងទាំងឡាយសោត ចូរញ៉ាំងទោសឲ្យកើតឡើងដល់ព្រះសមណគោតមហើយ ញ៉ាំងលាភសក្ការៈឲ្យវិនាសព្រោះអាស្រ័យនាង ។ នាងពោលថា សាធុ លោកម្ចាស់ទាំងឡាយ សេចក្តីនេះសូមជាភារៈរបស់ខ្ញុំ លោកម្ចាស់ទាំងឡាយកុំគិតឡើយ ដូច្នេះហើយ ចៀសចេញទៅ ដណ្តប់សំពត់មានពណ៌ដូចមេភ្លៀង មានគ្រឿងក្រអូប និងកម្រងផ្កាជាដើមក្នុងដៃ បែរមុខទៅកាន់វត្តជេតពន ទៅក្នុងសម័យជាទីស្តាប់ធម្មកថា របស់អ្នកក្រុងសាវត្ថី ហើយចេញទៅអំពីវត្តជេតពន ។ តាំងអំពីកាលនោះ ព្រោះនាងជាអ្នកឈ្លាសក្នុងមាយារបស់ស្ត្រី កាលអ្នកដទៃសួរថា នាងទៅណាក្នុងពេលនេះ ទើបពោលថា ប្រយោជន៍អ្វី

របស់អ្នកទាំងឡាយ ដោយការដែលខ្ញុំទៅស្នាក់នៅក្នុងវត្តរបស់ពួកតិរិយ ក្នុងទីមិនឆ្ងាយអំពីវត្តជេតពន កាលឧបាសកចេញអំពីនគរអំពីព្រលឹម ដោយបំណងថា នឹងថ្វាយបង្គំព្រះដ៏មានព្រះភាគ នាងធ្វើអាកប្បកិរិយា ដូចនៅក្នុងវត្តជេតពន ចូលទៅកាន់ព្រះនគរ កាលឧបាសកសួរថា នាងនៅទីណា ទើបពោលថា ប្រយោជន៍អ្វីរបស់អ្នកទាំងឡាយដោយការរបស់ខ្ញុំ ។ កន្លងទៅ ១ ឬ ២ ខែ កាលគេសួរ ទើបពោលថា ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណគោតម ក្នុងវត្តជេតពន ញុំាំងសេចក្តីសង្ស័យឲ្យកើតឡើងដល់បុថុជ្ជនទាំងឡាយថា សេចក្តីនោះ ពិត ឬមិនពិតហ្ន៎ ។ លុះកន្លងទៅ ៣-៤ ខែ យកកំណាត់សំពត់រុំពោះសម្តែងភេទរបស់ស្រីមានគភ៌ ឲ្យពួកជនអន្ធពាលកាន់យកថា គភ៌កើតឡើងព្រោះអាស្រ័យព្រះសមណគោតម លុះកន្លងទៅ ៨ ឬ ៩ ខែ ចងឈើមូលត្រង់ពោះ ដណ្តប់សំពត់ខាងលើ ឲ្យវាយដៃ និងជើងដោយឈើដែលមានចម្ពាមដូចចង្កាគោ សម្តែងអាការហើមឡើង មានឥន្ទ្រិយទន់ខ្សោយ ។ កាលព្រះតថាគតប្រថាប់គង់សម្តែងធម៌លើធម្មាសនៈ ដែលប្រដាប់ហើយក្នុងពេលល្ងាច ទៅកាន់ធម្មសភា ឈរចំពោះព្រះភក្ត្ររបស់ព្រះសាស្តា ហើយពោលថា មហាសមណៈ ទ្រង់គិតតែសម្តែងធម៌ដល់មហាជនប៉ុណ្ណោះ សំឡេងរបស់ព្រះអង្គពីរោះ ព្រះឱស្ឋរបស់ព្រះអង្គជិតល្អ ចំណែកខ្ញុំអាស្រ័យព្រះអង្គ មានគភ៌គ្រប់កំណត់ហើយ ទ្រង់មិនជ្រាបផ្ទះដែលជាទីប្រសូតសម្រាប់ខ្ញុំ ទ្រង់មិនជ្រាបគ្រឿងបរិហារគភ៌ មានសប្បិ និងប្រេងជាដើម បើទ្រង់មិនធ្វើ ក៏គួរប្រាប់ព្រះបាទកោសល ឬអនាថបិណ្ឌិក ឬ

នាងវិសាខាមហាឧបាសិកា បុគ្គលណាម្នាក់ បណ្ដាឧបដ្ឋាកទាំងឡាយថា អ្នកចូរធ្វើកិច្ចដែលគួរធ្វើដល់នាងចិញ្ចមាណវិកានេះ ទ្រង់ដឹងតែក្នុងរឿងអភិរម្យប៉ុណ្ណោះ ទ្រង់មិនដឹងគព្ភបរិហារសោះ ដូចព្យាឃាមចាប់លាមក គ្រវែងនូវមណ្ឌលព្រះចន្ទ ដូច្នោះ ជេរព្រះតថាគតកណ្ដាលបរិស័ទហើយ ។

ព្រះតថាគតទ្រង់ផ្អាកធម្មកថាហើយ កាលទ្រង់បន្លឺសីហនាទ ទើបត្រាស់ថា ម្នាលប្អូនស្រី ពាក្យដែលនាងពោលហើយ ពិត ឬមិនពិត តថាគតនឹងនាងប៉ុណ្ណោះរមែងដឹង នាងចិញ្ចមាណវិកាពោលថា យ៉ាងនោះឯងមហាសមណៈសេចក្ដីនោះ កើតហើយ ដោយការដែលព្រះអង្គនឹងខ្ញុំដឹងហើយ ។

ខណៈនោះ អាសនៈរបស់សក្កៈសម្ដែងអាការក្ដៅ សក្កៈទ្រង់ពិចារណាដឹងថា នាងចិញ្ចមាណវិកាជេរព្រះសាស្ដាដោយពាក្យមិនពិត ហើយទ្រង់ព្រះតម្រិះថា អញនឹងជម្រះរឿងនេះឲ្យបរិសុទ្ធ ទើបយាងមកជាមួយទេវបុត្រ ៤ អង្គ ។ ទេវបុត្រទាំងឡាយ កាឡាខ្លួនជាកូនកណ្ដុរកាត់ខ្សែដែលចងដុំឈើមូលដោយកកេរតែម្ដងប៉ុណ្ណោះ ។ ខ្យល់បក់បើងសំពត់ដណ្ដប់ឡើង ឈើមូលធ្លាក់ចុះលើខ្នងជើងរបស់នាងចិញ្ចមាណវិកានោះ ។ ចុងជើងទាំងពីរបែកហើយ មនុស្សទាំងឡាយពោលថា នែនាងកាឡកិណី ហងជេរព្រះសម្មាសម្ពុទ្ធ ស្ដោះទឹកមាត់ដាក់លើក្បាលមានដៃកាន់ដុំដី និងអន្ដត់ឧសទាញចេញអំពីវត្តជេតពន។

ក្នុងកាលនាងផុតគន្លងព្រះនេត្រព្រះសាស្ដាទៅ មហាប្រឹថពីបើកចន្លោះឲ្យហើយ អណ្ដាតភ្លើងចេញមកអំពីអវិចី ។ នាងចិញ្ចមាណវិកានោះ ទៅកើតក្នុងអវិចី ដូចដណ្ដប់សំពត់កម្ពលដែលត្រកូលឲ្យ ។ លាភសក្ការៈរបស់

ពួកតិរ្ថិយក៏សាបសូន្យទៅ បែរជាចម្រើនដល់ព្រះទសពលដោយប្រមាណក្រៃលែង ។

ក្នុងថ្ងៃស្អែកឡើង ពួកភិក្ខុសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ នាងចិញ្ចមាណវិកាជេរព្រះសម្មាសម្ពុទ្ធ ដែលគួរដល់ទក្ខិណាដ៏លើស ជាអ្នកមានគុណក្រៃលែងយ៉ាងនេះដោយពាក្យមិនពិត ដល់នូវសេចក្ដីវិនាសធំហើយ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយវាចាឈ្មោះនេះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន នាងចិញ្ចមាណវិកានោះ ក៏ជេរតថាគតដោយពាក្យមិនពិត ដល់នូវសេចក្ដីវិនាសហើយដូចគ្នា ដូច្នេះហើយ ទើបទ្រង់ត្រាស់មហាបទុមជាតក ក្នុងទ្វាទសកនិបាតឲ្យពិស្ដារថា

> ព្រះរាជាជាឥស្សរៈ បើមិនទាន់ឃើញទោសតូចធំ ដោយសព្វគ្រប់ អំពីសម្នាក់បុគ្គលដទៃ ទាំងមិនទាន់ពិចារណា ឲ្យឃើញច្បាស់ដោយខ្លួនឯងទេ មិនគប្បីដាក់អាជ្ញាឡើយ ។

ព្រះសាស្ដាត្រាស់ថា បានឮថា ក្នុងកាលនោះ នាងចិញ្ចមាណវិកានោះជាអ្នករួមប្ដី គឺមាតាចុងរបស់ព្រះពោធិសត្វ ព្រះនាមមហាបទុមកុមារ ជាអគ្គមហេសីរបស់ព្រះរាជា បបួលព្រះមហាសត្វដោយអសទ្ធម្ម មិនបាននូវការយល់ព្រម របស់ព្រះពោធិសត្វនោះហើយ ធ្វើប្រការចម្លែកក្នុងខ្លួនដោយខ្លួនឯង សម្ដែងអាការធ្វើជាឈឺ ក្រាបទូលដល់ព្រះរាជាថា ព្រះរាជឱរសរបស់

ព្រះអង្គ ញ៉ាំងខ្ញុំម្ចាស់ដែលមិនប្រាថ្នា ឲ្យដល់នូវប្រការចម្លែក ព្រះរាជាពិរោធ ទម្លាក់ព្រះពោធិសត្វក្នុងជ្រោះ ដែលជាទីទម្លាក់ពួកចោរ ។

លំដាប់នោះ ទេវតាដែលអាស្រ័យនឹងបាតភ្នំ ទទួលព្រះមហាសត្វនោះហើយ ឲ្យប្រតិស្ឋានលើពពាររបស់ស្តេចនាគ ស្តេចនាគនាំព្រះមហាសត្វនោះ ទៅកាន់ភពនាគ ទ្រង់ទទួលដោយរាជសម្បត្តិពាក់កណ្ដាល ព្រះមហាសត្វនៅក្នុងភពនាគនោះអស់មួយឆ្នាំ ប្រាថ្នានឹងបួស ទើបមកកាន់ហេមវន្តប្បទេស បួសហើយ ឲ្យឈាន និងអភិញ្ញាកើតហើយ ។

បន្ទាប់មក ព្រានព្រៃម្នាក់ឃើញមហាសត្វ ទើបក្រាបទូលដល់ព្រះរាជា ព្រះរាជាយាងចូលទៅកាន់សម្នាក់របស់មហាសត្វនោះហើយ មានបដិសណ្ឋារៈដែលព្រះមហាសត្វធ្វើហើយ ទ្រង់ជ្រាបព្រឹត្តិហេតុទាំងអស់នោះ ទ្រង់យាងព្រះមហាសត្វឲ្យសោយសម្បត្តិ ព្រះមហាសត្វឲ្យឱវាទថា កិច្ចដោយរាជសម្បត្តិរបស់ទូលបង្គំមិនមាន ឯទ្រង់កុំធ្វើរាជធម៌ ១០ ប្រការឲ្យកម្រើក សូមទ្រង់លះនូវអគតិចោលហើយ សោយរាជសម្បត្តិដោយធម៌ចុះ ដូច្នេះហើយ ទ្រង់ក្រោកចាកអាសនៈ ព្រះកន្ទ្រងយាងទៅកាន់ព្រះនគរ ទើបត្រាស់សួរអមាត្យទាំងឡាយក្នុងរវាងផ្លូវថា ខ្ញុំព្រាត់ប្រាសចាកកូនដែលសម្បូរដោយអាចារយ៉ាងនេះ ព្រោះអាស្រ័យអ្នកណា អមាត្យទូលថា បពិត្រព្រះអង្គ ព្រោះអាស្រ័យអគ្គមហេសីនោះឯង ។

ព្រះរាជាទ្រង់បញ្ជាឲ្យចាប់អគ្គមហេសីនោះ ឲ្យមានជើងឡើងលើហើយបោះទៅក្នុងជ្រោះដែលគេចោលចោរ ហើយយាងចូលទៅកាន់នគរ សោយ

រាជសម្បត្តិដោយធម៌ ។ មហាបទុមកុមារក្នុងកាលនោះ បានជាព្រះមហាសត្វ ស្រ្តីរួមប្តីរបស់ព្រះមាតា បានជានាងចិញ្ចមាណវិកា ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាបាបកម្មដែលបុគ្គលលះពាក្យសត្យដែលជាធម៌ឯកហើយ តាំងនៅក្នុងមុសាវាទ ជាអ្នកមានបរលោកលះបង់ហើយ មិនគប្បីធ្វើ រមែងមិនមាន ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**ឯកំ ធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ**
**វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ។**

បុគ្គលប្រព្រឹត្តកន្លង ( ពាក្យសច្ចៈ ) ដែលជាធម៌ឯក
និយាយតែពាក្យកុហក មានបរលោកលះចោលហើយ
ឈ្មោះថា មិនធ្វើបាប មិនមែនឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឯកំ ធម្មំ** គឺនូវពាក្យសត្យ ។ បទថា **មុសាវាទិស្ស** សេចក្តីថា បណ្តាពាក្យ ១០ ពាក្យ ពាក្យសត្យសូម្បីត្រឹមតែមួយ មិនមានដល់បុគ្គលណា បុគ្គលនេះ ឈ្មោះថា ជាបុគ្គលច្រើនដោយការពោលកុហក ។ បាទព្រះគាថាថា **វិតិណ្ណបរលោកស្ស** បានដល់មានបរលោកលះបង់ហើយ បុគ្គលបែបនេះ រមែងមិនជួបនូវសម្បត្តិ ៣ គឺ មនុស្សសម្បត្តិ ទេវសម្បត្តិ និព្វានសម្បត្តិក្នុងអវសាន ។ពីរបទថា **នត្ថិ បាបំ** សេចក្តីថា សេចក្តីសង្ស័យថា បាបឈ្មោះនេះ ដែលបុគ្គលនោះ គឺ

បុគ្គលបែបនោះ មិនគប្បីធ្វើ ដូច្នេះ រមែងមិនមាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៙

**រឿង ចិញ្ចមាណវិកា ចប់**

# រឿង អសទិសទាន

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអសទិសទាន ត្រាស់ព្រះធម្មទេសនានេះថា **ន វេ កទរិយា ទេវលោកំ វជន្តិ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ព្រះសាស្តាយាងចារិកទៅហើយ មានភិក្ខុប្រមាណ ៥០០ ជាបរិវារ ទ្រង់ចូលទៅក្នុងវត្តជេតពន ។ ព្រះរាជាយាងទៅវិហារទូលនិមន្តព្រះសាស្តា ក្នុងថ្ងៃស្អែកឡើងទ្រង់ត្រៀមអាគន្តុទានហើយ ត្រាស់ហៅអ្នកនគរថា ចូរអ្នកមើលទានរបស់យើង អ្នកនគរមកឃើញទានរបស់ព្រះរាជាហើយ ក្នុងថ្ងៃស្អែកឡើងទូលនិមន្តព្រះសាស្តាត្រៀមទានហើយ បញ្ជូនដំណឹងទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមទ្រង់ទតទានរបស់ពួកខ្ញុំព្រះអង្គ ព្រះរាជាយាងទៅទតទានរបស់អ្នកនគរទាំងនោះហើយ ទ្រង់ព្រះតម្រិះថា ទានដែលក្រៃលែងជាងទានរបស់យើង ដែលជនទាំងនេះធ្វើហើយ យើងនឹងធ្វើទានទៀត ទើបឲ្យត្រៀមទានហើយ ក្នុងថ្ងៃស្អែក ។

អ្នកនគរឃើញទាននោះហើយ ក្នុងថ្ងៃស្អែកឡើង ទើបត្រៀមទានហើយ ដោយប្រការដូច្នេះ ។ ដោយប្រការយ៉ាងនេះ ព្រះរាជាមិនអាចឲ្យអ្នកនគរចាញ់បានឡើយ អ្នកនគរក៏មិនអាចឲ្យព្រះរាជាចាញ់បាន ។ តមក ក្នុងវារៈទី ៦ អ្នកនគរបន្ថែមរយជង ពាន់ជង ត្រៀមទានដោយប្រការ ដែលបុគ្គលណាមិនអាចនិយាយបានថា វត្ថុឈ្មោះនេះ មិនមានក្នុងទានរបស់អ្នកនគរទាំងនេះ ព្រះរាជាទតទាននោះហើយ ទ្រង់ព្រះតម្រិះថា បើយើងមិនអាចធ្វើទានឲ្យក្រៃលែងជាងទានរបស់អ្នកនគរទាំងនោះសោត ប្រយោជន៍អ្វីរបស់អញដោយជីវិតនេះ ដូច្នេះហើយ បានផ្ទំត្រិះរិះដល់ឧបាយ ។

លំដាប់នោះ ព្រះនាងមល្លិកាទេវីចូលគាល់ព្រះរាជាហើយ ទូលសួរថា បពិត្រមហារាជ ព្រោះហេតុអ្វី ទើបទ្រង់ផ្ទំយ៉ាងនេះ ព្រះរាជាត្រាស់ថា ទេវី ឥឡូវនេះ នាងមិនទាន់ជ្រាបឬ ព្រះទេវីទូលថា ខ្ញុំម្ចាស់មិនជ្រាបទេព្រះអង្គ ។ ព្រះរាជាត្រាស់ប្រាប់សេចក្តីនោះដល់ព្រះនាងហើយ ។

លំដាប់នោះ ព្រះនាងមល្លិកាក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះអង្គកុំព្រួយឡើយ ព្រះរាជាជាធំក្នុងផែនដី ដែលអ្នកនគរទាំងឡាយឲ្យចាញ់ ទ្រង់ធ្លាប់ទតឬ ធ្លាប់ស្តាប់ហើយឬអំពីណា ខ្ញុំម្ចាស់នឹងចាត់ចែងជំនួសព្រះអង្គ ។

ព្រះនាងក្រាបទូលព្រះរាជាយ៉ាងនោះ ព្រោះភាពដែលព្រះនាង ជាអ្នកប្រាថ្នានឹងចាត់ចែងអសទិសទាន ហើយក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ត្រាស់ឲ្យគេធ្វើមណ្ឌប សម្រាប់គង់ខាងក្នុងបរិវេណ ដើម្បីភិក្ខុប្រមាណ

៥០០ រូប ដោយឈើដែលធ្វើដោយដើមសាលព្រឹក្ស និងដើមក្ដៅនាង ពួកភិក្ខុដ៏សេស នឹងអង្គុយខាងក្រៅវង្វង់ សូមទ្រង់ឲ្យធ្វើស្វេតច្ឆត្រ ៥០០ ដំរីប្រមាណ ៥០០ កាន់ស្វេតច្ឆត្រទាំងនោះឈរបាំងខាងលើនៃភិក្ខុប្រមាណ ៥០០ រូប សូមត្រាស់ឲ្យធ្វើទូកសម្រេចដោយមាសទឹកដប់ ៨ គ្រឿង ឬ ១០ គ្រឿង ទូកទាំងនោះដាក់ក្នុងកណ្ដាលមណ្ឌប ខត្តិយធីតាមួយអង្គៗ អង្គុយបុកគ្រឿងក្រអូបក្នុងចន្លោះភិក្ខុ ២ រូបៗ ខត្តិយធីតាមួយអង្គៗ ឈរកាន់ផ្លិតបក់ភិក្ខុ ២ រូបៗ ខត្តិយធីតាដ៏សេស នឹងនាំគ្រឿងក្រអូបដែលខ្ទុនបុកហើយ មកដាក់ក្នុងទូកមាសទាំងឡាយ បណ្ដាខត្តិយធីតាទាំងនោះ ខត្តិយធីតាពួកខ្លះនឹងកាន់នូវផ្កាឧប្បលខៀវ ជ្រលក់គ្រឿងក្រអូបដែលនៅក្នុងទូកហើយ នឹងឲ្យភិក្ខុទទួលយកនូវក្លិន ព្រោះខត្តិយធីតាមិនមានដល់ពួកអ្នកនគរឡើយ ស្វេតច្ឆត្រក៏មិនមាន ដំរីក៏មិនមាន ពួកអ្នកនគរនឹងចាញ់ដោយហេតុមានប្រមាណប៉ុណ្ណោះ ។ បពិត្រមហារាជ សូមទ្រង់ត្រាស់ឲ្យធ្វើយ៉ាងនេះចុះ ។ ព្រះរាជាទទួលថា សាធុ ព្រះទេវី នេះជាការល្អដែលនាងប្រាប់ហើយ ទើបត្រាស់ឲ្យធ្វើកិច្ចទាំងអស់ ដោយទំនងដែលព្រះនាងទូលហើយនោះឯង ឯដំរី ១ មិនគ្រប់គ្រាន់ដល់ភិក្ខុមួយរូប ។

លំដាប់នោះ ព្រះរាជាត្រាស់នឹងព្រះនាងមល្លិកាថា នែនាង ភិក្ខុមួយរូបខ្វះដំរីមួយ យើងនឹងធ្វើដូចម្ដេច ព្រះទេវីត្រាស់ថា ដំរីមាន ៥០០ មិនមែនឬ ព្រះរាជាត្រាស់ថា មាន តែដំរីដ៏សេស ជាដំរីកាច ដំរីទាំងនោះឃើញភិក្ខុទាំងឡាយ រមែងបៀតបៀន ដូចខ្យល់វេរម្ភវាត ព្រះទេវីត្រាស់ថា បពិត្រ

ព្រះសម្មតិទេព ខ្ញុំម្ចាស់ជ្រាបទីដែលឈរកាន់ឆត្ររបស់កូនដំរីដែលកាចនោះ ព្រះរាជាត្រាស់ថា នឹងដាក់ដំរីនោះឈរក្នុងទីណា ព្រះទេវីត្រាស់ថា ឈរក្នុងទីជិតរបស់លោកម្ចាស់ឈ្មោះអង្គុលិមាល ។

ព្រះរាជា ត្រាស់ឲ្យរាជបុរសធ្វើហើយយ៉ាងនោះ ដំរីស៊កកន្ទុយចូលក្នុងរវាងភ្លៅ ដាក់ត្រចៀកទាំងពីរទៅក្រោយ បិទភ្នែកឈរហើយ ។ មហាជនសម្លឹងមើលដំរីត្រង់ស្វេតច្ឆត្រដើម្បីព្រះថេរៈប៉ុណ្ណោះ ដោយគិតថា អាការរបស់ដំរីកាចដល់ម៉្លេះ ព្រះអង្គុលិមាលរមែងធ្វើបាន ព្រះរាជាទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអាហារដ៏ប្រណីតហើយ ថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន វត្ថុណាជាកប្បិយភណ្ឌ ឬអកប្បិយភណ្ឌក្នុងរោងទាននេះ ខ្ញុំអង្គនឹងថ្វាយវត្ថុទាំងអស់នោះ ដល់សង្ឃប៉ុណ្ណោះ ។

ក្នុងកាលនោះឯង ទ្រព្យមានប្រមាណ ១៤ កោដិ ព្រះរាជាបរិច្ចាគមួយថ្ងៃប៉ុណ្ណោះ ។ របស់ ៤ យ៉ាង គឺស្វេតច្ឆត្រ ១ បល្ល័ង្កសម្រាប់អង្គុយ ១ ជើងបាត្រ ១ តាំងសម្រាប់ជូតជើង ១ ជារបស់កាន់ថ្លៃមិនបាន ដើម្បីព្រះសាស្តា បុគ្គលណាមិនអាចធ្វើទានបែបនេះ ថ្វាយទានដល់ព្រះពុទ្ធទាំងឡាយបានឡើយ ព្រោះហេតុនោះឯង ទើបទាននោះប្រាកដឈ្មោះថា អសទិសទាន បានឮថា អសទិសទាននោះមានដល់ព្រះពុទ្ធគ្រប់អង្គ សម្រាប់មួយព្រះអង្គមានម្តងប៉ុណ្ណោះ ។ ស្ត្រីប៉ុណ្ណោះរមែងចាត់ចែងទានដើម្បីព្រះសាស្តា និងភិក្ខុទាំងពួង ។

អមាត្យរបស់ព្រះរាជាមាន ២ នាក់ គឺកាឡៈ ១ ជណ្ហៈ ១ បណ្ដាអមាត្យ ២ នាក់នោះ កាឡអាមាត្យគិតថា ឱ ការវិនាសដោយជុំវិញនៃរាជ-ត្រកូល ទ្រព្យប្រមាណ ១៤ កោដិ ដល់នូវការអស់ទៅមួយថ្ងៃប៉ុណ្ណោះ ភិក្ខុទាំងនេះបរិភោគទានហើយទៅដេកលក់ ឱ រាជត្រកូលវិនាសហើយ ។ ចំណែកជណ្ហអមាត្យគិតថា ឱ ទានរបស់ព្រះរាជា បុគ្គលណាមួយដែលមិនតាំងនៅក្នុងភាពជាព្រះរាជា មិនអាចថ្វាយទានបែបនេះបានឡើយ ។ ព្រះរាជាឈ្មោះថា មិនឲ្យចំណែកបុណ្យដល់សត្វទាំងពួងមិនមាន អញអនុមោទនាទាននេះ ។ ក្នុងទីបំផុតកត្តកិច្ចនៃព្រះសាស្ដា ព្រះរាជាទ្រង់ទទួលបាត្រ ដើម្បីអនុមោទនា ព្រះសាស្ដាទ្រង់ព្រះតម្រិះថា ព្រះរាជាថ្វាយមហាទាន ដូចឲ្យជំនាន់ទឹកជំប្រព្រឹត្តទៅ មហាជនអាចញុំាងចិត្តឲ្យជ្រះថ្លាឬហ្ន៎ ទ្រង់ជ្រាបវារចិត្តរបស់អមាត្យទាំងនោះហើយ ទ្រង់ជ្រាបថា បើតថាគតធ្វើអនុមោទនាឲ្យសមគួរដល់ទានរបស់ព្រះរាជាសោត ក្បាលរបស់កាឡអមាត្យនឹងបែកជា ៧ ភាគ ជុណ្ហអមាត្យនឹងតាំងនៅក្នុងសោតាបត្តិផល ទ្រង់អាស្រ័យសេចក្ដីអនុគ្រោះក្នុងកាឡអមាត្យ ទើបត្រាស់គាថា ៤ បាទប៉ុណ្ណោះដល់ព្រះរាជា ដែលទ្រង់ថ្វាយទានបែបនេះប្រថាប់ឈរហើយ ស្ដេចក្រោកចាកអាសនៈទៅកាន់វិហារ ។

ភិក្ខុទាំងឡាយសួរព្រះអង្គុលិមាលត្ថេរថា អាវុសោ លោកឃើញដំរីកាចឈរបាំងឆត្រមិនខ្លាចទេឬ ព្រះអង្គុលិមាលពោលថា អាវុសោទាំងឡាយ ខ្ញុំមិនខ្លាចទេ ភិក្ខុទាំងនោះចូលទៅគាល់ព្រះសាស្ដាហើយ ក្រាបទូលថា បពិត្រព្រះអង្គ ព្រះអង្គុលិមាលព្យាករអរហត្តផល ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ អន្តលីមាលមិនខ្វាច ព្រោះថា ភិក្ខុទាំងឡាយដូចបុត្ររបស់តថាគត ស្មើដោយគោដ៏ប្រសើរ ក្នុងវាងនៃគោ គឺព្រះខីណាស្រពទាំង-ឡាយ មិនខ្វាច ដូច្នេះហើយ ទើបត្រាស់ព្រះគាថាក្នុងព្រាហ្មណវគ្គថា

តថាគតហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែង
រកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ
ងូតលាងកិលេស ត្រាស់ដឹងសច្ចៈនោះ ថាជាព្រាហ្មណ៍ ។

ព្រះរាជាដល់នូវទោមនស្សថា ព្រះសាស្តាទ្រង់មិនធ្វើអនុមោទនា ឲ្យសមគួរដល់បុគ្គលថ្វាយទាន ហើយឈរក្នុងកណ្តាលបរិស័ទបែបនេះ ហើយទ្រង់ក្រោកចាកអាសនៈទៅ អញនឹងមិនធ្វើទានឲ្យសមគួរដល់ព្រះសាស្តា ធ្វើទានដែលមិនសមគួរ ។ អញនឹងមិនថ្វាយកប្បិយកណ្ឌ ថ្វាយតែអកប្បិយកណ្ឌតែម្យ៉ាងហើយ អញនឹងជាបុគ្គលដែលព្រះសាស្តាទ្រង់អាក់អន់ហើយ ការធ្វើអនុមោទនាដែលសមគួរដល់ទាន របស់បុគ្គលណាម្នាក់នោះឯងទើបគួរ ដូច្នេះហើយ ទើបយាងទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តាហើយ បានក្រាបទូលពាក្យនេះថា បពិត្រព្រះអង្គ ទានដែលគួរថ្វាយ ខ្ញុំព្រះអង្គមិនបានថ្វាយឬ ឬខ្ញុំព្រះអង្គមិនបានថ្វាយកប្បិយកណ្ឌដែលសមគួរដល់ទាន ថ្វាយតែអកប្បិយកណ្ឌប៉ុណ្ណោះឬ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ តើមានរឿងអ្វី ព្រះរាជាត្រាស់ថា ទ្រង់មិនធ្វើអនុមោទនាដែលសមគួរដល់ទានរបស់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ទ្រង់ថ្វាយទានសមគួរហើយ ទាននោះ ឈ្មោះថា អសទិសទាន

បុគ្គលណាម្នាក់អាចថ្វាយដល់ព្រះពុទ្ធមួយអង្គ ត្រឹមតែម្តងប៉ុណ្ណោះ ធម្មតាទានបែបនេះ ជារបស់លំបាកដែលបុគ្គលនឹងថ្វាយទៀត ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ បើដូច្នោះ ហេតុអ្វីក៏ទ្រង់មិនធ្វើអនុមោទនាឲ្យសមគួរដល់ទានរបស់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា ព្រោះបរិស័ទមិនបរិសុទ្ធ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ ទោសអ្វីហ្ន៎របស់បរិស័ទ ។

លំដាប់នោះ ព្រះសាស្តា ត្រាស់ប្រាប់វារចិត្តរបស់អមាត្យទាំងពីរនាក់ហើយ ត្រាស់ប្រាប់ភាពដែលអនុមោទនា ឈ្មោះថា ទ្រង់អាស្រ័យសេចក្តីអនុគ្រោះក្នុងកាឡអមាត្យ ទើបមិនធ្វើហើយដល់ព្រះរាជា ព្រះរាជាត្រាស់សួរថា កាឡះ បានឮថា អ្នកគិតយ៉ាងនេះឬ កាលកាឡអមាត្យទូលថា បពិត្រព្រះអង្គ សេចក្តីនោះពិត ទើបត្រាស់ថា យើង មួយអន្ទើដោយបុត្រកិរិយារបស់យើង មិនបានកាន់យករបស់ដែលមានរបស់អ្នក ឲ្យរបស់ដែលមានរបស់យើង បៀតបៀនអ្វីដល់អ្នក វត្ថុណាដែលយើងឲ្យដល់អ្នកហើយ វត្ថុនោះជាការឲ្យហើយនោះឯង តែចូរអ្នកចេញអំពីដែនរបស់យើង ដូច្នេះហើយ ទើបទ្រង់និរទេសកាឡអមាត្យនោះចេញអំពីដែន ហើយត្រាស់ឲ្យហៅជុណ្ហ-អមាត្យមក សួរថា បានឮថា អ្នកគិតយ៉ាងនេះពិតឬ កាលជុណ្ហអមាត្យទូលថា បពិត្រព្រះអង្គ សេចក្តីនោះពិត ទើបត្រាស់ថា សាធុ ខ្ញុំជ្រះថ្លា ចូរអ្នកទទួលរាជសម្បត្តិរបស់ខ្ញុំ ហើយឲ្យទាន ៧ ថ្ងៃ ដោយទំនងដែលខ្ញុំឲ្យហើយនោះឯង ។ ព្រះរាជាប្រទានរាជសម្បត្តិដល់ជុណ្ហអមាត្យ ៧ ថ្ងៃហើយ ទើបក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ សូមទ្រង់ទតការធ្វើរបស់បុគ្គល

ពាល បុគ្គលនោះបានឲ្យនូវការលុបគុណក្នុងទាន ដែលខ្ញុំព្រះអង្គថ្វាយហើយយ៉ាងនេះ ។

ព្រះសាស្តាត្រាស់ថា យ៉ាងនោះឯងមហាបពិត្រ ឈ្មោះថាបុគ្គលពាលមិនត្រេកអរក្នុងទានរបស់អ្នកដទៃឡើយ ជាបុគ្គលមានទុគ្គតិជាទីទៅខាងមុខ ចំណែកពួកអ្នកប្រាជ្ញ អនុមោទនាទានរបស់ជនដទៃ គប្បីជាអ្នកមានស្ថានសួគ៌ ជាទីទៅខាងមុខដោយពិត ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**ន វេ កទរិយា ទេវលោកំ វជន្តិ ពាលា ហវេ នប្បសំសន្តិ ទានំ**

**ធីរោ ច ទានំ អនុមោទមានោ តេនេវ សោ ហោតិ សុខី បរត្ថ។**

បុគ្គលកំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានឡើយ ចំណែកអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបានសេចក្តីសុខក្នុងលោកខាងមុខ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កទរិយា** គឺជាអ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ បុគ្គលមិនដឹងនូវប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ឈ្មោះថា ជាបុគ្គលពាល បណ្ឌិត ឈ្មោះថា ធីរជន ។ បទថា **សុខី បរត្ថ** សេចក្តីថា ធីរជននោះ កាលសោយទិព្វសម្បត្តិ ឈ្មោះថា ជាអ្នកមានសេចក្តីសុខក្នុងលោកខាងមុខ និងព្រោះបុណ្យដែលសម្រេចអំពីការអនុមោទនាទាននោះឯង ។

ក្នុងកាលចប់ទេសនា ជុណ្ហអមាត្យតាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ។ ជុណ្ហអមាត្យ កាលបានជាព្រះសោតាបន្នហើយ បានថ្វាយទានដោយទំនង ដែលព្រះរាជាថ្វាយហើយអស់ ៧ ថ្ងៃដូចគ្នា ដូច្នេះឯង ៕

**រឿង អសទិសទាន ចប់**

# រឿង កាឡៈកូនរបស់អនាថបិណ្ឌិកសេដ្ឋី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកូនរបស់អនាថ-បិណ្ឌិក ឈ្មោះកាឡៈ ត្រាស់ព្រះធម្មទេសនានេះថា **បថព្យា ឯករជ្ជេន** ជាដើម ។

បានឮថា កាឡៈនោះទោះបីជាកូនរបស់សេដ្ឋីដែលដល់ព្រមដោយសទ្ធាដូច្នោះ ក៏មិនប្រាថ្នាទៅកាន់សម្នាក់របស់ព្រះសាស្ដាឡើយ មិនប្រាថ្នានឹងស្ដាប់ធម៌ មិនប្រាថ្នានឹងធ្វើការខ្វល់ខ្វាយដល់សង្ឃ ត្រូវបិតាពោលថា អ្នកកុំធ្វើយ៉ាងនេះ ក៏មិនស្ដាប់ពាក្យរបស់លោក ។

លំដាប់នោះ បិតារបស់កាឡៈគិតថា កាឡៈនេះ កាលកាន់យកនូវទិដ្ឋិបែបនេះត្រាច់ទៅ នឹងជាអ្នកមានអវីចិជាទីទៅខាងមុខ កាលអញនៅរស់ កូនរបស់អញទៅកាន់នរកមិនសមគួរដល់អញឡើយ ឈ្មោះថា សត្វ មិនសម្ដីង

ក្នុងទ្រព្យមិនមានក្នុងលោកនេះឡើយ អញនឹងទម្លាយទិដ្ឋិរបស់កូននោះដោយទ្រព្យ ។

លំដាប់នោះ សេដ្ឋីនិយាយនឹងកាឡៈនោះថា នែបា ចូរបាជាអ្នករក្សាឧបោសថ ទៅកាន់វិហារស្តាប់ធម៌ហើយមកចុះ ឪពុកនឹងឲ្យកហាបណៈមួយរយដល់អ្នក កាឡៈពោលថា នឹងឲ្យពិតឬ សេដ្ឋីពោលថា អើ ឪពុកឲ្យ ។

កាឡៈនោះសួរបញ្ជាក់បីដងហើយ ជាអ្នករក្សាឧបោសថ បានទៅកាន់វិហារហើយ តែកិច្ចដោយការស្តាប់ធម៌របស់គាត់មិនមាន គាត់ដេកក្នុងទីតាមដែលសុខស្រួលហើយ បានទៅផ្ទះអំពីព្រលឹម ។ លំដាប់នោះ បិតារបស់គាត់ពោលថា កូនរបស់យើងបានជាអ្នករក្សាឧបោសថ ចូរអ្នកទាំងឡាយនាំបបរជាដើមមកឲ្យរហ័ស ដូច្នេះហើយ ប្រើអ្នកបម្រើឲ្យបម្រើ ។ កាឡៈនោះហាមអាហារហើយដោយពោលថា បើខ្ញុំមិនបានកហាបណៈក៏មិនបរិភោគ ។ គ្រានោះ បិតារបស់កាឡៈកាលអត់ធន់នឹងការរំខានមិនបាន ទើបឲ្យកញ្ចប់កហាបណៈហើយ កាឡៈនោះទទួលកហាបណៈប៉ុណ្ណោះក្នុងដៃហើយ ទើបរិភោគអាហារ ។

ក្នុងថ្ងៃស្អែកឡើង សេដ្ឋីបញ្ជូនទៅដោយពោលថា នែបា ឪពុកនឹងឲ្យកហាបណៈមួយពាន់ដល់ឯង ចូរឯងឈរត្រង់ព្រះភក្ត្រព្រះសាស្តា រៀនយកបទនៃធម៌ឲ្យបានមួយបទ ហើយមក ។ កាឡៈទៅកាន់វិហារ ឈរចំពោះព្រះភក្ត្ររបស់ព្រះសាស្តា ជាអ្នកប្រាថ្នានឹងរៀនយកបទនៃធម៌មួយបទប៉ុណ្ណោះហើយគេចទៅ ។ លំដាប់នោះ ព្រះសាស្តាទ្រង់បានធ្វើអាការ គឺមិនឲ្យកាឡៈ

កំណត់បាន កាឡៈកំណត់បទនោះមិនបានហើយ ទើបឈរស្តាប់ហើយនោះឯង ដោយគិតថា អញនឹងរៀនបទបន្តទៅទៀត បានឮថា ជនទាំងឡាយកំពុងស្តាប់ដោយគិតថា អញនឹងរៀនឲ្យបាន ឈ្មោះថាស្តាប់ដោយគោរព ។

ធម្មតា កាលជនទាំងឡាយកំពុងស្តាប់យ៉ាងនេះ ធម៌រមែងឲ្យសោតាបត្តិមគ្គជាដើមដល់កាឡៈនោះ ដែលកំពុងស្តាប់ដោយគិតថា អញនឹងរៀនឲ្យបាន សូម្បីព្រះសាស្តាក៏ទ្រង់ធ្វើអាការ គឺការកំណត់មិនបានដល់កាឡៈហើយ ។ គាត់កំពុងឈរស្តាប់នោះឯង ដោយគិតថា អញនឹងរៀនតទៅ ទើបតាំងនៅក្នុងសោតាបត្តិផល ។

ព្រឹកឡើង កាឡៈនោះទៅកាន់ក្រុងសាវត្ថី មួយអន្លើដោយភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាននោះឯង ។ សេដ្ឋីគ្រាន់តែឃើញក៏គិតថា ថ្ងៃនេះ អាត្មាអញពេញចិត្តក្នុងអាការរបស់បុត្រ សូម្បីនាយកាឡៈនោះ ក៏មានបរិវិតក្កដូច្នេះថា ឱហ្ន៎ ថ្ងៃនេះ បិតារបស់អញ កុំឲ្យកហាបណៈក្នុងទីជិតព្រះសាស្តាឡើយ គប្បីបិទបាំងភាពដែលអញជាអ្នករក្សាឧបោសថ ព្រោះហេតុនៃកហាបណៈ តែព្រះសាស្តាបានជ្រាបភាពដែលកាឡៈនោះ ជាអ្នករក្សាឧបោសថព្រោះកហាបណៈ ហើយកាលពីម្សិលមិញ មហាសេដ្ឋីថ្វាយបបរដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ ទើបប្រាប់ឲ្យគេឲ្យដល់បុត្រកាឡៈនោះជាអ្នកអង្គុយស្ងៀម បរិភោគបបរ ទំពារបស់គួរទំពាហើយបរិភោគភត្ត ។

ក្នុងកាលស្រេចភត្តកិច្ចរបស់ព្រះសាស្តា មហាសេដ្ឋី ឲ្យគេដាក់កញ្ចប់

កហាបណៈមួយពាន់ ត្រង់មុខបុត្រហើយ ពោលថា នែបា ឪពុកនិយាយថា នឹងឲ្យកហាបណៈមួយពាន់ដល់ឯង ទើបឲ្យឯងសមាទានឧបោសថ ទៅកាន់វិហារ នេះកហាបណៈមួយពាន់របស់ឯង ។ កាឡៈនោះ ឃើញកហាបណៈដែលបិតាឲ្យចំពោះព្រះភក្ត្ររបស់ព្រះសាស្តា មានការខ្មាសអៀន ទើបពោលថា ខ្ញុំមិនត្រូវការកហាបណៈទាំងឡាយ ត្រូវបិតាពោលថា នែបា ចូរបាទទួលយកចុះ ក៏មិនទទួល ។

លំដាប់នោះ បិតារបស់កាឡៈ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ថ្ងៃនេះខ្ញុំព្រះអង្គគាប់ចិត្តក្នុងអាការរបស់បុត្រ កាលព្រះសាស្តាត្រាស់សួរថា មហាសេដ្ឋី តើរឿងនោះដូចម្តេច ទើបក្រាបទូលថា ក្នុងថ្ងៃមុនកូនរបស់ខ្ញុំព្រះអង្គនេះ កាលខ្ញុំព្រះអង្គពោលថា ឪពុកនឹងឲ្យកហាបណៈមួយរយដល់អ្នក ហើយបញ្ជូនទៅកាន់វិហារ ស្អែកឡើង មិនទាន់បានទទួលកហាបណៈ ក៏មិនបរិភោគ តែថ្ងៃនេះ គេមិនប្រាថ្នាកហាបណៈដែលខ្ញុំព្រះអង្គឲ្យ ព្រះសាស្តាត្រាស់ថា មហាសេដ្ឋី យ៉ាងនោះឯង ថ្ងៃនេះ សោតាបត្តិផលនោះឯងរបស់កូនអ្នក ប្រសើរជាងសម្បត្តិរបស់ស្តេចចក្រពត្តិ និងក្រៃលែងជាងសម្បត្តិទេវលោក និងព្រហ្មលោក ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

បថព្យា ឯករជ្ជេន សគ្គស្ស គមនេន វា
សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។

សោតាបត្តិផល ជាគុណជាតិដ៏ប្រសើរជាងភាពនៃឯករាជ្យ
លើផែនដីផង ជាងដំណើរទៅកាន់ស្ថានសួគ៌ផង ជាងភាព
ជាធំក្នុងលោកទាំងមូលផង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **បថព្យា ឯករជ្ជេន** គឺក្រៃលែងជាងភាពជាស្តេចចក្រពត្តិ ។ បាទព្រះគាថាថា **សគ្គស្ស គមនេន វា** សេចក្តីថា ជាងការពោលដល់ស្ថានសួគ៌ ២៦ ជាន់ ។ បាទព្រះគាថាថា **សព្វលោកាធិបច្ចេន** សេចក្តីថា ក្រៃលែងជាងភាពជាធំក្នុងលោក មានប្រមាណប៉ុណ្ណោះៗ គឺក្នុងលោកទាំងពួង មួយអន្លើដោយនាគ គ្រុឌ និងវេមានិកប្រេត ។ បាទព្រះគាថាថា **សោតាបត្តិផលំ វរំ** សេចក្តីថា ព្រោះព្រះរាជា សូម្បីសោយរាជសម្បត្តិក្នុងទីមានប្រមាណប៉ុណ្ណោះ ក៏ជាបុគ្គលមិនផុតចាកនរកជាដើមបានឡើយ ចំណែកព្រះសោតាបន្ន ជាអ្នកមានទ្វារអបាយបិទហើយ សូម្បីមានកម្លាំងទន់ខ្សោយជាងសោតាបន្នទាំងអស់ ក៏មិនកើតក្នុងភពទី ៨ ដូច្នោះ សោតាបត្តិផលនោះឯង ទើបប្រសើរ គឺឧត្តម ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿងកាឡៈបុត្ររបស់អនាថបិណ្ឌិកសេដ្ឋី ចប់**

**លោកវគ្គ ចប់**

**វគ្គទី ១៣ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា ពុទ្ធវគ្គទី ១៤

[ ២៤ ] ជ័យជម្នះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជម្នះ របស់ព្រះពុទ្ធអង្គនោះ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ម្ដេចកើត ។ តណ្ហាដែលមានបណ្ដាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេងៗ មិនមានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅ ក្នុងភពណាមួយ នាងទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្ដេចកើត ។

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្វល់ខ្វាយក្នុងឈាន ត្រេកអរក្នុងនេក្ខម្ម: ជាស្ថានស្ងប់រម្ងាប់កិលេស សូម្បីទេវតា និងមនុស្សទាំងឡាយតែងរាប់រកចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹងខ្លួនឯងទាំងមានស្មារតី ។

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ ការស្ដាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ ។ ការមិនធ្វើបាបទាំងពួង ការញ៉ាំងកុសលឲ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

ខន្តិ គឺសេចក្ដីអត់ធន់ ជាតបធម៌ដ៏ឧត្ដម ព្រះពុទ្ធទាំងឡាយតែងពោលថា ព្រះនិព្វាន ជាធម្មជាតដ៏ឧត្ដម បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថាបព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថា សមណៈឡើយ ។

ការមិនតិះដៀល ១ ការមិនបៀតបៀន ១ ការសង្រួមក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត ១ ការដេក និងអង្គុយក្នុងទីស្ងាត់ ១ ការព្យាយាមក្នុងអធិចិត្ត ១ នុ៎ះជាពាក្យប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ។ ការស្កប់ស្កល់ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះកហាបណៈ ( ដែលធ្លាក់ចុះ ) ដូចទឹកភ្លៀងទេ កាមទាំងឡាយ មានសុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់ យ៉ាងនេះហើយ លោកមិនបានត្រេកអរ ក្នុងកាមទាំងឡាយសូម្បីជាទិព្វឡើយ សាវករបស់ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នកត្រេកអរ ក្នុងធម៌ ជាគ្រឿងអស់តណ្ហា ។ មនុស្សទាំងឡាយ ច្រើននាក់ ត្រូវភ័យគំរាមហើយ តែងយកភ្នំ អារាម និងរុក្ខចេតិយ ជាទីពឹង ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្ដមទេ បុគ្គលអាស្រ័យនូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ ។

លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ច ១ កន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះឯង ជាទីពឹងដ៏ក្សេម នេះឯង ជាទីពឹងដ៏ឧត្ដម បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខ

ទាំងពួងបាន ។

បុរសអាជានេយ្យ រកបានដោយកម្រ លោកមិនកើតក្នុងសព្វស្ថាន ឡើយ លោកជាអ្នកមានប្រាជ្ញាកើតក្នុងត្រកូលណា ត្រកូលនោះ តែងដល់ នូវសេចក្តីសុខ ។ ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ការសម្តែងព្រះសទ្ធម្ម ជាសុខ សេចក្តីព្រមព្រៀងគ្នានៃពួក ជាសុខ តបធម៌របស់បុគ្គលអ្នកព្រម ព្រៀងគ្នាទាំងឡាយ ជាសុខ ។

កាលបុគ្គលបូជា ដល់បូជារហបុគ្គល គឺព្រះពុទ្ធ ឬសាវករបស់ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្តីសោក និងខ្សឹកខ្សួល ឬ កាលបូជាដល់បូជារហបុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ លោក មិនមានភ័យអំពីទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាមួយ មិនអាចរាប់ បុណ្យថា បុណ្យនេះ មានប្រមាណប៉ុណ្ណោះបានឡើយ ។

**ពុទ្ធវគ្គទី ១៤ ចប់**

**បឋមភាណវារ ចប់**

# អដ្ឋកថា
# ពុទ្ធវគ្គទី ១៤

## រឿង មារធីតា
### លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងពោធិមណ្ឌលដ្ឋាន ទ្រង់ប្រារព្ធធីតាមារ ត្រាស់ព្រះធម្មទេសនានេះថា **យស្ស ជិតំ** ជាដើម ។

ព្រះសាស្តា ទ្រង់ញ៉ាំងព្រះធម្មទេសនាឲ្យតាំងឡើងក្នុងក្រុងសាវត្ថីហើយ ត្រាស់ដល់ព្រាហ្មណ៍ឈ្មោះមាគន្ទិយៈ ក្នុងដែនកុរុទៀត ។

បានឮថា ក្នុងដែនកុរុ កូនស្រីរបស់មាគន្ទិយព្រាហ្មណ៍ ឈ្មោះថា មាគន្ទិយាដូចគ្នា ជាអ្នកមានរូបឆោមស្រស់ត្រកាល ។ ព្រាហ្មណមហាសាលជាច្រើន និងពួកខត្តិយមហាសាល ចង់បាននាងមាគន្ទិយានោះ ទើបបញ្ជូនដំណឹងទៅដល់មាគន្ទិយៈថា ចូរឲ្យកូនស្រីដល់យើងទាំងឡាយចុះ ។ មាគន្ទិយព្រាហ្មណ៍ ក៏ឃាត់ព្រាហ្មណមហាសាល ខត្តិយមហាសាលទាំងអស់ដូចគ្នាថា ពួកអ្នកមិនសមនឹងធីតាខ្ញុំទេ ។

ថ្ងៃមួយ ក្នុងពេលទៀបភ្លឺ ព្រះសាស្តាទ្រង់ប្រមើលមើលលោក ទ្រង់ឃើញមាគន្ទិយព្រាហ្មណ៍ចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទើបទ្រង់ពិចារណាថា នឹងមានហេតុអ្វីហ្ន៎ ទ្រង់ឃើញឧបនិស្ស័យនៃមគ្គ និង

ផលទាំង ៣ របស់ព្រាហ្មណ៍ និងព្រាហ្មណី ។ ចំណែកព្រាហ្មណ៍ ក៏បម្រើភ្លើងជានិច្ចខាងក្រៅស្រុក ។ ព្រះសាស្តា ទ្រង់កាន់បាត្រ និងចីវរទៅកាន់ទីនោះ អំពីព្រលឹម ។ ព្រាហ្មណ៍សម្លឹងមើលរូបសិរីរបស់ព្រះសាស្តាបណ្តើរ គិតបណ្តើរថា ឈ្មោះថា បុរសក្នុងលោកនេះ ដែលនឹងដូចបុរសនេះមិនមាន បុរសនេះ ជាអ្នកសមគួរដល់កូនស្រីរបស់អញ អញនឹងឲ្យកូនស្រីរបស់អញដល់បុរសនេះ ហើយក្រាបទូលព្រះសាស្តាថា បពិត្រសមណ: ខ្ញុំមានធីតាម្នាក់ ខ្ញុំមិនឃើញបុរសដែលសមគួរដល់នាង ទើបមិនបានឲ្យនាងដល់បុគ្គលណាឡើយ ។ ចំណែកលោកជាបុគ្គលសមគួរដល់នាង ខ្ញុំប្រាថ្នានឹងឲ្យធីតាដល់លោក ឲ្យធ្វើជាស្រីបម្រើបាតជើង សូមលោកបន្អង់ចាំក្នុងទីនេះឯងទម្រាំខ្ញុំនាំធីតានោះមក ។ ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់បុរសនោះហើយ ទ្រង់មិនត្រេកអរ ហើយក៏មិនហាម ។

ចំណែកព្រាហ្មណ៍ទៅផ្ទះហើយ ប្រាប់ព្រាហ្មណីថា នែនាង ថ្ងៃនេះខ្ញុំបានឃើញបុរស ដែលសមគួរដល់ធីតារបស់យើងហើយ ពួកយើងនឹងលើកធីតានោះដល់បុរសនោះ ឲ្យធីតាតាក់តែងកាយហើយ នាំទៅកាន់ទីនោះ មួយអន្លើដោយព្រាហ្មណី សម្បីមហាជនក៏ភ្ញាក់ផ្អើលនាំគ្នាចេញទៅមើល ។ ព្រះសាស្តាមិនបានប្រថាប់ឈរក្នុងទីដែលព្រាហ្មណ៍ប្រាប់ឡើយ ទ្រង់ប្រតិស្ឋានចេតិយ គឺស្នាមព្រះបាទក្នុងទីនោះហើយ បានប្រថាប់ឈរក្នុងទីដទៃ ។ បានឮថា ចេតិយគឺស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដក្នុងទីដែលទ្រង់អធិដ្ឋានថា បុគ្គលឈ្មោះនោះចូរឃើញចេតិយ គឺស្នាមជើងនេះ ហើយទ្រង់ជាន់ទុក

ប៉ុណ្ណោះ ។ ឈ្មោះថា បុគ្គលដែលនឹងឃើញចេតិយ គឺស្នាមព្រះបាទនោះក្នុងទីដ៏សេស មិនមាន ។ ព្រាហ្មណ៍ត្រូវនាងព្រាហ្មណីទៅជាមួយខ្លួនសួរថា បុរសនោះនៅឯណា ទើបប្រាប់ថា ខ្ញុំបានប្រាប់បុរសនោះហើយ សូមលោកបន្ទន់នៅក្នុងទីនេះ ក៏រកមើលជួបស្នាមព្រះបាទហើយ ទើបចង្អុលថា នេះស្នាមជើងរបស់បុរសនោះ ។

ព្រាហ្មណីនោះពោលថា នែព្រាហ្មណ៍ នេះ មិនមែនស្នាមជើងរបស់បុគ្គលអ្នកបរិភោគកាមទេ ។ ព្រោះនាងជាបុគ្គលដែលឈ្លាសក្នុងមន្តជាគ្រឿងទាយលក្ខណៈ កាលព្រាហ្មណ៍ពោលថា នែនាងដ៏ចម្រើន នាងទាយដូចឃើញក្រពើក្នុងពាងទឹក សមណៈនោះខ្ញុំប្រាប់ហើយថា ខ្ញុំនឹងឲ្យធីតាដល់គេ ទោះបីគេក៏ទទួលពាក្យយើងហើយ ពោលថា ព្រាហ្មណ៍ អ្នកប្រាប់យ៉ាងនោះក៏ពិត តែស្នាមជើងនេះ ជាស្នាមជើងរបស់បុគ្គលដែលអស់កិលេសនោះឯងដូច្នេះហើយ ពោលគាថានេះថា

បុគ្គលដែលជារាគៈចរិត គប្បីមានស្នាមជើងកំពុងកណ្តាល
បុគ្គលដែលជាទោសៈចរិត រមែងមានស្នាមជើងធូន់ខាងក្រោយ
បុគ្គលដែលជាមោហៈចរិត រមែងមានស្នាមជើងធូន់ខាងមុខ
បុគ្គលមានកិលេសដូចគ្រឿងប្រក់ដែលបើកហើយ មានស្នាមបែបនេះ ។

ពេលនោះ ទើបព្រាហ្មណ៍ប្រាប់នាងព្រាហ្មណីថា នែនាង នាងកុំរអ៊ូឡើយ ចូរជាអ្នកស្ងៀមចុះ ទៅជួបព្រះសាស្តាហើយ ទើបបង្ហាញដល់

ព្រាហ្មណីនោះថា នេះ គឺបុរសនោះ ហើយចូលទៅគាល់ព្រះសាស្តាទូលថា សមណ: ខ្ញុំឲ្យធីតា ។ ព្រះសាស្តាមិនត្រាស់ថា តថាគតមិនត្រូវការធីតារបស់អ្នក បែរជាត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតនឹងប្រាប់ហេតុមួយដល់អ្នក តើអ្នកស្តាប់ដែរឬទេ កាលព្រាហ្មណ៍ទូលថា បពិត្រសមណ: សូមលោកពោលមកចុះ ខ្ញុំនឹងស្តាប់ ទើបទ្រង់នាំរឿងអតីត កាលទ្រង់ចេញមហាភិនិស្រ្កមណ៍មកសម្តែងហើយ ។

សេចក្តីសង្ខេបក្នុងរឿងនោះ មានដូចតទៅនេះ

ព្រះមហាសត្វ ទ្រង់លះសិរីរាជសម្បត្តិ ទ្រង់ឡើងកាន់សេះកណ្ឋក: មានឆន្នជាសម្លាញ់ ទ្រង់ចេញមហាភិនិស្រ្កមណ៍ កាលមារឈរត្រង់ទ្វារនៃព្រះនគរពោលថា នៃសុទ្ធត្ថ ចូរអ្នកត្រឡប់ចុះ រាប់អំពីថ្ងៃនេះទៅ ៧ ថ្ងៃទៀតចក្ករ័តន៍នឹងប្រាកដដល់អ្នក ទើបត្រាស់ថា នៃមារ យើងក៏ដឹងចក្ករ័តន៍នោះតែយើងមិនត្រូវការដោយចក្ករ័តន៍នោះឡើយ មារពោលថា បើដូច្នោះ អ្នកចេញទៅដើម្បីប្រយោជន៍អ្វី ព្រះមហាសត្វឆ្លើយថា ដើម្បីប្រយោជន៍ដល់សព្វញ្ញុតញ្ញាណ មារពោលថា បើដូច្នោះ ចាប់ពីថ្ងៃនេះទៅ បណ្តាវិតក្ក ៣ មានកាមវិតក្កជាដើម អ្នកកុំត្រិះរិះតិចតួចឡើយ ខ្ញុំនឹងដឹងកិច្ចដែលគួរធ្វើដល់អ្នក ។

តាំងអំពីនោះមក មារឃ្លាំចាំចាប់កំហុសជាប់តាមព្រះមហាសត្វ អស់ ៧ ឆ្នាំ សូម្បីព្រះសាស្តា ទ្រង់ប្រព្រឹត្តទុក្ករកិរិយាអស់ ៦ ឆ្នាំ ទ្រង់អាស្រ័យការធ្វើសេចក្តីព្យាយាមរបស់បុរស ចំពោះព្រះអង្គ ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុ-

តញ្ញាណ ដោយវិមុត្តិសុខត្រង់មណ្ឌលពោធិព្រឹក្ស ក្នុងសប្តាហ៍ទី ៥ ប្រថាប់គង់ត្រង់មណ្ឌលអជបាលនិគ្រោធ ។

សម័យនោះ មារដល់នូវកាពទោមនស្សហើយ អង្គុយត្រង់ផ្លូវធំ រំពឹងពិចារណាថា អញជាប់តាមមកអស់កាលមានប្រមាណប៉ុណ្ណេះ សូម្បីត្រឹមតែចាប់កំហុស ក៏មិនបានឃើញការភ្លាំងភ្លាត់ណាមួយរបស់សុទ្ធត្តនេះ ឥឡូវនេះ សុទ្ធត្តឈានកន្លងវិស័យអញទៅហើយ ។ ពេលនោះ ធីតា ៣ នាក់របស់មារនោះ គឺនាងតណ្ហា នាងអរតី នាងរាគាត្រិះរិះថា បិតារបស់អញមិនប្រាកដឥឡូវនេះ លោកនៅទីណាហ្ន៎ ក៏ត្រាច់រកមើល ឃើញបិតានោះ អង្គុយហើយយ៉ាងនោះ ទើបចូលទៅរកហើយសាកសួរថា បពិត្របិតា ព្រោះហេតុអ្វី ទើបលោកខូចចិត្ត មារនិយាយសេចក្តីនោះដល់ធីតាទាំងនោះ លំដាប់នោះ ទើបធីតាទាំងនោះប្រាប់មារជាបិតានោះថា បពិត្របិតា សូមបិតាកុំគិតថ្វីឡើយ ពួកខ្ញុំនឹងធ្វើសុទ្ធត្តនោះ ឲ្យនៅក្នុងអំណាចរបស់ខ្លួន ហើយនាំមក មារពោលថា នែនាងទាំងឡាយ បុគ្គលណាម្នាក់ក៏មិនអាចធ្វើសុទ្ធត្តនោះឲ្យនៅក្នុងអំណាចបានដែរ ធីតាមារពោលថា បពិត្រលោកឪពុក ពួកខ្ញុំជាស្រី ពួកខ្ញុំនឹងចងសុទ្ធត្តនោះដោយអន្ទាក់ មានអន្ទាក់ គឺរាគៈជាដើម ហើយនាំមកឥឡូវនេះឯង សូមបិតាកុំគិតឡើយ ហើយនាំគ្នាទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រសមណៈ ពួកខ្ញុំនឹងជាអ្នកបម្រើបាទារបស់ព្រះអង្គ ។

ព្រះសាស្តា ទ្រង់មិនបានដាក់ព្រះហឫទ័យ ដល់ពាក្យរបស់ធីតាមារទាំងនោះឡើយ ទ្រង់មិនបើកព្រះនេត្រទាំងពីរមើលឡើយ ពួកធីតាមារគិត

គ្នាទៀតថា បំណងរបស់ពួកបុរសខ្ពង់ៗ ទាបៗ ពួកខ្លះ ស្រឡាញ់ក្មេងស្រី ជំទង់ទាំងឡាយ ពួកខ្លះ ស្រឡាញ់ក្នុងពួកស្រីដែលតាំងនៅក្នុងបឋមវ័យ ពួកខ្លះ មានសេចក្តីស្រឡាញ់ក្នុងពួកស្រី ដែលតាំងនៅក្នុងមជ្ឈិមវ័យ ពួកខ្លះ មានសេចក្តីស្រឡាញ់ក្នុងស្រីដែលតាំងនៅក្នុងបច្ចិមវ័យ ។ ពួកយើងនឹងលួងលោមលោក ដោយប្រការផ្សេងៗ ម្នាក់ៗ និម្មិតអត្តភាពបានមួយរយៗ ដោយអំណាចនៃភេទ មានភេទជាស្រីជំទង់ជាដើម ជាស្រីក្រមុំទាំងឡាយ ជាស្រីមិនទាន់ប្រសូត ជាស្រីប្រសូតម្តង ប្រសូតពីរដង ជាស្រីកណ្តាលមនុស្ស ជាស្រីចាស់ ចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលថា បពិត្រសមណៈ ពួកខ្ញុំនឹងបម្រើបាទាទាំងពីររបស់ព្រះអង្គ ដូច្នេះអស់ ៦ ដង ព្រះសាស្តាទ្រង់មិនដាក់ព្រះហឫទ័យដល់ពាក្យរបស់ធីតាមារនោះទេ ដោយប្រការដែលទ្រង់បង្អោនទៅក្នុងធម៌ដែលអស់ឧបធិដ៏កំពូល ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងធីតាមារ ដែលជាប់តាមមក ដោយហេតុមានប្រមាណប៉ុណ្ណេះថា ពួកនាងចូរចៀសចេញទៅ ពួកនាងឃើញអ្វីទើបព្យាយាមយ៉ាងនេះ ការធ្វើកម្មបែបនេះ ចំពោះមុខរបស់បុគ្គលដែលមានរាគៈមិនទាន់ទៅប្រាស់ ទើបគួរ ចំណែកតថាគត លះកិលេសទាំងឡាយមានរាគៈជាដើមបានហើយ ពួកនាងនឹងនាំតថាគតទៅក្នុងអំណាចរបស់ខ្លួនដោយហេតុដូចម្តេច ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

**យស្ស ជិតំ នាវជីយតិ ជិតមស្ស នោយាតិ កោចិ លោកេ**
**តំ ពុទ្ធំ អនន្តគោចរំ អបទំ កេន បទេន នេស្សថ**

**យស្ស ជាលិនី វិសត្តិកា តណ្ហា នត្ថិ កុហិញ្ចិ នេតវេ**
**តំ ពុទ្ធំ អនន្តគោចរំ អបទំ កេន បទេន នេស្សថ ។**

*ជ័យជម្នះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេស ណាមួយ ក្នុងលោក រមែងមិនជាប់តាមជ័យជម្នះរបស់ព្រះពុទ្ធ អង្គនោះ នាងទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែល មានគោចររកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្ដេចកើត ។*

*តណ្ហាដែលមានបណ្ដាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេងៗ មិន មានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅក្នុងភពណាមួយ នាងទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេស ដូចស្នាមជើងម្ដេចកើត ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បាទព្រះគាថាថា* **យស្ស ជិតំ នាវជីយតិ** *សេចក្ដី ថា កិលេសជាតិ មានរាគៈជាដើម ដែលព្រះសម្មាសម្ពុទ្ធអង្គណា ទ្រង់ឈ្នះ ហើយដោយមគ្គនោះៗ ទ្រង់មិនត្រឡប់ចាញ់ គឺឈ្មោះថាឈ្នះហើយ មិនល្អ មិនមាន ព្រោះមិនត្រឡប់កើតឡើងទៀត ។*

*បទថា* **នោយាតិ** *កាត់ជា* **ន ឧយ្យាតិ** *ប្រែថា រមែងមិនទៅតាម*

អធិប្បាយថា បណ្ដាកិលេស មានរាគៈជាដើម កិលេសណាមួយ ក្នុងលោក ឈ្មោះថា ត្រឡប់ទៅក្រោយមិនមាន គឺមិនជាប់តាមកិលេសជាតិ ដែលព្រះសម្មាសម្ពុទ្ធអង្គណា ទ្រង់ឈ្នះហើយ ។

បទថា **អនន្តគោចរំ** សេចក្ដីថា ជាអ្នកមានអារម្មណ៍មិនមានទីបំផុត ដោយអំណាចសព្វញ្ញុតញ្ញាណ មានអារម្មណ៍មិនមានទីបំផុត ។

ពីរបទថា **កេន បទេន** ជាដើម សេចក្ដីថា បណ្ដាស្នាម មានស្នាម គឺរាគៈជាដើម សូម្បីស្នាមមួយមិនមានដល់ព្រះសម្ពុទ្ធអង្គណា ពួកនាងនឹងនាំព្រះសម្មាសម្ពុទ្ធអង្គនោះទៅដោយស្នាមដើងអ្វី គឺសូម្បីតែស្នាមមួយ មិនមានដល់ព្រះពុទ្ធ ពួកនាងនឹងនាំព្រះពុទ្ធនោះ ដែលមិនមានស្នាមជើងទៅដោយស្នាមជើងអ្វី ។

វិនិច្ឆ័យក្នុងគាថាទី ២ ឈ្មោះថា តណ្ហានោះ ពាក្យថា **ជាលិនី** ព្រោះវិគ្គហៈថា មានសំណាញ់ មានប្រក្រតីធ្វើនូវសំណាញ់ ប្រៀបដូចសំណាញ់ ព្រោះអត្ថថា រួបរឹត គឺចង ឈ្មោះថា **វិសត្តិកា** ព្រោះជាធម្មជាតផ្សាយទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ព្រោះប្រៀបដោយអាហារដែលមានពិស ព្រោះប្រៀបដោយផ្កាមានជាតិពុល ព្រោះប្រៀបដោយផ្លែឈើមានជាតិពុល ព្រោះប្រៀបដូចគ្រឿងបរិភោគមានពិស អធិប្បាយថា តណ្ហាបែបនោះ មិនមានដល់ព្រះពុទ្ធអង្គណា ដើម្បីនាំទៅក្នុងភពណា ពួកនាងនឹងនាំព្រះពុទ្ធអង្គនោះ ដែលមិនមានស្នាមជើង ដោយស្នាមជើងអ្វី ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យមានដល់ទេវតាដ៏ច្រើន សូម្បីមារ-

ធីតាក៏អន្តរធានទៅក្នុងទីនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាល មាគន្ទិយៈ ក្នុងកាលមុន តថាគតបានឃើញធីតាមារទាំង ៣ ប្រកបដោយអត្តភាពដូចមាស មិនប្រឡាក់ដោយរបស់ស្មោកគ្រោក មានស្នេហ៍ជាដើម ក្នុងកាលនោះ តថាគតមិនមានការពេញចិត្តក្នុងមេថុនឡើយ សរីរៈនៃធីតារបស់អ្នក ពេញទៅដោយសាកសព គឺអាការ ៣២ ដូចថ្នាំងដែលហូរទូវរបស់មិនស្អាត ដែលស្រស់ត្រកាលសម្រាប់ភ្នែកខាងក្រៅ សូម្បីជើងរបស់តថាគត គប្បីជាជើងប្រឡាក់ដោយរបស់មិនស្អាតសោត ហើយធីតារបស់អ្នក គប្បីឈរត្រង់ធរណីទ្វារ ទោះជាយ៉ាងនោះ ក៏តថាគតមិនប្រាថ្នានឹងប៉ះសរីរៈរបស់នាងដោយជើង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ការពេញចិត្តក្នុងមេថុនធម្មមិនមាន ព្រោះឃើញនាងតណ្ហា នាងអរតី និងនាងរាគា ព្រោះឃើញសរីរៈរបស់កូនស្រីអ្នកនេះ ដែលពេញដោយមូត្រ និងករីស តថាគតរមែងមិនប្រាថ្នានឹងប៉ះសរីរៈធីតារបស់អ្នកនោះ សូម្បីដោយជើង ក្នុងកាលចប់ទេសនា ប្តីប្រពន្ធទាំង ២ តាំងនៅក្នុងអនាគាមិផល ដូច្នេះឯង ។៙

## រឿង មារធីតា ចប់

# រឿង យមកប្បាដិហារ្យ

## លំនាំដើម

ព្រះសាស្តាទ្រង់ប្រារព្ធទេវតា និងមនុស្សជាច្រើនត្រង់ទ្វារនៃនគរសង្កស្សៈ ត្រាស់ព្រះធម្មទេសនានេះថា **យេ ឈានប្បសុតា ធីរា** ជាដើម ។ ទេសនានេះកើតឡើងក្នុងក្រុងរាជគ្រឹះ ។

សេចក្តីពិស្តារ សម័យមួយ សេដ្ឋីអ្នកក្រុងរាជគ្រឹះ ឲ្យសន្ទឹងសំណាញ់មានសណ្ឋានដូចជបដើម្បីសេចក្តីផុតភ័យ គឺដើម្បីរក្សាអាភរណៈជាដើម ដែលរបូតទៅដោយការភ្លេចភ្លាំង លេងកីឡាក្នុងស្ទឹងគង្គា ។

ក្នុងកាលនោះ ដើមចន្ទន៍មួយដើមកើតឡើងត្រង់ប្រាំងស្ទឹងខាងលើខ្សែទឹកនៃស្ទឹងគង្គា មានឫសត្រូវទឹកច្រោះ គាល់បាក់ខ្ចាត់ខ្ចាយ នៅលើថ្មនោះៗ កាលនោះ ពកមួយមានប្រមាណប៉ុនក្អម ត្រូវថ្មកួត ត្រូវរលកនាំមកជារបស់រលោង អណ្តែតទៅដោយលំដាប់ ត្រូវសារាយរួបរឹត មកជាប់សំណាញ់របស់សេដ្ឋីនោះ ។

សេដ្ឋីពោលថា នុ៎ះជាអ្វី បានឮថា នុ៎ះជាពកនៃដើមឈើ ទើបឲ្យនាំពកឈើនោះមកចាំងដោយចុងកាំបិត ដើម្បីពិចារណាថា នុ៎ះជាឈើអ្វី ។

រំពេចនោះឯង ចន្ទន៍ក្រហមមានពណ៌ដូចល័ក្តក៏ប្រាកដ សេដ្ឋីមិនទាន់ជាសម្មាទិដ្ឋិ មិនជាមិច្ឆាទិដ្ឋិ ដាក់ខ្លួនជាកណ្តាលគិតថា ចន្ទន៍ក្រហមក្នុងផ្ទះរបស់អញមានច្រើន អញនឹងយកចន្ទន៍នេះធ្វើអ្វីហ្ន៎ ពោលនោះគាត់គិតយ៉ាងនេះថា ក្នុងលោកនេះ ជនដែលពោលថា អញជាព្រះអរហន្តមានច្រើន អញមិន

ស្គាល់ព្រះអរហន្តសូម្បីត្រឹមតែមួយ អញនឹងប្រកបគ្រឿងក្រឡឹងទុកក្នុងផ្ទះ ឲ្យក្រឡឹងជាបាត្រហើយ ដាក់សង្រែកសំយុងក្នុងអាកាសប្រមាណ ៦០ ហត្ថ ដោយឫស្សីតគ្នា ពោលថា បើព្រះអរហន្តមាន សូមមកតាមអាកាសហើយកាន់យកបាត្រនេះ បុគ្គលណាកាន់យកបាត្រនោះបាន ខ្ញុំ មួយអន្លើដោយបុត្ត-ភរិយា នឹងដល់បុគ្គលនោះជាសរណៈ ហើយឲ្យក្រឡឹងបាត្រដោយទំនងដែលគិតហើយនោះឯង លើកឡើងដោយឫស្សីតគ្នា ពោលថា ក្នុងលោកនេះ បុគ្គលណាជាព្រះអរហន្ត សូមបុគ្គលនោះមកតាមអាកាសយកបាត្រនេះចុះ ។

គ្រូទាំងឡាយពោលថា បាត្រនោះសមគួរដល់ពួកយើង សូមលោកឲ្យបាត្រនោះដល់អាត្មាចុះ សេដ្ឋីនោះពោលថា សូមលោកម្ចាស់ទាំងឡាយ មកតាមអាកាសហើយយកចុះ ។

ក្នុងថ្ងៃទី ៦ និគណ្ឋនាដបុត្រ បញ្ជូនពួកអន្តេវាសិកទៅថា ចូរពួកលោកទៅ ចូរនិយាយនឹងសេដ្ឋីយ៉ាងនេះថា បាត្រនោះ សមគួរដល់អាចារ្យរបស់ពួកយើង លោកកុំធ្វើការមកតាមអាកាស ព្រោះហេតុត្រឹមតែរបស់តិចតួចឡើយ សូមលោកឲ្យបាត្រនោះចុះ ។ ពួកអន្តេវាសិកពោលនឹងសេដ្ឋីយ៉ាងនោះហើយ សេដ្ឋីពោលថា បុគ្គលដែលអាចមកតាមអាកាស ហើយកាន់យកបានប៉ុណ្ណោះ ចូរយកទៅ ។

នាដបុត្រជាអ្នកប្រាថ្នាទៅឯង ទើបឲ្យសញ្ញាដល់អន្តេវាសិកថា យើងនឹងលើកដៃ លើកជើងម្ខាង ធ្វើអាកប្បកិរិយាប្រាថ្នានឹងហោះ ចូរពួកអ្នកស្រែកប្រាប់យើងថា លោកអាចារ្យ លោកកុំធ្វើឡើយ លោកកុំសម្តែងភាពជាព្រះ

អរហន្តដែលខំបិទបាំង ព្រោះហេតុត្រឹមតែបាត្រឈើដល់មហាជនឡើយ ដូច្នេះហើយ ចូរនាំគ្នាចាប់យើងត្រង់ដៃ និងជើង ទាញឲ្យដួលចុះត្រង់ផែនដី ។ គាត់ទៅក្នុងទីនោះហើយ ពោលនឹងសេដ្ឋីថា លោកសេដ្ឋី បាត្រនេះសមគួរដល់អាត្មា មិនសមគួរដល់ជនដទៃឡើយ សូមលោកកុំគាប់ចិត្តនឹងការហោះទៅក្នុងអាកាសរបស់អាត្មា ព្រោះហេតុត្រឹមតែរបស់តូចតាច ចូរឲ្យបាត្រដល់អាត្មាចុះ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវហោះឡើងទៅក្នុងអាកាសហើយកាន់យកចុះ ។

លំដាប់នោះ នាដបុត្រពោលថា បើដូច្នោះ ចូរពួកអ្នកចៀសចេញ ពួកអន្តេវាសិកក៏ចៀសចេញទៅហើយ ពោលថា យើងនឹងហោះឡើងទៅក្នុងអាកាស ដូច្នេះហើយ លើកដៃ និងជើងម្ខាងឡើង ។ ពេលនោះ អន្តេវាសិកពោលនឹងអាចារ្យថា លោកអាចារ្យ លោកនឹងធ្វើអ្វីនឹង ប្រយោជន៍អ្វីដោយគុណដែលបិទបាំង ហើយលោកមកសម្ដែងដល់មហាជន ព្រោះហេតុត្រឹមតែបាត្រឈើនេះ ហើយនាំគ្នាចាប់នាដបុត្រនោះត្រង់ដៃ និងជើង ទាញមកឲ្យដួលចុះលើផែនដី នាដបុត្រប្រាប់សេដ្ឋីថា លោកសេដ្ឋី អន្តេសិកទាំងនេះមិនឲ្យអាត្មាហោះ ចូរលោកឲ្យបាត្រដល់អាត្មាចុះ ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ ត្រូវហោះឡើងហើយកាន់យកចុះ ។

ពួកតិរ្ថិយ សូម្បីព្យាយាមដោយអាការយ៉ាងនេះអស់ ៦ ថ្ងៃ ក៏មិនបានបាត្រនោះឡើយ ។

ក្នុងថ្ងៃទី៧ក្នុងកាលដែលព្រះមហាមោគ្គល្លាន និងព្រះបិណ្ឌោលភារទ្វាជៈ

ទៅឈរត្រង់ថ្មដាមួយកន្លែង ហើយស្លៀកដណ្ដប់ចីវរ ដោយតាំងចិត្តថានឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ពួកអ្នកលេងជជែកគ្នាថា ម្នាលគ្នាយើង ក្នុងកាលមុន គ្រូទាំង ៦ ពោលថា ពួកយើងជាព្រះអរហន្តក្នុងលោក កាលសេដ្ឋីអ្នកក្រុងរាជគ្រឹះលើកបាត្រហើយ ពោលថា បើព្រះអរហន្តមាន សូមមកតាមអាកាសហើយ កាន់យកចុះ នេះជាថ្ងៃទី ៧ បុគ្គលសូម្បីត្រឹមតែម្នាក់ ដែលហោះទៅក្នុងអាកាស ដោយបង្ហាញខ្លួនថា យើងជាព្រះអរហន្តក៏មិនមាន ថ្ងៃនេះ ពួកយើងដឹងនូវភាពដែលព្រះអរហន្ត មិនមានក្នុងលោកហើយ ។

ចំណែកព្រះមហាមោគ្គល្លាន បានឮពាក្យនោះហើយ ទើបពោលនឹងព្រះបិណ្ឌោលភារទ្វាជៈថា អាវុសោភារទ្វាជៈ លោកបានឮពាក្យរបស់ពួកអ្នកលេងទាំងនេះដែរឬទេ ពួកអ្នកលេងទាំងនេះ ពោលញាំញីព្រះពុទ្ធសាសនា លោកម្ចាស់មានឫទ្ធិច្រើន មានអានុភាពច្រើន សូមលោកទៅចុះ សូមមកតាមអាកាស ហើយកាន់យកបាត្រនោះ ។

ព្រះបិណ្ឌោលភារទ្វាជៈពោលថា អាវុសោមោគ្គល្លាន លោកជាកំពូលជាង ខាងបណ្ដាសាវកអ្នកមានឫទ្ធិ សូមលោកម្ចាស់កាន់យកបាត្រនោះ តែបើលោកមិនកាន់យក ខ្ញុំនឹងកាន់យក ។

កាលព្រះមហាមោគ្គល្លានពោលយ៉ាងនេះថា អាវុសោ សូមលោកកាន់យកចុះ ។ ព្រះបិណ្ឌោលភារទ្វាជៈចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ចេញហើយ យកចុងជើងផ្ទៀបថ្មដាប្រមាណ ១ គាវុត ហោះឡើងទៅកាន់អាកាសដូចប៉ុយ-គ ហើយប្រទក្សិណខាងលើនគររាជគ្រឹះ ៧ ជុំ ថ្មដានោះ

ប្រាកដដូចជញ្ជាំង សម្រាប់បិទព្រះនគរប្រមាណ ៣ គាវុត ពួកអ្នកនគរខ្លាច ស្រែកថា ថ្មនឹងធ្លាក់សង្កត់ពួកយើង ធ្វើគ្រឿងការពារ មានចង្អេរជាដើម ខាងលើក្បាល ហើយពួនក្នុងទីនោះៗ ក្នុងវារៈទី ៧ ព្រះថេរៈទម្លាយថ្ម ហើយបង្ហាញខ្លួន ។

មហាជនឃើញព្រះថេរៈហើយ ពោលថា ព្រះបិណ្ឌោលភារទ្វាជៈ សូមលោកម្ចាស់ ចាប់ថ្មរបស់លោកម្ចាស់ឲ្យមាំ កុំឲ្យពួកខ្ញុំទាំងអស់វិនាសឡើយ ។ ព្រះថេរៈយកចុងជើងគ្រវាត់ថ្មចោលទៅ ថ្មនោះទៅតាំងនៅក្នុងទីដើមនោះឯង ព្រះថេរៈបានឈរក្នុងទីបំផុតនៃផ្ទះរបស់សេដ្ឋី ។ សេដ្ឋីឃើញលោកហើយក្រាបចុះ ពិតថា សូមលោកម្ចាស់ចុះមកចុះ ។ និមន្តព្រះថេរៈ ចុះអំពីអាកាស ឲ្យគង់ហើយ ឲ្យនាំបាត្រចុះ ធ្វើឲ្យពេញដោយមធុរស ៤ យ៉ាង ហើយថ្វាយដល់ព្រះថេរៈៗ ទទួលបាត្រហើយ បែរមុខទៅកាន់វិហារ ទៅហើយ ។

លំដាប់នោះ ជនទាំងឡាយណាដែលនៅក្នុងព្រៃខ្លះ នៅក្នុងស្រុកខ្លះ មិនឃើញបាដិហារ្យរបស់ព្រះថេរៈ ជនទាំងនោះ ប្រជុំគ្នាហើយអង្វរព្រះថេរៈថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់សម្តែងបាដិហារ្យដល់ពួកខ្ញុំ ដូច្នេះហើយក៏នាំគ្នាជាប់តាមព្រះថេរៈទៅ ។ ព្រះថេរៈនោះ សម្តែងបាដិហារ្យដល់ជនទាំងនោះបណ្តើរ បានទៅកាន់វិហារហើយ ។

ព្រះសាស្តា ទ្រង់ស្តាប់សំឡេងមហាជន ដែលជាប់តាមព្រះថេរៈនោះទ្រហឹងអឺងកង ទើបត្រាស់សួរថា ម្នាលអានន្ទ នុ៎ះសំឡេងអ្វី ទ្រង់បានឮថា

ព្រះបិណ្ឌោលភារទ្វាជៈហោះទៅក្នុងអាកាសហើយ កាន់យកបាត្រខ្លឹមចន្ទន៍នោះ សំឡេងក្នុងសម្នាក់របស់លោក ទើបត្រាស់ឲ្យហៅព្រះបិណ្ឌោលភារទ្វាជៈមក ត្រាស់សួរថា បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ លោកក្រាបទូលថា ពិត ព្រះអង្គ ទើបត្រាស់ថា ម្នាលភារទ្វាជៈ ហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ ទ្រង់តិះដៀលព្រះថេរៈហើយ ត្រាស់ឲ្យទម្លាយបាត្រនោះធ្វើជាកំណាត់តូចធំ ចែកដល់ភិក្ខុទាំងឡាយ ដើម្បីប្រយោជន៍ផ្សំធ្វើជាថ្នាំបន្តក់ភ្នែក ហើយទ្រង់បញ្ញត្តិសក្ខាបទដល់សាវកទាំងឡាយ ដើម្បីមិនឲ្យធ្វើបាដិហារ្យ ។ ចំណែកពួកតិរ្ថិយបានឮថា ព្រះសមណគោតមឲ្យបំបែកបាត្រនោះហើយ ទ្រង់បញ្ញត្តិសិក្ខាបទដល់សាវកទាំងឡាយ ដើម្បីមិនឲ្យធ្វើបាដិហារ្យ ទើបដើរប្រាប់គ្នាក្នុងផ្លូវ ក្នុងព្រះនគរថា សាវកទាំងឡាយរបស់ព្រះសមណគោតម មិនកន្លងសិក្ខាបទដែលទ្រង់បញ្ញត្តិ សូម្បីហេតុនៃជីវិត សូម្បីព្រះសមណគោតមក៏រក្សាសិក្ខាបទដែលបញ្ញត្តិនោះដូចគ្នា ឥឡូវនេះ ពួកយើងបានឱកាសហើយ ហើយពោលថា ពួកយើងនឹងរក្សាគុណរបស់ខ្លួន ទើបមិនសម្ដែងគុណរបស់ខ្លួនដល់មហាជន ព្រោះហេតុនៃបាត្រក្នុងកាលមុន ពួកសាវករបស់ព្រះសមណគោតមសម្ដែងគុណរបស់ខ្លួនដល់មហាជន ព្រោះហេតុនៃបាត្រ ព្រះសមណគោតមត្រាស់ឲ្យបំបែកបាត្រនោះហើយ ទ្រង់បញ្ញត្តិសិក្ខាបទដល់ពួកសាវក ព្រោះទ្រង់ជាបណ្ឌិត ឥឡូវនេះ ពួកយើងនឹងធ្វើបាដិហារ្យជាមួយព្រះសមណ-គោតមនោះ ។

ព្រះបាទពិម្ពិសារ ទ្រង់ស្ដាប់ពាក្យនោះហើយ យាងទៅកាន់សម្នាក់ព្រះ

សាស្ដាក្រាបទូលថា បពិត្រព្រះអង្គ បានឮថា ទ្រង់បញ្ញត្តិសិក្ខាបទដល់ពួកសាវកដើម្បីមិនឲ្យធ្វើបាដិហារ្យពិតឬ ព្រះសាស្ដាត្រាស់ថា ពិតហើយមហារាជ ព្រះរាជាត្រាស់ថា ឥឡូនេះ ពួកតិរ្ថិយនាំគ្នាពោលថា ពួកយើងនឹងធ្វើបាដិហារ្យជាមួយទ្រង់ ឥឡូវនេះ ព្រះអង្គគិតដូចម្ដេច ។

ព្រះសាស្ដាត្រាស់ថា កាលតិរ្ថិយទាំងនោះធ្វើ តថាគតក៏នឹងធ្វើ ព្រះរាជាត្រាស់ថា ទ្រង់បញ្ញត្តិសិក្ខាបទហើយមិនមែនឬ ព្រះសាស្ដាត្រាស់ថា មហាបពិត្រ តថាគតមិនបានបញ្ញត្តិសិក្ខាបទដើម្បីខ្លួន សិក្ខាបទនោះឯង តថាគតបញ្ញត្តិដើម្បីសាវកទាំងឡាយ ។

ព្រះរាជាត្រាស់ថា សិក្ខាបទ ឈ្មោះថា ទ្រង់បញ្ញត្តិក្នុងសាវកទាំងឡាយវៀរទ្រង់ចេញឬ ព្រះសាស្ដាត្រាស់ថា មហាបពិត្រ បើដូច្នោះ តថាគតនឹងសួរព្រះអង្គនោះឯងព្រោះរឿងនេះ មហាបពិត្រ ព្រះរាជឧទ្យានក្នុងដែនរបស់ព្រះអង្គមានឬ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ មាន ។ ព្រះសាស្ដាត្រាស់ថា មហាបពិត្រ បើមហាជនបរិភោគផ្លែឈើមានផ្លែស្វាយជាដើម ក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គ ទ្រង់គប្បីធ្វើដូចម្ដេច ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ គប្បីដាក់ទោស ព្រះសាស្ដាត្រាស់ថា ចុះព្រះអង្គសោយបានឬ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ អាជ្ញាមិនមានដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គអាចសោយរបស់ខ្លួនបាន ព្រះសាស្ដាត្រាស់ថា មហាបពិត្រ រាជអាជ្ញារបស់តថាគតរមែងផ្សាយទៅក្នុងសែនកោដិចក្រវាល ដូចរាជអាជ្ញារបស់ព្រះអង្គដែលផ្សាយទៅក្នុងដែនប្រមាណ ៣០០ យោជន៍ អាជ្ញាមិនមានដល់ព្រះអង្គ

ដែលសោយផ្លែឈើទាំងឡាយ មានផ្លែស្វាយជាដើម ក្នុងព្រះរាជឧទ្យាន របស់ព្រះអង្គ តែមានដល់ជនដទៃ ឈ្មោះថា ការឈានកន្លងនូវបញ្ញត្តិ គឺសិក្ខាបទ រមែងមិនមានដល់ខ្លួន តែរមែងមានដល់សាវកដទៃ ទើបតថាគតអាចធ្វើបាដិហារ្យបាន ។

ពួកតិរ្ថិយស្តាប់ពាក្យនោះហើយប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងវិនាសហើយ បានឮថា ព្រះសមណគោតម ទ្រង់បញ្ញត្តិសិក្ខាបទដើម្បីពួកសាវកទាំងនោះ ទ្រង់មិនបញ្ញត្តិដើម្បីខ្លួន បានឮថា ទ្រង់ប្រាថ្នានឹងធ្វើបាដិហារ្យឯងនោះឯង ពួកយើងនឹងធ្វើដូចម្តេច ព្រះរាជាទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ទ្រង់នឹងធ្វើបាដិហារ្យក្នុងកាលណា ព្រះសាស្តាត្រាស់ថា មហាបពិត្រ កន្លងទៅ ៤ ខែទៀត បន្ទាប់អំពីថ្ងៃពេញបូណ៌មីខែអាសាឍ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ ទ្រង់នឹងធ្វើក្នុងទីណា ព្រះសាស្តាត្រាស់ថា មហាបពិត្រ តថាគតនឹងធ្វើអាស្រ័យក្រុងសាវត្ថី ។

មានពាក្យសួរជ្រៀតចូលមកថា ហេតុអ្វី ទើបព្រះសាស្តាអាងដល់ទីឆ្ងាយយ៉ាងនេះ ឆ្លើយថា ព្រោះទីនោះជាទីធ្វើបាដិហារ្យរបស់ព្រះពុទ្ធគ្រប់អង្គ ម្យ៉ាងទៀត ទ្រង់អាងទីឆ្ងាយនោះឯង ដើម្បីប្រយោជន៍ឲ្យមហាជនប្រជុំគ្នា ។

ពួកតិរ្ថិយស្តាប់ពាក្យនោះហើយ ពោលថា បានឮថា បន្ទាប់អំពីនេះទៅ ៤ ខែទៀត ព្រះសមណគោតមនឹងធ្វើបាដិហារ្យក្នុងក្រុងសាវត្ថី ឥឡូវនេះ ពួកយើងមិនលះបង់ យើងនឹងជាប់តាមព្រះអង្គទៅ មហាជនឃើញពួកយើងហើយនឹងសួរថា ពួកលោកម្ចាស់នឹងធ្វើអ្វី ពេលនោះ ពួកយើងនឹងប្រាប់ដល់ជនទាំង

នោះថា ពួកយើងពោលហើយថា នឹងធ្វើបាដិហារ្យជាមួយព្រះសមណគោតម ព្រះគោតមនោះ រមែងគេចទៅ ពួកយើងមិនឲ្យព្រះសមណគោតមនោះគេច ទើបជាប់តាមទៅ ។ ព្រះសាស្តា ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ចេញមកហើយ សូម្បីពួកតិរ្ថិយក៏ចេញមកតាមក្រោយទ្រង់នោះឯង ក្នុងទីជិតៗ ព្រះដ៏មានព្រះភាគដែលទ្រង់ធ្វើភត្តកិច្ច ស្អែកឡើង ពួកតិរ្ថិយបរិភោគអាហារព្រឹក ក្នុងទីដែលខ្លួននៅហើយ ។ តិរ្ថិយទាំងនោះ ត្រូវពួកមនុស្សសួរថា នេះអ្វី ទើបប្រាប់ដោយន័យនៃពាក្យដែលពោលហើយខាងដើមនោះឯង ។ ឯមហាជនគិតថា ពួកយើងនឹងមើលបាដិហារ្យ ដូច្នេះហើយ បានជាប់តាមទៅ ។ ព្រះសាស្តាដល់នគរសាវត្ថីដោយលំដាប់ ។

ពួកតិរ្ថិយក៏ទៅជាមួយព្រះអង្គដូចគ្នា បបួលឧបដ្ឋាកបានទ្រព្យមួយសែនហើយ ឲ្យធ្វើមណ្ឌបសសរគគីរ ប្រក់ដោយផ្កាឧប្បលខៀវ អង្គុយនិយាយគ្នាថា ពួកយើងនឹងធ្វើបាដិហារ្យក្នុងទីនេះ ។

គ្រានោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ ពួកតិរ្ថិយធ្វើមណ្ឌបហើយ ខ្ញុំព្រះអង្គនឹងធ្វើមណ្ឌបដើម្បីទ្រង់ ព្រះសាស្តាត្រាស់ថា មហាបពិត្រ កុំឡើយ អ្នកធ្វើមណ្ឌបរបស់តថាគត មានហើយ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ អ្នកដទៃវៀរខ្ញុំព្រះអង្គ តើអ្នកណានឹងធ្វើ ព្រះសាស្តាត្រាស់ថា អ្នកធ្វើ គឺសក្កទេវរាជ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ ទ្រង់នឹងធ្វើបាដិហារ្យក្នុងទីណា ព្រះសាស្តាត្រាស់ថា គល់មណ្ឌលគណ្ឌាម្ពព្រឹក្ស ។

ពួកតិរ្ថិយបានឮថា ព្រះសមណគោតម នឹងធ្វើបាដិហារ្យត្រង់គល់ស្វាយ ទើបប្រាប់ឧបដ្ឋាករបស់ខ្លួនឲ្យដកដើមស្វាយតូចៗ ដោយហោចដែលដុះក្នុងថ្ងៃនោះ ក្នុងទីវាងមួយយោជន៍ ហើយឲ្យបោះចោលក្នុងព្រៃ ។

ក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ព្រះសាស្តាចូលទៅខាងក្នុងព្រះនគរ អ្នករក្សាចម្ការស្វាយរបស់ព្រះរាជា ឈ្មោះគណ្ឌៈ ឃើញផ្លែស្វាយទុំធំមួយនៅក្នុងសម្បុកអង្ក្រង ដេញក្អែកដែលមកចោមរោមដោយចំណង់ក្នុងក្លិន និងរសនៃផ្លែស្វាយនោះឲ្យគេចទៅហើយ កាន់យកដើម្បីប្រយោជន៍ដល់ព្រះរាជា ដើរទៅឃើញព្រះសាស្តាក្នុងរវាងផ្លូវ គិតថា ព្រះរាជាសោយផ្លែស្វាយនេះហើយគប្បីព្រះរាជទានកហាបណៈ ៨ ឬ ១៦ កហាបណៈ កហាបណៈនោះមិនគ្រប់គ្រាន់ដើម្បីចិញ្ចឹមជីវិតក្នុងអត្តភាពមួយរបស់អញ បើអញប្រគេនផ្លែស្វាយនេះដល់ព្រះសាស្តា នឹងជាគុណនាំមកនូវប្រយោជន៍ឲ្យដល់អញអស់កាលមិនមានទីបំផុត ។ ទើបបង្អោនផ្លែស្វាយនោះដល់ព្រះសាស្តា ។

ព្រះសាស្តា ទតព្រះអានន្ទត្ថេរហើយ ។ លំដាប់នោះ ព្រះថេរៈនាំបាត្រដែលមហារាជទាំង ៤ ថ្វាយមកហើយ ដាក់ក្នុងព្រះហស្តរបស់ព្រះអង្គ ។

ព្រះសាស្តា ទ្រង់បង្អោនបាត្រទទួលផ្លែស្វាយហើយ ទ្រង់សម្តែងអាការដើម្បីប្រថាប់គង់ក្នុងទីនោះឯង ។ ព្រះថេរៈបានក្រាលចីវរថ្វាយហើយ លំដាប់នោះ កាលទ្រង់ប្រថាប់គង់លើចីវរនោះ ព្រះថេរៈត្រងទឹកថ្វាយ ហើយច្របាច់ផ្លែស្វាយនោះ ធ្វើជាទឹកបានថ្វាយ ។ ព្រះសាស្តាសោយទឹកបានស្វាយហើយត្រាស់នឹងគណ្ឌៈថា ចូរអ្នកកាយដីផង់ឡើងហើយ ដាំគ្រាប់ស្វាយនេះក្នុងទីនេះ

ឯង បុរសនោះបានធ្វើយ៉ាងនោះហើយ ។

ព្រះសាស្តាទ្រង់លាងព្រះហស្តលើគ្រាប់ស្វាយនោះ គ្រាន់ព្រះហស្តដែលទ្រង់លាងហើយប៉ុណ្ណោះ គ្រាប់ស្វាយមានដើមប៉ុនចុងនង្គ័លប្រមាណ ៥០ ហត្ថ ដោយកម្ពស់ ដុះឡើងហើយ មែកធំមាន ៥ ចេញទៅគ្រប់ទិសទាំង ៤ និងមែកមួយត្រង់ឡើងលើ មែកនីមួយៗ មានប្រមាណ ៥០ ហត្ថ ។ ដើមស្វាយនោះសម្បូរដោយផ្កា និងផ្លែ បានទ្រទ្រង់នូវចង្កោមនៃផ្លែស្វាយទុំ ក្នុងទីមួយកន្លែងក្នុងខណៈនោះឯង ។

ពួកភិក្ខុមកខាងក្រោយ ទំពាឆាន់នូវផ្លែស្វាយទុំដូចគ្នា ។ ព្រះរាជាទ្រង់បានឮថា ស្វាយបែបនេះកើតឡើងហើយ ទើបទ្រង់ចាត់ចែងរក្សាដោយព្រះតម្រាស់ថា បុគ្គលណាម្នាក់កុំកាប់ដើមស្វាយនោះ ដើមស្វាយនោះប្រាកដឈ្មោះថា គណ្ឌម្ពព្រឹក្ស ព្រោះគណ្ឌៈជាអ្នកដាំ សូម្បីពួកអ្នកលេងទំពាស៊ីផ្លែស្វាយទុំហើយ ពោលថា ពួកតិរ្ថិយថោកទាប ពួកអ្នកដឹងថាព្រះសមណគោតមទ្រង់ធ្វើបាដិហារ្យត្រង់គណ្ឌម្ពព្រឹក្ស ទើបបញ្ជាឲ្យដកដើមស្វាយតូចៗ សូម្បីកើតក្នុងថ្ងៃនោះក្នុងទីមួយយោជន៍ ដើមស្វាយនេះឈ្មោះគណ្ឌម្ពៈ ហើយយកគ្រាប់ស្វាយដែលជាសំណល់ ប្រហារពួកតិរ្ថិយទាំងនោះ ។

សក្កទេវរាជ ទ្រង់ប្រាប់វាតវលាហកទេវបុត្រថា ចូរពួកអ្នកបក់បំបើងមណ្ឌបរបស់ពួកតិរ្ថិយឲ្យរលំចុះលើផែនដី និងសំរាមទាំងឡាយ ។ ទេវបុត្រនោះបានធ្វើយ៉ាងនោះហើយ ។ សក្កទេវរាជប្រាប់សុរិយទេវបុត្រថា ចូរអ្នកពង្រីកមណ្ឌល ញុំាងពួកតិរ្ថិយឲ្យក្តៅក្រហាយ ទេវបុត្រនោះ ក៏បានធ្វើយ៉ាង

នោះហើយ ។ សក្កៈ ទ្រង់បញ្ជាវាតវលាហកទេវបុត្រទៀតថា ចូរអ្នកញ៉ាំង មណ្ឌបឲ្យរលំ ខ្យល់កំបុតត្បូងឲ្យតាំងឡើងហើយបក់ទៅ ទេវបុត្រនោះ ធ្វើ យ៉ាងនោះ កួចទូវធូលីលើសរីរៈរបស់ពួកតិរ្ថិយដែលកំពុងបែកញើស ។ ពួក តិរ្ថិយទាំងនោះ មានខ្លួនដូចកណ្ដៀរក្រហម ។ សក្កទេវរាជ ទ្រង់បញ្ជាវស្ស- វលាហកទេវបុត្រថា ចូរពួកអ្នកឲ្យតំណក់ទឹកធំៗ ធ្លាក់ចុះ ទេវបុត្រនោះ បាន ធ្វើយ៉ាងនោះហើយ ។ ពេលនោះ កាយរបស់ពួកតិរ្ថិយទាំងនោះ ដូចគ្នានឹង មេគោពពាលហើយ ពួកគេបែកគ្នាគេចទៅក្នុងទីចំពោះមុខនោះឯង ។ កាល ពួកជនទាំងនោះទៅយ៉ាងនោះ អ្នកស្រែម្នាក់ជាឧបដ្ឋាករបស់បូរណកស្សបៈ គិតថា ឥឡូវនេះ ជាពេលធ្វើបាដិហារ្យនៃលោកម្ចាស់របស់យើង យើងនឹង មើលបាដិហារ្យនោះ ហើយលែងគោ កាន់ថ្នាំងបបរ និងខ្សែដែលខ្លួននាំមក អំពីព្រលឹម ដើរមកឃើញបូរណកស្សបៈរត់ទៅយ៉ាងនោះ ទើបពោលថា លោកម្ចាស់ ខ្ញុំមកដោយបំណងថា នឹងមើលបាដិហារ្យរបស់លោកម្ចាស់ លោកម្ចាស់ទៅណា បូរណកស្សបៈពោលថា អ្នកត្រូវការអ្វីដោយបាដិហារ្យ ចូរឲ្យថ្នាំង និងខ្សែនេះដល់ខ្ញុំ ។ កាន់យកថ្នាំង និងខ្សែដែលឧបដ្ឋាកនោះឲ្យ ហើយ ទៅកាន់ច្រាំងស្ទឹង យកខ្សែចងថ្នាំងនឹងករបស់ខ្លួនហើយ លោតចូល ទៅក្នុងអន្លង់ទឹក ញ៉ាំងពពុះឲ្យតាំងឡើង ធ្វើកាលកិរិយាកើតក្នុងអវីចិហើយ ។

ព្រះសាស្ដា ទ្រង់និម្មិតទីចង្ក្រមកែវក្នុងអាកាស ទីបំផុតនៃទីចង្ក្រមនោះ ទល់គ្នានឹងកណ្ដាប់ចក្រវាលទិសខាងកើត ទីចង្ក្រមមួយទៀត ទល់គ្នានឹង កណ្ដាប់ចក្រវាលទិសខាងលិច ។ ព្រះសាស្ដា កាលបរិស័ទមានប្រមាណ

៣៦ យោជន៍ប្រជុំគ្នាហើយ ក្នុងពេលរសៀលទ្រង់ចេញអំពីព្រះគន្ធកុដិ ដោយទ្រង់ព្រះតម្រិះថា ឥឡូវនេះ ជាពេលដែលធ្វើបាដិហារ្យ ហើយបានប្រថាប់ឈរត្រង់យ៉ម្មុខ ។

គ្រានោះ ឧបាសិកាជាអនាគាមីម្នាក់ គឺនទូមាតាឈ្មោះឃរណី ចូលទៅគាល់ព្រះអង្គហើយក្រាបទូលថា បពិត្រព្រះអង្គ កាលធីតាដូចខ្ញុំម្ចាស់មាន កិច្ចដែលទ្រង់លំបាករមែងមិនមាន ព្រះសាស្តាត្រាស់ថា ម្នាលឃរណី នាងនឹងធ្វើដូចម្តេច ឃរណីពោលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងធ្វើផែនដីធំឲ្យជាល្វែងនៃចក្រវាលមួយ ហើយធ្វើឲ្យទៅជាទឹក ហើយមុជចុះដូចជាឈាមរា បង្ហាញខ្លួនត្រង់កណ្តាប់ចក្រវាលទិសខាងកើត មុជពីកណ្តាប់ចក្រវាលទិសខាងកើតផុសត្រង់ទិសខាងលិច ទិសខាងជើង ទិសខាងត្បូង ត្រង់កណ្តាលក៏ដូចគ្នា កាលបើដូច្នោះ មហាជនឃើញខ្ញុំម្ចាស់ហើយ កាលបុគ្គលណាម្នាក់ពោលឡើងថា នុ៎ះជាអ្នកណា ក៏ប្រាប់ថា នុ៎ះជានាងឃរណី អានុភាពរបស់ស្រីម្នាក់គង់អស្ចារ្យដល់ម៉្លេះ ចំណែកអានុភាពរបស់ព្រះពុទ្ធនឹងដូចម្តេចហ្ន៎ ពួកតិរ្ថិយមិនទាន់ឃើញព្រះអង្គ ក៏នឹងគេចទៅដោយអាការយ៉ាងនេះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា ម្នាលឃរណី តថាគតដឹងថានាងអាចធ្វើបាដិហារ្យបែបនេះបាន តែកម្រងផ្កានេះ គេមិនបានចងដើម្បីប្រយោជន៍ដល់នាង ហើយទ្រង់ហាម ។

នាងឃរណីនោះគិតថា ព្រះសាស្តាទ្រង់មិនអនុញ្ញាតដល់អញ អ្នកដទៃអាចធ្វើបាដិហារ្យក្រៃលែងជាងអញនឹងមានពិត ដូច្នេះហើយ ទើបឈរក្នុង

ចំណែកម្ខាង ។

ចំណែកព្រះសាស្តា ទ្រង់ព្រះតម្រិះថា គុណរបស់សាវកទាំងនោះ នឹងប្រាកដដោយអាការយ៉ាងនេះឯង ទ្រង់សម្គាល់ថា ពួកសាវកនឹងបន្លឺសីហនាទក្នុងកណ្តាលបរិស័ទមានប្រមាណ ៣៦ យោជន៍ដោយអាការយ៉ាងនេះ ទើបត្រាស់សួរសាវកដទៃថា ពួកអ្នកនឹងធ្វើបាដិហារ្យដូចម្តេច សាវកទាំងនោះក្រាបទូលថា ពួកខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនេះៗ ហើយឈរក្នុងទីចំពោះព្រះភក្ត្រនៃព្រះសាស្តានោះឯង បន្លឺសីហនាទ ។

បណ្តាសាវកទាំងនោះ បានឮថា ចូឡអនាថបិណ្ឌិកគិតថា បើអនាគាមី-ឧបាសក ដែលជាបុត្រដូចអាត្មាអញមាន កិច្ចដែលព្រះសាស្តាត្រូវលំបាកមិនមាន ទើបក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ត្រូវព្រះសាស្តាត្រាស់សួរថា អ្នកនឹងធ្វើដូចម្តេច ទើបក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងនិម្មិតអត្តភាពដូចព្រហ្ម មានប្រមាណ ១២ យោជន៍ នឹងគ្រហឹមដូចព្រហ្មដោយសំឡេង ដូចគ្នានឹងផ្គរលាន់ក្នុងកណ្តាលបរិស័ទនេះ មហាជននឹងសួរថា នេះជាសំឡេងអ្វីហ្ន៎ ហើយនឹងពោលថា បានឮថា នេះជាសំឡេងគ្រហឹមដូចព្រហ្មរបស់ចូឡអនាថបិណ្ឌិក ពួកតិរ្ថិយនឹងគិតថា អានុភាពរបស់គហបតីគង់ដល់ម៉្លេះ ចុះអានុភាពរបស់ព្រះពុទ្ធយ៉ាងណាហ្ន៎ ទាំងមិនទាន់បានឃើញព្រះអង្គ ក៏នឹងគេចទៅ ។ ព្រះសាស្តា ក៏ត្រាស់ដូចមុនដូចគ្នាដល់ចូឡ-អនាថបិណ្ឌិកនោះថា តថាគតដឹងអានុភាពរបស់អ្នកហើយ ទ្រង់មិនអនុញ្ញាតការធ្វើបាដិហារ្យ ។

បន្ទាប់មក សាមណេរីឈ្មោះវីរាអាយុ ៧ ឆ្នាំ សម្រេចបដិសម្ភិទា ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងធ្វើបាដិហារ្យ ព្រះសាស្តាត្រាស់ថា ម្នាលវីរា នាងនឹងធ្វើដូចម្តេច វីរាសាមណេរីពោលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងនាំភ្នំសិនេរុ ភ្នំកណ្តាប់ចក្រវាល និងភ្នំហិមពាន្ត តម្រៀបគ្នាក្នុងទីនេះ ហើយចេញអំពីភ្នំនោះទៅមិនឲ្យទើសទាក់ ដូចហង្សញីមហាជនឃើញខ្ញុំម្ចាស់នឹងសួរថា នុ៎ះជាអ្នកណា នឹងពោលថា វីរាសាមណេរីពួកតិរ្ថិយគិតគ្នាថា សាមណេរីអាយុ ៧ ឆ្នាំ គង់មានអានុភាពដល់ម៉្លេះ អានុភាពរបស់ព្រះពុទ្ធយ៉ាងណាហ្ន៎ ទាំងមិនទាន់បានឃើញព្រះអង្គ ក៏នឹងគេចទៅ ។ ខាងមុខអំពីនេះទៅ គប្បីជ្រាបពាក្យបែបនេះ ដោយទំនងដូចពោលហើយនោះឯង ។ ព្រះដ៏មានព្រះភាគ ត្រាស់ដល់សាមណេរីនោះថា តថាគតដឹងអានុភាពរបស់នាង ដូច្នេះហើយ ទ្រង់ក៏មិនអនុញ្ញាតក្នុងការធ្វើបាដិហារ្យ ។

លំដាប់នោះ សាមណេរឈ្មោះចុន្ទ ជាព្រះខីណាស្រព សម្រេចបដិ-សម្ភិទាមួយរូបអាយុ ៧ ឆ្នាំអំពីកំណើត ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយក្រាបទូលថា ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ព្រះសាស្តាត្រាស់សួរថា អ្នកធ្វើដូចម្តេច ទើបក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងចាប់ដើមព្រីងធំដែលជាទង់នៃជម្ពូទ្វីប ត្រង់ដើមហើយអង្រួន នាំយកផ្លែព្រីងធំមកឲ្យបរិស័ទទាំងនេះទំពាស៊ី ខ្ញុំព្រះអង្គនឹងនាំផ្កាប្រចៀងមកហើយ ថ្វាយបង្គំព្រះអង្គ ព្រះសាស្តាត្រាស់ថា តថាគតដឹងអានុភាពរបស់អ្នក ដូច្នេះហើយ ក៏ទ្រង់ហាមបាដិហារ្យរបស់សាមណេរនោះ ។

លំដាប់នោះ ព្រះថេរីឈ្មោះឧប្បលវណ្ណា ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងធ្វើបាដិហារ្យ ត្រូវព្រះសាស្តាត្រាស់សួរថា នាងនឹងធ្វើដូចម្តេច ទើបក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងបង្ហាញបរិស័ទប្រមាណ ៣២ យោជន៍ដោយជុំវិញ ជាស្តេចចក្រពត្តិដែលមានបរិស័ទប្រមាណ ៣៦ យោជន៍ដោយមណ្ឌលជុំវិញ ហើយមកថ្វាយបង្គំព្រះអង្គ ព្រះសាស្តាត្រាស់ថា តថាគតជ្រាបអានុភាពរបស់នាងហើយ ទ្រង់ហាមបាដិហារ្យ របស់ព្រះថេរីនោះ ។

លំដាប់នោះ ព្រះមហាមោគ្គល្លានត្ថេរ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ព្រះសាស្តាត្រាស់សួរថា អ្នកនឹងធ្វើអ្វី ទើបក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងដាក់ស្តេចភ្នំសិនេរុលើធ្មេញ ហើយទំពាភ្នំនោះដូចគ្រាប់ស្ពៃ ព្រះសាស្តាត្រាស់ថា អ្នកនឹងធ្វើអ្វីទៀត ព្រះមហាមោគ្គល្លានពោលថា ខ្ញុំព្រះអង្គនឹងមូរផែនដីធំនេះ ដូចកន្ទេលផែង ហើយញាត់ក្នុងចន្លោះម្រាមដៃ ព្រះសាស្តាត្រាស់ថា អ្នកនឹងធ្វើអ្វីទៀត ព្រះមហាមោគ្គល្លានពោលថា ខ្ញុំព្រះអង្គនឹងបង្វិលផែនដីធំ ឲ្យដូចជាក្តារយន្តបង្វិលភាជន៍ដីរបស់ជាងឆ្នាំង ហើយឲ្យមហាជនទំពាស៊ីឱជៈនៃផែនដី ព្រះសាស្តាត្រាស់ថា អ្នកនឹងធ្វើអ្វីទៀត ព្រះមហាមោគ្គល្លានពោលថា ខ្ញុំព្រះអង្គនឹងធ្វើផែនដីទុកក្នុងដៃខាងឆ្វេង ហើយដាក់សត្វទាំងនេះ ក្នុងទ្វីបដទៃដោយដៃខាងស្តាំ ព្រះសាស្តាត្រាស់ថា អ្នកនឹងធ្វើអ្វីទៀត ព្រះមហាមោគ្គល្លានពោលថា ខ្ញុំព្រះអង្គនឹងធ្វើភ្នំសិនេរុជាដងឆត្រ យកផែនដីធំដាក់លើភ្នំសិនេរុនោះ យកដៃ

ម្នាងកាន់ ដូចកិក្ខុមានចត្រក្នុងដែបង្ក្រមក្នុងអាកាស ព្រះសាស្តាត្រាស់ថា តថាគត ដឹងអានុភាពរបស់អ្នក ដូច្នេះហើយ ទ្រង់មិនអនុញ្ញាតការធ្វើបាដិហារ្យ របស់ព្រះថេរៈនោះ ។ ព្រះថេរៈគិតថា ប្រហែលព្រះសាស្តាទ្រង់ជ្រាបអ្នក អាចធ្វើបាដិហារ្យក្រៃលែងជាងអាត្មាអញ ទើបឈរក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះថេរៈថា ម្នាលមោគ្គល្លាន ផ្កានេះ មិនមែនចងដើម្បីប្រយោជន៍ដល់អ្នកទេ ព្រោះថា តថាគតមានធុរៈ មិនមាន ប្រមាណ បុគ្គលដទៃដែលឈ្មោះថាអាចនាំធុរៈរបស់តថាគតទៅបានមិនមាន ការដែលបុគ្គលអាចនាំធុរៈ របស់តថាគតទៅបានមិនគប្បីមាន ក្នុងកាលឥឡូវ នេះ មិនជារបស់អស្ចារ្យ សូម្បីក្នុងកាលដែលតថាគតកើតក្នុងកំណើតសត្វ តិរច្ឆាន ដែលជាអហេតុកកំណើត បុគ្គលដទៃដែលអាចនាំធុរៈរបស់តថាគត ទៅ ក៏មិនមានដូចគ្នា ព្រះថេរៈទូលសួរថា បពិត្រព្រះអង្គ តើក្នុងកាលណា ទើបទ្រង់នាំអតីតនិទាន មកត្រាស់កណ្ហឧសភជាតក[១] នេះ ឲ្យពិស្តារថា

ធុរៈធ្ងន់ ក្នុងទីណាៗ ផ្លូវដ៏ជ្រៅក្នុងទីណា កាលនោះឯង ពួក ជននាំគ្នាទឹមគោឈ្មោះកណ្ហៈ គោឈ្មោះកណ្ហៈនោះ ក៏អូសទូវ ធុរៈដ៏ធ្ងន់នោះទៅបាន ។

កាលទ្រង់សក្រៃលែងឡើង ទើបត្រាស់នន្ទិវិសាលជាតកនេះឲ្យពិស្តារថា បុគ្គលគប្បីនិយាយពាក្យជាទីគាប់ចិត្តតែម្យ៉ាង មិនគប្បីនិយាយ ពាក្យមិនជាទីគាប់ចិត្តក្នុងកាលណាឡើយ កាលព្រាហ្មណ៍និយាយ

---

១- បិដកខ្មែរ ជាកណ្ហជាតក ។

ពាក្យជាទីគាប់ចិត្ត ( គោនទ្វិវិសាល ) បានទាញភារៈដ៏ធ្ងន់ រួច ញ៉ាំងព្រាហ្មណ៍នោះឲ្យបានទ្រព្យផង ជាសត្វមានចិត្តរីករាយ ដោយការញ៉ាំងព្រាហ្មណ៍នោះ ឲ្យបានទ្រព្យនោះផង ។

គ្រានោះឯង ព្រះសាស្តាកាលត្រាស់ហើយ ទ្រង់ឡើងកាន់ទីចង្ក្រម កែវខាងមុខ មានបរិស័ទប្រមាណ ១២ យោជន៍ ខាងក្រោយ ខាងឆ្វេង និងខាងស្តាំក៏ដូចគ្នា ចំណែកដោយត្រង់ មានប្រមាណ ២៤ យោជន៍ ។ ព្រះដ៏មានព្រះភាគ ទ្រង់បានធ្វើយមកប្បាដិហារ្យក្នុងកណ្តាលបរិស័ទ យមកប្បា-ដិហារ្យនោះ បណ្ឌិតគប្បីជ្រាបតាមបាលីយ៉ាងនេះ ។

យមកប្បាដិហិរញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារ្យ ដែលមិនទូទៅដល់ពួកសាវ័ក ក្នុងលោកនេះ គឺគំនរភ្លើងចេញអំពីព្រះកាយខាងលើ ផ្ទារទឹកចេញអំពីព្រះកាយខាងក្រោម គំនរភ្លើងចេញអំពីព្រះកាយខាងក្រោម ផ្ទារទឹកចេញអំពីព្រះកាយខាងលើ គំនរភ្លើងចេញអំពីព្រះកាយខាងមុខ ផ្ទារទឹកចេញអំពីព្រះកាយខាងក្រោយ គំនរភ្លើងចេញអំពីព្រះកាយខាងក្រោយ ផ្ទារទឹកចេញអំពីព្រះកាយខាងមុខ គំនរភ្លើងចេញអំពីព្រះនេត្រខាងស្តាំ ផ្ទារទឹកចេញអំពីព្រះនេត្រខាងឆ្វេង គំនរភ្លើងចេញអំពីព្រះនេត្រខាងឆ្វេង ផ្ទារទឹកចេញអំពីព្រះនេត្រខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ផ្ទារទឹកចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌

ខាងឆ្វេង ផ្កាទឹកចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងស្តាំ ផ្កាទឹកចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង ផ្កាទឹកចេញអំពីរន្ធព្រះនាសិកាខាងស្តាំ គំនរភ្លើងចេញអំពីចន្ទយព្រះអង្សាខាងស្តាំ ផ្កាទឹកចេញអំពីចន្ទយព្រះអង្សាខាងឆ្វេង គំនរភ្លើងចេញអំពីចន្ទយព្រះអង្សាខាងឆ្វេង ផ្កាទឹកចេញអំពីចន្ទយព្រះអង្សាខាងស្តាំ គំនរភ្លើងចេញអំពីព្រះហស្តខាងស្តាំ ផ្កាទឹកចេញអំពីព្រះហស្តខាងឆ្វេង គំនរភ្លើងចេញអំពីព្រះហស្តខាងឆ្វេង ផ្កាទឹកចេញអំពីព្រះហស្តខាងស្តាំ គំនរភ្លើងចេញអំពីខាងខាងស្តាំ ផ្កាទឹកចេញអំពីខាងខាងឆ្វេង គំនរភ្លើងចេញអំពីខាងខាងឆ្វេង ផ្កាទឹកចេញអំពីខាងខាងស្តាំ គំនរភ្លើងចេញអំពីព្រះបាទខាងស្តាំ ផ្កាទឹកចេញអំពីព្រះបាទខាងឆ្វេង គំនរភ្លើងចេញអំពីព្រះបាទខាងឆ្វេង ផ្កាទឹកចេញអំពីព្រះបាទខាងស្តាំ គំនរភ្លើងចេញអំពីព្រះអង្គុលីមួយៗ ផ្កាទឹកចេញអំពីចន្លោះនៃព្រះអង្គុលី គំនរភ្លើងចេញ អំពីចន្លោះនៃព្រះអង្គុលី ផ្កាទឹកចេញអំពីព្រះអង្គុលីមួយៗ គំនរភ្លើងចេញអំពីព្រះលោមាមួយៗ ផ្កាទឹកចេញអំពីព្រះលោមាមួយៗ គំនរភ្លើងចេញអំពីរណ្តៅព្រះលោមាមួយៗ ផ្កាទឹកចេញអំពីរណ្តៅព្រះលោមា ( ព្រះមានព្រះភាគទ្រង់បញ្ចេញ ) នូវព្រះឆព្វណ្ណរង្សីខៀវ លឿង ក្រហម ស ហង្សបាទ ផ្លេកៗ ព្រះមាន

ព្រះភាគទ្រង់ចង្ក្រម ព្រះពុទ្ធនិម្មិត ទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ឈរ ព្រះពុទ្ធនិម្មិតទ្រង់ចង្ក្រម ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់គង់ ព្រះពុទ្ធនិម្មិតទ្រង់ចង្ក្រម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ចង្ក្រម ឬទ្រង់ឈរ ឬទ្រង់គង់ ព្រះមានព្រះភាគទ្រង់ចង្ក្រម ឬទ្រង់គង់ ឬផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ឈរ ព្រះមានព្រះភាគទ្រង់ចង្ក្រម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់គង់ ព្រះមានព្រះភាគទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ចង្ក្រម ព្រះពុទ្ធនិម្មិតទ្រង់ផ្ទំ នេះ ឈ្មោះថា យមកប្បាដិហិរញ្ញាណរបស់ព្រះតថាគត ។

ព្រះសាស្តាទ្រង់ចង្ក្រមលើទីចង្ក្រមនោះហើយ ។ ដើម្បីទ្រង់សម្តែងសេចក្តីនោះ ផ្ការភ្លើងរមែងផ្សាយចេញអំពីព្រះកាយខាងលើ ដោយអំណាចតេជោកសិណសមាបត្តិរបស់ព្រះសាស្តានោះ ផ្កាទឹកហូរចេញអំពីព្រះកាយខាងក្រោម ដោយអំណាចអាបោកសិណសមាបត្តិ ផ្ការភ្លើងហូរចេញអំពីទីដែលផ្កាទឹកហូរចេញហើយទៀត ផ្កាទឹកក៏ហូរចេញអំពីទីដែលផ្ការភ្លើងហូរចេញទៀត ទើបព្រះសារីបុត្តពោលថា **ហេដ្ឋិមកាយតោ ឧបរិមកាយតោ ។** ក្នុងបទទាំងពួងក៏ដូច្នេះ ។ ក្នុងយមកប្បាដិហារ្យនេះ ផ្ការភ្លើងមិនលាយជាមួយផ្កាទឹក ម្យ៉ាងទៀត ផ្កាទឹកក៏មិនបានលាយដោយផ្ការភ្លើង បានឮថា ផ្ការភ្លើង និងផ្កាទឹកទាំងពីរនេះ ផ្សាយឡើងដល់ព្រហ្មលោក ហើយក៏រាលទៅកាន់កណ្តាប់ចក្រវាល ។ ព្រោះព្រះសារីបុត្តត្ថេរពោលថា **ឆន្នំ វណ្ណានំ** ព្រះ

រស្មីមានពណ៌ ៦ ប្រការរបស់ព្រះសាស្តានោះ ផ្សាយឡើងអំពីល្វែងនៃចក្រវាលមួយ ដូចមាសដែលគេរំលាយ ហូរចេញអំពីស្នប់ និងដូចផ្ការទឹកមាសដែលហូរចេញអំពីនាឡិយន្ត្រ រហូតដល់ព្រហ្មលោក ហើយវិលត្រឡប់មកកាន់កណ្តាប់ចក្រវាលវិញ ។ ល្វែងនៃចក្រវាលមួយ ដូចជាខឿនពោធិព្រឹក្សដែលដោតដោយកន្ទះដែលវៀច មានពន្លឺតែមួយ ។

ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់យាងចង្រ្កមធ្វើបាដិហារ្យ សម្តែងធម្មកថាដល់មហាជនក្នុងចន្លោះៗ កាលទ្រង់សម្តែង ទ្រង់មិនធ្វើឲ្យមហាជនធុញចិត្តប្រទានឲ្យស្រោលចិត្ត ។ ក្នុងខណៈនោះ មហាជនញ៉ាំងសាធុការឲ្យប្រព្រឹត្តទៅហើយ ក្នុងកាលដែលសាធុការរបស់មហាជននោះប្រព្រឹត្តទៅ ព្រះសាស្តាទ្រង់ប្រមើលមើលចិត្តរបស់បរិស័ទ ដែលធំមានប្រមាណប៉ុណ្ណោះ ទ្រង់បានជ្រាបវារចិត្តរបស់បរិស័ទនីមួយៗ ដោយអំណាចអាការ ១៦ យ៉ាង ។ ចិត្តរបស់ព្រះពុទ្ធទាំងឡាយ ប្រព្រឹត្តទៅរហ័សយ៉ាងនេះ បុគ្គលណាម្នាក់ជ្រះថ្លាក្នុងធម៌ណា និងក្នុងបាដិហារ្យណា ព្រះសាស្តាទ្រង់សម្តែងធម៌ និងធ្វើបាដិហារ្យដោយអំណាចអធ្យាស្រ័យនៃបុគ្គលនោះៗ ។ កាលទ្រង់សម្តែងធម៌ ទ្រង់ធ្វើបាដិហារ្យដោយអាការយ៉ាងនេះ ធម្មាភិសម័យមានដល់មហាជនហើយ ។ ព្រះសាស្តាទ្រង់កំណត់ចិត្តរបស់ទ្រង់ ទ្រង់មិនឃើញបុគ្គលដទៃដែលអាចសួរបញ្ហាក្នុងសមាគមនោះ ទើបទ្រង់និម្មិតពុទ្ធនិម្មិត ។ ព្រះសាស្តាទ្រង់ឆ្លើយបញ្ហា ដែលពុទ្ធនិម្មិតនោះសួរហើយ ។ ពុទ្ធនិម្មិតនោះ ក៏ឆ្លើយបញ្ហាដែលព្រះសាស្តាត្រាស់សួរហើយ ។ ក្នុងកាលដែលព្រះដ៏មានព្រះភាគទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិត

សម្រេចឥរិយាបថ មានការឈរជាដើមណាមួយ ក្នុងកាលដែលពុទ្ធនិម្មិតចង្រ្កម ព្រះសាស្តាទ្រង់សម្រេចឥរិយាបថ មានការប្រថាប់ឈរជាដើមណាមួយ ដើម្បីសម្តែងសេចក្តីនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលពាក្យជាដើមថា ពុទ្ធនិម្មិតចង្រ្កមខ្វះជាដើម ។

ធម្មាភិសម័យមានដល់សត្វ ២០ កោដិ ក្នុងសមាគមនោះ ព្រោះឃើញបាដិហារ្យរបស់ព្រះសាស្តាដែលទ្រង់ធ្វើយ៉ាងនោះ និងព្រោះបានស្តាប់ធម្មកថា ។

ព្រះសាស្តា កំពុងធ្វើបាដិហារ្យនោះឯង ទ្រង់អាវជ្ជនៈថា ព្រះពុទ្ធក្នុងអតីតទាំងឡាយ ធ្វើបាដិហារ្យនេះហើយចាំវស្សាក្នុងទីណាហ្ន៎ ទ្រង់ឃើញថា ចាំវស្សាក្នុងតាវត្តិង្សព្ភិភព ហើយទ្រង់សម្តែងអភិធម្មបិដកដល់ព្រះពុទ្ធមាតាដូច្នេះហើយ ទ្រង់លើកព្រះបាទស្តាំជាន់លើកំពូលភ្នំយុគន្ធរ ទ្រង់លើកព្រះបាទម្ខាងទៀត ជាន់លើភ្នំសិនេរុ វារៈដែលឈានជំហាន ៣ មានហើយក្នុងទី ៦៨ សែនយោជន៍យ៉ាងនេះ ។ ចន្លោះជំហាន ២ ជំហាន បានឈានចេញដូចគ្នា និងការយាងតាមប្រក្រតី ។ បុគ្គលមិនគប្បីកំណត់ថា ព្រះសាស្តាទ្រង់ឈានព្រះបាទហើយ ព្រោះក្នុងកាលដែលទ្រង់លើកព្រះបាទនោះឯង កំពូលភ្នំនោះមកជិតព្រះបាទទទួលហើយ ក្នុងកាលដែលព្រះសាស្តាទ្រង់ជាន់ហើយ កំពូលភ្នំនោះ ក៏ប្រតិស្ឋានក្នុងកន្លែងដើម ។ សក្កទេវរាជ ទតឃើញព្រះសាស្តាហើយ ទ្រង់ព្រះតម្រិះថា ព្រះសាស្តាទ្រង់នឹងចាំវស្សាត្រង់បណ្ឌុកម្ពលសិលាឧបការៈនឹងមានដល់ពួកទេវតាច្រើនហ្ន៎ តែកាលព្រះសាស្តាចាំវស្សាក្នុងទីនោះ ទេវតាដទៃៗ មិនអាចបញ្ឈប់ដៃបាន ឯបណ្ឌុកម្ពលសិលានេះបណ្តោយ ៦០

យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍ កាលព្រះសាស្តា ប្រថាប់គង់ហើយ ក៏គង់ក្លាយជាទទេ ។ ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យ របស់សក្កទេវរាជ ទ្រង់បោះសង្ឃាដីរបស់ព្រះអង្គឲ្យគ្របថ្មហើយ សក្កៈទ្រង់ព្រះតម្រិះថា ព្រះសាស្តាទ្រង់បោះចីវរមកឲ្យគ្របថ្ម ទ្រង់នឹងប្រថាប់គង់ក្នុងទីបន្តិចបន្តួចដោយព្រះអង្គឯង ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យរបស់សក្ក-ទេវរាជ ទើបប្រថាប់គង់ធ្វើបណ្ឌុកម្ពលសិលាខាងក្នុងផ្នត់ចីវរនោះឯង ហាក់ដូចកិក្ខុដែលទទ្រង់សំពត់មហាបំសុកូល ធ្វើតាំងទាបទុកខាងក្នុងផ្នត់ចីវរ ដូច្នោះ ។ ខណៈនោះឯង មហាជនរកមើលព្រះសាស្តាក៏មិនឃើញ កាលនោះ ហាក់ដូចជាព្រះចន្ទលិច និងដូចពេលព្រះអាទិត្យលិច មហាជនកន្ទក់កន្ទេញពោលគាថានេះថា

ព្រះសាស្តាយាងទៅកាន់ភ្នំចិត្តកូដ ឬភ្នំកៃលាស ឬភ្នំយុគន្ធរ បាន ជាពួកយើងមិនឃើញនូវព្រះសម្មាសម្ពុទ្ធ ជាលោកជេដ្ឋ ប្រសើរជាងនរៈ ។

មួយពួកទៀតយំរៀបរាប់ថា ព្រះសាស្តា ទ្រង់ត្រេកអរហើយក្នុងវិវេក ទ្រង់នឹងទៅកាន់ដែនដទៃ ឬជនបទដទៃហើយ ព្រោះទ្រង់ខ្មាសថា តថាគតធ្វើបាដិហារ្យបែបនេះដល់បរិស័ទបែបនេះ ឥឡូវនេះ យើងទាំងឡាយមិនបានឃើញទ្រង់ ដូច្នេះហើយ ពោលគាថានេះថា

ព្រះសាស្តា ជាអ្នកប្រាជ្ញ ទ្រង់ត្រេកអរហើយក្នុងវិវេក ទ្រង់មិន ត្រឡប់មកទៀត យើងទាំងឡាយ មិនឃើញព្រះសម្មាសម្ពុទ្ធជា

លោកជេដ្ឋ ជាបុគ្គលប្រសើរជាងនរៈ ដូច្នេះ ។

ជនទាំងនោះសួរព្រះមហាមោគ្គល្លានថា បពិត្រលោកម្ចាស់ ព្រះសាស្តាយាងទៅទីណា លោកជ្រាបក៏ពោលថា ចូរសួរអនុរុទ្ធចុះ ដោយបំណងថា គុណរបស់សាវកដទៃៗ ចូរប្រាកដដូច្នេះ ។ ជនទាំងនោះសួរព្រះថេរៈយ៉ាងនោះថា បពិត្រលោកម្ចាស់ ព្រះសាស្តាយាងទៅទីណា ព្រះអនុរុទ្ធតបថា ទ្រង់យាងទៅចាំវស្សាត្រង់បណ្ឌុកម្ពលសិលាក្នុងស្ថានតាវត្តិង្ស ហើយទ្រង់សម្តែងអភិធម្មបិដកដល់ព្រះពុទ្ធមាតា មហាជនពោលថា បពិត្រលោកម្ចាស់ ទ្រង់នឹងយាងមកក្នុងកាលណា ព្រះអនុរុទ្ធពោលថា ទ្រង់សម្តែងអភិធម្មបិដកអស់កាល ៣ ខែហើយ ទ្រង់នឹងយាងមកក្នុងថ្ងៃមហាបវារណា ។

ជនទាំងនោះនិយាយគ្នាថា ពួកយើងមិនបានឃើញព្រះសាស្តា នឹងមិនទៅ ដូច្នេះហើយ បោះជម្រកស្នាក់នៅក្នុងទីនោះឯង បានឮថា ជនទាំងនោះមានអាកាសនោះឯងជាគ្រឿងប្រក់ ឈ្មោះថាញើសដែលហូរចេញអំពីខ្លួនរបស់បរិស័ទច្រើនដល់ម៉្លោះមិនបានប្រាកដឡើយ ។ ផែនដីបានបើកឱកាសឲ្យហើយ ផែនដីក្នុងទីគ្រប់កន្លែង ជាទីរាបស្មើស្អាតនោះឯង ។ ព្រះសាស្តា បានត្រាស់ប្រាប់ព្រះមហាមោគ្គល្លានមុនហើយថា ម្នាលមោគ្គល្លាន អ្នកគប្បីសម្តែងធម៌ដល់បរិស័ទនោះ ចូឡអនាថបិណ្ឌិកនឹងឲ្យអាហារ ព្រោះហេតុនោះ ចូឡ-អនាថបិណ្ឌិក បានឲ្យហើយនូវបបរ បាយ របស់ទំពា របស់ក្រអូប ផ្កាកម្រង និងគ្រឿងប្រដាប់ដល់បរិស័ទនោះ គ្រប់កាលទាំងព្រឹក និងល្ងាចរហូត ៣ ខែនោះ ។ ព្រះមហាមោគ្គល្លានសម្តែងធម៌ហើយ វិសជ្ជនាបញ្ហាដល់ពួក

ជនដែលមកហើយ ដើម្បីមើលបាដិហារ្យស្រួរហើយ ។

ទេវតាក្នុងម៉ឺនចក្រវាល ចោមរោមព្រះសាស្តាដែលទ្រង់ចាំវស្សា ត្រង់បណ្ឌុកម្ពលសិលា ដើម្បីទ្រង់សម្តែងអភិធម្មដល់ព្រះមាតា ព្រោះហេតុនោះទើបព្រះធម្មសង្គាហកាចារ្យពោលថា

ក្នុងកាលណាព្រះពុទ្ធ ជាកំពូលបុរសប្រថាប់នៅលើបណ្ឌុកម្ពល-សិលា ត្រង់គល់បារិច្ឆត្តកៈក្នុងស្ថានតាវត្តិង្ស ក្នុងកាលនោះទេវតាទាំងឡាយក្នុងម៉ឺនលោកធាតុ ប្រជុំព្រមគ្នាហើយ ចូលគាល់ព្រះសាស្តា ដែលប្រថាប់នៅលើកំពូលភ្នំ ទេវតាអង្គណាមួយ ក៏មិនរុងរឿងជាងព្រះសម្មាសម្ពុទ្ធ ដោយពណ៌សម្បុរឡើយ ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ រមែងរុងរឿងកន្លងនូវពួកទេវតាទាំងអស់ ។

កាលព្រះសាស្តា ប្រថាប់គង់គ្របសង្កត់ទេវតាគ្រប់ពួក ដោយរស្មីព្រះសរីរៈរបស់ទ្រង់យ៉ាងនេះ ពុទ្ធមាតាយាងមកអំពីវិមានជាន់តុសិត ប្រថាប់គង់ខាងស្តាំ ឥន្ទកទេវបុត្រក៏មកអង្គុយខាងស្តាំដូចគ្នា អង្កុរទេវបុត្រអង្គុយខាងឆ្វេង អង្កុរទេវបុត្រនោះ កាលទេវតាទាំងឡាយដែលមានសក្តិធំប្រជុំគ្នា ខ្ចាតចេញទៅហើយ បានឱកាសក្នុងប្រមាណ ១២ យោជន៍ ។ ឥន្ទកទេវបុត្រ អង្គុយក្នុងទីនោះឯង ព្រះសាស្តាទ្រង់ទតទេវបុត្រទាំងពីរនោះហើយ មានព្រះបំណងនឹងញុំាងបរិស័ទឲ្យជ្រាបភាពដែលទាន បុគ្គលឲ្យហើយដល់ទក្ខិណេយ្យបុគ្គលក្នុងសាសនារបស់ព្រះអង្គ មានអានិសង្សច្រើន ទើបត្រាស់យ៉ាងនេះថា អង្កុរៈ អ្នកធ្វើចង្ក្រានបណ្តោយ ១២ យោជន៍ ឲ្យទានសន្ទឹកសន្ធាប់ អស់

កាលមួយម៉ឺនឆ្នាំនេះ ជារយៈកាលយូរ ឥឡូវនេះ អ្នកមកក្នុងសមាគមរបស់តថាគត បាននិកាសក្នុងទីចម្ងាយ ១២ យោជន៍ ឆ្ងាយជាងទេវបុត្រទាំងអស់ អ្វីហ្ន៎ជាហេតុ ក្នុងសេចក្ដីនេះ ពិតហើយ ព្រះធម្មសង្គាហកាចារ្យទាំងឡាយបានពោលដូច្នេះថា

ព្រះសម្មាសម្ពុទ្ធទតអង្កុរទេវបុត្រ និងឥន្ទកទេវបុត្រហើយ កាលទ្រង់សរសើរទក្ខិណេយ្យបុគ្គល បានត្រាស់ពុទ្ធវចនៈនេះថា ម្នាលអង្កុរៈ អ្នកឲ្យទានសន្ទឹកសន្ធាប់ អស់កាលដ៏យូរ កាលអ្នកមកកាន់សម្នាក់តថាគត អង្គុយឆ្ងាយសន្ទឹម ។ ព្រះសូរសៀងនោះ ឮដល់ផែនដី បរិស័ទទាំងអស់បានឮសូរសៀងនោះ ។

ព្រះសាស្ដា កាលត្រាស់យ៉ាងនោះហើយ អង្កុរទេវបុត្រដែលព្រះដ៏មានព្រះភាគទ្រង់មានខ្ជួនអប់រំហើយ ដាស់តឿនហើយ បានក្រាបទូលពាក្យនេះថា

ប្រយោជន៍អ្វីដោយទាននោះរបស់ខ្ញុំព្រះអង្គ ព្រោះ ( ទាននោះ ) សូន្យចាកទក្ខិណេយ្យបុគ្គល ឥន្ទកយក្សនេះឯង ឲ្យទានតិចតួចទេ រុងរឿងជាងពួកខ្ញុំព្រះអង្គ ដូចជាព្រះចន្ទក្នុងពួកផ្កាយ ។

បណ្ដាបទទាំងនោះ បទថា **ឧជ្ឈា** កែជា **ឧត្វា** ប្រែថា ឲ្យហើយ កាលអង្កុរទេវបុត្រក្រាបទូលយ៉ាងនោះហើយ ព្រះសាស្ដាត្រាស់នឹងឥន្ទកទេវបុត្រថា ម្នាលឥន្ទកៈ អ្នកអង្គុយខាងស្ដាំតថាគត ហេតុអ្វីមិនខ្វាតចេញទៅឆ្ងាយ ឥន្ទកទេវបុត្រក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបានទក្ខិណេយ្យសម្បត្តិហើយ ដូចអ្នកស្រែព្រោះពូជបន្តិចបន្តួចក្នុងស្រែល្អ ដូច្នេះហើយ កាលប្រកាស

ទក្ខិណេយ្យបុគ្គល ទើបក្រាបទូលថា

ពូជដែលបុគ្គលព្រោះហើយ សូម្បីតិច ក្នុងស្រែដ៏ល្អ កាលភ្លៀងធ្លាក់ស្រួល ផលរមែងញុំាងអ្នកស្រែឲ្យត្រេកអរបាន ដូចម្ដេចមិញ សក្ការៈដែលបុគ្គលធ្វើហើយ សូម្បីតិចតួច ក្នុងតាទិបុគ្គលទាំងឡាយ មានសីល មានគុណ បុណ្យរមែងមានផលច្រើនក៏ដូច្នោះឯង ។

សួរថា បុព្វកម្មរបស់ឥន្ទកទេវបុត្រនោះដូចម្ដេច ។ ឆ្លើយថា បានឮថា ឥន្ទកទេវបុត្រនោះ បានប្រគេនបាយមួយវែក ដែលគេនាំមកហើយដើម្បីខ្លួន ដល់ព្រះអនុរុទ្ធត្ថេរ ដែលចូលទៅបិណ្ឌបាតខាងក្នុងស្រុក បុណ្យរបស់ឥន្ទកៈនោះ មានផលច្រើនជាងទាន ដែលអង្កុរទេវបុត្រធ្វើហើយដោយជួរនៃចង្ក្រានប្រវែង ១២ យោជន៍ ឲ្យហើយរាប់ម៉ឺនឆ្នាំ ព្រោះហេតុនោះ ទើបឥន្ទកទេវបុត្រក្រាបទូលយ៉ាងនោះ កាលឥន្ទកទេវបុត្រក្រាបទូលយ៉ាងនោះហើយ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអង្កុរៈ ការជ្រើសរើសមុនហើយ ឲ្យទាន ទើបគួរទាននោះរមែងមានផលច្រើនដោយអាការយ៉ាងនេះ ដូចពូជដែលគេព្រោះល្អក្នុងស្រែល្អដូច្នោះ តែអ្នកមិនបានធ្វើយ៉ាងនោះឡើយ ហេតុនោះ ទើបទានរបស់អ្នកមិនមានផលច្រើន កាលទ្រង់ប្រកាសអត្ថនេះឲ្យជាក់ច្បាស់ ទើបត្រាស់ថា

ទានដែលបុគ្គលពិចារណាហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរ ហើយទក្ខិណេយ្យបុគ្គលណា ដែលមាននៅក្នុងជីវលោកនេះ ទាន

ដែលបុគ្គលឲ្យហើយដល់ទក្ខិណេយ្យបុគ្គលទាំងនោះ រមែងមាន
ផលច្រើន ដូចពូជដែលបុគ្គលព្រោះហើយក្នុងស្រែល្អ ។
កាលទ្រង់សម្តែងធម៌ឲ្យក្រៃលែងឡើង បានត្រាស់ព្រះគាថានេះថា
ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះមានរាគៈ
ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នក
មានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំង
ឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានទោសៈជាទោស
ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានទោសៈ
អស់ហើយ រមែងជាទានមានផលច្រើន ។
ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានមោហៈ
ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នក
មានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំង-
ឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានសេចក្តីប្រណែន
ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នក
មានសេចក្តីស្រណែនអស់ហើយ រមែងជាទានមានផលច្រើន ។

ក្នុងកាលចប់ទេសនា អង្កុរទេវបុត្រ និងឥន្ទកទេវបុត្រតាំងនៅហើយក្នុង
សោតាបត្តិផល ។

លំដាប់នោះ ព្រះសាស្តាប្រថាប់គង់កណ្តាលទេវបរិស័ទ ទ្រង់ប្រារព្ធព្រះ
មាតា ផ្តើមសម្តែងអភិធម្មបិដកថា **កុសលា ធម្មា អកុសលា ធម្មា អព្យា-**

**កុសលា ធម្មា** ដូច្នេះជាដើម ។ ទ្រង់សម្ដែងអភិធម្មបិដក ដោយន័យនេះរឿយៗ ទៅអស់ ៣ ខែ ។ កាលទ្រង់កំពុងសម្ដែង ក្នុងវេលាភិក្ខាចារ ទ្រង់និម្មិតពុទ្ធ-និម្មិតដោយទ្រង់អធិដ្ឋានថា ចូរពុទ្ធនិម្មិតនេះសម្ដែងធម៌ឈ្មោះនេះ ទម្រាំតថាគតមក ហើយទ្រង់យាងទៅកាន់ព្រៃហិមពាន្ត ទ្រង់ទំពាឈើស្ទន់ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋត្រង់អនោតត្តស្រះ នាំបិណ្ឌបាតមកអំពីឧត្តរកុរុទ្វីប បានប្រថាប់គង់ធ្វើភត្តកិច្ចក្នុងរោងធំហើយ ព្រះសារីបុត្តត្ថេរនិមន្តទៅធ្វើវត្តដល់ព្រះសាស្ដាក្នុងទីនោះ ។ ព្រះសាស្ដាទ្រង់ធ្វើភត្តកិច្ចហើយ ត្រាស់ដល់ព្រះថេរៈថា ម្នាលសារីបុត្ត ថ្ងៃនេះ តថាគតសម្ដែងធម៌ឈ្មោះនេះ មានប្រមាណប៉ុណ្ណោះ ចូរអ្នកប្រាប់ដល់ភិក្ខុ ៥០០ ដែលជានិស្សិតរបស់ខ្លួន ។ បានឮថា កុលបុត្រ ៥០០ ជ្រះថ្លាក្នុងយមកប្បាដិហារ្យ បួសហើយក្នុងសម្នាក់របស់ព្រះថេរៈ ។ ព្រះសាស្ដាត្រាស់ហើយយ៉ាងនោះ ទ្រង់សំដៅយកភិក្ខុទាំងនោះ ។ កាលត្រាស់ហើយ ទ្រង់យាងទៅកាន់ទេវលោក ទ្រង់សម្ដែងធម៌ឯងបន្តអំពីព្រះពុទ្ធនិម្មិត ។ ព្រះថេរៈក៏ទៅសម្ដែងធម៌ដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ កាលដែលព្រះសាស្ដាយាងទៅក្នុងទេវលោកនោះឯង បានជាអ្នកជំនាញក្នុងបករណ៍ ៧ ហើយ ។

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ភិក្ខុទាំងនោះជាសត្វប្រចៀវ សំយុងខ្លួនត្រង់ញកភ្នំមួយកន្លែង កាលព្រះថេរៈ ២ រូបចង្ក្រមហើយស្វាធ្យាយអភិធម្ម បានស្ដាប់កាន់យកនិមិត្តក្នុងសំឡេងហើយ ប្រចៀវទាំងនោះមិនដឹងថា នេះឈ្មោះថាខន្ធ នេះឈ្មោះថាធាតុ ដោយហេតុត្រឹមតែកាន់យក

និមិត្តក្នុងសំឡេងប៉ុណ្ណោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក បានសោយទិព្វសម្បត្តិអស់ ១ ពុទ្ធន្តរ ចុតិអំពីទេវលោកនោះហើយ កើតក្នុងផ្ទះនៃត្រកូលក្នុងក្រុងសាវត្ថី កើតសេចក្ដីជ្រះថ្លាក្នុងយមកប្បាដិហារ្យ បួសក្នុងសម្នាក់របស់ព្រះថេរៈហើយ បានជាអ្នកជំនាញក្នុងបករណ៍ ៧ មុនភិក្ខុទាំងពួង ។ ព្រះសាស្ដា ទ្រង់ក៏សម្ដែងអភិធម្មដោយទំនងនោះឯងអស់ ៣ ខែ ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យមានដល់ទេវតា ៨ ម៉ឺនកោដិ ព្រះនាងមហាមាយាក៏តាំងនៅក្នុងសោតាបត្តិផលហើយ ។

បរិស័ទមានបរិមណ្ឌល ៣៦ យោជន៍នោះឯងគិតថា បន្ទាប់អំពីនេះទៅក្នុងថ្ងៃទី ៧ ត្រូវជាថ្ងៃមហាបវារណា ចូលទៅរកព្រះមហាមោគ្គល្លានត្ថេរ ពោលថា បពិត្រលោកម្ចាស់ យើងគួរជ្រាបថ្ងៃយាងចុះរបស់ព្រះសាស្ដា ព្រោះយើងទាំងឡាយ បើមិនឃើញព្រះសាស្ដាក៏មិនទៅ ។ ព្រះមហាមោគ្គល្លាន ស្ដាប់ពាក្យនោះហើយទទួលថា សាធុ ហើយមុជចុះក្នុងផែនដីត្រង់នោះឯង អធិដ្ឋានថា ចូរបរិស័ទឃើញអាត្មាអញ ដែលទៅដល់ជើងភ្នំសិនេរុហើយផុសឡើងមានរូបប្រាកដដូចសំពត់កម្ពល ដែលដោតនៅក្នុងកែវមណី ឡើងទៅហើយត្រង់កណ្ដាលភ្នំសិនេរុ សូម្បីពួកមនុស្សក៏ឃើញលោកថា ឡើងទៅហើយមួយយោជន៍ ឡើងទៅហើយពីរយោជន៍ជាដើម ព្រះថេរៈឡើងទៅថ្វាយបង្គំព្រះយុគលបាទរបស់ព្រះសាស្ដា ដូចទូលដោយក្បាល ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គ បរិស័ទបំណងនឹងគាល់ទ្រង់សិនហើយទើបទៅ ទ្រង់យាងចុះក្នុងកាលណា ព្រះសាស្ដាត្រាស់ថា ម្នាលមោគ្គល្លាន សារីបុត្តបងប្រុសរបស់

អ្នកនៅទីណា ព្រះមោគ្គល្លានទូលថា បពិត្រព្រះអង្គ លោកចាំវស្សាក្នុងសង្កស្ស-នគរ ។ ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ តថាគតនឹងចុះត្រង់ទ្វារនគរសង្កស្ស: ក្នុងថ្ងៃមហាបវារណា បុគ្គលណាប្រាថ្នានឹងជួបតថាគត ចូរទៅក្នុងទីនោះចុះ ។ សង្កស្សនគរ ឆ្ងាយអំពីក្រុងសាវត្ថីប្រមាណ ៣០ យោជន៍ ក្នុងផ្លូវប៉ុណ្ណោះ កិច្ចដែលត្រូវត្រៀមស្បៀង រមែងមិនមានដល់បុគ្គលណាម្នាក់ឡើយ អ្នកគប្បីប្រាប់ដល់មនុស្សទាំងនោះថា អ្នកទាំងឡាយ ចូរជាអ្នករក្សាឧបោសថ ដូចទៅកាន់វិហារដែលជិត ដើម្បីស្តាប់ធម៌ចុះ ។

ព្រះថេរ:ទូលថា សាធុ ហើយបានប្រាប់តាមបណ្តាំ ។ ព្រះសាស្តាទ្រង់ចាំវស្សាបវារណាហើយ ត្រាស់ប្រាប់ដល់សក្ក:ថា មហាបពិត្រ តថាគតនឹងទៅកាន់ទឹកដីមនុស្ស សក្កទេវរាជទ្រង់និម្មិតជណ្តើរ គឺជណ្តើរមាស ជណ្តើរកែវមណី ជណ្តើរប្រាក់ ។ ជើងជណ្តើរទាំងនោះ តាំងនៅត្រង់ខ្លោងទ្វារនគរសង្កស្ស: ។ ក្បាលជណ្តើរទាំងនោះតាំងនៅត្រង់កំពូលភ្នំសិនេរុ ក្នុងជណ្តើរទាំងនោះ ជណ្តើរមាសនៅខាងស្តាំដើម្បីពួកទេវតា ជណ្តើរប្រាក់នៅខាងឆ្វេងដើម្បីមហាព្រហ្មទាំងឡាយ ជណ្តើរកែវមណីនៅត្រង់កណ្តាល ដើម្បីព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាប្រថាប់ឈរលើកំពូលភ្នំសិនេរុ ទ្រង់ធ្វើយមកប្បាដិហារ្យក្នុងកាលដែលទ្រង់ចុះអំពីទេវលោក ទ្រង់សម្លឹងមើលខាងលើហើយ ទីដែលទ្រង់ទតហើយទាំងឡាយមានទូល ដូចគ្នាតែមួយដល់ព្រហ្មលោក ទ្រង់ទតខាងក្រោម ទីដែលទ្រង់ទតហើយមានទូល ដូចគ្នាតែមួយដល់អវីចិ ទ្រង់

សម្លឹងមើលទិសធំ និងទិសតូចទាំងឡាយ ចក្រវាលច្រើនសែនមានទួល ដូចគ្នាតែមួយ ទេវតាឃើញពួកមនុស្ស ពួកមនុស្សឃើញពួកទេវតា ពួកទេវតា និងមនុស្សទាំងអស់ឃើញគ្នាហើយចំពោះមុខនោះឯង ព្រះសាស្តាទ្រង់បញ្ចេញព្រះឆព្វណ្ណរង្សីទៅហើយ មនុស្សក្នុងបរិស័ទដែលមានបរិមណ្ឌល ៣៦ យោជន៍ បុគ្គលសូម្បីតែម្នាក់ កាលសម្លឹងមើលសិរីរបស់ព្រះពុទ្ធ ក្នុងថ្ងៃនោះហើយ ឈ្មោះថា មិនប្រាថ្នាភាពជាព្រះពុទ្ធមិនមាន ។ ពួកទេវតាចុះតាមជណ្តើរមាស ពួកមហាព្រហ្មចុះតាមជណ្តើរប្រាក់ ព្រះសម្មាសម្ពុទ្ធយាងចុះតាមជណ្តើរកែវមណី ។ គន្ធព្វទេវបុត្រ ឈ្មោះបញ្ចសិខៈ កាន់ពិណពណ៌លឿងដូចផ្លែព្នៅ ឈរខាងស្តាំ បូជាដោយការរាំជល់ព្រះសាស្តាចុះមកមាតលិសង្គាហកទេវបុត្រឈរខាងឆ្វេង កាន់កម្រងផ្កាដែលជាទិព្វ នមស្ការបូជាចុះមកមហាព្រហ្មបាំងឆត្រសុយាមកាន់ផ្លិតវាលវីជនី ។ ព្រះសាស្តាយាងចុះ មួយអន្លើដោយបរិវារនេះ ប្រថាប់នៅត្រង់ខ្លោងទ្វារសង្កស្សនគរ ។ ព្រះសារីបុត្តត្ថេរថ្វាយបង្គំព្រះសាស្តាហើយ ព្រោះព្រះសាស្តាយាងចុះដោយពុទ្ធសិរីបែបនោះ ដែលលោកមិនធ្លាប់ឃើញហើយ ក្នុងកាលមុនអំពីនេះ ព្រោះដូច្នោះ ទើបប្រកាសសេចក្តីត្រេកអររបស់ខ្លួនដោយគាថាទាំងឡាយថា

ព្រះសាស្តាទ្រង់មានពាក្យពីរោះ ទ្រង់ជាអាចារ្យនៃគណៈ យាងមកអំពីតុសិតយ៉ាងនេះ ខ្ញុំមិនទាន់ឃើញ មិនបានឮចំពោះនរណាក្នុងកាលមុនអំពីនេះជាដើម ហើយទូលថា បពិត្រព្រះអង្គ ថ្ងៃនេះ ទេវតា និងមនុស្សទាំងឡាយរមែងទន្ទឹងចំពោះព្រះអង្គ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត ឈ្មោះថាព្រះពុទ្ធដែលប្រកបព្រមដោយគុណបែបនេះ រមែងជាទីស្រឡាញ់របស់ទេវតា និងមនុស្សទាំងឡាយដោយពិត កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យេ ឈានបសុតា ធីរា    នេក្ខម្មូបសមេ រតា**
**ទេវាបិ តេសំ បិហយន្តិ    សម្ពុទ្ធានំ សតីមតំ ។**

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្វល់ខ្វាយក្នុងឈាន
ត្រេកអរក្នុងនេក្ខម្មៈ ជាស្ថានស្ងប់រម្ងាប់កិលេស សូម្បី
ទេវតា និងមនុស្សទាំងឡាយ តែងរាប់រកចំពោះអ្នក
ប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹងខ្លួនឯង
ទាំងមានស្មារតី ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យេ ឈានបសុតា** សេចក្តីថា ប្រកបហើយ ខ្វល់ខ្វាយហើយក្នុងឈាន ២ យ៉ាងនេះ គឺក្នុងលក្ខណូបនិជ្ឈាន ១ អារម្មណូបនិជ្ឈាន ១ ដោយអាវជ្ជនៈ ដោយការចូល ដោយការអធិដ្ឋាន ដោយការចេញ និងដោយការពិចារណា ។ បព្វជ្ជាដែលអ្នកសិក្សាមិនគប្បីកាន់យកថា នេក្ខម្មៈ ក្នុងពាក្យថា **នេក្ខម្មូបសមេ រតា** នេះ ពាក្យថា នេក្ខម្មៈនោះ ទ្រង់ត្រាស់សំដៅយកការត្រេកអរក្នុងនិព្វាន ដែលចូលទៅស្ងប់កិលេស ។ បទថា **ទេវាបិ** សេចក្តីថា ទេវតា និងមនុស្សទាំងឡាយរមែងទន្ទឹង គឺប្រាថ្នាចំពោះព្រះសម្ពុទ្ធទាំងអស់ ។ បទថា **សតីមតំ** សេចក្តីថា ទេវតា និងមនុស្ស

ទាំងឡាយ ប្រាថ្នាភាពជាព្រះពុទ្ធថា គួរអស្ចារ្យពិតហ្ន៎ សូម្បីអញក៏គប្បីជាព្រះពុទ្ធដូច្នេះ ឈ្មោះថា រមែងប្រាថ្នាចំពោះព្រះពុទ្ធទាំងអស់ បុគ្គលមានព្រះគុណបែបនេះ បុគ្គលប្រកបព្រមហើយដោយសតិ ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យមានដល់សត្វប្រមាណ ៣០ កោដិ ភិក្ខុ ៥០០ ដែលជាសទ្ធិវិហារិករបស់ព្រះថេរៈ តាំងនៅហើយក្នុងអរហត្ត ។

បានឮថា ការធ្វើយមកប្បាដិហារ្យ ហើយចាំវស្សាក្នុងទេវលោក ចុះត្រង់ទ្វារសង្កស្សនគរ ព្រះពុទ្ធគ្រប់អង្គទ្រង់មិនដែលលះបង់ឡើយ ទីដែលព្រះបាទខាងស្តាំប្រតិស្ឋាន ក្នុងទីដែលទ្រង់ចុះនោះ មានឈ្មោះថា អចលចេតិយដ្ឋាន ព្រះសាស្តាប្រថាប់ឈរក្នុងទីនោះ ត្រាស់សួរបញ្ហាក្នុងវិស័យរបស់បុថុជ្ជនជាដើម ពួកបុថុជ្ជនឆ្លើយបញ្ហាក្នុងវិស័យរបស់ខ្លួនប៉ុណ្ណោះ មិនអាចឆ្លើយបញ្ហាក្នុងវិស័យរបស់ព្រះសោតាបន្នបាន ។ ព្រះអរិយបុគ្គលទាំងឡាយមានព្រះសោតាបន្នជាដើមក៏ដូចគ្នា មិនអាចឆ្លើយបញ្ហាក្នុងវិស័យរបស់ព្រះអរិយបុគ្គលទាំងឡាយ មានសកទាគាមីជាដើម ព្រះសាវកដ៏សេស មិនអាចឆ្លើយបញ្ហា ក្នុងវិស័យរបស់ព្រះមហាមោគ្គល្លាន ព្រះមហាមោគ្គល្លានមិនអាចឆ្លើយបញ្ហាក្នុងវិស័យរបស់ព្រះសារីបុត្តត្ថេរបាន ព្រះសារីបុត្តត្ថេរក៏មិនអាចឆ្លើយបញ្ហាក្នុងពុទ្ធវិស័យបានដូចគ្នា ។ ព្រះសាស្តាត្រង់សម្លឹងមើលទិសទាំងពួង តាំងអំពីទិសបូព៌ ស្ថានទីទាំងពួង មានទួលដូចគ្នានោះឯង ។ ទេវតា និងមនុស្សក្នុងទិសទាំង ៨ និងទេវតាខាងលើទល់នឹងព្រហ្មលោក យក្ខ នាគ និងគ្រុឌដែលនៅត្រង់ផ្ទៃខាងក្រោម ផ្គងអញ្ជលីក្រាបទូលថា

បពិត្រព្រះអង្គ ឈ្មោះថា បុគ្គលវិសជ្ជនាបញ្ហានេះ មិនមានក្នុងសមាគមនេះ សូមទ្រង់ពិចារណាក្នុងសមាគមនេះឯង ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា សារីបុត្តរមែងលំបាក ព្រោះថា សារីបុត្តបានស្តាប់បញ្ហាដែលតថាគតសួរហើយ ក្នុងពុទ្ធវិស័យនេះថា

ម្នាលអ្នកនិទ្ទុក្ខ បុគ្គលអ្នកមានបញ្ញារក្សាខ្លួន កាលតថាគតសួរដល់ការប្រព្រឹត្តទៅរបស់អ្នក បុគ្គលមានធម៌ដែលរាប់ព្រមហើយទាំងឡាយ និងព្រះសេក្ខៈទាំងឡាយ ដែលមានច្រើនក្នុងលោកនេះ ចូរប្រាប់ការប្រព្រឹត្តទៅនោះដល់តថាគតដូច្នេះ ជាអ្នកអស់សេចក្តីសង្ស័យក្នុងបញ្ហាថា ព្រះសាស្តារមែងត្រាស់សួរដល់បដិបទាជាទីមក គឺមគ្គប្បដិបទារបស់ព្រះសេក្ខៈ និងអសេក្ខៈជាមួយអាត្មាអញដូច្នេះក៏ពិត តែក៏គួរសង្ស័យអធ្យាស្រ័យរបស់តថាគតថា កាលអញពោលបដិបទានេះដោយមុខណាមួយ ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ទើបអាចកាន់យកអធ្យាស្រ័យរបស់ព្រះសាស្តាបាន សារីបុត្តនោះកាលតថាគតមិនឲ្យន័យ នឹងមិនអាចឆ្លើយបាន តថាគតនឹងឲ្យន័យដល់សារីបុត្ត កាលទ្រង់សម្តែងន័យ ត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកពិចារណាឃើញសេចក្តីពិតនេះ ។ បានឮថា ទ្រង់ព្រះតម្រិះយ៉ាងនេះថា សារីបុត្ត កាលកាន់យកអធ្យាស្រ័យរបស់តថាគតឆ្លើយ នឹងឆ្លើយដោយអំណាចខន្ធ បញ្ហានោះ ប្រាកដដល់ព្រះថេរៈរាប់ រយរាប់ពាន់ន័យ មួយអន្លើដោយការប្រទានន័យ លោកតាំងនៅក្នុងន័យដែលព្រះសាស្តាប្រទាន ឆ្លើយបញ្ហានោះបានហើយ បានឮថា អ្នកដទៃវៀរព្រះដ៏មានព្រះភាគចេញ ឈ្មោះថាអាចទាន់នូវ

បញ្ញារបស់ព្រះសារីបុត្តត្រូវមិនមាន បានឮថា ហេតុនោះឯង ទើបព្រះថេរៈឈរចំពោះព្រះភក្ត្រព្រះសាស្តាបន្លឺសីហនាទថា បពិត្រព្រះអង្គ កាលភ្លៀងធ្លាក់អស់មួយកប្ប ខ្ញុំព្រះអង្គក៏អាចរាប់គណនាថា តំណក់ទាំងឡាយ ធ្លាក់ក្នុងមហាសមុទ្រប៉ុណ្ណេះតំណក់ ធ្លាក់លើផែនដីប៉ុណ្ណេះតំណក់ លើភ្នំប៉ុណ្ណេះតំណក់សូម្បីព្រះសាស្តាក៏ត្រាស់នឹងលោកថា សារីបុត្ត តថាគតក៏ដឹងភាពដែលអ្នកអាចនឹងរាប់បាន ឈ្មោះថា ឧបមាប្រៀបដោយបញ្ញារបស់អ្នកនោះ រមែងមិនមាន ហេតុនោះ ទើបលោកក្រាបទូលថា

> ខ្សាច់ក្នុងស្ទឹងគង្គាគប្បីអស់ទៅ ទឹកក្នុងមហាសមុទ្រគប្បីអស់ទៅ
> ដីក្នុងផែនដីគប្បីអស់ទៅ ការឆ្លើយបញ្ហាដោយការដឹងរបស់ខ្ញុំ
> ព្រះអង្គ រមែងមិនអស់ ទៅដោយការគណនា ។

មានពាក្យអធិប្បាយដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលសម្បូរដោយការដឹង ជាទីពឹងរបស់លោក បើខ្ញុំព្រះអង្គឆ្លើយបញ្ហាមួយហើយ បុគ្គលគប្បីដាក់ខ្សាច់មួយគ្រាប់ ឬតំណក់ទឹកមួយតំណក់ ឬដីស្អិតមួយដុំ កាលខ្ញុំព្រះអង្គឆ្លើយបញ្ហាមួយរយ ឬមួយពាន់ ឬមួយសែន គប្បីដាក់ខ្សាច់ទាំងឡាយ មានខ្សាច់ជាដើម មួយៗ ក្នុងចំណែកម្ខាងក្នុងស្ទឹងគង្គា ខ្សាច់ទាំងឡាយ មានខ្សាច់ជាដើមក្នុងស្ទឹងគង្គាជាដើម គប្បីអស់ទៅមុន ការឆ្លើយបញ្ហារបស់ខ្ញុំព្រះអង្គ រមែងមិនអស់នៅឡើយ ។

ភិក្ខុមានបញ្ញាច្រើនយ៉ាងនេះ ក៏មិនឃើញចំណុចខាងដើម ឬចំណុចខាងចុងនៃបញ្ហាដែលព្រះសាស្តាសួរហើយក្នុងពុទ្ធវិស័យ ទាល់តែតាំងនៅក្នុងន័យ

ដែលព្រះសាស្តាប្រទានហើយ ទើបឆ្លើយបញ្ហាបាន ។ ភិក្ខុទាំងឡាយ ស្តាប់ដូច្នោះហើយ សន្ទនាថា ជនទាំងអស់ដែលព្រះសាស្តាត្រាស់សួរបញ្ហាណា មិនអាចឆ្លើយបាន ព្រះសារីបុត្តត្ថេរ ដែលជាធម្មសេនាបតីម្នាក់ប៉ុណ្ណោះឆ្លើយបញ្ហានោះបាន ព្រះសាស្តាទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា សារីបុត្តឆ្លើយបញ្ហា ដែលមហាជនមិនអាចឆ្លើយបានក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែនសូម្បីក្នុងកាលមុន សារីបុត្តក៏ឆ្លើយបានហើយដូចគ្នា ដូច្នេះហើយ ទ្រង់នាំអតីតនិទានមក ត្រាស់ជាតកនេះដោយពិស្តារថា

ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងរយនាក់ ជនទាំងនោះ ឥតប្រាជ្ញា គប្បីពិចារណា ( នូវអត្ថនៃភាសិត ) អស់ ១០០ ឆ្នាំ បុរសណាប្រកបដោយប្រាជ្ញា ដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះម្នាក់ឯងប្រសើរវិញ ។

**រឿង យមកប្បាដិហារ្យ ចប់**

# រឿង ឯរកបត្តនាគរាជ

## លំនាំដើម

ព្រះសាស្តា ទ្រង់អាស្រ័យពារាណសីនគរ ប្រថាប់នៅត្រង់ដើមប្រេស ៧ ដើម ទ្រង់ប្រារព្ធស្តេចនាគ ឈ្មោះឯរកបត្ត ត្រាស់ព្រះធម្មទេសនានេះថា **កិច្ឆោមនុស្សប្បដិលាភោ** ជាដើម ។

បានឮថា ក្នុងសាសនារបស់ព្រះកស្សបសម្ពុទ្ធ ក្នុងកាលមុនស្តេចនាគនោះជាភិក្ខុកំលោះ ចុះទូកទៅក្នុងស្ទឹងគង្គា ទាញស្លឹកវរទឹកមួយក្តាប់ កាលទូកស្ទុះទៅដោយរហ័សក៏មិនលែង វរទឹកនោះដាច់ហើយ ។ ភិក្ខុកំលោះនោះមិនសម្តែងអាបត្តិដោយគិតថា នេះគ្រាន់តែជាទោសតិចតួច សូម្បីធ្វើសមណធម៌ក្នុងព្រៃអស់ ២ ម៉ឺនឆ្នាំ ក្នុងកាលមរណកាល ឃើញហាក់បីដូចស្លឹកវរទឹកមករុំក សូម្បីចង់សម្តែងអាបត្តិ កាលមិនឃើញភិក្ខុដទៃ ក៏ក្តៅក្រហាយឡើងថា អញមានសីលមិនបរិសុទ្ធ ចុតិចាកអត្តភាពនោះហើយ កើតជាស្តេចនាគ មានរាងកាយប្រមាណប៉ុនទូកកំពេល ។ នាគនោះមានឈ្មោះថា ឯរកបត្តនោះឯង ។ ក្នុងខណៈដែលកើតហើយនោះឯង ស្តេចនាគក្រឡេកមើលអត្តភាពហើយ មានការក្តៅក្រហាយថា អញធ្វើសមណធម៌អស់កាលមានប្រមាណប៉ុណ្ណោះ ជាអ្នកកើតក្នុងទីដែលមានកង្កែបជាអាហារ ក្នុងកំណើតអហេតុកសត្វ ។

ក្នុងកាលតមក នាគបានធីតាម្នាក់ បើកពពារធំលើផ្ទៃទឹកស្ទឹងគង្គា ដាក់ធីតាលើពពារនោះឲ្យរាំច្រៀងហើយ ។

បានឮថា នាគមានការគិតយ៉ាងនេះថា កាលព្រះពុទ្ធកើតឡើង អញនឹងបានឮភាពដែលព្រះពុទ្ធនោះកើតឡើងដោយឧបាយនេះឯង បុគ្គលណានាំយកចម្រៀងឆ្លើយនឹងចម្រៀងរបស់អញបាន អញនឹងឲ្យធីតា មួយអន្លើដោយនាគពិភពដ៏ធំដល់បុគ្គលនោះ ។ ដាក់ធីតានោះលើពពារ ក្នុងថ្ងៃឧបោសថរៀងរាល់កន្លះខែ ។ ធីតានោះឈររាំលើពពារនោះ ច្រៀងយ៉ាងនេះថា បុគ្គលជាធំ ឈ្មោះថា ព្រះរាជាដូចម្ដេច ព្រះរាជា ឈ្មោះថា មានធូលីលើក្បាលដូចម្ដេច ឈ្មោះថា ប្រាសចាកធូលីដូចម្ដេច លោកហៅថាបុគ្គលពាលដូចម្ដេច ។

អ្នកជម្ពូទ្វីបទាំងមូលនាំគ្នាមកដោយបំណងថា អញនឹងនាំយកនាងនាគមាណវិកា ហើយតែងបទចម្រៀងឆ្លើយ ច្រៀងដោយកម្លាំងបញ្ញារៀងៗ ខ្លួន ។ នាងតែងបដិសេធចម្រៀងដែលច្រៀងឆ្លើយនោះ កាលនាងឈរលើពពាររៀងរាល់កន្លះខែច្រៀងយ៉ាងនេះប៉ុណ្ណោះ មួយពុទ្ធន្តរកន្លងទៅហើយ ។

គ្រានោះ ព្រះសាស្ដាទ្រង់កើតឡើងហើយក្នុងលោក ថ្ងៃមួយ ពេលទៀបភ្លឺ ទ្រង់ប្រមើលមើលលោក ធ្វើឯរកបត្តនាគរាជឲ្យជាហេតុ ទ្រង់ឃើញមាណពឈ្មោះឧត្តរៈ ចូលទៅក្នុងសំណាញ់ គឺព្រះញាណរបស់ទ្រង់ ទ្រង់ពិចារណាមើលថា តើនឹងមានហេតុអ្វី ទ្រង់បានឃើញថា ថ្ងៃនេះ ជាថ្ងៃដែលឯរកបត្តនាគរាជ ដាក់ធីតាលើពពារហើយឲ្យរាំ ឧត្តរមាណពនេះ រៀនទូវបទចម្រៀងដែលតថាគតឲ្យហើយ នឹងបានជាសោតាបន្ន រៀនយកបទចម្រៀងនោះទៅកាន់សម្នាក់របស់នាគរាជនោះៗ ស្ដាប់ចម្រៀងឆ្លើយនោះហើយ នឹងដឹងថា ព្រះពុទ្ធកើតឡើងហើយ នឹងមកកាន់សម្នាក់របស់តថាគត

កាលនាគរាជនោះមកហើយ តថាគតនឹងពោលគាថាក្នុងមហាសមាគម ក្នុងកាលចប់គាថា សត្វប្រមាណ ៨៤០០០ នឹងត្រាស់ដឹងធម៌ ។

ព្រះសាស្តាយាងទៅក្នុងទីនោះហើយ ប្រថាប់គង់ត្រង់គល់ប្រេសមួយក្នុងបណ្តាប្រេស ៧ ដើម ដែលមាននៅមិនឆ្ងាយអំពីក្រុងពារាណសី ។ អ្នកជម្ពូទ្វីប នាំយកបទចម្រៀងឆ្លើយទៅប្រជុំគ្នាហើយ ។ ព្រះសាស្តាទតឃើញឧត្តរមាណពកំពុងទៅក្នុងទីមិនឆ្ងាយ ទើបត្រាស់ថា ឧត្តរៈ ឧត្តរៈពោលថា ករុណាព្រះអង្គ ព្រះសាស្តាត្រាស់ថា ចូរអ្នកមកណេះសិន ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងឧត្តរមាណពនោះ ដែលមកថ្វាយបង្គំអង្គុយចុះហើយ សួរថា ឧត្តរៈ អ្នកទៅណា ឧត្តរមាណពឆ្លើយថា ទៅកាន់ទីដែលធីតារបស់ឯរកបត្តនាគរាជច្រៀង ព្រះសាស្តាត្រាស់ថា អ្នកដឹងចម្រៀងដែលត្រូវឆ្លើយហើយឬ ឧត្តរមាណពទូលថា បពិត្រព្រះអង្គ មិនដឹងទេ ព្រះសាស្តាត្រាស់ថា ចូរអ្នកពោលចម្រៀងនោះជាមុន ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងឧត្តរមាណព ដែលពោលតាមចំណេះដឹងរបស់ខ្លួនប៉ុណ្ណោះថា នែឧត្តរៈ នុ៎ះមិនមែនជាបទចម្រៀងសម្រាប់ឆ្លើយទេ តថាគតនឹងឲ្យបទចម្រៀង ដែលជាចម្លើយដល់អ្នក អ្នកត្រូវរៀនបទចម្រៀងនោះឲ្យបាន ឧត្តរមាណពទូលថា សាធុ ព្រះអង្គ ។

គ្រានោះ ព្រះសាស្តាត្រាស់ថា ម្នាលឧត្តរៈ ក្នុងកាលដែលនាងនាគមាណវិកាច្រៀង អ្នកគប្បីច្រៀងឆ្លើយយ៉ាងនេះថា បុគ្គលជាធំក្នុងទ្វារ ៦ ឈ្មោះថា ជាព្រះរាជា ព្រះរាជាដែលប្រកបដោយតម្រេក ឈ្មោះថា មានធូលី

លើក្បាល បុគ្គលប្រាសចាកតម្រេក ឈ្មោះថា ប្រាសចាកធូលី បុគ្គលដែលប្រកបដោយតម្រេក លោក ហៅថា បុគ្គលពាល ។

ចម្រៀងរបស់នាគមាណវិកា មានអធិប្បាយថា បទថា **កឹសុ អធិបតី រាជា** សេចក្តីថា បុគ្គលជាធំដូចម្តេច ឈ្មោះថា ព្រះរាជា ។

បាទគាថាថា **កឹសុ រាជា រជស្សិរោ** សេចក្តីថា ព្រះរាជាដូចម្តេច ជាបុគ្គលឈ្មោះថា មានធូលីលើក្បាល ។

បទថា **កថំ សុ** សេចក្តីថា ព្រះរាជាដូចម្តេច ឈ្មោះថាប្រាសចាកធូលី ។ ចំណែកចម្រៀងឆ្លើយតប មានអធិប្បាយថា បាទព្រះគាថាថា **ឆទ្វារាធិបតី រាជា** សេចក្តីថា បុគ្គលណាជាធំនៃទ្វារ ៦ ដែលអារម្មណ៍ទាំង ៦ មានរូបជាដើម គ្របសង្កត់មិនបានក្នុងទ្វារមួយ បុគ្គលនេះ ឈ្មោះថា ជាព្រះរាជា ។

បាទព្រះគាថាថា **រជមានោ រជស្សិរោ** សេចក្តីថា ព្រះរាជាណាតម្រេកនៅក្នុងអារម្មណ៍ទាំងនោះ ព្រះរាជាដែលតម្រេកនោះ ឈ្មោះថា មានធូលីលើក្បាល ។ បទថា **អរជំ** សេចក្តីថា ចំណែកព្រះរាជាដែលមិនតម្រេកឈ្មោះថា ជាបុគ្គលប្រាសចាកធូលី ។ បទថា **រជំ** សេចក្តីថា ព្រះរាជាដែលតម្រេក លោកហៅថា ជាបុគ្គលពាល ។

ព្រះសាស្តា កាលប្រទានបទចម្រៀងឆ្លើយដល់ឧត្តរមាណពនោះយ៉ាងនេះហើយត្រាស់ថា ម្នាលឧត្តរៈ កាលអ្នកច្រៀងចម្រៀងនេះ នាងនឹងច្រៀងសួរនូវចម្រៀងរបស់អ្នកយ៉ាងនេះថា បុគ្គលពាល អ្វីរមែងបន្សាត់ទៅ បណ្ឌិតរមែងបន្ទោបង់នូវអ្វី អ្វីទើបបុគ្គលក្សេមចាកយោគៈ អ្នកកាលខ្ញុំសួរហើយ សូម

ប្រាប់សេចក្តីនោះដល់ខ្ញុំ ។

ពេលនោះ អ្នកគប្បីច្រៀងឆ្លើយដល់នាងថា បុគ្គលពាល ដែលជំនន់គឺកាមោឃៈជាដើមរមែងបន្សាត់ទៅ បណ្ឌិតរមែងបន្ទោបង់នូវឱឃៈនោះដោយសេចក្តីព្យាយាម បណ្ឌិតដែលមិនប្រកបដោយយោគៈទាំងពួង លោកហៅថា ជាអ្នកមានសេចក្តីក្សេមចាកយោគៈ ។

ចម្រៀងឆ្លើយនោះមានសេចក្តីថា បុគ្គលពាលត្រូវឱឃៈ ៤ មានកាមោឃៈជាដើមបន្សាត់ទៅ បណ្ឌិតរមែងបន្ទោបង់ឱឃៈនោះ ដោយសេចក្តីព្យាយាមពោល គឺសម្មប្បធាន បណ្ឌិតនោះ មិនប្រកបដោយយោគៈទាំងពួង មានកាមយោគៈជាដើម លោកហៅឈ្មោះថា ជាអ្នកមានការក្សេមចាកយោគៈ ។

ឧត្តរមាណព កាលកំពុងរៀនចម្រៀងឆ្លើយនេះ តាំងនៅក្នុងសោតាបត្តិផល គាត់ជាព្រះសោតាបន្ន រៀនគាថានោះ ទៅហើយ ពោលថា អ្នកដ៏ចម្រើន ខ្ញុំនាំចម្រៀងសម្រាប់ឆ្លើយមកហើយ ចូរពួកអ្នកឲ្យឱកាសដល់ខ្ញុំ បានលុតជង្គង់ទៅក្នុងចំណោមមហាជន ឈរប្រជ្រៀតគ្នាហើយ ។ នាងនាគមាណវិកាឈររាំលើពពាររបស់បិតា ហើយច្រៀងថា

បុគ្គលជាធំដូចម្តេច ឈ្មោះថា ជាព្រះរាជាជាដើម ។ ឧត្តរមាណពច្រៀងឆ្លើយថា បុគ្គលជាធំក្នុងទ្វារ ៦ ឈ្មោះថា ជាព្រះរាជាជាដើម នាគមាណវិកាច្រៀងចោទឧត្តរមាណពនោះទៀតថា បុគ្គលពាល អ្វីរមែងបន្សាត់ទៅជាដើម កាលឧត្តរមាណពនោះច្រៀងដល់នាង ទើបពោលគាថានេះថា

បុគ្គលពាល ត្រូវជំនន់បន្សាត់ទៅ ដូច្នេះជាដើម ។ នាគរាជបានស្តាប់

គាថានោះ ជ្រាបកាលដែលព្រះពុទ្ធកើតឡើង ត្រេកអរថា អញមិនធ្លាប់ស្តាប់បទចម្រៀងបែបនេះអស់ ១ ពុទ្ធន្តរ អ្នកដ៏ចម្រើន ព្រះពុទ្ធកើតឡើងក្នុងលោកហើយហ្ន៎ ទើបយកកន្ទុយគោះទឹក រលកធំៗ កើតឡើងហើយ ប្រាំងទាំងពីរបាក់ចុះ ពួកមនុស្សក្នុងទីប្រមាណ ១ ឧសភៈ ត្រើយនាយ និងត្រើយអាយធ្លាក់ចូលទៅក្នុងទឹក ។ នាគរាជនោះ លើកមហាជនមានប្រមាណប៉ុណ្ណោះ ដាក់លើពពារ ហើយដាក់លើគោក ។ នាគរាជនោះ ចូលទៅរកឧត្តរមាណពហើយ សួរថា នែអ្នក ព្រះសាស្តាប្រថាប់នៅទីណា ឧត្តរមាណពពោលថា ទ្រង់ប្រថាប់គង់ត្រង់គល់ឈើមួយដើម នាគរាជពោលថា មកពួកយើងនឹងនាំគ្នាទៅហើយ បានទៅជាមួយឧត្តរមាណព ចំណែកមហាជន បានទៅជាមួយនាគដូចគ្នា ។ នាគរាជនោះ ទៅដល់ ចូលទៅកាន់ចន្លោះរស្មីដែលមានពណ៌ ៦ ថ្វាយបង្គំព្រះសាស្តាហើយ បានឈរយំ ។ គ្រានោះ ព្រះសាស្តាត្រាស់នឹងនាគរាជនោះថា មហាបពិត្រ មានរឿងអ្វី នាគរាជពោលថា បពិត្រព្រះអង្គខ្ញុំព្រះអង្គជាសាវ័ករបស់ព្រះពុទ្ធដូចគ្នានឹងព្រះអង្គ ធ្វើសមណធម៌ ២ ម៉ឺនឆ្នាំសូម្បីសមណធម៌នោះក៏មិនអាចជួយខ្ញុំព្រះអង្គបាន ខ្ញុំព្រះអង្គអាស្រ័យហេតុត្រឹមតែឲ្យស្លឹកវែទឹកដាច់ទៅមានប្រមាណតិចតួច បដិសន្ធិក្នុងអហេតុកសត្វកើតក្នុងទីដែលត្រូវលូនទៅដោយទ្រូង រមែងមិនបាននូវភាពជាមនុស្សឡើយ មិនបានស្តាប់ធម៌ មិនបានឃើញព្រះពុទ្ធដូចគ្នានឹងព្រះអង្គអស់មួយពុទ្ធន្តរ ។

ព្រះសាស្តា ទ្រង់ស្តាប់វាចារបស់នាគរាជនោះហើយ ត្រាស់ថា មហាបពិត្រ ឈ្មោះថា ភាពជាមនុស្សបានដោយកម្រពន់ពេក ការស្តាប់ព្រះសទ្ធម្ម

ក៏យ៉ាងនោះ ការកើតឡើងនៃព្រះពុទ្ធ ក៏រកបានលំបាកដូចគ្នា ព្រោះថា ទាំង ៣ យ៉ាងនេះ បុគ្គលរមែងបានដោយលំបាក កាលទ្រង់សម្តែងធម៌ត្រាស់ព្រះគាថានេះថា

**កិច្ឆោ មនុស្សបដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។**

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំង-ឡាយ បានដោយកម្រ ។

## សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះ គប្បីជ្រាបដូច្នេះ ឈ្មោះថា ការបានអត្តភាពជាមនុស្ស ឈ្មោះថា ជាការលំបាក គឺរកបានដោយកម្រ ព្រោះភាពជាមនុស្ស បុគ្គលត្រូវបានដោយសេចក្តីព្យាយាមច្រើន ដោយកុសលច្រើន សូម្បីជីវិតរបស់សត្វទាំងឡាយ ក៏ឈ្មោះថារស់នៅដោយកម្រ ព្រោះធ្វើកម្ម មានកសិកម្មជាដើមរឿយៗ ហើយបន្តការប្រព្រឹត្តទៅនៃជីវិតផង ព្រោះជីវិតជារបស់តិចផង ការស្តាប់ព្រះសទ្ធម្មក៏ជាការក្រ ព្រោះបុគ្គលដែលសម្តែងធម៌ រកបានដោយកម្រ ក្នុងកប្បមិនមែនតិច ។ ម្យ៉ាងទៀត ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ជាការក្រដូចគ្នា គឺបានលំបាកពន់ពេក ព្រោះអភិនីហារសម្រេចដោយសេចក្តីព្យាយាមច្រើន និងព្រោះការកើតឡើងនៃបុគ្គលដែលមាន

អភិនីហារសម្រេចហើយ ជាការបានដោយលំបាក ដោយពាន់នៃកោដិកប្ប មិនមែនតិច ។

ក្នុងកាលចប់ទេសនា ពួកសត្វ ៨៤០០០ បានត្រាស់ដឹងធម៌ហើយ ចំណែកនាគរាជគួរបានសោតាបត្តិផលក្នុងថ្ងៃនោះ តែក៏មិនបានព្រោះភាពដែលខ្លួនជាសត្វតិរច្ឆាន ។ នាគរាជនោះដល់នូវការៈ គឺការមិនលំបាកក្នុងឋានៈទាំង ៥ ពោល គឺការបដិសន្ធិ ការសកស្រកា ការដាក់ចិត្តឈានចុះកាន់និទ្រា ការសេពមេថុនទីឯនាងនាគដែលមានជាតិស្មើគ្នា និងចុតិដែលពួកនាគកាន់យកសរីរៈនៃនាគនោះឯង ហើយលំបាក រមែងត្រាច់ទៅដោយរូបនៃមាណពនោះឯង ដូច្នេះ ។l៚

**រឿង ឯរកបត្តនាគរាជ ចប់**

# រឿង បញ្ហារបស់ព្រះអានន្ទត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សព្វបាបស្ស អករណំ** ជាដើម ។

បានឮថា ព្រះថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃគិតថា ព្រះសាស្តាត្រាស់ប្រាប់ហេតុនៃព្រះពុទ្ធ ៧ អង្គគ្រប់យ៉ាង គឺព្រះជននី និងព្រះជនក ការកំណត់ព្រះជន្មាយុ ឈើដែលត្រាស់ដឹង សាវកសន្និបាត អគ្គសាវក ឧបដ្ឋាក តែ

ឧបោសថមិនបានត្រាស់ប្រាប់ ឧបោសថនៃព្រះពុទ្ធទាំងនោះយ៉ាងនេះ ឬដទៃហ្ន៎ ។ ទើបចូលទៅគាល់ព្រះសាស្តា ហើយទូលសួរសេចក្តីនោះ ព្រោះការផ្សេងគ្នានៃកាល នៃព្រះពុទ្ធទាំងនោះប៉ុណ្ណោះមានហើយ ។ ការផ្សេងគ្នានៃគាថាមិនមាន ព្រោះថា ព្រះសម្មាសម្ពុទ្ធព្រះនាមវិបស្សី ទ្រង់ធ្វើឧបោសថរៀងរាល់ ៧ ឆ្នាំម្តង ព្រោះព្រះឱវាទដែលទ្រង់ប្រទានហើយ មួយថ្ងៃប៉ុណ្ណោះល្មមប្រព្រឹត្តទៅបាន ៧ ឆ្នាំ ព្រះសម្មាសម្ពុទ្ធព្រះនាមសិខី និងវេស្សភូ ទ្រង់ធ្វើឧបោសថរៀងរាល់ ៦ ឆ្នាំ ទ្រង់ប្រទានក្នុងមួយថ្ងៃប៉ុណ្ណោះ ល្មមប្រព្រឹត្តទៅបាន ៦ ឆ្នាំ ព្រះសម្មាសម្ពុទ្ធព្រះនាមកកុសន្ធៈ និងកោនាគមនៈ ទ្រង់ធ្វើឧបោសថរៀងរាល់ឆ្នាំ ព្រោះឱវាទដែលទ្រង់ប្រទានមួយថ្ងៃប៉ុណ្ណោះ ល្មមប្រព្រឹត្តទៅបានមួយឆ្នាំ ព្រះកស្សបទសពល ទ្រង់ធ្វើឧបោសថរៀងរាល់ ៦ ខែ ព្រោះព្រះឱវាទដែលប្រទានមួយថ្ងៃ ល្មមប្រព្រឹត្តទៅបាន ៦ ខែ ដូច្នោះ ទើបព្រះសាស្តាត្រាស់ភាពផ្សេងគ្នានៃកាលនេះ របស់ព្រះពុទ្ធទាំងនោះ ហើយត្រាស់ថា ចំណែកឱវាទគាថារបស់ព្រះពុទ្ធទាំងនោះយ៉ាងនេះឯង ដូច្នេះហើយ កាលទ្រង់ធ្វើឧបោសថនៃព្រះពុទ្ធគ្រប់អង្គដែលដូចគ្នានោះឲ្យជាក់ច្បាស់ ទើបត្រាស់ព្រះគាថានេះថា

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ**
**ខន្តិ បរមំ តបោ តីតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា**

ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ
បរំ វិហេឋយន្តោ ។

អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។

ការមិនធ្វើបាបទាំងពួង ការញុំាំងកុសលឲ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

ខន្តិ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំង-ឡាយ តែងពោលថា ព្រះនិព្វានជាធម្មជាតដ៏ឧត្តម បុគ្គលដែល សម្លាប់សត្វដទៃ មិនឈ្មោះថា បព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថាសមណៈ ឡើយ ។

ការមិនតិះដៀល ១ ការមិនបៀតបៀន ១ ការសង្រួម ក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត ១ ការ ដេក និងអង្គុយក្នុងទីស្ងាត់ ១ ការព្យាយាម ក្នុងអធិចិត្ត ១ នុ៎ះជា ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្វបាបស្ស** បានដល់ អកុសលកម្មគ្រប់

ប្រភេទ ។ ការញុំាងកុសលឲ្យកើតឡើងតាំងអំពីចេញបួស រហូតដល់អរ-ហត្តមគ្គ និងការញុំាងកុសលដែលខ្លួនឲ្យកើតឡើងហើយ ឲ្យចម្រើន ឈ្មោះថា ឧបសម្បទា ។ ការញុំាងចិត្តរបស់ខ្លួនឲ្យផូរផង់ចាកនីវរណៈទាំង ៥ ឈ្មោះថា **សចិត្តបរិយោទបនំ** ។

បាទព្រះគាថាថា **ឯតំ ពុទ្ធានសាសនំ** ដោយអត្ថថា នេះជាវាចាប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ៗ អង្គ ។

បទថា **ខន្តិ** សេចក្ដីថា ឈ្មោះថា ការអត់ធន់ ពោល គឺការអត់សង្កត់នេះ ជាតបៈដ៏ក្រៃលែង គឺយ៉ាងឧត្ដមក្នុងព្រះសាសនានេះ ។

បាទព្រះគាថាថា **និព្វានំ បរមំ វទន្តិ ពុទ្ធា** សេចក្ដីថា ពុទ្ធបុគ្គលទាំង ៣ ពួក គឺព្រះសម្មាសម្ពុទ្ធមួយពួក ព្រះបច្ចេកពុទ្ធមួយពួក ព្រះអនុពុទ្ធមួយពួក រមែងពោលព្រះនិព្វានថា ជាធម្មជាតដ៏ឧត្ដម ។

បទថា **ន ហិ បព្វជិតោ** សេចក្ដីថា បុគ្គលដែលបៀតបៀនសត្វដទៃដោយគ្រឿងប្រហារផ្សេងៗ មានបាតដៃជាដើម ឈ្មោះថា ជាអ្នកប្រទូស្ដអ្នកដទៃ មិនឈ្មោះថាជាបព្វជិត ។ បទថា **សមណោ** សេចក្ដីថា បុគ្គលដែលបៀតបៀនសត្វដទៃ ដោយន័យដែលពោលហើយនោះឯង មិនឈ្មោះថាជាសមណៈដូចគ្នា ។ ការមិនតិះដៀលឯង ការមិនញុំាងអ្នកដទៃឲ្យតិះដៀល ឈ្មោះថា **អនូបវាទោ** ។ ការមិនបៀតបៀនឯង និងការមិនប្រើអ្នកដទៃឲ្យបៀតបៀន ឈ្មោះថា **អនូបឃាតោ** ។

បទថា **បាតិមោក្ខេ** បានដល់ សីលដែលជាប្រធាន ។ ការបិទ ឈ្មោះ

*ថា* **សំវរោ។** *ភាពជាអ្នកដឹងល្មម គឺស្គាល់ប្រមាណ ឈ្មោះថា* **មត្តញ្ញុតា។** *បទថា* **បន្តំ** *បានដល់ ស្ងាត់ ។ បទថា* **អធិចិត្តេ** *សេចក្តីថា ក្នុងចិត្តដែលក្រៃលែង ពោល គឺចិត្តដែលសហគតៈដោយសមាបត្តិ ៨ ។ ការធ្វើសេចក្តីព្យាយាម ឈ្មោះថា* **អាយោគោ។** *បទថា* **ឯតំ** *សេចក្តីថា នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់អង្គក្នុងព្រះគាថានេះ ។ ក្នុងព្រះគាថានេះ ព្រះដ៏មានព្រះភាគត្រាស់សីល ដែលប្រព្រឹត្តទៅដោយវាចា ដោយអនូបវាទៈ ត្រាស់សីលដែលប្រព្រឹត្តទៅផ្លូវកាយ ដោយអនូបឃាតៈ ។ ត្រាស់បាតិមោក្ខសីល និងឥន្ទ្រិយសំវរសីល ដោយពាក្យនេះថា* **ចាតិមោក្ខេ ច សំវរោ។** *ត្រាស់អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ដោយមត្តញ្ញុតា ។ ត្រាស់សេនាសនៈ ដែលជាសប្បាយដោយបន្តៈសេនាសនៈ ។ ត្រាស់សមាបត្តិ ៨ ដោយអធិចិត្ត ដោយប្រការដូច្នេះ ។ សិក្ខាទាំង ៣ ឈ្មោះថា ទ្រង់ត្រាស់ហើយ ដោយព្រះគាថានេះឯង ដូច្នេះ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚*

**រឿង បញ្ហារបស់ព្រះអានន្ទត្ថេរ ចប់**

# រឿង ភិក្ខុមិនត្រេកអរ
## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមិនត្រេកអរក្នុងព្រហ្មចរិយមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **ឧ កហាបណវស្សេន** ជាដើម ។

បានឮថា ភិក្ខុនោះបព្វជ្ជាហើយក្នុងសាសនា បានឧបសម្បទាហើយ កាលព្រះឧបជ្ឈាយ៍បញ្ជូនទៅដោយពាក្យថា ចូរអ្នកទៅទីឈ្មោះនោះ ហើយរៀនឧទ្ទេស បានទៅក្នុងទីនោះហើយ ។ កាលនោះ រោគកើតឡើងដល់បិតារបស់លោក ។ បិតានោះប្រាថ្នានឹងឃើញបុត្រ តែមិនមានបុគ្គលណាម្នាក់ដែលអាចហៅបុត្រនោះមកឲ្យបាន ទើបកន្ទក់កន្ទេញព្រោះសេចក្ដីសោកដោយបុត្រនោះឯង ជាអ្នកមានសេចក្ដីស្លាប់ខិតចូលមកដល់ហើយ ទើបផ្ដាំនឹងប្អូនប្រុសថា អ្នកគប្បីធ្វើទ្រព្យនេះឲ្យជាថ្លៃបាត្រ និងចីវរដល់បុត្ររបស់យើង ហើយឲ្យទ្រព្យមួយរយកហាបណៈ ទុកក្នុងដៃប្អូនប្រុស បានធ្វើកាលកិរិយាហើយ ។

ក្នុងកាលដែលភិក្ខុកំលោះមកហើយ ទើបប្អូនប្រុសនោះ ក្រាបចុះទៀបបាតជើងទ្រហោយំបម្រះននៀលទៅមកពោលថា បពិត្រលោកម្ចាស់ ញោមរបស់លោកម្ចាស់ កន្ទក់កន្ទេញធ្វើកាលកិរិយាហើយ បិតានោះបានប្រគល់កហាបណៈមួយរយទុកក្នុងដៃរបស់ខ្ញុំ ខ្ញុំនឹងធ្វើដូចម្ដេចដោយទ្រព្យនោះ ទើបភិក្ខុកំលោះឃាត់ថា អាត្មាមិនត្រូវការដោយកហាបណៈ ក្នុងកាលតមក ទើបគិតថា ប្រយោជន៍អ្វីរបស់អញ ដោយការត្រាច់ទៅបិណ្ឌបាតក្នុងត្រកូលដទៃចិញ្ចឹមជីវិត អញអាចអាស្រ័យកហាបណៈមួយរយនោះចិញ្ចឹមជីវិតបាន អញ

នឹងសឹក ។ ភិក្ខុនោះ ត្រូវសេចក្ដីអផ្សុកបៀតបៀនហើយ ទើបលះនូវការស្វាធ្យាយ និងព្រះកម្មដ្ឋាន បានជាអ្នកមានរោគស្គមលឿង ។ គ្រានោះ ភិក្ខុកំលោះ និងសាមណេរសួរលោកថា តើលោកម្ចាស់កើតអ្វី ព្រះថេរៈឆ្លើយថា ខ្ញុំអផ្សុក ទើបនាំគ្នាប្រាប់ដល់អាចារ្យ និងឧបជ្ឈាយ៍ ។ ពេលនោះ អាចារ្យនិងឧបជ្ឈាយ៍ទាំងនោះ នាំលោកទៅកាន់សម្នាក់របស់ព្រះសាស្ដា បង្ហាញដល់ព្រះសាស្ដាហើយ ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកឬ កាលលោកក្រាបទូលថា ករុណាព្រះអង្គ ទើបទ្រង់ត្រាស់ថា ព្រោះហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ អ្វីជាបច្ច័យនៃការចិញ្ចឹមជីវិតរបស់អ្នកមានឬ ភិក្ខុនោះ ក្រាបទូលថា បពិត្រព្រះអង្គ មាន ព្រះសាស្ដាត្រាស់ថា អ្វីរបស់អ្នកមាន ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ កហាបណៈមួយរយ ។

ព្រះសាស្ដាត្រាស់ថា បើដូច្នោះ ចូរអ្នកនាំដុំក្រួសមកត្រឹមតិចតួច អ្នកសាកល្បងរាប់មើលនឹងដឹងបានថា អ្នកអាចចិញ្ចឹមជីវិតបានដោយកហាបណៈចំនួនប៉ុណ្ណោះឬ ឬមិនអាចចិញ្ចឹមជីវិតបាន ភិក្ខុកំលោះនោះនាំដុំក្រួសមកហើយ ។

ពេលនោះ ទើបព្រះសាស្ដាត្រាស់នឹងភិក្ខុនោះថា ចូរអ្នកដាក់ ៥០ ដើម្បីប្រយោជន៍ដល់គ្រឿងបរិភោគសិន ដាក់ ២៤ ដើម្បីប្រយោជន៍ដល់គោ ២ ដាក់ប៉ុណ្ណោះដើម្បីប្រយោជន៍ដល់ពូជ ដើម្បីប្រយោជន៍នឹម និងនង្គ័ល ដើម្បីប្រយោជន៍ដល់ចប ដើម្បីប្រយោជន៍ដល់កាំបិត និងពូថៅ កាលលោករាប់ដោយអាការយ៉ាងនេះ កហាបណៈមួយរយនោះ រមែងមិនគ្រប់គ្រាន់ ។ គ្រា

នោះ ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ កហាបណៈរបស់អ្នកមានតិច អ្នកអាស្រ័យកហាបណៈទាំងនោះ នឹងឲ្យសេចក្តីត្រូវការពេញបានដូចម្តេច ។ បានឮថា ក្នុងអតីតកាល បណ្ឌិតទាំងឡាយ គ្រប់គ្រងចក្រពត្តិរាជសម្បត្តិ អាចញ៉ាំងភ្លៀង គឺរតនៈ ៧ ឲ្យធ្លាក់ចុះមកត្រឹមចង្កេះ ក្នុងទីប្រមាណ ១២ យោជន៍ ដោយអាការត្រឹមតែទះដៃ សូម្បីគ្រងរាជសម្បត្តិក្នុងទេវលោក អស់ ៣៦ ព្រះឥន្ទ ក្នុងពេលទិវង្គត ក៏មិនញ៉ាំងសេចក្តីប្រាថ្នាឲ្យពេញបានឡើយ បានធ្វើកាលកិរិយាហើយ កាលភិក្ខុនោះអារាធនាហើយ ទ្រង់នាំអតីតនិទានមកញ៉ាំងមន្ធាតុរាជជាតកឲ្យពិស្តារហើយ ក្នុងលំដាប់នៃព្រះគាថានេះថា

ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយ ( ដើរក្រឡឹង ) ភ្នំសិនេរុ
ទិសទាំងឡាយភ្លឺរុងរឿង រហូតទីមានកំណត់ត្រឹមណា សត្វទាំង-
ឡាយណា ដែលអាស្រ័យលើផែនដី សត្វទាំងអស់នោះ ជា
ទាសៈរបស់ស្តេចមន្ធាតុ រហូតទីមានកំណត់ត្រឹមនោះ ។

បានភាសិតគាថា ២ នេះថា

**ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ**
**អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បិណ្ឌិតោ**
**អបិ ទិព្វេសុ កាមេសុ រតឹ សោ នាធិគច្ឆតិ**
**តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។**

ការស្កប់ស្កល់ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះ
កហាបណៈ ( ដែលធ្លាក់ចុះ ) ដូចទេ កាមទាំងឡាយមាន

សុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់យ៉ាងនោះ
ហើយ លោកមិនបានត្រេកអរក្នុងកាមទាំងឡាយ សូម្បី
ជាទិព្វឡើយ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នក
ត្រេកអរក្នុងធម៌ ជាគ្រឿងអស់តណ្ហា ។

## សេចក្ដីអធិប្បាយ

បណ្ដាបទថាទាំងនោះ បទថា **កហាបណវស្សេន** សេចក្ដីថា បណ្ឌិតនោះទះដៃហើយ ញ៉ាំងភ្លៀង គឺរតនៈ ៧ ប្រការឲ្យធ្លាក់ចុះបាន ភ្លៀង គឺរតនៈ ៧ ប្រការនោះ ត្រាស់ឲ្យឈ្មោះថា **កហាបណវស្សំ** ក្នុងព្រះគាថានេះ ឈ្មោះថា ការឆ្អែតក្នុងវត្ថុកាម និងកិលេសកាម រមែងមិនមាន ព្រោះភ្លៀងគឺរតនៈទាំង ៧ ប្រការនោះ ចំណង់នោះពេញបានដោយលំបាកដោយអាការយ៉ាងនេះ ។

បទថា **អប្បស្សាទា** គឺ ឈ្មោះថា មានសុខតិច ព្រោះកាមមានឧបមាដូចយល់សប្តិជាដើម ។

បទថា **ទុក្ខា** គឺ ឈ្មោះថា មានទុក្ខច្រើន ដោយអំណាចនៃទុក្ខដែលនាំមកក្នុងទុក្ខក្ខន្ធសូត្រជាដើម ។

បទថា **ឥតិ វិញ្ញាយ** គឺដឹងកាមទាំងឡាយនោះដោយអាការយ៉ាងនេះ ។

បទថា **អបិ ទិព្វេសុ** សេចក្ដីថា បើបុគ្គលណាគប្បីអញ្ជើញដោយកាមដែលចូលទៅសម្រេចដល់ទេវតាទាំងឡាយយ៉ាងនោះ លោករមែងមិនជួបនូវការត្រេកអរក្នុងកាមនោះឡើយ ដូចព្រះសមិទ្ធិ ត្រូវទេវតាអារាធនាដូច្នោះ ។

បទថា **តណ្ហក្ខយរតោ** សេចក្តីថា ជាអ្នកត្រេកអរក្រៃលែងក្នុងព្រះអរហត្ត និងក្នុងព្រះនិព្វាន គឺប្រាថ្នាអរហត្ត និងព្រះនិព្វាន ។

ភិក្ខុយោគាវចរ កើតក្នុងទីបំផុតនៃការស្តាប់ធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ ឈ្មោះថា ព្រះសាវករបស់ព្រះសម្មាសម្ពុទ្ធ ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ។ ទេសនាមានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

**រឿង ភិក្ខុមិនត្រេកអរ ចប់**

# រឿង អគ្គិទត្តបុរោហិត

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធគង់លើផ្នូកខ្សាច់ ទ្រង់ប្រារព្ធបុរោហិតរបស់ព្រះបាទកោសល ឈ្មោះអគ្គិទត្ត ត្រាស់ព្រះធម្មទេសនានេះថា **ពហុំ វេ សរណំ យន្តិ** ជាដើម ។

បានឮមកថា អគ្គិទត្តនោះបានជាបុរោហិតរបស់ព្រះបាទមហាកោសល កាលព្រះរាជបិតាសោយទិវង្គតហើយ ព្រះរាជាព្រះនាមបសេនទិកោសល ទ្រង់ព្រះតម្រិះថា បុគ្គលនេះជាបុរោហិតនៃព្រះជនករបស់អញ ទើបតាំងទុកក្នុងតំណែងនោះឯងដោយសេចក្តីគោរព ក្នុងកាលបុរោហិតមកកាន់ទីគាល់របស់ព្រះអង្គ ទ្រង់ធ្វើការក្រោកទទួល ត្រាស់ឲ្យព្រះរាជទានអាសនៈស្មើគ្នា

ដោយព្រះតម្រាស់ថា សូមលោកអាចារ្យអង្គុយលើអាសនៈនេះ ។

អគ្គិទត្តនោះគិតថា ព្រះរាជានេះ ទ្រង់ធ្វើសេចក្តីគោរពក្នុងអញយ៉ាងក្រៃលែង តែអញមិនអាចយកចិត្តរបស់ព្រះរាជាទាំងឡាយបាន អស់កាលជានិច្ចឡើយ ម្យ៉ាងទៀត ព្រះរាជានៅក្មេង នៅកំលោះ ឈ្មោះថា ភាពជាព្រះរាជា ដោយបុគ្គលមានវ័យស្មើគ្នានោះឯងជាហេតុឲ្យកើតសុខ ចំណែកអញជាមនុស្សចាស់ អញគួរបួស ។ បុរោហិតក្រាបទូលឲ្យព្រះរាជា ព្រះរាជទានការបួសហើយ ឲ្យមនុស្សវាយស្គរ ត្រាច់ទៅក្នុងព្រះនគរ លះបង់ទ្រព្យរបស់ខ្លួនទាំងអស់ ព្រោះការឲ្យទានជាធំអស់ ៧ ថ្ងៃហើយ បួសជាអ្នកបួសខាងក្រៅព្រះពុទ្ធសាសនា បុរសមួយម៉ឺននាក់អាស្រ័យអគ្គិទត្តនោះបួសតាមហើយ ។ អគ្គិទត្តនោះ មួយអន្លើដោយអ្នកបួសទាំងនោះ សម្រេចការនៅក្នុងរវាងដែនអង្គៈ ដែនមគធៈ និងដែនកុរុ ឲ្យឱវាទថា បាទាំងឡាយបណ្តាអ្នកទាំងឡាយ មានកាមវិតក្កជាដើមកើតឡើង បុគ្គលនោះត្រូវជញ្ជូនខ្សាច់មួយក្អមអំពីស្ទឹង មកគរក្នុងទីនេះ ។ ពួកអ្នកបួសទាំងនោះទទួលថាសាធុ ក្នុងកាលកាមវិតក្កជាដើមកើតឡើងហើយ ក៏ធ្វើយ៉ាងនោះ ។ ដោយសម័យដទៃទៀត មានគំនរខ្សាច់ធំហើយ ។ នាគរាជឈ្មោះអហិច្ឆត្តហួងហែងគំនរខ្សាច់ធំនោះ អ្នកអង្គៈ អ្នកមគធៈ និងអ្នកកុរុ នាំគ្រឿងសក្ការៈជាច្រើនទៅប្រគេនដល់អ្នកបួសទាំងនោះរៀងរាល់ខែ ។

គ្រានោះ អគ្គិទត្តបានឲ្យឱវាទដល់ជនទាំងនោះដូច្នេះថា ចូរពួកអ្នកយកភ្នំជាសរណៈ ចូរយកព្រៃជាសរណៈ ចូរយកអារាមជាសរណៈ ចូរដល់ដើម

ឈើជាសរណៈ ពួកអ្នកនឹងផុតចាកទុក្ខទាំងអស់បាន ដោយអាការយ៉ាងនេះ ពោលទូន្មានដល់អន្តេវាសិករបស់ខ្លួនដោយឱវាទនេះដូចគ្នា ។

ចំណែកព្រះពោធិសត្វ យាងចេញមហាភិនេស្រ្កមណ៍ ទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណហើយ ក្នុងសម័យនោះ ទ្រង់អាស្រ័យក្រុងសាវត្ថី គង់ប្រថាប់នៅក្នុងវត្តជេតពន ក្នុងកាលទៀបភ្លឺ ទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញអគ្គិទត្តព្រាហ្មណ៍ មួយអន្លើដោយអន្តេវាសិក ចូលក្នុងសំណាញ់ញាណរបស់ទ្រង់ហើយ ទ្រង់ជ្រាបថា ជនទាំងអស់នេះជាអ្នកដល់ព្រមដោយឧបនិស្ស័យនៃអរហត្ត ក្នុងពេលល្ងាច ត្រាស់នឹងមហាមោគ្គល្លានថា ម្នាលមោគ្គល្លាន អ្នកឃើញអគ្គិទត្តព្រាហ្មណ៍ ញុំាងមហាជនឲ្យស្ទុះទៅក្នុងទីដែលមិនមែនផ្លូវដែរឬទេ ចូរអ្នកទៅឲ្យឱវាទដល់មហាជនទាំងនោះ ។

ព្រះថេរៈទូលថា បពិត្រព្រះអង្គ ជនទាំងនោះច្រើន ខ្ញុំព្រះអង្គម្នាក់ឯងសង្កត់សង្កិនមិនបានឡើយ បើទ្រង់យាងមកសោត ជនទាំងនោះគប្បីសង្កត់សង្កិនបាន ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន តថាគតនឹងទៅ ចូរអ្នកទៅមុនចុះ ។

ព្រះថេរៈនិមន្តទៅបណ្តើរ គិតបណ្តើរថា ជនទាំងនោះ មានកម្លាំងផងច្រើនផង បើអាត្មាអញពោលពាក្យណាមួយ ក្នុងទីប្រជុំរបស់ជនទាំងពួងសោត ជនទាំងនោះ គប្បីក្រោកឡើងជាពួកៗ ញុំាងភ្លៀងតំណក់ធំៗ ឲ្យធ្លាក់ចុះ និងនាំគ្នាក្រោកឡើងហើយ ទៅកាន់បណ្ណសាលារៀងៗ ខ្លួន ។ ព្រះថេរៈឈរត្រង់ទ្វារបណ្ណសាលារបស់អគ្គិទត្ត ពោលថា អគ្គិទត្ត ។ គាត់បាន

ឮសំឡេងរបស់ព្រះថេរៈហើយ ពោលថា នុ៎ះជាអ្នកណា ព្រោះភាពជាអ្នករឹងត្អឹងដោយមានះថា ក្នុងលោកនេះ បុគ្គលណាម្នាក់ ដែលអាចហៅអញដោយឈ្មោះមិនមាន អ្នកណាហ្ន៎ហៅអញ ដោយចេញឈ្មោះ ព្រះថេរៈពោលថា ម្នាលព្រាហ្មណ៍ គឺអាត្មា អគ្គិទត្តពោលថា លោកម្ចាស់ពោលអ្វី ព្រះថេរៈពោលថា សូមលោកប្រាប់ទីសម្រាកក្នុងទីនេះ ដល់ខ្ញុំមួយរាត្រី ក្នុងថ្ងៃនេះ ។ អគ្គិទត្តពោលថា ទីសម្រាកក្នុងទីនេះមិនមាន បណ្ណសាលាមួយសម្រាប់មនុស្សម្នាក់ប៉ុណ្ណោះ ព្រះថេរៈពោលថា អគ្គិទត្ត ធម្មតា ពួកមនុស្សរមែងទៅកាន់សម្នាក់របស់ពួកមនុស្ស ពួកគោក៏ទៅកាន់សម្នាក់របស់ពួកគោ ពួកបព្វជិតក៏ទៅកាន់សម្នាក់របស់ពួកបព្វជិត លោកកុំធ្វើយ៉ាងនោះ ចូរឲ្យទីសម្រាកដល់ខ្ញុំ អគ្គិទត្តពោលថា លោកម្ចាស់ជាបព្វជិតឬ ព្រះថេរៈពោលថា អើខ្ញុំជាបព្វជិត អគ្គិទត្តពោលថា បើលោកម្ចាស់ជាបព្វជិតសោត របស់របរគឺសង្រែក បរិក្ខារនៃបព្វជិតរបស់លោកម្ចាស់នៅឯណា ព្រះថេរៈពោលថា បរិក្ខាររបស់ខ្ញុំមាន ខ្ញុំគិតឃើញថា ការកាន់បរិក្ខារនោះជាផ្នែក ត្រាច់ទៅលំបាក ដូច្នេះហើយ ទើបទុកដាក់បរិក្ខារនោះខាងក្នុងនោះឯងត្រាច់ទៅ ។

ព្រាហ្មណ៍ក្រោធនឹងព្រះថេរៈពោលថា លោកម្ចាស់កាន់បរិក្ខារនោះត្រាច់ទៅឬ លំដាប់នោះ ទើបព្រះថេរៈពោលថា អគ្គិទត្ត អ្នកកុំក្រោធ ចូរប្រាប់ទីសម្រាកដល់ខ្ញុំ អគ្គិទត្តពោលថា ទីសម្រាកក្នុងទីនេះមិនមាន ព្រះថេរៈសួរថា ចុះនរណានៅលើគំនរខ្សាច់នោះ អគ្គិទត្តពោលថា នាគរាជមួយ ព្រះថេរៈពោលថា ចូរឲ្យទីនោះដល់ខ្ញុំ អគ្គិទត្តពោលថា ខ្ញុំមិនអាចឲ្យបានទេ កម្មរបស់នាគ-

រាជនោះកាចសាហាវ ព្រះថេរៈពោលថា ណ្ហើយចុះ ចូរឲ្យដល់ខ្ញុំចុះ អគ្គិទត្ត ពោលថា បើយ៉ាងនោះ ចូរលោកដឹងឯងចុះ ។

ព្រះថេរៈបែរមុខតម្រង់ទៅកាន់គំនរខ្សាច់ហើយ នាគរាជឃើញព្រះថេរៈនោះមក ទើបត្រិះរិះថា សមណៈនេះមកខាងនេះ ប្រហែលជាមិនដឹងភាពដែលអញមាន អញនឹងបង្ហុយផ្សែងឲ្យសមណៈនោះស្លាប់ បង្ហុយផ្សែងហើយ ។

ព្រះថេរៈគិតថា នាគនេះប្រហែលជាយល់ថា អញប៉ុណ្ណោះ អាចបង្ហុយផ្សែងបាន ជនដទៃមិនអាច ដូច្នេះហើយ បង្ហុយផ្សែងឯង ។ ផ្សែងទាំងឡាយដែលផ្សាយចេញអំពីសរីរៈនៃនាគរាជ និងព្រះថេរៈទាំងពីរចំណែក តាំងឡើងរហូតដល់ព្រហ្មលោក ។ ផ្សែងទាំងពីរចំណែក មិនបៀតបៀនព្រះថេរៈ បៀតបៀនតែនាគរាជមួយចំណែក ។ នាគរាជមិនអាចអត់ធន់នឹងកម្លាំងផ្សែងបាន ទើបឲ្យឆេះជាភ្លើង ព្រះថេរៈចូលសមាបត្តិ មានតេជោធាតុជាអារម្មណ៍ហើយ ឲ្យឆេះជាភ្លើងព្រមជាមួយនាគរាជនោះដូចគ្នា ។ ភ្លើងផ្សាយឡើងរហូតដល់ព្រហ្មលោក ។ អណ្តាតភ្លើងទាំងពីរចំណែក មិនបៀតបៀនព្រះថេរៈ បៀតបៀនតែនាគរាជមួយចំណែក ។

លំដាប់នោះ សរីរៈទាំងមូលរបស់នាគរាជនោះ ហាក់ដូចជាត្រូវគប់ភ្លើងទាំងឡាយរោលពេញខ្លួនហើយ ។ ពួកឥសីសម្លឹងមើលហើយគិតថា នាគរាជដុតសមណៈ សមណៈមនុស្សល្អឬហ្ន៎ មិនជឿពាក្យរបស់អញ ទើបវិនាសហើយ ។

ព្រះថេរៈទូន្មាននាគរាជ ធ្វើឲ្យអស់ឫទ្ធិពិសហើយ អង្គុយលើពំនូកខ្សាច់

នាគរាជយករង្វេលព័ន្ធគំនរខ្សាច់ បើកពពារប្រមាណប៉ុនផ្ទះកំពូល បាំងខាងលើព្រះថេរៈ ។ ពួកឥសីទៅកាន់សម្នាក់របស់ព្រះថេរៈអំពីព្រលឹម ដោយគិតថា ពួកយើងនឹងដឹងភាពដែលសមណៈស្លាប់ឬមិនស្លាប់ ឃើញលោកអង្គុយលើគំនរខ្សាច់ហើយ ផ្គងអញ្ជលីសរសើរពោលថា សមណៈ នាគរាជមិនបៀតបៀនលោកម្ចាស់ទេឬ ព្រះថេរៈពោលថា អ្នកទាំងឡាយមិនឃើញនាគរាជបើកពពារខាងលើខ្ញុំទេឬ ឥសីទាំងនោះពោលថា គួរអស្ចារ្យហ្ន៎ អានុភាពនៃសមណៈបែបនេះ សមណៈនេះទូន្មាននាគបានហើយ បានឈរជុំជិតព្រះថេរៈ ។

ខណៈនោះ ព្រះសាស្តាយាងមកហើយ ព្រះថេរៈឃើញព្រះសាស្តាហើយក្រោកឡើងថ្វាយបង្គំ ។ លំដាប់នោះ ឥសីទាំងឡាយពោលនឹងព្រះថេរៈថា សមណៈនេះជាធំជាងលោកម្ចាស់ឬ ព្រះថេរៈពោលថា ព្រះដ៏មានព្រះភាគអង្គនោះជាព្រះសាស្តា ខ្ញុំជាសាវ័ករបស់ព្រះដ៏មានព្រះភាគអង្គនោះ ។

ព្រះសាស្តា ប្រថាប់គង់លើពំនូកខ្សាច់ហើយ ។ ពួកឥសីផ្គងអញ្ជលីសរសើរព្រះសាស្តាថា អានុភាពរបស់សាវ័កដល់ម្ល៉េះ តើអានុភាពរបស់ព្រះសាស្តា យ៉ាងណាទៅហ្ន៎ ។

ព្រះសាស្តា ត្រាស់ហៅអគ្គិទត្តមកហើយត្រាស់ថា ម្នាលអគ្គិទត្ត អ្នកកាលឲ្យឱវាទដល់សាវ័ក និងឧបដ្ឋាកទាំងឡាយរបស់អ្នក រមែងឲ្យដូចម្តេច អគ្គិទត្តពោលថា ខ្ញុំព្រះអង្គឲ្យឱវាទដល់សាវ័ក និងឧបដ្ឋាកទាំងនោះយ៉ាងនេះថា ចូរអ្នកទាំងឡាយដល់ភ្នំថាជាទីពឹង ចូរដល់ព្រៃ អារាម ចូរដល់ដើមឈើថាជាទីពឹង ព្រោះថាបុគ្គលដល់វត្ថុទាំងឡាយ មានភ្នំជាដើមនោះជាទីពឹងហើយ

រមែងផុតចាកទុក្ខទាំងពួងបាន ។

ព្រះសាស្តាត្រាស់ថា ម្នាលអគ្គិទត្ត បុគ្គលដល់នូវវត្ថុទាំងឡាយ មានភ្នំជាដើមនោះថាជាទីពឹងហើយ រមែងមិនផុតចាកទុក្ខបានឡើយ ចំណែកបុគ្គលដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃថាជាទីពឹង រមែងផុតចាកទុក្ខក្នុងវដ្តៈទាំងមូលបាន ដូច្នេះហើយ បានភាសិតព្រះគាថាទាំងឡាយថា

**ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច**
**អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា**
**នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ**
**នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ**
**យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ**
**ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ**
**ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ**
**អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ**
**ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ**
**ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។**

មនុស្សទាំងឡាយច្រើននាក់ ត្រូវភ័យគំរាមហើយ តែងយកភ្នំ អារាម និងរុក្ខចេតិយជាទីពឹង ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលអាស្រ័យនូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ លុះតែបុគ្គលណាយក

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង ឃើញច្បាស់នូវ
អរិយសច្ចទាំង ៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១
និរោធសច្ចកន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជា
ដំណើរទៅកាន់ព្រះនិព្វាន ដែលជាទីរម្ងាប់ទុក្ខ ១ ដោយ
ប្រាជ្ញាដ៏ប្រពៃ នេះឯងជាទីពឹងដ៏ក្សេម នេះឯងជាទីពឹង
ដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាក
ទុក្ខទាំងពួងបាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ពហុំ** បានដល់ **ពហូ** ប្រែថា ច្រើន ។ បទថា **បព្វតានិ** ជាដើម សេចក្តីថា មនុស្សទាំងនោះ ដែលភ័យនោះៗ គំរាមហើយ ចង់ផុតចាកភ័យ ឬប្រាថ្នាលាភទាំងឡាយ មានការបានបុត្រជាដើម រមែងដល់ភ្នំ មានភ្នំឥសិគិលិ ភ្នំវេបុល និងភ្នំវេភារៈជាដើម ព្រៃទាំងឡាយ មានព្រៃមហាវន ព្រៃគោសិង្គសាលវនជាដើម អារាមទាំងឡាយ មានវេឡុវន និងជីវកម្ពវនជាដើម និងរុក្ខចេតិយទាំងឡាយ មានឧទេនចេតិយ និងគោតមចេតិយជាដើម ក្នុងទីនោះៗ ថាជាទីពឹង ។

ពីរបទថា **នេតំ សរណំ** សេចក្តីថា សរណៈទាំងអស់នោះ មិនក្សេម មិនឧត្តម ព្រោះថា បណ្តាសត្វទាំងឡាយដែលមានការកើតជាដើម ជាធម្មតា សូម្បីបុគ្គលម្នាក់ អាស្រ័យសរណៈនោះ រមែងមិនផុតចាកទុក្ខទាំងពួង មានជាតិជាដើមបានឡើយ ។

ពាក្យថា **យោ ច** ជាដើមនេះ ព្រះសាស្ដាទ្រង់សំដែងសរណៈដែលមិនក្សេម មិនឧត្ដមហើយ ប្រារព្ធដើម្បីសំដែងសរណៈដ៏ក្សេម ដ៏ឧត្ដម ។

អត្ថនៃពាក្យថា **យោ ច** ជាដើមនោះ ដូចតទៅនេះថា ចំណែកបុគ្គលណា ជាគ្រហស្ថក្ដី ជាបព្វជិតក្ដី អាស្រ័យកម្មដ្ឋាន គឺការតាមរឭកដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាដើមថា ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្ត-សម្មាសម្ពុទ្ធ ព្រោះហេតុយ៉ាងនេះ ដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃថាជាទីពឹង ដោយអំណាចនៃភាពជាវត្ថុដ៏ប្រសើរ ការដល់សរណៈនោះ របស់បុគ្គលនោះ នៅកម្រើក នៅញាប់ញ័រដោយកិច្ចទាំងឡាយ មានការថ្វាយបង្គំតិរ្ថិយជាដើម ។ តែព្រះសាស្ដា ដើម្បីទ្រង់សំដែងការដល់សរណៈដែលមិនញាប់ញ័រនោះ កាលទ្រង់ប្រកាសសរណៈ ដែលមកហើយដោយមគ្គនោះឯង ទើបត្រាស់ថា រមែងឃើញអរិយសច្ច ៤ ដោយបញ្ញាប្រពៃ ព្រោះថាបុគ្គលណាដល់រតនៈទាំងឡាយ មានព្រះពុទ្ធរតនៈជាដើមនោះ ថាជាទីពឹងដោយអំណាចនៃការឃើញសច្ចៈទាំងនោះ សរណៈនោះ របស់បុគ្គលនោះក្សេម និងឧត្ដមបុគ្គលនោះ អាស្រ័យសរណៈនោះ រមែងផុតចាកទុក្ខក្នុងវដ្ដៈបាន ព្រោះហេតុនោះ ទើបព្រះសាស្ដាត្រាស់ថា **ឯតំ ខោ សរណំ ខេមំ** ជាដើម ។

ក្នុងកាលចប់ទេសនា ឥសីទាំងអស់សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយហើយ ថ្វាយបង្គំព្រះសាស្ដា ទូលសូមបព្វជ្ជាហើយ ។

ព្រះសាស្ដា ទ្រង់លាព្រះហស្ដចេញអំពីស្រទាប់ចីវរត្រាស់ថា ចូរអ្នក

ទាំងឡាយមកជាភិក្ខុចុះ ចូរប្រព្រឹត្តព្រហ្មចរិយៈ ។

ខណៈនោះឯង ឥសីទាំងនោះបានជាអ្នកទ្រទ្រង់នូវបរិក្ខារ ៨ ដូចព្រះថេរៈមានវស្សា ១០០ ។ ថ្ងៃនោះជាថ្ងៃដែលអ្នកដែនអង្គៈ ដែនមគធៈ និងដែនកុរុទាំងពួង កាន់នូវគ្រឿងសក្ការៈមក ។ ជនទាំងនោះកាន់គ្រឿងសក្ការៈមកហើយ ឃើញឥសីទាំងនោះបួសហើយគិតថា អគ្គិទត្តព្រាហ្មណ៍របស់ពួកយើងជាធំ ឬព្រះសមណគោតមជាធំហ្ន៎ បានសម្គាល់ថាអគ្គិទត្តជាធំ ព្រោះហេតុដែលព្រះសមណគោតមមករក ។

ព្រះសាស្តា ទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់ជនទាំងនោះ ហើយត្រាស់ថា អគ្គិទត្ត ចូរអ្នកកាត់សេចក្តីសង្ស័យរបស់បរិស័ទ ។ អគ្គិទត្តនោះក្រាបទូលថា ខ្ញុំព្រះអង្គក៏ទន្ទឹងហេតុមានប្រមាណប៉ុណ្ណោះដូចគ្នា ដូច្នេះហើយហោះទៅកាន់អាកាសដោយកម្លាំងឫទ្ធិ ហើយចុះមកថ្វាយបង្គំព្រះសាស្តារឿយៗអស់ ៧ ដងហើយ ពោលប្រកាសភាពដែលខ្លួនជាសាវកថា បពិត្រព្រះអង្គព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវកដូច្នេះឯង ។៚

**រឿង អគ្គិទត្តបុរោហិត ចប់**

# រឿង បញ្ហារបស់ព្រះអានន្ទត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ទុល្លភោ បុរិសាជញ្ញោ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃ គិតថា ព្រះសាស្តាកាលត្រាស់ពាក្យថា ដំរីអាជានេយ្យកើតឡើងក្នុងត្រកូលដំរីឆទ្ទន្ត ឬក្នុងត្រកូលដំរីឧបោសថ សេះអាជានេយ្យកើតក្នុងត្រកូលសេះសិន្ធព ឬត្រកូលសេះវលាហក គោអាជានេយ្យ កើតក្នុងទក្ខិណាបថជនបទជាដើម ជាការត្រាស់ទីកើតឡើងនៃសត្វដ៏ប្រសើរ មានដំរីអាជានេយ្យជាដើមហើយ ចំណែកបុរសអាជានេយ្យ រមែងកើតឡើងក្នុងទីណាហ្ន៎ ។

ព្រះថេរៈចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយទូលសួររឿងនោះ ព្រះសាស្តាត្រាស់ថា អានន្ទ ឈ្មោះថាបុរសអាជានេយ្យ រមែងមិនកើតក្នុងទីទូទៅ តែកើតឡើងក្នុងទីដែលជាមជ្ឈិមប្រទេស វាស់ដោយបណ្តោយ ៣០០ យោជន៍ ដោយជុំវិញ ៩០០ យោជន៍ កាលកើតឡើង ក៏រមែងមិនកើតឡើងក្នុងត្រកូលសាមញ្ញ រមែងកើតឡើងក្នុងត្រកូលខត្តិយមហាសាល និងព្រាហ្មណមហាសាល ត្រកូលណាមួយប៉ុណ្ណោះ ដូច្នេះហើយ ត្រាស់គាថានេះថា

**ទុល្លភោ បុរិសាជញ្ញោ ន សោ សព្វត្ថ ជាយតិ**
**យត្ថ សោ ជាយតី ធីរោ តំ កុលំ សុខមេធតិ ។**

បុរសអាជានេយ្យ រកបានដោយកម្រ លោកមិនកើតក្នុង
សព្វស្ថានឡើយ លោកជាអ្នកមានប្រាជ្ញា កើតក្នុងត្រកូល

ណា ត្រកូលនោះ តែងដល់នូវសេចក្ដីសុខ ។

# សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **ទុល្លភោ** ជាដើម សេចក្ដីថា បុរសអាជានេយ្យ ជាបុគ្គលដែលរកបានដោយកម្រ គឺមិនរកបានងាយដូចដំរីអាជានេយ្យជាដើមឡើយ ។ បុរសអាជានេយ្យនោះ រមែងមិនកើតក្នុងទីទូទៅ ក្នុងបច្ចន្តប្រទេស ឬក្នុងត្រកូលទាបឡើយ តែរមែងកើតក្នុងត្រកូលណាមួយ បណ្ដាត្រកូលក្សត្រ និងត្រកូលព្រាហ្មណ៍ ក្នុងទីដែលជាទីធ្វើសក្ការៈ មានអភិវាទជាដើមនៃមហាជនក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ បុរសអាជានេយ្យនោះជាអ្នកប្រាជ្ញ គឺជាអ្នកមានបញ្ញាដ៏ឧត្ដម បានដល់ ព្រះសម្មាសម្ពុទ្ធ ដែលទឹងកើតយ៉ាងនោះ រមែងកើតក្នុងត្រកូលណាមួយនោះ រមែងដល់នូវសេចក្ដីសុខ គឺរមែងជាត្រកូលដែលសម្រេចសេចក្ដីសុខពិត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង បញ្ហារបស់ព្រះអានន្ទ ចប់**

# រឿង សម្ពហុលភិក្ខុ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសន្ទនារបស់ភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **សុខោ ពុទ្ធានមុប្បាទោ** ជាដើម ។

សេចក្ដីពិស្ដារថា ថ្ងៃមួយ ភិក្ខុ ៥០០ អង្គុយក្នុងសាលាជាទីទំនុកបម្រុងសន្ទនាគ្នាថា អាវុសោទាំងឡាយ អ្វីហ្ន៎ជាសុខក្នុងលោកនេះ ។

បណ្ដាភិក្ខុទាំងនោះ ពួកខ្លះពោលថា ឈ្មោះថា សុខ ដូចគ្នានឹងសុខក្នុងរាជសម្បត្តិមិនមាន ពួកខ្លះពោលថា ឈ្មោះថា សុខ ដូចគ្នានឹងសុខក្នុងកាមរមែងមិនមាន ពួកខ្លះពោលថា ឈ្មោះថា សុខ ដូចគ្នានឹងសុខដែលកើតអំពីការបរិភោគស្រូវសាលី និងសាច់ មិនមាន ។

ព្រះសាស្ដាយាងមកកាន់ទីដែលភិក្ខុទាំងនោះអង្គុយហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយពាក្យឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលអ្វី សេចក្ដីសុខទាំងអស់នេះទាក់ទងដោយទុក្ខក្នុងវដ្ដៈទាំងអស់ តែហេតុនេះប៉ុណ្ណោះ គឺការកើតឡើងនៃព្រះពុទ្ធ ការស្ដាប់ធម៌ ការព្រមព្រៀងរបស់ពួកគណៈ ភាពជាអ្នកត្រូវរ៉ូវគ្នា ជាសុខក្នុងលោកនេះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**
**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។**

ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ការសម្តែងព្រះសទ្ធម្ម ជាសុខ សេចក្តីព្រមព្រៀងគ្នាជាពួក ជាសុខ តបធម៌របស់បុគ្គលអ្នកព្រមព្រៀងគ្នាទាំងឡាយ ជាសុខ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ពុទ្ធានមុប្បាទោ** សេចក្តីថា ព្រះពុទ្ធទាំងឡាយ កាលកើតឡើងរមែងញ៉ាំងមហាជនឲ្យឆ្លងកន្តារទាំងឡាយ មានរាគកន្តារជាដើម ហេតុណា ហេតុនោះការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ទើបឈ្មោះថាជាហេតុនាំមកនូវសុខ ។ សត្វទាំងឡាយដែលមានទុក្ខ មានជាតិជាដើមជាសភាវៈ អាស្រ័យការសម្តែងធម៌របស់សប្បុរស រមែងផុតចាកទុក្ខទាំងឡាយមានជាតិជាដើម ហេតុណា ហេតុនោះ ទើបការសម្តែងធម៌របស់សប្បុរសឈ្មោះថាជាហេតុនាំសុខមក ។ ភាពជាអ្នកមានចិត្តស្មើគ្នា ឈ្មោះថាសាមគ្គី ។ សាមគ្គីនោះក៏ឈ្មោះថាជាហេតុនាំសុខមកដោយពិត ម្យ៉ាងទៀត ការរៀនព្រះពុទ្ធវចនៈក្តី ការរក្សាធុតង្គទាំងឡាយក្តី ការធ្វើសមណធម៌ក្តីរបស់ពួកជនដែលព្រមព្រៀងគ្នា គឺមានចិត្តតែមួយ ជាហេតុនាំសុខមក ហេតុណា ហេតុនោះទើបព្រះសាស្តាត្រាស់ថា **សមគ្គានំ តបោ សុខោ** ព្រោះហេតុនោះឯង ទើបព្រះសាស្តាត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រជុំគ្នារឿយៗ
ប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាល
ភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដ

ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ (អស់

កាលត្រឹមណោះ) ។

ក្នុងកាលចប់ទេសនា ភិក្ខុជាច្រើនតាំងនៅក្នុងអរហត្តផលហើយ ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។៚

**រឿង សម្ពហុលភិក្ខុ ចប់**

# រឿង ព្រះចេតិយមាសរបស់ព្រះកស្សបទសពល

## លំនាំដើម

ព្រះបរមសាស្តា កាលទ្រង់ចារិកទៅ ទ្រង់ប្រារព្ធព្រះចេតិយមាសរបស់ព្រះកស្សបទសពល ទើបត្រាស់ព្រះធម្មទេសនានេះថា **បូជារហោ** ជាដើម ។

សេចក្ដីពិស្ដារថា ព្រះតថាគតមានមហាភិក្ខុសង្ឃជាពុទ្ធបរិវារ យាងចេញអំពីនគរសាវត្ថី ទៅកាន់នគរពារាណសីដោយលំដាប់ ដល់ទេវស្ថានមួយកន្លែងក្នុងទីជិតស្រុកតោទេយ្យគាម ក្នុងរវាងផ្លូវ ព្រះសុគតបានប្រថាប់ក្បែរទេវស្ថាននោះ ទ្រង់បញ្ជូនព្រះធម្មភណ្ឌាគារិក គឺព្រះអានន្ទ ឲ្យប្រាប់ព្រាហ្មណ៍ដែលកំពុងធ្វើកសិកម្មក្នុងទីមិនឆ្ងាយមកគាល់ ។ ព្រាហ្មណ៍នោះមកហើយ មិនអភិវាទដល់ព្រះតថាគត ថ្វាយបង្គំទេវស្ថានតែម្យ៉ាង ហើយឈរនៅ ។ ព្រះសុគតក៏ត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកសម្គាល់ប្រទេសនេះថាជាអ្វី ទើបព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គថ្វាយបង្គំដោយតាំងចិត្ត

ថា ទីនេះជាចេតិយដ្ឋានតាមប្រពៃណីរបស់ពួកខ្ញុំព្រះអង្គ ។ ទើបព្រះសុគត ឲ្យព្រាហ្មណ៍នោះត្រេកអរថា ម្នាលព្រាហណ៍ អ្នកថ្វាយបង្គំទីស្ថាននេះបានធ្វើកម្មល្អហើយ ។ ភិក្ខុទាំងឡាយបានស្តាប់ព្រះពុទ្ធតម្រាស់នោះហើយ ទើបកើតសេចក្តីសង្ស័យឡើងថា ព្រះសាស្តាទ្រង់ឲ្យព្រាហ្មណ៍ត្រេកអរយ៉ាងនេះដោយហេតុអ្វីហ្ន៎ ។ លំដាប់នោះ ព្រះតថាគតដើម្បីដោះសេចក្តីសង្ស័យរបស់ភិក្ខុទាំងនោះ ទើបត្រាស់ទេសនាឃដិកាសូត្រ ក្នុងមជ្ឈិមនិកាយ ហើយទ្រង់និម្មិតព្រះចេតិយមាសរបស់ព្រះកស្សបទសពលកម្ពស់ ១ យោជន៍ និងចេតិយមាសមួយទៀតក្នុងអាកាស ទ្រង់បង្ហាញឲ្យមហាជនឃើញហើយ ត្រាស់ថា ម្នាលព្រាហ្មណ៍ ការបូជានូវបុគ្គលដែលគួរបូជាបែបនេះ រមែងសមគួរពិត ដូច្នេះហើយ ទើបទ្រង់ប្រកាសបូជារហបុគ្គល ៤ ពួក មានព្រះពុទ្ធជាដើម ដោយន័យដូចបានត្រាស់ក្នុងមហាបរិនិព្វានសូត្រនោះឯង ហើយទ្រង់សម្តែងដោយពិសេសដល់ចេតិយ ៣ គឺសរីរចេតិយ ១ ឧទ្ទិសចេតិយ ១ បរិភោគចេតិយ ១ ហើយបានភាសិតព្រះគាថាថា

**បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ**
**បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេ**
**តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ**
**ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។**

កាលបុគ្គលបូជា ដល់បូជារហបុគ្គល គឺព្រះពុទ្ធ ឬសាវករបស់ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្តីសោក

និងខ្សឹកខ្សួល ឬកាលបូជាដល់បូជារហបុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពីទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាម្នាក់ មិនអាចរាប់បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណេះបានឡើយ ។

## សេចក្តីអធិប្បាយ

បុគ្គលគួរបូជា ឈ្មោះថា **បូជារហា** ក្នុងព្រះគាថានោះ ។ បទថា **បូជារហេ បូជយតោ** សេចក្តីថា បុគ្គលបូជាដោយការឱនលំទោន មានការក្រាបថ្វាយបង្គំជាដើម និងដោយបច្ច័យ ៤ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងបូជារហបុគ្គលដោយពាក្យថា **ពុទ្ធេ** ។ បទថា **ពុទ្ធេ** បានដល់ ព្រះសម្មាសម្ពុទ្ធ ។ និបាតសព្ទថា **យទិ** បានដល់ **យទិវា** អធិប្បាយថា **អថវា** ។ សូម្បីព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ឈ្មោះថា ត្រាស់ហើយក្នុងព្រះគាថានោះ ឬសាវកទាំងឡាយផងដែរ ។ បទថា **បបញ្ចសមតិក្កន្តេ** សេចក្តីថា បបញ្ចធម៌ គឺតណ្ហា ទិដ្ឋិ មានះ លោកឈានកន្លងបានហើយ ។ បទថា **តិណ្ណសោកបរិទ្ទវេ** បានដល់ ជាអ្នកមានសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលដែលកន្លងផុតហើយ អធិប្បាយថា ឆ្លងផុតបានទាំងពីរយ៉ាង ។ ភាពជាបុគ្គលគួរដល់ការបូជា ព្រះសាស្តាត្រាស់ដោយបទវិសេសនៈទាំងនោះ ។ បទថា **តេ** បានដល់ ព្រះពុទ្ធជាដើម ។ បទថា **តាទិសេ** បានដល់ បុគ្គលប្រកបដោយគុណបែបនោះ ដោយអំណាចនៃគុណដូចពោលហើយ ។ បទថា **និព្វុតេ** បានដល់ និព្វានដោយការរម្ងាត់កិលេស មានរាគៈជាដើម ។ ភ័យអំពីទីណា

មួយ គឺចាកកព ឬចាកអារម្មណ៍ រមែងមិនមានដល់បុគ្គលដែលគួរបូជាទាំង នោះ ដូច្នោះ ទើបលោកទាំងនោះ ឈ្មោះថា មិនមានភ័យអំពីទីណាមួយ ។ នូវលោកជាអ្នកមិនមានភ័យអំពីទីណាទាំងនោះ ។ បទថា **ន សក្កា បុញ្ញំ សង្ខាតុំ** សេចក្ដីថា មិនអាចគណនាបុណ្យបាន បើមានពាក្យសួរជ្រៀតចូល មកថា រាប់ដូចម្ដេច គប្បីឆ្លើយថា ដែលបុគ្គលណាម្នាក់មិនអាចរាប់ថាបុណ្យ នេះ មានប្រមាណប៉ុណ្ណេះ អធិប្បាយថា ដែលបុគ្គលណាម្នាក់ មិនអាចរាប់ថា បុណ្យនេះ មានប្រមាណប៉ុណ្ណេះ បុណ្យនេះ មានប្រមាណប៉ុណ្ណេះ ។ **អបិ** សព្ទ គប្បីភ្ជាប់ក្នុងបទថា **កេនចិ** អធិប្បាយថា ដែលបុគ្គលណាម្នាក់ ឬ ដោយរាប់វិធីណាមួយ ។ ក្នុងពាក្យពីរនោះ ពាក្យថា ដែលបុគ្គលណាម្នាក់ បានដល់ ដែលបុគ្គលមានព្រះព្រហ្មជាដើម ។ ពាក្យថា ដោយការរាប់ បាន ដល់ ដោយការរាប់ ៣ យ៉ាង គឺដោយការគណនា ដោយការថ្លឹង ដោយ ការវាល់ ។ ការរាប់ចំនួនដោយន័យថា របស់នេះមានប្រមាណប៉ុណ្ណេះ ឈ្មោះ ថា គណនា ការថ្លឹងដោយជញ្ជីង ឈ្មោះថា ថ្លឹង ការធ្វើឲ្យពេញដោយ អំណាចនៃកន្ទះទូកដៃ មួយទូកដៃ មួយកម្បង់ និងមួយនាឡិជាដើម ឈ្មោះ ថា វាល់ ដែលបុគ្គលណាម្នាក់ មិនអាចរាប់បុណ្យរបស់បុគ្គលដែលបូជានូវ បុគ្គលដែលគួរបូជា មានព្រះពុទ្ធជាដើម ដោយការរាប់ ៣ យ៉ាងនេះ ដោយ អំណាចនៃវិបាក គឺផល ព្រោះវៀរចាកទីបំផុត ដូច្នេះ ។

ផលរបស់អ្នកបូជាក្នុងស្ថានទាំងពីរដូចម្ដេច បុណ្យរបស់បុគ្គលដែលបូជា ព្រះពុទ្ធជាដើមដែលគង់ព្រះជន្ម បុគ្គលណាម្នាក់មិនអាចរាប់បាន ក៏ល្មមធ្វើតាម

សមគួរ ។ បុណ្យរបស់បុគ្គលដែលបូជាព្រះពុទ្ធជាដើមបែបនោះ សូម្បីនិព្វាន ហើយ ដោយខន្ធបរិនិព្វាន ដែលមានកិលេសបរិនិព្វានជានិមិត្ត បុគ្គលណា ម្នាក់ក៏មិនអាចរាប់បាន ព្រោះដូច្នោះ គួរផ្សេងគ្នាខ្លះ ព្រោះហេតុនោះ នឹង មានសេចក្ដីសង្ស័យនោះឯង ទើបសក្កទេវរាជពោលក្នុងវិមានវត្ថុថា

កាលព្រះតថាគតស្ថិតនៅក្ដី បរិនិព្វានទៅក្ដី បើតាំងចិត្តស្មើ
ផលក៏ស្មើ ដ្បិតថា សត្វទាំងឡាយ មានការតម្កល់ចិត្តជាហេតុ
ទើបទៅកាន់សុគតិបាន ដូច្នេះ ។

ក្នុងអាវសាននៃព្រះធម្មទេសនា ព្រាហ្មណ៍នោះ បានជាព្រះសោតា-បន្នហើយ ។

ព្រះចេតិយមាសកម្ពស់ ១ យោជន៍ បានតាំងនៅក្នុងអាកាសនោះឯង អស់ ៧ ថ្ងៃ ។ សមាគមមានហើយដោយជនជាច្រើន ពួកគេបូជាព្រះចេតិយ ដោយប្រការផ្សេងៗ អស់ ៧ ថ្ងៃ ។ បន្ទាប់អំពីនោះ ការបែកផ្សេងគ្នានៃលទ្ធិ របស់អ្នកមានលទ្ធិផ្សេងៗ គ្នា បានកើតមានហើយ ។

ព្រះចេតិយនោះ បានទៅកាន់ទីដើមរបស់ខ្លួនដោយពុទ្ធានុភាព ក្នុងខណៈ នោះ មហាសិលាចេតិយ មានឡើងហើយក្នុងទីនោះឯង សត្វប្រមាណ ៨ ម៉ឺន ៤ ពាន់ បានសម្រេចធម្មាភិសម័យហើយក្នុងសមាគមនោះ ។៚

**រឿងព្រះចេតិយមាសរបស់ព្រះកស្សបទសពល ចប់**

**ពុទ្ធវគ្គ ចប់**

**វគ្គទី ១៤ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា សុខវគ្គទី ១៥

[ ២៥ ] យើងជាអ្នកមិនមានពៀរ រស់នៅជាសុខពិត ក្នុងពួកមនុស្សមានពៀរ កាលពួកមនុស្សមានពៀរ យើងជាអ្នកមិនមានពៀរ ។ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ( ដោយកិលេស ) រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីក្តៅក្រហាយ កាលពួកមនុស្សមានសេចក្តីក្តៅក្រហាយ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ។ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ក្នុងការស្វែងរក រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីខ្វល់ខ្វយ កាលពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ។

យើងមិនមានកង្វល់ តែងរស់នៅជាសុខពិត ( ព្រោះ ) យើងមានបីតិជាអាហារ ដូចពួកទេវតាជាន់អាភស្សរៈ ។

បុគ្គលអ្នកឈ្នះ តែងរងនូវពៀរ បុគ្គលអ្នកចាញ់ តែងដេកជាទុក្ខ ចំណែកបុគ្គលលះបង់ការឈ្នះ និងការចាញ់ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។

ភ្លើង ស្មើដោយរាគៈ មិនមាន ទោសកំហុស ស្មើដោយទោសៈ មិនមាន ទុក្ខទាំងឡាយ ស្មើដោយខន្ធ មិនមាន សុខ ក្រៅពីសេចក្តីស្ងប់មិនមាន ។

សេចក្តីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយ ជាទុក្ខយ៉ាងក្រៃលែង ( អ្នកប្រាជ្ញ ) ដឹងច្បាស់សេចក្តីនុ៎ះតាមពិតហើយ ( រមែង

ធ្វើឲ្យច្បាស់ ) នូវព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

លាភ មានការមិនមានរោគ ជាយ៉ាងក្រៃលែង ទ្រព្យ មានសេចក្តីសន្តោស ជាយ៉ាងក្រៃលែង ញាតិ មានសេចក្តីស្និទ្ធស្នាល ជាយ៉ាងក្រៃលែង ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

ភិក្ខុផឹករសវិវេកផង រសព្រះនិព្វាន ជាទីរម្ងាប់កិលេសផង ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ មិនមានសេចក្តីស្មៅហ្មងឡើយ ។

ការជួបប្រទះព្រះអរិយបុគ្គលទាំងឡាយ ជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្តីសុខ សព្វកាល បុគ្គលគប្បីមានសេចក្តីសុខ អស់កាលជានិច្ចបាន ព្រោះមិនជួបប្រទះបុគ្គលពាលទាំងឡាយ ។

បុគ្គលអ្នកប្រព្រឹត្តសមគប់ដោយជនពាល រមែងសោកស្តាយអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខ សព្វកាល ។ ដូចជាការនៅរួមជាមួយនឹងសត្រូវ ចំណែកខាងការនៅរួមនឹងធីរជន រមែងជាសុខ ដូចការជួបជុំនៃញាតិទាំងឡាយ ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅ នូវធុរៈជាប្រក្រតីផង មានសីលវត្ត និងធុតង្គវត្តផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាល្អផង ប្រាកដដូច្នោះៗ ឲ្យដូចព្រះចន្ទគប់នូវផ្លូវនក្ខត្តឫក្ស ។

**សុខវគ្គទី ១៥ ចប់ ។**

# អដ្ឋកថា

# សុខវគ្គទី ១៥

## រឿង រម្ងាប់ជម្លោះនៃពួកញាតិ

### លំនាំដើម

*ព្រះសាស្តា គង់នៅក្នុងដែនសក្កៈ ទ្រង់ប្រារព្ធពួកព្រះញាតិ ដើម្បីរម្ងាប់នូវជម្លោះ ទើបត្រាស់ព្រះធម្មទេសនានេះថា* **សុសុខំ វត** *ជាដើម ។*

*បានឮមកថា ស្តេចសក្យៈ និងកោលិយៈ ឲ្យទប់ស្ទឹងឈ្មោះរោហិណី ដោយទំនប់តែមួយ ក្នុងរវាងនគរកបិលពស្តុ និងនគរកោលិយៈ ហើយឲ្យធ្វើសម្ទូង លុះដល់ដើមខែជេស្ឋ សម្ទូងក្រៀមស្វិត ពួកកម្មករនគរទាំងពីរប្រជុំគ្នា ។ ក្នុងនគរទាំងពីរនោះ អ្នកកោលិយៈពោលថា ទឹកនេះបើពួកយើងនាំទៅទាំងសងខាងនឹងមិនគ្រប់គ្រាន់ដល់ពួកអ្នក បើពួកអ្នកនាំទៅទាំងសងខាង ក៏នឹងមិនគ្រប់គ្រាន់ដល់ពួកខ្ញុំ តែសម្ទូងរបស់ពួកខ្ញុំ នឹងសម្រេចដោយទឹកតែម្តងប៉ុណ្ណោះ ។ ចូរពួកអ្នកឲ្យទឹកនេះដល់ពួកខ្ញុំចុះ ។ ចំណែកអ្នកសក្យៈពោលយ៉ាងនេះថា បើពួកអ្នកធ្វើជង្រុកឲ្យពេញហើយ ពួកខ្ញុំមិនអាចកាន់យកមាសទឹកដប់ កែវពណ៌ខៀវ កែវពណ៌ខ្មៅ និងកហាបណៈ ហើយមានល្អី និងបាវជាដើមក្នុងដៃ ត្រាច់ទៅត្រង់ទ្វារផ្ទះរបស់ពួកអ្នក សម្ទូងរបស់ពួកខ្ញុំសម្រេចដោយទឹកតែម្តងដូចគ្នា ចូរពួកអ្នកឲ្យទឹកនេះដល់ខ្ញុំចុះ ពួកកោលិយៈពោលថា*

ពួកខ្ញុំមិនឲ្យ ពួកសក្យៈពោលថា សូម្បីពួកខ្ញុំក៏មិនឲ្យ ។

អ្នកនគរទាំងពីរញុំាងពាក្យឲ្យចម្រើនឡើងយ៉ាងនោះហើយ ប្រហារនូវគ្នានិងគ្នាយ៉ាងនេះ គឺបុគ្គលម្នាក់ក្រោកឡើងហើយ បានឲ្យនូវការប្រហារដល់បុគ្គលម្នាក់ សូម្បីអ្នកដែលត្រូវប្រហារនោះ ក៏បានឲ្យនូវការប្រហារដល់អ្នកដទៃ ការប៉ះទង្គិចដល់ជាតិនៃរាជត្រកូលទាំងឡាយ បង្កនូវជម្លោះឲ្យចម្រើនឡើងហើយ ។ ពួកកម្មករអ្នកកោលិយៈពោលថា ចូរពួកអ្នកនាំក្មេងអ្នកក្រុងកបិលពស្តុទៅចុះ ជនទាំងឡាយណានៅរួមជាមួយបងស្រី ប្អូនស្រីរៀងៗខ្លួន ដូចឆ្កែស្រុក និងឆ្កែចចកជាដើម ដំរី សេះ ខែល និងអាវុធទាំងឡាយរបស់ជនទាំងនោះ នឹងធ្វើអ្វីដល់ពួកយើងបាន ។

ពួកកម្មករខាងសក្យៈពោលថា ឥឡូវនេះ ចូរពួកអ្នកនាំក្មេងឃ្លង់ទាំងនេះទៅចុះ ជនទាំងឡាយណាមិនមានទីពឹង មិនមានគតិ នៅត្រង់ដើមក្រពៅដូចសត្វតិរច្ឆាន ដំរី សេះ ខែល និងអាវុធរបស់ជនទាំងនោះ នឹងធ្វើអ្វីដល់ពួកយើងបាន ។ ជនទាំងនោះ ទៅប្រាប់ដល់ពួកអមាត្យដែលប្រកបក្នុងកម្មនោះ ពួកអមាត្យទូលដល់រាជត្រកូលទាំងឡាយ ។

លំដាប់នោះ ស្តេចសក្យៈទាំងឡាយគិតថា ពួកយើងនឹងបង្ហាញភាពក្លៀវក្លា និងកម្លាំងរបស់ពួកជនដែលនៅរួមជាមួយពួកបងស្រីប្អូនស្រី ហើយត្រៀមការច្បាំងចេញទៅ ។ ចំណែកស្តេចកោលិយៈទាំងឡាយគិតថា ពួកយើងនឹងបង្ហាញភាពក្លៀវក្លា និងកម្លាំងរបស់ពួកជនដែលនៅត្រង់ដើមក្រពៅ ដូច្នេះហើយ ត្រៀមការច្បាំងចេញទៅ ។

ព្រះសាស្តា ទ្រង់ប្រមើលមើលសត្វលោកក្នុងពេលជិតភ្លឺ ទតឃើញពួកញាតិ ទ្រង់ព្រះតម្រិះថា បើតថាគតមិនទៅ ញាតិទាំងនេះនឹងវិនាស ការដែលតថាគតទៅក៏គួរ ដូច្នេះហើយ ទើបយាងទៅតាមអាកាសមួយព្រះអង្គឯងប៉ុណ្ណោះ ប្រថាប់គង់ពត់ភ្នែនក្នុងអាកាស ត្រង់កណ្តាលស្ទឹងរោហិណី ព្រះញាតិទាំងឡាយ ឃើញព្រះសាស្តាហើយដាក់អាវុធថ្វាយបង្គំ ។ កាលនោះ ព្រះសាស្តាត្រាស់នឹងញាតិទាំងនោះថា មហាបពិត្រ នេះឈ្មោះថាជម្លោះរឿងអ្វី ព្រះញាតិពោលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គមិនដឹងទេ ព្រះសាស្តាត្រាស់ថា ឥឡូវនេះ តើអ្នកណាដឹង ។

ព្រះញាតិទាំងនោះ សួរដល់ពួកទាសៈ និងកម្មករដោយឧបាយនេះថា ឧបរាជនឹងជ្រាប សេនាបតីនឹងជ្រាបជាដើម ហើយក្រាបទូលថា បពិត្រព្រះអង្គ ឈ្លោះគ្នាព្រោះទឹក ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ តើទឹកមានតម្លៃប៉ុនណា ពួកព្រះញាតិទូលថា បពិត្រព្រះអង្គ មានតម្លៃតិចតួច ព្រះសាស្តាត្រាស់ថា ក្សត្រទាំងឡាយមានតម្លៃប៉ុនណា ពួកព្រះញាតិទូលថា បពិត្រព្រះអង្គ ឈ្មោះថា ក្សត្រទាំងឡាយ មានតម្លៃកាត់ថ្លៃមិនបាន ព្រះសាស្តាត្រាស់ថា ការដែលអ្នកទាំងឡាយ ញុំាងពួកក្សត្រដែលមានតម្លៃកាត់ថ្លៃមិនបានឲ្យវិនាស ព្រោះអាស្រ័យទឹក ដែលមានប្រមាណតិច គួរហើយឬ ។

ព្រះញាតិទាំងនោះនៅស្ងៀមហើយ ។ លំដាប់នោះ ព្រះសាស្តា ដាស់តឿនព្រះញាតិទាំងនោះហើយ ត្រាស់ថា មហាបពិត្រ ព្រោះហេតុអ្វី ទើបពួកអ្នកធ្វើកម្មបែបនេះ កាលតថាគតមិនមានក្នុងថ្ងៃនេះ សូម្បីទឹក គឺឈាម នឹង

ហូរ អ្នកទាំងឡាយ ធ្វើកម្មមិនសមគួរ អ្នកទាំងឡាយ ជាអ្នកមានបច្ចាវេរ តថាគតមិនមានពៀរ អ្នកទាំងឡាយ ជាអ្នកដល់នូវការក្តៅក្រហាយដោយកិលេស តថាគតមិនមានការក្តៅក្រហាយ អ្នកទាំងឡាយ ជាអ្នកមានសេចក្តីខ្វល់ខ្វាយក្នុងការស្វែងរកកាមគុណ តថាគតមិនមានការខ្វល់ខ្វាយ ហើយទ្រង់ភាសិតគាថានេះថា

**សុសុខំ វត ជីវាម　　　　　　វេរិនេសុ អវេរិនោ**

**វេរិនេសុ មនុស្សេសុ　　　　　វិហារាម អវេរិនោ**

**សុសុខំ វត ជីវាម　　　　　　អាតុរេសុ អនាតុរា**

**អាតុរេសុ មនុស្សេសុ　　　　　វិហារាម អនាតុរា**

**សុសុខំ វត ជីវាម　　　　　　ឧស្សុកេសុ អនុស្សុកា**

**ឧស្សុកេសុ មនុស្សេសុ　　　　វិហារាម អនុស្សុកា ។**

យើងជាអ្នកមិនមានពៀរ រស់នៅជាសុខពិត ក្នុងពួកមនុស្សមានពៀរ កាលពួកមនុស្សមានពៀរ យើងជាអ្នកមិនមានពៀរ ។ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ( ដោយកិលេស ) រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីក្តៅក្រហាយ កាលពួកមនុស្សមានសេចក្តីក្តៅក្រហាយ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ។ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយក្នុងការស្វែងរក រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ កាលពួកមនុស្សមាន

សេចក្តីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សុសុខំ** បានដល់ សប្បាយ ។ ព្រះសាស្តាត្រាស់ពាក្យបរិយាយនេះថា ក្នុងមនុស្សទាំងឡាយដែលមានពៀរ ដោយពៀរ ៥ តថាគតមិនមានពៀរ មនុស្សទាំងឡាយ មានសេចក្តីក្តៅក្រហាយដោយកិលេស តថាគតឈ្មោះថាមិនមានការក្តៅក្រហាយ ព្រោះជាអ្នកមិនមានកិលេស ក្នុងមនុស្សទាំងឡាយដែលមានសេចក្តីខ្វល់ខ្វាយ ក្នុងការស្វែងរកកាមគុណ ៥ តថាគតឈ្មោះថាមិនមានការខ្វល់ខ្វាយ ព្រោះមិនមានការស្វែងរកនោះ ទើបជាអ្នកនៅជាសុខជាងពួកគ្រហស្ថ ដែលញ៉ាំងការប្រព្រឹត្តទៅនៃជីវិតឲ្យកើតឡើង ដោយអំណាចនៃការកាត់ទីតជាដើម ឬជាងពួកបព្វជិតដែលញ៉ាំងការប្រព្រឹត្តទៅនៃជីវិតឲ្យកើតឡើង ដោយអំណាចនៃវេជ្ជកម្មជាដើមហើយពោលថា តថាគតជាអ្នកនៅដោយសេចក្តីសុខ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿងរម្ងាប់ជម្លោះនៃពួកញាតិ ចប់**

# រឿង មារ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងស្រុកព្រាហ្មណ៍ឈ្មោះបញ្ចសាលា ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា **សុសុខំ វត** ជាដើម ។

សេចក្ដីពិស្ដារថា ក្នុងថ្ងៃមួយ ព្រះសាស្ដាទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់កុមារី ៥០០ ទើបយាងចូលទៅអាស្រ័យស្រុកនោះ ។ ក្មេងស្រីទាំងនោះ ក្នុងថ្ងៃនក្ខត្តឫក្សមួយ ទៅកាន់ស្ទឹងងូតហើយ ប្រដាប់តាក់តែងហើយ បែរមុខទៅកាន់ស្រុក ។ ព្រះសាស្ដាយាងចូលទៅកាន់ស្រុកនោះ ត្រាច់ទៅដើម្បីបិណ្ឌបាត ។ មារចូលសណ្ឋិតក្នុងសរីរៈរបស់អ្នកស្រុកទាំងអស់ បានធ្វើឲ្យព្រះសាស្ដាមិនបានសូម្បីត្រឹមតែបាយមួយវែក ឈរត្រង់ទ្វារស្រុក ទូល ព្រះសាស្ដាដែលយាងចេញមកដោយបាត្រទទេថា បពិត្រសមណៈលោកបានបាយខ្លះទេ ព្រះសាស្ដាត្រាស់ថា ម្នាលមារមានចិត្តបាប អ្នកបានធ្វើឲ្យតថាគតមិនបានភិក្ខាឬ មារពោលថា បពិត្រព្រះអង្គ បើដូច្នោះ សូមទ្រង់យាងចូលទៅម្ដងទៀតចុះ ។

បានឮថា មារគិតយ៉ាងនេះថា បើសមណៈយាងចូលទៅទៀត អញនឹងចូលសណ្ឋិតក្នុងសរីរៈជនទាំងពួង ហើយទះដៃសើចចំអក ខាងមុខសមណៈនេះ ។ ខណៈនោះ ទារិកាទាំងនោះមកដល់ទ្វារស្រុក ឃើញព្រះសាស្ដាហើយថ្វាយបង្គំ ឈរក្នុងចំណែកម្ខាង ចំណែកមារទូលព្រះសាស្ដាថា បពិត្រព្រះអង្គទ្រង់មិនបានដុំបាយ ជាបុគ្គលដែលសេចក្ដីទុក្ខកើតអំពីការស្រេកឃ្លាន គ្របសង្កត់ខ្លះដែរឬ ។

*ព្រះសាស្តាត្រាស់ថា មារមានចិត្តបាប ក្នុងថ្ងៃនេះ សូម្បីតថាគតមិនបាន អ្វីមួយ ក៏នឹងញុំាងកាលឲ្យកន្លងទៅដោយសុខដែលកើតអំពីបីតិប៉ុណ្ណោះ ដូច ព្រហ្មលោកជាន់អាភស្សរៈ ហើយត្រាស់ព្រះគាថានេះថា*

**សុសុខំ វត ជីវាម យេសន្នោ នត្ថិ កិញ្ចនំ**
**បីតិភក្ខា ភវិស្សាម ទេវា អាភស្សរា យថា ។**

*យើងមិនមានកង្វល់ តែងរស់នៅជាសុខពិត ( ព្រោះ )*
*យើងមានបីតិ ជាអាហារ ដូចពួកទេវតាជាន់អាភស្សរៈ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **យេសន្នោ** *សេចក្តីថា បណ្តាកិលេសជាត គ្រឿងកង្វល់ មានរាគៈជាដើម កិលេសជាត គ្រឿងកង្វល់ណាមួយ ដោយអត្ថថា គ្រឿងជាប់ជំពាក់ មិនមានដល់តថាគតពួកណា ។*

*បទថា* **បីតិភក្ខា** *សេចក្តីថា ពួកទេវតាជាន់អាភស្សរៈ ជាអ្នកមានបីតិជាភក្ខា ញុំាងកាលឲ្យកន្លងទៅ យ៉ាងណា តថាគតក៏ដូច្នោះ ។*

*ក្នុងកាលចប់ទេសនា ក្មេងស្រីទាំង ៥០០ នោះ តាំងនៅក្នុងសោតាបត្តិផល ដូច្នេះឯង ។ល។*

**រឿង មារ ចប់**

# រឿង បរាជ័យរបស់ព្រះបាទកោសល

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបរាជ័យរបស់ព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះថា **ជយំ វេរំ** ជាដើម ។

បានឮថា ព្រះបាទកោសលនោះ ទ្រង់អាស្រ័យកាសិកគាម ច្បាំងជាមួយនឹងព្រះបាទអជាតសត្តុដែលជាម្ចាស់ក្មួយ ដែលព្រះបាទអជាតសត្តុនោះឲ្យបាញ់ ៣ ដង ក្នុងលើកទី ៣ ទ្រង់ព្រះតម្រិះថា អញមិនអាចញ៉ាំងកូនក្មេងដែលមាត់មិនទាន់បាត់ធុំទឹកដោះឲ្យបាញ់បាន ប្រយោជន៍អ្វីដោយការរស់នៅរបស់អញ ព្រះរាជាទ្រង់អត់អាហារ ផ្ទំលើព្រះទែន ។ កាលនោះ ការប្រព្រឹត្តទៅរបស់ព្រះរាជា រីករាលពេញព្រះនគរ ។ ភិក្ខុទាំងឡាយ ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ បានឮថា ព្រះរាជាទ្រង់អាស្រ័យកាសិក-គាម ដែលព្រះបាទអជាតសត្តុ ឲ្យបរាជ័យហើយអស់ ៣ ដង ឥឡូវនេះទ្រង់បរាជ័យត្រឡប់មកហើយ ទ្រង់មិនសោយអាហារ ផ្ទំលើព្រះទែន ដោយព្រះតម្រិះថា អញមិនអាចញ៉ាំងក្មេង ដែលមាត់មិនទាន់បាត់ធុំទឹកដោះឲ្យបាញ់បាន ប្រយោជន៍អ្វីដោយការរស់នៅរបស់អញ ។

ព្រះសាស្តា ទ្រង់ស្តាប់កថារបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកឈ្នះរមែងមានពៀរ អ្នកចាញ់រមែងដេកជាទុក្ខ ដូច្នេះហើយត្រាស់ព្រះគាថានេះថា

**ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ**
**ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។**

បុគ្គលអ្នកឈ្នះតែងរងនូវពៀរ បុគ្គលអ្នកចាញ់តែងដេក

ជាទុក្ខ ចំណែកបុគ្គលលះបង់ការឈ្នះ និងការចាញ់ចេញ

ហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ជយំ** សេចក្តីថា អ្នកឈ្នះជនដទៃ រមែងត្រឡប់បាននូវពៀរ ។ បទថា **បរាជិតោ** សេចក្តីថា អ្នកដែលបុគ្គលដទៃឲ្យចាញ់ហើយ រមែងរងនូវទុក្ខ គឺលំបាកក្នុងឥរិយាបថទាំងពួងនោះឯង ដោយគិតថា ក្នុងកាលណាហ្ន៎ អញអាចឃើញខ្នង ( គឺដេញពីក្រោយ ) របស់បច្ចាមិត្ត ។

បទថា **ឧបសន្តោ** សេចក្តីថា ព្រះខីណាស្រព ជាអ្នកមានកិលេស គឺរាគៈជាដើមខាងក្នុងស្ងប់ហើយ លះនូវការឈ្នះ និងការចាញ់បាន តែងនៅជាសុខ គឺរមែងនៅដោយសប្បាយក្នុងឥរិយាបថទាំងពួង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង បរាជ័យរបស់ព្រះបាទកោសល ចប់**

# រឿង ស្រីក្នុងត្រកូលណាមួយ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារិកាម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **នត្ថិ រាគសមោ អគ្គិ** ជាដើម ។

បានឮថា មាតារបស់កុមារិកានោះធ្វើអាវាហមង្គល និមន្តព្រះសាស្ដាក្នុងថ្ងៃមង្គល ព្រះសាស្ដាកាលភិក្ខុហែហមយាងទៅក្នុងទីនោះប្រថាប់គង់ហើយ ។ កូនក្រមុំនោះឯងត្រងទឹកជាដើម ដើម្បីពួកភិក្ខុដើរទៅដើរមក ស្វាមីរបស់នាងបានឈរសម្លឹងមើលហើយដោយអំណាចនៃរាគៈ កិលេសខាងក្នុងផ្សាយឡើងត្រូវសេចក្ដីមិនដឹងគ្របសង្កត់ហើយ ទើបមិនបម្រើព្រះសម្ពុទ្ធ មិនបម្រើព្រះមហាថេរៈ ៨០ តែបានធ្វើទុកក្នុងចិត្តថា អញនឹងលាដៃចាប់ស្រីនោះ ។ ព្រះសាស្ដាទតឃើញអធ្យាស្រ័យរបស់បុរសនោះហើយ បានធ្វើមិនឲ្យបុរសនោះឃើញស្រីនោះ ។ បុរសនោះ មិនឃើញស្រីនោះ ទើបបានឈរសម្លឹងព្រះសាស្ដា ក្នុងកាលដែលឈរនោះឯង ព្រះសាស្ដាត្រាស់ថា នៃកុមារ ឈ្មោះថា ភ្លើង ដូចគ្នានឹងភ្លើង គឺរាគៈ មិនមាន ឈ្មោះថា ទោស ដូចគ្នានឹងទោស គឺទោសៈ មិនមាន ឈ្មោះថា ទុក្ខ ដូចគ្នានឹងទុក្ខព្រោះថែរក្សាខន្ធ មិនមានសុខ ស្មើដោយព្រះនិព្វានមិនមានដូចគ្នា ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ កលិ**
**នត្ថិ ខន្ធសមា ទុក្ខា នត្ថិ សន្តិបរំ សុខំ ។**

ភ្លើង ស្មើដោយរាគៈ មិនមាន ទោសកំហុសស្មើដោយ
ទោសៈ មិនមាន ទុក្ខទាំងឡាយ ស្មើដោយខន្ធ មិនមាន

*សុខ ក្រៅពីសេចក្ដីស្ងប់មិនមាន ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បទថា* **នត្ថិ រាគសមោ** *សេចក្ដីថា ឈ្មោះថា ភ្លើង ដទៃស្មើដោយរាគៈដែលមិនមានផ្សែង អណ្ដាត រងើក ឆេះខាងក្នុងប៉ុណ្ណោះ ហើយទើបធ្វើគំនរផេះ រមែងមិនមាន ។*

*បទថា* **កលិ** *សេចក្ដីថា សូម្បីទោសស្មើដោយទោសៈរមែងមិនមាន ។*

*បទថា* **ខន្ធសមា** *បានដល់ ស្មើដោយខន្ធទាំងឡាយ អធិប្បាយថា ឈ្មោះថា ទុក្ខដទៃ ដូចខន្ធទាំងឡាយដែលបុគ្គលបរិហារជាទុក្ខ មិនមាន ។*

*ពីរបទថា* **សន្តិបរំ សុខំ** *សេចក្ដីថា សុខដទៃក្រៃលែងជាងព្រះនិព្វាន រមែងមិនមាន អធិប្បាយថា សេចក្ដីពិត សុខដទៃក៏ជាសុខដូចគ្នា តែព្រះនិព្វានជាបរមសុខ ។*

*ក្នុងកាលចប់ទេសនា កុមារ និងកុមារិកា តាំងនៅក្នុងសោតាបត្តិផល ហើយ ក្នុងខណៈនោះ ព្រះសាស្ដាទ្រង់ត្រាស់អាការៈឲ្យជនទាំងពីរឃើញគ្នា ដូច្នេះឯង ។៚*

### រឿង ស្រីក្នុងត្រកូលណាមួយ ចប់

# រឿង ឧបាសកម្នាក់

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងក្រុងអាឡវី ទ្រង់ប្រារព្ធឧបាសកម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ជិឃច្ឆា** ជាដើម ។

សេចក្ដីពិស្ដារ ថ្ងៃមួយ ព្រះសាស្ដាទ្រង់ប្រថាប់គង់ក្នុងព្រះគន្ធកុដិ ក្នុងជេតពន ទ្រង់ប្រមើលមើលលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញជនទុគ៌តម្នាក់ ក្នុងក្រុងអាឡវី ទ្រង់ជ្រាបដល់ឧបនិស្ស័យសម្បត្តិរបស់បុរសនោះ មានភិក្ខុ ៥០០ ជាបរិវារយាងទៅកាន់ក្រុងអាឡវី ។ អ្នកក្រុងអាឡវីនិមន្តព្រះសាស្ដា មនុស្សក្រីក្រម្នាក់បានឮថា ព្រះសាស្ដាយាងមក ដូច្នេះហើយ បានតាំងចិត្តថា អញនឹងស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា ក្នុងថ្ងៃនោះឯង គោមួយក្បាល របស់បុរសនោះគេចទៅ គាត់គិតថា អញស្វែងរកគោ ឬស្ដាប់ធម៌ហ្ន៎ ហើយគិតថា អញស្វែងរកគោឲ្យចូលហ្វូងហើយ សឹមទៅស្ដាប់ធម៌ឯក្រោយ ដូច្នេះហើយ ចេញពីផ្ទះទាំងព្រលឹម អ្នកក្រុងអាឡវីនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យគង់ហើយអង្គាស ទទួលបាត្រដើម្បីប្រយោជន៍ដល់ការអនុមោទនា ។ ព្រះសាស្ដាបាននៅស្ងៀម ដោយទ្រង់បំណងថា តថាគតអាស្រ័យបុគ្គលណាមកហើយ អស់ចម្ងាយផ្លូវ ៣០ យោជន៍ បុគ្គលនោះចូលកាន់ព្រៃដើម្បីស្វែងរកគោ កាលបុរសនោះមកហើយ ទើបតថាគតសម្ដែងធម៌ ។ បុរសនោះឃើញគោក្នុងពេលថ្ងៃ កៀងគោហើយគិតថា របស់ដទៃមិនមាន អញនឹងធ្វើកិច្ចត្រឹមតែថ្វាយបង្គំព្រះសាស្ដា សូម្បីត្រូវសេចក្ដីឃ្លានគ្របសង្កត់ ក៏មិនដាក់ចិត្តដើម្បី

ទៅផ្ទះ ម្ចីម្ចាមកកាន់សម្នាក់របស់ព្រះសាស្ដា ថ្វាយបង្គំព្រះសាស្ដាហើយ ឈរក្នុងចំណែកម្ខាង ។ ក្នុងពេលដែលឈរ ព្រះសាស្ដាត្រាស់នឹងបុគ្គលដែលខ្វល់ខ្វាយក្នុងទានថា របស់ណាមួយដែលសេសសល់អំពីភិក្ខុសង្ឃមានឬ អ្នកចាត់ចែងទានពោលថា បពិត្រព្រះអង្គ មានគ្រប់យ៉ាង ព្រះសាស្ដាត្រាស់ថា បើដូច្នោះ ចូរឲ្យបុរសនេះបរិភោគ ។

មនុស្សទាំងនោះ ឲ្យបុរសនោះអង្គុយក្នុងទីដែលព្រះសាស្ដាត្រាស់នោះឯង ហើយអង្គាសដោយបបរ របស់ទំពា និងរបស់គួរបរិភោគដោយគោរព មនុស្សនោះបរិភោគកត្តស្រេច ខ្ពុរមាត់ហើយ ។ បានឮថា ឈ្មោះថាការរៀបចំភត្តរបស់ព្រះតថាគត រមែងមិនមានក្នុងទីដទៃ ក្នុងបិដក ៣ វៀរទីនេះចេញ ។ ចិត្តរបស់បុរសនោះ ដល់នូវការស្ងប់ហើយ ជាចិត្តមានឯកគ្គតា ។ គ្រានោះព្រះសាស្ដាត្រាស់អនុបុព្វីកថាហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយដល់បុរសនោះ លុះចប់ទេសនាបុរសនោះតាំងនៅក្នុងសោតាបត្តិផល ព្រះសាស្ដាក៏ទ្រង់ធ្វើអនុមោទនាហើយ ក្រោកចាកអាសនៈចៀសចេញទៅ ។ មហាជនតាមជូនព្រះសាស្ដាហើយ ក៏ត្រឡប់ ។

ភិក្ខុទាំងឡាយដែលទៅជាមួយព្រះសាស្ដានោះ ពោលទោសថា អាវុសោទាំងឡាយ ចូរពួកលោកមើលកម្មរបស់ព្រះសាស្ដាចុះ កម្មបែបនេះរមែងមិនមានក្នុងថ្ងៃទាំងឡាយដទៃ តែថ្ងៃនេះព្រះសាស្ដាទ្រង់អាស្រ័យមនុស្សម្នាក់ ប្រើឲ្យមនុស្សរៀបចំបបរជាដើមឲ្យហើយ ។ ព្រះសាស្ដាយាងត្រឡប់ប្រថាប់ឈរហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនិយាយអ្វី ទ្រង់ស្ដាប់សេចក្ដី

នោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតគិតថា តថាគតមកអស់ចម្ងាយ ៣០ យោជន៍ ឃើញឧបនិស្ស័យរបស់ឧបាសកនោះហើយ ទើបមកឧបាសកនោះ ស្រេកឃ្លានណាស់ ក្រោកឡើងអំពីព្រលឹម ហើយដើររកគោក្នុងព្រៃ សូម្បីតថាគតសម្ដែងធម៌ ក៏មិនអាចសម្រេចមគ្គផលបាន ព្រោះភាពជាទុក្ខដែលកើតអំពីសេចក្ដីស្រេកឃ្លាន ទើបបានធ្វើយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ដ្បិតថា ឈ្មោះថា រោគ ដូចគ្នានឹងរោគ គឺការឃ្លាន មិនមានដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**ជិឃច្ឆា បរមា រោគា សង្ខារា បរមា ទុក្ខា**
**ឯតំ ញត្វា យថាភូតំ និព្វានំ បរមំ សុខំ ។**

សេចក្ដីស្រេកឃ្លាន ជារោគដ៏ក្រៃលែង សង្ខារទាំង-
ឡាយ ជាទុក្ខយ៉ាងក្រៃលែង ( អ្នកប្រាជ្ញ ) ដឹងច្បាស់
សេចក្ដីនុ៎ះតាមពិតហើយ ( រមែងធ្វើឲ្យច្បាស់ ) នូវ
ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បាទព្រះគាថាថា **ជិឃច្ឆា បរមា រោគា** សេចក្ដីថា ព្រោះរោគដទៃព្យាបាលតែម្ដងក៏ជា ឬថា បុគ្គលរមែងព្យាបាលបានដោយអំណាចនៃអង្គនោះៗ គឺម្ដងម្កាល ចំណែកសេចក្ដីស្រេកឃ្លាន ត្រូវព្យាបាលអស់កាលជានិច្ច ហេតុនោះទើបការឃ្លាននេះ ចាត់ជាកំពូលនៃរោគដ៏សេស ។

ខន្ធ ៥ ឈ្មោះថា សង្ខារទាំងឡាយ ។ ពីរបទថា **ឯតំ ញត្វា** សេចក្ដីថា

បណ្ឌិតជ្រាបអត្ថតាមសេចក្តីពិតថា រោគ ស្មើដោយការឃ្លាន មិនមាន ឈ្មោះថា ទុក្ខ ស្មើដោយការថែរក្សាខន្ធ មិនមាន ហើយធ្វើនូវព្រះនិព្វាន ឲ្យជាក់ច្បាស់ ។

បាទព្រះគាថាថា **និព្វានំ បរមំ សុខំ** សេចក្តីថា ព្រោះព្រះនិព្វាននោះជា សុខដ៏កំពូល គឺឧត្តមជាងសុខទាំងអស់ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ឧបាសកម្នាក់ ចប់**

# រឿង ព្រះបាទបសេនទិកោសល

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទបសេន-ទិកោសល ត្រាស់ព្រះធម្មទេសនានេះថា **អារោគ្យបរមា លាភា** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ព្រះរាជាសោយព្រះក្រយាហារទាំង នាឡិនៃអង្ករ ដោយសូបៈ និងព្យញ្ជនៈដ៏សមគួរ ដល់ព្រះក្រយាហារនោះ ។ ថ្ងៃមួយ ព្រះរាជាសោយព្រះក្រយាហារព្រឹកហើយ មិនទាន់បន្ទោបង់សេចក្តី ស្រវឹងក្នុងភត្ត យាងទៅកាន់សម្នាក់របស់ព្រះសាស្តា មានព្រះរូបធាត់ ទ្រង់ ប្រែប្រួលទៅឆ្វេងទៅស្តាំ ត្រូវងងុយគ្របសង្កត់ កាលមិនអាចផ្ទំត្រង់បាន

ទើបប្រថាប់គង់ក្នុងចំណែកម្ខាង ។ គ្រានោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ ទ្រង់មិនទាន់សម្រាកហើយយាងមកឬ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ យ៉ាងនោះឯង តាំងអំពីពេលបរិភោគហើយ ខ្ញុំព្រះអង្គមានទុក្ខច្រើន ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ ការបរិភោគច្រើនជាទុក្ខយ៉ាងនេះ ដូច្នេះហើយ ទ្រង់ទូន្មានដោយព្រះគាថានេះថា

ក្នុងកាលណា បុគ្គលជាអ្នកបរិភោគច្រើន ច្រើនដោយការងងុយ
និងការដេកលក់ រសាប់រសល់ ដូចជ្រូកធំដែលគេចិញ្ចឹមដោយ
អាហារ ក្នុងកាលនោះ បុគ្គលនោះ រមែងងោកងក់ រមែងចូល
បន្ទប់រឿយៗ ។

ហើយទ្រង់ត្រាស់បន្តថា មហាបពិត្រ ការបរិភោគភោជនតែល្មមប្រមាណ ទើបគួរ ព្រោះអ្នកបរិភោគល្មមប្រមាណ រមែងមានសេចក្តីសុខកាលទ្រង់ទូន្មានឲ្យក្រៃលែង ទើបត្រាស់គាថានេះថា

បុគ្គលមានសតិគ្រប់កាល ដឹងប្រមាណក្នុងភោជន ដែលបាន
ហើយនោះ មានវេទនាស្រាល អាហារដែលបរិភោគហើយ
ចិញ្ចឹមអាយុ រលួយសន្សឹមៗ ទៅ ។

ព្រះរាជាមិនអាចរៀនគាថាបាន តែត្រាស់នឹងក្មួយឈ្មោះសុទស្សនៈដែលឈរក្នុងទីជិតថា នែបា ចូរអ្នករៀនគាថានេះ ។ សុទស្សនៈនោះ រៀនគាថានោះហើយ ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងធ្វើដូចម្តេច កាលនោះព្រះសាស្តាត្រាស់ថា បើព្រះរាជាកំពុងសោយ អ្នកគប្បីពោលគាថា

នេះ ក្នុងកាលសោយពំនូតចុងក្រោយ ព្រះរាជាទ្រង់កំណត់អត្ថបានហើយ ទ្រង់នឹងចោលដុំបាយនោះ ក្នុងកាលចម្អិនភត្តដើម្បីព្រះរាជា អ្នកគប្បីបន្ថយអង្ករមានប្រមាណប៉ុណ្ណោះ ដោយការរាប់គ្រាប់អង្ករក្នុងដុំបាយនោះ ។ សុទស្សនៈនោះទទួលថា សាធុព្រះអង្គ កាលព្រះរាជាសោយពេលព្រឹកក្តី ពេលល្ងាចក្តី ក៏ពោលគាថានោះឡើងក្នុងកាលសោយពំនូតចុងក្រោយ ហើយឲ្យបន្ថយអង្ករដោយការរាប់គ្រាប់អង្ករ ក្នុងដុំបាយដែលព្រះរាជាទ្រង់បោះបង់ ។ ព្រះរាជាទ្រង់ស្តាប់គាថារបស់សុទស្សនៈនោះហើយ ទ្រង់ត្រាស់ឲ្យព្រះរាជទានទ្រព្យម្តង ១ ពាន់ ។

ក្នុងសម័យដទៃទៀត ព្រះរាជាទ្រង់តាំងនៅក្នុងភាជន៍ មានព្រះក្រយាហារនៃអង្ករត្រឹមតែមួយនាឡិយ៉ាងច្រើន ទ្រង់ដល់នូវសេចក្តីសុខហើយ មានព្រះសរីរៈស្រាល ។ សម័យថ្ងៃមួយ ព្រះរាជាយាងទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយទូលថា បពិត្រព្រះអង្គ ឥឡូវនេះ សេចក្តីសុខកើតដល់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គអាចដេញចាប់ម្រឹគក៏បាន សេះក៏បាន កាលមុនខ្ញុំព្រះអង្គមានការច្បាំងជាមួយក្មួយ ឥឡូវនេះ ខ្ញុំព្រះអង្គឲ្យធីតាឈ្មោះវជិរកុមារីដល់ក្មួយហើយឲ្យស្រុកនោះ ធ្វើឲ្យជាតម្លៃទឹកសម្រាប់ងូតរបស់ធីតានោះឯង ។ ការឈ្លោះគ្នានឹងក្មួយស្ងប់ហើយ សុខកើតហើយដល់ខ្ញុំព្រះអង្គ ព្រោះហេតុនោះ សូម្បីកែវមណីរបស់ព្រះបាទកុសរាជ ដែលបាត់ទៅហើយ ក្នុងវាំងរបស់ខ្ញុំព្រះអង្គ កាលពីថ្ងៃមុន ឥឡូវនេះ កែវមណីនោះ មកកាន់កណ្តាប់ដៃរបស់ខ្ញុំព្រះអង្គហើយ សេចក្តីសុខពិតកើតហើយដល់ខ្ញុំព្រះអង្គ ព្រោះហេតុនេះ ខ្ញុំ

*ព្រះអង្គប្រាថ្នាភាពស្និទ្ធស្នាលជាមួយសាវ័ករបស់ព្រះអង្គ ទើបធ្វើធីតានៃញាតិរបស់ព្រះអង្គទុកក្នុងវាំង សេចក្ដីសុខកើតហើយដល់ខ្ញុំព្រះអង្គ ព្រោះហេតុនេះ ។ ព្រះសាស្ដាត្រាស់ថា មហាបពិត្រ ឈ្មោះថា ការមិនមានរោគ ជាលាភដ៏ក្រៃលែង ទ្រព្យស្មើគ្នានឹងការសន្ដោស ដោយវត្ថុដែលខ្លួនបានហើយមិនមាន ឈ្មោះថា ញាតិ ដូចគ្នានឹងបុគ្គលអ្នកស្និទ្ធស្នាល មិនមាន ឈ្មោះថា សេចក្ដីសុខក្រៃលែង ស្មើដោយព្រះនិព្វាន មិនមាន ទើបត្រាស់ព្រះគាថានេះថា*

**អារោគ្យបរមា លាភា សន្តុដ្ឋិបរមំ ធនំ**
**វិស្សាសបរមា ញាតិ និព្វានំ បរមំ សុខំ ។**

*លាភ មានការមិនមានរោគជាយ៉ាងក្រៃលែង ទ្រព្យ មាន*
*សេចក្ដីសន្ដោសជាយ៉ាងក្រៃលែង ញាតិ មានសេចក្ដីស្និទ្ធ*
*ស្នាលជាយ៉ាងក្រៃលែង ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បទថា* **អារោគ្យបរមា** *សេចក្ដីថា មានភាពជាបុគ្គលមិនមានរោគយ៉ាងក្រៃលែង ពិតហើយ លាភទាំងឡាយ មានដល់បុគ្គលមានរោគ មិនចាត់ជាលាភ ព្រោះដូច្នោះ ទើបលាភទាំងពួង មកដល់បុគ្គលមិនមានរោគប៉ុណ្ណោះ ហេតុនោះ ទើបព្រះសាស្ដាត្រាស់ថា* **អារោគ្យបរមា លាភា ។**

*បាទព្រះគាថាថា* **សន្តុដ្ឋិបរមំ ធនំ** *សេចក្ដីថា ភាវៈ គឺការត្រេកអរដោយ*

វត្ថុដែលខ្លួនបានហើយ ដែលជារបស់មាននៃខ្លួន របស់គ្រហស្ថ ឬបព្វជិតនោះឯង ឈ្មោះថា សន្តោស សន្តោសនោះជាទ្រព្យដ៏ក្រៃលែងជាងទ្រព្យដ៏សេស ។

បាទព្រះគាថាថា **វិស្សាសបរមា ញាតី** សេចក្តីថា មាតាក្តី បិតាក្តីលើទុកចុះ មិនមានការស្និទ្ធស្នាលជាមួយបុគ្គលណា បុគ្គលនោះមិនមែនជាញាតិ តែមានការស្និទ្ធស្នាលជាមួយបុគ្គលណា ទោះបីបុគ្គលនោះមិនជាប់ខ្សែស្រឡាយ ឈ្មោះថា ជាញាតិយ៉ាងក្រៃលែង គឺយ៉ាងឧត្តម ហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **វិស្សាសបរមា ញាតី** ។

ម្យ៉ាងទៀត ឈ្មោះថា សេចក្តីសុខ ស្មើដោយព្រះនិព្វាន មិនមានហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **និព្វានំ បរមំ សុខំ** ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង ព្រះបាទបសេនទិកោសល ចប់**

# រឿង ព្រះតិស្សត្ថេរ

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងនគរវេសាលី ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា* **បវិវេករសំ** *ជាដើម ។*

*សេចក្តីពិស្តារថា កាលព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នៅ ៤ ខែទៀតបន្ទាប់អំពីនេះ តថាគតនឹងបរិនិព្វាន ។ ភិក្ខុ ៧០០ ក្នុងសម្នាក់របស់ព្រះសាស្តា ដល់នូវការសង្វេគហើយ ធម្មសង្វេគកើតឡើងដល់ព្រះខីណាស្រពទាំងឡាយ ភិក្ខុបុថុជ្ជនទាំងឡាយ មិនអាចទប់ទឹកភ្នែកបាន ។ ភិក្ខុទាំងឡាយជាពួកៗ ប្រឹក្សាគ្នាថា ពួកយើងនឹងធ្វើដូចម្តេចហ្ន៎ កាលនោះ ភិក្ខុមួយរូបឈ្មោះតិស្សៈ គិតថា បានឮថា ព្រះសាស្តានឹងបរិនិព្វានដោយកន្លងទៅ ៤ ខែ[1] ឯអាត្មាអញ ជាអ្នកមានរាគៈមិនទាន់ប្រាសទៅ កាលព្រះសាស្តាមានព្រះជន្មនៅនោះឯង អញគួរកាន់យកអរហត្ត ហើយទើបនៅម្នាក់ឯងប៉ុណ្ណោះក្នុងឥរិយាបថ ៤ ។ ការទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ឬមិនបានសន្ទនាប្រាស្រ័យជាមួយបុគ្គលណាមួយទេ ។ កាលនោះ ភិក្ខុទាំងឡាយពោលថា អាវុសោតិស្សៈ ហេតុអ្វី ទើបលោកធ្វើយ៉ាងនេះ ។ លោកមិនស្តាប់ពាក្យរបស់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ ក្រាបទូលការប្រព្រឹត្តទៅនោះ ដល់ព្រះសាស្តា ដោយទូលថា បពិត្រព្រះអង្គ តិស្សៈមិនស្រឡាញ់ក្នុងព្រះតថាគត ព្រះសាស្តាត្រាស់ឲ្យហៅលោកមកហើយ សួរថា តិស្សៈ ហេតុអ្វី ទើបអ្នកធ្វើ*

---

*១- រាប់ដោយចំពោះតែ ៣ ខែ ប៉ុណ្ណោះ តែក្នុងទីនេះ លោករាប់យកក្បាលខែ ទើបជា ៤ ខែ ។*

យ៉ាងនេះ កាលលោកក្រាបទូលបំណងរបស់ខ្លួនហើយ ប្រទានសាធុការថា សាធុ តិស្ស: ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសេចក្ដីស្រឡាញ់ក្នុងតថាគត ចូរជាបុគ្គលដូចតិស្សៈចុះ សូម្បីបុគ្គលធ្វើការបូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម មិនឈ្មោះថា បូជាតថាគតឡើយ តែបុគ្គលដែលបដិបត្តិធម៌សមគួរដល់ធម៌នោះឯង ឈ្មោះថា បូជាតថាគត ហើយត្រាស់ព្រះគាថានេះថា

**បវិវេករសំ បិត្វា រសំ ឧបសមស្ស ច**
**និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិរសំ បិវំ ។**

ភិក្ខុផឹករសវិវេកផង រសព្រះនិព្វានជាទីរម្ងាប់កិលេសផង
ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមាន
សេចក្ដីក្រវល់ក្រវាយ មិនមានសេចក្ដីសៅហ្មងឡើយ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **បវិវេករសំ** សេចក្ដីថា នូវរសដែលកើតហើយអំពីវិវេក អធិប្បាយថា នូវសេចក្ដីសុខដែលកើតអំពីការនៅម្នាក់ឯង ។

បទថា **បិត្វា** សេចក្ដីថា ផឹកហើយដោយអំណាចនៃភាពជាបុគ្គលធ្វើកិច្ចដែលកំណត់ដឹងទុក្ខជាដើម ធ្វើឲ្យជាក់ច្បាស់ដោយភាពជាអារម្មណ៍ ។

បាទព្រះគាថាថា **រសំ ឧបសមស្ស ច** សេចក្ដីថា ផឹកហើយនូវរសនៃព្រះនិព្វាន ដែលចូលទៅស្ងប់កិលេស ។

ពីរបទថា **និទ្ទរោ ហោតិ** សេចក្ដីថា ភិក្ខុដែលជាព្រះខីណាស្រពឈ្មោះ

ថា ជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ និងមិនមានបាប ព្រោះការមិនមាននៃសេចក្តីក្រវល់ក្រវាយ គឺរាគៈជាដើមខាងក្នុង ព្រោះផឹកនូវរសទាំងពីរយ៉ាងនោះ ។

ពីរបទថា **រសំ បិវំ** សេចក្តីថា កាលរសនៃបីតិ ដែលកើតឡើងហើយដោយអំណាចនៃលោកុត្តរធម៌ ៩ រមែងជាបុគ្គលមិនមានសេចក្តីក្រវល់ក្រវាយ និងមិនមានបាប ។

ក្នុងកាលចប់ទេសនា ព្រះតិស្សត្ថេរសម្រេចអរហត្តហើយ ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។ល។

**រឿង ព្រះតិស្សត្ថេរ ចប់**

# រឿង សក្កទេវរាជ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវេឡុវគ្រាម ទ្រង់ប្រារព្ធសក្កទេវរាជ ត្រាស់ព្រះធម្មទេសនានេះថា **សាធុ ទស្សនំ** ជាដើម ។

សេចក្តីពិស្តារថា សក្កទេវរាជទ្រង់ជ្រាបភាពដែលអាពាធ មានការស្ទុះទៅនៃព្រះលោហិតជាសមុដ្ឋាន កើតឡើងដល់ព្រះតថាគត ក្នុងកាលទ្រង់ដាក់អាយុសង្ខារហើយ ទ្រង់ព្រះតម្រិះថា ការដែលអញទៅកាន់សម្នាក់របស់ព្រះសាស្តា ហើយធ្វើគិលានុបដ្ឋាករមែងគួរ ទ្រង់លះអត្តភាពប្រមាណ ៣ គាវុត

ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ទ្រង់ប្របាច់ព្រះបាទដោយព្រះហស្ត ទាំងពីរ ។ កាលនោះព្រះសាស្តាត្រាស់នឹងសក្កទេវរាជនោះថា អ្នកជានរណា សក្កទេវរាជត្រាស់ថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គជាសក្កៈ ព្រះសាស្តាត្រាស់ថា អ្នកមកធ្វើអ្វី សក្កទេវរាជត្រាស់ថា បពិត្រព្រះអង្គ មកដើម្បីបម្រើទ្រង់ប្រឈួន ព្រះសាស្តាត្រាស់ថា សក្កៈ ក្លិនរបស់មនុស្សរមែងប្រាជកដល់ទេវតាទាំង-ឡាយ ដូចសាកសពដែលចងត្រង់ក ចម្ងាយ ១០០ យោជន៍ឡើងទៅលើ ចូរអ្នកទៅចុះ ភិក្ខុដែលជាគិលានុបដ្ឋាករបស់តថាគតមាន ។

សក្កទេវរាជក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គតាំងនៅក្នុងទីបំផុត ៨៤០០០ យោជន៍ ស្រូបនូវក្លិនសីលរបស់ទ្រង់មកហើយ ខ្ញុំព្រះអង្គនេះឯង នឹងបម្រើ មិនឲ្យបុគ្គលដទៃពាល់ត្រូវកាជនៈព្រះឧច្ចារៈរបស់ព្រះសាស្តាសូម្បី ដោយដៃ ទ្រង់ទូលលើព្រះសីសៈនោះឯងនាំទៅ មិនបានធ្វើសូម្បីអាការជ្រួញ ចិញ្ចើមស្រពោនព្រះភក្ត្រ បាននាំទៅដូចភាជនៈដាក់គ្រឿងក្រអូប សក្កៈបដិបត្តិ ព្រះសាស្តាយ៉ាងនេះហើយ ក្នុងកាលព្រះសាស្តាមានសេចក្តីសុខនោះឯង ទើបចៀសចេញទៅ ។

ភិក្ខុប្រជុំគ្នាពោលថា គួរសរសើរហ្ន៎ សក្កទេវរាជមានសេចក្តីស្នេហាក្នុង ព្រះសាស្តា ទ្រង់លះទិព្វសម្បត្តិបែបនេះ ទ្រង់នាំកាជនៈសម្រាប់រងព្រះឧច្ចារៈ របស់ព្រះសាស្តាទៅដោយសិរសា គឺត្បូង ទ្រង់មិនធ្វើអាការត្រឹមជ្រួញចិញ្ចើម ស្រពោនព្រះភក្ត្រឡើយ ដូចបុរសនាំកាជនៈ ដែលពេញដោយគ្រឿងក្រអូប ចេញទៅដូច្នោះ ទ្រង់បានធ្វើឧបដ្ឋាកហើយ ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់

ភិក្ខុទាំងនោះហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសន្ទនាគ្នាអំពីរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ រឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលសក្កទេវរាជធ្វើសេចក្តីស្រឡាញ់ក្នុងតថាគតនោះ មិនជាអស្ចារ្យទេ ព្រោះសក្កទេវរាជនេះស្តាប់ធម្មទេសនាហើយបានជាសោតាបន្ន លះនូវភាពជាសក្កៈចាស់ជរា ដល់នូវភាពជាសក្កៈកំលោះព្រោះអាស្រ័យតថាគត ពិតហើយ កាលសក្កៈគង់កណ្តាលបរិស័ទ ក្នុងឥន្ទ-សាលគុហា ក្នុងកាលខ្លួនត្រូវមរណភ័យគំរាម ធ្វើគន្ធព្វទេវបុត្រឈ្មោះបញ្ច-សិខៈអំពីខាងមុខយាងមក តថាគតបានពោលថា

ម្នាលស្តេចវាសវៈ សូមទ្រង់សួរបញ្ហាជាមួយនឹងតថាគត ទ្រង់ប្រាថ្នាបញ្ហាឯណានីមួយ ក្នុងព្រះហឫទ័យ តថាគតនឹងធ្វើបំផុតនៃបញ្ហានោះៗរបស់ទ្រង់បានពិត ។

កាលបន្ទោបង់នូវសេចក្តីសង្ស័យរបស់សក្កៈ ទើបសម្តែងធម្មទេសនាក្នុងកាលចប់ទេសនា ធម្មាភិសម័យមានដល់សត្វទាំងឡាយ ប្រមាណ ១៤ កោដិ ចំណែកសក្កទេវរាជ សម្រេចសោតាបត្តិផលក្នុងអាសនៈនោះឯង ជាសក្កៈកំលោះហើយ តថាគតមានឧបការៈច្រើនដល់សក្កៈនោះ ដោយប្រការយ៉ាងនេះ ឈ្មោះថាសេចក្តីស្នេហាក្នុងតថាគតរបស់សក្កទេវរាជនោះ មិនគួរអស្ចារ្យ ម្នាលភិក្ខុទាំងឡាយ ការជួបការឃើញពួកអរិយបុគ្គលក្តី ការនៅក្នុងទីជាមួយអរិយបុគ្គលក្តី នាំឲ្យកើតនូវសុខ តែកិច្ចបែបនោះជាមួយពួកបុគ្គលពាល ឲ្យកើតទុក្ខទាំងអស់ ហើយទើបទ្រង់ភាសិតគាថាទាំងនេះថា

សាធុ ទស្សនមរិយានំ    សន្និវាសោ សទា សុខោ
អទស្សនេន ពាលានំ    និច្ចមេវ សុខី សិយា
ពាលសង្គតចារី ហិ    ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ    អមិត្តេនេវ សព្វទា
ធីរោ ច សុខសំវាសោ    ញាតីនំវ សមាគមោ
តស្មា ហិ
ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច    ធោរយ្ហសីលំ វតវន្តមរិយំ
តំ តាទិសំ សប្បុរិសំ សុមេធំ    ភជេថ នក្ខត្តបថំវ ចន្ទិមា

ការជួបប្រទះព្រះអរិយបុគ្គលទាំងឡាយជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្តីសុខសព្វកាល បុគ្គលគប្បីមានសេចក្តីសុខអស់កាលជានិច្ចបាន ព្រោះមិនជួបប្រទះបុគ្គលពាលទាំងឡាយ ។ បុគ្គលអ្នកប្រព្រឹត្តសមគប់ដោយជនពាល រមែងសោកស្តាយអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខសព្វកាល ដូចការនៅរួមជាមួយនឹងសត្រូវ ចំណែកខាងការនៅរួមនឹងធីរជន រមែងជាសុខ ដូចការជួបជុំនៃញាតិទាំងឡាយ ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវត្ត និងធុតង្គផង

ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាល្អផង ប្រាកដដូច្នោះៗ ឲ្យដូចព្រះចន្ទគប់នូវផ្លូវនក្ខត្តឫក្ស ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សាធុ** បានដល់ ជាការញ៉ាំងប្រយោជន៍ឲ្យសម្រេច គឺជាការស្អាត បានដល់ កម្មដែលចម្រើន ។

បទថា **សន្និវាសោ** សេចក្តីថា មិនមែនត្រឹមតែការជួបព្រះអរិយបុគ្គលទាំងនោះតែម្យ៉ាងប៉ុណ្ណោះឡើយ ដល់នូវការកើត គឺជាខ្លួនថា ការអន្ទុយរួមជាមួយព្រះអរិយបុគ្គលទាំងនោះក្នុងទីជាមួយគ្នាក្តី ការកើត គឺការបាននូវការធ្វើវត្ត និងបដិវត្តដល់ព្រះអរិយបុគ្គលទាំងនោះក្តី ជាការល្អដោយពិត ។

បទថា **ពាលសង្គតចារី ហិ** សេចក្តីថា ព្រោះបុគ្គលណាត្រាច់រួមជាមួយបុគ្គលពាល ។

ប្រជុំបទថា **ទីឃមទ្ធានំ** ជាដើម សេចក្តីថា បុគ្គលនោះត្រូវសម្លាញ់ពាលពោលថា ចូរអ្នកមក ព្រោះខ្ញុំនឹងធ្វើកម្ម មានការកាត់ទី-តជាដើម ជាអ្នករួមធនុះនឹងសម្លាញ់ពាលនោះ ធ្វើកម្មទាំងនោះ ត្រូវព្រះរាជាដាក់កម្មករណៈច្រើនយ៉ាង មានកាត់ដៃជាដើមឈ្មោះថា រមែងសោយសោកអស់កាលយូរ ។

បទថា **សព្វធា** សេចក្តីថា ឈ្មោះថា ការនៅក្នុងទីជាមួយគ្នា ជាមួយសត្រូវដែលកាន់ដាវក្តី ពួកសត្វកាចមានអាសិរពិសជាដើមក្តី ឲ្យកើតទុក្ខជានិច្ច យ៉ាងណា ការនៅរួមជាមួយបុគ្គលពាល ក៏ដូច្នោះដូចគ្នា ។

ក្នុងបាទព្រះគាថាថា **ធីរោ ច សុខសំវាសោ** មានវិគ្គហៈថា ការនៅរួម

ដោយអ្នកប្រាជ្ញនោះ ជាសុខ ហេតុនោះ ទើបឈ្មោះថា មានការនៅរួមឲ្យកើតសុខ អធិប្បាយថា ការនៅក្នុងទីជាមួយគ្នាដោយបណ្ឌិត នាំឲ្យកើតសុខ ។ សួរថា ការនៅរួមដោយអ្នកប្រាជ្ញឲ្យកើតសុខដូចម្តេច ឆ្លើយថា ដូចសមាគមនៃពួកញាតិដូច្នោះ អធិប្បាយថា ការសមាគមនៃពួកញាតិដែលជាទីស្រឡាញ់ឲ្យកើតសុខ យ៉ាងណា ការនៅរួមដោយអ្នកប្រាជ្ញ ឲ្យកើតសុខដូច្នោះ ។

បទថា **តស្មា** សេចក្តីថា ព្រោះការនៅរួមជាមួយបុគ្គលពាល ឲ្យកើតទុក្ខ ជាមួយបណ្ឌិតឲ្យកើតសុខដូច្នោះឯង ចូរអ្នកទាំងឡាយគប់រក គឺចូលទៅអង្គុយជិតលោកដែលជាអ្នកប្រាជ្ញ សម្បូរដោយបញ្ញា និងបុគ្គលសម្បូរដោយបញ្ញា ជាលោកិយ និងលោកុត្តរ ឈ្មោះថា ជាអ្នកមានបញ្ញា និងជាអ្នកដល់ព្រមដោយអាគម និងអធិគម ដែលឈ្មោះថាពហុស្សុត ដែលឈ្មោះថានាំធុរៈទៅជាប្រក្រតី ព្រោះភាពជាបុគ្គលមានការនាំធុរៈទៅជាប្រក្រតី គឺឲ្យដល់អរហត្ត បុគ្គលឈ្មោះថាមានវត្ត ព្រោះវត្ត គឺសីល និងវត្ត គឺធុតង្គ ដែលឈ្មោះថា អរិយៈ ព្រោះភាពជាបុគ្គលឆ្ងាយចាកគំនរកិលេស បុគ្គលដែលជាសប្បុរស ជាអ្នកមានបញ្ញាស្អាតបែបនោះ ដូចព្រះចន្ទបញ្ចេញរស្មីក្នុងអាកាសដែលហៅថាគន្លងនៃនក្ខត្តឫក្ស ដែលមិនអាប់អួ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿងសក្កទេវរាជ ចប់**

**សុខវគ្គទី ១៥ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា បិយវគ្គទី ១៦

[ ២៦ ] បុគ្គលកាលប្រកបខ្លួនទុក ក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួនក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយ កាន់យកតាមគាប់ចិត្ត រមែងស្រឡាញ់បុគ្គលអ្នកប្រកបតាមខ្លួន ។ កុំគប់រកសត្វ និងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ ក្នុងកាលណាៗឡើយ ព្រោះថា ការមិនជួបប្រសព្វសត្វ និងសង្ខារជាទីស្រឡាញ់ក្តី ការជួបប្រសព្វសត្វ និងសង្ខារមិនជាទីស្រឡាញ់ក្តី ជាហេតុនាំមកនូវទុក្ខ ។

ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វ និងសង្ខារ ឲ្យជាទីស្រឡាញ់ ព្រោះការព្រាត់ប្រាសចាកសត្វ និងសង្ខារ ជាទីស្រឡាញ់ ជាសភាពអាក្រក់ ការស្រឡាញ់ និងការស្អប់ មិនមានដល់ពួកជនណា កិលេសគ្រឿងចាក់ស្រេះទាំងឡាយ តែងមិនមានដល់ពួកជននោះ ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យ នឹងមានមកពីណា ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្តីសោកកើតអំពីតម្រេក ភ័យកើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្តីសោក ក៏លែងមាន ភ័យ នឹងមានមកពីណា ។

សេចក្តីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្តីសោក ក៏លែងមាន ភ័យ នឹងមានមកពីណា ។

សេចក្តីសោកកើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្តីសោក ក៏លែងមាន ភ័យ នឹងមានមកពីណា ។ ជនតែងធ្វើបុគ្គលដែលបរិបូណ៌ ដោយសីល និងការឃើញត្រូវ ស្ថិតនៅក្នុងធម៌ ពោលសច្ចធម៌ជាប្រក្រតី ធ្វើកម្មជារបស់ខ្លួននោះ ឲ្យជាទីស្រឡាញ់ ។

បុគ្គលអ្នកមានសេចក្តីប្រាថ្នា ចំពោះព្រះនិព្វាន ដែលគេនិយាយប្រាប់គ្នាមិនបានផង ជាអ្នកមានមគ្គចិត្ត និងផលចិត្ត ( ខាងក្រោម ) ប៉ះពាល់ហើយផង មានចិត្តមិនប្រតិព័ទ្ធក្នុងកាមផង តថាគតហៅថា ជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅ ក្នុងខាងលើ ។

ពួកញាតិក្តី មិត្តក្តី សម្លាញ់ក្តី រមែងត្រេកអរនឹងបុរសដែលឃ្លាតគ្នាអស់កាលយូរ មកអំពីចម្ងាយដោយសួស្តី មកដល់ហើយ យ៉ាងណាមិញ បុណ្យទាំងឡាយ តែងទទួលបុគ្គលដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្សលោកនេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយ ទទួលបុរសជាទីស្រឡាញ់ទើបមកដល់ ដូច្នោះឯង ។

**បិយវគ្គទី ១៦ ចប់**

# អដ្ឋកថា
# បិយវគ្គទី ១៦

## រឿងបព្វជិត ៣ រូប
### លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបព្វជិត ៣ រូប ត្រាស់ព្រះធម្មទេសនានេះថា* **អយោគេ យុញ្ជមត្តានំ** *ជាដើម ។*

*បានឮថា មាតាបិតាក្នុងត្រកូលក្នុងក្រុងសាវត្ថី មានបុត្រតូចម្នាក់ប៉ុណ្ណោះ ជាទីស្រឡាញ់ជាទីគាប់ចិត្ត ។ ថ្ងៃមួយ បុត្រតូចនោះស្តាប់ធម្មកថារបស់ពួកភិក្ខុដែលនិមន្តមកក្នុងផ្ទះធ្វើអនុមោទនាចង់បួស ទើបសូមបួសនឹងមាតាបិតា ។ ឪពុកម្តាយមិនអនុញ្ញាត កាលនោះ កុលបុត្រនោះមានការគិតថា កាលឪពុកម្តាយមិនឃើញនោះឯង អញនឹងចេញទៅខាងក្រៅ ហើយបួស តមក បិតារបស់កុមារនោះ កាលចេញទៅខាងក្រៅ បានប្រាប់នឹងមាតាថា គប្បីរក្សាបុត្រតូចនោះ ។ មាតាកាលចេញទៅខាងក្រៅ ក៏ប្រគល់ឲ្យបិតាដូចគ្នា ។*

*សម័យក្រោយមក កាលបិតារបស់កុមារនោះទៅខាងក្រៅ មាតាតាំងចិត្តថានឹងរក្សាបុត្រ ផ្អែកទ្វារម្ខាង ម្ខាងទៀតយកជើងទាំងពីរខាំង ហើយអង្គុយចុះត្រង់ផែនដីខាងអំបោះ ។*

*កុមារគិតថា អញនឹងបញ្ឆោតមាតានេះហើយគេចទៅដូច្នេះហើយ ពោល*

ថា បពិត្រអ្នកម៉ែ ចៀសផ្លូវខ្ញុំបន្តិច ខ្ញុំនឹងបន្ទោបង់ឧច្ចារៈ កាលមាតានោះដក ជើងហើយក៏ចេញទៅ លួចរត់ទៅកាន់វិហារដោយរហ័ស ចូលទៅរកភិក្ខុ ទាំងឡាយអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បំបួសខ្ញុំចុះ ហើយ បួសក្នុងសម្នាក់របស់ភិក្ខុនោះឯង ។

លំដាប់នោះ ឪពុករបស់កុលបុត្រនោះត្រឡប់មកហើយសួរម្តាយថា កូន របស់យើងទៅណា មាតាឆ្លើយថា អើ អ្នក អម្បាញ់មិញ នៅទីនេះឯង បិតា នោះ ក៏រកមើលដើម្បីដឹងថា កូនរបស់អញនៅទីណាហ្ន៎ មិនឃើញហើយ គិត ថា កូនរបស់អញទៅវិហារ ទើបទៅកាន់វិហារហើយ ឃើញបុត្របួសហើយ ទ្រហោយំ ពោលថា នែបា ហេតុអ្វី ទើបធ្វើឲ្យពួកយើងវិនាស ដូច្នេះហើយ គិតថា បើកូនរបស់យើងបួសហើយ ឥឡូវនេះ យើងនឹងធ្វើអ្វីក្នុងផ្ទះ ដូច្នេះ ខ្លួនឯងក៏បួសហើយ ក្នុងសម្នាក់របស់ភិក្ខុទាំងឡាយ ។

លំដាប់នោះ មាតារបស់កុលបុត្រគិតថា ហេតុអ្វីហ្ន៎ កូន និងប្តីរបស់ អញ ទើបយឺតយូរ ។ ទៅកាន់វិហារបួសហើយទេដឹង សម្លឹងរកជនទាំងពីរ នោះបណ្តើរ ទៅវិហារបណ្តើរ ឃើញជនទាំងពីរបួសហើយ គិតថា ប្រយោជន៍ អ្វីដោយផ្ទះ អញក្នុងកាលនៃជនទាំងពីរនេះបួសហើយ សូម្បីខ្លួនឯងក៏ទៅ កាន់សម្នាក់ភិក្ខុនី បួសហើយ ។

ជនទាំងបីបួសហើយ មិនអាចបែកគ្នាបាន អង្គុយសន្ទនារួមគ្នាឲ្យថ្ងៃកន្លង ទៅទាំងក្នុងវិហារ ទាំងក្នុងសម្នាក់ភិក្ខុនី ហេតុនោះ ទាំងពួកភិក្ខុ ទាំងពួកភិក្ខុនី ទើបត្រូវបៀតបៀនហើយ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយក្រាបទូលនូវការធ្វើរបស់

ជនទាំងបីនោះដល់ព្រះសាស្តា ។

ព្រះសាស្តា ត្រាស់ឲ្យហៅជនទាំងបីមកហើយ ត្រាស់សួរថា បានឮថា ពួកអ្នកធ្វើយ៉ាងនោះពិតឬ កាលជនទាំងនោះទូលថា ពិត ត្រាស់សួរថា ហេតុអ្វី ទើបពួកអ្នកធ្វើយ៉ាងនោះ ព្រោះថា នុ៎ះមិនមែនសេចក្តីព្យាយាមរបស់ពួកបព្វជិត ។

ជនទាំងបីក្រាបទូលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គមិនអាចនៅបែកគ្នា ។ ព្រះសាស្តាត្រាស់ថា ឈ្មោះថា ការធ្វើយ៉ាងនេះ ចាប់តាំងពីកាលនៃខ្លួនបួស ហើយមិនគួរ ព្រោះថា ការមិនឃើញសត្វ និងសង្ខារជាទីស្រឡាញ់ និងការឃើញសត្វ និងសង្ខារដែលមិនជាទីស្រឡាញ់ ជាទុក្ខដោយពិត ហេតុនោះ ការធ្វើបណ្តាសត្វ និងសង្ខារទាំងឡាយណាមួយឲ្យជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ រមែងមិនសមគួរ ដូច្នេះហើយ បានភាសិតព្រះគាថានេះថា

**អយោគេ យុញ្ជមត្តានំ យោគស្មិញ្ច អយោជយំ**
**អត្ថំ ហិត្វា បិយគ្គាហី បិហេតត្តានុយោគិនំ ។**
**មា បិយេហិ សមាគញ្ឆិ អប្បិយេហិ កុទាចនំ**
**បិយានំ អទស្សនំ ទុក្ខំ អប្បិយានញ្ច ទស្សនំ ។**
**តស្មា បិយំ ន កយិរាថ បិយាបាយោ ហិ បាបកោ**
**គន្ថា តេសំ ន វិជ្ជន្តិ យេសំ នត្ថិ បិយាប្បិយំ ។**

បុគ្គលកាលប្រកបខ្លួនទុកក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួនក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយ កាន់

យកតាមគាប់ចិត្ត រមែងស្រឡាញ់បុគ្គលអ្នកប្រកបតាមខ្លួន ។

កុំគប់រកសត្វ និងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ និង មិនជាទីស្រឡាញ់ក្នុងកាលណាៗ ឡើយ ព្រោះថា ការមិនជួប ប្រសព្វសត្វ និងសង្ខារជាទីស្រឡាញ់ក្តី ការជួបប្រសព្វសត្វ និងសង្ខារមិនជាទីស្រឡាញ់ក្តី ជាហេតុនាំមកនូវទុក្ខ ។

ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វ និងសង្ខារឲ្យជាទីស្រឡាញ់ ព្រោះការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជា សភាពអាក្រក់ ការស្រឡាញ់ និងការស្អប់ មិនមានដល់ពួកជន ណា កិលេសគ្រឿងចាក់ស្រេះទាំងឡាយ តែងមិនមានដល់ពួក ជននោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អយោគេ** សេចក្តីថា ក្នុងវត្ថុដែលមិនគួរ ប្រកប គឺក្នុងការធ្វើទុកក្នុងចិត្ត ដែលមិនមែនឧបាយ អធិប្បាយថា ការ សេពអគោចរ ៦ យ៉ាង មានអគោចរ គឺកន្លែងស្រីពេស្យាជាដើម ឈ្មោះ ថា ការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ ក្នុងទីនេះ បុគ្គលប្រកបខ្លួនក្នុង ការធ្វើទុកក្នុងចិត្តដោយអយោនិសោមនសិការនោះ ។

បទថា **យោគស្មឹ** សេចក្តីថា មិនប្រកបខ្លួនក្នុងយោនិសោមនសិការ ដែលខុសអំពីអយោនិសោមនសិការនោះ ។

ពីរបទថា **អត្ថំ ហិត្វា** សេចក្តីថា ពួក ៣ នៃសិក្ខា មានអធិសីលសិក្ខា

ជាដើម ចាប់តាំងអំពីកាលនៃខ្លួនបួសហើយ ឈ្មោះថា ប្រយោជន៍លះហើយនូវប្រយោជន៍នោះ ។

បទថា **បិយគ្គាហី** សេចក្តីថា កាន់យកនូវអារម្មណ៍ដែលជាទីស្រឡាញ់ ពោល គឺការកាមគុណ ៥ ប៉ុណ្ណោះ ។

បទថា **បិហេតត្តានុយោគិនំ** សេចក្តីថា បុគ្គលកាលឃ្លាតចាកសាសនា ព្រោះកិច្ចបដិបត្តិនោះ ដល់នូវភាពជាគ្រហស្ថហើយ ខាងក្រោយ រមែងប្រាថ្នាចំពោះបុគ្គលទាំងឡាយដែលតាមប្រកបខ្លួន ញុំាងគុណទាំងឡាយ មានសីលជាដើម ឲ្យដល់ព្រមហើយ ( បាននូវ ) សក្ការៈអំពីសម្នាក់ទេវតា និងមនុស្សទាំងឡាយ គឺរមែងប្រាថ្នាថា ឱហ្ន៎ សូម្បីអញក៏គប្បីជាបុគ្គលដូច្នេះ ។

បទថា **មា បិយេហិ** សេចក្តីថា បុគ្គលមិនគប្បីសមាគមដោយសត្វ ឬសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ក្នុងកាលណាមួយ គឺក្នុងមួយជួរខណៈសត្វ ឬសង្ខារទាំងឡាយមិនជាទីស្រឡាញ់ក៏ដូចគ្នា ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការមិនឃើញសត្វ និងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ដោយអំណាចការព្រាត់ប្រាសផង ការឃើញសត្វ និងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ផង ដោយអំណាចការចូលទៅជិតជាទុក្ខ ។

បទថា **តស្មា** សេចក្តីថា ការឃើញ និងមិនឃើញ ទាំងពីរនេះជាទុក្ខហេតុនោះ បុគ្គលមិនគប្បីធ្វើសត្វ ឬសង្ខារណាមួយឲ្យជាទីស្រឡាញ់ឡើយ ។

ការទៅប្រាស គឺការព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ ឈ្មោះថា **បិយាបាយោ** ។ បទថា **បាបកោ** បានដល់ អាក្រក់ ។

បាទព្រះគាថាថា **គន្ថា តេសំ ន វិជ្ជន្តិ** សេចក្តីថា ជនទាំងឡាយណា មិនមានអារម្មណ៍ជាទីស្រឡាញ់ ជនទាំងនោះ រមែងលះកិលេស ជាគ្រឿងរួបរឹតផ្លូវកាយ គឺអភិជ្ឈាបាន ជនពួកណា មិនមានអារម្មណ៍ដែលមិនជាទីស្រឡាញ់ ជនទាំងនោះ រមែងលះគន្ថៈ គឺព្យាបាទចេញបាន កាលលះកិលេស ២ យ៉ាង នោះបានហើយ សូម្បីកិលេសជាគ្រឿងរួបរឹតដ៏សេស ក៏ឈ្មោះថា លះបានហើយដូចគ្នា ហេតុនោះ បុគ្គលមិនគប្បីធ្វើអារម្មណ៍ឲ្យជាទីស្រឡាញ់ ឬមិនឲ្យជាទីស្រឡាញ់ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។ ចំណែកជនទាំង ៣ គិតថា ពួកយើងមិនអាចនៅបែកគ្នាបាន ដូច្នេះហើយ បានសឹកទៅកាន់ផ្ទះដូចមុននោះឯង ។៚

**រឿង បព្វជិត ៣ រូប ចប់**

# រឿង កុដុម្ពិកៈម្នាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **បិយតោ ជាយតី** ជាដើម ។

សេចក្តីពិស្តារថា កុដុម្ពិកៈនោះ កាលកូនរបស់ខ្លួនធ្វើកាលកិរិយាហើយ កាលសេចក្តីសោកដល់កូនគ្របសង្កត់ ចូលទៅកាន់ព្រៃខ្មោចទ្រហោយំ មិន

អាចឃាត់សេចក្តីសោកដល់បុត្របាន ។

ព្រះសាស្តា ទ្រង់ពិចារណាមើលសត្វលោកក្នុងពេលជិតភ្លឺ ទ្រង់ឃើញឧបនិស្ស័យសោតាបត្តិមគ្គរបស់កុដុម្ពិកៈនោះ ត្រឡប់អំពីបិណ្ឌបាតហើយ ទ្រង់នាំភិក្ខុដែលជាបច្ឆាសមណៈមួយរូប យាងទៅកាន់ទ្វារផ្ទះរបស់កុដុម្ពិកៈនោះ កុដុម្ពិកៈនោះបានស្តាប់ភាពដែលព្រះសាស្តាយាងមក គិតថា ព្រះសាស្តាទ្រង់បំណងដើម្បីធ្វើបដិសណ្ឋារៈជាមួយ ទើបអារាធនាព្រះសាស្តាឲ្យចូលកាន់ផ្ទះក្រាលអាសនៈក្នុងផ្ទះ កាលព្រះសាស្តាប្រថាប់គង់ហើយ ក៏ថ្វាយបង្គំ អង្គុយក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរកុដុម្ពិកៈនោះថា ម្នាលឧបាសក អ្នកត្រូវទុក្ខព្រោះហេតុអ្វីហ្ន៎ កាលកុដុម្ពិកៈនោះក្រាបទូលនូវទុក្ខ ព្រោះព្រាត់ប្រាសចាកបុត្រហើយ ត្រាស់ថា កុំគិតឡើយឧបាសក ឈ្មោះថា ការស្លាប់នេះ មិនមែនមានក្នុងទីមួយ និងមិនមែនមានចំពោះដល់បុគ្គលម្នាក់ ឈ្មោះថាការប្រព្រឹត្តទៅនៃភពនៅមានដរាបណា ការស្លាប់ក៏រមែងមានដល់សត្វដរាបនោះដូចគ្នា សូម្បីសង្ខារមួយដែលឈ្មោះថា ទៀង មិនមាន ព្រោះហេតុនោះ អ្នកគប្បីពិចារណាដោយឧបាយប្រាជ្ញាថា ធម្មជាតមានការស្លាប់ជាធម្មតាស្លាប់ហើយ ធម្មជាតមានការបែកធ្លាយជាធម្មតា បែកធ្លាយហើយ មិនគប្បីសោយសោក ព្រោះថា បុរាណបណ្ឌិតទាំងឡាយ ក្នុងកាលដែលកូនជាទីស្រឡាញ់ស្លាប់ហើយ ពិចារណាថា ធម្មជាតមានការស្លាប់ជាធម្មតា ស្លាប់ហើយ ធម្មជាតមានការបែកធ្លាយជាធម្មតា បែកធ្លាយហើយ ដូច្នេះហើយ

មិនធ្វើនូវសេចក្តីសោក ចម្រើនមរណស្សតិតែម្យ៉ាង កាលកុដុម្ពិកៈទូលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន បណ្ឌិតក្នុងកាលណា បានធ្វើហើយយ៉ាងនោះ និងបានធ្វើក្នុងកាលណា សូមទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គ កាលទ្រង់ប្រកាសសេចក្តីនោះ ទើបទ្រង់នាំអតីតនិទានមក ញុំាងឧរគជាតក ក្នុងបញ្ចកនិបាតឲ្យពិស្តារហើយ ។

កូនរបស់ខ្ញុំ លះបង់នូវសរីរៈហើយទៅ ដូចជាពស់ លះបង់នូវសំណាកចាស់ កាលបើសរីរៈប្រើប្រាស់មិនបាន ធ្វើកាលកិរិយាទៅកាន់លោកខាងមុខយ៉ាងនេះ រាងកាយកាលត្រូវគេដុតរមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួលនៃញាតិទាំងឡាយ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយចំពោះកូនន៎ុះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

ដូច្នេះហើយ ត្រាស់បន្តទៀតថា បណ្ឌិតក្នុងកាលមុន កាលកូនជាទីស្រឡាញ់ធ្វើកាលកិរិយាហើយយ៉ាងនោះ មិនប្រព្រឹត្តដូចអ្នកបោះបង់ការងារហើយអត់អាហារទ្រហោយំ ឥឡូវនេះ មិនធ្វើសេចក្តីសោក ដោយអំណាចមរណស្សតិភាវនា បរិភោគអាហារ និងអធិដ្ឋានការងារ ព្រោះដូច្នោះ អ្នកកុំគិតថា កូនជាទីស្រឡាញ់ធ្វើកាលកិរិយាហើយ ពិតហើយ សេចក្តីសោកក្តី ភ័យក្តី កាលកើត រមែងអាស្រ័យរបស់ជាទីស្រឡាញ់នោះឯងកើត ដូច្នេះ

ហើយ ទើបត្រាស់ព្រះគាថានេះថា

**បិយតោ ជាយតី សោកោ បិយតោ ជាយតី ភយំ**

**បិយតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ។**

សេចក្តីសោក កើតអំពីសេចក្តីស្រឡាញ់ ភ័យ កើតអំពី

សេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់

ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បិយតោ** ជាដើម សេចក្តីថា សេចក្តីសោកក្តី ភ័យក្តីដែលមានវដ្តៈជាមូល កាលកើតឡើង រមែងអាស្រ័យសត្វ ឬសង្ខារដែលជាទីស្រឡាញ់ប៉ុណ្ណោះកើត តែសេចក្តីសោក និងភ័យទាំងពីរនោះ មិនមានដល់បុគ្គលដែលដោះចាកសត្វ ឬសង្ខារជាទីស្រឡាញ់នោះបានហើយ ។

ក្នុងកាលចប់ទេសនា កុដុម្ពិកៈតាំងនៅហើយក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។៙

**រឿង កុដុម្ពិកៈម្នាក់ ចប់**

# រឿង នាងវិសាខាឧបាសិកា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងវិសាខាឧបាសិកា ត្រាស់ព្រះធម្មទេសនានេះថា **បេមតោ ជាយតី** ជាដើម ។

បានឮថា នាងវិសាខានោះ តាំងកុមារិកាឈ្មោះសុទត្តី ដែលជាចៅក្នុងនាទីរបស់ខ្លួន ឲ្យធ្វើជាអ្នកខ្នះខ្នែងដល់ភិក្ខុសង្ឃក្នុងផ្ទះ ។

ដោយសម័យដទៃ កុមារិកានោះបានធ្វើកាលកិរិយាហើយ នាងវិសាខាឲ្យធ្វើការកប់សរីរៈនាងហើយ មិនអាចអត់ធន់សេចក្តីសោកបាន មានទុក្ខទោមនស្ស ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលនាងវិសាខា ហេតុអ្វីទើបនាងមានទុក្ខទោមនស្ស មានមុខជោកដោយទឹកភ្នែក អង្គុយទ្រហោយំ ទើបនាងទូលសេចក្តីនោះ ហើយក្រាបទូលថា បពិត្រព្រះអង្គ កុមារិកានោះជាទីស្រឡាញ់របស់ខ្ញុំម្ចាស់ ជាអ្នកសម្បូរដោយវត្ត ឥឡូវនេះខ្ញុំម្ចាស់មិនបានឃើញអ្នកណាដែលមានសភាពដូច្នោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលនាងវិសាខា ក្នុងក្រុងសាវត្ថីមានមនុស្សប្រមាណប៉ុន្មាន នាងវិសាខាទូលថា បពិត្រព្រះអង្គ ទ្រង់នោះឯងត្រាស់ដល់ខ្ញុំម្ចាស់ថា ក្នុងក្រុងសាវត្ថីមានមនុស្ស ៧ កោដិ ។

ព្រះសាស្តាត្រាស់ថា បើជនមានប្រមាណប៉ុណ្ណេះ បុគ្គលដូចជាចៅស្រីរបស់នាងសោត នាងគប្បីប្រាថ្នាឬ នាងវិសាខាទូលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ព្រះសាស្តាត្រាស់ថា ជនក្នុងក្រុងសាវត្ថីដែលធ្វើកាលកិរិយាមួយថ្ងៃ

ប៉ុន្មាន នាងវិសាខាទូលថា បពិត្រព្រះអង្គ ច្រើនណាស់ ព្រះសាស្ដាត្រាស់ថា បើដូច្នេះ ពេលដែលនាងសោយសោក ក៏មិនគប្បីមានមិនមែនឬ នាងដើរយំក្នុងពេលយប់ និងពេលថ្ងៃឬ នាងវិសាខាទូលថា បពិត្រព្រះអង្គ សូមលើកទុកចុះ ខ្ញុំម្ចាស់ជ្រាបហើយ ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងនាងថា បើដូច្នោះ នាងកុំសោយសោក សេចក្ដីសោកក្ដី ការខ្លាចក្ដី រមែងកើតអំពីសេចក្ដីស្រឡាញ់ ដូច្នេះហើយ ទើបត្រាស់គាថានេះថា

**បេមតោ ជាយតី សោកោ បេមតោ ជាយតី ភយំ**
**បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្ដីសោក កើតអំពីសេចក្ដីស្រឡាញ់ ភ័យ កើតអំពីសេចក្ដីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្ដីស្រឡាញ់ហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **បេមតោ** សេចក្ដីថា ព្រោះអាស្រ័យសេចក្ដីស្រឡាញ់ក្នុងបុត្រ និងធីតាជាដើមនោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង នាងវិសាខាឧបាសិកា ចប់**

# រឿង ស្តេចលិច្ឆវី

## លំនាំដើម

*ព្រះសាស្តា កាលទ្រង់អាស្រ័យនៅក្នុងក្រុងវេសាលី ប្រថាប់នៅនាគោជាគារសាលា ទ្រង់ប្រារព្ធស្តេចលិច្ឆវី ត្រាស់ព្រះធម្មទេសនានេះថា* **រតិយា ជាយតី** *ជាដើម ។*

*បានឮថា ក្នុងថ្ងៃមហោស្រពមួយ ស្តេចលិច្ឆវីប៉ុណ្ណោះ តែងគ្រឿងអលង្ការមិនដូចគ្នា ចេញអំពីព្រះនគរយាងទៅកាន់ឧទ្យាន ។ ព្រះសាស្តាចូលទៅបិណ្ឌបាត ទ្រង់ឃើញស្តេចលិច្ឆវីទាំងនោះ ទើបត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកមើលពួកស្តេចលិច្ឆវី ជនណាមិនធ្លាប់ឃើញទេវតាជាន់តាវត្តិង្ស ក៏ចូរមើលស្តេចលិច្ឆវីទាំងនោះចុះ ដូច្នេះហើយ យាងចូលទៅកាន់នគរ ។*

*ស្តេចលិច្ឆវីទាំងនោះ កាលទៅកាន់ឧទ្យាន នាំស្រីនគរសោភិនីម្នាក់ អាស្រ័យស្រីនោះ ត្រូវសេចក្តីប្រណែនគ្របសង្កត់ហើយ ប្រហារគ្នានិងគ្នា ញុំាងឈាមឲ្យហូរដូចស្ទឹង ។*

*គ្រានោះ ពួកក្នាក់ងារយកគ្រែសែងស្តេចលិច្ឆវីទាំងនោះមកហើយ ។ ចំណែកព្រះសាស្តា ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ក៏យាងចេញអំពីព្រះនគរ ។ ពួកភិក្ខុឃើញស្តេចលិច្ឆវី ដែលក្នាក់ងារនាំទៅយ៉ាងនោះ ទើបក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ពួកស្តេចលិច្ឆវីកាលអំពីព្រលឹម ប្រដាប់តាក់តែងហើយ ចេញអំពីព្រះនគរដូចពួកទេវតា ឥឡូវនេះ អាស្រ័យស្រីម្នាក់ ដល់នូវសេចក្តីវិនាសនេះហើយ ។*

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីសោកក្ដី ភ័យក្ដី កាលកើតរមែងកើតអាស្រ័យសេចក្ដីត្រេកអរនោះឯង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**រតិយា ជាយតី សោកោ    រតិយា ជាយតី ភយំ**
**រតិយា វិប្បមុត្តស្ស    នត្ថិ សោកោ កុតោ ភយំ ។**

សេចក្ដីសោក កើតអំពីតម្រេក ភ័យ កើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្ដីសោក ក៏លែងមាន ភ័យ នឹងមានមកអំពីណា ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **រតិយា** សេចក្ដីថា តែការត្រេកអរក្នុងកាមគុណ ៥ គឺព្រោះអាស្រ័យសេចក្ដីត្រេកអរក្នុងកាមគុណ ៥ នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ស្ដេចលិច្ឆវី ចប់**

# រឿង អនិត្ថិគន្ធកុមារ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនិត្ថិគន្ធកុមារ ត្រាស់ព្រះធម្មទេសនានេះថា **កាមតោ ជាយតី** ជាដើម ។

បានឮថា អនិត្ថិគន្ធកុមារនោះជាសត្វចុតិអំពីព្រហ្មលោក កើតក្នុងត្រកូលមានភោគៈច្រើនក្នុងក្រុងសាវត្ថី តាំងអំពីកើតហើយមិនប្រាថ្នាទៅជិតស្រី ត្រូវពួកស្រីចាប់ក៏ស្រែកយំ មាតាត្រូវពកុមារនោះដោយសំពត់ជូតក្បាល ( តែងខ្លួនធ្វើជាប្រុស ) ហើយទើបឲ្យបៅ ។

កុមារនោះចម្រើនវ័យហើយ កាលមាតាបិតាពោលថា នែបា អញធ្វើអាវាហមង្គលដល់អ្នក ក៏ឃាត់ថា ខ្ញុំមិនត្រូវការដោយស្រី កាលត្រូវអង្វររឿយៗ ទើបឲ្យហៅជាងមាស ៥០០ នាក់ ហើយឲ្យមាសទឹកដប់ មួយពាន់និក្ខៈ ឲ្យធ្វើជារូបស្រីយ៉ាងស្អាត គួរជ្រះថ្លាពន់ពេក កាលមាតាបិតាពោលទៀតថា នែបា កាលបាមិនធ្វើអាវាហមង្គល ត្រកូលវង្សនឹងតាំងនៅមិនបាន អញនឹងនាំកុមារិកាមកឲ្យ ក៏ពោលថា បើដូច្នោះ បើលោកទាំងពីរនាំកុមារិកាដែលមានសភាពដូច្នោះមកឲ្យខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់លោកទាំងពីរ ដូច្នេះហើយ ទើបបង្ហាញរូបមាសនោះ ។

លំដាប់នោះ មាតាបិតាឲ្យពួកព្រាហ្មណ៍មានឈ្មោះល្បីមក ហើយប្រាប់ថា កូនរបស់ខ្ញុំមានបុណ្យច្រើន គង់មានកុមារិកាធ្វើបុណ្យជាមួយបុត្រនេះពិត ចូរពួកអ្នកទៅ ចូរនាំយករូបមាសនេះទៅហើយ នាំនាងកុមារិកាដែលមានរូបដូច្នេះមក ដូច្នេះហើយ បញ្ជូនព្រាហ្មណ៍ទាំងនោះទៅ ។ ព្រាហ្មណ៍ទាំងនោះ

ទទួលថា សាធុ ត្រាច់ចារិកទៅដល់សាគលនគរ ក្នុងដែនមទ្ទៈ ។

ក្នុងនគរនោះ មានកុមារិកាម្នាក់មានរូបស្អាត មានអាយុ ១៦ ឆ្នាំ មាតាបិតាឲ្យនាងនៅត្រង់ផ្ទៃប្រាសាទខាងលើជាន់ទី ៧ ព្រាហ្មណ៍ទាំងនោះឯងគិតគ្នាថា បើក្នុងនគរនេះមានកុមារិកាបែបនេះ ជនទាំងឡាយឃើញរូបមាសនេះហើយក៏នឹងពោលថា រូបសូននេះ ដូចកូនស្រីរបស់ត្រកូលឈ្មោះនោះ ដូច្នេះហើយទើបតម្កល់រូបមាសនោះទុកត្រង់ផ្លូវទៅកាន់កំពង់ទឹក អង្គុយយាមក្នុងចំណែកម្ខាង ។

លំដាប់នោះ ស្រីមេដោះម្នាក់របស់កុមារិកានោះ ឲ្យកុមារិកានោះងូតទឹកហើយ ប្រាថ្នានឹងងូតឯងម្តង ទើបចុះកាន់កំពង់ទឹក ឃើញរូបនោះសម្គាល់ថាជាកូនស្រីរបស់អញ ទើបពោលថា ឱ ហងក្បាលរឹង អញឲ្យងូតទឹកហើយ ចេញមកអម្បាញ់មិញនេះឯង ហងមកទីនេះមុនអញ ដូច្នេះហើយ ទើបវាយដោយដៃ ដឹងភាពដែលរូបនោះរឹង មិនមានវិការ ទើបពោលថា អញស្មានថាស្រីនេះ ជាកូនស្រីរបស់អញ នេះជាអ្វីហ្ន៎ ។

លំដាប់នោះ ព្រាហ្មណ៍ទាំងនោះសួរមេដោះនោះថា នែនាង ធីតារបស់នាងបែបនេះឬ ស្រីមេដោះពោលថា របស់នេះមានតម្លៃអ្វីក្នុងសម្នាក់ធីតារបស់ខ្ញុំ ព្រាហ្មណ៍ពោលថា បើដូច្នោះ ចូរនាងបង្ហាញធីតារបស់នាងដល់ពួកយើង ស្រីមេដោះនោះទៅកាន់ផ្ទះ មួយអន្លើដោយព្រាហ្មណ៍ទាំងនោះហើយ ក៏ប្រាប់ដល់ចៅហ្វាយ ។ ម្ចាស់ផ្ទះធ្វើការរាក់ទាក់ជាមួយពួកព្រាហ្មណ៍ហើយ ឲ្យធីតាចុះមកឈរក្បែររូបមាស ក្នុងប្រាសាទជាន់ខាងក្រោម រូបមាសបានជារូបអស់

ស្មើហើយ ។ ពួកព្រាហ្មណ៍ឲ្យរូបមាសនោះដល់ម្ចាស់ផ្ទះហើយ នាំកុមារិកាទុកហើយ ទៅប្រាប់ដល់មាតាបិតារបស់អនិត្ថិគន្ធកុមារ ។

មាតាបិតានោះមានចិត្តត្រេកអរហើយពោលថា ចូរអ្នកទាំងឡាយទៅនាំកុមារិកានោះមកដោយរហ័ស ដូច្នេះហើយ បញ្ជូនទៅដោយសក្ការៈដ៏ច្រើន ។

ចំណែកកុមារបានឮដំណឹងនោះ ក៏ញុំាងសេចក្តីស្រឡាញ់ឲ្យកើត ដោយអំណាចការបានឮថា ទារិកាមានរូបស្អាតជាងរូបមាសទៅទៀត ទើបពោលថា អ្នកទាំងឡាយ ចូរនាំមកដោយរហ័សចុះ ។ កុមារិកានោះឯង ដែលគេលើកឡើងកាន់យានទាំមក មានរោគខ្យល់ព្រោះការរលាក់នៃយានឲ្យកើតឡើងហើយ បានធ្វើកាលកិរិយាក្នុងរវាងផ្លូវនោះឯង ព្រោះភាពដែលនាងជាសុខុមាលជាតិ ។

កុមារសួរជានិច្ចថា មកហើយឬ ជនទាំងឡាយមិនប្រាប់ដល់កុមារនោះដែលសួរដោយសេចក្តីស្នេហាដ៏ក្រៃលែង ដោយរហ័សនោះឯង ពន្យា ២-៣ ថ្ងៃហើយ ទើបប្រាប់រឿងនោះ ។ កុមារនោះកើតទោមនស្សឡើងថា អញមិនបានសមាគមជាមួយស្រីបែបនោះ បានជាអ្នកដល់នូវសេចក្តីទុក្ខ ដូចភ្នំសង្កត់ហើយ ។

ព្រះសាស្តា ទ្រង់ឃើញឧបនិស្ស័យរបស់កុមារនោះ កាលយាងទៅបិណ្ឌបាត ទើបយាងទៅកាន់ទ្វារផ្ទះនោះ ។ គ្រានោះ មាតាបិតារបស់កុមារនោះ យាងព្រះសាស្តាចូលទៅខាងក្នុងផ្ទះ ហើយអង្គាសដោយគោរព ។

ក្នុងកាលស្រេចភត្តកិច្ច ព្រះសាស្តាត្រាស់សួរថា អនិត្ថិគន្ធកុមារទៅណា មាតាបិតាពោលថា បពិត្រព្រះអង្គ អនិត្ថិគន្ធកុមារនោះ ដេកអត់អាហារក្នុង

បន្ទប់ ព្រះសាស្តាត្រាស់ថា ចូរហៅគេមក ។

អនិត្ថិគន្ធកុមារនោះ មកថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងចំណែកម្ខាង កាលព្រះសាស្តាត្រាស់សួរថា ម្នាលកុមារ សេចក្តីសោកដ៏មានកម្លាំងកើតឡើងហើយដល់អ្នកឬ ទើបក្រាបទូលថា ករុណាព្រះអង្គ សេចក្តីសោកមានកម្លាំងកើតឡើងដល់ខ្ញុំព្រះអង្គ ព្រោះបានឮថា ស្រីឈ្មោះនេះ ធ្វើកាលកិរិយាក្នុងរវាងផ្លូវហើយ សូម្បីកត្ត ខ្ញុំព្រះអង្គក៏មិនឃ្លាន ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងកុមារនោះថា ម្នាលកុមារ អ្នកដឹងទេថា សេចក្តីសោក កើតដល់អ្នក ព្រោះអាស្រ័យអ្វី អនិត្ថិគន្ធកុមារទូលថា បពិត្រព្រះអង្គ មិនដឹងទេ ព្រះសាស្តាត្រាស់ថា ម្នាលកុមារ សេចក្តីសោកមានកម្លាំង កើតឡើងដល់អ្នក ព្រោះអាស្រ័យកាម ព្រោះសេចក្តីសោកក្តី ភ័យក្តី រមែងកើតឡើង ព្រោះអាស្រ័យកាម ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**កាមតោ ជាយតី សោកោ កាមតោ ជាយតី ភយំ**
**កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្តីសោក កើតអំពីកាម ភ័យ កើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកអំពីណា ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កាមតោ** សេចក្តីថា ចាកវត្ថុកាម និង

កិលេសកាម អធិប្បាយថា សេចក្តីសោកក្តី ភ័យក្តី រមែងអាស្រ័យកាមទាំង ២ យ៉ាងនោះកើត ។

ក្នុងកាលចប់ទេសនា អនិត្ថិគន្ធកុមារតាំងនៅហើយក្នុងសោតាបត្តិផល ដូច្នេះឯង ។ល។

## រឿង អនិត្ថិគន្ធកុមារ ចប់

# រឿង ព្រាហ្មណ៍ម្នាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **តណ្ហាយ ជាយតី** ជាដើម ។

បានឮថា ព្រាហ្មណ៍នោះជាមិច្ឆាទិដ្ឋិបុគ្គល ថ្ងៃមួយ ទៅកាន់ច្រាំងស្ទឹង ហើយ ភ្ជួរស្រែ ។ ព្រះសាស្តាទ្រង់ឃើញការដល់ព្រមនៃឧបនិស្ស័យរបស់ព្រាហ្មណ៍នោះ ទើបយាងទៅកាន់សម្នាក់របស់ព្រាហ្មណ៍ ព្រាហ្មណ៍សូម្បីឃើញព្រះដ៏មានព្រះភាគ ក៏មិនធ្វើសាមីចិកម្ម បានអង្គុយស្ងៀម ។

គ្រានោះ ព្រះសាស្តាត្រាស់មុនថា ម្នាលព្រាហ្មណ៍ អ្នកកំពុងធ្វើអ្វី ព្រាហ្មណ៍ពោលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គកំពុងភ្ជួរស្រែ ព្រះសាស្តាត្រាស់ត្រឹមប៉ុណ្ណោះហើយ ក៏ចៀសចេញទៅ ។ ក្នុងថ្ងៃស្អែកឡើង ព្រះសាស្តាយាងទៅកាន់សម្នាក់របស់ព្រាហ្មណ៍នោះ ដែលមកហើយដើម្បីភ្ជួរ

ស្រែ ត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នកធ្វើអ្វី ទ្រង់បានឮថា បពិត្រព្រះគោតម ខ្ញុំកំពុងឆ្ការស្រែ ដូច្នេះហើយ ក៏យាងហួសទៅ សូម្បីក្នុងថ្ងៃបន្ទាប់មក ព្រះសាស្ដាក៏យាងទៅ ត្រាស់សួរយ៉ាងនោះ ទ្រង់បានស្ដាប់ថា បពិត្រព្រះគោតម ខ្ញុំកំពុងព្រោះ កំពុងបញ្ចូលទឹក កំពុងថែស្រែ ដូច្នេះហើយ ក៏ចៀសចេញទៅ ។

ថ្ងៃមួយ ព្រាហ្មណ៍ក្រាបទូលព្រះអង្គថា ព្រះគោតមយាងមកហើយតាំងអំពីថ្ងៃដែលខ្ញុំព្រះអង្គឆ្ការស្រែ បើសម្ទូងរបស់ខ្ញុំព្រះអង្គឲ្យផល ខ្ញុំព្រះអង្គនឹងចែកដល់ទ្រង់ខ្លះ បើមិនទាន់ថ្វាយទ្រង់ ខ្ញុំព្រះអង្គក៏មិនទំពាស៊ី តាំងអំពីនេះជាដើមទៅ ទ្រង់ជាសម្លាញ់របស់ខ្ញុំព្រះអង្គ ។

សម័យក្រោយទៀត ស្រូវរបស់ព្រាហ្មណ៍នោះចេញផ្លែហើយ កាលព្រាហ្មណ៍នោះ ធ្វើកិច្ចទាំងពួងដើម្បីប្រូតដោយតាំងចិត្តថា សម្ទូងរបស់អញឲ្យផលហើយ អញនឹងឲ្យប្រូតតាំងអំពីស្អែកនេះទៅ មហាមេឃញុំាងភ្លៀងឲ្យធ្លាក់មួយយប់ នាំយកស្រូវទៅអស់ ស្រែហាក់ដូចទីដែលបុគ្គលឆ្ការអស់ ។

ព្រះសាស្ដា ទ្រង់ជ្រាបហើយក្នុងថ្ងៃដំបូងនោះឯងថា សម្ទូងនោះនឹងមិនឲ្យផល ។ ព្រាហ្មណ៍ទៅហើយអំពីព្រលឹម គិតថា អញពិនិត្យមើលស្រូវឃើញតែស្រែទទេ ទើបកើតសេចក្ដីសោកជាកម្លាំងគិតថា ព្រះសមណគោតមមកកាន់ស្រែរបស់អញ តាំងអំពីអញឆ្ការស្រែ អញក៏បានពោលនឹងលោកថា កាលសម្ទូងឲ្យផលហើយ ខ្ញុំនឹងចែកចំណែកឲ្យដល់លោក មិនទាន់ឲ្យលោកហើយ ខ្ញុំក៏មិនទំពាស៊ីតាំងអំពីនេះជាដើមទៅ លោកជាសម្លាញ់របស់អញ

សេចក្តីប្រាថ្នាក្នុងចិត្តរបស់អញនោះ មិនដល់ទីបំផុតហើយ ព្រាហ្មណ៍នោះធ្វើការអត់អាហារ ដេកលើគ្រែតូចហើយ ។

លំដាប់នោះ ព្រះសាស្តា បានយាងទៅកាន់ទ្វារផ្ទះរបស់ព្រាហ្មណ៍នោះ ព្រាហ្មណ៍នោះជ្រាបការយាងមករបស់ព្រះសាស្តា ទើបប្រាប់បរិវារថា ចូរពួកអ្នកនាំសម្លាញ់របស់អញមក ឲ្យអង្គុយទីនេះ ។ ជនជាបរិវារបានធ្វើយ៉ាងនោះហើយ ព្រះសាស្តាប្រថាប់គង់ហើយ ត្រាស់សួរថា ព្រាហ្មណ៍ទៅណា កាលគេក្រាបទូលថា ដេកក្នុងបន្ទប់ ក៏ត្រាស់ឲ្យហៅមកដោយព្រះពុទ្ធតម្រាស់ថា ចូរពួកអ្នកហៅព្រាហ្មណ៍នោះមក ហើយត្រាស់នឹងព្រាហ្មណ៍ដែលមកអង្គុយហើយ ក្នុងចំណែកម្ខាងថា ម្នាលព្រាហ្មណ៍ តើអ្នកកើតអ្វី ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម លោកមកកាន់សម្នាក់របស់ខ្ញុំ តាំងអំពីថ្ងៃភ្ជួរស្រែ សូម្បីខ្ញុំក៏បានពោលថា កាលសម្ទូងឲ្យផលហើយ នឹងចែកចំណែកលោកខ្លះ ការប្រាថ្នាក្នុងចិត្តរបស់ខ្ញុំមិនសម្រេចឡើយ ព្រោះហេតុនោះ ទើបសេចក្តីសោកកើតហើយដល់ខ្ញុំ សូម្បីភត្តក៏ខ្ញុំមិនឃ្លាន ។

គ្រានោះ ព្រះសាស្តាត្រាស់សួរព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ អ្នកដឹងទេថា សេចក្តីសោកកើតហើយដល់អ្នកព្រោះអាស្រ័យអ្វី កាលព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំមិនជ្រាបទេ លោកជ្រាបឬ ទើបត្រាស់ថា យ៉ាងនោះឯងព្រាហ្មណ៍ សេចក្តីពិត សេចក្តីសោកក្តី ភ័យក្តី កាលនឹងកើតរមែងអាស្រ័យតណ្ហាកើតឡើង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**តណ្ហាយ ជាយតី សោកោ តណ្ហាយ ជាយតី ភយំ**

**តណ្ហាយ វិប្បមុត្តស្ស ឯត្ថិ សោកោ កុតោ ភយំ ។**

*សេចក្តីសោក កើតអំពីតណ្ហា ភ័យ កើតអំពីតណ្ហា កាលបើរូបស្រឡះចាកតណ្ហាហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **តណ្ហាយ** *បានដល់ តណ្ហាដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ អធិប្បាយថា សេចក្តីសោកជាដើមរមែងអាស្រ័យតណ្ហានោះកើតឡើង ។*

*ក្នុងកាលចប់ទេសនា ព្រាហ្មណ៍តាំងនៅហើយ ក្នុងសោតាបត្តិផលដូច្នេះឯង ៕៚*

រឿង ព្រាហ្មណ៍ម្នាក់ ចប់

# រឿង កុមារ ៥០០

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធកុមារ ៥០០ តាមចន្លោះផ្លូវ ត្រាស់ព្រះធម្មទេសនានេះថា* **សីលទស្សនសម្បន្នំ** *ជាដើម ។*

*សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះសាស្តាមានភិក្ខុ ៥០០ ជាបរិវារ មួយអន្ទើដោយព្រះអសីតិមហាថេរៈ ចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត បាន*

ទតឃើញកុមារ ៥០០ លើកល្អីនំចេញអំពីក្រុង ហើយទៅឧទ្យានក្នុងថ្ងៃមហោស្រពមួយ កុមារទាំងនោះ ថ្វាយបង្គំព្រះសាស្តាហើយ ចៀសចេញទៅមិនពោលនឹងភិក្ខុត្រឹមតែមួយរូបថា សូមលោកម្ចាស់ទទួលនំ ។

ព្រះសាស្តា ត្រាស់នឹងភិក្ខុទាំងឡាយ ក្នុងកាលដែលភិក្ខុនោះទៅហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឆាន់នំដែរឬទេ ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គនំនៅឯណា ព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយមិនឃើញពួកក្មេងកាន់ល្អីនំដើរធ្វងទៅហើយទេឬ ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ក្មេងបែបនោះមិនឲ្យនំដល់អ្នកណាឡើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្មេងទាំងនោះមិននិមន្តតថាគត ឬអ្នកទាំងឡាយដោយនំក៏ពិត តែភិក្ខុដែលជាម្ចាស់របស់នំកំពុងមកឯក្រោយ ឆាន់នំសិនហើយ សឹមទៅ ទើបគួរ ។

តាមធម្មតាព្រះពុទ្ធទាំងឡាយមិនមានសេចក្តីប្រណែន ឬការប្រទូស្តក្នុងបុគ្គលណាម្នាក់ឡើយ ព្រោះដូច្នោះ ព្រះសាស្តាត្រាស់ពាក្យនេះហើយ ទើបនាំភិក្ខុសង្ឃទៅប្រថាប់គង់ក្រោមម្លប់ឈើមួយដើម ។

ពួកក្មេងឃើញព្រះកស្សបត្ថេរដើរមកឯក្រោយ កើតសេចក្តីស្រឡាញ់មានសរីរៈពេញដោយកម្លាំងបីតិ ដាក់ល្អីថ្វាយបង្គំព្រះថេរៈ ដោយបញ្ចង្គប្រតិស្ឋាន លើកនំព្រមទាំងល្អីនោះឯង ពោលនឹងព្រះថេរៈថា សូមលោកម្ចាស់និមន្តទទួលចុះ ។

លំដាប់នោះ ព្រះថេរៈពោលនឹងកុមារទាំងនោះថា នុ៎ះព្រះសាស្តានាំភិក្ខុសង្ឃទៅប្រថាប់គង់ហើយត្រង់គល់ឈើ ទើបពួកក្មេងកាន់ទេយ្យធម៌ទៅថ្វាយ

ដល់ភិក្ខុសង្ឃ ពួកក្មេងទទួលពាក្យថា សាធុ លោកម្ចាស់ ហើយត្រឡប់ទៅព្រមជាមួយព្រះថេរៈនោះឯង ប្រគេននំហើយឈរមើលក្នុងចំណែកម្ខាង បានថ្វាយទឹកក្នុងពេលឆាន់ស្រេចហើយ ។

ភិក្ខុទាំងឡាយពោលទោសថា ពួកក្មេងប្រគេនភិក្ខាព្រោះយល់មុខ មិនទទួលព្រះសម្មាសម្ពុទ្ធ ឬព្រះមហាថេរៈទាំងឡាយដោយនំ ឃើញព្រះមហាកស្សបត្ថេរហើយ កាន់យកនំ មួយអន្ទើដោយល្អិនោះឯងមកហើយ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដូចគ្នានឹងកស្សបៈ ដែលជាបុត្ររបស់តថាគត ជាទីស្រឡាញ់របស់ពួកទេវតា និងមនុស្ស ទេវតា និងមនុស្សទាំងឡាយ ធ្វើការបូជាដោយបច្ច័យ ៤ ដល់លោកដោយពិត ដូច្នេះហើយ ត្រាស់ព្រះគាថាថា

**សីលទស្សនសម្បន្នំ ធម្មដ្ឋំ សច្ចវាទិនំ**
**អត្តនោ កម្មកុព្វានំ តញ្ជនោ កុរុតេ បិយំ ។**

ជនតែងធ្វើបុគ្គលដែលបរិបូណ៌ដោយសីល និងការឃើញត្រូវ ស្ថិតនៅក្នុងធម៌ ពោលសច្ចធម៌ជាប្រក្រតី ធ្វើកម្មជារបស់ខ្លួននោះឲ្យជាទីស្រឡាញ់ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សីលទស្សនសម្បន្នំ** សេចក្តីថា ជាអ្នកដល់ព្រមដោយចតុប្បារិសុទ្ធិសីល និងការឃើញត្រូវ ដែលសម្បយុត្តដោយមគ្គ និងផល ។

បទថា **ធម្មដ្ឋំ** សេចក្តីថា ជាអ្នកតាំងនៅក្នុងលោកុត្តរធម៌ ៩ ប្រការ អធិប្បាយថា មានលោកុត្តរធម៌ដែលធ្វើឲ្យជាស់ច្បាស់ហើយ ។

បទថា **សច្ចវាទិនំ** សេចក្តីថា ឈ្មោះថា មានប្រក្រតីពោលវាចាសត្យ ដោយសច្ចញ្ញាណ ព្រោះភាពដែលសច្ចៈ ៤ លោកធ្វើឲ្យជាស់ច្បាស់ហើយ ដោយអាការ ១៦ ។

បាទព្រះគាថាថា **អត្តនោ កម្មកុព្វានំ** សេចក្តីថា សិក្ខា ៣ ឈ្មោះថា ការងាររបស់ខ្លួន ដែលបំពេញសិក្ខា ៣ នោះ ។

ពីរបទថា **តំ ជនោ** សេចក្តីថា លោកិយមហាជន រមែងធ្វើបុគ្គលនោះ ឲ្យជាទីស្រឡាញ់ គឺដែលប្រាថ្នានឹងឃើញ ប្រាថ្នានឹងថ្វាយបង្គំ ប្រាថ្នានឹងបូជា ដោយបច្ច័យ ៤ ដោយពិត ។

ក្នុងកាលចប់ទេសនា កុមារទាំងអស់ តាំងនៅក្នុងសោតាបត្តិផល ដូច្នេះឯង ។ល។

**រឿង កុមារ ៥០០ ចប់**

# រឿង ព្រះអនាគាមិត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈដែលជាអនាគាមីមួយអង្គ ត្រាស់ព្រះធម្មទេសនានេះថា **ឆន្ទជាតោ** ជាដើម ។

សេចក្ដីពិស្ដារ ថ្ងៃមួយ ពួកសទ្ធិវិហារិកសួរព្រះថេរៈនោះថា បពិត្រលោកម្ចាស់ ការសម្រេចធម្មវិសេសរបស់លោកម្ចាស់មានឬ ។

ព្រះថេរៈខ្មាស ព្រោះថាសូម្បីជនជាគ្រហស្ថក៏គង់សម្រេចអនាគាមិផលបាន ក្នុងពេលសម្រេចអរហត្តហើយនោះឯង អញនឹងប្រាប់សទ្ធិវិហារិកទាំងនោះ ដូច្នេះហើយ មិនពោលពាក្យណាឡើយ ធ្វើកាលកិរិយាហើយកើតក្នុងទេវលោកជាន់សុទ្ធាវាស ។

លំដាប់នោះ ពួកសទ្ធិវិហារិករបស់លោកយំខ្សឹកខ្សួល ទៅកាន់សម្នាក់ព្រះសាស្ដា ថ្វាយបង្គំព្រះសាស្ដាហើយទ្រហោយំនោះឯង អង្គុយក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយពួកអ្នកយំធ្វើអ្វី ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គធ្វើកាលកិរិយាហើយ ព្រះសាស្ដាត្រាស់ថា ណ្ហើយចុះ ភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំគិតថ្វីឡើយ នុ៎ះ ឈ្មោះថា ជាធម៌ទៀង ។ ភិក្ខុទាំងឡាយទូលថា ករុណាព្រះអង្គ សូម្បីខ្ញុំព្រះអង្គក៏ជ្រាប តែពួកខ្ញុំព្រះអង្គបានសួរដល់ការសម្រេចធម៌វិសេសនឹងព្រះឧបជ្ឈាយ៍ លោកមិនប្រាប់ពាក្យណាឡើយ ធ្វើកាលកិរិយាហើយ ហេតុនោះ ទើបពួកខ្ញុំព្រះអង្គជាទុក្ខ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកកុំគិតឡើយ ឧបជ្ឈាយ៍របស់ពួកអ្នកបានអនាគាមិផលហើយ ខ្មាសថា សូម្បីពួកគ្រហស្ថក៏សម្រេចអនាគាមិផលនោះ តែលុះសម្រេចអរហត្តហើយ ទើបប្រាប់ដល់ពួកសទ្ធិវិហារិកនោះ មិនប្រាប់ពាក្យណាមួយដល់អ្នកឡើយ ធ្វើកាលកិរិយាហើយ កើតក្នុងសុទ្ធាវាស ម្នាលភិក្ខុទាំងឡាយ ចូរដាក់ចិត្តចុះ ឧបជ្ឈាយ៍របស់ពួកអ្នកដល់នូវភាពជាបុគ្គល ដែលមានចិត្តមិនអាឡោះអាល័យក្នុងកាមទាំងឡាយ មានក្រសែទៅខាងលើ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**ឆន្ទជាតោ អនក្ខាតេ មនសា ច ផុដោ សិយា**
**កាមេ ច អប្បដិពទ្ធចិត្តោ ឧទ្ធំសោតោតិ វុច្ចតិ ។**

បុគ្គលអ្នកមានសេចក្តីប្រាថ្នាចំពោះព្រះនិព្វាន ដែលគេនិយាយប្រាប់គ្នា មិនបានផង ជាអ្នកមានមគ្គចិត្ត និងផលចិត្ត ( ខាងក្រោម ) ប៉ះពាល់ហើយផង មានចិត្តមិនប្រតិព័ទ្ធក្នុងកាមផង តថាគតហៅថា ជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅក្នុងខាងលើ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឆន្ទជាតោ** សេចក្តីថា មានឆន្ទៈកើតហើយដោយអំណាចការពេញចិត្តក្នុងភាពជាបុគ្គលប្រាថ្នាដើម្បីធ្វើ គឺដល់នូវឧស្សាហ៍ហើយ ។

បទថា **អនក្ខាតេ** គឺក្នុងព្រះនិព្វាន ពិតហើយ ព្រះនិព្វាននោះ ឈ្មោះថា

**អនក្ខាត** ព្រោះជាធម្មជាតដែលបុគ្គលណាម្នាក់ប្រាប់មិនបានថា ដែលបច្ច័យនោះធ្វើ ឬបណ្តាពណ៌ផ្សេងៗ មានពណ៌ខៀវជាដើមបែបនេះឡើយ ។

បាទព្រះគាថាថា **មនសា ច ផុដោ សិយា** សេចក្តីថា គប្បីជាបុគ្គលដែលចិត្តសម្បយុត្តដោយមគ្គផល ៣ ខាងក្រោមពាល់ត្រូវហើយ គឺឲ្យពេញហើយ ។ បទថា **អប្បដិពទ្ធចិត្តោ** សេចក្តីថា មានចិត្តមិនប្រតិព័ទ្ធក្នុងកាមទាំងឡាយ ដោយអំណាចនៃព្រះអនាគាមិមគ្គក្តី ។

បទថា **ឧទ្ធំសោតោ** សេចក្តីថា ភិក្ខុបែបនេះ កើតហើយក្នុងអវិហា បន្ទាប់អំពីនោះទៅ ក៏ទៅកាន់អកនិដ្ឋភព ដោយអំណាចបដិសន្ធិ លោកហៅថា ជាអ្នកមានក្រសែទៅខាងលើ ឧបជ្ឈាយ៍របស់ពួកអ្នកជាបុគ្គលបែបនោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះ តាំងនៅហើយក្នុងអរហត្តផល ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។៚

**រឿង ព្រះអនាគាមិត្ថេរ ចប់**

# រឿង ឆន្ទិយឧបាសក

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងព្រៃឥសិបតនៈ ទ្រង់ប្រារព្ធនន្ទិយៈ ត្រាស់ព្រះធម្មទេសនានេះថា **ចិរប្បវាសឹ** ជាដើម ។

បានឮថា ក្នុងក្រុងពារាណសីមានបុត្រនៃត្រកូលមួយ ដល់ព្រមដោយសទ្ធា ឈ្មោះនន្ទិយៈ បានជាអ្នកសម្បូរដោយសទ្ធា ទំនុកបម្រុងភិក្ខុសង្ឃ សង្គ្រោះនូវមាតាបិតា កាលចម្រើនវ័យ មាតាបិតាមានបំណងនាំធីតារបស់អ៊ំឈ្មោះថា នាងរេវតីមកអំពីផ្ទះដែលផ្ទុយគ្នា ( គឺមិនមានសទ្ធា ) ។ តែនាងជាមនុស្សមិនមានសទ្ធា មិនមានការឲ្យជាប្រក្រតី ទើបនន្ទិយៈមិនប្រាថ្នា ។

កាលនោះ មាតារបស់នន្ទិយៈពោលនឹងនាងរេវតីថា នែនាង ចូរនាងបូកលាបទីនោះរបស់ភិក្ខុសង្ឃ ហើយក្រាលអាសនៈក្នុងផ្ទះនេះ ចូរតម្កល់ជើងបាត្រក្នុងពេលភិក្ខុទាំងឡាយមកហើយ ចូរទទួលបាត្រ និមន្តឲ្យគង់ យកធម្មក្រកត្រងទឹកឆាន់ប្រគេន ហើយលាងបាត្រក្នុងពេលលោកឆាន់ស្រេច កាលនាងធ្វើយ៉ាងនេះ នឹងជាទីជូនចិត្តដល់កូនរបស់ខ្ញុំ ។ នាងបានធ្វើយ៉ាងនោះហើយ ។ បន្ទាប់មក មាតាបិតាពោលដល់ការប្រព្រឹត្តរបស់នាងដល់បុត្រថា នាងជាអ្នកអត់ធន់ចំពោះឱវាទ កាលនន្ទិយៈទទួលថា សាធុ ទើបកំណត់ថ្ងៃហើយធ្វើអាវាហមង្គល ។

លំដាប់នោះ នន្ទិយៈពោលនឹងនាងថា បើនាងបម្រើភិក្ខុសង្ឃ និងមាតារបស់ខ្ញុំ នាងនឹងបានរបស់របរក្នុងផ្ទះនេះ ចូរជាអ្នកមិនប្រមាទចុះ ។ នាងទទួលថា សាធុ ហើយធ្វើជាអ្នកមានសទ្ធា ទំនុកបម្រុង ២-៣ ថ្ងៃ ដរាបដល់មាន

កូន ២ នាក់ ។ មាតារបស់នន្ទិយឧបាសក ធ្វើកាលកិរិយាហើយ កាពជាធំទាំងអស់ក្នុងផ្ទះ ក៏ធ្លាក់ដល់នាងរេវតីតែម្នាក់ ។

ចាប់តាំងអំពីមាតាធ្វើកាលកិរិយាហើយ នន្ទិយឧបាសក ក៏ជាមហាទានបតី ត្រៀមតម្កល់ទានសម្រាប់ភិក្ខុសង្ឃ និងផ្តើមតាំងតម្លៃអាហារសម្រាប់មនុស្សកំព្រា និងអ្នកដើរផ្លូវជាដើមត្រង់ទ្វារផ្ទះ ។ ក្នុងកាលបន្ទាប់មក គាត់ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា កំណត់អានិសង្សក្នុងការថ្វាយអាវាសបានហើយ ឲ្យធ្វើសាលា ៤ មុខ ប្រដាប់ដោយបន្ទប់ ៤ បន្ទប់ ក្នុងមហាវិហារ នាព្រៃឥសិបតនៈហើយ ឲ្យដាក់គ្រែ និងតាំងជាដើម ដើម្បីវេរអាវាសនោះ បានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយថ្វាយទឹកទក្ខិណោទកដល់ព្រះតថាគត ។ ប្រាសាទទិព្វសម្រេចដោយរតនៈ ៧ ប្រការសម្បូរដោយពួកនារីមានប្រមាណ ១២ យោជន៍ក្នុងទិសទាំងពួង ខាងលើប្រមាណ ១ រយយោជន៍ ផុសឡើងក្នុងតាវត្តិង្សទេវលោក ដំណាលគ្នានឹងការប្រូចទឹកទក្ខិណោទកក្នុងព្រះហស្តព្រះសាស្តានោះឯង ។

សម័យក្រោយមក ព្រះមហាមោគ្គល្លាន ទៅកាន់ទីចារិកក្នុងទេវលោកឈរហើយក្នុងទីមិនឆ្ងាយអំពីប្រាសាទនោះ សួរទេវបុត្រទាំងឡាយ ដែលមកកាន់សម្នាក់របស់ខ្លួនថា ប្រាសាទទិព្វពេញដោយពួកស្រីទេពអប្សរនោះ កើតហើយ ដើម្បីអ្នកណា ។

លំដាប់នោះ ពួកទេវបុត្រនោះ កាលប្រាប់ម្ចាស់របស់វិមានដល់ព្រះថេរៈនោះ ទើបពោលថា បពិត្រលោកម្ចាស់ វិមាននេះកើតហើយដើម្បីប្រយោជន៍

ដល់គហបតិបុត្ត ឈ្មោះនន្ទិយៈ ដែលសាងវិហារថ្វាយព្រះសាស្តា ក្នុងព្រៃឥសិបតនៈ ។ ចំណែកពួកស្រីទេពអប្សរ ឃើញព្រះថេរៈនោះហើយ ចុះអំពីប្រាសាទពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំកើតក្នុងទីនេះដោយបំណងថានឹងជាស្រីបម្រើរបស់នន្ទិយៈ តែមិនឃើញនន្ទិយៈនោះ ជាអ្នកខ្វាចពន់ពេក ព្រោះកាលលះមនុស្សសម្បត្តិ ហើយកាន់យកទិព្វសម្បត្តិ ដូចការទម្លាយថាសដី ហើយកាន់យកថាសមាសដូច្នេះ សូមលោកម្ចាស់ប្រាប់គាត់ ដើម្បីប្រយោជន៍ដល់ការមកក្នុងទីនេះ ។

ព្រះថេរៈត្រឡប់មកអំពីទេវលោកនោះហើយ ចូលទៅគាល់ព្រះសាស្តា ទូលសួរថា បពិត្រព្រះអង្គ ទិព្វសម្បត្តិរមែងកើតដល់បុគ្គលដែលធ្វើសេចក្តីល្អ ដែលនៅជាមនុស្សនេះឯងដែរឬទេ ។

ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន ទិព្វសម្បត្តិដែលកើតហើយដល់នន្ទិយៈក្នុងទេវលោក ក្រែងអ្នកឃើញហើយមិនមែនឬ ហេតុអ្វីទើបសួរតថាគតទៅវិញ ព្រះមោគ្គល្លានសួរថា បពិត្រព្រះអង្គ ទិព្វសម្បត្តិកើតបានយ៉ាងនោះឬ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះថេរៈថា មោគ្គល្លាន អ្នកនិយាយអ្វី ឧបមាដូចបុគ្គលដែលឈរត្រង់ទ្វារ ឃើញបុត្របងប្អូនដែលទៅកាន់ទឹកដីឆ្ងាយអស់កាលយូរត្រឡប់មក គប្បីមកកាន់ផ្ទះដោយរហ័សប្រាប់ថា មនុស្សឈ្មោះនោះមកហើយ បើដូច្នោះពួកញាតិរបស់គាត់ក៏ត្រេកអរហើយ ចេញមកដោយរួសរាន់ គប្បីត្រេកអរក្រៃលែងជាមួយបុគ្គលនោះថា ពុកមកហើយ ពុកមកហើយយ៉ាងណា ពួកទេវតាកាន់យកគ្រឿងបណ្ណាការដែលជាទិព្វ ១០ យ៉ាងទទួល ដោយគិតថា ខ្ញុំមុនៗ ហើយរមែងត្រេកអរនឹងស្ត្រី ឬបុរស ដែលធ្វើ

*បុណ្យក្នុងលោកនេះ លះលោកនេះទៅហើយ ទៅកាន់លោកខាងមុខដូច្នោះ ដូចគ្នា ដូច្នេះហើយ បានភាសិតព្រះគាថាទាំងនេះថា*

**ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ**
**ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ**
**តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ**
**បុញ្ញានិ បដិគ្គណ្ហន្តិ បិយំ ញាតីវ អាគតំ ។**

*ពួកញាតិក្តី មិត្រក្តី សម្លាញ់ក្តី រមែងត្រេកអរនឹងបុរស ដែលឃ្លាតគ្នាអស់កាលយូរ មកអំពីចម្ងាយដោយសួស្តី មកដល់ហើយ យ៉ាងណាមិញ បុណ្យទាំងឡាយ តែង ទទួលបុគ្គលដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្សលោកនេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយទទួលបុរស ជាទីស្រឡាញ់ ទើបមកដល់ដូច្នោះឯង ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **ចិរប្បវាសឹ** *គឺចេញទៅហើយអស់កាល យូរ ។*

*បាទព្រះគាថាថា* **ទូរតោ សោត្ថិមាគតំ** *សេចក្តីថា បុគ្គលបាននូវលាភ គឺមានសម្បត្តិដែលសម្រេចហើយ ព្រោះធ្វើពាណិជ្ជកម្ម ឬព្រោះធ្វើនូវទីដែល រាជបុរសមកហើយអំពីចម្ងាយ ដោយមិនមានឧបទ្រវៈ ។*

*បាទព្រះគាថា* **ញាតី មិត្តា សុហជ្ជា ច** *សេចក្តីថា ដល់ជនដែល ឈ្មោះថា ញាតិ ព្រោះអាចទាក់ទងគ្នាដោយត្រកូល និងឈ្មោះថា មិត្រ*

ព្រោះភាវៈដែលធ្លាប់ឃើញគ្នាជាដើម ហើយឈ្មោះថា មានចិត្តល្អ ព្រោះភាពជាអ្នកមានហទយៈល្អ ។

បាទព្រះគាថាថា **អភិនន្ទន្តិ អាគតំ** សេចក្តីថា ញាតិជាដើម ឃើញបុរសនោះហើយ រមែងត្រេកអរក្រៃលែងដោយអាការត្រឹមតែពោលថា មកល្អហើយ ឬដោយអាការត្រឹមតែធ្វើអញ្ជលី ម្យ៉ាងទៀត រមែងត្រេកអរក្រៃលែងនឹងបុគ្គលដែលមកដល់ផ្ទះហើយ ដោយអំណាចនាំទៅចំពោះនូវបណ្ណាការ មានប្រការផ្សេងៗ ។

បទថា **តថេវ** ជាដើម សេចក្តីថា បុណ្យទាំងឡាយ តាំងនៅក្នុងឋានៈដូចមាតាបិតានាំគ្រឿងបណ្ណាការ ១០ យ៉ាង គឺអាយុ វណ្ណៈ សុខ យសភាពជាអធិបតី និងភាពជាទិព្វ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈដែលជាទិព្វ ត្រេកអរ ឈ្មោះថា រមែងទទួលបុគ្គលដែលបានធ្វើបុណ្យហើយ ទៅអំពីលោកនេះ កាន់លោកខាងមុខដោយហេតុនោះឯង ។

ពីរបទថា **បិយំ ញាតីវ** សេចក្តីថា ដូចពួកញាតិដ៏សេស ឃើញញាតិជាទីស្រឡាញ់មកហើយ ទទួលក្នុងលោកនេះ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿងនន្ទិយឧបាសក ចប់**

**បិយវគ្គ ចប់**

**វគ្គទី ១៦ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា កោធវគ្គទី ១៧

[ ២៧ ] បុគ្គលគួរលះបង់សេចក្ដីក្រោធចេញ គួរលះបង់មានះចេញ គួរកន្លងសញ្ញោជនធម៌ទាំងអស់ចោលចេញ ទុក្ខទាំងឡាយ តែងមិនជាប់តាមបុគ្គល ដែលមិនជំពាក់ក្នុងនាម និងរូប មិនមានកិលេស គ្រឿងកង្វល់នោះឡើយ ។

បុគ្គលណា ឃាត់សេចក្ដីក្រោធ ដែលកើតឡើងហើយ ដូចសារថីទប់រថដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះថាជាសារថី ជនក្រៅពីនេះគ្រាន់តែជាអ្នកកាន់ខ្សែរ ( មិនមែនសារថីឡើយ ) ។ បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្ដីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។ បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១ កាលគេសុំវត្ថុសូម្បីមានតិច ក៏គួរឲ្យ ( តាមតិច ) ១ បុគ្គលគប្បីទៅកើតក្នុងសម្នាក់ទេវតាទាំងឡាយបាន ដោយហេតុទាំង ៣ នេះឯង ។

ជនទាំងឡាយណាជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ សង្រួមហើយដោយកាយទ្វារ ( ជាដើម ) ជានិច្ច ជនទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្ដាយ ។

អាសវៈទាំងឡាយរបស់បុគ្គល អ្នកភ្ញាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខា ទាំងថ្ងៃ ទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ។

ម្នាលអតុលៈ ការតិះដៀល និងការសរសើរនេះ ជារបស់បុរាណ ការតិះដៀល និងការសរសើរនេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ ( ព្រោះថា ) ជនទាំងឡាយ តែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀមក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើនក៏មាន និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណក៏មាន ( អ្នកណាៗក៏ដោយ ) ក្នុងលោក ដែលមិនត្រូវគេនិន្ទាគ្មានឡើយ បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយ តែក្នុងអតីតទេ នឹងមានទៅក្នុងអនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ ។

បើអ្នកប្រាជ្ញទាំងឡាយសង្កេតមើលរាល់ៗ ថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ក្នុងបញ្ញា និងសីល អ្នកណាគួរនឹងនិន្ទាបុគ្គល ដែលដូចជាគ្រឿងតែងមាសជម្ពូនទនោះបាន សូម្បីទេវតា និងមនុស្សទាំងឡាយ ក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរ ( ដូចគ្នា ) ។ បុគ្គលគប្បីរក្សានូវការកម្រើកកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត គប្បីរក្សានូវការកម្រើកវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត គប្បីរក្សានូវការកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោសុចរិត អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថាសង្រួមហើយដោយប្រពៃ ។

**កោធវគ្គទី ១៧ ចប់**

# អដ្ឋកថា
# កោធវគ្គទី ១៧

## រឿង ព្រះនាងរោហិណី
### លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធព្រះនាងរោហិណី ត្រាស់ព្រះធម្មទេសនានេះថា **កោធំ ជហេ** ជាដើម ។

បានឮថា គ្រាមួយ ព្រះអនុរុទ្ធបានទៅកាន់ក្រុងកបិលពស្ដុ មួយអន្លើដោយភិក្ខុ ៥០០ កាលនោះ ពួកព្រះញាតិរបស់លោក បានដំណឹងថាព្រះថេរៈនិមន្តមក ទើបទៅកាន់សម្នាក់ព្រះថេរៈ វៀរតែប្អូនស្រីរបស់ព្រះថេរៈ ឈ្មោះរោហិណី ។ ព្រះថេរៈសួរពួកព្រះញាតិថា ព្រះនាងរោហិណីនៅឯណា ពួកព្រះញាតិប្រាប់ថា បពិត្រលោកម្ចាស់ នៅក្នុងដំណាក់ ព្រះថេរៈសួរថា ហេតុអ្វីទើបមិនយាងមក ពួកញាតិប្រាប់ថា ព្រះនាងមិនអាចមកដោយខ្មាស ព្រោះថា រោគសើស្បែកកើតត្រង់សរីរៈរបស់នាង ។

ព្រះថេរៈពោលថា ចូរអ្នកទាំងឡាយយាងព្រះនាងមកចុះ ឲ្យទៅយាងព្រះនាងមកហើយ ទើបពោលយ៉ាងនេះនឹងព្រះនាង ដែលយាងមកហើយថា រោហិណី ហេតុអ្វីទើបព្រះនាងមិនយាងមក ព្រះនាងរោហិណីប្រាប់ថា បពិត្រលោកម្ចាស់ រោគស្បែកកើតឡើងត្រង់សរីរៈរបស់ខ្ញុំ ហេតុនោះទើបខ្ញុំមិនបាន

មកព្រោះខ្មាស ព្រះថេរៈប្រាប់ថា បើព្រះនាងធ្វើបុណ្យមិនគួរឬ ព្រះនាងរោហិណី សួរថា បពិត្រលោកម្ចាស់ តើធ្វើអ្វី ព្រះថេរៈពោលថា ចូរសាងរោងឆាន់ ព្រះនាងរោហិណីសួរថា ខ្ញុំនឹងយកអ្វីធ្វើ ព្រះថេរៈប្រាប់ថា គ្រឿងប្រដាប់របស់នាងមិនមានឬ ព្រះនាងរោហិណីពោលថា បពិត្រលោកម្ចាស់ មាន ព្រះថេរៈសួរថា តម្លៃប៉ុន្មាន ព្រះនាងរោហិណីទូលថា មានតម្លៃមួយម៉ឺន ។ ព្រះថេរៈពោលថា បើដូច្នោះ ចូរលក់គ្រឿងប្រដាប់នោះឲ្យសាងរោងឆាន់ចុះ ។

ព្រះនាងរោហិណីពោលថា បពិត្រលោកម្ចាស់ អ្នកណានឹងធ្វើឲ្យខ្ញុំ ។ ព្រះថេរៈសម្លឹងមើលញាតិដែលឈរក្នុងទីជិតហើយ ពោលថា ចូរជាភារៈរបស់ពួកអ្នកទាំងឡាយចុះ ។ ពួកព្រះញាតិពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់នឹងធ្វើអ្វី ព្រះថេរៈពោលថា អាត្មានឹងនៅក្នុងទីនេះដូចគ្នា បើដូច្នោះ ចូរពួកអ្នកនាំទព្វសម្ភារៈមកដើម្បីរោងឆាន់នេះ ។ ពួកព្រះញាតិទទួលថា សាធុ លោកម្ចាស់ ទើបនាំមកហើយ ។

ព្រះថេរៈរៀបចំរោងឆាន់ ទើបពោលនឹងនាងរោហិណីថា ចូរនាងធ្វើរោងឆាន់ពីរជាន់ ចាប់តាំងអំពីកាលដែលឲ្យផ្ទៃជាន់លើរៀបហើយ ចូរបោសផ្ទៃខាងក្រោម ហើយក្រាលអាសនៈជានិច្ច ចូរឲ្យតាំងឆ្នាំងទឹកផឹកជានិច្ច ។ ព្រះនាងទទួលថា សាធុលោកម្ចាស់ ហើយចំណាយគ្រឿងប្រដាប់ឲ្យធ្វើរោងឆាន់ពីរជាន់ ផ្តើមតាំងអំពីកាលដែលឲ្យផ្ទៃខាងលើរៀបហើយ បានធ្វើកិច្ច មានការបោសផ្ទៃខាងក្រោមជាដើមរឿយៗ ។ ពួកភិក្ខុក៏អង្គុយជានិច្ច ។

លំដាប់នោះ កាលព្រះនាងបោសរោងឆាន់នោះឯង រោគស្បែកក៏អន់ថយ

ទៅហើយ ។ កាលរោងឆាន់សម្រេច ព្រះនាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ បានថ្វាយខាទនីយៈដែលប្រណីតដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានគង់ពេញរោងឆាន់ ។

ព្រះសាស្ដា ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ត្រាស់សួរថា នេះជាទានរបស់អ្នកណា ព្រះអនុរុទ្ធពោលថា របស់នាងរោហិណីប្អូនស្រីរបស់ខ្ញុំព្រះអង្គ ព្រះសាស្ដាត្រាស់ថា នាងទៅណា ព្រះអនុរុទ្ធទូលថា បពិត្រព្រះអង្គនៅក្នុងជំណាក់ ព្រះសាស្ដាត្រាស់ថា ចូរពួកអ្នកហៅនាងមក ។

ព្រះនាងមិនបំណងនឹងយាងមក ពេលនោះព្រះសាស្ដាត្រាស់ឲ្យហៅព្រះនាងដែលមិនប្រាថ្នានឹងមកទាល់តែបាន ឯព្រះសាស្ដាត្រាស់នឹងព្រះនាងដែលយាងមកថ្វាយបង្គំប្រថាប់គង់ហើយថា រោហិណី ហេតុអ្វីទើបនាងមិនមក ព្រះនាងរោហិណីទូលថា បពិត្រព្រះអង្គ រោគស្បែកកើតត្រង់សរីរៈរបស់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់ខ្មាសដោយរោគនោះ ទើបមិនបានមក ។

ព្រះសាស្ដាត្រាស់ថា នាងដឹងទេថា រោគនុ៎ះ អាស្រ័យកម្មអ្វីរបស់នាងទើបកើតឡើង ។ ព្រះនាងរោហិណីទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មិនដឹងទេ ព្រះសាស្ដាត្រាស់ថា រោគនុ៎ះ អាស្រ័យសេចក្ដីក្រោធរបស់នាងទើបកើតឡើងហើយ ព្រះនាងរោហិណីទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់បានធ្វើកម្មអ្វី ។

លំដាប់នោះ ព្រះសាស្ដា ទ្រង់នាំអតីតនិទានមកត្រាស់ដល់ព្រះនាងថា

ក្នុងអតីតកាល អគ្គមហេសីរបស់ព្រះបាទពារាណសី ចង់អាឃាតក្នុងអ្នករបាំម្នាក់របស់ព្រះរាជា ព្រះនាងត្រិះរិះថា អញនឹងឲ្យទុក្ខដល់ស្រីនេះ ហើយ

*ឲ្យគេនាំខ្សែរធំមក ត្រាស់ឲ្យហៅស្រីអ្នករបាំនោះមកកាន់សម្នាក់របស់ខ្លួនហើយ ឲ្យដាក់កម្មេចខ្សែរលើដំណេក ត្រង់សំពត់ដណ្តប់ និងគ្រឿងប្រើប្រាស់ មានកម្រាលដេកជាដើមរបស់អ្នករបាំនោះ ដោយប្រការដែលនាងមិនដឹងខ្លួន បាចលើខ្លួនរបស់នាង ធ្វើនូវការចំអកលេង រំពេចនោះឯងខ្លួនប្រាណរបស់អ្នករបាំនោះបានពងឡើងជាដុំតូចដុំធំ នាងអេះ ទៅដេកលើដំណេក កាលនាងត្រូវកម្មេចខ្សែរលើដំណេកនោះ វេទនាដ៏ខ្លាំងបានកើតឡើងហើយ ។ អគ្គមហេសីក្នុងកាលនោះ បានជាព្រះនាងរោហិណី ។*

*ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ម្នាលនាងរោហិណី កម្មនោះ ដែលនាងធ្វើហើយក្នុងកាលនោះ សេចក្តីក្រោធក្តី ការប្រណៃនក្តី សូម្បីមានប្រមាណតិចតួច រមែងមិនគួរធ្វើឡើយ ដូច្នេះហើយ ទើបត្រាស់ ព្រះគាថានេះថា*

**កោធំ ជហេ វិប្បជហេយ្យ មានំ  សញ្ញោជនំ សព្វមតិក្កមេយ្យ**
**តន្នាមរូបស្មិំ  អសជ្ជមានំ  អកិញ្ចនំ នានុបតន្តិ ទុក្ខា ។**

*បុគ្គលគួរលះបង់សេចក្តីក្រោធចេញ គួរលះបង់មានះចេញ គួរកន្លងសញ្ញោជនធម៌ទាំងអស់ចោលចេញ ទុក្ខទាំងឡាយតែងមិនជាប់តាមបុគ្គល ដែលមិនចំពាក់ក្នុងនាម និងរូប មិនមានកិលេសគ្រឿងកង្វល់នោះឡើយ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **កោធំ** *សេចក្តីថា គប្បីលះសេចក្តីក្រោធ*

គ្រប់ៗ អាការក្តី មានះ ៩ យ៉ាងក្តី ។

បទថា **សញ្ញោជនំ** សេចក្តីថា គប្បីកន្លងនូវសញ្ញោជនៈទាំង ១០ យ៉ាង មានកាមរាគសញ្ញោជនៈជាដើម ។

បទថា **មសជ្ជមានំ** សេចក្តីថា មិនជាប់ជំពាក់ អធិប្បាយថា បុគ្គលណា ទាញយកនាមរូបដោយន័យថា រូបរបស់អញ វេទនារបស់អញជាដើម កាលនាមរូបនោះបែកទៅ រមែងសោយសោកក្តៅក្រហាយ បុគ្គលនេះ ឈ្មោះថា ជាប់ជំពាក់ក្នុងនាមរូប ចំណែកបុគ្គលមិនប្រកាន់យ៉ាងនោះ ឈ្មោះថា រមែងមិនជាប់ជំពាក់ ឈ្មោះថា ទុក្ខទាំងឡាយ រមែងមិនធ្លាក់ត្រូវបុគ្គលនោះ បុគ្គលមិនជាប់ជំពាក់នោះ ឈ្មោះថា មិនមានកិលេសជាគ្រឿងកង្វល់ ព្រោះមិនមានរាគៈជាដើម ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ព្រះនាងរោហិណីក៏តាំងនៅក្នុងសោតាបត្តិផល សរីរៈរបស់ព្រះនាងមានពណ៌ដូចមាសក្នុងខណៈនោះឯង ។ ព្រះនាងចុតិចាកអត្តភាពនោះហើយ កើតក្នុងវេវាងដែននៃទេវបុត្រ ៤ អង្គ ក្នុងស្ថានតាវត្តិង្ស បានជាអ្នកគួរជ្រះថ្លា ដល់នូវភាពជាបុគ្គលមានរូបស្អាតក្រៃលែង ទេវបុត្រទាំង ៤ អង្គឃើញនាងហើយ កើតនូវសេចក្តីស្រឡាញ់ដណ្តើមគ្នាថា នាងកើតក្នុងដែនរបស់យើង នាងកើតក្នុងដែនរបស់យើង ទៅកាន់សម្នាក់របស់សក្កទេវរាជក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គទាំង ៤ កើតនូវក្តីព្រោះអាស្រ័យទេពធីតានេះ សូមទ្រង់វិនិច្ឆ័យ

ក្តីនោះ ។ សក្កទេវរាជគ្រាន់តែឃើញព្រះនាង ក៏កើតសេចក្តីស្រឡាញ់ ត្រាស់យ៉ាងនេះថា ចាប់តាំងពីកាលដែលពួកអ្នកឃើញទេពធីតានេះហើយ ចិត្តកើតឡើងដូចម្តេច ។

លំដាប់នោះ ទេវបុត្រមួយអង្គក្រាបទូលថា ចិត្តរបស់ខ្ញុំព្រះអង្គដូចស្គរក្នុងពេលសង្គ្រាម មិនអាចស្ងប់បានឡើយ ។ ទេវបុត្រអង្គទី ២ ទូលថា ចិត្តរបស់ខ្ញុំព្រះអង្គដូចទឹកហូរធ្លាក់អំពីកំពូលភ្នំ រមែងប្រព្រឹត្តទៅរហ័សនោះឯង ។ ទេវបុត្រអង្គទី ៣ ទូលថា ចាប់តាំងពីកាលដែលខ្ញុំព្រះអង្គឃើញនាងហើយ ភ្នែកទាំងពីរលៀនចេញហើយ ដូចភ្នែករបស់ក្តាម ។ ទេវបុត្រអង្គទី ៤ពោលថា ចិត្តរបស់ខ្ញុំព្រះអង្គដូចទង់ដែលគេលើកឡើងលើចេតិយ មិនអាចតាំងនៅស្ងៀមបាន ។

គ្រានោះ សក្កទេវរាជត្រាស់នឹងទេវបុត្រ ៤ អង្គនោះថា បាទាំងឡាយចិត្តរបស់ពួកអ្នកល្មមអត់សង្កត់បាន ចំណែកខ្ញុំ កាលបានឃើញទេពធីតានេះទើបជាអ្នករស់នៅ បើមិនបាននឹងស្លាប់ ។ ទើបពួកទេវបុត្រទូលថា បពិត្រមហារាជ ពួកខ្ញុំព្រះអង្គ មិនត្រូវការដោយការស្លាប់របស់ព្រះអង្គ ហើយលះបង់ទេពធីតានោះថ្វាយសក្កទេវរាជ រួចចៀសចេញទៅ ។ ទេពធីតានោះបានជាទីសព្វព្រះហឫទ័យរបស់សក្កទេវរាជ កាលនាងក្រាបទូលថា ខ្ញុំម្ចាស់នឹងទៅកាន់ឧទ្យានឈ្មោះនោះ សក្កទេវរាជក៏មិនអាចជំទាស់ពាក្យរបស់នាងបានឡើយ ដូច្នេះឯង ។ល។

## រឿង ព្រះនាងរោហិណី ចប់

# រឿង ភិក្ខុមួយរូប

## លំនាំដើម

ព្រះសាស្តា កាលគង់នៅត្រង់អគ្គាឡវចេតិយ ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **យោ វេ ឧប្បតិតំ កោធំ** ជាដើម ។

សេចក្តីពិស្តារ ព្រះសាស្តា កាលទ្រង់អនុញ្ញាតសេនាសនៈដល់ភិក្ខុសង្ឃ ហើយ កាលសេនាសនៈទាំងឡាយ ដែលគ្រហស្ថទាំងឡាយ មានសេដ្ឋីអ្នកក្រុងរាជគ្រឹះជាដើមកំពុងឲ្យសាង ភិក្ខុក្រុងអាឡវីមួយរូប ធ្វើសេនាសនៈរបស់ខ្លួន ឃើញដើមឈើដែលពេញចិត្តមួយដើមហើយ ផ្តើមនឹងកាប់ ទេវតាកូនខ្ចីមួយអង្គ រូបកើតត្រង់ដើមឈើនោះ ពកូនដោយចង្កេះឈរអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំកាប់វិមានរបស់ខ្ញុំឡើយ ខ្ញុំមិនមានលំនៅ មិនអាចពកូនត្រាច់ ទៅកាន់ទីផ្សេងផ្សាសបានឡើយ ។

ភិក្ខុនោះគិតថា អញនឹងមិនបានដើមឈើបែបនេះក្នុងទីដទៃ ទើបមិនអើពើនឹងពាក្យរបស់ទេវតានោះ ។ ទេវតានោះគិតថា ភិក្ខុនេះ ឃើញទារកនេះហើយ គង់នឹងវៀរពិត ទើបដាក់បុត្រត្រង់មែកឈើ ។ ចំណែកភិក្ខុនោះមិនអាចញុំាំងពូថៅ ដែលខ្លួនងារឡើងហើយបាន ទើបកាប់ដៃទារកនោះដាច់ហើយ ទេវតាកើតសេចក្តីក្រោធដ៏មានកម្លាំង លើកដៃទាំងពីរឡើង ដោយចេតនាថា នឹងទះភិក្ខុនោះឲ្យស្លាប់ តែគិតទាន់យ៉ាងនេះថា ភិក្ខុនេះជាអ្នកមានសីល បើអញសម្លាប់ភិក្ខុនេះនឹងទៅកាន់នរក សូម្បីទេពធីតាដ៏សេស បានជួបភិក្ខុកាប់ដើមឈើរបស់ខ្លួន នឹងយកតម្រាប់តាមខ្ញុំថា ទេវតាអង្គនោះ សម្លាប់

ភិក្ខុ អញក៏ធ្វើយ៉ាងនោះដូចគ្នា ហើយនឹងសម្លាប់ភិក្ខុទាំងឡាយបង់ ភិក្ខុនេះមានម្ចាស់ អញនឹងត្រូវប្រាប់ដល់ម្ចាស់នោះឯង បញ្ឈប់ដៃទាំងពីរហើយទ្រហោយំ ទៅកាន់សម្នាក់របស់ព្រះសាស្ដា ថ្វាយបង្គំហើយ ឈរក្នុងទីសមគួរ នាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងនាងថា ម្នាលទេពធីតា តើនាងមានរឿងអ្វី ទេពធីតានោះពោលថា បពិត្រព្រះអង្គ សាវករបស់ព្រះអង្គធ្វើកម្មឈ្មោះនេះ ខ្ញុំម្ចាស់ប្រាថ្នានឹងសម្លាប់ តែគិតទាន់ ទើបមិនសម្លាប់ ហើយប្រញាប់មកទីនេះឯង ដូច្នេះហើយ ក្រាបទូលរឿងនោះដោយពិស្ដារ ។

ព្រះសាស្ដា ទ្រង់ស្ដាប់រឿងនោះហើយត្រាស់ថា ម្នាលទេពធីតា ត្រឹមត្រូវហើយ នាងសង្កត់សេចក្ដីក្រោធដែលកើតឡើងយ៉ាងនោះ ដូចហាមរថកំពុងវិលទៅបាន ឈ្មោះថាធ្វើល្អហើយ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ ធារយេ**
**តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ ។**

បុគ្គលណាឃាត់សេចក្ដីក្រោធ ដែលកើតឡើងហើយ ដូចសារថីទប់រថដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះថាជាសារថី ជនក្រៅអំពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ ( មិនមែនសារថីឡើយ ) ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះបទថា **ឧប្បតិតំ** បានដល់ ដែលកើតឡើងហើយ ។

ពីរបទថា **រថំ ភន្តំវ** សេចក្ដីថា ដូចនាយសារថីដែលឈ្លាស ហាមនូវរថដែលកំពុងស្ទុះទៅ ដោយសម្ទុះដ៏រហ័ស បញ្ឈប់បានតាមត្រូវការយ៉ាងណា បុគ្គលណាគប្បីសង្កត់ គឺអាចឃាត់សេចក្ដីក្រោធដែលកើតឡើងបានក៏ដូច្នោះ ។

បទថា **តមហំ** សេចក្ដីថា តថាគតហៅបុគ្គលនោះ ថាជាសារថី ។

ពីរបទថា **ឥតរោ ជនោ** សេចក្ដីថា ចំណែកជនក្រៅអំពីនេះ គឺសារថីរថរបស់ឥស្សរជន មានព្រះរាជា និងឧបរាជជាដើម រមែងឈ្មោះថាត្រឹមតែជាអ្នកកាន់ខ្សែ មិនមែនជាសារថីដ៏កំពូលឡើយ ។

ក្នុងកាលចប់ទេសនា ទេវតាតាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

ចំណែកទេពធីតា បានជាព្រះសោតាបន្ន ក៏នៅតែឈរយំ ។ គ្រានោះព្រះសាស្ដាត្រាស់សួរទេវតានោះថា ម្នាលទេពធីតា នាងមានរឿងអ្វី កាលទេវតាទូលថា បពិត្រព្រះអង្គ វិមានរបស់ខ្ញុំម្ចាស់ព្រះអង្គវិនាសហើយ ឥឡូវនេះ ខ្ញុំម្ចាស់ធ្វើដូចម្ដេច ទើបត្រាស់ថា កុំឡើយទេពធីតា នាងកុំគិត តថាគតនឹងឲ្យវិមានដល់នាង ហើយចង្អុលដើមឈើមួយដែលទេវតាចុតិទៅ កាលពីថ្ងៃមុន ក្បែរព្រះគន្ធកុដិ ក្នុងវត្តជេតពន ត្រាស់ថា ដើមឈើនោះ នៅក្នុងឱកាសឈ្មោះនោះ ទំនេរ ចូរនាងនៅអាស្រ័យត្រង់ដើមឈើនោះចុះ ។ ទេវតានោះចូលទៅអាស្រ័យដើមនោះហើយ តាំងអំពីនោះ ទេវតាដែលមានសក្តិធំដឹងថា វិមានរបស់ទេវតានេះ ព្រះសម្ពុទ្ធទ្រង់ប្រទាន ក៏មិនអាចធ្វើឲ្យនាងញាប់ញ័របាន ។

ព្រះសាស្តា ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុហើយ ទ្រង់បញ្ញត្តកូតគាមសិក្ខាបទដល់ភិក្ខុទាំងឡាយ ដូច្នេះឯង ។ល។

**រឿង ភិក្ខុមួយរូប ចប់**

# រឿង ឧត្តរាឧបាសិកា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ធ្វើកត្តកិច្ចក្នុងផ្ទះរបស់នាងឧត្តរាហើយ ទ្រង់ប្រារព្ធឧត្តរាឧបាសិកា ត្រាស់ព្រះធម្មទេសនានេះថា **អក្កោធេន ជិនេ កោធំ** ជាដើម ។

អនុបុព្វីកថាក្នុងរឿងឧត្តរាឧបាសិកានោះដូចតទៅនេះ

បានឮថា អ្នកកម្សត់ទុគ៌តឈ្មោះបុណ្ណៈ អាស្រ័យសុមនសេដ្ឋី ស៊ីឈ្នួលចិញ្ចឹមជីវិត នៅក្នុងក្រុងរាជគ្រឹះ ។ ក្នុងផ្ទះរបស់បុណ្ណៈ មានមនុស្សពីរនាក់ប៉ុណ្ណោះគឺ ភរិយារបស់គេម្នាក់ និងធីតាឈ្មោះឧត្តរាម្នាក់ ។

សម័យមួយ ពួករាជបុរសធ្វើនូវការឃោសនាក្នុងក្រុងរាជគ្រឹះថា អ្នកនគរគប្បីលេងនក្ខត្តឫក្សអស់ ៧ ថ្ងៃ ។ សុមនសេដ្ឋី បានឮពាក្យឃោសនានោះហើយ ទើបហៅបុណ្ណៈមកអំពីព្រលឹមពោលថា នែបា បរិជនរបស់ខ្ញុំបំណងនឹងលេងនក្ខត្តឫក្ស អ្នកនឹងលេងនក្ខត្តឫក្សដែរឬ ឬទៅធ្វើការស៊ីឈ្នួល បុណ្ណ-មាណពពោលថា បពិត្រលោកម្ចាស់ ឈ្មោះថា ការលេងនក្ខត្តឫក្ស ជា

របស់ពួកអ្នកមានទ្រព្យ ក្នុងផ្ទះរបស់ខ្ញុំ អង្ករសម្រាប់ដាំបាយ ដើម្បីទទួលទានក្នុងថ្ងៃស្អែកនេះក៏មិនមាន ។ ខ្ញុំត្រូវការអ្វីដោយនក្ខត្តឫក្ស ខ្ញុំបានគោហើយក៏នឹងទៅភ្ជួរស្រែ ។ សុមនសេដ្ឋីពោលថា បើដូច្នោះ ចូរឯងទទួលគោទៅចុះ ។ បុណ្ណមាណពបានទទួលគោដែលមានកម្លាំង និងនង្គ័លហើយ និយាយនឹងភរិយាថា នាងដ៏ចម្រើន អ្នកនគរលេងនក្ខត្តឫក្ស ខ្ញុំត្រូវទៅធ្វើការងារស៊ីឈ្នួល ព្រោះយើងជាមនុស្សក្រីក្រ ថ្ងៃនេះ នាងគប្បីស្ងោរបន្លែពីរចំណែក ហើយនាំភត្តទៅឲ្យខ្ញុំ រួចទៅស្រែ ។

ក្នុងកាលនោះ ព្រះសារីបុត្តត្ថេរ ចូលនិរោធសមាបត្តិ ៧ ថ្ងៃហើយ ក្នុងថ្ងៃនោះ ចេញហើយ ពិនិត្យមើលថា ថ្ងៃនេះ អាត្មាអញគួរប្រោសដល់អ្នកណាហ្ន៎ ឃើញបុណ្ណមាណពចូលក្នុងសំណាញ់ញាណរបស់ខ្លួនហើយ ពិចារណាថា បុណ្ណៈនេះមានសទ្ធាឬហ្ន៎ គេអាចសង្គ្រោះដល់អាត្មាអញដែរឬទេ ជ្រាបភាពដែលគេមានសទ្ធា អាចធ្វើការសង្គ្រោះបាន ហើយគេបានទទួលសម្បត្តិធំ ព្រោះបុណ្យនោះជាបច្ច័យហើយ ទើបកាន់យកបាត្រ និងចីវរ ទៅកាន់ទីភ្ជួរស្រែរបស់បុណ្ណៈ ឈរមើលគុម្ពឈើក្បែរមាត់អណ្តូង បុណ្ណៈឃើញព្រះថេរៈហើយ ទើបដាក់នង្គ័លថ្វាយបង្គំព្រះថេរៈ ដោយបញ្ចង្គប្រតិស្ឋាន គិតថា ព្រះថេរៈប្រហែលជាត្រូវការឈើស្ទន់ ទើបកាត់ឈើដែលជាកប្បិយប្រគេន ។

លំដាប់នោះ ព្រះថេរៈបាននាំយកបាត្រ និងសំពត់តម្រងទឹកចេញមកឲ្យគាត់គិតថា ព្រះថេរៈនឹងត្រូវការដោយទឹកឆាន់ ទើបកាន់យកបាត្រ និងសំពត់

តម្រងទឹកនោះហើយ ត្រងទឹកប្រគេន ។ ព្រះថេរៈគិតថា បុណ្ណៈនេះ នៅផ្ទះចុងគេនៃជនដទៃ បើអាត្មាអញទៅកាន់ផ្ទះរបស់គេ ភរិយារបស់បុណ្ណៈនេះនឹងមិនបានឃើញអាត្មាអញ ដូច្នេះ អាត្មាអញគួរនៅក្នុងទីនេះឯង ទម្រាំភរិយារបស់គេនាំភត្តដើរតាមផ្លូវមក ។ ព្រះថេរៈបានញុំាងកាលឲ្យកន្លងទៅបន្តិចបន្តួចក្នុងទីនោះឯង ជ្រាបភាពដែលភរិយារបស់បុណ្ណៈនោះ ឡើងកាន់ផ្លូវហើយ ទើបដើរបែរមុខទៅខាងក្នុងព្រះនគរ ។

នាងជួបព្រះថេរៈក្នុងរវាងផ្លូវហើយ គិតថា ជួនកាល ទេយ្យធម៌របស់អញមាន ជួនកាល កាលអញជួបលោកម្ចាស់ តែទេយ្យធម៌មិនមាន ថ្ងៃនេះអញជួបលោកម្ចាស់ផង ទេយ្យធម៌ក៏មានផង លោកម្ចាស់នឹងធ្វើសេចក្ដីអនុគ្រោះដល់អញ ឬអត់ហ្ន៎ នាងដាក់ភាជនៈភត្តចុះហើយ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋានហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំគិតថ្វីថា ភត្តនេះសៅហ្មង ឬប្រណីត សូមអនុគ្រោះដល់ទាសៈរបស់លោកម្ចាសផងចុះ ។

ព្រះថេរៈបង្អោនបាត្រចូលទៅ កាលនាងយកដៃម្ខាងទទួលភាជនៈ ម្ខាងទៀតប្រគេនភត្ត កាលបានពាក់កណ្ដាលទើបបិទបាត្រ ដោយពោលថា ល្មមហើយ ។ នាងពោលថា បពិត្រលោកម្ចាស់ ចំណែកត្រឹមតែមួយចំណែកខ្ញុំមិនអាចធ្វើឲ្យជាពីរចំណែកបាន លោកម្ចាស់ មិនចាំបាច់ធ្វើការសង្គ្រោះដល់ទាសៈរបស់លោកម្ចាស់តែក្នុងលោកនេះ សូមធ្វើសេចក្ដីសង្គ្រោះក្នុងបរលោកចុះ ខ្ញុំបំណងនឹងប្រគេនមិនឲ្យសេសសល់ឡើយ ដូច្នេះហើយ បានដាក់ភត្ត

ទាំងអស់ចូលក្នុងបាត្រព្រះថេរៈ ហើយធ្វើសេចក្តីប្រាថ្នាថា ខ្ញុំគប្បីជាអ្នកមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយនោះឯង ។

ព្រះថេរៈពោលថា ចូរសម្រេចយ៉ាងនោះចុះ ឈរធ្វើអនុមោទនាហើយ អង្គុយធ្វើភត្តកិច្ច ក្នុងទីដែលមានទឹកមួយកន្លែង ។

ចំណែកនាង ត្រឡប់ទៅរកអង្ករចម្អិនជាភត្តហើយ ។ សូម្បីបុណ្ណៈភ្ជួរដីបានប្រមាណកន្លះករីស មិនអាចអត់ធន់នឹងការស្រេកឃ្លានបាន ទើបដោះគោ ចូលទៅកាន់ម្លប់ឈើមួយកន្លែង អង្គុយចាំមើលផ្លូវ ។

លំដាប់នោះ ភរិយារបស់គាត់កាន់ភត្តដើរទៅ គ្រាន់តែឃើញគិតថា ប្តីរបស់អញត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ អង្គុយចាំមើលអញហើយ បើគាត់សម្លុតអញថា ម្តេចក៏ហ៊ានយឺតយូរម៉្លេះ ហើយយកជន្លួញវាយអញ កម្មដែលអញធ្វើហើយ ជារបស់ឥតប្រយោជន៍ អញគួរស្រែកប្រាប់ដល់គាត់មុននោះឯង ដូច្នេះហើយ ទើបពោលយ៉ាងនេះថា អ្នក សូមអ្នកធ្វើចិត្តឲ្យផូរផង់ត្រឹមតែមួយថ្ងៃចុះ ថ្ងៃនេះកុំធ្វើកម្មដែលខ្ញុំធ្វើហើយឲ្យឥតប្រយោជន៍ ខ្ញុំនាំភត្តមកឲ្យអ្នកតាំងអំពីព្រលឹម ជួបព្រះធម្មសេនាបតីក្នុងរវាងផ្លូវ ទើបប្រគេនភត្តរបស់អ្នកដល់ព្រះថេរៈនោះ ហើយទៅចម្អិនសាជាថ្មី សូមធ្វើចិត្តឲ្យជ្រះថ្លាចុះ ។ បុណ្ណៈសួរថា នែនាង នាងនិយាយអ្វី បានស្តាប់រឿងនោះដដែលទៀត ទើបពោលថា នែនាង នាងប្រគេនភត្តអញដល់លោកម្ចាស់ ជាការធ្វើល្អហើយ កាលពីព្រឹកមិញនេះ អញក៏បានប្រគេនឈើស្ទន់ និងទឹកខ្ពុរមាត់ដល់លោកម្ចាស់ហើយ មានចិត្តជ្រះថ្លាត្រេកអរនឹងពាក្យនុ៎ះហើយ ជាអ្នកមានកាយទន់

ខ្សោយ ព្រោះបានកត្តក្នុងពេលរសៀល ដាក់ក្បាលកើយភ្លៅរបស់ភរិយានោះហើយ ក៏ដេកលក់ទៅ ។

គ្រានោះ ទីដែលបុណ្ណមាណពភ្ជួរអំពីព្រលឹម បានជាមាសទឹកដប់ទាំងអស់ មួយអន្ទើដោយធូលី និងល្អង ក្រហមប្រាលដូចផ្កាកណិការ ។ គាត់ភ្ញាក់ឡើង សម្លឹងឃើញហើយ ទើបពោលនឹងភរិយាថា នែនាង ទីដែលខ្ញុំភ្ជួរហើយនោះ ប្រាកដដល់ខ្ញុំដូចមាសទាំងអស់ ព្រោះខ្ញុំបានកត្តយូរពេក ភ្នែកប្រហែលជាស្រវាំងទេដឹង ។

ភរិយារបស់គាត់ក៏ទូលថា ទីនោះក៏រមែងប្រាកដដល់ខ្ញុំយ៉ាងនោះដូចគ្នា គាត់ក្រោកឡើងទៅក្នុងទីនោះ ចាប់មួយដុំវាយនឹងយាមនង្គ័ល ដឹងថាជាមាស ទើបគិតថា ឱ ! ទានដែលយើងប្រគេនព្រះធម្មសេនាបតី ឲ្យផលក្នុងថ្ងៃនេះឯង ។ យើងមិនអាចជញ្ជូនទ្រព្យប្រមាណប៉ុណ្ណោះប្រើប្រាស់បានទេ ទើបយកមាសដាក់ពេញថាសបាយ ដែលភរិយាទូលមក ហើយបានទៅកាន់រាជត្រកូល កាលព្រះរាជាប្រទានឱកាសហើយ ទើបចូលទៅថ្វាយបង្គំព្រះរាជា ។ កាលទ្រង់ត្រាស់ថា នែបា ទុំះជាអ្វី ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ទីដែលទូលបង្គំបានភ្ជួរហើយ ក្នុងថ្ងៃនេះទាំងអស់ ជាទីពេញទៅដោយមាសតាំងនៅហើយ ព្រះអង្គគួរឲ្យគេជញ្ជូនមក ព្រះរាជាសួរថា អ្នកជាអ្នកណា មាណពទូលថា ទូលបង្គំឈ្មោះបុណ្ណៈ ព្រះរាជាសួរថា ថ្ងៃនេះ អ្នកធ្វើអ្វី បុណ្ណៈទូលថា ព្រឹកមិញនេះ ទូលបង្គំបានប្រគេនឈើស្ទន់ និងទឹកខ្ពុរមាត់ដល់ព្រះធម្មសេនាបតី ចំណែកភរិយារបស់ទូលបង្គំ បានប្រគេនកត្តដែលនាង

នាំមកឲ្យទូលបង្គំ ដល់ព្រះធម្មសេនាបតីនោះដូចគ្នា ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា បាដ៏ចម្រើន បានឮថា ទានដែលប្រគេនព្រះធម្មសេនាបតី ឲ្យវិបាកក្នុងថ្ងៃនេះឯង ហើយត្រាស់សួរថា នែបា យើងនឹងធ្វើដូចម្តេច បុណ្ណៈទូលថា សូមទ្រង់បញ្ជូនរទេះច្រើនពាន់ទៅឲ្យនាំមាសមកចុះ ។

ព្រះរាជាទ្រង់បញ្ជូនរទេះទាំងឡាយទៅហើយ កាលពួករាជបុរសពោលថាជារបស់ព្រះរាជាកាន់យក មាសដែលគេកាន់យកហើយ រមែងជាដីដូចមុន ។ ពួករាជបុរសទៅទូលព្រះរាជា កាលទ្រង់ត្រាស់សួរថា ពួកអ្នកពោលដូចម្តេចទើបកាន់យក ទើបទូលថា ទូលបង្គំពោលថា ជាព្រះរាជទ្រព្យរបស់ព្រះអង្គ ព្រះរាជាត្រាស់ថា មិនមែនជាទ្រព្យរបស់យើងឡើយ ចូរពួកអ្នកទៅ ចូរពោលថាជាទ្រព្យរបស់បុណ្ណៈកាន់យកចុះ ។ ពួករាជបុរសធ្វើយ៉ាងនោះ មាសដែលគេកាន់យកហើយនៅជាមាសពិត ទើបពួកគេជញ្ជូនមាសទាំងអស់នោះ មកធ្វើជាគំនរ ត្រង់លានព្រះរាជវាំង កម្ពស់ប្រមាណ ៨០ ហត្ថ ។

ព្រះរាជាត្រាស់ឲ្យហៅអ្នកនគរប្រជុំគ្នាហើយសួរថា ក្នុងព្រះនគរនេះអ្នកណាមានមាសប្រមាណប៉ុណ្ណេះខ្លះ ពួកអ្នកនគរទូលថា មិនមានទេព្រះអង្គ ព្រះរាជាសួរថា យើងគួរឲ្យអ្វីដល់បុណ្ណមាណព អ្នកនគរទូលថា ឆត្រសម្រាប់សេដ្ឋីក្រាបទូល ព្រះរាជាត្រាស់ថា បុណ្ណៈ ចូរអ្នកជាសេដ្ឋីឈ្មោះពហុធនសេដ្ឋី ហើយបានព្រះរាជទានឆត្រសម្រាប់សេដ្ឋីដល់បុណ្ណៈ មួយអន្លើដោយភោគៈដ៏ច្រើន ។

គ្រានោះ គាត់ក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ទូលបង្គំទាំងឡាយអាស្រ័យក្នុងត្រកូលដទៃ អស់កាលមានប្រមាណប៉ុណ្ណេះ សូមទ្រង់ព្រះរាជទានលំនៅដល់ទូលបង្គំចុះ ។

ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរអ្នកមើលគុម្ពឈើនោះ ប្រាកដក្នុងទិសទក្សិណ ចូរកោរគុម្ពឈើចេញឲ្យជាងធ្វើផ្ទះចុះ ដូច្នេះហើយ ក៏ត្រាស់ប្រាប់ទីសង់ផ្ទះរបស់សេដ្ឋីអំពីបុរាណ គាត់ឲ្យជាងធ្វើផ្ទះក្នុងទីនោះបាន ២-៣ ថ្ងៃប៉ុណ្ណោះ ធ្វើគេហប្បវេសនមង្គល និងឆត្តមង្គលដ៏ស្អាតដូចគ្នា បានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់កាល ៧ ថ្ងៃ ។ គ្រានោះ ព្រះសាស្ដា កាលទ្រង់ធ្វើអនុមោទនា ទើបត្រាស់អនុបុព្វីកថាហើយ ។

ក្នុងកាលចប់ទេសនា ជនទាំងបី គឺបុណ្ណសេដ្ឋី ១ ភរិយា ១ នាងឧត្តរាដែលជាធីតា ១ បានជាព្រះសោតាបន្នហើយ ។

ក្នុងកាលតមក សេដ្ឋីក្នុងក្រុងរាជគ្រឹះ សូមធីតារបស់បុណ្ណសេដ្ឋីឲ្យបុត្ររបស់ខ្លួន បុណ្ណសេដ្ឋីពោលថា ខ្ញុំឲ្យមិនបាន កាលសេដ្ឋីក្រុងរាជគ្រឹះពោលថា សូមលោកកុំធ្វើយ៉ាងនេះ លោកអាស្រ័យខ្ញុំ អស់កាលមានប្រមាណប៉ុណ្ណេះ ទើបបានសម្បត្តិ ចូរឲ្យធីតាដល់បុត្រខ្ញុំចុះ ទើបពោលថា បុត្ររបស់លោកជាមនុស្សមិច្ឆាទិដ្ឋិ ឯកូនស្រីរបស់ខ្ញុំឆ្ងាយអំពីព្រះរតនត្រ័យហើយ មិនអាចប្រព្រឹត្តទៅបាន ទើបខ្ញុំលើកធីតាឲ្យបុត្ររបស់លោកមិនបាន ។

គ្រានោះ កុលបុត្រទាំងឡាយ មានសេដ្ឋី និងគហបតីជាដើមជាច្រើន អង្វរថា កុំទម្លាយមិត្តភាពរវាងសេដ្ឋី ក្នុងក្រុងរាជគ្រឹះនោះឡើយ ចូរលើក

ធីតាឲ្យបុត្ររបស់គាត់ចុះ ។ បុណ្ណៈទទួលពាក្យរបស់កុលបុត្រទាំងនោះ ហើយ បាន លើកធីតាឲ្យក្នុងតិថីពេញបូណ៌មីខែអាសាឍ ។

ចាប់តាំងអំពីពេលទៅកាន់ត្រកូលស្វាមីហើយ នាងមិនបានចូលទៅរកភិក្ខុ ឬភិក្ខុនី ឬដើម្បីថ្វាយទាន ស្តាប់ធម៌ឡើយ ។ កាលវេលាកន្លងទៅបានប្រមាណ ២ ខែកន្លះ ដោយអាការយ៉ាងនេះ ទើបនាងសួរអ្នកបម្រើក្នុងសម្នាក់ថា ពេលនេះខាងក្នុងវស្សាសល់ប៉ុន្មានទៀត ស្រីបម្រើពោលថា នៅសល់កន្លះខែ នាងឧត្តរាបញ្ជូនដំណឹងឲ្យដល់បិតាថា ហេតុអ្វី ទើបបិតាឃុំខាំងខ្ញុំ ក្នុងផ្ទះមានសភាពបែបនេះ កាលដែលបិតាធ្វើខ្ញុំឲ្យជាមនុស្សខូចរូបឆោម ហើយប្រកាសថា ជាទាសីរបស់ជនណាម្នាក់ គង់ប្រសើរជាងការដែលលើកខ្ញុំឲ្យដល់ត្រកូលមិច្ឆាទិដ្ឋិបែបនេះមិនប្រសើរឡើយ តាំងអំពីខ្ញុំមកហើយ ខ្ញុំមិនបានធ្វើបុណ្យសូម្បីតែម្យ៉ាងក្នុងប្រភេទបុណ្យ មានការឃើញភិក្ខុជាដើមឡើយ ។

លំដាប់នោះ បិតារបស់នាងមិនសប្បាយចិត្តដោយគិតថា កូនស្រីរបស់អញបានទទួលទុក្ខហ្ន៎ ទើបបញ្ជូនទ្រព្យ ១ ម៉ឺន ៥ ពាន់កហាបណៈទៅដោយប្រាប់ថា ក្នុងនគរនេះមានស្រីគណិកាឈ្មោះសិរិមា ចូរនាងពោលថា ចូរនាងទទួលទ្រព្យមួយថ្ងៃមួយពាន់កហាបណៈ នាំនាងមកដោយកហាបណៈទាំងនេះឲ្យធ្វើជាអ្នកបម្រើរបស់ប្តីហើយ ខ្លួននាង ចូរធ្វើបុណ្យទាំងឡាយចុះ ។

នាងឲ្យអញ្ជើញនាងសិរិមាមកហើយ ពោលថា នែសម្លាញ់ ចូរនាងទទួលកហាបណៈទាំងនេះ ហើយបម្រើបុរសដែលជាសម្លាញ់របស់នាងកន្លះខែនេះចុះ ។ នាងសិរិមានោះទទួលថា សាធុ នាំនាងចូលទៅកាន់សម្នាក់

របស់ស្វាមី កាលប្តីនោះឃើញនាងសិរិមាហើយ ពោលថា តើនេះជាអ្វី ទើបប្រាប់ថា បពិត្រអ្នក សូមឲ្យស្រីសម្លាញ់របស់ខ្ញុំបម្រើអ្នកអស់កន្លះខែនេះ ខ្ញុំនឹងបានធ្វើទាន ស្តាប់ធម៌ក្នុងកាលកន្លះខែ ។ សេដ្ឋីបុត្រឃើញស្រីស្អាត កើតសេចក្តីស្នេហា ទើបទទួលថា សាធុ ។

នាងឧត្តរានិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានថា បពិត្រព្រះអង្គ សូមទ្រង់កុំយាងទៅទីដទៃ គប្បីទទួលភិក្ខាក្នុងផ្ទះនេះមួយកន្លែងអស់កន្លះខែនេះ ។ ទទួលបដិញ្ញារបស់ព្រះសាស្តាហើយ មានចិត្តត្រេកអរថា ឥឡូវនេះ អញបាន ឧបដ្ឋាកព្រះសាស្តា និងស្តាប់ធម៌ តាំងអំពីនេះទៅរហូតដល់ថ្ងៃមហាបវារណា ចាត់ចែងកិច្ចគ្រប់យ៉ាងក្នុងរោងចុងភៅធំថា ចូរពួកនាងចម្អិនបបរយ៉ាងនេះ ចូរចំហុយនំយ៉ាងនេះ ។

កាលនោះ ប្តីរបស់នាងគិតថា ស្អែកនេះជាថ្ងៃមហាបវារណា ឈរត្រង់បង្អួច បែរមុខទៅកាន់មហារោងពិនិត្យមើលគិតថា ស្រីអន្ធពាលនេះដើរធ្វើអ្វីហ្ន៎ ឃើញធីតាសេដ្ឋីនោះប្រឡាក់ទៅដោយញើស ផេះ និងធ្យូងដើរធ្វើយ៉ាងនោះ ទើបគិតថា ឱហ្ន៎ ស្រីអន្ធពាលមិនសោយសម្បត្តិមានសិរីបែបនេះ ក្នុងឋានៈបែបនេះ បែរជាត្រេកអរថា អញនឹងឧបដ្ឋាកសមណៈក្បាលត្រងោល ត្រាច់ទៅ បានសើចហើយចៀសចេញទៅ ។ កាលសេដ្ឋីបុត្រនោះចៀសចេញទៅហើយ នាងសិរិមាដែលឈរក្បែរនោះគិតថា សេដ្ឋីបុត្រនេះ មើលអ្វីហ្ន៎ ទើបសើច មើលទៅតាមបង្អួចនោះឯង ឃើញនាងឧត្តរាហើយ គិតថា សេដ្ឋីបុត្រនេះសើចព្រោះឃើញស្រីនេះ ការស្និទ្ធស្នាលរបស់សេដ្ឋីបុត្រនេះ គង់មាន

ជាមួយនឹងស្រីនេះពិត ៕

បានឮថា សិរិមានោះ ជាពាហិរកស្ត្រីក្នុងផ្ទះនោះអស់កន្លះខែ សោយសម្បត្តិនោះ ទើបមិនដឹងខ្លួនថា ជាស្រីខាងក្រៅ បានធ្វើនូវការសម្គាល់ថា ខ្លួនជាមេផ្ទះ នាងចងអាឃាតចំពោះនាងឧត្តរាថា នឹងត្រូវញុំាងទុក្ខឲ្យកើតឡើងដល់ស្រីនេះ ទើបចុះអំពីប្រាសាទ ចូលទៅកាន់រោងចុងភៅធំ យកវែកដួសសប្បិដ៏ក្តៅក្នុងទីដែលកំពុងចៀននំ ដើរតម្រង់ទៅរកនាងឧត្តរា នាងឧត្តរាឃើញនាងសិរិមាដើរមក ទើបផ្សាយមេត្តាចិត្តទៅដល់នាងថា សម្លាញ់របស់អញធ្វើឧបការៈដល់អញច្រើន ចក្កវាឡក៏ចង្អៀត ព្រហ្មលោកក៏ទាប គុណរបស់សម្លាញ់អញធំមហិមា អញអាស្រ័យនាង ទើបថ្វាយទាន និងស្តាប់ធម៌ បើអញមានសេចក្តីក្រោធលើនាងសិរិមានោះ ចូរសប្បិនេះរលាកអញចុះ បើមិនមាន ចូរកុំរលាកឡើយ សប្បិដែលក្តៅគគុក ដែលនាងសិរិមានោះស្រោចលើនាងឧត្តរា ហាក់ដូចជាទឹកត្រជាក់ ៕

លំដាប់នោះ ទាសីរបស់នាងឧត្តរាឃើញនាងដួសសប្បិពេញវែកទៀត ដោយយល់ថា សប្បិនេះត្រជាក់កាន់ដើរមក ទើបគំរាមថា នែស្រីក្បាលរឹង ចូរហាងចៀសចេញទៅ ហាងមិនគួរស្រោចសប្បិដែលក្តៅលើម្ចាស់ស្រីរបស់អញឡើយ ហើយក្រោកឡើងអំពីទីនោះខ្លះ អំពីទីនេះខ្លះ ប្រើដៃខ្លះ ជើងខ្លះ វាយឲ្យដួលចុះលើផែនដី ៕ នាងឧត្តរាមិនអាចឃាត់ទាសីទាំងនោះបាន ពេលនោះ ទើបឃាត់ទាសីគ្រប់គ្នា ដែលឈរចោមរោមលើនាងសិរិមានោះហើយសួរថា តើនាងមានបំណងដូចម្តេច ទើបធ្វើកម្មធ្ងន់បែបនេះ ដូច្នេះហើយ ឲ្យ

ដំបូន្មានទនាងសិរិមា ឲ្យផ្លូតដោយទឹកក្តៅ លាបដោយប្រេងដែលចម្រាញ់មួយរយដង ។

ខណៈនោះ នាងសិរិមាដឹងខ្លួនថា ជាស្រីខាងក្រៅហើយ គិតថា អញស្រោចសប្បិដែលក្តៅលើនាងឧត្តរានេះ ព្រោះហេតុត្រឹមតែការសើចរបស់ស្វាមី អញធ្វើកម្មធ្ងន់ហើយ ។ នាងឧត្តរានេះ មិនបញ្ជាទាសីថា ចូរពួកនាងចាប់វា បែរជាឃាត់ពួកទាសីទាំងអស់ ក្នុងពេលដែលចោមរោមអញ បានធ្វើកម្មដែលគួរដល់អញទាំងអស់ បើអញមិនសូមឲ្យនាងឧត្តរានេះអត់ទោសឲ្យក្បាលរបស់អញនឹងបែកជា ៧ ភាគ ដូច្នេះហើយ ទើបក្រាបចុះទៀបបាតជើងរបស់នាងឧត្តរានោះ ហើយពោលថា បពិត្រអ្នកនាង សូមអ្នកនាងអត់ទោសដល់ខ្ញុំចុះ នាងឧត្តរាពោលថា ខ្ញុំជាធីតាមានបិតា បើបិតាអត់ទោសឲ្យខ្ញុំក៏អត់ទោសឲ្យ នាងសិរិមាពោលថា អ្នកនាង សេចក្តីនោះ ចូរលើកទុកចុះ ខ្ញុំនឹងឲ្យបុណ្ណសេដ្ឋីបិតារបស់នាងអត់ទោសឲ្យ នាងឧត្តរាពោលថា បុណ្ណៈជាបិតាបង្កើតក្នុងវដ្តៈ តែកាលបិតាដែលជាវិវដ្តៈអត់ទោសឲ្យ ទើបខ្ញុំអត់ទោសឲ្យ នាងសិរិមាពោលថា អ្នកណាជាបិតាវិវដ្តៈរបស់នាង នាងឧត្តរាពោលថា គឺព្រះសម្មាសម្ពុទ្ធ នាងសិរិមាពោលថា ខ្ញុំមិនមានការស្និទ្ធស្នាលជាមួយទ្រង់ នាងឧត្តរាពោលថា ខ្ញុំនឹងធ្វើឯង ស្អែកនេះ ព្រះសាស្តាទ្រង់នឹងនាំភិក្ខុសង្ឃយាងមកទីនេះ ចូរនាងនាំយកសក្ការៈតាមដែលមានមកទីនេះឯង ហើយសូមឲ្យព្រះអង្គអត់ទោសចុះ ។

នាងសិរិមានោះទទួលថា សាធុ ក្រោកឡើងហើយ ទៅកាន់ផ្ទះរបស់ខ្លួន

ប្រាប់ស្រីជាបរិវារ ៥០០ ឲ្យត្រៀមខាទនីយៈ និងសូបេយ្យៈផ្សេងៗ ស្អែកឡើងកាន់សក្ការៈនោះមកផ្ទះរបស់នាងឧត្តរា មិនហ៊ានដាក់បាត្រភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទើបឈរហើយ នាងឧត្តរាទទួលយកវត្ថុទាំងអស់នោះមករៀបចំហើយ ។ ក្នុងកាលស្រេចភត្តកិច្ច នាងសិរិមា មួយអន្លើដោយបរិវារក្រាបចុះទៀបបាទារបស់ព្រះសាស្តា ។ គ្រានោះ ព្រះសាស្តាត្រាស់សួរថា នាងមានកំហុសអ្វី នាងសិរិមាទូលថា បពិត្រព្រះអង្គ ម្សិលមិញ ខ្ញុំម្ចាស់បានធ្វើកម្មឈ្មោះនេះ កាលបើដូច្នោះ សម្លាញ់របស់ខ្ញុំម្ចាស់នៅតែហាមទាសីដែលបៀតបៀនខ្ញុំម្ចាស់ បានធ្វើឧបការៈដល់ខ្ញុំម្ចាស់ដោយពិត ខ្ញុំម្ចាស់នោះ ដឹងនូវគុណរបស់ស្រីនេះ ទើបសូមឲ្យនាងអស់ទោស កាលបើដូច្នោះ នាងពោលនឹងខ្ញុំម្ចាស់ថា បើទ្រង់អត់ទោសឲ្យ ទើបនាងអត់ទោសឲ្យ ។

ព្រះសាស្តាត្រាស់ថា ម្នាលនាងឧត្តរា បានឮថា សេចក្តីនេះយ៉ាងនោះឬ នាងឧត្តរាពោលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ម្សិលមិញ សម្លាញ់របស់ខ្ញុំម្ចាស់ បានស្រោចសប្បិដ៏ក្តៅលើក្បាលរបស់ខ្ញុំម្ចាស់ ។ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ នាងគិតដូចម្តេច នាងឧត្តរាទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់គិតយ៉ាងនេះថា ចក្កវាឡនៅចង្អៀត ព្រហ្មលោកនៅទាប គុណរបស់សម្លាញ់ខ្ញុំម្ចាស់ប៉ុណ្ណោះធំជាង ព្រោះខ្ញុំម្ចាស់អាស្រ័យនាង ទើបបានថ្វាយទាន និងស្តាប់ធម៌ បើខ្ញុំម្ចាស់មានសេចក្តីក្រោធក្នុងស្រីនេះ ចូរសប្បិក្តៅនេះរលាកខ្ញុំម្ចាស់ចុះ បើមិនមាន សូមកុំរលាកឡើយ ហើយបានផ្សាយមេត្តាចិត្តទៅកាន់នាងសិរិមានេះ ។

ព្រះសាស្តាត្រាស់ថា សាធុ សាធុ ឧត្តរា ការឈ្នះសេចក្តីក្រោធយ៉ាង នោះសមគួរ ធម្មតាបុគ្គលច្រើនដោយសេចក្តីក្រោធ គប្បីឈ្នះដោយការមិនក្រោធ បុគ្គលគប្បីឈ្នះអ្នកជេរដោយការមិនជេរតប បុគ្គលឈ្នះសេចក្តីកំណាញ់ គប្បីឈ្នះបានដោយការឲ្យទាន គប្បីឈ្នះបុគ្គលនិយាយកុហកដោយពាក្យពិត ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

បុគ្គល គប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ
គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់
មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយ
ពាក្យមិនពិត ដោយពាក្យពិត ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អក្កោធេន** សេចក្តីថា បុគ្គលច្រើនដោយសេចក្តីក្រោធ គប្បីជាបុគ្គលឈ្នះដោយការមិនក្រោធ ។ បុគ្គលមិនល្អ ជាបុគ្គលមិនចម្រើន បុគ្គលគប្បីឈ្នះដោយសេចក្តីល្អ បុគ្គលកំណាញ់ គឺកំណាញ់ស្វិតស្វាញ បុគ្គលគប្បីឈ្នះដោយចិត្តគិតលះបង់របស់ខ្លួន អ្នកពោលឡេះឡោះ បុគ្គលគប្បីឈ្នះដោយពាក្យពិត ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់យ៉ាងនេះថា **អក្កោធេន ជិនេ កោធំ ។បេ។ សច្ចេនាលិកវាទិនំ ។**

ក្នុងកាលចប់ទេសនា នាងសិរិមា មួយអន្លើដោយញាតិទាំង ៥០០ តាំង

*ទៅហើយក្នុងសោតាបត្តិផល ដូច្នេះឯង ។*

**រឿង ឧត្តរាឧបាសិកា ចប់**

# រឿង បញ្ហារបស់ព្រះមហាមោគ្គល្លាន

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ព្រះមហាមោគ្គល្លានត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* **សច្ចំ ភណេ** *ជាដើម ។*

*សេចក្តីពិស្តារថា គ្រាមួយ ព្រះថេរៈទៅកាន់ទេវចារិក ឈរនៅត្រង់ទ្វារវិមានរបស់ទេពធីតាដែលមានសក្តិធំ ហើយពោលយ៉ាងនេះនឹងទេពធីតាអង្គនោះដែលមកកាន់សម្នាក់របស់លោក ថ្វាយបង្គំហើយឈរ ដោយពាក្យថា ម្នាលទេពធីតា សម្បត្តិរបស់នាងច្រើន នាងបានធ្វើកម្មអ្វី ។*

*ទេពធីតាពោលថា បពិត្រលោកម្ចាស់ កុំសួរខ្ញុំឡើយ ។ បានឮថា ទេពធីតាខ្មាសដោយកម្មតិចតួចរបស់ខ្លួន ទើបពោលយ៉ាងនេះ ទេពធីតានោះ កាលព្រះថេរៈពោលថា ចូរប្រាប់ចុះ ទើបពោលថា បពិត្រលោកម្ចាស់ ទាន ខ្ញុំមិនបានថ្វាយ ការបូជាក៏មិនបានធ្វើ ធម៌ក៏មិនបានស្តាប់ រក្សាត្រឹមតែពាក្យសច្ចៈតែម្យ៉ាង ។*

*ព្រះថេរៈទៅកាន់ទ្វារវិមានដទៃហើយ សួរទេពធីតាដទៃដែលមកហើយសូម្បីទេពធីតាទាំងនោះ មិនអាចបិទបាំងព្រះថេរៈបានយ៉ាងនោះឯង ទេពធីតា*

មួយអង្គពោលមុនថា បពិត្រលោកម្ចាស់ បណ្តាបុញ្ញកម្ម មានទានជាដើម ឈ្មោះថា បុញ្ញកម្មដែលខ្ញុំធ្វើហើយមិនមាន តែក្នុងពុទ្ធុប្បាទព្រះសម្មាសម្ពុទ្ធ-កស្សប: ខ្ញុំបានជាទាសីរបស់អ្នកដទៃ ចៅហ្វាយរបស់ខ្ញុំកាចពន់ពេក យកដំបងខ្លះ អង្កត់អុសខ្លះ ដែលខ្លួនកញ្ឆក់បានវាយត្រង់ក្បាល ខ្ញុំកាលសេចក្តីក្រោធកើតឡើង ក៏គិតខ្លួនឯងប៉ុណ្ណោះថា ចៅហ្វាយរបស់អញនេះជាធំ ធ្វើអញឲ្យខូចរូបសម្រស់ក៏បាន កាត់អាវ:យវ:មានច្រមុះជាដើមរបស់អញក៏បាន ជអ្នកកុំក្រោធឡើយ ដូច្នេះហើយ ក៏មិនធ្វើសេចក្តីក្រោធ ដោយហេតុនោះ ទើបខ្ញុំបានសម្បត្តិនេះ ។

ទេពធីតាអង្គដទៃ ក៏ប្រាប់ទានបន្តិចបន្តួចដែលខ្លួនធ្វើហើយ ដោយន័យជាដើមថា បពិត្រលោកម្ចាស់ ខ្ញុំរក្សាចម្ការអំពៅ បានប្រគេនអំពៅមួយកំណាត់ដល់ភិក្ខុមួយរូប ទេពធីតាអង្គខ្លះក៏ប្រាប់ថា ខ្ញុំប្រគេនផ្លែទន្លាប់មួយផ្លែ អង្គដទៃក៏ប្រាប់ថា ខ្ញុំប្រគេនល្ពៅមួយផ្លែ អង្គដទៃប្រាប់ថា ខ្ញុំបានប្រគេនផ្លែត្រប់លែនមួយផ្លែ អង្គខ្លះប្រាប់ថា ខ្ញុំបានថ្វាយជំឡូងមួយក្តាប់ អង្គខ្លះប្រាប់ថា ខ្ញុំបានប្រគេនស្តៅមួយក្តាប់ ដូច្នេះហើយ ក៏ប្រាប់ថា ដោយហេតុនេះ ទើបពួកខ្ញុំបានសម្បត្តិនេះ ។

ព្រះថេរ:ស្តាប់កម្មដែលទេពធីតាទាំងនោះធ្វើហើយ ទើបចុះអំពីស្ថានសួគ៌ទៅគាល់ព្រះសាស្តាទូលសួរថា បពិត្រព្រះអង្គ បុគ្គលអាចឬទេហ្ន៎ ដើម្បីបានទិព្វសម្បត្តិដោយហេតុត្រឹមតែពាក្យសច្ច: ត្រឹមតែរម្ងាប់សេចក្តីក្រោធ ត្រឹមតែថ្វាយទាន មានផ្លែទន្លាប់ជាដើមដែលតិចតួចពន់ពេក ព្រះសាស្តាត្រាស់ថា ម្នាល

មោគ្គល្លាន ព្រោះហេតុអ្វីទើបអ្នកសួរតថាគត ក្រែងពួកទេពធីតាប្រាប់សេចក្តីនេះដល់អ្នកហើយមិនមែនឬ ព្រះមោគ្គល្លានពោលថា យ៉ាងនោះឯងព្រះអង្គ បុគ្គលបានទិព្វសម្បត្តិ ដោយកម្មមានប្រមាណប៉ុណ្ណោះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះមោគ្គល្លាននោះថា ម្នាលមោគ្គល្លាន បុគ្គលពោលត្រឹមតែពាក្យសត្យក្តី លះត្រឹមតែសេចក្តីក្រោធក្តី ថ្វាយទានត្រឹមបន្តិចបន្តួចក្តី រមែងទៅទេវលោកបានពិត ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**សច្ចំ ភណេ ន កុជ្ឈេយ្យ ទជ្ជា អប្បស្មិ យាចិតោ**
**ឯតេហិ តីហិ ឋានេហិ គច្ឆេ ទេវាន សន្តិកេ ។**

បុគ្គលពោលពាក្យពិត ១ មិនគួរក្រោធ ១ កាលគេសូមនូវវត្ថុសម្បីមានតិចក៏គួរឲ្យ ( តាមតិច ) ១ បុគ្គលគប្បីទៅកើតក្នុងសម្នាក់ទេវតាទាំងឡាយបានដោយហេតុទាំង ៣ នេះឯង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **សច្ចំ ភណេ** សេចក្តីថា គប្បីសម្តែង គឺគប្បីពោលពាក្យសត្យ អធិប្បាយថា គួរតាំងមាំក្នុងសត្យ ។

បទថា **ន កុជ្ឈេយ្យ** បានដល់ មិនគួរក្រោធចំពោះបុគ្គលដទៃ ។

បទថា **យាចិតោ** សេចក្តីថា បព្វជិតដែលមានសីល ឈ្មោះថា ជាអ្នកសូម ។ សេចក្តីពិត បព្វជិតទាំងនោះមិនសូមថា ចូរអ្នកឲ្យ រមែងឈរត្រង់ទ្វារផ្ទះក៏ពិត តែអត្ថ ក៏ឈ្មោះថា រមែងសូមនោះឯង បុគ្គលដែលមាន

សីល សូមហើយយ៉ាងនោះ កាលទេយ្យធម៌សូម្បីតិចតួចមាន ក៏គប្បីឲ្យត្រឹមតែតិចតួច ។

ពីរបទថា **ឯតេហិ តីហិ** សេចក្តីថា បណ្តាហេតុទាំងនោះ ហេតុសូម្បីត្រឹមតែមួយ បុគ្គលគប្បីទៅទេវលោកបាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

**រឿង បញ្ហារបស់ព្រះមោគ្គល្លានត្ថេរ ចប់**

# រឿង បញ្ហាដែលភិក្ខុទូលសួរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាកេត ប្រថាប់នៅត្រង់អញ្ជនវ័នទ្រង់ប្រារព្ធបញ្ហាដែលភិក្ខុទូលសួរ ត្រាស់ព្រះធម្មទេសនានេះថា **អហឹសកាយេ** ជាដើម ។

បានឮមកថា ក្នុងកាលដែលព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោមយាងទៅក្រុងសាកេតដើម្បីបិណ្ឌបាត ព្រាហ្មណ៍ចាស់ជរាក្នុងក្រុងសាកេតម្នាក់កំពុងដើរចេញអំពីព្រះនគរ ជួបព្រះសាស្តាត្រង់រវាងទ្វារ ទើបក្រាបទៀបបាទាទាំងទ្វេ ហើយចាប់ត្រង់កព្រះបាទយ៉ាងមាំពោលថា នែបា ធម្មតា ឪពុកនិងម្តាយ ដែលពួកកូនគប្បីទំនុកបម្រុង ក្នុងកាលដែលចាស់ជរាហើយ មិន

មែនឬ ហេតុអ្វី ទើបកូនមិនបង្ហាញខ្លួនដល់ខ្ញុំព្រះអង្គ អស់កាលមានប្រមាណប៉ុណ្ណេះ ព្រះអង្គ ដែលខ្ញុំព្រះអង្គឃើញមុន សូមទ្រង់យាងមកសួរសុខទុក្ខមាតាផង ដូច្នេះហើយ ក៏បាននាំព្រះសាស្ដាទៅកាន់ផ្ទះរបស់ខ្លួន ព្រះសាស្ដាយាងទៅហើយ ប្រថាប់គង់លើអាសនៈដែលគេបានក្រាល មួយអន្លើដោយភិក្ខុសង្ឃ ។

ចំណែកព្រាហ្មណី មកក្រាបទៀបព្រះបាទទាំងពីររបស់ព្រះសាស្ដាហើយទូលថា នែបា កូនទៅណាអស់កាលដ៏យូរមានប្រមាណប៉ុណ្ណេះ ធម្មតាមាតានិងបិតា បុត្រធីតាគួរទំនុកបម្រុងក្នុងពេលដែលចាស់មិនមែនឬ ហើយឲ្យបុត្រនិងធីតាទាំងឡាយមកថ្វាយបង្គំដោយពាក្យថា ចូរពួកអ្នកមកថ្វាយបង្គំបងប្រុសរបស់អ្នក ។ ប្ដីប្រពន្ធពីរនាក់នោះ មានចិត្តត្រេកអរ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយទូលថា បពិត្រព្រះអង្គ សូមទ្រង់ទទួលភិក្ខាក្នុងផ្ទះនេះឯងជានិច្ចចុះ កាលព្រះសាស្ដាត្រាស់ថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មិនទទួលជានិច្ចក្នុងទីតែមួយប៉ុណ្ណោះ ទើបក្រាបទូលថា បើដូច្នេះ ទ្រង់គប្បីបញ្ជូនពួកជនដែលមកនិមន្តព្រះអង្គ ទៅកាន់សម្នាក់របស់ខ្ញុំព្រះអង្គផង ។

ចាប់តាំងអំពីនោះ ព្រះសាស្ដាទ្រង់បញ្ជូនពួកមនុស្សដែលមកដើម្បីនិមន្តទៅដោយព្រះតម្រាស់ថា ចូរពួកអ្នកទៅប្រាប់ដល់ព្រាហ្មណ៍ចុះ ។ មនុស្សដែលមកនិមន្តទាំងនោះ រមែងទៅប្រាប់ព្រាហ្មណ៍ថា យើងទាំងឡាយនិមន្តព្រះសាស្ដា ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ។

ថ្ងៃស្អែកឡើង ព្រាហ្មណ៍កាន់យកភាជនកគ្គ និងភាជនសម្លអំពីផ្ទះរបស់

ខ្លួន ទៅកាន់ទីដែលព្រះសាស្ដាប្រថាប់គង់ ។ ក្នុងកាលទិមន្ដទៅធាន់ក្នុងទីដទៃ មិនមាន ព្រះសាស្ដាទ្រង់ធ្វើភត្ដកិច្ចក្នុងផ្ទះរបស់ព្រាហ្មណ៍នោះឯង ពីរនាក់ស្វាមីភរិយានោះ ថ្វាយទេយ្យធម៌របស់ខ្លួនដល់ព្រះតថាគត ស្ដាប់ធម្មកថាអស់កាលជានិច្ច សម្រេចអនាគាមិផលហើយ ។

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ព្រាហ្មណ៍នោះដឹងថា ព្រះបាទសុទ្ធោទនៈជាព្រះបិតារបស់ព្រះតថាគត ព្រះនាងមហាមាយាជាព្រះមាតា ទាំងដឹងយ៉ាងនោះឯង មួយអន្លើដោយព្រាហ្មណីហៅព្រះតថាគតថា បុត្ររបស់អញ ។ ចំណែកព្រះសាស្ដា ក៏ទ្រង់ទទួលយ៉ាងនោះដូចគ្នា នឹងមានហេតុអ្វីហ្ន៎ ។

ព្រះសាស្ដា ទ្រង់ស្ដាប់កថារបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្ដីប្រពន្ធពីរនាក់នោះ ហៅបុត្ររបស់ខ្លួនប៉ុណ្ណោះថាបុត្រ ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមក ទ្រង់សម្ដែងភាពដែលទ្រង់ជាបុត្ររបស់ព្រាហ្មណ៍ប្ដីប្រពន្ធទាំងពីរនោះអស់ ៣ ពាន់ជាតិថា ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ព្រាហ្មណ៍នេះបានជាបិតារបស់តថាគត ៥០០ ជាតិជាប់តគ្នា ជាឪពុកមារបស់តថាគត ៥០០ ជាតិ ជាអ៊ំប្រុស ៥០០ ជាតិ សូម្បីព្រាហ្មណីនោះ បានជាមាតារបស់តថាគតជាប់តគ្នា ៥០០ ជាតិ ជាមីងរបស់តថាគត ៥០០ ជាតិ ជាអ៊ំស្រីរបស់តថាគត ៥០០ ជាតិ តថាគតចម្រើនហើយក្នុងដៃរបស់ព្រាហ្មណ៍ ១៥០០ ជាតិ ចម្រើនហើយក្នុងដៃរបស់ព្រាហ្មណី ១៥០០ ជាតិយ៉ាងនេះ ហើយទ្រង់បានភាសិតព្រះគាថាទាំងនេះថា

ចិត្តតាំងនៅស៊ប់ ឬក៏ចិត្តជ្រះថ្លាក្នុងបុគ្គលណា ដែលខ្លួន
មិនធ្លាប់ឃើញហើយ ជនតែងស្និទ្ធស្នាលចំពោះបុគ្គល
នោះដោយពិត ។

សេចក្ដីស្រឡាញ់នោះ រមែងកើតដោយហេតុ ២ យ៉ាង
គឺដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុក
បម្រុងគ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុង
ទឹក ដោយហេតុ ២ យ៉ាង គឺទឹក ១ ភក់ ១ ។

ព្រះសាស្ដាទ្រង់អាស្រ័យត្រកូលនោះ ប្រថាប់នៅហើយអស់ត្រៃមាស នោះឯង ចំណែកព្រាហ្មណ៍ និងព្រាហ្មណីទាំង ២ នោះ ធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលហើយ បរិនិព្វាន គ្រានោះ ជនទាំងឡាយ ធ្វើសក្ការៈដ៏សន្ធឹកសន្ធាប់ដល់ព្រាហ្មណ៍ និងព្រាហ្មណីទាំងនោះហើយ ក៏លើកជនទាំងពីរឡើងកាន់ផ្ទះកំពូលមួយខ្នងនោះឯង នាំទៅហើយ ។

ព្រះសាស្ដាមានភិក្ខុ ៥០០ រូបជាបរិវារ យាងទៅកាន់ឈាបនដ្ឋានជាមួយជនទាំងនោះដូចគ្នា ។

មហាជនចេញទៅហើយដោយគិតថា បានឮថា ព្រះសាស្ដា និងព្រះបិតារបស់ព្រះពុទ្ធធ្វើកាលកិរិយាហើយ ព្រះសាស្ដាបានទៅកាន់សាលាមួយខ្នងក្បែរប៉ាឆា ប្រថាប់ឈរហើយ ។ ពួកមនុស្សថ្វាយបង្គំព្រះសាស្ដា ហើយឈរក្នុងចំណែកម្ខាង ធ្វើបដិសណ្ឋារៈជាមួយព្រះសាស្ដាដោយទូលថា បពិត្រព្រះអង្គ សូមទ្រង់កុំគិតថា ព្រះមាតា និងព្រះបិតារបស់ទ្រង់ធ្វើកាលកិរិយា

ឡើយ ។

ព្រះសាស្តាទ្រង់មិនហាមជនទាំងនោះថា ពួកអ្នកកុំពោលយ៉ាងនោះ ទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់បរិស័ទហើយ កាលទ្រង់សម្តែងធម៌ឲ្យសមគួរដល់ខណៈនោះ ទើបត្រាស់ជាសូត្រដោយន័យជាដើមថា

ជីវិតនេះតិចណាស់ រមែងស្លាប់ខាងអាយ អំពី ១០០ ឆ្នាំ
បើបុគ្គលណា រស់នៅកន្លងហួស ( ពី ១០០ ឆ្នាំ ) ទៅ
បុគ្គលនោះ គង់ស្លាប់ព្រោះជរាពុំខាន ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យមានដល់សត្វ ៨៤០០០ ហើយ ។ ភិក្ខុទាំងឡាយកាលមិនជ្រាបភាពដែលព្រាហ្មណ៍ និងព្រាហ្មណីបរិនិព្វានហើយ ទើបទូលសួរថា បពិត្រព្រះអង្គ គតិខាងមុខរបស់ព្រាហ្មណ៍ និងព្រាហ្មណីនោះដូចម្តេច ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាអភិសម្បរាយគតិរបស់ព្រះអសេក្ខមុនីទាំងឡាយបែបនោះ មិនមាន ព្រោះថា ព្រះអសេក្ខ-មុនីបែបនោះ រមែងសម្រេចមហានិព្វានដែលមិនចុតិ ដែលមិនស្លាប់ ដូច្នេះហើយ ទើបត្រាស់គាថានេះថា

**អហឹសកា យេ មុនយោ និច្ចំ កាយេន សំវុតា**
**តេ យន្តិ អច្ចុតំ ឋានំ យត្ថ គន្ត្វា ន សោចរេ ។**

ជនទាំងឡាយណា ជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ
សង្រួមហើយ ដោយកាយទ្វារ ( ជាដើម ) ជានិច្ច ជន

ទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មុនយោ** គឺព្រះអសេក្ខមុនីទាំងឡាយសម្រេចមគ្គ និងផល ដោយមោនេយ្យបដិបទា ។

បទថា **កាយេន** នោះ ត្រឹមតែជាមាតិកានៃទេសនាប៉ុណ្ណោះ អធិប្បាយថា សង្រួមហើយ ដោយទ្វារទាំងប ៣ ។

បទថា **អច្ចុតំ** បានដល់ ទៀង ។ បទថា **ឋានំ** បានដល់ ឋានៈដែលមិនកម្រើក គឺឋានៈដែលស្ថិតស្ថេរ ។

បទថា **យត្ថ** ជាដើម សេចក្តីថា មុនីទាំងឡាយរមែងទៅកាន់ឋានៈគឺព្រះនិព្វានដែលមនុស្សទាំងឡាយទៅហើយ មិនសោយសោក គឺមិនក្តៅក្រហាយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

**រឿង បញ្ហាដែលភិក្ខុទូលសួរ ចប់**

# រឿង បុណ្ណាទាសី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅត្រង់ភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធទាសីរបស់សេដ្ឋីក្រុងរាជគ្រឹះ ឈ្មោះនាងបុណ្ណា ត្រាស់ព្រះធម្មទេសនានេះថា **សទា ជាគរមានានំ** ជាដើម ។

បានឮថា ថ្ងៃមួយ សេដ្ឋីឲ្យស្រូវជាច្រើនដល់នាងបុណ្ណានោះ ដើម្បីបុក ។ នាងអុជប្រទីបក្នុងពេលយប់បុកស្រូវ មានខ្លួនជោកដោយញើស ទើបទៅឈរហាលខ្យល់ខាងក្រៅដើម្បីសម្រាក ។

ក្នុងសម័យនោះ ព្រះទព្វមល្លបុត្តជាអ្នកចាត់ចែងសេនាសនៈ ដើម្បីភិក្ខុទាំងឡាយ លោកញុំាងម្រាមដៃឲ្យភ្លឺដើម្បីភិក្ខុទាំងឡាយ ដែលស្តាប់ធម៌ហើយទៅកាន់សេនាសនៈរៀងៗ ខ្លួន និម្មិតភិក្ខុទាំងឡាយទៅខាងមុខ ដើម្បីប្រយោជន៍ដល់ការបង្ហាញផ្លូវ ។ នាងបុណ្ណា ឃើញភិក្ខុទាំងឡាយត្រាច់ទៅលើភ្នំដោយពន្លឺនោះទើបគិតថា អញត្រូវទុក្ខរបស់ខ្លួនបៀតបៀនទើបដេកមិនលក់ សូម្បីក្នុងពេលនេះ ព្រោះហេតុអ្វី ទើបលោកម្ចាស់ទាំងឡាយមិនសិង ដូច្នេះហើយកំណត់ក្នុងចិត្តដោយខ្លួនឯងថា ការមិនផាសុកនឹងមានដល់ភិក្ខុរូបខ្លះ ឬព្រោះឧបទ្រវហេតុព្រោះពស់ នឹងមានក្នុងទីនោះពិត ក្រោកឡើងអំពីព្រលឹមខ្ចប់កន្ទក់ដែលសើមដោយទឹកហើយ ធ្វើនំលើបាតដៃ អាំងលើរងើកភ្លើង ដាក់ក្នុងថ្នក់គិតថា នឹងបរិភោគនំត្រង់ផ្លូវដែលទៅកាន់កំពង់ទឹក ទើបកាន់យកក្អមដើរបែរមុខទៅកាន់កំពង់ទឹក ។

ព្រះសាស្តា ក៏យាងទៅតាមផ្លូវនោះដូចគ្នាដើម្បីចូលស្រុក នាងឃើញព្រះសាស្តាហើយគិតថា ក្នុងថ្ងៃដទៃៗ សូម្បីអញជួបព្រះសាស្តា ទេយ្យធម៌របស់អញក៏មិនមាន កាលទេយ្យធម៌មាន អញមិនជួបព្រះសាស្តា ឥឡូវនេះ ទេយ្យធម៌របស់អញក៏មាន ទាំងព្រះសាស្តាក៏ប្រាកដចំពោះមុខ បើទ្រង់មិនគិតថា ទានរបស់អញសៅហ្មង ឬប្រណីត ហើយគប្បីទទួលសោត អញគប្បីថ្វាយនំនេះ ដូច្នេះហើយ ទើបដាក់ក្អមក្នុងចំណែកម្ខាង ថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ទទួលទានដែលសៅហ្មងនេះ ធ្វើនូវការសង្គ្រោះដល់ខ្ញុំម្ចាស់ចុះ ។

ព្រះសាស្តាទ្រង់ទតព្រះអានន្ទត្ថេរហើយ ទ្រង់បង្អោនបាត្រដែលមហារាជថ្វាយ ដែលព្រះអានន្ទត្ថេរនាំមកថ្វាយទទួលនំ ។ សូម្បីនាងបុណ្ណាដាក់នំនោះចូលក្នុងបាត្រព្រះសាស្តា ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក្រាបទូលថា បពិត្រព្រះអង្គ សូមធម៌ដែលទ្រង់ឃើញហើយនោះ សម្រេចដល់ខ្ញុំចុះ ព្រះសាស្តាប្រថាប់ឈរនោះឯង ទ្រង់ធ្វើអនុមោទនាថា ចូរសម្រេចយ៉ាងនោះចុះ ។

នាងបុណ្ណាគិតថា ព្រះសាស្តាទ្រង់ធ្វើការសង្គ្រោះដល់អញ ទទួលនំក៏ពិតតែទ្រង់ប្រហែលជាមិនសោយនំនោះ ឲ្យដល់ក្អែក ឬឆ្កែខាងមុខ យាងទៅកាន់ព្រះរាជមន្ទីររបស់ព្រះរាជា ឬផ្ទះរបស់អមាត្យ ហើយសោយភោជនដែលប្រណីតពិត ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា នាងបុណ្ណានោះគិតដូចម្តេចហ្ន៎ ទ្រង់ជ្រាបវារចិត្តរបស់នាងហើយ ទើបទតមើលព្រះអានន្ទ ហើយទ្រង់សម្តែងអាការ

ប្រឋាប់គន់ ។ ព្រះថេរៈបានក្រាលចីវរថ្វាយ ។ ព្រះសាស្តាប្រថាប់គង់ធ្វើកត្តកិច្ចខាងក្រៅព្រះនគរនោះឯង ។ ទេវតាក្នុងល្វែងនៃចក្កវាឡទាំងមូល ដាក់ព្រះឱជារសដ៏សមគួរដល់ទេវតា និងមនុស្សទាំងឡាយ ឲ្យដូចផ្លិតឃ្មុំក្នុងនំនោះ ចំណែកនាងបុណ្ណាបានឈរមើលហើយ ។

ក្នុងពេលស្រេចកត្តកិច្ច ព្រះថេរៈបានថ្វាយទឹក ។ ព្រះសាស្តាទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ត្រាស់ហៅនាងបុណ្ណាមក ត្រាស់ថា ម្នាលនាងបុណ្ណា ព្រោះហេតុអ្វី ទើបនាងរិះគន់សាវកទាំងឡាយរបស់តថាគត នាងបុណ្ណាទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មិនបានរិះគន់ឡើយ ។

ព្រះសាស្តាត្រាស់ថា បើដូច្នោះ នាងសម្លឹងមើលសាវកទាំងឡាយរបស់តថាគតហើយ គិតដូចម្តេច ។ នាងបុណ្ណាទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់គិតយ៉ាងនេះថា អញមិនបានដេកក៏ព្រោះឧបទ្ទវន្តរាយ គឺទុក្ខនេះ លោកម្ចាស់ទាំងឡាយមិនសិងដើម្បីអ្វីហ្ន៎ ការមិនផាសុកនឹងមានដល់ភិក្ខុរបខ្លះ ឬអន្តរាយព្រោះពស់នឹងមានពិត ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់នាងបុណ្ណានោះហើយ ទើបត្រាស់ថា ម្នាលនាងបុណ្ណា នាងមិនដេកព្រោះអន្តរាយ គឺទុក្ខរបស់ខ្លួន សាវកទាំងឡាយរបស់តថាគត មិនដេក ព្រោះភាពជាអ្នកប្រកបរឿយៗ នូវធម៌ ជាគ្រឿងភ្ញាក់រឭកសព្វកាល ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**សទា ជាគរមានានំ　　　　អហោរត្តានុសិក្ខិនំ**
**និព្វានំ អធិមុត្តានំ　　　　អត្ថំ គច្ឆន្តិ អាសវា ។**

អាសវៈទាំងឡាយ របស់បុគ្គលអ្នកភ្ញាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខា ទាំងថ្ងៃ ទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **អហោរត្តានុសិក្ខិនំ** បានដល់ សិក្សាត្រៃសិក្ខាទាំងថ្ងៃទាំងយប់ ។ បាទព្រះគាថាថា **និព្វានំ អធិមុត្តានំ** បានដល់ មានអធ្យាស្រ័យក្នុងព្រះនិព្វាន ។

ពីរបទថា **អត្ថំ គច្ឆន្តិ** សេចក្តីថា អាសវៈទាំងពួងរបស់បុគ្គលបែបនោះ រមែងដល់នូវការតាំងនៅមិនបាន ព្រោះដល់នូវការវិនាស បានដល់ ការមិនមាន ។ ក្នុងកាលចប់ទេសនា នាងបុណ្ណាកំពុងឈរនោះឯង តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយ ។

ព្រះសាស្តា កាលទ្រង់ធ្វើភត្តកិច្ចដោយអាំងលើរងើកភ្លើង ដែលធ្វើដោយកន្ទក់ហើយ បានទៅកាន់វិហារ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ កម្មធ្វើបានលំបាក ដែលព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើភត្តកិច្ចដោយនំអាំង ដែលធ្វើដោយកន្ទក់ ដែលនាងបុណ្ណាថ្វាយទ្រង់ធ្វើហើយ ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយរឿងឈ្មោះ

នេះ ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនតថាគតក៏បរិភោគកន្ទក់ ដែលនាងបុណ្ណានេះឲ្យហើយដូចគ្នា ហើយទ្រង់នាំអតីតនិទានមក ត្រាស់កុណ្ឌកសិន្ធវពោតកជាតកនេះឲ្យពិស្តារថា

ព្រះពោធិសត្វ កាលសាកល្បងកូនសេះសិន្ធពនោះ ទើបពោលគាថាទីមួយថា

អ្នកធ្លាប់បរិភោគស្មៅដ៏សល់ ដែលធ្លាប់បរិភោគបាយ
ក្តាំង និងកុណ្ឌកមកហើយ នេះជាភោជនរបស់អ្នក
ឥឡូវនេះ ហេតុអ្វី ក៏អ្នកមិនបរិភោគ ។

កូនសេះសន្ធពស្តាប់ដូច្នោះហើយ ទើបពោលគាថាពីរថា

បពិត្រមហាព្រហ្ម ជនទាំងឡាយមិនស្គាល់សត្វ ដែល
គួរចិញ្ចឹម ដោយជាតិ ឬដោយមារយាទ ដែលគួរទូន្មាន
ក្នុងទីណា ក្នុងទីនោះ ប្តីក៏ខ្ញុំមិនបរិភោគបាយក្តាំង និង
កុណ្ឌកច្រើន ។

ចំណែកខាងលោកស្គាល់ខ្ញុំច្បាស់ថា សេះនេះ ឧត្តម
យ៉ាងណាៗ ខ្ញុំកាលដឹង ព្រោះអាស្រ័យអ្នកជាអ្នកដឹង
ទើបមិនបរិភោគនូវកុណ្ឌករបស់អ្នក ដូច្នេះឯង ។

**រឿង បុណ្ណាទាសី ចប់**

# រឿង អតុលឧបាសក

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកឈ្មោះអតុលៈ ត្រាស់ព្រះធម្មទេសនានេះថា **បោរាណមេតំ** ជាដើម ។

សេចក្តីពិស្តារថា អតុលៈនោះជាឧបាសកក្រុងសាវត្ថី មានឧបាសកជាបរិវារ ៥០០ នាក់ ថ្ងៃមួយ នាំពួកឧបាសកទាំងនោះទៅវិហារ ដើម្បីស្តាប់ធម៌ ប្រាថ្នានឹងស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះរេវតៈ ថ្វាយបង្គំព្រះថេរៈហើយអង្គុយ ។

ព្រះថេរៈជាអ្នកត្រេកអរក្នុងការស្ងប់ស្ងាត់ ត្រាច់ទៅម្នាក់ឯងដូចរាជសីហ៍ ដូច្នោះ ទើបមិនពោលពាក្យណាមួយជាមួយឧបាសកនោះ ក្រោធថា ព្រះថេរៈនេះមិននិយាយអ្វីសោះ ទើបក្រោកឡើងទៅកាន់សម្នាក់ព្រះសារីបុត្តឈរក្នុងចំណែកម្ខាង កាលព្រះថេរៈពោលថា ពួកអ្នកមកដោយបំណងអ្វី ទើបពោលថា បពិត្រលោកម្ចាស់ ខ្ញុំនាំឧបាសកនេះ ចូលទៅរកព្រះរេវតៈ ដើម្បីស្តាប់ធម៌ ព្រះថេរៈមិនពោលអ្វីនឹងខ្ញុំសោះ ខ្ញុំក្រោធនឹងលោក ទើបមកទីនេះ សូមលោកម្ចាស់សម្តែងធម៌ដល់ខ្ញុំចុះ ។

លំដាប់នោះ ព្រះថេរៈពោលថា ឧបាសកទាំងឡាយ បើយ៉ាងនោះ ចូរពួកអ្នកអង្គុយចុះ ហើយសម្តែងអភិធម្មកថាជាច្រើន ។

ឧបាសកក្រោធថា ឈ្មោះថាអភិធម្មកថាជ្រាលជ្រៅពន់ពេក សុខុមពន់ពេក ព្រះថេរៈសម្តែងអភិធម្មច្រើនពេក ពួកយើងត្រូវការអ្វីដោយអភិធម្មនេះ ដូច្នេះហើយ បាននាំគ្នាទៅកាន់សម្នាក់ព្រះអានន្ទត្ថេរ កាលព្រះថេរៈពោលថា នែឧបាសក តើមានរឿងអ្វី ទើបពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំចូលទៅ

រកព្រះរេវតៈត្រូវការដើម្បីស្តាប់ធម៌ មិនបានត្រឹមតែការសន្ទនា និងប្រាស្រ័យក្នុងសម្នាក់របស់លោក ខ្ញុំក៏ក្រោធ ហើយទើបមកកាន់សម្នាក់របស់ព្រះសារីបុត្ត សូម្បីព្រះថេរៈនោះក៏សម្តែងអភិធម្មយ៉ាងល្អិតជាច្រើនដល់ខ្ញុំ ពួកខ្ញុំក្រោធចំពោះព្រះថេរៈនោះថា ពួកយើងត្រូវការអ្វីដោយអភិធម្មនេះ ហើយទើបមកទីនេះ សូមលោកម្ចាស់សម្តែងធម្មកថាដល់ពួកខ្ញុំចុះ ។ ព្រះថេរៈពោលថា បើដូច្នោះ ចូរពួកអ្នកអង្គុយស្តាប់ចុះ ។ ព្រះថេរៈសម្តែងធម៌ដល់ឧបាសកទាំងនោះតែបន្តិច ធ្វើឲ្យងាយយល់ ។

ពួកឧបាសកក្រោធចំពោះព្រះថេរៈហើយ ក៏ទៅកាន់សម្នាក់ព្រះសាស្តាថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងឧបាសកទាំងនោះថា ម្នាលឧបាសកទាំងឡាយ ពួកអ្នកមកធ្វើអ្វី ឧបាសកទាំងនោះទូលថា បពិត្រព្រះអង្គ ដើម្បីស្តាប់ធម៌ ព្រះសាស្តាត្រាស់ថា ពួកអ្នកស្តាប់ធម៌ហើយឬ ឧបាសកទូលថា បពិត្រព្រះអង្គ ដំបូងពួកខ្ញុំព្រះអង្គចូលទៅរកព្រះរេវតត្ថេរ លោកមិនពោលអ្វីសោះជាមួយខ្ញុំព្រះអង្គ ។ ពួកខ្ញុំព្រះអង្គក្រោធលោកហើយ ទើបទៅរកព្រះសារីបុត្ត ព្រះថេរៈនោះសម្តែងអភិធម្មដល់ខ្ញុំព្រះអង្គច្រើនពេក ខ្ញុំព្រះអង្គកំណត់អភិធម្មនោះមិនបាន ទើបក្រោធ ហើយចូលទៅរកព្រះអានន្ទ ព្រះថេរៈនោះសម្តែងធម៌ដល់ខ្ញុំព្រះអង្គតិចពេក ពួកខ្ញុំព្រះអង្គក្រោធចំពោះលោកហើយមកទីនេះ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ឧបាសកទាំងនោះហើយត្រាស់ថា ម្នាល

អតុល: សេចក្ដីនោះនរជនធ្លាប់ប្រព្រឹត្តមកតាំងអំពីបុរាណនោះឯង ជនទាំង-ឡាយតិះដៀលអ្នកដែលនៅស្ងៀមផង អ្នកនិយាយច្រើនផង អ្នកនិយាយតិចផង ដ្បិតថា បុគ្គលដែលគេមិននិន្ទាតែម្យ៉ាងប៉ុណ្ណោះ ឬដែលគេគប្បីសរសើរតែម្យ៉ាងមិនមាន សូម្បីព្រះរាជាទាំងឡាយ មនុស្សពួកខ្លះក៏និន្ទា មនុស្សពួកខ្លះក៏សរសើរ សូម្បីមហាប្រឹថពីក្ដី ព្រះចន្ទ និងព្រះអាទិត្យក្ដី ធាតុ មានអាកាសជាដើមក្ដី ជនពួកខ្លះក៏និន្ទា ពួកខ្លះក៏សរសើរ សូម្បីព្រះសម្មាសម្ពុទ្ធដែលប្រថាប់គង់សម្ដែងធម៌កណ្ដាលបរិស័ទ ៤ ពួកខ្លះក៏និន្ទា ពួកខ្លះក៏សរសើរ ការនិន្ទា និងការសរសើររបស់ពួកអន្ធពាលមិនជាប្រមាណ តែ បុគ្គលដែលត្រូវបណ្ឌិត អ្នកមានប្រាជ្ញាតិះដៀល ទើបឈ្មោះថា ជាការតិះដៀល ដែលបណ្ឌិតសរសើរហើយ ទើបឈ្មោះថា ជាការសរសើរ ដូច្នេះហើយ ទ្រង់បានភាសិតគាថាទាំងនេះថា

បោរាណមេតំ អតុល　　នេតំ អជ្ជតនាមិវ
និន្ទន្តិ តុណ្ហិមាសីនំ　　និន្ទន្តិ ពហុភាណិនំ
មិតភាណិម្បិ និន្ទន្តិ　　នត្ថិ លោកេ អនិន្ទិតោ ។
ន ចាហុ ន ច ភវិស្សតិ　　ន ចេតរហិ វិជ្ជតិ
ឯកន្តំ និន្ទិតោ បោសោ　　ឯកន្តំ វា បសំសិតោ ។
យញ្ចេ វិញ្ញូ បសំសន្តិ　　អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តឹ មេធាវឹ　　បញ្ញាសីលសមាហិតំ
នេក្ខំ ជម្ពោនទស្សេវ　　កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ　　ព្រហ្មុនាបិ បសំសិតោ ។

ម្នាលអតុលៈ ការតិះដៀល និងការសរសើរនេះ ជារបស់ បុរាណ ការតិះដៀល និងការសរសើរនេះ មិនមែនទើបនឹង កើតឡើងក្នុងថ្ងៃនេះទេ ( ព្រោះថា ) ជនទាំងឡាយ តែង និន្ទាបុគ្គលអ្នកអង្គុយស្ងៀមក៏មាន និន្ទាបុគ្គលអ្នកនិយាយ ច្រើនក៏មាន និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណក៏មាន ( អ្នក ណាៗ ក៏ដោយ ) ក្នុងលោក ដែលមិនត្រូវគេនិន្ទាគ្មានឡើយ បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយ តែក្នុងអតីតទេ នឹងមានទៅក្នុង អនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ ។

បើអ្នកប្រាជ្ញទាំងឡាយ សង្កេតមើលរាល់ៗ ថ្ងៃ ហើយ សរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ក្នុងបញ្ញា និងសីល អ្នកណាគួរនឹងនិន្ទា បុគ្គលដែលដូចជាគ្រឿងនៃមាសជម្ពូនទនោះបាន សូម្បីទេវតា និងមនុស្សទាំងឡាយ ក៏សរសើរបុគ្គលនោះ ទាំងព្រហ្ម ក៏សរសើរ ( ដូចគ្នា ) ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ពោរាណមេតំ** គឺការនិន្ទា និងការសរសើរ នោះឯង ជារបស់ចាស់ ។

ព្រះសាស្តាត្រាស់ហៅឧបាសកនោះថា អតុលៈ ។

បាទព្រះគាថាថា **នេតំ អជ្ជតនាមិវ** សេចក្តីថា ការនិន្ទា ឬការសរសើរនេះ ហាក់ដូចជាមានក្នុងថ្ងៃនេះ គឺកើតអម្បាញ់មិញក៏មិនមែន អធិប្បាយថា ពិតហើយ មនុស្សទាំងឡាយ រមែងនិន្ទាបុគ្គលម្នាក់ថា ហេតុអ្វី ទើបបុគ្គលនេះអង្គុយដូចមនុស្សគរ ដូចមនុស្សត្រចៀកថ្លង់ ហាក់ដូចមិនដឹងអ្វីសោះ ដូច្នេះក៏មាន រមែងនិន្ទាបុគ្គលដែលនិយាយច្រើនថា ហេតុអ្វី ទើបបុគ្គលនេះធ្វើសំឡេង កជៈ កជៈ ដូចស្លឹកត្នោតត្រូវខ្យល់បក់ វាចារបស់បុគ្គលនេះមិនមានទីបំផុតសោះ ដូច្នេះ រមែងនិន្ទាបុគ្គលដែលនិយាយល្មមប្រមាណថា ហេតុអ្វី ទើបបុគ្គលនេះ សម្គាល់នូវពាក្យរបស់ខ្លួនដូចមាស និងប្រាក់ និយាយពាក្យពីរមាត់ហើយ នៅស្ងៀម ដូច្នេះ បុគ្គល ឈ្មោះថា មិនត្រូវនិន្ទា មិនមានក្នុងលោកនេះ ដោយប្រការទាំងពួង ដោយប្រការយ៉ាងនោះ ។

បទថា **ន ចាហុ** ជាដើម បានដល់ មិនមានហើយក្នុងអតីត នឹងមិនមានក្នុងអនាគត ។

ពីរបទថា **យញ្ចេ វិញ្ញូ** សេចក្តីថា ការនិន្ទា ឬសរសើររបស់ពួកជនពាលមិនជាប្រមាណ តែបណ្ឌិតទាំងឡាយពិចារណាហើយ គឺជ្រាបហេតុនៃនិន្ទា ឬហេតុនៃសរសើរហើយរាល់ថ្ងៃ រមែងសរសើរបុគ្គលណា បុគ្គលឈ្មោះថាមានការប្រព្រឹត្តមិនដាច់ខ្សែ ព្រោះជាអ្នកប្រកបដោយសិក្ខាដែលមិនដាច់ ឬដោយការប្រព្រឹត្តទៅនៃជីវិតមិនដាច់ខ្សែ បុគ្គលឈ្មោះថាមានបញ្ញា ព្រោះជាអ្នកប្រកបដោយបញ្ញាដែលរុងរឿងក្នុងធម៌ ឈ្មោះថា តាំងមាំដោយបញ្ញានិងសីល ព្រោះជាការប្រកបដោយបញ្ញា ដែលជាលោកិយ និងលោកុត្តរ និងដោយបារិសុទ្ធិ-

សីល ៤ បុគ្គលណាគួរនិន្ទាបុគ្គលនោះ ដែលដូចជាមាសជម្ពោនទ ដែលវៀរចាកទោសនៃមាសដែលគួរជុសខាត់ ។

បទថា **ទេវាបិ** ជាដើម បានដល់ ទេវតាក្តី មនុស្សដែលជាបណ្ឌិតក្តី រមែងក្រោកឡើងលើកតម្កើង សរសើរនូវភិក្ខុនោះ ។

បទថា **ព្រហ្មុនាបិ** សេចក្តីថា មិនមែនទេវតា និងមនុស្សតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីមហាជនក្នុងម៉ឺនចក្រវាល ក៏សរសើរបុគ្គលនោះដូចគ្នា ។

ក្នុងកាលចប់ទេសនា ឧបាសកទាំង ៥០០ តាំងនៅហើយក្នុងសោតាបត្តិផល ដូច្នេះឯង ។៙

**រឿង អតុលឧបាសក ចប់**

# រឿង ឆព្វគ្គិយភិក្ខុ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា **កាយប្បកោបំ** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ ព្រះសាស្តាទ្រង់ស្តាប់សំឡេង ខដៈ ខដៈ នៃភិក្ខុទាំងនោះ ដែលកាន់ឈើប្រត់ត្រង់ដៃទាំងពីរ ពាក់ទ្រនាប់ជើង ចង្ក្រមលើផ្ទាំងថ្ម ត្រាស់សួរថា អានន្ទ នុ៎ះជាសំឡេងអ្វី ទ្រង់ស្តាប់ថាជាសំឡេង ខដៈ ខដៈ នៃពួកឆព្វគ្គិយភិក្ខុ ដែលពាក់ទ្រនាប់ជើងឈើចង្ក្រម ទើបទ្រង់បញ្ញត្ត

សិក្ខាបទ ហើយត្រាស់ថា ធម្មតាភិក្ខុគួររក្សាទ្វារ មានកាយទ្វារជាដើម ដូច្នេះ ហើយ កាលទ្រង់សម្តែងធម៌ ទើបភាសិតព្រះគាថានេះថា

កាយប្បកោបំ រក្ខេយ្យ　　កាយេន សំវុតោ សិយា
កាយទុច្ចរិតំ ហិត្វា　　កាយេន សុចរិតំ ចរេ
វចីបកោបំ រក្ខេយ្យ　　វាចាយ សំវុតោ សិយា
វចីទុច្ចរិតំ ហិត្វា　　វាចាយ សុចរិតំ ចរេ
មនោបកោបំ រក្ខេយ្យ　　មនសា សំវុតោ សិយា
មនោទុច្ចរិតំ ហិត្វា　　មនសា សុចរិតំ ចរេ
កាយេន សំវុតា ធីរា　　អថោ វាចាយ សំវុតា
មនសា សំវុតា ធីរា　　តេ វេ សុបរិសំវុតា ។

បុគ្គលគប្បីរក្សានូវការកម្រើកកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត គប្បីរក្សានូវការកម្រើកវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត គប្បីរក្សានូវការកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោ-សុចរិត អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថា សង្រួមហើយដោយប្រពៃ ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កាយប្បកោបំ** បានដល់ គប្បីរក្សាកាយទុច្ចរិត ៣ យ៉ាង ។

ពីរបទថា **កាយេន សំវុតោ** សេចក្តីថា គប្បីហាមការចូលទៅនៃទុច្ចរិតក្នុងកាយទ្វារ សង្រួមហើយ គឺមានទ្វារបិទហើយ ព្រោះបុគ្គលលះកាយ-ទុច្ចរិត ប្រព្រឹត្តកាយសុចរិត ឈ្មោះថា ធ្វើកម្មនោះទាំងពីរយ៉ាង ដូច្នោះ ទើបទ្រង់ត្រាស់ថា **កាយទុច្ចរិតំ ហិត្វា កាយេន សុចរិតំ ចរេ** ក្នុងគាថាជាលំដាប់ទៅ ក៏ន័យនេះដូចគ្នា ។

បាទព្រះគាថាថា **កាយេន សំវុតា ធីរា** សេចក្តីថា បណ្ឌិតពួកណាកាលមិនធ្វើកាយទុច្ចរិត មានបាណាតិបាតជាដើម ឈ្មោះថា សង្រួមហើយផ្លូវកាយ កាលមិនធ្វើវចីទុច្ចរិត មានមុសាវាទជាដើម ឈ្មោះថា សង្រួមហើយដោយវាចា កាលមិនឲ្យមនោទុច្ចរិត មានអភិជ្ឈាជាដើមតាំងឡើង ឈ្មោះថា សង្រួមហើយផ្លូវចិត្ត បណ្ឌិតទាំងនោះ ឈ្មោះថា សង្រួមល្អហើយ គឺរក្សាល្អហើយ ឃុំគ្រងល្អហើយ មានទ្វារបិទល្អហើយក្នុងលោកនេះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿងឆព្វគ្គិយភិក្ខុ ចប់**

**កោធវគ្គ ចប់**

**វគ្គទី ១៧ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា មលវគ្គទី ១៨

[ ២៨ ] ឥឡូវនេះ ខ្លួនអ្នកដូចស្លឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជ ប្រាកដដល់អ្នកហើយ ខ្លួនអ្នកតាំងនៅក្នុងមាត់សេចក្តីវិនាស សូម្បីស្បៀង គឺកុសលរបស់អ្នក ក៏មិនទាន់មានឡើយ ។ អ្នកចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក ( ធ្វើយ៉ាងនេះហើយ ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួល គឺកិលេស នឹងដល់នូវភូមិរបស់ព្រះអរិយៈ ដូចជាទិព្វបាន ។

ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលដល់ហើយ ជាអ្នករៀបដំណើរទៅកាន់សម្នាក់យមរាជ មួយទៀត ទីសំចតក្នុងចន្លោះ មិនមានដល់អ្នកទេ សូម្បីស្បៀងក៏មិនមានដល់អ្នក ។

អ្នកចូរធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក ( ធ្វើយ៉ាងនេះហើយ ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួល គឺកិលេស នឹងមិនត្រូវចូលទៅកាន់ជាតិ ជរា ព្យាធិ មរណៈទៀតឡើយ ។

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តងៗ រាល់ៗ ខណៈដោយលំដាប់ ដូចជាងមាស ជម្រះស្នឹម ឬច្រែះរបស់មាស ដូច្នោះ ។

ច្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញយ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញា

ជាគ្រឿងជម្រះចិត្ត ឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះឯង ។

មន្តទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល ផ្ទះទាំងឡាយ មានការមិនថែទាំជាមន្ទិល សេចក្តីខ្ជិល ជាមន្ទិលរបស់ពណ៌សម្បុរ សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ធម៌អាក្រក់ទាំងឡាយ ជាមន្ទិលក្នុងលោកនេះ និងលោកខាងមុខ ធម្មជាត ជាមន្ទិលដ៏លើសលុប ជាងមន្ទិលទាំងនោះ គឺអវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះមន្ទិលទាំងនេះចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ ។

បុគ្គលអ្នកមិនមានសេចក្តីអៀនខ្មាស ក្លៀវក្លាដូចសត្វក្អែក កម្ចាត់បង់គុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន ( យកមុខ ) ជាអ្នកឃ្នើសឃ្នង ជាមនុស្សសៅហ្មង រស់នៅដោយងាយ ។ ចំណែកបុគ្គលអ្នកមានសេចក្តីអៀនខ្មាស ស្វែងរកអំពើស្អាតជានិច្ច មិនឡេះឡោះ មិនឃ្នើសឃ្នង រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញត្រូវ រស់នៅដោយលំបាក ។

ជនណា សម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកវត្ថុដែលគេមិនបានឲ្យ ក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ជនណា ផឹកទឹកសុរា និងមេរ័យផង ជននោះឯងឈ្មោះថា គាស់រម្លើងឫសគល់របស់ខ្លួនក្នុងលោកនេះ ដោយពិត ។

ម្នាលបុរសដ៏ចម្រើន អ្នកចូរដឹងយ៉ាងនេះថា ជនទាំងឡាយមានធម៌

ដ៏លាមក រមែងមិនជាអ្នកសង្រួម ដូច្នេះ លោក: និងសភាពមិនមែនធម៌ គឺ ទោស: ចូរកុំបៀតបៀនអ្នក ឲ្យបានសេចក្តីទុក្ខអស់កាលយូរឡើយ ។ ជន រមែងឲ្យតាមសទ្ធា តាមសេចក្តីជ្រះថ្លា បុគ្គលណា ជាអ្នកអៀនខ្មាសក្នុងទឹក និងភោជន របស់ជនទាំងឡាយដទៃ ជននោះ រមែងមិនបានសមាធិ ក្នុង វេលាថ្ងៃ ឬក្នុងវេលាយប់ឡើយ ។

លុះតែសេចក្តីអៀនខ្មាសនោះ បុគ្គលណាបានផ្តាច់ផ្តិលដកឡើង ធ្វើ ឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះឯង ទើបបានសមាធិចិត្ត ក្នុង វេលាថ្ងៃ ឬក្នុងវេលាយប់ ។

ភ្លើង ស្មើដោយរាគ: មិនមាន ការចាប់ ស្មើដោយទោស: មិនមាន បណ្តាញ ស្មើដោយមោហ: មិនមាន ស្ទឹង ស្មើដោយតណ្ហា មិនមាន ។

ទោសរបស់ពួកជនដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ ខ្លួន ឃើញបានដោយលំបាក ព្រោះថា បុគ្គលនោះ រោយទោសទាំងឡាយ ចំពោះពួកជនដទៃ ដូចបុគ្គលរោយអង្កាម ដូច្នោះ តែថា រមែងបិទបាំងទោស របស់ខ្លួនទុក ដូចព្រានបក្សីបិទបាំងអត្តភាព ដោយវត្ថុសម្រាប់បិទបាំង ( មានមែកឈើជាដើម ) ដូច្នោះ ។

កាលបុគ្គលគយឃ្លាំមើលទោស របស់បុគ្គលដទៃ ជាប្រក្រតី មាន ការសម្គាល់ហេតុ ក្នុងការពោលទោស ( អ្នកដទៃ ) ជានិច្ច ជាប្រក្រតី អាសវ:ទាំងឡាយរបស់បុគ្គលនោះតែងចម្រើន បុគ្គលនោះ ឈ្មោះថា ស្ថិត នៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវ: ។

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន ពួកសត្វត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ ព្រះតថាគតទាំងឡាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ ។

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន សង្ខារទាំងឡាយជារបស់ទៀង មិនមាន ព្រះពុទ្ធទាំងឡាយ មិនមានកិលេសជាគ្រឿងញាប់ញ័រទេ ។

**មលវគ្គទី ១៨ ចប់**

# អដ្ឋកថា
# ធម្មបទដ្ឋកថា ខុទ្ទកនិកាយ គាថាធម្មបទ
# មលវគ្គទី ១៨

## រឿង កូនរបស់គោឃាតកៈ
### លំនាំដើម

ព្រះសាស្តា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធបុត្ររបស់គោឃាតកៈម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **បណ្ឌុបលាសោវទានិសិ** ជាដើម ។

បានឮមកថា គោឃាតកៈម្នាក់ក្នុងនគរសាវត្ថី សម្លាប់គោហើយ កាន់យកសាច់ល្អឲ្យអាំងហើយ អង្គុយជាមួយបុត្រ និងភរិយា ទំពាស៊ីសាច់ និងលក់យកតម្លៃ ។ គាត់ធ្វើកម្មរបស់អ្នកសម្លាប់គោយ៉ាងនេះអស់ ៥៥ ឆ្នាំ មិនបានថ្វាយយាគូ និងភត្ត សូម្បីត្រឹមតែមួយវែកក្នុងមួយថ្ងៃដល់ព្រះសាស្តា ដែលប្រថាប់នៅក្នុងវិហារជិត ។ គាត់បើគ្មានសាច់ មិនបរិភោគភត្ត ។ ថ្ងៃមួយគាត់លក់សាច់ក្នុងពេលថ្ងៃហើយ ឲ្យដុំសាច់មួយដុំដល់ភរិយាដើម្បីអាំង ជាប្រយោជន៍ដល់ខ្លួន ហើយទៅងូតទឹក ។

លំដាប់នោះ សម្លាញ់របស់គាត់មកកាន់ផ្ទះហើយ និយាយនឹងភរិយាថា នែនាង ចូរឲ្យសាច់ដែលគប្បីលក់ដល់ខ្ញុំបន្តិច ព្រោះភ្ញៀវមកឯផ្ទះខ្ញុំ ។

ភរិយាគោឃាតកៈពោលថា សាច់ដែលគប្បីលក់មិនមាន សម្លាញ់របស់

អ្នកលក់សាច់ហើយ ឥឡូវនេះ ទៅងូតទឹក ។

សម្លាញ់នោះពោលថា កុំធ្វើយ៉ាងនេះឡើយ បើដុំសាច់មាន ចូរឲ្យចុះ ។ ភរិយាគោឃាតកៈពោលថា វៀរដុំសាច់ដែលខ្ញុំទុកដើម្បីសម្លាញ់របស់អ្នក ហើយសាច់ដទៃមិនមាន ។ បុរសនោះគិតថា សាច់ដទៃក្រៅអំពីសាច់ដែលស្រីនេះទុកដើម្បីប្រយោជន៍ដល់សម្លាញ់របស់អញមិនមាន ម្យ៉ាងទៀត សម្លាញ់របស់អញនោះវៀរសាច់នេះ មិនបរិភោគ ស្រីនេះនឹងមិនឲ្យ ទើបកាន់យកសាច់នោះដោយខ្លួនឯង ចៀសចេញទៅ ។

ចំណែកគោឃាតកៈ ងូតទឹកហើយត្រឡប់មក កាលភរិយានោះដួសភត្តនាំចូលទៅ មួយអន្លើដោយបន្លែស្ងោរដើម្បីខ្លួន ទើបពោលថា សាច់នៅឯណា ភរិយាពោលថា នៃអ្នក សាច់មិនមាន គោឃាតកៈពោលថា អញឲ្យសាច់ដើម្បីអាំងហើយ ទើបទៅមិនមែនឬ ភរិយាពោលថា សម្លាញ់របស់អ្នកមកប្រាប់ថា ភ្ញៀវរបស់ខ្ញុំមក ចូរនាងឲ្យសាច់ដែលគប្បីឲ្យដល់ខ្ញុំ កាលខ្ញុំឆ្លើយថា សាច់ដទៃក្រៅអំពីសាច់ដែលខ្ញុំទុកដើម្បីសម្លាញ់របស់អ្នកមិនមាន ម្យ៉ាងទៀត សម្លាញ់របស់អ្នកនោះ វៀរចាកសាច់ រមែងមិនបរិភោគ ក៏កាន់យកសាច់នោះដោយខ្លួនឯង ទៅហើយ ។

គោឃាតកៈពោលថា អញវៀរចាកសាច់មិនបរិភោគភត្ត ចូរនាងនាំភត្តនោះទៅ ភរិយាពោលថា ខ្ញុំអាចធ្វើអ្វីបាន សូមអ្នកបរិភោគចុះ ។

គោឃាតកៈនោះពោលថា អញមិនបរិភោគភត្ត ឲ្យភរិយានាំភត្តនោះទៅហើយ កាន់កាំបិតទៅកាន់សម្នាក់គោ ដែលកំពុងឈរក្រោយផ្ទះ ហើយលូក

ដៃចូលទៅក្នុងមាត់ ទាញអណ្តាត យកកាំបិតកាត់ត្រង់គល់ ហើយកាន់យកទៅអាំងលើរងើកភ្លើង ដាក់លើកត្តអន្ទុយបរិភោគ ដុំកត្តមួយដុំ ដាក់សាច់មួយដុំក្នុងមាត់ ។ ក្នុងខណៈនោះឯង អណ្តាតរបស់គាត់ដាច់ធ្លាក់ចុះក្នុងថាសសម្រាប់ដាក់កត្ត ។ ក្នុងខណៈនោះឯង គាត់បានវិបាកដែលឃើញសមដោយកម្ម គាត់ដូចជាគោដែលឈាមហូរចេញអំពីមាត់ ចូលទៅខាងក្នុងផ្ទះ ដើរដោយជង្គង់ ទ្រហោយំ ។

សម័យនោះ កូនរបស់គោឃាតកៈ ឈរមើលបិតាក្នុងទីជិត ។ គ្រានោះ មាតាពោលនឹងគាត់ថា នែកូន ចូរកូនមើលឪពុកដែលដើរដោយជង្គង់ទ្រហោយំត្រង់កណ្តាលផ្ទះដូចគោ សេចក្តីទុក្ខនេះ នឹងធ្លាក់លើអំបែងក្បាលរបស់ឯង ឯងមិនត្រូវជាប់ជំពាក់នឹងម៉ែ ចូរធ្វើនូវសួស្តីដល់ខ្លួនគេចទៅចុះ ។ កូនរបស់គោឃាតកៈនោះ ត្រូវមរណភ័យគំរាម ថ្វាយបង្គំមាតាហើយគេចចេញទៅ កាលគេចទៅហើយ ទៅកាន់នគរតក្កសិលា សូម្បីគោឃាតកៈក៏ដូចគ្នានឹងសត្វគោ ស្រែករោទ៍ក្នុងកណ្តាលផ្ទះ ធ្វើកាលកិរិយាហើយកើតក្នុងអវីចិ សូម្បីគោក៏បានស្លាប់ហើយ ។ ចំណែកកូនរបស់គោឃាតកៈ ទៅនគរតក្កសិលារៀនការងាររបស់ជាងមាស ។ លំដាប់នោះ អាចារ្យរបស់គាត់ទៅកាន់ស្រុកផ្តាំថា អ្នកគប្បីធ្វើគ្រឿងប្រដាប់ឈ្មោះនេះ ហើយចៀសចេញទៅ ។ គាត់ក៏បានធ្វើគ្រឿងប្រដាប់បែបនោះហើយ ។ កាលនោះ អាចារ្យរបស់គាត់មកឃើញគ្រឿងប្រដាប់ហើយត្រិះរិះថា បុរសនេះទៅក្នុងទីណាមួយ ជាអ្នកអាចចិញ្ចឹមជីវិតបាន ទើបឲ្យធីតាដែលចម្រើនវ័យរបស់ខ្លួនដល់គាត់ គាត់ចម្រើន

ដោយបុត្រ និងធីតាហើយ ។

លំដាប់នោះ កូនទាំងឡាយរបស់គាត់ចម្រើនវ័យហើយ រៀនសិប្បៈក្នុងកាលតមក ទៅកាន់នគរសាវត្ថី ញុំាងយាវាសឲ្យប្រព្រឹត្តទៅក្នុងនគរនោះ បានជាអ្នកមានសទ្ធាជ្រះថ្លា ។ ចំណែកបិតារបស់ពួកគាត់ មិនធ្វើកុសលណាមួយឡើយ ទោះបីនៅក្នុងកាលជាកក្នុងនគរតក្កសិលានោះ ។ លំដាប់នោះ ពួកកុលបុត្ររបស់គាត់ប្រឹក្សាគ្នាថា ឪពុករបស់ពួកយើងចាស់ ហើយឲ្យហៅមកកាន់សម្នាក់របស់ខ្លួនពោលថា ពួកខ្ញុំនឹងថ្វាយទានដើម្បីប្រយោជន៍ដល់លោកឪពុក ហើយនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ស្អែកឡើង ពួកជនទាំងនោះ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យគង់ក្នុងផ្ទះ ហើយអង្គាសដោយគោរព ក្នុងកាលស្រេចភត្តកិច្ច ក្រាបទូលព្រះសាស្ដាថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គ ថ្វាយភត្តនេះឲ្យជាជីវភត្តដើម្បីបិតា ។ សូមទ្រង់ធ្វើអនុមោទនាដល់បិតារបស់ខ្ញុំព្រះអង្គចុះ ។

ព្រះសាស្ដា ត្រាស់ហៅបិតារបស់ពួកគេមកហើយត្រាស់ថា ឧបាសកអ្នកជាមនុស្សចាស់ មានសរីរៈចាស់ជរា ដូចគ្នានឹងស្លឹកឈើពណ៌លឿង ស្បៀងគឺកុសលដើម្បីទៅកាន់បរលោករបស់អ្នកមិនទាន់មាន ចូរអ្នកធ្វើទីពឹងដល់ខ្លួន ចូរជាបណ្ឌិត កុំជាបុគ្គលពាលឡើយ ដូច្នេះហើយ កាលទ្រង់ធ្វើអនុ-មោទនា ទើបត្រាស់ព្រះគាថានេះថា

**បណ្ឌុបលាសោវទានិសិ យមបុរិសាបិ ច តេ ឧបដ្ឋិតា**
**ឧយ្យោគមុខេ ច តិដ្ឋសិ បាថេយ្យម្បិ ច តេ ន វិជ្ជតិ**

**សោ ករោហិ ទីបមត្តនោ   ខិប្បំ វាយម បណ្ឌិតោ ភវ**
**និទ្ធន្តមលោ អនង្គណោ   ទិព្វំ អរិយភូមិមេហិសិ ។**

ឥឡូវនេះ ខ្លួនអ្នកដូចស្លឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជប្រាកដដល់អ្នកហើយ ខ្លួនអ្នកតាំងនៅក្នុងមាត់នៃសេចក្តីវិនាស ស្បៀង គឺកុសលរបស់អ្នក ក៏មិនទាន់មានឡើយ ចូរអ្នកធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក ( ធ្វើយ៉ាងនេះហើយ ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួល គឺកិលេស នឹងដល់នូវភូមិរបស់ព្រះអរិយៈ ដូចជាទិព្វបាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **បណ្ឌុបលាសោវ ទានិសិ** សេចក្តីថា ឧបាសក ឥឡូវនេះ អ្នកដូចជាស្លឹកឈើ ដែលមានពណ៌លឿង ដែលដាច់ធ្លាក់ចុះលើផែនដី ។

ទូតរបស់ស្តេចយម ព្រះសាស្តាត្រាស់ហៅថា **យមបុរិសា** ។ តែពាក្យនេះ ទ្រង់ត្រាស់សំដៅដល់ការស្លាប់នោះឯង អធិប្បាយថា ការស្លាប់ប្រាកដដល់អ្នកហើយ ។

បទថា **ឧយ្យោគមុខេ** សេចក្តីថា អ្នកជាបុគ្គលតាំងនៅក្បែរមាត់នៃសេចក្តីវិនាស គឺជិតមាត់នៃសេចក្តីមិនចម្រើន ។

បទថា **បាថេយ្យំ** សេចក្តីថា ស្បៀង គឺកុសលរបស់អ្នកដែលទៅកាន់

បរលោក ក៏មិនទាន់មាន ដូចស្បៀង មានអង្ករជាដើម របស់បុគ្គលដែលត្រៀមនឹងទៅ មិនទាន់មាន ដូច្នោះ ។

ពីរបទថា **សោ ករោហិ** សេចក្តីថា ចូរអ្នកធ្វើទីពឹង គឺកុសលដល់ខ្លួនដូចបុគ្គលកាលទូកលិចក្នុងសមុទ្រ ធ្វើនូវទីពឹងពោល គឺកោះដល់ខ្លួន ដូច្នោះកាលអ្នកធ្វើ ចូរប្រញាប់ព្យាយាម គឺចូរប្រារព្ធសេចក្តីព្យាយាមឲ្យរហ័ស ចូរជាបណ្ឌិតដោយការធ្វើទីពឹង ពោល គឺកុសលកម្មដល់ខ្លួន ដ្បិតថា បុគ្គលណាធ្វើកុសល ក្នុងកាលដែលខ្លួនមិនទាន់ដល់មាត់នៃសេចក្តីស្លាប់ អាចនឹងធ្វើបាននោះឯង ។ បុគ្គលនោះ ឈ្មោះថា ជាបណ្ឌិត អធិប្បាយថា ចូរអ្នកជាបុគ្គលដូច្នោះ កុំជាអន្ធពាលឡើយ ។

ពីរបទថា **ទិព្វំ អរិយភូមិ** សេចក្តីថា អ្នកធ្វើសេចក្តីព្យាយាមយ៉ាងនេះ ឈ្មោះថា កម្ចាត់មន្ទិលបានហើយ ព្រោះភាពជាអ្នកនាំមន្ទិល មានរាគៈជាដើមចេញបាន ឈ្មោះថា មិនមានកិលេសដែលជាទីទួល គឺអស់កិលេស ព្រោះមិនមានកិលេសដូចទីទួល នឹងដល់ជាន់សុទ្ធាវាសភូមិ ដែលជាលំនៅនៃព្រះអរិយបុគ្គល ដែលបរិសុទ្ធហើយ ៥ ភូមិ ។

ក្នុងកាលចប់ទេសនា ឧបាសក តាំងនៅក្នុងសោតាបត្តិផលហើយ ។ ទេសនាមានប្រយោជន៍ដល់ពួកជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

កូនទាំងនោះ និមន្តព្រះសាស្តាដើម្បីប្រយោជន៍ក្នុងថ្ងៃស្អែក ថ្វាយទានហើយ បានក្រាបទូលព្រះសាស្តា ទ្រង់ធ្វើភត្តកិច្ចហើយក្នុងកាលទ្រង់អនុមោទនាហើយថា បពិត្រព្រះអង្គ ភត្តនេះពួកខ្ញុំព្រះអង្គថ្វាយឲ្យជាជីវភត្ត ដើម្បីបិតា

របស់ពួកខ្ញុំព្រះអង្គដូចគ្នា សូមទ្រង់ធ្វើអនុមោទនាដល់បិតានេះឯង ។

ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនា បានត្រាស់ពីរគាថាដូច្នេះថា

**ឧបនីតវយោ វទានិសិ សម្បយាតោសិ យមស្ស សន្តិកំ**
**វាសោបិ ច តេ នត្ថិ អន្តរា បាថេយ្យម្បិ ច តេ ន វិជ្ជតិ**
**សោ ករោហិ ទីបមត្តនោ ខិប្បំ វាយម បណ្ឌិតោ ភវ**
**និទ្ធន្តមលោ អនង្គណោ ន បុន ជាតិជរំ ឧបេហិសិ ។**

ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលដល់ហើយ ជាអ្នករៀបដំណើរទៅកាន់សម្នាក់យមរាជ មួយទៀត ទីសំចតក្នុងចន្លោះមិនមានដល់អ្នកទេ សូម្បីស្បៀង ក៏មិនមានដល់អ្នក ។

ចូរអ្នកធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក ( ធ្វើយ៉ាងនេះហើយ ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួល គឺកិលេស នឹងមិនត្រូវចូលទៅកាន់ជាតិ ជរា ព្យាធិ មរណៈទៀតឡើយ ។

## សេចក្តីអធិប្បាយ

សព្ទថា **ឧប** ក្នុងបទថា **ឧបនីតវយោ** ក្នុងព្រះគាថានោះ ត្រឹមតែជានិបាត ។ អ្នកមានវ័យដែលជរានាំទៅហើយ គឺមានវ័យកន្លងទៅហើយ បានដល់មានវ័យកន្លងហើយ អធិប្បាយថា ឥឡូវនេះ អ្នកកន្លងវ័យទាំង ៣ ហើយ តាំងនៅជិតមាត់របស់សេចក្តីស្លាប់ ។

បាទព្រះគាថាថា **សម្បយាតោសិ យមស្ស សន្តិកំ** សេចក្តីថា អ្នក

ត្រៀមទៅកាន់មាត់របស់មច្ចុ តាំងនៅហើយ ។

បាទព្រះគាថាថា **វាសោបិ ច តេ នត្ថិ អន្តរា** សេចក្តីថា ពួកអ្នកដើរផ្លូវ រមែងស្នាក់ធ្វើកិច្ចនោះៗក្នុងរវាងផ្លូវបានយ៉ាងណា បុគ្គលទៅកាន់បរលោករមែងស្នាក់នៅដូច្នោះមិនបាន ព្រោះខ្លួនទៅកាន់បរលោក មិនអាចនឹងពោលពាក្យជាដើមថា សូមអ្នករង់ចាំ ២-៣ ថ្ងៃ ខ្ញុំនឹងឲ្យទានសិន ឬស្តាប់ធម៌សិន ។ បុគ្គលកាលឃ្លាតចាកលោកនេះហើយ រមែងកើតក្នុងបរលោកនោះឯង ពាក្យនោះ ព្រះសាស្តាត្រាស់សំដៅយកសេចក្តីនេះ ។

បទថា **ចាជយ្យំ** នេះ ព្រះសាស្តាបានត្រាស់ខាងដើមហើយក៏ពិត តែព្រះសាស្តាទ្រង់កាន់យកក្នុងព្រះគាថានេះ ក៏ដើម្បីទ្រង់ធ្វើឲ្យរឿយៗ ដល់ឧបាសក សូម្បីព្យាធិនិងមរណៈ ក៏ឈ្មោះថាទ្រង់កាន់យកក្នុងបទថា **ជាតិជរំ** ដូច្នេះដូចគ្នា ។

ព្រះសាស្តា ត្រាស់អនាគាមិមគ្គដោយព្រះគាថាខាងដើម ត្រាស់អរហត្តមគ្គក្នុងព្រះគាថានេះ ។ កាលបើដូច្នោះ ឧបាសក កាលព្រះសាស្តាទ្រង់សម្តែងធម៌ ដោយអំណាចមគ្គខាងលើ ក៏សម្រេចសោតាបត្តិផលខាងក្រោមហើយ ទើបសម្រេចអនាគាមិផល ក្នុងកាលចប់អនុមោទនានេះ តាមកម្លាំងឧបនិស្ស័យរបស់ខ្លួន ដូចកាលព្រះរាជាទ្រង់ពូតព្រះក្រយាហារ ទំហំប៉ុនព្រះឱស្ឋរបស់ព្រះអង្គ ហើយទ្រង់នាំចូលទៅដល់ព្រះឱរស ព្រះកុមារទ្រង់ទទួលដោយប្រមាណព្រះឱស្ឋរបស់ព្រះកុមារប៉ុណ្ណោះ ដូច្នេះ ។

ព្រះធម្មទេសនា មានប្រយោជន៍ដល់បរិស័ទដ៏សេសដូច្នេះឯង ។ល។

# រឿង ព្រាហ្មណ៍ម្នាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **អនុបុព្វេន មេធាវី** ជាដើម ។

បានឮថា ថ្ងៃមួយ ព្រាហ្មណ៍នោះចេញទៅអំពីព្រលឹម បានឈរមើលពួកភិក្ខុដណ្តប់ចីវរ ក្នុងទីដែលជាទីដណ្តប់ចីវររបស់ភិក្ខុ ។ ទីនោះមានស្មៅដុះឡើងហើយ ។ ក្រោយមក ភិក្ខុមួយរូបដណ្តប់ចីវរ ជាយចីវរក៏អូសលើស្មៅសើមដោយតំណក់ទឹកសន្សើមហើយ ។ ព្រាហ្មណ៍ឃើញហេតុនោះហើយគិតថា អញគួរធ្វើទីនេះឲ្យប្រាសចាកស្មៅ ក្នុងថ្ងៃស្អែកឡើង ក៏យកចបទៅចាំងទីនោះ ធ្វើឲ្យដូចជាមណ្ឌលលាន ។

ស្អែកឡើង កាលភិក្ខុទៅកាន់ទីនោះដណ្តប់ចីវរ ព្រាហ្មណ៍ឃើញជាយចីវររបស់ភិក្ខុមួយរូបអូសលើផែនដី ប្រឡាក់ដោយធូលី ទើបគិតថា អញរោយខ្សាច់ក្នុងទីនេះគួរ ហើយជញ្ជូនខ្សាច់រោយ ។

ខាងក្រោយមកទៀត ក្នុងពេលមុនភត្តមានកម្តៅខ្លាំង ។ ក្នុងកាលនោះព្រាហ្មណ៍ឃើញញើសហូរចេញអំពីកាយរបស់ពួកភិក្ខុ ដែលកំពុងឃ្លុំចីវរ ទើបគិតថា អញសាងមណ្ឌបក្នុងទីនេះគួរ ទើបសាងមណ្ឌបហើយ ។

ស្អែកឡើង មានភ្លៀងធ្លាក់អំពីព្រលឹម ក្នុងកាលនោះព្រាហ្មណ៍សម្លឹងមើលភិក្ខុ ឃើញពួកភិក្ខុមានចីវរសើមគិតថា អញធ្វើសាលាក្នុងទីនេះគួរ ទើបសាងសាលា ហើយគិតថា អញនឹងធ្វើការឆ្លងសាលា ទើបនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យភិក្ខុទាំងឡាយគង់ខាងក្នុងផង ខាងក្រៅផង ថ្វាយ

*ទាន ក្នុងពេលស្រេចភត្តកិច្ច ទទួលបាត្រព្រះសាស្តា ដើម្បីប្រយោជន៍ដល់ការអនុមោទនា ហើយក្រាបទូលរឿងទាំងអស់នោះ តាំងអំពីដើមដល់ចប់ថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឈរមើលក្នុងទីនេះ ក្នុងកាលដែលពួកភិក្ខុឃ្លុំចីវរ ឃើញហេតុការណ៍យ៉ាងនេះៗ ទើបសាងវត្ថុនេះៗ ឡើង ។*

*ព្រះសាស្តា ស្តាប់ពាក្យរបស់បុរសនោះហើយត្រាស់ថា ម្នាលព្រាហ្មណ៍ ធម្មតាបណ្ឌិតទាំងឡាយ ធ្វើកុសលបន្តិចម្តងៗ គ្រប់ៗ ខណៈ រមែងនាំមន្ទិល គឺអកុសលរបស់ខ្លួនចេញដោយលំដាប់នោះឯង ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា*

**អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ**
**កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។**

*អ្នកមានប្រាជ្ញា គួរកម្ចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តងៗ រាល់ៗ ខណៈ ដោយលំដាប់ ដូចជាងមាសជម្រះស្នឹម ឬច្រែះរបស់មាស ដូច្នោះ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **អនុបុព្វេន** *គឺដោយលំដាប់ ។ បុគ្គលប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ឈ្មោះថា* **មេធាវី ។**

*ពីរបទថា* **ខណេ ខណេ** *សេចក្តីថា ធ្វើកុសលគ្រប់ៗ ឱកាស ។*

*បាទព្រះគាថាថា* **កម្មារោ រជតស្សេវ** *សេចក្តីថា បណ្ឌិតធ្វើកុសលរឿយៗ ឈ្មោះថា គប្បីកម្ចាត់មន្ទិល គឺកិលេស មានរាគៈជាដើមរបស់ខ្លួន*

ដ្បិតថា កាលបើយ៉ាងនោះ បណ្ឌិតរមែងជាបុគ្គលឈ្មោះថា មានមន្ទិលដែលកម្ចាត់ហើយ គឺមិនមានកិលេស ដូចជាងមាសរម្លាយជំមាសតែម្តងប៉ុណ្ណោះ រមែងមិនអាចដេញមន្ទិលចេញ ហើយធ្វើគ្រឿងប្រដាប់ផ្សេងៗ បាន តែកាលរម្លាយជំមាសរឿយៗ រមែងដេញមន្ទិលចេញបាន ខាងក្រោយ រមែងធ្វើឲ្យជាគ្រឿងប្រដាប់ផ្សេងៗ ច្រើនយ៉ាងបាន ដូច្នោះ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។៚

រឿង ព្រាហ្មណ៍ម្នាក់ ចប់

# រឿង ព្រះតិស្សត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ឈ្មោះតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អយសាវ មលំ សមុដ្ឋិតំ** ជាដើម ។

បានឮមកថា កុលបុត្រអ្នកក្រុងសាវត្ថីម្នាក់ បានបួស ឧបសម្បទាហើយ ប្រាកដឈ្មោះថា ព្រះតិស្សៈ ។ សម័យតមក ព្រះតិស្សៈនោះចាំវស្សាក្នុងវិហារក្នុងជនបទ បានសំពត់សាច់គ្រោតគ្រាតប្រមាណ ៨ ហត្ថ ចាំវស្សាបវារណាហើយ កាន់យកសំពត់នោះទៅដាក់ក្បែរដៃបងស្រី បងស្រីនោះត្រិះរិះថា សំពត់សាដកនេះមិនសមគួរដល់ប្អូនប្រុសអញ ហើយកាត់សំពត់

នោះ ដោយកាំបិតដ៏មុត ធ្វើឲ្យជាកំណាត់តូចធំ គ្រលុកក្នុងត្បាល់ ជជុះ សិតខារ រវៃឲ្យជាអំបោះល្អិត ត្បាញជាសំពត់សាដកហើយ ។

ឯព្រះថេរៈក៏ចាត់ចែងអំបោះ និងម្ជុល និមន្តភិក្ខុកំលោះ និងសាមណេរ ដែលធ្វើចីវរឲ្យប្រជុំគ្នាហើយ ទៅកាន់សម្នាក់បងស្រីពោលថា សូមបងឲ្យសំពត់សាដកនោះដល់អាត្មាៗ នឹងធ្វើចីវរ ។

បងស្រីនោះ នាំសំពត់សាដកប្រមាណ ៩ ហត្ថ មកដាក់ក្បែរដៃរបស់ព្រះថេរៈប្អូនប្រុស ។ លោកទទួលសំពត់សាដកនោះ មកពិចារណាហើយ ពោលថា សំពត់សាដករបស់អាត្មាសាច់គ្រោតគ្រាត ប្រមាណ ៨ ហត្ថ សំពត់នេះ សាច់ល្អិតប្រមាណ ៩ ហត្ថ សំពត់នេះ មិនមែនសំពត់សាដករបស់អាត្មាទេ ជាសំពត់សាដកបងស្រី អាត្មាមិនត្រូវការសំពត់នេះ ចូរបងស្រីឲ្យសំពត់សាដកផ្ទាំងនោះដល់អាត្មាចុះ ។ បងស្រីឆ្លើយថា បពិត្រលោកម្ចាស់ នេះជាសំពត់របស់លោកម្ចាស់នោះឯង សូមលោកម្ចាស់ទទួលសំពត់នោះចុះ ។ លោកមិនប្រាថ្នាឡើយ ។

លំដាប់នោះ ទើបបងស្រីប្រាប់កិច្ច ដែលខ្លួនធ្វើគ្រប់យ៉ាងដល់ព្រះថេរៈនោះ ហើយបានប្រគេនថា បពិត្រលោកម្ចាស់ នេះជាសំពត់របស់លោកម្ចាស់នោះឯង សូមលោកម្ចាស់ទទួលយកសំពត់នោះចុះ លោកកាន់សំពត់នោះទៅវិហារ ផ្តើមធ្វើចីវរកម្ម ។

លំដាប់នោះ បងស្រីរបស់លោកចាត់ចែងវត្ថុ មានបបរ និងកត្តជាដើម ដើម្បីប្រយោជន៍ដល់ភិក្ខុសាមណេរ ដែលធ្វើចីវររបស់ព្រះតិស្សៈនោះ ក្នុងថ្ងៃ

ដែលចីវរស្រេច បងស្រីឲ្យធ្វើសក្ការៈជាច្រើន លោកសម្លឹងមើលចីវរហើយ កើតនូវការជាប់ជំពាក់ក្នុងចីវរនោះ គិតថា ស្អែកនេះ អញនឹងដណ្ដប់ចីវរនោះ ហើយពាក់ត្រង់ខ្សែស្បៀង ក្នុងរាត្រីនោះ មិនអាចឲ្យអាហារដែលឆាន់ហើយ រលួយបាន ធ្វើមរណកាលហើយ កើតជាចៃត្រង់ចីវរនោះឯង ។

ចំណែកបងស្រី ឮការអនិច្ចធម្មរបស់លោកហើយ ទ្រហោយំបម្រះនទៀលទៀបបាតជើងរបស់ពួកភិក្ខុ ។ ពួកភិក្ខុធ្វើសរីរកិច្ចរបស់លោកហើយ ពោលថា ចីវរនោះជារបស់សង្ឃនោះឯង ព្រោះមិនមានគិលានុបដ្ឋាក ពួកយើងនឹងចែកចីវរនោះ ហើយឲ្យនាំចីវរនោះចេញមក ចៃរត់ស្រែកទៅខាងនោះខាងនេះថា ភិក្ខុពួកនេះចែកចីវរដែលជារបស់អញ ។

ព្រះសាស្ដា ប្រថាប់នៅក្នុងព្រះគន្ធកុដិ ទ្រង់ស្ដាប់ឮសំឡេងចៃនោះដោយទិព្វសោតត្រាស់ថា អានន្ទ ចូរអ្នកប្រាប់កុំឲ្យពួកភិក្ខុចែកចីវររបស់តិស្សភិក្ខុ ហើយរក្សាទុក ៧ ថ្ងៃ ព្រះថេរៈឲ្យធ្វើយ៉ាងនោះហើយ ។ ចៃនោះ ធ្វើកាលកិរិយាក្នុងថ្ងៃទី ៧ កើតក្នុងវិមានជាន់តុសិតហើយ ក្នុងថ្ងៃទី ៨ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកចែកចីវររបស់តិស្សៈ ហើយកាន់យក ពួកភិក្ខុធ្វើយ៉ាងនោះហើយ ។ ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា ហេតុអ្វីហ្ន៎ ទើបព្រះសាស្ដាឲ្យរក្សា ចីវររបស់ព្រះតិស្សៈអស់ ៧ ហើយទ្រង់អនុញ្ញាតដើម្បីកាន់យកក្នុងថ្ងៃទី ៨ ។

ព្រះសាស្ដាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាប

ទូលថា ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តិស្សៈ កើតជាចៃត្រង់ចីវររបស់ខ្លួន កាលពួកអ្នកចែកចីវរនោះ រត់ទៅ រត់មក ពោល យ៉ាងនេះថា ភិក្ខុទាំងនេះដណ្តើមចីវរដែលជារបស់អញ បើពួកអ្នកកាន់យក ចីវរ ចៃនោះអាក់អន់ក្នុងពួកអ្នកហើយ គប្បីកើតក្នុងនរក ព្រោះហេតុនោះ ទើបតថាគតឲ្យរក្សាទុក ឥឡូវនេះ តិស្សៈកើតក្នុងវិមានជាន់តុសិតហើយ ព្រោះហេតុនោះ ទើបតថាគតអនុញ្ញាតការកាន់យកចីវរដល់ពួកអ្នក ។ កាល ភិក្ខុនោះក្រាបទូលទៀតថា បពិត្រព្រះអង្គ ឈ្មោះថា តណ្ហានេះ គ្រោតគ្រាត ហ្ន៎ ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ឈ្មោះថា តណ្ហារបស់សត្វទាំងនេះគ្រោតគ្រាត ធម្មតាច្រែះតាំងឡើងអំពីដែក រមែងស៊ី ដែកនោះឯង រមែងឲ្យដែកវិនាសទៅ ធ្វើឲ្យជារបស់ប្រើប្រាស់មិនបាន យ៉ាង ណា តណ្ហានេះក៏ដូច្នោះដូចគ្នា កើតឡើងខាងក្នុងរបស់សត្វទាំងនេះហើយ រមែងឲ្យសត្វទាំងនោះកើតក្នុងអបាយ មាននរកជាដើម ឲ្យដល់នូវសេចក្តី វិនាស ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**អយសា វ មលំ សមុដ្ឋិតំ តទុដ្ឋាយ តមេវ ខាទតិ**
**ឯវំ អតិធោនចារិនំ សានិ កម្មានិ នយន្តិ ទុគ្គតឹ ។**

ច្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះ វិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នក ប្រព្រឹត្តកន្លងបញ្ញាជាគ្រឿងជម្រះចិត្ត ឲ្យទៅកាន់ទុគ្គតិក៏យ៉ាង នោះឯង ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អយសា** គឺអំពីដែក ។ បទថា **សមុដ្ឋិតំ** គឺតាំងឡើងហើយ ។ បទថា **តទុដ្ឋាយ** គឺកាលតាំងឡើងអំពីដែកនោះ ។

ក្នុងបទថា **អតិធោនចារិនំ** បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បញ្ញាជាគ្រឿងពិចារណាបច្ច័យ ៤ ថា ការបរិភោគនេះ ជាប្រយោជន៍ដោយបច្ច័យទាំងនេះ ហើយបរិភោគ ព្រះសាស្តាត្រាស់ថា **ធោនា** បុគ្គលប្រព្រឹត្តកន្លងនូវបញ្ញា ឈ្មោះថា **ធោនា** នោះ ឈ្មោះថា **អតិធោនចារី** ។

ព្រះសាស្តាត្រាស់ដូច្នេះថា ច្រែះកើតអំពីដែក តាំងឡើងអំពីដែក តែងស៊ីដែកនោះឯង យ៉ាងណា កម្មទាំងឡាយរបស់ខ្លួន គឺកម្មទាំងនោះ ឈ្មោះថាជារបស់ខ្លួននោះឯង ព្រោះតាំងឡើងក្នុងខ្លួន រមែងនាំបុគ្គលដែលមិនពិចារណាបច្ច័យ ៤ ហើយបរិភោគ ឈ្មោះថា ប្រព្រឹត្តឈានកន្លងនូវបញ្ញា ឈ្មោះថា **ធោនា** ទៅកាន់ទុគ្គតិដូច្នោះដូចគ្នា ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕៚

**រឿង ព្រះតិស្សត្ថេរ ចប់**

# រឿង ព្រះលោឡុទាយិត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលោឡុទាយី ត្រាស់ព្រះធម្មទេសនានេះថា **អសជ្ឈាយមលា មន្តា** ជាដើម ។

បានឮមកថា ពួកអរិយសាវកប្រមាណ ៥ កោដិ ក្នុងនគរសាវត្ថីថ្វាយទានមុនភត្តហើយ ក្រោយភត្ត កាន់វត្ថុទាំងឡាយ មានសប្បិ ប្រេង ទឹកឃ្មុំ ទឹកអំពៅ និងសំពត់ជាដើមទៅវិហារ ហើយស្តាប់ធម្មកថា ក្នុងកាលស្តាប់ធម៌ហើយ ដើរទៅ រមែងពោលគុណរបស់ព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។

ព្រះឧទាយិត្ថេរ ស្តាប់ពាក្យរបស់អរិយសាវកទាំងនោះហើយ ទើបពោលថា ពួកអ្នកស្តាប់ធម្មកថារបស់ព្រះថេរៈទាំងពីរនោះ គង់ពោលដល់ម៉្លេះ បើស្តាប់ធម្មកថារបស់អាត្មាហើយ នឹងពោលយ៉ាងណាហ្ន៎ ។

ពួកមនុស្សស្តាប់ពាក្យរបស់លោកហើយ គិតថា ព្រះថេរៈនេះប្រហែលជាព្រះធម្មកថិកមួយអង្គ ពួកយើងស្តាប់ធម្មកថារបស់ព្រះថេរៈនេះ គួរ ។ ថ្ងៃមួយ ពួកជនទាំងនោះអារាធនាព្រះថេរៈថា បពិត្រលោកម្ចាស់ ថ្ងៃនេះ ជាថ្ងៃស្តាប់ធម៌របស់ពួកខ្ញុំ ថ្វាយទានដល់ព្រះសង្ឃហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ពោលធម្មកថាក្នុងពេលថ្ងៃចុះ ចំណែកព្រះថេរៈនោះ ទទួលនិមន្តរបស់ពួកមនុស្សនោះហើយ ។

កាលពួកមនុស្សមកក្នុងពេលស្តាប់ធម៌ហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ពោលធម៌ដល់ពួកខ្ញុំចុះ ។ ព្រះលោឡុទាយិត្ថេរអង្គុយលើអាសនៈហើយ ចាប់ផ្ចិតដ៏វិចិត្រ ក៏ញ័រមិនឃើញបទធម៌ សូម្បីមួយបទ

ពោលថា អាត្មានឹងសូធ្យសរភញ្ញ សូមភិក្ខុអង្គដទៃពោលធម្មកថាចុះ ដូច្នេះហើយ ក៏ចុះអំពីធម្មាសនៈ ។ មនុស្សទាំងនោះ និមន្តភិក្ខុរូបដទៃឲ្យពោលធម្មកថាហើយ និមន្តព្រះលោឡុទាយីឡើងកាន់អាសនៈទៀត ដើម្បីសូធ្យសរភញ្ញ ព្រះលោឡុទាយីនោះ មិនឃើញបទធម៌ណាមួយទៀត ទើបពោលថា អាត្មានឹងពោលក្នុងពេលយប់ សូមភិក្ខុរូបដទៃសូធ្យសរភញ្ញចុះ ហើយក៏ចុះ មនុស្សទាំងនោះ និមន្តភិក្ខុដទៃឲ្យសូធ្យសរភញ្ញហើយ នាំព្រះថេរៈមកក្នុងពេលយប់ទៀត ព្រះថេរៈនោះក៏មិនឃើញធម្មបទណាមួយសូម្បីក្នុងពេលយប់ ពោលថា អាត្មានឹងពោលក្នុងពេលទៀបភ្លឺ សូមភិក្ខុរូបដទៃពោលក្នុងពេលយប់ចុះ ហើយក៏ចុះ ។ មនុស្សទាំងនោះ និមន្តភិក្ខុរូបដទៃឲ្យពោលហើយក្នុងពេលទៀបភ្លឺ ក៏នាំព្រះថេរៈនោះមកទៀត ។ ព្រះថេរៈនោះ សូម្បីក្នុងពេលទៀបភ្លឺ ក៏មិនបានឃើញបទធម៌ណាមួយ ។

មហាជនកាន់យកវត្ថុទាំងឡាយ មានដុំដី និងអន្ទត់ឧសជាដើមគំរាមថា ភិក្ខុអន្ធពាល កាលពួកខ្ញុំពោលសរសើរព្រះសារីបុត្ត និងព្រះមោគ្គល្លាន លោកពោលយ៉ាងនេះ និងយ៉ាងនេះ ឥឡូវនេះ ហេតុអ្វីទើបមិនពោល ដូច្នេះហើយក៏ជាប់តាមព្រះថេរៈដែលគេចទៅ ។ ព្រះថេរៈនោះ គេចទៅធ្លាក់ក្នុងវច្ចកុដិមួយកន្លែង ។

មហាជនសន្ទនាគ្នាថា ព្រះលោឡុទាយី កាលពាក្យសរសើរគុណព្រះសារីបុត្ត និងព្រះមោគ្គល្លានប្រព្រឹត្តទៅ អួតអាងប្រកាសភាពដែលខ្លួនជាធម្មកថិក កាលពួកមនុស្សធ្វើសក្ការៈហើយ ពោលថា ពួកខ្ញុំនឹងស្តាប់ធម៌

អង្គុយលើអាសនៈអស់ ៤ ដង មិនឃើញបទធម៌ណាមួយដែលគប្បីពោលត្រូវពួកមនុស្សក្រាន់វត្ថុទាំងឡាយ មានដុំដី និងអង្កត់ឧសជាដើម គំរាមថា លោកម្ចាស់លើកខ្លួនផ្ទឹមនឹងព្រះសារីបុត្ត និងព្រះមោគ្គល្លាន លោកម្ចាស់របស់ពួកយើង ដេញឲ្យគេចទៅធ្លាក់ក្នុងវច្ចកុដិហើយ ។

ព្រះសាស្ដាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះទេ សូម្បីក្នុងកាលមុន លោឡុទាយីនេះ ក៏លិចចុះក្នុងវណ្ដៅលាមកដូចគ្នា ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ជាតកនេះ ឲ្យដោយពិស្ដារថា

ម្នាលសម្លាញ់អ្នកមានធុរៈស្មើ ខ្ញុំមានជើង ៤ ម្នាលសម្លាញ់
អ្នកឯងក៏មានជើង ៤ ដែរ ម្នាលសម្លាញ់ ចូរអ្នកត្រឡប់មក
អ្នកខ្លាចឬ បានជារត់ចេញ ។

ដូច្នេះហើយ ត្រាស់ថា រាជសីហ៍ក្នុងកាលនោះ បានជាសារីបុត្ត ជ្រូកបានជាលោឡុទាយី ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោឡុទាយីរៀនធម៌មានប្រមាណតិចពិត ម្យ៉ាងទៀតមិនបានធ្វើការទន្ទេញសោះ ការរៀនបរិយត្តិណាមួយហើយ មិនធ្វើនូវការស្វាធ្យាយ បរិយត្តិនោះជាមន្ទិលពិត ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា**
**មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។**

មន្តទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល ផ្ទះទាំងឡាយ មានការមិនថែទាំជាមន្ទិល សេចក្ដីខ្ជិល ជាមន្ទិលរបស់ពណ៌សម្បុរ សេចក្ដីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **អសជ្ឈាយមលា** ជាដើម សេចក្ដីថា ព្រោះបរិយត្តិ គឺសិប្បៈណាមួយ កាលបុគ្គលមិនទន្ទេញ មិនប្រកបរឿយៗ រមែងសាបសូន្យ ឬមិនប្រាកដជាប់គ្នា ដូច្នោះ ទើបព្រះសាស្ដាត្រាស់ថា **អសជ្ឈាយមលា មន្តា ។**

ម្យ៉ាងទៀត ព្រោះឈ្មោះថា ផ្ទះរបស់បុគ្គលដែលគ្រប់គ្រងផ្ទះ ក្រោកឡើងស្រេចបាច់ហើយ មិនធ្វើកិច្ចមានការជួសជុលផ្ទះដែលទ្រុឌទ្រោមជាដើម រមែងវិនាស ដូច្នោះ ទើបព្រះសាស្ដាត្រាស់ថា **អនុដ្ឋានមលា ឃរា ។**

ព្រោះកាយរបស់គ្រហស្ថ ឬបព្វជិតដែលមិនធ្វើការជម្រះសរីរៈ ឬធ្វើការជម្រះបរិក្ខារ ដោយអំណាចការខ្ជិលច្រអូស រមែងមានពណ៌សម្បុរអាប់ ដូច្នោះ ទើបព្រះសាស្ដាត្រាស់ថា **មលំ វណ្ណស្ស កោសជ្ជំ ។**

ម្យ៉ាងទៀត ព្រោះកាលបុគ្គលរក្សាគោ ដេកលក់ ឬរវល់តែលេងដោយអំណាចសេចក្ដីប្រមាទ គោទាំងនោះរមែងដល់នូវសេចក្ដីវិនាស ដោយហេតុមានរត់ទៅកាន់ទីដែលមិនមែនកំពង់ជាដើមខ្លះ ដោយអន្តរាយ មានសត្វសាហាវ

និងចោរជាដើមខ្លះ ដោយអំណាចការឈានចុះកាន់ទីទាំងឡាយ មានស្រែស្រូវសាលីជាដើមរបស់ពួកជនដទៃ ហើយទំពាស៊ីខ្លះ សូម្បីខ្លួនឯងរមែងដល់នូវអាជ្ញាខ្លះ ការបរិកាសខ្លះ ។

ម្យ៉ាងទៀត កិលេសទាំងឡាយកន្លងចូលទៅ ដោយអំណាចសេចក្តីប្រមាទ រមែងញ៉ាំងបព្វជិតដែលមិនរក្សាទ្វារ ៦ ឲ្យឃ្លាតចាកសាសនា ដូច្នោះទើបព្រះសាស្តាត្រាស់ថា **បមាទោ រក្ខតោ មលំ** អធិប្បាយថា ការប្រមាទនោះ ឈ្មោះថា ជាមន្ទិល ព្រោះការប្រមាទ ជាទីតាំងនៃមន្ទិល ដោយការនាំសេចក្តីវិនាសមក ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៙

រឿង ព្រះលោឡុទាយិត្ថេរ ចប់

# រឿង កុលបុត្រម្នាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុលបុត្រម្នាក់ត្រាស់ព្រះធម្មទេសនានេះថា **មលិត្ថិយា ទុច្ចរិតំ** ជាដើម ។

បានឮមកថា មាតា និងបិតានាំកុលធីតាមានជាតិស្មើគ្នា ដើម្បីកុលបុត្រនោះ ។ នាងបានជាស្រីអ្នកប្រព្រឹត្តក្រៅចិត្តប្តី តាំងអំពីថ្ងៃដែលនាំមកហើយ

កុលបុត្រនោះខ្មាស ព្រោះការប្រព្រឹត្តក្រៅចិត្តរបស់នាង មិនអាចចូលដល់នូវការជួបមុខដល់បុគ្គលណាម្នាក់ វៀរលែងកុសលកម្ម មានការទំនុកបម្រុងព្រះសម្ពុទ្ធជាដើម ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះសាស្ដាត្រាស់សួរថា ឧបាសក ព្រោះហេតុអ្វី ទើបតថាគតមិនឃើញអ្នក ឧបាសកក្រាបទូលសេចក្ដីនោះហើយ ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងកុលបុត្រនោះថា ឧបាសក ក្នុងកាលមុន តថាគតបានពោលហើយថា ឈ្មោះថា ស្ត្រីទាំងឡាយ ដូចគ្នានឹងស្ទឹងជាដើម បណ្ឌិតមិនគួរធ្វើសេចក្ដីក្រោធក្នុងស្ត្រីទាំងនោះ តែអ្នកចាំមិនបាន ព្រោះអន្តរកពបិទបាំង កាលកុលបុត្រនោះអារាធនាហើយ ត្រាស់ជាតកឲ្យពិស្ដារថា

> ស្ទឹង ផ្លូវ រោងសុរា រោងជាទីប្រជុំ និងអណ្ដូងទឹក យ៉ាងណា ធម្មតាពួកស្រីក្នុងលោក ក៏យ៉ាងនោះដែរ វេលា ( នៃសេចក្ដីស្រើបក្នុងកាម ) របស់ពួកស្រីទាំងនោះ មិនមានឈប់ឈរទេ ។

ដូច្នេះហើយ ត្រាស់ថា ឧបាសក ភាពជាបុគ្គលប្រព្រឹត្តក្រៅចិត្ត ជាមន្ទិលរបស់ស្ត្រី សេចក្ដីកំណាញ់ជាមន្ទិលរបស់អ្នកឲ្យទាន អកុសលកម្មជាមន្ទិលរបស់សត្វទាំងឡាយក្នុងលោកនេះ និងលោកខាងមុខ ព្រោះអត្ថថាជាគ្រឿងញ៉ាំងសត្វឲ្យវិនាស តែអវិជ្ជាជាមន្ទិលដ៏ក្រៃលែងជាងមន្ទិលទាំងពួង ដូច្នេះហើយ ទ្រង់បានភាសិតគាថាទាំងនេះថា

មលិត្ថិយា ទុច្ចរិតំ មច្ឆេរំ ទទតោ មលំ
មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច ។
តតោ មលា មលតរំ អវិជ្ជា បរមំ មលំ
ឯតំ មលំ បហន្ត្វាន និម្មលា ហោថ ភិក្ខវោ ។

ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ធម៌អាក្រក់ទាំងឡាយ ជាមន្ទិល ក្នុងលោកនេះ និងលោកខាងមុខ ធម្មជាតជាមន្ទិលដ៏លើស លុបជាងមន្ទិលទាំងនោះ គឺអវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះមន្ទិលទាំងនេះ ចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ ។

## សេចក្តីអធិប្បាយ

ការប្រព្រឹត្តក្រៅចិត្ត ឈ្មោះថាការប្រព្រឹត្តអាក្រក់ក្នុងព្រះគាថានោះ សូម្បីស្វាមី រមែងដេញស្ត្រីដែលប្រព្រឹត្តក្រៅចិត្តចេញទៅខាងក្រៅផ្ទះ ស្រីនោះទៅកាន់សម្នាក់របស់មាតាបិតា ក៏ត្រូវមាតាបិតាបណ្តេញដោយពាក្យថា ហាង មិនមានការគោរពត្រកូល អញមិនអាចឃើញហាងដោយភ្នែកទាំងពីរ ស្ត្រីនោះអស់ទីពឹង ត្រាច់ទៅ រមែងដល់នូវសេចក្តីលំបាកច្រើន ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ការប្រព្រឹត្តអាក្រក់របស់ស្ត្រីនោះថា ជាមន្ទិល ។

បទថា **ទទតោ** ប្រែថា របស់បុគ្គលអ្នកឲ្យ កាលបុគ្គលណាក្នុងពេល ភ្ជួរស្រែគិតថា កាលស្រែនេះសម្បូរហើយ អញនឹងថ្វាយកត្តទាំងឡាយ មាន

សលាកកត្ថជាដើម កាលសម្ផួនឲ្យផលហើយ សេចក្តីកំណាញ់កើតឡើងហាម ចិត្តដែលសម្បយុត្តដោយចាគៈ បុគ្គលនោះ កាលចិត្តសម្បយុត្តដោយចាគៈ មិនដុះដាលឡើងបាន ដោយអំណាចសេចក្តីកំណាញ់ រមែងមិនបានសម្បត្តិ ៣ យ៉ាង គឺមនុស្សសម្បត្តិ ទិព្វសម្បត្តិ និងនិព្វានសម្បត្តិ ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ថា ការកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ សូម្បីក្នុងបទ ដទៃៗ ដែលមានរូប ( សភាព ) យ៉ាងនេះ ក៏មានន័យនេះដូចគ្នា ។

ពីរបទថា **ចាបកា ធម្មា** សេចក្តីថា អកុសលធម៌ទាំងឡាយ ជាមន្ទិលទាំងអស់ ទាំងក្នុងលោកនេះ ទាំងលោកខាងមុខ ។ បទថា **តតោ** សេចក្តីថា ជាងមន្ទិលដែលប្រាសហើយខាងដើម ។ បទថា **មលតរំ** សេចក្តីថា តថាគតនឹងប្រាប់មន្ទិលដែលក្រៃលែងដល់អ្នកទាំងឡាយ ។

បទថា **អវិជ្ជា** សេចក្តីថា ការមិនដឹងដែលមានវត្ថុ ៨ នោះឯង ជាមន្ទិលដ៏ក្រៃលែង ។

បទថា **បហាត្វាន** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយលះមន្ទិលនោះបានហើយ រមែងជាអ្នកឃាត់នូវមន្ទិលមិនបាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។៚

## រឿងកុលបុត្រម្នាក់ ចប់

# រឿង ភិក្ខុឈ្មោះ ចូឡសារី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ ឈ្មោះចូឡសារី ទើបត្រាស់ព្រះធម្មទេសនានេះថា **សុជីវំ អហិរិកេន** ជាដើម ។

បានឮមកថា ថ្ងៃមួយ ព្រះចូឡសារីនោះ ធ្វើវេជ្ជកម្មហើយ បានភោជនប្រណីតហើយកាន់យកចេញទៅ ជួបព្រះថេរៈតាមផ្លូវ ទើបពិតថា បពិត្រលោកម្ចាស់ ភោជននេះខ្ញុំធ្វើវេជ្ជកម្មបានហើយ លោកម្ចាស់នឹងមិនបានភោជនបែបនេះក្នុងទីដទៃ សូមលោកម្ចាស់ឆាន់ភោជននេះ ខ្ញុំនឹងធ្វើវេជ្ជកម្មនាំអាហារបែបនេះមកដើម្បីលោកម្ចាស់អស់កាលជានិច្ច ។ ព្រះថេរៈស្តាប់ពាក្យរបស់ព្រះចូឡសារីនោះហើយ ក៏អង្គុយស្ងៀម ចៀសចេញទៅហើយ ។ ភិក្ខុទាំងឡាយមកកាន់វិហារហើយ ក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាបុគ្គលដែលមិនមានការខ្មាស ជាអ្នកក្តាំក្តងដូចក្អែក តាំងនៅក្នុងអនេសនៈ ២១ យ៉ាង រមែងរស់នៅស្រួល ចំណែកបុគ្គលដែលសម្បូរដោយហិរិ និងឱត្តប្បៈ រមែងរស់នៅបានដោយលំបាក ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

**សុជីវំ អហិរិកេន　　　កាកសូរេន ធំសិនា**
**បក្ខន្ទិនា បគព្ភេន　　　សង្កិលិដ្ឋេន ជីវិតំ ។**
**ហិរីមតា ច ទុជ្ជីវំ　　　និច្ចំ សុចិគវេសិនា**
**អលីនេនាបគព្ភេន　　　សុទ្ធាជីវេន បស្សតា ។**

បុគ្គលមិនមានសេចក្ដីអៀនខ្មាស ក្លៀវក្លាដូចសត្វក្អែក កម្ចាត់បង់នូវគុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន ( យកមុខ ) ជាអ្នកឃ្នើសឃ្នង ជាមនុស្សសៅហ្មង រស់នៅដោយងាយ ។ ចំណែកបុគ្គលអ្នកមានសេចក្ដីអៀនខ្មាស ស្វែងរកអំពើស្អាតជានិច្ច មិនខ្ជិលច្រអូស មិនឃ្នើសឃ្នង រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញត្រូវ រស់នៅដោយលំបាក ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **អហិរិកេន** គឺបុគ្គលខ្វះនូវហិរិ និងឱត្តប្បៈ អធិប្បាយថា ដែលបុគ្គលបែបនោះ អាចហៅស្រីដែលមិនមែនមាតានោះឯងជាមាតារបស់អញ ហៅបុរសទាំងឡាយដែលមិនមែនបិតាជាដើមនោះឯងដោយន័យជាដើមថា បិតារបស់អញ តាំងនៅក្នុងអនេសនា ២១ យ៉ាង ជាអ្នករស់នៅបានស្រួល ។

បទថា **កាកសូរេន** បានដល់ ដូចក្អែកក្លៀវក្លា អធិប្បាយថា ដូចក្អែកក្លៀវក្លា ប្រាថ្នានឹងពាំវត្ថុទាំងឡាយ មានបបរជាដើមក្នុងផ្ទះនៃត្រកូលទាំងឡាយ ទំក្នុងទីទាំងឡាយ មានជញ្ជាំងជាដើមហើយ ដឹងថាគេក្រឡេកមើលខ្លួន ធ្វើដូចជាមិនបានឃើញ ដូចជាបញ្ជូនចិត្តទៅក្នុងទីដទៃ និងធ្វើដូចដេកលក់ កំណត់ការភ្លេចខ្លួនរបស់មនុស្សបានហើយ ក៏ធាប កាលពួកមនុស្សដេញថា សុ សុ នោះឯង ក៏ពាំអាហារពេញមាត់អំពីភាជនៈ ហើយហើរគេចទៅ យ៉ាងណា

សូម្បីបុគ្គលមិនមានការខ្មាស ក៏ដូច្នោះដូចគ្នា ចូលទៅកាន់ស្រុកជាមួយភិក្ខុទាំងឡាយហើយ រមែងកំណត់ទីទាំងឡាយ មានទីតាំងនៃបបរ និងភត្តជាដើម ភិក្ខុទាំងឡាយត្រាច់ទៅបិណ្ឌបាតក្នុងស្រុកនោះ ទទួលយកអាហារ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ទៅកាន់រោងឆាន់ ពិចារណា ឆាន់បបរហើយ ធ្វើកម្មដ្ឋានទុកក្នុងចិត្ត ស្វាធ្យាយ បោសសម្អាតរោងឆាន់ ចំណែកបុគ្គលនេះមិនធ្វើវត្តណាមួយ ជាអ្នកបែរមុខទៅកាន់ស្រុក ត្រូវភិក្ខុទាំងឡាយប្រាប់ថា ចូរមើលបុគ្គលនេះ ហើយសម្លឹងមើល ក៏ធ្វើដូចជាមិនក្រឡេកមើល ដូចបញ្ជូនទៅក្នុងទីដទៃ ដូចដេកលក់ ធ្វើដូចខ្វាស់ក្តុំ ធ្វើអកប្បកិរិយាដូចរៀបចំចីវរ ពោលថា ការងាររបស់ខ្ញុំឈ្មោះនេះមាន ក្រោកចាកអាសនៈចូលទៅស្រុក ចូលទៅកាន់ផ្ទះខ្លះឯណានីមួយ បណ្តាផ្ទះដែលបានកំណត់ហើយអំពីព្រលឹម ៗ កាលពួកមនុស្សក្នុងផ្ទះរាំងទ្វារហើយ អង្គុយរវៃអំបោះត្រង់មាត់ទ្វារ យកដៃម្ខាងច្រានទ្វារហើយ ចូលទៅខាងក្នុង ៗ លំដាប់នោះ មនុស្សទាំងនោះឃើញបុគ្គលនោះហើយ មិនប្រាថ្នា និមន្តឲ្យអង្គុយលើអាសនៈ រួចថ្វាយរបស់ មានយាគូជាដើមដែលមាន ៗ បរិភោគតាមត្រូវការហើយ កាន់យករបស់ចំណែកដ៏សេស ដោយបាត្រ ចៀសចេញទៅ បុគ្គលនេះឈ្មោះថាជាអ្នកក្លៀវក្លាដូចក្អែក ដែលបុគ្គលមិនមានហិរិ បែបនេះ ជាអ្នករស់នៅស្រួល ៗ

បទថា **ធំសិនា** សេចក្តីថា ឈ្មោះថា មានប្រក្រតីកម្ចាត់ ព្រោះកាលមនុស្សទាំងឡាយពោលពាក្យជាដើមថា ព្រះថេរៈឈ្មោះនេះជាអ្នកមានសេចក្តី

ប្រាថ្នាតិច កម្ចាត់នូវគុណរបស់បុគ្គលដទៃចោលដោយពាក្យជាដើមថា សូម្បីពួកយើងមិនជាអ្នកមានសេចក្តីប្រាថ្នាតិចទេឬ មនុស្សទាំងឡាយស្តាប់ពាក្យរបស់បុគ្គលបែបនោះហើយ កាលសម្គាល់ថា សូម្បីបុគ្គលនេះក៏ជាអ្នកប្រកបដោយគុណ មានភាពជាបុគ្គលប្រាថ្នាតិចជាដើម រមែងសម្គាល់របស់ដែលខ្លួនគួរឲ្យ តែចាប់តាំងអំពីនេះទៅ បុគ្គលនោះកាលមិនអាចញុំាងចិត្តរបស់បុរសដែលជាអ្នកប្រាជ្ញទាំងឡាយឲ្យត្រេកអរ រមែងសូន្យចាកលាភនោះ ។ បុគ្គលមានប្រក្រតីកម្ចាត់យ៉ាងនេះ រមែងញុំាងលាភទាំងឡាយរបស់ខ្លួន និងរបស់អ្នកដទៃឲ្យវិនាសដោយពិត ។

បទថា **បក្ខន្ទិនា** សេចក្តីថា ជាអ្នកច្រើនដោយការប្រព្រឹត្តស្ទុះទៅ គឺជាអ្នកសម្តែងកិច្ចរបស់អ្នកដទៃឲ្យដូចកិច្ចរបស់ខ្លួន កាលភិក្ខុទាំងឡាយធ្វើវត្តត្រង់លានព្រះចេតិយជាដើម អំពីព្រលឹម អង្គុយដោយការធ្វើទុកក្នុងចិត្តនូវកម្មដ្ឋានបន្តិចហើយក្រោកឡើង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត បុគ្គលនោះលប់មុខហើយ តាក់តែងអត្តភាពដោយដណ្តប់សំពត់កាសាវពស្ត្រ មានពណ៌លឿង បន្ទក់ក្អែក និងលាបក្បាលជាដើម ឲ្យប្រហារដោយអម្បោស ២-៣ ហាក់ដូចជាកំពុងបោស ជាបុគ្គលបែរមុខទៅកាន់ខ្លោងទ្វារ ពួកមនុស្សមកអំពីព្រលឹមដោយគិតថា នឹងថ្វាយបង្គំព្រះចេតិយ នឹងធ្វើការបូជាដោយផ្កាកម្រងឃើញបុគ្គលនោះហើយនិយាយគ្នាថា វិហារនេះអាស្រ័យភិក្ខុកំលោះនេះ ទើបបាននូវកិច្ចបដិបត្តិទំនុកបម្រុង អ្នកទាំងឡាយ កុំលះបង់ភិក្ខុនេះ ដូច្នេះហើយ រមែងសម្គាល់របស់ដែលខ្លួនគប្បីឲ្យដល់បុគ្គលនោះ ដែលបុគ្គលច្រើនដោយ

ការស៊ុះទៅបែបនេះ ក៏ជាអ្នករស់នៅបានស្រួល ។

បទថា **បគព្ភេន** សេចក្ដីថា បុគ្គលប្រកបដោយការថ្កាំថ្កូងដោយកាយជាដើម ។ ពីរបទថា **សង្កិលិដ្ឋេន ជីវិតំ** សេចក្ដីថា បុគ្គលដែលចិញ្ចឹមជីវិតរស់នៅយ៉ាងនេះ ឈ្មោះថា ជាអ្នកសៅហ្មងហើយ ។ ការរស់នៅនោះ ឈ្មោះថា រស់នៅអាក្រក់ គឺរស់នៅដ៏លាមក ។

បទថា **ហិរិមតា ច** សេចក្ដីថា បុគ្គលដែលសម្បូរដោយហិរិ និងឱត្តប្បៈ រស់នៅលំបាក ព្រោះបុគ្គលនោះមិនពោលពាក្យថា មាតារបស់អញជាដើមនឹងស្រីដែលមិនមែនជាមាតាជាដើម ខ្ពើមបច្ច័យដែលកើតឡើង ដែលមិនប្រកបដោយធម៌ដូចលាមក ស្វែងរកបច្ច័យដោយធម៌ជានិច្ច ត្រាច់បិណ្ឌបាតតាមលំដាប់ច្រក សម្រេចជីវិតរស់នៅសៅហ្មង ។

បទថា **សុចិគវេសិនា** សេចក្ដីថា ស្វែងរកកម្មទាំងឡាយ មានកាយកម្មជាដើមដ៏ស្អាត ។ បទថា **អលីនេន** សេចក្ដីថា មិនរួញរាដោយការប្រព្រឹត្តទៅនៃជីវិត ។

ពីរបទថា **សុទ្ធាជីវេន បស្សតា** សេចក្ដីថា បុគ្គលបែបនេះ រមែងជាបុគ្គលឈ្មោះថាមានអាជីវៈបរិសុទ្ធ ។ បុគ្គលដែលមានអាជីវៈបរិសុទ្ធហើយយ៉ាងនេះ ឃើញអាជីវៈបរិសុទ្ធនោះឯង ដោយភាពជាសារៈ រមែងជាអ្នករស់នៅលំបាក ដោយអំណាចភាពជាបុគ្គលសៅហ្មង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

# រឿង ឧបាសក ៥ នាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសក ៥ នាក់ ត្រាស់ព្រះធម្មទេសនានេះថា **យោ បាណមតិបាតេតិ** ជាដើម ។

សេចក្តីពិស្តារថា បណ្តាឧបាសកទាំងនោះ ឧបាសកម្នាក់រក្សាសិក្ខាបទ គឺបាណាតិបាតតែមួយ ។ ចំណែកឧបាសកទាំងឡាយក្រៅអំពីនេះ រក្សាសិក្ខាបទទាំងឡាយក្រៅអំពីនេះ ។ ថ្ងៃមួយ ឧបាសកទាំងនោះ កើតនូវការប្រកែកគ្នាថា ខ្ញុំតែងធ្វើកម្មដែលធ្វើបានដោយលំបាក ។ ខ្ញុំរក្សាវត្តដែលរក្សាបានដោយលំបាក ទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយ ក្រាបទូលសេចក្តីនោះ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ឧបាសកទាំងនោះហើយ ទ្រង់មិនបានធ្វើសីលណាមួយឲ្យទាបឡើយ ត្រាស់ថា សីលទាំងអស់ ជារបស់រក្សាបានលំបាកទាំងអស់នោះឯង ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

**យោ បាណមតិបាតេតិ មុសាវាទញ្ច ភាសតិ**
**លោកេ អទិន្នំ អាទិយតិ បរទារញ្ច គច្ឆតិ ។**
**សុរាមេរយបានញ្ច យោ នរោ អនុយុញ្ជតិ**
**ឥធេវមេសោ លោកស្មឹ មូលំ ខនតិ អត្តនោ ។**
**ឯវំ ភោ បុរិស ជានាហិ បាបធម្មា អសញ្ញតា**
**មា តំ លោភោ អធម្មោ ច ចិរំ ទុក្ខាយ រន្ធយុំ ។**

ជនណាសម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យក

*វត្ថុដែលគេមិនបានឲ្យក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ជនណាផឹកទឹកសុរា និងមេរ័យផង ជននោះឯងឈ្មោះថា គាស់រម្លើងឫសគល់របស់ខ្លួន ក្នុងលោកនេះដោយពិត ។ ម្នាលបុរសដ៏ចម្រើន ចូរអ្នកដឹងយ៉ាងនេះថា ជនទាំងឡាយ មានធម៌ដ៏លាមក រមែងមិនជាអ្នកសង្រួម ដូច្នេះ លោភៈ និងសភាពមិនមែនធម៌ គឺទោសៈ ចូរកុំបៀតបៀនអ្នកឲ្យបាននូវសេចក្តីទុក្ខ អស់កាលយូរឡើយ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បាទព្រះគាថាថា* **យោ បាណមតិបាតេតិ** *សេចក្តីថា បណ្តាប្រយោគទាំង ៦ មានសាហត្ថិកប្បយោគជាដើម នរៈណាតែងចូលទៅកាត់នូវជីវិតិន្ទ្រិយរបស់អ្នកដទៃដោយប្រយោគ ១ ។*

*បទថា* **មុសាវាទំ** *សេចក្តីថា តែងពោលមុសាវាទ ដែលកាច់បំបាក់នូវប្រយោជន៍របស់អ្នកដទៃ ។*

*បាទព្រះគាថាថា* **លោកេ អទិន្នំ អាទិយតិ** *សេចក្តីថា រមែងកាន់យកទ្រព្យដែលបុគ្គលដទៃហួងហែងហើយ ដោយបណ្តាអវហារទាំងឡាយ មានថេយ្យាវហារជាដើម អវហារណាមួយ ក្នុងសត្វលោកនេះ ។*

*បាទព្រះគាថាថា* **បរទារញ្ច គច្ឆតិ** *សេចក្តីថា នរៈ កាលខុសក្នុងភណ្ឌៈទាំងឡាយ ដែលបុគ្គលដទៃរក្សា និងគ្រប់គ្រងហើយ ឈ្មោះថា តែងប្រព្រឹត្តក្រៅផ្លូវ ។*

បទថា **សុរាមេរយបានំ** បានដល់ ការផឹកនូវសុរា និងមេរ័យណាមួយនោះឯង ។ បទថា **អនុយុញ្ជតិ** គឺរមែងសេព បានដល់ រមែងធ្វើឲ្យច្រើន ។

ពីរបទថា **មូលំ ខណតិ** សេចក្តីថា បរលោក ចូរលើកទុក ក្នុងលោកនេះឯង នរៈនេះធ្វើនូវការបញ្ចាំ ឬលក់នូវទ្រព្យដែលជាដើមទុន មានស្រែនិងចម្ការជាដើម ដែលជាគ្រឿងគប្បីតម្កល់ខ្លួនបាន ផឹកនូវសុរា ឈ្មោះថារមែងជីកនូវឫសគល់របស់ខ្លួន គឺជាបុគ្គលមិនមានទីពឹង ជាបុគ្គលកំព្រាត្រាច់ទៅ ។

ព្រះសាស្តា រមែងត្រាស់ហៅបុគ្គលដែលកំណត់កម្ម គឺទ្រុស្តសីល ៥ ដោយពាក្យថា **ឯវំ ភោ** ។ បទថា **បាបធម្មា** បានដល់ ជាអ្នកមានធម៌លាមក ។ បទថា **អសញ្ញតា** បានដល់ ដែលវៀរហើយ ចាកការសង្រួម មានការសង្រួមផ្លូវកាយជាដើម ។ ព្រះបាលីថា **អចេតសា** ដូច្នេះក៏មាន សេចក្តីថា ជាអ្នកមិនមានចិត្ត ។

ពីរបទថា **លោភោ អធម្មោ ច** បានដល់ លោភៈ និងទោសៈ ពិតហើយ កិលេសជាតទាំងពីរនេះ ជាអកុសលដោយពិត ។

បាទព្រះគាថាថា **ចិរំ ទុក្ខាយ រន្ធយុំ** សេចក្តីថា ធម៌ទាំងនេះ ចូរកុំសម្លាប់ កុំញាំញីនូវអ្នក ដើម្បីប្រយោជន៍ដល់ទុក្ខទាំងឡាយមានទុក្ខក្នុង នរកជាដើម អស់កាលយូរ ។

ក្នុងកាលចប់ទេសនា ឧបាសក ៥ នាក់នោះតាំងនៅក្នុងសោតាបត្តិផលហើយ ព្រះធម្មទេសនាមានប្រយោជន៍ដល់មហាជន ដែលប្រជុំគ្នាហើយ

ដូច្នេះឯង ។

**រឿង ឧបាសក ៥ នាក់ ចប់**

# រឿង ភិក្ខុកំលោះ ឈ្មោះ តិស្សៈ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះឈ្មោះតិស្សៈ ត្រាស់ព្រះធម្មទេសនានេះថា **ទទាតិ វេ យថាសទ្ធំ** ជាដើម ។

បានឮថា ព្រះតិស្សៈនោះត្រាច់តិះដៀលទានរបស់ព្រះអរិយសាវក ៥ កោដិ គឺអនាថបិណ្ឌិកគហបតី នាងវិសាខាឧបាសិកាជាដើម ។ សូម្បីអសទិសទាន ក៏តិះដៀលដូចគ្នា បានរបស់ត្រជាក់ក្នុងរោងទានរបស់អរិយសាវកទាំងនោះ រមែងតិះដៀលថា ត្រជាក់ បានរបស់ក្តៅតិះដៀលថា ក្តៅ កាលគេឲ្យតិច រមែងតិះដៀលថា ព្រោះហេតុអ្វី ទើបជនទាំងនេះឲ្យរបស់បន្តិចបន្តួច សូម្បីគេឲ្យច្រើន ក៏តិះដៀលថា ក្នុងផ្ទះរបស់ជនទាំងនេះ ប្រហែលជាមិនមានកន្លែងទុកដាក់ ធម្មតាបុគ្គលគួរឲ្យវត្តុល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដល់ភិក្ខុទាំងឡាយ មិនមែនឬ យាគូ និងភត្តប៉ុណ្ណោះ រមែងវិបត្តិទៅមិនមានប្រយោជន៍ឡើយ តែពោលប្រារព្ធញាតិរបស់ខ្លួនជាដើមថា គួរសរសើរផ្ទះរបស់ពួកញាតិរបស់ខ្ញុំ ជារោងអគ្គាសរបស់ភិក្ខុទាំងឡាយ ដែលមកហើយអំពីទិសទាំង ៤ ដូច្នេះហើយ រមែងញ៉ាំងនូវពាក្យសរសើរឲ្យប្រព្រឹត្តទៅ ។

ព្រះតិស្សៈនោះ ជាកូនរបស់អ្នករក្សាទ្វារម្នាក់ ត្រាច់ទៅជាមួយពួកជាងឈើ ដែលត្រាច់ទៅកាន់ជនបទ ដល់នគរសាវត្ថី បួសហើយ ។

គ្រានោះ ភិក្ខុទាំងឡាយឃើញលោក ដែលត្រាច់តិះដៀលទានរបស់មនុស្សទាំងឡាយយ៉ាងនោះ គិតគ្នាថា ពួកយើងនឹងសាកសួរភិក្ខុនោះ ទើបសួរថា អាវុសោ ពួកញាតិរបស់លោកនៅឯណា បានឮថា នៅក្នុងស្រុកឈ្មោះនោះ ទើបបញ្ជូនភិក្ខុកំលោះទៅ ២-៣ រូប ។

ភិក្ខុកំលោះទាំងនោះទៅកាន់ស្រុកនោះហើយ កាលអ្នកស្រុកនិមន្តឲ្យគង់ត្រង់រោងឆាន់ហើយ ធ្វើសក្ការៈ ទើបសួរថា កំលោះឈ្មោះតិស្សៈ ចេញអំពីស្រុកនេះទៅបួសហើយមានឬ ជនពួកណាជាញាតិរបស់តិស្សៈនោះ មនុស្សទាំងឡាយគិតថា ក្នុងស្រុកនេះកុមារចេញអំពីផ្ទះនៃត្រកូលទៅបួសហើយមិនមាន ភិក្ខុទាំងនេះពោលដល់អ្នកណាហ្ន៎ ហើយសាកសួរថា បពិត្រលោកម្ចាស់ពួកយើងទាំងឡាយបានឮថា កូនរបស់អ្នករក្សាទ្វារម្នាក់ ត្រាច់ទៅជាមួយពួកជាងឈើបួសហើយ លោកម្ចាស់ទាំងឡាយពោលសំដៅយកលោកទេដឹង ។

ភិក្ខុកំលោះទាំងឡាយជ្រាបថា ពួកញាតិរបស់តិស្សភិក្ខុកំលោះនោះ មិនមានក្នុងស្រុកនោះហើយ ទើបនាំគ្នាត្រឡប់ទៅកាន់នគរសាវត្ថី ប្រាប់រឿងនោះដល់ភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ ព្រះតិស្សៈរមែងដើរពោលផ្ដេសផ្ដាសដល់វត្ថុដែលមិនមានហេតុផល ភិក្ខុទាំងឡាយ ក៏ក្រាបទូលរឿងនោះដល់ព្រះតថាគត ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថាតិស្សៈនោះ រមែង

ដើរអួតក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន លោកក៏ជាអ្នកអួតហើយ កាលភិក្ខុទាំងឡាយអារាធនាហើយ ទ្រង់នាំអតីតនិទានមកហើយ ទ្រង់ញ៉ាំងកជាហកជាតកនេះឲ្យពិស្តារថា

ទាសៈ ឈ្មោះកជាហកនោះ ទៅកាន់ជនបទដទៃ ពោលអួតនូវ
ពាក្យច្រើន សេដ្ឋីជាម្ចាស់មកតាម ( ម្តងទៀត ) គប្បីប្រទូស្តមិន
ខាន ។ ម្នាលកជាហក ចូរអ្នកបរិភោគនូវភោគៈទាំងឡាយទៅ ។

ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណា កាលជនដទៃឲ្យនូវវត្ថុតិចក្តី ច្រើនក្តី សៅហ្មងក្តី ប្រណីតក្តី ឬឲ្យវត្ថុដល់ជនដទៃ តែមិនឲ្យដល់ខ្លួន រមែងជាអ្នកខ្នាសអៀន ឈានក្តី វិបស្សនាក្តី មគ្គ និងផលក្តី រមែងមិនកើតឡើងដល់បុគ្គលនោះ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានភាសិតព្រះគាថាទាំងនេះថា

**ទទាតិ វេ យថាសទ្ធំ យថាបសាទនំ ជនោ**
**តត្ថ យោ មង្កុតោ ហោតិ បរេសំ ចានភោជនេ**
**ន សោ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។**
**យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ សមូហតំ**
**ស វេ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។**

ជនរមែងឲ្យតាមសទ្ធា តាមសេចក្តីជ្រះថ្លា បុគ្គលណា ជា
អ្នកអៀនខ្នាស ក្នុងទឹក និងភោជន របស់ជនទាំងឡាយ
ដទៃ ជននោះ រមែងមិនបានសមាធិចិត្ត ក្នុងវេលាថ្ងៃ ឬក្នុង

វេលាយប់ឡើយ លុះតែសេចក្ដីអៀនខ្មាសនោះ បុគ្គលណា បានផ្ដាច់ផ្ដិលដកឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះឯង ទើបបានសមាធិចិត្តក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បាទព្រះគាថាថា **ទទាតិ វេ យថាសទ្ធំ** សេចក្ដីថា ជន កាលឲ្យនូវបណ្ដាវត្ថុ មានរបស់សៅហ្មង និងរបស់ប្រណីតជាដើមឯណានីមួយ ឈ្មោះថា រមែងឲ្យតាមសទ្ធា គឺតាមសមគួរដល់សទ្ធារបស់ខ្លួន ។

បទថា **យថាបសាទនំ** សេចក្ដីថា បណ្ដាភិក្ខុដែលជាថេរៈ និងភិក្ខុថ្មីជាដើម ការជ្រះថ្លាក្នុងភិក្ខុណាមួយអង្គ រមែងកើតឡើងដល់បុគ្គលនោះ គ្រាថ្វាយទានដល់ភិក្ខុនោះ ឈ្មោះថា រមែងថ្វាយតាមការជ្រះថ្លា គឺតាមគួរដល់សេចក្ដីជ្រះថ្លារបស់ខ្លួននោះឯង ។

បទថា **តត្ថ** ជាដើម សេចក្ដីថា រមែងដល់នូវភាពជាអ្នកខ្មាសអៀន ព្រោះទានរបស់ជនដទៃនោះថា អញបានវត្ថុតិចតួច អញបានរបស់សៅហ្មង ។

បទថា **សមាធឹ** ជាដើម សេចក្ដីថា បុគ្គលនោះតែងមិនសម្រេចសមាធិ ដោយអំណាចនៃឧបចារសមាធិ និងអប្បនាសមាធិ ឬដោយអំណាចនៃមគ្គ និងផល ក្នុងពេលថ្ងៃ និងពេលយប់ ។

ពីរបទថា **យស្ស ចេតំ** សេចក្ដីថា អកុសលកម្មនោះ ពោល គឺភាពជាអ្នកខ្មាសអៀនក្នុងឋានៈទាំងនេះ កាលបុគ្គលណាកាត់ផ្ដាច់ហើយ ដកឡើង

ធ្វើឲ្យមានឫសដាច់ហើយ ដោយអរហត្តមគ្គញ្ញាណ បុគ្គលនោះ តែងតែសម្រេចសមាធិ មានប្រការដូចពោលហើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕៚

**រឿង ភិក្ខុកំលោះ ឈ្មោះ តិស្សៈ ចប់**

# រឿង ឧបាសក ៥ នាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសក ៥ នាក់ ត្រាស់ព្រះធម្មទេសនានេះថា **នត្ថិ រាគសមោ អគ្គិ** ជាដើម ។

បានឮថា ឧបាសកទាំងនោះប្រាថ្នានឹងស្តាប់ធម៌ ទៅកាន់វិហារថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងចំណែកម្ខាង ។ កាលត្រិះរិះថា បុគ្គលនេះជាក្សត្រ បុគ្គលនេះជាព្រាហ្មណ៍ បុគ្គលនេះជាអ្នកស្តុកស្តម្ភ បុគ្គលនេះជាអ្នកក្រីក្រ តថាគតសម្តែងធម៌ឲ្យក្រៃលែងដល់បុគ្គលនេះ នឹងមិនសម្តែងឲ្យក្រៃលែងដល់បុគ្គលនេះ រមែងមិនកើតឡើងដល់ព្រះពុទ្ធទាំងឡាយឡើយ ។

ព្រះសាស្តា កាលទ្រង់សម្តែងធម៌ប្រារព្ធបុគ្គលណាម្នាក់ រមែងធ្វើនូវការគោរពធម៌ជាធំ ហើយទើបសម្តែង ប្រៀបដូចទេវតាមានឫទ្ធិ បណ្តាលឲ្យទឹកក្នុងអាកាសហូរចុះមក ដូច្នោះ បណ្តាឧបាសកទាំងនោះ ដែលអង្គុយហើយ ក្នុង

សម្នាក់របស់ព្រះសាស្តា ដែលទ្រង់សម្តែងយ៉ាងនោះ ឧបាសកម្នាក់អង្គុយដេកលក់ហើយ ឧបាសកម្នាក់អង្គុយគូសផែនដីដោយម្រាមដៃ ឧបាសកម្នាក់អង្គុយអង្រួនដើមឈើ ឧបាសកម្នាក់អង្គុយងើយមើលអាកាស តែឧបាសកម្នាក់ ស្តាប់ធម៌ដោយគោរព ។

ព្រះអានន្ទ ថ្វាយនូវការបក់ផ្លិតព្រះសាស្តា សម្លឹងមើលអាការរបស់ឧបាសកទាំងនោះ ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ទ្រង់បន្លឺដូចមហាមេឃ ទ្រង់សម្តែងធម៌ដល់ឧបាសកទាំងនេះ តែឧបាសកទាំងនេះ កាលទ្រង់សម្តែងធម៌ អង្គុយធ្វើកម្មនេះឯង ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកមិនស្គាល់ឧបាសកទាំងនោះទេឬ ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនស្គាល់ទេ ។

ព្រះសាស្តាត្រាស់ថា បណ្តាឧបាសកទាំងនោះ ឧបាសកដែលអង្គុយដេកលក់ហើយនោះ កើតក្នុងកំណើតពស់អស់ ៥០០ ជាតិ ដាក់ក្បាលលើរង្វេលទាំងឡាយដេកលក់ហើយ ។ សូម្បីឥឡូវនេះ ការឆ្អែតក្នុងការដេកលក់របស់ឧបាសកនោះមិនមាន ។ សំឡេងរបស់តថាគតមិនចូលទៅកាន់ត្រចៀករបស់ឧបាសកនោះឡើយ ។ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទ្រង់ត្រាស់ដោយលំដាប់ ឬត្រាស់ដោយវគ្គៗ ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ពិតមែន សូម្បីព្រះសព្វញ្ញុតញ្ញាណក៏មិនអាចកំណត់នូវការកើតរបស់ឧបាសកនោះ ដែលបដិសន្ធិក្នុងចន្លោះៗ យ៉ាងនេះ គឺភាពជាមនុស្សតាមកាល ភាពជាទេវតាតាមកាល ភាពជានាគតាម

កាល តែឧបាសកនេះ កើតហើយក្នុងកំណើតនៃនាគអស់ ៥០០ ជាតិដោយលំដាប់ តែងតែដេកលក់ ការផ្ទៃតក្នុងការដេកលក់មិនមានឡើយ ។

ចំណែកបុរស ដែលអង្គុយគួសផែនដីដោយម្រាមដៃ កើតក្នុងកំណើតជន្លេនអស់ ៥០០ ជាតិដោយលំដាប់ ជីកផែនដីហើយ សូម្បីឥឡូវនេះ ក៏នៅតែគួសផែនដី ដោយអំណាចការប្រព្រឹត្តដែលខ្លួនធ្លាប់ប្រព្រឹត្តហើយក្នុងកាលមុន រមែងមិនស្តាប់សំឡេងរបស់តថាគត ។

ចំណែកបុរស អង្គុយអង្រួនដើមឈើនោះ កើតហើយក្នុងកំណើតស្វាអស់ ៥០០ ជាតិដោយលំដាប់ ។ ឥឡូវនេះ ក៏នៅតែអង្រួនដើមឈើដោយអំណាចនៃការប្រព្រឹត្ត ដែលខ្លួនធ្លាប់ប្រព្រឹត្តមកហើយក្នុងកាលមុននោះឯង ។ សំឡេងរបស់តថាគត មិនចូលត្រចៀករបស់ឧបាសកនោះឡើយ ។

ព្រាហ្មណ៍ដែលអង្គុយងើយមើលអាកាសនោះ ក៏កើតជាហោរា ប្រកបនក្ខត្តឫក្សអស់ ៥០០ ជាតិដោយលំដាប់ ទោះបីឥឡូវនេះ ក្នុងថ្ងៃនេះក៏នៅមើលអាកាស ដោយអំណាចនៃការប្រព្រឹត្ត ដែលខ្លួនធ្លាប់ប្រព្រឹត្តមកហើយក្នុងកាលមុននោះឯង ។ សំឡេងរបស់តថាគត រមែងមិនចូលត្រចៀករបស់ឧបាសកនោះ ។

ចំណែកព្រាហ្មណ៍ ដែលស្តាប់ធម៌ដោយគោរពនោះ កើតជាព្រាហ្មណ៍ដែលទន្ទេញមន្ត្រ ដល់ត្រើយនៃត្រៃវេទអស់ ៥០០ ជាតិដោយលំដាប់ ទោះបីឥឡូវនេះ ក៏ស្តាប់ធម៌ដោយគោរព ហាក់ដូចប្រៀបធៀបមន្ត្រ ។ ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ព្រះធម្មទេសនារបស់ព្រះអង្គ រមែងជ្រែកអវយវៈ

ទាំងឡាយ មានស្បែកជាដើម រហូតដល់ខួរក្នុងឆ្អឹងតាំងនៅ ព្រោះហេតុអ្វី បានជាឧបាសកទាំងនេះ កាលទ្រង់សម្តែងធម៌ ទើបមិនស្តាប់ដោយគោរព ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកប្រហែលជាធ្វើសេចក្តីសម្គាល់ថា ធម៌របស់តថាគត បុគ្គលគប្បីស្តាប់បានដោយងាយទេដឹង ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ធម៌របស់ទ្រង់បុគ្គលគប្បីស្តាប់បានដោយលំបាកឬ ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ត្រឹមត្រូវហើយ ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ព្រោះហេតុអ្វី ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ បទថា **ពុទ្ធោ** ក្តី **ធម្មោ** ក្តី **សង្ឃោ** ក្តី ដែលសត្វទាំងនេះមិនធ្លាប់ស្តាប់ហើយ ក្នុងសែនកប្បដ៏អនេក ព្រោះដូច្នោះ ទើបសត្វទាំងនេះ មិនអាចស្តាប់ធម៌នេះបាន តែក្នុងសង្សារ មានទីបំផុត ដែលបុគ្គលណាម្នាក់តាមដឹងមិនបាន សត្វទាំងនេះស្តាប់តិរច្ឆានកថា មានបែបផ្សេងៗ នោះឯង មកហើយ ព្រោះដូច្នោះ ទើប សត្វទាំងនេះ ត្រាច់ច្រៀងរាំក្នុងទីទាំងឡាយ មានរោងសុរា និងសួនសម្រាប់លេងជាដើម ទើបមិនអាចស្តាប់ធម៌បាន ។ ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ឧបាសកទាំងឡាយនោះ អាស្រ័យអ្វី ទើបមិនអាច ។

លំដាប់នោះ ព្រះសាស្តាត្រាស់ដល់ព្រះអានន្ទថា ម្នាលអានន្ទ ឧបាសកទាំងនោះអាស្រ័យរាគៈ អាស្រ័យទោសៈ អាស្រ័យមោហៈ អាស្រ័យតណ្ហា ទើបមិនអាច ឈ្មោះថា ភ្លើង ដូចគ្នានឹងភ្លើង គឺរាគៈ មិនមាន ភ្លើងណាមិនសម្តែងនូវផេះ រមែងឆេះនូវសត្វទាំងឡាយ ពិតហើយ ភ្លើងដែលញុំាងកប្បឲ្យវិនាស ដែលអាស្រ័យការប្រាកដនៃព្រះអាទិត្យ ៧ ដួងកើតឡើង រមែង

ឆេះលោក មិនឲ្យវត្ថុណាមួយសេសសល់ក៏ពិត តែភ្លើងនោះ រមែងឆេះម្តងម្កាលប៉ុណ្ណោះ ឈ្មោះថា កាល ដែលភ្លើង គឺរាគៈមិនឆេះ មិនមាន ព្រោះដូច្នោះ ឈ្មោះថា ភ្លើង ស្មើដោយរាគៈក្តី ភ្លើង ស្មើដោយទោសៈក្តី សំណាញ់ ស្មើដោយមោហៈក្តី ឈ្មោះថា ស្ទឹង ស្មើដោយតណ្ហាក្តី មិនមាន ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា

**នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ**
**នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។**

ភ្លើង ស្មើដោយរាគៈ មិនមាន ការចាប់ ស្មើដោយទោសៈ មិនមាន បណ្តាញ ស្មើដោយមោហៈ មិនមាន ស្ទឹង ស្មើដោយតណ្ហា មិនមាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **រាគសមោ** សេចក្តីថា ឈ្មោះថា ភ្លើង ស្មើដោយរាគៈ រមែងមិនមាន ដោយអំណាចនៃការមិនបង្ហាញអ្វីមួយ ដូចជាផ្សែងជាដើម តាំងឡើងដុតខាងក្នុងនោះឯង ។ បទថា **ទោសសមោ** សេចក្តីថា អ្នកចាប់ទាំងឡាយ មានអ្នកចាប់ គឺយក្ខ អ្នកចាប់ គឺពស់ថ្លាន់ អ្នកចាប់ គឺក្រពើជាដើម រមែងអាចចាប់បានក្នុងអត្តភាពមួយប៉ុណ្ណោះ តែអ្នកចាប់ គឺទោសៈ រមែងចាប់ដោយចំណែកមួយនោះឯង ព្រោះដូច្នោះ ឈ្មោះថា អ្នកចាប់ ស្មើដោយទោសៈ រមែងមិនមាន ។

ពីរបទថា **មោហសមំ ជាលំ** សេចក្តីថា ឈ្មោះថា សំណាញ់ ស្មើ

ដោយមោហៈ រមែងមិនមាន ព្រោះអត្ថថា ចងរឹត និងរួបរឹត ។

បទថា **តណ្ហាសមា** សេចក្តីថា ពេលពេញក្តី ពេលខ្វះខាតក្តី ពេលរីងស្ងួតក្តីរបស់ស្ទឹងទាំងឡាយ មានស្ទឹងគង្គាជាដើម រមែងប្រាកដ តែកាលពេញ ឬកាលរីងស្ងួតនៃតណ្ហារ មែងមិនមាន ការខ្វះតែម្យ៉ាងរមែងប្រាកដជានិច្ច ព្រោះដូច្នោះ ឈ្មោះថា ស្ទឹង ស្មើដោយតណ្ហា រមែងមិនមាន ព្រោះអត្ថថា ឲ្យពេញបានដោយលំបាក ។

ក្នុងកាលចប់ទេសនា ឧបាសកដែលស្តាប់ធម៌ដោយគោរពនោះ តាំងនៅក្នុងសោតាបត្តិផលហើយ ។ ព្រះធម្មទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នោះឯង ។៕

**រឿង ឧបាសក ៥ នាក់ ចប់**

# រឿង មេណ្ឌកសេដ្ឋី

## លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យភទ្ទិយនគរ ប្រថាប់នៅក្នុងជាតិយាវន គឺព្រៃម្រិះ ទ្រង់ប្រារព្ធមេណ្ឌកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះថា **សុទស្សំ វជ្ជមញ្ញេសំ** ជាដើម ។

បានឮថា ព្រះសាស្តា កាលចារិកទៅក្នុងអង្គុត្តរាបថជនបទទាំងឡាយ ទ្រង់ឃើញឧបនិស្ស័យសោតាបត្តិផលរបស់មនុស្សទាំងនេះ គឺមេណ្ឌកសេដ្ឋី

១ ភរិយារបស់សេដ្ឋីនោះ ឈ្មោះនាងចន្ទបទុមា ១ កូនប្រុសឈ្មោះធនញ្ជយសេដ្ឋី ១ កូនប្រសាស្រី ឈ្មោះនាងសុមនទេវី ១ ចៅស្រីឈ្មោះវិសាខា ១ ទាសៈ ឈ្មោះបុណ្ណៈ ១ ទើបយាងទៅកាន់ភទ្ទិយនគរ ប្រថាប់នៅក្នុងជាតិយាវ័ន ។ មេណ្ឌកសេដ្ឋីបានស្ដាប់ការយាងមករបស់ព្រះសាស្ដាហើយ ។

សួរថា ព្រោះហេតុអ្វី ទើបសេដ្ឋីឈ្មោះថាមេណ្ឌកៈ ឆ្លើយថា បានឮថា ពពែមាសទាំងឡាយ ប្រមាណប៉ុនដំរី សេះ និងគោឧសភ ជ្រែកផែនដី យកខ្នងទល់គ្នាផុសឡើងក្នុងទីប្រមាណ ៨ ករីស ក្រោយផ្ទះរបស់សេដ្ឋីនោះ ។ បុញ្ញកម្មដាក់ដុំអំបោះ ៥ ពណ៌ ក្នុងមាត់របស់ពពែទាំងនោះ ។ កាលសេចក្ដីត្រូវការដោយភេសជ្ជៈ មានសប្បិ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ឬដោយវត្ថុ មានសំពត់ គ្រឿងដណ្ដប់ ប្រាក់ និងមាសជាដើម ជនទាំងឡាយតែងនាំដុំអំបោះចេញអំពីមាត់របស់ពពែទាំងនោះ សប្បិ ប្រេង ទឹកឃ្មុំ ទឹកអំពៅ សំពត់ គ្រឿងបិទបាំង ប្រាក់ និងមាស រមែងហូរចេញអំពីមាត់ពពែនីមួយៗ គ្រប់គ្រាន់ ដល់មនុស្សក្នុងជម្ពូទ្វីប ។ ចាប់តាំងអំពីនោះមក ទើបសេដ្ឋីនោះប្រាកដឈ្មោះថា មេណ្ឌកសេដ្ឋី ។

សួរថា បុព្វកម្មរបស់សេដ្ឋីនោះដូចម្ដេច ឆ្លើយថា បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមវិបស្សី សេដ្ឋីនោះ ជាក្មួយរបស់កុដុម្ពិកៈឈ្មោះអវរោជៈ ឈ្មោះអវរោជៈ គឺឈ្មោះដូចអ៊ំ ។ គ្រានោះ អ៊ំរបស់គាត់ប្រារព្ធសាងព្រះគន្ធកុដិ ដើម្បីព្រះសាស្ដា ចូលទៅកាន់សម្នាក់របស់អ៊ំហើយ ពោលថា បពិត្រលោក

អំ យើងទាំងពីរនឹងសាងរួមគ្នា ក្នុងពេលដែលអំនោះឃាត់ថា អញតែម្នាក់ប៉ុណ្ណោះនឹងសាង មិនឲ្យសាធារណៈដល់ជនដទៃឡើយ ទើបគិតថា កាលអំសាងព្រះគន្ធកុដិក្នុងទីនេះហើយ អញគួរបានសាលាក្នុងទីនេះ ទើបឲ្យមនុស្សនាំឈើមកអំពីព្រៃ ឲ្យធ្វើសសរយ៉ាងនេះ គឺសសរមួយដើមស្រោបដោយមាស សសរមួយដើមស្រោបដោយប្រាក់ សសរមួយដើមស្រោបដោយកែវមណី ឲ្យធ្វើធ្នឹម រត សន្ទះទ្វារ សន្ទះបង្អួច បង្កង់ គ្រឿងប្រក់ និងឥដ្ឋទាំងអស់ ស្រោបដោយវត្ថុ មានមាសជាដើម ឲ្យធ្វើសាលាសម្រេចដោយរតនៈ ៧ ប្រការ ដល់ព្រះតថាគត ត្រង់ទីខាងមុខព្រះគន្ធកុដិ នៅខាងលើសាលានោះ មានកំពូល ៣ ដែលសម្រេចហើយដោយមាសទឹក ១០ និងជុំនៃកែវផលិក និងកែវប្រពាល ឲ្យសាងមណ្ឌបប្រដាប់ដោយកែវ ត្រង់កណ្តាលសាលា តម្កល់ធម្មាសនៈ ។

ជើងធម្មាសនៈនោះ សម្រេចដោយមាស មៅគ្រែទាំង ៤ ក៏ដូចគ្នា តែឲ្យធ្វើពពែមាស ៤ តាំងទុកខាងក្រោមនៃជើងទាំង ៤ របស់អាសនៈ ។ ឲ្យធ្វើពពែមាស ២ ទុកខាងក្រោមតាំងសម្រាប់រងជើង ឲ្យធ្វើពពែមាស ៦ ដាក់ជុំវិញមណ្ឌប ឲ្យត្បាញធម្មាសនៈដោយខ្សែរសែល្អិតសម្រេចដោយអំបោះហើយ ទើបឲ្យត្បាញដោយខ្សែដែលសម្រេចដោយមាសត្រង់កណ្តាល ហើយឲ្យត្បាញដោយខ្សែសម្រេចដោយកែវមុក្តាទុកខាងលើ បង្អែកនៃធម្មាសនៈនោះសម្រេចដោយដើមចន្ទន៍ ។ កាលឲ្យសាលាសម្រេចយ៉ាងនេះហើយ កាលនឹងធ្វើការឆ្លង ទើបនិមន្តព្រះសាស្តា មួយអន្លើដោយភិក្ខុ ៦ លាន ៨ សែន បាន

ថ្វាយទានអស់កាល ៤ ខែ ។ ក្នុងថ្ងៃចុងក្រោយ បានថ្វាយត្រៃចីវរ ។ បណ្ដាភិក្ខុទាំងនោះចីវរមានតម្លៃមួយពាន់ ធ្លាក់ដល់ភិក្ខុដែលបួសថ្មីក្នុងសង្ឃហើយ ។

បុរសនោះធ្វើបុញ្ញកម្ម ក្នុងកាលព្រះវិបស្សីសម្ពុទ្ធយ៉ាងនោះហើយ ឃ្លាតចាកអត្តភាពនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងភទ្ទកប្បនេះ កើតក្នុងត្រកូលសេដ្ឋីមានភោគៈច្រើន ក្នុងក្រុងពារាណសី មានឈ្មោះថាពារាណសីសេដ្ឋី ។

ថ្ងៃមួយ សេដ្ឋីទៅកាន់ទីបម្រើព្រះរាជា ជួបបុរោហិត ទើបពោលថាលោកអាចារ្យ លោកពិនិត្យមើលឫក្ស និងយាមឬ បុរោហិតពោលថា លោកសេដ្ឋី ខ្ញុំពិនិត្យមើល យើងទាំងឡាយមានការងារអ្វីដទៃ សេដ្ឋីសួរថា បើដូច្នោះ ការប្រព្រឹត្តទៅក្នុងជនបទដូចម្ដេច បុរោហិតពោលថា ភ័យមួយនឹងកើតមាន សេដ្ឋីសួរថា ភ័យនុ៎ះជាអ្វី បុរោហិតពោលថា បពិត្រលោកសេដ្ឋីគឺឆាតកភ័យ ( ភ័យកើតអំពីការខ្វះអាហារ ) សេដ្ឋីពោលថា នឹងមានក្នុងកាលណា បុរោហិតពោលថា នឹងមានក្នុងកាលកន្លងទៅ ៣ ឆ្នាំ បន្ទាប់អំពីឆ្នាំនេះ ។

សេដ្ឋីស្ដាប់ពាក្យនោះហើយ ឲ្យមនុស្សធ្វើកសិកម្មជាច្រើន ទិញចំពោះតែស្រូវដោយទ្រព្យដែលមានក្នុងផ្ទះ ឲ្យធ្វើជង្រុក ១២៥០ ដាក់ជង្រុកទាំងអស់ឲ្យពេញដោយស្រូវ កាលជង្រុកមិនគ្រប់គ្រាន់ ក៏ដាក់ក្នុងភាជនៈ មានពាងជាដើមឲ្យពេញហើយ ជីករណ្ដៅកប់ស្រូវដែលសល់ក្នុងផែនដី ប្របាច់ស្រូវដែលសល់អំពីកប់ជាមួយដីឥដ្ឋបូកជញ្ជាំងទាំងឡាយ ។

សម័យដទៃមកទៀត កាលភ័យ គឺការអត់ឃ្លានចូលមកដល់ហើយ ក៏បរិភោគស្រូវតាមដែលរក្សា កាលស្រូវដែលដាក់ក្នុងជង្រុក និងភាជនៈ មានពាងជាដើមអស់ហើយ ទើបហៅបរិវារជនមកហើយពោលថា នែបាទាំងឡាយ ចូរអ្នកទាំងឡាយទៅកាន់ភ្នំហើយរស់នៅ បើបំណងមកកាន់សម្នាក់យើង ចូរមកក្នុងកាលដែលមានកិច្ចការកបានងាយ បើមិនចង់មកទេ ក៏ចូររស់នៅទីនោះចុះ ជនទាំងនោះបានធ្វើយ៉ាងនោះហើយ ។ ចំណែកអ្នកបម្រើម្នាក់ឈ្មោះបុណ្ណៈ នៅសល់ក្នុងសម្នាក់របស់សេដ្ឋីនោះ រួមជា ៥ នាក់ គឺសេដ្ឋី ១ ភរិយារបស់សេដ្ឋី ១ បុត្ររបស់សេដ្ឋី ១ កូនប្រសារបស់សេដ្ឋី ១ ទាសៈឈ្មោះបុណ្ណៈនោះ ១ ។

ជនទាំងនោះ កាលស្រូវដែលកប់ទុកក្នុងផែនដីអស់ហើយ ដំបំបែកដីដែលបូកត្រង់ជញ្ជាំងត្រាំទឹក ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយស្រូវដែលបានហើយអំពីជញ្ជាំងនោះ ។

គ្រានោះ ភរិយាសេដ្ឋីកាលសេចក្តីឃ្លានគ្របសង្កត់ កាលដីអស់ទៅ ដំដីដែលសល់ក្នុងចំណែកនៃជញ្ជាំងទាំងឡាយហើយត្រាំទឹក បានស្រូវប្រមាណកន្លះអាឡ្ហក គឺ ២ នាឡិ បុកហើយកាន់យកអង្ករប្រមាណ ១ នាឡិ ដាក់ក្នុងឆ្នាំងមួយ ព្រោះខ្លាចអំពីចោរថា ក្នុងកាលកើតឆាតកភ័យ ចោរមានច្រើន បិទហើយកប់ទុកក្នុងផែនដី ។ លំដាប់នោះ សេដ្ឋីមកអំពីទីបម្រុងព្រះរាជាហើយ ពោលនឹងភរិយាថា នែនាង ខ្ញុំឃ្លាន វត្ថុណាមួយមានដែរឬទេ ភរិយាមិនបានពោលដល់វត្ថុដែលមានថាមិនមាន តែពោលថា នែអ្នក អង្ករមាន ១

នាឡិ សេដ្ឋីពោលថា អង្ករ ១ នាឡិនោះនៅឯណា ភរិយាពោលថា ខ្ញុំកប់ទុក ព្រោះខ្លាចចោរ សេដ្ឋីពោលថា បើដូច្នោះ ចូរនាងគាស់ឡើងមក ហើយចម្អិនចុះ ភរិយាពោលថា បើយើងបបរអាចគ្រប់គ្រាន់ ២ ពេល បើដាំបាយបានត្រឹមមួយពេលប៉ុណ្ណោះ ខ្ញុំនឹងចម្អិនដូចម្តេច សេដ្ឋីពោលថា បច្ច័យដទៃរបស់ពួកយើងមិនមាន ពួកយើងបរិភោគបាយហើយក៏ស្លាប់ ចូរនាងដាំបាយ ។

ភរិយានៃសេដ្ឋីនោះ ចម្អិនបាយហើយ ចែកជា ៥ ចំណែក ដួសបាយមួយចំណែកដាក់ខាងមុខលោកសេដ្ឋី ។

ក្នុងខណៈនោះ ព្រះបច្ចេកពុទ្ធមួយអង្គ នៅត្រង់ភ្នំគន្ធមាទន៍ ចេញអំពីសមាបត្តិ ជ្រាបថា ខាងក្នុងសមាបត្តិ ការស្រេកឃ្លាន រមែងមិនបៀតបៀន ព្រោះផលនៃសមាបត្តិ តែកាលព្រះបច្ចេកពុទ្ធទាំងឡាយ ចេញអំពីសមាបត្តិហើយ ការស្រេកឃ្លានដ៏មានកម្លាំងរមែងកើតឡើង ហាក់បីដូចដុតនូវផ្ទៃពោះដូច្នោះ ព្រោះដូច្នោះ ទើបព្រះបច្ចេកពុទ្ធទាំងនោះ ពិចារណាមើលឋានៈដែលអាចបានអាហារហើយ ទើបទៅ ។

ក្នុងថ្ងៃនោះ ជនទាំងឡាយណាបានថ្វាយទានដល់ព្រះបច្ចេកពុទ្ធហើយ រមែងបាននូវសម្បត្តិ មានតំណែងជាសេនាបតីជាដើមណាមួយ ព្រោះដូច្នោះ ព្រះបច្ចេកពុទ្ធនោះ ពិចារណាមើលដោយទិព្វចក្ខុ ត្រិះរិះថា ឆាតកភ័យកើតឡើងហើយក្នុងជម្ពូទ្វីបទាំងមូល ក្នុងផ្ទះសេដ្ឋី គេចម្អិនបាយដែលសម្រេចដោយអង្ករមួយនាឡិ ដើម្បីមនុស្ស ៥ នាក់ អ្នកទាំងនោះនឹងមានសទ្ធាដើម្បីសង្គ្រោះដល់អាត្មាអញដែរឬទេហ្ន៎ ឃើញភាពដែលជនទាំងនោះ ជាអ្នកមាន

សទ្ធាផង អាចធ្វើការសង្គ្រោះផង ទើបកាន់យកបាត្រ និងចីវរ ទៅបង្ហាញខ្លួនត្រង់ទ្វារផ្ទះ អំពីមុខលោកសេដ្ឋី ។ សេដ្ឋីនោះ គ្រាន់តែឃើញក៏មានចិត្តជ្រះថ្លា គិតថា អញជួបនូវធាតកក័យបែបនេះ ព្រោះអញមិនបានធ្វើទានក្នុងកាលមុន ភត្តនេះគប្បីរក្សាអញត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ឯភត្តដែលអញប្រគេនហើយដល់លោកម្ចាស់ នឹងនាំមកនូវប្រយោជន៍ដល់អញច្រើនកោដិកប្ប ហើយនាំថាស និងភត្តនោះចេញមក ចូលទៅរកព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន និមន្តឲ្យចូលទៅកាន់ផ្ទះ កាលលោកគង់លើអាសនៈហើយ ទើបលាងជើងរបស់លោក ដាក់ថាសភត្តលើតាំងមាស ហើយកាន់យកភត្តនោះមកដាក់ក្នុងបាត្រ ព្រះបច្ចេកពុទ្ធ កាលភត្តសល់ពាក់កណ្តាល ព្រះបច្ចេកពុទ្ធយកដៃបិទបាត្រ ។

ពេលនោះ ទើបសេដ្ឋីពោលនឹងព្រះបច្ចេកពុទ្ធថា បពិត្រលោកម្ចាស់ នេះជាចំណែកមួយនៃបាយដែលគេចម្អិនដើម្បីមនុស្ស ៥ នាក់ ដោយអង្ករមួយនាឡិ ខ្ញុំមិនអាចចែកភត្តនេះឲ្យជាពីរចំណែកបានទេ សូមលោកម្ចាស់កុំធ្វើការសង្គ្រោះដល់ខ្ញុំតែក្នុងលោកនេះឡើយ ខ្ញុំប្រាថ្នាប្រគេនមិនឲ្យសេសសល់ ហើយបានប្រគេនភត្តទាំងអស់ ។ កាលប្រគេនហើយ បានតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ ខ្ញុំកុំបីជួបធាតកក័យបែបនេះ ក្នុងទីដែលខ្ញុំកើតឡើយ តាំងអំពីឥឡូវនេះទៅ ខ្ញុំគប្បីឲ្យនូវភត្តដែលជាពូជដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូល មិនចាំបាច់ធ្វើការងារចិញ្ចឹមជីវិត ដោយដៃរបស់ខ្លួនឯងខណៈដែលខ្ញុំប្រើឲ្យមនុស្សសម្អាតជង្រុក ១២៥០ ហើយ កក់សក់ អង្គុយ

ត្រង់ទ្វារនៃជង្រុកទាំងនោះហើយ សម្លឹងមើលខាងលើប៉ុណ្ណោះ ធារានៃស្រូវសាលីគប្បីធ្លាក់ចុះមកកាន់ជង្រុកទាំងអស់ឲ្យពេញដើម្បីខ្ញុំ ។ បុគ្គលនោះឯង ចូរជាភរិយា បុគ្គលនេះឯង ចូរជាបុត្រ បុគ្គលនេះឯង ចូរជាកូនប្រសាស្រី បុគ្គលនេះឯង ចូរជាទាសៈរបស់ខ្ញុំ ក្នុងទីដែលខ្ញុំកើតហើយ ។

ចំណែកភរិយារបស់សេដ្ឋីនោះ គិតថា បើប្តីរបស់អញត្រូវសេចក្តីឃ្លានបៀតបៀន អញក៏មិនអាចលេបរួច ទើបប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ តាំងអំពីនេះទៅ ខ្ញុំមិនគប្បីជួបនូវឆាតកភ័យបែបនេះ ក្នុងទីដែលខ្ញុំកើតហើយ ម្យ៉ាងទៀត កាលខ្ញុំដាក់ថាសភត្តខាងមុខ ឲ្យនូវភត្តដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូល បើខ្ញុំមិនក្រោកដរាបណា ទីនៃភត្តដែលខ្ញុំដួសហើយ សូមពេញបរិបូណ៌ដូចដើមនោះឯង បុរសនេះសូមជាស្វាមី បុរសនេះសូមជាបុត្រ ស្ត្រីនេះសូមជាកូនប្រសា បុរសនេះសូមជាទាសៈ ។ កូនប្រុសរបស់សេដ្ឋីនោះ ក៏ប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាថា តាំងអំពីនេះទៅ ឆាតកភ័យបែបនេះ កុំបីមានដល់ខ្ញុំឡើយ ម្យ៉ាងទៀត បើខ្ញុំកាន់ថង់ប្រាក់ដាក់កហាបណៈមួយពាន់ សូម្បីឲ្យកហាបណៈដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូលថង់នោះ សូមពេញដូចដើម លោកទាំងពីរនោះ សូមជាមាតាបិតា ស្រីនេះសូមជាភរិយា បុរសនេះ សូមជាទាសៈរបស់ខ្ញុំ សូម្បីកូនប្រសាស្រីរបស់សេដ្ឋីនោះ ប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធហើយ បានតាំងសេចក្តីប្រាថ្នាថា តាំងអំពីនេះទៅ ឆាតកភ័យបែបនេះ កុំបីជួបខ្ញុំឡើយ ម្យ៉ាងទៀត

កាលខ្ញុំកាន់ល្អីស្រូវដាក់ខាងមុខ ឲ្យនូវភត្តដែលជាពូជដល់មនុស្សក្នុងជម្ពូទ្វីបទាំងមូល ការអស់ទៅ កុំបីប្រាកដ លោកទាំងពីរនោះសូមជាមាតាបិតាក្មេកបុរសនោះសូមជាប្តី បុរសនោះសូមជាទាសៈរបស់ខ្ញុំ ។ សូម្បីទាសៈរបស់សេដ្ឋីនោះ ក៏ប្រគេនចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយក៏តាំងសេចក្តីប្រាថ្នាថា តាំងអំពីនេះទៅ ខ្ញុំមិនគប្បីយល់នូវធាតុកភ័យបែបនេះឡើយ ជនទាំងអស់សូមជាចៅហ្វាយ កាលខ្ញុំភ្ជួរស្រែ គន្លង ៧ ប៉ុនទូកកំរោល គឺខាងនេះ ៣ ខាងនោះ ៣ ត្រង់កណ្តាល ១ ចូរប្រព្រឹត្តទៅ ។ បុណ្ណៈនោះ ទោះបីប្រាថ្នាតំណែងសេនាបតី ក៏អាចបានក្នុងថ្ងៃនោះឯង តែដោយអំណាចស្រឡាញ់ក្នុងម្ចាស់ទាំងឡាយ ទើបតាំងសេចក្តីប្រាថ្នាថា ជនទាំងនោះឯងសូមជាចៅហ្វាយរបស់ខ្ញុំ ។ ក្នុងទីបំផុតនៃវាចារបស់ជនទាំងអស់ ព្រះបច្ចេកពុទ្ធពោលថា ចូរសម្រេចយ៉ាងនោះចុះ ហើយធ្វើអនុមោទនាដោយគាថារបស់ព្រះបច្ចេកពុទ្ធ ហើយគិតថា អញនឹងញុំាងចិត្តរបស់ជនទាំងឡាយនេះ ឲ្យជ្រះថ្លា គួរ ទើបអធិដ្ឋានថា ចូរជនទាំងនេះ ឃើញអាត្មាអញរហូតដល់ភ្នំគន្ធមាទន៍ ដូច្នេះហើយ ក៏ចៀសចេញទៅ សូម្បីជនទាំងនោះ បានឈរមើលនោះឯង ។ ព្រះបច្ចេកពុទ្ធនោះនិមន្តទៅហើយ ចែកភត្តនោះដល់ព្រះបច្ចេកពុទ្ធ ៥០០ ដោយអានុភាពនៃព្រះបច្ចេកពុទ្ធទាំងនោះ ភត្តនោះ គ្រប់គ្រាន់ហើយដល់ព្រះបច្ចេកពុទ្ធទាំងអស់ ។ ជនទាំងនោះ បានឈរមើលនោះឯង ។

ពេលថ្ងៃត្រង់កន្លងទៅហើយ ភរិយាសេដ្ឋីលាងឆ្នាំងបាយហើយបិទទុកចំណែកសេដ្ឋី ត្រូវសេចក្តីឃ្លានគ្របសង្កត់ដេកលក់ទៅ លុះភ្ញាក់ឡើងក្នុងពេល

ល្ងាច ពោលនឹងកិរិយារបស់ខ្លួនថា នែនាង ខ្ញុំឃ្លានពន់ពេក បាយក្តាំងបាត ឆ្នាំង មានខ្លះឬហ្ន៎ កិរិយានោះសូម្បីដឹងថា ខ្លួនបានលាងឆ្នាំងហើយ ក៏មិន ពោលថា មិនមាន គិតថា អញបើកឆ្នាំងបាយហើយសឹមប្រាប់ ដូច្នេះហើយ ទើបក្រោកឡើងទៅក្បែរឆ្នាំងបាយ ហើយបើក ។

ខណៈនោះឯង ឆ្នាំងបាយពេញដោយកត្ត មានពណ៌ដូចផ្កាម្លិះក្រពុំ បាន ទុលគម្របតាំងនៅហើយ ។ កិរិយានោះឃើញកត្តហើយ ជាអ្នកមានសរីរៈ ពេញដោយបីតិ ពោលនឹងសេដ្ឋីថា សូមក្រោកឡើងចុះ ខ្ញុំលាងឆ្នាំងបាយបិទ ទុក តែឆ្នាំងនោះពេញដោយកត្ត មានពណ៌ដូចផ្កាម្លិះក្រពុំ ឈ្មោះថា បុណ្យទាំង ឡាយគួរតែធ្វើ ឈ្មោះថា ទានគួរតែឲ្យ សូមអ្នកក្រោកឡើងបរិភោគចុះ ។

កិរិយានោះ បានឲ្យកត្តដល់ឪពុក និងកូនទាំងពីរហើយ កាលឪពុក និង កូននោះបរិភោគហើយ នាងអង្គុយបរិភោគជាមួយកូនប្រសា ហើយឲ្យកត្តដល់ បុណ្ណៈ ។ ទីនៃកត្តដែលជនទាំងនោះដួសហើយ មិនអស់ទៅ ប្រាកដចំពោះ ត្រង់ទីដែលដួសមួយវែកដំបូងប៉ុណ្ណោះ ។

ក្នុងថ្ងៃនោះឯង ជង្រុកជាដើមក៏ពេញហើយដោយទំនងដែលពេញពីមុន នោះឯង នាងឲ្យធ្វើការប្រកាសក្នុងនគរថា កត្តកើតឡើងហើយក្នុងផ្ទះរបស់ សេដ្ឋី បុគ្គលត្រូវការដោយកត្តដែលជាពូជ ចូរមកទទួលយកចុះ ។ មនុស្ស ទាំងឡាយ កាន់យកកត្តដែលជាពូជអំពីផ្ទះរបស់សេដ្ឋីនោះហើយ សូម្បីមនុស្ស ក្នុងជម្ពូទ្វីបទាំងមូល ក៏អាស្រ័យសេដ្ឋីនោះ បាននូវជីវិតហើយនោះឯង ។

សេដ្ឋីនោះ ឃ្លាតចាកអត្តភាពនោះហើយ កើតក្នុងទេវលោក អន្ទោល

ក្នុងទេវលោក និងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលសេដ្ឋី ក្នុងភទ្ទិយនគរ សូម្បីភរិយារបស់គាត់ កើតក្នុងត្រកូលមានភោគៈច្រើន ចម្រើនវ័យហើយ បានទៅកាន់ផ្ទះរបស់លោកសេដ្ឋីនោះឯង ពពែទាំងឡាយ មានប្រការដូចពោលហើយ អាស្រ័យកម្មក្នុងកាលមុនរបស់សេដ្ឋី ក៏ផុសឡើងត្រង់ក្រោយផ្ទះ សូម្បីកូនប្រុស ក៏បានជាកូនប្រុសរបស់លោកនោះឯង ស្រីកូនប្រសាបានជាកូនប្រសាដូចគ្នា ទាសៈក៏បានជាទាសៈនោះឯង ។ ថ្ងៃមួយ សេដ្ឋីប្រាថ្នាដើម្បីល្បងបុណ្យរបស់ខ្លួន ទើបឲ្យមនុស្សសម្អាតជង្រុក ១២៥០ កក់សក់ហើយ អង្គុយត្រង់ទ្វារសម្លឹងមើលខាងលើ ជង្រុកទាំងអស់ ពេញហើយដោយស្រូវសាលី មានប្រការដូចពោលហើយ ។ សេដ្ឋីនោះ ប្រាថ្នានឹងសាកល្បងបុណ្យរបស់ជនដ៏សេស ទើបពោលនឹងភរិយា និងកូនប្រុសជាដើមថា អ្នកទាំងឡាយ ចូរពិសោធបុណ្យរបស់ពួកអ្នកចុះ ។ លំដាប់នោះ ភរិយារបស់សេដ្ឋីនោះ ប្រដាប់ហើយដោយគ្រឿងអលង្ការទាំងពួង កាលមហាជនកំពុងមើលនោះឯង ប្រើឲ្យមនុស្សវាល់អង្ករទាំងឡាយ ឲ្យចម្អិនបាយដោយអង្ករទាំងនោះ អង្គុយលើអាសនៈដែលគេក្រាលហើយត្រង់ខ្លោងទ្វារ កាន់វែកមាស ហើយប្រកាសថា បុគ្គលណាត្រូវការដោយភត្ត ចូរមក ហើយបានឲ្យរហូតពេញភាជនៈ ដល់ជនដែលមកហើយ ។ កាលនាងឲ្យអស់មួយថ្ងៃ ប្រាកដចំពោះត្រង់ទីដែលជួសដោយវែកប៉ុណ្ណោះ ។ បទុមលក្ខណៈ កើតត្រង់បាតដៃខាងឆ្វេង ចន្ទលក្ខណៈ កើតត្រង់បាតដៃខាងស្តាំ ព្រោះនាងចាប់ឆ្នាំងបាយដោយដៃឆ្វេង ចាប់វែកដោយដៃស្តាំ ហើយប្រគេនភត្តរហូតពេញ

បាត្រដល់ភិក្ខុសង្ឃ របស់ព្រះពុទ្ធទាំងឡាយ ក្នុងកាលមុនដោយប្រការដូច្នេះឯង ព្រោះហេតុដែលនាងកាន់យកធម្មក្រកត្រងទឹកប្រគេនដល់ភិក្ខុសង្ឃ ដើរទៅមក ដូច្នោះ ទើបចន្ទលក្ខណៈកើតត្រង់បាតជើងខាងស្តាំរបស់នាង បទុមលក្ខណៈកើតត្រង់បាតជើងខាងឆ្វេងរបស់នាង ព្រោះហេតុនេះ ទើបញាតិទាំងឡាយដាក់ឈ្មោះនាងថា ចន្ទបទុមា ។

ចំណែកកូនប្រុសរបស់សេដ្ឋីនោះ កក់សក់ហើយ កាន់យកថង់កហាបណៈមួយពាន់ពោលថា អ្នកណាត្រូវការកហាបណៈ ចូរមក ហើយឲ្យរហូតពេញភាជនៈក្នុងបណ្តាជនដែលមក កហាបណៈមួយពាន់ក៏មាននៅក្នុងថង់នោះឯង សូម្បីកូនប្រសារបស់សេដ្ឋីនោះ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កាន់យកល្អីដាក់ស្រូវហើយ អង្គុយត្រង់ទីវាលពោលថា អ្នកត្រូវការកត្តដែលជាពូជចូរមក ហើយបានឲ្យពេញភាជនៈក្នុងជនដែលមកហើយ ល្អីស្រូវក៏នៅពេញដូចដើមនោះឯង ។ សូម្បីទាសៈរបស់សេដ្ឋីនោះ ប្រដាប់ហើយដោយគ្រឿងអលង្ការទាំងពួង ទឹមគោទាំងឡាយត្រង់នឹមដែលធ្វើអំពីមាស ដោយខ្សែមាស កាន់យកដងជន្ទញមាស ឲ្យនូវគ្រឿងក្រអូបដែលបុគ្គលគប្បីប្រោះដោយម្រាមដៃទាំង ៥ ដល់គោទាំងឡាយ ដែលពាក់ចង្កឹមាសត្រង់ស្នែងទាំងឡាយ ចុះកាន់ស្រែហើយ ភ្ជួរទៅ ។ គន្លង ៣ គឺខាងឆ្វេង ៣ ខាងស្តាំ ៣ កណ្តាល ១ បានបែកទៅហើយ ។ ចំណែកអ្នកជម្ពូទ្វីប កាន់យកទ្រព្យ មានកត្ត ពូជប្រាក់ មាសជាដើម តាមដែលខ្លួនគាប់ចិត្តអំពីផ្ទះរបស់សេដ្ឋីប៉ុណ្ណោះ ។

សេដ្ឋីមានអានុភាពច្រើនយ៉ាងនោះ បានឮថា ព្រះសាស្តាយាងមកហើយ

គិតថា អញនឹងធ្វើការទទួលដំណើរព្រះសាស្តា ចេញទៅជួបពួកតិរ្ថិយក្នុងតាមផ្លូវ សូម្បីត្រូវពួកតិរ្ថិយទាំងនោះឃាត់ថា គហបតី លោកជាកិរិយវាទ ទៅកាន់សម្នាក់របស់ព្រះគោតម ដែលជាអកិរិយវាទធ្វើអ្វី ក៏មិនបានជឿពាក្យរបស់តិរ្ថិយទាំងនោះ ត្រាច់ទៅហើយ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីបំផុត នាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់អនុបុព្វីកថាដល់សេដ្ឋីនោះ ក្នុងកាលចប់ទេសនា សេដ្ឋីសម្រេចសោតាបត្តិផល ហើយក្រាបទូលភាពដែលខ្លួនត្រូវពួកតិរ្ថិយពោលទោស ហើយឃាត់ដល់ព្រះសាស្តា ។ កាលនោះ ព្រះសាស្តាត្រាស់នឹងលោកសេដ្ឋីនោះថា ម្នាលគហបតី ឈ្មោះថា សត្វទាំងនេះ មិនឃើញទោសរបស់ខ្លួនសូម្បីច្រើន រមែងឃើញទោសរបស់ជនដទៃ សូម្បីមិនមានធ្វើឲ្យមាន ដូចបុគ្គលបាចអង្កាមទៅក្នុងទីនោះៗ ដូច្នោះ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**សុទស្សំ វជ្ជមញ្ញេសំ អត្តនោ បន ទុទ្ទសំ**
**បរេសំ ហិ សោ វជ្ជានិ ឱបុណាតិ យថាភុសំ**
**អត្តនោ បន ឆាទេតិ កលឹវ កិតវា សឋោ ។**

ទោសរបស់ពួកជនដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ខ្លួន ឃើញបានដោយលំបាក ព្រោះថា បុគ្គលនោះ រោយទោសទាំងឡាយចំពោះពួកជនដទៃ ដូចបុគ្គលរោយអង្កាម ដូច្នោះ តែថា រមែងបិទបាំងទោសរបស់ខ្លួន ដូច

ព្រានបក្សី បិទបាំងអត្តភាពដោយវត្ថុសម្រាប់បិទបាំង ( មានមែកឈើជាដើម ) ដូច្នោះ ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សុទស្សំ** សេចក្តីថា ទោស គឺការភ្លាំងភ្លាត់របស់បុគ្គលដទៃ សូម្បីមានប្រមាណតិច បុគ្គលឃើញបានងាយ គឺអាចឃើញបានងាយនោះឯង ចំណែកទោសរបស់ខ្លួន សូម្បីធំក្រៃលែង បុគ្គលរមែងឃើញបានដោយលំបាក ។

បទថា **បរេសំ ហិ** សេចក្តីថា ព្រោះហេតុនោះឯង បុគ្គលនោះរមែងបាចសាចនូវទោសទាំងឡាយរបស់ជនដទៃ ទៅក្នុងកណ្តាលជំនុំសង្ឃជាដើម ដូចបុគ្គលឈរលើទីខ្ពស់ ហើយរោយនូវអង្កាម ដូច្នោះ ។

អត្តភាព ឈ្មោះថា **កលិ** ដោយអំណាចដែលប្រព្រឹត្តខុសក្នុងបក្សីទាំងឡាយ ក្នុងពាក្យថា **កលឹវ កិតវា សឋោ** នេះ ។

គ្រឿងបិទបាំង មានមែកឈើដែលល្មមកាច់បានជាដើម ឈ្មោះថា **កិតវា** ក្នុងពាក្យថា **កិតវា** នេះ ។

នាយព្រាន ឈ្មោះថា **សឋោ** ក្នុងពាក្យថា **សឋោ** នេះ អធិប្បាយថា ព្រានបក្សី បំណងនឹងចាប់បក្សីសម្លាប់ រមែងបិទបាំងអត្តភាពដោយគ្រឿងបិទបាំង យ៉ាងណា បុគ្គលរមែងបិទបាំងទោសរបស់ខ្លួនឯងក៏យ៉ាងនោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

# រឿង ព្រះឧជ្ឈានសញ្ញិត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈមួយរូបឈ្មោះឧជ្ឈានសញ្ញី ត្រាស់ព្រះធម្មទេសនានេះថា **បរវជ្ជានុបស្សិស្ស** ជាដើម ។

បានឮថា ព្រះថេរៈនោះដើររំពៃតែទោស របស់ភិក្ខុទាំងឡាយប៉ុណ្ណោះថា ភិក្ខុនេះរមែងស្លៀកយ៉ាងនេះ ភិក្ខុនេះរមែងដណ្តប់យ៉ាងនេះ ពួកភិក្ខុក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះថេរៈឈ្មោះនោះរមែងធ្វើយ៉ាងនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុតាំងនៅក្នុងកតិកា ពោលប្រៀនប្រដៅយ៉ាងនេះ បុគ្គលមិនគួរតិះដៀល ចំណែកភិក្ខុណាស្វែងរកទោសរបស់អ្នកដទៃ ព្រោះបំណងនឹងលើកទោស ពោលយ៉ាងនេះហើយត្រាច់ទៅ បណ្តាគុណវិសេសមានឈានជាដើម គុណវិសេសណាមួយ រមែងមិនកើតឡើងដល់ភិក្ខុនោះ អាសវៈទាំងឡាយប៉ុណ្ណោះ តែងចម្រើនតែម្យ៉ាង ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**បរវជ្ជានុបស្សិស្ស  និច្ចំ ឧជ្ឈានសញ្ញិនោ**
**អាសវា តស្ស វឌ្ឍន្តិ  អារា សោ អាសវក្ខយា ។**

កាលបុគ្គល គយយ៉ាំមើលទោសរបស់បុគ្គលដទៃជាប្រក្រតី មានការសម្គាល់ហេតុ ក្នុងការពោលទោស ( អ្នកដទៃ ) ជានិច្ចជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះ តែងចម្រើន បុគ្គលនោះ ឈ្មោះថា ស្ថិតនៅឆ្ងាយអំពីធម៌ ជាគ្រឿងអស់អាសវៈ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **ឧជ្ឈានសញ្ញិនោ** សេចក្ដីថា បណ្ដាធម៌ទាំងឡាយ មានឈានជាដើម ធម៌ណាមួយរមែងមិនចម្រើនដល់បុគ្គលដែលឈ្មោះថា ច្រើនទៅដោយការលើកទោស ព្រោះភាពជាបុគ្គលគន់រំពៃទោសរបស់អ្នកដទៃថា គួរស្លៀកយ៉ាងនេះ គួរដណ្ដប់យ៉ាងនេះជាដើម ។ ដោយពិត អាសវៈទាំងឡាយរមែងចម្រើន ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា ជាអ្នកនៅឆ្ងាយ គឺឆ្ងាយក្រៃលែងអំពីការអស់ទៅនៃអាសវៈ ពោលគឺអរហត្ត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង ព្រះឧជ្ឈានសញ្ញិត្ថេរ ចប់**

# រឿង សុភទ្ទបរិព្វាជក

## លំនាំដើម

ព្រះសាស្ដាផ្ទំហើយ លើព្រះទែនដែលជាទីបរិនិព្វាន ក្នុងសាលវ័នរបស់មល្លក្សត្រទាំងឡាយ ដែលជាទីសម្រាកក្បែរនគរកុសិនារា ទ្រង់ប្រារព្ធបរិព្វាជកឈ្មោះសុភទ្ទ ត្រាស់ព្រះធម្មទេសនានេះថា **អាកាសេវ បទំ នត្ថិ** ជាដើម ។

បានឮថា ក្នុងអតីតកាល សុភទ្ទបរិព្វាជកនោះ កាលប្អូនប្រុសឲ្យទានដ៏ប្រសើរដល់ទៅ ៩ ដង ក្នុងសម្ទូងមួយរដូវ មិនប្រាថ្នានឹងឲ្យ រួញរាហើយ

បានឲ្យក្នុងកាលជាទីបំផុត ។

ព្រោះដូច្នោះ ទើបមិនបានគាល់ព្រះសាស្ដា ទាំងនៅក្នុងបឋមពោធិកាល ទាំងក្នុងមជ្ឈិមពោធិកាល តែក្នុងបច្ឆិមពោធិកាល ក្នុងកាលដែលបរិនិព្វានរបស់ព្រះសាស្ដា គិតថា អញសួរសេចក្ដីសង្ស័យរបស់ខ្លួនក្នុង ៣ បញ្ហានឹងបរិព្វាជកទាំងឡាយដែលជាមនុស្សចាស់ មិនសួរនឹងព្រះសមណគោតម ដោយសម្គាល់ថាជាក្មេង ឥឡូវនេះ ជាកាលបរិនិព្វានរបស់ព្រះសមណគោតមនោះ វិប្បដិសារីគប្បីកើតដល់អញ ក្នុងកាលជាក្រោយ ព្រោះហេតុមិនសាកសួរព្រះសមណ-គោតម ហើយចូលទៅគាល់ព្រះសាស្ដា សូម្បីត្រូវព្រះអានន្ទត្ថេរឃាត់ ចូលទៅខាងក្នុងវាំងនន ព្រោះភាពដែលព្រះសាស្ដាទ្រង់ឲ្យឱកាសហើយ ត្រាស់ថាអានន្ទ អ្នកកុំឃាត់សុភទ្ទៈឡើយ ចូរសុភទ្ទសួរបញ្ហាជាមួយតថាគត ទើបអង្គុយក្បែរគ្រែ ទូលសួរបញ្ហាទាំងនេះថា បពិត្រព្រះសមណៈ ឈ្មោះថា ស្នាមជើងក្នុងអាកាសមានឬហ្ន៎ ឈ្មោះថា សមណៈខាងក្រៅសាសនានេះមានឬ សង្ខារទាំងឡាយ ឈ្មោះថា ទៀង មានឬ ។

លំដាប់នោះ ព្រះសាស្ដាកាលត្រាស់ប្រាប់ការមិនមាននៃស្នាមជើងក្នុងអាកាសជាដើមដល់សុភទ្ទៈ ទើបទ្រង់សម្ដែងធម៌ដោយព្រះគាថានេះថា

**អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរោ**
**បបញ្ចាភិរតា បជា និប្បបញ្ចា តថាគតា**
**អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរោ**
**សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធានមិញ្ជិតំ ។**

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន
ពួកសត្វត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ ព្រះ
តថាគតទាំងឡាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ ។
ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន
សង្ខារទាំងឡាយ ជារបស់ទៀង មិនមាន ព្រះពុទ្ធទាំងឡាយ
មិនមានកិលេសជាគ្រឿងញាប់ញ័រទេ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បទំ** សេចក្តីថា ឈ្មោះថា ស្នាមជើងនៃសត្វណាមួយ ដែលបុគ្គលគប្បីបញ្ញត្តថា មានរូបយ៉ាងនេះ ដោយអំណាចនៃពណ៌ និងសណ្ឋាន ក្នុងអាកាសនេះ មិនមាន ។

បទថា **ពាហិរោ** សេចក្តីថា ឈ្មោះថា សមណៈដែលតាំងនៅក្នុងមគ្គ និងផល ខាងក្រៅសាសនារបស់តថាគត មិនមាន ។

បទថា **បជា** សេចក្តីថា ពួកសត្វ ពោល គឺសត្វលោកត្រេកអរក្រៃលែងហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ មានតណ្ហាជាដើមប៉ុណ្ណោះ ។

បទថា **និប្បបញ្ចា** សេចក្តីថា ចំណែកព្រះតថាគតទាំងឡាយជាបុគ្គលឈ្មោះថា មិនមានធម៌ជាគ្រឿងយឺតយូរ ព្រោះភាពដែលទ្រង់កាត់នូវធម៌ជាគ្រឿងយឺតយូរទាំងពួងជាសមុច្ឆេទហើយ ត្រង់មណ្ឌលពោធិព្រឹក្សនោះឯង ។

ខន្ធ ៥ ឈ្មោះថា សង្ខារ ក្នុងខន្ធទាំង ៥ នោះ ខន្ធឯណានីមួយឈ្មោះថា ទៀង មិនមាន ។

បទថា **ឥញ្ជិតំ** សេចក្តីថា ជនទាំងឡាយគប្បីកាន់យកថា សង្ខារទាំងឡាយជាសភាពទៀង ដោយបណ្តាកិលេសជាត គ្រឿងញាប់ញ័រ គឺតណ្ហា មានះ និងទិដ្ឋិឯណា សូម្បីកិលេសជាតជាគ្រឿងញាប់ញ័រនោះណាមួយ ក៏មិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ក្នុងកាលចប់ទេសនា សុភទ្ទបរិព្វាជក តាំងនៅហើយក្នុងអនាគាមិផល ព្រះធម្មទេសនាមានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយដូច្នេះឯង ៕

**រឿងសុភទ្ទបរិព្វាជក ចប់**

**មលវគ្គ ចប់**

**វគ្គទី ១៨ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា ធម្មដ្ឋវគ្គទី ១៩

[ ២៩ ] បុគ្គលកាត់សេចក្តីដោយអាក្រក់ ដោយហេតុណា ឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាត់សេចក្តីទាំង ២ គឺសេចក្តីពិត និងសេចក្តីមិនពិត ណែនាំជនទាំងឡាយដទៃ ដោយមិនអាក្រក់ ដោយសារធម៌តាមសមគួរ ( ដល់ទោស ) បុគ្គលនោះ ឈ្មោះថា ជាអ្នកមានប្រាជ្ញារក្សាធម៌ ទើបហៅថា តាំងនៅក្នុងធម៌ ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុនណា ឈ្មោះថា ជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលដែលមានសេចក្តីក្សេម មិនមានពៀរ មិនមានភ័យ ទើបហៅថា បណ្ឌិតបាន ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុនណា ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ស្តាប់ពុទ្ធវចនៈ សូម្បីមានប្រមាណតិច ហើយឃើញធម៌ដោយនាមកាយ គឺចិត្តបាន បុគ្គលនោះ ទើបឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ បុគ្គលណា មិនមើលងាយធម៌ បុគ្គលនោះឯង ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ។

បុគ្គលមានក្បាលស្កូវហើយ ដោយហេតុណា ឈ្មោះថា ជាថេរៈដោយនោះ មិនទាន់បានទេ វ័យរបស់បុគ្គលនោះចាស់ជ្រុលហើយ ហៅថា ចាស់ជាមោឃៈ ។ លុះត្រាតែសច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការ

សង្រួមផង ការទូន្មានខ្លួនផង មានក្នុងបុគ្គលណា បុគ្គលនោះឯង ជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ថេរៈ ។

បុគ្គលមានសេចក្តីឫស្យា មានសេចក្តីកំណាញ់ ជាអ្នកអួតអាង ឈ្មោះថា ជាមនុស្សល្អ ដោយហេតុត្រឹមតែធ្វើការនិយាយពាក្យ ( ល្អ ) ឬដោយភាពជាអ្នកមានសម្បុរជាទីគាប់ចិត្ត ក៏មិនទាន់បានទេ ។

លុះត្រាតែទោសជាត មានឫស្យាជាដើមនេះ បុគ្គលណាបានផ្តាច់ផ្តិលដកឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះជាអ្នកមានទោសខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ជាមនុស្សល្អបាន ។ បុគ្គលមិនបានឈ្មោះថា ជាសមណៈ ដោយភាពជាអ្នកមានក្បាលត្រងោលទេ បុគ្គលអ្នកមិនមានសីលវត្ត និងធុតង្គវត្ត ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្តីប្រាថ្នា និងលោភៈ ឈ្មោះថា ជាសមណៈដូចម្តេចបាន ។ លុះត្រាតែបុគ្គលណា រម្ងាប់បាបទាំងឡាយ ទាំងតូច ទាំងធំ ដោយប្រការទាំងពួងបាន ទើបហៅថា សមណៈ ព្រោះបាបទាំងឡាយ ដែលបុគ្គលនោះរម្ងាប់បានហើយ ។

បុគ្គលណា ដើរសូមជនទាំងឡាយដទៃ ដោយហេតុត្រឹមណា បុគ្គលនោះ មិនបានឈ្មោះថា ជាភិក្ខុ ដោយហេតុត្រឹមនោះទេ បុគ្គលសមាទានធម៌ជាពិស ឈ្មោះថា ជាភិក្ខុ ដោយហេតុត្រឹមតែការដើរសូមប៉ុណ្ណោះ មិនទាន់បានទេ ។ លុះត្រាតែបុគ្គលណា ក្នុងលោក បន្សាត់បុណ្យ និងបាបចេញហើយ ជាអ្នកមានការប្រព្រឹត្តដ៏ប្រសើរ ត្រាច់ទៅក្នុងលោក ដោយសេចក្តី

ចេះដឹង បុគ្គលនោះឯង ទើបហៅថា ជាភិក្ខុ ។

បុគ្គលមានសេចក្ដីវង្វេង ជាធម្មតា មិនមានការចេះដឹង មិនបានឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ វៀរចាកបាបទាំងឡាយ ដូចបុគ្គលកាន់ជញ្ជីង ហើយថ្លឹង ដូច្នោះ បុគ្គលនោះ ទើបឈ្មោះថា ជាមុនី ដោយភាពជាអ្នកស្ងៀមនោះបាន បុគ្គលណា ដឹងប្រយោជន៍ទាំង ២ ក្នុងលោក បុគ្គលនោះ ហៅថា មុនី ដោយហេតុនោះ ។

បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបានឈ្មោះថា ជាអរិយៈ ដោយហេតុនោះទេ បុគ្គលដែលតថាគតហៅថា អរិយៈ ព្រោះមិនបៀតបៀនសត្វទាំងពួង ។

ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំអាលទុកចិត្ត ដោយគុណត្រឹមតែសីល និងវត្ត ឬដោយភាពជាអ្នកចេះដឹងច្រើនឡើយ មួយទៀត ដោយការបានសមាធិ ឬដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណ មានប្រមាណប៉ុណ្ណេះថា អាត្មាអញពាល់ត្រូវនេក្ខម្មសុខ ដែលបុថុជ្ជន មិនដែលជួបប្រសព្វ ដូច្នេះឡើយ ។

**ធម្មដ្ឋវគ្គទី ១៩ ចប់**

# អដ្ឋកថា

# ធម្មដ្ឋវគ្គទី ១៩

## រឿង មហាមាត្យអ្នកវិនិច្ឆ័យក្តី

### លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាមាត្យអ្នកវិនិច្ឆ័យ ត្រាស់ព្រះធម្មទេសនានេះថា* **ន តេន ហោតិ ធម្មដ្ឋោ** *ជាដើម ។*

*សេចក្តីពិស្តារ ថ្ងៃមួយ ពួកភិក្ខុត្រាច់បិណ្ឌបាតក្នុងស្រុកក្បែរទ្វារទិសឧត្តរនៃនគរសាវត្ថី ត្រឡប់អំពីបិណ្ឌបាតហើយ មកកាន់វិហារកាត់តាមត្រង់កណ្តាលព្រះនគរ ខណៈនោះ ពពកខ្មៅធំតាំងឡើង ញុំាងភ្លៀងឲ្យធ្លាក់ហើយ ។ ភិក្ខុទាំងនោះ ចូលទៅកាន់សាលាសម្រាប់វិនិច្ឆ័យក្តី ដែលតាំងនៅចំពោះមុខ ឃើញពួកមហាមាត្យ ដែលវិនិច្ឆ័យទទួលសំណូកហើយ ធ្វើម្ចាស់ទ្រព្យមិនឲ្យជាម្ចាស់ទ្រព្យ ទើបគិតថា ឱ ! អមាត្យទាំងនេះមិនតាំងនៅក្នុងធម៌ តែពួកយើងមានសេចក្តីសម្គាល់ថា មហាមាត្យទាំងនេះធ្វើការវិនិច្ឆ័យដោយធម៌ កាលភ្លៀងរាំងហើយ មកដល់វិហារ ថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងទីបំផុត នាចំណែកម្ខាងហើយ ក្រាបទូលសេចក្តីនោះ ។*

*ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអមាត្យអ្នកវិនិច្ឆ័យ ជាអ្នកធ្លាក់នៅក្នុងអំណាចអគតិ មានឆន្ទាគតិជាដើម សម្រេចសេចក្តីដោយ*

វួសរាន់ មិនឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ចំណែកពួកដែលសាកសួរនូវកំហុសហើយ កាត់ក្តី ដោយភាពល្អិតល្អន់តាមសមគួរដល់កំហុសនោះឯង ជាបុគ្គលឈ្មោះថាតាំងនៅក្នុងធម៌ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

**ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ**
**យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ ។**
**អសាហសេន ធម្មេន សមេន នយតី បរេ**
**ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។**

បុគ្គលកាត់សេចក្តីដោយអាក្រក់ ដោយសារហេតុណា ឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិត កាត់សេចក្តីទាំងពីរ គឺសេចក្តីពិត និងសេចក្តីមិនពិត ណែនាំជនទាំងឡាយដទៃ ដោយមិនអាក្រក់ ដោយសារធម៌តាមសមគួរ ( ដល់ទោស ) បុគ្គលនោះ ឈ្មោះថា ជាអ្នកមានប្រាជ្ញារក្សាធម៌ ទើបហៅថា អ្នកតាំងនៅក្នុងធម៌ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **តេន** ប្រែថា ព្រោះហេតុត្រឹមតែប៉ុណ្ណោះឯង ។ បទថា **ធម្មដ្ឋោ** សេចក្តីថា បុគ្គលតាំងនៅក្នុងធម៌ ជាគ្រឿងវិនិច្ឆ័យដែលស្តេចផែនដីទាំងឡាយគប្បីធ្វើដោយព្រះអង្គ មិនជាបុគ្គល ឈ្មោះថា

តាំងនៅក្នុងធម៌ឡើយ ។ បទថា **យេន** ប្រែថា ព្រោះហេតុណា ។

បទថា **អត្ថំ** សេចក្ដីថា នូវក្ដីដែលឈមចុះហើយ ដែលគួរសម្រេច ។

ពីរបទថា **សហសា នយេ** សេចក្ដីថា បុគ្គលតាំងនៅក្នុងអគតិ មានឆន្ទាគតិជាដើម សម្រេចក្ដីដោយប្រញាប់ប្រញាល់ គឺដោយពោលកុហក ។ អធិប្បាយថា ពិតហើយ បុគ្គលណា តាំងនៅក្នុងការពេញចិត្ត ពោលមុសាវាទ រមែងធ្វើញាតិ ឬមិត្ររបស់ខ្លួន ដែលមិនមែនម្ចាស់ទ្រព្យនោះឯងឲ្យជាម្ចាស់ទ្រព្យ តាំងនៅក្នុងការប្រឹងប្រែងពោលកុហក រមែងធ្វើបុគ្គលដែលជាសត្រូវរបស់ខ្លួនដែលជាម្ចាស់របស់ មិនឲ្យជាម្ចាស់របស់ តាំងនៅក្នុងសេចក្ដីវង្វេង ទទួលសំណូកហើយ ក្នុងកាលកាត់សេចក្ដី ធ្វើហាក់ដូចជាបញ្ជូនចិត្តទៅក្នុងទីដទៃ សម្លឹងមើលខាងនោះខាងនេះ ពោលកុហក តែងនាំបុគ្គលដទៃចេញដោយពាក្យថា បុគ្គលនេះ ឈ្នះ បុគ្គលនេះ ចាញ់ តាំងនៅក្នុងការខ្លាច រមែងលើកនូវការឈ្នះឲ្យបុគ្គលជាធំ បុគ្គលខ្លះនោះឯងឲ្យដល់នូវការចាញ់ បុគ្គលនេះ ឈ្មោះថា នាំក្ដីទៅដោយប្រញាប់ប្រញាល់ បុគ្គលនោះ មិនឈ្មោះថា តាំងនៅក្នុងធម៌ ។

បាទព្រះគាថាថា **យោ ច អត្ថំ អនត្ថញ្ច** សេចក្ដីថា នូវហេតុដែលពិត និងមិនពិត ។ ពីរបទថា **ឧភោ និច្ឆេយ្យ** សេចក្ដីថា ចំណែកបុគ្គលណា ជាបណ្ឌិត វិនិច្ឆ័យហេតុដែលជាក្ដី និងមិនមែនជាក្ដីទាំងពីរហើយ រមែងពោល ។

បទថា **អសាហសេន** គឺ ដោយមិនពោលកុហក ។ បទថា **ធម្មេន** ប្រែថា ដោយធម៌ជាគ្រឿងវិនិច្ឆ័យ គឺមិនប្រើដោយអំណាចអគតិ មានឆន្ទាគតិ

ជាដើមឡើយ ។ បទថា **សមេន** គឺរមែងនាំបុគ្គលពួកដទៃទៅ គឺឲ្យដល់នូវការឈ្នះ ឬការចាញ់ ដោយសមគួរដល់កំហុសនោះឯង ។

ពីរបទថា **ធម្មស្ស គុត្តោ** សេចក្ដីថា បុគ្គលនោះ ដែលធម៌រក្សាគ្រប់គ្រងហើយ គឺដែលធម៌រក្សាហើយ ប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ឈ្មោះជាមានបញ្ញា ព្រះដ៏មានព្រះភាគត្រាស់ថា បុគ្គលតាំងនៅក្នុងធម៌ ព្រោះជាអ្នកតាំងនៅក្នុងធម៌ជាគ្រឿងវិនិច្ឆ័យ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៙

**រឿង មហាមាត្យអ្នកវិនិច្ឆ័យក្ដី ចប់**

## រឿង ឆព្វគ្គិយភិក្ខុ

### លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា **ន តេន បណ្ឌិតោ ហោតិ** ជាដើម ។

បានឮថា ភិក្ខុទាំងនោះ ធ្វើរោងភត្តឲ្យកខ្វក់ក្នុងវត្តខ្លះ ក្នុងស្រុកខ្លះ ។ សម័យមួយ ភិក្ខុទាំងឡាយសួរភិក្ខុកំលោះ និងសាមណេរដែលធ្វើភត្តកិច្ចក្នុងស្រុកហើយមកថា អាវុសោ រោងភត្តដូចម្ដេច ភិក្ខុកំលោះ និងសាមណេរឆ្លើយថា បពិត្រលោកម្ចាស់ កុំសួរឡើយ ពួកឆព្វគ្គិយភិក្ខុពោលថា ពួកយើងជា

អ្នកឈ្លោស ពួកយើងជាបណ្ឌិត នឹងប្រហារភិក្ខុទាំងនេះ រោយសំរាមត្រង់សីសៈ ហើយនាំចេញទៅ ហើយចាប់ខ្នងពួកខ្ញុំរោយសំរាម ក្នុងរោងភត្តឲ្យកខ្វក់ ។ ភិក្ខុទាំងឡាយ ទៅកាន់សម្នាក់ព្រះសាស្តាហើយ ក្រាបទូលរឿងនោះ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនហៅបុគ្គលដែលច្រើនដោយការបៀតបៀនថាជាបណ្ឌិតឡើយ តែតថាគតហៅបុគ្គលដែលមានការក្សេម មិនមានពៀរ មិនមានភ័យថា ជាបណ្ឌិត ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ន តេន បណ្ឌិតោ ហោតិ　　យាវតា ពហុ ភាសតិ**
**ខេមី អវេរី អភយោ　　បណ្ឌិតោតិ បវុច្ចតិ ។**

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុន្មាន
ឈ្មោះថា ជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុណ្ណោះ
មិនទាន់បានទេ លុះត្រាតែបុគ្គលដែលមានសេចក្តីក្សេម
មិនមានពៀរ មិនមានភ័យ ទើបហៅថា បណ្ឌិតបាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យាវតា** ជាដើម សេចក្តីថា បុគ្គលមិនឈ្មោះថា ជាបណ្ឌិត ព្រោះហេតុដែលនិយាយច្រើនក្នុងជំនុំសង្ឃជាដើមឡើយ ចំណែកបុគ្គលណា ខ្លួនឯងជាបុគ្គលមានសេចក្តីក្សេម ឈ្មោះថា មិនមានពៀរ ព្រោះពៀរ ៥ មិនមាន ជាអ្នកមិនមានភ័យ គឺភ័យរមែងមិនមានដល់មហាជន ព្រោះអាស្រ័យបុគ្គលនោះ បុគ្គលនោះ ឈ្មោះថា ជាបណ្ឌិត

ដូច្នេះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៙

# រឿង ឆព្វគ្គិយភិក្ខុ

# រឿង ព្រះឯកុទានត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះខីណាស្រព ឈ្មោះឯកុទានត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ន តាវតា ធម្មធរោ** ជាដើម ។

បានឮថា ព្រះថេរៈនោះនៅក្នុងដងព្រៃមួយកន្លែង តែមួយអង្គឯង ឧទានតែមួយ ១ ប៉ុណ្ណោះថា

សេចក្តីសោកទាំងឡាយ រមែងមិនមានដល់បុគ្គលដែលមាន
ចិត្តមាំទាំ មិនប្រមាទ ជាមុនី សិក្សាក្នុងផ្លូវនៃមោនបដិបត្តិ ជា
អ្នកមិនញាប់ញ័រ ស្ងប់រម្ងាប់ហើយ មានសតិសព្វកាល ។

បានឮថា ក្នុងថ្ងៃឧបោសថ លោកប្រកាសការស្តាប់ធម៌ រមែងពោលគាថានេះ ។ សំឡេងទេវតាសាធុការ ដូចសំឡេងផែនដីស្រុត ។ ឧបោសថថ្ងៃមួយ ភិក្ខុទ្រទ្រង់បិដក ២ រូប មានបរិវារមួយរូប ៥០០ បានទៅលំនៅរបស់លោក គ្រាន់តែឃើញភិក្ខុនោះប៉ុណ្ណោះ ក៏មានចិត្តត្រេកអរ ពោលថា

លោកម្ចាស់ទាំងឡាយ និមន្តមកទីនេះជាការល្អហើយ ថ្ងៃនេះ ពួកខ្ញុំនឹងស្តាប់ធម៌ក្នុងសម្នាក់របស់លោកម្ចាស់ទាំងឡាយ ។ ពួកភិក្ខុពោលថា អាវុសោ មនុស្សស្តាប់ធម៌ក្នុងទីនេះ មានឬ ព្រះឯកុទានពោលថា មាន លោកម្ចាស់ ដងព្រៃនេះ មានសំឡេងទេវតាឲ្យសាធុការរំពងព្រៃ ក្នុងថ្ងៃស្តាប់ធម៌ ។

បណ្តាភិក្ខុ ២ រូបនោះ ព្រះថេរៈទ្រទ្រង់ព្រះត្រៃបិដក មួយអង្គសូធ្យធម៌ មួយអង្គពោលធម៌ ទេវតាមួយអង្គក៏មិនបានឲ្យសាធុការ ទើបភិក្ខុទាំងនោះពោលថា អាវុសោ លោកពោលថា ក្នុងថ្ងៃស្តាប់ធម៌ពួកទេវតាក្នុងដងព្រៃនេះ តែងឲ្យសាធុការដោយសំឡេងខ្លាំង ចុះថ្ងៃនេះដូចម្តេច ព្រះឯកុទានពោលថា ក្នុងថ្ងៃដទៃៗ យ៉ាងនោះ តែថ្ងៃនេះ ខ្ញុំមិនដឹងថា មានរឿងអ្វីឡើយ ពួកភិក្ខុពោលថា អាវុសោ បើយ៉ាងនោះ ចូរលោកពោលធម៌ចុះ ។

ព្រះថេរៈចាប់ផ្ចិតវាលវីជនី អង្គុយលើអាសនៈហើយ ពោលគាថានោះឯង ទេវតាទាំងឡាយបានឲ្យសាធុការដោយសំឡេងខ្លាំង ។ គ្រានោះ ភិក្ខុដែលជាបរិវារព្រះថេរៈទាំងពីរលើកទោសថា ទេវតាក្នុងព្រៃនេះ ឲ្យសាធុការដោយយល់មុខ កាលភិក្ខុទ្រទ្រង់បិដកពោលប្រមាណប៉ុណ្ណេះ ក៏មិនពោលត្រឹមតែការសរសើរ កាលព្រះថេរៈមួយអង្គពោលគាថាមួយហើយ នាំគ្នាឲ្យសាធុការដោយសំឡេងដ៏ខ្លាំង ។ ភិក្ខុទាំងនោះទៅដល់វិហារហើយ ក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនហៅអ្នករៀនច្រើន ឬនិយាយច្រើនថាជាអ្នកទ្រទ្រង់ធម៌ ចំណែកបុគ្គលណា រៀនគាថាសូម្បីតែ

មួយ ហើយចាក់ធ្លុះនូវសច្ចៈទាំងឡាយ បុគ្គលនោះឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ន តាវតា ធម្មធរោ យាវតា ពហុ ភាសតិ**
**យោ ច អប្បម្បិ សុត្វាន ធម្មំ កាយេន បស្សតិ**
**ស វេ ធម្មធរោ ហោតិ យោ ធម្មំ នប្បមជ្ជតិ ។**

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុនណា ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ស្តាប់ពុទ្ធវចនៈ សូម្បីមានប្រមាណតិច ហើយឃើញធម៌ដោយនាមកាយ គឺចិត្តបាន បុគ្គលនោះ ទើបឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ បុគ្គលណា មិនមើលងាយធម៌ បុគ្គលនោះឯង ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យាវតា** ជាដើម សេចក្តីថា បុគ្គលមិនឈ្មោះថា ទ្រទ្រង់ធម៌ ព្រោះហេតុដែលពោលច្រើន ដោយហេតុមានការរៀននិងការទ្រទ្រង់ចាំ និងប្រាប់ជាដើម តែឈ្មោះថាតាមរក្សាវង្សរក្សាប្រពៃណី ។

បទថា **អប្បម្បិ** ជាដើម សេចក្តីថា ចំណែកបុគ្គលណាស្តាប់ធម៌មានប្រមាណតិច អាស្រ័យធម្ម អាស្រ័យអត្ថ ជាអ្នកបដិបត្តិធម៌សមគួរដល់ធម៌កំណត់ដឹងសច្ចៈ មានទុក្ខជាដើម ឈ្មោះថា រមែងឃើញសច្ចធម៌ ៤ ដោយនាមកាយ បុគ្គលនោះឯង ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ។

បាទព្រះគាថាថា **យោ ធម្មំ ឆព្បមដ្ឋតិ** សេចក្តីថា បុគ្គលណាជាអ្នកមានសេចក្តីព្យាយាមប្រារព្ធហើយ ទន្ទឹងនូវការចាក់ធ្លុះថា អញនឹងចាក់ធ្លុះក្នុងថ្ងៃនេះឯង ឈ្មោះថា រមែងមិនប្រមាទក្នុងធម៌ បុគ្គលនេះ ឈ្មោះថា ទ្រទ្រង់នូវធម៌ដូចគ្នា ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

រឿង ព្រះឯកុទានត្ថេរ ចប់

# រឿង ព្រះលកុណ្ឌកភទ្ទិយត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលកុណ្ឌក-កទ្ទិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ន តេន ថេរោ ហោតិ** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ កាលព្រះថេរៈនោះទៅកាន់ទីបម្រើព្រះសាស្តា លុះចៀសចេញទៅហើយ ភិក្ខុនៅព្រៃប្រមាណ ៣០ រូប ក៏ឃើញលោក រួចមកថ្វាយបង្គំព្រះសាស្តា ហើយអង្គុយ ។ ព្រះសាស្តាទ្រង់ទតឃើញឧបនិស្ស័យអរហត្តរបស់ភិក្ខុទាំងនោះហើយ ត្រាស់សួរបញ្ហានេះថា ព្រះថេរៈមួយអង្គចេញអំពីទីនេះ តើពួកអ្នកឃើញដែរឬទេ ពួកភិក្ខុទូលថា បពិត្រព្រះអង្គ មិនឃើញទេ ព្រះសាស្តាត្រាស់ថា ពួកអ្នកឃើញព្រះថេរៈនោះមិនមែនឬ ពួកភិក្ខុ

ក្រាបទូលថា បពិត្រព្រះអង្គ ឃើញសាមណេរមួយរូប ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នុ៎ះមិនមែនសាមណេរទេ នុ៎ះជាព្រះថេរៈ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ព្រះថេរៈនោះតូចពេក ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនហៅថា ថេរៈ ព្រោះភាពជាបុគ្គលចាស់ ព្រោះហេតុគ្រាន់តែអង្គុយលើអាសនៈនៃថេរៈទេ ឯបុគ្គលណា ចាក់ធ្លុះនូវសច្ចៈទាំងឡាយ ហើយតាំងនៅក្នុងភាពជាបុគ្គលមិនបៀតបៀនមហាជន បុគ្គលនេះ ឈ្មោះថា ព្រះថេរៈ ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា

**ន តេន ថេរោ ហោតិ យេនស្ស បលិតំសិរោ**
**បរិបក្កោ វយោ តស្ស មោឃជិណ្ណោតិ វុច្ចតិ ។**
**យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សញ្ញមោ ទមោ**
**ស វេ វន្តមលោ ធីរោ សោ ថេរោតិ បវុច្ចតិ ។**

បុគ្គលមានក្បាលស្កូវហើយ ដោយហេតុណា ឈ្មោះថា ជាថេរៈ ដោយហេតុនោះមិនទាន់បានទេ វ័យរបស់បុគ្គលនោះចាស់ជ្រុលហើយ ហៅថា ចាស់ជាមោឃៈ ។ លុះត្រាតែសច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការសង្រួមផង ការទូន្មានខ្លួនផង មានក្នុងបុគ្គលណា បុគ្គលនោះឯង ជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ថេរៈ ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បរិបក្កោ** សេចក្តីថា ដែលជរាបង្អោនទៅជុំវិញហើយ គឺដល់នូវភាពជាបុគ្គលចាស់ហើយ ។ បទថា **មោឃជិណ្ណោ** សេចក្តីថា ឈ្មោះថា ចាស់ទទេ ព្រោះខាងក្នុងមិនមានធម៌ ជាគ្រឿងធ្វើឲ្យជាថេរៈ ។ បទថា **សច្ចញ្ច** សេចក្តីថា បុគ្គលណាមានសច្ចៈទាំង ៤ ព្រោះភាពជាអ្នកចាក់ធ្លុះដោយអាការ ១៦ និងមានលោកុត្តរធម៌ ៩ យ៉ាង ព្រោះភាពជាបុគ្គលធ្វើឲ្យជាក់ច្បាស់ដោយញាណ ។

ពាក្យថា **អហឹសា** នោះ គ្រាន់តែជាមាតិកានៃទេសនា អធិប្បាយថា អប្បមញ្ញាភាវនា ៤ យ៉ាង មានក្នុងបុគ្គលណា ។ ពីរបទថា **សញ្ញមោ ទមោ** បានដល់ សីល និងឥន្ទ្រិយសំវរៈ ។ បទថា **វន្តមលោ** គឺមានមន្ទិលដែលនាំចេញហើយដោយមគ្គញាណ ។ បទថា **ធីរោ** គឺសម្បូរដោយបញ្ញាជាគ្រឿងទ្រទ្រង់ចាំ ។ បទថា **ថេរោ** សេចក្តីថា បុគ្គលនោះ ព្រះមានព្រះភាគត្រាស់ថា ថេរៈ ព្រោះជាអ្នកប្រកបដោយធម៌ ជាគ្រឿងធ្វើនូវភាពមាំទាំទាំងនេះ ។

ចប់ទេសនា ភិក្ខុទាំងនោះ តាំងនៅក្នុងអរហត្តហើយដូច្នេះ ៕

**រឿងព្រះលកុណ្ឌកភទ្ទិយត្ថេរ ចប់**

# រឿង ភិក្ខុច្រើនរូប

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **ន វាក្ករណមត្តេន** ជាដើម ។

សេចក្ដីពិស្ដារ សម័យមួយ ព្រះថេរៈពួកខ្លះ ឃើញភិក្ខុកំលោះ និងសាមណេរធ្វើការបម្រើទាំងឡាយ មានជ្រលក់ចីវរដល់អាចារ្យជាដើម ដែលប្រាប់ធម៌របស់ខ្លួននោះឯង គិតថា សូម្បីអញក៏ឈ្លាសក្នុងលទ្ធិព្យញ្ជនៈ ផលណាមួយមិនមានដល់អញឡើយ បើដូច្នោះ អញគប្បីចូលគាល់ព្រះសាស្ដា ទូលយ៉ាងនេះថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គជាអ្នកឈ្លាសក្នុងលទ្ធិព្យញ្ជនៈ សូមទ្រង់ប្រាប់ភិក្ខុកំលោះ និងសាមណេរទាំងឡាយថា ចូរពួកអ្នករៀនធម៌ក្នុងសម្នាក់របស់អាចារ្យដទៃហើយ បើមិនទាន់សាកសួរក្នុងសម្នាក់របស់ភិក្ខុទាំងនេះហើយកុំស្វាធ្យាយ លាភសក្ការៈនឹងចម្រើនដល់អ្នកទាំងឡាយដោយអាការយ៉ាងនេះឯង ព្រះថេរៈទាំងនោះ ចូលទៅគាល់ព្រះសាស្ដាហើយ ក្រាបទូលយ៉ាងនោះ ។ ព្រះសាស្ដាទ្រង់ស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ទ្រង់ជ្រាបថា បុគ្គលណាម្នាក់ពោលយ៉ាងនោះបាន ដោយអំណាចប្រពៃណីក្នុងសាសនានេះប៉ុណ្ណោះ តែភិក្ខុទាំងនេះអាស្រ័យលាភសក្ការៈ ទើបត្រាស់ថា តថាគតមិនហៅពួកអ្នកថាជាបុគ្គលល្អ ព្រោះហេតុត្រឹមតែនិយាយ ចំណែកបុគ្គលណាកាត់បង់នូវធម៌ មានប្រណែនជាដើមទាំងនេះបានហើយ ដោយអរហត្តមគ្គ បុគ្គលនោះឯង ឈ្មោះថាជាមនុស្សល្អ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

**ន វាក្ករណមត្តេន វណ្ណបោក្ខរតាយ វា**
**សាធុរូបោ នរោ ហោតិ ឥស្សុកី មច្ឆរី សឋោ ។**
**យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ សមូហតំ**
**ស វន្តទោសោ មេធាវី សាធុរូបោតិ វុច្ចតិ ។**

*បុគ្គលមានសេចក្តីប្ញស្សា មានសេចក្តីកំណាញ់ ជាអ្នកអួតអាង ឈ្មោះថា ជាមនុស្សល្អដោយហេតុត្រឹមតែធ្វើការនិយាយពាក្យ ( ល្អ ) ឬដោយភាពជាអ្នកមានសម្បុរជាទីគាប់ចិត្ត ក៏មិនទាន់បានទេ លុះត្រាតែទោសជាតមានប្ញស្សាជាដើមនោះ បុគ្គលណាផ្តាច់ផ្តិលដកឡើង ធ្វើឲ្យមានឫសគាល់ដាច់ហើយ បុគ្គលនោះ ជាអ្នកមានទោសខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ជាមនុស្សល្អបាន ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **ន វាក្ករណមត្តេន** *សេចក្តីថា ព្រោះហេតុត្រឹមតែធ្វើការនិយាយ គឺត្រឹមតែពាក្យដែលដល់ព្រមដោយលក្ខណៈ ។ បទថា* **វណ្ណបោក្ខរតាយ វា** *គឺព្រោះភាពជាអ្នកញុំាងចិត្តឲ្យឆ្អែតដោយមានសរីរៈសម្បូរដោយពណ៌សម្បុរ ។ បទថា* **នរោ** *ជាដើម សេចក្តីថា នរៈមិនមានចិត្តប្រណែនព្រោះលាភអ្នកដទៃជាដើម ប្រកបដោយសេចក្តីកំណាញ់ ៥ យ៉ាង ឈ្មោះថា ជាអ្នកអួតអាង ព្រោះគប់រកធម៌ខាងសត្រូវ និងឈ្មោះថា*

បុគ្គលល្អ ព្រោះហេតុមានប្រមាណប៉ុណ្ណេះ មិនទាន់បានទេ ។

ពីរបទថា **យស្ស ចេតំ** ជាដើម សេចក្តីថា ចំណែកបុគ្គលណាកាត់នូវទោសជាត មានការច្រណែនជាដើម បានជាសមុច្ឆេទហើយ ដោយអរហត្ត-មគ្គញ្ញាណជកឡើង ធ្វើឲ្យដាច់ឫសគាល់ហើយ បុគ្គលនោះ មានទោសខ្ជាក់ចោលហើយ ប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ព្រះមានព្រះភាគត្រាស់ថាជាបុគ្គលល្អ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ភិក្ខុច្រើនរូប ចប់**

# រឿង ភិក្ខុឈ្មោះ ហត្ថកៈ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុឈ្មោះហត្ថកៈ ត្រាស់ព្រះធម្មទេសនានេះថា **ន មុណ្ឌកេន សមណោ** ជាដើម ។

បានឮថា ភិក្ខុនោះនិយាយអួតពោលថា លោកទាំងឡាយគប្បីទៅកាន់ទីឈ្មោះនោះ ក្នុងកាលនោះយើងនឹងធ្វើវាទៈ ហើយទៅក្នុងទីនោះមុន ពោលពាក្យទាំងឡាយជាដើមថា មើលចុះលោកទាំងឡាយ ពួកតិរ្ថិយមិនមកព្រោះខ្លាចខ្ញុំ នេះឯងជាការចាញ់របស់ពួកតិរ្ថិយទាំងនោះ ដើរពោលអួតទៅ

បិទបាំងពាក្យដទៃដោយពាក្យដទៃ ។

ព្រះសាស្តាទ្រង់ឮថា ភិក្ខុឈ្មោះហត្ថកៈធ្វើយ៉ាងនោះ ហើយត្រាស់ឲ្យហៅលោកមកសួរថា ហត្ថកៈ បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ កាលលោកក្រាបទូលថា បពិត្រព្រះអង្គ ពិតមែន ទើបត្រាស់ថា ព្រោះហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ ព្រោះថា បុគ្គលធ្វើមុសាវាទបែបនោះ នឹងឈ្មោះថាជាសមណៈ ព្រោះហេតុត្រឹមតែមានក្បាលត្រងោលជាដើមប៉ុណ្ណោះក៏ទេ ចំណែកបុគ្គលណាញ៉ាំងបាបតូច និងបាបធំ ឲ្យស្ងប់ហើយ តាំងនៅ បុគ្គលនោះឯង ឈ្មោះថាសមណៈ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

**ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ**
**ឥច្ឆាលោភសមាបន្នោ សមណោ កឹ ភវិស្សតិ ។**
**យោ ច សមេតិ បាបានិ អណុំថូលានិ សព្វសោ**
**សមិតត្តា ហិ បាបានំ សមណោតិ បវុច្ចតិ ។**

បុគ្គលមិនបានឈ្មោះថាជាសមណៈ ព្រោះភាពជាអ្នកមានក្បាលត្រងោលទេ បុគ្គលអ្នកមិនមានសីលវត្ត និងធុតង្គវត្ត ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្តីប្រាថ្នា និងលោភៈ ឈ្មោះថា ជាសមណៈដូចម្តេចបាន ។ លុះត្រាតែបុគ្គលណារម្ងាប់បាបទាំងឡាយ ទាំងតូចទាំងធំដោយប្រការទាំងពួងបាន ទើបហៅថាសមណៈ ព្រោះបាបទាំងឡាយ ដែលបុគ្គលនោះរម្ងាប់បានហើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មុណ្ឌកេន** សេចក្តីថា ព្រោះហេតុត្រឹមតែក្បាលត្រងោល ។ បទថា **អព្វតោ** គឺវៀរចាកសីលវត្ត និងធុតង្គវត្ត ។ ពីរបទថា **អលិកំ ភណំ** សេចក្តីថា បុគ្គលពោលមុសាវាទ ប្រកបដោយការចង់បានក្នុងអារម្មណ៍ដែលមិនទាន់មកដល់ និងដោយចំណង់ក្នុងអារម្មណ៍ដែលមកដល់ហើយ ឈ្មោះថាជាសមណៈដូចម្តេចបាន ។ បទថា **សមេតិ** សេចក្តីថា ចំណែកបុគ្គលណា ញុំាងបាបតូច ឬបាបធំឲ្យស្ងប់ បុគ្គលនោះ ព្រះសាស្តាត្រាស់ថា ជាសមណៈ ព្រោះញុំាងបាបទាំងនោះឲ្យស្ងប់ហើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

រឿង ភិក្ខុឈ្មោះហត្ថកៈ ចប់

# រឿង ព្រាហ្មណ៍ម្នាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ន តេន ភិក្ខុ សោ ហោតិ** ជាដើម ។

បានឮថា ព្រាហ្មណ៍នោះបួសក្នុងលទ្ធិខាងក្រៅ ត្រាច់ភិក្ខា គិតថា ព្រះសមណគោតម ហៅសាវករបស់ខ្លួនដែលត្រាច់ភិក្ខាថា ភិក្ខុ ការដែលព្រះសមណគោតមហៅអញថា ភិក្ខុ ក៏គួរ ។ គាត់ចូលទៅរកព្រះសាស្តាទូលថា

បពិត្រព្រះគោតម ខ្ញុំក៏ត្រាច់ភិក្ខាចិញ្ចឹមជីវិត សូមទ្រង់ហៅខ្ញុំថា ភិក្ខុ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ តថាគតមិនហៅថាភិក្ខុព្រោះត្រឹមតែសូមគេនោះឡើយ ព្រោះបុគ្គលសមាទានធម៌ដែលជាពិសហើយប្រព្រឹត្ត ឈ្មោះថាជាភិក្ខុមិនបានឡើយ ឯបុគ្គលណាប្រព្រឹត្តទៅដោយពិចារណាសង្ខារទាំងពួង បុគ្គលនោះឈ្មោះថាជាភិក្ខុ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

**ន តេន ភិក្ខុ សោ ហោតិ យាវតា ភិក្ខតេ បរេ**
**វិសំ ធម្មំ សមាទាយ ភិក្ខុ ហោតិ ន តាវតា ។**
**យោធ បុញ្ញញ្ច បាបញ្ច ពាហេត្វា ព្រហ្មចរិយវា**
**សង្ខាយ លោកេ ចរតិ ស វេ ភិក្ខូតិ វុច្ចតិ ។**

បុគ្គលណា ដើរសូមជនទាំងឡាយដទៃ ដោយហេតុត្រឹមណា បុគ្គលនោះ មិនបានឈ្មោះថាជាភិក្ខុ ដោយហេតុត្រឹមនោះទេ បុគ្គលសមាទានធម៌ជាពិស ឈ្មោះថា ជាភិក្ខុ ដោយហេតុត្រឹមតែការដើរសូមប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ក្នុងលោកនេះ បន្សាត់បុណ្យ និងបាបចេញ ហើយជាអ្នកមានការប្រព្រឹត្តដ៏ប្រសើរ ត្រាច់ទៅក្នុងលោកដោយសេចក្តីចេះដឹង បុគ្គលនោះឯង ទើបហៅថា ជាភិក្ខុ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យាវតា** សេចក្តីថា ឈ្មោះថាជាភិក្ខុ ព្រោះ

ហេតុត្រឹមតែសូមនឹងជនពួកដទៃក៏មិនមែន ។ បទថា **វិសំ** ជាដើម សេចក្តីថា បុគ្គលដែលសមាទានធម៌មិនស្មើ ឬធម៌ មានកាយកម្មជាដើម ដែលមានក្លិនជាពិសកំពុងប្រព្រឹត្ត មិនទាន់ឈ្មោះថាជាភិក្ខុឡើយ ។ បទថា **យោធ** ជាដើម សេចក្តីថា បុគ្គលណាក្នុងសាសនានេះ បន្សាត់ គឺបន្ទោបង់នូវបុណ្យនិងបាបទាំងពីរនេះដោយមគ្គព្រហ្មចរិយៈ ឈ្មោះថា ជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ ។ បទថា **សង្ខាយ** គឺដោយញាណ ។ បទថា **លោកេ** ជាដើម សេចក្តីថា បុគ្គលដឹងធម៌ទាំងអស់ក្នុងលោក មានខន្ធលោកជាដើមយ៉ាងនេះថា ខន្ធទាំងនេះ ជាខាងក្នុង ខន្ធទាំងនេះ ជាខាងក្រៅ ត្រាច់ទៅ បុគ្គលនោះព្រះសាស្តាត្រាស់ហៅថា ភិក្ខុ ព្រោះជាអ្នកទម្លាយកិលេសទាំងឡាយ ដោយញាណនោះហើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រាហ្មណ៍ម្នាក់ ចប់

# រឿង តិត្ថិយ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកតិត្ថិយ ត្រាស់ព្រះធម្មទេសនានេះថា **ន មោនេន** ជាដើម ។

បានឮថា ពួកតិរ្ថិយទាំងនោះ ធ្វើអនុមោទនាដល់ពួកមនុស្សក្នុងទីដែលខ្ញុំនបរិភោគហើយ ពោលមង្គលដោយន័យជាដើមថា សេចក្តីក្សេមចូរមាន សេចក្តីសុខចូរមាន អាយុចូរចម្រើន ក្នុងទីឈ្មោះនោះ មានភក់ ក្នុងទីឈ្មោះនោះ មានបន្លា ការទៅក្នុងទីបែបនោះ មិនគួរ ហើយចៀសចេញទៅ ។ ក្នុងបឋមពោធិកាល កាលដែលព្រះសាស្តាទ្រង់មិនទាន់អនុញ្ញាត អនុមោទនាវិធីជាដើម ភិក្ខុទាំងឡាយក៏មិនធ្វើអនុមោទនាដល់ពួកមនុស្សក្នុងរោងភត្តឡើយ រមែងចៀសចេញទៅ ។ ពួកមនុស្សលើកទោសថា ពួកយើងបានស្តាប់មង្គលអំពីសម្នាក់របស់តិរ្ថិយទាំងឡាយ តែលោកម្ចាស់ទាំងឡាយនៅស្ងៀមចៀសចេញទៅហើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះ ដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តាំងអំពីនេះទៅ ចូរអ្នកទាំងឡាយធ្វើអនុមោទនាក្នុងទីទាំងឡាយ មានរោងភត្តជាដើម តាមសប្បាយចុះ ចូរពោលឧបនិសិន្នកថាចុះ ភិក្ខុទាំងនោះធ្វើយ៉ាងនោះហើយ ។

ពួកមនុស្សស្តាប់អនុមោទនាវិធីជាដើម ដល់នូវឧស្សាហ៍ហើយ និមន្តភិក្ខុទាំងឡាយធ្វើសក្ការៈ ។ ពួកតិរ្ថិយពោលទោសថា ពួកយើងជាមុនីធ្វើនូវភាពជាអ្នកស្ងៀម ពួកសាវករបស់ព្រះសមណគោតម ត្រាច់ពោលកថាច្រើនក្នុងទីទាំងឡាយ មានរោងភត្តជាដើម ។

ព្រះសាស្តាទ្រង់ស្តាប់សេចក្តីនោះត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលថាមុនី ដោយហេតុគ្រាន់តែជាអ្នកស្ងៀម ព្រោះបុគ្គលពួកខ្លះមិនដឹង

*រមែងមិននិយាយ ពួកខ្លះមិននិយាយព្រោះភាពដែលខ្លួនមិនក្លៀវក្លា ពួកខ្លះមិនពោលព្រោះកំណាញ់ថា ជនពួកដទៃកុំបីដឹងអត្ថដ៏ក្រៃលែងនេះរបស់អញឡើយ ព្រោះដូច្នោះ បុគ្គលមិនឈ្មោះថាជាមុនី ព្រោះហេតុត្រឹមតែជាអ្នកស្ងៀម តែឈ្មោះថា ជាមុនី ព្រោះញ៉ាំងបាបឲ្យស្ងប់ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា*

**ន មោនេន មុនិ ហោតិ មូឡ្ហរូបោ អវិទ្ទសុ**
**យោ ច តុលំវ បគ្គយ្ហ វរមាទាយ បណ្ឌិតោ ។**
**បាបានិ បរិវជ្ជេតិ ស មុនិ តេន សោ មុនិ**
**យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ ។**

*បុគ្គលមានសេចក្ដីវង្វេងជាធម្មតា មិនមានការចេះដឹង មិនបានឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមទេ លុះត្រាតែបុគ្គលណាជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ វៀរចាកបាបទាំងឡាយ ដូចបុគ្គលកាន់ជញ្ជីង ហើយថ្លឹងដូច្នោះ ទើបបុគ្គលនោះ ឈ្មោះថា ជាមុនី ដោយភាពជាអ្នកស្ងៀមនោះបាន បុគ្គលណា ដឹងប្រយោជន៍ទាំងពីរក្នុងលោក បុគ្គលនោះ ហៅថា មុនី ដោយហេតុនោះ ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បទថា* **ន មោនេន** *សេចក្ដីថា បុគ្គលឈ្មោះថាជាមុនី ព្រោះមោនៈ គឺមគ្គញាណ ពោល គឺបដិបទាដែលជាមុនីក៏ពិត ។ តែ*

ក្នុងព្រះគាថានេះ ព្រះសាស្ដាត្រាស់ថា **មោនេន** សំដៅយកភាពជាអ្នកស្ងៀម ។ បទថា **មូឡ្ហរូបោ** គឺជាអ្នកទទេ ។

បទថា **អវិទ្ទសុ** គឺមិនដឹងដោយប្រក្រតី អធិប្បាយថា បុគ្គលបែបនោះសូម្បីជាអ្នកស្ងៀម ក៏មិនឈ្មោះថាជាមុនី ម្យ៉ាងទៀត មិនឈ្មោះថាមោនេយ្យមុនី តែជាបុគ្គលទទេជាសភាវៈ និងមិនដឹងដោយប្រក្រតី ។

បាទព្រះគាថាថា **យោ ច តុលំវ បគ្គយ្ហ** សេចក្ដីថា ដូចបុគ្គលឈរកាន់ជញ្ជីង បើរបស់ច្រើនពេកក៏នាំយកចេញ បើរបស់តិចក៏បន្ថែមចូល យ៉ាងណាបុគ្គលណានាំចេញ ឈ្មោះថាវៀរនូវបាប ដូចបុគ្គលយករបស់ដែលច្រើនចេញបំពេញកុសល ដូចបុគ្គលបន្ថែមរបស់ដែលតិចចូលដូច្នោះដូចគ្នា កាលបើធ្វើយ៉ាងនោះ ឈ្មោះថាកាន់យកធម៌ដ៏ប្រសើរ គឺឧត្តមនោះឯង ពោល គឺសីលសមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ វៀរបង់នូវបាប គឺកម្មដែលជាអកុសលទាំងឡាយ ។ ពីរបទថា **ស មុនិ** សេចក្ដីថា បុគ្គលនោះឈ្មោះថាជាមុនី ។ ច្រើនបទថា **តេន សោ មុនិ** សេចក្ដីថា បើមានពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី ទើបបុគ្គលនោះឈ្មោះថាជាមុនី ត្រូវឆ្លើយថា បុគ្គលនោះ ជាមុនី ព្រោះហេតុដែលពោលហើយខាងដើម ។

បាទព្រះគាថាថា **យោ មុនាតិ ឧភោ លោកេ** សេចក្ដីថា បុគ្គលណាដឹងអត្ថទាំងពីរនេះក្នុងលោក មានខន្ធលោកជាដើមនេះ ដោយន័យជាដើមថាខន្ធទាំងនេះជាខាងក្នុង ខន្ធទាំងនេះជាខាងក្រៅ ដូចបុគ្គលលើកជញ្ជីងឡើងថ្លឹងដូច្នោះ ។ ច្រើនបទថា **មុនិ តេន បវុច្ចតិ** សេចក្ដីថា បុគ្គលនោះ ព្រះដ៏មាន

ព្រះភាគហៅថាជាមុនី ព្រោះហេតុនោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង តិរ្ថិយ ចប់**

# រឿង ព្រានសន្ទូចឈ្មោះ អរិយៈ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រានសន្ទូចម្នាក់ឈ្មោះអរិយៈ ត្រាស់ព្រះធម្មទេសនានេះថា **ន តេន អរិយោ ហោតិ** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់អរិយៈនោះ ទ្រង់យាងបិណ្ឌបាតក្នុងស្រុក តាមទ្វារទិសខាងជើងនៃក្រុងសាវត្ថី ដែលភិក្ខុសង្ឃចោមរោម យាងមកអំពីស្រុកនោះ ។ ខណៈនោះអ្នកស្ទូចត្រី ស្ទូចត្រីដោយសន្ទូច ឃើញភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន បានបោះដងសន្ទូចចោលឈរហើយ ។

ព្រះសាស្តា យាងត្រឡប់ ប្រថាប់ឈរមិនឆ្ងាយអំពីព្រានសន្ទូចនោះ ត្រាស់សួរឈ្មោះរបស់សាវកទាំងឡាយ មានព្រះសារីបុត្តជាដើមថា អ្នកឈ្មោះអ្វី អ្នកឈ្មោះអ្វី សាវកទាំងនោះក៏ក្រាបទូលឈ្មោះរបស់ខ្លួនថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឈ្មោះសារីបុត្ត បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឈ្មោះមោគ្គល្លាន

ជាដើម ។ ព្រានសន្ទូចគិតថា ព្រះសាស្ដាត្រាស់សួរឈ្មោះសាវកគ្រប់អង្គ ម្ដេចក៏មិនត្រាស់សួរឈ្មោះរបស់អញផង ។

ព្រះសាស្ដាទ្រង់ជ្រាបសេចក្ដីប្រាថ្នារបស់ព្រានសន្ទូចនោះ ទើបត្រាស់សួរថា នែអ្នក តើអ្នកឈ្មោះអ្វី កាលបុរសនោះក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឈ្មោះអរិយៈ ទើបត្រាស់ថា នែអ្នក បុគ្គលដែលសម្លាប់សត្វដូចអ្នកមិនឈ្មោះថាអរិយៈឡើយ ចំណែកបុគ្គលដែលតាំងនៅក្នុងការមិនបៀតបៀនមហាជន ទើបឈ្មោះថា អរិយៈ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ន តេន អរិយោ ហោតិ យេន បាណានិ ហឹសតិ**
**អហឹសា សព្វបាណានំ អរិយោតិ បវុច្ចតិ ។**

បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបាន
ឈ្មោះថា ជាអរិយៈ ដោយហេតុនោះទេ បុគ្គលដែល
តថាគតហៅថាអរិយៈ ព្រោះមិនបៀតបៀនសត្វទាំងពួង ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **អហឹសា** សេចក្ដីថា ព្រោះមិនបៀតបៀន ។

មានអធិប្បាយដូច្នេះថា បុគ្គលមិនឈ្មោះថាអរិយៈ ព្រោះហេតុដែលបៀតបៀនសត្វទាំងឡាយ ចំណែកបុគ្គលណាតាំងនៅឆ្ងាយចាកការបៀតបៀន ព្រោះមិនបៀតបៀនសត្វទាំងពួងដោយបាតដៃជាដើម គឺព្រោះភាពដែលខ្លួនតាំងនៅហើយ ក្នុងមេត្តាភាវនាជាដើម បុគ្គលនេះ ព្រះសាស្ដាត្រាស់ហៅថា អរិយៈ ។

ក្នុងកាលចប់ទេសនា ព្រានសទ្ទូច តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។៙

**រឿង ព្រានសទ្ទូចឈ្មោះអរិយៈ ចប់**

# រឿង ភិក្ខុច្រើនរូប

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូបដែលដល់ព្រមដោយគុណ មានសីលជាដើម ត្រាស់ព្រះធម្មទេសនានេះថា **ន សីលព្វតមត្តេន** ជាដើម ។

បានឮថា បណ្ដាភិក្ខុទាំងនោះ ពួកខ្លះមានការគិតយ៉ាងនេះថា ពួកយើងមានសីលបរិបូណ៌ហើយ ពួកយើងទ្រទ្រង់នូវធុតង្គ ពួកយើងជាពហូសូត ពួកយើងនៅក្នុងសេនាសនៈស្ងាត់ ពួកយើងបានឈាន អរហត្ត ពួកយើងបានមិនលំបាក ពួកយើងនឹងសម្រេចអរហត្តក្នុងថ្ងៃដែលពួកយើងត្រូវការនោះឯង បណ្ដាភិក្ខុទាំងនោះ ភិក្ខុដែលជាអនាគាមីគិតយ៉ាងនេះថា ឥឡូវនេះ អរហត្ត ពួកយើងបានមិនលំបាក ។ ថ្ងៃមួយ ភិក្ខុទាំងអស់ ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ កាលព្រះសាស្ដាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ កិច្ចនៃបព្វជិតរបស់ពួកអ្នកដល់ទីបំផុតហើយឬ ក៏ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គបែបនេះ បែបនេះ ព្រោះដូច្នោះ ទើបពួកខ្ញុំព្រះអង្គគិតថា

ពួកយើងអាចសម្រេចអរហត្ត ក្នុងខណៈដែលប្រាថ្នាហើយនោះឯង ដូច្នេះ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ភិក្ខុ ទោះឃើញថាទុក្ខក្នុងភពរបស់ពួកយើងតិចតួចដោយគុណត្រឹមតែភាពជាអ្នកមានសីលបរិសុទ្ធជាដើម ឬដោយគុណត្រឹមតែសេចក្តីសុខរបស់ព្រះអនាគាមី មិនគួរ បើមិនទាន់ដល់នូវការអស់អាសវៈ មិនគប្បីឲ្យនូវការគិតកើតឡើងថា អញដល់សេចក្តីសុខហើយ ទើបត្រាស់ព្រះគាថានេះថា

**ន សីលព្វតមត្តេន ពាហុសច្ចេន វា បន**
**អថវា សមាធិលាភេន វិវិត្តសយនេន វា ។**
**ផុសាមិ នេក្ខម្មសុខំ អបុថុជ្ជនសេវិតំ**
**ភិក្ខុ វិស្សាសមាបាទិ អប្បត្តោ អាសវក្ខយំ ។**

ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំអាលទុកចិត្តដោយគុណត្រឹមតែសីល និងវត្ត ឬដោយភាពជាអ្នកចេះដឹងច្រើនឡើយ មួយទៀត ដោយការបានសមាធិ ឬក៏ដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណ មានប្រមាណប៉ុណ្ណេះថា អាត្មាអញពាល់ត្រូវនេក្ខម្មសុខ ដែលបុថុជ្ជនមិនដែលជួបប្រសព្វ ដូច្នេះឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សីលព្វតមេត្តេន** គឺដោយហេតុត្រឹមតែបារិសុទ្ធិសីល ៤ ឬធុតង្គគុណ ១៣ ។

បទថា **ពាហុសច្ចេន វា** សេចក្តីថា ឬដោយហេតុត្រឹមតែភាពជាបុគ្គលរៀនបិដក ៣ ។

បទថា **សមាធិលាភេន** សេចក្តីថា ឬដោយការបានសមាបត្តិ ៨ ។

បទថា **នេក្ខម្មសុខំ** គឺសុខរបស់ព្រះអនាគាមី ព្រោះដូច្នោះ ភិក្ខុកុំដល់នូវការទុកចិត្ត ដោយហេតុមានប្រមាណត្រឹមតែដឹងប៉ុណ្ណោះថា អញពាល់ត្រូវសុខរបស់ព្រះអនាគាមី ។

បទថា **អបុថុជ្ជនសេវិតំ** សេចក្តីថា ដែលបុថុជ្ជនទាំងឡាយសេពមិនបាន គឺដែលព្រះអរិយៈសេពហើយតែម្យ៉ាង ។ ភិក្ខុទាំងនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សាកសួរភិក្ខុរូបណាមួយអង្គ ក៏ត្រាស់ថា ភិក្ខុ ។

បទថា **វិស្សាសមាបាទិ** សេចក្តីថា កុំដល់នូវការទុកចិត្ត មានពាក្យអធិប្បាយដូច្នេះថា ភិក្ខុ ឈ្មោះថា ជាអ្នកដែលមិនសម្រេចអរហត្ត ពោលគឺការអស់ទៅនៃអាសវៈ មិនគប្បីទុកចិត្តថា ភពរបស់អញតិចតួច ដោយហេតុត្រឹមតែភាពជាអ្នកមានគុណ មានសីលបរិបូណ៌ជាដើមប៉ុណ្ណោះ ដូចលាមក សូម្បីមានប្រមាណតិច ក៏នៅតែមានក្លិនស្អុយ យ៉ាងណា ភពមានប្រមាណតិច ក៏ជាហេតុឲ្យកើតទុក្ខ ដូច្នោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះតាំងនៅក្នុងអរហត្តហើយ ។ ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយដូច្នេះ ។ល។

**រឿងភិក្ខុច្រើនរូប ចប់**

**ធម្មដ្ឋវគ្គទី ១៩ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា មគ្គវគ្គទី ២០

[ ៣០ ] ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺអរិយសច្ច ប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ប្រសើរជាងធម៌ទាំងឡាយ មួយទៀត ព្រះតថាគតមានចក្ខុ ប្រសើរជាងសត្វទ្វេបាទទាំងឡាយ ផ្លូវនេះឯងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានទេ ។

ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ ផ្លូវនេះជាផ្លូវញុំាងមារឲ្យវង្វេង អ្នកទាំងឡាយដើរទៅកាន់ផ្លូវនេះហើយ អាចនឹងធ្វើឲ្យផុតទុក្ខបាន ។ ផ្លូវនេះហើយ ដែលតថាគតដឹងថា ជាផ្លូវកម្ចាត់បង់កូនសរ ប្រាប់ដល់អ្នកទាំងឡាយ សេចក្តីព្យាយាម ញុំាងកិលេសឲ្យក្តៅសព្វ អ្នកទាំងឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ ជនទាំងឡាយមានការពិនិត្យ បើបានដើរទៅហើយ នឹងរួចចាកចំណងរបស់មារបាន ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀងដូច្នេះ កាលនោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង នាំមកនូវសេចក្តីទុក្ខ ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។ កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា ធម៌ទាំងពួង មិនមែនជារបស់ខ្លួនដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

បុគ្គលនៅកំលោះមានកម្លាំង ទាស់តែប្រកបដោយសេចក្ដីខ្ជិលច្រអូស មិនប្រឹងប្រែង ក្នុងកាលដែលគួរប្រឹងប្រែង មានសេចក្ដីត្រិះរិះក្នុងចិត្តលិចចុះក្នុងអកុសលវិតក្ក ជាមនុស្សខ្ជិល បុគ្គលខ្ជិល ( នោះ ) រមែងមិនបានផ្លូវបញ្ញាឡើយ ។

បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមឲ្យល្អ ដោយចិត្ត ទាំងមិនគប្បីធ្វើអកុសលដោយកាយ បុគ្គលគប្បីជម្រះកម្មបថទាំង ៣ នេះ និងគប្បីត្រេកអរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណដ៏ល្អ សម្ដែងទុកហើយ ។

ប្រាជ្ញា រមែងកើតអំពីការប្រកប សេចក្ដីវិនាសប្រាជ្ញា រមែងកើតអំពីការមិនប្រកប អ្នកមានប្រាជ្ញា ដឹងការប្រកប និងការមិនប្រកបទាំង ២ នេះថា ជាគន្លងនៃសេចក្ដីចម្រើន និងសេចក្ដីវិនាសហើយ ប្រាជ្ញាចម្រើនឡើងដោយប្រការណា គួរតម្កល់ខ្លួនទុក ដោយប្រការនោះ ។

អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ ( ព្រោះ ) ភ័យកើតអំពីកិលេសដូចជាព្រៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរកាត់កិលេសដូចជាព្រៃផង កិលេសដូចជាដើមឈើដុះក្នុងព្រៃផង ហើយចូរជាអ្នកកុំមានកិលេស ដូចជាព្រៃឡើយ ព្រោះថា កិលេសដូចដើមឈើដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនដាច់ក្នុងពួកនារីដរាបណា នរជននោះឯង តែងមានចិត្តជាប់ចំពោះក្នុងពួកនារីដូចកូនគោនៅកំពុងបៅដោះ ដែលមានចិត្តជាប់នៅនឹងមេ ដរាបនោះ ។

អ្នកចូរដកសេចក្ដីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គលដកផ្កាកុមុទៈ ដែលកើត

ក្នុងសរទកាលដោយដៃ អ្នកចូរបណ្តុះនូវផ្លូវសន្តិភាពតែម្យ៉ាង ព្រះនិព្វាន ព្រះសុគតសម្តែងទុកហើយ ។

អញនឹងនៅក្នុងទីនេះអស់វស្សានរដូវ អញនឹងនៅក្នុងទីនេះក្នុងហេមន្ត-រដូវ និងគិម្ហរដូវ ជនពាល រមែងគិតខុសដូច្នេះ តែងមិនដឹងច្បាស់សេចក្តីអន្តរាយឡើយ ។

មច្ចុ គឺសេចក្តីស្លាប់តែងនាំយកនរជន អ្នកប្រវឹងជ្រុប ក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗ នោះ ដូចជំនន់ទឹកធំនាំយកអ្នកស្រុកកំពុងដេកលក់ ។

កាលបុគ្គល ត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមានដើម្បីជាទីពឹង បិតា ក៏មិនមាន ទាំងផៅពង្ស ក៏មិនមាន ដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ ជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វានឲ្យបាន ។

**មគ្គវគ្គទី ២០ ចប់**

# អដ្ឋកថា
# មគ្គវគ្គទី ២០

## រឿងភិក្ខុ ៥០០ រូប
### លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥០០ រូប ត្រាស់ព្រះធម្មទេសនានេះថា **មគ្គានដ្ឋង្គិកោ** ជាដើម ។

បានឮមកថា ភិក្ខុទាំងនោះ កាលព្រះសាស្ដាចារិកទៅក្នុងជនបទ ហើយយាងមកកាន់ក្រុងសាវត្ថីទៀត អង្គុយក្នុងរោងដែលជាទីបម្រើ ពោលមគ្គកថា ប្រារព្ធផ្លូវដែលខ្លួនត្រាច់ទៅហើយ ដោយន័យជាដើមថា ផ្លូវនៃស្រុកនោះ ទៅស្រុកនោះ រាបស្មើល្អ ផ្លូវនៃស្រុកនោះ ទៅស្រុកនោះ មិនរាបស្មើ មានក្រួស មិនមានក្រួស ។

ព្រះសាស្ដា ទ្រង់ឃើញឧបនិស្ស័យនៃអរហត្តរបស់ភិក្ខុទាំងនោះ យាងមកកាន់ទីនោះហើយ ប្រថាប់គង់លើអាសនៈដែលគេក្រាល ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផ្លូវដែលពួកអ្នកនិយាយដល់នេះ ជាផ្លូវខាងក្រៅ ធម្មតាភិក្ខុធ្វើកម្មក្នុងអរិយមគ្គ ទើបគួរ ព្រោះថា ភិក្ខុកាលធ្វើយ៉ាងនោះ រមែងផុតចាកទុក្ខ

ទាំងពួងបាន ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

មគ្គានដ្ឋង្គិកោ សេដ្ឋោ   សច្ចានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ   ទិបទានញ្ច ចក្ខុមា
ឯសេវ មគ្គោ នត្ថញ្ញោ   ទស្សនស្ស វិសុទ្ធិយា ។
ឯតញ្ហិ តុម្ហេ បដិបជ្ជថ   មារស្សេតំ បមោហនំ
ឯតញ្ហិ តុម្ហេ បដិបន្នា   ទុក្ខស្សន្តំ ករិស្សថ ។
អក្ខាតោ វោ មយា មគ្គោ   អញ្ញាយ សល្លសត្តនំ
តុម្ហេហិ កិច្ចំ អាតប្បំ   អក្ខាតារោ តថាគតា
បដិបន្នា បមោក្ខន្តិ   ឈាយិនោ មារពន្ធនា ។

ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺ អរិយសច្ច ប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ ប្រសើរជាងធម៌ទាំងឡាយ មួយទៀត ព្រះតថាគត មានចក្ខុ ប្រសើរជាងសត្វទ្វេបាទទាំងឡាយ ផ្លូវនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្ដីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានទេ ។ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ ផ្លូវនេះជាផ្លូវញ៉ាំងមារឲ្យវង្វេង អ្នកទាំងឡាយដើរទៅកាន់ផ្លូវនោះហើយ អាចនឹងធ្វើឲ្យផុតទុក្ខបាន ។ ផ្លូវនេះហើយ ដែលតថាគតដឹងថា ជាផ្លូវកម្ចាត់បង់កូនសរ ប្រាប់ដល់អ្នកទាំងឡាយ សេចក្ដីព្យាយាមញ៉ាំងកិលេសឲ្យក្ដៅសព្វ អ្នក

ទាំងឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ ជនទាំងឡាយមានការពិនិត្យ បើបានដើរទៅហើយ នឹងរួចចាកចំណងរបស់មារបាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មគ្គានដ្ឋង្គិកោ** សេចក្តីថា ផ្លូវទាំងឡាយជាផ្លូវទៅដោយស្មងជាដើមក្តី ជាផ្លូវនៃទិដ្ឋិ ៦២ ក្តី បណ្តាផ្លូវទាំងអស់ ផ្លូវមានអង្គ ៨ ដែលធ្វើការលះបង់នូវផ្លូវ ៨ មានមិច្ឆាទិដ្ឋិជាដើម ដោយអង្គ ៨ មានសម្មាទិដ្ឋិជាដើម ។ ធ្វើនិរោធឲ្យជាអារម្មណ៍ ញុំាំងកិច្ច មានការកំណត់ដឹងទុក្ខជាដើម ក្នុងសច្ចៈទាំង ៤ ឲ្យសម្រេច ប្រសើរ គឺកំពូល ។

បាទព្រះគាថាថា **សច្ចានំ ចតុរោ បទា** សេចក្តីថា បណ្តាសច្ចៈទាំងអស់នេះ ចូរជាវចីសច្ចដែលមកហើយក្នុងបាលីថា បុគ្គលគប្បីពោលពាក្យសច្ចៈមិនគប្បីក្រោធជាដើមក្តី ជាសម្មតិសច្ច មានសច្ចៈជាដើមថា ជាព្រាហ្មណ៍ពិត ជាក្សត្រពិតក្តី ជាទិដ្ឋិសច្ច ដោយន័យថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទទេជាដើមក្តី ជាបរមត្ថសច្ច មានសច្ចៈជាដើមថា ទុក្ខជារបស់ពិតដ៏ប្រសើរក្តី ៤ បទ មានបទថា ទុក្ខជារបស់ពិតដ៏ប្រសើរជាដើម ឈ្មោះថា ប្រសើរ ព្រោះអត្ថថា ទុក្ខ ដែលព្រះយោគាវចរគួរកំណត់ដឹង ព្រោះអត្ថថា សមុទយៈ ដែលព្រះយោគាវចរគួរលះ ព្រោះអត្ថថា និរោធ ដែលព្រះយោគាវចរគួរធ្វើឲ្យជាក់ច្បាស់ ព្រោះអត្ថថា មគ្គមានអង្គ ៨ ដែលព្រះយោគាវចរគួរបម្រើន ព្រោះអត្ថថា ចាក់ធ្លុះបានដោយញាណនោះឯង ព្រោះអត្ថថា ចាក់ធ្លុះបាន

ដោយពិតប្រាកដ ។

បាទព្រះគាថាថា **វិរាគោ សេដ្ឋោ ធម្មានំ** សេចក្តីថា បណ្តាធម៌ទាំងពួង វិរាគៈ ពោល គឺព្រះនិព្វានឈ្មោះថាប្រសើរ ព្រោះព្រះពុទ្ធវចនៈថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលបច្ច័យតាក់តែងក្តី ដែលបច្ច័យមិនតាក់តែងក្តី មានប្រមាណត្រឹមណា បណ្តាធម៌ទាំងនោះ វិរាគៈ តថាគតពោលថាជាកំពូល ។

បាទព្រះគាថាថា **ទិបទានញ្ច ចក្ខុមា** សេចក្តីថា បណ្តាសត្វជើងពីរ មានទេវតា និងមនុស្សជាដើម ព្រះតថាគតមានចក្ខុ ៥ ប្រការប៉ុណ្ណោះប្រសើរ ។ ច សព្ទ មានការប្រមូលមកជាអត្ថ រមែងប្រមូលយកអរូបធម៌ទាំងឡាយផង ព្រោះដូច្នោះ បណ្តាអរូបធម៌ទាំងឡាយ ព្រះតថាគតក៏ជាបុគ្គលប្រសើរ គឺឧត្តម ។

បាទព្រះគាថាថា **ទស្សនស្ស វិសុទ្ធិយា** សេចក្តីថា ផ្លូវណាដែលតថាគតពោលថា ប្រសើរ ផ្លូវនោះប៉ុណ្ណោះ ដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ គឺមគ្គនិងផល ផ្លូវដទៃមិនមាន ។

បទថា **ឯតំ ហិ** សេចក្តីថា ព្រោះហេតុនោះ ចូរអ្នកទាំងឡាយ ដើរផ្លូវនោះឯង ។

បទថា **មារសេនប្បមោហនំ** នោះ ព្រះសាស្តារមែងត្រាស់ថា ជាទីដែលមារវង្វេង គឺទីដែលកន្ទេងពួកមារ ។

បទថា **ទុក្ខស្សន្តំ** សេចក្តីថា អ្នកទាំងឡាយនឹងធ្វើទីបំផុត គឺព្រំដែននៃសេចក្តីទុក្ខក្នុងវដ្តៈទាំងមូលបាន ។

បទថា **សល្លសត្ថនំ** ជាដើម សេចក្ដីថា តថាគតវៀរចាកកិច្ចទាំងឡាយ មានការបានស្ដាប់អំពីអ្នកដទៃជាដើម ដឹងនូវផ្លូវនោះ ដែលជាទីរលាស់ចេញ គឺញាំញី បានដល់ ដកឡើងនូវកូនសរទាំងឡាយ មានរាគៈជាដើមដោយប្រចក្ស ដល់ខ្លួនហើយនោះឯង ទើបប្រាប់ផ្លូវនេះ ។ ឥឡូវនេះ អ្នកទាំងឡាយគប្បីធ្វើ បាន ដល់ គួរធ្វើសេចក្ដីព្យាយាម គឺសម្មប្បធាន ដែលដល់នូវការរាប់ថាជាអាតប្បៈ ព្រោះជាគ្រឿងដុតកិលេសទាំងឡាយ ដើម្បីប្រយោជន៍ដល់ការសម្រេចផ្លូវនោះ ព្រោះព្រះតថាគតទាំងឡាយ ជាអ្នកប្រាប់តែម្យ៉ាង ព្រោះដូច្នោះ ជនទាំងឡាយ ដែលបដិបត្តិហើយ ដោយអំណាចនៃផ្លូវ ដែលព្រះតថាគតទាំងនោះត្រាស់ប្រាប់ហើយ មានប្រក្រតីសម្លឹងដោយឈាន ២ យ៉ាង រមែងរួចផុតចាកចំណងនៃមារ ពោល គឺវដ្ដៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ភិក្ខុទាំងនោះ បានតាំងនៅហើយ ក្នុងអរហត្តផល ព្រះធម្មទេសនា បានសម្រេចប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។៚

## រឿងភិក្ខុ ៥០០ រូប ចប់

# រឿង ភិក្ខុ ៥០០ ជាទេរៀត

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥០០ រូប ត្រាស់ព្រះធម្មទេសនានេះថា **សព្វេ សង្ខារា** ជាដើម ។

បានឮមកថា ភិក្ខុទាំងនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ សូម្បីព្យាយាមក្នុងព្រៃក៏មិនសម្រេចអរហត្ត ទើបគិតថា ពួកយើងនឹងរៀនកម្មដ្ឋានឲ្យវិសេស ដូច្នេះហើយ បានទៅកាន់សម្នាក់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់ពិចារណាថា កម្មដ្ឋានណាហ្ន៎ ជាទីសប្បាយរបស់ភិក្ខុទាំងនេះ ទើបទ្រង់ត្រិះរិះថា ភិក្ខុទាំងនេះ ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សប តាមប្រកបហើយក្នុងអនិច្ចលក្ខណៈអស់ ២ ម៉ឺនឆ្នាំ ព្រោះដូច្នោះ ការសម្ដែងគាថាអំពីអនិច្ចលក្ខណៈនោះឯងដល់លោកទាំងឡាយ ត្រឹមតែមួយគាថា គួរ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងពួងក្នុងភពទាំងឡាយ មានកាមភពជាដើម ជាសភាពមិនទៀង ព្រោះអត្ថថា មានហើយ ទៅជាមិនមាន ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង
មិនទៀង ដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្ដី
ទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្វេ សង្ខារា** ជាដើម សេចក្តីថា កាលណាបណ្ឌិតឃើញដោយវិបស្សនាបញ្ញាថា ខន្ធទាំងឡាយកើតឡើងហើយក្នុងភពទាំងឡាយ មានកាមភពជាដើម ឈ្មោះថា មិនទៀង ព្រោះត្រូវរលត់ក្នុងភពនោះៗ ឯង ។ កាលនោះ រមែងនឿយណាយក្នុងទុក្ខ ដែលទាក់ទងដោយការបរិហារខន្ធនេះ កាលនឿយណាយ រមែងចាក់ធ្លុះសច្ចៈទាំងឡាយ ដោយអំណាចនៃកិច្ច មានការកំណត់ដឹងទុក្ខជាដើម ។

បាទព្រះគាថាថា **ឯស មគ្គោ វិសុទ្ធិយា** សេចក្តីថា ការនឿយណាយក្នុងទុក្ខនោះ ជាផ្លូវនៃសេចក្តីបរិសុទ្ធ គឺផ្លូវនៃសេចក្តីផូរផង់ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះតាំងនៅក្នុងអរហត្តហើយ ទេសនាបានសម្រេចប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

**រឿងភិក្ខុ ៥០០ ដទៃទៀត ចប់**

ក្នុងព្រះគាថាទីពីរ រឿងក៏យ៉ាងនោះដូចគ្នា ក្នុងកាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបភាពដែលភិក្ខុទាំងនោះ ធ្វើសេចក្តីព្យាយាមក្នុងកាលកំណត់សង្ខារដោយភាពជាទុក្ខហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ខន្ធទាំងពួងជាទុក្ខពិត ព្រោះអត្ថថា ត្រូវទុក្ខគ្របសង្កត់ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំង
ពួងនាំមកនូវសេចក្ដីទុក្ខ ដូច្នេះ កាលណោះ រមែងនឿយ
ណាយក្នុងសេចក្ដីទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **ទុក្ខា** សេចក្ដីថា ឈ្មោះថា ជាទុក្ខ ព្រោះអត្ថថា ត្រូវទុក្ខបៀតបៀន ។ បទដ៏សេស ក៏ដូចគ្នានឹងបទមុននោះឯង ។

**រឿងភិក្ខុ ៥០០ ដទៃទៀត ចប់**

ក្នុងព្រះគាថាទីបី រឿងក៏យ៉ាងនោះដូចគ្នា ។ ក្នុងព្រះគាថាទីបីនេះ ព្រះសាស្ដាទ្រង់ជ្រាបភាពដែលភិក្ខុទាំងនោះ ជាអ្នកតាមប្រកបហើយក្នុងការកំណត់សង្ខារ ដោយភាពជាអនត្តា ក្នុងកាលមុនដោយឥតសេសសល់ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ខន្ធទាំងពួងជាអនត្តាពិត ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា ធម៌ទាំងពួង
មិនមែនជារបស់ខ្លួន ដូច្នេះ កាលណោះ រមែងនឿយ
ណាយក្នុងសេចក្ដីទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ ពីរបទថា **សព្វេ ធម្មា** ព្រះសាស្ដាទ្រង់សម្ដៅយក ខន្ធ ៥ នេះឯង ។

បទថា **អនត្តា** សេចក្ដីថា ឈ្មោះថា អនត្តា គឺទទេ មិនមានម្ចាស់ បានដល់ មិនមានឥស្សរៈ ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះ បុគ្គលណាម្នាក់មិនអាចឲ្យប្រព្រឹត្តទៅក្នុងអំណាចថា ធម៌ទាំងពួង ចូរកុំចាស់ ចូរកុំស្លាប់ ។ បទដ៏សេស ដូចគ្នានឹងបទដែលមានហើយក្នុងកាលមុន នោះឯង ដូច្នេះ ។៚

**រឿង ភិក្ខុ ៥០០ ដទៃទៀត ចប់**

# រឿង បធានកម្មិកតិស្សត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបធានកម្មិកតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧដ្ឋានកាលម្ហិ** ជាដើម ។

បានឮថា កុលបុត្រអ្នកក្រុងសាវត្ថីប្រមាណ ៥០០ នាក់ បួសក្នុងសម្នាក់ ព្រះសាស្ដា រៀនកម្មដ្ឋានហើយ បានទៅកាន់ព្រៃ ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុ មួយរូបស្នាក់នៅក្នុងទីនោះឯង ។ ភិក្ខុដ៏សេស ធ្វើសមណធម៌ក្នុងព្រៃសម្រេច អរហត្ត គិតថា ពួកយើងនឹងក្រាបទូលគុណដែលខ្លួនបានហើយដល់ព្រះមាន ព្រះភាគ បានត្រឡប់ទៅកាន់ក្រុងសាវត្ថី ។ ឧបាសកម្នាក់ឃើញភិក្ខុទាំងនោះ

ដែលត្រាច់បិណ្ឌបាតនៅក្នុងស្រុកមួយកន្លែង ក្នុងទីប្រមាណមួយយោជន៍អំពីក្រុងសាវត្ថី ទើបទទួលដោយវត្ថុទាំងឡាយ មានបបរ និងភត្តជាដើម បានស្តាប់អនុមោទនាហើយ ទើបនិមន្តដើម្បីប្រយោជន៍ដល់ការឆាន់ក្នុងថ្ងៃស្អែកឡើង ភិក្ខុទាំងនោះ ទៅដល់ក្រុងសាវត្ថីក្នុងថ្ងៃនោះឯង ទុកដាក់បាត្រ និងចីវរហើយ ក្នុងពេលល្ងាច ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំអង្គុយហើយ ។ ព្រះសាស្តាទ្រង់សម្តែងសេចក្តីត្រេកអរក្រៃលែង ជាមួយភិក្ខុទាំងនោះ ទ្រង់បានធ្វើការទទួលហើយ ។

ខណៈនោះ ភិក្ខុសម្លាញ់នៃភិក្ខុទាំងនោះ ដែលសល់ក្នុងទីនោះ គិតថា កាលព្រះសាស្តា ទ្រង់ធ្វើការទទួលភិក្ខុទាំងនោះ ព្រះឧស្សាហ៍មែងមិនគ្រប់គ្រាន់ តែមិនត្រាស់ប្រាស្រ័យជាមួយអញឡើយ ព្រោះមគ្គ និងផលរបស់អញមិនមាន ។ ក្នុងថ្ងៃនេះឯង អញសម្រេចអរហត្ត នឹងឲ្យព្រះសាស្តាប្រាស្រ័យជាមួយអញ ភិក្ខុទាំងនោះទូលលាព្រះសាស្តាថា ពួកខ្ញុំព្រះអង្គ កាលឧបាសកម្នាក់ក្នុងផ្លូវដែលជាទីមក និមន្តដើម្បីឆាន់ក្នុងពេលព្រឹកស្អែកនេះ នឹងទៅក្នុងទីនោះអំពីព្រលឹម ។ លំដាប់នោះ ភិក្ខុដែលសម្លាញ់នៃភិក្ខុទាំងនោះ ដើរចង្ក្រមមួយយប់ទល់ភ្លឺ ដួលចុះត្រង់ផ្ទាំងថ្មមួយផ្ទាំងក្នុងទីបំផុតនៃទីចង្ក្រម ដោយអំណាចការដេកលក់ ។ ឆ្អឹងស្ទងក៏បាក់ លោកស្រែកដោយសំឡេងខ្លាំង ។

ពួកភិក្ខុជាសម្លាញ់ទាំងនោះរបស់លោកចាំសំឡេងបាន ស្ទុះចូលទៅក្នុងទីនោះទីនេះ ។ អុជប្រទីបធ្វើកិច្ចដែលគួរធ្វើដល់ភិក្ខុនោះឯង ។ អរុណរះឡើង

ហើយ ភិក្ខុទាំងនោះក៏មិនបានឱកាសទៅកាន់ស្រុកនោះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនទៅកាន់ស្រុក ដែលត្រាច់ភិក្ខាទេឬ ភិក្ខុទាំងនោះទូលថា យ៉ាង នោះឯង ព្រះអង្គ ហើយក្រាបទូលរឿងនោះ ។ ព្រះសាស្តាត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ ភិក្ខុនោះធ្វើអន្តរាយលាភរបស់ពួកអ្នក តែក្នុងឥឡូវនេះ ប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ធ្វើហើយដូចគ្នា ។ កាលភិក្ខុទាំង នោះទូលអារាធនាហើយ ទ្រង់នាំអតីតនិទានមក ត្រាស់ជាតកឲ្យពិស្តារថា

អំពើទាំងឡាយ ដែលគេត្រូវធ្វើក្នុងកាលមុន នរណា
ប្រាថ្នាធ្វើខាងក្រោយវិញ នរនោះ រមែងក្តៅក្រហាយ
រឿយៗ ក្នុងកាលជាខាងក្រោយ ដូចជាមាណពដែលកាច់
ឧសឈើថ្វាន់ ។

បានឮថា ភិក្ខុទាំងនោះបានជាមាណព ៥០០ ក្នុងកាលមុន មាណពដែល ខ្ជិលច្រអូសបានជាភិក្ខុនេះ ចំណែកអាចារ្យបានជាតថាគតដោយប្រការដូច្នេះ ។

ព្រះសាស្តា កាលទ្រង់នាំព្រះទេសនានេះមកហើយត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ បុគ្គលណាមិនធ្វើការខ្មីឃ្មាត ក្នុងកាលដែលគួរខ្មីឃ្មាត ជាអ្នក មានការត្រិះរិះលិចចុះហើយ ជាបុគ្គលខ្ជិលច្រអូស បុគ្គលនោះរមែងមិនសម្រេច គុណវិសេស មានឈានជាដើម ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ យុវា ពលី អាលសិយំ ឧបេតោ**
**សំសន្នសង្កប្បមនោ កុសីតោ បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។**

បុគ្គលនៅកំលោះ មានកម្លាំង ទាស់តែប្រកបដោយសេចក្ដីខ្ជិល
ប្រអូស មិនប្រឹងប្រែង ក្នុងកាលដែលគួរប្រឹងប្រែង មានសេចក្ដី
ត្រិះរិះក្នុងចិត្តលិចចុះ ក្នុងអកុសលវិតក្ក ជាមនុស្សខ្ជិល បុគ្គល
ខ្ជិល ( នោះ ) រមែងមិនបានផ្លូវបញ្ញាឡើយ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **អនុដ្ឋហានោ** សេចក្ដីថា មិនប្រឹងប្រែង គឺមិនព្យាយាម ។ ពីរបទថា **យុវា ពលី** សេចក្ដីថា ជាអ្នកតាំងនៅក្នុងភាពជាកំលោះ ដល់ព្រមដោយកម្លាំង ។ ពីរបទថា **អាលសិយំ ឧបេតោ** សេចក្ដីថា រមែងជាបុគ្គលចូលដល់ហើយនូវភាពជាអ្នកខ្ជិលប្រអូស គឺស៊ីហើយដេក ដេកហើយស៊ី ។ បទថា **សំសន្នសង្កប្បមនោ** សេចក្ដីថា បុគ្គលមានចិត្តប្រកបដោយការត្រិះរិះដែលលិចចុះ គឺលិចចុះហើយ ព្រោះមិច្ឆាវិតក្ក ៣ ។ បទថា **កុសីតោ** បានដល់ មិនមានសេចក្ដីព្យាយាម ។ បទថា **អលសោ** សេចក្ដីថា បុគ្គលនោះខ្ជិលប្រអូសច្រើន កាលមិនឃើញអរិយមគ្គ គប្បីឃើញដោយបញ្ញា ទើបឈ្មោះថារមែងមិនជួប គឺមិនបាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៙

**រឿង បធានកម្មិកតិស្សត្ថេរ ចប់**

# រឿង សូករប្រេត

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសូករប្រេត ត្រាស់ព្រះធម្មទេសនានេះថា **វាចានុរក្ខី** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះមហាមោគ្គល្លាន ចុះអំពីភ្នំគិជ្ឈកូដជាមួយព្រះលក្ខណៈ បានធ្វើការញញឹមក្នុងទីមួយកន្លែង កាលព្រះលក្ខណៈសួរថា អាវុសោ ព្រោះហេតុអ្វីហ្ន៎ ជាហេតុនៃការញញឹមឲ្យប្រាកដ ក៏ពោលថា អាវុសោ កាលនេះមិនមែនជាកាលនៃការសួរបញ្ហានេះ ចូរលោកសួរក្នុងសម្នាក់របស់ព្រះសាស្តា ដូច្នេះហើយ ត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះជាមួយព្រះលក្ខណត្ថេរនោះឯង ត្រឡប់អំពីបិណ្ឌបាតហើយ ទៅកាន់វត្តវេឡុវ័ន ថ្វាយបង្គំព្រះសាស្តាហើយអង្គុយ ។

គ្រានោះ ព្រះលក្ខណៈសួរសេចក្តីនោះ លោកក៏ពោលថា អាវុសោ ខ្ញុំឃើញប្រេតមួយ សរីរៈរបស់ប្រេតនោះប្រមាណ ៣ គាវុត សរីរៈនោះស្រដៀងនឹងរាងកាយរបស់មនុស្ស ចំណែកក្បាលដូចក្បាលរបស់ជ្រូក កន្ទុយដុះចេញអំពីមាត់ ពួកដង្កូវហូរចេញអំពីមាត់នោះ ខ្ញុំគិតថា ខ្ញុំមិនធ្លាប់ឃើញសត្វមានរូបយ៉ាងនេះ កាលឃើញប្រេតនោះហើយ ទើបធ្វើការញញឹមឲ្យប្រាកដ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកសាវ័ករបស់តថាគតមានចក្ខុហ្ន៎ ហើយត្រាស់ថា សូម្បីតថាគតក៏បានឃើញសត្វនោះ ត្រង់មណ្ឌលនៃពោធិព្រឹក្សដូចគ្នា តែមិននិយាយដោយអនុគ្រោះដល់ជនដទៃថា ជនពួកណាមិនគប្បីជឿតថាគត ការមិនជឿនោះ គប្បីមានកម្មដែលមិនជាប្រយោជន៍ដល់

ជនទាំងនោះ ។ ឥឡូវនេះ តថាគតបានមោគ្គល្លានជាសាក្សីទើបពោល ម្នាល
ភិក្ខុទាំងឡាយ មោគ្គល្លាននិយាយពិត ។

ភិក្ខុទាំងឡាយស្តាប់រឿងនេះហើយ ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ
បុព្វកម្មរបស់ប្រេតនោះដូចម្តេច ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើ
យ៉ាងនោះ ចូរពួកអ្នកស្តាប់ចុះ ហើយទ្រង់នាំអតីតនិទានមក ត្រាស់បុព្វកម្ម
របស់ ប្រេតនោះដូចតទៅនេះ ។

បានឮមកថា ក្នុងសាសនារបស់ព្រះពុទ្ធកស្សបៈ ព្រះថេរៈពីររូបព្រម
ព្រៀងគ្នាក្នុងអាវាសជិតភូមិមួយកន្លែង ។ ក្នុងព្រះថេរៈពីររូបនោះ មួយរូបមាន
វស្សា ៦០ មួយរូបមានវស្សា ៥៩ ភិក្ខុដែលមានវស្សា ៥៩ នោះកាន់បាត្រ
និងចីវររបស់ព្រះថេរៈត្រាច់ទៅ បានធ្វើវត្តបដិបត្តិគ្រប់យ៉ាងដូចសាមណេរ ។
ព្រះថេរៈទាំងពីររូបនៅព្រមព្រៀងគ្នាដូចបងប្អូន ដែលរួមផ្ទៃមាតាតែមួយ ព្រះ
ធម្មកថិកមួយរូប មកកាន់លំនៅរបស់ព្រះថេរៈទាំងពីរហើយ ។ ក្នុងកាលនោះ
ជាថ្ងៃស្តាប់ធម៌ ព្រះថេរៈទាំងពីរសង្គ្រោះព្រះធម្មកថិកហើយពោលថា សប្បុរស
ចូរលោកពោលធម្មកថាដល់ពួកយើងចុះ ព្រះធម្មកថិកនោះ ក៏ពោលធម្មកថា
ហើយ ព្រះថេរៈទាំងពីរមានចិត្តត្រេកអរថា ពួកយើងបានព្រះធម្មកថិកហើយ
ស្អែកឡើង នាំលោកចូលទៅបិណ្ឌបាតក្បែរស្រុកជិតនោះ ធ្វើភត្តកិច្ចស្រេច
ក្នុងស្រុកនោះហើយពោលថា អាវុសោ សូមលោកពោលធម្មកថាបន្តិចអំពីទី
ដែលសម្រាកកាលពីម្សិលមិញ ហើយនិមន្តឲ្យលោកពោលធម៌ដល់ពួកមនុស្ស
ពួកមនុស្សស្តាប់ធម្មកថាហើយ និមន្តឲ្យឆាន់ក្នុងថ្ងៃស្អែក ព្រះថេរៈទាំងពីរនាំ

ព្រះធម្មកថិកនោះត្រាច់បិណ្ឌបាតក្នុងស្រុក ដែលជាទីត្រាច់ភិក្ខា ក្នុងស្រុក ២ ឬ ៣ ថ្ងៃដោយជុំវិញយ៉ាងនេះ ។ ព្រះធម្មកថិកគិតថា ព្រះថេរៈពីររូបនេះ ទាន់ភ្ញាក់ក្រៃលែង បើអញឲ្យព្រះថេរៈទាំងពីររូបនេះគេចទៅ ហើយនៅក្នុងវត្តនេះ គួរ ។ ក្នុងថ្ងៃល្ងាច លោកទៅកាន់ទីបម្រើរបស់ព្រះថេរៈ ក្នុងកាលដែលភិក្ខុទាំងពីរក្រោកទៅហើយ ត្រឡប់ចូលទៅរកព្រះមហាថេរៈ ពោលថា បពិត្រលោកម្ចាស់ រឿងខ្លះដែលខ្ញុំគួរពោលមាន កាលព្រះមហាថេរៈពោលថា អាវុសោ ចូរពោលចុះ ភិក្ខុនោះគិតបន្តិចហើយពោលថា បពិត្រលោកម្ចាស់ ឈ្មោះថា ការពោល មានទោសច្រើន មិននិយាយហើយចៀសចេញទៅ ព្រះធម្មកថិកនោះ ទៅកាន់សម្នាក់របស់ព្រះអនុត្ថេរ ក៏បានធ្វើយ៉ាងនោះដូចគ្នា ។ ក្នុងថ្ងៃទីពីរ លោកក៏ធ្វើយ៉ាងនោះដដែល ។ ក្នុងថ្ងៃទីបី កាលការអល់អែកកើតឡើងដល់ព្រះថេរៈទាំងពីរនោះហើយ ចូលទៅរកព្រះមហាថេរៈ ហើយពោលថា បពិត្រលោកម្ចាស់ ពាក្យខ្លះដែលខ្ញុំគួរពោល មាន តែខ្ញុំមិនអាចពោលក្នុងសម្នាក់របស់លោកម្ចាស់បាន ត្រូវព្រះថេរៈដេញដោលថា អាវុសោ មិនជាការអ្វីទេ ចូរនិយាយចុះ ទើបពោលថា បពិត្រលោកម្ចាស់ ហេតុអ្វីទើបអនុត្ថេរមិនត្រូវជាមួយលោកម្ចាស់ ព្រះមហាថេរៈពោលថា សប្បុរស អ្នកពោលអ្វី យើងទាំងពីរដូចគ្នានឹងកូន ដែលនៅពោះម៉ែតែមួយ ខ្ញុំទាំងពីររូប មួយរូបបានរបស់ហើយ មួយរូបក្រៅអំពីនេះក៏បានដូចគ្នា ទោសរបស់ព្រះថេរៈនោះដែលខ្ញុំធ្លាប់ឃើញ មិនមាន អស់កាលមានប្រមាណប៉ុណ្ណោះ ព្រះថេរៈធម្មកថិកពោលថា បពិត្រលោកម្ចាស់ យ៉ាងនោះឬ ព្រះមហាថេរៈ

ពោលថា អាវុសោ យ៉ាងនោះឯង ព្រះធម្មកឋិកពោលថា បពិត្រលោកម្ចាស់ ព្រះអនុត្ថេរពោលនឹងខ្ញុំយ៉ាងនេះថា សប្បុរស លោកជាកុលបុត្រ លោកកុំធ្វើការគប់រកព្រះមហាថេរៈនោះ ដោយធ្វើក្នុងចិត្តថា ព្រះមហាថេរៈនេះមានការខ្មាសបាប មានសីលជាទីស្រឡាញ់ គួរពិចារណាហើយសឹមធ្វើ តាំងអំពីថ្ងៃដែលខ្ញុំមកដល់ ព្រះអនុត្ថេរនោះពោលនឹងខ្ញុំយ៉ាងនេះ ។

ព្រះថេរៈគ្រាន់តែស្តាប់ពាក្យនោះ មានចិត្តក្រោធអាក់អន់បែកហើយដូចភាជនៈដែលធ្វើដោយដី ដែលបុគ្គលជំដោយឈើដូច្នោះ ។ ព្រះធម្មកឋិកក្រោកទៅកាន់សម្នាក់របស់ព្រះអនុត្ថេរ ហើយពោលយ៉ាងនោះ ។ សូម្បីព្រះអនុត្ថេរក៏បានបែកយ៉ាងនោះដូចគ្នា ។ ក្នុងព្រះថេរៈពីររូបនោះ មួយរូបឈ្មោះថាធ្លាប់បែកគ្នាចូលទៅបិណ្ឌបាត មិនមាន អស់កាលមានប្រមាណប៉ុណ្ណេះក៏ពិតតែក្នុងថ្ងៃស្អែកឡើង ព្រះថេរៈទាំងពីរបានបែកគ្នាទៅបិណ្ឌបាត ព្រះអនុត្ថេរមកដល់មុន បានឈរត្រង់សាលា ជាទីបម្រើ ព្រះមហាថេរៈ មកដល់ខាងក្រោយ ព្រះអនុត្ថេរឃើញលោកហើយ គិតថា អញគួរទទួលបាត្រ និងចីវររបស់ព្រះថេរៈនេះដែរឬហ្ន៎ លោក សូម្បីគិតថា ឥឡូវនេះ នឹងមិនទទួលដូច្នេះហើយ ក៏គង់ធ្វើចិត្តឲ្យទន់បាន ដោយធ្វើក្នុងចិត្តថា ណ្ហើយចុះ កម្មបែបនេះ អញមិនធ្លាប់ធ្វើ ការដែលញុំាងវត្តរបស់ខ្លួនឲ្យខូច មិនគួរ ដូច្នេះហើយចូលទៅរកព្រះថេរៈ ពោលថា បពិត្រលោកម្ចាស់ សូមឲ្យបាត្រ និងចីវរមកចុះ ព្រះថេរៈយកដៃកៀសចេញ ពោលថា ទៅចុះ អាវុសោ អ្នកមិនគួរទទួលបាត្រ និងចីវររបស់ខ្ញុំទេ ។ កាលអនុត្ថេរពោលថា ពិតឬ លោកម្ចាស់

ខ្ញុំក៏គិតហើយថា នឹងមិនទទួលបាត្រ និងចីវររបស់លោក ទើបពោលថា អាវុសោ ហេតុអ្វី ទើបលោកគិតថា ការទាក់ទងណាមួយក្នុងវិហារនេះរបស់យើង មាន ។ សូម្បីអនុត្ថេរក៏ពោលថា បពិត្រលោកម្ចាស់ ហេតុអ្វី ទើបលោកសម្គាល់យ៉ាងនេះថា ការទាក់ទងណាមួយក្នុងវិហារនេះរបស់ពួកយើងមាន នេះជាវិហាររបស់លោក ហើយកាន់បាត្រ និងចីវរចេញទៅ ។ សូម្បីព្រះមហាថេរៈ ក៏បានចេញទៅដូចគ្នា ។

ព្រះថេរៈទាំងពីររូបនោះ មិនទៅផ្លូវតែមួយ មួយរូបកាន់យកផ្លូវទៅទិសខាងលិច មួយរូបកាន់យកផ្លូវទៅទិសខាងកើត ។ ព្រះធម្មកបិកពោលថា បពិត្រលោកម្ចាស់ សូមកុំធ្វើយ៉ាងនេះ សូមកុំធ្វើយ៉ាងនេះ កាលព្រះថេរៈពោលថា អាវុសោ ចូរឈប់ចុះ ហើយត្រឡប់ ។ ស្អែកឡើង ព្រះធម្មកបិកនោះ ចូលទៅស្រុកក្បែរៗ កាលពួកមនុស្សពោលថា លោកម្ចាស់ទាំងពីរទៅណា ក៏ពោលថា នែអ្នកទាំងឡាយ សូមអ្នកកុំសួរឡើយ លោកម្ចាស់ក្នុងត្រកូលរបស់ពួកអ្នក ម្សិលមិញនេះឈ្លោះគ្នាហើយចេញទៅ អាត្មាឃាត់ក៏មិនត្រឡប់ ។មនុស្សទាំងនោះ ជនដែលល្ងង់ខ្លៅក៏នៅស្ងៀម ចំណែកមនុស្សដែលឈ្លាសវៃគិតថា ឈ្មោះថា កំហុសណាមួយរបស់លោកម្ចាស់ទាំងពីរ យើងមិនធ្លាប់ឃើញអស់កាលមានប្រមាណប៉ុណ្ណេះ ភ័យកើតឡើងដល់លោកម្ចាស់ទាំងពីរនោះ គង់កើតឡើងព្រោះអាស្រ័យធម្មកបិករូបនេះ ហើយបានជាអ្នកដល់នូវការអាក់អន់ចិត្ត ។ ព្រះថេរៈទាំងនោះ មិនបាននូវការសប្បាយចិត្ត ក្នុងទីដែលទៅហើយ ព្រះមហាថេរៈគិតថា ឱ ! កម្មរបស់អាវុសោ ធ្ងន់ ព្រោះលោកនិយាយនឹង

អាគន្តុកៈដែលខ្លួនឃើញត្រឹមមួយរំពេចថា លោកកុំធ្វើការគប់រកព្រះមហាថេរៈ ។ សូម្បីព្រះអនុត្ថេរក៏បានគិតថា ឱ ! កម្មរបស់ព្រះមហាថេរៈធ្ងន់ លោកបាននិយាយនឹងអាគន្តុកៈ ដែលខ្លួនឃើញហើយត្រឹមតែមួយរំពេចថា លោកកុំគប់រកព្រះអនុត្ថេរនេះ ។ ការស្វាធ្យាយ និងយោនិសោមនសិការ មិនមានដល់ព្រះថេរៈទាំងពីរនោះ ។ ពេលវេលាកន្លងទៅមួយរយឆ្នាំ ព្រះថេរៈទាំងពីរនោះបានទៅកាន់វិហារមួយ ក្នុងបច្ចិមប្បទេស សេនាសនៈជាមួយគ្នានោះឯង ត្រូវបានដល់ព្រះថេរៈទាំងពីរនោះ ។ កាលព្រះមហាថេរៈចូលទៅអង្គុយលើគ្រែហើយ ព្រះអនុត្ថេរក៏បានចូលទៅ ។ ព្រះមហាថេរៈឃើញអនុត្ថេរនោះក៏ចាំបាន មិនអាចទប់ទឹកភ្នែកបាន សូម្បីព្រះអនុត្ថេរក៏ចាំព្រះមហាថេរៈបាន មានភ្នែកពេញហើយដោយទឹកភ្នែក គិតថា អញគួរពោលឬមិនពោលហ្ន៎ ហើយគិតថា ការទុំមិនគួរជឿ ហើយថ្វាយបង្គំព្រះថេរៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំកាន់បាត្រ និងចីវរដើរ តាមលោកម្ចាស់អស់កាលប្រមាណប៉ុណ្ណេះ មារយាទដែលមិនសមគួរណាមួយ ក្នុងទ្វារទាំង ៦ មានកាយទ្វាររបស់ខ្ញុំ លោកម្ចាស់ធ្លាប់ឃើញហើយឬ ព្រះថេរៈពោលថា អាវុសោ ខ្ញុំមិនធ្លាប់ឃើញទេ ព្រះអនុត្ថេរពោលថា បើដូច្នោះ ហេតុអ្វី ទើបលោកម្ចាស់និយាយនឹងធម្មកថិកថា កុំធ្វើការសេពគប់ជាមួយព្រះអនុត្ថេរនោះ ព្រះមហាថេរៈពោលថា អាវុសោ ខ្ញុំនិយាយយ៉ាងនោះបានដូចម្ដេច បានឮថា លោកពោលយ៉ាងនេះក្នុងរវាងខ្ញុំ អនុត្ថេរពោលថា បពិត្រលោកម្ចាស់ ខ្ញុំក៏មិនបានពោល ។ ក្នុងខណៈនោះ ព្រះថេរៈទាំងពីរនោះ ក៏ដឹងបានថា ព្រះ

ធម្មកថិកនោះ ប្រាថ្នាបំបែកយើងទាំងពីរ ទើបពោលយ៉ាងនោះ ហើយញ៉ាំង គ្នានិងគ្នាឲ្យសម្តែងទោសហើយ ។ ព្រះថេរៈទាំងពីរនោះ មិនបានទទួលការ សប្បាយចិត្តអស់កាលមួយរយឆ្នាំ ជាអ្នកព្រមព្រៀងគ្នាក្នុងថ្ងៃនោះ បបួលគ្នា ថា មកយើងនឹងអូសធម្មកថិកនោះ ចេញអំពីវិហារនោះ ហើយធ្វើដំណើរទៅ ដល់វិហារនោះ ដោយលំដាប់ ។ ព្រះធម្មកថិកឃើញព្រះថេរៈទាំងពីរហើយ ចូលទៅជិតដើម្បីទទួលបាត្រ និងចីវរ ព្រះថេរៈទាំងពីរពោលថា លោកមិន គួរនៅក្នុងវិហារនេះឡើយ ។ ព្រះធម្មកថិកនោះមិនអាចតាំងនៅបាន គេច ចេញទៅមួយរំពេចនោះឯង ។ គ្រានោះ សមណធម៌ដែលលោកបំពេញអស់ ២ ម៉ឺនឆ្នាំ មិនអាចទ្រទ្រង់បាន លោកឃ្លាតចាកអត្តនោះហើយ កើតក្នុង អវិចីអស់ ១ ពុទ្ធន្តរ មានអត្តភាព មានប្រការដូចពោលហើយ សោយទុក្ខ ត្រង់ភ្នំគិជ្ឈកូដក្នុងឥឡូវនេះ ។

ព្រះសាស្តាត្រាស់បុព្វកម្មនេះ របស់សូករប្រេតនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុ គប្បីជាអ្នកចូលទៅស្ងប់ដោយកាយជាដើម ហើយត្រាស់ព្រះគាថានេះថា

**វាចានុរក្ខី មនសា សុសំវុតោ កាយេន ច អកុសលំ ន កយិរា**
**ឯតេ តយោ កម្មបថេ វិសោធយេ អារាធយេ មគ្គំ ឥសិប្បវេទិតំ ។**

បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមឲ្យល្អដោយចិត្ត ទាំងមិនគប្បីធ្វើ អកុសលដោយកាយ បុគ្គលគប្បីជម្រះកម្មបថទាំង ៣ នេះ នឹងគប្បី ត្រេកអរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណដ៏ល្អសម្តែងហើយ ។

## សេចក្ដីអធិប្បាយ

សេចក្ដីនៃគាថានោះថា បុគ្គលឈ្មោះថាមានប្រក្រតីតាមរក្សាវាចា ព្រោះវៀរទុច្ចរិត ៤ ឈ្មោះថា សង្រួមចិត្តហើយដោយល្អ ព្រោះមិនញុំាងមនោ-ទុច្ចរិត មានអភិជ្ឈាជាដើមឲ្យកើតឡើង កាលកាយទុច្ចរិត មានបាណាតិបាតជាដើម ឈ្មោះថា មិនគួរធ្វើអកុសលដោយកាយ គប្បីញុំាងកម្មបថ ៣ ឲ្យបរិសុទ្ធដោយអាការយ៉ាងនេះ កាលឲ្យបរិសុទ្ធបានយ៉ាងនោះ ឈ្មោះថា គប្បីត្រេកអរក្នុងមគ្គមានអង្គ ៨ ដែលលោកអ្នកស្វែងរកគុណទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ស្វែងរកគុណ គឺសីលជាដើម ប្រកាសហើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

### រឿង សូករប្រេត ចប់

## រឿង ព្រះបោឋិលត្ថេរ

### លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះថាបោឋិលៈ ត្រាស់ព្រះធម្មទេសនានេះថា **យោគា វេ** ជាដើម ។

បានឮមកថា ព្រះបោឋិលៈនោះ ទ្រទ្រង់ព្រះត្រៃបិដកក្នុងសាសនាព្រះពុទ្ធ ៧ អង្គ បង្រៀនធម៌ដល់ភិក្ខុ ៥០០ រូប ព្រះសាស្ដាទ្រង់ត្រិះរិះថា ភិក្ខុនេះមិនមានការគិតថា អញនឹងធ្វើការរលាស់ចេញចាកទុក្ខដល់ខ្លួន តថាគតនឹង

ញ៉ាំងគេឲ្យសង្វេគ ។

ចាប់តាំងអំពីនោះមក ព្រះសាស្តាត្រាស់នឹងព្រះថេរៈនោះ ក្នុងពេលដែលព្រះថេរៈមកកាន់ទីបម្រើថា មកចុះភិក្ខុស្ទឹកទំរីតទទេ អង្គុយចុះភិក្ខុស្ទឹកទំរីតទទេ ទៅចុះភិក្ខុស្ទឹកទំរីតទទេ ក្នុងកាលដែលព្រះថេរៈក្រោកទៅ ក៏ត្រាស់ថា ភិក្ខុស្ទឹកទំរីតទទេទៅហើយ ព្រះបោឋិលៈនោះគិតថា អញទ្រទ្រង់នូវព្រះត្រៃបិដក មួយអន្លើដោយអដ្ឋកថា ប្រាប់ធម៌ដល់ភិក្ខុ ៥០០ រូប រហូតដល់ ១៨ មហាគណៈ កាលបើដូច្នោះ ព្រះសាស្តាត្រាស់ហៅអញរឿយៗ ថា ភិក្ខុស្ទឹកទំរីតទទេ ព្រះដ៏មានព្រះភាគត្រាស់ ហៅអញយ៉ាងនេះ ព្រោះមិនមានគុណវិសេស មានឈានជាដើមពិត ។ លោកមានសេចក្តីសង្វេគកើតឡើងហើយ ទើបគិតថា ឥឡូវនេះ អញនឹងចូលទៅកាន់ព្រៃហើយធ្វើសមណធម៌ ចាត់ចែងបាត្រ និងចីវរឯង ហើយបានចេញទៅ មួយអន្លើដោយភិក្ខុដែលរៀនធម៌ ហើយចេញទៅខាងក្រោយភិក្ខុនោះទាំងអស់ក្នុងពេលទៀបភ្លឺ ។ ពួកភិក្ខុនោះ ស្វាធ្យាយក្នុងបរិវេណ មិនបានកំណត់លោកថាជាអាចារ្យ ព្រះថេរៈទៅអស់ចម្ងាយ ១២០ យោជន៍ហើយ ។ ចូលទៅរកភិក្ខុ ៣០ រូប ដែលនៅក្នុងអាវាស ក្នុងដងព្រៃមួយកន្លែង ថ្វាយបង្គំព្រះសង្ឃត្ថេរហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ជាទីពឹងរបស់ខ្ញុំ ។ ព្រះសង្ឃត្ថេរពោលថា អាវុសោ លោកជាព្រះធម្មកថិក វត្តណាមួយ ឈ្មោះថា ពួកខ្ញុំគប្បីដឹងបាន ក៏ព្រោះអាស្រ័យលោក ហេតុអ្វី ទើបពោលយ៉ាងនេះ ព្រះបោឋិលៈពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំធ្វើយ៉ាងនេះ សូមលោក

ម្ចាស់ជាទីពឹងរបស់ខ្ញុំចុះ ។

ព្រះថេរៈទាំងនោះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ ។ លំដាប់នោះ ព្រះមហាថេរៈបញ្ជូនព្រះបោឋិលៈនោះ ទៅកាន់សម្នាក់ព្រះអនុត្ថេរ ដោយគិតថា ភិក្ខុនេះមានមានះព្រោះអាស្រ័យចំណេះដឹងពិត សូម្បីអនុត្ថេរនោះក៏ពោលនឹងព្រះបោឋិលៈនោះយ៉ាងនោះដូចគ្នា ។ សូម្បីព្រះថេរៈទាំងអស់ កាលបញ្ជូនលោកទៅដោយទំនងនេះ ក៏បញ្ជូនទៅកាន់សម្នាក់របស់សាមណេរ អាយុ ៧ ឆ្នាំ ដែលបួសថ្មីជាងសាមណេរទាំងអស់ ដែលអង្គុយធ្វើចីវរកម្មក្នុងទីសម្រាកពេលថ្ងៃ ។ ព្រះថេរៈទាំងឡាយ នាំមានះរបស់លោកចេញបានដោយឧបាយយ៉ាងនេះ ។

ព្រះបោឋិលៈនោះ មានមានះដែលព្រះថេរៈទាំងឡាយ នាំចេញហើយ ទើបផ្គងអញ្ជលីក្នុងសម្នាក់របស់សាមណេរ ហើយពោលថា សប្បុរស សូមលោកជាទីពឹងរបស់ខ្ញុំ សាមណេរពោលថា ឱហ្ន៎លោកអាចារ្យ លោកនិយាយអ្វី លោកជាថេរៈ ជាពហុសូត ហេតុណាមួយគប្បីជាកិច្ចដែលខ្ញុំគួរដឹង ក៏ដឹងក្នុងសម្នាក់របស់លោកម្ចាស់ ព្រះបោឋិលៈពោលថា សប្បុរស លោកកុំធ្វើយ៉ាងនេះ សូមលោកជាទីពឹងរបស់ខ្ញុំចុះ សាមណេរពោលថា លោកម្ចាស់ បើលោកម្ចាស់អត់ធន់ចំពោះឱវាទបានសោត ខ្ញុំនឹងជាទីពឹងរបស់លោកម្ចាស់ ព្រះបោឋិលៈពោលថា សប្បុរស ខ្ញុំធ្វើបាន កាលលោកពោលថា សូមចូលទៅកាន់ភ្លើង ខ្ញុំនឹងចូលទៅកាន់ភ្លើងនោះឯង ។

គ្រានោះ ទើបសាមណេរបង្ហាញស្រះមួយក្នុងទីមិនឆ្ងាយ ហើយពោល

ថា លោកម្ចាស់ លោកម្ចាស់ស្លៀកដូចប្រក្រតីនោះឯង ចុះក្នុងស្រះនេះ ។ ពិតហើយ សាមណេរនោះដឹងភាពដែលចីវរពីរជាន់ មានតម្លៃច្រើន ព្រះថេរៈស្លៀកដណ្តប់ហើយ កាលសាកល្បងថា ព្រះថេរៈជាអ្នកអត់ធន់ចំពោះឱវាទមែនឬទេ ទើបពោលយ៉ាងនោះ ។ ព្រះថេរៈក៏ចុះទៅ ដោយពាក្យត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ ។ លំដាប់នោះ ក្នុងកាលដែលជាយចីវរសើម ទើបសាមណេរពោលថា មកចុះ លោកម្ចាស់ ហើយពោលនឹងលោកដែលមកឈរដោយពាក្យមួយម៉ាត់ប៉ុណ្ណោះថា លោកម្ចាស់ ក្នុងដំបូកមួយ មានរន្ធ ៦ ក្នុងរន្ធនោះ ទន្សងចូលទៅខាងក្នុងរន្ធនីមួយៗ បុគ្គលប្រាថ្នានឹងចាប់ទន្សងទើបចុករន្ធទាំង ៥ ក្រៅអំពីនេះ បើករន្ធទី ៦ ហើយទើបចាប់យកដោយរន្ធដែលវាចូលទៅនោះឯង បណ្តាទ្វារទាំង ៦ សូមលោកបិទទ្វារ ៥ យ៉ាងនោះហើយ សូមផ្តើមនូវកម្មនេះក្នុងមនោទ្វារ ។ ដោយន័យមានប្រមាណប៉ុណ្ណោះការជាក់ច្បាស់មានដល់ភិក្ខុដែលជាពហូសូត ដូចការឆេះឡើងនៃដួងប្រទីបដូច្នោះ ។ ព្រះបោឋិលៈនោះពោលថា សប្បុរស ពាក្យមានប្រមាណប៉ុណ្ណោះឯង សមល្មមហើយ ទើបឈមចុះក្នុងករជកាយ ប្រារព្ធសមណធម៌ ។

ព្រះសាស្តាប្រថាប់គង់ក្នុងទីបំផុតប្រមាណ ១២០ យោជន៍នោះឯង ទតមើលភិក្ខុនោះហើយត្រិះរិះថា ភិក្ខុនោះជាអ្នកមានបញ្ញាដូចផែនដី ដោយប្រការណា កាលដែលលោកតម្កល់ខ្លួនដោយប្រការនោះឯង សមគួរ ។ ហើយទ្រង់បញ្ចេញព្រះរស្មីទៅហាក់ដូចត្រាស់ជាមួយភិក្ខុនោះ ដោយព្រះគាថានេះថា

**យោគា វេ ជាយតី ភូរិ អយោគា ភូរិសង្ខយោ**
**ឯតំ ទ្វេធា បថំ ញត្វា ភវាយ វិភវាយ ច**
**តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ ។**

*ប្រាជ្ញា រមែងកើតពីការប្រកប សេចក្ដីវិនាសប្រាជ្ញា រមែងកើតអំពីការមិនប្រកប អ្នកមានប្រាជ្ញាដឹងការប្រកប និងការមិនប្រកបទាំងពីរនេះថា ជាគន្លងនៃសេចក្ដីចម្រើន និងសេចក្ដីវិនាសហើយ ប្រាជ្ញាចម្រើនឡើងដោយប្រការណា គួរតម្កល់ខ្លួន ដោយប្រការនោះ ។*

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **យោគា** សេចក្ដីថា ព្រោះការធ្វើទុកក្នុងចិត្តដោយយោនិសោមនសិការ ក្នុងអារម្មណ៍ ៣៨ ។

ពាក្យថា **ភូរិ** នោះ ជាឈ្មោះនៃបញ្ញាដែលទូលំទូលាយ ស្មើដោយផែនដី សេចក្ដីវិនាស ឈ្មោះថា **សង្ខយោ** ។ ពីរបទថា **ឯតំ ទ្វេធា បថំ** គឺនូវការប្រកប និងការមិនប្រកបនោះ ។ បាទព្រះគាថាថា **ភវាយ វិភវាយ ច** គឺនៃការចម្រើន និងការមិនចម្រើន ។ បទថា **តថត្តានំ** សេចក្ដីថា បណ្ឌិតគប្បីតម្កល់ខ្លួន ដោយប្រការដែលបញ្ញា ពោល គឺ **ភូរិ** នេះ នឹងចម្រើនឡើងបាន ។ ក្នុងកាលចប់ទេសនា ព្រះបោឋិលត្ថេរ តាំងនៅក្នុងអរហត្តហើយ ដូច្នេះឯង ។l៚

**រឿងព្រះបោឋិលត្ថេរ ចប់**

# រឿង ព្រះថេរៈចាស់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចាស់ច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **វជ្ជំ ជិណ្ណេ** ជាដើម ។

បានឮថា ភិក្ខុទាំងនោះ ក្នុងពេលជាគ្រហស្ថ ជាកុដុម្ពិកៈ ជាអ្នកមានស្តុកស្តម្ភ មានទ្រព្យច្រើនក្នុងក្រុងសាវត្ថី ជាសម្លាញ់នឹងគ្នា ធ្វើបុណ្យរួមគ្នា ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ គិតថា ពួកយើងជាមនុស្សចាស់ ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះរបស់ពួកយើង ដូច្នេះហើយ ទូលសូមបព្វជ្ជាជាមួយព្រះសាស្តា បួសហើយ តែព្រោះភាពជាមនុស្សចាស់ មិនអាចរៀនធម៌បាន ទើបឲ្យមនុស្សសាងបណ្ណសាលាក្នុងទីបំផុតនៃវិហារ ហើយនៅរួមគ្នា កាលត្រាច់ទៅបិណ្ឌបាត ដោយច្រើនក៏ទៅកាន់ផ្ទះរបស់បុត្រ និងភរិយានោះឯង ហើយឆាន់ ។

ក្នុងភិក្ខុទាំងនោះ ភិក្ខុមួយរូបមានអតីតភរិយា ឈ្មោះនាងមធុរបាណិកា នាងមានឧបការៈដល់ភិក្ខុទាំងនោះគ្រប់រូប ព្រោះដូច្នោះ ភិក្ខុគ្រប់រូប កាន់យកអាហារដែលខ្លួនបានហើយ ទៅអង្គុយឆាន់ត្រង់ផ្ទះរបស់នាងនោះឯង ចំណែកនាងប្រគេនសម្ល និងម្ហូបដល់ភិក្ខុទាំងនោះ តាមដែលខ្លួនបានរៀបចំ ។

នាងកាលអាពាធប្រភេទណាមួយពាល់ត្រូវហើយ បានធ្វើកាលកិរិយាហើយ ។ លំដាប់នោះ ព្រះថេរៈចាស់ទាំងនោះ ប្រជុំគ្នាក្នុងបណ្ណសាលារបស់ព្រះថេរៈដែលជាសម្លាញ់ ឱបគ្នានិងគ្នាយំរៀបរាប់ថា ឧបាសិកាមានថ្វីដៃឆ្ងាញ់ ធ្វើកាលកិរិយាហើយ ។ ភិក្ខុទាំងឡាយរត់ចូលទៅដោយជុំវិញ ហើយសួរថា

បពិត្រលោកម្ចាស់ តើមានរឿងអ្វី ទើបពោលថា បពិត្រលោកម្ចាស់ ភរិយាចាស់របស់សម្លាញ់ពួកខ្ញុំ ធ្វើកាលកិរិយាហើយ នាងមានឧបការៈដល់ពួកខ្ញុំពន់ពេក ឥឡូវនេះ ពួកខ្ញុំនឹងបានឃើញអំពីណា ពួកខ្ញុំយំព្រោះហេតុនេះ ។

ភិក្ខុទាំងឡាយសន្ទនាក្នុងរោងធម្មសភាហើយ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនកាលនាងមធុរបាណិកានោះ កើតក្នុងកំណើតក្អែក ត្រាច់ទៅត្រង់មាត់សមុទ្រត្រូវរលកសមុទ្រក្ដួចឲ្យស្លាប់ហើយ ភិក្ខុទាំងនោះកើតជាក្អែក យំកន្ទក់កន្ទេញហើយគិតថា ពួកយើងនឹងនាំក្អែកញីនោះទៅ ទើបនាំគ្នាបាចមហាសមុទ្រដោយចំពុះ ដល់នូវសេចក្ដីលំបាកហើយ ហើយទ្រង់នាំអតីតនិទានមកត្រាស់កាកជាតកឲ្យពិស្តារថា

> អើ ចង្កាយើងក៏រោយ ទាំងមាត់ក៏ស្ងួតក្រៀមក្រោះ យើងមិនអាចបាចទឹកក្នុងសមុទ្រឲ្យរីងបានទេ ព្រោះមហាសមុទ្រនៅតែពេញដដែល ។

ហើយហៅភិក្ខុទាំងនោះមក ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអាស្រ័យព្រៃ គឺរាគៈ ទោសៈ និងមោហៈ ទើបដល់នូវទុក្ខនេះ កាលដែលពួកអ្នកកាប់នូវព្រៃនោះចេញ គួរ ពួកអ្នកនឹងអស់ទុក្ខបានដោយអាការយ៉ាងនេះ ហើយទ្រង់ភាសិតព្រះគាថាទាំងនេះថា

**វនំ ឆិន្ទថ មា រុក្ខំ វនតោ ជាយតី ភយំ**
**ឆេត្វា វនំ វនថញ្ច និព្វនា ហោថ ភិក្ខវោ ។**
**យាវញ្ហិ វនថោ ន ឆិជ្ជតិ អណុមត្តោបិ នរស្ស នារិសុ**
**បដិពទ្ធមនោ វ តាវ សោ វច្ឆោ ខីរបកោវ មាតរិ ។**

*អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ (ព្រោះ) ភ័យកើតអំពីកិលេសដូចជាព្រៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃផង កិលេសដូចជាដើមឈើដុះក្នុងព្រៃផង ហើយចូរជាអ្នកកុំមានកិលេសដូចជាព្រៃឡើយ ព្រោះថា កិលេសដូចដើមឈើ ដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនដាច់ក្នុងពួកនារីជនណា នរជននោះឯង តែងមានចិត្តជាប់ជំពាក់ក្នុងពួកនារី ដូចកូនគោនៅកំពុងបៅដោះ ដែលមានចិត្តជាប់ជំពាក់នៅនឹងមេដរាបនោះ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **មា រុក្ខំ** *សេចក្តីថា កាលព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយចូរកាត់ព្រៃ ភិក្ខុទាំងនោះ ដែលបួសមិនទាន់យូរ ការគិតក្នុងការជាអ្នកប្រាថ្នាកាប់ដើមឈើនឹងកើតឡើងថា ព្រះសាស្តាព្រមឲ្យពួកយើងកាន់កាំបិតជាដើមកាប់ព្រៃ កាលបើដូច្នោះ ព្រះសាស្តាកាលទ្រង់ហាមភិក្ខុទាំងនោះថា តថាគតពោលពាក្យនោះ សម្តៅយកព្រៃ គឺកិលេស មានរាគៈជាដើម*

មិនបានសម្ដៅយកដើមឈើ ទើបត្រាស់ថា កុំកាប់ដើមឈើ ។

បទថា **វនតោ** សេចក្ដីថា ភ័យកើតអំពីសត្វសាហាវ មានសីហៈជាដើម តែងកើតអំពីព្រៃតាមប្រក្រតី យ៉ាងណា ភ័យមានជាតិជាដើម រមែងកើតអំពីព្រៃ គឺកិលេសក៏ដូច្នោះ ។

ក្នុងពីរបទថា **វនំ វនថញ្ច** នេះ គប្បីជ្រាបវិនិច្ឆ័យថា ដើមឈើធំឈ្មោះថា ព្រៃ ដើមឈើតូចដែលតាំងនៅក្នុងព្រៃនោះ ឈ្មោះថា ពួកឈើតាំងនៅក្នុងព្រៃ ម្យ៉ាងទៀត ដើមឈើដែលកើតមុន ឈ្មោះថា ព្រៃ ដែលកើតក្រោយៗ មក ឈ្មោះថា ពួកឈើតាំងនៅក្នុងព្រៃ យ៉ាងណា កិលេសធំៗ ដែលទាញសត្វទុកក្នុងភព ឈ្មោះថា កិលេសដូចព្រៃ កិលេសដែលឲ្យផលក្នុងបច្ចុប្បន្ន ឈ្មោះថា កិលេសដូចពួកឈើតាំងនៅក្នុងព្រៃ ម្យ៉ាងទៀត កិលេសដែលកើតមុន ឈ្មោះថា កិលេសដូចព្រៃ កិលេសដែលកើតបន្ទាប់ៗ មក ឈ្មោះថា កិលេសដូចពួកឈើតាំងនៅក្នុងព្រៃដូច្នោះដូចគ្នា ។ កិលេសជាតទាំងពីរយ៉ាងនោះ ដែលព្រះយោគីគប្បីកាត់ដោយញាណ ដែលសម្បយុត្តដោយមគ្គទី ៤ ព្រោះហេតុនោះ ទើបព្រះសាស្ដាត្រាស់ថា ចូរកាត់កិលេសដូចព្រៃ និងដូចពួកឈើដែលតាំងនៅក្នុងព្រៃ ។

ពីរបទថា **និព្វនា ហោថ** សេចក្ដីថា អ្នកទាំងឡាយ ចូរជាអ្នកមិនមានកិលេសចុះ ។

ពីរបទថា **យាវញ្ហិ វនថោ** សេចក្ដីថា ពួកឈើដែលតាំងនៅក្នុងព្រៃ គឺកិលេសនោះ ទោះបីមានប្រមាណតិចតួចរបស់នរជន នៅមិនដាច់ក្នុងពួកនារី

ទាំងឡាយដ៏រាបណា បុគ្គលនោះ ដូចគ្នានឹងកូនគោដែលនៅបៅដោះមេ មានចិត្តប្រតិព័ទ្ធ គឺមានចិត្តជាប់ជំពាក់ក្នុងមេដ៏រាបនោះ ។

ក្នុងកាលចប់ទេសនា ព្រះថេរៈចាស់ទាំងនោះ តាំងនៅក្នុងសោតាបត្តិផល ហើយទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។៚

រឿង ព្រះថេរៈចាស់ ចប់

# រឿង សទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧច្ឆិន្ទ** ជាដើម ។

បានឮថា កូនរបស់ជាងមាសម្នាក់មានរូបស្អាត បួសក្នុងសម្នាក់របស់ព្រះថេរៈហើយ ព្រះថេរៈត្រិះរិះថា ពួកភិក្ខុកំលោះមានរាគៈក្រាស់ ហើយបានឲ្យអសុភកម្មដ្ឋានដល់លោក ដើម្បីកម្ចាត់រាគៈ ។ តែកម្មដ្ឋាននោះ មិនជាទីសប្បាយសម្រាប់លោក ព្រោះហេតុនោះ លោកចូលកាន់ព្រៃហើយ ព្យាយាមអស់ ៣ ខែ មិនបានសូម្បីត្រឹមឯកគ្គតា ទើបមកកាន់សម្នាក់ព្រះថេរៈ កាលព្រះថេរៈពោលថា អាវុសោ កម្មដ្ឋានប្រាកដដល់លោកហើយឬ ទើបប្រាប់ការប្រព្រឹត្តទៅនោះ ។ គ្រានោះ ព្រះថេរៈពោលថា ការដាក់ចិត្តថា កម្មដ្ឋាន មិនសម្រេចដូច្នេះ រមែងមិនសមគួរ ហើយប្រាប់កម្មដ្ឋាននោះឯង ឲ្យល្អក្រៃលែង

ឡើងទៀត ហើយបានឲ្យដល់លោក ។ ក្នុងវារៈទី ២ លោកក៏មិនអាចញ៉ាំង គុណវិសេសណាមួយឲ្យកើតឡើងបាន ទើបត្រឡប់មកប្រាប់ដល់ព្រះថេរៈ ។ សូម្បីព្រះថេរៈប្រាប់កម្មដ្ឋាននោះឯង ធ្វើឲ្យមានហេតុមានឧបមា លោកក៏មក ប្រាប់ភាពដែលកម្មដ្ឋានមិនសម្រេចទៀត ។ ព្រះថេរៈគិតថា ភិក្ខុធ្វើសេចក្តី ព្យាយាមរមែងជ្រាបនីវរណធម៌ មានកាមច្ឆន្ទៈជាដើម ដែលមាននៅក្នុងខ្លួនថា មាន និងដែលមិនមានថាមិនមាន ភិក្ខុនេះជាអ្នកធ្វើសេចក្តីព្យាយាម មិនមែន មិនធ្វើ ជាអ្នកបដិបត្តិ មិនមែនមិនបដិបត្តិ តែអញមិនដឹងអធ្យាស្រ័យរបស់ ភិក្ខុនេះ ភិក្ខុនេះប្រហែលជាពុទ្ធវេនេយ្យ ទើបនាំទៅគាល់ព្រះសាស្តាក្នុងពេល ល្ងាច ហើយក្រាបទូលការប្រព្រឹត្តទៅនោះទាំងអស់ថា បពិត្រព្រះអង្គ ភិក្ខុនេះ ជាសទ្ធិវិហារិករបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គឲ្យកម្មដ្ឋានឈ្មោះនេះ ដល់ភិក្ខុនេះ ដោយហេតុនេះ ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងព្រះថេរៈនោះថា ឈ្មោះថា អាសយា-នុសញ្ញាណនោះ រមែងមានដល់ព្រះពុទ្ធទាំងឡាយ ដែលបំពេញបារមីហើយ ញ៉ាំងលោកធាតុ ១ ម៉ឺនឲ្យកងរំពង ដល់នូវភាពជាសព្វញ្ញូនោះឯង ហើយ ទ្រង់រំពឹងថា ភិក្ខុនេះបួសអំពីត្រកូលណាហ្ន៎ ទ្រង់ជ្រាបថា អំពីត្រកូលជាង មាស ទ្រង់ពិចារណាអត្តភាពដែលកន្លងមកហើយ ទ្រង់ឃើញអត្តភាព ៥០០ របស់ភិក្ខុនោះ កើតដោយលំដាប់ក្នុងត្រកូលជាងមាស ហើយទ្រង់ត្រិះរិះថា ភិក្ខុនេះ ធ្វើជាងមាសអស់កាលដ៏យូរ រម្លាយតែមាសទឹកដប់តែម្យ៉ាង ដោយ គិតថា អញនឹងធ្វើជាផ្កាកណិការ និងផ្កាឈូកជាដើម ។ អសុភបដិកូល-

កម្មដ្ឋាន មិនសមគួរដល់ភិក្ខុកំលោះនេះ កម្មដ្ឋានដែលពេញចិត្តប៉ុណ្ណោះ ទើបជាកម្មដ្ឋានសប្បាយដល់លោក ទើបត្រាស់ថា សារីបុត្ត អ្នកនឹងឃើញភិក្ខុដែលអ្នកឲ្យកម្មដ្ឋាន លំបាកហើយអស់កាល ៤ ខែ សម្រេចអរហត្តខាងក្រោយភត្ត ក្នុងថ្ងៃនេះឯង ចូរអ្នកទៅចុះ ដូច្នេះហើយ ទ្រង់បញ្ជូនព្រះថេរៈទៅ ទ្រង់និម្មិតផ្កាឈូកមាសប្រមាណប៉ុនចក្រដោយឫទ្ធិ ហើយទ្រង់ធ្វើឲ្យដូចជាហូរនូវដំណក់ទឹកអំពីស្លឹក និងទង ហើយប្រទានឲ្យដោយព្រះតម្រាស់ថា យកចុះភិក្ខុ ចូរអ្នកកាន់យកផ្កាឈូកនោះ ទៅទុកត្រង់គំនរខ្សាច់ខាងចុងវិហារ អង្គុយពត់ភ្នែនក្នុងទីចំពោះមុខ ហើយធ្វើបរិកម្មថា **លោហិតកំ លោហិតកំ** ក្រហម ក្រហម ។ កាលភិក្ខុនោះ ទទួលផ្កាឈូកអំពីព្រះហស្តរបស់ព្រះសាស្តាប៉ុណ្ណោះចិត្តក៏ជ្រះថ្លាហើយ លោកទៅកាន់ខាងចុងវិហារ ពូនខ្សាច់ឡើងដោតទងផ្កាឈូកត្រង់គំនរខ្សាច់នោះហើយ អង្គុយពត់ភ្នែនក្នុងទីចំពោះមុខ ផ្តើមបរិកម្មថា **លោហិតកំ លោហិតកំ** ។

គ្រានោះ នីវរណៈទាំងឡាយរបស់លោកស្ងប់រម្ងាប់ហើយ ក្នុងខណៈនោះឯង ឧបចារជ្ឈានកើតហើយ ។ លោកញ៉ាំងបឋមជ្ឈានឲ្យកើតឡើងក្នុងលំដាប់នៃឧបចារជ្ឈាននោះ ឲ្យដល់នូវភាពជាអ្នកជំនាញ ដោយអាការ ៥ អង្គុយក្នុងឥរិយាបថនោះឯង សម្រេចឈានទាំងឡាយ មានទុតិយជ្ឈានជាដើមហើយ អង្គុយចូលចតុត្ថជ្ឈានដែលជំនាញហើយ ។

ព្រះមានព្រះភាគទ្រង់ជ្រាបថា ឈានកើតឡើងដល់ភិក្ខុនោះហើយ ទ្រង់ពិចារណាថា ភិក្ខុនេះអាចញ៉ាំងគុណវិសេសដែលក្រៃលែង ឲ្យកើតឡើងតាម

ធម្មតារបស់ខ្លួនបានឬហ្ន៎ ទ្រង់ជ្រាបថា មិនអាច ហើយទ្រង់អធិដ្ឋានថា ចូរផ្កាបទុមនោះរុះរោយទៅ ផ្កាបទុមនោះក៏ក្រៀមស្រពោនមានពណ៌ខ្មៅ ដូចផ្កាបទុមដែលត្រូវឈ្លីដោយដៃដូច្នោះ ។ ភិក្ខុនោះចេញអំពីឈានហើយ សម្លឹងមើលផ្កាបទុមនោះ ឃើញអនិច្ចលក្ខណៈថា ឱហ្ន៎ ផ្កាបទុមនេះ ត្រូវជរាប៉ះខ្ទប់ហើយទើបប្រាកដបាន កាលអនុបាទិន្នកសង្ខារ ដែលជរាគ្របសង្កត់បានយ៉ាងនេះ ចំណង់បើឧបាទិន្នកសង្ខារ តើនឹងអាចចៀសបានដូចម្ដេច ជរាគង់គ្របសង្កត់ឧបាទិន្នកសង្ខារនេះ កាលអនិច្ចលក្ខណៈនោះដែលលោកឃើញហើយ ទុក្ខលក្ខណៈ និងអនត្តលក្ខណៈ ក៏ឈ្មោះថាឃើញហើយដូចគ្នា ។ ភព ៣ ប្រាកដដល់លោក ដូចភ្លើងដែលឆេះទូទៅហើយ និងដូចសាកសពដែលបុគ្គលចងនៅត្រង់ក ។

ក្នុងខណៈនោះ ពួកក្មេងចុះកាន់ស្រះមួយ ក្នុងទីមិនឆ្ងាយអំពីភិក្ខុនោះ កាច់ផ្កាកុមុទទាំងឡាយហើយ ធ្វើឲ្យជាគំនរទុកលើគោក ។ ភិក្ខុនោះសម្លឹងមើលផ្កាកុមុទទាំងឡាយលើគោក និងក្នុងទឹក លំដាប់នោះ ផ្កាកោមុទក្នុងទឹកស្អាតប្រាកដដល់លោកដូចកំពង់ហូរទឹក ។ ផ្កាកុមុទក្រៅអំពីនេះ ក្រៀមស្ងួតហើយត្រង់ចុងត្របក ភិក្ខុនោះ ឃើញអនិច្ចលក្ខណៈជាដើមល្អឡើងថា ជរារមែងប៉ះខ្ទប់អនុបាទិន្នកសង្ខារយ៉ាងនេះ នឹងមិនប៉ះខ្ទប់ឧបាទិន្នកសង្ខារដូចម្ដេច ។

ព្រះសាស្ដាទ្រង់ជ្រាបថា ឥឡូវនេះ កម្មដ្ឋានប្រាកដដល់ភិក្ខុនោះហើយ ប្រថាប់គង់ក្នុងព្រះគន្ធកុដិ ទ្រង់បញ្ចេញព្រះរស្មីទៅ ព្រះរស្មីនោះប៉ះខ្ទប់នឹងមុខរបស់ភិក្ខុនោះ កាលលោកពិចារណាថា នុ៎ះអ្វីហ្ន៎ ព្រះសាស្ដាក៏ហាក់ដូចយាង

មកប្រថាប់ឈរត្រង់ទីចំពោះមុខ ភិក្ខុក្រោកឡើងផ្គងអញ្ជលី ។ លំដាប់នោះ ព្រះសាស្តាទ្រង់កំណត់ធម៌ដែលជាសប្បាយហើយ ទើបត្រាស់ព្រះគាថានេះថា

**ឧច្ឆិន្ទ សិនេហមត្តនោ កុមុទំ សារទិកំវ បាណិនា**
**សន្តិមគ្គមេវ ព្រូហយ និព្វានំ សុគតេន ទេសិតំ ។**

ចូរអ្នកដកសេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គលដកផ្កាកុមុទ ដែលកើតក្នុងសរទកាលដោយដៃ ចូរអ្នកបណ្តុះនូវផ្លូវសន្តិភាពតែម្យ៉ាង ព្រះនិព្វាន ព្រះសុគតបានសម្តែងហើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧច្ឆិន្ទ** គឺចូរកាត់ដោយអរហត្តមគ្គ ។ បទថា **សារទិកំ** បានដល់ ដែលកើតហើយក្នុងសរទកាល ។

បទថា **សន្តិមគ្គំ** គឺនូវផ្លូវដែលមានអង្គ ៨ ដែលញុំាងសត្វឲ្យដល់នូវព្រះនិព្វាន ។ បទថា **ព្រូហយ** គឺចូរចម្រើន ។ បទថា **និព្វានំ** សេចក្តីថា ព្រោះព្រះនិព្វាន ព្រះសុគតទ្រង់សម្តែងហើយ ព្រោះដូច្នោះ ចូរអ្នកចម្រើនផ្លូវនៃព្រះនិព្វាននោះ ។ ក្នុងកាលចប់ទេសនា ភិក្ខុនោះ តាំងនៅក្នុងអរហត្តហើយ ដូច្នេះឯង ៕

**រឿងសទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ ចប់**

# រឿង ឈ្មួញមានទ្រព្យច្រើន

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឈ្មួញមានទ្រព្យច្រើន ត្រាស់ព្រះធម្មទេសនានេះថា **៩៨ វស្សំ** ជាដើម ។

បានឮមកថា ឈ្មួញនោះដាក់សំពត់ដែលជ្រលក់ដោយផ្កាដកគាំ ពេញរទេះ ៥០០ ចេញអំពីក្រុងពារាណសីហើយ មកកាន់ក្រុងសាវត្ថីដើម្បីជួញដូរ ដល់ច្រាំងស្ទឹងហើយគិតថា ស្អែកនេះនឹងឆ្លងស្ទឹង ដោះរទេះស្នាក់នៅត្រង់ច្រាំងនោះឯង ។ លុះពេលយប់ មហាមេឃតាំងឡើងញ៉ាំងភ្លៀងឲ្យធ្លាក់ ។ ស្ទឹងពេញដោយទឹកអស់ ៧ ថ្ងៃ ។ ក្នុងព្រះនគរ ពួកជនក៏លេងនក្ខត្តឫក្សអស់ ៧ ថ្ងៃ កិច្ចដោយសំពត់ជ្រលក់ដោយផ្កាដកគាំ មិនមាន ។ ឈ្មួញគិតថា អញមកអំពីចម្ងាយ បើអញទៅទៀត ការយឺតយូរនឹងមាន អញនឹងនៅធ្វើការងាររបស់អញ ក្នុងទីនេះឯងអស់រដូវភ្លៀង រដូវរងា និងរដូវក្តៅ ហើយលក់សំពត់ទាំងនេះ ។

ព្រះសាស្តា ត្រាច់ទៅបិណ្ឌបាតក្នុងព្រះនគរ ទ្រង់ជ្រាបចិត្តរបស់ឈ្មួញហើយ ទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ព្រះអានន្ទត្ថេរសួរហេតុនៃការញញឹម ទ្រង់ត្រាស់ថា អានន្ទ អ្នកឃើញឈ្មួញមានទ្រព្យច្រើនដែរទេ អានន្ទទូលថា ឃើញព្រះអង្គ ព្រះសាស្តាត្រាស់ថា បុរសនេះមិនដឹងអន្តរាយនៃជីវិត ទើបតាំងចិត្តនៅលក់របស់ក្នុងទីនេះអស់មួយឆ្នាំ អានន្ទទូលថា បពិត្រព្រះអង្គ អន្តរាយនឹងមានដល់គាត់ឬ ព្រះសាស្តាត្រាស់ថា អើអានន្ទ បុរសនេះនៅបាន ៧ ថ្ងៃទៀតប៉ុណ្ណោះ នឹងតាំងនៅក្នុងមាត់នៃមច្ចុ ដូច្នេះហើយ ទ្រង់ភាសិតព្រះ

គាថាទាំងនេះថា

ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះ
ឯង អ្នកណាអាចដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក
បាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុ ដែលមាន
សេនាដ៏ច្រើននោះ មិនមានសោះឡើយ អ្នកប្រាជ្ញដែលស្ងប់
ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មាន
ព្យាយាមដុតកម្តៅកិលេស ជាអ្នកមិនខ្ជិលច្រអូសអស់ថ្ងៃ
និងថ្ងៃយប់នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះនឹងទៅប្រាប់ដល់ឈ្មួញនេះ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកស្និទ្ធស្នាលនឹងបុរសនោះ ទៅក៏ទៅចុះ ។

ព្រះថេរៈទៅកាន់ទីដែលរទេះត្រាច់ទៅដើម្បីភិក្ខា ឈ្មួញទទួលព្រះថេរៈដោយអាហារ ។ លំដាប់នោះ ព្រះថេរៈពោលនឹងឈ្មួញនោះថា អ្នកនៅក្នុងទីនេះអស់កាលមានប្រមាណប៉ុន្មាន ឈ្មួញពិតថា បពិត្រលោកម្ចាស់ ខ្ញុំមកអំពីឆ្ងាយ បើនឹងទៅទៀតការយឺតយូរនឹងមាន ខ្ញុំនឹងនៅក្នុងទីនេះអស់មួយឆ្នាំ លក់របស់អស់ហើយ នឹងទៅ ។

ព្រះអានន្ទពោលថា ឧបាសក អន្តរាយនៃជីវិតដឹងបានលំបាក ការធ្វើសេចក្តីមិនប្រមាទ ទើបគួរ ឈ្មួញពោលថា បពិត្រលោកម្ចាស់ អន្តរាយនឹងមានឬ ព្រះអានន្ទពោលថា អើ ឧបាសក ជីវិតរបស់អ្នកនៅបាន ៧ ថ្ងៃប៉ុណ្ណោះ បុរសនោះ មានចិត្តសង្វេគហើយ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជា

ប្រធាន ថ្វាយមហាទានអស់ ៧ ថ្ងៃ ហើយទទួលបាត្រដើម្បីប្រយោជន៍ដល់ការអនុមោទនា ។

លំដាប់នោះ ព្រះសាស្តាកាលទ្រង់ធ្វើអនុមោទនាដល់បុរសនោះ ត្រាស់ថា ម្នាលឧបាសក ធម្មតាបណ្ឌិត គិតថា អញនឹងនៅក្នុងទីនេះឯងអស់រដូវភ្លៀងជាដើម នឹងប្រកបការងារបែបនេះៗ រមែងមិនគួរ គួរគិតដល់អន្តរាយនៃជីវិតរបស់ខ្លួនប៉ុណ្ណោះ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**ឥធ វស្សំ វសិស្សាមិ ឥធ ហេមន្តគិម្ហិសុ**

**ឥតិ ពាលោ វិចិន្តេតិ អន្តរាយំ ន ពុជ្ឈតិ ។**

អញនឹងនៅក្នុងទីនេះ អស់វស្សានរដូវ អញនឹងនៅក្នុងទីនេះក្នុងហេមន្តរដូវ និងគិម្ហរដូវ ជនពាលតែងគិតខុសដូច្នេះ តែងមិនដឹងច្បាស់នូវសេចក្តីអន្តរាយឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឥធ វស្សំ** សេចក្តីថា អញនឹងនៅធ្វើការងារនេះៗ ក្នុងទីនេះ អស់រដូវភ្លៀង ៤ ខែ ។

បទថា **ហេមន្តគិម្ហិសុ** សេចក្តីថា បុគ្គលពាលមិនដឹងប្រយោជន៍ប្រព្រឹត្តទៅក្នុងទិដ្ឋធម្ម និងសម្បរាយភព រមែងគិតយ៉ាងនេះថា អញនឹងនៅធ្វើការងារនេះៗ ក្នុងទីនេះឯង អស់កាល ៤ ខែ ក្នុងរដូវរងា និងរដូវក្តៅ ។

បទថា **អន្តរាយំ** សេចក្តីថា រមែងមិនដឹងអន្តរាយនៃជីវិតរបស់ខ្លួនថា អញនឹងស្លាប់ក្នុងកាល ក្នុងបទេស ឬក្នុងវ័យឈ្មោះនោះ ។

ក្នុងកាលចប់ទេសនា ឈ្មួញនោះ តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ។ ចំណែកឈ្មួញរទេះ ជូនដំណើរព្រះសាស្ដាហើយ ត្រឡប់មកដេកលើដំណោកដោយគិតថា រោគក្នុងក្បាលហាក់ដូចជាកើតឡើងដល់អញ ដេកហើយដោយអាការនោះឯង ធ្វើកាលកិរិយាហើយ កើតក្នុងតុសិតវិមាន ដូច្នេះឯង ។៙

**រឿង ឈ្មួញមានទ្រព្យច្រើន ចប់**

# រឿង នាងកិសាគោតមី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកិសោគោតមី ត្រាស់ព្រះធម្មទេសនានេះថា **តំ បុត្តបសុសម្មត្តំ** ជាដើម ។

រឿងរ៉ាវខ្ញុំបានពោលហើយ ក្នុងកិច្ចពណ៌នាព្រះគាថាក្នុងសហស្សវគ្គថា

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន
ការរស់នៅសូម្បីតែ ១ ថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះ
និព្វាន ប្រសើរជាង ។

ក្នុងកាលនោះ ព្រះសាស្ដាត្រាស់ថា ម្នាលកិសាគោតមី គ្រាប់ស្ពៃប្រមាណមួយចឹប នាងរកបានហើយឬ កិសាគោតមីពោលថា បពិត្រព្រះអង្គមិនបានទេ ក្នុងស្រុកទាំងមូល អ្នកស្លាប់នោះឯងមានច្រើនជាងអ្នករស់ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា នាងយល់ថាបុត្ររបស់នាងប៉ុណ្ណោះស្លាប់ហើយ ការស្លាប់នោះជាធម៌ទៀងពិតរបស់សព្វសត្វ ។ ព្រោះមច្ចុរាជ អូសសព្វសត្វដែលមានអធ្យាស្រ័យមិនទាន់ពេញប៉ុណ្ណោះ បន្សាត់ទៅក្នុងសមុទ្រ គឺអបាយ ដូចជំនន់ទឹកធំដូច្នោះ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ**
**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

មច្ចុ គឺសេចក្តីស្លាប់ តែងនាំយកនរជនអ្នកស្រវឹងជ្រប់ ក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ នោះ ដូចជំនន់ទឹកធំ នាំយកអ្នកស្រុកកំពុងដេកលក់ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **តំ បុត្តបសុសម្មត្តំ** សេចក្តីថា នរៈនោះដែលបានបុត្រ និងបសុសត្វទាំងឡាយ ដែលដល់ព្រមដោយរូប និងកម្លាំងជាដើមហើយ ស្រវឹង គឺប្រមាទហើយ ដោយបុត្រ និងបសុសត្វទាំង-ឡាយយ៉ាងនេះថា កូនរបស់អញមានរូបស្អាត មានកម្លាំងបរិបូណ៌ ឈ្លាសអាចក្នុងកិច្ចគ្រប់យ៉ាង គោរបស់អញមានរូបស្អាត ប្រាសចាករោគ អាចនាំរបស់ទៅបានច្រើន មេគោរបស់អញ មានទឹកដោះច្រើន ។

បទថា **ព្យាសត្តមនសំ** សេចក្តីថា ឈ្មោះថា បុគ្គលមានចិត្តជាប់ជំពាក់ហើយ ( ក្នុងអារម្មណ៍ ) ព្រោះបានបណ្តាប្រាក់ និងមាសជាដើម ឬសមណ-

បរិក្ខារទាំងឡាយ មានបាត្រ និងចីវរជាដើមណាមួយប៉ុណ្ណោះ ហើយប្រាថ្នាក្រៃលែងឡើងជាងនោះ ។ ម្យ៉ាងទៀត ឈ្មោះថា មានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ ព្រោះជាប់ជំពាក់ក្នុងបណ្ដាអារម្មណ៍ទាំងឡាយ ដែលគប្បីដឹងដោយចក្ខុជាដើម ឬបណ្ដាសមណបរិក្ខារទាំងឡាយ មានប្រការដូចពោលហើយ ក្នុងអារម្មណ៍ និងបរិក្ខារដែលខ្លួនបានហើយនោះឯង ។

ពីរបទថា **សុត្តំ គាមំ** បានដល់ ពួកសត្វដែលចូលដល់នូវការដេកលក់ ។

បទថា **មហោឃោវ** ជាដើម សេចក្ដីថា អន្លង់មហានទី ជ្រៅផង ធំផង កួចអ្នកស្រុកបែបនោះទៅទាំងអស់ ដោយហោចសូម្បីឆ្កែក៏មិនទុក យ៉ាងណា មច្ចុ រមែងនាំទៅនូវសត្វមានប្រការដូចពោលហើយទៅ ដូច្នោះ ។

ក្នុងកាលចប់ទេសនា នាងកិសាគោតមី តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់បុគ្គលប្រជុំគ្នាហើយ ដូច្នេះឯង ។៚

**រឿង នាងកិសាគោតមី ចប់**

# រឿង នាងបដាចារា

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបដាចារា ត្រាស់ព្រះធម្មទេសនានេះថា **ន សន្តិ បុត្តា** ជាដើម ។

រឿងរ៉ាវខ្ញុំពោលពិស្ដារហើយ ក្នុងកិច្ចពណ៌នាព្រះគាថា ក្នុងសហស្សវគ្គថា

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញការកើតឡើង និង
ការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោក
ដែលឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។

ក្នុងកាលនោះ ព្រះសាស្តាទ្រង់ជ្រាបនាងបដាចារាថា មានសេចក្តីសោកធូរស្រាលហើយ ទើបត្រាស់ថា ម្នាលនាងបដាចារា ឈ្មោះថា បិយជនទាំងឡាយ មានកូនជាដើម រមែងមិនអាចជាទីជ្រកកោន ឬការពាររបស់បុគ្គលទៅកាន់បរលោកបានឡើយ ព្រោះដូច្នោះ ជនទាំងនោះ សូម្បីមាន ក៏ឈ្មោះថា មិនមានពិត ឯការដែលបណ្ឌិតជម្រះសីលឲ្យបរិសុទ្ធហើយ ជម្រះផ្លូវដែលជាទីទៅកាន់ព្រះនិព្វាន ដើម្បីខ្លួននោះឯង គួរ ដូច្នេះហើយ ទើបទ្រង់សម្តែងធម៌ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

**ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា**
**អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា ។**
**ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ**
**និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។**

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយមិនមាន
ដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមាន ដើម្បី
ជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយក៏មិនមាន
បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុង
សីល គួរប្រញាប់ប្រញាលជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វាន
ឲ្យបាន ។

# សេចក្តីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **តាណាយ** សេចក្តីថា ដើម្បីភាពជាអ្នកជ្រកកោន គឺដើម្បីប្រយោជន៍ដល់ភាពជាទីពឹង ។

ញាតិ មិត្ត និងបុគ្គលចិត្តល្អដ៏សេស វៀរកូន និងមាតាបិតាចេញ ឈ្មោះថា ផៅពង្ស ។

បទថា **អន្តកេនាធិបន្នស្ស** គឺបុគ្គលត្រូវសេចក្តីស្លាប់គ្របសង្កត់ ។ ពិតហើយ ក្នុងបច្ចុប្បន្នកាល បិយជនទាំងឡាយ មានបុត្រជាដើម សូម្បីជាបុគ្គលជ្រកកោនបាន ដោយការឲ្យបាយ និងទឹកជាដើម និងដោយការជួយកិច្ចដែលកើតឡើងហើយ តែក្នុងពេលស្លាប់ ឈ្មោះថា មិនមានប្រយោជន៍ដល់ការជ្រកកោន គឺដើម្បីប្រយោជន៍ដល់ការការពារ ព្រោះភាពជាបុគ្គលមិនអាចការពារសេចក្តីស្លាប់ ដោយឧបាយណាមួយបាន ព្រោះហេតុនោះឯង ទើបព្រះសាស្ដាត្រាស់ថា **នត្ថិ ញាតីសុ តាណាតា ។**

បទថា **ឯតមត្ថវសំ** សេចក្តីថា បណ្ឌិតជ្រាបហេតុនោះ ពោល គឺភាពដែលជនទាំងនោះជាអ្នកមិនអាច ដើម្បីជាអ្នកជ្រកកោនដល់គ្នានិងគ្នាហើយ ជាអ្នកសង្រួម គឺរក្សា បានដល់ គ្រប់គ្រងដោយបារិសុទ្ធិសីល ៤ គប្បីជម្រះផ្លូវមានអង្គ ៨ ដែលជាទីទៅកាន់ព្រះនិព្វានឲ្យបរិសុទ្ធដោយរួសរាន់ ។

ក្នុងកាលចប់ទេសនា បដាចារាតាំងនៅក្នុងសោតាបត្តិផលហើយ ជនដទៃជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង នាងបដាចារា ចប់**

**មគ្គវគ្គទី ២០ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា បកិណ្ណកវគ្គទី ២១

[៣១] បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខធំទូលាយ គប្បីលះសុខល្មមប្រមាណចេញ ។

ជនប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយបន្តុទុក្ខឲ្យអ្នកដទៃ ជននោះឈ្មោះថា ប្រឡូកច្របល់ហើយ ដោយការជាប់ជំពាក់ គឺពៀរ រមែងមិនរួចចាកពៀរទេ ។

របស់ណាដែលខ្លួនគួរធ្វើ របស់នោះពួកភិក្ខុណាលះបង់ចោលហើយ តែរបស់ដែលមិនគួរធ្វើ ត្រឡប់ជាធ្វើវិញ អាសវៈទាំងឡាយ តែងចម្រើនឡើងដល់ពួកភិក្ខុនោះ ជាអ្នកមានសេចក្តីប្រមាទ មានមានះដូចជាដើមបបុសលើកឡើងហើយ ។

លុះតែសតិប្រព្រឹត្តទៅ ក្នុងកាយជានិច្ច ដែលពួកភិក្ខុណាបានប្រារព្ធប្រពៃហើយ ភិក្ខុទាំងនោះ រមែងជាអ្នកធ្វើការដែលគួរធ្វើរឿយៗ មិនធ្វើការដែលមិនគួរធ្វើ អាសវៈទាំងឡាយ របស់ពួកភិក្ខុនោះ ដែលជាអ្នកមានសតិ មានសម្បជញ្ញៈ រមែងដល់នូវការអស់ទៅ ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ដូចស្តេចជាក្សត្រ ២ ព្រះអង្គផង សម្លាប់អាយតនៈដូចជាដែន ប្រព្រឹត្តទៅ មួយអន្លើដោយបុរសអ្នកដើរតាម គឺស្នៀនផង រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។ បុគ្គលសម្លាប់តណ្ហាដូចជាមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សត-

ទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ដូចជាស្តេចជាព្រាហ្មណ៍ទាំង ២ ផង សម្លាប់វិចិកិច្ឆា ដូចជាខ្លាធំ ជាគម្រប់ ៥ ផង ( ដែលនៅស្កាត់ផ្លូវ ) បានហើយ រមែងបាន ទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះពុទ្ធគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែង ភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះធម្មគុណ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់ រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះសង្ឃគុណ អស់កាល ជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងកាយ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងការមិនបៀតបៀនគេ ទាំង ថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែង ភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងមេត្តាភាវនាទាំងថ្ងៃ ទាំងយប់

ជនពួកនោះ ឈ្មោះថា សាវករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

ការចេញបួសបានដោយក្រ ការត្រេកអរត្រូវបានដោយក្រ ផ្ទះទាំងឡាយ មានការនៅគ្រប់គ្រងដោយលំបាក ជាការក្រ ការនៅរួមដោយជនស្មើគ្នា ( ដែលមិនមានសេចក្តីកោតក្រែង ) ជាការក្រ ជនអ្នកដើរផ្លូវឆ្ងាយគឺវដ្ត តែងត្រូវសេចក្តីទុក្ខធ្លាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្តីទុក្ខជាប់តាមផង ។ បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់ដោយយស និងភោគសម្បត្តិ គប់រកប្រទេសណាៗ គេតែងបូជាក្នុងប្រទេសនោះៗ ។

ពួកសប្បុរស តែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្ត ដូច្នោះ ពួកអសប្បុរស ( ទុកជាស្ថិតនៅ ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ។

បុគ្គល គួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរក្នុងព្រៃស្ងាត់ ។

**បកិណ្ណកវគ្គទី ២១ ចប់**

# អដ្ឋកថា

# បកិណ្ណកវគ្គទី ២១

## រឿង បុព្វកម្មព្រះសាស្តា

### លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុព្វកម្មរបស់ព្រះអង្គ ត្រាស់ព្រះធម្មទេសនានេះថា* **មត្តាសុខបរិច្ចាគា** *ជាដើម ។*

*សេចក្តីពិស្តារ សម័យមួយ ក្រុងវេសាលី បានជាក្រុងមាំទាំទូលំទូលាយ មានជនច្រើន មានមនុស្សកុះករ ។ ក្នុងក្រុងវេសាលីនោះ មានក្សត្រគ្រប់គ្រងរាជសម្បត្តិតាមវារៈរហូតដល់ ៧ ពាន់ ៧ រយអង្គ ។ ប្រាសាទដើម្បីជាប្រយោជន៍ ជាទីប្រថាប់របស់ក្សត្រទាំងនោះ ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ផ្ទះកំពូល ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ទីកន្លែងដែលគួរត្រេកអរ និងស្រះបោក្ខរណី ដើម្បីប្រយោជន៍ជាទីប្រថាប់ក្នុងព្រះរាជឧទ្យាន ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ។*

*ដោយសម័យដទៃទៀត កាលក្រុងវេសាលីនោះជាក្រុងមានកិក្ខារកបានលំបាក សម្លងក៏អន្តរាយ ។ ដំបូង ពួកមនុស្សដែលក្រីក្រក្នុងក្រុងវេសាលីបានស្លាប់ហើយជាច្រើន ព្រោះទោស គឺការអត់ឃ្លាន ។ ពួកអមនុស្សក៏ចូលទៅក្នុងព្រះនគរ ព្រោះក្លិនសាកសពរបស់មនុស្សទាំងនោះ ដែលគេចោល*

ក្នុងទីនោះៗ មនុស្សទាំងឡាយស្លាប់ច្រើនឡើងៗ ព្រោះឧបទ្រវដែលកើតអំពីអមនុស្ស ។ អហិវាតករោគកើតឡើងដល់សត្វទាំងឡាយ ព្រោះភាពបដិកូលដោយក្លិនសាកសពនៃមនុស្សទាំងនោះ ។ ភ័យ ៣ យ៉ាង គឺភ័យកើតអំពីកិច្ចារកបានលំបាក ១ ភ័យកើតអំពីអមនុស្ស ១ ភ័យកើតអំពីរោគ ១ កើតឡើងហើយ ដោយប្រការដូច្នេះ ។

អ្នកនគរប្រជុំគ្នាហើយ ក្រាបទូលព្រះរាជាថា បពិត្រមហារាជ ភ័យ ៣ យ៉ាង កើតឡើងហើយក្នុងព្រះនគរនេះ ក្នុងកាលមុនអំពីនេះ រហូតដល់ព្រះរាជា ៧ ជំនាន់ ឈ្មោះថា ភ័យបែបនេះ មិនធ្លាប់កើតឡើងឡើយ ព្រោះថា ក្នុងរជ្ជកាលរបស់ព្រះរាជាដែលទ្រទ្រង់ធម៌ទាំងឡាយ ភ័យបែបនេះ មិនកើតឡើងឡើយ ។

ព្រះរាជា ត្រាស់ឲ្យធ្វើការប្រជុំជនទាំងពួង ក្នុងព្រះរាជមន្ទីរ ហើយត្រាស់ថា បើការមិនទ្រទ្រង់ធម៌របស់សយើងមានសោត អ្នកទាំងឡាយ ចូរពិនិត្យមើលនូវហេតុនោះ ។ អ្នកក្រុងវេសាលីពិនិត្យមើលប្រពៃណីគ្រប់យ៉ាងមិនឃើញទោសណាមួយរបស់ព្រះរាជា ទើបក្រាបទូលថា បពិត្រមហារាជទោសរបស់ទ្រង់មិនមាន ទើបប្រឹក្សាគ្នាថា ធ្វើម្តេចហ្ន៎ភ័យ របស់ពួកយើងគប្បីដល់នូវសេចក្តីស្ងប់ បណ្តាជនទាំងនោះ កាលជនពួកខ្លះពោលថា ភ័យគប្បីដល់នូវការស្ងប់ដោយពលីកម្ម ដោយការបួងសួង ដោយការធ្វើមង្គលជនទាំងនោះ ធ្វើវិធីទាំងអស់នោះ ក៏មិនអាចការពារបាន ។

ជនពួកខ្លះពោលយ៉ាងនេះថា គ្រូទាំង ៦ មានអានុភាពច្រើន កាលគ្រូ

ទាំង ៦ មកទីនេះហើយ ភ័យគប្បីស្ងប់ ។ ជនពួកខ្លះទៀតពោលថា ព្រះសម្មាសម្ពុទ្ធកើតឡើងក្នុងលោក ព្រះសាស្តាអង្គនោះមានឫទ្ធិច្រើន មានទនុវអានុភាពច្រើន ទ្រង់សម្តែងធម៌ដើម្បីប្រយោជន៍ដល់សព្វសត្វ កាលទ្រង់យាងមកទីនេះហើយ ភ័យទាំងនេះ គប្បីដល់នូវសេចក្តីស្ងប់បាន ។

ជនទាំងអស់ គាប់ចិត្តនឹងពាក្យរបស់ជនទាំងនោះហើយពោលថា ឥឡូវនេះ ព្រះដ៏មានព្រះភាគអង្គនោះ ប្រថាប់នៅក្នុងទីណាហ្ន៎ ក្នុងកាលនោះ ជាតិថីដែលចាំវស្សាខិតជិតចូលមកហើយ ព្រះសាស្តាទ្រង់ព្រះរាជទានបដិញ្ញាដល់ព្រះបាទពិម្ពិសារ ហើយយាងចូលក្នុងវត្តវេឡុវ័ន ។

គ្រានោះ ស្តេចលិច្ឆវីព្រះនាមមហាលិ ទ្រង់សម្រេចសោតាបត្តិផលមួយអន្លើដោយព្រះបាទពិម្ពិសារ ក្នុងសមាគមនៃព្រះបាទពិម្ពិសារ ប្រថាប់គង់ក្នុងទីជិតនៃបរិស័ទនោះ ។ អ្នកក្រុងវេសាលី ត្រៀមបណ្ណាការជំបញ្ជូនមហាលិលិច្ឆវី និងបុត្ររបស់បុរោហិតទៅដោយប្រាប់ថា អ្នកទាំងឡាយ ចូរញ៉ាំងព្រះបាទពិម្ពិសារ ឲ្យយល់ព្រមហើយ នាំព្រះសាស្តាមកក្នុងនគរនេះ ។ មហាលិលិច្ឆវី និងកូនបុរោហិតទៅហើយ ថ្វាយបណ្ណាការដល់ព្រះរាជា ក្រាបទូលការប្រព្រឹត្តទៅឲ្យទ្រង់ជ្រាបហើយ ទូលសូមថា បពិត្រមហារាជ សូមទ្រង់បញ្ជូនព្រះសាស្តាទៅកាន់នគររបស់ខ្ញុំ ព្រះរាជាត្រាស់ថា អ្នកទាំងឡាយ ចូរដឹងឯងចុះ ហើយមិនទទួលបណ្ណាការនោះ ។ ជនទាំងនោះចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ទូលអារាធនាថា បពិត្រព្រះអង្គ ក្នុងក្រុងវេសាលីកើតភ័យ ៣ យ៉ាង កាលទ្រង់យាងទៅភ័យនឹងស្ងប់ សូមទ្រង់យាងចុះ ខ្ញុំ

ព្រះអង្គទាំងឡាយនឹងទៅ ។ ព្រះសាស្ដា ទ្រង់ស្ដាប់ពាក្យរបស់ជនទាំងនោះ ហើយ ទ្រង់ពិចារណា ក៏ជ្រាបថា ក្នុងក្រុងវេសាលី កាលតថាគតសូធ្យនូវ រតនសូត្រ អាជ្ញានឹងផ្សាយទៅមួយសែនកោដិចក្កវាឡ ក្នុងកាលចប់ព្រះសូត្រ ការសម្រេចធម៌មានដល់សត្វ ៨៤០០០ ភ័យទាំងនោះនឹងស្ងប់ទៅ ហើយ ទ្រង់ទទួលពាក្យរបស់ជនទាំងនោះ ។

ព្រះបាទពិម្ពិសារទ្រង់ស្ដាប់ថា ព្រះសាស្ដាទ្រង់ទទួលដើម្បីយាងទៅក្រុង វេសាលី ហើយទ្រង់ធ្វើការប្រកាសក្នុងព្រះនគរ ចូលទៅគាល់ព្រះសាស្ដាទូល សួរថា បពិត្រព្រះអង្គ ព្រះអង្គទទួលការយាងទៅក្រុងវេសាលីឬ កាលព្រះ សាស្ដាត្រាស់ថា ពិតហើយ មហារាជ ក៏ក្រាបទូលថា បើដូច្នោះ សូមទ្រង់ បង្អង់សិន ទូលបង្គំនឹងរៀបចំផ្លូវជាមុន ហើយត្រាស់ឲ្យពង្រាបដី ៥ យោជន៍ ក្នុងរវាងក្រុងរាជគ្រឹះ និងស្ទឹងគង្គាឲ្យរាបស្មើ ឲ្យបាត់វិហារមួយយោជន៍ៗ ១ ទើបក្រាបទូលកាលយាងទៅ ដល់ព្រះសាស្ដា ។

កាលនោះ ព្រះសាស្ដាយាងជាមួយភិក្ខុ ៥០០ រូប ព្រះរាជាទ្រង់រោយ ផ្កា ៥ ពណ៌ កម្ពស់ប្រមាណស្មើក្បាលជង្គង់ ក្នុងរវាងមួយយោជន៍ៗ រួច ឲ្យលើកទង់ជ័យ ទង់ផ្កាលា និងដើមចេកជាដើម ឲ្យបាំងស្វេតច្ឆត្រពីរជាន់ ដល់ព្រះសាស្ដា បាំងស្វេតច្ឆត្រមួយជាន់ដល់ភិក្ខុទាំងឡាយ ដែលជាបរិវារ ទ្រង់ធ្វើការបូជាដោយផ្កា និងគ្រឿងក្រអូបជាដើម ទ្រង់អារាធនាព្រះសាស្ដា ឲ្យប្រថាប់ក្នុងវិហារទីមួយៗ ថ្វាយមហាទាន ហើយទ្រង់យាងដល់មាត់ច្រាំង ស្ទឹងគង្គា ដោយរយៈកាល ៥ ថ្ងៃ ព្រះរាជាទ្រង់រៀបចំទូកក្នុងទីនោះ ទ្រង់

បញ្ជូនដំណឹងទៅដល់អ្នកក្រុងវេសាលីថា អ្នកក្រុងវេសាលី ចូររៀបចំធ្វើផ្លូវ ធ្វើការទទួលព្រះសាស្តាចុះ ។

អ្នកក្រុងវេសាលីទាំងនោះគិតថា យើងនឹងបូជាទ្វេគុណ ហើយពង្រាបផែនដីប្រមាណ ៣ យោជន៍ក្នុងរវាងក្រុងវេសាលី និងស្ទឹងគង្គាឲ្យស្មើ ហើយត្រៀមស្វេតច្ឆត្រ ដើម្បីព្រះសាស្តា ៤ ជាន់ ដើម្បីភិក្ខុមួយរូប ២ ជាន់ ធ្វើនូវការបូជា បានមកឈរត្រង់ច្រាំងស្ទឹងគង្គាហើយ ។

ព្រះបាទពិម្ពិសារទ្រង់រៀបចំទូក ២ ធ្វើឲ្យល្អ ប្រដាប់ដោយផ្កាជាដើម ក្រាលពុទ្ធាសនៈដោយរតនៈគ្រប់យ៉ាង ព្រះសាស្តាប្រថាប់គង់លើពុទ្ធាសនៈនោះ សូម្បីភិក្ខុទាំងឡាយក៏ឡើងកាន់ទូក អង្គុយចោមរោមព្រះសាស្តាហើយ ។ ព្រះរាជាកាលតាមជូនដំណើរ បានចុះទៅក្នុងទឹកប្រមាណត្រឹមព្រះសូរង ក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់យាងមកដរាបណា ខ្ញុំព្រះអង្គនឹងនៅត្រង់ច្រាំងស្ទឹងនេះឯងដរាបនោះ បញ្ជូនទូកទៅហើយ ទ្រង់យាងត្រឡប់ ។ ព្រះសាស្តាទៅក្នុងស្ទឹងគង្គាអស់ចម្ងាយ ១ យោជន៍ ដល់ដែនរបស់អ្នកក្រុងវេសាលី ។

ស្តេចលិច្ឆវីទាំងឡាយ ទ្រង់ទទួលព្រះសាស្តា លុយទឹកប្រមាណត្រឹមព្រះសូរង នាំទូកឡើងកាន់ច្រាំងហើយ យាងព្រះសាស្តាចុះអំពីទូក ។ កាលព្រះសាស្តាឡើងអំពីទូក ជាន់ច្រាំងស្ទឹងប៉ុណ្ណោះ មហាមេឃតាំងឡើង ញុំាងភ្លៀងបោក្ខរព័ស្សឲ្យធ្លាក់ហើយ ។ ក្នុងទីគ្រប់អន្លើ ទឹកប្រមាណត្រឹមក្បាលជង្គង់ត្រឹមភ្លៅ ត្រឹមចង្កេះហូរនាំសាកសពទាំងពួងចូលទៅកាន់ស្ទឹងគង្គាហើយ ភូមិភាគបានស្អាតហើយ ស្តេចលិច្ឆវីទាំងឡាយ ទូលឲ្យព្រះសាស្តាប្រថាប់នៅក្នុង

ទីមួយយោជន៍ថ្វាយមហាទាន ធ្វើការបូជាទ្វេដង នាំចូលទៅកាន់ក្រុងវេសាលីអស់ ៣ ថ្ងៃ ។ សក្កទេវរាជ កាលពួកទេវតាចោមរោម បានយាងមកហើយ ។ អមនុស្សទាំងឡាយបានគេចទៅដោយច្រើន ព្រោះទេវតាទាំងឡាយមានសក្តិធំប្រជុំគ្នាហើយ ។

ព្រះសាស្តា ប្រថាប់ឈរត្រង់ទ្វារនគរក្នុងពេលល្ងាច ត្រាស់ហៅព្រះអានន្ទមកហើយ ត្រាស់ថា អានន្ទ ចូរអ្នករៀនរតនសូត្រនេះ ហើយត្រាច់ទៅជាមួយលិច្ឆវីកុមារទាំងឡាយ ធ្វើព្រះបរិត្តក្នុងរវាងកំពែង ៣ ជាន់ក្នុងក្រុងវេសាលី ។ ព្រះថេរៈរៀនរតនសូត្រដែលព្រះសាស្តាប្រទាន ហើយយកបាត្រសម្រេចដោយថ្ម របស់ព្រះសាស្តាទៅដងទឹក ឈរត្រង់ទ្វារព្រះនគរហើយ ។ រម្លឹកដល់គុណរបស់ព្រះសាស្តាទាំងអស់ តាំងអំពីផ្តើមសេចក្តីព្យាយាមថា បារមី ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ មហាបរិច្ចាគ ៥ ចរិយា ៣ គឺលោកត្ថចរិយា ១ ញាតត្ថចរិយា ១ ពុទ្ធត្ថចរិយា ១ ការឈានកន្លងចុះកាន់គភ៌ក្នុងភពទីបំផុត ការប្រសូតិ ការយាងចេញមហាភិនេស្ក្រមណ៍ ការប្រព្រឹត្តព្យាយាម ការឈ្នះមារ ការចាក់ធ្លុះសព្វញ្ញុតញ្ញាណលើរតនបល្ល័ង្ក ត្រង់មណ្ឌលពោធិព្រឹក្ស ការញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ និងព្រះលោកុត្តរធម៌ ៩ ហើយចូលទៅកាន់ព្រះនគរ ត្រាច់ធ្វើព្រះបរិត្តក្នុងរវាងកំពែងទាំង ៣ អស់ ៣ យាមនៃរាត្រី កាលពាក្យថា **យំ កិញ្ចិ** ជាដើមដែលព្រះថេរៈនោះពោលហើយប៉ុណ្ណោះ ទឹកដែលប្រោសឡើងទៅខាងលើធ្លាក់លើក្បាលអមនុស្សទាំងឡាយ ។

ចាប់តាំងអំពីពោលគាថាថា **យានីធ ភូតានិ** ជាដើម តំណក់ទឹកហាក់បីដូចឈូតប្រាក់ តាំងឡើងនៅក្នុងអាកាស ហើយធ្លាក់ខាងលើមនុស្សទាំង-ឡាយដែលឈឺ ។ មនុស្សទាំងឡាយ ក៏ជាសះស្បើយរោគក្នុងរំពេចនោះឯង ហើយក្រោកឡើងចោមរោមព្រះថេរៈ ។ ចាប់តាំងអំពីបទថា **យំ កិញ្ចិ** ជាដើម ដែលព្រះថេរៈពោលហើយ អមនុស្សទាំងឡាយ ត្រូវតំណក់ទឹកប៉ះខ្លួនហើយ ដែលមិនទាន់គេចទៅកាលអំពីមុន ដែលអាស្រ័យគំនរសំរាម និងចំណែកនៃជញ្ជាំងផ្ទះជាដើម ក៏គេចទៅតាមទ្វារនោះៗ ទ្វារទាំងឡាយមិនគ្រប់គ្រាន់ ពួកអមនុស្សទាំងនោះ កាលមិនបានឱកាស ក៏ទំលុះកំពែងគេចទៅ ។ មហាជនប្រោះព្រំព្រះរាជមន្ទីរ ត្រង់កណ្តាលលានព្រះនគរ ដោយគ្រឿងក្រអូបទាំងពួង ចងពិដានដ៏វិចិត្រ ដោយផ្កាយមាសជាដើមខាងលើ តាក់តែងពុទ្ធាសនៈនាំព្រះសាស្តាមកហើយ ។

ព្រះសាស្តា ប្រថាប់គង់លើអាសនៈដែលតាក់តែងហើយ ភិក្ខុសង្ឃក្តី ស្តេចលិច្ឆវីក្តី អង្គុយចោមរោមព្រះសាស្តាហើយ ។ សក្កទេវរាជ ដែលពួកទេវតាចោមរោមហើយ បានប្រថាប់ឈរក្នុងឱកាសសមគួរ ។ ចំណែកព្រះថេរៈត្រាច់ទៅកាន់ព្រះនគរទាំងមូលដោយលំដាប់ហើយ មកជាមួយមហាជនដែលជាសះស្បើយរោគ ថ្វាយបង្គំព្រះសាស្តាអង្គុយហើយ ព្រះសាស្តាទ្រង់តមើលបរិស័ទហើយ ទ្រង់បានភាសិតរតនសូត្រនោះដដែលទៀត ក្នុងកាលចប់ទេសនាការត្រាស់ដឹងធម៌ មានដល់សត្វ ៨៤០០០ ហើយ ។

ព្រះសាស្តា ទ្រង់សម្តែងរតនសូត្រនោះអស់ ៧ ថ្ងៃ គឺក្នុងស្អែកឡើង

ក៏ទ្រង់សម្ដែងយ៉ាងនោះ ទ្រង់ជ្រាបភ័យទាំងពួងស្ងប់ហើយ ត្រាស់តៀនស្ដេចលិច្ឆវីហើយ យាងចេញអំពីនគរវេសាលី ស្ដេចលិច្ឆវីទាំងឡាយទ្រង់ធ្វើសក្ការៈទ្វេគុណ នាំព្រះសាស្ដាទៅកាន់ស្ទឹងគង្គាអស់ ៣ ថ្ងៃ ។

ស្ដេចនាគទាំងឡាយ ដែលកើតក្នុងស្ទឹងគង្គាគិតថា មនុស្សទាំងឡាយធ្វើសក្ការៈដល់ព្រះតថាគត យើងទាំងឡាយនឹងធ្វើអ្វីហ្ន៎ ស្ដេចនាគទាំងនោះនិម្មិតទូកសម្រេចដោយមាស ប្រាក់ និងកែវមណី រៀបចំបល្ល័ង្កសម្រេចដោយមាស ប្រាក់ និងកែវមណី ធ្វើទឹកឲ្យដេរដាសដោយផ្កាឈូក ៥ ពណ៌ ហើយទូលអារាធនាព្រះសាស្ដា ដើម្បីឡើងកាន់ទូករៀងៗ ខ្លួនថា បពិត្រព្រះអង្គសូមទ្រង់ធ្វើការអនុគ្រោះដល់ខ្ញុំព្រះអង្គទាំងឡាយចុះ មនុស្ស និងនាគទាំង-ឡាយ រមែងធ្វើការបូជាព្រះតថាគត ។

ទេវតាទាំងពួង តាំងអំពីទេវតាដែលស្ថិតក្នុងភាគផែនដី រហូតដល់ព្រហ្មលោកជាន់អកនិដ្ឋៈ គិតថា ពួកយើងនឹងធ្វើអ្វីហ្ន៎ ហើយធ្វើសក្ការៈ ។ បណ្ដាមនុស្ស និងអមនុស្សទាំងនោះ នាគទាំងឡាយ លើកស្វេតច្ឆត្រត្រួតគ្នាឡើង ប្រមាណ ១ យោជន៍ ឆត្រដែលត្រួតគ្នា ដែលមនុស្ស និងអមនុស្សទាំងឡាយ គឺនាគខាងក្រោម មនុស្សត្រង់ផែនដី ភុម្មដ្ឋកទេវតាត្រង់ដើមឈើគុម្ពឈើ និងក្លុំជាដើម អាកាសដ្ឋកទេវតាលើកត្រង់កណ្ដាលហើយ តាំងអំពីនាគពិភព រហូតដល់ព្រហ្មលោក មានជុំវិញចក្កវាឡជាទីបំផុត ដោយប្រការដូច្នេះ ។ ក្នុងរវាងឆត្រមានទង់ជ័យ ក្នុងរវាងទង់ជ័យមានទង់ជ្វាលា ក្នុងរវាងទង់ជ្វាលាមាន គ្រឿងសក្ការៈ មានផ្កាលម្អិត គ្រឿងអប់ និងគ្រឿងក្រអូប

ជាដើម ។ ទេវបុត្រទាំងឡាយ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កាន់យកកេទនៃអ្នកលេងមហោស្រព ត្រាច់ទៅក្នុងអាកាស ។ បានឮថា សមាគម ៣ កន្លែងប៉ុណ្ណោះ គឺសមាគមក្នុងពេលសម្តែងយមកប្បាដិហារ្យ ១ សមាគមក្នុងពេលទ្រង់ចុះអំពីទេវលោក ១ សមាគមក្នុងពេលចុះកាន់ស្ទឹងគង្គានេះ ១ ជាសមាគមធំ ។

ចំណែកព្រះបាទពិម្ពិសារ ទ្រង់ត្រៀមសក្ការៈទ្វេគុណ អំពីសក្ការៈដែលពួកស្តេចលិច្ឆវីធ្វើ ទ្រង់បានឈរមើលការយាងមករបស់ព្រះសាស្តាត្រង់ត្រើយម្ខាង ។ ព្រះសាស្តាទតនូវការបរិច្ចាគធំរបស់ព្រះរាជាទាំងឡាយ ក្នុងត្រើយស្ទឹងគង្គា និងទ្រង់ជ្រាបអធ្យាស្រ័យរបស់សត្វទាំងឡាយ មាននាគជាដើម ហើយទ្រង់និម្មិតព្រះពុទ្ធនិម្មិតមួយអង្គៗ មានភិក្ខុ ៥០០ ជាបរិវារក្នុងទូកនីមួយៗ ។ ព្រះដ៏មានព្រះភាគ កាលពួកនាគចោមរោមហើយ បានប្រថាប់គង់ខាងក្រោមស្វេតច្ឆត្រនីមួយៗ និងដើមកប្បព្រឹក្ស និងកម្រងផ្កា ។ ទ្រង់និម្មិតព្រះពុទ្ធនិម្មិតមួយអង្គៗ ព្រមទាំងបរិវារក្នុងឱកាសនីមួយៗ ក្នុងទេវតាទាំងឡាយ មានភុម្មដ្ឋកៈជាដើម ។ ក្នុងល្វែងនៃចក្កវាឡនីមួយៗ ហាក់បីដូចមានមហោស្រពតែមួយ និងមានការលេងតែមួយដោយប្រការដូច្នេះហើយ ព្រះសាស្តាកាលទ្រង់ធ្វើការអនុគ្រោះដល់នាគទាំងឡាយ បានយាងឡើងកាន់ទូកកែវមួយ សូម្បីភិក្ខុទាំងឡាយ ភិក្ខុមួយរូបៗ ក៏ឡើងកាន់ទូកមួយៗដូចគ្នា ។

ស្តេចនាគទាំងឡាយ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យចូលទៅកាន់នាគពិភព ស្តាប់ធម្មកថាក្នុងសម្នាក់របស់ព្រះសាស្តា អស់មួយប់ទល់ភ្លឺ

ក្នុងថ្ងៃទី ២ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយរបស់គួរទំពា ដោយរបស់គួរបរិភោគដែលជាទិព្វ ។ ព្រះសាស្ដាទ្រង់ធ្វើអនុមោទនាហើយ ចេញអំពីនាគពិភព ដែលទេវតាក្នុងចក្កវាឡទាំងមូលបូជា ទ្រង់ចូលស្ទឹងគង្គាដោយទូក ៥០០ ហើយ ។

ព្រះរាជា ទ្រង់ទទួលព្រះសាស្ដាឲ្យចុះអំពីទូក ទ្រង់ធ្វើសក្ការៈទ្វេគុណក្រៃលែងជាងសក្ការៈស្ដេចលិច្ឆវីទាំងឡាយ ដែលធ្វើក្នុងពេលយាងមក នាំព្រះសាស្ដាទៅកាន់ក្រុងរាជគ្រឹះ អស់ ៥ ថ្ងៃ ដោយន័យមុននោះឯង ។

ក្នុងថ្ងៃទី ២ ភិក្ខុត្រឡប់អំពីបិណ្ឌបាតហើយ ក្នុងពេលល្ងាចអង្គុយប្រជុំគ្នាក្នុងរោងធម្មសភាសន្ទនាគ្នាថា គួរសរសើរអានុភាពរបស់ព្រះពុទ្ធទាំងឡាយគួរអស្ចារ្យ ទេវតា និងមនុស្សទាំងឡាយនាំគ្នាជ្រះថ្លាក្នុងព្រះសាស្ដា ព្រះរាជាទាំងឡាយទ្រង់ធ្វើផែនដីឲ្យស្មើដោយចម្ងាយផ្លូវ ៨ យោជន៍ ទាំងត្រើយអាយនិងត្រើយនាយនៃស្ទឹងគង្គា រោយខ្សាច់ ក្រាលដោយផ្កាមានពណ៌ផ្សេងៗកម្ពស់ប្រមាណត្រឹមជង្គង់ ដោយការជ្រះថ្លាដែលប្រព្រឹត្តទៅហើយក្នុងព្រះពុទ្ធ ទឹកក្នុងស្ទឹងគង្គាក៏ដេរដាសដោយផ្កាឈូកមាន ៥ ពណ៌ ដោយអានុភាពរបស់នាគ ទេវតាទាំងឡាយក៏លើកឆត្រត្រួតៗ គ្នាឡើងរហូតដល់អកនិដ្ឋភព ល្វែងចក្កវាឡទាំងមូល មានគ្រឿងប្រដាប់តែមួយ និងមានមហោស្រពតែមួយ ។

ព្រះសាស្ដាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រឿងបូជា

និងសក្ការៈនេះ មិនបានកើតឡើងដល់តថាគតដោយពុទ្ធានុភាព មិនបានកើតឡើងដោយអានុភាពរបស់នាគ ទេវតា និងព្រហ្មឡើយ តែកើតដោយអានុភាពនៃការបរិច្ចាគមានប្រមាណតិចតួចក្នុងអតីត កាលភិក្ខុទាំងឡាយទូលអារាធនាហើយ ប្រាថ្នានឹងប្រកាសសេចក្តីនោះ ទើបទ្រង់នាំអតីតនិទាន មកត្រាស់ថា

ក្នុងអតីតកាល ក្នុងនគរតក្កសិលា មានព្រាហ្មណ៍ម្នាក់ ឈ្មោះសង្ខៈ មានកូនប្រុសម្នាក់ ឈ្មោះសុសិមៈ មានអាយុ ១៦ ឆ្នាំ ក្នុងថ្ងៃមួយសុសិមមាណពនោះ ចូលទៅរកបិតាហើយ ពោលថា បពិត្រលោកឪពុក ខ្ញុំប្រាថ្នានឹងទៅកាន់ក្រុងពារាណសី រៀនមន្ត ។ លំដាប់នោះ បិតាពោលនឹងមាណពថា នែបា បើដូច្នោះ ព្រាហ្មណ៍ឈ្មោះនោះ ជាសម្លាញ់របស់ឪពុក ចូរបាទៅកាន់សម្នាក់របស់សម្លាញ់នោះ ហើយរៀនចុះ បុរសនោះទទួលថា សាធុ ហើយទៅដល់ក្រុងពារាណសីដោយលំដាប់ ចូលទៅរកព្រាហ្មណ៍នោះហើយប្រាប់ភាពដែលខ្លួនបិតាបញ្ជូនមកហើយ ។

លំដាប់នោះ ព្រាហ្មណ៍នោះទទួលមាណពដោយគិតថា កូនសម្លាញ់របស់អញ ហើយប្រាប់មន្តដល់មាណព បុគ្គលមានសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ ដោយថ្ងៃចម្រើន សុសិមមាណពនោះរៀនដោយរហ័សផង រៀនបានច្រើនផង ទ្រទ្រង់ចាំនូវមន្តដែលរៀនហើយ មិនឲ្យវិនាសទៅ ហាក់បីដូចខ្លាញ់សីហៈ ដែលគេចាក់ក្នុងភាជន៍មាស ។ ក្នុងកាលមិនយូរប៉ុន្មាន បានរៀនមន្តទាំងឡាយអស់ ដែលខ្លួនគប្បីរៀនអំពីមាត់របស់អាចារ្យ ធ្វើការស្វាធ្យាយរមែងឃើញខាងដើម កណ្តាលនៃសិប្បៈដែលខ្លួនរៀនហើយប៉ុណ្ណោះ មិនឃើញ

ទីបំផុត ។ មាណពចូលទៅរកអាចារ្យហើយពោលថា ខ្ញុំឃើញតែខាងដើម និងកណ្តាលនៃសិប្បៈនេះប៉ុណ្ណោះ មិនឃើញខាងចុង កាលអាចារ្យពោលថា នែបា សូម្បីខ្ញុំក៏មិនឃើញដែរ ទើបសួរថា បពិត្រលោកអាចារ្យ កាលបើដូច្នោះ អ្នកណាដឹងទីបំផុត កាលអាចារ្យពោលថា នែបា ឥសីទាំងឡាយនៅក្នុងព្រៃឥសិបតនៈ ឥសីទាំងនោះ ដឹង ចូរអ្នកទៅកាន់សម្នាក់របស់លោកហើយ សួរចុះ ។ ទើបចូលទៅរកព្រះបច្ចេកពុទ្ធទាំងឡាយ ហើយសួរថា បានឮថា លោកម្ចាស់ទាំងឡាយដឹងនូវទីបំផុតឬ ព្រះបច្ចេកពុទ្ធទាំងឡាយពោលថា អើ អាត្មាទាំងឡាយ ដឹង សុសិមៈពោលថា បើដូច្នោះ សូមលោកម្ចាស់ទាំង-ឡាយប្រាប់ដល់ខ្ញុំចុះ ព្រះបច្ចេកពុទ្ធពោលថា អាត្មាទាំងឡាយមិនប្រាប់ដល់បុគ្គលដែលមិនមែនបព្វជិត បើអ្នកមានបំណងដឹងទីបំផុត ចូរបួសចុះ ។

សុសិមមាណពទទួលថា សាធុ ហើយបួសក្នុងសម្នាក់ព្រះបច្ចេកពុទ្ធទាំងនោះ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធទាំងនោះពោលនឹងសុសិមៈថា ចូរសិក្សាសេចក្តីនេះមុន ហើយប្រាប់អភិសមាចារិកវត្តដោយន័យជាដើមថា គប្បីស្លៀកយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ ។ លោកសិក្សាអភិសមាចារិកវត្តនោះ ព្រោះភាពដែលខ្លួនមានឧបនិស្ស័យបរិបូរ ក្នុងកាលមិនយូរក៏ត្រាស់ដឹងបច្ចេកពោ-ធិញ្ញាណ ប្រាកដក្នុងក្រុងពារាណសីទាំងមូល ដូចព្រះចន្ទពេញវង់ ប្រាកដកណ្តាលអាកាស បានជាបុគ្គលដល់នូវភាពប្រសើរដោយលាភ និងយស ។ ក្នុងកាលមិនយូរឡើយ លោកក៏បរិនិព្វាន ព្រោះភាពនៃកម្មដែលឲ្យផល ជាអ្នកមានអាយុខ្លីដែលលោកបានធ្វើហើយ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធទាំង-

ឡាយ និងមហាជននាំគ្នាធ្វើសរីរកិច្ចរបស់លោក កាន់យកធាតុប្រតិស្ឋានព្រះស្តូបទុកក្បែរទ្វារព្រះនគរ ។

ចំណែកសង្ខព្រាហ្មណ៍គិតថា កូនរបស់អញទៅយូរហើយ អញនឹងដឹងការប្រព្រឹត្តទៅរបស់កូនអញ ប្រាថ្នានឹងឃើញកូន ទើបចេញពីនគរតក្កសិលាដល់នគរពារាណសីដោយលំដាប់ ឃើញពួកមហាជនប្រជុំគ្នាហើយគិតថា ក្នុងជនទាំងនេះ សូម្បីជនម្នាក់ស្គាល់ការប្រព្រឹត្តទៅកូនរបស់អញដោយពិត ទើបចូលទៅរកហើយសួរថា មាណពឈ្មោះសុសិមៈមកក្នុងទីនេះ អ្នកទាំងឡាយជ្រាបការប្រព្រឹត្តទៅរបស់គេដែរឬ មហាជនឆ្លើយថា អើ ព្រាហ្មណ៍ យើងដឹង សុសិមមាណពនោះ ស្វាធ្យាយត្រៃវេទក្នុងសម្នាក់របស់ព្រាហ្មណ៍ឈ្មោះនោះ បួសហើយ ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ បរិនិព្វានហើយ នេះស្តូបរបស់លោក ដែលយើងទាំងឡាយធ្វើហើយ ។ សង្ខព្រាហ្មណ៍នោះប្រហារដីដោយដៃ កន្ទក់កន្ទេញហើយ ទៅកាន់លានព្រះចេតិយដកស្មៅ យកសំពត់វេចខ្សាច់មករោយត្រង់លានព្រះចេតិយ ប្រោះដោយទឹក ហើយប្រោះព្រំដោយទឹកក្រអូប បូជាដោយផ្កា លើកទង់សំពត់សាដក ចងឆត្ររបស់ខ្លួនអំពីខាងលើនៃព្រះស្តូប ហើយក៏ចៀសចេញទៅ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះតថាគតជាសង្ខព្រាហ្មណ៍ បានដកស្មៅក្នុងលានព្រះចេតិយរបស់ព្រះបច្ចេកពុទ្ធ ឈ្មោះសុសិមៈ ដោយផលនៃកម្មរបស់តថាគតនោះ ទើបជនទាំងឡាយធ្វើផ្លូវ ៨ យោជន៍ ឲ្យប្រាសចាកជង្គត់ និងបន្ទាឲ្យ

ស្អាត មានផ្ទៃរាបស្មើ តថាគតបានរោយខ្សាច់ក្នុងលានព្រះចេតិយនោះ ដោយផលនៃកម្មរបស់តថាគតនោះ ទើបជនទាំងឡាយក្រាលខ្សាច់ក្នុងផ្លូវប្រមាណ ៨ យោជន៍ហើយ ធ្វើនូវការបូជាដោយផ្កាក្នុងព្រៃ ត្រង់ព្រះស្តូបនោះ ដោយផលនៃកម្មរបស់តថាគតនោះ ទើបជនទាំងឡាយរោយផ្កាមានពណ៌ផ្សេងៗក្នុងផ្លូវ ៨ យោជន៍ ទឹកក្នុងគង្គាក្នុងទីប្រមាណមួយយោជន៍ ដេរដាសដោយផ្កាឈូក ៥ ពណ៌ តថាគតបានប្រោះព្រំផ្ទៃដីក្នុងលានព្រះចេតិយនោះ ដោយទឹកក្នុងឃ្លោក ដោយផលនៃកម្មរបស់តថាគតនោះ ទើបភ្លៀងបោក្ខរព័ស្សធ្លាក់ចុះក្នុងនគរវេសាលី តថាគតបានលើកទង់សំពត់ហើយ និងបង់ឆត្រអំពីខាងលើព្រះចេតិយនោះ ដោយផលនៃកម្មរបស់តថាគតនោះ ទើបល្វែងនៃចក្កវាឡទាំងមូល ហាក់បីដូចមានមហោស្រពតែមួយ ដោយទង់ជ័យ ទង់ផ្កាលា និងឆត្ររួតរបូតដល់អកនិដ្ឋកភព ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនេះឯងទើបសក្ការៈនោះកើតឡើងដល់តថាគត មិនមែនដោយពុទ្ធានុភាពឡើយ កើតឡើងដោយអានុភាពនៃនាគ ទេវតា និងព្រហ្មក៏មិនមែន តែកើតឡើងដោយអានុភាពនៃការបរិច្ចាគមានប្រមាណតិចក្នុងអតីតកាល ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ**
**ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។**

បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មម
ប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខធំទូលាយ

គប្បីលះសុខល្មមប្រមាណចេញ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មត្តាសុខបរិច្ចាគា** សេចក្តីថា ព្រោះលះសុខតូចតាចល្មមប្រមាណ ដែលព្រះដ៏មានព្រះភាគត្រាស់ថា **មត្តាសុខំ ។** សុខដ៏ឧឡារ បានដល់ សុខ គឺព្រះនិព្វាន ព្រះដ៏មានព្រះភាគត្រាស់ថា សុខដ៏ទូលាយ សេចក្តីថា បើបុគ្គលគប្បីឃើញសុខដ៏ទូលាយនោះ ។

លោកអធិប្បាយដូច្នេះថា ឈ្មោះថា សុខល្មមប្រមាណ តែងកើតឡើងដល់បុគ្គលដែលឲ្យចាត់ចែងថាសភោជនមួយ ហើយបរិភោគ ចំណែកឈ្មោះថានិព្វានសុខដ៏ទូលាយ គឺដ៏ឧឡារ រមែងកើតឡើងដល់បុគ្គលដែលលះសុខល្មមប្រមាណនោះចេញ ហើយធ្វើឧបោសថខ្លះ ឲ្យទានខ្លះ ព្រោះហេតុនោះ បើបុគ្គលឃើញសុខដ៏ទូលាយ ព្រោះលះសុខល្មមប្រមាណនោះ យ៉ាងនោះ កាលបើដូច្នោះ បណ្ឌិតកាលឃើញសុខដ៏ទូលាយនោះដោយប្រពៃ ក៏គប្បីលះសុខល្មមប្រមាណនោះចេញ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង បុព្វកម្មព្រះសាស្តា ចប់**

# រឿង កុមារិកាបរិភោគពងមាន់

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារិកាដែលស៊ីពងមាន់ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **បរទុក្ខូបធានេន** ជាដើម ។

បានឮថា ស្រុកមួយឈ្មោះបណ្ឌុរៈ នៅមិនឆ្ងាយអំពីក្រុងសាវត្ថី ក្នុងស្រុកនោះមានអ្នកប្រមង់ម្នាក់ បុរសនោះកាលចូលទៅកាន់ក្រុងសាវត្ថី ឃើញពងអណ្ដើកត្រង់ច្រាំងស្ទឹងអចិរវតីហើយ កាន់យកពងអណ្ដើកនោះ ទៅកាន់ក្រុងសាវត្ថី ឲ្យស្ងោរក្នុងផ្ទះមួយខ្នងហើយបរិភោគ បានឲ្យពងមួយដល់កុមារិកាក្នុងផ្ទះនោះ ។ កុមារិកាបានបរិភោគពងអណ្ដើកនោះហើយ ចាប់តាំងអំពីនោះមិនប្រាថ្នានូវរបស់ទំពាដទៃ ។ កាលនោះ មាតារបស់នាងកាន់យកពងមួយអំពីសម្បុកមាន់ហើយឲ្យដល់កុមារិកានោះ ។ កុមារិកាបរិភោគពងនោះហើយត្រូវចំណង់ក្នុងរសចងហើយ ចាប់តាំងអំពីនោះ ក៏កាន់យកពងមាន់មកបរិភោគឯង ។ ក្នុងពេលពង មេមាន់ឃើញកុមារិកានោះកាន់យកពងរបស់ខ្លួនទំពាស៊ីត្រូវកុមារិកានោះបៀតបៀនហើយ ចងអាឃាតតាំងសេចក្ដីប្រាថ្នាថា ឥឡូវនេះអញឃ្លាតចាកអត្តភាពនេះហើយ គប្បីកើតជាយក្ខិនី ជាអ្នកអាចទំពាស៊ីទារករបស់ហាង ធ្វើកាលកិរិយាហើយកើតជាឆ្មាក្នុងផ្ទះនោះឯង ។

នាងកុមារិកានោះ ធ្វើកាលកិរិយាហើយកើតជាមេមាន់ក្នុងផ្ទះនោះ ដូចគ្នា ។ មេមាន់ពងហើយ មេឆ្មាទំពាស៊ីនូវពងទាំងនោះហើយ សូម្បីលើកទីពីរលើកទីបី ក៏ទំពាស៊ីដូចគ្នា ។ មេមាន់ធ្វើសេចក្ដីប្រាថ្នាថា ហាងទំពាស៊ីពងទាំង-ឡាយរបស់អញ ២-៣ ដង ឥឡូវនេះ ចង់ប្រាថ្នានឹងស៊ីអញទៀត អញឃ្លាត

ចាកអត្តភាពនេះហើយ គប្បីស៊ីហង្ស ព្រមទាំងកូន ។ កាលឃ្លាតចាកអត្តភាព នោះហើយ កើតជាមេខ្លា ។

ឯមេធ្នា ស្លាប់ហើយ កើតជាមេម្រឹគ ។ ក្នុងពេលម្រឹគនោះកើតកូនហើយ មេខ្លាក៏មកទំពាស៊ីមេម្រឹគនោះ មួយអន្លើដោយកូនទាំងឡាយ ។ សត្វទាំងពីរនោះ ទំពាស៊ីនូវគ្នានិងគ្នាយ៉ាងនេះ ញុំាងទុក្ខឲ្យកើតឡើងដល់គ្នានិងគ្នាអស់ ៥០០ អត្តភាព ក្នុងទីបំផុតនាងម្នាក់កើតជាយក្ខិនី នាងម្នាក់កើតជាកុលធីតាក្នុងក្រុងសាវត្ថី ។

រឿងបន្ទាប់អំពីនេះទៅ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងព្រះគាថាថា **ន ហិ វេរេន វេរានិ** ជាដើមនោះឯង ។

តែក្នុងរឿងនេះ ព្រះសាស្តាត្រាស់ថា ពៀររមែងរម្ងាប់ដោយការមិនមានពៀរ រមែងមិនរម្ងាប់ដោយពៀរ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ដល់ជនទាំងពីរ ទើបត្រាស់ព្រះគាថានេះថា

**បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ**
**វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។**

ជនប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយបន្ទុកទុក្ខឲ្យអ្នកដទៃ
ជននោះ ឈ្មោះថា ច្រឡូកច្របល់ហើយដោយការជាប់
ជំពាក់ គឺពៀរ រមែងមិនរួចចាកពៀរទេ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បរទុក្ខូបធានេន** សេចក្តីថា ព្រោះញុំាង

ទុក្ខឲ្យអ្នកដទៃ អធិប្បាយថា ព្រោះញុំាងទុក្ខឲ្យកើតឡើងដល់អ្នកដទៃ ។

បាទព្រះគាថាថា **វេរសំសគ្គសំសដ្ឋោ** សេចក្តីថា បុគ្គលនោះលាយឡំហើយដោយគ្រឿងលាយឡំ គឺពៀរ ដែលខ្លួនធ្វើឲ្យដល់គ្នានិងគ្នា គឺដោយអំណាចនៃការជេរ និងការជេរតប ការប្រហារ និងការប្រហារតបជាដើម ។

បាទព្រះគាថាថា **វេរា សោ ន បរិមុច្ចតិ** សេចក្តីថា រមែងដល់នូវទុក្ខតែម្យ៉ាង អស់កាលជានិច្ច ដោយអំណាចនៃពៀរ ។

ក្នុងកាលចប់ទេសនា យក្ខិនីតាំងនៅក្នុងសរណៈទាំងឡាយ សមាទានសីល ៥ ផុតហើយចាកពៀរ ចំណែកកុលធីតា តាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ៕

**រឿង កុមារិកាបរិភោគពងមាន់ ចប់**

# រឿង ភិក្ខុអ្នកនគរកទ្ទិយៈ

## លំនាំដើម

ព្រះសាស្តា កាលអាស្រ័យកទ្ទិយនគរ ប្រថាប់នៅក្នុងជាតិយាវ័ន ទ្រង់ប្រារព្ធភិក្ខុអ្នកកទ្ទិយនគរ ត្រាស់ព្រះធម្មទេសនានេះថា **យញ្ហិ កិច្ចំ** ជាដើម ។

បានឮមកថា ភិក្ខុអ្នកកទ្ទិយនគរទាំងនោះ ជាអ្នកខ្វល់ខ្វាយក្នុងការប្រដាប់ទ្រនាប់ជើង សមដូចព្រះឧបាលិត្ថេរពោលថា សម័យនោះឯង ពួកកទ្ទិយភិក្ខុ ( ភិក្ខុដែលនៅក្នុងក្រុងកទ្ទិយៈ ) មានសេចក្តីខ្វល់ខ្វាយក្នុងការប្រដាប់ទ្រនាប់

ជើង មានប្រការផ្សេងៗ គឺធ្វើទ្រនាប់ជើងស្មៅខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅយាប្លងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅជំណេកទន្សាយខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្លឹកទន្សែខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ។បេ។ ធ្វើទ្រនាប់ជើងសំពត់ ដែលគេត្បាញដោយរោមសត្វខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ហើយលះបង់នូវបាលី អដ្ឋកថា អធិសីល អធិចិត្ត និងអធិប្បញ្ញាសោះ ។ វេលានោះ ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះ ដល់ព្រះព្រះមានព្រះភាគ ។

ព្រះសាស្តា ទ្រង់តិះដៀលភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មកដោយកិច្ចដទៃហើយ ខ្វល់ខ្វាយក្នុងកិច្ចដទៃដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានត្រាស់ព្រះគាថាទាំងនេះថា

**យញ្ហិ កិច្ចំ តទបវិទ្ធំ អកិច្ចំ បន កយិរតិ**
**ឧន្នឡានំ បមត្តានំ តេសំ វឌ្ឍន្តិ អាសវា**
**យេសញ្ច សុសមារទ្ធា និច្ចំ កាយគតា សតិ**
**អកិច្ចន្តេ ន សេវន្តិ កិច្ចេ សាតច្ចការិនោ**
**សតានំ សម្បជានានំ អត្ថំ គច្ឆន្តិ អាសវា ។**

របស់ណាដែលខ្លួនគួរធ្វើ របស់នោះ ពួកភិក្ខុណា លះបង់
ចោលហើយ តែរបស់ដែលមិនគួរធ្វើ ត្រឡប់ជាធ្វើវិញ
អាសវៈទាំងឡាយ តែងចម្រើនឡើង ដល់ពួកភិក្ខុនោះ ជា
អ្នកមានសេចក្តីប្រមាទ មានមានះដូចជាដើមបបុសលើក

ឡើងហើយ ។ លុះតែសតិប្រព្រឹត្តទៅ ក្នុងកាយជានិច្ច ដែលពួកភិក្ខុណា បានប្រារព្ធប្រព្រឹត្តហើយ ភិក្ខុទាំងនោះ រមែងជាអ្នកធ្វើការដែលគួរធ្វើរឿយៗ មិនធ្វើការដែលមិនគួរធ្វើ អាសវៈទាំងឡាយ របស់ពួកភិក្ខុនោះ ដែលជាអ្នកមានសតិ មានសម្បជញ្ញៈ រមែងដល់នូវការអស់ទៅ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យញ្ហិ កិច្ចំ** សេចក្តីថា កម្មមានយ៉ាងនេះ គឺការគ្រប់គ្រងសីលក្ខន្ធដែលមិនមានប្រមាណ ការនៅព្រៃជាវត្ត ការរក្សាធុតង្គ ភាពជាអ្នកត្រេកអរក្នុងភាវនា ឈ្មោះថា ជាកិច្ចដែលគួរធ្វើរបស់ភិក្ខុ តាំងអំពីកាលបួសហើយ ។ តែភិក្ខុទាំងនេះ លះបង់ គឺរលាស់ចោលនូវកិច្ចដែលគួរធ្វើរបស់ខ្លួន ។

បទថា **អកិច្ចំ** ជាដើម សេចក្តីថា ការប្រដាប់ឆត្រ ការប្រដាប់ស្បែកជើង ការប្រដាប់ទ្រនាប់ជើង បាត្រ ស្មុគ ធម្មក្រក វត្តពន្ធចង្កេះ អង្រឹក ឈ្មោះថា ជាកិច្ចមិនគួរធ្វើរបស់ភិក្ខុ អធិប្បាយថា ភិក្ខុពួកណា ធ្វើវត្ថុនោះ អាសវៈទាំង ៤ រមែងចម្រើនដល់ភិក្ខុទាំងនោះ ដែលឈ្មោះថា មានមានះដូចដើមបបុស ដែលលើកឡើងហើយ ព្រោះការលើកមានះ ដូចដើមបបុសត្រាច់ទៅ ឈ្មោះថា ប្រមាទហើយ ព្រោះបណ្តោយបណ្តោយសតិ ។

បទថា **សុសមារទ្ធា** បានដល់ ផ្គងល្អហើយ ។ ពីរបទថា **កាយ-គតាសតិ** បានដល់ ភាវនាដែលជាគ្រឿងតាមឃើញនូវកាយ ។

បទថា **អកិច្ចំ** សេចក្តីថា ភិក្ខុទាំងនោះ មិនសេព គឺមិនធ្វើវត្ថុដែលមិនគួរធ្វើនោះ មានការប្រដាប់ឆត្រជាដើម ។

បទថា **កិច្ចេ** សេចក្តីថា ក្នុងវត្ថុដែលខ្លួនគប្បីធ្វើ គឺក្នុងករណី មានការគ្រប់គ្រងសីលក្ខន្ធដែលមិនមានប្រមាណជាដើម ចាប់តាំងអំពីកាលដែលបួសហើយ ។

បទថា **សាតច្ចការិនោ** បានដល់ មានប្រក្រតីធ្វើរឿយៗ គឺធ្វើមិនឈប់ អធិប្បាយថា អាសវៈទាំង ៤ របស់ភិក្ខុទាំងនោះ ដែលឈ្មោះថាមានសតិ ព្រោះមិនទៅប្រាសចាកសតិ បុគ្គលឈ្មោះថាមានសម្បជញ្ញៈ ព្រោះសម្បជញ្ញៈ ៤ យ៉ាង គឺសាថកសម្បជញ្ញៈ ១ សប្បាយសម្បជញ្ញៈ ១ គោចរសម្បជញ្ញៈ ១ អសម្មោហសម្បជញ្ញៈ ១ រមែងដល់នូវការតាំងនៅមិនបាន គឺដល់នូវការអស់ទៅ បានដល់ មិនមាន ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះ តាំងនៅក្នុងអរហត្តផល ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។៚

**រឿង ភិក្ខុអ្នកនគរភទ្ទិយៈ ចប់**

# រឿង លកុណ្ឋកភទ្ទិយត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលកុណ្ឋក-ភទ្ទិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **មាតរំ បិតរំ ហន្ត្វា** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ អាគន្តុកភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ ប្រថាប់នៅក្នុងទីប្រថាប់ពេលថ្ងៃ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ខណៈនោះ ព្រះលកុណ្ឋកភទ្ទិយត្ថេរ ដើរឆ្លងទៅក្នុងទីមិនឆ្ងាយអំពីព្រះដ៏មានព្រះភាគ ។

ព្រះសាស្តា ទ្រង់ជ្រាបវារៈចិត្តរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឃើញឬ ភិក្ខុនេះសម្លាប់មាតាបិតាហើយ ជាអ្នកមិនមានទុក្ខ ។ កាលភិក្ខុទាំងនោះ មើលមុខគ្នានឹងគ្នាហើយ មានសេចក្តីសង្ស័យថា ព្រះសាស្តាត្រាស់អ្វីហ្ន៎ ទើបក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ត្រាស់ដូចម្តេច កាលទ្រង់សម្តែងធម៌ដល់ភិក្ខុទាំងនោះ ទើបត្រាស់ព្រះគាថានេះ

**មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ**
**រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។**

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានៈដូចបិតាផង សម្លាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិដូចជាក្សត្រពីរព្រះអង្គផង សម្លាប់អាយតនៈដូចជាដែន ប្រព្រឹត្តទៅមួយអន្លើដោយបុរសអ្នកដើរតាម គឺស្នៀនផង រមែងបានទៅជាខីណាស្រវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សាធុចរំ** បានដល់ ប្រព្រឹត្តទៅដោយអ្នកចាត់ការស្ទួយឲ្យសម្រេច គឺក្នាក់ងារអ្នកគ្រប់គ្រងស្ទួយ ។

ក្នុងព្រះគាថានេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យថា តណ្ហា ឈ្មោះថា មាតា ព្រោះឲ្យសត្វទាំងឡាយកើតក្នុងភព ៣ ព្រោះព្រះបាលីថា តណ្ហាញុំាងបុរសឲ្យកើត ។

អស្មិមានះ ឈ្មោះថា បិតា ព្រោះអស្មិមានះអាស្រ័យបិតាកើតឡើងថា អញជារាជឱរសរបស់ព្រះរាជាឈ្មោះនោះ ឬអញជាកូនរបស់អមាត្យ របស់ព្រះរាជាឈ្មោះនោះជាដើម ។

ទិដ្ឋិគ្រប់យ៉ាងតែងអាស្រ័យសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិទាំងពីរ ដូចសត្វលោកអាស្រ័យព្រះរាជា ដូច្នោះ ព្រោះហេតុនោះ ទើបសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ឈ្មោះថា ជាក្សត្រពីរព្រះអង្គ ។

អាយតនៈ ១២ ឈ្មោះថា ដែន ព្រោះដូចគ្នានឹងដែន ដោយអត្ថថាទូលំទូលាយ ។ តម្រេកដោយសេចក្តីត្រេកអរ ដែលអាស្រ័យអាយតនៈនោះ ដូចស្មៀនចាត់ការស្ទួយឲ្យសម្រេច ឈ្មោះថា ជាក្នាក់ងាររក្សាស្ទួយ ។

បទថា **អនីឃោ** បានដល់ មិនមានទុក្ខ ។ បទថា **ព្រាហ្មណោ** បានដល់ បុគ្គលមានអាសវៈអស់ហើយ ។

ក្នុងព្រះគាថានេះ មានអធិប្បាយដូច្នេះថា បុគ្គលឈ្មោះថាមានអាសវៈអស់ហើយ ព្រោះកិលេសទាំងនោះ មានតណ្ហាជាដើម ដែលខ្ញុំនកម្ចាត់បានដោយដាវ គឺអរហត្តមគ្គញាណ ទើបជាអ្នកមិនមានទុក្ខ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះតាំងនៅក្នុងអរហត្តហើយ ។

**រឿងលកុណ្ឌកភទ្ទិយត្ថេរ ចប់**

ក្នុងគាថាទីពីរ រឿងក៏ដូចគ្នានឹងរឿងមុននោះឯង ។

ក្នុងកាលនោះ ព្រះសាស្តាទ្រង់ប្រារព្ធព្រះលកុណ្ឌកភទ្ទិយត្ថេរដូចគ្នា កាលសម្តែងធម៌ដល់ភិក្ខុទាំងនោះ ទើបត្រាស់ព្រះគាថានេះថា

**មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច សោត្ថិយេ**
**វេយ្យគ្ឃបញ្ចមំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។**

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិដូចជាស្តេច ជាព្រាហ្មណ៍ទាំងពីរផង សម្លាប់វិចិកិច្ឆា ដូចជាខ្លាធំ ជាគម្រប់ ៥ ផង ( ដែលនៅស្កាត់ផ្លូវ ) បានហើយ រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទ្វេ ច សោត្ថិយេ** គឺព្រាហ្មណ៍ទាំងពីរផង ។

ក្នុងព្រះគាថានេះ ព្រះសាស្តាត្រាស់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ឲ្យជាព្រះរាជា ដែលជាព្រាហ្មណ៍ទាំងពីរ ព្រោះទ្រង់ជាជំក្នុងធម៌ និងព្រោះទ្រង់ជាអ្នកឈ្លាសក្នុងវិធីទេសនា ។

បណ្ឌិតគប្បីជ្រាបវិគ្គហៈ ក្នុងបទ **វេយគ្ឃបញ្ចមំ** នេះថា ផ្លូវដែលខ្លាធំត្រាច់ទៅមានភ័យដោយជុំវិញ ដើរទៅលំបាក ឈ្មោះថា ផ្លូវដែលខ្លាធំត្រាច់ទៅហើយ ។ វិចិកិច្ឆានីវរណៈ ឈ្មោះថា ជាផ្លូវដែលខ្លាធំត្រាច់ទៅហើយ ព្រោះការដែលវិចិកិច្ឆានីវរណៈនោះ ដូចគ្នានឹងផ្លូវដែលខ្លាធំត្រាច់ទៅហើយនោះ វិចិកិច្ឆានីវរណៈ ដូចគ្នានឹងផ្លូវដែលខ្លាធំត្រាច់ទៅហើយនោះ ជាគម្រប់ ៥ នៃពួក ៥ របស់នីវរណៈនោះ ព្រោះដូច្នោះ ទើបនីវរណបញ្ចកៈ ឈ្មោះថា មានវិចិកិច្ឆានីវរណៈ ដូចគ្នានឹងផ្លូវដែលខ្លាធំត្រាច់ទៅហើយ ជាគម្រប់ ៥ ។

ក្នុងគាថាទីពីរនេះ មានអធិប្បាយដូច្នេះថា បុគ្គលសម្លាប់បញ្ចកនីវរណៈមានវិចិកិច្ឆាជាគម្រប់ ៥ ដូចគ្នានឹងផ្លូវដែលខ្លាធំត្រាច់ទៅហើយនេះ មិនឲ្យមានសេសសល់ដោយដាវ គឺអរហត្តមគ្គញាណ ជាព្រាហ្មណ៍មិនមានទុក្ខ ត្រាច់ទៅ ។ បទដ៏សេស ដូចគ្នានឹងបទមុននោះឯងដូច្នេះ ៕

**រឿងលកុណ្ឌកភទ្ទិយត្ថេរ ចប់**

# រឿង ទារុសាកដិកៈ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុត្ររបស់ទារុសាកដិកៈ ត្រាស់ព្រះធម្មទេសនានេះថា **សុប្បពុទ្ធំ** ជាដើម ។

សេចក្ដីពិស្ដារថា ក្មេងក្នុងនគររាជគ្រឹះពីរនាក់ គឺកូនរបស់បុគ្គលដែលជាសម្មាទិដ្ឋិម្នាក់ និងកូនរបស់បុគ្គលដែលជាមិច្ឆាទិដ្ឋិម្នាក់ លេងឃ្លីជាមួយគ្នារឿយៗ ។ ក្មេងទាំងពីរនោះ កូនរបស់សម្មាទិដ្ឋិបុគ្គល កាលបាញ់ឃ្លី រឭកដល់ពុទ្ធានុស្សតិថា **នមោពុទ្ធស្ស** ហើយទើបបាញ់ ។ ក្មេងក្រៅពីនេះ រឭកចំពោះគុណទាំងឡាយរបស់ពួកតិរ្ថិយថា **នមោ អរហន្តានំ** ហើយទើបបាញ់ ក្មេងទាំងពីរ បុត្ររបស់បុគ្គលដែលជាសម្មាទិដ្ឋិ រមែងឈ្នះ ក្មេងក្រៅអំពីនេះរមែងចាញ់ ។ កូនរបស់មិច្ឆាទិដ្ឋិបុគ្គលនោះ ឃើញកិរិយាបុត្ររបស់បុគ្គលសម្មាទិដ្ឋិនោះហើយ គិតថា សម្លាញ់អញនេះ រឭកយ៉ាងនោះហើយ ពោលយ៉ាងនោះហើយ បាញ់ឃ្លីទៅ ទើបឈ្នះអញ អញនឹងធ្វើយ៉ាងនោះដែរ ដោយធ្វើការសន្សំក្នុងពុទ្ធានុស្សតិហើយ ។

ថ្ងៃមួយ បិតារបស់ក្មេងដែលជាសម្មាទិដ្ឋិនោះ ទឹមរទេះហើយដើម្បីទៅរកឧស បាននាំកុមារនោះទៅហើយ ដាក់ឈើពេញរទេះក្នុងព្រៃបរមក ដល់ខាងក្រៅនគរ ដោះគោក្នុងទីដែលមានការសម្បូរដោយទឹក ក្នុងទីជិតព្រៃខ្មោច ហើយធ្វើការបាត់បែងកត្ត ។

លំដាប់នោះ គោរបស់បុរសនោះ ចូលទៅកាន់នគរជាមួយហ្វូងគោដែលចូលទៅកាន់នគរក្នុងពេលល្ងាច ។ សាកដិកៈដើរតាមគោទៅដល់នគរហើយ

ក្នុងពេលល្ងាច ជួបគោហើយដឹកមកមិនទាន់ដល់ទ្វារ ទ្វារបិទហើយ ។ ខណៈនោះ កូនរបស់គាត់ម្នាក់ឯងប៉ុណ្ណោះដេកហើយក្រោមរទេះ ក្នុងចំណែកនៃរាត្រីឈានចូលកាន់និទ្រាហើយ ។

ក្រុងរាជគ្រឹះតាមប្រក្រតីច្រើនទៅដោយអមនុស្ស ម្យ៉ាងទៀត ក្មេងនេះក៏ដេកហើយក្នុងទីមិនឆ្ងាយអំពីព្រៃខ្មោច ។ ពួកអមនុស្ស ក្នុងទីជិតព្រៃខ្មោចនោះឃើញកុមារហើយ ។ អមនុស្សមួយរូបជាមិច្ឆាទិដ្ឋិ ជាបច្ចាមិត្រចំពោះព្រះសាសនា អមនុស្សមួយទៀត ជាសម្មាទិដ្ឋិ ។

ក្នុងអមនុស្សទាំងពីរនោះ អមនុស្សដែលជាមិច្ឆាទិដ្ឋិពោលថា ក្មេងនេះជាចំណីរបស់ពួកយើង ពួកយើងនឹងទំពាស៊ីក្មេងនេះ ។ អមនុស្សដែលជាសម្មាទិដ្ឋិ ឃាត់អមនុស្សដែលជាមិច្ឆាទិដ្ឋិនោះដោយពាក្យថា កុំឡើយ អ្នកកុំពេញចិត្តឡើយ ។ អមនុស្សដែលជាមិច្ឆាទិដ្ឋិនោះ សូម្បីត្រូវអមនុស្សដែលជាសម្មាទិដ្ឋិនោះឃាត់ ក៏មិនអើពើនឹងពាក្យរបស់អមនុស្សនោះ ចាប់ជើងទាញមកហើយ ។ ក្នុងខណៈនោះក្មេងនោះពោលថា **នមោ ពុទ្ធស្ស** ព្រោះភាពជាអ្នកសន្សំក្នុងពុទ្ធានុស្សតិ ។ អមនុស្សនោះខ្លាចកិតភ័យ ទើបថយទៅឈរហើយ ។

លំដាប់នោះ អមនុស្សដែលជាសម្មាទិដ្ឋិក្រៅអំពីនេះ ពោលនឹងអមនុស្សដែលជាមិច្ឆាទិដ្ឋិនោះថា ពួកយើងធ្វើវត្ថុដែលមិនគួរធ្វើហើយ ពួកយើងចូរធ្វើទណ្ឌកម្មដើម្បីក្មេងនោះចុះ ដូច្នេះហើយ ឈររក្សាក្មេងនោះ អមនុស្សដែលជាមិច្ឆាទិដ្ឋិ ចូលទៅកាន់ព្រះនគរ ញុំាំងថាសភោជនរបស់ព្រះរាជាឲ្យពេញហើយ

នាំភោជនមក ។

តមក អមនុស្សទាំងពីរហាក់ដូចជាមាតា និងបិតារបស់ក្មេងនោះ លើកក្មេងនោះឲ្យក្រោកឡើង ឲ្យបរិភោគភោជននោះ ប្រកាសការប្រព្រឹត្តទៅនោះហើយចារឹកអក្សរត្រង់ថាសភោជន ដោយអនុភាពរបស់យក្ខ ដោយអធិដ្ឋានថា ព្រះរាជាប៉ុណ្ណោះ ចូរឃើញអក្សរទាំងនេះ អ្នកដទៃកុំបីឃើញឡើយ ដូច្នេះហើយ ទើបទៅ ។

ស្អែកឡើង ពួករាជបុរសធ្វើនូវកោលាហលថា ពួកចោរលួចកណ្ឋៈ គឺភាជនៈទៅអំពីរាជត្រកូលហើយ ទើបបិទទ្វារទាំងឡាយរកមើល កាលមិនឃើញក្នុងព្រះនគរ ទើបចេញទៅអំពីព្រះនគរ រកមើលក្នុងទីផ្សេងៗ ក៏ឃើញថាសជាវិការនៃមាសលើរទេះដែលដាក់ឧស ទើបចាប់ក្មេងនោះ ដោយសម្គាល់ថា នេះជាចោរ ដូច្នេះហើយ បង្ហាញដល់ព្រះរាជា ។

ព្រះរាជាទតឃើញអក្សរទាំងឡាយហើយត្រាស់សួរថា នេះជាអ្វី កុមារនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនជ្រាប មាតាបិតារបស់ទូលបង្គំមកឲ្យបរិភោគក្នុងរាត្រី ហើយបានឈររក្សា ទូលបង្គំគិតថា មាតាបិតារក្សាអញ ទើបមិនមានការភ័យខ្លាច ចូលដល់នូវការនិទ្រាហើយ ទូលបង្គំជ្រាបត្រឹមតែប៉ុណ្ណោះ ។

លំដាប់នោះ មាតា និងបិតារបស់ក្មេងនោះ បានទៅកាន់ទីនោះហើយ ។ ព្រះរាជាទ្រង់ជ្រាបការប្រព្រឹត្តទៅនោះហើយ ទ្រង់នាំជនទាំង ៣ នោះទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលការប្រព្រឹត្តទៅទាំងពួង ហើយទូលសួរថា

បពិត្រព្រះអង្គ ពុទ្ធានុស្សតិប៉ុណ្ណោះ រមែងជាគុណជាតជាគ្រឿងរក្សាឬ ឬអនុស្សតិដទៃ មានធម្មានុស្សតិជាដើម ជាគុណជាតជាគ្រឿងរក្សា ។

គ្រានោះ ព្រះសាស្តាត្រាស់ដល់ព្រះរាជានោះថា មហាបពិត្រ ពុទ្ធានុស្សតិតែម្យ៉ាងប៉ុណ្ណោះ ជាគុណជាតជាគ្រឿងរក្សាក៏មិនមែន ចិត្តដែលជនទាំងឡាយណាអប់រំល្អហើយដោយឋានៈ ៦ កិច្ចដោយការរក្សា និងការការពារដទៃ ឬដោយមន្ត្រ និងឱសថ រមែងមិនមានដល់ជនទាំងនោះ ដូច្នេះហើយ កាលទ្រង់សម្តែងឋានៈ ៦ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ កាយគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច អហឹសាយ រតោ មនោ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច ភាវនាយ រតោ មនោ ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះពុទ្ធគុណ អស់

កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះធម្មគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងព្រះសង្ឃគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលស្ថិតនៅក្នុងកាយ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយក្នុងការមិនបៀតបៀនគេ ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃ សព្វកាល ។

*ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងមេត្តាភាវនា*
*ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវករបស់*
*ព្រះគោតម រមែងភ្ញាក់រឭកៗ ដោយប្រពៃសព្វកាល ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បាទព្រះគាថាថា* **សុប្បពុទ្ធំ បពុជ្ឈន្តិ** *សេចក្តីថា ជនទាំងនោះ តម្កល់សតិដែលទៅហើយក្នុងព្រះពុទ្ធ កំពុងនិទ្រានោះឯង កាលភ្ញាក់ឡើង ឈ្មោះថា ភ្ញាក់ដោយប្រពៃ ។*

*បាទព្រះគាថាថា* **សទា គោតមសាវកា** *សេចក្តីថា ឈ្មោះថាជាសាវករបស់ព្រះគោតម ព្រោះភាពដែលខ្លួន ជាអ្នកកើតហើយក្នុងទីបំផុតនៃការស្តាប់របស់ព្រះសម្ពុទ្ធគោតមគោត្រ និងព្រោះភាពជាបុគ្គល គឺដែលស្តាប់អនុសាសនីរបស់ព្រះពុទ្ធអង្គនោះឯង ។*

*ពីរបទថា* **ពុទ្ធគតា សតិ** *សេចក្តីថា សតិរបស់ជនពួកណាប្រារព្ធពុទ្ធគុណទាំងឡាយមាន* **ឥតិបិ សោ ភគវា** *ជាដើម កើតឡើងអស់កាលជានិច្ច ជនទាំងនោះ ឈ្មោះថា ភ្ញាក់ដោយល្អ សព្វកាល ជនទាំងនោះ កាលមិនអាចធ្វើយ៉ាងនោះបាន ធ្វើនូវពុទ្ធានុស្សតិតែក្នុងចិត្ត ក្នុងមួយថ្ងៃ ៣ ដង ២ ដង ឬ ១ ដង ឈ្មោះថា ភ្ញាក់ដោយល្អដូចគ្នា ។*

*ពីរបទថា* **ធម្មគតា សតិ** *សេចក្តីថា សតិ ដែលប្រារព្ធធម្មគុណទាំងឡាយមាន* **ស្វាក្ខាតោ ភគវតា ធម្មោ** *ជាដើម ដែលកើតឡើង ។*

*ពីរបទថា* **សង្ឃគតា សតិ** *សេចក្តីថា សតិដែលប្រារព្ធសង្ឃគុណ*

ទាំងឡាយ មាន **សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ជាដើម ដែលកើតឡើង ។

ពីរបទថា **កាយគតា សតិ** សេចក្តីថា សតិ ដែលកើតឡើងដោយអំណាចនៃអាការ ៣២ ដោយអំណាចនៃការនៅក្នុងព្រៃខ្មោចទាំង ៩ ដោយអំណាចនៃរូបជ្ឈាន មាននីលកសិណដែលប្រព្រឹត្តទៅខាងក្នុងជាដើម ។

ពីរបទថា **អហឹសាយ រតោ** សេចក្តីថា ត្រេកអរហើយក្នុងករុណាភាវនា ដែលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះថា ភិក្ខុនោះមានចិត្តសហគតៈដោយករុណា ផ្សាយទៅអស់ទិសមួយ ។

បទថា **ភាវនាយ** បានដល់ មេត្តាភាវនា ពិតហើយ ភាវនាដ៏សេសទាំងអស់ ព្រះសាស្តាទ្រង់បំណាងយកក្នុងបទថា **ភាវនាយ** នេះ ព្រោះភាពដែលករុណាភាវនា ទ្រង់ត្រាស់ហើយខាងដើមដោយពិត តែមេត្តាភាវនាប៉ុណ្ណោះ ទ្រង់បំណាងយកក្នុងបទថា **ភាវនាយ** នេះ ។ ពាក្យដ៏សេស អ្នកសិក្សាគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងគាថានោះឯង ។

ក្នុងកាលចប់ទេសនា ទារកនោះតាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយមាតា និងបិតាហើយ ក្រោយមក ជនទាំងអស់បួស សម្រេចអរហត្ត ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយដូច្នេះឯង ។

**រឿង ទារុសាកដិកៈ ចប់**

# រឿង ភិក្ខុវជ្ជីបុត្រ

## លំនាំដើម

ព្រះសាស្ដាកាលទ្រង់អាស្រ័យក្រុងវេសាលី ប្រថាប់នៅក្នុងព្រៃមហាវ័ន ទ្រង់ប្រារព្ធភិក្ខុជាឱរស របស់ស្ដេចវជ្ជីមួយរូប ដែលព្រះធម្មសង្គាហកាចារ្យ ពោលសំដៅយកថា ភិក្ខុដែលជាឱរសរបស់ស្ដេចវជ្ជីអង្គណាមួយអង្គ ក្នុងដងព្រៃណាមួយ ជិតក្រុងវេសាលី ។ ក្នុងសម័យនោះឯង ក្នុងក្រុងវេសាលីមានការលេងមហោស្រព មួយយប់ទល់ភ្លឺ ។ គ្រានោះឯង ភិក្ខុនោះ បានឮសំឡេងគគ្រឹកគគ្រេងនៃតន្ត្រីដែលគេប្រគំហើយ កន្ទក់កន្ទេញពោលគាថានេះក្នុងពេលនោះថា

យើងមកនៅក្នុងព្រៃតែម្នាក់ឯង ដូចជាកំណាត់ឈើដែលគេបោលក្នុងព្រៃ ក្នុងរាត្រីប្រាកដ ដូច្នេះ មិនមានអ្នកណាអន់ជាងយើងទៅទៀតទេ ។

ព្រះសាស្ដាត្រាស់ព្រះធម្មទេសនានេះថា **ទុប្បព្វជ្ជំ ទុរភិរមំ** ជាដើម ។

បានឮថា ភិក្ខុនោះជារាជឱរសក្នុងដែនវជ្ជី លះរាជសម្បត្តិដែលដល់ហើយតាមវារៈ បួសហើយក្នុងក្រុងវេសាលី កាលក្នុងព្រះនគរគេប្រដាប់ហើយដោយគ្រឿងប្រដាប់ទាំងឡាយ មានទទង់ជ័យ និងទង់ផ្កាលាជាដើម ធ្វើឲ្យជាប់គ្នាតែមួយ ដូចជាន់ចាតុម្មហារាជ កាលវារៈជាទីលេងមហោស្រព មួយយប់ទល់ភ្លឺ ក្នុងថ្ងៃ ១៥ កើត ជាទីរីកនៃផ្កាកោមុទប្រព្រឹត្តទៅ ។ បានឮសំឡេងកងរំពងនៃតន្ត្រី មានស្គរជាដើមវាយហើយ និងសំឡេងតន្ត្រី មានពិណាជាដើម ដែលគេប្រគំហើយ កាលព្រះរាជា ៧៧០៧ អង្គ និងខ្ញុំរាជការ

ទាំងឡាយ មានឧបរាជ និងសេនាបតីជាដើមរបស់ព្រះរាជាទាំងនោះ មានចំនួនប៉ុណ្ណោះដូចគ្នា ដែលមាននៅក្នុងក្រុងវេសាលី ប្រដាប់តាក់តែងហើយ ឈានចុះកាន់វិថីដើម្បីលេងនក្ខត្តឫក្ស ចង្ក្រមត្រង់ទីចង្ក្រមធំប្រមាណ ៦០ ហត្ថ ឃើញព្រះចន្ទពេញវង់ អណ្តែតក្នុងលម្ហមេឃ ឈរផ្អែកបង្ហួចក្តារ ខាងចុងទីចង្ក្រម ហើយសម្លឹងមើលអត្តភាព ដូចដុំឈើដែលគេទុកចោលក្នុងព្រៃ ព្រោះភាពដែលខ្លួនវៀរហើយចាកសំពត់សម្រាប់ជួតក្បាល និងគ្រឿងអលង្ការ គិតថា អ្នកដទៃ ដែលអាក្រក់ជាងអាត្មាអញមានឬហ្ន៎ សូម្បីប្រកបដោយគុណ មានការនៅព្រៃជាវត្តតាមប្រក្រតីជាដើម ក្នុងខណៈនោះ ត្រូវសេចក្តីមិនត្រេកអរគ្របសង្កត់ ទើបពោលយ៉ាងនោះ ។

ទេវតាដែលអាស្រ័យនៅក្នុងដងព្រៃនោះបានឮគាថានេះ ដែលលោកពោលហើយ ក៏ពោលតបថា

លោកនៅក្នុងព្រៃតែម្នាក់ឯង ដូចជាកំណាត់ឈើដែលគេចោល
នៅក្នុងព្រៃមែន តែមានជនច្រើនគ្នា ស្រឡាញ់លោកនោះ ដូច
ពពួកសត្វក្នុងស្ថាននរក ស្រឡាញ់ពួកទេវតាក្នុងស្ថានសួគ៌ ។

ដោយបំណងថា អាត្មាអញនឹងញ៉ាំងភិក្ខុនេះឲ្យសង្វេគ ក្នុងថ្ងៃស្អែកឡើង ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយ ។

ព្រះសាស្តាទ្រង់ជ្រាបរឿងនោះហើយ បំណងប្រកាសភាពដែលឃរាវាសជាទុក្ខ ទើបទ្រង់សរុបនូវទុក្ខ ៥ យ៉ាង ហើយត្រាស់ព្រះគាថានេះថា

**ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុខា**
**ទុក្ខោសមានសំវាសោ ទុក្ខានុបតិតទ្ធគូ**
**តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា ។**

ការចេញបួសបានដោយក្រ ការត្រេកអរត្រូវបានដោយក្រ ផ្ទះទាំងឡាយ មានការនៅគ្រប់គ្រងដោយលំបាក ជាការក្រ ការនៅរួមដោយជនស្មើគ្នា ( ដែលមិនមានសេចក្តីកោតក្រែង ) ជាការក្រ ជនអ្នកដើរផ្លូវឆ្ងាយគឺវដ្តៈ តែងត្រូវសេចក្តីទុក្ខធ្លាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្តីទុក្ខធ្លាក់ជាប់តាមផង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទុប្បព្វជ្ជំ** សេចក្តីថា ឈ្មោះថា ការលះគំនរនៃភោគៈតិចក្តី ច្រើនក្តី និងពួកញាតិ បួស ប្រគល់ឧរៈ គឺថ្វាយជីវិតក្នុងសាសនានេះជាការក្រ ។

បទថា **ទុរភិរមំ** សេចក្តីថា ការដែលកុលបុត្របួសហើយយ៉ាងនោះ បន្តការប្រព្រឹត្តទៅនៃជីវិត ដោយការត្រាច់ទៅដើម្បីភិក្ខា ដែលល្អក្រៃលែងដោយអំណាចនៃការគ្រប់គ្រងគុណ គឺសីលដែលមិនមានប្រមាណ និងបំពេញបដិបទាដែលសមគួរដល់ធម៌ឲ្យបរិបូណ៌ ជាការលំបាក ។

បទថា **ទុរាវាសា** សេចក្តីថា រាជកិច្ចរបស់ព្រះរាជា ឥស្សរកិច្ចរបស់

ឥស្សរជនទាំងឡាយ ដែលគ្រប់គ្រងផ្ទះត្រូវនាំទៅ ជនជិតខាង និងសមណ-ព្រាហ្មណ៍ដែលប្រព្រឹត្តធម៌ ដែលគ្រប់គ្រងផ្ទះត្រូវសង្គ្រោះ កាលបើយ៉ាងនេះ ការគ្រប់គ្រងផ្ទះក៏បំពេញបានលំបាក ដូចថ្នាំងដែលធ្លុះ និងមហាសមុទ្រ ព្រោះដូច្នោះ ឈ្មោះថា ផ្ទះទាំងនោះគ្រប់គ្រងមិនល្អ ទើបឈ្មោះថាឲ្យកើតទុក្ខ គឺឲ្យលំបាក ដើម្បីនៅគ្រប់គ្រង ព្រោះហេតុនោះឯង ។

បាទព្រះគាថាថា **ទុក្ខោ សមានសំវាសោ** សេចក្តីថា ពិតហើយ ជនណាជាគ្រហស្ថ សូម្បីស្មើគ្នាដោយជាតិ គោត្រ ត្រកូល និងភោគៈក្តី ជាបព្វជិត ស្មើគ្នាដោយគុណទាំងឡាយ មានសីល អាចារៈ និងពហុសច្ចៈជាដើមក្តី តែពោលពាក្យជាដើមថា លោកជាអ្នកណា ខ្ញុំជាអ្នកណា ជាអ្នកខ្វល់ខ្វាយក្នុងអធិករណ៍ ជនទាំងនោះ ឈ្មោះថា មិនស្មើគ្នា ឈ្មោះថា ការនៅរួមគ្នាជាមួយជនទាំងនោះជាទុក្ខ ។

បាទព្រះគាថាថា **ទុក្ខានុបតិតទ្ធគូ** សេចក្តីថា ជនទាំងឡាយណាឈ្មោះថា ជាអ្នកដើរផ្លូវឆ្ងាយ ព្រោះជាអ្នកដើរទៅកាន់ផ្លូវឆ្ងាយ ពោល គឺវដ្តៈ ជនទាំងនោះ ត្រូវទុក្ខជាប់តាមពិត ។

ពីរបទថា **តស្មា ន ចទ្ធគូ** សេចក្តីថា ភាពជាបុគ្គលដែលទុក្ខជាប់តាមជាទុក្ខ សូម្បីភាពជាបុគ្គលអ្នកដើរផ្លូវឆ្ងាយក៏ជាទុក្ខ ព្រោះដូច្នោះ បុគ្គលមិនគប្បីជាអ្នកឈ្មោះថាដើរផ្លូវឆ្ងាយ ព្រោះការដើរផ្លូវឆ្ងាយ ពោល គឺវដ្តៈផង មិនគប្បីជាអ្នកមានទុក្ខ ដូចពោលហើយជាប់តាមផង ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះនៀយណាយក្នុងទុក្ខ ដែលទ្រង់ត្រាស់ក្នុង

ឋានៈ ៥ ហើយ ទម្លាយសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ ដែលជាចំណែកខាងលើ ៥ តាំងនៅក្នុងអរហត្តហើយ ដូច្នេះឯង ។ល។

**រឿង ភិក្ខុវជ្ជីបុត្រ ចប់**

# រឿង ចិត្តគហបតី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធចិត្តគហបតី ត្រាស់ព្រះធម្មទេសនានេះថា **សទ្ធោ សីលេន សម្បន្នោ** ជាដើម ។

រឿងចិត្តគហបតីខ្ញុំឲ្យពិស្តារហើយក្នុងពាលវគ្គថា **អសន្តំ ភាវមិច្ឆេយ្យ** ជាដើម ។ ព្រះគាថានេះក៏មកហើយក្នុងពាលវគ្គនោះដូចគ្នា ពិតហើយ ក្នុងពាលវគ្គនោះ ខ្ញុំពោលថា ព្រះអានន្ទត្ថេរទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ សក្ការៈនេះកើតឡើងដល់ចិត្តគហបតីនោះ ដែលមកកាន់សម្នាក់របស់ព្រះអង្គតែប៉ុណ្ណោះឬ ឬក្នុងទីដទៃកើតឡើងដូចគ្នា ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ កាលចិត្តគហបតីនោះមកកាន់សម្នាក់របស់តថាគតក្តី ទៅក្នុងទីដទៃក្តីសក្ការៈរមែងកើតឡើងទាំងអស់ ព្រោះឧបាសកនេះជាអ្នកមានសទ្ធា សម្បូរដោយសីល ឧបាសកនេះទៅបទេសណាមួយ លាភសក្ការៈរមែងកើតឡើងដល់ចិត្តគហបតីក្នុងបទេសនោះៗ ឯង ដូច្នេះហើយ ទើប ទ្រង់ត្រាស់ព្រះគាថានេះថា

**សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ**
**យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។**

*បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់ ដោយយស និងភោគសម្បត្តិ គប់រកប្រទេសណាៗ គេ តែងបូជាក្នុងប្រទេសនោះៗ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **សទ្ធោ** *បានដល់ ដែលប្រកបដោយសទ្ធា ដែលជាលោកិយ និងលោកុត្តរ ។*

*បទថា* **សីលេន** *សេចក្តីថា សីលមាន ២ យ៉ាង គឺសីលសម្រាប់អ្នក គ្រប់គ្រងផ្ទះ ១ សីលសម្រាប់អ្នកមិនគ្រប់គ្រងផ្ទះ ១ ក្នុង ២ យ៉ាងនោះ សីលសម្រាប់អ្នកគ្រប់គ្រងផ្ទះ ព្រះសាស្តាទ្រង់បំណងយកក្នុងបទនេះ ។ សេចក្តីថា ជាអ្នកប្រកបដោយសីលសម្រាប់អ្នកគ្រប់គ្រងផ្ទះនោះ ។*

*បាទព្រះគាថាថា* **យសោភោគសមប្បិតោ** *សេចក្តីថា ជាអ្នកប្រកប ហើយដោយយសសម្រាប់អ្នកគ្រប់គ្រងផ្ទះ ពោល គឺការមានឧបាសក ៥០០ ជាបរិវារ ដូចគ្នានឹងរបស់ជនទាំងឡាយ មានអនាថបិណ្ឌិកសេដ្ឋីជាដើម និង ដោយភោគៈ ២ យ៉ាង គឺភោគៈមានទ្រព្យ និងស្រូវជាដើមឯណានីមួយ គឺ អរិយទ្រព្យ ៧ យ៉ាង ។*

*ពីរបទថា* **យំ យំ** *ជាដើម សេចក្តីថា កុលបុត្របែបនេះទៅកាន់ប្រទេស ណា ក្នុងទិសទាំងឡាយ មានទិសខាងកើតជាដើម រមែងជាបុគ្គលដែលគេ*

បូជាហើយ ក្នុងប្រទេសនោះៗ ដោយលាភ និងសក្ការៈបែបនោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។៙

**រឿង ចិត្តគហបតី ចប់**

# រឿង ចូឡសុភទ្ទា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធធីតារបស់ អនាថបិណ្ឌិកសេដ្ឋី ឈ្មោះនាងចូឡសុភទ្ទា ត្រាស់ព្រះធម្មទេសនានេះថា **ទូរេ សន្តោ បកាសេន្តិ** ជាដើម ។

បានឮមកថា សេដ្ឋីបុត្រម្នាក់ឈ្មោះឧគ្គៈ អ្នកឧគ្គនគរ ជាសម្លាញ់របស់ អនាថបិណ្ឌិកសេដ្ឋី តាំងអំពីកាលនៅជាកំលោះ សម្លាញ់ទាំងពីរនោះរៀនសិប្បៈ ក្នុងត្រកូលអាចារ្យជាមួយគ្នា សន្យានឹងគ្នាថា ក្នុងពេលដែលយើងទាំង ២ ចម្រើនវ័យ បុត្រ និងធីតាកើតហើយ បុគ្គលណាសុំធីតាដើម្បីប្រយោជន៍ ដល់បុត្រ បុគ្គលនោះត្រូវឲ្យធីតានោះ ។ ជនទាំងពីរចម្រើនវ័យហើយ គ្រប់ គ្រងតំណែងសេដ្ឋីក្នុងនគររៀងៗ ខ្លួន ។

សម័យមួយ ឧគ្គសេដ្ឋីប្រកបការលក់ដូរ បានទៅកាន់ក្រុងសាវត្ថីដោយ រទេះ ៥០០ ។ អនាថបិណ្ឌិកសេដ្ឋីហៅនាងចូឡសុភទ្ទាធីតារបស់ខ្លួនមកប្រាប់

ថា នែនាង បិតារបស់នាងឈ្មោះឧគ្គសេដ្ឋីមក កិច្ចដែលគួរធ្វើដល់គេជាភារៈរបស់នាង ។

នាងទទួលថា សាធុ បានរៀបចំភោជន មានសម្ល និងម្ហូបជាដើមដោយដៃខ្លួនឯង តាំងអំពីថ្ងៃឧគ្គសេដ្ឋីនោះមក ត្រៀមវត្ថុផ្សេងៗ មានកម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាបជាដើម ក្នុងពេលបរិភោគ ក៏រៀបចំទឹកសម្រាប់ងូតរង់ចាំលោកសេដ្ឋីនោះ តាំងអំពីងូតទៅ រមែងធ្វើកិច្ចគ្រប់យ៉ាងសម្រេចរៀបរយ ។

ឧគ្គសេដ្ឋីបានឃើញអាចារសម្បត្តិរបស់នាងសុភទ្ទានោះហើយ មានចិត្តជ្រះថ្លា ។ ថ្ងៃមួយ អង្គុយជាមួយអនាថបិណ្ឌិកសេដ្ឋី ដោយកថាប្រារព្ធសេចក្តីសុខ ហើយរឭកបានថា កាលនៅកំលោះ យើងទាំងពីរធ្វើកតិកាឈ្មោះនេះ ទើបសូមនាងចូឡសុភទ្ទា ដើម្បីប្រយោជន៍ដល់បុត្ររបស់ខ្លួន តែឧគ្គសេដ្ឋីនោះដោយប្រក្រតីជាមិច្ឆាទិដ្ឋិ ព្រោះដូច្នោះ ទើបអនាថបិណ្ឌិកសេដ្ឋីក្រាបទូលសេចក្តីនោះដល់ព្រះទសពល ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យរបស់ឧគ្គសេដ្ឋីហើយ ទ្រង់អនុញ្ញាត ។ ទើបប្រឹក្សាជាមួយភរិយា ហើយទទួលពាក្យរបស់ឧគ្គសេដ្ឋីនោះ កំណត់ថ្ងៃរៀបការហើយ ធ្វើសក្ការៈជាច្រើន ដូចធនញ្ជ័យសេដ្ឋី ធ្វើឲ្យនាងវិសាខាដែលជាធីតា ហើយបញ្ជូនទៅដូច្នោះ ហៅនាងសុភទ្ទាមកហើយឲ្យឱវាទ ១០ ប្រការថា នែនាង ធម្មតាស្ត្រីនៅក្នុងត្រកូលប្តី មិនគួរនាំភ្លើងខាងក្នុងចេញទៅខាងក្រៅ ដោយន័យដែលធនញ្ជ័យសេដ្ឋីឲ្យដល់នាងវិសាខានោះឯង ។ កាលនឹងបញ្ជូនទៅ ប្រគល់កុដុម្ពិកៈ ៨ ឲ្យជាអ្នកធានាថា បើ

ទោសរបស់ធីតាយើង កើតក្នុងទីដែលទៅហើយ ចូរពួកអ្នកជម្រះ ។ ក្នុងថ្ងៃដែលបញ្ជូនធីតានោះទៅ ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ បញ្ជូនធីតាទៅដោយសក្ការៈដ៏ច្រើន ហាក់ដូចសម្តែងសេចក្តីចម្រើននៃផលសុចរិតទាំងឡាយ ដែលធីតាធ្វើហើយ ក្នុងភពមុនឲ្យប្រាកដដល់សត្វលោក ។ ក្នុងពេលនាងទៅដល់ឧគ្គនគរដោយលំដាប់ មហាជន មួយអន្លើដោយត្រកូលឪពុកក្មេក បានធ្វើការទទួល ។

ចំណែកនាងចូឡសុភទ្ទានោះ បង្ហាញខ្លួនដល់អ្នកនគរទាំងមូល ដូចនាងវិសាខា ដើម្បីធ្វើសិរីសម្បត្តិរបស់ខ្លួនឲ្យប្រាកដ ឈរនៅលើរថចូលទៅកាន់នគរ ទទួលគ្រឿងបណ្ណាការដែលបញ្ជូនមកហើយទៅដល់ជនទាំងនោះ ដោយអំណាចនៃវត្តតាមសមគួរ បានធ្វើអ្នកនគរទាំងមូលឲ្យជាប់តែមួយដោយគុណរបស់ខ្លួន ។

ក្នុងថ្ងៃមង្គល ឪពុកក្មេករបស់នាង កាលធ្វើសក្ការៈដល់ពួកអ្នកបួសអាក្រាត បញ្ជូនទៅដោយពាក្យថា ចូរនាងមកថ្វាយបង្គំសមណៈទាំងឡាយរបស់ពួកយើង នាងមិនអាចមើលអ្នកបួសអាក្រាតទាំងឡាយព្រោះខ្មាស មិនប្រាថ្នានឹងទៅ លុះឪពុកក្មេកបញ្ជូនដំណឹងទៅរឿយៗ ត្រូវនាងឃាត់ហើយ ទើបក្រោធពោលថា ចូរពួកអ្នកបណ្តេញស្រីនេះទៅចុះ នាងគិតថា ឪពុកក្មេកមិនអាចលើកទោសដល់ខ្លួន ព្រោះហេតុមិនសមគួរបាន ឲ្យហៅកុដុម្ពិកៈមកហើយប្រាប់សេចក្តីនោះ ។ កុដុម្ពិកៈទាំងនោះ ជ្រាបភាពដែលនាងមិនមានទោស ទើបឲ្យសេដ្ឋីយល់ព្រមហើយ សេដ្ឋីប្រាប់ដល់ភរិយាថា កូនប្រសានេះមិនថ្វាយបង្គំ

សមណៈទាំងឡាយរបស់យើង ដោយយល់ថា ជាអ្នកមិនមានទូវការខ្មាស ។

កិរិយាសេដ្ឋីនោះគិតថា សមណៈរបស់កូនប្រសានេះដូចម្តេចហ្ន៎ នាងសរសើរសមណៈទាំងនោះពន់ពេក បានឲ្យមនុស្សហៅនាងមកហើយ ពោលថា សមណៈរបស់នាងដូចម្តេច ទើបនាងសរសើរសមណៈទាំងនោះពន់ពេក សមណៈទាំងនោះមានប្រក្រតីដូចម្តេច មានសមាចារដូចម្តេច កាលយើងសួរហើយ ចូរប្រាប់រឿងនោះដល់យើង ។

លំដាប់នោះ នាងសុភទ្ទាប្រកាសគុណទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធ និងសាវករបស់ព្រះអង្គដល់ម្តាយក្មេកនោះ ឲ្យម្តាយក្មេកត្រេកអរហើយដោយពាក្យទាំងឡាយយ៉ាងនេះថា

សមណៈទាំងនោះ ជាអ្នកមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ ដើរក្តី ឈរក្តី សន្រួមល្អ មានភ្នែកដាក់ចុះ និយាយល្មមប្រមាណ សមណៈទាំងឡាយរបស់ខ្ញុំយ៉ាងនេះ ។ កាយកម្មរបស់លោកស្អាត វចីកម្មមិនល្អក់កករ មនោ-កម្មបរិសុទ្ធ សមណៈទាំងឡាយរបស់ខ្ញុំយ៉ាងនោះ ។ លោកមិនមានមន្ទិលមានរស្មីដូចសង្ខ និងមុក្តា បរិសុទ្ធខាងក្នុងផង ខាងក្រៅផង ពេញហើយដោយធម៌ ដែលបរិសុទ្ធទាំងឡាយ ពួកសមណៈរបស់ខ្ញុំយ៉ាងនោះ លោកមិនប៉ោងឡើងព្រោះលាភ និងមិនអាក់អន់ព្រោះវិនាសលាភ លោកតាំងនៅតែម្យ៉ាងព្រោះលាភ និងវិនាសលាភ ពួកសមណៈរបស់ខ្ញុំយ៉ាងនោះ លោកមិនប៉ោងឡើងព្រោះយស មិនអាក់អន់ព្រោះវិនាសយស លោកតាំងនៅតែម្យ៉ាង ព្រោះយស និងវិនាសយស ពួកសមណៈរបស់ខ្ញុំយ៉ាងនោះ លោកមិនប៉ោងឡើង

ព្រោះសរសើរ និងមិនអាក់អន់ព្រោះនិន្ទា លោកស្មើក្នុងនិន្ទា និងសរសើរ ពួកសមណៈរបស់ខ្ញុំយ៉ាងនោះ លោកមិនប៉ោងឡើងព្រោះសុខ មិនទោមនស្សព្រោះទុក្ខ លោកមិនញាប់ញ័រព្រោះសុខ និងទុក្ខ ពួកសមណៈរបស់ខ្ញុំ ដូច្នោះ ។

លំដាប់នោះ ម្តាយក្មេកពោលថា នាងអាចបង្ហាញសមណៈទាំងឡាយដល់ពួកយើងបានដែរឬ នាងឆ្លើយថា អាច ទើបពោលថា បើដូច្នោះ ចូរនាងធ្វើឲ្យពួកយើងឃើញសមណៈទាំងនោះ ។ នាងទទួលថា សាធុ ត្រៀមនូវមហាទានដើម្បីភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ ឈរលើផ្ទៃប្រាសាទខាងលើ បែរមុខទៅកាន់វត្តជេតពន ថ្វាយបង្គំដោយគោរពដោយបញ្ចង្គប្រតិស្ឋាន រឭកដល់ពុទ្ធគុណទាំងឡាយ ធ្វើការបូជាដោយគ្រឿងក្រអូប គ្រឿងអប់ ផ្កា និងធូប ពោលនិមន្តថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីឆាន់ក្នុងថ្ងៃស្អែក ដោយសញ្ញាណរបស់ខ្ញុំម្ចាស់នេះ សូមព្រះមានព្រះភាគជ្រាបថា ខ្ញុំម្ចាស់និមន្តហើយ ដូច្នេះហើយ ទើបបាចផ្កាម្ទិះ ៨ ក្តាប់ ទៅក្នុងអាកាស ។

ផ្កាទាំងឡាយ អណ្តែតជាពិដានសម្រេចដោយរបៀបផ្កា បានទៅតាំងខាងលើព្រះសាស្តា ដែលទ្រង់កំពុងសម្តែងធម៌ ក្នុងកណ្តាលបរិស័ទ ៤ ។

ក្នុងខណៈនោះ សុម្បីអនាថបិណ្ឌិកសេដ្ឋី ស្តាប់ធម្មកថាហើយ និមន្តព្រះសាស្តាដើម្បីសោយក្នុងថ្ងៃស្អែក ព្រះសាស្តាត្រាស់ថា គហបតី តថាគតទទួលភត្តដើម្បីឆាន់ក្នុងថ្ងៃស្អែករួចហើយ កាលអនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គ អ្នកដទៃមកមុនខ្ញុំព្រះអង្គមិនមាន ទ្រង់ទទួលភត្តរបស់អ្នក

ណាហ្ន៎ ទើបទ្រង់ត្រាស់ថា ម្នាលគហបតី នាងចូឡសុភទ្ទានិមន្តហើយ កាល លោកសេដ្ឋីពោលថា នាងសុភទ្ទានៅក្នុងទីឆ្ងាយប្រមាណ ១២០ យោជន៍អំពីនេះ មិនមែនឬ ព្រះសាស្តាត្រាស់ថា គហបតី សប្បុរសទាំងឡាយ សូម្បីនៅក្នុងទីឆ្ងាយ រមែងប្រាកដដូចនៅក្នុងទីចំពោះមុខ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ**
**អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា ។**

ពួកសប្បុរសរមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្ត ដូច្នោះ ពួកអសប្បុរស ( ទុកជាស្ថិតនៅ ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សន្តោ** ជាដើម សេចក្តីថា អ្នកប្រាជ្ញទាំង-ឡាយ មានព្រះពុទ្ធជាដើម ឈ្មោះថា សប្បុរស ព្រោះកិលេសទាំងឡាយមានរាគៈជាដើមស្ងប់ហើយ តែក្នុងទីនេះ ព្រះសាស្តាទ្រង់បំណងយកសត្វដែលមានអធិការ គឺបុណ្យដែលបានធ្វើហើយក្នុងព្រះពុទ្ធមុនៗ មានកុសល-មូលសន្សំហើយ អប់រំភាវនាហើយថា សប្បុរស ។

បទថា **បកាសេន្តិ** សេចក្តីថា សូម្បីឈរក្នុងទីឆ្ងាយ កាលមកកាន់គន្លងព្រះញាណនៃព្រះពុទ្ធទាំងឡាយ ឈ្មោះថា ប្រាកដបាន ។

បទថា **ហិមវន្តោវ** សេចក្តីថា ដូចភ្នំហិមពាន្ត ទំហំ ៣ ពាន់យោជន៍

កម្ពស់ ៥០០ យោជន៍ ប្រដាប់ដោយកំពូល ៨៤០០០ រមែងប្រាកដដល់ជនទាំងឡាយ ដែលឈរក្នុងទីឆ្ងាយ ដូចតាំងនៅចំពោះមុខ យ៉ាងណា សប្បុរសទាំងឡាយ រមែងប្រាកដ ដូច្នោះ ។

បទថា **អសន្តេត្ថ** សេចក្តីថា បុគ្គលពាលធ្ងន់ក្នុងទិដ្ឋធម៌ មានបរលោកធ្វេងទៅហើយ ឃើញតែអាមិស បួសដើម្បីប្រយោជន៍ដល់ជីវិត ឈ្មោះថាអសប្បុរស អសប្បុរសទាំងនោះ សូម្បីអង្គុយក្នុងទីនេះ គឺក្នុងទីជិតមណ្ឌលនៃព្រះជានុខាងស្តាំរបស់ព្រះពុទ្ធទាំងឡាយ រមែងមិនប្រាកដ គឺមិនដឹង ។

ពីរបទថា **រត្តឹ ខិត្តា** គឺដូចព្រួញដែលបាញ់ទៅក្នុងពេលយប់ ក្នុងទីងងឹត ដែលប្រកបដោយអង្គ ៤ អធិប្បាយថា អសប្បុរសទាំងនោះ រមែងមិនប្រាកដ ព្រោះការមិនមានបុព្វហេតុ ដែលជាឧបនិស្ស័យបែបនោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

សក្កទេវរាជទ្រង់ជ្រាបថា ព្រះសាស្តាទ្រង់ទទួលនិមន្ត របស់នាងចូឡ-សុភទ្ទាហើយ ទ្រង់បញ្ជាវិស្សកម្មទេវបុត្រថា ចូរអ្នកនិម្មិតផ្ទះកំពូល ៥០០ ហើយនាំភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទៅកាន់ឧគ្គនគរក្នុងថ្ងៃស្អែក ។

ស្អែកឡើងវិស្សកម្មទេវបុត្រនោះ និម្មិតផ្ទះកំពូល ៥០០ បានឈរត្រង់ទ្វារនៃវត្តជេតពន ។ ព្រះសាស្តាទ្រង់ជ្រើសរើសហើយ នាំភិក្ខុខីណាស្រពដែលបរិសុទ្ធទាំង ៥០០ រូបនោះ មួយអន្លើដោយបរិវារ ប្រថាប់គង់ក្នុងផ្ទះកំពូលហើយយាងទៅកាន់ឧគ្គនគរ ។

ឧគ្គសេដ្ឋី មួយអន្លើដោយបរិវារ សម្លឹងមើលផ្លូវយាងមកនៃព្រះតថាគត ដោយន័យដែលនាងសុភទ្ទាឲ្យហើយ ឃើញព្រះសាស្តាយាងមកដោយព្រះសិរីសម្បត្តិធំ មានចិត្តជ្រះថ្លាហើយ ធ្វើសក្ការៈដោយវត្ថុទាំងឡាយ មានកម្រងផ្កាជាដើម ទទួលហើយ ថ្វាយបង្គំ ថ្វាយមហាទាន និមន្តដដែលទៀត បានថ្វាយមហាទានអស់ ៧ ថ្ងៃ ។

ព្រះសាស្តា ទ្រង់កំណត់ធម៌ដែលជាសប្បាយរបស់សេដ្ឋីនោះហើយ ទ្រង់សម្តែងធម៌ សត្វ ៨៤០០០ មានសេដ្ឋីជាដើម បានត្រាស់ដឹងធម៌ហើយ ។

ព្រះសាស្តា ដើម្បីទ្រង់អនុគ្រោះនាងសុភទ្ទា ទើបត្រាស់ឲ្យព្រះអនុរុទ្ធត្រឡប់ដោយព្រះតម្រាស់ថា ចូរអ្នកស្នាក់នៅក្នុងទីនេះឯង ហើយបានយាងទៅកាន់ក្រុងសាវត្ថីនោះឯង តាំងអំពីនោះមក អ្នកនគរនោះមានសទ្ធាជ្រះថ្លាដូច្នេះឯង ៕

## រឿង នាងចូឡសុភទ្ទា ចប់

# រឿង ព្រះថេរៈឈ្មោះ ឯកវិហារី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះ ឯកវិហារី ត្រាស់ព្រះធម្មទេសនានេះថា **ឯកាសនំ** ជាដើម ។

បានឮថា ព្រះថេរៈនោះបានជាអ្នកប្រាកដក្នុងវាងបរិស័ទ ៤ ថា អង្គុយម្នាក់ឯង ដើរម្នាក់ឯង ឈរតែម្នាក់ឯង ។ តមក ភិក្ខុទាំងឡាយក្រាបទូលដល់ព្រះតថាគតថា បពិត្រព្រះអង្គ ព្រះថេរៈនេះមានការប្រព្រឹត្តយ៉ាងនេះ ។

ព្រះសាស្ដាប្រទានសាធុការថា សាធុ សាធុ ដូច្នេះហើយ ទ្រង់ទូន្មានថា ធម្មតាភិក្ខុគប្បីជាអ្នកស្ងាត់ រួចត្រាស់អានិសង្សក្នុងវិវេក ហើយទើបត្រាស់ព្រះគាថានេះថា

**ឯកាសនំ ឯកសេយ្យំ ឯកោ ចរមតន្ទិតោ**
**ឯកោ ទមយមត្តានំ វនន្តេ រមិតោ សិយា ។**

បុគ្គល គួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរក្នុងព្រៃស្ងាត់ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ ពីរបទថា **ឯកាសនំ ឯកសេយ្យំ** សេចក្ដីថា ទីអង្គុយរបស់ភិក្ខុ ដែលមិនលះមូលកម្មដ្ឋាន អង្គុយត្រង់កណ្ដាលភិក្ខុរាប់ពាន់ដោយការធ្វើទុកក្នុងចិត្តនោះឯង ឈ្មោះថាអង្គុយម្នាក់ឯង ទីដេករបស់ភិក្ខុដែលចូលទៅតាំងសតិ ហើយដេកលើដំណេកដែលគេក្រាលក្នុងប្រាសាទ ដូចជា

លោហប្រាសាទក្តី ក្នុងកណ្តាលភិក្ខុរាប់ពាន់រូបក្តី ត្រង់កម្រាលដ៏វិចិត្រមានតម្លៃច្រើន ដោយបង្អៀងស្មាំក្តី ដោយមនសិការៈក្នុងមូលកម្មដ្ឋាន ឈ្មោះថាទីដេកម្នាក់ឯង ។ ភិក្ខុគប្បីសេពទីអង្គុយម្នាក់ឯង និងទីដេកម្នាក់ឯងបែបនេះ ។

បទថា **អតន្ទិតោ** សេចក្តីថា ភិក្ខុដែលមិនខ្ជិលច្រអូសដោយការអាស្រ័យកម្លាំងស្មងចិញ្ចឹមជីវិត ត្រាច់ទៅម្នាក់ឯងគ្រប់ឥរិយាបថ ។

បាទព្រះគាថាថា **ឯកោ ទមយមត្តានំ** សេចក្តីថា ជាបុគ្គលម្នាក់ឯងប៉ុណ្ណោះទូន្មានខ្លួន ដោយអំណាចនៃការតាមប្រកបកម្មដ្ឋាន ក្នុងទីទាំងឡាយមានទីសម្រាកពេលយប់ជាដើម ហើយសម្រេចមគ្គ និងផល ។

បាទព្រះគាថាថា **វនន្តេ រមិតោ សិយា** សេចក្តីថា ភិក្ខុកាលទូន្មានខ្លួនយ៉ាងនោះ ឈ្មោះថា គប្បីជាអ្នកត្រេកអរក្រៃលែងក្នុងដងព្រៃ ដែលស្ងាត់ចាកសំឡេងទាំងឡាយ មានសំឡេងបុរស និងស្ត្រីជាដើម ។ ព្រោះភិក្ខុអ្នកមានប្រក្រតី នៅច្របូកច្របល់ មិនអាចទូន្មានខ្លួនយ៉ាងនោះបាន ។

ក្នុងកាលចប់ទេសនា ភិក្ខុជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

តាំងអំពីនោះមក មហាជនប្រាថ្នាការនៅម្នាក់ឯងប៉ុណ្ណោះ ដូច្នេះ ៕

**រឿងព្រះថេរៈឈ្មោះឯកវិហារី ចប់**

**បកិណ្ណកវគ្គទី ២១ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា និរយវគ្គទី ២២

[ ៣២ ] អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ ( អំពើអាក្រក់ ) ហើយ និយាយថា អញមិនធ្វើទេ ( បុគ្គលនោះ ) រមែងទៅកាន់នរក ជនទាំង ២ នាក់ ដែលមានអំពើទាបថោក ( ស្មើគ្នា ) នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា ( ដោយគតិ ) ក្នុងលោកខាងមុខទៀត ។

ពួកជនច្រើននាក់ ដែលមានកព័ន្ធព័ទ្ធ ដោយសំពត់កាសាវៈ តែ ( ប្រព្រឹត្ត ) ធម៌ដ៏លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះ រមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយ ដ៏លាមកនោះ ។

បព្វជិតទ្រុស្តសីល សូវបរិភោគដុំដែក ដែលកំពុងក្តៅ មានពណ៌ដូចអណ្តាតភ្លើង ប្រសើរជាង បព្វជិតទ្រុស្តសីល មិនសង្រួម បរិភោគដុំបាយអ្នកដែន នឹងប្រសើរដូចម្តេចបាន ។

នរជន អ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គលដទៃ រមែងដល់នូវហេតុនៃសេចក្តីទុក្ខ ៤ យ៉ាងគឺ ទី ១ បានរបស់មិនមែនជាបុណ្យ ទី ២ ដេកមិនបានតាមប្រាថ្នា ទី ៣ ការតិះដៀល ទី ៤ ការធ្លាក់នរក ។ ( ហេតុនៃសេចក្តីទុក្ខ ៤ យ៉ាង ផ្សេងទៀត ) គឺបានរបស់មិនជាបុណ្យ ១ មានគតិអាក្រក់ ១ តម្រេករបស់បុរសអ្នកខ្លាច ជាមួយនឹងស្ត្រីដែលខ្លាចដែរមានប្រមាណតិច ១ ព្រះរាជានឹងដាក់អាជ្ញាយ៉ាងធ្ងន់ ១ ព្រោះហេតុនោះ បុរសមិនគួរសេពប្រពន្ធរបស់បុគ្គលដទៃឡើយ ។

ស្បូវក្លាំង ដែលបុគ្គលកាន់មិនចំណាប់ រមែងលះដៃ យ៉ាងណាមិញ ភាពជាសមណៈដែលបព្វជិតកាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះទៅនរក យ៉ាងនោះឯង ។

កម្មណាមួយ ដែលធូរថយក្តី វត្តណាមួយដែលសៅហ្មងក្តី ព្រហ្មចរិយៈ ដែលបុគ្គលរព្វកដោយសេចក្តីរង្កៀសក្តី កម្មទាំង ៣ ជារបស់មិនមានផលច្រើនឡើយ ។

បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឲ្យមែនទែន គប្បីប្រឹងប្រែងធ្វើកិច្ចនោះឲ្យមាំមួន ព្រោះថា សមណធម៌ជាគ្រឿងវៀរចាកកិលេសធូរថយ រមែងរោយធូលី គឺរាគាទិកិលេសដល់បុគ្គលដោយក្រៃលែង ។

អំពើអាក្រក់ ដែលបុគ្គលមិនធ្វើ ប្រសើរជាង ( ព្រោះថា ) អំពើអាក្រក់ រមែងធ្វើឲ្យក្តៅក្រហាយ ក្នុងកាលខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយក្រោយ អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គលប្រសើរ ។

នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ទាំងខាងក្រៅ យ៉ាងណា អ្នកទាំងឡាយ គួររក្សាខ្លួនយ៉ាងនោះ កុំឲ្យខណៈកន្លងអ្នកទាំងឡាយបានឡើយ ព្រោះថា ជនទាំងឡាយ ដែលឲ្យខណៈកន្លងហើយ រមែងសោកស្តាយ ក្នុងនរក មិរដេរដាស ។

សត្វទាំងឡាយដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាស ក្នុងហេតុដែលគេមិនត្រូវខ្មាស រមែងមិនខ្មាស ក្នុងហេតុដែលគេត្រូវខ្មាស សត្វទាំងនោះ

តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញក្នុងហេតុដែលគេមិនត្រូវខ្លាច ថាជាហេតុដែលគេត្រូវខ្លាចផង យល់ឃើញក្នុងហេតុដែលគេត្រូវខ្លាច ថាជាហេតុដែលគេមិនត្រូវខ្លាចផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញក្នុងហេតុដែលមានទោស ថាជាហេតុឥតទោសផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់មានទោស ថាជារបស់មានទោសផង ដឹងរបស់មិនមានទោស ថាជារបស់មិនមានទោសផង សត្វទាំងនោះ តែងទៅកាន់សុគតិ ។

**និរយវគ្គទី ២២ ចប់**

# អដ្ឋកថា
# និរយវគ្គទី ២២

## រឿង នាងបរិព្វាជិកាឈ្មោះ សុន្ទរី
### លំនាំដើម

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងបរិព្វាជិកាឈ្មោះសុន្ទរី ត្រាស់ព្រះធម្មទេសនានេះថា* **អភូតវាទី** *ជាដើម ។*

*រឿងមកពិស្ដារក្នុងគម្ពីរឧទាននោះឯងថា សម័យនោះឯង ព្រះសាស្ដាដែលមហាជនធ្វើសក្ការៈ ធ្វើសេចក្ដីគោរពកោតក្រែង បូជាហើយជាដើម ។ ឯអត្ថដោយសង្ខេបក្នុងរឿងនេះ មានដូចតទៅ*

*បានឮថា កាលលាភសក្ការៈ ដូចគ្នានឹងជំនន់ទឹកធំនៃស្ទឹងទាំង ៥ កើតឡើងដល់ព្រះសាស្ដា និងភិក្ខុសង្ឃហើយ ពួកតិរ្ថិយក៏សាបសូន្យលាភសក្ការៈ ជាអ្នកអាប់រស្មី ដូចអំពិលអំពែកក្នុងពេលព្រះអាទិត្យរះឡើង រួមប្រជុំប្រឹក្សាគ្នាថា តាំងអំពីកាលនៃព្រះសមណគោតមកើតឡើង ពួកយើងក៏វិនាសលាភសក្ការៈ បុគ្គលណាម្នាក់រមែងមិនដឹងភាពដែលពួកយើងទាំងឡាយមាន ពួកយើងគប្បីរួមគ្នាជាមួយអ្នកណាហ្ន៎ បង្កទោសឲ្យកើតឡើងដល់ព្រះសមណ-គោតម ហើយញ៉ាំងលាភសក្ការៈរបស់លោកឲ្យសាបសូន្យ ។*

*គ្រានោះ ការគិតបានកើតឡើងដល់តិរ្ថិយទាំងនោះថា ពួកយើងរួមជា*

មួយនាងសុន្ទរីនឹងអាចធ្វើបាន ។ ថ្ងៃមួយ ពួកតិរ្ថិយទាំងនោះ ក្លែងធ្វើមិននិយាយជាមួយនាងសុន្ទរី ដែលចូលទៅកាន់អារាមតិរ្ថិយ ថ្វាយបង្គំហើយឈរ សូម្បីនាងប្រាស្រ័យរឿយៗ ក៏មិនបានពាក្យឆ្លើយតប ទើបសួរថា លោកម្ចាស់ទាំងឡាយត្រូវអ្នកណាបៀតបៀនឬ ពួកតិរ្ថិយពោលថា នែប្អូនស្រី នាងមិនឃើញព្រះសមណគោតម ដែលត្រាច់បៀតបៀនពួកយើង ធ្វើឲ្យវិនាសលាភសក្ការៈទេឬ ។

នាងសុន្ទរីពោលថា ខ្ញុំគួរធ្វើអ្វីក្នុងរឿងនេះ តិរ្ថិយពោលថា ប្អូនស្រីនាងមានរូបស្អាត ដល់នូវភាពជាអ្នកល្អលើស ចូរលើកទោសឡើងដល់ព្រះសមណគោតម ហើយឲ្យមហាជនជឿពាក្យ ធ្វើឲ្យវិនាសលាភសក្ការៈ ។

នាងសុន្ទរីនោះទទួលថា សាធុ ហើយចៀសចេញទៅ តាំងអំពីនោះមកនាងកាន់យករបស់មានកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប កប្បូរ និងគ្រឿងទេសជាដើម ដើរបែរមុខទៅកាន់វត្តជេតពន ក្នុងពេលដែលមហាជនស្តាប់ព្រះធម្មទេសនា របស់ព្រះសាស្តាហើយ ត្រឡប់ចូលព្រះនគរក្នុងពេលល្ងាច ត្រូវមហាជនសួរថា នាងទៅណា ក៏ឆ្លើយថា ទៅសម្នាក់ព្រះសមណ-គោតម ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណគោតមនោះ ហើយទៅកាន់អារាមតិរ្ថិយមួយកន្លែង ដើរទៅកាន់ផ្លូវដែលមិនទាន់ដល់វត្តជេតពនអំពីព្រលឹមដើរបែរមុខមកកាន់ព្រះនគរ ត្រូវមហាជនសួរថា នែសុន្ទរីនាងទៅណា ក៏ឆ្លើយថា ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណគោតម លោកត្រេកអរដោយការត្រេកអរ ព្រោះកិលេសហើយ ទើបខ្ញុំត្រឡប់មក ។

បន្ទាប់អំពីនោះមក កន្លងទៅបាន ២-៣ ថ្ងៃ ពួកតិរ្ថិយឲ្យកហាបណៈ ដល់អ្នកលេងហើយពោលថា ចូរពួកអ្នកទៅសម្លាប់នាងសុន្ទរី ហើយកប់ក្នុងគំនរសំរាម នៃផ្កាដែលស្ថិតស្រពោន ក្បែរព្រះគន្ធកុដិរបស់ព្រះសមណគោតម ហើយត្រឡប់មក ។ ពួកអ្នកលេងក៏បានធ្វើយ៉ាងនោះ ។

លំដាប់នោះ តិរ្ថិយទាំងឡាយបានធ្វើកោលាហលឡើងថា ពួកយើងមិនឃើញនាងសុន្ទរី ហើយទូលដល់ព្រះរាជា ត្រូវព្រះរាជាត្រាស់សួរថា តើពួកអ្នកមានសង្ស័យក្នុងទីណា ទូលថា នាងសុន្ទរីនៅក្នុងវត្តជេតពន អស់ថ្ងៃមានប្រមាណប៉ុណ្ណេះ ពួកអាត្មាមិនជ្រាបការប្រព្រឹត្តទៅរបស់នាង ក្នុងវត្តជេតពននោះ កាលព្រះរាជាអនុញ្ញាតថា បើដូច្នោះ ចូរពួកអ្នកទៅរកមើលក្នុងវត្តជេតពននោះចុះ នាំពួកឧបដ្ឋាករបស់ខ្លួន ទៅកាន់វត្តជេតពន រកមើល ក៏ឃើញក្នុងរវាងគំនរសំរាមនៃផ្កាដែលគេចោល ទើបលើកឡើងដាក់លើគ្រែចូលទៅកាន់ព្រះនគរ ទូលដល់ព្រះរាជាថា សាវករបស់ព្រះសមណគោតមសម្លាប់នាងសុន្ទរី ហើយកប់ក្នុងរវាងគំនរសំរាម នៃកម្រងផ្កាដែលគេចោលដោយគិតថា នឹងបិទបាំងកម្មលាមកដែលព្រះសាស្តាធ្វើ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរពួកអ្នកទៅប្រកាសពេញព្រះនគរចុះ ។ ពួកតិរ្ថិយនាំគ្នាពោលពាក្យជាដើមថា ចូរអ្នកទាំងឡាយ មើលកម្មរបស់ពួកសមណសក្យបុត្តចុះក្នុងវិថីនៃព្រះនគរហើយ បានទៅកាន់ទ្វារព្រះរាជនិវេសន៍ទៀត ព្រះរាជាត្រាស់ឲ្យលើកសរីរៈរបស់នាងសុន្ទរីឡើងដាក់លើគ្រែ ទុកក្នុងព្រៃខ្មោចហើយឲ្យរក្សា ។ ពួកអ្នកនគរសាវត្ថី វៀរព្រះអរិយសាវកដ៏សេសដោយច្រើន នាំ

គ្នាពោលពាក្យជាដើមថា សូមអ្នកទាំងឡាយ មើលកម្មរបស់ពួកសមណ-សក្យបុត្តចុះ ហើយដើរជេរពួកភិក្ខុខាងក្នុងព្រះនគរខ្លះ ខាងក្រៅព្រះនគរខ្លះ ក្នុងព្រៃខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះ ដល់ព្រះតថាគត ។

ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ ចូរពួកអ្នកត្រឡប់ចោទ ពួកមនុស្សទាំងនោះយ៉ាងនេះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អភូតវាទី និរយំ ឧបេតិ យោ វាបិ កត្វា ន ករោមីតិ ចាហ**

**ឧភោបិ តេ បេច្ច សមា ភវន្តិ និហីនកម្មា មនុជា បរត្ថ ។**

អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ ( អំពើអាក្រក់ ) ហើយ និយាយថា អញមិនធ្វើទេ ( បុគ្គលនោះ ) រមែងទៅកាន់នរក ជនទាំងពីរនាក់ ដែលមានអំពើទាបថោក ( ស្មើគ្នា ) នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា ( ដោយគតិ ) ក្នុងលោកខាងមុខទៀត ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អភូតវាទី** បានដល់ មិនឃើញទោសរបស់បុគ្គលដទៃ ធ្វើនូវការពោលកុហក ចោទអ្នកដទៃដោយពាក្យទទេ ។

បទថា **កត្វា** សេចក្តីថា បុគ្គលធ្វើកម្មលាមកហើយ ពោលថា ខ្ញុំមិនបានធ្វើកម្មនោះ ។

ប្រើនបទថា **បេច្ច សមា ភវន្តិ** សេចក្តីថា ជនទាំងពីរនោះ ទៅកាន់បរលោក រមែងជាអ្នកស្មើគ្នាដោយគតិ ព្រោះការចូលដល់នរក ។ គតិរបស់

ជនទាំងនោះប៉ុណ្ណោះ អ្នកប្រាជ្ញកំណត់ហើយ ។ តែអាយុរបស់បុគ្គលនោះ លោកមិនបានកំណត់ ព្រោះថា ជនទាំងឡាយ ធ្វើបាបកម្មច្រើន រមែងឆេះក្នុងនរក ធ្វើបាបកម្មតិច រមែងឆេះអស់កាលតិចតួចប៉ុណ្ណោះ ព្រោះកម្មដែលលាមករបស់ជនទាំងពីរនោះឯងជាហេតុ ព្រោះដូច្នោះ ទើបព្រះសាស្ដាត្រាស់ថា **និរយាំ ឧបបជ្ជន្តិ ទ្បាកា ។**

បទថា **បរត្ថ** សម្ពន្ធចូលជាមួយបទថា **បេច្ច** ខាងមុខ អធិប្បាយថា ជនមានកម្មអាក្រក់ទាំងនោះ លះទៅក្នុងលោកដទៃ គឺទៅចាកលោកនេះ រមែងជាអ្នកស្មើក្នុងបរលោក ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ព្រះរាជា ទ្រង់បញ្ជូនរាជបុរសទៅដោយព្រះតម្រាស់ថា ចូរពួកអ្នកដឹងភាពដែលអ្នកដទៃ ដែលសម្លាប់នាងសុន្ទរី ។ គ្រានោះ អ្នកលេងទាំងនោះផឹកស្រាដោយកហាបណៈទាំងនោះ ធ្វើនូវការឈ្លោះគ្នានិងគ្នា ជនម្នាក់ពោលនឹងជនម្នាក់ថា ឯងសម្លាប់នាងសុន្ទរីដោយការប្រហារត្រឹមតែម្ដង ហើយកប់ក្នុងគំនរផ្កាដែលស្វិត ផឹកស្រាដោយកហាបណៈដែលបានអំពីការប្រហារនោះ រឿងនោះ លើកទុកចុះ ។ ទើបពួករាជបុរសចាប់អ្នកលេងនោះ ទៅបង្ហាញដល់ព្រះរាជា ។ លំដាប់នោះ ព្រះរាជាត្រាស់សួរអ្នកលេងទាំងនោះថា ពួកអ្នកសម្លាប់នាងសុន្ទរីឬ ពួកអ្នកលេងពោលថា ករុណាថ្លៃវិសេស ព្រះរាជាត្រាស់ថា អ្នកណាប្រើពួកឯងឲ្យសម្លាប់ អ្នកលេងពោលថា បពិត្រព្រះអង្គ

គឺពួកត្រិយ ។

ព្រះរាជាត្រាស់ឲ្យហៅពួកត្រិយមកហើយត្រាស់ថា ចូរពួកអ្នកត្រាច់ទៅពោលក្នុងព្រះនគរយ៉ាងនេះថា នាងសុន្ទរី ត្រូវពួកខ្ញុំដែលប្រាថ្នាលើកទោសដល់ព្រះសមណគោតមសម្លាប់ហើយ ទោសសាវ័ករបស់ព្រះសមណគោតមមិនមានឡើយ ជាទោសរបស់ខ្ញុំតែម្យ៉ាង ។ ពួកត្រិយបានធ្វើយ៉ាងនោះ ។ មហាជនល្ងង់ខ្លៅជឿហើយក្នុងគ្រានោះ ។ ពួកត្រិយក្តី ពួកអ្នកលេងក្តីដល់នូវអាជ្ញាព្រោះការសម្លាប់មនុស្ស ចាប់តាំងពីនោះមក សក្ការៈមានដល់ព្រះពុទ្ធនិងសាវ័កទាំងឡាយក្រៃលែងឡើង ដូច្នេះឯង ។

**រឿង នាងបរិព្វាជិកាឈ្មោះ សុន្ទរី ចប់**

# រឿង សត្វដែលត្រូវទុក្ខបៀតបៀន

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសត្វទាំងឡាយដែលអានុភាពនៃផលទុច្ចរិតបៀតបៀន ត្រាស់ព្រះធម្មទេសនានេះថា **កាសាវកណ្ឋា** ជាដើម ។

សេចក្តីពិស្តារថា ព្រះមហាមោគ្គល្លានត្ថេរ ចុះអំពីភ្នំគិជ្ឈកូដ មួយអន្លើដោយព្រះលក្ខណត្ថេរ ឃើញអត្តភាពពួកនេរយិកសត្វ មានប្រេតដែលមានតែរាងឆ្អឹងជាដើម ទើបធ្វើការញញឹម ត្រូវព្រះលក្ខណត្ថេរសួរដល់ហេតុដែល

ធ្វើការញញឹម ក៏ពោលថា អាវុសោ កាលនេះ មិនមែនកាលនៃបញ្ហានេះ អាវុសោគប្បីសួរខ្ញុំក្នុងសម្នាក់ព្រះតថាគត ។ កាលព្រះថេរៈសួរក្នុងសម្នាក់ព្រះតថាគតហើយ ប្រាប់ភាពដែលខ្លួនឃើញនេរយិកសត្វ គឺប្រេតដែលមានតែរាងឆ្អឹងជាដើមហើយ ទើបប្រាប់សហធម្មិកទាំង ៥ ដែលក្តៅក្រហាយដោយសមណបរិក្ខារ មានបាត្រ ចីវរ និងវត្ថពន្ធជាដើម ដោយន័យថា អាវុសោ ខ្ញុំចុះអំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុក្នុងពុទ្ធសាសនានេះ ទៅកាន់អាកាស កាយរបស់ភិក្ខុនោះ ក៏ក្តៅក្រហាយ ។

ព្រះសាស្តា ត្រាស់ប្រាប់ភាពដែលសត្វទាំងនោះ បួសក្នុងសាសនាព្រះកស្សបទសពលហើយ មិនអាចធ្វើឲ្យសមគួរដល់បព្វជ្ជា ជាភិក្ខុលាមក កាលទ្រង់សម្តែងផលនៃទុច្ចរិតកម្មរបស់ភិក្ខុលាមកទាំងឡាយ ដែលអង្គុយក្នុងទីនោះក្នុងខណៈនោះ ទើបត្រាស់ព្រះគាថានេះថា

**កាសាវកណ្ឋា ពហវោ ចាបធម្មា អសញ្ញតា**
**បាបា បាបេហិ កម្មេហិ និរយន្តេ ឧបបជ្ជរេ ។**

ពួកជនច្រើននាក់ ដែលមានកព័ន្ធព័ទ្ធដោយសំពត់កាសាវៈ តែ ( ប្រព្រឹត្ត ) ធម៌ដ៏លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះ រមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយ ដ៏លាមកនោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កាសាវកណ្ឋា** បានដល់ បុគ្គលមានក

រុំដោយសំពត់កាសាវៈ ។

បទថា **ចាបធម្មា** ប្រែថា ដែលមានធម៌លាមក ។

បទថា **អសញ្ញតា** បានដល់ ដែលវៀរចាកការសង្រួមផ្លូវកាយជាដើម អធិប្បាយថា បុគ្គលលាមកបែបនោះរមែងចូលដល់នរក ព្រោះអកុសលកម្ម ទាំងឡាយដែលខ្លួនធ្វើ ជនទាំងនោះ ឆេះក្នុងនរកនោះហើយ ចុតិអំពីនរក នោះ ឆេះក្នុងបេតវិស័យទាំងឡាយយ៉ាងនោះ ព្រោះកម្មដែលឲ្យផលនៅ សេសសល់ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ៕

រឿង សត្វដែលត្រូវទុក្ខបៀតបៀន ចប់

# រឿង ភិក្ខុនៅត្រង់ច្រាំងស្ទឹងឈ្មោះ វគ្គុមុទា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងវេសាលី នាព្រៃមហាវ័ន ទ្រង់ប្រារព្ធ ពួកភិក្ខុដែលនៅត្រង់ច្រាំងស្ទឹងវគ្គុមុទា ត្រាស់ព្រះធម្មទេសនានេះថា **សេយ្យោ អយោគុឡោ** ជាដើម ។

រឿងនេះមកហើយ ក្នុងឧត្តរិមនុស្សធម្មបារាជិកសិក្ខាបទនោះឯង ។ ក្នុង កាលនោះឯង ព្រះសាស្តាត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពួក

អ្នកនាំគ្នាពោលគុណនៃឧត្តរិមនុស្សធម្ម នៃគ្នានិងគ្នាដល់ពួកគ្រហស្ថ ដើម្បីតែផ្ទៃឬ ។ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ដូច្នេះហើយ ទ្រង់តិះដៀលភិក្ខុទាំងនោះដោយអនេកបរិយាយ ហើយត្រាស់ព្រះគាថានេះថា

**សេយ្យោ អយោគុឡោ ភុត្តោ តត្តោ អគ្គិសិខូបមោ**
**យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ រដ្ឋបិណ្ឌំ អសញ្ញតោ ។**

បព្វជិតទ្រុស្តសីល សូវបរិភោគដុំដែកដែលកំពុងក្តៅ មានពណ៌ដូចអណ្តាតភ្លើងប្រសើរជាង បព្វជិតទ្រុស្តសីល មិនសង្រួមបរិភោគ ដុំបាយអ្នកដែន នឹងប្រសើរដូចម្តេចបាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យញ្ចេ ភុញ្ជេយ្យ** សេចក្តីថា ភិក្ខុទ្រុស្តសីល គឺភិក្ខុមិនមានសីល មិនសង្រួមផ្លូវកាយជាដើម ប្តេជ្ញាខ្លួនថា អញជាសមណៈ ទទួលដុំបាយអ្នកដែនដែលប្រគេនដោយសទ្ធា ដែលឈ្មោះថារដ្ឋបិណ្ឌឯណាហើយគប្បីឆាន់ ដុំដែកក្តៅមានពណ៌ដូចភ្លើងដែលភិក្ខុឆាន់ហើយ ប្រសើរជាង គឺល្អជាងនោះ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអត្តភាពមួយ គប្បីត្រូវភ្លើងឆេះ ព្រោះការបរិភោគដុំដែកនោះជាបច្ច័យ សូម្បីបុគ្គលទ្រុស្តសីល បរិភោគដុំបាយដែលគេប្រគេនដោយសទ្ធា គប្បីឆេះក្នុងនរកទាំងឡាយ រាប់រយអត្តភាព ។ ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ភិក្ខុនៅត្រង់ច្រាំងស្ទឹងឈ្មោះវគ្គុមុទា ចប់**

# រឿង សេដ្ឋីបុត្រឈ្មោះ ខេមកៈ

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីបុត្រឈ្មោះខេមកៈ ដែលជាក្មួយរបស់អនាថបិណ្ឌិកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះថា* **ចត្តារិ ឋានានិ** *ជាដើម ។*

*បានឮមកថា ខេមកៈនោះជាបុរសរូបស្អាត ដោយច្រើនស្រីទាំងឡាយឃើញគាត់ហើយ ត្រូវរាគៈគ្របសង្កត់ មិនអាចតាំងនៅតាមការៈរបស់ខ្លួនបាន គាត់បានត្រេកអរក្នុងបរទារកម្មនោះដូចគ្នា ។*

*បន្ទាប់មកក្នុងពេលរាត្រី ពួករាជបុរសចាប់នាំទៅបង្ហាញដល់ព្រះរាជា ។ ព្រះរាជាមិនបានត្រាស់ ដោយត្រិះរិះថា យើងខ្មាសចំពោះមហាសេដ្ឋី ហើយឲ្យដោះលែងទៅ ចំណែកខេមកៈនោះ មិនបានរាងចាលឡើយ ។ បន្ទាប់មកពួករាជបុរសក៏ចាប់បង្ហាញដល់ព្រះរាជាអស់វារៈ ២ ដង អស់វារៈ ៣ ដង ព្រះរាជាត្រាស់ឲ្យដោះលែងដដែល ។ សេដ្ឋីជ្រាបរឿងនោះហើយ នាំខេមកៈចូលទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលរឿងនោះហើយទូលថា បពិត្រព្រះអង្គ សូមទ្រង់សម្តែងធម៌ដល់ខេមកៈនេះ ។*

*ព្រះសាស្តាត្រាស់សង្វេគកថាដល់ខេមកៈហើយ កាលទ្រង់សម្តែងទោសក្នុងការសេពកិរិយាអ្នកដទៃ ទ្រង់ភាសិតព្រះគាថាទាំងនោះថា*

**ចត្តារិ ឋានានិ នរោ បមត្តោ អាបជ្ជតី បរទារូបសេវី**
**អបុញ្ញលាភំ ន និកាមសេយ្យំ និន្ទំ តតិយំ និរយំ ចតុត្ថំ ។**

**អបុញ្ញលាភោ ច គតី ច បាបិកា ភីតស្ស ភីតាយ រតី ច ថោកិកា រាជា ច ទណ្ឌំ គរុកំ បណេតិ តស្មា នរោ បរទារំ ន សេវេ ។**

នរជនអ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គលដទៃ រមែងដល់នូវហេតុនៃសេចក្ដីទុក្ខ ៤ យ៉ាងគឺ ទី ១ បានរបស់មិនមែនជាបុណ្យ ទី ២ ដេកមិនបានតាមប្រាថ្នា ទី ៣ ការតិះដៀល ទី ៤ ការធ្លាក់នរក ។ ( ហេតុនៃសេចក្ដីទុក្ខ ៤ យ៉ាងផ្សេងទៀត ) គឺបានរបស់មិនជាបុណ្យ ១ មានគតិអាក្រក់ ១ តម្រេករបស់បុរសអ្នកខ្លាចជាមួយនឹងស្ត្រីដែលខ្លាចដែរ មានប្រមាណតិច ១ ព្រះរាជានឹងដាក់អាជ្ញាយ៉ាងធ្ងន់ ១ ព្រោះហេតុនោះ បុរស មិនគួរសេពប្រពន្ធរបស់បុគ្គលដទៃឡើយ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **ឋានានិ** បានដល់ ហេតុនៃទុក្ខទាំងឡាយ ។ បទថា **បមត្តោ** បានដល់ ប្រកបដោយការបណ្ដោយសតិ ។ បទថា **អាបជ្ជតិ** គឺរមែងដល់ ។

បទថា **បរទារូបសេវី** សេចក្ដីថា ចូលទៅសេពកិរិយារបស់អ្នកដទៃឈ្មោះថា ប្រព្រឹត្តក្រៅផ្លូវ ។

បទថា **អបុញ្ញលាភំ** បានដល់ ការបាននូវអកុសល ។

បទថា **ន និកាមសេយ្យំ** សេចក្ដីថា បុគ្គលនោះ មិនបានការដេកតាម

ប្រាថ្នា រមែងបាននូវការដេកអស់កាលបន្តិចបន្តួចប៉ុណ្ណោះដែលខ្លួនមិនប្រាថ្នា ។

បទថា **អបុញ្ញលាភោ ច** សេចក្តីថា ការបាននូវវត្ថុ ដែលមិនមែនជាបុណ្យ ១ គតិដ៏លាមក ពោល គឺនរក ព្រោះវត្ថុដែលមិនមែនជាបុណ្យនោះជាហេតុ ១ រមែងមិនមានដល់បុគ្គលនោះយ៉ាងនេះ ។

ពីរបទថា **រតី ច ថោកិកា** សេចក្តីថា ការត្រេកអររបស់បុរសដែលខ្លាចនោះ ជាមួយស្រីដែលខ្លាចមានប្រមាណតិច គឺមានតិចតួច ។

បទថា **គរុកំ** សេចក្តីថា ម្យ៉ាងទៀត ព្រះរាជារមែងដាក់នូវអាជ្ញាយ៉ាងធ្ងន់ ដោយអំណាចនៃការកាត់ដៃជាដើម ។

បទថា **តស្មា** ជាដើម សេចក្តីថា បុគ្គលសេពកិរិយារបស់អ្នកដទៃរមែងដល់នូវឋានៈទាំងឡាយ ដែលមិនមែនជាបុណ្យជាដើមនោះ ព្រោះដូច្នោះទើបនរៈមិនគួរសេពកិរិយារបស់អ្នកដទៃ ។

ក្នុងកាលចប់ទេសនា ខេមកៈតាំងនៅក្នុងសោតាបត្តិផល តាំងអំពីនោះមក មហាជនញុំាងកាលឲ្យកន្លងទៅយ៉ាងសប្បាយ ។

សួរថា បុព្វកម្មរបស់ខេមកៈនោះដូចម្តេច ឆ្លើយថា បានឮមកថា ក្នុងសម័យរបស់ព្រះពុទ្ធព្រះនាមកស្សបទសពល ខេមកៈជាអ្នកប្រដាល់ដែលពូកែបំផុត គាត់លើកទង់មាសពីរបន្ទះឡើង ត្រង់កាញ្ចនស្តូបរបស់ព្រះទសពលហើយ តាំងសេចក្តីប្រាថ្នាថា វៀរតែស្រីដែលជាញាតិចេញ ស្រីដ៏សេសឃើញខ្ញុំព្រះអង្គហើយ សូមមានតម្រេក ។ នេះជាបុព្វកម្មរបស់ខេមកៈដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ ស្រីរបស់ជនដទៃឃើញខេមកៈ ក្នុងទីដែលខេមកៈ

*កើតហើយ ទើបមិនអាចតាំងនៅតាមការៈរបស់ខ្លួនបាន ដូច្នេះឯង ។*

**រឿង សេដ្ឋីបុត្រឈ្មោះ ខេមកៈ ចប់**

# រឿង ភិក្ខុប្រដៅក្រ

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះថា* **កុសោ យថា** *ជាដើម ។*

*បានឮមកថា ភិក្ខុមួយរូបមិនក្លែង គឺធ្វើឲ្យដាច់ស្មៅមួយដើម កាលសេចក្តីរង្កៀសកើតឡើង ទើបចូលទៅរកភិក្ខុមួយរូប ប្រាប់កម្មដែលខ្លួនធ្វើហើយ សួរថា អាវុសោ ភិក្ខុកាត់ស្មៅ ទោសណាមួយរមែងមានដល់ភិក្ខុនោះ លំដាប់នោះ ភិក្ខុក្រៅអំពីនេះពោលនឹងលោកថា លោកធ្វើការសម្គាល់ថា ទោសណាមួយមាន ព្រោះហេតុនៃស្មៅដែលលោកផ្តាច់ហើយ ទោសណាមួយរមែងមិនមានក្នុងទីនេះ កាលលោកសម្តែងហើយ រមែងផុតបានសូម្បីខ្លួនឯង ក៏បានយកដៃទាំងពីរដកស្មៅហើយកាន់ ភិក្ខុទាំងឡាយ ក្រាបទូលរឿងនោះ ដល់ព្រះសាស្តា ។*

*ព្រះសាស្តា ទ្រង់តិះដៀលភិក្ខុនោះដោយអនេកបរិយាយ កាលសម្តែងធម៌ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា*

កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយុបកឌ្ឍតិ ។
យំ កិញ្ចិ សិថិលំ កម្មំ សង្កិលិដ្ឋញ្ច យំ វតំ
សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ ។
កយិរា ចេ កយិរាថេនំ ទឡ្ហមេនំ បរក្កមេ
សិថិលោ ហិ បរិព្វាជោ ភិយ្យោ អាកិរតេ រជំ ។

*ស្បូវក្លាំងដែលបុគ្គលកាន់មិនចំណាប់ រមែងលះដៃ យ៉ាងណាមិញ ភាពជាសមណៈ ដែលបព្វជិតកាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះទៅនរក យ៉ាងនោះឯង ។ កម្មណាមួយដែលធូរថយក្តី វត្តណាមួយដែលសៅហ្មងក្តី ព្រហ្មចរិយៈដែលបុគ្គលរឭកដោយសេចក្តីរង្កៀសក្តី កម្មទាំង ៣ នោះ ជារបស់មិនមានផលច្រើនឡើយ។ បើបុគ្គលធ្វើ គប្បីធ្វើកិច្ចនោះឲ្យមែនទែន គប្បីប្រឹងប្រែងធ្វើកិច្ចនោះឲ្យមាំមួន ព្រោះថា សមណធម៌ ជាគ្រឿងវៀរចាកកិលេសធូរថយ រមែងរោយធូលី គឺរាគាទិក្កិលេសដល់បុគ្គលដោយក្រៃលែង ។*

## សេចក្តីអធិប្បាយ

*ស្មៅដែលមានជ្រុងមុត ដោយហោចសូម្បីស្លឹកត្នោតឈ្មោះថា* **កុសោ** *ក្នុងព្រះគាថានោះ ។ ស្បូវក្លាំងនោះ បុគ្គលណាចាប់មិនល្អរមែងមុត គឺរមែង*

លះដៃរបស់បុគ្គលនោះ យ៉ាងណា សូម្បីគុណជាគ្រឿងរបស់សមណៈ ពោល គឺសមណធម៌ក៏ដូច្នោះដូចគ្នា ឈ្មោះថា បុគ្គលស្ទាបអង្អែលមិនល្អ ព្រោះភាពជាអ្នកមានសីលដាច់ជាដើម ។

បាទព្រះគាថាថា **និរយាយុបកឌ្ឍតិ** សេចក្ដីថា រមែងឲ្យកើតក្នុងនរក ។

បទថា **សិថិលំ** បានដល់ ការងារឯណានីមួយដែលបុគ្គលធ្វើ ធ្វើឲ្យជាការកាន់យកធូរថយ ដោយធ្វើឲ្យធូររលុង ។

បទថា **សង្កិលិដ្ឋំ** សេចក្ដីថា ឈ្មោះថា សៅហ្មងព្រោះការត្រាច់ទៅក្នុងអគោចរ មានស្រីបេស្យាជាដើម ។

បទថា **សង្កស្សរំ** បានដល់ គប្បីរឭកដោយការសង្ស័យទាំងឡាយ គឺឃើញសង្ឃដែលប្រជុំគ្នាដោយកិច្ចណាមួយ ក្នុងបណ្ដាកិច្ច មានឧបោសថជាដើម ហើយរឭកដោយសេចក្ដីសង្ស័យរបស់ខ្លួន គឺរង្កៀស បានដល់ សង្ស័យយ៉ាងនេះថា ភិក្ខុទាំងនេះជ្រាបនូវការប្រព្រឹត្តរបស់អញ មានបំណងនឹងលើកវត្តអញ ទើបប្រជុំគ្នាពិត ។

ពីរបទថា **ន តំ ហោតិ** សេចក្ដីថា ព្រហ្មចរិយៈ ពោល គឺសមណធម៌នោះ គឺបែបនោះ រមែងមិនមានផលច្រើនដល់បុគ្គលនោះ ព្រោះមិនមានផលច្រើនដល់លោក ក៏រមែងមិនមានផលច្រើនដល់ទាយក ដែលជាអ្នកប្រគេនភិក្ខាផងដែរ ។

បទថា **កយិរា ចេ** សេចក្ដីថា ព្រោះហេតុនោះ បុគ្គលគប្បីធ្វើការងារណា ចូរធ្វើការងារនោះពិតៗ ។

បាទព្រះគាថាថា **ទឡ្ហមេនំ បរក្កមេ** សេចក្តីថា គួរធ្វើការងារនោះឲ្យជារបស់ដែលខ្លួនធ្វើមាំទាំ គឺជាអ្នកមានការសមាទានតាំងមាំ ធ្វើការងារនោះ ។

បទថា **បរិព្វាជោ** បានដល់ សមណធម៌ដែលបុគ្គលធ្វើដោយការប្រកាន់ធូរថយ ដែលដល់នូវភាវៈ មានការដាច់ជាដើម ។

បទថា **ភិយ្យោ** សេចក្តីថា សមណធម៌បែបនោះ រមែងមិនអាចនាំចេញនូវធូលី មានធូលី គឺរាគៈជាដើម ដែលមានក្នុងខាងក្នុងដោយពិត រមែងរោយនូវធូលី មានរាគៈជាដើមដទៃ លើបុគ្គលនោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ។ ភិក្ខុនោះតាំងនៅក្នុងការសង្រួមហើយ ក្រោយមកចម្រើនវិបស្សនា សម្រេចអរហត្ត ដូច្នេះឯង ។

**រឿង ភិក្ខុប្រដៅក្រចប់**

# រឿង ស្រីប្ញាស

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្រីកាចម្នាក់ត្រាស់ព្រះធម្មទេសនានេះថា **អកតំ** ជាដើម ។

បានឮមកថា ប្តីរបស់ស្រីនោះ បានធ្វើការស្និទ្ធស្នាលជាមួយស្រីបម្រើក្នុងផ្ទះម្នាក់ ។ ស្រីកាចនោះ ចងដៃចងជើងស្រីបម្រើនោះហើយ កាត់ត្រចៀក

កាត់ប្រមុះ បង្ខាំងក្នុងបន្ទប់តូចមួយបិទទ្វារហើយ ដើម្បីបិទបាំងកម្មអាក្រក់នោះ ដែលខ្លួនធ្វើហើយបបួលប្តីថា មកយើងនឹងទៅស្តាប់ធម៌ នាំប្តីទៅវត្តអន្ទយស្តាប់ធម៌ ។ ខណៈនោះ ពួកញាតិមកពីចម្ងាយរបស់នាង មកកាន់ផ្ទះហើយ បើកទ្វារឃើញអាការចម្លែកនោះហើយ ស្រាយស្រីបម្រើចេញ ។ ស្រីបម្រើនោះទៅវត្ត ក្រាបទូលសេចក្តីនោះដល់ព្រះទសពល ត្រង់កណ្តាលបរិស័ទ ៤ ។ ព្រះសាស្តាស្តាប់ពាក្យរបស់ស្រីបម្រើហើយត្រាស់ថា ឈ្មោះថា ទុច្ចរិតទោះបីតិចតួចបុគ្គលមិនគួរធ្វើ ដោយការសម្គាល់ថា ជនដទៃតែងមិនដឹងកម្មនោះរបស់អញ ចំណែកសុចរិតនោះឯង ទោះបីបុគ្គលដទៃមិនដឹងក៏គួរធ្វើ ព្រោះថា ឈ្មោះថា ទុច្ចរិត ទោះបីបុគ្គលធ្វើដោយបិទបាំង រមែងធ្វើការដុតរោលក្នុងកាលជាខាងក្រោយ ចំណែកសុចរិត ញុំាងនូវសេចក្តីត្រេកអរតែម្យ៉ាងឲ្យកើតឡើង ដូច្នេះហើយ ទើបត្រាស់គាថានេះថា

**អកតំ ទុក្កតំ សេយ្យោ　　　បច្ឆា តប្បតិ ទុក្កតំ**
**កតញ្ច សុកតំ សេយ្យោ　　　យំ កត្វា នានុតប្បតិ ។**

អំពើអាក្រក់ដែលបុគ្គលមិនធ្វើ ប្រសើរជាង ( ព្រោះថា )
អំពើអាក្រក់ រមែងធ្វើឲ្យក្តៅក្រហាយក្នុងកាលខាងក្រោយ
បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយក្រោយ
អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គល
ប្រសើរ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **ទុក្កដំ** សេចក្ដីថា កម្មដែលមានទោស ញ៉ាំងសត្វឲ្យប្រព្រឹត្តទៅក្នុងអបាយ មិនធ្វើល្អជាង គឺប្រសើរ បានដល់ ឧត្តម ។

ពីរបទថា **បច្ឆា តបតិ** សេចក្ដីថា ព្រោះកម្មនោះ រមែងដុតរោលក្នុងកាលដែលខ្លួនតាមរឭកដល់ហើយរឿយៗ ទៅ ។ បទថា **សុកតំ** សេចក្ដីថា ចំណែកកម្មដែលមិនមានទោស មានសុខជាផល ញ៉ាំងសត្វឲ្យប្រព្រឹត្តទៅក្នុងសុគតិតែម្យ៉ាង បុគ្គលធ្វើហើយល្អជាង ។ ពីរបទថា **យំ កត្វា** សេចក្ដីថា បុគ្គលធ្វើកម្មណាហើយ រមែងមិនក្ដៅក្រហាយក្នុងកាលជាក្រោយ គឺក្នុងកាលដែលរឭកដល់ ឈ្មោះថា រមែងមិនតាមក្ដៅក្រហាយ គឺជាអ្នកមានសោមនស្សតែម្យ៉ាង កម្មនោះ ដែលបុគ្គលធ្វើហើយ ប្រសើរ ។

ក្នុងកាលចប់ទេសនា ឧបាសក និងស្រីនោះ តាំងនៅក្នុងសោតាបត្តិផលហើយ ជនទាំងឡាយ ធ្វើស្រីនោះឲ្យជាអ្នកជាក្នុងទីនោះឯង ធ្វើឲ្យជាស្រីមានប្រក្រតីប្រព្រឹត្តធម៌ ដូច្នេះឯង ។៚

រឿង ស្រីផ្សាស ចប់

# រឿង អាគន្តុកភិក្ខុ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអាគន្តុកភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **នគរំ យថា** ជាដើម ។

បានឮថា ពួកភិក្ខុទាំងនោះ ចាំវស្សាក្នុងបច្ចន្តនគរមួយកន្លែង បាននៅជាសុខក្នុងខែដំបូង ក្នុងខែកណ្ដាល ពួកចោរបានមកប្លន់ស្រុកដែលជាទីគោចររបស់ភិក្ខុទាំងនោះ ចាប់អ្នកស្រុកជាឈ្លើយ ។ ចាប់តាំងពីកាលនោះ មនុស្សទាំងឡាយបាននាំគ្នាមកថែរក្សាបច្ចន្តនគរនោះ ដើម្បីការពារចោរ មិនបានឱកាសឧបដ្ឋាកភិក្ខុទាំងនោះ ។ ពួកភិក្ខុទាំងនោះ ចាំវស្សាមិនបានសុខស្រួល ចេញវស្សាហើយ បានទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះសាស្ដា ថ្វាយបង្គំព្រះសាស្ដាហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។

ព្រះសាស្ដាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងនោះ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនាំគ្នានៅជាសុខឬ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គនៅជាសុខក្នុងខែដំបូងប៉ុណ្ណោះ ក្នុងខែកណ្ដាលពួកចោរបានប្លន់ស្រុក ចាប់តាំងអំពីកាលនោះ មនុស្សទាំងឡាយនាំគ្នាការពារនគរមិនបានឱកាសទំនុកបម្រុងជិតដល់ឡើយ ព្រោះដូច្នោះ ទើបពួកខ្ញុំព្រះអង្គចាំវស្សាមិនមានសេចក្ដីសុខ ទើបត្រាស់ថា ណ្ហើយចុះ ភិក្ខុទាំងឡាយ ពួកអ្នកកុំគិតថ្វីឡើយ ធម្មតាការនៅជាសុខអស់កាលជានិច្ច ដែលបុគ្គលរកបានលំបាក ធម្មតាភិក្ខុរក្សាអត្តភាពនោះឯង ដូចគ្នានឹងពួកមនុស្សទាំងនោះ គ្រប់គ្រងនគរដូច្នោះគួរ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ**
**ឯវំ គោបេថ អត្តានំ ខណោ វោ មា ឧបច្ចគា**
**ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។**

នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ទាំងខាងក្រៅ យ៉ាងណា អ្នកទាំងឡាយគួររក្សាខ្លួនយ៉ាងនោះ កុំឲ្យខណៈកន្លងអ្នកទាំងឡាយបានឡើយ ព្រោះថា ជនទាំង-ឡាយ ដែលឲ្យខណៈកន្លងហើយ រមែងសោកស្តាយក្នុងនរកមិនដែរជាស ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សន្តរពាហិរំ** ជាដើម សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បច្ចន្តនគរនោះ ដែលមនុស្សទាំងនោះនាំគ្នាធ្វើ ទីមាំទាំទាំងឡាយ មានទ្វារផ្ទះ និងកំពែងជាដើម ឈ្មោះថា ធ្វើឲ្យមាំទាំខាងក្នុង គេធ្វើទីមាំទាំទាំងឡាយ មានប៉ម និងគូទឹកជាដើម ឈ្មោះថា ធ្វើឲ្យមាំទាំខាងក្រៅ ព្រោះហេតុនោះ បច្ចន្តនគរនោះ ទើបជាក្រុងដែលពួកមនុស្សធ្វើឲ្យមាំទាំទាំងខាងក្នុង ទាំងខាងក្រៅ រក្សាហើយ យ៉ាងណា ចូរពួកអ្នកចូលទៅតាំងសតិ ចូរបិទទ្វារទាំង ៦ ដែលជាខាងក្នុង មិនបណ្តោយសតិដែលរក្សាទ្វារ ធ្វើអាយតនៈខាងក្នុង ៦ ឲ្យមាំទាំ ដោយការមិនកាន់យក ដោយប្រការដែលអាយតនៈខាងក្រៅ ៦ ដែលកំពុងប្រកាន់ នឹងប្រព្រឹត្តទៅដើម្បីកម្ចាត់អាយតនៈខាងក្នុង មិនលះសតិដែលរក្សាទ្វារ ដើម្បីមិនឲ្យអាយតនៈខាងក្រៅទាំងនោះ ចូលទៅប្រព្រឹត្ត ឈ្មោះថា រក្សាខ្លួន ដូច្នោះ ។

បាទព្រះគាថាថា **ខណោ វោ មា ឧបច្ចគា** សេចក្តីថា បុគ្គលណាមិនគ្រប់គ្រងខ្លួនយ៉ាងនោះ ខណៈនេះទាំងអស់ គឺខណៈដែលកើតឡើងនៃព្រះពុទ្ធ

១ ខណៈដែលកើតក្នុងមជ្ឈិមប្រទេស ១ ខណៈដែលបានសម្មាទិដ្ឋិ ១ ខណៈដែលមិនខ្វះខាតអាយតនៈទាំង ៦ ប្រការ ១ រមែងឈានកន្លងនូវបុគ្គលនោះ ខណៈនោះ ចូរកុំឈានកន្លងអ្នកទាំងឡាយឡើយ ។

បទថា **ខណាតីតា** ជាដើម សេចក្តីថា ព្រោះថា បុគ្គលណាកន្លងនូវខណៈនោះ និងខណៈនោះកន្លងបង់នូវបុគ្គលនោះ ជនទាំងនោះជាអ្នកកុះករក្នុងនរក គឺកើតក្នុងនរកនោះហើយ សោយសោក ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះកើតនូវសេចក្តីសង្វេគ តាំងនៅក្នុងអរហត្តផលហើយ ដូច្នេះឯង ។៘

**រឿង អាគន្តុកភិក្ខុ ចប់**

# រឿង និគ្គណ្ឋ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនិគ្គណ្ឋ ត្រាស់ព្រះធម្មទេសនានេះថា **អលជ្ជិតាយេ** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ ភិក្ខុទាំងឡាយឃើញពួកនិគ្គណ្ឋហើយ សន្ទនាគ្នាថា អាវុសោ ពួកនិគ្គណ្ឋទាំងនេះប្រសើរជាងពួកអ្នកបួសអាក្រាត ដែលមិនបិទបាំងដោយប្រការទាំងពួង ព្រោះថា ពួកនិគ្គណ្ឋបិទបាំងខាងមុខតែម្យ៉ាងប៉ុណ្ណោះ ប្រហែលជាអ្នកមានទ្បាសខ្លះ ពួកនិគ្គណ្ឋស្តាប់ពាក្យនោះហើយ ក៏

ពោលថា ពួកយើងបិទបាំងព្រោះហេតុនោះក៏មិនមែន ពួកយើងបិទបាំងព្រោះហេតុនេះ គឺល្អងធូលីជាដើមនោះឯង ជារបស់ទាក់ទងដល់ជីវិតិន្ទ្រិយ កាលបើដូច្នោះ ល្អងផ្សេងៗ មានកម្ទេចកម្ទី និងធូលីជាដើមនោះ កុំធ្លាក់ចូលទៅក្នុងភាជនកិក្ខាទាំងឡាយរបស់ពួកយើង ដូច្នេះហើយ និយាយជាមួយភិក្ខុទាំងនោះយ៉ាងច្រើន ដោយអំណាចនៃការលើកវាទៈ ។ ភិក្ខុទាំងឡាយចូលគាល់ព្រះសាស្តា ក្រាបទូលរឿងនោះ ក្នុងកាលដែលខ្លួនអង្គុយហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ឈ្មោះថាខ្មាសក្នុងវត្ថុដែលមិនគួរខ្មាស មិនខ្មាសក្នុងវត្ថុដែលគួរខ្មាស ជាអ្នកមានទុគ្គតិ ជាទីទៅខាងមុខពិត ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានភាសិតព្រះគាថាទាំងនេះថា

**អលជ្ជិតាយេ លជ្ជន្តិ           លជ្ជិតាយេ ន លជ្ជរេ**<br>
**មិច្ឆាទិដ្ឋិសមាទានា           សត្តា គច្ឆន្តិ ទុគ្គតឹ ។**<br>
**អភយេ ភយទស្សិនោ           ភយេ ច អភយទស្សិនោ**<br>
**មិច្ឆាទិដ្ឋិសមាទានា           សត្តា គច្ឆន្តិ ទុគ្គតឹ ។**

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាសក្នុងហេតុ<br>
ដែលគេមិនត្រូវខ្មាស រមែងមិនខ្មាសក្នុងហេតុដែលគេត្រូវ<br>
ខ្មាស សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។<br>
សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ<br>
ក្នុងហេតុដែលគេមិនត្រូវខ្លាច ថាជាហេតុដែលគេត្រូវខ្លាច

ផង យល់ឃើញក្នុងហេតុដែលគេត្រូវខ្លាច ថាជាហេតុដែល
គេមិនត្រូវខ្លាចផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

# សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **អលជ្ជិតាយេ** បានដល់ ព្រោះភាជនកិច្ចាដែលមិនគួរខ្មាស ពិតហើយ ភាជនកិច្ចា ឈ្មោះថា វត្ថុដែលមិនគួរខ្មាស ។ ឯសត្វទាំងនោះ កាលបិទបាំងភាជនកិច្ចានោះហើយ ត្រាច់ទៅ ឈ្មោះថា ខ្មាសព្រោះភាជនកិច្ចាដែលមិនគួរខ្មាស ។

បទថា **លជ្ជិតាយេ** សេចក្ដីថា ព្រោះអង្គដែលញុំាងហិរិឲ្យកម្រើកមិនបិទបាំងហើយ ពិតហើយ អង្គដែលញុំាងហិរិឲ្យកម្រើក ឈ្មោះថា វត្ថុដែលគួរខ្មាស សត្វទាំងនោះមិនបិទបាំងអង្គ ដែលញុំាងហិរិឲ្យកម្រើកនោះត្រាច់ទៅ ឈ្មោះថា មិនខ្មាសព្រោះវត្ថុដែលគួរខ្មាស ព្រោះហេតុនោះ កាលសត្វទាំងនោះ ខ្មាសព្រោះវត្ថុដែលមិនគួរខ្មាស មិនខ្មាសព្រោះវត្ថុដែលគួរខ្មាស ។ ឈ្មោះថា ជាមិច្ឆាទិដ្ឋិ ព្រោះភាវៈ គឺការប្រកាន់ទទេ និងព្រោះភាវៈ គឺការប្រកាន់ដោយប្រការដទៃ សត្វទាំងនោះ សមាទានមិច្ឆាទិដ្ឋិនោះហើយ ត្រាច់ទៅ ឈ្មោះថា សមាទានមិច្ឆាទិដ្ឋិ តែងដល់នូវទុគ្គតិ អបាយ មាននរកជាដើម ។

បទថា **អភយេ** ជាដើម សេចក្ដីថា ភាជនកិច្ចា ឈ្មោះថា វត្ថុដែលមិនគួរខ្លាចព្រោះកិលេស គឺរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងភ័យ គឺទុច្ចរិតមិនកើតឡើង ព្រោះអាស្រ័យភាជនកិច្ចាឡើយ ។ សត្វទាំងឡាយ បិទបាំង

ភាជនៈនោះព្រោះការខ្មាច ឈ្មោះថា មានប្រក្រតីឃើញក្នុងវត្ថុដែលមិនគួរខ្មាច ថាគួរខ្មាច អន្តដែលញ៉ាំងហិរិឲ្យកម្រើកនោះ ឈ្មោះថា វត្ថុដែលគួរខ្មាច ព្រោះកិលេសទាំងឡាយ មានរាគៈជាដើម កើតឡើងព្រោះអាស្រ័យអន្តដែលញ៉ាំងហិរិឲ្យកម្រើក ។ ព្រោះមិនបិទបាំងអន្តដែលញ៉ាំងហិរិឲ្យកម្រើក ទើបឈ្មោះថា ជាអ្នកមានប្រក្រតីឃើញក្នុងវត្ថុដែលគួរខ្មាច ថាមិនគួរខ្មាច ។ សត្វទាំងឡាយ ឈ្មោះថា សមាទានមិច្ឆាទិដ្ឋិ ព្រោះអំណាចដែលខ្លួនសមាទានការប្រកាន់ទទេនោះ និងការប្រកាន់ដោយប្រការដទៃ រមែងដល់ទុគ្គតិ ។

ក្នុងកាលចប់ទេសនា ពួកនិគ្គណ្ឋមានចិត្តសង្វេគ ហើយបួស ។ ទេសនាសម្រេចប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ៕

រឿង និគ្គណ្ឋ ចប់

# រឿង សាវកតិរ្ថិយ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកសាវកតិរ្ថិយ ត្រាស់ព្រះធម្មទេសនានេះថា **អវជ្ជេ** ជាដើម ។

សេចក្តីពិស្តារ សម័យមួយ ពួកសាវកតិរ្ថិយ ឃើញកូនទាំងឡាយរបស់ខ្លួន មួយអន្ទើដោយបរិវារ លេងជាមួយពួកកូនរបស់ឧបាសក ដែលជា

សម្មាទិដ្ឋិ ក្នុងកាលកូនទាំងនោះមកផ្ទះហើយ ទើបឲ្យធ្វើប្ដេជ្ញាថា ពួកសមណ-សក្យបុត្រ ពួកឯងមិនគប្បីថ្វាយបង្គំ សូម្បីវិហាររបស់សមណៈទាំងនោះ ពួកឯងក៏មិនគប្បីចូលទៅ ។ ថ្ងៃមួយ កូនរបស់ពួកតិរ្ថិយទាំងនោះកំពុងលេងក្នុងទីជិតនៃខ្លោងទ្វារ ខាងក្រៅវត្តជេតពន ការស្រេកទឹកក៏កើតឡើង ពេលនោះក្មេងទាំងនោះ បញ្ជូនក្មេងរបស់ឧបាសកម្នាក់ទៅកាន់វិហារប្រាប់ថា ចូរឯងទៅផឹកទឹកក្នុងវិហារនោះហើយ ដងមកដើម្បីពួកយើងផង ក្មេងនោះក៏ចូលទៅកាន់ព្រះវិហារថ្វាយបង្គំព្រះសាស្ដាហើយ ក្រាបទូលសេចក្ដីនោះ ។

គ្រានោះ ព្រះសាស្ដាត្រាស់នឹងក្មេងនោះថា អ្នកប៉ុណ្ណោះផឹកទឹកហើយ បញ្ជូនពួកក្មេងទាំងនោះមកដើម្បីផឹកទឹកក្នុងទីនេះ កុមារនោះក៏ធ្វើយ៉ាងនោះ ។ ពួកក្មេងទាំងនោះ មកផឹកទឹកហើយ ព្រះសាស្ដាហៅក្មេងទាំងនោះមកហើយ ត្រាស់ធម្មកថា ដែលជាទីសប្បាយដល់ក្មេងទាំងនោះ ទ្រង់ធ្វើក្មេងទាំងនោះឲ្យមានសទ្ធាមាំទាំហើយ ឲ្យតាំងនៅក្នុងសរណៈ និងសីល ក្មេងទាំងនោះទៅកាន់ផ្ទះរៀងៗ ខ្លួនហើយ ប្រាប់សេចក្ដីនោះដល់មាតានិងបិតា ។ គ្រានោះ មាតានិងបិតា ដល់នូវការទោមនស្សរៀបរាប់ថា កូនរបស់ពួកយើងទៅជាមនុស្សមានទិដ្ឋិវិបត្តិហើយ ។ កាលនោះ មនុស្សអ្នកស្និទ្ធស្នាលរបស់ជនទាំងនោះជាអ្នកឈ្លាស មកពោលធម៌ដល់ជនទាំងនោះ ដើម្បីញ៉ាំងទោមនស្សឲ្យស្ងប់ ។

មាតា និងបិតារបស់ក្មេងទាំងនោះ ស្ដាប់ពាក្យរបស់ជនទាំងនោះហើយ ទើបពោលថា ពួកយើងនឹងប្រគល់ក្មេងទាំងនេះដល់ព្រះសមណគោតម ដូច្នេះហើយ នាំទៅកាន់វិហារ មួយអន្លើដោយពួកញាតិជាច្រើន ។

ព្រះសាស្តា កាលទ្រង់ប្រមើលមើលអាសយៈ របស់មនុស្សទាំងនោះ ហើយ កាលទ្រង់សម្តែងធម៌ ទ្រង់បានភាសិតគាថាទាំងនេះថា

**អវជ្ជេ វជ្ជមតិនោ វជ្ជេ ច អវជ្ជទស្សិនោ**
**មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។**
**វជ្ជញ្ច វជ្ជតោ ញត្វា អវជ្ជញ្ច អវជ្ជតោ**
**សម្មាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ សុគតឹ ។**

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញក្នុងហេតុដែលមានទោសថា ជាហេតុឥតទោសផង សត្វទាំងនោះ តែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់មានទោស ថាជារបស់មានទោសផង ដឹងរបស់មិនមានទោស ថាជារបស់មិនមានទោសផង សត្វទាំងនោះ តែងទៅកាន់សុគតិ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អវជ្ជេ** គឺក្នុងសម្មាទិដ្ឋិ មានវត្ថុ ១០ និងក្នុងធម៌ដែលជាឧបនិស្ស័យនៃសម្មាទិដ្ឋិនោះ ។

បទថា **វជ្ជមតិនោ** គឺមានមតិកើតឡើងថា នេះមានទោស តែសត្វទាំងនោះ មានប្រក្រតីឃើញថា មិនមានទោសក្នុងធម៌ដែលមានទោស គឺមិច្ឆាទិដ្ឋិ

មានវត្ថុ ១០ គឺធម៌ដែលជាឧបនិស្ស័យនៃមិច្ឆាទិដ្ឋិនោះ អធិប្បាយថា សត្វទាំងឡាយ ឈ្មោះថា កាន់យកដោយល្អនូវមិច្ឆាទិដ្ឋិ ព្រោះភាពដែលខ្លួនកាន់យកដោយល្អហើយនូវមិច្ឆាទិដ្ឋិនោះ គឺការដឹងធម៌ដែលមិនមានទោស ដោយភាពជាធម៌មានទោស និងដឹងធម៌ដែលមានទោស ដោយភាពជាធម៌មិនមានទោស ហើយប្រកាន់មាំ រមែងទៅកាន់ទុគ្គតិ ។

សេចក្តីនៃព្រះគាថាទី ២ បណ្ឌិតគប្បីជ្រាបដោយន័យផ្ទុយគ្នា តាមដែលពោលហើយ ។

ក្នុងកាលចប់ទេសនា ជនទាំងនោះតាំងនៅក្នុងសរណៈ ៣ ស្តាប់ធម៌ដទៃៗ ទៀត ក៏បានតាំងនៅក្នុងសោតាបត្តិផល ដូច្នេះឯង ៕

**រឿងសាវកតិត្ថិយ ចប់**

**និរយវគ្គ ចប់**

**វគ្គទី ២២ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា នាគវគ្គទី ២៣

[ ៣៣ ] តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដំរីកាលអត់ទ្រាំចំពោះព្រួញ ដែលរបូតចេញអំពីធ្នូ ក្នុងសង្គ្រាម ដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។ ពួកជនតែងនាំវាហនៈដែលទូន្មានហើយ ទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងកាន់វាហនៈ ដែលទូន្មានហើយ បណ្តាមនុស្សទាំង-ឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះ ជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅបានបទហើយ រាប់ថា ជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មាន បានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

បុគ្គលទូន្មានខ្លួន បានបទហើយ ទូន្មានខ្លួនល្អហើយ ឈ្មោះថា ទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានទាំងឡាយនោះឡើយ ។

ដំរីឈ្មោះធនបាល ជាសត្វចុះប្រេង ក្លៀវក្លា នាយហត្ថាចារ្យឃាត់បានដោយលំបាក បើនាយហត្ថាចារ្យ ចងភ្ជាប់ មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃវិ្វង ដែលដំរីនោះធ្លាប់នៅ ។

កាលណា បុគ្គលអ្នកមានសេចក្តីងោកងុយផង អ្នកបរិភោគភោជនមានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះនទៀលផង ដូចជ្រូក

ស្រុកដែលបុគ្គលចិញ្ចឹមដោយសូករភត្ត កាលនោះ បុគ្គលនោះ ជាមនុស្ស ខ្ជិល រមែងចូលទៅកាន់គភ៌រឿយៗ ។

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមអាការ ដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្ដីសប្បាយ ក្នុងថ្ងៃ នេះ អញនឹងសង្កត់សង្កិនចិត្តនោះ ដោយឧបាយ ដូចហ្មដំរីកាន់កង្វេរសង្កត់ សង្កិនដំរីចុះប្រេង ដូច្នោះដែរ ។

អ្នកទាំងឡាយ ចូរត្រេកអរ ក្នុងសេចក្ដីមិនប្រមាទ ចូររក្សាចិត្តរបស់ ខ្លួន ចូររើខ្លួនចេញចាកភក់ គឺកិលេស ដែលធ្លងបានដោយកម្រ ដូចដំរីដែល ជាប់នៅក្នុងភក់ រើខ្លួនឲ្យរួចបាន ។

បើបុគ្គលបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញា ចងចាំ មានគុណធម៌ជាគ្រឿងនៅ ញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្ដីអន្ត-រាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសម្លាញ់នោះឯង ។ បើស្វែងរកមិន បានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណ ធម៌ជាគ្រឿងញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ ទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ ដែលទ្រង់ឈ្នះហើយ ស្ដេចទៅតែ ឯកអង្គ ពុំនោះសោត ដូចដំរីឈ្មោះមាតង្គៈ ដែលលះហ្វូងត្រាច់ទៅតែឯក ឯង ក្នុងព្រៃ ដូច្នោះដែរ ។

កាលត្រាច់ទៅ របស់បុគ្គលឯកឯង ជាគុណជាតិប្រសើរផុត ( ព្រោះ

ថា ) សហាយតាគុណ រមែងមិនមាន ក្នុងជនពាលឡើយ បុគ្គលនោះ គប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯកឯង ក្នុងព្រៃ ដូច្នោះដែរ ។

កាលបើសេចក្តីត្រូវការ កើតឡើងហើយ សម្លាញ់ទាំងឡាយ នាំសេចក្តីសុខមកឲ្យ សេចក្តីត្រេកអរជាបច្ច័យ តាមមាន តាមបាន ជាហេតុនាំសេចក្តីសុខមកឲ្យ បុណ្យនាំសេចក្តីសុខមកឲ្យ ក្នុងកាលទៀបក្ស័យជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឲ្យ ។

សេចក្តីប្រតិបត្តិល្អក្នុងមាតា នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អក្នុងបិតា នាំសេចក្តីសុខមកឲ្យ សេចក្តីប្រតិបត្តិល្អក្នុងសមណៈ នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អក្នុងព្រាហ្មណ៍ នាំសេចក្តីសុខមកឲ្យ សីលនាំសេចក្តីសុខមកឲ្យ ដរាបដល់ចាស់ សទ្ធាដែលបុគ្គលតម្កល់ស៊ប់ហើយ ញុំាងសេចក្តីសុខមកឲ្យ ការបានប្រាជ្ញា នាំសេចក្តីសុខមកឲ្យ ការមិនធ្វើបាបទាំងឡាយ នាំសេចក្តីសុខមកឲ្យ ។

**នាគវគ្គទី ២៣ ចប់**

# អដ្ឋកថា
# ឆាតវគ្គទី ២៣

## រឿង របស់ព្រះសាស្តា
### លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងកោសម្ពី ទ្រង់ប្រារព្ធព្រះអង្គផ្ទាល់ ត្រាស់ព្រះធម្មទេសនានេះថា **អហំ នាគោវ** ជាដើម ។

រឿង ខ្ញុំឲ្យពិស្តារហើយក្នុងពណ៌នានៃគាថាដំបូង ក្នុងអប្បមាទវគ្គនោះឯង ។ ពិតហើយ ក្នុងទីនោះខ្ញុំពោលដូច្នេះថា ព្រះនាងមាគន្ទិយា មិនអាចធ្វើអ្វីដល់ស្រី ៥០០ មានព្រះនាងសាមាវតីជាប្រធានទាំងនោះបាន ទើបត្រិះរិះថា យើងនឹងធ្វើកិច្ចដែលគួរធ្វើដល់ព្រះសមណគោតមឲ្យបាន ដូច្នេះហើយ ឲ្យថ្លៃឈ្នួលដល់អ្នកនគរទាំងឡាយ ពោលថា អ្នកទាំងឡាយ មួយអន្លើដោយកូនប្រុស ទាសៈ និងកម្មករ ចូរជេរបរិភាសព្រះសមណគោតម ដែលត្រាច់ចូលមកខាងក្នុងព្រះនគរឲ្យគេចទៅ ។

ពួកមិច្ឆាទិដ្ឋិ មិនជ្រះថ្លាក្នុងព្រះរតនត្រ័យ បានជាប់តាមព្រះសាស្តា ដែលយាងចូលទៅខាងក្នុងព្រះនគរ កំពុងជេរ កំពុងបរិភាស ដោយអក្កោសវត្ថុ ១០ ថា ឯងជាចោរ ឯងជាបុគ្គលពាល ឯងជាមនុស្សវង្វេង ឯងជាឱដ្ឋ ឯងជាគោ ឯងជាលា ឯងជាសត្វនរក ឯងជាសត្វតិរច្ឆាន សុគតិមិន

មានសម្រាប់ឯង ទុគ្គតិប៉ុណ្ណោះ ដែលឯងគប្បីដល់ ។

ព្រះអានន្ទស្តាប់ពាក្យនោះហើយ បានក្រាបទូលពាក្យនេះនឹងព្រះសាស្តាថា បពិត្រព្រះអង្គ អ្នកនគរទាំងនេះ ជេរ បរិភាសយើងទាំងឡាយៗ ទៅក្នុងនគរដទៃក្រៅអំពីនគរនេះចុះ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ អ្នកទៅណា ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅកាន់នគរដទៃ ព្រះសាស្តាត្រាស់ថា បើមនុស្សក្នុងនគរដទៃនោះ ជេរ បរិភាស យើងនឹងទៅទីណាទៀត ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅកាន់នគរផ្សេងៗ អំពីនគរនោះទៀត ព្រះសាស្តាត្រាស់ថា បើមនុស្សក្នុងទីនោះជេរ បរិភាស យើងទាំង-ឡាយទៀត តើទៅណា ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅកាន់នគរដទៃក្រៅអំពីនេះទៀត ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ធ្វើយ៉ាងនោះ មិនគួរ អធិករណ៍កើតឡើងក្នុងទីណា ត្រូវធ្វើឲ្យស្ងប់ហើយក្នុងទីនោះឯង ការទៅកាន់ទីដទៃ មិនគួរ ម្នាលអានន្ទ តើជនពួកណា ជាអ្នកជេរ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ជនទាំងអស់ តាំងអំពីទាសៈ និងកម្មករ ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ តថាគតដូចគ្នានឹងដំរីដែលចូលកាន់សង្គ្រាម ការអត់ធន់នឹងព្រួញ ដែលហើរមកអំពីទិសទាំង ៤ ជាភារៈរបស់ដំរីដែលចូលកាន់សង្គ្រាម យ៉ាងណា ឈ្មោះថា ការអត់ធន់នឹងពាក្យសម្តី ដែលជនទ្រុស្តសីលពោលហើយ ជាភារៈរបស់តថាគតដូចគ្នា ។ កាលទ្រង់ប្រារព្ធព្រះអង្គសម្តែងធម៌ ទ្រង់បានភាសិតព្រះគាថាទាំងនេះ ក្នុងនាគវគ្គថា

**អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ**

អតិវាក្យន្តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ ។
ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ
ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យន្តិតិក្ខតិ ។
វរមស្សតរា ទន្តា អាជានីយា វ សិន្ធវា
កុញ្ជរា វ មហានាគា អត្តទន្តោ តតោ វរំ ។

តថាគត នឹងអត់ទ្រាំពាក្យល្មើស ដូចដំរីកាលអត់ទ្រាំចំពោះព្រួញ ដែលរបូតចេញអំពីធ្នូ ក្នុងសង្គ្រាម ដូច្នោះព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។ ពួកជនតែងនាំវាហនៈ ដែលទូន្មានហើយ ទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងកាន់វាហនៈ ដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះ ជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅ បានបទហើយ រាប់ថា ជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មាន បានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **នាគោវ** គឺដូចដំរី ។ ពីរបទថា **ចាបាតោ**

**បតិតំ** សេចក្តីថា របូតចេញអំពីធ្នូ ។

បទថា **អតិវាក្យំ** សេចក្តីថា នូវពាក្យកន្លងល្មើសដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃអរិយវោហារ ៨ ។

បទថា **តិតិក្ខិស្សំ** សេចក្តីថា ដំរីធំដែលគេបង្ហឹកហើយ ចូលកាន់សង្គ្រាម ជាសត្វអត់ធន់ មិនតក់ស្លុតនូវព្រួញដែលរបូតចាកអំពីបន្ទោះ ធ្លាក់ចុះលើខ្លួន ឈ្មោះថា អត់ធន់ចំពោះការប្រហារទាំងឡាយ មានប្រហារដោយលំពែងជាដើមបាន យ៉ាងណា តថាគត នឹងអត់ធន់ គឺអត់ធន់ចំពោះពាក្យដែលមានសភាពយ៉ាងនោះ ដូច្នេះដូចគ្នា ។

បទថា **ទុស្សីលោ ហិ** សេចក្តីថា ព្រោះលោកិយមហាជននេះ ដោយច្រើន ជាអ្នកទ្រុស្តសីល ដើរបញ្ចេញវាចាស៊កសៀត ដោយអំណាចនៃការពេញចិត្តរបស់ខ្លួន ការអត់ធន់ គឺការប្រងើយកន្តើយក្នុងពាក្យនោះ ជាភារៈរបស់តថាគត ។

បទថា **សមិតឹ** សេចក្តីថា ជនទាំងឡាយ កាលទៅកណ្តាលមហាជនក្នុងសមាគម មានឧទ្យាន និងទីលានកីឡាជាដើម ទឹមគោ ឬសេះដែលបង្ហឹកហើយប៉ុណ្ណោះ ចូលក្នុងយាម នាំទៅ ។

បទថា **រាជា** សេចក្តីថា សូម្បីព្រះរាជាកាលនឹងយាងទៅកាន់ទីបែបនោះឯង រមែងជិះសត្វពាហនៈដែលហ្វឹកហើយ ។

បទថា **មនុស្សេសុ** សេចក្តីថា ក្នុងមនុស្សទាំងឡាយដែលទូន្មានហើយ គឺមនុស្សដែលអស់ព្យសន៍ហើយ ដោយអរិយមគ្គ ៤ ដ៏ប្រសើរ ។

បទថា **យោតិវាក្យំ** សេចក្តីថា បុគ្គលណា អត់ធន់ គឺរមែងមិនតបត មិនភ្ញាក់ផ្អើលដល់ពាក្យល្មើសមានសភាពបែបនោះ ដែលបុគ្គលពោលទ្រគោះ បុគ្គលដែលទូន្មានហើយបែបនោះ ជាបុគ្គលប្រសើរ ។

សេះដែលកើតអំពីមេសេះ ដែលមានបាជាសត្វលា ឈ្មោះថា សេះអស្សតរ ។ បទថា **អាជានីយា** សេចក្តីថា សេះដែលអាចដឹងហេតុដែលនាយសារថីបង្ហឹក ឲ្យធ្វើ ។

សេះដែលកើតក្នុងដែនសិន្ធព ឈ្មោះថា សេះសិន្ធព ។ ដំរីធំដែលហៅថា កុញ្ជរ ឈ្មោះថា មហានាគ ។

បទថា **អត្តទន្តោ** ជាដើម សេចក្តីថា សេះអស្សតរក្តី សេះសិន្ធពក្តី ដំរីកុញ្ជរក្តី ទាំងនោះ ដែលហ្វឹកហើយ ជាសត្វប្រសើរ ដែលមិនទាន់បានបង្ហឹក មិនប្រសើរឡើយ តែបុគ្គលណា ឈ្មោះថា មានខ្លួនហ្វឹកហើយ គឺអស់ព្យសន៍ហើយ ព្រោះភាពដែលខ្លួនជាអ្នកទូន្មានដោយអរិយមគ្គ ៤ ។ បុគ្គលនេះ ប្រសើរជាងសត្វពាហនៈ មានសេះអស្សតរជាដើមនោះ គឺជាបុគ្គលក្រៃលែងជាងសត្វពាហនៈ មានសេះអស្សតរទាំងអស់នោះជាដើម ។

ក្នុងកាលចប់ទេសនា មហាជនទាំងអស់នោះ ដែលជាអ្នកទទួលស៊ីឈ្នួលជេរហើយ ឈរជេរក្នុងទីទាំងឡាយ មានផ្លូវបែកជា ៣ ជាដើម សម្រេចសោតាបត្តិផលហើយ ដូច្នេះឯង ។

## រឿងរបស់ព្រះសាស្តា ចប់

# រឿង ភិក្ខុធ្លាប់ជាហត្ថាចារ្យ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ដែលធ្លាប់ជាហត្ថាចារ្យ ត្រាស់ព្រះធម្មទេសនានេះថា **ន ហិ ឯតេហិ** ជាដើម ។

បានឮថា ថ្ងៃមួយ ភិក្ខុនោះឃើញហ្មដំរីដែលតាំងចិត្តថា អញបង្ហាត់ដំរីមួយ ហើយមិនអាចឲ្យដំរីសិក្សាហេតុដែលខ្លួនប្រាថ្នាបាន នៅក្បែរឆ្នេរស្ទឹងអចិរវតី ទើបភិក្ខុនោះហៅភិក្ខុទាំងឡាយ ដែលឈរជិតមកហើយ ពោលថា អាវុសោទាំងឡាយ បើហត្ថាចារ្យនេះ ចាក់ដំរីនេះក្នុងទីឈ្មោះនោះសោត គាត់គប្បីឲ្យដំរីសិក្សាហេតុនោះបានដោយរហ័ស ។ គាត់ស្តាប់ពាក្យរបស់ភិក្ខុនោះហើយ ទើបធ្វើយ៉ាងនោះ ក៏ហ្វឹកដំរីនោះឲ្យរៀបរយបាន ។ ទើបភិក្ខុទាំងនោះក្រាបទូលរឿងនោះដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា ម្នាលភិក្ខុបានឮថា អ្នកនិយាយយ៉ាងនេះពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ទើបទ្រង់តិះដៀលភិក្ខុនោះ ហើយត្រាស់ថា នែមោឃបុរស អ្នកត្រូវការអ្វីដោយយាន គឺដំរី ឬយានដទៃដែលបង្ហឹកហើយ ព្រោះ ឈ្មោះថាបុគ្គលដែលអាចទៅកាន់ទីដែលមិនធ្លាប់ទៅ ដោយយានទាំងនេះ មិនមាន តែបុគ្គលដែលទូន្មានខ្លួនល្អហើយ អាចទៅកាន់ទីមិនធ្លាប់ទៅបាន ព្រោះដូច្នោះ អ្នកគប្បីទូន្មានខ្លួនប៉ុណ្ណោះ អ្នកត្រូវការអ្វីដោយការទូន្មានសត្វពាហនៈទាំងនេះ ហើយត្រាស់ព្រះគាថានេះថា

**ន ហិ ឯតេហិ យានេហិ គច្ឆេយ្យ អគតំ ទិសំ**
**យថាត្តនា សុទន្តេន ទន្តោ ទន្តេន គច្ឆតិ ។**

បុគ្គលទូន្មានខ្លួន បានបទហើយ ទូន្មានខ្លួន ល្អហើយ ឈ្មោះថា ទូន្មានហើយ ទើបទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានទាំងឡាយនោះឡើយ ។

## សេចក្តីអធិប្បាយ

ព្រះគាថានោះ មានសេចក្តីថា បុគ្គលណាម្នាក់គប្បីទៅកាន់ទិស គឺព្រះនិព្វាន ដែលរាប់ថា មិនទាន់បានទៅ ព្រោះភាពជាទិសដែលខ្លួនមិនធ្លាប់ទៅ ដោយហោច ត្រឹមតែការយល់សប្តិ ដោយយានទាំងឡាយ មានដំរីជាដើមទាំងនេះបានឡើយ ដូចបុគ្គលទូន្មានខ្លួនហើយ គឺជាអ្នកអស់ព្យសន៍ មានបញ្ញាទៅកាន់ទិស ដែលមិនធ្លាប់ទៅ ដូច្នោះ គឺសម្រេចដល់ភូមិនៃលោកអ្នកដែលទូន្មានខ្លួនហើយ ដោយខ្លួនដែលទូន្មានហើយ ដោយការទូន្មានឥន្ទ្រិយក្នុងចំណែកខាងដើម ទូន្មានល្អហើយ ដោយអរិយមគ្គភាវនា ក្នុងចំណែកខាងក្រោយដូច្នោះក៏មិនមែន ព្រោះដូច្នោះ ការទូន្មានខ្លួនប៉ុណ្ណោះ ទើបប្រសើរសម្រាប់អ្នក ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង ភិក្ខុធ្លាប់ជាហត្ថាចារ្យ ចប់**

# រឿង កូនរបស់ព្រាហ្មណ៍ចាស់ជរា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធពួកបុត្ររបស់ព្រាហ្មណ៍ចាស់ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ធនបាលកោ** ជាដើម ។

បានឮថា ព្រាហ្មណ៍ម្នាក់នៅក្នុងក្រុងសាវត្ថី មានសម្បត្តិប្រមាណ ៨ សែន រៀបការឲ្យកូន ៤ នាក់ ចម្រើនវ័យហើយ បានឲ្យទ្រព្យ ៤ សែន ។ បន្ទាប់មក កាលព្រាហ្មណីធ្វើកាលកិរិយាទៅហើយ ទើបពួកកូនប្រឹក្សាព្រមគ្នាថា បើឪពុករបស់យើងនាំព្រាហ្មណីដទៃមកសោត ដោយអំណាចនៃបុត្រទាំងឡាយដែលកើតក្នុងផ្ទៃរបស់នាង ត្រកូលនឹងត្រូវទម្លាយ ណ្ហើយចុះ ពួកយើងនាំគ្នាសង្គ្រោះលោក ។ ពួកគេទំនុកបម្រុងព្រាហ្មណ៍ចាស់នោះ ដោយបច្ច័យ មានអាហារ គ្រឿងស្លៀកដណ្តប់ជាដើមដែលប្រណីត ធ្វើកិច្ច មានការគក់ប្រចាច់ដៃ និងជើងជាដើម កាលទំនុកបម្រុងហើយ ថ្ងៃមួយ កាលព្រាហ្មណ៍ចាស់នោះ ដេកលក់ពេលថ្ងៃហើយក្រោកឡើង ទើបប្រចាច់ដៃជើងបណ្តើរ ពោលដល់ទោសក្នុងឃរាវាសផ្សេងៗ ហើយអង្វរថា ពួកខ្ញុំនឹងទំនុកបម្រុងលោកឪពុកយ៉ាងនេះដរាបដល់អស់ជីវិត សូមពុកឲ្យនូវទ្រព្យដែលសេសសល់ដល់ពួកខ្ញុំចុះ ។ ព្រាហ្មណ៍ឲ្យទ្រព្យដល់បុត្រម្នាក់ ១ សែនទៀត ចែកគ្រឿងឧបភោគទាំងអស់ឲ្យជា ៤ ចំណែក ប្រគល់ឲ្យ បន្សល់ត្រឹមតែសំពត់ស្លៀកសំពត់ដណ្តប់របស់ខ្លួន ។ កូនច្បង ទំនុកបម្រុងព្រាហ្មណ៍នោះ ២-៣ ថ្ងៃ ។ ថ្ងៃមួយ កូនប្រសាស្រីឈរត្រង់មាត់ទ្វារ និយាយនឹងព្រាហ្មណ៍ចាស់នោះ ដែលងូតទឹកហើយដើរមកយ៉ាងនេះថា ទ្រព្យមួយរយ ឬមួយពាន់

ដែលលោកឪពុកឲ្យដល់កូនច្បង ក្រៃលែងជាងបុត្រទាំងឡាយមានឬ ឪពុកឲ្យទ្រព្យដល់បុត្រគ្រប់គ្នា ម្នាក់ ២ សែនមិនមែនឬ ហេតុអ្វី ទើបលោកឪពុកមិនស្គាល់ផ្លូវទៅផ្ទះរបស់កូនដ៏សេស ។

សូម្បីព្រាហ្មណ៍គំរាមស្រីនោះថា មេថោកទាប ហងចូរវិនាស ក្រោធខឹងហើយ បានទៅកាន់ផ្ទះរបស់បុត្រដទៃ លុះកន្លងទៅ ២-៣ ថ្ងៃ ត្រូវកូនប្រសាស្រីដទៃឲ្យចេញពីផ្ទះដោយឧបាយដូចគ្នានោះឯង បានទៅកាន់ផ្ទះកូនដទៃ កាលមិនបានការចូលទៅកាន់ផ្ទះណាមួយយ៉ាងនេះ ដោយប្រការនេះ ទើបបួសស្លៀកសពាក់សត្រាច់រកភិក្ខា ។ ពេលវេលាកន្លងទៅ គាត់ក៏ទ្រុឌទ្រោមព្រោះជរា មានសរីរៈសៅហ្មងព្រោះភោជនមិនល្អ ដេកលំបាក ត្រាច់រកភិក្ខាត្រឡប់មកដាក់ខ្នងលើដំណេក ឈានចុះកាន់និទ្រាហើយ ក្រោកឡើងអង្គុយមើលខ្លួនទើបមានសេចក្តីក្រវល់ក្រវាយរម្ងាប់ហើយ មិនឃើញទីពឹងរបស់ខ្លួនក្នុងកូនទាំងឡាយ គិតថា បានឮថា ព្រះសមណគោតមមានភក្ត្រមិនស្រពោន មានព្រះភក្ត្រីក មានពាក្យសម្តីពីរោះ ទ្រង់ឈ្លាសក្នុងការទទួល អញអាចទៅរកព្រះគោតមហើយ បាននូវការទទួល ។ គាត់រៀបចំស្លៀកសំពត់ដណ្តប់រៀបរយហើយ ចាប់ភាជន៍ភិក្ខា កាន់ឈើច្រត់ បានទៅកាន់សម្នាក់ព្រះសម្ពុទ្ធ ។

ពិតហើយ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ពោលពាក្យនេះថា គ្រានោះឯង ព្រាហ្មណមហាសាលម្នាក់ ជាអ្នកសៅហ្មង មានសំពត់ដណ្តប់ក៏សៅហ្មង ចូលទៅគាល់ព្រះសាស្តាដល់ទីដែលទ្រង់ប្រថាប់ ។

ព្រះសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈជាមួយព្រាហ្មណ៍ ដែលអង្គុយក្នុង

ចំណែកម្ខាងហើយ បានត្រាស់ពាក្យនេះថា ម្នាលព្រាហ្មណ៍ អ្វីហ្ន៎ ទើបលោកជាអ្នកសៅហ្មង មានសំពត់ដ៏សៅហ្មង ។

ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គមានបុត្រ ៤ នាក់ក្នុងលោកនេះ បុត្រទាំងនោះត្រូវភរិយាញុះញង់ ទើបបណ្តេញខ្ញុំព្រះអង្គចេញអំពីផ្ទះ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នេះ ចូរអ្នករៀនគាថាទាំងនេះ កាលពួកមហាជនប្រជុំគ្នាក្នុងទីប្រជុំ កាលកូនទាំងឡាយរបស់អ្នកអង្គុយហើយ ចូរពោលថា

ខ្ញុំត្រេកអរដោយបុត្រដែលកើតហើយណា នឹងប្រាថ្នាសេចក្តីចម្រើនដល់បុត្រណា បុត្រទាំងនោះ ត្រូវភរិយាញុះញង់ បៀតបៀនខ្ញុំ ដូចឆ្កែបៀតបៀនជ្រូក ដូច្នោះ ។ បានឮថា កូនទាំងនោះជាអសប្បុរស ជាអ្នកថោកទាប ហៅខ្ញុំថា ពុក ពុក ពួកកូនទាំងនោះ គឺអារក្សទឹក មកហើយដោយរូបរាងជាបុត្រ បោះបង់ខ្ញុំឲ្យដល់នូវសេចក្តីវិនាស បិតារបស់ជនពាលជាមនុស្សចាស់ត្រូវដើរសូមទានត្រង់ផ្ទះជនដទៃ ដូចសេះដែលចាស់ធ្វើការមិនបាន ត្រូវគេផ្តាច់អាហារដូច្នោះ បានឮថា ឈើច្រត់របស់ខ្ញុំគង់ប្រសើរជាង កូនទាំងឡាយដែលមិនស្តាប់បង្គាប់ នឹងប្រសើរដូចម្តេច ព្រោះឈើច្រត់ការពារគោកាចក៏បាន ការពារឆ្កែក៏បាន រាវក្នុងទីងងឹតក៏បាន ប្រើច្រត់ចុះទៅក្នុងទីជ្រៅក៏បាន ព្រោះអានុភាពនៃឈើច្រត់ មនុស្សចាស់ជរាដូចខ្ញុំដួលហើយ ក៏ច្រត់ក្រោកឡើងបាន ។

ព្រាហ្មណ៍រៀនគាថានោះ ក្នុងសម្នាក់ព្រះសាស្តាហើយ កាលពួកបុត្រ

ប្រដាប់តាក់តែងដោយគ្រឿងអលង្ការហើយ ចូលទៅកាន់ទីប្រជុំនោះ អង្គុយលើអាសនៈដែលគួរដល់តម្លៃច្រើន ក្នុងកណ្ដាលពួកព្រាហ្មណ៍ ក្នុងថ្ងៃប្រជុំនៃពួកព្រាហ្មណ៍ទាំងនោះ គាត់សម្រេចចិត្តថា កាលនេះជាកាលរបស់អញហើយ ចូលទៅកាន់កណ្ដាលទីប្រជុំ លើកដៃឡើងពោលថា អ្នកដ៏ចម្រើន ខ្ញុំបំណងនឹងពោលគាថាដល់អ្នកទាំងឡាយ អ្នកទាំងឡាយស្ដាប់ដែរឬទេ កាលព្រាហ្មណ៍ទាំងនោះពោលថា ពោលចុះព្រាហ្មណ៍ ពួកខ្ញុំនឹងស្ដាប់ បានឈរពោលគាថាហើយ ។

សម័យនោះ មនុស្សទាំងឡាយមានវត្តយ៉ាងនេះថា កូនណាប្រើប្រាស់ទ្រព្យដែលជារបស់មាតាបិតា តែមិនចិញ្ចឹមមាតាបិតា កូននោះត្រូវសម្លាប់ចោល ។ ព្រោះដូច្នោះ ទើបកូនរបស់ព្រាហ្មណ៍ទាំងនោះ ក្រាបចុះទៀបបាតជើងរបស់បិតា អង្វរថា បពិត្រលោកឪពុក សូមលោកឪពុកឲ្យជីវិតដល់ពួកខ្ញុំចុះ ។ ព្រោះភាពដែលហទយៈរបស់ឪពុកជាធម្មជាតទន់ ទើបពោលថា អ្នកដ៏ចម្រើនទាំងឡាយ អ្នកកុំឲ្យកូនទាំងឡាយរបស់ខ្ញុំវិនាសឡើយ ពួកគេនឹងចិញ្ចឹមខ្ញុំ ។

រំពេចនោះ ទើបមនុស្សទាំងឡាយពោលនឹងបុត្ររបស់ព្រាហ្មណ៍ថា អ្នកដ៏ចម្រើន តាំងអំពីថ្ងៃនេះទៅ បើពួកអ្នកមិនផ្គត់ផ្គង់បិតាឲ្យល្អសោត ពួកយើងនឹងសម្លាប់អ្នកចោល កូនទាំងនោះខ្លាចហើយ អញ្ជើញឪពុកឲ្យអង្គុយលើតាំងលើកឡើងទៅកាន់ផ្ទះដោយខ្លួនឯង លាបសរីរៈដោយប្រេង ដុសខាត់ឲ្យស្អាតប្រើវត្ថុមានក្លិនក្រអូបជាដើមលាបស្រលាបហើយ ឲ្យហៅព្រាហ្មណីទាំងឡាយ

មមកប្រាប់ថា តាំងអំពីថ្ងៃនេះទៅ នាងទាំងឡាយ ចូរចិញ្ចឹមបិតារបស់ពួកខ្ញុំឲ្យល្អ បើនាងទាំងឡាយដល់នូវសេចក្តីប្រមាទហើយសោត ពួកខ្ញុំនឹងតិះដៀលនាងទាំងឡាយ ហើយឲ្យបិតាបរិភោគភោជនដ៏ប្រណីត ។

ព្រាហ្មណ៍អាស្រ័យភោជនដែលល្អ ទីដេកដែលសប្បាយ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ក៏មានកម្លាំងឥន្ទ្រិយស្រស់ថ្លា សម្លឹងមើលអត្តភាពហើយត្រិះរិះថា សម្បត្តិនេះអញបានព្រោះអាស្រ័យព្រះគោតម កាន់យកសំពត់មួយគូ ដើម្បីប្រយោជន៍ជាបណ្ណាការ ទៅកាន់សម្នាក់របស់ព្រះដ៏មានព្រះភាគ មានបដិសណ្ឋារៈដែលទ្រង់ធ្វើហើយ អង្គុយក្នុងចំណែកម្ខាង ដាក់សំពត់ចុះទៀបបាទមូលរបស់ព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះថាជាព្រាហ្មណ៍ តែងស្វែងរកទ្រព្យ ដែលជាចំណែកនៃអាចារ្យដើម្បីអាចារ្យ សូមព្រះគោតមដែលជាអាចារ្យរបស់ខ្ញុំព្រះអង្គ ទទួលទ្រព្យជាចំណែកអាចារ្យ ។ ព្រះសាស្តា ទ្រង់ទទួលសំពត់គូនោះ ដើម្បីអនុគ្រោះដល់ព្រាហ្មណ៍ហើយ ទ្រង់ក៏សម្តែងធម៌ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍តាំងនៅក្នុងសរណៈហើយ ទើបក្រាបទូលយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គថ្វាយធុវកត្តពីរសម្រាប់អំពីធុវកត្ត ៤ សម្រាប់ ដែលកូនទាំងឡាយឲ្យដល់ខ្ញុំព្រះអង្គ ដល់ទ្រង់ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ថា សាធុព្រាហ្មណ៍ តែតថាគតទៅកាន់ទីដែលពេញចិត្តប៉ុណ្ណោះ ហើយទ្រង់បញ្ជូនព្រាហ្មណ៍ទៅ ។

ព្រាហ្មណ៍ទៅដល់ផ្ទះហើយ ប្រាប់កូនទាំងឡាយថា បាទាំងឡាយ ព្រះ

សមណគោតមជាសម្លាញ់របស់ឪពុក ចូរបាថ្វាយធុរកត្តពីរសម្រាប់ដល់ទ្រង់ បាទាំងឡាយកុំរំលង បើទ្រង់យាងមកដល់ កូនទាំងឡាយទទួលថា សាធុ ។

ស្អែកឡើង ព្រះសាស្តាយាងទៅបិណ្ឌបាត បានទៅដល់ទ្វារផ្ទះនៃកូនច្បងរបស់ព្រាហ្មណ៍ បុរសនោះឃើញព្រះសាស្តាហើយ ទទួលបាត្រ យាងព្រះដ៏មានព្រះភាគឲ្យចូលទៅកាន់ផ្ទះ និមន្តឲ្យប្រថាប់គង់លើបល្ល័ង្កដែលមានតម្លៃច្រើន ហើយបានថ្វាយភោជនដ៏ប្រណីត ។ ព្រះសាស្តា បានយាងទៅកាន់ផ្ទះរបស់កូនព្រាហ្មណ៍ទាំងអស់តាមលំដាប់ គឺស្អែកឡើង យាងទៅកាន់ផ្ទះរបស់បុត្រព្រាហ្មណ៍ក្រៅអំពីនេះ ស្អែកឡើង ក៏យាងទៅកាន់ផ្ទះរបស់បុត្រម្នាក់ទៀត កូនទាំងនោះ បានធ្វើសក្ការៈយ៉ាងនោះដូចគ្នា ។

ថ្ងៃមួយ កូនច្បង កាលមង្គលប្រាកដចំពោះហើយ ទើបពោលនឹងបិតាថា បពិត្រលោឪពុក ពួកខ្ញុំនឹងឲ្យមង្គលដល់អ្នកណា ព្រាហ្មណ៍ពោលថា ឪពុកមិនស្គាល់អ្នកដទៃ ព្រះសមណគោតម ជាសម្លាញ់របស់ឪពុកមិនមែនឬ កូនច្បងពោលថា បើដូច្នោះ សូមលោកឪពុកនិមន្តទ្រង់ មួយអន្លើដោយភិក្ខុ ៥០០ រូបដើម្បីឆាន់ក្នុងថ្ងៃស្អែក ។

ព្រាហ្មណ៍បានធ្វើយ៉ាងនោះ ស្អែកឡើង ព្រះសាស្តា មួយអន្លើដោយភិក្ខុសង្ឃ បានយាងទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ គាត់និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យគង់ក្នុងផ្ទះដែលលាបដោយគោម័យស្រស់ ប្រដាប់ដោយអលង្ការគ្រប់យ៉ាង ហើយអង្គាសដោយមធុបាយាស ដែលមានទឹកតិច និងដោយខាទនីយដ៏ប្រណីត ។

ក្នុងវេលាក្រោយនោះឯង បុត្រ ៤ នាក់របស់ព្រាហ្មណ៍ អង្គុយក្នុងសម្នាក់របស់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គទាំងឡាយផ្គត់ផ្គង់បិតារបស់ខ្ញុំព្រះអង្គ មិនប្រមាទ សូមទ្រង់ទតអត្តភាពរបស់លោកចុះ ។

ព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយធ្វើកម្មស្អាតហើយ ឈ្មោះថា ការចិញ្ចឹមមាតាបិតា បុរាណបណ្ឌិតទាំងឡាយធ្លាប់ប្រព្រឹត្តមកហើយដូចគ្នា ហើយត្រាស់មាតុបោសកនាគជាតក[១] ក្នុងឯកាទសកនិបាត ដោយពិស្តាថា ដើមពោនស្វាផង ដើមខ្ទឹងគន់ផង ... ព្រោះតែដំរីនោះមិននៅ ដូច្នេះជាដើម ហើយបានភាសិតព្រះគាថានេះថា

**ធនបាលកោ នាម កុញ្ជរោ កដុកប្បភេទនោ ទុន្និវារយោ**
**ពទ្ធោ កពឡំ ន ភុញ្ជតិ សុមរតិ នាគវនស្ស កុញ្ជរោ ។**

ដំរីឈ្មោះធនបាល ជាសត្វចុះប្រេង ក្លៀវក្លា នាយហត្ថាចារ្យឃាត់បាន ដោយលំបាក បើនាយហត្ថាចារ្យចងភ្ជាប់មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃខ្ទឹង ដែលដំរីនោះធ្លាប់នៅ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ធនបាលកោ នាម** នោះ ជាឈ្មោះរបស់ដំរីដែលព្រះបាទកាសិករាជ ទ្រង់បញ្ជូននាយហត្ថាចារ្យទៅចាប់ក្នុងនាគវនដែលជាទីត្រេកអរក្នុងកាលនោះ ។

បទថា **កដុកប្បភេទនោ** សេចក្តីថា ចុះប្រេងខ្លាំង ។ ដែលពិត ក្នុង

---

១- បិដកខ្មែរជាមាតុបោសកជាតក ។

កាលដែលចុះប្រេងរបស់ដំរីទាំងឡាយ គុម្ពត្រចៀកទាំងពីររមែងរីក តាមប្រក្រតីក្នុងកាលនោះ ដំរីទាំងឡាយរមែងមិននាំនូវកង្វេរ ជន្ទញ ឬថ្មោង រមែងជាសត្វកាច តែដំរីធនបាលកៈនោះកាចស្រោប់នោះឯង ព្រោះដូច្នោះ ទើបព្រះសាស្ដាត្រាស់ថា **កដុកប្បភេទនោ ទុន្និវារយោ ។**

បាទព្រះគាថាថា **ពទ្ធោ កពឡំ ន ភុញ្ជតិ** សេចក្ដីថា ដំរីធនបាលកៈនោះ មិនបានដោះត្រដោក តែត្រូវគេនាំទៅកាន់រោងដំរីឲ្យបាំងដោយវាំងននដ៏វិចិត្រហើយ បញ្ឈរត្រង់ផែនដី ដែលប្រោះព្រំដោយគ្រឿងក្រអូប មានពិដានវិចិត្រខាងលើ ដែលព្រះរាជាទំនុកបម្រុងដោយភោជនមានរសដ៏ប្រសើរផ្សេងៗ គួរដល់ព្រះរាជា ក៏មិនបានត្រេកអរក្នុងការបរិភោគ ។ ពាក្យថា **ពទ្ធោ កពឡំ ន ភុញ្ជតិ** ព្រះសាស្ដាត្រាស់សំដៅដល់អាការៈត្រឹមតែដំរី ត្រូវបញ្ចូលទៅកាន់រោងដំរី ។

ពីរបទថា **សុមរតិ នាគវនស្ស** សេចក្ដីថា ដំរីធនបាលកៈនោះរឭកដល់នាគវន គឺព្រៃខ្លឹងដែលជាលំនៅគួរត្រេកអរ ប្រមាណមិនបាន មេរបស់ដំរីនោះជាសត្វដល់នូវទុក្ខ ព្រោះព្រាត់អំពីកូនក្នុងព្រៃ ដំរីនោះបំពេញមាតា-បិតុប្បដ្ឋានធម៌នោះឯងត្រិះរិះថា ប្រយោជន៍អ្វីរបស់អញដោយភោជននេះ រឭកដល់មាតាបិតុប្បដ្ឋានធម៌ ដែលប្រកបដោយធម៌ប៉ុណ្ណោះ ដំរីនោះនៅក្នុងនាគវននោះឯង អាចបំពេញមាតាបិតុប្បដ្ឋានធម៌នោះបាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **សុមរតិ នាគវនស្ស កុញ្ជរោ ។**

កាលព្រះសាស្ដា ទ្រង់នាំបុព្វចរិយារបស់ព្រះអង្គមកត្រាស់នោះឯង បុត្រ

មរបស់ព្រាហ្មណ៍ទាំងអស់ ញ៉ាំងអស្សុធារៈឲ្យហូរហើយ មានហទយៈទន់ភ្លន់ ផ្ទៀងនូវសោតៈស្តាប់ហើយ ។ គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបដល់ធម៌ជាទីសប្បាយរបស់ពួកកូនទាំងនោះហើយ ទើបទ្រង់សម្តែងធម៌ប្រកាសសច្ចៈទាំងឡាយ ។ ក្នុងកាលចប់ទេសនា ព្រាហ្មណ៍ បុត្រ និងកូនប្រសាទាំងឡាយ តាំងនៅក្នុងសោតាបត្តិផលហើយ ដូច្នេះឯង ។៚

**រឿង កូនរបស់ព្រាហ្មណ៍ចាស់ជរា ចប់**

# រឿង ព្រះបាទបសេនទិកោសល

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទបសេនទិកោសល ត្រាស់ព្រះធម្មទេសនានេះថា **មិទ្ធី យទា** ជាដើម ។

សេចក្តីពិស្តារ សម័យមួយ ព្រះរាជាសោយព្រះស្ងោយ នៃអង្ករមួយនាឡិជាមួយសូបព្យញ្ជនៈ សមគួរដល់បាយនោះ ។ ថ្ងៃមួយ ព្រះរាជាសោយព្រះក្រយាហារព្រឹកហើយ ទ្រង់មិនទាន់បន្ទោបង់សេចក្តីស្រវឹងក្នុងភត្តបានឡើយ បានយាងទៅកាន់សម្នាក់របស់ព្រះសាស្តា មានព្រះរូបលំបាក បម្រះទៅខាងនេះ និងខាងនោះ ត្រូវងងុយគ្របសង្កត់ មិនអាចផ្ទំត្រង់ៗ បាន ទើបប្រថាប់គង់ក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ ទ្រង់មិនទាន់

បានសម្រាកឡើយ យាងមកទេដឹង ព្រះរាជាត្រាស់ថា ពិតហើយ ព្រះអង្គ តាំងអំពីបរិភោគហើយ ខ្ញុំព្រះអង្គមានទុក្ខច្រើន ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងព្រះរាជាថា មហាបពិត្រ បុគ្គល បរិភោគច្រើន រមែងមានទុក្ខយ៉ាងនេះ ទើបត្រាស់ព្រះគាថានេះថា

**មិទ្ធី យទា ហោតិ មហគ្ឃសោ ច និទ្ទាយិតា សម្បរិវត្តសាយី**
**មហាវរាហោវ និវាបបុដ្ឋោ បុនប្បុនំ គព្ភមុបេតិ មន្ទោ ។**

កាលណា បុគ្គលអ្នកមានសេចក្ដីងោកងុយផង អ្នកបរិភោគភោជន មានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះនទៀលផង ដូចជ្រូកស្រុកដែលបុគ្គលចិញ្ចឹមដោយសូករភត្ត កាលនោះ បុគ្គល នោះ ជាមនុស្សខ្លៅ រមែងចូលទៅកាន់គភ៌រឿយៗ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **មិទ្ធី** សេចក្ដីថា ដែលការរួញរា និងការ ងោកងុយគ្របសង្កត់ ។

បទថា **មហគ្ឃសោ** សេចក្ដីថា អ្នកបរិភោគច្រើន ដូចអាហរហត្ថក-ព្រាហ្មណ៍ អលង្សាដកព្រាហ្មណ៍ តត្ថវដ្ដកព្រាហ្មណ៍ កាកមាសកព្រាហ្មណ៍ និងភុត្តវម្មិកព្រាហ្មណ៍ណាម្នាក់ ។

បទថា **និវាបបុដ្ឋោ** សេចក្ដីថា ត្រូវទំនុកបម្រុងហើយដោយសូករភត្ត មានកុណ្ឌកជាដើម ពិតហើយ ជ្រូកស្រុកគេចិញ្ចឹមតាំងពីនៅតូច ក្នុងពេល មានសរីរៈធាត់ មិនបានចេញអំពីផ្ទះទៅខាងក្រៅ ធ្វេធ្វាទៅមកក្នុងទីផ្សេងៗ

មានក្រោមគ្រែជាដើម ហើយរមែងដេកដកដង្ហើមយូរៗ ប៉ុណ្ណោះ ។ លោក អធិប្បាយថា បុគ្គលមានការសោកងុយ ជាអ្នកបរិភោគច្រើន កាលមិនអាច ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយឥរិយាបថដទៃ ច្រើនដោយការដេកលក់ បម្រះនទៀលទៅមក តាមប្រក្រតី ដូចជ្រូកធំដែលផ្តល់ដោយចំណី ដូច្នោះ ក្នុងខណៈណា ខណៈនោះ បុគ្គលនោះ មិនអាចមនសិការត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តាបាន ព្រោះមិនមនសិការត្រៃលក្ខណ៍ទាំងនោះ ទើបឈ្មោះថា មានបញ្ញាទន់ខ្សោយ តែងចូលបន្ទប់ គឺមិនផុតអំពីការនៅក្នុងបន្ទប់ ។

ក្នុងកាលចប់ទេសនា ព្រះសាស្តាត្រាស់ព្រះគាថានេះ ដោយឧបការៈ ដល់ព្រះរាជាថា

បុគ្គលមានសតិសព្វកាល ស្គាល់ប្រមាណក្នុងភោជនដែលបានហើយ នោះ រមែងមិនមានរោគ ភ័យ និងអាពាធ មិនចាស់មុនអាយុ មានអាយុ យឺនយូរ ដូច្នេះហើយ ឲ្យឧត្តរមាណពរៀន ហើយទ្រង់ឲ្យឧបាយថា អ្នកគប្បី ពោលគាថានេះ ក្នុងកាលដែលព្រះរាជាសោយ នឹងគប្បីឲ្យព្រះរាជាទ្រង់បន្ថយ ភោជន ដោយឧបាយនេះ ហើយបានធ្វើយ៉ាងនោះ ។

សម័យក្រោយមក ព្រះរាជាទ្រង់ស្រស់បស់ មានព្រះកាយស្រោល ទ្រង់ ដល់នូវភាពសុខស្រួល ព្រោះទ្រង់មានព្រះក្រយាហារមួយនាឡិយ៉ាងក្រៃលែង ទ្រង់មានសេចក្តីស្និទ្ធស្នាល កើតឡើងក្នុងព្រះសាស្តាហើយ ទ្រង់ឲ្យអសទិស- ទានប្រព្រឹត្តទៅ ៧ ថ្ងៃ ។ ព្រោះទ្រង់អនុមោទនាទាន មហាជនប្រជុំគ្នាក្នុងទី នោះ សម្រេចគុណវិសេសធំហើយ ដូច្នេះឯង ។៚

# រឿង សានុសាមណេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាមណេរឈ្មោះ សានុ ត្រាស់ព្រះធម្មទេសនានេះថា **ឥធំ បុរេ** ជាដើម ។

បានឮថា សាមណេរនោះជាបុត្រទោលរបស់ឧបាសិកាម្នាក់ ។ គ្រានោះ ឧបាសិកាឲ្យលោកបព្វជ្ជាក្នុងកាលដែលនៅជាកុមារនោះឯង ។ តាំងអំពីកាលដែលបព្វជ្ជាហើយ លោកជាអ្នកមានសីល សម្បូរដោយវត្ត បានធ្វើវត្តដល់អាចារ្យ ឧបជ្ឈាយ៍ និងអាគន្តុកភិក្ខុទាំងឡាយនោះឯង អស់កាល ៨ ថ្ងៃក្នុងមួយខែ លោកក្រោកឡើងអំពីព្រឹក ចូលទៅតម្កល់ទឹកក្នុងរោងទឹក បោសរោងធម្មស្សវនៈ អុជប្រទីប ប្រកាសធម្មស្សវនៈដោយសំឡេងដ៏ពីរោះ ភិក្ខុទាំងឡាយជ្រាបកម្លាំងរបស់លោកហើយ តែងនិមន្តថា ចូរលោកពោលបទភាណចុះ ។ លោកមិនធ្វើការរាវែកអ្វីឡើយ ដោយពោលថា ខ្យល់សៀតចាក់ដោតហទយៈរបស់ខ្ញុំ ឬរោគក្អកបៀតបៀនខ្ញុំ ឡើងកាន់ធម្មាសនៈពោលបទភាណ ដូចធ្វើឲ្យទឹកក្នុងអាកាសធ្លាក់ចុះ កាលនឹងចុះ រមែងពោលថា ខ្ញុំឲ្យចំណែកបុណ្យ ព្រោះការពោលនេះដល់មាតា និងបិតារបស់ខ្ញុំ ។ មនុស្សទាំងឡាយមិនជ្រាបភាពដែលលោកឲ្យចំណែកបុណ្យដល់មាតាបិតាឡើយ ។

មាតារបស់លោក កើតជាយក្ខិនីក្នុងអត្តភាពជាលំដាប់ នាងមកជាមួយទេវតាទាំងឡាយស្តាប់ធម៌ហើយ កាលអនុមោទនាចំណែកបុណ្យដែលសាមណេរឲ្យ តែងពោលថា ខ្ញុំសូមអនុមោទនា ។ ធម្មតាភិក្ខុទាំងឡាយ ដែលសម្បូរដោយសីល រមែងជាទីស្រឡាញ់របស់លោក ព្រមទាំងទេវលោក ព្រោះដូច្នោះ

ពួកទេវតាដែលមានការខ្មាស មានការគោរពក្នុងសាមណេរ រមែងសម្គាល់លោកដូចមហាព្រហ្ម និងគំនរភ្លើង ។ ហើយរមែងឃើញយក្ខិនីនោះថា គួរគោរព ព្រោះគោរពក្នុងសាមណេរ ក្នុងសម័យទាំងឡាយ មានសម័យស្តាប់ធម៌ និងសម័យយក្ខសន្និបាតជាដើម អមនុស្សទាំងឡាយរមែងឲ្យអាសនៈល្អ ទឹកល្អ អាហារល្អដល់យក្ខិនី ដោយគិតថា យក្ខិនីនេះ ជាម្តាយរបស់សានុសាមណេរ យក្សទាំងឡាយដែលមានសក្តិធំ ឃើញយក្ខិនីហើយ មែងចៀសផ្លូវ រមែងក្រោកឡើងចាកអាសនៈ ។

កាលសាមណេរនោះដល់នូវសេចក្តីចម្រើន មានឥន្ទ្រិយចាស់ក្លា ត្រូវសេចក្តីមិនត្រេកអរបៀតបៀន មិនអាចបន្ទោបង់ការមិនត្រេកអរបាន ទុកសក់ និងក្រចកវែង មានសំពត់ស្លៀក និងសំពត់ដណ្តប់រយីករយាក មិនប្រាប់ឧបាសិកាឃើញបុត្រហើយ ថ្វាយបង្គំ ពោលថា នែបា ពីមុនបាមកក្នុងទីមួយអន្លើដោយអាចារ្យ និងឧបជ្ឈាយ៍ ឬមួយអន្លើដោយភិក្ខុកំលោះនិងសាមណេរ ហេតុអ្វីក្នុងថ្ងៃនេះ ទើបបាមកមួយអង្គឯង លោកប្រាប់ភាពដែលលោកអផ្សុកដល់មាតាហើយ ។ ឧបាសិកាជាអ្នកមានសទ្ធា បង្ហាញទោសឃរាវាសដោយប្រការផ្សេងៗ ដាស់តឿនកូនក៏មិនអាចឲ្យយល់ព្រមបាន ក៏មិនអាចស្រោចស្រង់បានដោយគិតថា បើដូច្នោះ លោកគប្បីកំណត់បានតាមធម្មតារបស់ខ្លួនហើយពោលថា នែបា ចូរបាបន្អង់រង់ចាំខ្ញុំរៀបចំបបរ និងកត្តដើម្បីបាសិន ខ្ញុំនឹងនាំសំពត់ដែលពេញចិត្តមកប្រគេនដល់បាដែលឆាន់បបរ ធ្វើកត្តកិច្ចហើយបានតាក់តែងអាសនៈប្រគេន សាមណេរគង់ហើយ ។ ឧបាសិកាចាត់ចែងបបរ

និងរបស់ទំពាមួយរំពេចប៉ុណ្ណោះ បានប្រគេនហើយ ។ គ្រានោះ ឧបាសិកា គិតថា អញនឹងចាត់ចែងភត្ត អង្គុយក្នុងទីមិនឆ្ងាយលាងអង្ករ ។

សម័យនោះ យក្ខិនីពិចារណាថា សាមណេរទៅទីណាហ្ន៎ លោកបាន ភិក្ខា ឬមិនទាន់បាន ជ្រាបភាពដែលលោកគង់ហើយ ដោយភាពជាអ្នក ប្រាថ្នានឹងសឹក ទើបគិតថា លោកកុំញុំាងការខ្មាសឲ្យកើតឡើងដល់អញក្នុង វាងទេវតាទាំងឡាយឡើយ អញនឹងទៅធ្វើអន្តរាយក្នុងការសឹករបស់លោក ដូច្នេះហើយ ទើបមកចូលសណ្ឋិតក្នុងសរីរៈរបស់សាមណេរនោះ កាច់កឲ្យ អោនចុះលើផែនដី មានភ្នែកទាំងពីរលៀន មានទឹកមាត់ហូរ បម្រះនទៀល លើផែនដី ឧបាសិកាឃើញការចម្លែករបស់បុត្រ ប្រញាប់មកត្រកងបុត្រ ហើយឲ្យសិងលើភ្លៅ អ្នកស្រុកទាំងមូល នាំគ្នាមកធ្វើការបួងសួង មាន ពលីកម្មជាដើម ។ ឧបាសិកាខ្សឹកខ្សួល បានពោលគាថានេះថា

ខ្ញុំបានឮព្រះអរហន្តទាំងឡាយថា បុគ្គលទាំងឡាយណា រក្សា ឧបោសថប្រកបដោយអង្គ ៨ ក្នុងថ្ងៃទី ១៤ ថ្ងៃទី ១៥ និង ថ្ងៃទី ៨ នៃបក្ស ទាំងបាដិហារិកបក្ខផង ឈ្មោះថា ប្រព្រឹត្ត ព្រហ្មចរិយៈ ពួកយក្ខមិនយាយី បុគ្គលនោះឡើយ ឥឡូវថ្ងៃនេះ ខ្ញុំឯងឃើញពួកយក្ខយាយីសានុសាមណេរ ។

យក្ខិនីស្តាប់ពាក្យរបស់ឧបាសិកាហើយពោលថា

នាងបានឮពាក្យព្រះអរហន្តទាំងឡាយ ដោយប្រពៃថា បុគ្គល ទាំងឡាយណា រក្សាឧបោសថ ប្រកបដោយអង្គ ៨ ក្នុងថ្ងៃទី

១៤ ថ្ងៃទី ១៥ និងថ្ងៃទី ៨ នៃបក្ស ទាំងបាដិហារិកបក្ខផង ឈ្មោះថា ប្រព្រឹត្តព្រហ្មចរិយៈ ពួកយក្ខមិនយាយីបុគ្គលទាំងនោះទេ នាងគប្បីនិយាយប្រាប់សានុសាមណេរ ដែលភ្ញាក់ឡើងថា នេះជាពាក្យរបស់ពួកយក្ខ ( ប្រាប់ ) ថា លោកកុំធ្វើអំពើអាក្រក់ក្នុងទីចំពោះមុខ ឬទីកំបាំងនោះឡើយ បើលោកនឹងធ្វើ ឬកំពុងធ្វើ នូវអំពើលាមក លោកទុកជាហោះរត់ទៅ ក៏មិនរួចអំពីសេចក្តីទុក្ខដែរ ។

យក្ខិនីនោះពោលថា ការរួចផុតមិនមានដល់បុគ្គលដែលធ្វើបាបកម្មយ៉ាងនេះហើយ ហោះគេចទៅដូចបក្សី រួចក៏ដោះលែងសាមណេរ ។

សាមណេរនោះបើកភ្នែកឡើង ឃើញញោមស្រីកំពុងរំសាយសក់ទ្រហោយំ និងឃើញអ្នកស្រុកប្រជុំគ្នាហើយ មិនជ្រាបភាពដែលខ្លួនត្រូវយក្សចូលសណ្ឋិត ទើបនឹកសង្ស័យថា មុននេះអញកំពុងអង្គុយលើតាំង មាតារបស់អញលាងអង្គុយក្នុងទីមិនឆ្ងាយ តែឥឡូវនេះ អញបែរជាដេកលើផែនដី តើមានរឿងអ្វីហ្ន៎ កំពុងសិងនោះឯង ពោលនឹងមាតាថា

ញោម ពួកជនតែងយំរកបុគ្គល ដែលស្លាប់បាត់ទៅហើយ ឬបុគ្គលដែលរស់នៅ តែគេមិនឃើញញោម ញោមឃើញអាត្មានៅរស់នៅឡើយ ញោម ហេតុអ្វីក៏ញោមយំរកអាត្មា ។

គ្រានោះ មាតាសម្តែងទោសក្នុងការមកដើម្បីសឹក របស់បុគ្គលអ្នកលះវត្ថុកាម និងកិលេសកាមបួសហើយដល់លោក ទើបពោលថា

លោកកូន ជនទាំងឡាយតែងយំរក បុគ្គលដែលស្លាប់បាត់ទៅហើយ ឬបុគ្គលដែលរស់នៅ តែគេមិនឃើញ ម្យ៉ាងទៀត បុគ្គលណា លះបង់កាមទាំងឡាយហើយ បែរជាត្រឡប់មករកកាមក្នុងលោកនេះវិញ លោកកូន សូម្បីតែបុគ្គលនោះ ក៏ពួកជនយំរកដែរ ព្រោះថា បុគ្គលនោះ រស់នៅមែន តែទុកដូចជាមនុស្សស្លាប់ហើយ លោកកូន ខ្ញុំបានស្រង់លោកអំពីផេះក្តៅ គឺឃរាវាសហើយ លោកចង់ធ្លាក់ទៅក្នុងផេះក្តៅវិញ លោកកូន ខ្ញុំបានស្រង់ដល់លោក ខ្ញុំនឹងប្រាប់ដល់អ្នកណាកើត លោក ( ចេញអំពីឃរាវាស ទៅបួសហើយ ) ដូចជាគ្រឿងភណ្ឌៈ ដែលគេនាំចេញអំពីផ្ទះភ្លើងឆេះ ហើយចង់ឆេះ ( ក្នុងឃរាវាស ) វិញ ។

កាលពោលយ៉ាងនោះហើយ ដើម្បីសម្តែងទោសក្នុងការគ្រប់គ្រងផ្ទះ ធ្វើការគ្រប់គ្រងផ្ទះឲ្យដូចគ្មានទីងរងើកភ្លើង និងឲ្យដូចជាជ្រោះ ទើបពោលទៀតថា

> លោកកូន ខ្ញុំបានស្រង់លោក អំពីផេះក្តៅ គឺឃរាវាសហើយ លោកចង់ធ្លាក់ទៅក្នុងផេះក្តៅវិញ លោកកូន ខ្ញុំបានស្រង់លោកអំពីរណ្តៅហើយ លោកចង់ធ្លាក់ទៅក្នុងរណ្តៅវិញ ។

បន្ទាប់មក កាលសម្តែងថា សូមលោកកូនមានសេចក្តីចម្រើនចុះ ខ្ញុំនឹងដាក់ទុក្ខដល់បុគ្គលណា នឹងឲ្យបុគ្គលណា ជួយគិតសេចក្តីនេះថា កូនតូចរបស់ខ្ញុំនេះ កាលខ្ញុំនាំចេញទៅបួសក្នុងព្រះពុទ្ធសាសនា ហាក់បីដូចភណ្ឌៈដែលត្រូវនាំចេញចាកផ្ទះ ដែលកំពុងត្រូវភ្លើងឆេះហើយ នៅប្រាថ្នាវិលមកក្តៅ

ក្នុងឃរាវាសទៀត សូមអ្នកទាំងឡាយជួយជាស់តឿន ជួយការពារដល់ខ្ញុំផង ចុះ ហើយពោលគាថានេះ នឹងសានុសាមណេរនោះថា

លោកចូរស្ទុះចេញទៅ សេចក្តីចម្រើន ចូរមានដល់លោក ខ្ញុំនឹងប្រាប់ដល់អ្នកណាកើត លោក ( ចេញអំពីឃរាវាសទៅបួសហើយ ) ដូចជាគ្រឿងកណ្ឌ: ដែលគេនាំចេញអំពីផ្ទះភ្លើងឆេះ ហើយចង់ឆេះ ( ក្នុងឃរាវាស ) វិញ ។

សានុសាមណេរនោះ កំណត់បានក្នុងកាលមាតាកំពុងពោល ទើបពោលថា ខ្ញុំមិនត្រូវការដោយភាពជាគ្រហស្ថទេ ។ គ្រានោះ មាតារបស់លោកពោលថា សាធុ ពេញចិត្តហើយ ឲ្យបរិភោគភោជនដ៏ប្រណីត សួរថា នែបារដូវវស្សាប៉ុន្មានហើយ ជ្រាបភាពដែលលោកមានរដូវ មានវស្សាគ្រប់ហើយ ក៏រៀបចំត្រៃចីវរឲ្យលោក មានបាត្រ ចីវរគ្រប់ បានឧបសម្បទាហើយ ។

ព្រះសាស្តា កាលទ្រង់ញុំាងឧស្សាហ៍ ក្នុងការសង្កត់ចិត្តឲ្យកើតឡើងដល់បុគ្គលដែលឧបសម្បទាហើយថ្មីៗ ទើបត្រាស់ថា ធម្មតាចិត្តនេះត្រាច់ទៅក្នុងអារម្មណ៍ផ្សេងៗ អស់កាលយូរ ឈ្មោះថា សួស្តី មិនមានដល់បុគ្គលដែលមិនសង្កត់ចិត្តនោះបាន ព្រោះដូច្នោះ ទើបគួរធ្វើសេចក្តីព្យាយាមក្នុងការសង្កត់ចិត្ត ដូចហត្ថាចារ្យធ្វើសេចក្តីព្យាយាម ក្នុងការសង្កត់សង្កិនដំរីចុះប្រេងដោយកង្វេរ ដូច្នោះហើយ ត្រាស់ព្រះគាថានេះថា

**ឥទំ បុរេ ចិត្តមចារិ ចារិកំ យេនិច្ឆកំ យត្ថកាមំ យថាសុខំ**
**តទជ្ជហំ និគ្គហេស្សាមិ យោនិសោ ហត្ថិប្បភិន្នំ វិយ អំកុសគ្គហោ ។**

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមអាការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្ដីសប្បាយ ក្នុងថ្ងៃនេះ អញនឹងសង្កត់សង្កិនចិត្តនោះដោយឧបាយ ដូចហ្មដំរីកាន់កង្វេរសង្កត់សង្កិនដំរីចុះប្រេង ដូច្នោះដែរ ។

## សេចក្ដីអធិប្បាយ

អត្ថនៃព្រះគាថានោះថា មុនអំពីនេះ ឈ្មោះថា ចិត្តនេះ ត្រាច់ចារិកទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើមអស់កាលយូរ ឈ្មោះថា តាមអាការដែលប្រាថ្នាដោយអំណាចនៃកិលេសទាំងឡាយ មានរាគៈជាដើម ដែលជាហេតុប្រាថ្នា ឈ្មោះថា ត្រាច់ទៅតាមអារម្មណ៍ដែលជាទីប្រាថ្នា ដោយអំណាចនៃអារម្មណ៍ដែលជាទីកើតសេចក្ដីប្រាថ្នានៃចិត្តនោះឯង ឈ្មោះថា តាមសេចក្ដីសប្បាយ ព្រោះកាលចិត្តត្រាច់ទៅដោយអាការណា ទើបសេចក្ដីសុខមាន ក៏ត្រាច់ទៅដោយអាការនោះឯង ថ្ងៃនេះ អញនឹងសង្កត់សង្កិនចិត្តដោយយោនិសោមនសិការ គឺមិនព្រមឲ្យចិត្តឈានកន្លងបាន ដូចបុរសជាក់កង្វេរក្នុងដៃ បុគ្គលឈ្លាស គឺហត្ថាចារ្យ សង្កត់សង្កិនដំរីចុះប្រេង គឺចុះប្រេងដោយកង្វេរនោះ ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យមានដល់ទេវតាជាច្រើន ដែលចូលទៅស្ដាប់ធម៌ជាមួយសានុ ព្រះថេរៈនោះ រៀនពុទ្ធវចនៈ គឺព្រះត្រៃបិដកហើយបានជាធម្មកថិកដ៏ជំនាញ តម្កល់ជីវិតនៅអស់ ១២០ ឆ្នាំ ញុំាងជម្ពូទ្វីបទាំងមូលឲ្យល្បីខ្ទរខ្ទារ ហើយបរិនិព្វាន ដូច្នេះ ។៚

**រឿង សានុសាមណេរ ចប់**

# រឿង ដំរីឈ្មោះ បាវេរកៈ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធដំរីឈ្មោះបាវេរកៈ របស់ព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះថា **អប្បមាទរតា** ជាដើម ។

បានឮថា ដំរីនោះ កាលនៅក្មេងជាសត្វមានកម្លាំងច្រើន ដោយសម័យដទៃទៀត ត្រូវកម្លាំងខ្យល់កើតឡើង ព្រោះជរាបៀតបៀន ចុះទៅកាន់ស្រះធំមួយ ជាប់ក្នុងភក់ហើយមិនអាចឡើងបាន មហាជនឃើញដំរីនោះហើយ ទើបសន្ទនាគ្នាថា ដំរីមានសភាពបែបនេះ គង់ដល់នូវទុព្វលភាពបែបនេះ ។ ព្រះរាជាទ្រង់ស្តាប់រឿងនោះហើយ ទ្រង់បង្គាប់នាយហត្ថាចារ្យថា ចូរអ្នកលើកដំរីនោះឡើងអំពីភក់ បុរសនោះទៅហើយ សម្តែងការច្បាំងក្នុងទីនោះ ឲ្យវាយស្គរជុំទិសឡើង ។ ដំរីជាសត្វមានពូជនៃមានះ ក្រោកឡើងដោយរហ័ស តាំងនៅលើគោកបាន ។ ភិក្ខុទាំងឡាយឃើញហេតុនោះហើយ ទើបក្រាបទូលដល់ព្រះសាស្តាៗ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដំរីនោះរើខ្លួនឡើងចាកភក់ គឺភក់តាមប្រក្រតី ចំណែកអ្នកទាំងឡាយ លិចចុះហើយក្នុងភក់ គឺកិលេស ព្រោះដូច្នោះ អ្នកទាំងឡាយ ចូរផ្តើមសេចក្តីព្យាយាម ដោយឧបាយហើយ រើខ្លួនឡើងចាកភក់ គឺកិលេសនោះចុះ ហើយត្រាស់ព្រះគាថានេះថា

**អប្បមាទរតា ហោថ សចិត្តមនុរក្ខថ**
**ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។**

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្តីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួន ចូររើខ្លួនចេញចាកភក់ គឺកិលេសដែលធ្ងន់

បានដោយកម្រ ដូចដំរីជាប់នៅក្នុងភក់ រើខ្លួនឲ្យរួចបាន ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមាទរតា** សេចក្តីថា អ្នកទាំងឡាយ ចូរត្រេកអរក្នុងការមិននៅប្រាសចាកសតិ ។

បទថា **សចិត្តំ** សេចក្តីថា ចូររក្សាចិត្តរបស់ខ្លួនក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ដោយអាការដែលចិត្តធ្វើនូវការឈានកន្លងមិនបាន ។

បទថា **សន្នោ** សេចក្តីថា ដំរីដែលលិចចុះទៅហើយក្នុងភក់នោះ ធ្វើនូវសេចក្តីព្យាយាមដោយជើងមុខ និងជើងក្រោយ ដកខ្លួនឡើងចាកភក់ តាំងនៅលើគោកបាន យ៉ាងណា អ្នកទាំងឡាយ ក៏ចូររើខ្លួនឡើងចាកភក់ គឺកិលេស គឺញុំាងខ្លួនឲ្យតាំងនៅលើគោក គឺព្រះនិព្វានដូច្នោះចុះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ភិក្ខុនោះ តាំងនៅហើយក្នុងអរហត្តផល ដូច្នេះឯង ។៕

**រឿងដំរីឈ្មោះបាវេរកៈ ចប់**

# រឿង សម្ពហុលភិក្ខុ

## លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យព្រៃឈ្មោះបាលិលេយ្យកៈ ប្រថាប់នៅក្នុងជងព្រៃឈ្មោះរក្ខិតៈ ទ្រង់ប្រារព្ធភិក្ខុជាច្រើន ត្រាស់ព្រះធម្មទេសនានេះថា **សចេ លភេថ** ជាដើម ។

រឿងមកក្នុងអដ្ឋកថានៃព្រះគាថាថា **បរេ ច ន វិជានន្តិ** ជាដើម ក្នុងយមកវគ្គនោះឯង ។ ដែលពិត ខ្ញុំពោលរឿងនេះហើយថា ការប្រថាប់នៅរបស់ព្រះតថាគត ដែលស្តេចដីរក្នុងជងព្រៃ ឈ្មោះរក្ខិតៈនោះ ទំនុកបម្រុងបានប្រាកដក្នុងសកលជម្ពូទ្វីបហើយ ។ ត្រកូលធំ មានអនាថបិណ្ឌិកសេដ្ឋីនាងវិសាខាមហាឧបាសិកា បញ្ជូនដំណឹងទៅអំពីនគរសាវត្ថីដល់ព្រះអានន្ទត្ថេរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្ហាញព្រះសាស្តាដល់យើងខ្ញុំទាំង-ឡាយចុះ ។ ភិក្ខុប្រមាណ ៥០០ រូប សូម្បីមានប្រក្រតីនៅក្នុងទិស ចេញវស្សាហើយ ចូលទៅរកព្រះអានន្ទត្ថេរអង្វរថា អាវុសោអានន្ទ យើងទាំងឡាយខានស្តាប់ធម្មកថា ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ អស់កាលយូរហើយ សាធុ អាវុសោអានន្ទ យើងទាំងឡាយគប្បីបានស្តាប់ធម្មកថា ក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ។

ព្រះថេរៈនាំភិក្ខុទាំងនោះទៅកាន់ជងព្រៃ ឈ្មោះរក្ខិតៈនោះហើយ ត្រិះរិះថា ការចូលទៅកាន់សម្នាក់ព្រះតថាគត ដែលមានប្រក្រតីប្រថាប់នៅមួយអង្គឯងអស់ត្រីមាស មួយអន្លើដោយភិក្ខុមានប្រមាណប៉ុណ្ណោះ មិនសមគួរ ដូច្នេះ

ហើយ មួយអង្គឯងប៉ុណ្ណោះចូលទៅគាល់ព្រះសាស្តា ។ដំរីឈ្មោះបាលិលេយ្យកៈ ឃើញលោកហើយ ចាប់ឈើស្ទុះទៅ ព្រះសាស្តាទតឃើញហើយ ត្រាស់ថា បាលិលេយ្យកៈ ចូរអ្នកចៀសចេញទៅកុំឃាត់ នុ៎ះជាពុទ្ធុបដ្ឋាក ដំរីបោះកំណាត់ ឈើចោលក្នុងទីនោះឯង សួរដោយអើពើដល់ការទទួលបាត្រ និងចីវរ ។ ព្រះ ថេរៈមិនបានឲ្យ ។ ដំរីគិតថា បើភិក្ខុនេះជាអ្នកមានវត្តដែលរៀនហើយសោត លោកនឹងមិនដាក់បរិក្ខាររបស់ខ្លួន លើផ្ទាំងថ្មដែលជាទីប្រថាបគន់របស់ព្រះ មានព្រះភាគ ព្រះថេរៈដាក់បាត្រ និងចីវរលើផែនដី ។ ពិតហើយ ភិក្ខុដែល សម្បូរដោយវត្តទាំងឡាយ រមែងមិនដាក់បរិក្ខាររបស់ខ្លួនលើទីអង្គុយ ឬទី ដេករបស់គ្រូ ព្រះថេរៈថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងចំណែកម្ខាង ព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ អ្នកមកមួយរូបប៉ុណ្ណោះឬ ទ្រង់ស្តាប់ ភាពដែលព្រះថេរៈ និងភិក្ខុប្រមាណ ៥០០ រូប ត្រាស់ថា ភិក្ខុទាំងនោះនៅ ទីណា កាលព្រះថេរៈក្រាបទូលថា ខ្ញុំព្រះអង្គកាលនឹងជ្រាបចិត្តរបស់ទ្រង់ ទើបឲ្យលោករង់ចាំក្នុងទីខាងក្រៅ ហើយមកគាល់តែឯង ។ ព្រះសាស្តា ត្រាស់ថា ចូរហៅភិក្ខុទាំងនោះមកចុះ ព្រះថេរៈបានធ្វើយ៉ាងនោះ ។ ព្រះ សាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយនឹងភិក្ខុទាំងនោះហើយ កាលភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ជាបុគ្គលសុខុមាលជាតិ និងជាក្សត្រ សុខុមាលជាតិ ទ្រង់នៅមួយអង្គឯង ប្រថាប់ឈរ ប្រថាប់គង់ អស់ត្រីមាស ទ្រង់ធ្វើកម្មដែលធ្វើបានដោយក្រហើយ បុគ្គលធ្វើវត្ត និងបដិបត្តិក្តី អ្នកថ្វាយ វត្ត មានទឹកខ្ពុរព្រះឱស្ឋជាដើមក្តី ប្រហែលជាមិនមាន ទើបទ្រង់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កិច្ចគ្រប់យ៉ាងដំរីបាលិលេយ្យកៈ ធ្វើហើយដល់តថាគត ។ ពិតហើយ បុគ្គលកាលបានសម្លាញ់មានសភាពបែបនេះ នៅរួមគ្នា សមគួរ ហើយ កាលបុគ្គលមិនបានសម្លាញ់បែបនេះ ការត្រាច់ទៅម្នាក់ឯងប៉ុណ្ណោះ ជា ការប្រសើរ ហើយបានភាសិតព្រះគាថានេះ ក្នុងនាគវគ្គថា

**សចេ លភេថ និបកំ សហាយំ សទ្ធឹ ចរំ សាធុវិហារិ ធីរំ**
**អភិភុយ្យ សព្វានិ បរិស្សយានិ ចរេយ្យ តេនត្តមនោ សតីមា ។**
**នោ ចេ លភេថ និបកំ សហាយំ សទ្ធឹ ចរំ សាធុវិហារិ ធីរំ**
**រាជាវ រដ្ឋំ វិជិតំ បហាយ ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។**
**ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា**
**ឯកោ ចរេ ន ច បាបានិ កយិរា អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។**

បើបុគ្គលបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញា ចងចាំ មានគុណធម៌ជាគ្រឿងនៅ ញុំាងប្រយោជន៍ឲ្យសម្រេច ជា អ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្រប សង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសម្លាញ់ នោះឯង ។ បើស្វែងរកមិនបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿង រក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ ជាគ្រឿងញុំាងប្រយោជន៍ ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯកឯងវិញ ដូច ព្រះរាជាលះបង់រដ្ឋដែលទ្រង់ឈ្នះហើយ ស្តេចទៅតែឯកអង្គ ពុំនោះ សោត ដូចដំរីឈ្មោះមាតង្គៈ ដែលលះហ្វូង ត្រាច់ទៅតែឯកឯង ក្នុងព្រៃ

ដូច្នោះដែរ ។ ការត្រាច់ទៅរបស់បុគ្គលឯកឯង ជាគុណជាតប្រសើរ ផុត ( ព្រោះថា ) សហាយតាគុណ រមែងមិនមានក្នុងជនពាល ឡើយ បុគ្គលនោះ គប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែ ម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯកឯងក្នុង ព្រៃដូច្នោះដែរ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **និបកំ** គឺដែលប្រកបដោយបញ្ញា ជាគ្រឿង រក្សាខ្លួន ។

បទថា **សាធុវិហារិ ធីរំ** គឺបុគ្គលដែលមានធម៌ជាគ្រឿងនៅដ៏ចម្រើន ជាបណ្ឌិត ។

បទថា **បរិស្សយានិ** ជាដើម សេចក្តីថា បុគ្គលនោះកាលបានសម្លាញ់ ដែលមានមេត្តាជាវិហារធម៌បែបនោះ គប្បីគ្របសង្កត់អន្តរាយទាំងឡាយ គឺ អន្តរាយដែលប្រាកដ មានសីហៈ និងខ្លាធំជាដើម និងអន្តរាយកំបាំង មាន រាគៈ ទោសៈ ទាំងអស់នេះឯងជាដើមហើយ គប្បីជាអ្នកមានចិត្តត្រេកអរ មានសតិតាំងមាំ ត្រាច់ទៅ គឺនៅជាមួយសម្លាញ់នោះ ។

បទថា **រាជាវ រដ្ឋំ** សេចក្តីថា ដូចព្រះរាជាជាឥសី ទ្រង់លះបង់ដែនបួស ដូច្នោះ ។ លោកពោលពាក្យអធិប្បាយនេះថា ព្រះរាជាដែលមានប្រទេស ដែលទ្រង់ឈ្នះហើយ ទ្រង់លះដែនដែលទ្រង់ឈ្នះជាសមុច្ឆេទហើយ ដោយ

ទ្រង់ត្រិះរិះថា ឈ្មោះថា ភាពជាព្រះរាជានេះ ជាទីតាំងនៃសេចក្ដីប្រមាទធំ ប្រយោជន៍អ្វីរបស់អញ ដោយរាជសម្បត្តិ ដែលអញគ្រប់គ្រងហើយ គ្រានោះឯង យាងចូលទៅកាន់ព្រៃធំ បួសជាតាបស ហើយត្រាច់ទៅចំពោះមួយអង្គឯង ដោយឥរិយាបថ ៤ យ៉ាងណា បុគ្គលគប្បីត្រាច់ទៅ ចំពោះម្នាក់ឯង ដូច្នោះ ។

ពីរបទថា **មាតង្គរញ្ញេវ នាគោ** សេចក្ដីថា ដូចស្ដេចដំរីឈ្មោះមាតង្គៈ ព្រោះពិចារណាយ៉ាងនេះថា អញនៅច្រឡូកច្រឡំដោយពួកដំរីស្ដ ដំរីញី ដំរីជំទង់ និងកូនដំរីទាំងឡាយ អញតែងទំពាស៊ីស្មៅដែលគេកាត់ត្រង់ចុងហើយ និងរមែងទំពាស៊ីមែក ដែលល្មមកាច់បានហើយ អញរមែងផឹកទឹកដែលល្អក់ កាលអញឈមចុះកាន់កំពង់ទឹក និងឈានឡើង ដំរីមេរមែងដើរត្រដុសកាយទៅ បើដូច្នោះ គប្បីចៀសចេញអំពីហ្វូង ដូច្នេះហើយ ដើរទៅដោយការដឹងលះបង់ហ្វូងហើយ រមែងត្រាច់ទៅក្នុងព្រៃតាមសប្បាយ ដោយឯកឯងប៉ុណ្ណោះ ក្នុងឥរិយាបថទាំងពួង យ៉ាងណា បុគ្គលគប្បីត្រាច់ទៅម្នាក់ឯងប៉ុណ្ណោះដូច្នោះ ។

បទថា **ឯកស្ស** សេចក្ដីថា ការត្រាច់ទៅនៃបព្វជិត ដែលត្រេកអរក្រៃលែងហើយក្នុងឯកីភាព តាំងអំពីកាលដែលខ្លួនបួស ឈ្មោះថា ជាបុគ្គលម្នាក់ឯងប៉ុណ្ណោះ ប្រសើរ ។

បាទព្រះគាថាថា **នត្ថិ ពាលេ សហាយតា** សេចក្ដីថា ព្រោះគុណធម៌នេះ គឺចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ អមតមហានិព្វាន ១ ឈ្មោះថា

សហាយតាគុណ ។ បុគ្គលមិនអាចសម្រេចគ្រឿងជាសហាយនោះ ព្រោះអាស្រ័យពួកពាលជន ព្រោះដូច្នោះ គុណជាសម្លាញ់ ទើបឈ្មោះថា មិនមានក្នុងពាលជន ។

បទថា **ឯកោ** ជាដើម សេចក្តីថា ព្រោះហេតុនេះ បុគ្គលគប្បីជាបុគ្គលម្នាក់ឯងប៉ុណ្ណោះ ត្រាច់ទៅក្នុងឥរិយាបថទាំងពួង និងមិនគប្បីធ្វើបាបទាំងឡាយ សូម្បីមានប្រមាណតិច ។ អធិប្បាយថា បុគ្គលនោះ គប្បីជាបុគ្គលម្នាក់ឯងប៉ុណ្ណោះត្រាច់ទៅ ។ ដំរីឈ្មោះមាតង្គៈ មានសេចក្តីខ្វល់ខ្វាយតិច គឺមិនមានអាល័យ ត្រាច់ទៅតាមសប្បាយ ក្នុងទីដែលខ្លួនប្រាថ្នាហើយ ក្នុងព្រៃនេះ ដូច្នោះ មិនគប្បីធ្វើបាបទាំងឡាយ សូម្បីមានប្រមាណតិច ។

ព្រោះដូច្នោះ ព្រះសាស្តា កាលទ្រង់សម្តែងអត្ថនេះថា អ្នកទាំងឡាយបើមិនបានសម្លាញ់ ដែលមានសភាពបែបនេះ គប្បីជាអ្នកត្រាច់ទៅម្នាក់ឯងប៉ុណ្ណោះ ទើបទ្រង់សម្តែងព្រះធម្មទេសនានេះ ដល់ភិក្ខុទាំងនោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំង ៥០០ រូបនោះ តាំងនៅក្នុងអរហត្តផល ដូច្នេះឯង ៕៚

## រឿងសម្ពហុលភិក្ខុ ចប់

# រឿង មារ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងកុដិដែលតាំងនៅក្នុងព្រៃហិមពាន្ត ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា **អត្ថម្ហិ** ជាដើម ។

បានឮថា ក្នុងកាលនោះ ព្រះរាជាទាំងឡាយ គ្រប់គ្រងរាជសម្បត្តិបៀតបៀនដល់ពួកមនុស្ស ។ គ្រានោះ ព្រះដ៏មានព្រះភាគទតឃើញមនុស្សទាំងឡាយត្រូវបៀតបៀនដោយដាក់អាជ្ញា ក្នុងវជ្ជសម័យរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ទ្រង់ត្រិះរិះដោយអំណាចនៃសេចក្តីករុណា យ៉ាងនេះថា តថាគតអាចគ្រប់គ្រងរាជសម្បត្តិដោយធម៌ មិនបៀតបៀនខ្លួនឯង មិនឲ្យអ្នកដទៃបៀតបៀន មិនឈ្នះខ្លួនឯង មិនឲ្យអ្នកដទៃឈ្នះ មិនសោយសោកឯង មិនឲ្យអ្នកដទៃសោយសោកឬហ្ន៎ ។

មារមានចិត្តបាប ជ្រាបបរិវិតក្កក្នុងសេចក្តីនោះ របស់ព្រះសាស្តាហើយ ទើបត្រិះរិះថា ព្រះសមណគោតមទ្រង់ត្រិះរិះថា អញអាចគ្រប់គ្រងរាជសម្បត្តិឬហ្ន៎ ឥឡូវនេះ ព្រះសមណគោតមនោះ នឹងជាអ្នកប្រាថ្នាដើម្បីគ្រប់គ្រងរាជសម្បត្តិ ឈ្មោះថា រាជសម្បត្តិនេះ ជាទីតាំងនៃសេចក្តីប្រមាទ កាលព្រះសមណគោតមគ្រប់គ្រងរាជសម្បត្តិនោះ អញអាចបានឱកាស អញនឹងទៅញ៉ាំងនូវឧស្សាហៈឲ្យកើតឡើងដល់ទ្រង់ ហើយចូលទៅគាល់ព្រះសាស្តាក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់គ្រងរាជសម្បត្តិ សូមទ្រង់គ្រងរាជ-សម្បត្តិដោយធម៌ មិនបៀតបៀនឯង មិនឲ្យអ្នកដទៃបៀតបៀន មិនឈ្នះឯង មិនឲ្យអ្នកដទៃឈ្នះ មិនសោយសោកឯង មិនឲ្យអ្នកដទៃសោយសោក ។

គ្រានោះ ព្រះសាស្ដាត្រាស់នឹងមារនោះថា ម្នាលមារមានចិត្តបាប អ្នកឃើញអ្វីរបស់តថាគត ទើបអ្នកពោលយ៉ាងនេះ កាលមារទូលថា បពិត្រព្រះអង្គ ទ្រង់អប់រំឥទ្ធិបាទ ៤ ល្អហើយ ព្រះដ៏មានព្រះភាគ កាលទ្រង់មានព្រះចំណង់ ទើបទ្រង់បង្អោនទឹកដល់ស្ដេចភ្នំហិមពាន្តថា ចូរជាមាស ហើយស្ដេចភ្នំដែលទ្រង់ទឹកដល់នោះ គប្បីជាមាសនោះឯង ខ្ញុំព្រះអង្គនឹងធ្វើកិច្ចដែលគួរធ្វើដោយទ្រព្យដើម្បីព្រះអង្គ ។ ព្រោះហេតុនេះ ទ្រង់នឹងគ្រប់គ្រងរាជសម្បត្តិដោយធម៌ ដូច្នេះហើយ ទ្រង់ញុំាងមារឲ្យសង្វេគដោយគាថាទាំងនេះថា

> ព្រះអង្គត្រាស់ថា ភ្នំមាសសុទ្ធមានសម្បុរល្អ ទោះបីភ្នំពីរ ក៏មិនល្មមគ្រាន់ដល់បុគ្គលម្នាក់ឡើយ បុគ្គលដឹងដូច្នេះ គួរប្រព្រឹត្តស្មើ សត្វណាបានឃើញសេចក្ដីទុក្ខ ដែលមានកាមជាហេតុ សត្វនោះនឹងបង្អោនចិត្តទៅរកកាមដូចម្ដេចកើត លុះសត្វបានដឹងច្បាស់នូវឧបធិក្នុងលោកថា ជាគ្រឿងចំពាក់ ដូច្នេះហើយ គួរសិក្សាដើម្បីកម្ចាត់បង់នូវឧបធិនោះចេញ ។

ហើយទ្រង់ត្រាស់ថា ម្នាលមារមានចិត្តបាប ឱវាទរបស់អ្នកម្យ៉ាងរបស់តថាគតក៏ម្យ៉ាង ឈ្មោះថា ការប្រឹក្សាធម៌ជាមួយអ្នក រមែងមិនមានព្រោះតថាគតតែងទូន្មានយ៉ាងនេះ ហើយទ្រង់ភាសិតព្រះគាថាទាំងនេះថា

**អត្ថម្ហិ ជាតម្ហិ សុខា សហាយា តុដ្ឋី សុខា យា ឥតរីតរេន**
**បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ សព្វស្ស ទុក្ខស្ស សុខំ បហានំ ។**

សុខា មត្តេយ្យតា លោកេ អថោ បេត្តេយ្យតា សុខា
សុខា សាមញ្ញតា លោកេ អថោ ព្រហ្មញ្ញតា សុខា ។
សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា
សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ ។

កាលបើសេចក្តីត្រូវការកើតឡើងហើយ សម្លាញ់ទាំងឡាយ នាំសេចក្តីសុខមកឲ្យ សេចក្តីត្រេកអរដោយបច្ច័យតាមមាន តាមបាន ជាហេតុនាំសេចក្តីសុខមកឲ្យ បុណ្យនាំសេចក្តីសុខមកឲ្យក្នុងកាលទៀបក្ស័យជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឲ្យ ។ សេចក្តីប្រតិបត្តិល្អក្នុងមាតា នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អក្នុងបិតា នាំសេចក្តីសុខមកឲ្យ សេចក្តីប្រតិបត្តិល្អក្នុងសមណៈ នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អក្នុងព្រាហ្មណ៍ នាំសេចក្តីសុខមកឲ្យ សីល នាំសេចក្តីសុខមកឲ្យដរាបដល់ចាស់ សទ្ធាដែលបុគ្គលតម្កល់ស៊ប់ហើយ នាំសេចក្តីសុខមកឲ្យ ការបាននូវប្រាជ្ញា នាំសេចក្តីសុខមកឲ្យ ការមិនធ្វើបាបទាំងឡាយ នាំសេចក្តីសុខមកឲ្យ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អត្ថម្ហិ** សេចក្តីថា កិច្ច មានការធ្វើចីវរជាដើមក្តី មានការរម្ងាប់អធិករណ៍ជាដើមក្តី កើតឡើងដល់បព្វជិតក៏មាន ។

កាលកិច្ច មានកសិកម្មជាដើមក្តី មានការដែលត្រូវពួកជនអាស្រ័យរួមដោយចំណែកដែលមានកម្លាំងញ៉ាំញីក្តី រមែងកើតឡើងដល់គ្រហស្ថក៏មាន សម្លាញ់ណាអាចញ៉ាំងកិច្ចនោះឲ្យសម្រេចបាន ឬឲ្យស្ងប់បាន សម្លាញ់បែបនោះ នាំសេចក្តីសុខមកឲ្យ ។

ពីរបទថា **តុដ្ឋី សុខា** សេចក្តីថា គ្រហស្ថទាំងឡាយដែលមិនសន្តោសដោយរបស់ខ្លួន ទើបប្រារព្ធទុច្ចរិតកម្ម មានការកាត់ទី-តជាដើម សូម្បីបព្វជិតទាំងឡាយ ដែលមិនសន្តោសហើយដោយបច្ច័យរបស់ខ្លួន ទើបប្រារព្ធអនេសនាមានប្រការផ្សេងៗ ព្រោះហេតុនេះ គ្រហស្ថ និងបព្វជិតទាំងពីរនោះ ទើបមិនជួបនូវសេចក្តីសុខឡើយ ព្រោះដូច្នោះ ការសន្តោសដោយរបស់ដែលមាននៃខ្លួនក្រៅអំពីនេះ គឺតិចតួច ឬច្រើននេះឯង នាំសេចក្តីសុខមកឲ្យ ។

បទថា **បុញ្ញំ** សេចក្តីថា បុញ្ញកម្មដែលផ្តើមធ្វើតាមអធ្យាស្រ័យយ៉ាងណានោះឯង នាំសេចក្តីសុខមកឲ្យក្នុងមរណកាល ។

បទថា **សព្វស្ស** សេចក្តីថា ម្យ៉ាងទៀត អរហត្ត ពោល គឺការលះវដ្តទុក្ខទាំងមូលបាននោះឯង ឈ្មោះថា នាំសេចក្តីសុខមកឲ្យក្នុងលោក ។

កិច្ចបដិបត្តិប្រពៃក្នុងមាតា ឈ្មោះថា **មត្តេយ្យតា** បដិបត្តិប្រពៃក្នុងបិតា ឈ្មោះថា **បេត្តេយ្យតា ។** ការទំនុកបម្រុងមាតាបិតានេះឯង ព្រះមានព្រះភាគត្រាស់ហើយដោយបទទាំងពីរ ។ មែនពិត មាតា និងបិតាដឹងថា កូនទាំងឡាយមិនទំនុកបម្រុងហើយ រមែងកប់ទ្រព្យដែលជារបស់ខ្លួនចោលក្នុងផែនដីខ្លះ លះឲ្យជនដទៃខ្លះ ម្យ៉ាងទៀត ការនិន្ទារមែងប្រព្រឹត្តទៅដល់បុត្រ

ទាំងនោះថា ជនទាំងនេះ មិនទំនុកបម្រុងមាតាបិតា បុត្រទាំងនោះ រមែងកើតក្នុងគូថនរក ព្រោះកាយបែកធ្លាយទៅ ចំណែកបុត្រពួកណា ទំនុកបម្រុងមាតាបិតាដោយគោរព បុត្រទាំងនោះ រមែងបានទ្រព្យដែលជារបស់មាតាបិតាទាំងនោះ រមែងបាននូវការសរសើរ ព្រោះរាងកាយបែកធ្លាយទៅ រមែងទៅកើតក្នុងស្ថានសួគ៌ ព្រោះដូច្នោះ ទើបបទទាំងពីរនេះ ព្រះសាស្ដាត្រាស់ថា នាំសេចក្ដីសុខមកឲ្យ ដូច្នេះ ។

កិច្ចបដិបត្តិប្រពៃក្នុងបព្វជិតទាំងឡាយ ឈ្មោះថា **សាមញ្ញតា** បដិបត្តិប្រពៃក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកនៃព្រះពុទ្ធទាំងឡាយ មានបាបដែលបន្សាត់ហើយប៉ុណ្ណោះឈ្មោះថា **ព្រហ្មញ្ញតា** ។ ភាពជាអ្នកទំនុកបម្រុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធសាវកទាំងឡាយនោះដោយបច្ច័យ ៤ ព្រះដ៏មានព្រះភាគត្រាស់ហើយដោយបទទាំងពីរ ។ បទនេះ ទ្រង់ក៏ត្រាស់ថា នាំសេចក្ដីសុខមកឲ្យក្នុងលោក ។

បទថា **សីលំ** ជាដើម សេចក្ដីថា មែនពិត គ្រឿងអលង្ការទាំងឡាយមានកែវមណី កុណ្ឌល និងសំពត់ក្រហមជាដើម រមែងស្អាតសម្រាប់ជនដែលតាំងនៅហើយក្នុងវ័យនោះៗ ប៉ុណ្ណោះ គ្រឿងអលង្ការរបស់កំលោះក្រមុំ គង់ស្អាតក្នុងកាលចាស់ ឬគ្រឿងអលង្ការរបស់មនុស្សចាស់ គង់ស្អាតក្នុងកាលកំលោះក្រមុំក៏មិនមែន ម្យ៉ាងទៀត រមែងញុំាងឲ្យកើតសេចក្ដីវិនាសតែម្យ៉ាង ព្រោះឲ្យនូវការនិន្ទាកើតឡើងថា ជនទាំងនោះ ប្រហែលជាឆ្កួត ( បើតែងខ្លួនខុសវ័យ ) ចំណែកសីល ៥ និងសីល ១០ ជាដើម រមែងស្អាតគ្រប់វ័យ

ទាំងដល់កំលោះក្រមុំ និងមនុស្សចាស់នោះឯង រមែងនាំមកតែសោមនស្ស តែម្យ៉ាង ព្រោះឲ្យនូវការសរសើរកើតឡើងថា ឱ ! បុគ្គលនេះ មានសីលហ្ន៎ ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ថា **សុខំ យាវ ជរា សីលំ** ។

ពីរបទថា **សទ្ធា បតិដ្ឋិតា** សេចក្តីថា សទ្ធាដែលជាលោកិយ និងលោកុត្តរទាំងពីរយ៉ាង ជាគុណជាតមិនញាប់ញ័រ តាំងមាំហើយ នាំសេចក្តីសុខមកឲ្យ ។

បាទព្រះគាថាថា **សុខោ បញ្ញាបដិលាភោ** សេចក្តីថា ការបានចំពោះនូវបញ្ញា ដែលជាលោកិយ និងលោកុត្តរ នាំសេចក្តីសុខមកឲ្យ ។

ពីរបទថា **បាបានំ អករណំ** សេចក្តីថា ម្យ៉ាងទៀត ការមិនធ្វើបាបទាំងឡាយ ដោយអំណាចសេតុឃាតៈ គឺអរិយមគ្គ នាំសេចក្តីសុខមកឲ្យក្នុងលោកនេះ ។ ក្នុងកាលចប់ទេសនា ធម្មាភិសម័យ មានដល់ទេវតាជាច្រើន ដោយប្រការដូច្នេះឯង ៕ ០៚

**រឿងមារ ចប់**

**នាគវគ្គ ចប់**

**វគ្គទី ២៣ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា តណ្ហាវគ្គទី ២៤

[ ៣៤ ] តណ្ហា តែងចម្រើនដល់មនុស្សអ្នកមានការប្រព្រឹត្ត ដោយសេចក្តីប្រមាទជាប្រក្រតី ដូចវល្លិ៍ រួបរឹតដើមឈើហើយ ចម្រើនឡើង បុគ្គលនោះ តែងស្ទុះទៅកាន់ភពតូចភពធំ ដូចស្វា កាលប្រាថ្នាផ្លែឈើ លោតទៅក្នុងព្រៃ ដូច្នោះដែរ ។ តណ្ហានុ៎ះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្តីសោកស្តាយតែងចម្រើនឡើង ដល់បុគ្គលនោះ ដូចស្បូវវណ្ណាស ដែលត្រូវភ្លៀងធ្លាក់ចុះជញ្រាំ ហើយពន្លក លូតលិចឡើង ដូច្នោះដែរ ។

ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមកក្នុងលោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្តីសោកស្តាយ តែងធ្លាក់ចេញចាកជននោះឯងដូចដំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូក ដូច្នោះដែរ ។

ព្រោះហេតុនោះ បានជាតថាគតប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយមានប៉ុន្មានរូប ដែលមកប្រជុំក្នុងទីនេះ សេចក្តីចម្រើន ចូរមានដល់អ្នកទាំង-ឡាយ ទាំងប៉ុណ្ណោះចុះ អ្នកទាំងឡាយ ចូររម្លើងឫសតណ្ហាចោលចេញ ដូចបុគ្គលត្រូវការដោយស្បូវភ្លាំង គាស់ស្បូវវណ្ណាសចោលចេញ ដូច្នោះ ។ មារកុំរុករានអ្នកទាំងឡាយរឿយៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុសដូច្នោះឡើយ ។

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំមួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះឡើងទៀតបាន មានឧបមាដូចម្តេចមិញ កាល

បើតណ្ហានុស័យ បុគ្គលកម្ចាត់មិនទាន់បានហើយ ទុក្ខ ( មានជាតិទុក្ខជាដើម ) នេះ ក៏តែងកើតរឿយៗ មានឧបមេយ្យដូច្នោះឯង ។ ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅ ក្នុងអារម្មណ៍ ជាទីគាប់ចិត្ត ជាធម្មជាតិក្លៀវក្លា មានដល់បុគ្គលណា តម្រិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ តែងនាំនូវទិដ្ឋិអាក្រក់របស់បុគ្គលនោះ ។

ខ្សែតណ្ហាទាំងឡាយ តែងហូរទៅក្នុងអារម្មណ៍ទាំងពួង ដូចជាវល្លិ៍ដែលបែកខ្នែងឡើង តាំងនៅដូច្នោះ បើអ្នកទាំងឡាយ ឃើញតណ្ហាដូចជាវល្លិ៍នោះ កើតឡើងហើយ ចូរកាត់ឫសបោលចេញ ដោយកាំបិត គឺបញ្ញា ។

សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្ដីស្រឡាញ់ផង រមែងមានដល់សត្វ ពួកសត្វនោះជាអ្នកអាស្រ័យនូវសេចក្ដីរីករាយ អ្នកស្វែងរកសេចក្ដីសុខ នរជនទាំងឡាយនោះឯង តែងឈមទៅរកជាតិ និងជរា ។

ពួកសត្វដែលតណ្ហា ជាទីញុំាងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងរន្ធត់ ដូចទន្សាយ ដែលព្រានទាក់បានហើយដូច្នោះ ពួកសត្វដែលជាប់ក្នុងសំយោជនៈ និងសង្គធម៌ ( ធម៌ជាគ្រឿងជំពាក់ ) តែងដល់នូវសេចក្ដីទុក្ខរឿយៗ អស់កាលអង្វែង ។

ពួកសត្វដែលតណ្ហា ជាទីញុំាងសត្វឲ្យតក់ស្លុត ក្រុងទុកហើយ តែងរន្ធត់ ដូចទន្សាយ ដែលនាយព្រានទាក់បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌ ជាគ្រឿងប្រាសចាករាគៈ ដើម្បីខ្លួន គប្បីបន្ទោបង់តណ្ហា

ដែលជាគ្រឿងតក់ស្លុត ចោលចេញ ។

បុគ្គលណា មិនមានអាល័យ ក្នុងគិហិភាពដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តចុះស៊ប់ក្នុងព្រៃ គឺតបធម៌ ជាអ្នករួចស្រឡះចាកព្រៃ គឺតណ្ហា ហើយស្ទុះទៅរកព្រៃ គឺតណ្ហាវិញ អ្នកទាំងឡាយ ចូរមើលបុគ្គលនោះឯង បុគ្គលនោះ រួចចាកចំណង គឺឃរាវាសហើយ ស្ទុះទៅរកចំណង គឺឃរាវាសវិញ ។ ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅឃាប្លងក្តី អ្នកប្រាជ្ញមិនហៅចំណងនោះថា ជាចំណងមាំមួនឡើយ ។

ពួកជនណា ត្រេកអរក្រៃពេក ក្នុងកែវមណី និងកុណ្ឌលទាំងឡាយក្តី សេចក្តីអាឡោះអាល័យ កូន និងប្រពន្ធទាំងឡាយក្តី អ្នកប្រាជ្ញទាំងឡាយហៅសេចក្តីត្រេកអរ និងសេចក្តីអាឡោះអាល័យនោះ ថាជាចំណងមាំមួន ជាចំណងនាំចុះ ( ទាញសត្វទម្លាក់ទៅក្នុងអបាយ ) ជាចំណងធូរទេ ប៉ុន្តែសត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញទាំងឡាយ កាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់កាមសុខ ហើយចេញបួស ។

ជនណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះទុក្ខទាំងពួងចេញទៅ ។

អ្នកចូរដោះ ( សេចក្តីអាល័យ ) ក្នុងកាលមុនចេញ ចូរដោះ ( សេចក្តីអាល័យ ) ក្នុងខាងក្រោយចេញ ចូរដោះ ( សេចក្តីអាល័យ ) ក្នុងកាល

ជាកណ្តាលចេញ ( កាលបើធ្វើយ៉ាងនេះ ) អ្នកនឹងដល់ត្រើយនៃភព នឹងមានចិត្តរួចស្រឡះ ចាកសង្ខតធម៌ទាំងពួង មិនត្រូវទៅកាន់ជាតិ និងជរាទៀតឡើយ ។

តណ្ហា រមែងចម្រើនក្រៃលែង ដល់ជនដែលវិតក្កញាំញី មានតម្រេកក្លៀវក្លា យល់ឃើញអារម្មណ៍ថាល្អ បុគ្គលនោះឯង ឈ្មោះថា ធ្វើចំណងឲ្យមាំមួន ។ លុះតែបុគ្គលណា ត្រេកអរក្នុងអសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់រម្ងាប់នូវវិតក្ក មានស្មារតីសព្វកាល តែងចម្រើនអសុភជ្ឈាន បុគ្គលនោះឯង នឹងធ្វើតណ្ហាឲ្យអស់ទៅបាន បុគ្គលនោះឯង ទើបឈ្មោះថា កាត់ចំណងមារបាន ។

បុគ្គលណា ដល់សេចក្តីសម្រេច គឺអរហត្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេសដូចទីទួល បានកាត់កូនសរ គឺកិលេស ជាហេតុញាំងសត្វឲ្យទៅកាន់ភពបានហើយ កាយដែលឆ្អឹង ៣០០ កំណាត់ផ្គុំគ្នាហើយនេះ របស់បុគ្គលនោះ ឈ្មោះថា តាំងនៅក្នុងទីបំផុត ។

បុគ្គលណា មិនមានតណ្ហា មិនមានសេចក្តីប្រកាន់មាំ ជាអ្នកឈ្លាសក្នុងនិរុត្តិ ( វាចាជាគ្រឿងសម្តែងចេញ ) និងបទដ៏សេស ដឹងច្បាស់នូវប្រជុំនៃអក្ខរៈទាំងឡាយផង នូវខាងដើម និងខាងចុង នៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯង តថាគតហៅថា អ្នកមានសរីរៈឋិតនៅក្នុងទីបំផុត មានបញ្ញាច្រើន ជាមហាបុរស ។

តថាគតជាអ្នកគ្របសង្កត់ គេកូមិកធម៌ទាំងអស់ ដឹងច្បាស់ចតុព្ភូមិក-

ធម៌ទាំងអស់ មានចិត្តមិនបានជាប់នៅ ក្នុងតេភូមិកធម៌ទាំងអស់ លះបង់តេភូមិកធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា បើតថាគតត្រាស់ដឹងធម៌ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណាជាគ្រូអាចារ្យទៀត ។ ធម្មទាន ឈ្នះអាមិសទានទាំងពួង ធម្មរស ឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហា ឈ្នះទុក្ខទាំងពួង ។ ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញា ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយ គឺព្រះនិព្វានទេ ឯបុគ្គលអប្បប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងភោគៈ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្តីស្រណោះជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានសេចក្តីស្រណោះអស់ហើយ រមែងជាទាន មានផលច្រើន ។

**តណ្ហាវគ្គទី ២៤ ចប់**

# អដ្ឋកថា
# តណ្ហាវគ្គទី ២៤

## រឿង កបិលមច្ឆៈ

ចូលទៅកាន់ព្រៃព្យាយាមក៏សម្រេចអរហត្តផល ។

ចំណែកភិក្ខុជាប្អូនគិតថា អញនៅកំលោះ ក្នុងពេលចាស់សឹមបំពេញវិបស្សនាធុរៈ ទើបផ្តើមតាំងគន្ថធុរៈ រៀនព្រះត្រៃបិដក បរិវារជាច្រើនបានកើតឡើង ព្រោះអាស្រ័យបរិយត្តិរបស់លោក លាភបានកើតឡើងព្រោះអាស្រ័យបរិវារ ស្រវឹងហើយដោយសេចក្តីស្រវឹងក្នុងភាពជាអ្នកស្តាប់ច្រើន ត្រូវការចង់បានក្នុងលាភគ្របសង្កត់ហើយ ព្រោះជាអ្នកសម្គាល់ខ្លួនថាឈ្លាសក្រៃលែង រមែងពោលរបស់ដែលជាកប្បិយៈ ដែលមនុស្សដទៃពោលហើយថាជាអកប្បិយៈ ពោលវត្ថុដែលជាអកប្បិយៈថាជាកប្បិយៈ ពោលវត្ថុដែលមានទោសថា មិនមានទោស ពោលវត្ថុដែលមិនមានទោសថាមានទោស សូម្បីភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងឡាយពោលថា អាវុសោកបិល អ្នកកុំពោលយ៉ាងនេះ ហើយសម្តែងធម៌និងវិន័យ ពោលប្រៀនប្រដៅ ហើយក៏ពោលថា ពួកលោកចេះអ្វី ពួកលោកដូចក្តាប់ដៃទទេជាដើមហើយ ក៏ត្រាច់ពោលសម្ងុតភិក្ខុទាំង-ឡាយ ។

គ្រានោះ ភិក្ខុទាំងឡាយប្រាប់សេចក្តីនោះដល់ព្រះសោធនត្ថេរ ដែលជា

បងប្រុសរបស់លោក សូម្បីព្រះសោធនត្ថេរ ចូលទៅរកលោកហើយ ដាស់តឿនថា អាវុសោកបិល កិច្ចបដិបត្តិប្រពៃរបស់ភិក្ខុទាំងឡាយដូចអ្នក ឈ្មោះថាជាអាយុនៃសាសនា ព្រោះដូច្នោះ អ្នកកុំលះកិច្ចបដិបត្តិប្រពៃ ហើយពោលជំទាស់វត្ថុដែលជាកប្បិយជាដើមយ៉ាងនោះឡើយ លោកមិនបានអើពើនឹងពាក្យរបស់ព្រះថេរៈ កាលបើដូច្នេះ ព្រះថេរៈក៏ដាស់តឿន ២-៣ ដង ដឹងថា លោកមិនទទួលពាក្យដាស់តឿនថា ភិក្ខុនេះមិនធ្វើតាមពាក្យរបស់អញ ទើបពោលថា អាវុសោ បើដូច្នោះ អ្នកនឹងប្រាកដដោយកម្មរបស់ខ្លួន ដូច្នេះហើយ ចៀសចេញទៅ ។

ចាប់តាំងអំពីនោះ ភិក្ខុទាំងឡាយ ដែលជាអ្នកមានសីលជាទីស្រឡាញ់ពួកដទៃបោះបង់លោកហើយ លោកជាអ្នកមានការប្រព្រឹត្តអាក្រក់ ដែលពួកអ្នកមានការប្រព្រឹត្តអាក្រក់ចោមរោម ថ្ងៃមួយគិតថា អញនឹងសូធ្យបាតិមោក្ខ ទើបកាន់ផ្ចិត ទៅអង្គុយលើធម្មាសនៈ ក្នុងរោងឧបោសថ ហើយសួរថា អាវុសោ បាតិមោក្ខរមែងប្រព្រឹត្តទៅដើម្បីភិក្ខុទាំងឡាយ ដែលប្រជុំគ្នាហើយក្នុងទីនេះឬ ឃើញភិក្ខុទាំងឡាយនៅស្ងៀម ដោយគិតថា ប្រយោជន៍អ្វីដោយពាក្យឆ្លើយ ដែលអញឲ្យដល់ភិក្ខុនេះ ទើបពោលថា អាវុសោ ធម៌ក្តីវិន័យក្តី មិនមានប្រយោជន៍អ្វីដោយបាតិមោក្ខ ដែលពួកលោកស្តាប់ ឬមិនស្តាប់ ដូច្នេះហើយ ក៏ក្រោកចាកអាសនៈ ញុំាងសាសនា គឺបរិយត្តិរបស់ព្រះកស្សបទសពលឲ្យសាបសូន្យ ដោយអាការយ៉ាងនេះ សូម្បីព្រះសោធនៈក៏បរិនិព្វានក្នុងថ្ងៃនោះឯង ។ ក្នុងកាលអស់អាយុ កបិលភិក្ខុកើតក្នុងអវីចី-

មហានរក មាតា និងប្អូនស្រីរបស់លោក ដល់នូវទិដ្ឋានុគតិរបស់លោកនោះឯង ជេរបរិភាសភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ហើយ ក៏កើតក្នុងអវិចីមហានរកដូចគ្នា ។

ក្នុងកាលនោះ បុរស ៥០០ នាក់ ធ្វើចោរកម្ម មានការប្លន់ស្រុកជាដើម ជាអ្នកនៅដោយកិរិយារបស់ចោរ ត្រូវពួកមនុស្សក្នុងជនបទ តាមចាប់ហើយ គេចចូលព្រៃ មិនឃើញទីពឹងក្នុងព្រៃនោះ ឃើញភិក្ខុនៅព្រៃជាវត្តមួយរូប ថ្វាយបង្គំហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ជាពឹងរបស់ពួកខ្ញុំផងចុះ ។

ព្រះថេរៈពោលថា ឈ្មោះថា ទីពឹង ដូចគ្នានឹងសីល មិនមានដល់អ្នកទាំងឡាយ ពួកអ្នកទាំងអស់ ចូរសមាទានសីល ៥ ចុះ ចោរទាំងនោះទទួលថា សាធុ ដូច្នេះហើយ សមាទានសីលទាំងឡាយ ។ លំដាប់នោះ ព្រះថេរៈដាស់តឿនចោរទាំងនោះថា ឥឡូវនេះ ពួកអ្នកជាអ្នកមានសីល ពួកអ្នកមិនគួរកន្លងនូវសីល សូម្បីព្រោះហេតុនៃជីវិតឡើយ ការប្រទូស្តផ្លូវចិត្តក៏មិនគួរធ្វើ ចោរទាំងនោះទទួលថា សាធុ ហើយ ។

គ្រានោះ អ្នកជនបទទាំងនោះមកដល់ទីនោះហើយ រកមើលក្នុងទីផ្សេងៗ ជួបចោរទាំងនោះហើយ ក៏នាំគ្នាផ្តាច់ជីវិតទាំងអស់ ពួកចោរទាំងនោះធ្វើកាលកិរិយាហើយ កើតក្នុងទេវលោក មេចោរបានជាប្រធាននៃទេវបុត្រ ។

ទេវបុត្រទាំងនោះ អន្ទោលទៅក្នុងទេវលោកអស់ពុទ្ធន្តរមួយ ដោយអំណាចអនុលោម និងបដិលោមក្នុងពុទ្ធុប្បាទកាលនេះ កើតហើយក្នុងស្រុក

អ្នកប្រមង់ ៥០០ ត្រកូលជិតទ្វារនគរសាវត្ថី ។ ប្រធានទេវបុត្របដិសន្ធិក្នុងផ្ទះរបស់ប្រធានអ្នកប្រមង់ ចំណែកទេវបុត្រក្រៅអំពីនេះ បដិសន្ធិក្នុងផ្ទះអ្នកប្រមង់ដទៃៗ ។ កិច្ចបដិសន្ធិ និងការប្រសូតចាកផ្ទៃមាតានៃជនទាំងនោះមានហើយក្នុងថ្ងៃជាមួយគ្នានោះឯង ដោយប្រការដូច្នេះ ។

ប្រធានអ្នកប្រមង់ ឲ្យមនុស្សដើរស្វែងរកថា ពួកទារកដទៃក្នុងស្រុកនេះកើតហើយក្នុងថ្ងៃនេះមានដែរឬទេ ។ បានឮភាពដែលទារកទាំងនោះកើតហើយទើបឲ្យទ្រព្យជាតម្លៃចិញ្ចឹមដល់អ្នកប្រមង់ទាំងនោះដោយតាំងចិត្តថា ពួកទារកនោះ ជាសម្លាញ់នឹងកូនរបស់យើង ។ ទារកទាំងនោះ ជាសម្លាញ់លេងធូលីរួមគ្នា បានជាអ្នកចម្រើនវ័យដោយលំដាប់ហើយ បណ្តាកុមារទាំងនោះ កូនរបស់ប្រធានអ្នកប្រមង់ បានជាបុគ្គលឧត្តមដោយយស និងអំណាច ។

កបិលភិក្ខុឆេះក្នុងនរកអស់មួយពុទ្ធន្តរហើយ ក្នុងកាលនោះ មកកើតជាត្រីធំក្នុងស្ទឹងអចិរវតី មានពណ៌ដូចមាស មានមាត់ស្អុយ ដោយវិបាកដែលសេសសល់ ។

ថ្ងៃមួយ សម្លាញ់ទាំងនោះប្រឹក្សាគ្នាថា យើងនឹងចាប់ត្រី ទើបកាន់យកឧបករណ៍ចាប់សត្វទឹក មានសំណាញ់ជាដើម បង់ទៅក្នុងស្ទឹង ពេលនោះត្រីនោះ បានចូលទៅខាងក្នុងសំណាញ់របស់ជនទាំងនោះ អ្នកប្រមង់ទាំងអស់ បានឃើញត្រីនោះហើយ បន្លឺសំឡេងអ៊ូអរថា កូនរបស់យើងចាប់ត្រីមុនគេ ចាប់បានត្រីមាសហើយ ពេលនេះ ព្រះរាជានឹងព្រះរាជទានទ្រព្យដល់យើងគ្រប់គ្រាន់ ។ សម្លាញ់ទាំងនោះ យកត្រីដាក់ទូក លើកទូកឡើងហើយ

ទៅកាន់ព្រះរាជសម្នាក់ ។

កាលព្រះរាជាទ្រង់ទតឃើញត្រីនោះ ត្រាស់ថា នុ៎ះជាអ្វី ពួកមាណព ក្រាបទូលថា បពិត្រព្រះអង្គ ត្រី ព្រះរាជាទតឃើញត្រីមានពណ៌ដូចមាស ទ្រង់ត្រិះរិះថា ព្រះសាស្តាទ្រង់នឹងជ្រាបហេតុដែលត្រីនោះជាមាស ដូច្នេះហើយ ត្រាស់ឲ្យមនុស្សកាន់យកត្រីទៅកាន់សម្នាក់ព្រះសាស្តា កាលមាត់ត្រីនោះហា ឡើងប៉ុណ្ណោះ វត្តជេតពនទាំងមូល មានក្លិនស្អុយពន់ពេក ។

ព្រះរាជាទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ហេតុអ្វី ត្រីនេះ មានពណ៌ដូចមាស ហេតុអ្វី ទើបក្លិនស្អុយផ្សាយចេញអំពីមាត់របស់ត្រីនេះ ។ ព្រះមានព្រះភាគត្រាស់ថា ត្រីនេះ ជាភិក្ខុឈ្មោះកបិល ជាពហូសូត មានបរិវារ ច្រើន ក្នុងធម្មវិន័យរបស់ព្រះមានព្រះភាគ ព្រះនាមកស្សប ត្រូវចំណង់ក្នុង លាភគ្របសង្កត់ហើយ ជេរបរិភាសពួកភិក្ខុដែលមិនកាន់យកពាក្យសម្តីរបស់ ខ្លួន ញ៉ាំងសាសនារបស់ព្រះកស្សបសម្ពុទ្ធឲ្យវិនាសហើយ កើតក្នុងអវិចី ដោយកម្មនោះ ឥឡូវនេះ កើតជាត្រីដោយវិបាកដែលសេសសល់ ព្រោះ លោកប្រាប់ពុទ្ធវចនៈ ពោលសរសើរគុណរបស់ព្រះសម្ពុទ្ធ អស់កាលយូរ ទើបមានអត្តភាពពណ៌ដូចមាសដោយផលនៃកម្មនោះ ភិក្ខុនោះ បានជេរបរិ-ភាសភិក្ខុទាំងឡាយ ទើបក្លិនស្អុយចេញអំពីមាត់ដោយផលនៃកម្មនោះ មហាបពិត្រ តថាគតនឹងឲ្យត្រីនេះនិយាយ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ សូមទ្រង់ឲ្យនិយាយចុះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរត្រីថា អ្នកឈ្មោះកបិលឬ ត្រីពោល

*ថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឈ្មោះកបិល ព្រះសាស្តាត្រាស់ថា អ្នកមកអំពីទីណា ត្រីពោលថា បពិត្រព្រះអង្គ មកអំពីអវីចីមហានរក ព្រះសាស្តាត្រាស់ថា សោធនៈបងប្រុសច្បងរបស់អ្នកទៅឯណា ត្រីពោលថា បពិត្រព្រះអង្គ បរិនិព្វានហើយ ព្រះសាស្តាត្រាស់ថា នាងសាធនីម្តាយរបស់អ្នកនៅឯណា ត្រីពោលថា បពិត្រព្រះអង្គ កើតក្នុងនរក ព្រះសាស្តាត្រាស់ថា នាងតាបនាប្អូនស្រីរបស់អ្នកនៅឯណា ត្រីពោលថា បពិត្រព្រះអង្គ កើតក្នុងមហានរក ព្រះសាស្តាសួរថា ឥឡូវនេះ អ្នកនឹងទៅណា ត្រីឈ្មោះកបិលមច្ឆៈក្រាបទូលថា បពិត្រព្រះអង្គ នឹងទៅកាន់អវីចីមហានរក ដូច្នេះហើយ ត្រូវសេចក្តីក្តៅក្រហាយគ្របសង្កត់ហើយ យកក្បាលបោកនឹងទូក ធ្វើកាលកិរិយាក្នុងទីនោះឯង កើតក្នុងនរកហើយ មហាជនកើតព្រឺរោម ព្រឺស្បែក ដោយប្រការដូច្នេះ ។*

*គ្រានោះ ព្រះសាស្តាប្រមើលមើលចិត្តរបស់បរិស័ទ ដែលប្រជុំគ្នាក្នុងខណៈនោះ ដើម្បីទ្រង់សម្តែងធម៌ឲ្យសមគួរដល់ខណៈនោះ ទើបត្រាស់កបិលសូត្រ ក្នុងសុត្តនិបាតថា អ្នកប្រាជ្ញទាំងឡាយ បានពោលការប្រព្រឹត្តធម៌ ១ ការប្រព្រឹត្តព្រហ្មចរិយៈ ១ នុ៎ះថាជាកែវដ៏ឧត្តមដូច្នេះជាដើមហើយ បានត្រាស់ព្រះគាថាទាំងនេះថា*

| | |
|---|---|
| មនុជស្ស បមត្តចារិនោ | តណ្ហា វឌ្ឍតិ មាលុវា វិយ |
| សោ បលវតី ហុរាហុរំ | ផលមិច្ឆំវ វនស្មឹ វានរោ ។ |
| យំ ឯសា សហតី ជម្មី | តណ្ហា លោកេ វិសត្តិកា |
| សោកា តស្ស បវឌ្ឍន្តិ | អភិវឌ្ឍំវ វីរណំ ។ |

យោ វេ តំ សហតី ជម្មឹ តណ្ហំ លោកេ ទុរច្ចយំ
សោកា តម្ហា បបតន្តិ ឧទពិន្ទុវ ចោក្ខរា ។
តំ វោ វទាមិ ភទ្ទំ វោ យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខណថ ឧសីរត្ថោវ វីរណំ ។
មា វោ នឡំ វ សោតោវ មារោ ភញ្ជិ បុនប្បុនំ ។

តណ្ហាតែងចម្រើនដល់មនុស្ស អ្នកមានការប្រព្រឹត្តដោយសេចក្តីប្រមាទជាប្រក្រតី ដូចវល្លិ៍រួបរឹតដើមឈើ ហើយចម្រើនឡើង បុគ្គលនោះ តែងស្ទុះទៅកាន់ភពតូច ភពធំដូច ស្វា កាលប្រាថ្នាផ្លែឈើ លោតទៅក្នុងព្រៃដូច្នោះដែរ ។ តណ្ហានុ៎ះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្តីសោកស្តាយ តែងចម្រើនឡើងដល់បុគ្គលនោះ ដូចស្បូវរណ្តាស ដែលត្រូវភ្លៀងធ្លាក់ចុះជញ្ជ្រាំ ហើយពន្លកលូតលិចឡើង ដូច្នោះដែរ ។ ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមកក្នុងលោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្តីសោកស្តាយ តែងធ្លាក់ចេញចាកជននោះឯង ដូចតំណក់ទឹកដែលធ្លាក់ចុះចាកស្លឹកឈូកដូច្នោះដែរ ។ ព្រោះហេតុនោះ បានជាតថាគតប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយ មានប៉ុន្មានរូប ដែលមកប្រជុំ

ក្នុងទីនេះ សេចក្តីចម្រើនចូរមានដល់អ្នកទាំងឡាយ ទាំង
ប៉ុណ្ណោះចុះ អ្នកទាំងឡាយ ចូររម្លើងឫសតណ្ហាចោល
ចេញ ដូចបុគ្គលត្រូវការដោយស្បូវក្លាំង គាស់ស្បូវ
វណ្តាសចោលចេញ ដូច្នោះ មារកុំរុករានអ្នកទាំងឡាយ
រឿយៗ ដូចខ្សែទឹកកាច់បំបាក់ដើមបបុសដូច្នោះឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បមត្តចារិនោ** សេចក្តីថា ឈានមិនចម្រើន វិបស្សនា មគ្គ និងផល ក៏មិនចម្រើន ដល់បុគ្គលដែលមានប្រក្រតីប្រព្រឹត្ត ប្រមាទ ដោយសេចក្តីប្រមាទ មានការបណ្តែតបណ្តោយសតិជាលក្ខណៈ អធិប្បាយថា ដូចពួរជ្រៃរួបរឹតនូវដើមឈើ រមែងចម្រើនដើម្បីសេចក្តីវិនាស នៃដើមឈើនោះ យ៉ាងណា តណ្ហាក៏ដូច្នោះ ឈ្មោះថា ចម្រើនដល់បុគ្គលនោះ ព្រោះអាស្រ័យទ្វារទាំង ៦ កើតឡើងរឿយៗ ។

បាទព្រះគាថាថា **សោ បលវតី ហុរាហុរំ** សេចក្តីថា បុគ្គលនោះ គឺ បុគ្គលប្រព្រឹត្តទៅក្នុងគតិនៃតណ្ហារមែងក្តៅ គឺស្ទុះទៅក្នុងភពតូចភពធំ ។ សួរថា បុគ្គលនោះរមែងឆ្វេឆ្វាទៅដូចអ្វី ឆ្លើយថា ដូចស្វាប្រាថ្នាផ្លែឈើ លោតទៅក្នុងព្រៃដូច្នោះ អធិប្បាយថា ពានរ កាលប្រាថ្នាផ្លែឈើ រមែងលោតទៅក្នុងព្រៃចាប់នូវមែកឈើនោះៗ លែងនូវមែកឈើនោះហើយ ចាប់នូវមែកឈើដទៃ រមែងមិនដល់នូវភាពជាសត្វ ដែលបុគ្គលគួរពោលបានថា ស្វានោះមិនបាននូវមែក ទើបអង្គុយហើយយ៉ាងណា បុគ្គលដែលប្រព្រឹត្តទៅក្នុងគតិនៃ

តណ្ហាក៏ដូច្នោះដូចគ្នា ស្ទុះស្ទាទៅកាន់ភពតូចភពធំ រមែងមិនដល់នូវភាពជាបុគ្គល ដែលបុគ្គលណាម្នាក់គួរពោលបានថា បុគ្គលមិនបានអារម្មណ៍ហើយទើបដល់នូវការមិនប្រព្រឹត្តទៅតាមចំណង់តណ្ហា ។

បទថា **យំ** ជាដើម សេចក្ដីថា តណ្ហាដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ នេះឈ្មោះថា លាមក ព្រោះភាពជារបស់អាក្រក់ ដល់នូវការរាប់ថា **វិសត្តិកា** ព្រោះភាពដែលតណ្ហានោះ ជាធម្មជាតិបន្សាត់ទៅ គឺជាអ្នកជាប់ជំពាក់ក្នុងអារម្មណ៍ មានរូបជាដើម ដោយភាពជាអាហារលាយដោយថ្នាំពិស ដោយភាពដូចជាផ្កាលាយដោយពិស ដោយភាពដូចជាផ្លែឈើលាយដោយពិស ដោយភាពដូចជាគ្រឿងបរិភោគលាយដោយពិស រមែងគ្របសង្កត់បុគ្គលណា សេចក្ដីសោកទាំងឡាយ មានវដ្ដៈជាមូល រមែងចម្រើនក្រៃលែង ក្នុងខាងក្នុងរបស់បុគ្គលនោះ ដូចស្បូវភ្លាំងដែលភ្លៀងធ្លាក់រឿយៗ រមែងដុះលូតលាស់ក្នុងព្រៃ ដូច្នោះ ។

បទថា **ទុរច្ចយំ** ជាដើម សេចក្ដីថា បុគ្គលណារមែងសង្កត់ គឺរមែងគ្របសង្កត់តណ្ហានោះ គឺមានប្រការដែលខ្ញុំពោលហើយ ឈ្មោះថា លំបាកដែលបុគ្គលណាឆ្លងបាន ព្រោះជារបស់លំបាកនឹងឈានកន្លង គឺលំបាកលះបាន សេចក្ដីសោកទាំងឡាយ មានវដ្ដៈជាមូល រមែងធ្លាក់អំពីបុគ្គលនោះ គឺមិនតាំងនៅបាន ដូចតំណក់ទឹកធ្លាក់ទៅលើស្លឹកឈូក គឺលើស្លឹកបទុមមិនជាប់ ដូច្នោះ ។

ត្រើនបទថា **តំ វោ វទាមិ** គឺព្រោះហេតុនោះ តថាគតសូមពោលនឹង

អ្នកទាំងឡាយ ។

ពីរបទថា **ភទ្ទំ វោ** សេចក្តីថា បូរសេចក្តីចម្រើនមានដល់អ្នកទាំងឡាយ អធិប្បាយថា អ្នកទាំងឡាយកុំបីដល់នូវសេចក្តីវិនាស ដូចកបិលភិក្ខុនេះ ។

បទថា **មូលំ** ជាដើម សេចក្តីថា ចូរអ្នកទាំងឡាយជីកនូវឫសនៃតណ្ហា ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ នេះ ដោយញាណដែលសម្បយុត្តដោយអរហត្ត-មគ្គ សួរថា ជីកឫសនៃតណ្ហានោះដូចអ្វី ឆ្លើយថា ដូចបុគ្គលត្រូវការស្បូវភ្លាំង ជីកនូវស្បូវណ្តាសដូច្នោះ អធិប្បាយថា បុរសត្រូវការស្បូវភ្លាំង រមែងជីកស្បូវណ្តាសដោយចបធំ យ៉ាងណា ចូរអ្នកទាំងឡាយជីកនូវឫសនៃតណ្ហានោះចោល ដូច្នោះ ។

ពីរបាទគាថាថា **មា វោ នឡំវ សោតោវ មារោ ភញ្ជិ បុនប្បុនំ** សេចក្តីថា កិលេសមារ មរណមារ និងទេវបុត្តមារ ចូរកុំរុករានអ្នកទាំងឡាយរឿយៗ ដូចក្រសែទឹកហូរមកដោយកម្លាំង កាច់បំបាក់នូវដើមបបុសដែលកើតត្រង់មាត់ច្រាំង ដូច្នោះ ។

ក្នុងកាលចប់ទេសនា បុត្ររបស់អ្នកប្រមង់ទាំង ៥០០ ដល់នូវសេចក្តីសង្វេគ ប្រាថ្នាធ្វើនូវទីបំផុតនៃទុក្ខ បួសក្នុងសម្នាក់ព្រះសាស្តា ធ្វើទីបំផុតនៃទុក្ខក្នុងកាលមិនយូរឡើយ បានជាអ្នកមានការបរិភោគតែមួយ ដោយធម៌ជាគ្រឿងបរិភោគ គឺអនេញ្ជវិហារធម៌ និងសមាបត្តិធម៌ រួមជាមួយនឹងព្រះសាស្តា ដូច្នេះឯង ៕៚

**រឿងកបិលមច្ឆៈ ចប់**

# រឿង ជ្រូកញី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធជ្រូកញីស៊ីលាមកមួយក្បាល ត្រាស់ព្រះធម្មទេសនានេះថា **យថាបិ មូលេ** ជាដើម ។

បានឮថា ថ្ងៃមួយ ព្រះសាស្តាចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ទតឃើញជ្រូកមួយ ទើបទ្រង់ធ្វើការញញឹមឲ្យប្រាកដ កាលព្រះអង្គទ្រង់ញញឹម ព្រះអានន្ទត្ថេរ បានឃើញមណ្ឌលនៃទស្សនោភាសន៍ ដែលចេញអំពីព្រះឱស្ឋ ទើបទូលសួរហេតុនៃការញញឹមថា បពិត្រព្រះអង្គ អ្វីជាហេតុ អ្វីជាបច្ច័យនៃការធ្វើនូវការញញឹមឲ្យប្រាកដ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះអានន្ទថា អានន្ទ អ្នកឃើញជ្រូកញីនោះដែរឬទេ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ឃើញ ព្រះសាស្តាត្រាស់ថា ជ្រូកញីនោះបានកើតជាមេមាន់ នៅក្នុងជិតរោងឆាន់មួយកន្លែង ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមកកុសន្ធៈ មេមាន់នោះ ស្តាប់សំឡេងប្រកាសធម៌របស់ភិក្ខុ ដែលជាយោគាវចរមួយរូប ស្វាធ្យាយវិបស្សនាកម្មដ្ឋាន ចុតិចាកអត្តភាពនោះហើយ បានកើតក្នុងរាជត្រកូល ជារាជធីតា ព្រះនាមឧព្វរី ក្នុងកាលតមក ព្រះនាងយាងចូលទៅកាន់ទីសម្រាប់បន្ទោបង់ឧច្ចារៈ ទតឃើញពួកដង្កូវហើយ ញុំាងបុឡុវកសញ្ញាឲ្យកើតឡើងក្នុងទីនោះ បានបឋមជ្ឈានហើយ ព្រះនាងតាំងនៅក្នុងអត្តភាពនោះ ដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយកើតក្នុងព្រហ្មលោក កាលព្រះនាងចុតិអំពីអត្តភាពនោះហើយ ប្រឡូក

ប្រទូ្យំដោយអំណាចគតិ ទើបកើតក្នុងកំណើតជ្រូកក្នុងឥឡូវនេះ ។ តថាគតឃើញហេតុនេះ ទើបបានធ្វើការញញឹមឲ្យប្រាកដ ។

ភិក្ខុទាំងឡាយ មានអានន្ទត្ថេរជាប្រធាន ស្តាប់រឿងនោះហើយ ដល់នូវសេចក្តីសង្វេគ ។

ព្រះសាស្តា ទ្រង់ញុំាងសេចក្តីសង្វេគ ឲ្យកើតដល់ភិក្ខុទាំងនោះហើយ កាលទ្រង់ប្រកាសទោសនៃរាគតណ្ហា ប្រឋាប់ឈរក្នុងរវាងផ្លូវនោះ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។
យស្ស ឆត្តឹសតីសោតា មនាបស្សវនា ភុសា
មហា វហន្តិ ទុទ្ទិដ្ឋឹ សង្កប្បា រាគនិស្សិតា ។
សវន្តិ សព្វធី សោតា លតា ឧព្ភិជ្ជ តិដ្ឋតិ
តញ្ច ទិស្វា លតំ ជាតំ មូលំ បញ្ញាយ ឆិន្ទថ ។
សរិតានិ សិនេហិតានិ ច សោមនស្សានិ ភវន្តិ ជន្តុនោ
តេ សាតសិតា សុខេសិនោ តេ វេ ជាតិជរូបគា នរា ។
តសិណាយ បុរក្ខតា បជា បរិសប្បន្តិ សសោវ ពាធិតោ
សញ្ញោជនសង្គសត្តា ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។
តសិណាយ បុរក្ខតា បជា បរិសប្បន្តិ សសោវ ពាធិតោ
តស្មា តសិណំ វិនោទយេ ភិក្ខុ អាកង្ខី វិរាគមត្តនោ ។

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំមួនទេ ដើម

ឈើទុកជាកាត់ចោលហើយ ក៏តែងដុះឡើងទៀតបាន មាន ឧបមាដូចម្ដេចមិញ កាលបើតណ្ហានុស័យ បុគ្គលកម្ចាត់មិន ទាន់បានហើយ ទុក្ខ ( មានជាតិទុក្ខជាដើម ) នេះ ក៏តែង កើតរឿយៗ មានឧបមេយ្យដូច្នោះឯង ។

ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅក្នុងអារម្មណ៍ជាទីគាប់ចិត្ត ជា ធម្មជាតិក្លៀវក្លា មានដល់បុគ្គលណា តម្រិះទាំងឡាយដ៏ធំ ដែល អាស្រ័យនូវរាគៈ តែងនាំនូវទិដ្ឋិអាក្រក់របស់បុគ្គលនោះ ។ ខ្សែ តណ្ហាទាំងឡាយ តែងហូរទៅក្នុងអារម្មណ៍ទាំងពួង ដូចជា វល្លិ៍ ដែលបែកខ្នែងឡើងតាំងនៅដូច្នោះ បើអ្នកទាំងឡាយ ឃើញ តណ្ហាដូចជាវល្លិ៍នោះកើតឡើងហើយ ចូរកាត់ឫសចោលចេញ ដោយកាំបិត គឺបញ្ញា ។ សោមនស្សទាំងឡាយ ដែលផ្សាយទៅ ហើយផង ដែលប្រព្រឹត្តទៅដោយសេចក្ដីស្រឡាញ់ផង រមែង មានដល់សត្វ ពួកសត្វនោះជា អ្នកអាស្រ័យនូវសេចក្ដីរីករាយ ជាអ្នកស្វែងរកសេចក្ដីសុខ នរជនទាំងឡាយនោះឯង តែងឈម ទៅរកជាតិ និងជរា ។ ពួកសត្វដែលតណ្ហា ជាទីញុំាងសត្វឲ្យ តក់ស្លុតក្រុងទុកហើយ តែងរន្ធត់ ដូចទន្សាយដែលព្រានទាក់ បានហើយ ដូច្នោះ ពួកសត្វដែលជាប់ក្នុងសំយោជនៈ និង សង្គធម៌ ( ធម៌ជាគ្រឿងជំពាក់ ) តែងដល់នូវសេចក្ដីទុក្ខ រឿយៗ អស់កាលជាអង្វែង ពួកសត្វដែលតណ្ហាជាទីញុំាងសត្វ

ឲ្យតក់ស្លុតក្រុងទុកហើយ តែងវន្ទត់ ដូចទន្សាយ ដែលនាយព្រានទាក់បានហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌ជាគ្រឿងប្រាសចាករាគៈដើម្បីខ្លួន គប្បីបន្ទោបង់តណ្ហា ដែលជាគ្រឿងតក់ស្លុតចោលចេញ ។

# សេចក្តីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **មូលេ** ជាដើម សេចក្ដីថា កាលឫសទាំង ៥ របស់ដើមឈើណា ដែលចាកទៅក្នុងទិសទាំង ៤ និងចាកចុះទៅក្រោម ឈ្មោះថា មិនមានអន្តរាយ ព្រោះអន្តរាយណាមួយ បណ្ដាអន្តរាយ មានការកាប់ និងការចោះ ឈ្មោះថា មាំទាំ ព្រោះដល់នូវភាពជារបស់មាំទាំ ដើមឈើនោះ សូម្បីបុគ្គលដកហើយទៅខាងលើ រមែងដុះឡើងបានទៀតនោះឯង ដោយអំណាចមែកជំតូច យ៉ាងណា ទុក្ខនេះ មានជាតិទុក្ខជាដើម កាលអនុស័យមាន ការដេកត្រាំនៃតណ្ហាដែលប្រព្រឹត្តទៅតាមទ្វារ ៦ ដែលអរហត្តមគ្គញាណមិនទាន់កម្ចាត់ គឺមិនទាន់កាត់ផ្ដាច់ហើយ រមែងកើតរឿយៗទៅក្នុងភពនោះៗ បាន ដូច្នោះឯង ។

បទថា **យស្ស** ជាដើម សេចក្តីថា តណ្ហាប្រកបដោយក្រសែ ៣៦ ដោយអំណាចនៃតណ្ហាវិចរិតទាំងនេះ គឺតណ្ហាវិចរិត អាស្រ័យអាយតនៈខាងក្នុង ១៨ តណ្ហាវិចរិតអាស្រ័យអាយតនៈខាងក្រៅ ១៨ ដោយប្រការដូច្នេះ ឈ្មោះថា ហូរទៅក្នុងអារម្មណ៍ដែលជាប់ចិត្ត ព្រោះអត្ថវិគ្គហៈថា រមែងហូរទៅ គឺប្រព្រឹត្តទៅក្នុងអារម្មណ៍ មានរូបជាដើម ជាធម្មជាតិក្លៀវក្លា គឺមានកម្លាំង តែង

មានដល់បុគ្គលណា ការត្រិះរិះទាំងឡាយ ឈ្មោះថា ជាធម្មជាតិធំ ព្រោះភាពជារបស់ធំ ដោយកើតឡើងរឿយៗ មិនអាស្រ័យឈាន ឬវិបស្សនា អាស្រ័យរាគៈ រមែងនាំបុគ្គលនោះ ដែលឈ្មោះថាមានទិដ្ឋិអាក្រក់ ព្រោះភាពជាបុគ្គលមានញាណវិបត្តិ ។

បាទព្រះគាថាថា **សវន្តិ សព្វធិ សោតា** សេចក្តីថា ក្រសែតណ្ហាទាំងនេះ ឈ្មោះថា រមែងហូរទៅក្នុងអារម្មណ៍ទាំងពួង ព្រោះហូរទៅក្នុងអារម្មណ៍ទាំងពួង មានរូបជាដើម ដោយអំណាចនៃចក្ខុទ្វារជាដើម ឬព្រោះតណ្ហាទាំងអស់ គឺរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ហូរទៅក្នុងភពទាំងពួង ។

បទថា **លតា** សេចក្តីថា តណ្ហា ឈ្មោះថា **លតា** ព្រោះអត្ថវិគ្គហៈថា ដូចជាវល្លិ៍ ព្រោះអត្ថថាជាគ្រឿងរួបរឹត និងដោយអត្ថថា ជាគ្រឿងចង ។

ពីរបទថា **ឧព្ភិជ្ជ តិដ្ឋតិ** សេចក្តីថា តណ្ហាដូចវល្លិ៍កើតឡើងដោយទ្វារ ៦ ហើយ រមែងតាំងនៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ។

ពីរបទថា **តញ្ច ទិស្វា** សេចក្តីថា បើអ្នកឃើញតណ្ហាដូចវល្លិ៍នោះ ដោយអំណាចដែលតណ្ហានោះកើតហើយថា តណ្ហានេះ កាលនឹងកើត រមែងកើតឡើងក្នុងបិយរូប និងសាតរូបនេះ ។

បទថា **បញ្ញាយ** សេចក្តីថា អ្នកទាំងឡាយ ចូរកាត់ត្រង់ឫសដោយមគ្គបញ្ញា ដូចបុគ្គលកាត់នូវវល្លិ៍ដែលកើតក្នុងព្រៃ ដោយកាំបិត ដូច្នោះ ។

បទថា **សរិតានិ** គឺផ្សាយទៅ បានដល់ ជ្រួតជ្រាបទៅ ។

បទថា **សិនេហិតានិ ច** សេចក្តីថា នឹងប្រឡាក់ដោយតណ្ហា ដូចជ័រ ដោយអំណាចតណ្ហាសិនេហៈ ដែលប្រព្រឹត្តទៅក្នុងបរិក្ខារ មានចីវរជាដើម អធិប្បាយថា ដែលជ័រ គឺតណ្ហាប្រកលាបហើយ ។

បទថា **សោមនស្សានិ** សេចក្តីថា សោមនស្សទាំងឡាយបែបនោះ រមែងមានដល់សត្វ ដែលប្រព្រឹត្តទៅក្នុងអំណាចតណ្ហា ។

ពីរបទថា **តេ សាតសិតា** សេចក្តីថា បុគ្គលទាំងនោះ គឺដែលប្រព្រឹត្តទៅក្នុងអំណាចនៃតណ្ហា ដែលជាបុគ្គលអាស្រ័យសេចក្តីសុខ គឺអាស្រ័យសេចក្តីសុខនោះឯង ទើបជាអ្នកស្វែងរកសេចក្តីសុខ គឺជាអ្នកស្វែងរកសេចក្តីសុខ ។

បទថា **តេ វេ** ជាដើម សេចក្តីថា ពួកនរៈបែបនេះ រមែងចូលដល់ការកើត ការចាស់ ការឈឺ និងការស្លាប់ពិត ដូច្នោះ ទើបជាបុគ្គលឈ្មោះថា ចូលដល់ជាតិ និងជរា ។

បទថា **បជា** ជាដើម សេចក្តីថា សត្វទាំងនេះ ជាបុគ្គលដែលតណ្ហា ដែលដល់នូវការរាប់ថា **តសិណា** គឺការបម្រះនទៀល ព្រោះធ្វើនូវការតក់ស្លុត ចោមរោម គឺចោមរោមហើយ ។

បទថា **ពាធិតោ** សេចក្តីថា សត្វទាំងនោះ រមែងរន្ធត់ គឺតក់ស្លុត ដូចទន្សាយដែលជាប់អន្ទាក់ព្រានក្នុងព្រៃ ដូច្នោះ ។

បទថា **សញ្ញោជនសង្គសត្តា** សេចក្តីថា សត្វទាំងឡាយជាបុគ្គល ដែលសំយោជនៈ ១០ យ៉ាង និងកិលេសជាគ្រឿងចង គឺភគៈជាដើមចង ហើយ ឬជាបុគ្គលជាប់ហើយក្នុងសំយោជនៈជាដើមនោះ ។

បទថា **ចិរាយ** សេចក្តីថា សត្វទាំងឡាយរមែងចូលដល់នូវទុក្ខ មានជាតិជាដើមរឿយៗ ទៅ អស់កាលយូរ គឺអស់កាលវែង ។

បទថា **តស្មា** ជាដើម សេចក្តីថា ព្រោះសត្វទាំងឡាយដែលតណ្ហាធ្វើនូវសេចក្តីតក់ស្លុតចោមរោម គឺរួបរឹតហើយ ដូច្នោះ កាលភិក្ខុប្រាថ្នានូវធម៌ដែលអស់នូវតម្រេក គឺព្រះនិព្វាន ដែលជាទីទៅប្រាសចាកកិលេស មានរាគៈជាដើមដើម្បីខ្លួន គប្បីបន្ទោបង់ គឺគប្បីបណ្តេញចេញនូវតណ្ហា ដែលធ្វើនូវការតក់ស្លុតនោះ ដោយអំណាចអរហត្តមគ្គនោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

មេជ្រូកនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងរាជត្រកូល ក្នុងសុវណ្ណភូមិ ចុតិចាកអត្តភាពនោះហើយ កើតក្នុងក្រុងពារាណសីដូច្នោះឯង ។ ចុតិចាកអត្តភាពនោះហើយ កើតក្នុងផ្ទះអ្នកជំនួញសេះ ត្រង់កំពង់សុប្បារកៈ ចុតិចាកអត្តភាពនោះហើយ កើតក្នុងផ្ទះរបស់នាយទូក ត្រង់កំពង់គាវិរៈ ចុតិចាកអត្តភាពនោះហើយ កើតក្នុងផ្ទះរបស់ឥស្សរជនក្នុងក្រុងអនុរាធបុរី ចុតិចាកអត្តភាពនោះហើយ កើតជាធីតាក្នុងផ្ទះរបស់កុដុម្ពិកៈឈ្មោះសុមនៈ ក្នុងភេក្កន្តគ្រាម ក្នុងទិសទក្សិណរបស់ក្រុងនោះហើយ មានឈ្មោះថាសុមនា តាមឈ្មោះកុដុម្ពិកៈនោះ ។ បន្ទាប់មកឪពុករបស់នាង កាលជនទាំងឡាយលះបង់ស្រុកនោះហើយ បានទៅកាន់ដែនទីឃវាបិ ក្នុងស្រុកឈ្មោះមហាមុនីគ្រាម ។ អមាត្យរបស់ព្រះបាទទុដ្ឋគាមិនី ឈ្មោះលកុណ្ឋកអតិម្ពរៈ ទៅត្រង់ស្រុកនោះ

ដោយករណីយកិច្ចឯណានីមួយ ឃើញនាងហើយ ធ្វើការមង្គលយ៉ាងធំ នាំនាងទៅកាន់ស្រុកមហាបុណ្ណគ្រាមហើយ ។ គ្រានោះ ព្រះមហាអតុលត្ថេរ ជាអ្នកនៅក្នុងវិហារឈ្មោះ កោដិបព្វតៈ ត្រាច់ទៅក្នុងស្រុកនោះដើម្បីបិណ្ឌបាត ឈរត្រង់ទ្វារផ្ទះរបស់នាង ឃើញនាងហើយ ទើបពោលនឹងភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ ជ្រុកញីដល់នូវភាពជាភរិយារបស់អមាត្យ ឈ្មោះលកុណ្ឌកអតិម្ពរៈហើយ ឱ ! គួរអស្ចារ្យហ្ន៎ នាងស្តាប់ពាក្យនោះហើយ រឭកជាតិបាន ត្រឡប់បាននូវញាណ ដែលជាហេតុរឭកជាតិក្នុងខណៈនោះឯង នាងមានសេចក្តីសង្វេគកើតឡើងហើយ អង្វរស្វាមីបួសក្នុងសម្នាក់ព្រះថេរី ដែលប្រកបដោយកម្លាំង ៥ ដោយឥស្សរិយយសដ៏ធំ បានស្តាប់កថាពណ៌នាមហាសតិបដ្ឋានសូត្រ ក្នុងតិស្សមហាវិហារហើយ តាំងនៅក្នុងសោតាបត្តិផល ។ ក្រោយមក កាលព្រះបាទទុដ្ឋគាមិនីទ្រង់បង្ក្រាបទមិឡបានហើយ ព្រះនាងម្ចាស់សុមនាថេរីបានទៅកាន់ស្រុកភេក្កន្តគ្រាម ដែលជាលំនៅរបស់មាតាបិតានោះឯង នៅក្នុងស្រុកនោះ ស្តាប់អាសីវិសូបមសូត្រ ក្នុងកាលកមហាវិហារ សម្រេចអរហត្តហើយ ។

ក្នុងថ្ងៃបរិនិព្វាន នាងត្រូវពួកភិក្ខុនីសាកសួរហើយ បាននិទានប្រវត្តិទាំងអស់នេះយ៉ាងនេះឯងដល់ភិក្ខុនីសង្ឃ ហើយសន្ទនាជាមួយព្រះមហាតិស្សត្ថេរ ដែលពោលបទនៃធម៌ ដែលមានប្រក្រតីនៅក្នុងមណ្ឌលារាម ក្នុងកណ្តាលភិក្ខុនីសង្ឃដែលប្រជុំគ្នាហើយពោលថា ក្នុងកាលមុនខ្ញុំចុតិអំពីកំណើតមនុស្សហើយ កើតជាមេមាន់ ដល់នូវការកាត់ក្បាល អំពីសម្នាក់របស់ស្ទាំងក្នុងអត្តភាពនោះ

ហើយ ទៅកើតក្នុងក្រុងរាជគ្រឹះ ហើយបួសក្នុងសម្នាក់បរិព្វាជិកាទាំងឡាយ ហើយកើតក្នុងបឋមជ្ឈានភូមិ ចុតិចាកអត្តភាពនោះហើយ កើតក្នុងត្រកូលសេដ្ឋី ក្នុងកាលមិនយូរប៉ុន្មាន ចុតិហើយ ទៅកើតក្នុងកំណើតជ្រូក ចុតិអំពីអត្តភាពនោះហើយ ទៅកាន់សុវណ្ណភូមិ ចុតិចាកអត្តភាពនោះហើយ ទៅកាន់ក្រុងពារាណសី ចុតិចាកអត្តភាពនោះហើយ ទៅកាន់កំពង់ឈ្មោះសុប្បារកៈ ចុតិចាកអត្តភាពនោះហើយ ទៅកាន់កំពង់គាវិរៈ ចុតិចាកអត្តភាពនោះហើយ ទៅកាន់ក្រុងអនុរាធបុរី ចុតិចាកអត្តភាពនោះហើយ ទៅកាន់ស្រុកភេក្កន្តគ្រាម ខ្ញុំបានដល់អត្តភាព ១៣ ដែលខ្ពស់ និងទាបយ៉ាងនេះ ដោយប្រការដូច្នេះ ឥឡូវនេះ កើតក្នុងអត្តភាពឧក្រិដ្ឋហើយ សូមអ្នកទាំងឡាយញុំាងធម៌ជាកុសលទាំងឡាយ ឲ្យដល់ព្រម ដោយសេចក្ដីមិនប្រមាទចុះ ដូច្នេះហើយ ញុំាងបរិស័ទ ៤ ឲ្យសង្វេគហើយ បរិនិព្វាន ដូច្នេះ ។

**រឿងជ្រូកញី ចប់**

# រឿងវិព្ភន្តកភិក្ខុ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធវិព្ភន្តកភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **យោ និព្វនដ្ឋោ** ជាដើម ។

បានឮថា ភិក្ខុមួយរូប ជាសទ្ធិវិហារិករបស់ព្រះមហាកស្សបត្ថេរ ញ៉ាំងឈាន ៤ ឲ្យកើតឡើងហើយ ឃើញរូបារម្មណ៍ជាវិសភាគៈក្នុងផ្ទះរបស់ជាងមាស ដែលជាអ៊ំរបស់ខ្លួន មានចិត្តប្រតិព័ទ្ធក្នុងរូបារម្មណ៍នោះ សឹកហើយ ។

បន្ទាប់មក ព្រោះភាពជាអ្នកខ្ជិលច្រអូស ទើបពួកមនុស្សដេញបុគ្គលនោះ ដែលមិនប្រាថ្នានឹងធ្វើការងារចេញអំពីផ្ទះ គាត់ត្រាច់ចិញ្ចឹមជីវិត ដោយធ្វើចោរកម្ម ព្រោះសេពគប់ជាមួយមិត្តអាក្រក់ ។

ថ្ងៃមួយ ពួករាជបុរសចាប់គាត់បានហើយ ចងស្លាបសេកយ៉ាងណែន វាយដោយផ្ដៅក្នុងផ្លូវបែកជា ៤ ហើយនាំទៅកាន់ត្រឡែងកែង ។

ព្រះថេរៈចូលទៅបិណ្ឌបាត ឃើញបុរសនោះត្រូវពួករាជបុរសនាំបុរសនោះទៅតាមទ្វារទិសខាងត្បូង ទើបសូមឲ្យពួករាជបុរសបន្ធូរចំណងពោលថា ចូរអ្នករឭកដល់កម្មដ្ឋាន ដែលអ្នកធ្លាប់សន្សំហើយក្នុងកាលមុនចុះ គាត់មានសតិឡើងព្រោះឱវាទនោះហើយ ញ៉ាំងចតុត្ថជ្ឈានឲ្យកើតឡើងជាថ្មី ។

លំដាប់នោះ ពួករាជបុរសនាំចូលទៅកាន់ត្រឡែងកែង ឲ្យបុរសនោះដេកផ្ងារលើលំពែង ដោយគិតថា ពួកយើងនឹងសម្លាប់ បុរសនោះមិនខ្លាច មិនតក់ស្លុតឡើយ ។

លំដាប់នោះ មនុស្សទាំងឡាយដែលឈរក្នុងទិសាភាគៈនោះៗ សូម្បី

នាគ្រឿងប្រហារទាំងឡាយ មានដាវ លំពែង និងច្បូកជាដើមដល់បុរសនោះ ឃើញគាត់មិនតក់ស្លុតពោលថា អ្នកដ៏ចម្រើន ចូរពួកអ្នកមើលបុរសនោះចុះ គេមិនញាប់ញ័រ មិនតក់ស្លុតក្នុងកណ្ដាលនៃបុរសដែលមានអាវុធក្នុងដៃសូម្បីច្រើនរយនាក់ ឱ ! គួរអស្ចារ្យពិត ដូច្នេះហើយ កើតនូវការអស្ចារ្យ និងចម្លែកក្នុងចិត្ត ហើយក៏បន្លឺសំឡេងតគ្នា ហើយក្រាបទូលរឿយនោះដល់ព្រះរាជា ។

ព្រះរាជាស្ដាប់ហេតុនោះហើយត្រាស់ថា ចូរពួកអ្នកដោះលែងបុរសនេះចុះ ដូច្នេះហើយ យាងទៅកាន់សម្នាក់ព្រះសាស្ដាក្រាបទូលសេចក្ដីនោះហើយ ព្រះសាស្ដា ទ្រង់បញ្ចេញព្រះឱភាសទ៍ទៅហើយ កាលទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យោ និព្វនថោ វនាធិមុត្តោ វនមុត្តោ វនមេវ ធាវតិ**
**តំ បុគ្គលមេវ បស្សថ មុត្តោ ពន្ធនមេវ ធាវតិ ។**

បុគ្គលណា មិនមានអាល័យក្នុងគិហិភាព ដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តចុះស៊ប់ក្នុងព្រៃ គឺតបធម៌ ជាអ្នករួចស្រឡះចាកព្រៃ គឺតណ្ហាហើយ ស្ទុះទៅរកព្រៃ គឺតណ្ហាវិញ ចូរអ្នកទាំងឡាយ មើលបុគ្គលនោះឯង បុគ្គលនោះ រួចចាកចំណង គឺឃរាវាសហើយ ស្ទុះទៅរកចំណង គឺឃរាវាសវិញ ។

# សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា បុគ្គលណា ឈ្មោះថា មានអាល័យដូចពួកឈើទាំងឡាយ ដែលតាំងនៅក្នុងព្រៃចេញហើយ ព្រោះភាពដែលខ្ទួនលះនូវពួកឈើទាំងឡាយដែលតាំងនៅក្នុងព្រៃ ពោល គឺអាល័យក្នុងភាពជាគ្រហស្ថ ហើយបួសបង្អោនទៅក្នុងព្រៃ គឺតបះ ពោល គឺវិហារធម៌ ជាអ្នកផុតចាកព្រៃ គឺតណ្ហា ដែលចាត់ជាគ្រឿងចង គឺការគ្រប់គ្រងផ្ទះហើយ ស្ទុះទៅរកព្រៃ គឺតណ្ហានោះឯង ដែលជាគ្រឿងចង គឺការគ្រប់គ្រងផ្ទះនោះទៀត ចូរអ្នកទាំងឡាយមើលបុគ្គលនោះយ៉ាងនោះ បុគ្គលនោះផុតចាកចំណង គឺការគ្រប់គ្រងផ្ទះហើយ នៅស្ទុះទៅកាន់ចំណង គឺការគ្រប់គ្រងផ្ទះទៀតនោះឯង ។

បុរសនោះ អង្គុយស្តាប់ធម៌ទេសនានេះ នៅលើលំពែងក្នុងរវាងពួករាជបុរសនោះឯង ផ្តើមតាំងនូវការកើតឡើង និងការអស់ទៅ សូន្យទៅ លើកចិត្តឡើងកាន់ត្រៃលក្ខណ៍ ពិចារណាសង្ខារទាំងឡាយ សម្រេចសោតាបត្តិផលហើយ សោយសុខដែលកើតអំពីសមាបត្តិ ហោះទៅកាន់អាកាសមកកាន់សម្នាក់ព្រះសាស្តាថ្វាយបង្គំហើយបួស បានសម្រេចអរហត្ត ក្នុងកណ្តាលបរិស័ទ មួយអន្លើដោយព្រះរាជានោះឯង ដូច្នេះ ។

**រឿងវិព្ភន្តកភិក្ខុ ចប់**

# រឿង ពន្ធនាគារ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពន្ធនាគារ ត្រាស់ព្រះធម្មទេសនានេះថា **ន តំ ទឡ្ហំ** ជាដើម ។

បានឮថា ក្នុងសម័យមួយ ពួករាជបុរសនាំពួកចោរដែលកាត់ទី-ត ប្លន់ស្កាត់ផ្លូវ និងសម្លាប់មនុស្សជាច្រើន ទូលស្នើដល់ព្រះបាទកោសលហើយ ។ ព្រះរាជាត្រាស់ឲ្យចងចោរទាំងនោះ ដោយគ្រឿងចង គឺឃ្នាង គ្រឿងចង គឺខ្សែ គ្រឿងចង គឺច្រវាក់ជើងទាំងឡាយ ។ ពួកភិក្ខុអ្នកជនបទមានប្រមាណ ៣០ រូប ប្រាថ្នានឹងគាល់ព្រះសាស្តា មកថ្វាយបង្គំហើយ ក្នុងថ្ងៃស្អែកឡើងត្រាច់ទៅក្នុងក្រុងសាវត្ថីដើម្បីបិណ្ឌបាត ទៅដល់គុក ឃើញចោរទាំងនោះត្រឡប់អំពីបិណ្ឌបាតហើយ ចូលទៅគាល់ព្រះតថាគតក្នុងពេលល្ងាច ក្រាបទូលសួរថា បពិត្រព្រះអង្គ ថ្ងៃនេះ ពួកខ្ញុំព្រះអង្គត្រាច់បិណ្ឌបាត ឃើញចោរជាច្រើនក្នុងគុក ត្រូវចងដោយចំណង មានឃ្នាងជាដើម សោយទុក្ខច្រើន ។ ពួកចោរមិនអាចកាត់ចំណងទាំងនោះគេចទៅបាន បពិត្រព្រះអង្គ ឈ្មោះថាចំណងប្រភេទដទៃ ដែលមាំទាំជាងចំណងទាំងនោះ មានឬហ្ន៎ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចំណងនោះមិនឈ្មោះថាជាចំណងឡើយ ឯគ្រឿងចង គឺកិលេស ពោល គឺតណ្ហា ក្នុងសវិញ្ញាណក-ទ្រព្យ និងអវិញ្ញាណកទ្រព្យទាំងឡាយ មានទ្រព្យ គឺស្រូវ កូន ប្រពន្ធជាដើម ជាគ្រឿងចងដែលមាំទាំជាងគ្រឿងចង គឺឃ្នាងជាដើមទាំងនោះមួយរយដង មួយពាន់ដង មួយសែនដង តែបុរាណបណ្ឌិតទាំងឡាយ កាត់គ្រឿងចងនោះ

ដែលធំៗ កាត់បានដោយលំបាក ដោយប្រការដូច្នេះហើយ ចូលកាន់ព្រៃហិមពាន្ត បួស ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វកើតហើយ ក្នុងត្រកូលគហបតីក្រីក្រមួយ កាលព្រះពោធិសត្វចម្រើនវ័យហើយ បិតាបានធ្វើកាលកិរិយាហើយ ព្រះពោធិសត្វធ្វើការស៊ីឈ្នួលចិញ្ចឹមមាតា ។ បន្ទាប់មក មាតាធ្វើនាងកុលធីតាម្នាក់ទុកក្នុងផ្ទះ ដើម្បីព្រះពោធិសត្វនោះ ដែលមិនប្រាថ្នាដោយភរិយា ក្នុងកាលបន្តមក មាតាធ្វើកាលកិរិយាហើយ ។ ចំណែកភរិយារបស់ព្រះពោធិសត្វនោះ មានទម្ងន់ហើយ ។ ព្រះពោធិសត្វមិនជ្រាបថាគភ៌តាំងឡើងឡើយ ទើបពោលថា នែនាង ចូរនាងធ្វើការស៊ីឈ្នួលចិញ្ចឹមជីវិតចុះ ខ្ញុំនឹងបួស ។ ភរិយាពោលថា នែអ្នក គភ៌កើតឡើងដល់ខ្ញុំមិនមែនឬ ចាំខ្ញុំប្រសូតហើយ អ្នកឃើញទារកហើយសឹមបួស ព្រះពោធិសត្វទទួលថា សាធុ ក្នុងកាលនាងប្រសូតហើយ ទើបលាថា នែនាង នាងប្រសូតបុត្រដោយសួស្តីហើយ ឥឡូវនេះខ្ញុំនឹងបួស ពេលនោះនាងពោលនឹងព្រះពោធិសត្វថា សូមអ្នកបង្អង់ចាំសិន ទម្រាំកូនតូចរបស់អ្នកផ្តាច់ដោះហើយក៏មានទម្ងន់ទៀត ។

ព្រះពោធិសត្វត្រិះរិះថា អញមិនអាចឲ្យស្រីនេះយល់ព្រមបាន អញនឹងមិនប្រាប់ដល់នាង ទើបគេចទៅបួសមិនប្រាប់ដល់ភរិយាឡើយ ក្រោកឡើងក្នុងពេលរាត្រី គេចទៅហើយ ។

គ្រានោះ អ្នករក្សាព្រះនគរចាប់ព្រះពោធិសត្វហើយ ព្រះពោធិសត្វ

ពោលថា នែអ្នក ខ្ញុំឈ្មោះថាជាអ្នកចិញ្ចឹមមាតា សូមអ្នកទាំងឡាយលែងខ្ញុំចុះ ។ ពួករាជបុរសលែងខ្ញុំហើយ ស្នាក់នៅក្នុងទីមួយកន្លែង ហើយចូលទៅកាន់ព្រៃហិមពាន្ត បួសជាឥសី ញុំាងអភិញ្ញា និងសមាបត្តិឲ្យកើតហើយជាអ្នកលេងឈាន ។ លោកនៅក្នុងទីនោះឯងបន្លឺឧទានថា ចំណង គឺបុត្រ និងភរិយា ចំណង គឺកិលេស ដែលបុគ្គលកាត់បានដោយលំបាកបែបនោះ ខ្ញុំកាត់ផ្តាច់បានហើយ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ កាលទ្រង់ប្រកាសឧទានដែលព្រះពោធិសត្វនោះបន្លឺហើយ បានត្រាស់ព្រះគាថាទាំងនេះថា

**ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា យទាយសំ ទារុជំ ពព្វជញ្ច ។**
**សារត្តរត្តា មណិកុណ្ឌលេសុ បុត្តេសុ ទារេសុ ច យា អបេក្ខា**
**ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា ឱហារិនំ សិថិលំ ទុប្បមុញ្ចំ**
**ឯតំបិ ឆេត្វាន បរិព្វជន្តិ អនបេក្ខិនោ កាមសុខំ បហាយ ។**

ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅយាបូងក្តី អ្នកប្រាជ្ញមិនហៅចំណងនោះ ថាជាចំណងមាំមួនឡើយ ។ ពួកជនណា ត្រេកអរក្រៃពេកក្នុងកែវមណី និងកុណ្ឌលទាំងឡាយក្តី សេចក្តីអាឡោះអាល័យ កូន និងប្រពន្ធទាំងឡាយក្តី អ្នកប្រាជ្ញទាំងឡាយហៅសេចក្តីត្រេកអរ និងសេចក្តីអាឡោះអាល័យនោះថា ជាចំណងមាំមួន ជាចំណងនាំចុះ ( ទាញសត្វទម្លាក់ទៅក្នុងអបាយ ) ជាចំណងធូរទេ ប៉ុន្តែ សត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញទាំង-

ឡាយកាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់កាមសុខហើយ ចេញបួស ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ធីរា** ជាដើម សេចក្តីថា បុរសដែលជាបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម មិនពោលគ្រឿងចងដែលកើតអំពីដែកពោល គឺច្រវាក់ជើង ឈ្មោះថា កើតអំពីដែក ដែលកើតអំពីឈើ ពោលគឺឃ្នាងខ្នោះ និងចំណង គឺខ្សែ ដែលគេយកស្មៅឃាប្លង ឬវត្ថុដទៃ មានព្រាលជាដើម វេញធ្វើជាខ្សែថា ជារបស់មាំទាំឡើយ ព្រោះភាពជាចំណងដែលបុគ្គលអាចកាត់ដោយសស្ត្រាទាំងឡាយ មានដាវជាដើមបាន ។

បទថា **សារត្តរត្តា** បានដល់ ជាអ្នកត្រេកត្រអាលហើយ អធិប្បាយថា ជាអ្នកត្រេកអរដោយរាគៈខ្លាំងក្លា ។

បទថា **មណិកុណ្ឌលេសុ** គឺក្នុងកែវមណី និងកុណ្ឌលទាំងឡាយ ម្យ៉ាងទៀត ក្នុងកុណ្ឌលទាំងឡាយដែលវិចិត្រដោយកែវមណី ។

បទថា **ឧត្តំ** សេចក្តីថា តម្រេកណារបស់ជនទាំងឡាយដែលត្រេកអរក្រៃលែងក្នុងកែវមណី និងកុណ្ឌលទាំងឡាយនោះឯង និងការជាប់ជំពាក់ គឺការចង់បានក្នុងបុត្រ និងភរិយាណា បុរសដែលជាបណ្ឌិតទាំងឡាយ រមែងពោលតម្រេក និងការជាប់ជំពាក់នោះ ដែលជាគ្រឿងចងសម្រេចដោយកិលេសថា ជារបស់មាំទាំ ។

បទថា **ឱហារិនំ** សេចក្តីថា ឈ្មោះថា មានប្រក្រតីទាញទម្លាក់ចុះ

ព្រោះរមែងទាញចុះ គឺនាំទៅកាន់ទីទាប ព្រោះទាញមកហើយ ឲ្យធ្លាក់ទៅក្នុងអបាយ ៤ ។

បទថា **សិថិលំ** សេចក្ដីថា ឈ្មោះថា ធូរថយ ព្រោះមិនមុតស្បែកនិងសាច់ គឺរមែងមិននាំលោហិតចេញក្នុងទីដែលត្រូវចង បានដល់ មិនឲ្យដឹងសូម្បីភាពជាចំណង រមែងឲ្យធ្វើការងារទាំងឡាយក្នុងទីទាំងឡាយ មានការងារលើគោក និងការងារក្នុងទឹកជាដើមបាន ។

បទថា **ទុប្បមុញ្ចំ** សេចក្ដីថា ឈ្មោះថា ដោះបានដោយលំបាក ព្រោះគ្រឿងចង គឺកិលេស ដែលកើតឡើងដោយអំណាចនៃការលោភ សូម្បីត្រឹមតែម្ដង រមែងជាកិលេសជាតិដែលបុគ្គលដោះបានដោយលំបាក ដូចអណ្ដើកដោះអំពីទីដែលចង បានលំបាក ដូច្នោះ ។

ពីរបទថា **ឯតំបិ ឆេត្វាន** សេចក្ដីថា អ្នកប្រាជ្ញទាំងឡាយ កាត់គ្រឿងចង គឺកិលេសនោះ ដែលមាំយ៉ាងនោះដោយព្រះខ័ន គឺញាណ ជាអ្នកអស់នូវការជាប់ជំពាក់ លះកាមសុខហើយ វៀរដោយជុំវិញ គឺចៀសចេញ អធិប្បាយថា បួស ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿងពន្ធនាគារ ចប់**

# រឿង ព្រះនាងខេមា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះអគ្គមហេសីរបស់ព្រះបាទពិម្ពិសារ ព្រះនាមខេមា ត្រាស់ព្រះធម្មទេសនានេះថា **យេ រាគរត្តា** ជាដើម ។

បានឮមកថា ព្រះនាងខេមានោះ តាំងនូវសេចក្តីប្រាថ្នាទៀបបាទមូលរបស់ព្រះបទុមុត្តរសម្ពុទ្ធ បានជាអ្នកមានរូបរាងស្អាត គួរជ្រះថ្លាពន់ពេក ។ ព្រះនាងបានឮថា ព្រះសាស្តាទ្រង់តិះដៀលទោសរបស់រូប ទើបមិនប្រាថ្នាទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ព្រះរាជាទ្រង់ជ្រាបភាពដែលអគ្គមហេសីនោះស្រវឹងក្នុងរូប ទើបត្រាស់ឲ្យពួកអ្នកកវីតែងចម្រៀង ពណ៌នាសរសើរវត្តវេឡុវ័ន ហើយក៏ត្រាស់ឲ្យព្រះរាជទានដល់ពួកអ្នករបាំជាដើម កាលអ្នករបាំទាំងនោះកំពុងច្រៀង ព្រះនាងស្តាប់ហើយ វត្តវេឡុវ័នបានហាក់ដូចមិនធ្លាប់ទតនិងទ្រង់ស្តាប់ហើយ ។ ព្រះនាងត្រាស់សួរថា ពួកអ្នកច្រៀងច្រើនដល់ឧទ្យានណា កាលអ្នកចម្រៀងទូលថា បពិត្រព្រះទេវី សំដៅដល់ឧទ្យានវេឡុវ័នរបស់ព្រះរាជា ព្រះនាងក៏ប្រាថ្នាយាងទៅព្រះរាជឧទ្យាន ។ ព្រះសាស្តា ទ្រង់ជ្រាបការយាងមករបស់ព្រះនាង កាលប្រថាប់គង់សម្តែងធម៌ ក្នុងកណ្តាលបរិស័ទ ទើបទ្រង់និម្មិតស្រីរូបស្អាត ឈរកាន់ផ្លិតស្ទឹកត្នោតបក់ក្បែរព្រះអង្គ ។

ឯព្រះនាងខេមាទេវីយាងទៅ ទតឃើញស្រីនោះ ទើបព្រះតម្រិះថា ជនទាំងឡាយនិយាយថា ព្រះសម្មាសម្ពុទ្ធត្រាស់ទោសរបស់រូប ស្រីនេះឈរបក់ផ្លិត ក្នុងសម្នាក់របស់ព្រះអង្គ ។ អញមិនចូលដល់ចំណែកមួយចម្រៀក

របស់ស្រីនេះ រូបស្រីនេះអញមិនធ្លាប់ឃើញ ជនទាំងឡាយប្រហែលពោលទោសព្រះសាស្តាដោយពាក្យមិនពិត ដូច្នេះហើយ មិនបានដាក់ចិត្តដល់ព្រះតម្រាស់របស់ព្រះតថាគត បានប្រឋាប់ឈរទតមើលស្រីនោះឯង ។

ព្រះសាស្តា ទ្រង់ជ្រាបភាពដែលព្រះនាងមានមានះខ្លាំង កើតឡើងក្នុងរូបនោះ កាលទ្រង់សម្តែងរូបនោះដោយអំណាចវ័យ មានបឋមវ័យជាដើម ទើបទ្រង់សម្តែង ធ្វើឲ្យសល់ត្រឹមតែឆ្អឹងក្នុងទីបំផុត ដោយន័យដែលខ្ញុំពោលហើយខាងដើមនោះឯង ។

ព្រះនាងខេមាទតឃើញរូបនោះ ទើបព្រះតម្រិះថា រូបបែបនេះក៏ដល់នូវការវិនាសទៅមួយរំពេចប៉ុណ្ណោះ សារៈក្នុងរូបនេះមិនមានឡើ ។

ព្រះសាស្តា ទ្រង់ទតមើលវារចិត្តរបស់ព្រះនាងខេមានោះហើយ ទើបត្រាស់ថា ម្នាលខេមា នាងគិតថា សារៈមាននៅក្នុងរូបនេះឬ ចូរនាងមើលភាពដែលរូបនោះមិនមានសារៈក្នុងឥឡូវនេះ ហើយត្រាស់ព្រះគាថានេះថា

> ម្នាលនាងខេមា ចូរនាងមើលកាយដែលរសាប់រសល់ មិនស្អាត មានក្លិនស្អុយ ជារបស់រលួយ ហូរចេញទាំងខាងលើ ហូរចេញទាំងខាងក្រោម ដែលជនពាលទាំងឡាយប្រាថ្នាក្រៃលែង ។

ក្នុងកាលចប់ទេសនា ព្រះនាងតាំងនៅក្នុងសោតាបត្តិផល ។ លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលនាងខេមា សត្វទាំងនេះត្រេកអរដោយរាគៈក្តៅក្រហាយដោយទោសៈ វង្វេងដោយមោហៈ ទើបមិនអាចឈានកន្លងក្រសែតណ្ហារបស់ខ្លួនបាន ត្រូវជាប់ជំពាក់ក្នុងក្រសែតណ្ហានោះឯង ដូច្នេះ

ហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់គាថានេះថា

**យេ រាគរត្តានុបតន្តិ សោតំ សយំ កតំ មក្កដកោវ ជាលំ**
**ឯតម្បិ ឆេត្វាន វជន្តិ ធីរា អនបេក្ខិនោ សព្វទុក្ខំ បហាយ ។**

ជនពួកណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាំងទម្លាក់ខ្លួនចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះទុក្ខទាំងពួងចេញទៅ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **មក្កដកោវ ជាលំ** សេចក្តីថា ដូចពីងពាងធ្វើអន្ទាក់ គឺសំណាញ់ហើយ ដេកត្រង់កណ្តាល ហើយប្រញាប់រត់ទៅសម្លាប់កណ្តូប ឬសត្វល្អិត ដែលធ្លាក់ក្នុងសំណាញ់ បឺតជញ្ជក់នូវរសរបស់សត្វទាំងនោះហើយ ក៏ត្រឡប់មកដេកក្នុងទីដើមយ៉ាងណា សត្វទាំងឡាយណា ដែលតម្រេកហើយដោយរាគៈ ក្រោធហើយដោយទោសៈ វង្វេងហើយដោយមោហៈ សត្វទាំងនោះរមែងធ្លាក់ទៅកាន់ក្រសែតណ្ហា ដែលខ្លួនធ្វើខ្លួនឯង គឺមិនអាចឈានកន្លងក្រសែតណ្ហានោះទៅបានដូច្នោះដូចគ្នា ក្រសែតណ្ហាបុគ្គលកន្លងបានលំបាកយ៉ាងនេះ ។

បាទព្រះគាថាថា **ឯតម្បិ ឆេត្វាន វជន្តិ ធីរា** សេចក្តីថា បណ្ឌិតទាំងឡាយ កាត់នូវគ្រឿងចងនោះហើយ ជាអ្នកអស់នូវការជាប់ជំពាក់ គឺមិនមានអាល័យ លះទុក្ខទាំងពួងដោយអរហត្តមគ្គហើយ ក៏វៀរ គឺទៅ ។

ក្នុងកាលចប់ទេសនា ព្រះនាងខេមាតាំងនៅក្នុងអរហត្ត ទេសនាមានប្រយោជន៍ដល់មហាជនហើយ ។ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ ព្រះនាងខេមានឹងបួស ឬបរិនិព្វានទើបគួរ ។ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ សូមទ្រង់ឲ្យនាងបួសចុះ កុំជ្រុលដល់ដោយការបរិនិព្វាន ។

ព្រះនាងបព្វជ្ជាហើយ ក៏បានជាអគ្គសាវិកាដូច្នេះឯង ។៚

**រឿង ព្រះនាងខេមា ចប់**

# រឿង ឧគ្គសេនសេដ្ឋីបុត្រ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធឧគ្គសេន ត្រាស់ព្រះធម្មទេសនានេះថា **មុញ្ច បុរេ** ជាដើម ។

បានឮថា គ្រប់ ៦ ឆ្នាំ ឬ ៦ ខែហើយ អ្នករបាំប្រមាណ ៥០០ ទៅកាន់ក្រុងរាជគ្រឹះ ធ្វើមហោស្រពថ្វាយដល់ព្រះរាជារហូត ៧ ថ្ងៃ បានប្រាក់និងមាសជាច្រើន ការជូនរង្វាន់ក្នុងចន្លោះៗ មិនមានទីបំផុត មហាជនក៏ឈរលើគ្រែជាដើមមើលមហោស្រព ។ លំដាប់នោះ ធីតារបស់អ្នករបាំម្នាក់ឡើងកាន់រ៉ាវ ដើររាំ និងច្រៀងលើអាកាសក្នុងទីបំផុតនៃរ៉ាវនោះ ។

សម័យនោះ សេដ្ឋីបុត្រឈ្មោះឧគ្គសេន ឈរលើគ្រែដែលត្រួតលើគ្នាជាមួយសម្លាញ់ សម្លឹងមើលស្រីនោះ មានការស្រឡាញ់កើតឡើងក្នុងអាការ

ទាំងឡាយមានការត្រេកអរដៃ និងជើងជាដើមរបស់នាង ទៅកាន់ផ្ទះហើយគិតថា បើអញបាននាងទើបអញមានជីវិត បើមិនបានក៏នឹងស្លាប់ក្នុងទីនេះឯង ដូច្នេះហើយ ក៏អត់អាហារដេកលើគ្រែ ត្រូវមាតាបិតាសួរថា នែបា បាកើតអ្វី ក៏ឆ្លើយថា បើខ្ញុំបានកូនស្រីរបស់អ្នករបាំនោះ នឹងមានជីវិតរស់នៅ បើមិនបានក៏នឹងស្លាប់ក្នុងទីនេះឯង កាលមាតាលួងលោមថា នែបា បាកុំធ្វើយ៉ាងនេះឡើយ ពួកយើងនឹងនាំកុមារិកាដទៃ ដែលសមគួរដល់ត្រកូល និងភោគៈរបស់ពួកយើងមកឲ្យដល់បា ក៏នៅតែដេកពោលយ៉ាងនោះដដែល ។

លំដាប់នោះ បិតារបស់ឧគ្គសេន សូម្បីអង្វរច្រើន កាលមិនអាចឲ្យគេយល់ព្រមបាន ទើបហៅសម្លាញ់របស់អ្នករបាំនោះមក ឲ្យទ្រព្យមួយពាន់កហាបណៈហើយ បញ្ជូនទៅដោយពាក្យថា ចូរអ្នកទទួលយកកហាបណៈទាំងនេះហើយ ឲ្យកូនស្រីរបស់អ្នកដល់កូនប្រុសរបស់ខ្ញុំចុះ ។

អ្នករបាំនោះពោលថា ខ្ញុំទទួលយកកហាបណៈហើយ ក៏ឲ្យមិនបាន បើកូនប្រុសរបស់លោកមិនបានកូនស្រីរបស់ខ្ញុំហើយ មិនអាចរស់នៅសោត បើដូច្នោះ បុត្ររបស់លោក ចូរត្រាច់ទៅជាមួយពួកខ្ញុំចុះ ពួកខ្ញុំនឹងឲ្យកូនស្រីដល់បុត្ររបស់លោក ។ មាតាបិតាប្រាប់សេចក្ដីនោះដល់ឧគ្គសេនហើយ ឧគ្គសេនពោលថា ខ្ញុំនឹងដើរតាមពួកអ្នករបាំនោះ មិនអើពើនឹងពាក្យរបស់មាតាបិតាដែលកំពុងអង្វរ បានចេញទៅកាន់សម្នាក់នៃអ្នករបាំហើយ ។

អ្នករបាំនោះ ឲ្យកូនស្រីដល់ឧគ្គសេនហើយ ដើរសម្ដែងសិប្បៈក្នុងស្រុក និគម និងរាជធានីជាមួយគ្នានោះឯង ។ ចំណែកទារិកានោះ អាស្រ័យការនៅ

រួមជាមួយបុត្រសេដ្ឋីនោះ ក្នុងកាលមិនយូរក៏បានបុត្រ កាលនឹងលួងបុត្រនោះ ពោលថា កូនរបស់អ្នកយាមរទេះ កូនអ្នករែករបស់របរ កូនអ្នកមិនចេះអ្វីសោះ ។ ចំណែកសេដ្ឋីបុត្រនោះ ជញ្ជូនស្មៅមកឲ្យគោទាំងឡាយ ក្នុងទីដែលជនទាំងនោះធ្វើការដាក់រទេះហើយ លើកយករបស់របរដែលបានក្នុងទីសម្តែងសិប្បៈ ហើយនាំទៅ បានឮថា ស្រីនោះសំដៅយកបុត្រសេដ្ឋីនោះឯង កាលនឹងលួងកូន ទើបពោលយ៉ាងនោះឯង បុត្រសេដ្ឋីជ្រាបភាពដែលនាងច្រៀងប្រារព្ធខ្លួន ទើបសួរថា នាងពោលសំដៅដល់ខ្ញុំឬ ភរិយាពោលថា ចាំ ខ្ញុំពោលសំដៅដល់អ្នក សេដ្ឋីបុត្រពោលថា បើដូច្នោះខ្ញុំចៀសចេញទៅ ភរិយាពោលថា ប្រយោជន៍អ្វីរបស់ខ្ញុំ ដែលអ្នកគេចទៅឬមកនោះ ដូច្នេះហើយ ច្រៀងបទនោះឯងរឿយៗ ទៅ ។

បានឮថា នាងអាស្រ័យរូបសម្បត្តិរបស់ខ្លួន និងទ្រព្យចំណូល ទើបមិនក្រែងចិត្តបុត្រសេដ្ឋីនោះ ក្នុងរឿងណាមួយឡើយ ។ បុត្រសេដ្ឋីនោះគិតថា ស្រីនេះមានការប្រកាន់ខ្លួនបែបនេះ ព្រោះអាស្រ័យអ្វីហ្ន៎ ដឹងថា ព្រោះអាស្រ័យសិប្បៈ ទើបគិតថា ណ្ហើយចុះ អញនឹងរៀនសិប្បៈ ហើយចូលទៅរកឪពុកក្មេក រៀនសិប្បៈរបស់ឪពុកក្មេកនោះ សម្តែងសិប្បៈក្នុងស្រុកនិគមជាដើម មកដល់រាជគ្រឹះដោយលំដាប់ ឲ្យប្រកាសថា ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ បុត្រសេដ្ឋីឈ្មោះឧគ្គសេននឹងសម្តែងសិប្បៈដល់អ្នកនគរ ។ អ្នកនគរឲ្យចងគ្រែត្រួតៗលើគ្នាជាដើមហើយ ប្រជុំគ្នាក្នុងថ្ងៃទី ៧ ។ ចំណែកឧគ្គសេន ឡើងកាន់រ៉ាវកម្ពស់ ៦០ ហត្ថ ឈរលើចុងរ៉ាវនោះ ។ ក្នុងថ្ងៃនោះ ព្រះសាស្តា

ទ្រង់ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញឧគ្គសេននោះចូលក្នុងសំណាញ់ញាណរបស់ព្រះអង្គ ទើបទ្រង់ពិចារណាថា នឹងមានហេតុអ្វីហ្ន៎ បានជ្រាបថា ស្អែកនេះ បុត្រសេដ្ឋី នឹងឈរលើចុងរ៉ាវ ដោយបំណងថា នឹងសម្ដែងសិប្បៈ មហាជនប្រជុំគ្នាដើម្បីមើល តថាគតនឹងសម្ដែងគាថាប្រកបដោយបទ ៤ ក្នុងសមាគមនោះ ការសម្រេចធម៌នឹងមានដល់សត្វ ៨៤០០០ ព្រោះស្ដាប់ធម៌នោះ សូម្បីឧគ្គសេន ក៏តាំងនៅក្នុងអរហត្ត ។

ក្នុងថ្ងៃរះឡើង ទ្រង់កំណត់ពេលហើយ មានភិក្ខុសង្ឃចោមរោម ចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ចំណែកឧគ្គសេន កាលព្រះសាស្ដាមិនទាន់យាងទៅខាងក្នុងព្រះនគរនោះឯង ទើបឲ្យសញ្ញាដោយម្រាមដៃដល់មហាជន ដើម្បីឲ្យគគ្រឹកគគ្រេង ឈរលើចុងរ៉ាវក្នុងអាកាសនោះឯង ៧ ដង ចុះមកហើយ ឈរលើចុងរ៉ាវទៀត ។

ខណៈនោះ ព្រះសាស្ដាកំពុងចូលទៅកាន់ព្រះនគរ ទ្រង់ធ្វើដោយអាការដែលបរិស័ទមិនមើលឧគ្គសេន ឲ្យមើលចំពោះទ្រង់ប៉ុណ្ណោះ ឧគ្គសេនសម្លឹងមើលបរិស័ទហើយ ដល់នូវការអន់ចិត្តថា បរិស័ទទាំងនេះមិនសម្លឹងមើលអញ ទើបគិតថា សិប្បៈដែលអញគប្បីសម្ដែងប្រចាំឆ្នាំ កាលព្រះសាស្ដាយាងចូលទៅកាន់ព្រះនគរ បរិស័ទមិនមើលអញមើលតែព្រះសាស្ដាប៉ុណ្ណោះ ការសម្ដែងសិប្បៈរបស់អញទទេហើយហ្ន៎ ។

ព្រះសាស្ដា ទ្រង់ជ្រាបការគិតរបស់ឧគ្គសេន ទើបត្រាស់ហៅព្រះមហាមោគ្គល្លានមកហើយត្រាស់ថា មោគ្គល្លាន ចូរអ្នកទៅនិយាយនឹងសេដ្ឋីបុត្រថា

ចូរសម្ដែងសិប្បៈចុះ ។ ព្រះថេរៈបានឈរខាងក្រោមរាវនោះឯង ហៅសេដ្ឋី-បុត្រមកហើយ ពោលគាថានេះថា

ឧគ្គសេនកូនអ្នករបាំ ដែលមានកម្លាំងច្រើន ចូរអ្នកមើល ចូរអ្នកធ្វើសេចក្ដីត្រេកអរដល់បរិស័ទចុះ ចូរអ្នកធ្វើឲ្យមហាជនត្រេកអរចុះ ។ ឧគ្គសេនបានឮពាក្យរបស់ព្រះថេរៈហើយ មានចិត្តត្រេកអរ គិតថា ព្រះសាស្ដាមានបំណងនឹងទតសិប្បៈរបស់អញ ឈរលើចុងរាវហើយ ពោលគាថានេះថា បពិត្រព្រះមោគ្គល្លាន លោកម្ចាស់មានបញ្ញាច្រើន មានឫទ្ធិច្រើន សូមលោកម្ចាស់មើល ខ្ញុំនឹងធ្វើការត្រេកអរដល់បរិស័ទ នឹងញ៉ាំងមហាជនឲ្យត្រេកអរ ។

កាលពោលយ៉ាងនោះហើយ ក៏លោតអំពីចុងរាវឡើងកាន់អាកាសអស់ ១៤ ដងក្នុងអាកាសហើយ ចុះមកឈរលើចុងរាវវិញ ។ លំដាប់នោះ ព្រះសាស្ដាត្រាស់ថា ឧគ្គសេន ធម្មតាបណ្ឌិតត្រូវលះសេចក្ដីអាល័យក្នុងខន្ធទាំង-ឡាយ ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្នចេញ ហើយផុតចាកទុក្ខទាំងឡាយ មានជាតិជាដើមទើបគួរ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**មុញ្ច បុរេ មុញ្ច បច្ឆតោ មជ្ឈេ មុញ្ច ភវស្ស បារគូ**
**សព្វត្ថ វិមុត្តមានសោ ន បុន ជាតិជរំ ឧបេហិសិ ។**

អ្នកចូរដោះ ( សេចក្ដីអាល័យ ) ក្នុងកាលមុនចេញ ចូរដោះ ( សេចក្ដីអាល័យ ) ក្នុងខាងក្រោយចេញ ចូរដោះ ( សេចក្ដីអាល័យ ) ក្នុងកាលជាកណ្ដាលចេញ ( កាលបើធ្វើយ៉ាងនេះ ) អ្នកនឹងដល់ត្រើយនៃភព និងមានចិត្តរួចស្រឡះចាកសង្ខតធម៌

ទាំងពួង មិនត្រូវទៅកាន់ជាតិ និងជរាទៀតឡើយ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ ពីរបទថា **មុញ្ច បុរេ** សេចក្ដីថា ចូរដោះអាល័យ គឺការត្រេកអរ ការងប់ជ្រប់ ការប្រាថ្នា ការជាប់ជំពាក់ ការប្រកាន់ ការស្ងាប អង្អែល ការចង់បានក្នុងខន្ធទាំងឡាយ ដែលជាអតីតចេញ ។

បទថា **បច្ឆតោ** សេចក្ដីថា ចូរដោះនូវអាល័យជាដើមក្នុងខន្ធទាំងឡាយ ដែលជាអនាគត ។

បទថា **មជ្ឈេ** សេចក្ដីថា ចូរដោះអាល័យទាំងនោះក្នុងខន្ធទាំងឡាយដែល ជាបច្ចុប្បន្នចេញ ។

ពីរបទថា **ភវស្ស បារគូ** សេចក្ដីថា កាលបដិបត្តិបានយ៉ាងនោះ នឹងជា អ្នកដល់ត្រើយ គឺទៅហើយកាន់ប្រាំងនៃភពទាំង ៣ បាន ដោយអំណាច នៃការកំណត់ដឹង ការលះ ការចម្រើន និងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ ក្រៃលែង មានចិត្តរួចផុតហើយក្នុងសង្ខតធម៌ទាំងពួង មានខន្ធ ធាតុ អាយតនៈជាដើម តទៅ មិនត្រូវចូលដល់ជាតិ ជរា និងមរណៈ ។

ក្នុងកាលចប់ទេសនា ការត្រាស់ដឹងធម៌មានដល់សត្វ ៨៤០០០ ហើយ ។ ចំណែកសេដ្ឋីបុត្រ កំពុងឈរលើចុងរ៉ាវ សម្រេចអរហត្ត មួយអន្លើដោយ បដិសម្ភិទាហើយ ចុះអំពីរ៉ាវមកកាន់ទីជិតព្រះសាស្ដា ថ្វាយបង្គំដោយបញ្ចង្គ- ប្រតិស្ឋាន ទូលសូមបព្វជ្ជានឹងព្រះសស្ដា ។ លំដាប់នោះ ព្រះសាស្ដាទ្រង់លា ព្រះហស្តខាងស្ដាំ ត្រាស់នឹងឧគ្គសេនថា ចូរអ្នកមកជាភិក្ខុចុះ ឧគ្គសេនក៏បាន

ជាអ្នកទ្រទ្រង់នូវបរិក្ខារ ៨ ហាក់ដូចជាព្រះថេរៈ មានវស្សា ៦០ ក្នុងខណៈនោះឯង ។

បន្ទាប់មក ពួកភិក្ខុសួរលោកថា ឧគ្គសេន កាលលោកចុះអំពីរ៉ាវកម្ពស់ ៦០ ហត្ថ ឈ្មោះថា ការខ្លាចមិនមានទេឬ កាលលោកឆ្លើយថា អាវុសោ ការខ្លាចមិនមានដល់ខ្ញុំឡើយ ទើបក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ឧគ្គសេនពោលថា ខ្ញុំមិនខ្លាច លោកពោលមិនពិត រមែងអួតគុណវិសេស ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលមានសំយោជនៈកាត់បានហើយ ដូចឧគ្គសេនបុត្ររបស់តថាគត ការខ្លាច ការតក់ស្លុត មិនមាន ដូច្នេះហើយ ត្រាស់ព្រះគាថានេះក្នុងព្រាហ្មណវគ្គថា

បុគ្គលណា កាត់សំយោជនៈទាំងអស់បាន មិនតក់ស្លុត តថាគតហៅបុគ្គលនោះ ដែលគ្មានកិលេសជាគ្រឿងជំពាក់ អ្នករួចស្រឡះចាកកិលេសថា ជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ការសម្រេចធម្មវិសេសមានហើយដល់មហាជន ។ ស្អែកឡើង ពួកភិក្ខុសន្ទនាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ហេតុ គឺការអាស្រ័យកូនក្រមុំអ្នករបាំ ត្រាច់ទៅជាមួយអ្នករបាំរបស់ភិក្ខុ ដែលដល់ព្រមដោយឧបនិស្ស័យនៃអរហត្តយ៉ាងនេះ ដូចម្តេចហ្ន៎ ហេតុនៃឧបនិស្ស័យអរហត្តដូចម្តេចហ្ន៎ ។ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ហេតុទាំងពីរនោះ ដែលឧគ្គសេនធ្វើហើយ ។ កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបទ្រង់ទាញអតីតនិទានមកត្រាស់ថា

បានឮថា ក្នុងអតីតកាល កាលសុវណ្ណចេតិយសម្រាប់ព្រះកស្សបទសពលគេកំពុងធ្វើ ពួកកុលបុត្រអ្នកនគរពារាណសីផ្ទុករបស់ទំពា របស់បរិភោគ ជាច្រើនក្នុងយានទាំងឡាយ កំពុងទៅកាន់ទីចេតិយ ដោយតាំងចិត្តថា ពួកយើងនឹងធ្វើហត្ថកម្ម ជួបព្រះថេរៈមួយអង្គកំពុងចូលទៅបិណ្ឌបាតក្នុងវាងផ្លូវ លំដាប់នោះ កុលធីតាម្នាក់ឃើញព្រះថេរៈហើយ ពោលនឹងស្វាមីថា នែអ្នក លោកម្ចាស់របស់យើងចូលមកដើម្បីបិណ្ឌបាត ម្យ៉ាងទៀត របស់ទំពារបស់បរិភោគ នៃពួកយើងនៅក្នុងយានមានជាច្រើន សូមអ្នកនាំបាត្ររបស់លោកមក យើងទាំងពីរនឹងប្រគេនភិក្ខា ។ ស្វាមីនាំបាត្រមកហើយ ករិយាញុំាងបាត្រនោះឲ្យពេញដោយរបស់ទំពា របស់បរិភោគហើយ ឲ្យប្ដីយកទៅដាក់ក្នុងដៃរបស់ព្រះថេរៈ ជនទាំងពីរនាក់ធ្វើសេចក្ដីប្រាថ្នាថា ទានរបស់ខ្ញុំទាំងពីរ គប្បីមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយនោះឯង ព្រះថេរៈជាព្រះខីណាស្រព ព្រោះដូច្នោះ កាលលោកពិចារណាមើល ដឹងភាវៈដែលនឹងសម្រេចសេចក្ដីប្រាថ្នារបស់ជនទាំងពីរនោះហើយ បានធ្វើនូវការញញឹម ស្រីនោះឃើញអាការនោះ ទើបពោលនឹងប្ដីថា នែអ្នក លោកម្ចាស់របស់យើងធ្វើអាការញញឹម លោកប្រហែលជាអ្នករបាំទេដឹង ។ ចំណែកប្ដីរបស់នាងឆ្លើយថា អើ នាងប្រហែលជាយ៉ាងនោះឯង ដូច្នេះហើយ ចៀសចេញទៅ ។ នេះជាបុព្វកម្មរបស់ជនទាំងពីរ ។

ស្វាមីភរិយានោះ តាំងនៅក្នុងអត្តភាពនោះអស់អាយុហើយ កើតក្នុងទេវលោក ឃ្លាតចាកទីនោះហើយ ស្រីនោះកើតក្នុងត្រកូលអ្នករបាំ ប្រុសកើតក្នុងផ្ទះរបស់សេដ្ឋី ។ ឧគ្គសេននោះ ព្រោះភាពដែលឲ្យនូវការឆ្លើយដល់ភរិយានោះថា អើនាង ប្រហែលជាយ៉ាងនោះឯង ទើបត្រាច់ទៅជាមួយអ្នករបាំ អាស្រ័យបិណ្ឌបាតដែលគេប្រគេនដល់ព្រះថេរៈ ដែលជាព្រះខីណាស្រព ទើបសម្រេចអរហត្តហើយ ។

ធីតារបស់អ្នករបាំនោះគិតថា គតិរបស់ប្ដីអញយ៉ាងណា គតិរបស់អញក៏យ៉ាងនោះឯង ដូច្នេះហើយ ក៏បព្វជាក្នុងសម្នាក់របស់ភិក្ខុនីទាំងឡាយហើយ តាំងនៅក្នុងអរហត្ត ដូច្នេះឯង ។

## រឿង ឧគ្គសេនសេដ្ឋីបុត្រ ចប់

# រឿង ចូឡធនុគ្គហបណ្ឌិត

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **វិតក្កមថិតស្ស** ជាដើម ។

បានឮមកថា ភិក្ខុកំលោះមួយរូប ចាប់ស្លាករបស់ខ្លួនក្នុងរោងស្លាក កាន់យកបបរតាមស្លាកទៅកាន់រោងឆាន់ ហើយឆាន់ ។ ភិក្ខុនោះ មិនបានទឹកក្នុងរោងឆាន់ ក៏ទៅកាន់ផ្ទះមួយខ្នងដើម្បីទឹក ។ កញ្ញាម្នាក់ក្នុងផ្ទះនោះ បានឃើញភិក្ខុនោះ កើតសេចក្តីស្នេហា ពោលថា បពិត្រលោកម្ចាស់ បើត្រូវការដោយទឹកឆាន់ សូមនិមន្តមកកាន់ផ្ទះនេះទៀតចុះ ។

តាំងអំពីនោះមក ភិក្ខុនោះមិនបានទឹកក្នុងកាលណា ក៏ទៅកាន់ផ្ទះនោះឯងក្នុងកាលនោះ ។ ចំណែកស្រីនោះ ទទួលបាត្ររបស់លោកហើយប្រគេនទឹកឆាន់ ។ ពេលវេលាកន្លងទៅដោយអាការយ៉ាងនោះ ។ ថ្ងៃមួយ នាងប្រគេនបបរ ហើយនិមន្តឲ្យគង់ឆាន់ក្នុងផ្ទះនោះឯងហើយប្រគេនបាយ ។ នាងអង្គុយក្នុងទីជិតភិក្ខុនោះហើយ លែបខាយពាក្យសម្តីឡើងថា បពិត្រលោកម្ចាស់ ក្នុងផ្ទះនេះអ្វីដែលឈ្មោះថាអត់ មិនមានឡើយ ខ្ញុំខ្វះតែអ្នកចាត់ចែងការប៉ុណ្ណោះ ភិក្ខុនោះស្តាប់ពាក្យរបស់ស្រីនោះហើយ ២-៣ ថ្ងៃប៉ុណ្ណោះក៏អផ្សុកហើយ ។

ថ្ងៃមួយ ពួកអាគន្តុកភិក្ខុជួបភិក្ខុនោះ ក៏សួរថា អាវុសោ ហេតុអ្វីទើបលោកស្គមលឿងខ្លាំងម៉្លេះ កាលភិក្ខុនោះឆ្លើយថា អាវុសោ ខ្ញុំអផ្សុក ទើបនាំទៅកាន់សម្នាក់អាចារ្យ និងឧបជ្ឈាយ៍ៗ ទាំងនោះ ក៏នាំភិក្ខុនោះទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលសេចក្តីនោះហើយ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកចង់សឹកឬ ភិក្ខុនោះទូលថា ពិតហើយព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ តើព្រោះហេតុអ្វី អ្នកបួសក្នុងសាសនារបស់ព្រះពុទ្ធ ដែលប្រារព្ធសេចក្តីព្យាយាមដូចតថាគត មិនបានឲ្យគេហៅខ្លួនថាជាព្រះសោតាបន្ន ឬព្រះសកទាគាមី បែរជាឲ្យគេហៅថា ជាអ្នកអផ្សុកទៅវិញ អ្នកធ្វើកម្មធ្ងន់ហើយ ទើបទ្រង់សួរថា ព្រោះហេតុអ្វី ទើបអ្នកអផ្សុក ភិក្ខុនោះទូលថា បពិត្រព្រះអង្គ ទារិកាម្នាក់និយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ កិរិយារបស់ស្រីនោះមិនគួរអស្ចារ្យ ព្រោះក្នុងកាលមុន នាងលះបង់បណ្ឌិតដ៏កំពូល លើជម្ពូទ្វីបទាំងមូល ហើយទៅស្នេហាក្នុងបុរសម្នាក់ ដែលខ្លួនឃើញមួយភ្លែតនោះកើតឡើង ធ្វើបណ្ឌិតនោះឲ្យដល់នូវការអស់ជីវិត ។ ភិក្ខុទាំងឡាយទូលអារាធនា ដើម្បីឲ្យព្រះអង្គសម្តែងរឿងនោះ ទើបទ្រង់ធ្វើឲ្យជាក់ច្បាស់នូវភាពដែលចូឡធនុគ្គហបណ្ឌិត រៀនសិប្បៈក្នុងសម្នាក់របស់អាចារ្យទិសាបាមោក្ខ ក្នុងក្រុងតក្កសិលា នាំធីតាដែលអាចារ្យនោះត្រេកអរឲ្យហើយ មកកាន់ក្រុងពារាណសីកាលខ្លួនសម្លាប់ ចោរ ៤៩ នាក់ ដោយព្រួញ ៤៩ ត្រង់មាត់ព្រៃមួយកន្លែងកាលព្រួញអស់ហើយ ទើបចាប់មេចោរឲ្យដួលចុះត្រង់ផែនដី ពោលថា នែនាង ចូរនាងយកដាវមក នាងបែរជាធ្វើសេចក្តីស្រឡាញ់ក្នុងចោរ ដែលខ្លួនឃើញក្នុងខណៈនោះ ហើយដាក់ដងដាវក្នុងដៃចោរ ឲ្យចោរសម្លាប់ហើយក្នុងកាលជាចូឡធនុគ្គហបណ្ឌិតក្នុងអតីតកាល និងភាវៈដែលចោរនាំស្រីនោះទៅបណ្តើរ គិតបណ្តើរថា ស្រីនេះ ឃើញប្រុសដទៃហើយ នឹងឲ្យគេសម្លាប់

អញដែរ ដូចគ្នានឹងប្តីរបស់ខ្លួន អញត្រូវការអ្វីដោយស្រីនេះ ឃើញស៊ីងមួយខែ្សទើបទុកនាងត្រង់ត្រើយអាយ កាន់បង្វេចកណ្តៈរបស់នាងទៅ ប្រាប់ថា ចូរនាងចាំក្នុងទីនេះឯង ទម្រាំខ្ញុំនាំកណ្តៈឆ្លងទៅ ទុកនាងបោលក្នុងទីនោះឯង គេចទៅ ។ ហើយព្រះសាស្តា ត្រាស់ចុល្លធនុគ្គហជាតកនេះ ក្នុងបញ្ចកនិបាត ឲ្យពិស្តារថា

ស្ត្រីនោះនិយាយថា ម្នាលព្រាហ្មណ៍ អ្នកនាំយកទ្រព្យទាំងអស់ ឆ្លងទៅកាន់ត្រើយនាយ ម្នាលអ្នកដ៏ចម្រើន អ្នកចូរត្រឡប់មកវិញយ៉ាងឆាប់រួសរាន់ សូមអ្នកចម្លងខ្ញុំឥឡូវនេះផង ។

ចោរនិយាយថា នាងផ្លាស់ប្តូរយកអញ អ្នកមិនស្និទ្ធស្នាល ដោយប្តីដែលស្និទ្ធស្នាលអស់កាលយូរ ផ្លាស់ប្តូរយកអញដែលមិនមែនជាប្តីទៀងទាត់ ដោយប្តីទៀងទាត់ នាងនឹងផ្លាស់ប្តូរយកប្រុសឯទៀតនឹងអញមិនខាន អញនឹងទៅកាន់ទីឆ្ងាយជាងទីនេះ ។

ចចកនិយាយថា ស្ត្រីនេះជាអ្វី ទើបធ្វើនូវសំណើចយ៉ាងខ្លាំងទៀបគុម្ពរំទឹក ការរាំក្តី ច្រៀងក្តី ប្រគំក្តី ដែលគេតាំងទុកដោយល្អ ក្នុងទីនេះមិនមានទេ ម្នាលស្ត្រី មានត្រគាកល្អ មានរូបល្អ ហេតុដូចម្តេច ទើបនាងសើចក្អាកក្អាយ ក្នុងកាលគួរយំ ។

នាងនោះនិយាយថា ម្នាលចចកជម្ពុកៈពាល ឥតប្រាជ្ញា ឯងជាសត្វគ្មានប្រាជ្ញា ឯងសាបសូន្យចាកត្រី និងដុំសាច់ សញ្ជប់សញ្ជឹងដូចសត្វកំព្រា ។

ចចកនិយាយថា ទោសរបស់ជនទាំងឡាយឯងទៀត ឃើញបានដោយងាយ ចំណែកខាងទោសរបស់ខ្លួន ឃើញបានដោយក្រណាស់ នាងឯងជាស្រ្តីសាបសូន្យចាកប្តី និងសហាយ សញ្ជប់សញ្ជឹងជាងអញទៅទៀត ។

នាងនោះនិយាយថា ម្នាលស្តេចម្រឹគជម្ពុកៈ អ្នកនិយាយយ៉ាងណា ពាក្យនុ៎ះយ៉ាងហ្នឹងហើយ ខ្ញុំនោះទៅអំពីទីនេះ នឹងលុះអំណាចប្តីដោយពិត ។

សក្កទេវរាជពោលថា អ្នកណាហ៊ានលួចភាជន៍ដី អ្នកនោះគង់ហ៊ានលួចភាជន៍សំរិទ្ធទៀត បាបដែលនាងបានធ្វើ រួចហើយនាងនឹងធ្វើយ៉ាងនេះទៀត មិនលែងឡើយ ។

ហើយទ្រង់ត្រាស់ថា ក្នុងកាលនោះ ចុល្លធនុគ្គហបណ្ឌិត បានជារូបអ្នកស្រីនោះ បានជាទារិកានោះក្នុងកាលឥឡូវនេះ ។ សក្កទេវរាជ ដែលនិម្មិតរូបជាចចក ធ្វើការសង្កត់សង្កិនស្រីនោះ គឺតថាគតនេះឯង ។ ព្រះសាស្តាទ្រង់ទូន្មានភិក្ខុនោះថា ស្រីនោះ ផ្តាច់ជីវិតបណ្ឌិតដែលជាកំពូល ក្នុងជម្ពូទ្វីបទាំងមូល ឲ្យអស់ជីវិត ព្រោះស្រឡាញ់ក្នុងមនុស្សម្នាក់ដែលខ្លួនឃើញមួយភ្លែតយ៉ាងនេះ ម្នាលភិក្ខុ ចូរអ្នកកាត់តណ្ហារបស់អ្នក ដែលប្រារព្ធស្រីនោះកើតឡើងចោលចេញ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ឲ្យក្រៃលែងឡើងទើបទ្រង់ភាសិតព្រះគាថាទាំងនេះថា

**វិតក្កមថិតស្ស ជន្តុនោ តិព្វរាគស្ស សុភានុបស្សិនោ**
**ភិយ្យោ តណ្ហា បវឌ្ឍតិ ឯស ខោ ទឡ្ហំ ករោតិ ពន្ធនំ ។**
**វិតក្កូបសមេ ច យោ រតោ អសុភំ ភាវយតី សទា សតោ**
**ឯស ខោ វ្យន្តិកាហិតិ ឯសច្ឆេច្ឆតិ មារពន្ធនំ ។**

តណ្ហា រមែងចម្រើនក្រៃលែងដល់ជនដែលវិតក្កញាំញី មានតម្រេកក្លៀវក្លា យល់ឃើញអារម្មណ៍ថាល្អ បុគ្គលនោះឯងឈ្មោះថា ធ្វើចំណងឲ្យមាំមួន ។ លុះតែបុគ្គលណា ត្រេកអរក្នុងអសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់រម្ងាប់ នូវវិតក្ក មានស្មារតីសព្វកាល តែងចម្រើនអសុភជ្ឈាន បុគ្គលនោះឯង នឹងធ្វើតណ្ហាឲ្យអស់ទៅបាន បុគ្គលនោះឯង ទើបឈ្មោះថា កាត់ចំណងមារបាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **វិតក្កមថិតស្ស** បានដល់ ដែលត្រូវវិតក្ក ៣ មានកាមវិតក្កជាដើមញាំញីក្រៃលែង ។

បទថា **តិព្វរាគស្ស** គឺជាអ្នកមានរាគៈក្រាស់ ។

បទថា **សុភានុបស្សិនោ** សេចក្តីថា ឈ្មោះថាជាអ្នកតាមឃើញអារម្មណ៍ថាស្អាត ព្រោះជាអ្នកមានចិត្ត ដែលបណ្តែតបណ្តោយទៅក្នុងអារម្មណ៍ដែលគួរប្រាថ្នាទាំងឡាយ ដោយអំណាចនៃការប្រកាន់ដោយសុភនិមិត្តជាដើម ។

បទថា **តណ្ហា** ជាដើម សេចក្តីថា បណ្តាឈាន សូម្បីឈានមួយរមែង

មិនចម្រើនដល់បុគ្គលបែបនោះដោយពិត តណ្ហាកើតតាមទ្វារ ៦ រមែងចម្រើនក្រៃលែង ។

បទថា **ឯស ខោ** សេចក្តីថា បុគ្គលនោះឯង រមែងធ្វើគ្រឿងចង គឺតណ្ហាឲ្យមាំ ។

បទថា **វិតក្កូបសមេ** សេចក្តីថា បណ្តាអសុភ ១០ ក្នុងបឋមជ្ឈានពោល គឺធម៌ជាទីរម្ងាប់មិច្ឆាវិតក្កទាំងឡាយ ។

ពីរបទថា **សទា សតោ** សេចក្តីថា ភិក្ខុណាជាអ្នកត្រេកក្នុងបឋមជ្ឈាននេះ ឈ្មោះថា មានសតិ ព្រោះភាពជាអ្នកមានសតិមាំទាំជានិច្ច ចម្រើនអសុភជ្ឈាននោះ ។

បទថា **វ្យន្តិកាហាតិ** សេចក្តីថា ភិក្ខុនោះនឹងធ្វើតណ្ហា ដែលនឹងឲ្យកើតក្នុងភព ៣ ឲ្យទៅប្រាសបាន ។

បទថា **មារពន្ធនំ** សេចក្តីថា ភិក្ខុនោះ នឹងកាត់សូម្បីគ្រឿងចងនៃមារពោល គឺវដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ចេញបាន ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់បុគ្គលដែលប្រជុំគ្នាហើយ ដូច្នេះឯង ។៚

**រឿងចុល្លធនុគ្គហបណ្ឌិត ចប់**

# រឿង មារ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា **និដ្ឋង្គតោ** ជាដើម ។

សេចក្ដីពិស្ដារថា ថ្ងៃមួយ ក្នុងវេលាវិកាល ព្រះថេរៈជាច្រើន ចូលទៅកាន់ជេតពនមហាវិហារ បានទៅដល់ទីលំនៅរបស់ព្រះរាហុលត្ថេរ ហើយក៏ដេញលោកឲ្យក្រោកឡើង កាលមិនឃើញទីលំនៅដទៃ ទើបសិងត្រង់យ៉មុខព្រះគន្ធកុដិរបស់ព្រះតថាគត គ្រានោះ ភិក្ខុនោះសម្រេចអរហត្តហើយ ទាំងជាបុគ្គលមិនទាន់មានវស្សា ។

មារឈ្មោះវសវត្តី តាំងនៅក្នុងភពនោះឯង ឃើញព្រះរាហុលសិងត្រង់យ៉មុខព្រះគន្ធកុដិ ទើបគិតថា សាមណេរតូចរបស់ព្រះសមណគោតម សិងខាងក្រៅ ចំណែកព្រះអង្គផ្ទំខាងក្នុងព្រះគន្ធកុដិ កាលអញគ្របសង្កត់សាមណេរតូច ឯខ្លួនព្រះអង្គក៏ដូចជាអញគ្របសង្កត់ដែរ ។ មារនោះនិម្មិតជាដំរីធំមកយកប្រមោយរឹតព្រះសីសៈព្រះថេរៈ ហើយស្រែកដូចសំឡេងក្រៀលដ៏ខ្លាំង ។

ព្រះសាស្ដាផ្ទំក្នុងព្រះគន្ធកុដិ ទ្រង់ជ្រាបដំរីនោះជាមារ ទើបត្រាស់ថា ម្នាលមារ ជនដូចអ្នកសូម្បីមួយសែន ក៏មិនអាចឲ្យនូវការខ្លាចកើតដល់បុត្ររបស់តថាគតបាន ព្រោះថា បុត្ររបស់តថាគត មានប្រក្រតីមិនតក់ស្លុត មានតណ្ហាទៅប្រាសហើយ ជាអ្នកមានព្យាយាមធំ មានបញ្ញាច្រើន ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

និដ្ឋង្គតោ អសន្តាសី វីតតណ្ហោ អនង្គណោ
អច្ឆិន្ទិ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។
វីតតណ្ហោ អនាទានោ និរុត្តិបទកោវិទោ
អក្ខរានំ សន្និបាតំ ជញ្ញា បុព្វាបរានិ ច
ស វេ អន្តិមសារីរោ មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ ។

បុគ្គលណាដល់នូវសេចក្តីសម្រេច គឺអរហត្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេសដូចទីទួល បានកាត់កូនសរ គឺកិលេស ជាហេតុញ៉ាំងសត្វឲ្យទៅកាន់ភពបានហើយ កាយដែលឆ្អឹង ៣០០ កំណាត់ផ្គុំគ្នាហើយនេះរបស់បុគ្គលនោះ ឈ្មោះថា តាំងនៅក្នុងទីបំផុត ។

បុគ្គលណាមិនមានតណ្ហា មិនមានសេចក្តីប្រកាន់មាំ ជាអ្នកឈ្លាសក្នុងនិរុត្តិ ( វាចាជាគ្រឿងសម្តែងចេញ ) និងបទដ៏សេស ដឹងច្បាស់នូវប្រជុំនៃអក្ខរៈទាំងឡាយផង នូវខាងដើម និងខាងចុងនៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯងតថាគតហៅថា អ្នកមានសរីរៈស្ថិតនៅក្នុងទីបំផុត មានបញ្ញាច្រើន ជាមហាបុរស ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **និដ្ឋង្គតោ** សេចក្តីថា អរហត្ត ឈ្មោះថាការសម្រេចរបស់បព្វជិតទាំងឡាយក្នុងសាសនានេះ ដល់ គឺសម្រេចអរហត្ត

នោះ ។

បទថា **អសន្ធាសិ** គឺដែលឈ្មោះថាមិនតក់ស្លុត ព្រោះមិនមានកិលេស ជាគ្រឿងតក់ស្លុត មានរាគៈជាដើម ក្នុងខាងក្នុងឡើយ ។

បាទព្រះគាថាថា **អច្ឆិន្ទិ ភវសល្លានិ** គឺបានកាត់នូវសរដែលមានប្រក្រតី ឲ្យទៅកាន់កពទាំងមូល ។

បទថា **សមុស្សយោ** គឺរាងកាយនេះរបស់បុគ្គលនោះមានក្នុងទីបំផុត ។

បទថា **អនាទានោ** គឺជាអ្នកមិនមានការប្រកាន់ក្នុងខន្ធជាដើម ។

បាទព្រះគាថាថា **និរុត្តិបទកោវិទោ** សេចក្ដីថា បុគ្គលឈ្លាសក្នុង បដិសម្ភិទាទាំង ៤ គឺក្នុងនិរុត្តិ និងបទដ៏សេស ។

ពីរបាទព្រះគាថាថា **អក្ខរានំ សន្និបាតំ ជញ្ញា បុព្វាបរានិ ច** សេចក្ដី ថា រមែងដឹងនូវពួកនៃអក្ខរៈ ពោលគឺទីប្រជុំនៃអក្ខរៈទាំងឡាយ និងដឹងអក្ខរៈ ខាងចុងដោយអក្ខរៈខាងដើម និងអក្ខរៈខាងដើមដោយអក្ខរៈខាងចុង ឈ្មោះ ថា ស្គាល់អក្ខរៈខាងចុងដោយអក្ខរៈខាងដើម គឺកាលខាងដើមប្រាកដ កណ្ដាល និងទីបំផុតមិនប្រាកដ ក៏រមែងដឹងបានថា នេះជាកណ្ដាលនៃអក្ខរៈទាំងនោះ នេះ ជាទីបំផុត ឈ្មោះថា ស្គាល់អក្ខរៈខាងដើម ដោយអក្ខរៈខាងចុង គឺកាល ទីបំផុតប្រាកដ កាលខាងដើម និងកណ្ដាលមិនប្រាកដ ក៏រមែងដឹងបានថា នេះ ជាកណ្ដាលនៃអក្ខរៈទាំងនេះ នេះជាដើម កាលកណ្ដាលប្រាកដ កាលខាង ដើម និងខាងចុងមិនប្រាកដ រមែងជ្រាបបានដូចគ្នាថា នេះជាខាងដើមនៃ អក្ខរៈទាំងនេះ នេះជាទីបំផុត ។

បទថា **មហាបញ្ញោ** សេចក្តីថា លោកអ្នកមានសរីរៈ តាំងនៅក្នុងទីបំផុតនោះ ព្រះសាស្តាត្រាស់ហៅថា អ្នកមានបញ្ញាច្រើន ព្រោះជាអ្នកប្រកបដោយបញ្ញាដែលកំណត់កាន់យកនូវអត្ថ ធម៌ និរុត្តិ បដិភាណ និងសីលក្ខន្ធជាដើមដ៏ធំ និងត្រាស់ថាជាមហាបុរស ព្រោះជាអ្នកមានចិត្តរួចផុតហើយ ដោយព្រះបាលីថា ម្នាលសារីបុត្ត តថាគតហៅបុគ្គលមានចិត្តរួចផុតហើយថាមហាបុរស ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

ចំណែកមារមានចិត្តបាបគិតថា ព្រះគោតមទ្រង់ស្គាល់អញហើយ ក៏អន្តរធានទៅក្នុងទីនោះឯង ដូច្នេះ ។

**រឿងមារ ចប់**

# រឿង ឧបកាជីវក

## លំនាំដើម

*ព្រះសាស្តាប្រារព្ធអាជីវកឈ្មោះឧបកៈក្នុងរវាងផ្លូវ ត្រាស់ព្រះធម្មទេសនា នេះថា* **សព្វាភិភូ** *ជាដើម ។*

*សេចក្តីពិស្តារថា សម័យមួយព្រះសាស្តាទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ហើយ ទ្រង់ញុំាងកាលឲ្យកន្លងទៅត្រង់មណ្ឌលពោធិព្រឹក្ស ៧ សប្តាហ៍ ទ្រង់ កាន់បាត្រ និងចីវររបស់ព្រះអង្គ យាងទៅអស់ចម្ងាយផ្លូវ ១៨ យោជន៍ តម្រង់ ទៅកាន់ក្រុងពារាណសី ដើម្បីញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ បានទតឃើញអាជីវក ឈ្មោះឧបកៈក្នុងរវាងផ្លូវ ។*

*ចំណែកឧបកាជីវកនោះ ឃើញព្រះសាស្តាហើយទូលសួរថា អាវុសោ ឥន្ទ្រិយរបស់អ្នកផូរផង់ ពណ៌សម្បុរក៏បរិសុទ្ធ អាវុសោបួសឧទ្ទិសអ្នកណា អ្នកណាជាសាស្តារបស់អ្នក អ្នកគាប់ចិត្តក្នុងធម៌របស់អ្នកណា ។ លំដាប់នោះ ព្រះសាស្តាត្រាស់ថា តថាគតមិនមានឧបជ្ឈាយ៍ ឬអាចារ្យឡើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះដល់ឧបកាជីវកនោះថា*

**សព្វាភិភូ សព្វវិទូហមស្មិ សព្វេសុ ធម្មេសុ អនូបលិត្តោ**
**សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។**

*តថាគតជាអ្នកគ្របសង្កត់តេភូមិកធម៌ទាំងអស់ ដឹងច្បាស់នូវចតុភូមិក-ធម៌ទាំងអស់ មានចិត្តមិនបានជាប់នៅក្នុងតេភូមិកធម៌ទាំងអស់ លះបង់ តេភូមិកធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា បើតថាគត*

*ត្រាស់ដឹងធម៌ ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណា ជាគ្រូអាចារ្យទៀត ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បទថា* **សព្វាភិភូ** *គឺគ្របសង្កត់ធម៌ក្នុងភូមិ ៣ បានទាំងអស់ ។*

*បទថា* **សព្វវិទូ** *គឺជាអ្នកមានធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងពួងដែលដឹងហើយ ។*

*ពីរបទថា* **សព្វេសុ ធម្មេសុ** *សេចក្ដីថា បុគ្គលដែលតណ្ហា និងទិដ្ឋិទាំងឡាយបូកលាបមិនបាន ក្នុងធម៌ទាំងអស់ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។*

*បទថា* **សព្វញ្ជហោ** *គឺលះធម៌ទាំងអស់ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ តាំងនៅ ។*

*ពីរបទថា* **តណ្ហក្ខយេ វិមុត្តោ** *គឺផុតហើយព្រោះអរហត្ត ពោល គឺធម៌ជាទីអស់ទៅនៃតណ្ហា ដែលខ្លួនឲ្យកើតឡើងហើយក្នុងទីបំផុតនៃការអស់ទៅនៃតណ្ហា ដោយវិមុត្តិដែលជារបស់ព្រះអសេក្ខៈ ។*

*ពីរបទថា* **សយំ អភិញ្ញាយ** *គឺដឹងធម៌ មានអភិញ្ញេយ្យធម៌ជាដើមបានឯង ។*

*បទថា* **កមុទ្ទិសេយ្យំ** *សេចក្ដីថា តថាគតគប្បីអាងអ្នកណាទៀតថា នេះជាឧបជ្ឈាយ៍ ឬអាចារ្យរបស់តថាគត ។*

*ក្នុងកាលចប់ទេសនា ឧបកាជីវកមិនត្រេកអរ មិនជំទាស់ព្រះតម្រាស់*

របស់ព្រះតថាគត តែគាត់ងក់ក្បាល ហៀនអណ្តាត កាន់យកផ្លូវដែលដើរទៅម្នាក់ឯង បានទៅកាន់ទីអាស្រ័យនៅរបស់ព្រានម្នាក់ហើយ ដូច្នេះឯង ។៙

**រឿង ឧបកាជីវក ចប់**

# រឿង សក្កទេវរាជ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសក្កទេវរាជ ត្រាស់ព្រះធម្មទេសនានេះថា **សព្វទានំ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ទេវតាក្នុងស្ថានតាវត្តិង្សទេវលោក ប្រជុំគ្នាហើយ តាំងប្រស្នា ៤ ប្រការថា បណ្តាទានទាំងឡាយ ទានប្រភេទណាហ្ន៎ បណ្ឌិតពោលថា កំពូល បណ្តារសទាំងឡាយ រសប្រភេទណាហ្ន៎ បណ្ឌិតពោលថា កំពូល បណ្តាសេចក្តីត្រេកអរទាំងឡាយ ការត្រេកអរប្រភេទណាហ្ន៎ បណ្ឌិតពោលថា កំពូល ការអស់ទៅនៃតណ្ហា បណ្ឌិតពោលថា ប្រសើរបំផុត ព្រោះហេតុអ្វី សូម្បីទេវតាមួយអង្គក៏មិនអាចវិនិច្ឆ័យបញ្ហាទាំងនោះបាន ។ ទេវតាមួយអង្គសួរទេវតាមួយអង្គ ទេវតាមួយអង្គនោះ ក៏សួរទេវតាមួយអង្គទៀត ទេវតាទាំងឡាយសួរគ្នានិងគ្នាយ៉ាងនេះ ដោយអាការយ៉ាងនេះ បានត្រាច់ទៅក្នុងម៉ឺនចក្កវាឡអស់ ១២ ឆ្នាំ ។

ទេវតាក្នុងម៉ឺនចក្កវាឡ មិនឃើញអត្ថនៃបញ្ហាដោយកាល សូម្បីមាន

ប្រមាណប៉ុណ្ណោះប្រជុំគ្នាហើយ ទៅកាន់សម្នាក់ទេវរាជទាំង ៤ កាលទេវរាជពោលថា បាទាំងឡាយ ហេតុអ្វី ទើបមានសន្និបាតធំ ទើបពោលថា ពួកខ្ញុំចងបញ្ហា ៤ ឡើងហើយ កាលមិនអាចវិនិច្ឆ័យបាន ទើបមកកាន់សម្នាក់របស់លោក កាលមហារាជពោលថា តើបញ្ហានោះដូចម្តេច ទើបប្រាប់សេចក្តីនោះថា ពួកខ្ញុំមិនអាចវិនិច្ឆ័យបញ្ហាទាំងនេះបាន គឺបណ្តាទាន រស និងសេចក្តីត្រេកអរ ទាន រស និងសេចក្តីត្រេកអរប្រភេទណាហ្ន៎ ប្រសើរបំផុត ការអស់ទៅនៃតណ្ហា ប្រសើរបំផុត ព្រោះហេតុអ្វី ទើបចូលមករក ។

មហារាជទាំង ៤ ពោលថា បាទាំងឡាយ ពួកខ្ញុំក៏មិនដឹងអត្ថនៃបញ្ហាទាំងនោះឡើយ តែព្រះរាជារបស់ពួកយើង ទ្រង់ត្រិះរិះអត្ថដែលជនរាប់ពាន់គិតហើយ ទ្រង់រមែងជ្រាបដោយខណៈមួយប៉ុណ្ណោះ ទ្រង់ប្រសើរវិសេសជាងពួកយើងទាំងឡាយ ទាំងផ្នែកបញ្ញា និងផ្នែកបុណ្យ ពួកយើងចូលទៅកាន់សម្នាក់របស់ទ្រង់ចុះ ហើយនាំពួកទេវតាទាំងនោះ ទៅកាន់សម្នាក់របស់សក្កទេវរាជសូម្បីសក្កទេវរាជក៏ត្រាស់ថា បាទាំងឡាយ ហេតុអ្វី ទើបមានទេវសន្និបាតធំក៏ក្រាបទូលសេចក្តីនោះ ។

សក្កទេវរាជត្រាស់ថា បាទាំងឡាយ អ្នកដទៃមិនអាចដឹងអត្ថនៃបញ្ហាទាំងនេះបាន បញ្ហាទាំងនោះ ជាវិស័យរបស់ព្រះពុទ្ធ ហើយត្រាស់សួរថាឥឡូវនេះ ព្រះសាស្តាប្រថាប់នៅក្នុងទីណា ពួកទេវតាទូលថា ក្នុងជេតពនមហាវិហារ ទើបសក្កៈត្រាស់ថា មកចុះ ពួកយើងនឹងទៅកាន់សម្នាក់របស់ព្រះអង្គ មួយអន្លើដោយពួកទេវតា ឲ្យវត្តជេតពនទាំងមូលភ្លឺហើយ ក្នុង

ចំណែកនៃរាត្រី ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ប្រថាប់ឈរក្នុងចំណែកម្ខាង កាលព្រះសាស្តាត្រាស់ថា មហាបពិត្រ ហេតុអ្វី ទើបទ្រង់យាងមក មួយអន្លើដោយពួកទេវតាសន្ធឹកសន្ធាប់ ទើបក្រាបទូលថា បពិត្រព្រះអង្គ ពួកទេវតានាំគ្នាតាំងបញ្ហាឈ្មោះនេះ អ្នកដទៃ ឈ្មោះថា អាចដឹងនូវអត្ថនៃបញ្ហាទាំងនេះមិនមាន សូមទ្រង់ប្រកាសអត្ថនៃបញ្ហាទាំងនេះ ដល់ពួកខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តាត្រាស់ថា សាធុ មហាបពិត្រ តថាគតបំពេញបារមី ៣០ មហាបរិច្ចាគ ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណហើយ ក៏ដើម្បីកាត់សេចក្តីសង្ស័យរបស់ជនដូចទ្រង់នោះឯង ។ សូមទ្រង់ស្តាប់បញ្ហាដែលទ្រង់សួរហើយចុះ ។ បណ្តាទានគ្រប់យ៉ាង ធម្មទានជាកំពូល បណ្តារសគ្រប់ប្រភេទ រសនៃធម៌ជាកំពូល បណ្តាសេចក្តីត្រេកអរគ្រប់យ៉ាង ការត្រេកអរក្នុងធម៌ប្រសើរ ចំណែកការអស់ទៅនៃតណ្ហាប្រសើរបំផុតពិត ព្រោះជាហេតុឲ្យសត្វសម្រេចអរហត្តដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ**
**សព្វរតឹ ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។**

ធម្មទានឈ្នះអាមិសទានទាំងពួង ធម្មរសឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហាឈ្នះទុក្ខទាំងពួង ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្វទានំ** ជាដើម សេចក្តីថា បើបុគ្គលគប្បីថ្វាយត្រៃចីវរ ដូចស្លឹកចេកខ្ចីដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយ ដែលអង្គុយជាប់គ្នាក្នុងល្វែងនៃចក្កវាឡ ដល់ព្រហ្មលោក ការអនុមោទនា ដែលព្រះពុទ្ធជាដើមទ្រង់ធ្វើដោយគាថា ៤ បាទ ក្នុងសមាគមនោះប្រសើរ ទាននោះមិនមានតម្លៃស្មើនឹងចម្រៀកទី ១៦ នៃព្រះគាថានោះឡើយ ការសម្តែងក្តី ការបង្រៀនក្តី ការស្តាប់ក្តីនូវធម៌ដែលជារបស់ធំដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត បុគ្គលឲ្យធ្វើនូវការស្តាប់ធម៌ អានិសង្សជាច្រើនរមែងមានដល់បុគ្គលនោះពិត ធម្មទាននោះឯង ដែលព្រះពុទ្ធជាដើម ទ្រង់ឲ្យប្រព្រឹត្តទៅហើយ ដោយអំណាចអនុមោទនា ដោយហោចសូម្បីគាថា ៤ បាទ ប្រសើរជាងទាន ដែលទាយកដាក់បាត្រឲ្យពេញ ដោយបិណ្ឌបាតដ៏ប្រណីត ហើយថ្វាយដល់លោកអ្នកទាំងនោះឯង ក្រៃលែងជាងភេសជ្ជទានដែលទាយកដាក់ពេញបាត្រ ដោយសប្បិ និងប្រេងជាដើមហើយថ្វាយ ជាងសេនាសនទានដែលទាយកឲ្យសាងវិហារ ដូចគ្នានឹងមហាវិហារ និងលោហប្រាសាទទាំងឡាយមួយសែនហើយថ្វាយ ជាងបរិច្ចាគដែលអនាថបិណ្ឌិកសេដ្ឋីជាដើមប្រារព្ធវិហារទាំងឡាយ ហើយធ្វើ ព្រោះហេតុអ្វី ព្រោះថា ជនទាំងឡាយកាលបំពេញបុណ្យបែបនោះ លុះស្តាប់ធម៌ហើយប៉ុណ្ណោះ ទើបធ្វើបាន បើមិនបានស្តាប់ មិនអាចធ្វើបានឡើយ បើសត្វទាំងនេះមិនស្តាប់ធម៌សោត ក៏មិនអាចឲ្យសូម្បីបបរប្រមាណមួយវែក កត្តប្រមាណមួយវែក ព្រោះហេតុនេះ ទើបធម្មទាននោះឯង ប្រសើរជាងទានទាំងអស់ ។

ម្យ៉ាងទៀត វៀរព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធ សូម្បីសាវ័កទាំងឡាយ មានព្រះសារីបុត្តជាដើមដែលប្រកបដោយបញ្ញា ដែលអាចរាប់តំណក់ទឹកបានក្នុងកាលភ្លៀងធ្លាក់អស់មួយកប្ប ក៏មិនអាចសម្រេចសោតាបត្តិផលជាដើមដោយធម្មតារបស់ខ្លួនបាន លុះណាតែស្តាប់ធម៌ដែលព្រះអស្សជិត្ថេរជាដើមសំដែងហើយ ទើបធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល និងធ្វើឲ្យជាក់ច្បាស់នូវសាវកបារមីញាណ ដោយព្រះធម្មទេសនារបស់ព្រះសាស្តា ព្រោះហេតុនេះ មហាបពិត្រ ធម្មទាននោះឯង ទើបឈ្មោះថា ប្រសើរបំផុត ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **សព្វទានំ ធម្មទានំ ជិនាតិ ។**

ម្យ៉ាងទៀត រស មានរសកើតអំពីដើមជាដើមគ្រប់ប្រភេទ ដោយចំណែកខ្ពស់ សូម្បីរសនៃសុធាភោជនរបស់ទេវតាទាំងឡាយ រមែងជាបច្ច័យនៃការញុំាងសត្វឲ្យធ្លាក់ទៅក្នុងសង្សារវដ្ត ហើយសោយទុក្ខដោយពិត ។ ចំណែកធម្មរស ពោល គឺពោធិបក្ខិយធម៌ ៣៧ ប្រការ ពោល គឺលោកុត្តរធម៌ ៩ ប្រការនេះឯង ប្រសើរជាងរសទាំងពួង ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **សព្វរសំ ធម្មរសោ ជិនាតិ ។**

ម្យ៉ាងទៀត សេចក្តីត្រេកអរក្នុងបុត្រ សេចក្តីត្រេកអរក្នុងធីតា សេចក្តីត្រេកអរក្នុងទ្រព្យ សេចក្តីត្រេកអរក្នុងស្ត្រី សេចក្តីត្រេកអរមានប្រភេទមិនមែនតែមួយ មានសេចក្តីត្រេកអរក្នុងការច្រៀង និងការប្រគំជាដើម រមែងជាបច្ច័យនៃការញុំាងសត្វឲ្យធ្លាក់ទៅក្នុងសង្សារវដ្ត ហើយសោយទុក្ខដោយពិត ចំណែកការត្រេកអរដែលកើតឡើងខាងក្នុងនៃអ្នកសំដែងក្តី អ្នកស្តាប់ក្តី បុគ្គល

ពោលទូន្មានក្តីនូវធម៌ រមែងឲ្យកើតការត្រេកអរ ហូរទឹកភ្នែក ឲ្យកើតព្រឺរោម ការត្រេកអរនោះ រមែងធ្វើទីបំផុតនៃសង្សារវដ្ត មានអរហត្ត ជាបរិយោសាន សេចក្តីត្រេកអរក្នុងធម៌បែបនេះឯង ប្រសើរជាងសេចក្តីត្រេកអរទាំងពួង ។ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **សព្វរតឹ ធម្មរតិ ជិនាតិ ។**

ចំណែកការអស់ទៅនៃតណ្ហា គឺព្រះអរហត្ត ដែលកើតឡើងក្នុងទីបំផុតនៃការអស់ទៅរបស់តណ្ហា ព្រះអរហត្តនោះ ប្រសើរជាងរបស់គ្រប់យ៉ាងពិត ព្រោះគ្របសង្កត់វដ្តទុក្ខទាំងមូល ។ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា **តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។**

កាលព្រះសាស្តា ត្រាស់អត្ថនៃព្រះគាថានេះដោយប្រការដូច្នេះនោះឯង ធម្មាភិសម័យ មានដល់សត្វ ៨៤០០០ ហើយ ។

សក្កទេវរាជ ទ្រង់ស្តាប់ធម្មកថារបស់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តា ហើយទូលថា បពិត្រព្រះអង្គ ដើម្បីប្រយោជន៍អ្វីទើបទ្រង់មិនត្រាស់ឲ្យចំណែកបុណ្យដល់ពួកខ្ញុំព្រះអង្គ ក្នុងធម្មទានដែលកំពូលយ៉ាងនេះ ចាប់តាំងអំពីនេះទៅ សូមទ្រង់ប្រាប់ដល់ភិក្ខុសង្ឃ ឲ្យលោកឲ្យនូវចំណែកបុណ្យដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់សក្កៈហើយ ត្រាស់ឲ្យភិក្ខុសង្ឃប្រជុំគ្នាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តាំងអំពីនេះទៅ ពួកអ្នកធ្វើការស្តាប់ធម៌ធំក្តី ស្តាប់ធម៌តាមប្រក្រតីក្តី ពោលឧបនិសិន្នកថាក្តី ដោយហោចសូម្បីត្រឹមតែការអនុមោទនាក្តី ហើយគប្បីឲ្យចំណែកបុណ្យដល់សត្វទាំងពួង ។

**រឿងសក្កទេវរាជ ចប់**

# រឿង អបុត្តកសេដ្ឋី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះអបុត្តកៈ ត្រាស់ព្រះធម្មទេសនានេះថា **ហនន្តិ ភោគា ទុម្មេធំ** ជាដើម ។

បានឮមកថា ព្រះបាទបសេនទិកោសល ទ្រង់ស្តាប់ការធ្វើកាលកិរិយារបស់សេដ្ឋីនោះហើយ ទើបត្រាស់សួរថា ទ្រព្យសម្បត្តិរបស់បុគ្គលដែលឥតបុត្រគួរបានអ្នកណា ទ្រង់បានស្តាប់ថា គួរដល់ព្រះរាជា ទើបឲ្យនាំទ្រព្យអំពីផ្ទះរបស់សេដ្ឋីនោះមកកាន់រាជត្រកូលអស់ ៧ ថ្ងៃ ហើយទើបយាងចូលទៅកាន់សម្នាក់របស់ព្រះសាស្តា កាលព្រះសាស្តាត្រាស់ថា មហាបពិត្រ ទ្រង់យាងមកអំពីណាទាំងកណ្តាលថ្ងៃ ទើបក្រាបទូលថា បពិត្រព្រះអង្គ គហបតីដែលជាសេដ្ឋីក្នុងក្រុងសាវត្ថីនេះ ធ្វើកាលកិរិយាហើយ ខ្ញុំព្រះអង្គនាំទ្រព្យសម្បត្តិសេដ្ឋីដែលមិនមានកូននោះ ទៅទុកក្នុងរាជសម្នាក់ ហើយទើបត្រឡប់មក ។

រឿងទាំងពួង គប្បីជ្រាបតាមន័យដែលមកក្នុងព្រះសូត្រនោះឯង ។

កាលព្រះរាជាក្រាបទូលយ៉ាងនេះថា បានឮថា សេដ្ឋីនោះ កាលគេនាំភោជន មានរសប្រសើរផ្សេងៗ ចូលទៅដោយថាសមាស ក៏ពោលថា ពួកមនុស្សរមែងបរិភោគភោជនបែបនេះដែរឬ ពួកអ្នកធ្វើការចំអកឲ្យខ្ញុំក្នុងផ្ទះនេះឬ កាលជនទាំងនោះចូលទៅតាំងភោជន ក៏ឲ្យនូវការប្រហារដល់មនុស្សទាំងនោះដោយដុំដី និងអង្កត់ឧសជាដើម ឲ្យគេចទៅហើយ បរិភោគបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ពីរ ដោយពោលថា នេះទើបជាភោជនរបស់ពួកមនុស្ស ។ កាលគេរៀបចំសំពត់ យាន និងឆត្រដែលគួរពេញចិត្តឲ្យ ក៏

ប្រហារមនុស្សទាំងនោះ ដោយដុំដី និងអង្កត់ឧសជាដើម ឲ្យគេចទៅហើយ ទ្រទ្រង់នូវសំពត់សម្បកឈើ មានចត្រស្លឹកឈើដែលទ្រទ្រង់ រមែងទៅដោយរទេះចាស់ៗ ទើបព្រះមានព្រះភាគត្រាស់ដល់បុព្វកម្មរបស់អបុត្តកសេដ្ឋីនោះ

មហាបពិត្រ រឿងធ្លាប់មានមកហើយ គហបតីសេដ្ឋីនោះ ទទួលព្រះបច្ចេកពុទ្ធព្រះនាមតគរសិខីដោយបិណ្ឌបាត ពោលថា ចូរអ្នកទាំងឡាយឲ្យបិណ្ឌបាតដល់សមណៈ ដូច្នេះហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ បានឮថា កាលសេដ្ឋីនោះមិនមានសទ្ធា ជាអ្នកល្ងង់ខ្លៅ ពោលយ៉ាងនោះហើយចៀសចេញទៅ ភរិយារបស់គាត់មានសទ្ធាជ្រះថ្លា គិតថា យូរហើយហ្ន៎ ទើបអញបានឮពាក្យថា ចូរឲ្យអំពីមាត់របស់សេដ្ឋីនេះ មនោរថរបស់អញពេញក្នុងថ្ងៃនេះ អញនឹងថ្វាយបិណ្ឌបាត ហើយទទួលបាត្ររបស់ព្រះបច្ចេកពុទ្ធ ឲ្យពេញដោយភោជនដ៏ប្រណីត ហើយប្រគេន ។ ចំណែកសេដ្ឋីនោះ ត្រឡប់មកឃើញព្រះបច្ចេកពុទ្ធអង្គនោះ ទើបសួរថា សមណៈបានអ្វីហើយឬ ហើយចាប់បាត្រ ឃើញបិណ្ឌបាតដ៏ប្រណីតក៏មានសេចក្ដីក្ដៅក្រហាយ ទើបគិតយ៉ាងនេះថា ពួកទាសៈ ឬពួកកម្មករគប្បីបរិភោគបិណ្ឌបាតនេះល្អជាង ព្រោះថា ជនទាំងនោះ កាលបរិភោគបិណ្ឌបាតនេះហើយ នឹងធ្វើការងារឲ្យអញ ចំណែកសមណៈនេះ កាលទៅបរិភោគហើយ ក៏នឹងដេកលក់ បិណ្ឌបាតរបស់អញវិនាសទទេ ម្យ៉ាងទៀត សេដ្ឋីនោះផ្ដាច់ហើយនូវជីវិតរបស់កុមារម្នាក់ ដែលជាកូនរបស់បងប្រុស ព្រោះហេតុនៃទ្រព្យសម្បត្តិ ។ បានឮថា កុមារនោះចាប់ដៃរបស់សេដ្ឋីនោះត្រាច់ទៅពោលថា យាននេះជារបស់បិតាខ្ញុំ គោនេះក៏ជារបស់

គាត់ ។ លំដាប់នោះ សេដ្ឋីគិតថា ក្នុងឥឡូវនេះ ក្មេងនេះគង់ពោលយ៉ាងនេះ ក្នុងកាលដែលក្មេងនេះ ដល់នូវសេចក្តីចម្រើនហើយ អ្នកណានឹងរក្សាភោគ-ទ្រព្យទាំងឡាយក្នុងផ្ទះនេះបាន ទើបនាំក្មេងនោះទៅកាន់ព្រៃ ចាប់ត្រង់កហើយប្របាច់ក ដូចប្របាច់ដំឡូងឲ្យស្លាប់ហើយត្រង់គុម្ពឈើមួយកន្ទែង ហើយចោលក្មេងនោះក្នុងទីនោះឯង នេះជាបុព្វកម្មរបស់សេដ្ឋីនោះ ។

ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា មហាបពិត្រ ដោយផលនៃកម្មដែលគហបតីជាសេដ្ឋី ទទួលព្រះបច្ចេកពុទ្ធ ព្រះនាមតគរសិខី ដោយបិណ្ឌបាតនោះឯង ទើបសេដ្ឋីនោះចូលដល់សុគតិ គឺស្ថានសួគ៌អស់ ៧ ដង ដោយផលដ៏សេសនៃកម្មនោះឯង ទើបសេដ្ឋីបានជាសេដ្ឋីក្នុងក្រុងសាវត្ថីនេះអស់ ៧ ដង ។ មហាបពិត្រ ដោយផលនៃកម្មដែលគហបតីជាសេដ្ឋីនោះឲ្យទានហើយ មានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយថា ពួកទាសៈឬកម្មករ គប្បីបរិភោគបិណ្ឌបាតនេះល្អជាង ចិត្តរបស់សេដ្ឋីនោះមិនបង្អោនទៅដើម្បីបរិភោគភត្តដែលប្រណីត មិនបង្អោនទៅដើម្បីការប្រើប្រាស់សំពត់ប្រណីត មិនបង្អោនទៅដើម្បីប្រើប្រាស់យានល្អៗ មិនបង្អោនទៅដើម្បីបរិភោគកាមគុណ ៥ ដែលល្អក្រៃលែង មហាបពិត្រ ដោយផលនៃកម្មដែលគហបតីជាសេដ្ឋីនោះផ្តាច់នូវជីវិតកុមារម្នាក់របស់បងប្រុស ព្រោះហេតុនៃទ្រព្យសម្បត្តិ ទើបសេដ្ឋីនោះឆេះហើយក្នុងនរកអស់ឆ្នាំជាច្រើន អស់រយឆ្នាំជាច្រើន អស់ពាន់ឆ្នាំជាច្រើន អស់សែនឆ្នាំជាច្រើន ។ ជនទាំងឡាយញ៉ាំងសម្បត្តិ ដែលឥតកូនលើកទី ៧ នេះ ឲ្យចូលកាន់ឃ្លាំងព្រះរាជាដោយផលដ៏សេសនៃកម្មនោះឯង ។

មហាបពិត្រ មួយសោត បុណ្យចាស់របស់គហបតីដែលជាសេដ្ឋីនោះអស់ហើយ និងបុណ្យថ្មីដែលគហបតីសេដ្ឋីនោះសន្សំហើយ មហាបពិត្រ ក្នុងថ្ងៃនេះ គហបតីដែលជាសេដ្ឋី ឆេះក្នុងមហារោរុវនរក ។

ព្រះរាជាទ្រង់ស្តាប់ព្រះតម្រាស់របស់ព្រះសាស្តាហើយ ទើបក្រាបទូលថា បពិត្រព្រះអង្គ គួរអស្ចារ្យ នេះជាកម្មធ្ងន់ សេដ្ឋីនោះកាលភោគៈឈ្មោះថាមានប្រមាណប៉ុណ្ណោះមាន មិនប្រើប្រាស់ដោយខ្លួនឯង កាលព្រះពុទ្ធដូចទ្រង់ប្រថាប់នៅក្នុងវិហារជិតបង្កើយ ក៏មិនបានធ្វើបុញ្ញកម្ម ។

ព្រះសាស្តាត្រាស់ថា ពិតហើយ ឈ្មោះថា បុគ្គលមានបញ្ញាថោកថយបាននូវភោគៈទាំងឡាយហើយ រមែងមិនស្វែងរកព្រះនិព្វាន ម្យ៉ាងទៀត តណ្ហាដែលកើតឡើងព្រោះអាស្រ័យភោគៈទាំងឡាយ រមែងសម្លាប់មនុស្សទាំងនោះអស់កាលយូរ ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា

**ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**
**ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។**
**តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា**
**តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។**

ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញា ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយ គឺព្រះនិព្វានទេ ឯបុគ្គលអប្បប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃព្រោះចំណង់ក្នុងភោគៈ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ

មានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យ

ហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមាន

ផលច្រើន ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បាទព្រះគាថាថា **នោ ច ចារគវេសិនោ** សេចក្ដីថា តែភោគៈទាំងឡាយ មិនសម្លាប់បុគ្គលដែលស្វែងរកត្រើយ គឺព្រះនិព្វានដោយប្រក្រតីឡើយ ។

បាទព្រះគាថាថា **ហន្តិ អញ្ញេវ អត្តនំ** សេចក្ដីថា បុគ្គលដែលមានបញ្ញាថោកថយ រមែងសម្លាប់ខ្លួនឯងដូចសម្លាប់បុគ្គលដទៃ ព្រោះការចង់បានដែលកើតឡើងព្រោះអាស្រ័យភោគៈទាំងឡាយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿងអបុត្តកសេដ្ឋី ចប់**

# រឿង អង្កុរទេវបុត្រ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅលើផែនបណ្ឌុកម្ពលសិលា ទ្រង់ប្រារព្ធអង្កុរ-ទេវបុត្រ ត្រាស់ព្រះធម្មទេសនានេះថា **តិណទោសានិ ខេត្តានិ** ជាដើម ។

ខ្ញុំធ្វើរឿងឲ្យពិស្តារហើយ ក្នុងព្រះគាថាថា **យេ ឈានបសុតា ធីរា** ជាដើម សមដូចពាក្យដែលខ្ញុំប្រារព្ធឥន្ទកទេវបុត្រ ពោលក្នុងរឿងនោះ ដូច្នេះ ថា បានឮថា ឥន្ទកទេវបុត្រនោះ ញ៉ាំងភិក្ខាមួយវែកដែលគេនាំមកដើម្បីខ្លួន ដល់ព្រះអនុរុទ្ធត្ថេរ ដែលចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ បុណ្យរបស់ឥន្ទកទេវបុត្រនោះ មានផលច្រើនជាងទានដែលអង្កុរទេវបុត្រធ្វើដោយចង្រ្កានតម្រៀបគ្នា ១២ យោជន៍ ថ្វាយហើយអស់មួយម៉ឺនឆ្នាំ ព្រោះហេតុនោះ ទើបឥន្ទកទេវបុត្រពោលយ៉ាងនោះ ។ កាលឥន្ទកទេវបុត្រពោលយ៉ាងនោះហើយ ទើបព្រះសាស្តាត្រាស់ថា ម្នាលអង្កុរៈ ឈ្មោះថា ការជ្រើសរើសឲ្យទាន គួរ ទានរបស់ឥន្ទកៈនោះ ជាទានមានផលច្រើន ដូចពូជដែលព្រោះល្អហើយ ក្នុងស្រែល្អយ៉ាងនេះ តែអ្នកមិនបានធ្វើយ៉ាងនោះ ព្រោះហេតុនោះ ទើបទានរបស់អ្នកមិនមានផលច្រើន កាលទ្រង់ប្រកាសអត្ថនេះ ទើបត្រាស់ថា

បុគ្គលគួរជ្រើសរើសឲ្យទាន ក្នុងខេត្តដែលខ្លួនឲ្យហើយ នឹងមាន
ផលច្រើន ព្រោះការជ្រើសរើសឲ្យ ព្រះសុគតទ្រង់សរសើរ
ហើយ ទានដែលឲ្យក្នុងបុគ្គលជាទក្ខិណេយ្យ ក្នុងជីវលោកនេះ
ជាទានមានផលច្រើន ដូចពូជដែលព្រោះក្នុងស្រែល្អ ដូច្នោះ ។

កាលទ្រង់សម្តែងឲ្យក្រៃលែងឡើង ទើបទ្រង់ភាសិតព្រះគាថាទាំងនេះ

តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា
តស្មា ហិ វីតតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្តីប្រណែនជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានសេចក្តីប្រណែនអស់ហើយ រមែងជាទានមានផលច្រើន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **តិណទោសានិ** សេចក្តីថា សេចក្តីពិតស្មៅទាំងឡាយ មានថ្លៅជាដើមកាលដុះឡើង រមែងប្រទូស្តស្រែនៃបុព្វណ្ណជាតិ

និងអបរណ្ណជាតិ ព្រោះហេតុនោះ ទើបស្រែទាំងនោះ មិនដុះលូតលាស់ល្អបាន រាគៈកាលកើតឡើងខាងក្នុងនៃសត្វទាំងឡាយ រមែងប្រទូស្តសត្វទាំងឡាយ ព្រោះហេតុនោះ ទានដែលឲ្យក្នុងបុគ្គលដែលត្រូវរាគៈប្រទូស្តទាំងនោះ ទើបជារបស់មិនមានផលច្រើន ចំណែកទានដែលឲ្យក្នុងព្រះខីណាស្រពទាំងឡាយ ជារបស់មានផលច្រើន ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ថា ស្រែទាំងឡាយ មានស្មៅជាទោស ពួកសត្វមានរាគៈជាទោសដូច្នោះឯង ទានដែលឲ្យក្នុងបុគ្គលដែលប្រាសចាករាគៈ ទើបជារបស់មានផលច្រើន ។ ក្នុងគាថាដ៏សេសក៏ន័យនេះឯង ។

ក្នុងកាលចប់ទេសនា អង្កុរទេវបុត្រ និងឥន្ទកទេវបុត្រតាំងនៅក្នុងសោតាបត្តិផល ។ ទេសនាបានជាប្រយោជន៍ដល់ពួកទេវបុត្រដែលប្រជុំគ្នាហើយ ដូច្នេះឯង ៕

**រឿងអង្កុរទេវបុត្រ ចប់**

**តណ្ហាវគ្គ ចប់**

**វគ្គទី ២៤ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា ភិក្ខុវគ្គទី ២៥

[ ៣៥ ] ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

ជនណា សង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋាន ដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយហៅជននោះថា ភិក្ខុ ។

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សម្តែងអត្ថផង ធម៌ផងបាន ភាសិតរបស់ភិក្ខុនោះ ទើបឈ្មោះថា ពីរោះ ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

ភិក្ខុមិនគប្បីមើលងាយលាភរបស់ខ្លួន ( ដែលកើតឡើងដោយធម៌ ) មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃ រមែងមិនបានសមាធិឡើយ ។ បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតា និងមនុស្សទាំងឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាមជាគ្រឿងអាស្រ័យរស់នៅដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាម និងរូបថាជារបស់អញ ដោយប្រការទាំងពួង មួយទៀត បុគ្គលណា មិនសោកស្តាយ ព្រោះនាម និងរូបដែលមិនមាន បុគ្គលនោះឯង តថាគតហៅថា ភិក្ខុ ។

ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។ ម្នាលភិក្ខុ ចូរអ្នកស្តារទូក គឺអត្តភាពនេះ ទូកដែលអ្នកស្តារហើយ នឹងដល់ត្រើយឆាប់ អ្នកកាត់រាគៈ និងទោសៈបានហើយ អំពើនោះ នឹងអាចដល់នូវព្រះនិព្វាន ។

ភិក្ខុគប្បីកាត់ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់ឧទ្ធម្ភាគិយ-សំយោជនៈ ៥ ផង គប្បីចម្រើនឥន្ទ្រិយ ៥ តទៅ ភិក្ខុអ្នកកន្លងកិលេសជាគ្រឿងជំពាក់ ៥ ( រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ ) បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន ។

ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្តរបស់អ្នក ចូរកុំវិលទៅរកកាមគុណឡើយ អ្នកចូរកុំប្រមាទ ទំពាស៊ីនូវដុំលោហៈ កុំឲ្យជាអ្នកកាលភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខ ដូច្នេះឡើយ ។ ការពិនិត្យមិនមានដល់បុគ្គល អ្នកមិនមានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យ និងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះឯង ឈ្មោះថាស្ថិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

សេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ ។ ភិក្ខុ

ពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។

គុណ ៣ ប្រការនេះ គឺការរក្សាឥន្ទ្រិយ ១ សេចក្ដីសន្ដោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជាខាងដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ ( ម្នាលភិក្ខុ ) អ្នកចូរគប់រកកល្យាណមិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្វើបដិសណ្ឋារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារព្រោះហេតុទាំង ២ នោះ អ្នកនឹងមានបាមោជ្ជច្រើន នឹងធ្វើទីបំផុតទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជម្រុះរាគៈ និងទោសៈចេញ ដូចម្លិះជម្រុះផ្កាម្លិះទាំងឡាយ ដែលស្វិតហើយ ដូច្នោះ ។

ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសក្នុងលោក ខ្ជាក់ចោលហើយ ទើបតថាគតហៅថា អ្នកស្ងប់រម្ងាប់ ។

អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង ចូរពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះ បើមានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។

មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររារាំងខ្លួន ដូចពាណិជ្ជរារាំងសេះដ៏ល្អ ។

ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែង បាននូវបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

ភិក្ខុណានៅកំលោះ ប្រឹងប្រែងក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែង ញ៉ាំងលោកនេះឲ្យភ្លឺស្វាងបាន ដូចព្រះចន្ទ្រដែលរះផុតអំពីពពក ។

**ភិក្ខុវគ្គទី ២៥ ចប់**

# អដ្ឋកថា
# ភិក្ខុវគ្គទី ២៥

## រឿងភិក្ខុ៥រូប
### លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥ រូប ត្រាស់ព្រះធម្មទេសនានេះថា **ចក្ខុនា សំវរោ សាធុ** ជាដើម ។

បានឮថា បណ្តាភិក្ខុ ៥ រូបនោះ មួយរូបៗ រក្សាទ្វារទាំង ៥ មានចក្ខុទ្វារជាដើម មួយរូបមួយទ្វារប៉ុណ្ណោះ ។

ថ្ងៃមួយ ពួកលោកប្រជុំគ្នាហើយ ប្រកែកគ្នាថា ខ្ញុំរមែងរក្សាទ្វារដែលរក្សាបានលំបាក ខ្ញុំរក្សាទ្វារដែលរក្សាបានលំបាក ហើយពោលថា ពួកយើងក្រាបទូលព្រះសាស្តាហើយ នឹងដឹងសេចក្តីនេះ ទើបចូលទៅគាល់ព្រះសាស្តាក្រាបទូលសួរថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គរក្សាទ្វារ មានចក្ខុទ្វារជាដើម រមែងសម្គាល់ថា ទ្វារដែលខ្លួនរក្សានោះឯង ជាទ្វារដែលរក្សាបានដោយលំបាក បណ្តាពួកខ្ញុំព្រះអង្គ អ្នកណាហ្ន៎រក្សាទ្វារ ដែលរក្សាបានដោយលំបាក ។

ព្រះសាស្តា ទ្រង់មិនញ៉ាំងភិក្ខុណាមួយឲ្យអាក់អន់ចិត្ត ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទ្វារទាំងអស់នោះជាវត្ថុរក្សាបានដោយលំបាកពិត ម្យ៉ាងទៀត ពួកអ្នកមិនសង្រួមហើយក្នុងទ្វារទាំង ៥ ក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុង

កាលមុន ពួកអ្នកក៏មិនសង្រួមហើយ ពួកអ្នកមិនប្រព្រឹត្តក្នុងឱវាទរបស់បណ្ឌិតទាំងឡាយ ដល់នូវការអស់ទៅនៃជីវិត ព្រោះភាពដែលទ្វារទាំងនោះ ខ្ញុំមិនបានសង្រួមហើយនោះឯង កាលភិក្ខុទាំងនោះទូលអង្វរថា បពិត្រព្រះអង្គ តើមិនសង្រួមក្នុងកាលណា ទើបត្រាស់រឿងតក្កសិលាជាតកឲ្យពិស្តារ ហើយត្រាស់ព្រះគាថានេះថា

> យើងមិនបានលុះក្នុងអំណាចនៃពួកយក្ខិនីឡើយ ព្រោះមានសេចក្ដីព្យាយាមដ៏មាំ ក្នុងឧបាយគ្រឿងណែនាំរបស់ព្រះបច្ចេកពុទ្ធ ជាអ្នកឈ្លាសផង ព្រោះភាពជាអ្នកគ្រប សង្កត់សេចក្ដីខ្លាច និងសេចក្ដីតក់ស្លុតផង សុវត្ថិភាពចាកភ័យដ៏ធំនោះ មានដល់ខ្ញុំ ។

ព្រះមហាសត្វបានទទួលអភិសេកហើយ ក្នុងកាលរាជត្រកូលដល់នូវការអស់ទៅនៃជីវិត ព្រោះអំណាចនៃយក្ខិនីទាំងឡាយ ប្រថាប់គង់លើរាជអាសនៈខាងក្រោមស្វេតច្ឆត្រ ទតសិរីសម្បត្តិរបស់ទ្រង់ហើយ ត្រាស់ថា ឈ្មោះថា សេចក្ដីព្យាយាមនេះ សត្វទាំងឡាយគួរធ្វើពិត ហើយទ្រង់បន្លឺដោយអំណាចបីតិ ទ្រង់ប្រជុំជាតកថា សូម្បីក្នុងកាលនោះ អ្នកទាំងឡាយជាជន ៥ នាក់ មានអាវុធក្នុងដៃ ចោមរោមព្រះមហាសត្វដែលយាងចេញទៅដើម្បីប្រយោជន៍គ្រប់គ្រងរាជសម្បត្តិ ក្នុងនគរតក្កសិលា ធ្វើដំណើរទៅមិនសង្រួមហើយក្នុងអារម្មណ៍ មានរូបារម្មណ៍ជាដើម ដែលយក្ខិនីទាំង-ឡាយនាំចូលមក ដោយអំណាចនៃទ្វារ មានចក្ខុទ្វារជាដើមក្នុងរវាងផ្លូវ មិន

ប្រព្រឹត្តក្នុងឱវាទរបស់បណ្ឌិត សម្លឹងមើល ត្រូវយក្ខិនីទាំងឡាយទំពាស៊ី ដល់នូវការអស់ទៅនៃជីវិត ។ ចំណែកព្រះរាជា ទ្រង់សង្រួមក្នុងអារម្មណ៍ទាំងនោះ មិនអើពើដល់យក្ខិនី ដែលនិម្មិតភេទដូចទេពធីតា ដើរទៅអំពីខាងក្រោយ ដល់នគរតក្កសិលាដោយសួស្ដី ហើយបានជាព្រះរាជា គឺតថាគតនេះឯង ហើយត្រាស់ថា ធម្មតាភិក្ខុ គួរសង្រួមទ្វារទាំងឡាយ ព្រោះថា ភិក្ខុសង្រួមទ្វារទាំងនោះ តែងផុតចាកទុក្ខទាំងពួងបាន ដូច្នេះហើយ កាលទ្រង់សម្ដែងធម៌ បានភាសិតព្រះគាថាទាំងនេះថា

**ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ**
**ឃានេន សំវរោ សាធុ សាធុ ជិវ្ហាយ សំវរោ**
**កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ**
**មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ**
**សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។**

ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្ដាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

## សេចក្ដីអធិប្បាយ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចក្ខុនា** ជាដើមក្នុងព្រះគាថានោះដូចតទៅ

ក្នុងកាលណារូបារម្មណ៍ មកកាន់គន្លងចក្ខុទ្វាររបស់ភិក្ខុ ក្នុងកាលនោះ កាលភិក្ខុមិនត្រេកអរក្នុងអារម្មណ៍ដែលគួរប្រាថ្នា មិនប្រទូស្តក្នុងអារម្មណ៍ដែលមិនគួរប្រាថ្នា មិនញុំាងការវង្វេងឲ្យកើតឡើង ព្រោះការសម្លឹងដែលមិនស្មើ ការសង្រួម គឺការរារាំង បានដល់ ការបិទ សំដៅដល់ការរក្សា ឈ្មោះថាជាកិរិយាដែលភិក្ខុធ្វើហើយក្នុងទ្វារនោះ ការសង្រួមចក្ខុនោះ បែបនោះរបស់ភិក្ខុនោះ ជាគុណញុំាងប្រយោជន៍ឲ្យសម្រេច ន័យសូម្បីក្នុងទ្វារដទៃ មានសោតទ្វារជាដើម ក៏ដូចគ្នានឹងន័យនេះ ។

ការសង្រួម ឬការមិនសង្រួម រមែងមិនកើតក្នុងទ្វារទាំងឡាយ មានចក្ខុទ្វារជាដើមឡើយ តែការសង្រួម ឬការមិនសង្រួមនេះ រមែងបានក្នុងវិថីនៃជវនចិត្តខាងមុខ ពិតហើយ ក្នុងកាលនោះ ការមិនសង្រួមកាលកើតឡើងជាអកុសលធម៌ ៥ យ៉ាង គឺការមិនជឿ ១ ការមិនអត់ធន់ ១ ការខ្ជិលច្រអូស ១ ការមិនមានស្មារតី ១ ការមិនដឹង ១ រមែងបានក្នុងអកុសលវិថី ។ សេចក្តីសង្រួមកាលកើតឡើង ជាកុសលធម៌ ៥ យ៉ាង គឺការជឿ ១ ការអត់ធន់ ១ សេចក្តីព្យាយាម ១ ការមានស្មារតី ១ ការដឹង ១ រមែងបានក្នុងកុសលវិថី ។

ឯកាយបសាទក្តី ចោបនកាយក្តី រមែងបានក្នុងពីរបទថា **កាយេន សំវរោ** ពាក្យថា កាយបសាទ និងចោបនកាយទាំងពីរយ៉ាងនោះ គឺកាយទ្វារនោះឯង ។ ក្នុងកាយទ្វារទាំងពីរនោះ ព្រះសាស្តាត្រាស់ការសង្រួម និងការមិនសង្រួមក្នុងបសាទទ្វារនោះឯង ។ ត្រាស់បាណាតិបាត អទិន្នាទាន និង

មិច្ឆាចារ ដែលមានបសាទទ្វារនោះជាទីតាំងក្នុងចោបនទ្វារ ។ ទ្វារនោះ ឈ្មោះថា កិក្ខុមិនសង្រួមហើយ ព្រោះអកុសលធម៌ទាំងនោះ ដែលកើតឡើងក្នុងអកុសលវិថី មួយអន្លើដោយបសាទទ្វារ និងចោបនទ្វារទាំងនោះ ទ្វារនោះ ឈ្មោះថា កិក្ខុសង្រួមហើយ ព្រោះវិរតិទាំងឡាយ មានចេតនាជាគ្រឿងវៀរចាក បាណាតិបាតជាដើម ដែលកើតឡើងក្នុងកុសលវិថី ។

ចោបនវាចា ត្រាស់ក្នុងពីរបទនេះថា **សាធុ វាចាយ** ទ្វារនោះឈ្មោះថា កិក្ខុមិនសង្រួមហើយ ព្រោះវិចីទុច្ចរិតទាំងឡាយ មានមុសាវាទជាដើម ដែលកើតឡើង មួយអន្លើដោយចោបនវាចានោះ ឈ្មោះថាដែលកិក្ខុសង្រួមហើយ ព្រោះវិរតិទាំងឡាយ មានចេតនាជាគ្រឿងវៀរចាកមុសាវាទជាដើម ។

មនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជាដើម និងដោយចិត្តដទៃចាកចិត្តដែលស្មុះទៅ រមែងមិនមានក្នុងពីរបទនេះថា **មនសា សំវរោ** ។ តែទ្វារនោះឈ្មោះថា កិក្ខុមិនសង្រួមហើយ ព្រោះមនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជាដើម ដែលកើតឡើងក្នុងខណៈនៃជវនចិត្តក្នុងមនោទ្វារ ឈ្មោះថា កិក្ខុសង្រួមហើយ ព្រោះមនោសុចរិតទាំងឡាយ មានអនភិជ្ឈាជាដើម ( ដែលកើតឡើង ក្នុងខណៈនៃជវនចិត្តក្នុងមនោទ្វារ ) ។

ពីរបទថា **សាធុ សព្វត្ថ** សេចក្តីថា ការសង្រួមក្នុងទ្វារទាំងពួង មានចក្ខុទ្វារជាដើមនោះ ជាគុណញ៉ាំងប្រយោជន៍ឲ្យសម្រេច ។ ព្រះមានព្រះភាគទ្រង់សម្តែងទ្វារ ដែលកិក្ខុសង្រួម ៨ យ៉ាង និងទ្វារដែលកិក្ខុមិនសង្រួម ៨ យ៉ាង ដោយព្រះពុទ្ធវចនៈមានប្រមាណប៉ុណ្ណោះ ។ កិក្ខុដែលតាំងនៅក្នុងទ្វារ

ដែលមិនសង្រួម ៨ យ៉ាងនោះ រមែងមិនផុតចាកទុក្ខ ដែលមានវដ្ដៈជាមូល ចំណែកភិក្ខុតាំងនៅក្នុងទ្វារដែលសង្រួម រមែងផុតចាកទុក្ខ ដែលមានវដ្ដៈជាមូលទាំងអស់បាន ព្រោះដូច្នោះ ទើបព្រះសាស្ដាត្រាស់ថា **សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។**

ក្នុងកាលចប់ទេសនា ភិក្ខុ ៥ រូបតាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់មហាជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។០៚

**រឿង ភិក្ខុ ៥ រូប**

# រឿង ភិក្ខុសម្លាប់ហង្ស

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកសម្លាប់ហង្សមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **ហត្ថសញ្ញតោ** ជាដើម ។

បានឮថា សម្លាញ់ពីរនាក់ក្នុងក្រុងសាវត្ថី បានចេញបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ភិក្ខុទាំងឡាយហើយ ដោយច្រើនត្រាច់ទៅរួមគ្នា ។

ថ្ងៃមួយ ភិក្ខុពីររូបនោះ ទៅកាន់ស្ទឹងអចិរវតី ស្រង់ទឹកហើយអាំងកម្ដៅថ្ងៃ បានឈរនិយាយគ្នាដល់សារាណីយកថា ក្នុងខណៈនោះ ហង្សពីរហើរមកតាមអាកាស ។

ខណៈនោះ ភិក្ខុមួយរូបរើសដុំក្រួសហើយពោលថា ខ្ញុំនឹងផ្ចាត់ភ្នែករបស់

ហង្សមួយ ភិក្ខុមួយរូបទៀតពោលថា លោកគ្មានសមត្ថភាពទេ ភិក្ខុមួយរូបទៀតពោលថា ក្អែកខាងនេះលើកទុកចុះ ខ្ញុំនឹងផ្ទាត់ក្អែកម្ខាងទៀត ភិក្ខុមួយរូបទៀតពោលថា ក្អែកខាងនោះ លោកក៏មិនអាចផ្ទាត់ចំដូចគ្នា ភិក្ខុមួយរូបទៀតពោលថា បើយ៉ាងនោះ ចូរលោកចាំមើល ហើយផ្ទាត់គ្រាប់ក្រួសមួយដុំទៅអំពីក្រោយហង្ស ហង្សបានឮសំឡេងក្រួស ( ជ្រែកខ្យល់ ) ទើបត្រឡប់ក្រោយដើម្បីមើល ខណៈនោះ លោកក៏ផ្ទាត់ដុំក្រួសទីពីរ ត្រូវក្អែកហង្សម្ខាងធ្លុះទៅម្ខាង ហង្សស្រែក ហើយធ្លាក់ទៀបជើងរបស់ភិក្ខុទាំងនោះឯង ។

ភិក្ខុទាំងឡាយ ឈរក្នុងទីនោះៗ ឃើញហើយ ទើបពោលថា អាវុសោ អ្នកបួសក្នុងព្រះពុទ្ធសាសនាធ្វើបាណាតិបាត ឈ្មោះថា ធ្វើកម្មមិនសមគួរហើយ នាំភិក្ខុទាំងពីររូបនោះ ទៅគាល់ព្រះតថាគត ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើបាណាតិបាតពិតឬ កាលលោកក្រាបទូលថា ករុណាព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនា ដែលជាហេតុនាំសត្វចេញចាកទុក្ខបែបនេះ បានធ្វើហើយយ៉ាងនេះ ព្រោះហេតុអ្វី បណ្ឌិតក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់កើតឡើងនៅគ្រប់គ្រងផ្ទះ គង់ធ្វើសេចក្តីរង្កៀសក្នុងឋានៈសូម្បីមានប្រមាណតិចតួច ឯអ្នក បួសក្នុងព្រះពុទ្ធសាសនាបែបនេះ មិនធ្វើសូម្បីត្រឹមតែសេចក្តីរង្កៀសកាលភិក្ខុទាំងនោះទូលអារាធនាហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីត កាលព្រះបាទធនញ្ជ័យសោយរាជសម្បត្តិ ក្នុងនគរឈ្មោះឥន្ទបត្ត ក្នុងដែនកុរុ ។ ព្រះពោធិសត្វបដិសន្ធិក្នុងព្រះគភ៌របស់អគ្គមហេសីនៃ

ព្រះរាជាអង្គនោះ ដល់នូវភាពជាអ្នកដឹងក្ដីហើយដោយលំដាប់ ទ្រង់រៀនសិប្បៈទាំងឡាយក្នុងនគរតក្កសិលាហើយ ព្រះបិតាទ្រង់ឲ្យតាំងនៅក្នុងតំណែងជាឧបរាជ ។ ចំណេរតមក អំណឹះឥតពីព្រះបិតាទៅ បានទទួលរាជសម្បត្តិហើយ ទ្រង់មិនកន្លងទសពិធរាជធម៌ ទ្រង់តាំងនៅក្នុងកុរុធម៌ហើយ ។ សីល ៥ ឈ្មោះថា កុរុធម៌ ។ ព្រះពោធិសត្វទ្រង់រក្សាសីល ៥ នោះ ធ្វើឲ្យបរិសុទ្ធ ព្រះជននី ព្រះអគ្គមហេសី ព្រះអនុជ ឧបរាជ ព្រាហ្មណបុរោហិត អមាត្យអ្នកកាន់ខ្សែ គឺអ្នកវាស់វែង សារថី សេដ្ឋី មហាមាត្យ នាយឃ្លាំង អ្នករក្សាទ្វារ នាងវណ្ណទាសី ដែលជាស្រីធ្វើនគរឲ្យស្អាតរបស់ព្រះពោធិសត្វនោះ តែងរក្សាសីល ៥ ដូចព្រះពោធិសត្វ ដោយប្រការដូច្នេះ ។

កាលជនទាំង ១១ នាក់នោះ រក្សាកុរុធម៌យ៉ាងនោះ កាលព្រះរាជាព្រះនាមកាលិង្គៈ សោយរាជសម្បត្តិក្នុងនគរទន្តបុរីក្នុងដែនកាលិង្គៈ ភ្លៀងមិនបានធ្លាក់ក្នុងដែនរបស់ព្រះអង្គឡើយ ឯដំរីមង្គលឈ្មោះអញ្ជនាសភៈរបស់ព្រះមហាសត្វ ជាសត្វមានបុណ្យច្រើន អ្នកដែននាំគ្នាក្រាបទូលដោយសម្គាល់ថា កាលនាំដំរីនោះមកហើយ ភ្លៀងនឹងធ្លាក់ ។

ព្រះរាជាទ្រង់បញ្ជូនពួកព្រាហ្មណ៍ទៅដើម្បីនាំដំរីនោះមក ។ ព្រាហ្មណ៍ទាំងនោះទៅហើយ ទូលសូមដំរីជាមួយព្រះមហាសត្វហើយ ដើម្បីសម្ដែងអាការសូមនេះរបស់ព្រាហ្មណ៍ទាំងនោះ ទើបព្រះសាស្ដាត្រាស់ជាតក ក្នុងតិកនិបាតនេះជាដើមថា

បពិត្រព្រះជនាធិបតី យើងទាំងឡាយដឹងច្បាស់នូវសទ្ធា និង

សីលរបស់ព្រះអង្គហើយ នឹងទទួលយកនូវដំរីមានសម្បុរប្រាកដស្មើដោយផ្កាអញ្ជ័ន ទៅក្នុងសម្នាក់នៃព្រះបាទកាលិង្គៈ ។

កាលព្រាហ្មណ៍ទាំងឡាយនាំដំរីមកហើយ កាលភ្លៀងមិនធ្លាក់ ដោយទ្រង់សម្គាល់ថា ព្រះរាជានោះទ្រង់រក្សាកុរុធម៌ ព្រោះដូច្នោះ ទើបភ្លៀងធ្លាក់ក្នុងដែនរបស់ព្រះអង្គ ទើបព្រះបាទកាលិង្គៈទ្រង់បញ្ជូនពួកព្រាហ្មណ៍ និងអមាត្យទៅទៀត ដោយព្រះតម្រាស់ថា ពួកលោកចូរចារឹកកុរុធម៌ដែលព្រះរាជានោះរក្សាក្នុងជំពាវមាសហើយនាំមក កាលព្រាហ្មណ៍ និងអមាត្យទាំងនោះទៅទូលសូម ជនទាំងអស់នោះរាប់តាំងអំពីព្រះរាជាជាដើម ធ្វើអាការត្រឹមតែការរង្កៀសណាមួយក្នុងសីលទាំងឡាយរៀងៗ ខ្លួនហើយឃាត់ថា សីលរបស់ពួកយើងមិនបរិសុទ្ធ ត្រូវព្រាហ្មណ៍ និងអមាត្យទាំងនោះអង្វរពេកថា ការបែកធ្លាយនៃសីលមិនមានដោយហេតុត្រឹមប៉ុណ្ណោះឡើយ ទើបបានប្រាប់សីលទាំងឡាយ រៀងៗ ខ្លួនហើយ ។

ព្រះបាទកាលិង្គៈ បានទតកុរុធម៌ដែលពួកព្រាហ្មណ៍ និងអមាត្យចារឹកក្នុងជំពាវមាសនាំមក ទ្រង់សមាទានបំពេញឲ្យបរិសុទ្ធដោយល្អ ទើបភ្លៀងធ្លាក់ក្នុងដែនរបស់ព្រះអង្គ ដែនបានក្សេម មានភិក្ខារកបានដោយងាយហើយ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ប្រជុំជាតកថាស្រីផ្កាមាសក្នុងកាលនោះ បានមកជាឧប្បលវណ្ណា អ្នករក្សាទ្វារបានមកជាភិក្ខុឈ្មោះបុណ្ណៈ អមាត្យអ្នកកាន់ខ្សែបានមកជាកច្ចានភិក្ខុ អមាត្យដែលជានាយឃ្លាំងបានមកជាកោលិតៈ សេដ្ឋីក្នុងកាលនោះបានជាសារីបុត្ត នាយសារថីបាន

ជាអនុរុទ្ធ ព្រាហ្មណ៍បានជាកស្សបត្ថេរ ឧបរាជបានជាននូបណ្ឌិត ព្រះមហេសីបានជារាហុលមាតា ព្រះជននីបានជាព្រះនាងមាយាទេវី ព្រះបាទកុរុបានជាព្រះពោធិសត្វ ចូរពួកអ្នកចាំជាតកដោយអាការយ៉ាងនេះ ។

ដូច្នេះហើយត្រាស់ថា ម្នាលភិក្ខុ បណ្ឌិតក្នុងកាលមុន កាលសេចក្តីសុខមានប្រមាណតិចកើតឡើងហើយ ធ្វើសីលភេទរបស់ខ្លួនឲ្យជាគ្រឿងវង្វៀសហើយយ៉ាងនេះ ចំណែកអ្នកបួសក្នុងសាសនារបស់ព្រះពុទ្ធដូចតថាគត គង់ធ្វើបាណាតិបាត ឈ្មោះថា ធ្វើកម្មធ្ងន់ក្រៃពេក ធម្មតាភិក្ខុ គួរជាអ្នកសង្រួមដោយដៃ ជើង និងវាចា ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ហត្ថសញ្ញតោ បាទសញ្ញតោ  វាចាយ សញ្ញតោ សញ្ញតុត្តមោ**
**អជ្ឈត្តរតោ សមាហិតោ  ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។**

ជនណាសង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព
ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋាន ដែលមានក្នុងខ្លួន ជាអ្នកមាន
ចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌
បណ្ឌិតទាំងឡាយហៅ ជននោះថាភិក្ខុ ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ហត្ថសញ្ញតោ** សេចក្តីថា ឈ្មោះថា ជាអ្នកមានដៃសង្រួមហើយ ព្រោះមិនមានការគ្នាំគ្នងដៃជាដើម ឬការប្រហារសត្វដទៃដោយដៃជាដើម ។ ន័យក្នុងបទទីពីរ ក៏ដូចគ្នា ។

ឈ្មោះថាជាអ្នកមានវាចាសង្រួមហើយ ព្រោះមិនបានធ្វើវចីទុច្ចរិត មាន

និយាយកុហកដោយវាចាជាដើម ។

បទថា **សញ្ញតត្តមោ** គឺអ្នកមានអត្តភាពសង្រួមហើយ អធិប្បាយថា ជាអ្នកមិនធ្វើអាការប្លែក មានគ្រវែងកាយ គ្រវីក្បាល និងញាក់ចិញ្ចើម ជាដើម ។

បទថា **អជ្ឈត្តរតោ** សេចក្តីថា ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋាន ពោល គឺគោចរធម៌ ដែលប្រព្រឹត្តទៅខាងក្នុង ។

បទថា **សមាហិតោ** គឺដែលមានចិត្តតាំងមាំដោយល្អហើយ ។

ពីរបទថា **ឯកោ សន្តុសិតោ** សេចក្តីថា ជាអ្នកមានប្រក្រតីនៅម្នាក់ឯង ត្រេកអរហើយដោយល្អ គឺមានចិត្តត្រេកអរហើយ ដោយអធិគមនៃខ្លួន ចាប់តាំងពីការប្រព្រឹត្តក្នុងវិបស្សនា ពិតហើយ ព្រះសេក្ខបុគ្គលគ្រប់ពួក តាំងអំពីកល្យាណបុថុជ្ជន រមែងត្រេកអរដោយអធិគមនៃខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថាជាអ្នកសន្តោស ចំណែកព្រះអរហន្ត ជាអ្នកត្រេកអរហើយដោយចំណែកមួយ ព្រះដ៏មានព្រះភាគទ្រង់សំដៅយកព្រះអរហន្តនោះ ទើបត្រាស់ពាក្យនោះថា **ឯកោ សន្តុសិតោ** ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង ភិក្ខុសម្លាប់ហង្ស ចប់**

# រឿង កោកាលិកភិក្ខុ

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឈ្មោះកោកាលិកៈ ត្រាស់ព្រះធម្មទេសនានេះថា* **យោ មុខសញ្ញតោ** *ជាដើម ។*

*រឿងមកហើយក្នុងព្រះសូត្រថា កាលនោះឯង ភិក្ខុឈ្មោះកោកាលិកៈបានទៅគាល់ដោយទីដែលព្រះដ៏មានព្រះភាគប្រថាប់នៅជាដើម ។ អត្ថនៃរឿងនោះ បណ្ឌិតគប្បីជ្រាបដោយន័យ ដែលព្រះអដ្ឋកថាចារ្យពោលហើយ ក្នុងអដ្ឋកថានោះឯង ។*

*កាលកោកាលិកៈកើតក្នុងបទុមនរក ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា ឱភិក្ខុឈ្មោះកោកាលិកៈដល់នូវការវិនាសហើយ ព្រោះអាស្រ័យមាត់របស់ខ្លួន កាលលោកជេរអគ្គសាវកទាំងពីរនោះឯង ផែនដីបានឲ្យចន្លោះហើយ ។*

*ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីអម្បាញ់មិញនេះ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កោកាលិកភិក្ខុវិនាសព្រោះអាស្រ័យមាត់របស់ខ្លួន ក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន កោកាលិកភិក្ខុក៏វិនាសហើយព្រោះអាស្រ័យមាត់របស់ខ្លួនដូចគ្នា កាលភិក្ខុទាំងឡាយ ប្រាថ្នានឹងស្តាប់សេចក្តីនោះ ទូលអារាធនាហើយ កាលទ្រង់ប្រកាសសេចក្តីនោះ ទ្រង់បាននាំអតីតនិទានមកត្រាស់ថា*

*ក្នុងអតីតកាល អណ្តើកមួយអាស្រ័យនៅក្នុងស្រះមួយកន្លែង ក្នុងហិមវន្តប្បទេស កូនហង្សពីរត្រាច់ទៅដើម្បីរកចំណី ធ្វើនូវការស្និទ្ធស្នាលជាមួយនឹង*

អណ្តើកនោះ ជាអ្នកស្និទ្ធស្នាលយ៉ាងក្រៃលែង ។ ថ្ងៃមួយ ទើបសួរអណ្តើកថា នែសម្លាញ់ លំនៅរបស់ពួកខ្ញុំក្នុងគុហាមាស លើកំពូលភ្នំឈ្មោះចិត្តកូដ ក្នុងហិមវន្តប្បទេស ជាប្រទេសដែលគួរត្រេកអរ ឯងទៅជាមួយពួកយើងដែរឬទេ អណ្តើកពោលថា តើខ្ញុំទៅបានដូចម្តេច ហង្សពោលថា ពួកយើងនឹងនាំឯងទៅ បើឯងអាចរក្សាមាត់បាន អណ្តើកពោលថា នែសម្លាញ់ ខ្ញុំអាច សូមឯងទាំងពីរនាំខ្ញុំទៅចុះ ហង្សទាំងពីរពោលថា សាធុ ហើយឲ្យអណ្តើកខាំកំណាត់ឈើមួយ ចំណែកខ្លួនឯងពាំចុងទាំងសងខាង នៃកំណាត់ឈើនោះ ហើយហើរទៅកាន់អាកាស ។

ពួកក្មេងអ្នកស្រុក ឃើញអណ្តើកត្រូវហង្សនាំទៅយ៉ាងនោះ ទើបនិយាយគ្នាថា ហង្សពីរនាំអណ្តើកទៅដោយកំណាត់ឈើ ។ អណ្តើកប្រាថ្នានឹងពោលថា បើសម្លាញ់ទាំងពីរនាំអញទៅ ប្រយោជន៍អ្វីរបស់ពួកឯងក្នុងរឿងនេះ វ៉ើយ ពួកក្មេងប្រេតអាក្រក់ ទើបរបូតកំណាត់ឈើដែលខ្លួនពាំ ក្នុងពេលដែលដល់ចំណែកខាងលើព្រះរាជនិវេសន៍ ក្នុងនគរពារាណសី ព្រោះហង្សទាំងពីរជាសត្វមានកម្លាំងរហ័ស ទើបធ្លាក់ត្រង់លានព្រះរាជវាំង បែកជាពីរចំណែក ។

ព្រះសាស្តាទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ញ៉ាំងពហុភាណិជាតក ក្នុងទុកនិបាតនេះឲ្យពិស្តារថា

អណ្តើក កាលបើឈើ ខ្លួនពាំស៊ប់ហើយ ហានិយាយ
សម្លាប់នូវខ្លួនឯង ឈ្មោះថា សម្លាប់ដោយវាចារបស់ខ្លួន ។
បពិត្រព្រះអង្គអ្នកមានព្យាយាមប្រសើរជាងជន ( ឯបណ្ឌិត

បុរស ) ឃើញនូវហេតុនេះហើយ មិនគប្បីបញ្ចេញវាចា
ជាកុសល ឲ្យហួសវេលា ព្រះអង្គគង់នឹងទតឃើញអណ្តើក
ដែលដល់នូវសេចក្តីវិនាសព្រោះតែនិយាយច្រើន ។

ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីជាអ្នកសង្រួមមាត់ ប្រព្រឹត្តស្មើ មិនរាយមាយ មានចិត្តស្ងប់ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**យោ មុខសញ្ញតោ ភិក្ខុ មន្តភាណី អនុទ្ធតោ**
**អត្ថំ ធម្មញ្ច ទីបេតិ មធុរំ តស្ស ភាសិតំ ។**

ភិក្ខុណាសង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្ត
មិនរាយមាយ សម្តែងអត្ថផង ធម៌ផងបាន ភាសិតរបស់
ភិក្ខុនោះ ទើបឈ្មោះថា ពីរោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មុខសញ្ញតោ** សេចក្តីថា ឈ្មោះថា ជាអ្នកសង្រួមហើយដោយមាត់ ព្រោះមិនពោលពាក្យជាដើមថា ឯងជាមនុស្សជាតិអាក្រក់ ជាមនុស្សទ្រុស្តសីលជាមួយមនុស្សទាំងឡាយ មានទាសៈ និងចណ្ឌាលជាដើម ។

បទថា **មន្តភាណី** សេចក្តីថា បញ្ញា ព្រះដ៏មានព្រះភាគត្រាស់ហៅថា **មន្ត** ជាអ្នកមានប្រក្រតីនិយាយដោយបញ្ញានោះ ។

បទថា **អនុទ្ធតោ** បានដល់ ជាអ្នកមានចិត្តស្ងប់ហើយ ។

*បាទព្រះគាថាថា* **អត្ថំ ធម្មញ្ច ទីបេតិ** *សេចក្តីថា រមែងសម្តែងអត្ថនៃភាសិតផង ធម៌ គឺទេសនាផង ។*

*បទថា* **មធុរំ** *សេចក្តីថា ភាសិតរបស់ភិក្ខុបែបនោះ ឈ្មោះថា ពីរោះ ។*

*ភិក្ខុណាឲ្យអត្ថតែមួយដល់ព្រម មិនឲ្យព្រះបាលីដល់ព្រម ឲ្យព្រះបាលីតែម្យ៉ាងដល់ព្រម មិនឲ្យអត្ថដល់ព្រម ឬមិនឲ្យទាំងពីរយ៉ាងដល់ព្រម ភាសិតរបស់ភិក្ខុនោះ ឈ្មោះថា ជាភាសិតមិនពីរោះឡើយ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚*

**រឿង កោកាលិកភិក្ខុ ចប់**

# រឿង ព្រះធម្មារាមត្ថេរ

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធម្មារាមត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* **ធម្មារាមោ ធម្មរតោ** *ជាដើម ។*

*បានឮមកថា កាលព្រះសាស្តាត្រាស់ថា បរិនិព្វានរបស់តថាគតនឹងមានដោយកន្លងទៅ ៤ ខែ តាំងអំពីខែនេះទៅ ភិក្ខុច្រើនពាន់រូបត្រាច់ចោមរោមព្រះសាស្តាហើយ ។*

*បណ្តាភិក្ខុទាំងនោះ ភិក្ខុដែលជាបុថុជ្ជន មិនអាចអត់សង្កត់ទប់នូវ*

ទឹកភ្នែកបាន ធម្មសង្វេគកើតដល់ព្រះវិណាស្រេពហើយ ភិក្ខុទាំងពួងប្រឹក្សាគ្នាថា យើងនឹងធ្វើអ្វីហ្ន៎ ដូច្នេះហើយ ក៏ត្រាច់ទៅដោយរួមគ្នាជាពួកៗ ។

ចំណែកភិក្ខុមួយរូប ឈ្មោះធម្មារាមៈ មិនចូលទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ទោះភិក្ខុទាំងឡាយពោលថា អាវុសោ អ្នកយ៉ាងម៉េចទៅហើយ ក៏មិនឆ្លើយ គិតថា បានឮថា ព្រះសាស្តានឹងបរិនិព្វានក្នុងកាលកន្លងទៅ ៤ ខែ ចំណែកអាត្មាអញ ជាអ្នកមានរាគៈមិនទាន់ទៅប្រាស កាលព្រះសាស្តាគង់ព្រះជន្មនៅនេះឯង អញនឹងព្យាយាមសម្រេចអរហត្ត ដូច្នេះហើយ ជាបុគ្គលម្នាក់ឯងប៉ុណ្ណោះ អាវជ្ជនៈ គិត រឭកដល់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយ ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះ ដល់ព្រះតថាគតថា បពិត្រព្រះអង្គ ធម្មារាមៈ មិនបានធ្វើសូម្បីត្រឹមតែការអើពើក្នុងព្រះអង្គ មិនធ្វើសូម្បីត្រឹមតែការប្រឹក្សាជាមួយពួកខ្ញុំព្រះអង្គថា បានឮថា ព្រះសាស្តានឹងបរិនិព្វាន តើពួកយើងនឹងធ្វើអ្វី ។

ព្រះសាស្តា ទ្រង់ឲ្យហៅភិក្ខុនោះមកហើយត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ ព្រះធម្មារាមៈពោលថា ករុណាព្រះអង្គ ព្រះមានព្រះភាគត្រាស់ថា ព្រោះហេតុអ្វី ព្រះធម្មារាមៈពោលថា បានឮថាព្រះអង្គនឹងបរិនិព្វានក្នុងកាលកន្លងទៅ ៤ ខែ ចំណែកខ្ញុំព្រះអង្គជាអ្នកមានរាគៈមិនទាន់ទៅប្រាស កាលព្រះអង្គគង់ព្រះជន្មនោះឯង ខ្ញុំព្រះអង្គនឹងព្យាយាមដើម្បីសម្រេចអរហត្ត ព្រោះហេតុនោះ ទើបខ្ញុំព្រះអង្គអាវជ្ជនៈ គិត រឭកដល់ធម៌ដែលទ្រង់សម្តែងហើយ ។

ព្រះសាស្តាប្រទានសាធុការដល់លោកថា សាធុ សាធុ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានសេចក្តីស្រឡាញ់ក្នុងតថាគត គប្បីដូចធម្មារាមភិក្ខុនេះឯង ពិតហើយ ម្នាលភិក្ខុទាំងឡាយ កាលបូជាដោយកម្រងផ្កានិងគ្រឿងក្រអូបជាដើម ឈ្មោះថា មិនធ្វើការបូជាដល់តថាគតឡើយ បុគ្គលបដិបត្តិធម៌សមគួរដល់ធម៌ប៉ុណ្ណោះ ទើបឈ្មោះថាបូជាតថាគត ដូច្នេះហើយត្រាស់ព្រះគាថានេះថា

**ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ**
**ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។**

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

# សេចក្តីអធិប្បាយ

គប្បីជ្រាបវិគ្គហៈក្នុងបទទាំងនោះថា ធម៌ គឺសមថៈ និងវិបស្សនា ជាទីមកត្រេកអររបស់ភិក្ខុនោះ ព្រោះអត្ថថា ជាលំនៅ ព្រោះហេតុនោះ ឈ្មោះថា ជាអ្នកមានធម៌ជាទីមកត្រេកអរ ជាអ្នកត្រេកអរហើយក្នុងធម៌នោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកត្រេកអរហើយក្នុងធម៌ ឈ្មោះថា ជាអ្នកពិចារណានូវធម៌ ព្រោះនឹកដល់ធម៌នោះឯងរឿយៗ អធិប្បាយថា ជាអ្នកពិចារណាដល់ធម៌នោះ ។

បទថា **អនុស្សរំ** បានដល់ រឭកដល់ធម៌នោះឯង ។

បទថា **សទ្ធម្មា** សេចក្តីថា ភិក្ខុបែបនោះ រមែងមិនវិនាសចាកពោធិ-បក្ខិយធម៌ ៣៧ ប្រការ និងលោកុត្តរធម៌ ៩ ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងអរហត្ត ទេសនាមានប្រយោជន៍ដល់បុគ្គលប្រជុំគ្នាហើយ ដូច្នេះឯង ។

**រឿង ព្រះធម្មារាមត្ថេរ ចប់**

# រឿង ភិក្ខុណាមួយ
## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុអ្នកសេពគប់ខុសមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **សលាភំ នាតិមញ្ញេយ្យ** ជាដើម ។

បានឮមកថា ភិក្ខុដែលជាបក្ខពួកទេវទត្តមួយរូប ជាសម្លាញ់របស់ភិក្ខុរូបនោះ ភិក្ខុខាងទេវទត្តនោះ ឃើញភិក្ខុជាសម្លាញ់ត្រាច់ទៅបិណ្ឌបាតជាមួយភិក្ខុទាំងឡាយ ធ្វើភត្តកិច្ចហើយត្រឡប់មកទើបសួរថា អាវុសោទៅណា ភិក្ខុម្នាងទៀតពោលថា ខ្ញុំទៅកាន់ទីឈ្មោះនោះដើម្បីបិណ្ឌបាត ភិក្ខុដែលជាបក្ខពួកទេវទត្តពោលថា លោកបានបិណ្ឌបាតហើយឬ ភិក្ខុមួយរូបទៀតពោលថា អើ ខ្ញុំបានហើយ ភិក្ខុខាងទេវទត្តពោលថា ក្នុងទីនេះឯងពួកខ្ញុំមានលាភ និងសក្ការៈជាច្រើន សូមលោកនៅក្នុងទីនេះឯងត្រឹម ២-៣ ថ្ងៃចុះ ។

លោកនៅក្នុងទីនោះ ២-៣ ថ្ងៃតាមពាក្យរបស់ភិក្ខុនោះហើយ ទើបទៅ

កាន់លំនៅរបស់ខ្លួន ។ គ្រានោះ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះដល់ព្រះសាស្ដាថា បពិត្រព្រះអង្គ ភិក្ខុនេះបរិភោគលាភសក្ការៈ ដែលកើតឡើងដល់ទេវទត្ត ភិក្ខុនេះជាបក្ខពួករបស់ទេវទត្ត ។ ព្រះសាស្ដាឲ្យហៅភិក្ខុនោះមកហើយត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះឬ ភិក្ខុនោះពោលថា ករុណាព្រះអង្គ ខ្ញុំព្រះអង្គអាស្រ័យភិក្ខុកំលោះមួយរូប នៅក្នុងទីនោះ ២-៣ ថ្ងៃ តែខ្ញុំព្រះអង្គមិនបានគាប់ចិត្តក្នុងលទ្ធិរបស់ទេវទត្តទេ ។

គ្រានោះ ព្រះសាស្ដាត្រាស់ថា អ្នកមិនគាប់ចិត្តក្នុងលទ្ធិទេវទត្តក៏ពិតតែអ្នកត្រាច់ទៅ ហាក់បីដូចគាប់ចិត្តនឹងលទ្ធិរបស់ជនដែលអ្នកជួបហើយនោះឯង អ្នកធ្វើយ៉ាងនេះ ក្នុងឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន អ្នកក៏ធ្លាប់បែបនេះដូចគ្នា ។ កាលភិក្ខុទាំងឡាយទូលអារាធនាថា បពិត្រព្រះអង្គ ក្នុងឥឡូវនេះ ពួកខ្ញុំព្រះអង្គឃើញភិក្ខុនេះដោយខ្លួនឯងហើយ តែក្នុងកាលមុនភិក្ខុនេះគាប់ចិត្តក្នុងលទ្ធិរបស់អ្នកណាត្រាច់ទៅ សូមទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គចុះ ទើបទ្រង់នាំអតីតនិទានមក ទ្រង់ញ៉ាំងមហិឡាមុខជាតកនេះឲ្យពិស្ដារថា

ដំរីដ៏ឧត្ដមឈ្មោះមហិឡាមុខៈ បានស្ដាប់ពាក្យរបស់ចោរ
ទាំងឡាយមុនហើយ ក៏ប្រព្រឹត្តតាម បានបោសសម្លាប់
( ហ្មដំរី ) លុះបានស្ដាប់ពាក្យពួកលោកអ្នកមានខ្លួន
សង្រួមល្អហើយ ក៏បានតាំងនៅក្នុងគុណគ្រប់យ៉ាង ។

ហើយទ្រង់ត្រាស់បន្តថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុជាអ្នកត្រេកអរដោយលាភរបស់ខ្លួនប៉ុណ្ណោះ ការប្រាថ្នាលាភរបស់អ្នកដទៃ មិនសមគួរព្រោះបណ្តាឈាន វិបស្សនា មគ្គ និងផលទាំងឡាយ សូម្បីធម៌ត្រឹមតែម្យ៉ាង មិនកើតឡើងដល់ភិក្ខុដែលប្រាថ្នាលាភរបស់អ្នកដទៃ តែគុណជាតិទាំងឡាយ មានឈានជាដើម តែងកើតឡើងដល់ភិក្ខុដែលត្រេកអរដោយលាភរបស់ខ្លួនប៉ុណ្ណោះ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានភាសិតព្រះគាថានេះថា

**សលាភំ នាតិមញ្ញេយ្យ　　នាញ្ញេសំ បិហយញ្ចរេ**
**អញ្ញេសំ បិហយំ ភិក្ខុ　　សមាធឹ នាធិគច្ឆតិ ។**
**អប្បលាភោបិ ចេ ភិក្ខុ　　សលាភំ នាតិមញ្ញតិ**
**តំ វេ ទេវា បសំសន្តិ　　សុទ្ធាជីវំ អតន្ទិតំ ។**

ភិក្ខុមិនគប្បីមើលងាយលាភរបស់ខ្លួន ( ដែលកើតឡើងដោយធម៌ ) មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃ តែងមិនបានសមាធិឡើយ ។ បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតា និងមនុស្សទាំងឡាយតែងសរសើរភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាម ជាគ្រឿងអាស្រ័យរស់នៅដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សលាភំ** បានដល់ លាភដែលកើតឡើង ដល់ខ្លួន ពិតហើយ ភិក្ខុវៀរការត្រាច់ទៅតាមលំដាប់ប្រក ចិញ្ចឹមជីវិតដោយការស្វែងរកដែលមិនសមគួរ ឈ្មោះថាមើលងាយ គឺប្រមាថ បានដល់ វង្វៀស ក្នុងលាភរបស់ខ្លួន ព្រោះហេតុនោះ ភិក្ខុមិនគួរមើលងាយលាភរបស់ខ្លួនដោយការមិនធ្វើយ៉ាងនោះ ។

ពីរបទថា **នាញ្ញេសំ បិហាយំ** សេចក្តីថា មិនគួរត្រាច់ប្រាថ្នាលាភរបស់អ្នកដទៃ ។

បាទព្រះគាថាថា **សមាធឹ នាធិគច្ឆតិ** សេចក្តីថា ភិក្ខុកាលប្រាថ្នាលាភរបស់ជនដទៃ ដល់នូវការខ្វល់ខ្វាយក្នុងការធ្វើបរិក្ខារ មានចីវរជាដើម ដល់ជនទាំងនោះ រមែងមិនសម្រេចអប្បនាសមាធិ ឬឧបចារសមាធិ ។

បាទព្រះគាថាថា **សលាភំ នាតិមញ្ញតិ** សេចក្តីថា ភិក្ខុសូម្បីជាអ្នកមានលាភតិច កាលត្រាច់ទៅតាមលំដាប់ប្រក ដោយលំដាប់នៃត្រកូលខ្ពស់និងទាប ឈ្មោះថា មិនមើលងាយលាភរបស់ខ្លួន ។

បទថា **តំ វេ** ជាដើម សេចក្តីថា ទេវតាទាំងឡាយរមែងសរសើរ គឺលើកតម្កើងភិក្ខុនោះ ដែលជាបុគ្គលបែបនោះ ឈ្មោះថា ជាអ្នកមានអាជីវៈបរិសុទ្ធ ព្រោះភាពជាអ្នកមានជីវិតជាសារៈ ឈ្មោះថា មិនខ្ជិលច្រអូស ព្រោះជាអ្នកមិនរួញរា ដោយអាស្រ័យកម្លាំងស្មូនចិញ្ចឹមជីវិត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕៚

**រឿងភិក្ខុណាមួយ ចប់**

# រឿង បញ្ចគ្គទាយកព្រាហ្មណ៍

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ឈ្មោះបញ្ចគ្គទាយកៈ ត្រាស់ព្រះធម្មទេសនានេះថា **សព្វសោ នាមរូបស្មឹ** ជាដើម ។

បានឮមកថា ព្រាហ្មណ៍នោះរមែងថ្វាយទានឈ្មោះខេត្តគ្គៈ ក្នុងពេលនៃស្រូវដែលប្រួតស្រេចហើយនោះឯង ក្នុងពេលដែលជញ្ជូនស្រូវដាក់លាន ក៏ថ្វាយទានឈ្មោះខលគ្គៈ ក្នុងពេលបោកបែន ក៏ថ្វាយទានឈ្មោះខលភណ្ឌគ្គៈ ក្នុងពេលអង្ករបូលក្នុងផ្ទាំង ក៏ថ្វាយទានឈ្មោះឧក្ខលិកគ្គៈ ក្នុងពេលដែលដួសបាយដាក់ភាជនៈ ក៏ថ្វាយទានឈ្មោះបាជិគ្គៈ ព្រាហ្មណ៍រមែងថ្វាយទានដ៏លើស ៥ យ៉ាងនេះ ។ ព្រាហ្មណ៍នោះ ឈ្មោះថាមិនទាន់ឲ្យដល់បដិគ្គាហកដែលមកដល់ហើយ មិនបរិភោគ ព្រោះហេតុនោះ ទើបព្រាហ្មណ៍បានឈ្មោះថាបញ្ចគ្គទាយកនោះឯង ។

ព្រះសាស្តាឃើញឧបនិស្ស័យផលទាំង ៣ របស់ព្រាហ្មណ៍នោះ និងព្រាហ្មណី ទើបយាងទៅក្នុងពេលបរិភោគរបស់ព្រាហ្មណ៍ ហើយទ្រង់ឈរប្រថាប់ត្រង់ទ្វារ ។ ព្រាហ្មណ៍នោះ អង្គុយបែរមុខទៅខាងក្នុងផ្ទះ បរិភោគត្រង់មាត់ទ្វារ គាត់មិនឃើញព្រះសាស្តាប្រថាប់ឈរត្រង់ទ្វារឡើយ ។

ចំណែកព្រាហ្មណី កំពុងអង្គាសព្រាហ្មណ៍ ឃើញព្រះសាស្តា គិតថាព្រាហ្មណ៍នេះថ្វាយទានដ៏ប្រសើរក្នុងឋានៈទាំង ៥ ហើយទើបបរិភោគ ឥឡូវនេះព្រះសមណគោតម យាងមកប្រថាប់ឈរត្រង់ទ្វារ បើព្រាហ្មណ៍ឃើញព្រះសមណគោតមហើយ នឹងនាំភត្តរបស់ខ្លួនទៅថ្វាយ អញមិនអាចចម្អិនដើម្បី

គាត់ទៀត ។ ហើយនាងគិតទៀតថា ព្រាហ្មណ៍នេះកុំបីឃើញព្រះសមណគោតម ដោយអាការយ៉ាងនេះ ទើបបែរខ្នងឲ្យព្រះសាស្តា បានឈរបាំងព្រះសាស្តា អំពីក្រោយព្រាហ្មណ៍នោះ ដូចបាំងព្រះចន្ទពេញបូណ៌មីដោយបាតដៃ ដូច្នោះ ។ ព្រាហ្មណីឈរយ៉ាងនោះឯង ហើយក៏ឆ្មៀងមើលព្រះសាស្តាដោយកន្ទុយភ្នែក ព្រោះគិតថា ព្រះសាស្តាយាងទៅហើយឬនៅហ្ន៎ ។

ព្រះសាស្តា បានប្រថាប់ឈរត្រង់ទីដដែលនោះឯង ចំណែកព្រាហ្មណី មិនបានពោលថា សូមទ្រង់និមន្តប្រោសសត្វខាងមុខចុះ ព្រោះខ្លាចព្រាហ្មណ៍ ឮ តែនាងថយទៅពោលតិចៗ ថា សូមទ្រង់និមន្តទៅប្រោសសត្វខាងមុខចុះ ។

ព្រះសាស្តាគ្រវីព្រះសិសៈ ដោយអាការដែលទ្រង់សម្តែងថា តថាគត មិនទៅ កាលព្រះសម្ពុទ្ធដែលជាទីគោរពរបស់សត្វលោក ទ្រង់គ្រវីសិសៈដោយ អាការសម្តែងថា តថាគតមិនទៅ នាងមិនអាចទប់បាន ទើបសើចខ្លាំងឡើង ខណៈនោះ ព្រះសាស្តាទ្រង់បញ្ចេញរស្មីទៅត្រង់ជញ្ជាំងផ្ទះ ព្រាហ្មណ៍អង្គុយ បែរខ្នងនោះឯង បានឮសំឡេងសើចរបស់ព្រាហ្មណី និងឃើញពន្លឺនៃ ឆព្វណ្ណរង្សី ៦ ប្រការ ទើបបានឃើញព្រះសាស្តា ។

ធម្មតាព្រះពុទ្ធទាំងឡាយ បើទ្រង់មិនបានបង្ហាញខ្លួនដល់ជនទាំងឡាយ ដែលដល់ព្រមហើយដោយហេតុ ក្នុងស្រុក ឬក្នុងព្រៃហើយ ទ្រង់មិនចៀស ចេញទៅ ។ ព្រាហ្មណ៍ឃើញព្រះសាស្តាហើយ ទើបពោលថា នែនាង នាង មិនប្រាប់ព្រះរាជបុត្រ ដែលទ្រង់មកប្រថាប់ឈរត្រង់ទ្វារដល់ខ្ញុំ ឲ្យខ្ញុំវិនាស ហើយ នាងធ្វើកម្មធ្ងន់ ដូច្នេះហើយ ក៏កាន់យកភាជនៈនៃភោជន ដែលខ្លួន

បរិភោគហើយ ពាក់កណ្តាល ទៅកាន់សម្នាក់ព្រះសាស្តា ហើយក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គឲ្យទានដ៏ប្រសើរ ក្នុងឋានៈទាំង ៥ ហើយទើបបរិភោគ តែចំណែកនៃភត្តមួយចំណែកប៉ុណ្ណោះ ខ្ញុំព្រះអង្គវំលែកពាក់កណ្តាលអំពីចំណែកនេះបរិភោគ ចំណែកនៃភត្តមួយចំណែកនៅសល់ សូមទ្រង់ទទួលភត្តចំណែកនេះរបស់ខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តាមិនត្រាស់ថា តថាគតមិនត្រូវការដោយភត្ត ដែលសល់របស់អ្នក តែទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ចំណែកដ៏ប្រសើរក្តី ភត្តដែលវំលែកពាក់កណ្តាលបរិភោគហើយក្តី ជារបស់សមគួរដល់តថាគតទាំងអស់ សូម្បីដុំភត្តជារបស់សល់ដែល ក៏ជារបស់សមគួរដល់តថាគតដូចគ្នា ម្នាលព្រាហ្មណ៍ ព្រោះតថាគតជាអ្នកអាស្រ័យអាហារដែលអ្នកដទៃឲ្យ ចិញ្ចឹមជីវិត ដូចគ្នានឹងពួកប្រេត ហើយទ្រង់ត្រាស់ព្រះគាថានេះថា

> ភិក្ខុអាស្រ័យអាហារដែលបុគ្គលដទៃឲ្យ ចិញ្ចឹមជីវិត បានដុំភត្តណាអំពីចំណែកដ៏ប្រសើរក្តី អំពីចំណែកពាក់កណ្តាលក្តី អំពីចំណែកដែលសល់ក្តី ភិក្ខុនោះ ជាអ្នកមិនគួរសរសើរដុំភត្តនោះ និងមិនគួរតិះដៀល ហើយទំពាធាន់ដុំភត្តនោះ ធីរជនទាំងឡាយរមែងសរសើរនូវភិក្ខុនោះថា ជាមុនី ។

ព្រាហ្មណ៍បានស្តាប់ព្រះគាថានោះ ក៏ជាអ្នកមានចិត្តជ្រះថ្លាហើយ គិតថា ឱ គួរអស្ចារ្យពិត ព្រះរាជបុត្រដែលឈ្មោះថាជាម្ចាស់នៃប្រទីប មិនបានត្រាស់ថា តថាគតមិនត្រូវការដោយភត្តដែលជាសំណល់របស់អ្នក គង់ត្រាស់យ៉ាង

នោះ ហើយឈរត្រង់ទ្វារនោះឯង ទូលសួរបញ្ហានឹងព្រះសាស្ដាថា បពិត្រព្រះគោតម ទ្រង់ត្រាស់ហៅពួកសាវ័ករបស់ព្រះអង្គថា ភិក្ខុ ដោយហេតុមានប្រមាណប៉ុនណា បុគ្គលឈ្មោះថាជាភិក្ខុ ។

ព្រះសាស្ដាទ្រង់ពិចារណាថា ធម្មទេសនាដូចម្ដេចហ្ន៎ ទើបជាសប្បាយដល់ព្រាហ្មណ៍នេះ ទ្រង់ត្រិះរិះថា ជនទាំងពីរនេះ ក្នុងកាលព្រះពុទ្ធព្រះនាមកស្សប បានស្ដាប់ពាក្យរបស់ភិក្ខុទាំងឡាយដែលពោលថា នាមរូប ការដែលតថាគតមិនលះនាមរូបនោះឯង ហើយសម្ដែងធម៌ដល់ជនទាំងពីរនោះ គួរហើយទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលមិនមានតម្រេក មិនជាប់ជំពាក់ក្នុងនាមរូប ឈ្មោះថា ជាភិក្ខុ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ**
**អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។**

បុគ្គលណា មិនមានសេចក្ដីប្រកាន់ក្នុងនាម និងរូបថា ជារបស់អញ ដោយប្រការទាំងពួង មួយទៀត បុគ្គលណា មិនសោកស្ដាយ ព្រោះនាម និងរូបដែលមិនមាន បុគ្គលនោះឯង តថាគតហៅថ ាភិក្ខុ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **សព្វសោ** គឺក្នុងនាមរូបទាំងពួង ដែលប្រព្រឹត្តទៅហើយដោយអំណាចខន្ធ ៥ គឺនាមក្ខន្ធ ៤ មានវេទនាជាដើម និងរូបក្ខន្ធ ។

បទថា **មមាយិតំ** សេចក្តីថា ការប្រកាន់ថា អញ ឬថា របស់អញ មានដល់បុគ្គលណា ។

បាទព្រះគាថាថា **អសតា ច ន សោចតិ** សេចក្តីថា កាលនាមរូបនោះ ដល់នូវការអស់ទៅ និងការវិនាស បុគ្គលណារមែងមិនសោយសោក គឺមិន ក្តៅក្រហាយថា រូបរបស់អញអស់ទៅហើយ ។បេ។ វិញ្ញាណរបស់អញអស់ ទៅហើយ គឺឃើញតាមសេចក្តីពិតថា នាមរូប មានការអស់ទៅសូន្យទៅជា ធម្មតា អស់ទៅហើយ ។

បទថា **ស វេ** ជាដើម សេចក្តីថា បុគ្គលនោះ គឺបុគ្គលបែបនោះ បាន ដល់ ជាអ្នកវៀរចាកសេចក្តីប្រកាន់ក្នុងនាមរូបដែលមានថា ជារបស់អញក្តី មិនសោយសោកព្រោះនាមរូបនោះ ដែលមិនមានក្តី ព្រះសាស្តាត្រាស់ហៅថា ភិក្ខុ ។

ក្នុងកាលចប់ទេសនា ប្តីប្រពន្ធទាំងពីរ តាំងនៅក្នុងអនាគាមិផលហើយ ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ៕

**រឿង បញ្ចគ្គទាយកព្រាហ្មណ៍ ចប់**

# រឿង សម្ពហុលភិក្ខុ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **មេត្តាវិហារី** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ កាលព្រះមហាកច្ចាយនៈអាស្រ័យកុររឃរនគរ ក្នុងអវន្តីជនបទ ត្រង់ភ្នំឈ្មោះបវត្តៈ ឧបាសកម្នាក់ឈ្មោះសោណកុដិកណ្ណៈ ជ្រះថ្លាក្នុងធម្មកថារបស់ព្រះថេរៈ ប្រាថ្នានឹងបួសក្នុងសម្នាក់របស់ព្រះថេរៈ សូម្បីព្រះថេរៈឃាត់ដល់ទៅ ២ ដងថា នែសោណៈ ព្រហ្មចរិយៈមានកត្តម្តង ដេកម្តង ដរាបដល់អស់ជីវិត ជាវត្ថុដែលបុគ្គលធ្វើបានដោយលំបាក ក៏នៅជាអ្នកមានឧស្សាហ៍យ៉ាងខ្លាំងក្លាក្នុងបព្វជ្ជា ក្នុងវារៈទី ៣ អង្វរព្រះថេរៈ ក៏បព្វជ្ជាហើយ កន្លងទៅ ៣ ឆ្នាំ ទើបបានឧបសម្បទា ព្រោះទក្ខិណាជនបទមានភិក្ខុតិច ជាអ្នកប្រាថ្នាគាល់ព្រះសាស្តាចំពោះព្រះភក្ត្រ ទើបលាព្រះឧបជ្ឈាយ៍ កាន់យកដំណឹងដែលឧបជ្ឈាយ៍ឲ្យហើយ ទៅកាន់វត្តជេតពនដោយលំដាប់ ថ្វាយបង្គំព្រះសាស្តា បានទទួលបដិសណ្ឋារៈហើយ កាលព្រះសាស្តាទ្រង់អនុញ្ញាតសេនាសនៈ ក្នុងព្រះគន្ធកុដិជាមួយទ្រង់នោះឯង ឲ្យរាត្រីចំណែកច្រើនកន្លងទៅខាងក្រៅ គឺនៅខាងក្រៅព្រះគន្ធកុដិ ហើយចូលទៅកាន់ព្រះគន្ធកុដិ ក្នុងកណ្តាលរាត្រី ឲ្យចំណែក នៃរាត្រីនោះកន្លងទៅហើយ ត្រង់សេនាសនៈដែលដល់ហើយដល់ខ្លួន ក្នុងពេលទៀបភ្លឺ កាលព្រះសាស្តាទ្រង់និមន្តហើយ បានសូធ្យព្រះសូត្រអស់ ១៦ សូត្រ ដោយទំនងសរភញ្ញដែលចាត់ជាអដ្ឋកវគ្គ ។

កាលនោះ ព្រះដ៏មានព្រះភាគទ្រង់អនុមោទនាជាពិសេស ប្រទាននូវសាធុការដល់លោក ក្នុងកាលចប់សរភញ្ញថា សាធុ សាធុ ភិក្ខុ ។

កុម្មដ្ឋកទេវតា នាគ និងគ្រុឌស្តាប់សាធុការ ដែលព្រះសាស្តាប្រទានហើយបានឲ្យសាធុការហើយ សំឡេងសាធុការតែមួយ មានហើយរហូតដល់ព្រហ្មលោកយ៉ាងនេះដោយប្រការដូច្នេះ ។ ក្នុងខណៈនោះ សូម្បីទេវតាដែលអាស្រ័យនៅក្នុងផ្ទះរបស់មហាឧបាសិកា ដែលជាញោមស្រីរបស់ព្រះថេរៈក្នុងកុររឃរនគរក្នុងទីចម្ងាយប្រមាណ ១២០ យោជន៍ អំពីជេតពនមហាវិហារបានឲ្យសាធុការ ដោយសំឡេងដ៏ខ្លាំងហើយ ។ កាលនោះ មហាឧបាសិកាសួរទេវតានោះថា អ្នកណាឲ្យសាធុការ ទេវតាពោលថា នែប្អូនស្រី គឺខ្ញុំ ឧបាសិកាសួរថា អ្នកជាអ្នកណា ទេវតាពោលថា ខ្ញុំជាទេវតា អាស្រ័យនៅក្នុងផ្ទះរបស់នាង ឧបាសិកាពោលថា ក្នុងកាលមុននេះ អ្នកមិនបានឲ្យសាធុការដល់ខ្ញុំ ហេតុអ្វី ទើបថ្ងៃនេះបានឲ្យ ទេវតាពោលថា ខ្ញុំមិនបានឲ្យសាធុការដល់នាងទេ ឧបាសិកាពោលថា បើដូច្នោះ អ្នកឲ្យសាធុការដល់នរណា ទេវតាពោលថា ខ្ញុំឲ្យដល់ព្រះសោណកុដិកណ្ណត្ថេរដែលជាកូនរបស់នាង ឧបាសិកាពោលថា កូនរបស់ខ្ញុំធ្វើអ្វី ទេវតាពោលថា ក្នុងថ្ងៃនេះ កូនរបស់នាង នៅក្នុងព្រះគន្ធកុដិជាមួយព្រះសាស្តា ហើយសម្តែងធម៌ដល់ព្រះសាស្តា ព្រះសាស្តាទ្រង់ស្តាប់ធម៌បុត្ររបស់នាងហើយ ទ្រង់ជ្រះថ្លា ទើបប្រទានសាធុការ ព្រោះហេតុនោះ ទើបខ្ញុំឲ្យសាធុការដល់ព្រះថេរៈនោះ ក៏ព្រោះទទួលសាធុការរបស់ព្រះសម្មាសម្ពុទ្ធ ទើបកើតសាធុការតែមួយដូចគ្នា

ទាំងអស់ រាប់តាំងអំពីភុម្មដ្ឋកទេវតា រហូតដល់ព្រហ្មលោក ឧបាសិកាពោលថា នៃអ្នក កូនរបស់ខ្ញុំសម្តែងធម៌ដល់ព្រះសាស្តា ឬព្រះសាស្តាសម្តែងធម៌ដល់កូនរបស់ខ្ញុំ ទេវតាពោលថា កូនរបស់នាងសម្តែងធម៌ដល់ព្រះសាស្តា ។ កាលទេវតាកំពុងពោលយ៉ាងនោះ បីតិ ៥ ប្រការ កើតឡើងដល់ឧបាសិកាផ្សាយទូទៅពេញសរីរៈទាំងមូល ។ កាលនោះ មហាឧបាសិកាមានគំនិតយ៉ាងនេះថា បើកូនរបស់អញនៅក្នុងព្រះគន្ធកុដិជាមួយព្រះសាស្តា ហើយអាចសម្តែងធម៌ដល់ព្រះសាស្តាបាន ក៏អាចឲ្យសម្តែងធម៌ដល់អញបានដូចគ្នា ក្នុងពេលកូនអញមកដល់ អញនឹងធ្វើការស្តាប់ធម្មកថា ។

ចំណែកព្រះសោណត្ថេរ កាលព្រះសាស្តាប្រទានសាធុការហើយ គិតថា ពេលនេះ ជាពេលសមគួរដែលអញក្រាបទូលពាក្យផ្តាំ ដែលឧបជ្ឈាយ៍ផ្តាំមក ដូច្នេះហើយ ទើបទូលសូមពរ ៥ នឹងព្រះដ៏មានព្រះភាគ ចាប់តាំងអំពីការឧបសម្បទាដោយគណៈសង្ឃ មានវិនយធរជាគម្រប់ ៥ ក្នុងបច្ចន្តជនបទ ហើយនៅក្នុងសម្នាក់របស់ព្រះសាស្តា ២-៣ ថ្ងៃប៉ុណ្ណោះ ទូលលាព្រះសាស្តាថា ខ្ញុំព្រះអង្គនឹងសួរសុខទុក្ខព្រះឧបជ្ឈាយ៍ បានចេញអំពីជេតពនវិហារ ទៅកាន់សម្នាក់ព្រះឧបជ្ឈាយ៍ដោយលំដាប់ ។

ស្អែកឡើង ព្រះថេរៈនាំលោកទៅបិណ្ឌបាត ដល់ទ្វារផ្ទះរបស់ឧបាសិកាដែលជាញោមស្រី ។ ចំណែកឧបាសិកានោះ ឃើញកូនហើយ ត្រេកអរថ្វាយបង្គំ អង្គាសដោយគោរព ហើយសួរថា បពិត្រលោកកូន បានឮថា លោកកូននៅក្នុងព្រះគន្ធកុដិជាមួយនឹងព្រះសាស្តា ហើយសម្តែងធម្មកថាដល់ព្រះ

សាស្តា មែន ឬមិនមែន ព្រះសោណៈពោលថា ឧបាសិកា រឿងនេះ អ្នកណាប្រាប់ញោម ឧបាសិកាពោលថា ទេវតាអាស្រ័យនៅក្នុងផ្ទះនេះឲ្យសាធុការដោយសំឡេងខ្លាំង កាលញោមសួរថា នុ៎ះជាអ្នកណា ក៏ពោលថា គឺខ្ញុំ ហើយប្រាប់យ៉ាងនោះឯង ព្រោះស្តាប់រឿងនោះ ទើបញោមគិតយ៉ាងនេះថា បើកូនរបស់អញសម្តែងធម្មកថាដល់ព្រះសាស្តាបានសោត ក៏អាចសម្តែងធម៌ដល់អញបានដែរ ។

គ្រានោះ ឧបាសិកាពោលនឹងព្រះសោណៈនោះថា បពិត្រលោកកូន ព្រោះលោកកូនសម្តែងធម៌ចំពោះព្រះភក្ត្រ របស់ព្រះសាស្តាបានហើយ លោកកូនក៏អាចសម្តែងដល់ញោមបានដូចគ្នា ក្នុងថ្ងៃឈ្មោះនោះ ញោមនឹងឲ្យធ្វើការស្តាប់ធម៌ ហើយនឹងស្តាប់ធម៌របស់លោកកូន ព្រះសោណៈទទួលនិមន្តហើយ ។ ឧបាសិកាគិតថា អញថ្វាយទានដល់ភិក្ខុសង្ឃ ធ្វើការបូជាហើយនឹងស្តាប់ធម្មកថាបុត្ររបស់អញ ទើបតាំងស្រីទាសីម្នាក់ប៉ុណ្ណោះ ឲ្យជាអ្នកចាំផ្ទះ ហើយនាំបរិវារជនទាំងអស់ទៅស្តាប់ធម្មកថារបស់ព្រះថេរៈ ដែលឡើងកាន់ធម្មាសនៈដែលគេរៀបចំហើយ ក្នុងមណ្ឌប ដែលខនសាងខាងក្នុងព្រះនគរ ដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ ។

ក្នុងពេលនោះ ពួកចោរ ៩០០ ដើរសម្លឹងឱកាសក្នុងផ្ទះរបស់ឧបាសិកានោះ ។ ផ្ទះរបស់ឧបាសិកានោះព័ទ្ធដោយកំពែង ៧ ជាន់ ប្រកបដោយខ្លោងទ្វារ ៧ ជាន់ គេចងឆ្កែកាចក្នុងទីនោះៗ គ្រប់ខ្លោងទ្វារ ម្យ៉ាងទៀត គេជីកគូទឹក ក្នុងទីដែលទឹកធ្លាក់ត្រង់សំយាបក្នុងផ្ទះ ហើយឲ្យដាក់សំណទាល់តែពេញ

ពេលថ្ងៃ សំណានោះប្រាកដជាហាក់ដូចរលាយក្តៅព្រោះកម្តៅថ្ងៃ ក្នុងពេលយប់ប្រាកដជារបស់រឹង គេបោះចម្រូងដែកធំៗ ក្នុងវាំងគូនោះជាប់ៗ គ្នា ពួកចោរទាំងនោះមិនបានឱកាស ព្រោះអាស្រ័យការរក្សានេះ និងព្រោះអាស្រ័យភាពដែលឧបាសិកានៅខាងក្នុងផ្ទះ ថ្ងៃនោះ ដឹងថាឧបាសិកានោះទៅហើយ ទើបជីកឧម្មង្គចូលទៅកាន់ផ្ទះខាងក្រោមគូនៃសំណា និងចម្រូងដែកនោះឯង ហើយបញ្ជូនមេចោរទៅកាន់សម្នាក់របស់ឧបាសិកានោះដោយប្រាប់ថា បើឧបាសិកានោះបានឮថាពួកយើងចូលទៅក្នុងទីនេះហើយ បែរមុខមកកាន់ផ្ទះ ចូរលោកកាប់ឧបាសិកានោះឲ្យស្លាប់ដោយដាវ មេចោរនោះ បានទៅឈរក្នុងសម្នាក់របស់ឧបាសិកានោះ ។

ចំណែកពួកចោរ ដុតភ្លើងឲ្យភ្លឺខាងក្នុងផ្ទះ ហើយបើកទ្វារបន្ទប់ យកកហាបណៈ ។ ទាសីនោះឃើញពួកចោរហើយ ទើបទៅកាន់សម្នាក់ឧបាសិកាប្រាប់ថា បពិត្រអ្នកនាងម្ចាស់ ចោរជាច្រើនចូលទៅកាន់ផ្ទះ បើកទ្វារហើយយកកហាបណៈ ឧបាសិកាពោលថា ពួកចោរចូរដឹកនូវកហាបណៈ ដែលខ្លួនឃើញហើយទៅចុះ យើងនឹងស្តាប់ធម្មកថាកូនរបស់យើង កុំធ្វើអន្តរាយដល់ធម៌របស់យើងឡើយ ចូរនាងទៅផ្ទះចុះ ។

ចំណែកពួកចោរ ធ្វើបន្ទប់ដាក់កហាបណៈ ឲ្យជាបន្ទប់ទទេហើយ ទើបបើកបន្ទប់ប្រាក់ ទាសីក៏មកប្រាប់សេចក្តីនោះម្តងទៀត ឧបាសិកាពោលថា ពួកចោរចូរដឹកនូវយកទ្រព្យដែលខ្លួនប្រាថ្នាទៅចុះ យើងនឹងស្តាប់ធម្មកថានៃបុត្ររបស់យើង នាងកុំធ្វើអន្តរាយដល់យើងឡើយ ហើយបញ្ជូនទាសីនោះចេញ

ទៅ ។

ពួកចោរធ្វើបន្ទប់ដាក់ប្រាក់ ឲ្យជាបន្ទប់ទទេហើយ ទើបបើកបន្ទប់មាស ទាសីនោះក៏ទៅប្រាប់សេចក្ដីនោះដល់ឧបាសិកាទៀត ។ គ្រានោះ ឧបាសិកាហៅទាសីមកហើយពោលថា នែនាងមានខ្ជួនល្អ នាងមកសម្នាក់របស់យើងច្រើនដងហើយ យើងក៏បានប្រាប់ថា ពួកចោរចូរជញ្ជូនយកទៅតាមគាប់ចិត្តចុះ យើងនឹងស្ដាប់ធម្មកថាបុត្ររបស់យើង នាងកុំធ្វើអន្តរាយដល់យើងឡើយ ក៏មិនអើពើនឹងពាក្យរបស់យើងឡើយ នៅតែចចេសមកម្ដងហើយម្ដងទៀត លើកនេះ បើនាងនៅតែមក យើងនឹងដឹងវត្ថុដែលគួរធ្វើដល់នាង ចូរនាងត្រឡប់ចុះហើយបញ្ជូនទៅ ។

ចោរស្ដាប់ពាក្យរបស់ឧបាសិកានោះហើយគិតថា កាលពួកយើងនាំទ្រព្យស្រីបែបនេះទៅ រន្ទះគប្បីបាញ់ត្រង់អំបែងក្បាល ដូច្នេះហើយ ទើបទៅកាន់សម្នាក់ពួកចោរប្រាប់ថា ពួកឯងចូរជញ្ជូនទ្រព្យឧបាសិកាទៅទុកកន្លែងដើមវិញឲ្យឆាប់ ចោរទាំងនោះឲ្យបន្ទប់កហាបណៈពេញដោយកហាបណៈ ឲ្យបន្ទប់ប្រាក់ពេញដោយប្រាក់ ឲ្យបន្ទប់មាសពេញដោយមាសហើយ ។ បានឮថា ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ជាធម្មតា ព្រោះហេតុនោះឯង ទើបព្រះដ៏មានព្រះភាគត្រាស់ថា

ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំល្អហើយ រមែងនាំមកនូវសេចក្ដីសុខ នេះជាអានិសង្សក្នុងធម៌ ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នក

ប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

ពួកចោរបានឈរក្នុងទីស្តាប់ធម៌ ចំណែកព្រះថេរៈសម្តែងធម៌ហើយ កាលរាត្រីភ្លឺស្វាង ទើបចុះចាកអាសនៈ ក្នុងខណៈនោះ មេចោរក្រាបទៀបបាតជើងរបស់ឧបាសិកា ពោលថា បពិត្រអ្នកនាងម្ចាស់ សូមអ្នកនាងម្ចាស់អត់ទោសដល់ខ្ញុំចុះ ឧបាសិកាពោលថា នែអ្នក តើមានរឿងអ្វី មេចោរពោលថា ពួកខ្ញុំចងអាឃាតក្នុងអ្នកនាងម្ចាស់ បំណងនឹងសម្លាប់ ទើបឈររង់ចាំឧបាសិកា ពោលថា អើ អ្នក បើដូច្នោះ ខ្ញុំអត់ទោសឲ្យ ។

សូម្បីពួកចោរដ៏សេស ក៏ធ្វើយ៉ាងនោះដូចគ្នា កាលឧបាសិកាពោលថា បាទាំងឡាយខ្ញុំអត់ទោសឲ្យ ទើបពោលថា បពិត្រអ្នកនាងម្ចាស់ បើអ្នកនាងម្ចាស់អត់ទោសដល់ពួកខ្ញុំសោត សូមអ្នកនាងម្ចាស់ ឲ្យបព្វជ្ជាដល់ពួកខ្ញុំក្នុងសម្នាក់នៃបុត្ររបស់អ្នកនាងម្ចាស់ចុះ ។ ឧបាសិកានោះ ថ្វាយបង្គំព្រះថេរៈហើយពោលថា បពិត្រលោកកូន ពួកចោរទាំងនេះជ្រះថ្លាក្នុងគុណរបស់ញោមនិងធម្មកថារបស់កូន ទើបនាំគ្នាសូមបព្វជ្ជា សូមលោកម្ចាស់ឲ្យចោរទាំងនេះបួសចុះ ។

ព្រះថេរៈពោលថា សាធុ ហើយឲ្យកាត់ជាយសំពត់ដែលចោរទាំងនោះស្លៀកហើយ ជ្រលក់ដោយដីក្រហម ឲ្យពួកចោរបួសហើយ ឲ្យតាំងនៅក្នុងសីល ក្នុងកាលឧបសម្បទាហើយ ព្រះថេរៈបានឲ្យព្រះកម្មដ្ឋានផ្សេងៗ ដល់ភិក្ខុរូបនោះម្តងមួយរយ ។ ភិក្ខុ ៩០០ រូបនោះ រៀនកម្មដ្ឋាន ៩ យ៉ាងផ្សេងៗ គ្នា ហើយនាំគ្នាឡើងកាន់ភ្នំមួយ អង្គុយធ្វើសមណធម៌ក្រោមម្លប់

ឈើនោះៗ ហើយ ។

ព្រះសាស្តាប្រថាប់គង់ក្នុងជេតពនមហាវិហារ ចម្ងាយ ១២០ យោជន៍ នោះឯង ទ្រង់សម្លឹងមើលភិក្ខុទាំងនោះ ទ្រង់កំណត់ព្រះធម្មទេសនាដោយការសម្លឹងចរិយារបស់ភិក្ខុទាំងនោះ ទ្រង់បញ្ចេញព្រះរស្មីទៅ ហាក់បីដូចប្រថាប់គង់ក្នុងទីចំពោះមុខ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

មេត្តាវិហារី យោ ភិក្ខុ  បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ  សង្ខារូបសមំ សុខំ ។
សិញ្ច ភិក្ខុ ឥមំ នាវំ  សិត្តា តេ លហុមេស្សតិ
ឆេត្វា រាគញ្ច ទោសញ្ច  តតោ និព្វានមេហិសិ ។
បញ្ច ឆិន្ទេ បញ្ច ជហេ  បញ្ច ឧត្តរិ ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ  ឱឃតិណ្ណោតិ វុច្ចតិ ។
ឈាយ ភិក្ខុ មា ច បមាទោ  មា តេ កាមគុណេ ភមស្សុ ចិត្តំ
មា លោហគុឡំ គិលី បមត្តោ  មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ ។
នត្ថិ ឈានំ អបញ្ញស្ស  នត្ថិ បញ្ញា អឈាយិនោ
យម្ហិ ឈានញ្ច បញ្ញា ច  ស វេ និព្វានសន្តិកេ ។
សុញ្ញាគារំ បវិដ្ឋស្ស  សន្តចិត្តស្ស ភិក្ខុនោ
អមានុសី រតី ហោតិ  សម្មា ធម្មំ វិបស្សតោ ។
យតោ យតោ សម្មសតិ  ខន្ធានំ ឧទយព្វយំ
លភតិ បីតិចាមោជ្ជំ  អមតំ តំ វិជានតំ ។
តត្រាយមាទិ ភវតិ  ឥធ បញ្ញស្ស ភិក្ខុនោ

ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ ចាតិមោក្ខេ ច សំវរោ
មិត្តេ ភជស្សុ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។
បដិសន្ថារវុត្យស្ស អាចារកុសលោ សិយា
តតោ ចាមោជ្ជពហុលោ ទុក្ខស្សន្តំ ករិស្សតិ ។

ភិក្ខុណា នៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។ ម្នាលភិក្ខុ អ្នកចូរស្តារទូក គឺអត្តភាពនេះ ទូកដែលអ្នកស្តារហើយ នឹងដល់ត្រើយឆាប់ អ្នកកាត់រាគៈ និងទោសៈបានហើយ អំពីនោះ នឹងអាចដល់នូវព្រះនិព្វាន ។ ភិក្ខុគប្បីកាត់ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់ឧទ្ធម្ភាគិយសំយោជនៈ ៥ ផង គប្បីចម្រើនឥន្ទ្រិយ ៥ តទៅ ភិក្ខុអ្នកកន្លងកិលេសជាគ្រឿងចំពាក់ ៥ ( រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ ) បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន ។ ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្តរបស់អ្នក ចូរកុំវិលទៅរកកាមគុណឡើយ ចូរអ្នកកុំប្រមាទទំពាស៊ីនូវដុំលោហៈ កុំឲ្យជាអ្នក កាលភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខ ដូច្នេះឡើយ ។ ការពិនិត្យ មិនមានដល់បុគ្គលអ្នកមិនមានប្រាជ្ញា ប្រាជ្ញា មិនមានដល់បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យ និងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះ

ឯង ឈ្មោះថា ស្ថិតនៅក្នុងទីជិតនៃព្រះនិព្វាន ។ សេចក្ដីត្រេកអរដែលមិនមែនជារបស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូរទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ ។ ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះ រមែងបាននូវបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអតមធម៌របស់បណ្ឌិត អ្នកដឹងនូវធម៌ទាំងឡាយ ។ គុណ ៣ ប្រការនេះ គឺការរក្សាឥន្ទ្រិយ ១ សេចក្ដីសន្ដោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជាខាងដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ ( ម្នាលភិក្ខុ ) ចូរអ្នកគប់រកកល្យាណ-មិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

ភិក្ខុគប្បីជាអ្នកប្រព្រឹត្តធ្វើបដិសណ្ឋារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារ ព្រោះហេតុទាំងពីរនោះ អ្នកនឹងមានបាមោជ្ជច្រើន នឹងធ្វើទីបំផុតទុក្ខបាន ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **មេត្តាវិហារី** សេចក្ដីថា បុគ្គលធ្វើកម្មក្នុងព្រះកម្មដ្ឋានដែលប្រកបដោយមេត្តាក្ដី ជាអ្នកញ៉ាំងឈានពួក ៣ និងពួក ៤ ឲ្យកើតឡើងដោយអំណាចនៃមេត្តា ហើយតាំងនៅក្ដី ឈ្មោះថា មាន

ប្រក្រតីនៅដោយមេត្តាពិត ។

ពាក្យថា **បសន្នោ** សេចក្តីថា ភិក្ខុណាជាអ្នកជ្រះថ្លាហើយ អធិប្បាយថា រមែងជាំបណ្តុះនូវសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនានោះឯង ។

ពីរបទថា **បទំ សន្តំ** នោះ ជាឈ្មោះនៃព្រះនិព្វាន ពិតហើយ ភិក្ខុបែបនោះ រមែងសម្រេច អធិប្បាយថា រមែងជួបដោយពិតនូវព្រះនិព្វានដែលជាចំណែកនៃសេចក្តីស្ងប់ ឈ្មោះថា ជាទីចូលទៅរម្ងាប់សង្ខារ ព្រោះភាពដែលសង្ខារទាំងពួង ជាសភាវៈស្ងប់រម្ងាប់ហើយ ដែលមានឈ្មោះថា សុខ ព្រោះភាពជាសុខយ៉ាងក្រៃលែង ។

បាទព្រះគាថាថា **សិញ្ច ភិក្ខុ ឥមំ នាវំ** សេចក្តីថា ម្នាលភិក្ខុ ចូរអ្នកស្តារទូក ពោល គឺអត្តភាពនេះ ដែលមានទឹក គឺមិច្ឆាវិតក្កចោល ។

បាទព្រះគាថាថា **សិត្តា តេ លហុមេស្សតិ** សេចក្តីថា ដូចទូកដែលពេញហើយដោយទឹកក្នុងសមុទ្រនោះឯង ឈ្មោះថា គេស្តារហើយ ព្រោះភាពដែលទឹកដែលគេបិទប្រហោងទាំងឡាយ ស្តារហើយ ជាទូកដែលស្រាលមិនក្រឡាប់ក្នុងមហាសមុទ្រ រមែងស្ទុះទៅដល់កំពង់បានរហ័ស យ៉ាងណាទូក គឺអត្តភាពរបស់អ្នកនេះ ដែលពេញហើយដោយទឹក គឺមិច្ឆាវិតក្កក៏ដូច្នោះឈ្មោះថា អ្នកស្តារហើយ ព្រោះភាពដែលទឹក គឺមិច្ឆាវិតក្ក ដែលកើតឡើងហើយ ដែលភិក្ខុបិទប្រហោងទាំងឡាយ មានចក្ខុទ្វារជាដើមដោយការសង្រួមស្តារចេញហើយ ទើបស្រាល មិនលិចក្នុងសង្សារវដ្ត នឹងធាប់ដល់ព្រះនិព្វាន ។

បទថា **ឆេត្វា** ជាដើម សេចក្តីថា ចូរភិក្ខុកាត់គ្រឿងចង គឺរាគៈ និងទោសៈ កាលកាត់គ្រឿងចងទាំងនោះហើយ នឹងសម្រេចអរហត្ត អធិប្បាយថា បន្ទាប់អំពីនោះ គឺក្នុងកាលតមក នឹងសម្រេចអនុបាទិសេសនិព្វាន ។

ពីរបទថា **បញ្ច ឆិន្ទេ** គឺកាត់សំយោជនៈ ដែលមានក្នុងចំណែកខាងក្រោម ៥ យ៉ាង ដែលញ៉ាំងសត្វឲ្យដល់អបាយជាន់ទាបដោយពួក ៣ នៃអ្នកជាន់ទាប ដូចបុរសកាត់ខ្សែដែលចងហើយត្រង់ជើង ដោយសស្រ្តាដូច្នោះ ។

ពីរបទថា **បញ្ច ជហេ** សេចក្តីថា គប្បីលះ គឺចោល អធិប្បាយថា គប្បីកាត់សំយោជនៈដែលមានក្នុងចំណែកខាងលើ ៥ យ៉ាង ដែលញ៉ាំងសត្វឲ្យដល់ទេវលោកជាន់ខ្ពស់ ដោយអំណាចអរហត្តមគ្គ ដូចបុរសកាត់ខ្សែដែលជាប់ត្រង់កដូច្នោះ ។

បាទព្រះគាថាថា **បញ្ច ឧត្តរិ ភាវយេ** គឺគប្បីញ៉ាំងឥន្ទ្រិយ ៥ មានសទ្ធាជាដើមឲ្យចម្រើនក្រៃលែង ដើម្បីប្រយោជន៍ដល់ការលះសំយោជនៈ ដែលមានក្នុងចំណែកខាងលើ ។

បទថា **បញ្ចសង្គាតិគោ** សេចក្តីថា កាលបើដូច្នោះ ភិក្ខុឈ្មោះថាជាអ្នកកន្លងនូវកិលេស ដែលជាគ្រឿងជាប់ជំពាក់ ៥ យ៉ាងបាន ព្រោះឈានកន្លងកិលេសជាគ្រឿងជាប់ជំពាក់ គឺរាគៈ ទោសៈ មោហៈ មានះ និងទិដ្ឋិ ៥ យ៉ាង ព្រះសាស្តាត្រាស់ហៅថាជាអ្នកឆ្លងឱឃៈបាន អធិប្បាយថា ភិក្ខុនោះព្រះសាស្តាត្រាស់ហៅថា ជាអ្នកឆ្លងឱឃៈ ៤ បានពិត ។

ពីរបទថា **ឈាយ ភិក្ខុ** សេចក្តីថា ម្នាលភិក្ខុ ចូរអ្នកសម្លឹងដោយអំណាច

ឈាន ២ នេះ ឈ្មោះថា កុំប្រមាទឡើយ ព្រោះភាពជាបុគ្គលមានប្រក្រតីមិនប្រមាទក្នុងកាយកម្មជាដើម ។

បទថា **ភមស្សុ** គឺចិត្តរបស់ភិក្ខុកុំវិលត្រឡប់ទៅក្នុងកាមគុណ ៥ យ៉ាង ។

បទថា **មា លោហគុឡំ** សេចក្តីថា ជនទាំងឡាយដែលប្រមាទហើយដោយការភ្លើតភ្លើន មានការបណ្តែតបណ្តោយសតិជាលក្ខណៈ រមែងលេបដុំលោហៈដែលក្តៅហើយក្នុងនរក ព្រោះដូច្នោះ ទើបតថាគតពោលនឹងអ្នក អ្នកកុំជាអ្នកប្រមាទលេបនូវដុំដែក កុំជាអ្នកត្រូវភ្លើងដុតក្នុងនរក កន្ទក់កន្ទេញថា នេះទុក្ខ នេះទុក្ខ ។

ពីរបទថា **នត្ថិ ឈានំ** សេចក្តីថា ឈ្មោះថា ឈាន រមែងមិនមានដល់បុគ្គលឥតប្រាជ្ញា ដោយបញ្ញាជាហេតុព្យាយាមញ៉ាំងឈានឲ្យកើតឡើង ។

ពីរបទថា **នត្ថិ បញ្ញា** សេចក្តីថា បញ្ញាដែលមានលក្ខណៈ ដែលព្រះដ៏មានព្រះភាគត្រាស់ថា ភិក្ខុមានចិត្តតាំងមាំហើយ រមែងដឹង រមែងឃើញតាមសេចក្តីពិត រមែងមិនមានដល់បុគ្គលដែលមិនសម្ងំ ។

បាទព្រះគាថាថា **យម្ហិ ឈានញ្ច បញ្ញា ច** សេចក្តីថា ឈាននិងបញ្ញា ទាំងពីរនេះ មានក្នុងបុគ្គលណា បុគ្គលនោះ ឈ្មោះថា តាំងនៅហើយ ក្នុងទីជិតនៃព្រះនិព្វានដោយពិតនោះឯង ។

បាទព្រះគាថាថា **សុញ្ញាគារំ បវិដ្ឋស្ស** គឺជាអ្នកមិនលះបង់កម្មដ្ឋានអង្គុយដោយការធ្វើកម្មដ្ឋានក្នុងចិត្ត ក្នុងឱកាសដែលស្ងាត់ ទីណាមួយនោះឯង ។

បទថា **សន្តចិត្តស្ស** គឺជាអ្នកមានចិត្តស្ងប់ហើយ ។

បទថា **សម្មា** ជាដើម សេចក្ដីថា ការត្រេកអរ មិនមែនជារបស់មាននៃមនុស្ស ពោល គឺវិបស្សនាក្តី សេចក្ដីត្រេកអរដែលជាទិព្វ ពោល គឺសមាបត្តិ ៨ ក្តី រមែងមាន អធិប្បាយថា រមែងកើតឡើងដល់បុគ្គលដែលឃើញច្បាស់នូវធម៌ ដោយហេតុ ដោយការណ៍ ។

បាទព្រះគាថាថា **យតោ យតោ សម្មសតិ** សេចក្ដីថា ធ្វើកម្មក្នុងអារម្មណ៍ ៣៨ ប្រការ ដោយអាការណាមួយ គឺធ្វើកម្មក្នុងកាលទាំងឡាយ មានកាលមុនភត្តជាដើម ក្នុងកាលណាមួយដែលខ្ជួនពេញចិត្តហើយ ឬធ្វើកម្មក្នុងព្រះកម្មដ្ឋានដែលខ្ជួនពេញចិត្តហើយ ឈ្មោះថា ពិចារណាឃើញ ។

បទថា **ឧទយព្វយំ** គឺនូវការកើតឡើងនៃខន្ធ ៥ ដោយលក្ខណៈ ២៥ និងការវិនាសនៃខន្ធ ៥ ដោយលក្ខណៈ ២៥ ដូចគ្នា ។

បទថា **បីតិបាមោជ្ជំ** គឺកាលពិចារណាការកើតឡើង និងការសូន្យទៅនៃខន្ធទាំងឡាយយ៉ាងនេះ ឈ្មោះថា រមែងបាននូវបីតិក្នុងធម៌ និងបាមោជ្ជក្នុងធម៌ ។

បទថា **អមតំ** សេចក្ដីថា កាលនាមរូប មួយអន្លើដោយបច្ច័យជាសភាវៈប្រាកដតាំងឡើង បីតិ និងបាមោជ្ជដែលកើតឡើងហើយនោះ ឈ្មោះថាជាអមតៈរបស់អ្នកប្រាជ្ញទាំងឡាយ គឺរបស់បណ្ឌិតដោយពិត ព្រោះបីតិ និងបាមោជ្ជជាធម៌ឲ្យសត្វដល់អមតមហានិព្វាន ។

បាទព្រះគាថាថា **តត្រាយមាទិ ភវតិ** គឺនេះជាខាងដើម គឺបីតិ និងបាមោជ្ជ

នេះ ជាឋានៈមានខាងដើមក្នុងអមតធម៌នោះ ។

ពីរបទថា **ឥធ បញ្ញស្ស** គឺដល់ភិក្ខុដែលឈ្លាសក្នុងព្រះសាសនានេះ ។

ឥឡូវនេះ ព្រះសាស្តាកាលទ្រង់សម្តែងកម្មដ្ឋានដែលមានខាងដើម ដែលទ្រង់ត្រាស់ថា **អាទិ** នោះ ទើបត្រាស់ពាក្យជាដើមថា **ឥន្ទ្រិយគុត្តិ** មែនពិតបារិសុទ្ធិសីល ៤ ឈ្មោះថា ជាឋានៈមានខាងដើម ។

ការសង្រួមឥន្ទ្រិយ ឈ្មោះថា **ឥន្ទ្រិយគុត្តិ** ក្នុងព្រះគាថានោះ ។ ការសន្តោសដោយបច្ច័យ ៤ ឈ្មោះថា **សន្តុដ្ឋិ** ។ អាជីវបារិសុទ្ធិសីល និងបច្ច-យសន្និស្សិតសីល ព្រះសាស្តាត្រាស់ដោយបទថា **សន្តុដ្ឋិ** នោះឯង ។

ភាពជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល ដ៏ប្រសើរបំផុត ពោល គឺបាតិមោក្ខព្រះសាស្តាត្រាស់ដោយបទថា **បាតិមោក្ខេ** ។

បាទព្រះគាថាថា **មិត្តេ ភជស្សុ កល្យាណេ** សេចក្តីថា លោកលះបង់សម្លាញ់ដែលមិនសមគួរ មានការងារដែលលះបង់ហើយ ចូរគប់រក គឺចូរសេពកល្យាណមិត្ត ដែលឈ្មោះថាមានអាជីវៈបរិសុទ្ធ ព្រោះមានជីវិតប្រកបដោយសារៈ និងឈ្មោះថាជាអ្នកមិនខ្ជិលច្រអូស ព្រោះអាស្រ័យកម្លាំងស្មូនចិញ្ចឹមជីវិត ។

បាទព្រះគាថាថា **បដិសន្ថារវុត្យស្ស** គឺគប្បីជាបុគ្គលឈ្មោះថាប្រព្រឹត្តក្នុងបដិសណ្ឋារៈ ព្រោះជាអ្នកប្រព្រឹត្តពេញហើយ ដោយអាមិសបដិសណ្ឋារ និងធម្មបដិសណ្ឋារៈ អធិប្បាយថា គប្បីជាបុគ្គលធ្វើបដិសណ្ឋារៈ ។

បទថា **អាចារកុសលោ** សេចក្តីថា សូម្បីសីលក៏ឈ្មោះថា មារយាទ

សុប្បវិត្ត និងបដិវត្ត ក៏ឈ្មោះថាមារយាទ គប្បីជាអ្នកឈ្លាស អធិប្បាយថា គប្បីជាអ្នកឈ្លាសក្នុងមារយាទនោះ ។

បាទព្រះគាថាថា **តតោ ចាមោជ្ជពហុលោ** សេចក្ដីថា ភិក្ខុនោះឈ្មោះថា ជាអ្នកច្រើនដោយបាមោជ្ជ ព្រោះជាអ្នកត្រេកអរក្នុងធម៌ដែលកើតឡើងហើយចាកការប្រព្រឹត្តបដិសណ្ឋារៈ និងភាពជាអ្នកឈ្លាសក្នុងមារយាទនោះ និងធ្វើទីបំផុតនៃទុក្ខទាំងអស់បាន ។

បណ្ដាបទព្រះគាថាទាំងនេះ ដែលព្រះសាស្ដាទ្រង់សម្ដែងយ៉ាងនេះ ក្នុងកាលចប់គាថានីមួយៗភិក្ខុមួយរយៗសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ ក្នុងទីដែលអង្គុយហើយនោះឯង ហោះឡើងទៅកាន់អាកាសហើយភិក្ខុទាំងអស់នោះ ឈានកន្លងផ្លូវកន្តារ ១២០ យោជន៍ តាមផ្លូវអាកាសនោះឯង សរសើរព្រះសរីរៈដែលមានពណ៌ដូចមាសរបស់ព្រះតថាគត ថ្វាយបង្គំព្រះបាទាហើយ ដូច្នេះឯង ។៚

## រឿងសម្ពហុលភិក្ខុ ចប់

# រឿង ភិក្ខុ៥០០រូប

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រមាណ ៥ រយរូប ត្រាស់ព្រះធម្មទេសនានេះថា **វស្សិកា វិយ បុប្ផានិ** ជាដើម ។

បានឮមកថា ភិក្ខុទាំងនោះរៀនកម្មដ្ឋាន ក្នុងសម្នាក់របស់ព្រះសាស្តា បំពេញសមណធម៌ក្នុងព្រៃ ឃើញផ្កាម្លិះរីកហើយអំពីព្រលឹម ជ្រុះចាកទងក្នុងពេលល្ងាច ទើបនាំគ្នាព្យាយាម ដោយសង្ឃឹមថា ពួកយើងនឹងរួចផុតចាកកិលេស មានរាគៈជាដើម ឲ្យបានមុនផ្កាទាំងឡាយដែលជ្រុះចាកទង ។

ព្រះសាស្តា ទ្រង់ប្រមើលមើលភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីព្យាយាមដើម្បីរួចផុតចាកទុក្ខឲ្យបាន ដូចផ្កាដែលជ្រុះចាកទងដូច្នោះ ប្រថាប់គង់ត្រង់ព្រះគន្ធកុដិនោះឯង ទ្រង់បញ្ចេញព្រះរស្មីទៅហើយ ត្រាស់ព្រះគាថានេះថា

**វស្សិកា វិយ បុប្ផានិ　　មទ្ទវានិ បមុញ្ចតិ**
**ឯវំ រាគញ្ច ទោសញ្ច　　វិប្បមុញ្ចេថ ភិក្ខវោ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីជម្រុះរាគៈ និងទោសៈចេញ ដូចម្លិះជម្រុះផ្កា ម្លិះទាំងឡាយដែលស្វិតហើយ ដូច្នោះ ។

## សេចក្តីអធិប្បាយ

ផ្កាម្លិះ ឈ្មោះថា **វស្សិកា** ក្នុងព្រះគាថានោះ ។

បទថា **មទ្ទវានិ** ប្រែថា ក្រៀមស្វិតហើយ លោកអធិប្បាយថា ផ្កាម្លិះ

រមែងជម្រុះនូវផ្កាដែលរីកហើយ កាលពីម្សិលមិញ ក្នុងថ្ងៃរះឡើង ជាផ្កាចាស់ឲ្យជ្រុះចាកទង យ៉ាងណា អ្នកទាំងឡាយ ក៏ចូរជម្រុះនូវទោសទាំងឡាយមានរាគៈជាដើមនោះចុះ ។ ក្នុងកាលចប់ទេសនា ភិក្ខុទាំងអស់តាំងនៅក្នុងអរហត្តហើយ ដូច្នេះឯង ។l៚

រឿងភិក្ខុ ៥០០ រូប ចប់

# រឿង ព្រះសន្តកាយត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសន្តកាយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សន្តកាយោ** ជាដើម ។

បានឮថា ឈ្មោះថា ការថ្គាំថ្គងដៃ និងជើងរបស់ព្រះថេរៈនោះមិនមានឡើយ លោកជាអ្នកវៀរចាកការទម្រន់កាយ ជាអ្នកមានអត្តភាពស្ងប់ ។

បានឮថា ព្រះថេរៈនោះមកពីកំណើតរាជសីហ៍ ។ បានឮថា រាជសីហ៍ទាំងឡាយ កាន់យកអាហារក្នុងថ្ងៃមួយហើយ ចូលទៅកាន់គុហាប្រាក់ គុហាមាស គុហាកែវមណី គុហាកែវបវាឡ គុហាណាមួយដេកត្រង់លម្អិតនៃមនោសិលា និងហរតាលអស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៧ ក្រោកឡើងហើយ ពិនិត្យមើលទីដែលខ្លួនដេកហើយ បើឃើញថាលម្អិតនៃមនោសិលា និងហរតាលខ្ចាត់ខ្ចាយរាត់រាយហើយ ព្រោះភាពដែលកន្ទុយ ត្រចៀក ឬជើងដែលខ្លួន

កម្រើកហើយ គិតថា ការធ្វើបែបនេះមិនសមគួរដល់ជាតិ ឬគោត្ររបស់អ្នក ហើយក៏ដេកអត់អាហារ ៧ ថ្ងៃទៀត តែកាលមិនមានលម្អិតទាំងឡាយខ្ចាត់ខ្ចាយទៅ ទើបគិតថា ការធ្វើបែបនេះសមគួរដល់ជាតិ និងគោត្ររបស់អ្នកដូច្នេះហើយ ក៏ចេញចាកទីអាស្រ័យពត់កាយ សម្លឹងមើលទិសទាំងឡាយ បន្លឺសីហនាទ ៣ ដង ហើយក៏ចេញទៅរកស៊ី ។ ភិក្ខុនេះមកហើយ ដោយកំណើតរាជសីហ៍បែបនេះ ។

ភិក្ខុទាំងឡាយ ឃើញការប្រព្រឹត្តរៀបរយផ្លូវកាយរបស់លោក ទើបក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុដូចព្រះសន្តកាយត្ថេរ ពួកខ្ញុំព្រះអង្គមិនធ្លាប់ឃើញឡើយ ការគ្រាំគ្រងដៃ គ្រាំគ្រងជើង ឬការប្រអូសកាយរបស់ភិក្ខុនេះ ក្នុងទីនៃភិក្ខុនេះអង្គុយហើយ មិនមាន ។

ព្រះសាស្តាស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីជាអ្នកស្ងប់ទ្វារទាំងឡាយ មានកាយទ្វារជាដើមដោយពិត ដូចសន្តកាយត្ថេរ ដូច្នោះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**សន្តកាយោ សន្តវាចោ សន្តមនោ សុសមាហិតោ**
**វន្តលោកាមិសោ ភិក្ខុ ឧបសន្តោតិ វុច្ចតិ ។**

ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសក្នុងលោកខ្ជាក់ចោលហើយ ទើបតថាគត ហៅថា អ្នកស្ងប់រម្ងាប់ ។

# សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **សន្តកាយោ** *ជាដើម សេចក្តីថា ឈ្មោះថាជាអ្នកមានកាយស្ងប់ហើយ ព្រោះការមិនមានកាយទុច្ចរិតទាំងឡាយ មានបាណាតិបាតជាដើម ឈ្មោះថាជាអ្នកមានវាចាស្ងប់ហើយ ព្រោះការមិនមានវចីទុច្ចរិតទាំងឡាយ មានមុសាវាទជាដើម ឈ្មោះថា មានចិត្តស្ងប់ហើយ ព្រោះមិនមានមនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជាដើម ឈ្មោះថា ជាអ្នកតាំងមាំល្អហើយ ព្រោះភាពដែលទ្វារទាំង ៣ មានកាយជាដើមតាំងមាំហើយដោយល្អ ឈ្មោះថា មានអាមិសក្នុងលោកខ្ជាក់ចោលហើយ ព្រោះភាពដែលអាមិសក្នុងលោក ជារបស់ដែលខ្លួនខ្ជាក់ចោលហើយដោយមគ្គ ៤ ព្រះសាស្តាត្រាស់ហៅថា ឈ្មោះថា ជាអ្នកស្ងប់ ព្រោះភាពដែលកិលេសទាំង-ឡាយ មានរាគៈជាដើម ខាងក្នុងស្ងប់រម្ងាប់ហើយ ។*

*ក្នុងកាលចប់ទេសនា ព្រះថេរៈតាំងនៅក្នុងអរហត្តហើយ ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។ល។*

**រឿងព្រះសន្តកាយត្ថេរ ចប់**

# រឿង ព្រះនង្គលកូដត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនង្គលកូដត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អត្តនា ចោទយត្តានំ** ជាដើម ។

បានឮថា បុរសទុគ៌តម្នាក់ ធ្វើការស៊ីឈ្នួលឲ្យជនដទៃចិញ្ចឹមជីវិត ។ ភិក្ខុមួយរូប ឃើញបុរសនោះស្លៀកសំពត់ចាស់លីនង្គ័លដើរទៅ ទើបពោលយ៉ាងនេះថា បើអ្នកបួស មិនប្រសើរជាងការរស់នៅបែបនេះឬ បុរសទុគ៌តពោលថា អ្នកណានឹងឲ្យខ្ញុំដែលមានសភាពយ៉ាងនេះបួស ភិក្ខុពោលថា បើអ្នកបួស អាត្មានឹងបំបួស បុរសទុគ៌តពោលថា សាធុ បើលោកម្ចាស់ឲ្យខ្ញុំបួស ខ្ញុំនឹងបួស ។

គ្រានោះ ព្រះថេរៈនាំបុរសនោះចូលទៅកាន់វត្តជេតពន ហើយឲ្យងូតទឹកដោយដៃខ្លួនឯង ឲ្យសម្រាកត្រង់រោងហើយ ឲ្យបួស ឲ្យបុរសនោះទុកដាក់នង្គ័ល មួយអន្លើដោយសំពត់ចាស់ ដែលគាត់ស្លៀកត្រង់មែកឈើក្បែររោងនោះឯង ក្នុងកាលឲ្យឧបសម្បទា លោកបានប្រាកដឈ្មោះថា នង្គលកូដត្ថេរនោះឯង ។

ព្រះនង្គលកូដត្ថេរនោះ អាស្រ័យលាភសក្ការៈដែលកើតឡើងដើម្បីព្រះសម្ពុទ្ធទាំងឡាយចិញ្ចឹមជីវិត អផ្សុកឡើងហើយ កាលមិនអាចបន្ទោបង់បាន ទើបសម្រេចចិត្តថា ឥឡូវនេះ អញនឹងស្លៀកដណ្ដប់កាសាវពស្ត្រទាំងឡាយដែលគេឲ្យដោយសទ្ធា ដូច្នេះហើយ ក៏ទៅកាន់គល់ឈើ ឲ្យឱវាទខ្លួនឯងដោយខ្លួនឯងថា ឯងមិនមានហិរិ មិនមានឱត្តប្បៈ ឯងចង់ស្លៀកដណ្ដប់សំពត់

ដាច់ដាចនេះ សឹកទៅធ្វើការស៊ីឈ្នួលចិញ្ចឹមជីវិតឬ ។ កាលលោកទូន្មានខ្លួនយ៉ាងនោះឯង ចិត្តដល់នូវភាពជាធម្មជាតស្រាល ប្រាសចាកអផ្សុកហើយ ។

លោកត្រឡប់មកហើយ កន្លងមក ២-៣ ថ្ងៃ ក៏អផ្សុកទៀត ទើបទូន្មានខ្លួនយ៉ាងនោះឯង លោកប្រែចិត្តបានទៀត ក្នុងកាលអផ្សុកកើតឡើង លោកទៅក្នុងទីនោះហើយ ទូន្មានខ្លួនដោយទំនងនេះឯង ។

គ្រានោះ ភិក្ខុទាំងឡាយឃើញលោកទៅក្នុងទីនោះរឿយៗ ទើបសួរថា នង្គលកូដត្ថេរ ហេតុអ្វី ទើបលោកទៅក្នុងទីនោះ ព្រះថេរៈឆ្លើយថា ខ្ញុំទៅកាន់សម្នាក់អាចារ្យ ដូច្នេះហើយ កន្លងមក ២-៣ ថ្ងៃប៉ុណ្ណោះ ក៏សម្រេចអរហត្តផល ។

ភិក្ខុទាំងឡាយ កាលធ្វើនូវការលេលង ទើបពោលថា នង្គលកូដៈ ផ្លូវត្រាច់ទៅរបស់លោក ហាក់ដូចជារកស្នាមមិនបាន ប្រហែលជាលោកមិនទៅកាន់សម្នាក់របស់អាចារ្យទៀតទេដឹង ព្រះថេរៈពោលថា យ៉ាងនោះឯងលោកម្ចាស់ កាលកិលេសជាគ្រឿងជាប់ជំពាក់នៅមាន ខ្ញុំបានទៅហើយ តែឡូវនេះកិលេសជាគ្រឿងជាប់ជំពាក់ខ្ញុំកាត់បានហើយ ព្រោះដូច្នោះ ទើបខ្ញុំមិនទៅ ។

ភិក្ខុទាំងឡាយ ស្តាប់ចម្លើយនោះហើយយល់ថា ភិក្ខុនេះពោលមិនពិតព្យាករអរហត្តផល ដូច្នេះហើយ ទើបក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នង្គលកូដៈបុត្ររបស់តថាគតដាស់តឿនខ្លួនឯងដោយខ្លួនឯង ហើយទើបដល់ទីបំផុតនៃកិច្ចរបស់បព្វជិត ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ បានភាសិតព្រះគាថាទាំងនេះថា

**អត្តនា ចោទយត្តានំ បដិមំសេតមត្តនា**
**សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។**
**អត្តា ហិ អត្តនោ នាថោ អត្តាហិ អត្តនោ គតិ**
**តស្មា សញ្ញម អត្តានំ អស្សំ ភទ្រំ វាណិជោ ។**

*អ្នកចូរជាស់តឿនខ្លួនឯងដោយខ្លួនឯង ចូរពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះបើមានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។ ពិតហើយ ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររវាំងខ្លួន ដូចពាណិជរវាំងសេះដ៏ល្អ ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បទថា* **ចោទយត្តានំ** *សេចក្ដីថា ចូរជាស់តឿនខ្លួនដោយខ្លួនឯង គឺចូរញ៉ាំងខ្លួនឲ្យភ្ញាក់រឭកដោយខ្លួនឯង ។*

*បទថា* **បដិមំសេ** *គឺពិនិត្យមើលខ្លួនដោយខ្លួនឯង ។*

*បទថា* **សោ** *ជាដើម សេចក្ដីថា ម្នាលភិក្ខុ បុគ្គលនោះកាលជាស់តឿនពិចារណាមើលខ្លួនយ៉ាងនោះ ជាបុគ្គលឈ្មោះថាគ្រប់គ្រងខ្លួនបាន ព្រោះភាពជាបុគ្គល មានខ្លួនគ្រប់គ្រងហើយដោយខ្លួនឯង ជាបុគ្គលឈ្មោះថា មានសតិ ព្រោះជាអ្នកមានសតិតាំងមាំហើយ នឹងនៅសប្បាយគ្រប់ឥរិយាបថ ។*

*បទថា* **នាថោ** *សេចក្ដីថា ជាទីអាស្រ័យ គឺជាទីពំនាក់ ព្រោះបុគ្គលអាស្រ័យក្នុងអត្តភាពរបស់អ្នកដទៃ មិនអាចជាអ្នកធ្វើកុសលហើយ មានឋាន*

សុគតិជាទីទៅខាងមុខ ឬជាអ្នកញុំាងមគ្គឲ្យចម្រើនហើយ ធ្វើផលឲ្យជាក់ច្បាស់បាន ព្រោះហេតុនោះ ទើបមានអធិប្បាយថា បុគ្គលដទៃណាគប្បីជាទីពឹងបាន ។

បទថា **តស្មា** ជាដើម សេចក្ដីថា ហេតុដែលខ្លួនឯងជាគតិ គឺជាទីពំនាក់បានដល់ ជាសរណៈរបស់ខ្លួន ។

ឈ្មួញសេះ អាស្រ័យសេះដែលចម្រើន គឺសេះអាជានេយ្យនោះប្រាថ្នាលាភ ទើបវៀរចាកការគ្រាច់ទៅក្នុងទីមិនស្មើ គឺមិនសមគួរនៃសេះនោះឲ្យងូតទឹក ឲ្យបរិភោគមួយថ្ងៃ ៣ ដង ឈ្មោះថា រក្សា គឺផ្គត់ផ្គង់ យ៉ាងណា សូម្បីអ្នក កាលការពារនូវការកើតឡើងនៃអកុសលដែលមិនទាន់កើត កម្ចាត់ទីកើតឡើងហើយ ព្រោះការមិនមានស្មារតី ឈ្មោះថា ជាអ្នករវាំង គឺគ្រប់គ្រងខ្លួន ដូច្នោះ កាលអ្នករក្សាខ្លួនបានយ៉ាងនេះ អ្នកនឹងសម្រេចគុណវិសេស ជាលោកិយផង ជាលោកុត្តរផង តាំងអំពីបឋមជ្ឈានជាដើមទៅ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

## រឿង ព្រះនង្គលកូដត្ថេរ ចប់

# រឿង ព្រះវក្កលិត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះវក្កលិត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ចាមោជ្ជពហុលោ ភិក្ខុ** ជាដើម ។

បានឮថា ព្រះវក្កលិត្ថេរនោះ កើតក្នុងត្រកូលព្រាហ្មណ៍ នាក្រុងសាវត្ថី ចម្រើនវ័យហើយ ឃើញព្រះតថាគតយាងចូលទៅដើម្បីបិណ្ឌបាត សម្លឹងព្រះសរីរសម្បត្តិរបស់ព្រះសាស្តាហើយ មិនឆ្អែតដោយការឃើញព្រះសរីរសម្បត្តិ ទើបបព្វជ្ជាក្នុងសម្នាក់ព្រះសាស្តា ដោយតាំងចិត្តថា អញនឹងបានឃើញព្រះដ៏មានព្រះភាគជានិច្ចកាលដោយឧបាយនេះ ដូច្នេះហើយ ក៏ឈរក្នុងទីដែលខ្លួនឈរ ដែលអាចឃើញព្រះទសពលបាន លះកិច្ចវត្តទាំងឡាយ មានការស្វាធ្យាយ និងមនសិការកម្មដ្ឋានជាដើម ត្រាច់មើលព្រះសាស្តា ។

ព្រះសាស្តាទ្រង់រង់ចាំការចាស់ក្លានៃញាណរបស់លោក ទើបមិនត្រាស់អ្វីឡើយ លុះទ្រង់ជ្រាបថា ឥឡូវនេះ ញាណរបស់លោកចាស់ក្លាហើយ ទើបត្រាស់ឱវាទថា វក្កលិ ប្រយោជន៍អ្វីរបស់អ្នកដោយការមើលកាយស្អុយនេះ ម្នាលវក្កលិ បុគ្គលណាឃើញធម៌ បុគ្គលនោះ ឈ្មោះថា ឃើញតថាគត បុគ្គលណាឃើញតថាគត បុគ្គលនោះ ឈ្មោះថា ឃើញធម៌ ។

ព្រះវក្កលិនោះ កាលព្រះសាស្តាទូន្មានហើយយ៉ាងនោះ ក៏មិនអាចលះនូវការមើលព្រះសាស្តាទៅក្នុងទីដទៃបានឡើយ ។ កាលនោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា ភិក្ខុនេះមិនបាននូវការសង្វេគ នឹងមិនបានត្រាស់ដឹង កាលវស្សូបនាយិកសម័យជិតចូលមកហើយ ទើបយាងទៅកាន់ក្រុងរាជគ្រឹះ ក្នុង

ថ្ងៃចូលវស្សា ទ្រង់បណ្តេញព្រះវក្កលិដោយព្រះតម្រាស់ថា វក្កលិ ចូរអ្នកចៀសចេញទៅ ព្រះថេរៈគិតថា ព្រះសាស្តាមិនត្រាស់ជាមួយអញ មិនអាចតាំងនៅក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តាបាន អស់ត្រីមាស ទើបគិតថា ប្រយោជន៍អ្វីរបស់អញដោយជីវិត អញនឹងឲ្យខ្លួនធ្លាក់ពីលើភ្នំចុះ ដូច្នេះហើយ ទើបឡើងទៅកាន់ភ្នំគិជ្ឈកូដ ។ ព្រះសាស្តា ទ្រង់ជ្រាបការហត់នឿយរបស់ព្រះថេរៈហើយទ្រង់ព្រះតម្រិះថា ភិក្ខុនេះបើមិនបាននូវការលួងលោមអំពីសម្នាក់របស់តថាគតគប្បីញ៉ាំងឧបនិស្ស័យនៃមគ្គ និងផលឲ្យវិនាស ទើបទ្រង់បញ្ចេញព្រះរស្មីទៅហើយ ដើម្បីបង្ហាញព្រះកាយឲ្យប្រាកដ ។

លំដាប់នោះ តាំងអំពីកាលលោកឃើញព្រះសាស្តាហើយ សេចក្តីសោកសូម្បីច្រើនដល់ម៉្លោះ ក៏បាត់ទៅហើយ ។ ព្រះសាស្តា ហាក់ដូចជាញ៉ាំងស្រះដែលរីងស្ងួតឲ្យពេញដោយទឹក ដើម្បីទ្រង់ញ៉ាំងបីតិ និងបាមោជ្ជដ៏មានកម្លាំងឲ្យកើតដល់ព្រះថេរៈ ទើបត្រាស់ព្រះគាថានេះថា

**ចាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ**
**អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។**

ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធ-
សាសនា រមែងបាននូវបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ
នាំមកនូវសេចក្តីសុខ ។

## សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះថា ភិក្ខុអ្នកច្រើនដោយបាមោជ្ជ ដោយ

ប្រក្រតី រមែងបណ្តុះនូវសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះជ្រះថ្លាយ៉ាងនោះ គប្បីសម្រេចព្រះនិព្វានក្នុងព្រះពុទ្ធសាសនា ដែលបានឈ្មោះថា សន្តបទ ជាទីចូលទៅស្ងប់សង្ខារជាសុខ ។ ព្រះសាស្តាកាលត្រាស់ព្រះគាថានេះហើយ ទ្រង់លាព្រះហស្ត បានត្រាស់ព្រះគាថាទាំងនេះ ដល់ព្រះវក្កលិត្ថេរថា

មកចុះវក្កលិ អ្នកកុំខ្លាច ចូរសម្លឹងមើលតថាគត តថាគតនឹងលើកអ្នកឡើង ដូចបុគ្គលលើកដំរីដែលលិចក្នុងភក់ឡើងដូច្នោះ មកចុះវក្កលិ ចូរអ្នកកុំខ្លាច ចូរអ្នកសម្លឹងតថាគត តថាគតនឹងលើកអ្នកឡើង ដូចបុគ្គលដែលជួយព្រះចន្ទ ដែលត្រូវរាហូចាប់ ដូច្នោះ ។

កាលញុំាងបីតិយ៉ាងខ្លាំងក្លា ឲ្យកើតឡើងហើយថា អញបានឃើញព្រះទសពលហើយ ទ្រង់ត្រាស់ហៅអញថា មកចុះ ទើបគិតថា អញគប្បីទៅតាមផ្លូវណាហ្ន៎ កាលមិនឃើញផ្លូវជាទីទៅ ទើបហោះឡើងទៅក្នុងអាកាស ក្នុងទីចំពោះព្រះភក្ត្រព្រះទសពល កាលជើងទីមួយតាំងនៅត្រង់ភ្នំនោះឯង នឹកដល់ព្រះគាថា ដែលព្រះសាស្តាត្រាស់ហើយ សង្កត់បីតិបានក្នុងអាកាសនោះឯង សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយហើយ ថ្វាយបង្គំព្រះតថាគតនោះឯង បានចុះមកឈរក្នុងសម្នាក់ព្រះសាស្តាហើយ ។

ក្នុងកាលតមក ព្រះសាស្តា ទ្រង់តាំងលោកទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាសទ្ធាធិមុត្ត ដូច្នេះឯង ៕

**រឿងព្រះវក្កលិត្ថេរ ចប់**

# រឿង សុមនសាមណេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងបុព្វារាម ទ្រង់ប្រារព្ធសុមនសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ហវេ** ជាដើម ។

អនុបុព្វីកថា ក្នុងរឿងនោះ មានដូចតទៅនេះ

សេចក្តីពិស្តារថា ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ កុលបុត្រម្នាក់ ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ លើសភិក្ខុទាំងឡាយខាងមានទិព្វចក្ខុ ក្នុងកណ្តាលបរិស័ទ ៤ ប្រាថ្នាសម្បត្តិនោះទើបនិមន្តព្រះសាស្តា ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គគប្បីជាកំពូលជាងភិក្ខុទាំងឡាយអ្នកមានទិព្វចក្ខុ ក្នុងព្រះសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ។

ព្រះសាស្តាទ្រង់ប្រមើលមើលអស់សែនកប្ប ទ្រង់ជ្រាបការសម្រេចនៃសេចក្តីប្រាថ្នារបស់កុលបុត្រនោះហើយ ទើបទ្រង់ព្យាករថា ក្នុងទីបំផុតនៃសែនកប្បបន្ទាប់អំពីកប្បនេះ អ្នកនឹងបានជាភិក្ខុឈ្មោះអនុរុទ្ធត្ថេរ ជាកំពូលជាងភិក្ខុទាំងឡាយខាងទិព្វចក្ខុ ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមគោតម ។ កុលបុត្រស្តាប់ពាក្យព្យាករនោះហើយ សម្គាល់សម្បត្តិនោះហាក់ដូចជាបានក្នុងថ្ងៃស្អែក ។ កាលព្រះសាស្តាបរិនិព្វានហើយ ទើបសួរការបរិកម្មដើម្បីបានទិព្វចក្ខុ ពួកភិក្ខុឲ្យធ្វើគោមដើមច្រើនពាន់ដើម ព័ទ្ធជុំវិញព្រះស្តូបមាស ដែលមានកម្ពស់ ៧ យោជន៍ ហើយឲ្យធ្វើការបូជាដោយប្រទីប ចុតិអំពីអត្តភាពនោះហើយកើតក្នុង

ទេវលោក អន្ទោលទៅក្នុងទេវលោក និងមនុស្សលោកអស់មួយសែនកប្ប ក្នុងកប្បនេះ កើតក្នុងត្រកូលជនទុគ៌ត ក្នុងក្រុងពារាណសី អាស្រ័យសុមន-សេដ្ឋី ជាអ្នកជញ្ជូនស្មៅរបស់សេដ្ឋីនោះចិញ្ចឹមជីវិត ។ បុរសនោះបានឈ្មោះថា អន្នភារៈ សូម្បីសុមនសេដ្ឋី ក៏ថ្វាយមហាទានក្នុងព្រះនគរនោះអស់កាលជានិច្ច ។

ថ្ងៃមួយ ព្រះបច្ចេកពុទ្ធព្រះនាមថា ឧបរិដ្ឋៈ ចេញអំពីនិរោធសមាបត្តិ ត្រង់ភ្នំគន្ធមាទន៍ហើយគិតថា ថ្ងៃនេះអាត្មាអញនឹងធ្វើសេចក្តីអនុគ្រោះដល់អ្នកណាហ្ន៎ ជ្រាបថា ថ្ងៃនេះការដែលអាត្មាអញធ្វើសេចក្តីអនុគ្រោះដល់បុរសឈ្មោះអន្នភារៈគួរ ឥឡូវនេះ បុរសនោះរែកស្មៅចេញអំពីព្រៃហើយនឹងមកផ្ទះ ដូច្នេះហើយ ទើបកាន់យកបាត្រ និងចីវរទៅដោយឫទ្ធិ ប្រាកដចំពោះមុខអន្នភារៈ ។ កាលអន្នភារៈឃើញព្រះបច្ចេកពុទ្ធ មានបាត្រទទេក្នុងដៃហើយសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់បានភិក្ខាខ្លះដែរឬទេ កាលព្រះបច្ចេកពុទ្ធតបថា នែអ្នកមានបុណ្យច្រើន អាត្មានឹងបាន ទើបពិតថា បពិត្រលោកម្ចាស់ បើដូច្នោះសូមលោកម្ចាស់មេត្តារង់ចាំបន្តិចចុះ ដូច្នេះហើយ ក៏ទុកអម្រែកស្មៅ រត់ទៅកាន់ផ្ទះ ដោយរហ័ស សួរភរិយាថា នែនាង ភត្តចំណែកដែលនាងទុកដើម្បីខ្ញុំ តើមានដែរឬទេ កាលនាងឆ្លើយថា មានអ្នក ទើបត្រឡប់មកដោយរហ័សទទួលបាត្ររបស់ព្រះបច្ចេកពុទ្ធទៅកាន់ផ្ទះ ដោយគិតថា កាលអញប្រាថ្នាដើម្បីឲ្យ ទេយ្យធម៌មិនមាន កាលទេយ្យធម៌មាន អញមិនបានបដិគ្គាហកតែថ្ងៃនេះ បដិគ្គាហកក៏អញជួបហើយ ទេយ្យធម៌របស់អញក៏មាន ជាលាភ

របស់អញហ្ន៎ ឲ្យបាក់កត្តុចុះក្នុងបាត្រ ហើយនាំត្រឡប់មកដាក់ក្នុងដៃរបស់ព្រះបច្ចេកពុទ្ធ តាំងសេចក្ដីប្រាថ្នាថា ដោយទាននេះ ភាពជាអ្នកក្រីក្រ កុំបីមានដល់ខ្ញុំឡើយ ពាក្យថា មិនមាន កុំបីមានឡើយ ក្នុងភពតូចភពធំ ។

បពិត្រលោកម្ចាស់ ខ្ញុំគប្បីរួចផុតចាកការចិញ្ចឹមជីវិតខ្វះខាតបែបនេះ មិនគប្បីបានឮពាក្យថា មិនមានឡើយ ។

ព្រះបច្ចេកពុទ្ធធ្វើអនុមោទនាថា សូមសេចក្ដីប្រាថ្នារបស់អ្នក សម្រេចយ៉ាងនោះចុះ ដូច្នេះហើយ ក៏ចៀសចេញទៅ ។

ទេវតាដែលអាស្រ័យត្រង់ស្វេតច្ឆត្ររបស់សុមនសេដ្ឋីពោលថា

គួរត្រេកអរពិតហ្ន៎ ទាននេះជាទានដ៏កំពូល អន្នភារៈតម្កល់ទុកល្អហើយក្នុងព្រះឧបរិដ្ឋបច្ចេកពុទ្ធ ដូច្នេះហើយ បានឲ្យសាធុការ ៣ ដង ។

គ្រានោះ សេដ្ឋីពោលនឹងទេវតានោះថា អ្នកមិនឃើញយើងឲ្យទានជានិច្ចអស់កាលមានប្រមាណប៉ុណ្ណោះទេឬ ទេវតាពោលថា ខ្ញុំប្រាថ្នាទានរបស់លោកហើយ ឲ្យសាធុការក៏មិនមែន តែសាធុការនេះ ខ្ញុំឲ្យប្រព្រឹត្តទៅហើយ ព្រោះសេចក្ដីជ្រះថ្លាក្នុងបិណ្ឌបាត ដែលអន្នភារៈប្រគេនហើយ ដល់ព្រះឧបរិដ្ឋ-បច្ចេកពុទ្ធ ។

សេដ្ឋីនោះគិតថា គួរអស្ចារ្យហ្ន៎ អញឲ្យទានអស់កាលមានប្រមាណប៉ុណ្ណោះ ក៏មិនអាចឲ្យទេវតាឲ្យនូវសាធុការបាន អន្នភារៈ អាស្រ័យអញរស់នៅ គង់ឲ្យទេវតាធ្វើសាធុការដោយបិណ្ឌបាតម្ដងប៉ុណ្ណោះ អញនឹងធ្វើវត្ថុដែលសមគួរក្នុងទានរបស់អន្នភារៈ ហើយធ្វើបិណ្ឌបាតនោះឲ្យជារបស់អញ ដូច្នេះ

ហើយ ទើបឲ្យហៅអន្ធការៈមកសួរថា ថ្ងៃនេះឯងបានឲ្យអ្វីដល់អ្នកណាដែរឬទេ អន្ធការៈពោលថា បពិត្រលោកម្ចាស់ ថ្ងៃនេះខ្ញុំប្រគេនភត្តាហារដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធ សេដ្ឋីពោលថា ណ្ហើយចុះបា ចូរឯងយកកហាបណៈ ហើយឲ្យបិណ្ឌបាតនោះដល់យើងចុះ អន្ធការៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំឲ្យមិនបានទេ ។ សេដ្ឋីនោះ ឡើងតម្លៃឲ្យរហូតដល់មួយពាន់ ចំណែកអន្ធការៈ ក៏មិនបានឲ្យស្ដុំទ្រព្យមួយពាន់ ។ លំដាប់នោះ សេដ្ឋីពោលថា អ្នកដ៏ចម្រើន សេចក្ដីនោះលើកទុកចុះ បើឯងមិនឲ្យបិណ្ឌបាត ចូរកាន់យកទ្រព្យមួយពាន់ ហើយឲ្យចំណែកបុណ្យចុះ អន្ធការៈពោលថា ខ្ញុំប្រឹក្សាជាមួយព្រះបច្ចេកពុទ្ធហើយ ទើបដឹងបាន ប្រញាប់រត់ទៅទាន់ព្រះបច្ចេកពុទ្ធហើយសួរថា បពិត្រលោកម្ចាស់ សុមនសេដ្ឋីឲ្យទ្រព្យមួយពាន់ ហើយសូមចំណែកបុណ្យក្នុងបិណ្ឌបាតរបស់លោកម្ចាស់ តើខ្ញុំត្រូវធ្វើដូចម្ដេច ។

ពេលនោះព្រះបច្ចេកពុទ្ធ នាំឧបមាមកប្រៀបធៀបដល់បុរសនោះថា នែអ្នក ប្រទីបក្នុងផ្ទះមួយខ្នង ក្នុងស្រុកដែលមានត្រកូលមួយរយ គប្បីឆេះឡើង ពួកជនដ៏សេស យកប្រេងរបស់ខ្លួនជ្រលក់ប្រឆេះហើយគប្បីទៅអុជបន្ត ហើយកាន់យក ពន្លឺប្រទីបដើមបុគ្គលគប្បីពោលថាមានឬមិនមាន ។ អន្ធការៈពោលថា ពន្លឺរមែងមានច្រើនជាង ព្រះបច្ចេកពុទ្ធពោលថា ដូច្នោះឯងបណ្ឌិត ទោះជាបបរមួយវែក ឬភិក្ខាមួយវែកក្តី កាលបុគ្គលឲ្យចំណែកបុណ្យក្នុងបិណ្ឌបាតរបស់ខ្លួនដល់អ្នកដទៃ ឲ្យដល់មនុស្សប៉ុនណា បុណ្យទាំងនោះរមែងចម្រើន ឯអ្នកបានឲ្យបិណ្ឌបាតមួយចំណែកប៉ុណ្ណោះ តែកាលអ្នកឲ្យចំណែកបុណ្យ

ដល់សេដ្ឋី បិណ្ឌបាត ឈ្មោះថា ពីរចំណែក មួយចំណែកជារបស់អ្នក មួយចំណែកជារបស់សេដ្ឋី អន្នភារៈទទួលថា សាធុ ហើយថ្វាយបង្គំព្រះបច្ចេកពុទ្ធ ទៅកាន់សម្នាក់សេដ្ឋីពោលថា សូមលោកម្ចាស់ទទួលយកនូវចំណែកបុណ្យចុះ សេដ្ឋីពោលថា បើដូច្នោះ ចូរអ្នកទទួលយកកហាបណៈទាំងនេះ អន្នភារៈពោលថា ខ្ញុំមិនបានលក់បិណ្ឌបាត ខ្ញុំឲ្យចំណែកបុណ្យដល់លោកម្ចាស់ដោយសទ្ធា សេដ្ឋីពោលថា អ្នកឲ្យដោយសទ្ធា ខ្ញុំក៏បូជាគុណរបស់អ្នកដោយសទ្ធា ចូរទទួលយកចុះ ម្យ៉ាងទៀត ចាប់តាំងអំពីនេះទៅ អ្នកកុំធ្វើការដោយដៃរបស់ខ្លួន ចូរសង់ផ្ទះក្បែរផ្លូវវិថីចុះ ចូរកាន់យកវត្ថុគ្រប់យ៉ាង ដែលអ្នកត្រូវការអំពីសម្នាក់របស់ខ្ញុំ ។

បិណ្ឌបាតដែលបុគ្គលថ្វាយដល់អ្នកចេញអំពីនិរោធ រមែងឲ្យផលក្នុងថ្ងៃនោះឯង ព្រោះដូច្នោះ សូម្បីព្រះរាជាទ្រង់ស្តាប់ការប្រព្រឹត្តទៅនោះហើយ ទើបត្រាស់ឲ្យហៅអន្នភារៈមក ហើយទ្រង់ទទួលចំណែកបុណ្យ ព្រះរាជទានភោគៈច្រើន ហើយត្រាស់ឲ្យព្រះរាជទានតំណែងសេដ្ឋីដល់អន្នភារៈ ។

អន្នភារៈនោះ បានជាសម្លាញ់របស់សុមនសេដ្ឋី ធ្វើបុណ្យទាំងឡាយដរាបដល់អស់ជីវិត ចុតិអំពីអត្តភាពនោះហើយកើតក្នុងទេវលោក អន្ទោលទៅក្នុងទេវលោក និងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងព្រះរាជវាំងរបស់ស្តេចសក្យៈ ព្រះនាមអមិតោទនៈ ក្នុងនគរកបិលពស្តុ ព្រះញាតិទាំងឡាយថ្វាយព្រះនាមដល់ព្រះកុមារនោះថា អនុរុទ្ធ ។ កុមារនោះ ជាព្រះកនិដ្ឋភាតារបស់មហានាមសក្យៈ ជាឱរសរបស់ម្ចាស់មានៃព្រះសាស្តា បានជា

សុខមាលជាតិយ៉ាងក្រៃលែង ជាអ្នកមានបុណ្យច្រើន ។

បានឮថា ថ្ងៃមួយ កាលក្សត្រ ៦ អង្គលេងឃ្លី យកនំសម្រាប់ភ្នាល់គ្នា ព្រះអនុរុទ្ធចាញ់ ទើបបញ្ជូនដំណឹងទៅកាន់សម្នាក់របស់ព្រះមាតា ដើម្បីនំ ព្រះមាតាយកភាជនៈធំដាក់នំពេញហើយបញ្ជូនមកឲ្យ ព្រះអនុរុទ្ធសោយនំ ហើយ ទ្រង់លេងចាញ់ទៀត ក៏បញ្ជូនដំណឹងទៅយ៉ាងនោះឯង ។

កាលមនុស្សនាំនំមកយ៉ាងនេះអស់ ៣ ដង លើកទី ៤ មាតាបញ្ជូន ដំណឹងទៅថា ឥឡូវនេះ នំមិនមាន ព្រះអនុរុទ្ធទ្រង់ស្តាប់ពាក្យរបស់មាតា នោះហើយ ធ្វើសេចក្តីសម្គាល់ថា នំឈ្មោះមិនមាន នឹងមានក្នុងឥឡូវនេះ ព្រោះបទថា មិនមាន ជាបទដែលខ្លួនមិនធ្លាប់ឮហើយ ទើបទ្រង់បញ្ជូនទៅ ដោយព្រះតម្រាស់ថា ចូរឯងទៅយកនំមិនមានមក ។ កាលនោះ មាតារបស់ ព្រះកុមារ កាលអ្នកបម្រើទូលថា បពិត្រព្រះនាង សូមព្រះនាងឲ្យនំមិនមាន ទើបព្រះនាងត្រិះរិះថា ពាក្យថា មិនមាន កូនរបស់អញ មិនធ្លាប់ឮមកហើយ អញគប្បីឲ្យកូនរបស់អញដឹងភាពដែលមិនមាននោះដូចម្តេចហ្ន៎ ទើបព្រះនាង លាងថាសមាស គ្របដោយថាសមាស ដទៃបញ្ជូនទៅថា ទៅចុះបា ចូរបា ឲ្យថាសមាសនេះដល់កូនរបស់យើង ។

ខណៈនោះ ទេវតាទាំងឡាយ ដែលជាអ្នករក្សានគរគិតថា ព្រះអនុរុទ្ធ របស់ពួកយើង ប្រគេនភត្តជាចំណែកខ្លួនដល់ព្រះបច្ចេកពុទ្ធព្រះនាមថាឧបរិដ្ឋៈ ហើយតាំងសេចក្តីប្រាថ្នាថា ខ្ញុំមិនគប្បីបានឮពាក្យថាមិនមាន កាលនៅជាអ្នក រែកស្មៅឈ្មោះអន្នភារៈ ។ បើអញដឹងសេចក្តីនោះហើយ គប្បីប្រងើយកន្តើយ

សោត ក្បាលរបស់អញនឹងបែកជា ៧ ភាគ ទើបធ្វើថាសឲ្យពេញដោយនំទិព្វទាំងឡាយហើយ ។ បុរសនោះនាំថាសមកទុកក្នុងសម្នាក់របស់សក្យៈទាំងនោះហើយបើក ក្លិនរបស់នំទិព្វទាំងនោះ ក៏ផ្សាយទៅពេញព្រះនគរ កាលនំគ្រាន់តែស្តេចសក្យៈទាំងនោះដាក់ក្នុងព្រះឱស្ឋ ក្លិននោះបានផ្សាយទៅកាន់សរសៃសម្រាប់ទទួលរសទាំង ៧ ពាន់ តាំងនៅហើយ ។

ព្រះអនុរុទ្ធទ្រង់ត្រិះរិះថា ពីមុនព្រះមាតាប្រហែលជាមិនស្រឡាញ់អញ ព្រោះក្នុងកាលដទៃទ្រង់មិនធ្លាប់ធ្វើនំមិនមានឲ្យដល់អញ ។ កុមារនោះទៅហើយទូលនឹងមាតាយ៉ាងនេះថា បពិត្រព្រះមាតា ខ្ញុំមិនជាទីស្រឡាញ់របស់ទ្រង់ឬ ព្រះមាតាពោលថា នែបា កូននិយាយអ្វី បាជាទីស្រឡាញ់ក្រៃលែងរបស់មាតា ក្រៃលែងជាងកែវភ្នែកទាំងគូ ក្រៃលែងជាងសាច់បេះដូង ព្រះអនុរុទ្ធពោលថា បពិត្រព្រះមាតា បើខ្ញុំជាទីស្រឡាញ់របស់ទ្រង់សោត ព្រោះហេតុអ្វីក្នុងកាលមុន ទើបមាតាមិនប្រទាននំមិនមានបែបនេះដល់ខ្ញុំ ព្រះនាងត្រាស់សួរបុរសនោះថា នែបា តើមានអ្វីកើតក្នុងថាសនោះឬ បុរសនោះពោលថា បពិត្រព្រះនាង មាន ថាសនោះពេញដោយនំទាំងឡាយ នំបែបនោះ ទូលបង្គំមិនធ្លាប់ឃើញទេ្បីយ ។ ព្រះនាងត្រិះរិះថា កូនរបស់អញបានធ្វើបុណ្យទុកហើយ នំទិព្វដែលជារបស់ទេវតាទាំងឡាយ បញ្ជូនឲ្យទៅឲ្យបុត្ររបស់អញ ។ ព្រះអនុរុទ្ធក៏ទូលនឹងព្រះមាតាថា បពិត្រព្រះមាតា នំបែបនេះ ខ្ញុំមិនធ្លាប់សោយឡើយ តាំងអំពីថ្ងៃនេះទៅ សូមព្រះមាតាធ្វើនំមិនមាននេះប៉ុណ្ណោះដល់ខ្ញុំ ។

តាំងពីកាលនោះមក ព្រះនាងលាងថាសមាសហើយ គ្របដោយថាស

ដទៃបញ្ជូនទៅក្នុងពេលដែលព្រះអនុរុទ្ធពោលថា ខ្ញុំត្រូវការបរិភោគនំ ។ ទេវតាទាំងឡាយ រមែងញុំាងថាសឲ្យពេញ ។ ព្រះកុមារនោះ កាលនៅក្នុងរាជវាំង មិនបានជ្រាបពាក្យថាមិនមានដោយប្រការយ៉ាងនេះសោយតែនំទិព្វទាំងនោះ ។

កាលឱរសរបស់សក្យៈ បួសតាមលំដាប់ត្រកូល ដើម្បីជាបរិវាររបស់ព្រះសាស្ដា កាលព្រះបាទមហានាមសក្យៈត្រាស់ថា នែបា ក្នុងត្រកូលរបស់ពួកយើង បុគ្គលណាម្នាក់ដែលបួសហើយមិនមាន ឯង ឬខ្ញុំគួរបួស អនុរុទ្ធត្រាស់ថា ខ្ញុំជាសុខុមាលជាតិក្រៃលែង មិនអាចបួសបានទេ មហានាមពោលថា បើដូច្នេះ ចូរប្អូនរៀនការងារចុះ បងនឹងបួស អនុរុទ្ធពោលថា ឈ្មោះថាការងារនោះដូចម្ដេច ។ ពិតហើយ ព្រះអនុរុទ្ធរមែងមិនដឹងទីកើតឡើងនៃកត្តនឹងជ្រាបការងារបានដូចម្ដេច ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះ ។

ថ្ងៃមួយ សក្យៈ ៣ អង្គ គឺអនុរុទ្ធ ភទ្ទិយៈ កិម្ពិលៈប្រឹក្សាគ្នាថា ឈ្មោះថា ភត្ត កើតក្នុងទីណា បណ្ដាសក្យៈទាំង ៣ អង្គនោះ កិម្ពិលៈត្រាស់ថា ភត្ត កើតឡើងក្នុងជង្រុក បានឮថា ថ្ងៃមួយ កិម្ពិលៈនោះ បានឃើញស្រូវគេជញ្ជូនដាក់ក្នុងជង្រុក ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះដោយសម្គាល់ថា ភត្តរមែងកើតឡើងក្នុងជង្រុក ។ កាលណោះ ភទ្ទិយៈពោលនឹងកិម្ពិលៈថា ឯងមិនដឹង ដូច្នេះហើយ ទើបត្រាស់ថា ធម្មតាភត្ត គឺកើតឡើងក្នុងឆ្នាំងបាយ បានឮថា ថ្ងៃមួយ ភទ្ទិយៈនោះ ឃើញជនទាំងឡាយដួសភត្តចេញអំពីឆ្នាំងបាយ ហើយធ្វើសេចក្ដីសម្គាល់ថា ភត្តនោះ កើតក្នុងឆ្នាំងនោះឯង ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះ ។

ព្រះអនុរុទ្ធត្រាស់នឹងស្តេចទាំងពីរអង្គថា ឯងទាំងពីរក៏មិនដឹង ហើយត្រាស់ថា ភត្តកើតឡើងក្នុងថាសមាសធំកម្ពស់មួយហត្ថ បានឮថា ព្រះអនុរុទ្ធមិនធ្លាប់ឃើញគេបុកស្រូវ មិនធ្លាប់ឃើញគេដាំបាយ ឃើញតែភត្តដែលគេដួសទុកក្នុងថាសមាសហើយ តម្កល់ទុកចំពោះមុខប៉ុណ្ណោះ ព្រោះដូច្នោះ ទើបធ្វើសេចក្តីសម្គាល់ថា ភត្តនោះ រមែងកើតឡើងក្នុងថាសនោះឯង ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះ ។ កុលបុត្រមានបុណ្យច្រើន មិនដឹងទីកើតនៃភត្តយ៉ាងនោះ នឹងដឹងការងារទាំងឡាយបានដូចម្តេច ។

ព្រះអនុរុទ្ធនោះ បានស្តាប់របៀបធ្វើការងារទាំងឡាយ ដែលបងប្រុសប្រាប់ដោយន័យជាដើមថា អនុរុទ្ធមក បងនឹងបង្រៀនដើម្បីនឹងគ្រប់គ្រងផ្ទះដល់ឯងដែលជាអ្នកគ្រប់គ្រងផ្ទះ ជាបឋមត្រូវភ្ជួរស្រែដូច្នេះ ជារបស់មិនមានទីបំផុត ហើយទូលលាព្រះមាតាថា សេចក្តីត្រូវការដោយការគ្រប់គ្រងផ្ទះរបស់ខ្ញុំមិនមាន ហើយយាងចេញទៅ មួយអន្លើដោយព្រះឱរសរបស់សក្យៈ ៥ អង្គមានភទ្ទិយៈជាប្រធាន ចូលទៅគាល់ព្រះសាស្តាត្រង់អនុបិយម្ពវ័ន ទ្រង់ផ្នួសហើយ កាលទ្រង់ផ្នួសហើយ ព្រះអនុរុទ្ធជាអ្នកបដិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា ៣ ដោយលំដាប់ ជាអ្នកអង្គុយលើអាសនៈមួយ អាចឃើញលោកធាតុមួយពាន់បានដោយទិព្វចក្ខុ ដូចផ្លែកន្ទួតព្រៃ ដែលបុគ្គលដាក់លើបាតដៃដូច្នោះ ទើបបន្លឺឧទានថា

ខ្ញុំរឭកបាននូវបុព្វេនិវាស ទិព្វចក្ខុខ្ញុំក៏ជម្រះហើយ ខ្ញុំជាអ្នកបានវិជ្ជា ៣ ជាអ្នកដល់នូវឫទ្ធិ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។

ព្រះថេរៈពិចារណាថា អញធ្វើកម្មអ្វីហ្ន៎ ទើបបានសម្បត្តិនេះ បានជ្រាបថា បានតាំងនូវសេចក្តីប្រាថ្នាទៀបបាទមូល របស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ហើយជ្រាបបន្តទៀតថា អាត្មាអញអន្ទោលទៅក្នុងសង្សារអស់កាលឈ្មោះនោះ អាស្រ័យសុមនសេដ្ឋីក្នុងក្រុងពារាណសីចិញ្ចឹមជីវិតឈ្មោះអន្នភារៈ ដូច្នេះហើយពោលថា

ក្នុងកាលមុន ខ្ញុំឈ្មោះអន្នភារៈ ជាជនទុគ៌ត ជាអ្នករែកស្មៅ បានប្រគេនបិណ្ឌបាតដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធ ជាអ្នកមានយស ។

កាលនោះ ព្រះថេរៈបរិវិតក្កថា សុមនសេដ្ឋីសម្លាញ់របស់អញ បានឲ្យកហាបណៈហើយ ទទួលយកចំណែកបុណ្យអំពីបិណ្ឌបាត ដែលអាត្មាអញប្រគេនដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធក្នុងកាលនោះ ឥឡូវនេះកើតក្នុងទីណាហ្ន៎ ក៏បានឃើញសេដ្ឋីនោះថា កើតក្នុងស្រុកឈ្មោះមុណ្ឌនិគម ត្រង់ជើងភ្នំក្បែរព្រៃភ្លើងឆេះ ឧបាសកឈ្មោះមហាមុណ្ឌៈ ក្នុងមុណ្ឌនិគមនោះមានកូនប្រុសពីរនាក់ គឺមហាសុមនៈ ១ ចូឡសុមនៈ ១ ក្នុងកូនទាំងពីរនោះ សុមនសេដ្ឋីកើតជាចូឡសុមនៈ កាលឃើញហើយគិតថា បើអាត្មាអញទៅក្នុងទីនោះ ឧបការៈនឹងមានឬហ្ន៎ លោកពិចារណាបានឃើញហេតុនេះថា កាលអញទៅទីនោះ ចូឡ-សុមនៈនោះមានអាយុ ៧ ឆ្នាំប៉ុណ្ណោះនឹងចេញបួស នឹងសម្រេចអរហត្តក្នុងពេលកោរសក់ស្រេចនោះឯង ។ កាលឃើញហើយ រដូវភ្លៀងជិតចូលមកដល់ ទើបទៅតាមអាកាសចុះត្រង់ទ្វារស្រុក ។ ចំណែកមហាមុណ្ឌឧបាសក ជាអ្នកស្និទ្ធស្នាលរបស់ព្រះថេរៈក្នុងកាលមុនដូចគ្នា ឃើញព្រះថេរៈឃ្លុំចីវរក្នុងពេល

បិណ្ឌបាត ទើបពោលនឹងមហាសុមនៈជាកូនថា នែបា ព្រះអនុរុទ្ធត្ថេរ របស់យើងនិមន្តមកហើយ ចូរបាទៅទទួលបាត្រឲ្យទាន់ពេលដែលអ្នកដទៃមិនទាន់ទទួលបាត្រលោកទៅ ឪពុកនឹងឲ្យគេក្រាលអាសនៈ ។ មហាសុមនៈបានធ្វើយ៉ាងនោះហើយ ឧបាសកអង្គាសព្រះថេរៈខាងក្នុងដោយគោរពហើយ ទទួលប្តេជ្ញាដើម្បីការនៅចាំវស្សាអស់ត្រីមាស ព្រះថេរៈទទួលនិមន្តហើយ ។

គ្រានោះ ឧបាសកបដិបត្តិព្រះថេរៈអស់ត្រីមាស ដូចបដិបត្តិមួយថ្ងៃនោះឯង ក្នុងថ្ងៃមហាបវារណា ទើបនាំត្រៃចីវរ និងអាហារវត្ថុដែលមានទឹកតិចប្រេង អង្ករជាដើមមកហើយ ដាក់ទៀបបាតជើងរបស់ព្រះថេរៈពោលថា សូមលោកម្ចាស់ទទួលចុះ ។ ព្រះថេរៈពោលថា កុំឡើយឧបាសក សេចក្តីត្រូវការដោយវត្ថុនេះរបស់អាត្មាមិនមាន ឧបាសកពោលថា បពិត្រលោកម្ចាស់នេះឈ្មោះថាវស្សាវាសិកលាភ សូមលោកម្ចាស់ទទួលវត្ថុនេះចុះ ព្រះថេរៈពោលថា កុំឡើយឧបាសក ឧបាសកពោលថា បពិត្រលោកម្ចាស់ ហេតុអ្វីទើបលោកម្ចាស់មិនទទួល ព្រះថេរៈពោលថា សាមណេរដែលជាកប្បិយការកក្នុងសម្នាក់របស់អាត្មាក៏មិនមាន ឧបាសកពោលថា បើយ៉ាងនោះមហាសុមនៈជាកូនរបស់ខ្ញុំនឹងជាសាមណេរ ព្រះថេរៈពោលថា ឧបាសក សេចក្តីត្រូវការដោយមហាសុមនៈរបស់អាត្មាមិនមាន ឧបាសកពោលថា បពិត្រលោកម្ចាស់ បើដូច្នោះសូមលោកម្ចាស់ឲ្យចូឡសុមនៈបួសចុះ ព្រះថេរៈទទួលថា សាធុ ហើយឲ្យចូឡសុមនៈបួស ។ ចូឡសុមនៈសម្រេចអរហត្តក្នុងពេលកោរសក់ស្រេចនោះឯង ។ ព្រះថេរៈនៅក្នុងទីនោះជាមួយចូឡសុមនសាមណេរនោះប្រមាណកន្លះ

ខែហើយ លាពួកញាតិរបស់លោកថា ពួកអាត្មានឹងគាល់ព្រះសាស្តា ដូច្នេះហើយ បានទៅតាមអាកាស ចុះត្រង់តួបដែលតាំងនៅក្នុងព្រៃ នាហិមវន្តប្បទេស ។

ព្រះថេរៈ តាមប្រក្រតីជាអ្នកប្រារព្ធសេចក្តីព្យាយាម កាលលោកកំពុងចង្រ្កមក្នុងទីនោះ យប់ដំបូង និងយប់បន្ទាប់មក ខ្យល់ក្នុងផ្ទៃតាំងឡើងហើយ ក្នុងកាលនោះ សាមណេរឃើញព្រះថេរៈលំបាក ទើបសាកសួរថា បពិត្រលោកម្ចាស់ រោគអ្វីចាក់ដោតលោកម្ចាស់ ព្រះថេរៈពោលថា ខ្យល់សៀតផ្ទៃកើតឡើងដល់ខ្ញុំហើយ សាមណេរពោលថា ក្នុងកាលដទៃខ្យល់សៀតផ្ទៃធ្លាប់កើតឡើងឬ ព្រះថេរៈពោលថា អើអាវុសោ សាមណេរពោលថា ការសប្បាយរមែងមានដោយអ្វី ព្រះថេរៈពោលថា កាលខ្ញុំបានទឹកអំពីអនោតត្តស្រះផឹក ការសប្បាយរមែងមានអាវុសោ ។ សាមណេរពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ ខ្ញុំនឹងទៅយកមក ព្រះថេរៈពោលថា លោកអាចនាំមកបានឬ សាមណេរពោលថា អាចលោកម្ចាស់ ព្រះថេរៈពោលថា បើដូច្នោះ នាគរាជឈ្មោះបន្នកៈ ក្នុងអនោតត្តស្រះស្គាល់ខ្ញុំ ចូរលោកប្រាប់ដល់នាគរាជនោះ រួចហើយនាំទឹកមួយបំពង់មក ដើម្បីប្រយោជន៍ដល់ការប្រកបថ្នាំចុះ សាមណេរទទួលថា សាធុ ហើយថ្វាយបង្គំឧបជ្ឈាយ៍ ហោះទៅកាន់អាកាសដែលមានចម្ងាយផ្លូវ ៥០០ យោជន៍ហើយ ។

ថ្ងៃនោះ នាគរាជមានអ្នករបាំចោមរោមហើយ ប្រាថ្នានឹងលេងទឹក នាគរាជនោះលុះឃើញសាមណេរកំពុងទៅប៉ុណ្ណោះក៏ក្រោធហើយគិតថា សមណៈត្រងោលនេះ រោយធូលីដែលជាប់នឹងបាតជើងលើអំបែងក្បាលរបស់អញ

សមណៈត្រងោលនេះ មកហើយដើម្បីទឹកក្នុងអនោតត្តស្រះ ឥឡូវនេះ អញនឹងមិនឲ្យទឹកដល់លោក ដូច្នេះហើយ ដេកបិទអនោតត្តស្រះ ដែលមានប្រមាណ ៥០ យោជន៍ដោយពពារ ដូចបិទផ្ទាំងបាយដោយថាសធំ ដូច្នោះ ។ សាមណេរសម្លឹងមើលអាការរបស់នាគរាជហើយ ដឹងថា នាគនេះ ក្រោធហើយ ទើបពោលគាថាថា

នាគរាជ អ្នកជាបុគ្គលមានតេជៈខ្លាំងក្លា មានកម្លាំងច្រើន ចូរអ្នកស្តាប់ពាក្យខ្ញុំចុះ ចូរឲ្យទឹកផឹកដល់ខ្ញុំ ខ្ញុំមកហើយដើម្បីប្រយោជន៍ដល់ទឹកសម្រាប់ធ្វើថ្នាំ ។ នាគរាជស្តាប់គាថានោះហើយ ពោលគាថានេះថា

ស្ទឹងធំឈ្មោះគង្គាត្រង់ទិសបូព៌ា រមែងហូរទៅកាន់មហាសមុទ្រ សូមលោកនាំទឹកផឹកអំពីស្ទឹងគង្គានោះទៅចុះ ។

សាមណេរស្តាប់ពាក្យនោះហើយគិតថា ស្តេចនាគនេះមិនឲ្យតាមសេចក្តីប្រាថ្នារបស់អញ អាត្មាអញនឹងប្រើកម្លាំងឲ្យនាគនេះដឹងអានុភាពធំ អញនឹងសង្កត់ស្តេចនាគនេះហើយយកទឹកទៅ ដូច្នេះហើយ ពោលថា មហារាជ ព្រះឧបជ្ឈាយ៍ឲ្យខ្ញុំនាំទឹកផឹកអំពីអនោតត្តស្រះប៉ុណ្ណោះ ព្រោះហេតុនោះ ទើបខ្ញុំនាំទឹកផឹកនេះតែម្យ៉ាងទៅ ចូរលោកចៀសចេញ កុំឃាត់ខ្ញុំឡើយ ដូច្នេះហើយពោលគាថានេះថា

ខ្ញុំនឹងនាំទឹកផឹកអំពីអនោតត្តស្រះនេះប៉ុណ្ណោះ ខ្ញុំជាបុគ្គលមានសេចក្តីត្រូវការដោយទឹកផឹកនេះប៉ុណ្ណោះ បើថាមពល និងកម្លាំងមានសោត ចូរនាគរាជបិទស្រះចុះ ។ កាលនោះ ស្តេចនាគពោលថា នែសាមណេរ បើលោកក្លាហាន

ជាកូនប្រុសសោត ខ្ញុំពេញចិត្តនឹងពាក្យរបស់លោក សូមអញ្ជើញលោកនាំទឹករបស់ខ្ញុំទៅចុះ ។

លំដាប់នោះ សាមណេរឆ្លើយនឹងស្តេចនាគថា មហារាជ ខ្ញុំនឹងនាំទៅយ៉ាងនោះ កាលស្តេចនាគពោលថា បើលោកអាចក៏ចូរនាំទៅចុះ ទទួលបេ្ដជ្ញាអស់វារៈ ៣ ដងថា បើដូច្នោះ ចូរលោកដឹងដោយល្អចុះ ហើយគិតថា ការដែលអញសម្តែងអានុភាពរបស់ព្រះពុទ្ធសាសនា ហើយយកទឹកទៅរមែងគួរបានទៅកាន់សម្នាក់របស់ពួកអាកាសដ្ឋកទេវតាមុន ទេវតាទាំងនោះមកថ្វាយបង្គំ ហើយពោលថា មានរឿងអ្វីលោកម្ចាស់ ហើយនាំគ្នាឈរ ។

សាមណេរពោលថា សង្គ្រាមរបស់អាត្មា និងបន្នកនាគរាជនឹងមានត្រង់ផ្ទៃអនោតត្តស្រះនេះ សូមពួកលោកទៅកាន់ទីនោះហើយ មើលនូវការឈ្នះនិងការចាញ់ ។ សាមណេរទៅរកស្តេចចតុលោកបាល និងសក្កទេវរាជ ស្តេចសុយាម ស្តេចសន្តុសិត ស្តេចសុនិម្មិត និងស្តេចវសវត្តី ហើយប្រាប់សេចក្តីនោះដោយទំនងនោះឯង ។ បន្ទាប់អំពីនោះ សាមណេរទៅដោយលំដាប់រហូតដល់ព្រហ្មលោក កាលព្រហ្មទាំងឡាយក្នុងទីនោះៗ មកថ្វាយបង្គំ ហើយឈរសួរថា មានរឿងអ្វីលោកម្ចាស់ ទើបប្រាប់សេចក្តីនោះ ។

សាមណេរ ប្រាប់ក្នុងទីគ្រប់កន្លែងមួយរំពេច វៀរតែអសញ្ញិសត្ត និងអរូបព្រហ្មដោយអាការយ៉ាងនេះ សូម្បីទេវតាគ្រប់ពួក ស្តាប់ពាក្យលោកហើយ ប្រជុំគ្នាពេញអាកាសមិនមានចន្លោះ ត្រង់អនោតត្តស្រះ ដូចលម្អិតនៃនំដែលបុគ្គលដាក់ក្នុងនាឡិ ដូច្នោះ ។

កាលពួកទេវតាប្រជុំគ្នាហើយ សាមណេរឈរក្នុងអាកាស ពោលនឹងស្តេចនាគថា

នាគរាជ អ្នកជាបុគ្គលមានតេជះខ្លាំងក្លា មានកម្លាំងច្រើន ចូរអ្នកស្តាប់ពាក្យខ្ញុំ សូមអ្នកឲ្យក្អមទឹកផឹកដល់ខ្ញុំ ខ្ញុំមកដើម្បីត្រូវការទឹកធ្វើថ្នាំ ពេលនោះនាគរាជពោលថា

សាមណេរ បើលោកក្លាហាន ជាកូនប្រុសសោត ខ្ញុំពេញចិត្តនឹងពាក្យរបស់លោក សូមលោកនាំទឹកផឹករបស់ខ្ញុំទៅចុះ ។

សាមណេរនោះទទួលពាក្យប្តេជ្ញារបស់នាគរាជ ៣ ដងហើយ ឈរក្នុងអាកាសនោះឯង និម្មិតអត្តភាពជាព្រហ្មប្រមាណ ១២ យោជន៍ ហើយទម្លាក់ខ្លួនពីលើអាកាស ជាន់ត្រង់ពពាររបស់ស្តេចនាគ សង្កត់ឲ្យផ្កាប់មុខចុះហើយ រំពេចនោះឯង កាលសាមណេរជាន់ពពាររបស់ស្តេចនាគប៉ុណ្ណោះ ពពារស្តេចនាគបានរួញទៅសល់ប្រមាណប៉ុនវែក ដូចស្បែកស្រស់ដែលបុរសមានកម្លាំងជាន់ហើយ ដូច្នោះ ។ ក្នុងទីដែលផុតចាកពពាររបស់ស្តេចនាគមក ខ្សែទឹកប្រមាណ ប៉ុនដើមត្នោតក៏បាញ់ឡើងលើ សាមណេរញុំាំងបំពង់ទឹកឲ្យពេញក្នុងអាកាសនោះឯង ពួកទេវតាបានឲ្យសាធុការហើយ ។

នាគរាជខ្មាស ក្រោធចំពោះសាមណេរហើយ ភ្នែកទាំងពីររបស់នាគរាជនោះមានពណ៌ដូចផ្កាច្បា ស្តេចនាគគិតថា សមណៈគ្រងោលនេះឲ្យពួកទេវតាប្រជុំគ្នាហើយ កាន់យកទឹកផឹក ធ្វើអញឲ្យខ្មាសហើយ អញនឹងចាប់លោកលូកដៃចូលក្នុងមាត់ហើយ ប្រេបាច់បេះដូងរបស់លោក ឬចាប់ជើងរបស់លោក

ហើយគ្រវែងទៅត្រើយស្ទឹងម្ខាង ដូច្នេះហើយ ដេញតាមសាមណេរដោយសម្ទុះដ៏រហ័ស តែមិនអាចទាន់សាមណេរឡើយ ។ សាមណេរមកហើយ ដាក់ទឹកផឹកទុកក្នុងដៃព្រះឧបជ្ឈាយ៍ ពិតថា សូមលោកម្ចាស់ឆាន់ចុះ ។

ស្តេចនាគក៏មកតាមក្រោយពោលថា បពិត្រព្រះអនុរុទ្ធ សាមណេរកាន់យកទឹកដែលខ្ញុំមិនបានឲ្យមក សូមលោកម្ចាស់កុំឆាន់ ព្រះថេរៈសួរថា នែសាមណេរ បានឮថា សេចក្តីនោះយ៉ាងនោះឬ សាមណេរពោលថា សូមលោកម្ចាស់និមន្តឆាន់ចុះ ទឹកផឹកនេះស្តេចនាគឲ្យហើយ ទើបខ្ញុំនាំមក ។ ព្រះថេរៈដឹងថា ឈ្មោះថា ការពោលពាក្យកុហករបស់សាមណេរ ដែលជាព្រះខីណាស្រព មិនមាន ទើបឆាន់ទឹកហើយ អាពាធក៏ស្ងប់ក្នុងខណៈនោះឯង ។ នាគរាជពោលនឹងព្រះថេរៈទៀតថា បពិត្រលោកម្ចាស់ ខ្ញុំជាបុគ្គលដែលសាមណេរឲ្យពួកទេវតាទាំងអស់ប្រជុំគ្នា ធ្វើឲ្យខ្មាសហើយ ខ្ញុំនឹងហែកហទយៈរបស់លោក ឬនឹងចាប់លោកត្រង់ជើង គ្រវែងទៅកាន់ត្រើយស្ទឹងម្ខាង ព្រះថេរៈពោលថា មហារាជ សាមណេរមានអានុភាពច្រើន អ្នកមិនអាចប្រយុទ្ធជាមួយសាមណេរបានឡើយ ចូរអ្នកឲ្យសាមណេរអត់ទោសហើយទៅវិញចុះ ។

ស្តេចនាគ ដឹងអានុភាពរបស់សាមណេរឯង តែដេញមក ព្រោះការខ្មាស ។ លំដាប់នោះ ស្តេចនាគឲ្យសាមណេរនោះ អត់ទោសតាមពាក្យរបស់ព្រះថេរៈ ធ្វើនូវការពេញចិត្តជាមិត្តភាព ទើបពោលថា តាំងអំពីកាលនេះទៅ បើសេចក្តីត្រូវការដោយទឹកក្នុងអនោតត្តស្រះមាន កិច្ចដោយការមកនៃលោកម្ចាស់ មិនមាន សូមលោកម្ចាស់បញ្ជូនដំណឹងដល់ខ្ញុំ ខ្ញុំនឹងនាំទឹកមក

ប្រគេនឯង ដូច្នេះហើយ បៀសចេញទៅ សូម្បីព្រះថេរៈក៏នាំសាមណេរទៅហើយ ។

ព្រះសាស្តា ទ្រង់ជ្រាបការមករបស់ព្រះថេរៈហើយ ប្រថាប់គង់ទតការមករបស់ព្រះថេរៈលើប្រាសាទរបស់មិគារមាតា ។ សូម្បីពួកភិក្ខុក៏ឃើញព្រះថេរៈកំពុងមក ក្រោកឡើងទទួល ទទួលបាត្រ និងចីវរ ។

គ្រានោះ ភិក្ខុពួកខ្លះស្ទាបសាមណេរត្រង់ក្បាលខ្លះ ចាប់ត្រចៀកទាំងពីរខ្លះ ដើមដៃខ្លះ អង្រួនខ្លះ ពោលថា នែសាមណេរ លោកមិនអផ្សុកទេឬ ។ ព្រះសាស្តាទតឃើញកិរិយារបស់ភិក្ខុទាំងនោះហើយ ទ្រង់ត្រិះរិះថា កម្មរបស់ភិក្ខុទាំងនេះគ្រោតគ្រាតពិត ភិក្ខុទាំងនេះចាប់សាមណេរ ដូចចាប់អាសិរពិសត្រង់កពួកភិក្ខុទាំងនេះមិនដឹងអានុភាពរបស់សាមណេរឡើយ ថ្ងៃនេះសមគួរតថាគតនឹងធ្វើគុណរបស់សុមនសាមណេរឲ្យប្រាកដ ។ ព្រះថេរៈក៏មកថ្វាយបង្គំព្រះសាស្តាហើយ ។

ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈ ហើយហៅព្រះអានន្ទត្ថេរមកថា អានន្ទតថាគតមានបំណងនឹងលាងជើងទាំងពីរ ដោយទឹកក្នុងអនោតត្តស្រះ ចូរអ្នកឲ្យក្អមដល់សាមណេរឲ្យនាំទឹកមកចុះ ព្រះថេរៈឲ្យសាមណេរប្រមាណ ៥០០ ក្នុងវិហារប្រជុំគ្នាហើយ ។

បណ្តាសាមណេរទាំងនោះ សុមនសាមណេរបួសថ្មីជាងសាមណេរទាំងពួង ។ ព្រះថេរៈពោលនឹងសាមណេរចាស់ជាងគេបង្អស់ថា នែសាមណេរ ព្រះសាស្តាមានបំណងលាងព្រះបាទទាំងគូ ដោយទឹកក្នុងអនោតត្តស្រះ លោក

កាន់ក្អមទឹកទៅនាំទឹកមកចុះ ។ សាមណេរនោះមិនប្រាថ្នាដោយពោលថា ខ្ញុំមិនអាច ព្រះថេរៈសួរសាមណេរទាំងឡាយដ៏សេសដោយលំដាប់ សាមណេរទាំងនោះ ក៏ពោលដោះខ្លួនយ៉ាងនោះឯង ។

មានពាក្យសួរថា បណ្តាសាមណេរទាំងនោះ សាមណេរជាព្រះខីណាស្រពមិនមានឬ ឆ្លើយថា មាន តែសាមណេរទាំងនោះមិនប្រាថ្នាដោយគិតឃើញថា កម្រងផ្កានេះ ព្រះសាស្តាទ្រង់មិនចងដើម្បីពួកយើង ទ្រង់ចងដើម្បីសុមនសាមណេរមួយអង្គប៉ុណ្ណោះ ។ តែពួកសាមណេរដែលជាបុថុជ្ជន មិនប្រាថ្នាទៅ ក៏ព្រោះភាពដែលខ្លួនជាអ្នកមិនអាចនោះឯង ក្នុងទីបំផុត កាលវារៈដល់សុមនសាមណេរ ព្រះថេរៈពោលថា សាមណេរ ព្រះសាស្តាមានបំណងលាងព្រះបាទទាំងគូ ដោយទឹកក្នុងអនោតត្តស្រះ ចូរអ្នកកាន់យកក្អមទឹកទៅដងទឹកមក សុមនសាមណេរនោះពិតថា កាលព្រះសាស្តាទ្រង់ឲ្យនាំមក ខ្ញុំនឹងនាំមក ដូច្នេះហើយ ថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ បានឮថា ទ្រង់ឲ្យខ្ញុំព្រះអង្គនាំទឹកមកអំពីអនោតត្តស្រះឬ ព្រះសាស្តាត្រាស់ថា ម្នាលសុមនៈ ពិតហើយ សុមនសាមណេរនោះយកដៃចាប់ក្អមធំមួយ ដែលដាក់ទឹកបាន ៦០ ក្អម ក្នុងបណ្តាក្អមសម្រាប់សេនាសនៈ ដែលធ្វើអំពីមាស ដែលនាងវិសាខាសាង កាន់ទៅដោយគិតថា សេចក្តីត្រូវការរបស់អញដោយក្អមដែលអញលើកឡើងដាក់លើស្មាមិនមាន ប្រញាប់ហោះឡើងទៅកាន់អាកាស បែរមុខទៅកាន់ហិមវន្តប្បទេស ។

នាគរាជឃើញសាមណេរកំពុងមកអំពីចម្ងាយ ទើបទទួលលីក្អមដោយស្មា ពោលថា បពិត្រលោកម្ចាស់ បើអ្នកបម្រើដូចខ្ញុំមាន ព្រោះហេតុអ្វី ទើបលោកម្ចាស់មកឯង បើសេចក្តីត្រូវការទឹកមាន ហេតុអ្វីលោកម្ចាស់មិនបញ្ជូនដំណឹងមក ដូច្នេះហើយ យកក្អមជងទឹកលីដោយស្មាពោលថា សូមលោកម្ចាស់ និមន្តទៅមុនចុះ ខ្ញុំនឹងនាំទៅ សាមណេរពោលថា មហារាជចូរលោកឈប់ចុះ ខ្ញុំឯងដែលព្រះសម្មាសម្ពុទ្ធប្រើមក ដូច្នេះ ឲ្យស្តេចនាគត្រឡប់ហើយ យកដៃចាប់ត្រង់កណ្តាប់មាត់ឆ្នាំង ហោះមកតាមអាកាស ។

លំដាប់នោះ ព្រះសាស្តាទ្រង់សម្លឹងមើលសាមណេរដែលកំពុងត្រឡប់មក ហៅពួកភិក្ខុមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកមើលលីលារបស់សាមណេរ ដែលល្អដូចស្តេចហង្សក្នុងអាកាសដូច្នោះ ។ សាមណេរដាក់ក្អមទឹកហើយ ថ្វាយបង្គំព្រះសាស្តាឈរក្នុងចំណែកម្ខាង ។ លំដាប់នោះ ព្រះសាស្តាត្រាស់ថា សុមនៈអ្នកមានអាយុប៉ុន្មាន សាមណេរក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមានអាយុ ៧ ឆ្នាំ ព្រះសាស្តាត្រាស់ថា សុមនៈ បើដូច្នោះតាំងអំពីនេះទៅ ចូរអ្នកជាភិក្ខុចុះ ដូច្នេះហើយ បានប្រទានទាយជ្ជឧបសម្បទា ។

បានឮថា សាមណេរអាយុ ៧ ឆ្នាំពីររូបប៉ុណ្ណោះ ដែលបានឧបសម្បទា គឺសុមនសាមណេរនេះមួយរូប និងសោបាកសាមណេរមួយរូប ។ កាលសុមនសាមណេរឧបសម្បទាហើយយ៉ាងនោះ ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ កម្មនេះ គួរអស្ចារ្យ អានុភាពរបស់សាមណេរតូចបែបនេះ ក៏មានអានុភាពបែបនេះ ពួកយើងមិនធ្លាប់ឃើញឡើយ ក្នុងកាលមុនអំពីនេះ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលពួកលោកក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនារបស់តថាគត បុគ្គលទោះជាក្មេងបដិបត្តិប្រពៃហើយ រមែងបានសម្បត្តិបែបនេះដូចគ្នា កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ**
**សោ មំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។**

ភិក្ខុណានៅកំលោះ ប្រឹងប្រែងក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងញុំាងលោកនេះឲ្យភ្លឺស្វាងបាន ដូចព្រះចន្ទ្រដែលរះផុតអំពីពពក ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យុញ្ជតិ** បានដល់ ប្រឹងប្រែង គឺព្យាយាម ។

បទថា **បភាសេតិ** ជាដើម សេចក្តីថា ភិក្ខុនោះរមែងញុំាងលោក មានខន្ធលោកជាដើមឲ្យភ្លឺស្វាងបាន គឺរមែងធ្វើឲ្យមានពន្លឺតែមួយ ដោយញាណដែលសម្បយុត្តដោយអរហត្តមគ្គរបស់ខ្លួន ដូចព្រះចន្ទ្រដែលផុតចាកគ្រឿងបិទបាំង មានពពកជាដើម ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៙

**រឿងសុមនសាមណេរ ចប់**

**ភិក្ខុវគ្គទី ២៥ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា ព្រាហ្មណវគ្គទី ២៦

[ ៣៦ ] ម្នាលព្រាហ្មណ៍ អ្នកចូរប្រឹងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយចេញ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថា ជាអ្នកដឹងព្រះនិព្វាន ដែលបច្ច័យតាក់តែងមិនបាន ។

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការ គឺសមថធម៌ និងវិបស្សនាធម៌ ក្នុងកាលណោះ កិលេស គ្រឿងប្រកបសត្វទុកទាំងអស់របស់ព្រាហ្មណ៍ អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។ ត្រើយក្តី ទីមិនមែនត្រើយក្តី ត្រើយ និងទីមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា ( សេចក្តីប្រកាន់អាយតនៈមិនមានដល់បុគ្គលណា ) តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ ។ តថាគតហៅបុគ្គលអ្នកចម្រើនឈាន មានធូលី គឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ដោយលំដាប់ហើយនោះ ថាជាព្រាហ្មណ៍ ។

ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទរុងរឿងក្នុងវេលាយប់ ក្សត្រប្រដាប់ពេញយសហើយ រមែងរុងរឿង សមណព្រាហ្មណ៍ជាអ្នកមានឈានរមែងរុងរឿង ឯព្រះពុទ្ធ រមែងរុងរឿងដោយតេជៈរហូតថ្ងៃ និងយប់ទាំងអស់ ។

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា ព្រាហ្មណ៍ អ្នកដែលតថាគតហៅថា សមណៈ ព្រោះការប្រព្រឹត្តរម្ងាប់ អ្នកដែលបណ្តេញមន្ទិលនៃខ្លួន ហេតុនោះ ទើបតថាគតហៅថា បព្វជិត ។

ព្រាហ្មណ៍ មិនគប្បីប្រហារព្រាហ្មណ៍ទេ ( ចំណែក ) ព្រាហ្មណ៍ ( ដែលត្រូវគេប្រហារហើយ ) មិនគប្បីចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍ ដែលប្រហារព្រាហ្មណ៍ ព្រាហ្មណ៍ណា ចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍នោះ ក្រៃលែងជាងនោះទៅទៀត ។

ការហាមឃាត់ចិត្ត ចាកអារម្មណ៍ជាទីស្រឡាញ់ របស់ព្រាហ្មណ៍នោះ មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ ឆាកចេញចាកវត្ថុណាៗ សេចក្តីទុក្ខព្រោះវត្ថុនោះៗ ក៏រម្ងាប់ទៅបាន ។

អំពើអាក្រក់ដោយទ្វារកាយ ទ្វារវាចា ទ្វារចិត្ត របស់បុគ្គលណា មិនមានទេ តថាគតហៅបុគ្គល ដែលបានសង្រួមដោយឋានទាំង ៣ នោះថាជាព្រាហ្មណ៍ ។

បុគ្គលចេះធម៌អាថ៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងហើយ អំពីសម្នាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើង ដូច្នោះដែរ ។

បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ ព្រោះផ្នួងសក់ក៏មិនមែន ព្រោះគោត្រក៏មិនមែន ព្រោះជាតិក៏មិនមែន សច្ចៈផង ធម៌ផង មានក្នុងបុគ្គលណា

បុគ្គលនោះ ឈ្មោះថា អ្នកស្អាតផង បុគ្គលនោះ ឈ្មោះថា ព្រាហ្មណ៍ផង ។ នែអ្នកអប្បប្រាជ្ញាអើយ អ្នកមានប្រយោជន៍អ្វី ដោយការទុកផ្នួងសក់ អ្នកមានប្រយោជន៍អ្វី ដោយការទ្រទ្រង់សំពត់ស្បែកខ្លា បើសន្ដានខាងក្នុងរបស់អ្នកសឹងសាំញ៉ាំដោយរាគាទិក្កិលេស អ្នកឈ្មោះថា ដុសខាត់តែកាយខាងក្រៅទេ ។

តថាគតហៅបុគ្គលអ្នកទ្រទ្រង់សំពត់បង្សុកូល មានកាយស្គម មានខ្លួនរវាមដោយសរសៃ ជាបុគ្គលឯកឯង ចម្រើនឈានក្នុងព្រៃនោះ ថាជាព្រាហ្មណ៍ ។ តថាគតនឹងហៅអ្នកកើតអំពីកំណើត អ្នកកើតក្នុងផ្ទៃនៃព្រាហ្មណីជាមាតា ថាជាព្រាហ្មណ៍ក៏ទេ បុគ្គលនោះ គ្រាន់តែបាននាមថាភោវាទី ( អ្នកពោលថា ចម្រើន ) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេស គ្រឿងកង្វល់នៅហើយ តថាគតហៅបុគ្គលអ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នកមិនមានសេចក្ដីប្រកាន់មាំនោះឯង ថាជាព្រាហ្មណ៍ ។

បុគ្គលណា កាត់សំយោជនៈទាំងអស់បាន មិនតក់ស្លុត តថាគតហៅបុគ្គលនោះ ដែលគ្មានកិលេលជាគ្រឿងចំពាក់ អ្នករួចស្រឡះចាកកិលេសថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលដែលកាត់សេចក្ដីក្រោធ ដូចព្ធរផង កាត់តណ្ហាដូចព្រ័ត្រផង កាត់ទិដ្ឋិ ៦២ ដូចទី-ត ព្រមទាំងអនុស័យ ដូចអ្នកដើរតាមផងអ្នកមានអវិជ្ជា ដូចសសរខឿនដកបោលហើយ អ្នកត្រាស់ដឹងសច្ចៈ ៤ នោះឯង ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនប្រទូស្ត អត់សង្កត់ពាក្យជេរផង ការបៀតបៀន និង ការចងផងបាន ទើបតថាគតហៅបុគ្គលដែលមានខន្តិជាពល មានខន្តិជារេហ៍ ពលនោះឯង ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលមិនមានសេចក្តីក្រោធ មានធុតង្គវត្ត មាន ចតុប្បារិសុទ្ធិសីល មិនមានតណ្ហាគ្រឿងប៉ោងចិត្ត មានឥន្ទ្រិយទូន្មានហើយ មានសរីរៈស្ថិតនៅ ក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹក ឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជា ព្រាហ្មណ៍ ។

បុគ្គលណា ក្នុងសាសនានេះឯង ដឹងច្បាស់នូវការអស់ទុក្ខរបស់ខ្លួន តថាគតហៅបុគ្គលនោះ ដែលមានខន្ធភារៈ ដាក់ចុះហើយ ដែលរួចស្រឡះ ចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកមានប្រាជ្ញាជ្រៅ មានប្រាជ្ញាជាគ្រឿងទម្លាយ កិលេស អ្នកឈ្លាសក្នុងផ្លូវ និងមិនមែនផ្លូវ បានសម្រេចប្រយោជន៍ ដ៏ ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលមិនច្រឡំដោយជនទាំងឡាយ ២ ពួក គឺ គ្រហស្ថ ១ បព្វជិត ១ ជាអ្នកត្រាច់ទៅដោយមិនមានសេចក្តីអាល័យ មាន សេចក្តីប្រាថ្នាតិចនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្តី

ដែលមាំមួន គឺមិនមានតក់ស្លុតក្តី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកដែលមិនខឹង ចំពោះពួកជនដែលខឹងហើយ អ្នករលត់ចំពោះពួកជន ដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ចំពោះពួកជន ដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

រាគៈ ទោសៈ មានៈ និងមក្ខៈ ដែលបុគ្គលណា បានជម្រុះចេញហើយ ដូចគ្រាប់ស្ពៃដែលជ្រុះចុះ អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។ បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹងសេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណាឲ្យទាស់ចិត្ត តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនកាន់យករបស់វែង ឬខ្លី តូច ឬធំ ល្អ ឬអាក្រក់ ដែលគេមិនបានឲ្យហើយក្នុងលោកនេះ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

អ្នកណា មិនមានសេចក្តីប្រាថ្នា ក្នុងលោកនេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គលនោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះចាកកិលេស ថាជាព្រាហ្មណ៍ ។

អ្នកណា មិនមានសេចក្តីអាល័យ គឺតណ្ហា មិនមានសេចក្តីសង្ស័យក្នុងអ្វីសោះ ព្រោះដឹងច្បាស់ធម៌ តថាគតហៅបុគ្គលនោះ ដែលមានចិត្តចុះស៊ប់កាន់ព្រះនិព្វាន ដែលមានព្រះអរហត្តផលដល់ហើយ ដោយលំដាប់ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ និងបាបទាំងពីរ និងកិលេសជាគ្រឿងជំពាក់ ( មានរាគៈជាដើម ) ចេញហើយ តថាគតហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីសោក មានធូលី គឺកិលេសអស់ហើយ ជាអ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលមិនមានសេចក្តីសៅហ្មង ដូចព្រះចន្ទ្រប្រាសចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តជ្រះថ្លា មិនកករល្អក់ អស់សេចក្តីត្រេកអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា កន្លងផ្លូវវាង គឺរាគៈ និងភក់ដែលគេឆ្លងបានដោយកម្រ គឺកិលេស និងសង្សារវដ្ត និងមោហៈទាំងនេះបាន ជាអ្នកឆ្លងអន្លង់ទាំង ៤ បានដល់ត្រើយ គឺព្រះនិព្វាន ជាអ្នកមានឈាន មិនញាប់ញ័រដោយតណ្ហា មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាមបាន តថាគតហៅបុគ្គលនោះ ដែលអស់កាមភពហើយ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន តថាគតហៅបុគ្គល ដែលអស់តណ្ហា និងភពហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា លះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្ស កន្លង

កិលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វបានហើយ តថាគតហៅបុគ្គល ដែលផុតស្រឡះ ចាកកិលេសជាគ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលលះបង់សេចក្តីត្រេកអរក្នុងកាមគុណ និង មិនត្រេកអរក្នុងកិរិយានៅក្នុងព្រៃ ជាអ្នកមានចិត្តត្រជាក់មិនមានឧបក្កិលេស គ្របសង្កត់លោកទាំងពួង មានសេចក្តីព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ដឹងច្បាស់ចុតិ និងបដិសន្ធិរបស់ពួកសត្វ ដោយអាការ ទាំងពួងបាន តថាគតហៅបុគ្គលដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមាន ដំណើរល្អ ដោយសេចក្តីប្រតិបត្តិ អ្នកត្រាស់ដឹងនូវសច្ចៈ ៤ នោះ ថាជា ព្រាហ្មណ៍ ។

ទេវតា គន្ធព្វ និងពួកមនុស្សទាំងឡាយ មិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្តនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនមានសេចក្តីកង្វល់ ក្នុងកាលមុនផង ក្នុងកាលជាខាង ក្រោយផង ក្នុងកាលជាកណ្តាលផង តថាគតហៅបុគ្គល ដែលជាអ្នកមិន មានកង្វល់ មិនមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ ងូតលាងកិលេស ត្រាស់ ដឹងសច្ចៈនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ដឹងច្បាស់ខន្ធបញ្ចកៈ ដែលខ្លួនធ្លាប់នៅអាស្រ័យ ក្នុងកាលមុនផង ឃើញច្បាស់ស្ថានសួគ៌ និងអបាយភូមិផង មួយទៀត បានសម្រេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញ ស្រេចកិច្ចហើយ ព្រោះអភិញ្ញា តថាគតហៅបុគ្គល ដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ចប់សព្វគ្រប់ហើយនោះ ថាជាព្រាហ្មណ៍ ។

ព្រាហ្មណវគ្គទី ២៦ ចប់

## ឧទ្ទាននៃធម្មបទគាថាគឺ

[ ៣៧ ] សម្ដែងពីយមកវគ្គ ១ អប្បមាទវគ្គ ១ ចិត្តវគ្គ ១ បុប្ផវគ្គ ១ ពាលវគ្គ ១ បណ្ឌិតវគ្គ ១ អរហន្តវគ្គ ១ សហស្សវគ្គ ១ បាបវគ្គ ១ ទណ្ឌវគ្គ ១ ត្រូវជា ១០ វគ្គ ។

ជរាវគ្គ ១ អត្តវគ្គ ១ លោកវគ្គ ១ ពុទ្ធវគ្គ ១ សុខវគ្គ ១ បិយវគ្គ ១ កោធវគ្គ ១ មលវគ្គ ១ ធម្មដ្ឋវគ្គ ១ មគ្គវគ្គ ១ រួបនឹងវគ្គខាងដើមត្រូវជា ២០ វគ្គ ។

បកិណ្ណកវគ្គ ១ និរយវគ្គ ១ នាគវគ្គ ១ តណ្ហាវគ្គ ១ ភិក្ខុវគ្គ ១ ព្រាហ្មណវគ្គ ១ បូករួមត្រូវជា ២៦ វគ្គ ដែលព្រះអាទិច្ចពន្ធុទ្រង់សម្ដែងទុកហើយ ។ ក្នុងយមកវគ្គ មាន ២០ គាថា ក្នុងអប្បមាទវគ្គ មាន ១២ គាថា ក្នុងចិត្តវគ្គ មាន ១១ គាថា ក្នុងបុប្ផវគ្គ មាន ១៦ គាថា ក្នុងពាលវគ្គ

មាន ១៧ គាថា ក្នុងបណ្ឌិតវគ្គ មាន ១៤ គាថា ក្នុងអរហន្តវគ្គ មាន ១០ គាថា ក្នុងសហស្សវគ្គ មាន ១៦ គាថា ក្នុងបាបវគ្គ មាន ១៣ គាថា ក្នុងទណ្ឌវគ្គ មាន ១៧ គាថា ក្នុងជរាវគ្គ មាន ១១ គាថា ក្នុងអត្តវគ្គ មាន ១២ គាថា ក្នុងលោកវគ្គ មាន ១ គាថា ក្នុងពុទ្ធវគ្គ មាន ១៦ គាថា ក្នុងសុខវគ្គ និងបិយវគ្គ មាន ១២ គាថាដូចគ្នា ក្នុងកោធវគ្គ មាន ១៤ គាថា ក្នុងមលវគ្គ មាន ២១ គាថា ក្នុងធម្មដ្ឋវគ្គ មាន ១៧ គាថា ក្នុងមគ្គវគ្គ មាន ១៦ គាថា ក្នុងបកិណ្ណកវគ្គ មាន ១៦ គាថា ក្នុងនិរយវគ្គ និងនាគវគ្គ មាន ១៤ គាថាដូចគ្នា ក្នុងតណ្ហាវគ្គ មាន ២២ គាថា ក្នុងភិក្ខុវគ្គ មាន ២៣ គាថា ក្នុងព្រាហ្មណវគ្គដ៏ឧត្តម មាន ៤០ គាថា ។ ៤២៣ គាថាដទៃទៀត ព្រះអាទិច្ចពន្ធុទ្រង់សម្តែងទុកហើយ ក្នុងធម្មបទនិបាត ។

**ធម្មបទ ចប់**

# អដ្ឋកថា
# ព្រាហ្មណវគ្គទី ២៦

## រឿង ព្រាហ្មណ៍មានសេចក្ដីជ្រះថ្លាច្រើន
### លំនាំដើម

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ មានសេចក្ដីជ្រះថ្លាច្រើន ត្រាស់ព្រះធម្មទេសនានេះថា* **ឆិន្ទ សោតំ បរក្កម្ម** *ជាដើម ។*

*បានឮថា ព្រាហ្មណ៍នោះ ស្ដាប់ព្រះធម្មទេសនារបស់ព្រះដ៏មានព្រះភាគហើយ មានចិត្តជ្រះថ្លា ផ្ដើមតាំងនិច្ចភត្តដើម្បីភិក្ខុមានប្រមាណ ១៦ រូប ក្នុងផ្ទះរបស់ខ្លួន ទទួលបាត្រក្នុងពេលភិក្ខុទាំងឡាយមកហើយ ពោលថា សូមព្រះអរហន្តទាំងឡាយនិមន្តមក សូមព្រះអរហន្តទាំងឡាយនិមន្តគង់ ។ កាលពោលពាក្យណាមួយ ក៏ពោលពាក្យប្រកបចំពោះដោយវាទៈថា ព្រះអរហន្តប៉ុណ្ណោះ បណ្ដាភិក្ខុទាំងនោះ ភិក្ខុជាបុថុជ្ជនគិតថា ព្រាហ្មណ៍នេះសម្គាល់ក្នុងពួកយើងថាជាព្រះអរហន្ត ភិក្ខុដែលជាព្រះខីណាស្រពគិតថា ព្រាហ្មណ៍ដឹងភាពដែលពួកយើងជាព្រះខីណាស្រព ភិក្ខុទាំងឡាយនោះ ប្រព្រឹត្តរង្កៀសយ៉ាងនេះ ទើបមិនទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ គាត់ទោមនស្សគិតថា ហេតុអ្វីហ្ន៎ ទើបលោកម្ចាស់មិននិមន្តមក ទៅកាន់វិហារថ្វាយបង្គំព្រះសាស្ដា ក្រាបទូលសេចក្ដីនោះ ព្រះសាស្ដាត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ*

ទាំងឡាយ សេចក្ដីនោះដូចម្ដេច កាលភិក្ខុទាំងនោះក្រាបទូលសេចក្ដីនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកត្រេកអរនឹងវាទៈថាជាព្រះអរហន្ត ឬ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនត្រេកអរទេ ព្រះសាស្ដាត្រាស់ថា បើដូច្នោះ ពាក្យនោះ គ្រាន់តែជាពាក្យពោលដោយការជ្រះថ្លារបស់មនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវអាបត្តិព្រោះការពោលដោយសេចក្ដីជ្រះថ្លាឡើយ ម៉្យាងទៀត សេចក្ដីស្រឡាញ់ក្នុងព្រះអរហន្តទាំងឡាយរបស់ព្រាហ្មណ៍ មានប្រមាណក្រៃលែង ហេតុនោះសូម្បីពួកអ្នកកាត់ក្រសែតណ្ហា ហើយសម្រេចអរហត្តនោះឯងគួរ ដូច្នេះហើយ កាលទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**ឆិន្ទ សោតំ បរក្កម្ម កាមេ បនូទ ព្រាហ្មណ**
**សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ ។**

ម្នាលព្រាហ្មណ៍ ចូរអ្នកខំប្រឹងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយចេញ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថា ជាអ្នកដឹងនូវព្រះនិព្វាន ដែលបច្ច័យតាក់តែងមិនបាន ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **បរក្កម្ម** ជាដើម សេចក្ដីថា ឈ្មោះថាក្រសែតណ្ហា បុគ្គលណាម្នាក់មិនអាចកាត់បាន ដោយសេចក្ដីព្យាយាម មានប្រមាណតិច ហេតុនោះ ចូរអ្នកព្យាយាមកាត់ក្រសែនោះ ដោយការប្រឹងប្រែង

ដ៏ធំ ដែលសម្បយុត្តដោយញាណ គឺចូរបន្ទោបង់ បានដល់ ចូរបណ្តេញកាម ទាំងពីរចុះ ។

បទថា **ព្រាហ្មណ** នោះ ជាពាក្យហៅព្រះខីណាស្រពទាំងឡាយ ។

បទថា **សង្ខារានំ** សេចក្តីថា ដឹងនូវការអស់ទៅនៃខន្ធ ៥ ។

បទថា **អកតញ្ញូ** សេចក្តីថា កាលបើដូច្នោះ អ្នកជាបុគ្គលឈ្មោះថា អកតញ្ញូ ព្រោះដឹងនូវព្រះនិព្វាន ដែលធម៌ណាមួយ បណ្តាលោកធាតុទាំង-ឡាយ មានមាសជាដើមធ្វើមិនបាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ៕

**រឿងព្រាហ្មណ៍មានសេចក្តីជ្រះថ្លាច្រើន ចប់**

# រឿង ភិក្ខុច្រើនរូប

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **យទា ទ្វយេសុ ធម្មេសុ** ជាដើម ។

ថ្ងៃមួយ ភិក្ខុនៅក្នុងទិសប្រមាណ ៣០ រូប មកថ្វាយបង្គំព្រះសាស្តាហើយ អង្គុយ ។ ព្រះសារីបុត្តត្ថេរ ឃើញឧបនិស្ស័យនៃព្រះអរហត្តរបស់ភិក្ខុទាំងនោះហើយ ចូលទៅគាល់ព្រះសាស្តា ឈរទូលសួរបញ្ហានេះថា បពិត្រព្រះអង្គ ធម៌ទាំងឡាយដែលទ្រង់ត្រាស់ហៅថា ធម៌ ២ ប្រការ ធម៌ ២ ប្រការដូច្នោះ តើធម៌ ២ ប្រការនេះ ដូចម្តេចហ្ន៎ ។

ពេលនោះ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត សមថៈ និង វិបស្សនា ហៅថា ធម៌ ២ ប្រការ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**យទា ទ្វយេសុ ធម្មេសុ    បារគូ ហោតិ ព្រាហ្មណោ**
**អថស្ស សព្វេ សំយោគា    អត្ថំ គច្ឆន្តិ ជានតោ ។**

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ ២ ប្រការ គឺ សមថធម៌ និងវិបស្សនាធម៌ ក្នុងកាលនោះ កិលេសជាគ្រឿងប្រកបសត្វទុកទាំងអស់ របស់ព្រាហ្មណ៍អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យទា** ជាដើម សេចក្តីថា ក្នុងកាលណា ព្រះខីណាស្រពនោះ ជាអ្នកដល់នូវត្រើយក្នុងធម៌ គឺសមថៈ និងវិបស្សនា

ដែលតាំងនៅដោយចំណែក ២ ដោយអំណាចនៃការដល់នូវត្រើយ គឺអភិញ្ញាជាដើម ក្នុងកាលនោះ កិលេសជាគ្រឿងប្រកបទាំងឡាយ មានកិលេសទាំងពួងជាគ្រឿងប្រកប គឺកាមជាដើម ដែលអាចប្រកបក្នុងវដ្តៈរបស់ព្រះខីណាស្រពនោះ ជាអ្នកដឹងយ៉ាងនេះ រមែងដល់នូវការតាំងនៅមិនបាន គឺកាលអស់ទៅ ។ ក្នុងកាលចប់ទេសនា ភិក្ខុទាំងឡាយនោះ តាំងនៅក្នុងអរហត្តហើយ ដូច្នេះឯង ៗ៙

**រឿង ភិក្ខុច្រើនរូប ចប់**

# រឿង មារ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមារ ត្រាស់ព្រះធម្មទេសនានេះថា **យស្ស បារំ អបារំ វា** ជាដើម ។

បានឮថា ថ្ងៃមួយ មារនោះកាឡាខ្លួនជាបុរសម្នាក់ ចូលទៅគាល់ព្រះសាស្តា ហើយទូលសួរថា បពិត្រព្រះអង្គ ទីដែលទ្រង់ត្រាស់ថា ត្រើយៗ អ្វីហ្ន៎ ឈ្មោះថា ត្រើយនោះ ព្រះសាស្តាទ្រង់ជ្រាបថា នេះជាមារ ទើបត្រាស់ថា ម្នាលមារមានចិត្តបាប ប្រយោជន៍អ្វីរបស់អ្នកដោយត្រើយ ត្រើយនោះបុគ្គលទាំងឡាយ ដែលមានរាគៈទៅប្រាសហើយគប្បីដល់ ដូច្នេះហើយត្រាស់ព្រះគាថានេះថា

**យស្ស បារំ អបារំ វា បារាបារំ ន វិជ្ជតិ**
**វីតទ្ទរំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*ត្រើយក្តី មិនមែនត្រើយក្តី ត្រើយ និងទីមិនមែនត្រើយក្តី មិនមានដល់បុគ្គលណា ( សេចក្តីប្រកាន់អាយតនៈ មិនមានដល់បុគ្គលណា ) តថាគតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ ។*

## សេចក្តីអធិប្បាយ

*អាយតនៈដែលប្រព្រឹត្តទៅក្នុងខាងក្នុង ៦ ឈ្មោះថា* **បារំ** *ក្នុងព្រះគាថានោះ ។ អាយតនៈដែលមានខាងក្រៅ ៦ ឈ្មោះថា* **អបារំ** ។ *អាយតនៈទាំងពីរនោះ ឈ្មោះថា* **បារាបារំ** ។

*បទថា* **ន វិជ្ជតិ** *សេចក្តីថា ត្រើយ និងមិនមែនត្រើយទាំងអស់នោះ មិនមានដល់បុគ្គលណា ព្រោះការមិនមានការប្រកាន់ថា អញ ឬរបស់អញ តថាគតហៅបុគ្គលនោះ ដែលឈ្មោះថា មានសេចក្តីក្រវល់ក្រវាយទៅប្រាសហើយ ព្រោះដែលទៅប្រាសនៃសេចក្តីក្រវល់ក្រវាយ គឺកិលេសទាំងឡាយ បុគ្គលប្រាសចាកកិលេសទាំងពួងបានហើយ ថាជាព្រាហ្មណ៍ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៗល៚*

**រឿងមារ ចប់**

# រឿង ព្រាហ្មណ៍ម្នាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ឈាយឹ** ជាដើម ។

បានឮថា ព្រាហ្មណ៍នោះគិតថា ព្រះសាស្តាហៅសាវ័ករបស់ព្រះអង្គថា ព្រាហ្មណ៍ ចំណែកអញក៏ជាព្រាហ្មណ៍ដោយជាតិ និងគោត្រ ការដែលព្រះអង្គត្រាស់ហៅអញយ៉ាងនោះដែរក៏គួរ គាត់ចូលទៅគាល់ព្រះសាស្តា ទូលសួរសេចក្តីនោះហើយ ។

ព្រះសាស្តាត្រាស់ថា តថាគតមិនបានហៅបុគ្គលថាព្រាហ្មណ៍ដោយហេតុត្រឹមតែជាតិ និងគោត្រ តែតថាគតហៅបុគ្គលដែលសម្រេចប្រយោជន៍ដ៏ឧត្តមនោះប៉ុណ្ណោះ ថាជាព្រាហ្មណ៍ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ឈាយឹ វិរជមាសីនំ កតកិច្ចំ អនាសវំ**
**ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គលអ្នកចម្រើនឈាន មានធូលី គឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង អ្នកមានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ដោយលំដាប់ហើយនោះ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឈាយឹ** ជាដើម សេចក្តីថា តថាគតហៅបុគ្គលដែលសម្ងំដោយឈាន ២ យ៉ាង ដែលប្រាសចាកធូលី ដោយធូលី

គឺកាម នៅតែឯកឯងក្នុងព្រៃ ឈ្មោះថា ជាអ្នកមានកិច្ចដែលធ្វើហើយ ព្រោះកិច្ច ១៦ ដែលខ្លួនធ្វើដោយមគ្គ ៤ ហើយ ឈ្មោះថា ជាអ្នកមិនមានអាសវៈ ព្រោះមិនមានអាសវៈទាំងឡាយ សម្រេចប្រយោជន៍ដ៏ឧត្តម គឺអរហត្តហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាបានជាប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ៕

**រឿងព្រាហ្មណ៍ម្នាក់ ចប់**

# រឿង ព្រះអានន្ទត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងប្រាសាទរបស់ឧបាសិកាឈ្មោះមិគារមាតា ទ្រង់ប្រារព្ធព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ទិវា តបតិ អាទិច្ចោ** ជាដើម ។

បានឮថា ក្នុងថ្ងៃមហាបវារណា ព្រះបាទបសេនទិកោសល ទ្រង់ប្រដាប់គ្រឿងរាជឥស្សរិយាករណៈសព្វគ្រប់ ទ្រង់កាន់យកវត្ថុទាំងឡាយ មានគ្រឿងក្រអូបជាដើម បានយាងទៅកាន់វិហារហើយ ។

ខណៈនោះ ព្រះកាឡុទាយិត្ថេរអង្គុយចូលឈានខាងចុងបរិស័ទ ។ ពាក្យថា កាឡុទាយិត្ថេរនោះ ជាឈ្មោះរបស់លោកនោះឯង ។ សរីរៈរបស់លោក

មានពណ៌ដូចនិល ។ ក្នុងខណៈនោះ ព្រះចន្ទកំពុងរះ ព្រះអាទិត្យកំពុងអស្តង្គត ។ ព្រះអានន្ទត្ថេរសម្លឹងមើលរស្មីរបស់ព្រះអាទិត្យ ដែលកំពុងអស្តង្គត និងរបស់ព្រះចន្ទដែលកំពុងរះ ហើយសម្លឹងមើលព្រះសរីរោភាសរបស់ព្រះរាជា សរីរោភាសរបស់ព្រះថេរៈ និងព្រះសរីរោភាសរបស់ព្រះតថាគត ។ ក្នុងជនទាំងនោះ ព្រះសាស្តារមែងរុងរឿងកន្លងរស្មីទាំងពួង ។ ព្រះថេរៈថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះអង្គ ក្នុងថ្ងៃនេះកាលខ្ញុំព្រះអង្គសម្លឹងមើលរស្មីទាំងនេះ រស្មីរបស់ព្រះអង្គប៉ុណ្ណោះ ខ្ញុំព្រះអង្គគាប់ចិត្ត ព្រោះថា សរីរៈរបស់ព្រះអង្គរមែងរុងរឿងកន្លងរស្មីទាំងពួង ។

គ្រានោះ ព្រះសាស្តាត្រាស់ថា អានន្ទ ធម្មតាព្រះអាទិត្យ រមែងរុងរឿងក្នុងពេលថ្ងៃ ព្រះចន្ទ រមែងរុងរឿងក្នុងពេលយប់ ព្រះរាជា រមែងរុងរឿងក្នុងកាលប្រដាប់ហើយប៉ុណ្ណោះ ព្រះខីណាស្រពលះការប្រឡូកប្រឡំដោយពួកគណៈហើយ រមែងរុងរឿងខាងក្នុងសមាបត្តិប៉ុណ្ណោះ ចំណែកព្រះពុទ្ធ រមែងរុងរឿងដោយតេជះ ៥ យ៉ាង ទាំងពេលយប់ ទាំងពេលថ្ងៃ ដូច្នេះហើយត្រាស់ព្រះគាថានេះថា

**ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា**
**សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ**
**អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា ។**

ព្រះអាទិត្យរុងរឿងក្នុងពេលថ្ងៃ ព្រះចន្ទរុងរឿងក្នុងពេលយប់
ក្សត្រទ្រង់ប្រដាប់ពេញយសហើយ រមែងរុងរឿង សមណ-

ព្រាហ្មណ៍អ្នកមានឈានរមែងរុងរឿង ឯព្រះសម្ពុទ្ធរមែងរុង
រឿងដោយតេជះរហូត ថ្ងៃនិងយប់ទាំងអស់ ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ទិវា តបតិ** សេចក្តីថា ព្រះអាទិត្យរមែងរុងរឿងតែក្នុងពេលថ្ងៃ សូម្បីតែផ្លូវដែលព្រះអាទិត្យនោះទៅក្នុងពេលយប់ក៏មិនប្រាកដ ។

បទថា **ចន្ទិមា** សេចក្តីថា សូម្បីព្រះចន្ទដែលផុតហើយចាកពពកជាដើមក៏រុងរឿងចំពោះក្នុងពេលយប់ មិនមែនរុងរឿងក្នុងពេលថ្ងៃឡើយ ។

បទថា **សន្នទ្ធោ** សេចក្តីថា ព្រះរាជាទ្រង់ប្រដាប់ដោយគ្រឿងអាភរណៈទាំងពួងដ៏វិចិត្រ ដោយមាស និងកែវមណី មានសេនាប្រកបដោយអង្គ ៤ ចោមរោមហើយប៉ុណ្ណោះរមែងរុងរឿង ព្រះរាជាប្រថាប់នៅដោយភេទដែលបុគ្គលមិនដឹង គឺបន្ទំខ្លួន មិនរុងរឿងឡើយ ។

បទថា **ឈាយី** សេចក្តីថា ចំណែកព្រះខីណាស្រព គេចចេញអំពីពួកហើយ សម្ងំស្ងាត់ទៅ ឈ្មោះថា រមែងរុងរឿង ។

បទថា **តេជសា** សេចក្តីថា ចំណែកព្រះសម្មាសម្ពុទ្ធ ទ្រង់គ្របសង្កត់តេជះនៃការទ្រុស្តសីល ដោយតេជះ គឺសីល តេជះនៃគុណាថោកថយ ដោយតេជះ គឺគុណ តេជះនៃបញ្ញាថោកថយ ដោយតេជះ គឺបញ្ញា តេជះនៃវត្ថុដែលមិនមែនជាបុណ្យ ដោយតេជះ គឺបុណ្យ តេជះនៃអធម៌ ដោយតេជះ គឺធម៌ រមែងរុងរឿងដោយតេជះ ៥ យ៉ាងនេះអស់កាលជានិច្ចនោះឯង ។

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚*

**រឿង ព្រះអានន្ទត្ថេរ ចប់**

# រឿង បព្វជិតមួយរូប

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបព្វជិតមួយរូប ត្រាស់ព្រះធម្មទេសនានេះថា* **ពាហិតបាបោ** *ជាដើម ។*

*បានឮថា ព្រាហ្មណ៍ម្នាក់បួសហើយដោយការបួសក្នុងលទ្ធិខាងក្រៅ គិតថា ព្រះសមណគោតមហៅសាវករបស់ព្រះអង្គថា បព្វជិត ចំណែកអ្នកក៏ជាបព្វជិត កាលដែលព្រះអង្គហៅអញយ៉ាងនោះដែរក៏គួរ ហើយចូលទៅគាល់ព្រះសាស្តា ទូលសួរសេចក្តីនោះ ។*

*ព្រះសាស្តាត្រាស់ថា តថាគតមិនមែនហៅថាបព្វជិតដោយហេតុត្រឹមតែប៉ុណ្ណោះឡើយ ចំណែកបុគ្គលឈ្មោះថាជាបព្វជិត ព្រោះភាពដែលមន្ទិល គឺកិលេសទាំងឡាយដែលខ្លួនរៀរបានជាសមុច្ឆេទ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា*

**ពាហិតបាបោ ហិ ព្រាហ្មណោ សមចរិយា សមណោតិ វុច្ចតិ**
**បព្វាជយមត្តនោ មលំ តស្មា បព្វជិតោតិ វុច្ចតិ ។**

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា ព្រាហ្មណ៍ អ្នកដែលតថាគតហៅថា សមណៈ ព្រោះការប្រព្រឹត្តរម្ងាប់ អ្នកដែលបណ្ដេញមន្ទិលនៃខ្លួន ហេតុនោះ ទើបតថាគតហៅថា បព្វជិត ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **សមចរិយា** គឺព្រោះការប្រព្រឹត្តរម្ងាប់នូវអកុសលធម៌ទាំងពួង ។

បទថា **តស្មា** សេចក្ដីថា បុគ្គលដែលព្រះសាស្ដាត្រាស់ហៅថាព្រាហ្មណ៍ ព្រោះភាពជាអ្នកមានបាបបន្សាត់ហើយ ។ បុគ្គលដែលព្រះសាស្ដាត្រាស់ហៅថា សមណៈ ព្រោះការប្រព្រឹត្តស្ងប់នូវអកុសលធម៌ទាំងឡាយ ហេតុនោះ បុគ្គលណាប្រព្រឹត្តបណ្ដេញ គឺកម្ចាត់មន្ទិល មានរាគៈជាដើមរបស់ខ្លួន បុគ្គលនោះ ព្រះសាស្ដាត្រាស់ហៅថា បព្វជិត ព្រោះការបណ្ដេញនោះ ។

ក្នុងកាលចប់ទេសនា បព្វជិតនោះ តាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ៗ៚

**រឿងបព្វជិតមួយរូប ចប់**

# រឿង ព្រះសារីបុត្តត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ន ព្រាហ្មណស្ស** ជាដើម ។

បានឮថា មនុស្សជាច្រើនក្នុងទីមួយកន្លែង ពោលគុណកថារបស់ព្រះថេរៈថា គួរសរសើរ លោកម្ចាស់របស់ពួកយើង ប្រកបដោយកម្លាំង គឺខន្តិ កាលជនដទៃជេរក្តី ប្រហារក្តី សូម្បីត្រឹមតែការក្រោធ មិនមាន កាលនោះ ព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់សួរថា អ្នកណាមិនក្រោធ ពួកមនុស្សពោលថា ព្រះថេរៈរបស់ពួកខ្ញុំ ព្រាហ្មណ៍ពោលថា បុគ្គលធ្វើឲ្យលោកក្រោធមិនមានទេដឹង ពួកមនុស្សពោលថា នែព្រាហ្មណ៍ សេចក្តីនោះមិនមែនយ៉ាងនោះឡើយ ព្រាហ្មណ៍ពោលថា បើដូច្នោះ ខ្ញុំនឹងធ្វើឲ្យលោកក្រោធ ពួកមនុស្សពោលថា បើអាចសោត ក៏ចូរធ្វើឲ្យលោកក្រោធចុះ ។

ព្រាហ្មណ៍នោះគិតថា ណ្ហើយចុះ អញនឹងដឹងកិច្ចដែលគួរធ្វើ ដូច្នេះហើយ ឃើញព្រះថេរៈចូលទៅដើម្បីភិក្ខា ទើបធ្វើដើរទៅអំពីខាងក្រោយ ឲ្យនូវការប្រហារដោយបាតដៃយ៉ាងខ្លាំងត្រង់កណ្តាលខ្នង ។

ព្រះថេរៈមិនបានគិតដល់ថា នេះជាអ្វីហ្ន៎ និមន្តទៅហើយ ។ ការក្តៅក្រហាយកើតឡើងពេញសរីរៈរបស់ព្រាហ្មណ៍ គាត់សង្វេគថា ឱ លោកម្ចាស់សម្បូរដោយគុណ ដូច្នេះហើយ ក្រាបចុះទៀបបាតជើងរបស់ព្រះថេរៈពោលថា សូមលោកម្ចាស់អត់ទោសដល់ខ្ញុំចុះ កាលព្រះថេរៈពោលថា តើមានរឿងអ្វី ទើបប្រាប់ថា ខ្ញុំប្រហារលោកម្ចាស់ដើម្បីល្បងមើល ព្រះថេរៈពោលថា

ណ្ហើយចុះ អាត្មាអត់ទោសឲ្យ ទើបព្រាហ្មណ៍ពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់អត់ទោសឲ្យខ្ញុំសោត សូមគង់ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំចុះ ដូច្នេះហើយ បានទទួលបាត្ររបស់ព្រះថេរៈ ចំណែកព្រះថេរៈឲ្យបាត្រហើយ ។ ព្រាហ្មណ៍នាំព្រះថេរៈទៅកាន់ផ្ទះអង្គាសហើយ ។

ពួកមនុស្សក្រោធហើយក៏គិតថា លោកម្ចាស់របស់ពួកយើងមិនមានទោស ត្រូវព្រាហ្មណ៍នេះប្រហារហើយ ការផុតចាកដំបងមិនមានដល់ព្រាហ្មណ៍នោះ ពួកយើងនឹងសម្លាប់វាចោលក្នុងទីនោះឯង ដូច្នេះហើយ មានដុំដី និងដំបងជាដើមក្នុងដៃ បានឈរជួបជុំគ្នាត្រង់ទ្វារផ្ទះរបស់ព្រាហ្មណ៍ ។

ព្រះថេរៈក្រោកឡើង បានឲ្យបាត្រក្នុងដៃរបស់ព្រាហ្មណ៍ ពួកមនុស្សបានឃើញព្រាហ្មណ៍នោះដើរទៅជាមួយព្រះថេរៈ ទើបពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលបាត្ររបស់លោកម្ចាស់ ហើយឲ្យព្រាហ្មណ៍ត្រឡប់ចុះ ព្រះថេរៈពោលថា នេះមានរឿងអ្វី ពួកមនុស្សពោលថា ព្រាហ្មណ៍ប្រហារលោកម្ចាស់ ពួកខ្ញុំនឹងដឹងកិច្ចដែលគួរធ្វើដល់គេ ព្រះថេរៈសួរថា ពួកអ្នកត្រូវព្រាហ្មណ៍នេះប្រហារ ឬអាត្មាត្រូវព្រាហ្មណ៍ប្រហារ ពួកមនុស្សពោលថា លោកម្ចាស់ត្រូវព្រាហ្មណ៍ប្រហារ ព្រះថេរៈពោលថា ព្រាហ្មណ៍នោះប្រហារអាត្មាហើយ បានសូមខមាទោសហើយ ចូរពួកអ្នកត្រឡប់ចុះ បញ្ជូនពួកមនុស្សទៅហើយ ឲ្យព្រាហ្មណ៍ត្រឡប់ ហើយនិមន្តទៅកាន់វិហារនោះឯង ។

ភិក្ខុទាំងឡាយលើកទោសថា ហេតុអ្វី ព្រះសារីបុត្តត្ថេរត្រូវព្រាហ្មណ៍ប្រហារ នៅតែអង្គុយទទួលភិក្ខាក្នុងផ្ទះរបស់ព្រាហ្មណ៍នោះ និមន្តមកហើយ

ចាប់តាំងពីកាលដែលព្រះថេរៈ ត្រូវព្រាហ្មណ៍នោះប្រហារហើយ តទៅនេះ ព្រាហ្មណ៍នោះលែងខ្មាសចំពោះបុគ្គលណាម្នាក់ នឹងដើរវាយភិក្ខុទាំងឡាយដ៏សេស ។

ព្រះសាស្ដាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យដូចម្ដេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយពាក្យឈ្មោះនេះ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ឈ្មោះថាប្រហារព្រាហ្មណ៍ មិនមាន តែព្រាហ្មណ៍ដែលជាសមណៈទោះជាត្រូវព្រាហ្មណ៍ជាគ្រហស្ថប្រហារ ឈ្មោះថា សេចក្ដីក្រោធនោះ រមែងដល់នូវការដកឡើងបានដោយអនាគាមិមគ្គ ដូច្នេះហើយ កាលទ្រង់សម្ដែងធម៌ បានភាសិតព្រះគាថាទាំងនេះថា

**ន ព្រាហ្មណស្ស បហរេយ្យ នាស្ស មុញ្ចេថ ព្រាហ្មណោ**
**ធិ ព្រាហ្មណស្ស ហន្តារំ តតោ ធិ យស្ស មុញ្ចតិ ។**
**ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ យទានិសេធោ មនសោ បិយេហិ**
**យតោ យតោ ហឹសមនោ និវត្តតិ តតោ តតោ សម្មតិមេវ ទុក្ខំ ។**

ព្រាហ្មណ៍មិនគប្បីប្រហារព្រាហ្មណ៍ទេ ( ចំណែក ) ព្រាហ្មណ៍ ( ដែលត្រូវគេប្រហារហើយ ) មិនគប្បីចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍ដែលប្រហារព្រាហ្មណ៍ ព្រាហ្មណ៍ណាចងពៀរចំពោះព្រាហ្មណ៍នោះ តថាគតតិះដៀលព្រាហ្មណ៍នោះ ក្រៃលែងជាងនោះទៅទៀត ។ ការហាមឃាត់ចិត្តចាកអារម្មណ៍ ជាទីស្រឡាញ់របស់

ព្រាហ្មណ៍នោះ មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ ឆាកចេញចាកវត្ថុណាៗ សេចក្តីទុក្ខព្រោះវត្ថុនោះៗ ក៏រម្ងាប់ទៅបាន ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បហរេយ្យ** សេចក្តីថា ព្រាហ្មណ៍ជាព្រះខីណាស្រពដឹងថា អាត្មាអញជាព្រះខីណាស្រព មិនគួរប្រហារដល់ព្រាហ្មណ៍ដែលជាព្រះខីណាស្រព ឬព្រាហ្មណ៍ដទៃ ។

ពីរបទថា **នាស្ស មុញ្ចេថ** សេចក្តីថា ព្រាហ្មណ៍ខីណាស្រពនោះ ត្រូវគេប្រហារហើយ មិនគួរចងពៀរដល់បុគ្គលប្រហារ ហើយឈរនៅ គឺមិនគួរធ្វើសេចក្តីក្រោធក្នុងព្រាហ្មណ៍នោះ ។

បទថា **ធិ ព្រាហ្មណស្ស** សេចក្តីថា តថាគតរមែងតិះដៀលព្រាហ្មណ៍ដែលប្រហារព្រាហ្មណ៍ជាខីណាស្រព ។

បទថា **តតោ ធិ** សេចក្តីថា បុគ្គលណាប្រហារតបនូវបុគ្គលដែលប្រហារ ឈ្មោះថា ចងពៀរក្នុងខាងលើរបស់បុគ្គលនោះ តថាគតតិះដៀលអ្នកចងពៀរនោះ ក្រៃលែងជាងអ្នកប្រហារនោះទៅទៀត ។

ពីរបទថា **ឯតទកិញ្ចិ សេយ្យោ** សេចក្តីថា ការមិនជេរតបនូវបុគ្គលដែលជេរ ឬការមិនប្រហារតបនូវបុគ្គលដែលប្រហារ របស់ព្រះខីណាស្រពណា ការមិនជេរតប ឬការមិនប្រហារតបនោះ រមែងជាការប្រសើរ មិនមែនតិច គឺមិនជាការប្រសើរមានប្រមាណតិច ដល់ព្រាហ្មណ៍ដែលជាខីណាស្រពនោះ ដែលពិត ជាការប្រសើរដែលមានប្រមាណក្រៃលែងនោះឯង ។

បាទព្រះគាថាថា **យធានិសេធោ មនសោ បិយេហិ** សេចក្តីថា ការកើតឡើងនៃសេចក្តីក្រោធ ឈ្មោះថា អារម្មណ៍ជាទីស្រឡាញ់នៃចិត្ត របស់បុគ្គលដែលច្រើនដោយសេចក្តីក្រោធ បុគ្គលអ្នកក្រោធនោះ ទោះខុសក្នុងមាតាបិតាក្តី ក្នុងព្រះពុទ្ធជាដើមក្តី ក៏ព្រោះអារម្មណ៍ជាទីស្រឡាញ់ទាំងនោះ ហេតុនោះការសង្កត់សង្កិនចិត្តចាកអារម្មណ៍ ដែលជាទីស្រឡាញ់ទាំងនោះ គឺការសង្កត់សង្កិនចិត្តដែលកើតឡើងដោយអំណាចសេចក្តីក្រោធ របស់បុគ្គលដែលច្រើនដោយសេចក្តីក្រោធនោះ ការសង្កត់សង្កិននោះ រមែងជាការប្រសើរមិនមែនតិច ។

ចិត្តដែលសម្បយុត្តដោយសេចក្តីក្រោធ ឈ្មោះថា **ហឹសមនោ** ចិត្តដែលសម្បយុត្តដោយសេចក្តីក្រោធរបស់បុគ្គលនោះ កាលដល់នូវការដកឡើងដោយអនាគាមិមគ្គ ឈ្មោះថា រមែងត្រឡប់បានចាកវត្ថុឯណានីមួយ ។

ពីរបទថា **តតោ តតោ** សេចក្តីថា វដ្តទុក្ខទាំងអស់ រមែងត្រឡប់បានព្រោះវត្ថុនោះៗ ឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

## រឿងព្រះសារីបុត្តត្ថេរ ចប់

# រឿង ព្រះនាងមហាបជាបតិគោតមី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងមហាបជាបតិគោតមី ត្រាស់ព្រះធម្មទេសនានេះថា **យស្ស កាយេន** ជាដើម ។

សេចក្តីពិស្តារថា ព្រះនាងមហាបជាបតិគោតមី មួយអន្លើដោយបរិវារ ទទួលគរុធម៌ ៨ ប្រការដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តិហើយ ក្នុងកាលដែលរឿងមិនទាន់កើតឡើង ដូចបុរសអ្នកមានជាតិ ច្រើនដោយការប្រដាប់ទទួលកម្រងផ្កាក្រអូបដោយសិរសា គឺត្បូង បានឧបសម្បទាហើយ ឧបជ្ឈាយ៍ឬអាចារ្យដទៃរបស់ព្រះនាងមិនមាន ភិក្ខុទាំងឡាយ ប្រារព្ធព្រះថេរីដែលមានឧបសម្បទា ដែលបានហើយយ៉ាងនោះ សម័យដទៃក្រោយមក ក៏សន្ទនាគ្នាថា អាចារ្យ និងឧបជ្ឈាយ៍របស់ព្រះនាងមហាបជាបតិគោតមីមិនប្រាកដ ព្រះនាងកាន់យកសំពត់កាសាវៈទាំងឡាយ ដោយដៃរបស់ខ្លួនឯង ។

កាលពោលយ៉ាងនោះហើយ ភិក្ខុនីទាំងឡាយប្រព្រឹត្តរង្កៀស រមែងមិនធ្វើឧបោសថ មិនធ្វើបវារណារួមជាមួយព្រះនាងឡើយ ភិក្ខុនីទាំងឡាយនោះ ទៅក្រាបទូលសេចក្តីនោះដល់ព្រះតថាគតហើយ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុនីទាំងនោះហើយ ទើបត្រាស់ថា គរុធម៌ ៨ ប្រការ តថាគតឲ្យហើយដល់ព្រះនាងបជាបតិគោតមី តថាគតនេះ ឯងជាអាចារ្យ ជាឧបជ្ឈាយ៍របស់ព្រះនាង ឈ្មោះថា សេចក្តីរង្កៀសក្នុងព្រះខីណាស្រពទាំងឡាយ ជាអ្នកវៀរហើយចាកទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើមដែលអ្នកទាំងឡាយមិនគួរធ្វើ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌

ទើបត្រាស់ព្រះគាថានេះថា

**យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កតំ**
**សំវុតំ តីហិ ឋានេហិ តមហំ ព្រូមិ ព្រាហ្មណំ ។**

អំពើអាក្រក់ដោយទ្វារកាយ ទ្វារវាចា ទ្វារចិត្តរបស់បុគ្គល ណាមិនមានទេ តថាគតហៅបុគ្គលដែលបានសង្រួមដោយ ឋានៈទាំង ៣ នោះ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

កម្មមានទោស គឺមានទោសជាផល ដែលញុំាងសត្វឲ្យប្រព្រឹត្តទៅក្នុង អបាយ ឈ្មោះថា **ទុក្កតំ** ក្នុងព្រះគាថានោះ ។

ពីរបទថា **តីហិ ឋានេហិ** សេចក្តីថា តថាគតហៅបុគ្គលដែលមានទ្វារ បិទហើយ ដើម្បីហាមការចូលទៅនៃទុច្ចរិតជាដើម ដោយហេតុ ៣ មានកាយ ជាដើមទាំងនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។l។

**រឿង ព្រះនាងមហាបជាបតិគោតមី ចប់**

# រឿង ព្រះសារីបុត្តត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យម្ហា ធម្មំ វិជានេយ្យ** ជាដើម ។

បានឮថា ព្រះសារីបុត្តនោះ ចាប់តាំងពីកាលដែលលោកស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះអស្សជិត្ថេរ ហើយសម្រេចសោតាបត្តិផល បានឮថា ព្រះថេរៈនៅក្នុងទិសណា ផ្គងអញ្ជលីទៅក្នុងទិសនោះ សិងបែរក្បាលទៅកាន់ទិសនោះឯង ។

ភិក្ខុទាំងឡាយពោលថា ព្រះសារីបុត្តជាមិច្ឆាទិដ្ឋិ សូម្បីថ្ងៃនេះក៏នៅតែសិងនមស្ការទិសទាំងឡាយ ដូច្នេះហើយ ក្រាបទូលសេចក្ដីនោះដល់ព្រះដ៏មានព្រះភាគ ។

ព្រះសាស្ដាត្រាស់ឲ្យហៅព្រះថេរៈមកហើយ ត្រាស់សួរថា ម្នាលសារីបុត្ត បានឮថា អ្នកដេកនមស្ការទិសទាំងឡាយពិតឬ កាលព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ប៉ុណ្ណោះរមែងជ្រាបការគោរពទិស ឬមិនគោរពទិសទាំង-ឡាយរបស់ខ្ញុំព្រះអង្គ ដូច្នេះហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តមិនមែនគោរពទិសទាំងឡាយ តែព្រោះសារីបុត្តបានស្ដាប់ធម៌អំពីសម្នាក់របស់អស្សជិ ហើយសម្រេចសោតាបត្តិផល ទើបដេកគោរពអាចារ្យរបស់ខ្លួន ព្រោះថា ភិក្ខុអាស្រ័យអាចារ្យណាត្រាស់ដឹងធម៌ ភិក្ខុនោះ គប្បីនមស្ការអាចារ្យនោះដោយគោរព ដូចព្រាហ្មណ៍នមស្ការភ្លើងដូច្នោះ ដូច្នេះហើយ កាលទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យម្ហា ធម្មំ វិជានេយ្យ សម្មាសម្ពុទ្ធទេសិតំ**

**សក្កច្ចំ តំ នមស្សេយ្យ អគ្គិហុត្តំវ ព្រាហ្មណោ ។**

*បុគ្គលចេះធម៌អាថ៌ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយ អំពីសម្នាក់គ្រូណា គប្បីនមស្ការគ្រូនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលគោរពការបូជាភ្លើងដូច្នោះដែរ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **អគ្គិហុត្តំវ** *សេចក្តីថា បុគ្គលគប្បីដឹងច្បាស់នូវធម៌ដែលតថាគតប្រកាសហើយអំពីអាចារ្យណា គប្បីនមស្ការអាចារ្យនោះដោយគោរព ដូចព្រាហ្មណ៍នមស្ការការបូជាភ្លើងដោយគោរព ដោយការបម្រើដោយល្អ និងដោយកិច្ចទាំងឡាយ មានអញ្ជលីកម្មជាដើម ដូច្នោះ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។*

**រឿងព្រះសារីបុត្តត្ថេរ ចប់**

# រឿង ជដិលព្រាហ្មណ៍

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធជដិលព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ន ជដាហិ** ជាដើម ។

បានឮថា ជដិលព្រាហ្មណ៍នោះគិតថា អញកើតល្អហើយទាំងខាងមាតាទាំងខាងបិតា ក្នុងត្រកូលព្រាហ្មណ៍ បើព្រះសមណគោតមហៅសាវកទាំង-ឡាយរបស់ព្រះអង្គថា ព្រាហ្មណ៍ ការដែលទ្រង់ត្រាស់ហៅអញយ៉ាងនោះដែរក៏គួរ ដូច្នេះហើយ ទើបទៅកាន់សម្នាក់ព្រះសាស្ដា ទូលសួរសេចក្ដីនោះ ។

គ្រានោះ ព្រះសាស្ដាត្រាស់នឹងព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ តថាគតមិនហៅថា ព្រាហ្មណ៍ ព្រោះហេតុត្រឹមតែផ្នួងសក់ មិនហៅដោយហេតុត្រឹមតែជាតិ និងគោត្រ តែតថាគតហៅបុគ្គលដែលមានសច្ចៈ ចាក់ធ្លុះហើយប៉ុណ្ណោះ ថាជាព្រាហ្មណ៍ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ន ជដាហិ ន គោត្តេហិ ន ជច្ចា ហោតិ ព្រាហ្មណោ**
**យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច ព្រាហ្មណោ ។**

បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះផ្នួងសក់ ក៏មិនមែន ព្រោះគោត្រ ក៏មិនមែន ព្រោះជាតិ ក៏មិនមែន សច្ចៈផង ធម៌ផង មានក្នុងបុគ្គលណា បុគ្គលនោះ ឈ្មោះថា អ្នកស្អាតផង បុគ្គលនោះឈ្មោះថា ព្រាហ្មណ៍ផង ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **សច្ចំ** ជាដើម សេចក្ដីថា សច្ចញ្ញាណដែល

ចាក់ធ្លុះនូវសច្ចៈ ៤ យ៉ាងដោយអាការ ១៦ ហើយតាំងនៅ និងលោកុត្តរធម៌ ៩ មានក្នុងបុគ្គលណា បុគ្គលនោះ ជាអ្នកស្អាត និងជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

រឿង ជដិលព្រាហ្មណ៍ ចប់

# រឿង កុហកព្រាហ្មណ៍

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងកូដាគារសាលា ទ្រង់ប្រារព្ធកុហកព្រាហ្មណ៍ដែលមានវត្តដូចប្រចៀវម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **កិន្តេ** ជាដើម ។

បានឮថា ព្រាហ្មណ៍នោះឡើងដើមថ្វាន់មួយដើម ជិតទ្វារនគរវេសាលី យកជើងទាំងពីរពាក់លើមែកឈើ សំយុងក្បាលចុះក្រោមពោលថា ចូរអ្នកទាំងឡាយឲ្យគោក្របមួយរយដល់យើង ចូរឲ្យកហាបណៈទាំងឡាយដល់យើង ចូរឲ្យទាសីដល់យើង បើអ្នកទាំងឡាយមិនឲ្យទេ យើងនឹងទម្លាក់ខ្លួនពីលើដើមថ្វាន់នេះឲ្យស្លាប់ នឹងធ្វើព្រះនគរមិនឲ្យជាព្រះនគរ ។ ក្នុងកាលព្រះដ៏មានព្រះភាគយាងចូលទៅកាន់ព្រះនគរ ដែលមានពួកភិក្ខុចោមរោមហើយ ភិក្ខុទាំងឡាយឃើញព្រាហ្មណ៍នោះហើយ ក្នុងកាលដែលទ្រង់ចេញទៅ ក៏បានឃើញព្រាហ្មណ៍នោះ សំយុងក្បាលយ៉ាងនោះដូចគ្នា ចំណែកអ្នកនគរ

ត្រិះរិះថា ព្រាហ្មណ៍នេះ សំយុងយ៉ាងនេះតាំងអំពីព្រឹកគប្បីធ្លាក់ស្លាប់ ធ្វើនគរមិនឲ្យជានគរ ខ្មាចការលិចចុះនៃព្រះនគរ ទើបព្រមទទួលថា ពួកយើងនឹងឲ្យគ្រប់យ៉ាងតាមដែលព្រាហ្មណ៍សូម ហើយបានឲ្យព្រាហ្មណ៍បានចុះ ទទួលយករបស់ទាំងពួងទៅ ។

ភិក្ខុទាំងឡាយ ឃើញព្រាហ្មណ៍ត្រាច់ទៅដូចមេគោក្បែរឧបចារៈនៃវិហារចាំបាន ក៏សួរថា នែព្រាហ្មណ៍ លោកបានទ្រព្យតាមប្រាថ្នាហើយឬ ព្រាហ្មណ៍ប្រាប់ថា ខ្ញុំបានហើយ ទើបក្រាបទូលរឿងនោះដល់ព្រះតថាគតខាងក្នុងវិហារ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នោះជាចោរ បោកបញ្ឆោតក្នុងកាលនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏ជាចោរបោកបញ្ឆោតហើយដូចគ្នា ឥឡូវនេះ ព្រាហ្មណ៍នោះបោកបានតែជនពាល តែក្នុងកាលមុនមិនអាចបោកបញ្ឆោតបណ្ឌិតបានឡើយ ដូច្នេះហើយ កាលភិក្ខុទាំងនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល តាបសបោកបញ្ឆោតមួយរូប អាស្រ័យកាសិកគ្រាមមួយសម្រេចការនៅ ។ ត្រកូលមួយទំនុកបម្រុងតាបសនោះ គឺប្រគេនចំណែកមួយដល់តាបស អំពីរបស់គួរទំពា និងគួរបរិភោគដែលកើតឡើងហើយក្នុងពេលថ្ងៃ ដូចឲ្យដល់បុត្ររបស់ខ្លួន ទុកចំណែកដែលកើតក្នុងពេលល្ងាចប្រគេនក្នុងថ្ងៃទីពីរ ។

ថ្ងៃមួយ ត្រកូលនោះបានសាច់ទន្សងក្នុងពេលល្ងាច ស្លស្រេចបាច់ហើយទុកចំណែកមួយអំពីចំណែកនោះប្រគេនក្នុងថ្ងៃទីពីរ តាបសបរិភោគសាច់ហើយ

ត្រូវចំណង់ក្នុងរសគ្រប់សង្កត់ សួរថា នេះជាសាច់អ្វី លុះបានដឹងថា ជាសាច់ទន្សង ដូច្នេះហើយ ត្រាច់ទៅដើម្បីភិក្ខា ទទួលយកសប្បិ ទឹកដោះជូរ និងគ្រឿងហឹរជាដើម ទៅកាន់បណ្ណសាលា ហើយទុកក្នុងចំណែកម្ខាង ។

ស្តេចទន្សងនៅក្នុងជំបូកមួយ មិនឆ្ងាយអំពីបណ្ណសាលា ស្តេចទន្សងចេញមកថ្វាយបង្គំតាបសតាមកាលសមគួរ ។ ក្នុងថ្ងៃនោះ តាបសនោះគិតថា អញនឹងសម្លាប់ទន្សងនេះ ដូច្នេះហើយ លាក់ដំបង អង្គុយធ្វើដូចដេកលក់ក្នុងទីជិតជំបូកនោះ ។ ស្តេចទន្សងចេញអំពីជំបូកហើយ មកកាន់សម្នាក់តាបស កំណត់អាការបានហើយ ទើបត្រឡប់អំពីទីនោះដោយគិតថា ថ្ងៃនេះ អញមិនពេញចិត្តក្នុងអាការរបស់អាចារ្យ តាបសដឹងការត្រឡប់របស់ទន្សងនោះហើយ គ្រវែងដំបងទៅដើម្បីបំណងសម្លាប់ទន្សងនោះ ដំបងខុសទៅ ស្តេចទន្សងចូលកាន់ជំបូកហើយ អើតក្បាលចេញអំពីជំបូក ហើយមើលផ្លូវដែលមក ពោលនឹងតាបសថា

ទន្សងពោធិសត្វនិយាយនឹងតាបសថា ខ្ញុំស្មានអ្នកថា ជាសមណៈ បានចូលទៅរកអ្នក ជាអ្នកមិនសង្រួម អ្នកនោះ ប្រហារខ្ញុំដោយដំបង ដូចមនុស្សមិនមែនជាសមណៈដែរ ។ ម្នាលតាបសកម្ចៅ ប្រយោជន៍អ្វី ដោយផ្នួងសក់របស់អ្នក ប្រយោជន៍អ្វី ដោយស្បែកខ្លាឃ្មុំរបស់អ្នក ខាងក្នុងរបស់អ្នកសាំញ៉ាំដោយកិលេស អ្នកបោសរំលីងតែសរីរៈខាងក្រៅ ។

គ្រានោះ តាបសលួងលោមស្តេចទន្សងនោះដោយទ្រព្យដែលមានរបស់

ខ្លួន ទើបពោលគាថានេះថា

នែទនុ្យង ឯងចូរមកណោះ ឯងត្រឡប់មកវិញ ចូរបរិភោគបាយស្រូវសាលីចុះ ប្រេង និងអំបិលរបស់អញក៏មាន ជីប្ញរបស់អញក៏មានច្រើន ។

ស្តេចទនុ្យងស្តាប់ពាក្យនោះហើយពោលថា លោកពោលដោយប្រការណា ភាពដែលខ្ញុំបំណាំងគេចទៅតែម្យ៉ាង រមែងមានដោយប្រការនោះ ដូច្នេះហើយ ពោលគាថានេះថា

ខ្ញុំនោះ នឹងចូលទៅរកដំបូកជម្រៅ ១០០ ជួរបុរស យ៉ាងក្រៃលែង ថ្វីបើអ្នកឯងមានប្រេង និងអំបិល ជីប្ញរបស់អ្នកមិនជាប្រយោជន៍ដល់ខ្ញុំឡើយ ។

កាលពោលយ៉ាងនោះហើយពោលបន្តថា ខ្ញុំបានធ្វើសេចក្តីសម្គាល់ក្នុងលោកថាជាសមណៈ អស់កាលមានប្រមាណប៉ុណ្ណោះ ឥឡូវនេះ លោកគ្រវែងដំបងទៅព្រោះបំណាំងនឹងប្រហារខ្ញុំ លោកមិនជាសមណៈតាំងអំពីកាលដែលគ្រវែងដំបងទៅហើយនោះឯង ប្រយោជន៍អ្វីដោយផ្នួងសក់របស់បុគ្គលដែលមានបញ្ញាថោកថយដូចលោក ប្រយោជន៍អ្វីដោយស្បែកម្រឹគ ឈ្មោះអជិនៈទាំងក្រចក ព្រោះខាងក្នុងរបស់លោកសាំរញ៉ាំ លោកដុសខាត់តែខាងក្រៅតែម្យ៉ាងប៉ុណ្ណោះ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ប្រជុំជាតកថាតាបសបោកបញ្ឆោតក្នុងកាលនោះ បានមកជាព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ

ចំណែកស្តេចទេវទត្ត បានជាតថាគតនេះឯង កាលទ្រង់សម្តែងហេតុនៃតាបស នោះ ត្រាទទួលដែលជាសត្វឈ្លាស សង្កត់សង្កិនក្នុងកាលនោះ ទើបត្រាស់ព្រះគាថានេះថា

**កិន្តេ ជដាហិ ទុម្មេធ    កិន្តេ អជិនសាដិយា**
**អព្ភន្តរន្តេ គហនំ    ពាហិរំ បរិមជ្ជសិ ។**

នៃអ្នកអប្បប្រាជ្ញាអើយ អ្នកមានប្រយោជន៍អ្វីដោយការ
ទុកផ្នួងសក់ អ្នកមានប្រយោជន៍អ្វីដោយការទ្រទ្រង់សំពត់
ស្បែកខ្លា បើសន្តានខាងក្នុងរបស់អ្នក សឹងសាំញ៉ាំ
ដោយរាគាទិក្កិលេស អ្នក ឈ្មោះថា ដុសខាត់តែកាយ
ខាងក្រៅទេ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **កិន្តេ ជដាហិ** សេចក្តីថា នៃអ្នកមានបញ្ញាថោកថយ ប្រយោជន៍អ្វីដោយជដាទាំងនេះ ដែលអ្នកចងល្អហើយ និងដោយសំពត់សាជក ដែលធ្វើដោយស្បែកម្រឹគឈ្មោះអជិនៈនេះ មួយអន្លើដោយក្រចកដែលអ្នកស្លៀកហើយរបស់អ្នក ។

បទថា **អព្ភន្តរំ** សេចក្តីថា ខាងក្នុងរបស់អ្នកសាំញ៉ាំដោយកិលេសមានរាគៈជាដើម អ្នកដុសខាត់តែខាងក្រៅ ដូចលាមកដំរី លាមកសេះរលោងតែខាងក្រៅតែម្យ៉ាង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

រឿង កុហកព្រាហ្មណ៍ ចប់

# រឿង កិសាគោតមី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅត្រង់ភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធនាងកិសាគោតមី ត្រាស់ព្រះធម្មទេសនានេះថា **បំសុកូលធរំ** ជាដើម ។

បានឮថា ក្នុងកាលនោះ សក្កទេវរាជចូលគាល់ព្រះសាស្តា មួយអន្លើដោយទេវបរិស័ទ ក្នុងទីបំផុតនៃបឋមយាម ថ្វាយបង្គំហើយប្រថាប់គង់ ទ្រង់ស្តាប់ធម្មកថា ដែលជាទីតាំងនៃសេចក្តីរឭកដល់ ក្នុងចំណែកម្ខាង ។

ក្នុងខណៈនោះ នាងកិសាគោតមីគិតថា អញនឹងគាល់ព្រះសាស្តា ហោះតាមអាកាសហើយ ឃើញសក្កទេវរាជ ទើបត្រឡប់ទៅ ។ សក្កទេវរាជ ទតឃើញនាងដែលថ្វាយបង្គំហើយត្រឡប់ទៅ ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុនីនោះឈ្មោះអ្វី មកឃើញទ្រង់ហើយក៏ត្រឡប់ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ភិក្ខុនីនោះឈ្មោះកិសាគោតមី ជាធីតារបស់តថាគត ជាកំពូលនៃព្រះថេរីខាងទ្រទ្រង់សំពត់បង្សុកូលទាំងឡាយដូច្នេះ ត្រាស់ព្រះគាថានេះថា

**បំសុកូលធរំ ជន្តុំ កិសន្ធមនិសន្ថតំ**
**ឯកំ វនស្មឹ ឈាយន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*តថាគត ហៅបុគ្គលអ្នកទ្រទ្រង់សំពត់បង្សុកូល មានកាយស្គម មានខ្លួនរវាមដោយសរសៃ ជាបុគ្គលឯកឯង ចម្រើនឈានក្នុងព្រៃនោះ ថាជាព្រាហ្មណ៍ ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បទថា* **កិសំ** *សេចក្ដីថា ជនទាំងឡាយដែលទ្រទ្រង់សំពត់បង្សុកូល បំពេញបដិបទាសមគួរដល់ខ្លួន រមែងជាអ្នកមានសាច់ និងឈាមតិច ជាបុគ្គលមានខ្លួនរវាមដោយសរសៃ ហេតុនោះ ទើបព្រះសាស្ដាត្រាស់យ៉ាងនោះ ។*

*ពីរបទថា* **ឯកំ វនស្មឹ** *សេចក្ដីថា តថាគតរមែងហៅបុគ្គលដែលសម្ងឹងជាអ្នកនៅតែឯងក្នុងទីស្ងាត់នោះ ថាជាព្រាហ្មណ៍ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚*

**រឿង កិសាគោតមី ចប់**

# រឿង ព្រាហ្មណ៍ម្នាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ន ចាហំ** ជាដើម ។

បានឮថា ព្រាហ្មណ៍នោះគិតថា ព្រះសមណគោតមត្រាស់ហៅសាវក ទាំងឡាយរបស់ព្រះអង្គថា ព្រាហ្មណ៍ ចំណែកអញ ជាអ្នកកើតក្នុងកំណើត ព្រាហ្មណ៍ កាលដែលទ្រង់ត្រាស់ហៅអញយ៉ាងនោះដែរមែងគួរ ដូច្នេះហើយ ចូលគាល់ព្រះសាស្តា ទូលសួរសេចក្តីនោះ ។ លំដាប់នោះ ព្រះសាស្តាត្រាស់ ថា ម្នាលព្រាហ្មណ៍ តថាគតមិនហៅថាព្រាហ្មណ៍ដោយហេតុគ្រាន់តែកើតក្នុង កំណើតព្រាហ្មណ៍ប៉ុណ្ណោះទេ ចំណែកបុគ្គលណា មិនមានកិលេសជាគ្រឿង កង្វល់ មិនប្រកាន់មាំ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិសម្ភវំ**
**ភោវាទី នាម សោ ហោតិ ស វេ ហោតិ សកិញ្ចនោ**
**អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត នឹងហៅអ្នកកើតអំពីកំណើត អ្នកកើតក្នុងផ្ទៃនៃ ព្រាហ្មណីជាមាតា ថាជាព្រាហ្មណ៍ក៏ទេ បុគ្គលនោះ គ្រាន់តែបាន នាមថា ភោវាទី ( អ្នកពោលថាចម្រើន ) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសគ្រឿងកង្វល់នៅឡើយ តថាគតហៅបុគ្គល អ្នកមិនមានកិលេសគ្រឿងកង្វល់ អ្នកមិនមានសេចក្តីប្រកាន់មាំ

នោះឯង ថាជាព្រាហ្មណ៍ ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យោនិជំ** បានដល់ ជាអ្នកកើតហើយអំពីកំណើត ។

បទថា **មត្តិសម្ភវំ** សេចក្តីថា អ្នកកើតហើយក្នុងផ្ទៃ ដែលជារបស់មាននៃមាតា ដែលជាព្រាហ្មណី ។

បទថា **ភោវាទី** សេចក្តីថា បុគ្គលនោះដើរពោលថា អ្នកចម្រើន អ្នកចម្រើន ក្នុងពាក្យដែលហៅគ្នាជាដើមរមែងជាបុគ្គលឈ្មោះថា ភោវាទី បុគ្គលនោះ នៅជាបុគ្គលមានកិលេសគ្រឿងកង្វល់ ដោយកិលេសជាគ្រឿងកង្វល់ទាំងឡាយ មានរាគៈជាដើម តែតថាគតហៅអ្នកមិនមានកិលេសគ្រឿងកង្វល់ ដោយកិលេសទាំងឡាយ មានរាគៈជាដើម ដែលមិនប្រកាន់មាំដោយឧបាទាន ៤ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់មហាជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។ល។

## រឿង ព្រាហ្មណ៍ម្នាក់ ចប់

# រឿង ឧគ្គសេន

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសេដ្ឋីបុត្រឈ្មោះ ឧគ្គសេន ត្រាស់ព្រះធម្មទេសនានេះថា **សព្វសំយោជនំ** ជាដើម ។

រឿងខ្ញុំបានឲ្យពិស្តារហើយ ក្នុងអត្ថនៃព្រះគាថាថា **មុញ្ច បុរេ មុញ្ច បច្ឆតោ** ជាដើមនោះឯង ។

ក្នុងកាលនោះ ព្រះសាស្តាកាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ព្រះឧគ្គសេនតែងពោលថាខ្ញុំមិនខ្លាច ប្រហែលជាចង់ព្យាករអរហត្តផលដោយពាក្យមិនពិត ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចគ្នានឹងបុត្រតថាគត មានសំយោជនៈកាត់បានហើយ មិនខ្លាចឡើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**សព្វសំយោជនំ ឆេត្វា យោ វេ ន បរិតស្សតិ**
**សង្គាតិគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា កាត់សញ្ញោជនៈទាំងអស់បាន មិនតក់ស្លុត
តថាគតហៅ បុគ្គលនោះ ដែលគ្មានកិលេសជាគ្រឿងចំពាក់
អ្នករួចស្រឡះចាកកិលេស ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្វសំយោជនំ** បានដល់ សំយោជនៈ ១០ យ៉ាង ។ បទថា **ន បរិតស្សតិ** បានដល់ រមែងមិនខ្លាចព្រោះតណ្ហា ។

បទថា **តមហំ** កាត់បទជា **តំ អហំ** សេចក្តីថា តថាគតហៅបុគ្គលនោះ ដែលឈ្មោះថាឈានកន្លងនូវកិលេស ដែលជាគ្រឿងជាប់ជំពាក់ ព្រោះភាពដែលកិលេស គ្រឿងជាប់ជំពាក់ទាំងឡាយ មានរាគៈជាដើម ដែលកន្លងបានហើយ ជាបុគ្គលឈ្មោះថា ធ្វើឲ្យប្រាសបានហើយ ព្រោះមិនមានសំយោជនៈ ៤ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ឧគ្គសេន ចប់**

# រឿង ព្រាហ្មណ៍ពីរនាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ពីរនាក់ ត្រាស់ព្រះធម្មទេសនានេះថា **ឆេត្វា នទ្ធឹ** ជាដើម ។

បានឮថា ព្រាហ្មណ៍ពីរនាក់នោះ ម្នាក់មានគោឈ្មោះចូឡរោហិត ម្នាក់ទៀត មានគោឈ្មោះមហារោហិត ។

ថ្ងៃមួយ ព្រាហ្មណ៍ទាំងពីរប្រកែកគ្នាថា គោរបស់អ្នករឹងប៉ុន ឬគោរបស់ខ្ញុំរឹងប៉ុន ដូច្នេះហើយ ប្រកែកគ្នាថា ប្រយោជន៍អ្វីរបស់យើងទាំងឡាយដោយការប្រកែកគ្នា យើងប្រណាំងគ្នាហើយនឹងដឹង ទើបដាក់រទេះឲ្យពេញដោយ

ខ្សែចាប់ ត្រង់ស៊ីងអចិរវតី ហើយទឹមគោ ។

ក្នុងខណៈនោះ សូម្បីភិក្ខុទាំងឡាយក៏បានទៅហើយក្នុងទីនោះដើម្បីស្រង់ទឹក ព្រាហ្មណ៍ទាំងឡាយប្រណាំងគោគ្នាហើយ រទេះបានឈប់ស្បៀម ឯព្រ័ត្រ និងខ្សែទាំងឡាយដាច់ហើយ ។

ភិក្ខុទាំងឡាយឃើញហើយ ទៅកាន់វិហារក្រាបទូលសេចក្ដីនោះដល់ព្រះសាស្ដា ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រ័ត្រ និងខ្សែនោះគ្រាន់តែជារបស់ខាងក្រៅ បុគ្គលណាក៏កាត់ព្រ័ត្រ និងខ្សែទាំងនោះបាន ឯភិក្ខុកាត់ព្រ័ត្រ គឺសេចក្ដីក្រោធ កាត់ខ្សែ គឺតណ្ហា ដែលប្រព្រឹត្តទៅខាងក្នុង គួរដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ឆេត្វា នទ្ធឹ វរត្តញ្ច សន្ទានំ សហានុក្កមំ**
**ឧក្ខិត្តបលិឃំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅបុគ្គលដែលកាត់សេចក្ដីក្រោធ ដូចព្រ័ត្រផង កាត់តណ្ហា ដូចព្រ័ត្រផង កាត់ទិដ្ឋិ ៦២ ដូចទី-ត ព្រមទាំងអនុស័យ ដូចអ្នកដើរតាមផង អ្នកមានអវិជ្ជា ដូចសសរខឿនដកចោលហើយ អ្នកត្រាស់ដឹងសច្ចៈ ៤ នោះឯង ថាជាព្រាហ្មណ៍ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **នទ្ធឹ** បានដល់ សេចក្ដីក្រោធដែលប្រព្រឹត្តទៅដោយភាពជាគ្រឿងចងរឹត ។

បទថា **វរត្តំ** បានដល់ តណ្ហាដែលប្រព្រឹត្តទៅដោយភាពជាគ្រឿងចង ។

បាទព្រះគាថាថា **សន្ទានំ សហានុក្កមំ** ជាដើម សេចក្តីថា តថាគតហៅបុគ្គលដែលកាត់គ្រឿង-ត គឺទិដ្ឋិ ៦២ ដែលប្រកបដោយខ្សែ គឺអនុស័យទាំងពួងតាំងនៅហើយ ជាបុគ្គលឈ្មោះថា មានសសរខឿនដកឡើងហើយ ព្រោះសសរខឿន គឺអវិជ្ជា ជារបស់ដកឡើងហើយ បុគ្គលឈ្មោះថា ដឹងហើយ ព្រោះដឹងសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ភិក្ខុ ៥០០ រូបតាំងនៅក្នុងអរហត្តផលហើយ ទេសនាមានប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។៙

**រឿង ព្រាហ្មណ៍ពីរនាក់ ចប់**

# រឿង អក្កោសកភារទ្វាជព្រាហ្មណ៍

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអក្កោសកភារទ្វាជព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា **អក្កោសំ** ជាដើម ។

សេចក្តីពិស្តារថា នាងព្រាហ្មណីឈ្មោះធនញ្ជានី ជាភរិយារបស់ភារទ្វាជព្រាហ្មណ៍ ដែលជាបងប្រុសរបស់អក្កោសកភារទ្វាជព្រាហ្មណ៍ បានជាព្រះសោតាបន្នហើយ ។ នាងកណ្តាស់ក្តី ក្អកក្តី ភ្លាត់ជើងក្តី តែងបន្លឺឧទានថា **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

ថ្ងៃមួយ ក្នុងពេលដែលអគ្គាសព្រាហ្មណ៍ នាងក្លាក់ហើយ បន្លឺឧទាន យ៉ាងនោះឯងដោយសំឡេងខ្លាំង ព្រាហ្មណ៍ក្រោធហើយពោលថា ស្រីថោកទាបនេះ ភ្លាក់ហើយក្នុងទីណាមួយ រមែងពោលសរសើរសមណៈក្បាលត្រងោលនោះ គ្រប់ទីកន្លែង ដូច្នេះហើយ ពោលបន្តថា ស្រីថោកទាបឥឡូវនេះ អញនឹងទៅលើកវាទៈជាមួយសាស្តារបស់ឯង ។

លំដាប់នោះ នាងពោលនឹងព្រាហ្មណ៍ថា អញ្ជើញចុះព្រាហ្មណ៍ ខ្ញុំមិនឃើញបុគ្គលដែលអាចលើកវាទៈ ចំពោះព្រះដ៏មានព្រះភាគអង្គនោះបាន អើបើទៅហើយ សូមទូលសួរបញ្ហានឹងព្រះសាស្តាផង ។ ព្រាហ្មណ៍ចូលទៅកាន់សម្នាក់ព្រះសាស្តា មិនថ្វាយបង្គំ ឈរក្នុងចំណែកម្ខាងហើយ កាលនឹងទូលសួរបញ្ហា ទើបពោលគាថានេះថា

បុគ្គលកាត់បង់នូវអ្វី ទើបដេកជាសុខ បុគ្គលកាត់បង់នូវអ្វី
ទើបមិនសោកសៅ បពិត្រព្រះគោតម ព្រះអង្គពេញព្រះ
ហឫទ័យនឹងសម្លាប់ធម៌ណាដែលជាធម៌ឯក ។

លំដាប់នោះ ព្រះសាស្តា ទ្រង់ព្យាករបញ្ហាជាមួយព្រាហ្មណ៍ ទើបត្រាស់ព្រះគាថានេះថា

បុគ្គលកាត់បង់នូវសេចក្តីក្រោធ ទើបដេកជាសុខ បុគ្គលកាត់
បង់នូវសេចក្តីក្រោធ ទើបមិនសោកសៅ ម្នាលព្រាហ្មណ៍
ពួកព្រះអរិយៈ តែងសរសើរនូវការសម្លាប់សេចក្តីក្រោធ ដែល
មានឫសជាពិស មានចុងដ៏ផ្អែម ព្រោះថា បុគ្គលកាត់បង់នូវ

សេចក្តីក្រោធនោះបានហើយ ទើបមិនសោកសៅ ។

ព្រាហ្មណ៍ជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ សម្រេចអរហត្ត ។ គ្រានោះ អក្កោសកភារទ្វាជព្រាហ្មណ៍ ប្អូនប្រុសរបស់ព្រាហ្មណ៍ បានដំណឹងថា បងប្រុសរបស់ខ្លួនបួសហើយក៏ក្រោធ ទើបមកជេរព្រះសាស្តាដោយវាចាគ្រោតគ្រាត មិនមែនវាចាសប្បុរស សូម្បីព្រាហ្មណ៍នោះ ក៏ត្រូវព្រះសាស្តាឲ្យសិក្សាហើយ ដោយឧបមាអំពីរបស់គួរទំពាជាដើម ដល់ភ្ញៀវទាំងឡាយជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ សម្រេចអរហត្ត ។

ប្អូនប្រុសទាំងពីររបស់ព្រាហ្មណ៍ដទៃទៀត គឺសុន្ទរិកភារទ្វាជៈ ពិលង្គិកភារទ្វាជៈ ជេរព្រះសាស្តាដូចគ្នា កាលព្រះសាស្តាទ្រង់ទូន្មានបួសហើយ សម្រេចអរហត្ត ។

ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ គុណរបស់ព្រះពុទ្ធគួរអស្ចារ្យហ្ន៎ កាលព្រាហ្មណ៍បងប្អូនទាំង ៤ ជេរព្រះដ៏មានព្រះភាគមិនត្រាស់ពាក្យណាមួយ ត្រឡប់បានជាទីពឹងនៃព្រាហ្មណ៍ទាំងនោះទៀត ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាដូចម្តេច កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនប្រទូស្ត ក្នុងជនទាំងឡាយដែលជាអ្នកប្រទូស្ត ព្រោះតថាគតប្រកបដោយកម្លាំង គឺខន្តី រមែងជាទីពឹងរបស់មហាជនដោយពិត ដូច្នេះហើយ ត្រាស់

ព្រះគាថានេះថា

**អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ**
**ខន្តិពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនប្រទូស្ត អត់សង្កត់ពាក្យជេរផង ការបៀតបៀន និងការចងផងបាន ទើបតថាគតហៅបុគ្គល ដែលមានខន្តីជាពល មានខន្តីជាវេហ៍ពលនោះឯង ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អទុដ្ឋោ** ជាដើម សេចក្តីថា បុគ្គលណា ជាអ្នកមានចិត្តមិនក្រោធ អត់សង្កត់នូវពាក្យជេរ និងពាក្យបរិភាសដោយអក្កោសវត្ថុ ១០ និងការវាយដោយបាតដៃជាដើម និងការចងដោយគ្រឿងចង មានខ្នោះជាដើម តថាគតហៅបុគ្គលនោះ គឺបុគ្គលបែបនោះ ដែលឈ្មោះថា មានកម្លាំង គឺខន្តី ព្រោះជាអ្នកប្រកបដោយកម្លាំង គឺខន្តី បុគ្គលឈ្មោះថា មានវេហ៍ពល ព្រោះជាអ្នកប្រកបដោយកម្លាំង គឺខន្តីដែលជាពួក ព្រោះកើតឡើងរឿយៗ នោះឯង ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿងអក្កោសកភារទ្វាជព្រាហ្មណ៍ ចប់**

# រឿង ព្រះសារីបុត្តត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អក្កោធនំ** ជាដើម ។

បានឮថា ក្នុងកាលនោះ ព្រះថេរៈត្រាច់ទៅបិណ្ឌបាតជាមួយភិក្ខុ ៥០០ រូប បានទៅកាន់ទ្វារផ្ទះរបស់មាតាក្នុងស្រុកនាលកៈ ។ គ្រានោះ នាងនិមន្តឲ្យលោកគង់ហើយ អង្គាសហើយ ជេរថា បពិត្រលោកម្ចាស់ លោកមិនបានរបស់ទំពា ដែលជាសំណល់ និងទឹកដែលជាសំណល់ ក៏សមគួរនឹងបរិភោគទឹកបាយ ដែលជាប់នៅនឹងបាតត្រឡោកក្នុងផ្ទះរបស់អ្នកដទៃ លោកលះបង់ទ្រព្យ ៨០ កោដិបួសបាន លោកឲ្យខ្ញុំវិនាសហើយ ឥឡូវនេះ សូមលោកបរិភោគចុះ ។ នាងថ្វាយភត្តបណ្តើរដល់ភិក្ខុទាំងឡាយ ពោលថា កូនរបស់ខ្ញុំត្រូវលោកទាំងឡាយធ្វើឲ្យជាអ្នកបម្រើរបស់ខ្លួនហើយ ឥឡូវនេះ សូមពួកលោកបរិភោគចុះ ព្រះថេរៈទទួលភិក្ខាហើយ បានទៅកាន់វិហារនោះឯង ។ គ្រានោះ ព្រះរាហុលអើពើនឹងព្រះសាស្តាដោយបិណ្ឌបាតហើយ ។ ពេលនោះ ព្រះសាស្តាត្រាស់ថា រាហុល ពួកអ្នកទៅក្នុងទីណា រាហុលពោលថា បពិត្រព្រះអង្គ ទៅកាន់ស្រុករបស់យាយ ព្រះសាស្តាត្រាស់ថា ឧបជ្ឈាយ៍របស់អ្នកត្រូវយាយពោលដូចម្តេច រាហុលពោលថា បពិត្រព្រះអង្គ ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គត្រូវយាយជេរហើយ ព្រះសាស្តាត្រាស់ថា ឧបជ្ឈាយ៍របស់អ្នកត្រូវយាយជេរដូចម្តេច ព្រះរាហុលពោលថា លោកយាយជេរដោយពាក្យឈ្មោះនេះ ព្រះសាស្តាត្រាស់ថា ចំណែកឧបជ្ឈាយ៍របស់អ្នកពោល

ដូចម្តេច រាហុលពោលថា លោកមិនពោលដូចម្តេចឡើយ ។

ភិក្ខុទាំងឡាយ ស្តាប់ពាក្យនោះហើយ សន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ គុណទាំងឡាយរបស់ព្រះសារីបុត្ត គួរអស្ចារ្យហ្ន៎ កាលមាតារបស់លោកជេរយ៉ាងនោះ សូម្បីត្រឹមតែក្រោធ ក៏មិនមានឡើយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយកថាដូចម្តេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រពទាំងឡាយ ជាអ្នកមិនក្រោធឡើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អក្កោធនំ វតវន្តំ សីលវន្តំ អនុស្សទំ**
**ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅបុគ្គលដែលមិនមានសេចក្តីក្រោធ មានធុតង្គវត្ត មានចតុប្បារិសុទ្ធិសីល មិនមានតណ្ហា ជាគ្រឿងរបាំងចិត្ត មានឥន្ទ្រិយទូន្មានហើយ មានសរីរៈស្ថិតនៅក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **វតវន្តំ** ជាដើម សេចក្តីថា តថាគតហៅបុគ្គលប្រកបដោយវត្ត គឺធុតង្គ ដែលមានសីលដោយបារិសុទ្ធិសីល ៤ ឈ្មោះថា មិនមានតណ្ហាជាគ្រឿងប៉ោងឡើង ព្រោះមិនមានគ្រឿងប៉ោងឡើង គឺតណ្ហា បុគ្គលឈ្មោះថាទូន្មានហើយ ព្រោះទូន្មានឥន្ទ្រិយ ៦ ដែល

ឈ្មោះថា មានសរីរៈក្នុងទីបំផុត ព្រោះអត្តភាពតាំងនៅក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង ព្រះសារីបុត្តត្ថេរ ចប់**

# រឿង ឧប្បលវណ្ណាថេរី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងឧប្បលវណ្ណាថេរី ត្រាស់ព្រះធម្មទេសនានេះថា **វារិ បោក្ខរបត្តេវ** ជាដើម ។

រឿងខ្ញុំឲ្យពិស្តារហើយ ក្នុងអដ្ឋកថានៃព្រះគាថាថា **មធុវា មញ្ញតី ពាលោ** ជាដើម ។

ពិតហើយ ក្នុងទីនោះ ខ្ញុំពោលថា ដោយសម័យដទៃទៀត មហាជនសន្ទនាក្នុងរោងធម្មសភាថា សូម្បីព្រះខីណាស្រព ប្រហែលជានៅតែសេពកាម ហេតុអ្វីនឹងមិនសេព ព្រោះលោកទាំងនោះ មិនមែនឈើពុក មិនមែនដំបូក នៅមានសាច់ស្រស់ និងសរីរៈស្រស់នោះឯង ហេតុនោះ សូម្បីព្រះខីណាស្រពទាំងនោះ គង់ត្រេកអរក្នុងកាមសុខ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់

មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ខីណាស្រពទាំងឡាយ មិនត្រេកអរនូវកាមសុខ មិនសេពកាម ដូចតំណក់ទឹកដែលធ្លាក់លើស្លឹកឈូករមែងមិនជាប់ មិនដក់នៅ រមែងរមៀលធ្លាក់ទៅនោះឯង យ៉ាងណា ម្យ៉ាងទៀត ដូចគ្រាប់ស្ពៃ រមែងមិនជាប់ មិនតាំងនៅលើចុងដែកស្រួច រមែងរមៀលចុះទៅនោះឯង យ៉ាងណា សូម្បីកាមទាំងពីរយ៉ាង រមែងមិនជាប់ មិនតាំងនៅក្នុងចិត្តរបស់ព្រះខីណាស្រពដូច្នោះ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថាក្នុងព្រាហ្មណវគ្គនេះថា

**វារិ ពោក្ខរបត្តេវ អារគ្គេរិវ សាសបោ**
**យោ ន លិម្បតិ កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យោ ន លិម្បតិ** ជាដើម សេចក្តីថា បុគ្គលណា រមែងមិនជាប់ក្នុងកាមទាំងពីរយ៉ាងក្នុងខាងក្នុង គឺមិនតាំងនៅក្នុងកាមនោះយ៉ាងនេះឯង តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕៚

# រឿង ព្រាហ្មណ៍ម្នាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **យោ ទុក្ខស្ស** ជាដើម ។

បានឮថា ទាសៈម្នាក់របស់ព្រាហ្មណ៍នោះ កាលសិក្ខាបទព្រះសាស្តាទ្រង់មិនទាន់បញ្ញត្តិ គេចទៅបួសសម្រេចអរហត្តហើយ ។ ព្រាហ្មណ៍រកមិនឃើញ ក្នុងថ្ងៃមួយ ជួបលោកកំពុងចូលទៅបិណ្ឌបាតជាមួយព្រះសាស្តា ត្រង់វាំងទ្វារ បានទាញចីវរយ៉ាងមាំ ព្រះសាស្តាយាងត្រឡប់ត្រាស់សួរថា ម្នាលព្រាហ្មណ៍ តើមានរឿងអ្វី ព្រាហ្មណ៍ពោលថា បពិត្រព្រះគោតម ភិក្ខុនេះជាខ្ញុំបម្រើរបស់ខ្ញុំព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ ភិក្ខុនោះមានភារៈដាក់ចុះហើយ ។

កាលព្រះសាស្តាត្រាស់ថា ជាអ្នកមានភារៈដាក់ចុះហើយ ព្រាហ្មណ៍កំណត់បានថា ជាព្រះអរហន្ត ហេតុនោះ កាលព្រាហ្មណ៍ក្រាបទូលទៀតថា បពិត្រព្រះគោតមយ៉ាងនោះឬ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ ត្រឹមត្រូវហើយ ភិក្ខុនោះជាបុគ្គលមានភារៈដាក់ចុះហើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**យោ ទុក្ខស្ស បជានាតិ ឥធេវ ខយមត្តនោ**
**បន្នភារំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងសាសនានេះឯង ដឹងច្បាស់នូវការអស់ទុក្ខ
របស់ខ្លួន តថាគតហៅបុគ្គលនោះ ដែលមានខន្ធភារៈដាក់ចុះ

ហើយ ដែលរួចស្រឡះចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **ឧក្កស្ស** បានដល់ ខន្ធទុក្ខ ។

បទថា **បណ្ណភារំ** ជាដើម សេចក្ដីថា តថាគតហៅបុគ្គលមានភារៈ គឺខន្ធដែលដាក់ចុះហើយ ដែលបន្សាត់បានហើយចាកយោគៈ ៤ ឬកិលេសទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាមានប្រយោជន៍ដល់មហាជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

**រឿង ព្រាហ្មណ៍ម្នាក់ ចប់**

# រឿង ខេមាភិក្ខុនី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅត្រង់ភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធព្រះនាងខេមាភិក្ខុនី ត្រាស់ព្រះធម្មទេសនានេះថា **គម្ភីរបញ្ញំ** ជាដើម ។

សេចក្ដីពិស្ដារថា ក្នុងថ្ងៃមួយ សក្កទេវរាជយាងមកជាមួយទេវបរិស័ទក្នុងវេលានៃបឋមយាម ប្រថាប់គង់ស្ដាប់ធម្មកថា ដែលជាទីតាំងនៃការរឭកដល់ ក្នុងសម្នាក់របស់ព្រះសាស្ដា ។

ខណៈនោះ ព្រះនាងខេមាភិក្ខុនីមកដោយឫទ្ធិរិះថានឹងគាល់ព្រះសាស្តា ឃើញសក្កទេវរាជហើយ ឈរក្នុងអាកាសនោះឯង ថ្វាយបង្គំព្រះសាស្តាហើយ ក៏ត្រឡប់ទៅ ។

សក្កទេវរាជទតឃើញព្រះនាងខេមាហើយ ទូលសួរថា បពិត្រព្រះអង្គ ភិក្ខុនីនោះឈ្មោះអ្វី មកឈរក្នុងអាកាសនោះឯង ថ្វាយបង្គំហើយត្រឡប់ទៅ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ភិក្ខុនីនោះជាធីតារបស់តថាគត ឈ្មោះខេមា ដែលជាអ្នកមានបញ្ញាច្រើន ឈ្លាសក្នុងផ្លូវ និងមិនមែនផ្លូវ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**គម្ភីរបញ្ញំ មេធាវឹ មគ្គាមគ្គស្ស កោវិទំ**
**ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅបុគ្គលអ្នកមានប្រាជ្ញាជ្រៅ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស អ្នកឈ្លាសក្នុងផ្លូវ និងមិនមែនផ្លូវ បានសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **គម្ភីរបញ្ញំ** ជាដើម សេចក្តីថា តថាគត ហៅបុគ្គលដែលប្រកបដោយបញ្ញា ដែលប្រព្រឹត្តទៅក្នុងធម៌ទាំងឡាយ មានខន្ធជាដើមដ៏ជ្រាលជ្រៅ ជាអ្នកប្រាជ្ញ ប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ បុគ្គលឈ្មោះថា ឈ្លាសក្នុងផ្លូវ និងមិនមែនផ្លូវ ព្រោះភាពជាអ្នកឈ្លាសក្នុងផ្លូវ និងមិនមែនផ្លូវយ៉ាងនេះ គឺនេះជាផ្លូវនៃទុគ្គតិ នេះជាផ្លូវនៃសុគតិ នេះជាផ្លូវនៃព្រះ

និព្វាន នេះមិនមែនផ្លូវ បុគ្គលសម្រេចប្រយោជន៍ដ៏ឧត្តម ពោល គឺព្រះអរហត្តនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង ខេមាភិក្ខុនី ចប់**

# រឿង ព្រះតិស្សត្ថេរអ្នកនៅក្នុងញកភ្នំ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរដែលនៅក្នុងញកភ្នំ ត្រាស់ព្រះធម្មទេសនានេះថា **អសំសដ្ឋំ** ជាដើម ។

បានឮថា ព្រះថេរៈនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដាហើយ ចូលកាន់ព្រៃ សម្លឹងរកសេនាសនៈជាទីសប្បាយ ដល់ញកភ្នំមួយកន្លែង ក្នុងខណៈដែលលោកដល់នោះឯង ចិត្តរបស់លោកបានដល់ភាពជាធម្មជាតតែមួយហើយ លោកគិតថា បើអញនៅក្នុងទីនេះនឹងអាចឲ្យកិច្ចរបស់បព្វជិតសម្រេចបាន ។

ទេវតាដែលអាស្រ័យនៅក្នុងគុហានោះគិតថា ភិក្ខុមានសីលមកហើយ កាលដែលអញនៅក្នុងទីជាមួយគ្នានឹងភិក្ខុនេះ លំបាក ភិក្ខុនេះនឹងនៅអស់រាត្រីមួយប៉ុណ្ណោះ ក៏នឹងចេញទៅ ទើបពាកូនទាំងឡាយចេញទៅ ។

ក្នុងថ្ងៃស្អែកឡើង ព្រះថេរៈចូលទៅកាន់គោចរគ្រាមអំពីព្រលឹមដើម្បីបិណ្ឌបាត កាលនោះ ឧបាសិកាម្នាក់ឃើញលោកហើយ បាននូវការស្រឡាញ់ដូចកូន និមន្តឲ្យគង់ក្នុងផ្ទះឲ្យឆាន់ហើយ អង្វរដើម្បីឲ្យអាស្រ័យខ្លួនអស់កាល ៣ ខែ លោកក៏ទទួលដោយគិតថា អាត្មាអញអាស្រ័យឧបាសិកានេះ អាចធ្វើនូវការរលាស់ចេញចាកភពបាន ដូច្នេះហើយ បានទៅកាន់គុហានោះឯង ។

ទេវតាឃើញលោកកំពុងដើរមក គិតថា ព្រះថេរៈនេះពិតជាបុគ្គលណាម្នាក់និមន្តពិត លោកនឹងទៅក្នុងថ្ងៃស្អែកនេះ ឬខានស្អែកនេះ ។

កន្លះខែកន្លងទៅហើយយ៉ាងនេះ ទេវតាគិតថា ភិក្ខុនេះពិតជានៅក្នុងទីនេះពិតៗ ខាងក្នុងវេជ្ជវក្កៀង ការដែលអញ និងកូនតូចទាំងឡាយ នៅក្នុងទីតែមួយនឹងអ្នកមានសីល ជាការធ្វើបានលំបាក ការក្ដាំងក្ដាត់ក្នុងសីលរបស់ភិក្ខុនេះមានដែរឬទេហ្ន៎ ដូច្នេះហើយ សម្លឹងមើលដោយទិព្វចក្ខុ ក៏មិនឃើញការក្ដាំងក្ដាត់ក្នុងសីលរបស់លោក តាំងអំពីឧបសម្បទាមក ទើបគិតថា សីលរបស់លោកបរិសុទ្ធ អញនឹងធ្វើហេតុណាមួយនោះឯង ឲ្យនូវការវិនាសកើតឡើងដល់លោក ដូច្នេះហើយ ទើបចូលទៅសណ្ឋិតក្នុងសរីរៈកូនច្បងរបស់ឧបាសិកា ក្នុងត្រកូលឧបដ្ឋាក មួលកហើយ ភ្នែកទាំងពីររបស់កុមារនោះបញ្ឈរហើយ ទឹកមាត់ហូរចេញអំពីមាត់ ឧបាសិកាឃើញបុត្រនោះហើយ ស្រែកថា តើមានរឿងអ្វី ។

គ្រានោះ ទេវតាមានរូបមិនប្រាកដ ពោលនឹងឧបាសិកានោះយ៉ាងនេះថា កូននោះយើងចាប់ហើយ យើងមិនត្រូវការដោយពលីកម្ម តែចូរអ្នកសូមឈើ

អែមនឹងព្រះថេរៈ ដែលចូលដល់ត្រកូលរបស់អ្នក ហើយយកឈើអែមនោះ ចៀននឹងប្រេងហើយ ចូរឲ្យដល់បុត្រនេះដោយវិធីនត្ថុះ កាលបើធ្វើយ៉ាងនេះ ទើបយើងលែងបុត្រនេះ ។

ឧបាសិកាពោលថា បុត្រនោះចូរវិនាស ឬស្លាប់ក៏ដោយចុះ ខ្ញុំមិនអាចសូមឈើអែមនឹងព្រះថេរៈបានឡើយ ទេវតាពោលថា បើមិនអាចសូមឈើអែមសោត ចូរអ្នកប្រាប់ដើម្បីដាក់លម្អិតហិង្គុក្នុងប្រមុះបុត្រនោះចុះ ។

ឧបាសិកាពោលថា ខ្ញុំមិនអាចពោលពាក្យយ៉ាងនេះបាន ទេវតាពោលថា បើយ៉ាងនោះ ចូរអ្នកធ្វើទឹកលាងជើងរបស់ព្រះថេរៈនោះ ស្រោចលើក្បាលកូនចុះ ។ ឧបាសិកាពោលថា ខ្ញុំអាចធ្វើសេចក្ដីនេះបាន និមន្តឲ្យព្រះថេរៈមកតាមកាលគន់ហើយ ថ្វាយយាគូ និងរបស់ទំពា លាងជើងរបស់ព្រះថេរៈក្នុងវាងកត្ត ត្រងយកទឹកហើយ ពិតឲ្យជ្រាបថា បពិត្រលោកម្ចាស់ ខ្ញុំនឹងស្រោចទឹកនេះលើក្បាលរបស់ក្មេង ព្រះថេរៈអនុញ្ញាតថា ចូរស្រោចចុះ បានធ្វើយ៉ាងនោះហើយ ។ ទេវតាលែងកុមារនោះក្នុងខណៈនោះឯង ហើយបានទៅឈរត្រង់ទ្វារគុហា ។

ព្រះថេរៈ ក្នុងវេលាស្រេចភត្តកិច្ច ក្រោកចាកអាសនៈ ស្វាធ្យាយអាការ ៣២ នោះឯង ព្រោះលោកមិនលះបង់កម្មដ្ឋាន ចៀសចេញទៅហើយ ។ ក្នុងកាលលោកមកដល់ទ្វារគុហា ទេវតាពោលនឹងលោកថា គ្រូធំ សូមលោកកុំចូលក្នុងទីនេះ លោកឈរក្នុងទីនោះឯង ពោលថា អ្នកជាអ្នកណា ទេវតាពោលថា ខ្ញុំជាទេវតាអាស្រ័យនៅក្នុងទីនេះ ព្រះថេរៈគិតថា អញធ្វើវេជ្ជកម្ម

មានឬហ្ន៎ ដូច្នេះហើយ ពិនិត្យមើល ចាប់តាំងពីឧបសម្បទាមក ក៏មិនឃើញការសៅហ្មង ពព្រុស ពពាល ក្នុងសីលរបស់ខ្លួន ទើបពោលថា ខ្ញុំមិនឃើញទីដែលខ្ញុំធ្វើវេជ្ជកម្មឡើយ អ្នកពោលយ៉ាងនោះ ព្រោះហេតុអ្វី ទេវតាពោលថា លោកមើលមិនឃើញឬ ព្រះថេរៈពោលថា អើ ខ្ញុំមិនឃើញ ទេវតាពោលថា បើយ៉ាងនោះ ខ្ញុំនឹងប្រាប់ដល់លោក ព្រះថេរៈពោលថា អញ្ជើញអ្នកប្រាប់ចុះ ទេវតាពោលថា ការនិយាយវត្ថុដែលឆ្ងាយ ចូរស្ទះចុះ ក្នុងថ្ងៃនេះឯង លោកស្រោចទឹកលាងជើងលើក្បាលដល់កូនរបស់ឧបដ្ឋាក ដែលត្រូវអមនុស្សសណ្ឋិតហើយ តើមែនឬទេ ព្រះថេរៈពោលថា អើ ខ្ញុំស្រោច ទេវតាពោលថា នុ៎ះជាអ្វី លោកមិនឃើញឬ ព្រះថេរៈពោលថា អ្នកបំណងហេតុនោះឬ ទេវតាពោលថា ខ្ញុំពោលបំណងហេតុនោះឯង ព្រះថេរៈគិតថា ឱហ្ន៎ខ្លួនអាត្មាអញ ប្រព្រឹត្តហើយ អញប្រព្រឹត្តសមគួរដល់សាសនាហើយ សូម្បីតែទេវតាក៏មិនបានឃើញការសៅហ្មង ឬពព្រុស ពពាល ក្នុងចតុប្បារិសុទ្ធិ-សីលរបស់អញ បានឃើញត្រឹមតែទឹកលាងជើង ដែលអញស្រោចហើយលើក្បាលទារក ៗ បីតិដ៏មានកម្លាំង ប្រារព្ធសីលកើតឡើងហើយដល់លោក លោកសង្កត់បីតិដ៏មានកម្លាំងហើយ មិនធ្វើនូវការលើកជើងឡើង សម្រេចអរហត្តក្នុងទីនោះឯង ហើយពោលថា អ្នកប្រទូស្តសមណៈដែលបរិសុទ្ធដូចខ្ញុំ អ្នកកុំនៅក្នុងព្រៃនេះ អ្នកនោះឯង ចូរចេញទៅ កាលទូន្មានទេវតា ទើបបន្លឺឧទានថា

ការនៅរបស់ខ្ញុំបរិសុទ្ធហើយហ្ន៎ អ្នកកុំប្រទូស្តខ្ញុំដែលមិនមានមន្ទិល ជាអ្នកមានតបៈបរិសុទ្ធហើយ ចូរអ្នកចេញអំពីព្រៃធំនេះចុះ ។

លោកនៅក្នុងទីនោះឯងអស់ ៣ ខែ ចេញវស្សាហើយទៅកាន់សម្នាក់ព្រះសាស្ដា ត្រូវភិក្ខុទាំងឡាយសួរថា អាវុសោ កិច្ចនៃបព្វជិតលោកធ្វើដល់ទីបំផុតហើយឬ ទើបប្រាប់រឿងទាំងអស់នោះ ចាប់តាំងពីការនៅចាំវស្សាក្នុងគុហានោះដល់ភិក្ខុទាំងឡាយ កាលភិក្ខុទាំងឡាយពោលថា អាវុសោ លោកត្រូវទេវតាពោលយ៉ាងនោះ មិនក្រោធទេឬ ក៏ពោលថា ខ្ញុំមិនក្រោធទេ ។

ភិក្ខុទាំងឡាយក្រាបទូលរឿងនោះដល់ព្រះសាស្ដាថា បពិត្រព្រះអង្គ ភិក្ខុនេះព្យាករអរហត្តផល ត្រូវទេវតាពោលពាក្យឈ្មោះនេះ ពោលថា ខ្ញុំមិនក្រោធទេ ។

ព្រះសាស្ដា ទ្រង់ស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កូនរបស់តថាគតមិនក្រោធឡើយ ព្រោះឈ្មោះថាការជាប់ជំពាក់ដោយគ្រហស្ថ ឬបព្វជិតទាំងឡាយ រមែងមិនមានដល់បុត្ររបស់តថាគតនោះ បុត្ររបស់តថាគតនោះ មិនជាប់ជំពាក់ ជាអ្នកប្រាថ្នាតិច សន្ដោស ដូច្នេះហើយ កាលនឹងសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ**
**អនោកសារឹ អប្បិច្ឆំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅបុគ្គលដែលមិនច្រឡំដោយជនទាំងឡាយ ២ ពួក គឺគ្រហស្ថ ១ បព្វជិត ១ ជាអ្នកត្រាច់ទៅដោយមិនមាន

សេចក្តីអាល័យ មានសេចក្តីប្រាថ្នាតិចនោះថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អសំសដ្ឋំ** សេចក្តីថា ឈ្មោះថា មិនជាប់ជំពាក់ ព្រោះការមិនមានការជាប់ជំពាក់ដោយការមើល ការស្តាប់ ការសន្ទនា ការបរិភោគ និងដោយកាយ ។

បទថា **ឧភយំ** បានដល់ មិនជាប់ជំពាក់ដោយជន ២ ពួក គឺគ្រហស្ថ ១ បព្វជិត ១ ។

បទថា **អនោកសារឹ** បានដល់ ជាអ្នកមិនអាល័យត្រាច់ទៅ អធិប្បាយថា តថាគតហៅបុគ្គលនោះ គឺបុគ្គលបែបនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿងព្រះតិស្សត្ថេរអ្នកនៅក្នុងញកភ្នំ ចប់**

# រឿង ភិក្ខុមួយរូប
## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **ឆិន្ទាយ** ជាដើម ។

បានឮថា ភិក្ខុនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ព្យាយាមនៅព្រៃ សម្រេចអរហត្តហើយគិតថា អញនឹងក្រាបទូលគុណដែលខ្លួនបានហើយដល់ព្រះសាស្តា ទើបចេញអំពីព្រៃនោះ ។

គ្រានោះ ស្រីម្នាក់ក្នុងស្រុកមួយធ្វើការវិវាទគ្នាជាមួយស្វាមី កាលស្វាមីនោះចេញទៅខាងក្រៅ គិតថា អញនឹងទៅកាន់ផ្ទះត្រកូល ទើបធ្វើដំណើរទៅជួបភិក្ខុនោះក្នុងរវាងផ្លូវគិតថា អញនឹងអាស្រ័យព្រះថេរៈនេះទៅ ទើបដើរតាមក្រោយ តែព្រះថេរៈមិនឃើញនាង ។

គ្រានោះ ប្តីដើរមកកាន់ផ្ទះមិនឃើញភរិយា គិតថា នាងទៅកាន់ផ្ទះនៃត្រកូលហើយដេញតាមទៅ ជួបហើយគិតថា ស្រីនេះម្នាក់ឯងមិនអាចដើរឆ្លងព្រៃនេះបាន នាងអាស្រ័យអ្វីហ្ន៎ទើបទៅបាន ដូច្នេះហើយ ពិនិត្យមើលក៏ឃើញព្រះថេរៈ គិតថា ព្រះថេរៈនេះជាអ្នកនាំស្រីនេះចេញទៅហើយ ទើបសម្លុតព្រះថេរៈ ។ កាលនោះ ទើបស្រីនោះពោលនឹងស្វាមីថា នែអ្នក លោកម្ចាស់មិនបានឃើញ មិនបានហៅខ្ញុំឡើយ អ្នកកុំស្តីថាពាក្យណាមួយជាមួយលោកម្ចាស់ឡើយ ។

ប្តីនោះមានសេចក្តីក្រោធពោលថា នាងមិនប្រាប់បុគ្គលដែលនាំនាងទៅដល់អញឬ អញនឹងធ្វើកម្មដែលសមគួរដល់ភិក្ខុនេះ ជំនួសខ្លួននាងឲ្យបាន ។

ដោយការអាឃាតក្នុងស្រី ទើបវាយព្រះថេរៈ ហើយនាំស្រីនោះត្រឡប់ ។

សរីរៈរបស់ព្រះថេរៈប៉ោងឡើងហើយ ក្នុងកាលព្រះថេរៈមកកាន់វិហារ ភិក្ខុទាំងឡាយនាំគ្នាប្របាច់សរីរៈ ឃើញពកហើយសួរថា នេះអ្វី លោកប្រាប់សេចក្ដីនោះដល់ភិក្ខុទាំងនោះ ។

លំដាប់នោះ ពួកភិក្ខុសួរថា អាវុសោ កាលបុរសនោះប្រហារយ៉ាងនោះ លោកបានពោលពាក្យអ្វី ឬសេចក្ដីក្រោធកើតឡើងដល់លោកដែរឬទេ ព្រះថេរៈពោលថា អាវុសោទាំងឡាយ សេចក្ដីក្រោធមិនកើតឡើងដល់ខ្ញុំទេ ។

ភិក្ខុទាំងនោះ ទៅកាន់សម្នាក់ព្រះសាស្ដា ក្រាបទូលសេចក្ដីនោះហើយ ទូលថា បពិត្រព្រះអង្គ ភិក្ខុនោះកាលខ្ញុំព្រះអង្គពោលថា សេចក្ដីក្រោធកើតឡើងដល់លោកដែរឬទេ លោកពោលថា អាវុសោទាំងឡាយ សេចក្ដីក្រោធមិនកើតឡើងដល់ខ្ញុំឡើយ ភិក្ខុនោះពោលពាក្យមិនពិត ព្យាករអរហត្តផល ។

ព្រះសាស្ដា ទ្រង់ស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រពទាំងឡាយ មានអាជ្ញាដាក់ចុះហើយ ព្រះខីណាស្រពទាំងនោះ រមែងមិនធ្វើសេចក្ដីក្រោធក្នុងជនទាំងឡាយ ជាអ្នកសូម្បីមានអ្នកប្រហារ ដូច្នេះហើយ ត្រាស់គាថានេះថា

**និធាយ ទណ្ឌំ ភូតេសុ តសេសុ ថាវរេសុ ច**
**យោ ន ហន្តិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅ
តក់ស្លុតក្ដី ដែលមាំមួន គឺមិនមានតក់ស្លុតក្ដី មិនបៀតបៀន

ដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គល

នោះ ថាជាព្រាហ្មណ៍ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **និធាយ** បានដល់ ដាក់ហើយ គឺដាក់ចុះហើយ ។

ពីរបទថា **តសេសុ ថាវរេសុ ច** សេចក្ដីថា បុគ្គលឈ្មោះថាតក់ស្លុត ព្រោះការតក់ស្លុតដោយអំណាចនៃតណ្ហា និងបុគ្គលឈ្មោះថាមាំទាំ ព្រោះជាអ្នកមាំទាំដោយការមិនមាននៃតណ្ហា ។

ពីរបទថា **យោ ន ហន្តិ** ជាដើម សេចក្ដីថា បុគ្គលណា ឈ្មោះថាមានអាជ្ញាដាក់ចុះហើយ ព្រោះភាពជាអ្នកមានបដិឃៈទៅប្រាសហើយ ក្នុងសត្វទាំងពួងយ៉ាងនេះ រមែងមិនសម្លាប់ឯង មិនប្រើឲ្យអ្នកដទៃសម្លាប់នូវសត្វណាមួយឡើយ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង ភិក្ខុមួយរូប ចប់**

# រឿង សាមណេរ

## លំនាំដើម

ព្រះសាស្តា កាលគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាមណេរទាំងឡាយ ត្រាស់ព្រះធម្មទេសនានេះថា **អភិរុទ្ធំ** ជាដើម ។

បានឮថា ព្រាហ្មណីម្នាក់ រៀបចំឧទ្ទេសភត្តដើម្បីភិក្ខុ ៤ រូប ពោលនឹងព្រាហ្មណ៍ថា នែព្រាហ្មណ៍ សូមអ្នកទៅវិហារ ហើយនាំព្រាហ្មណ៍ចាស់ ៤ អង្គមក ព្រាហ្មណ៍ទៅកាន់វិហារហើយពោលថា សូមលោកម្ចាស់ទាំងឡាយឲ្យព្រាហ្មណ៍ ៤ អង្គដល់ខ្ញុំ ។

ព្រះថេរៈបានឲ្យសាមណេរជាខីណាស្រព ៤ រូប ដែលមានអាយុ ៧ ឆ្នាំ គឺសង្កិច្ចសាមណេរ បណ្ឌិតសាមណេរ សោបាកសាមណេរ រេវតសាមណេរ ដល់ព្រាហ្មណ៍នោះ ។

ព្រាហ្មណីរៀបចំអាសនៈទាំងឡាយដែលមានតម្លៃច្រើន ឃើញសាមណេរហើយក្រោធ ឆេវឆាវ ដូចអំបិលដែលបុគ្គលដាក់ក្នុងភ្លើងពោលថា អ្នកទៅវិហារហើយ នាំកូនក្មេង ៤ នាក់ ដូចជាចៅរបស់ខ្លួន ដែលមិនសមគួរមកហើយ ទើបមិនឲ្យសាមណេរទាំងនោះគង់លើអាសនៈទាំងនោះ ដាក់តាំងទាបៗ ហើយពោលថា សូមលោកទាំងឡាយអង្គុយលើតាំងទាំងនោះ ពោលថា នែព្រាហ្មណ៍ ចូរអ្នកទៅជ្រើសរើសព្រាហ្មណ៍ចាស់ហើយនាំមក ។

ព្រាហ្មណ៍ទៅកាន់វិហារ ជួបព្រះសារីបុត្តត្ថេរហើយ ពិតថា មកចុះយើងនឹងទៅផ្ទះរបស់យើងទាំងឡាយ ដូច្នេះហើយ នាំមក ព្រះថេរៈមកឃើញសាមណេរទាំងឡាយហើយសួរថា ព្រាហ្មណ៍ទាំងនេះ បានភត្តហើយឬ

កាលព្រាហ្មណ៍ឆ្លើយថា មិនទាន់បានទេ ទើបជ្រាបភាពដែលគេរៀបចំភត្ត ដើម្បីព្រាហ្មណ៍ ៤ អង្គនោះ ពោលថា ចូរពួកអ្នកនាំបាត្ររបស់យើងមក ហើយទទួលបាត្រ ចៀសចេញទៅ ។

ព្រាហ្មណីសួរថា ព្រាហ្មណ៍នេះពោលអ្វី កាលព្រាហ្មណ៍ឆ្លើយថា លោកពោលថា ព្រាហ្មណ៍ដែលអង្គុយនោះបានអាហារមុនទើបគួរ ចូរនាំបាត្រអាត្មាមក ទទួលយកបាត្ររបស់ខ្លួនហើយទៅ ទើបព្រាហ្មណីពោលថា ព្រះថេរៈនោះ ប្រហែលជាមិនបំណងនឹងឆាន់ ចូរប្រញាប់ទៅជ្រើសរើសព្រាហ្មណ៍ដទៃនាំមក ព្រាហ្មណ៍ទៅជួបព្រះមហាមោគ្គល្លានត្ថេរ ក៏ពោលយ៉ាងនោះដូចគ្នា នាំមកហើយ លោកឃើញសាមណេរទាំងឡាយហើយ ពោលយ៉ាងនោះដូចគ្នា ហើយទទួលបាត្រ ចៀសចេញទៅ ។

លំដាប់នោះ ព្រាហ្មណីពោលនឹងព្រាហ្មណ៍នោះថា ព្រាហ្មណ៍ទាំងនោះជាអ្នកមិនបំណងដើម្បីឆាន់ទេដឹង ចូរអ្នកទៅកាន់រោងស្វាធ្យាយរបស់ព្រាហ្មណ៍ នាំព្រាហ្មណ៍ចាស់ម្នាក់មក ។

សាមណេរទាំងឡាយ មិនបានវត្ថុណាមួយតាំងពីព្រឹក ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់អង្គុយហើយ ។ គ្រានោះ អាសនៈរបស់ព្រះឥន្ទ្រ សម្តែងអាការក្តៅហើយ ព្រោះតេជះនៃគុណរបស់សាមណេរទាំងនោះ ។ សក្កទេវរាជទ្រង់ពិចារណា ក៏ជ្រាបភាពដែលសាមណេរទាំងនោះ អង្គុយស្រេកឃ្លានតាំងអំពីព្រឹក ទ្រង់ព្រះតម្រិះថា ការដែលអញទៅក្នុងទីនោះគួរ ទើបកាឡាខ្លួនជាព្រាហ្មណ៍ចាស់ជរា ប្រថាប់អង្គុយលើអាសនៈដ៏ប្រសើររបស់ព្រាហ្មណ៍

ទាំងឡាយ ក្នុងរោងស្វាធ្យាយរបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍ឃើញសក្កៈនោះហើយគិតថា គ្រានេះ ព្រាហ្មណីរបស់អញនឹងពេញចិត្ត ពោលថា មកលោក ពួកយើងទៅកាន់ផ្ទះ បាននាំសក្កៈទៅកាន់ផ្ទះហើយ ។

ព្រាហ្មណីគ្រាន់តែឃើញសក្កៈប៉ុណ្ណោះ មានចិត្តត្រេកអរហើយ លាតកម្រាលលើអាសនៈពីរជាន់ក្នុងទីតែមួយពោលថា សូមលោកអញ្ជើញអង្គុយលើកម្រាលនេះចុះ ។

សក្កៈយាងចូលទៅកាន់ផ្ទះ ហើយថ្វាយបង្គំសាមណេរទាំង ៤ ដោយបញ្ចង្គប្រតិស្ឋានហើយ ទើបប្រថាប់គង់ដោយបល្ល័ង្ក ដែលជាអាសនៈខាងចុងនៃសាមណេរទាំងនោះ ។

គ្រានោះ ព្រាហ្មណីឃើញសក្កៈហើយពោលនឹងព្រាហ្មណ៍ថា លំបាកហ្ន៎ ព្រាហ្មណ៍ដែលអ្នកនាំមកហើយ ជាព្រាហ្មណ៍ធ្លួត ព្រាហ្មណ៍នោះ ថ្វាយបង្គំសាមណេរដែលស្រករនឹងចៅរបស់ខ្លួន ប្រយោជន៍អ្វីដោយព្រាហ្មណ៍នេះ ចូរលោកបណ្តេញព្រាហ្មណ៍នេះចេញទៅ ព្រាហ្មណ៍កាឡាខ្លួននោះ ត្រូវគេចាប់ត្រង់កខ្លះ ត្រង់ដៃខ្លះ ត្រង់ក្លៀកខ្លះទាញចេញទៅ ក៏មិនប្រាថ្នានឹងក្រោកឡើង ។ លំដាប់នោះ ព្រាហ្មណីពោលនឹងព្រាហ្មណ៍ជាប្តីថា មកព្រាហ្មណ៍ ចូរអ្នកចាប់ដៃម្ខាង ខ្ញុំចាប់ដៃម្ខាង ទាំងពីរនាក់ចាប់ត្រង់ដៃទាំងពីរហើយវាយត្រង់ខ្នង នាំគ្នាអូសទៅខាងក្រៅទ្វារផ្ទះហើយ ។

ចំណែកសក្កទេវរាជ ក៏បាត់ពីទីនោះ មកប្រថាប់គង់ក្នុងទីដើមនោះឯងគ្រវីដៃហើយ ។ ព្រាហ្មណ៍ប្តីប្រពន្ធនោះ ត្រឡប់មកឃើញសក្កៈនោះប្រថាប់

គន់ដូចដើម ស្រែកដោយសេចក្តីខ្លាច ហើយលែងទៅ ។ ខណៈនោះ សក្កទេវរាជ ឲ្យព្រាហ្មណ៍ជ្រាបភាពដែលទ្រង់ជាសក្កៈហើយ ។

លំដាប់នោះ ប្តីប្រពន្ធទាំងពីរ បានថ្វាយអាហារដល់សាមណេរទាំងនោះហើយ ជនទាំង ៥ ទទួលអាហារហើយ មួយរូបទម្លាយមណ្ឌលហោងជាន់ហោះទៅ មួយរូបទម្លាយដំបូលខាងមុខហោះទៅ មួយរូបទម្លាយដំបូលខាងក្រោយហោះទៅ មួយរូបមុជចូលក្នុងផែនដី ចំណែកសក្កទេវរាជ ទៅដោយផ្លូវមួយ ជនទាំង ៥ បានទៅកាន់ទីទាំង ៥ ដោយប្រការដូច្នេះ ។

ចាប់តាំងពីកាលនោះមក បានឮថា ផ្ទះនោះ ឈ្មោះថាផ្ទះប្រហោង ៥ ។ ក្នុងកាលដែលសាមណេរទៅកាន់វិហារ ភិក្ខុទាំងឡាយ សួរសាមណេរទាំងឡាយថា អាវុសោទាំងឡាយ រឿងនេះដូចម្តេច ។

ពួកសាមណេរប្រាប់ថា សូមលោកម្ចាស់ទាំងឡាយ កុំសួរពួកខ្ញុំ ចាប់តាំងពីកាលដែលព្រាហ្មណ៍ឃើញពួកខ្ញុំហើយ ព្រាហ្មណីត្រូវសេចក្តីក្រោធគ្របសង្កត់ មិនឲ្យពួកខ្ញុំអង្គុយលើអាសនៈដែលតាក់តែង ហើយពោលថា ចូរអ្នកនាំព្រាហ្មណ៍ចាស់មកឲ្យឆាប់ ឧបជ្ឈាយ៍របស់ពួកខ្ញុំ ឃើញពួកខ្ញុំហើយពោលថា ពួកព្រាហ្មណ៍ដែលអង្គុយទាំងនេះបានអាហារមុនគួរ បានយកបាត្រមកហើយ ចេញទៅ ។

កាលព្រាហ្មណីពោលថា ចូរអ្នកនាំព្រាហ្មណ៍ចាស់ដទៃមក ព្រាហ្មណ៍នាំព្រះមោគ្គល្លានត្ថេរមកហើយ លោកឃើញពួកខ្ញុំ ក៏ពោលយ៉ាងនោះដូចគ្នាហើយចៀសចេញទៅ ពេលនោះ ព្រាហ្មណីពោលថា ព្រាហ្មណ៍ទាំងនេះ មិន

បំណាំងនឹងធាន់ ចូរអ្នកទៅនាំព្រាហ្មណ៍ចាស់ម្នាក់ អំពីរោងស្វាធ្យាយរបស់ព្រាហ្មណ៍មកចុះ ហើយបញ្ជូនព្រាហ្មណ៍ទៅ ព្រាហ្មណ៍នោះ ទៅត្រង់រោងស្វាធ្យាយនោះហើយ នាំសក្កៈកាឡាខ្លួនជាព្រាហ្មណ៍មក ក្នុងកាលដែលសក្កៈនោះយាងមកហើយ ទើបប្តីប្រពន្ធទាំងពីរឲ្យអាហារដល់ពួកខ្ញុំ ភិក្ខុទាំងឡាយសួរថា ពួកលោកមិនក្រោធជាមួយព្រាហ្មណ៍ដែលធ្វើយ៉ាងនោះទេឬ សាមណេរពោលថា ពួកខ្ញុំមិនក្រោធទេ ភិក្ខុទាំងឡាយស្តាប់ពាក្យនោះហើយ ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ សាមណេរទាំងនេះពោលពាក្យមិនពិតថា ពួកខ្ញុំមិនក្រោធ ជាការព្យាករអរហត្តផល ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រពទាំង-ឡាយ រមែងមិនចង្អៀតចង្អល់ក្នុងជនទាំងឡាយ ដែលជាអ្នកខឹងក្រោធហើយ ដូច្នេះហើយ ត្រាស់គាថានេះថា

**អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្វុតំ**
**សាទានេសុ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅពួកអ្នកដែលមិនខឹង ចំពោះពួកជនដែលខឹងហើយ អ្នករម្ងាប់ចំពោះពួកជន ដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ចំពោះពួកជន ដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អវិរុទ្ធំ** ជាដើម សេចក្តីថា តថាគតរមែង

ហៅបុគ្គលនោះ គឺបែបនោះ ដែលឈ្មោះថាមិនចង្អៀតចង្អល់ ព្រោះការមិនមានអាឃាតក្នុងពួកលោកិយមហាជន ដែលជាអ្នកចង្អៀតចង្អល់ហើយដោយអំណាចនៃសេចក្ដីអាឃាត ជាអ្នកឈ្មោះថារម្ងាប់បាន គឺមានអាជ្ញាដាក់ចុះហើយក្នុងជនទាំងឡាយ ដែលឈ្មោះថាមានអាជ្ញាក្នុងខ្លួន ព្រោះភាពដែលបុគ្គលនោះជាបុគ្គលមិនវៀរចាកការឲ្យនូវការប្រហារជនដទៃ ក្នុងកាលដំបង ឬសស្ត្រាក្នុងដៃសូម្បីមិនមាន ជាបុគ្គលឈ្មោះថា មិនប្រកាន់មាំ ព្រោះមិនមានការប្រកាន់នោះក្នុងជនទាំងឡាយ ជាបុគ្គលឈ្មោះថាមានការប្រកាន់មាំ ព្រោះការប្រកាន់ក្នុងខន្ធ ៥ ថាអញ ថារបស់អញ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿងសាមណេរ ចប់**

# រឿង ព្រះមហាបន្ថកត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះមហាបន្ថកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យស្ស រាគោ** ច ជាដើម ។

សេចក្តីពិស្តារថា ព្រះមហាបន្ថកៈនោះ បណ្តេញព្រះចូឡបន្ថកៈ ដែលមិនអាចធ្វើ គឺទន្ទេញមួយគាថាឲ្យស្ទាត់ជំនាញបាន អស់កាល ៤ ខែ ចេញអំពីវិហារ ដោយពាក្យថា លោកមានអត្តភាពក្នុងព្រះសាសនា ទាំងជាអ្នកវិនាសចាកគោគៈរបស់គ្រហស្ថ ប្រយោជន៍អ្វីរបស់លោក ដោយការនៅក្នុងវិហារនេះ ចូរអ្នកចេញអំពីវិហារនេះ ហើយបើកទ្វារ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា អាវុសោទាំងឡាយ កម្មឈ្មោះនេះព្រះមហាបន្ថកៈបានធ្វើ ប្រហែលជាសេចក្តីក្រោធ កើតឡើងដល់ព្រះខីណាស្រពទាំងឡាយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយពាក្យឈ្មោះនេះ ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កិលេសទាំងឡាយ មានរាគៈជាដើម មិនមានដល់ព្រះខីណាស្រពទំាំងឡាយ តែបុត្ររបស់តថាគតធ្វើកម្មនោះ ព្រោះភាពដែលខ្លួនជាអ្នកប្រាថ្នាអត្ថខាងមុខ ព្រោះជាអ្នកប្រាថ្នាធម៌ខាងមុខ ដូច្នេះហើយត្រាស់ព្រះគាថានេះថា

**យស្ស រាគោ ច ទោសោ ច  មានោ មក្ខោ ច ចាតិតោ**
**សាសបោរិវ អារគ្គា  តមហំ ព្រូមិ ព្រាហ្មណំ ។**

*រាគៈ ទោសៈ មានៈ និងមក្ខៈដែលបុគ្គលណាបានជម្រុះចេញហើយ ដូចគ្រាប់ស្ពៃដែលជ្រុះចុះអំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **អារគ្គា** *ជាដើម សេចក្តីថា កិលេសទាំងឡាយ មានរាគៈជាដើមនោះ និងមក្ខៈ ដែលមានការលុបគុណអ្នកដទៃជាលក្ខណៈនេះ បុគ្គលណាឲ្យធ្លាក់ទៅហើយ ដូចគ្រាប់ស្ពៃធ្លាក់អំពីចុងដែកស្រួច ដូច្នោះ កិលេសទាំងនោះរមែងមិនតាំងនៅក្នុងចិត្ត ដូចគ្រាប់ស្ពៃមិនជាប់ត្រង់ចុងដែកស្រួច ដូច្នោះ ។ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚*

**រឿងព្រះមហាបន្ថកត្ថេរ ចប់**

# រឿង ព្រះបិលិន្ទវច្ឆត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបិលិន្ទវច្ឆត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អក្កោសំ** ជាដើម ។

បានឮថា ព្រះបិលិន្ទវច្ឆៈនោះ ពោលពាក្យជាដើមថា អ្នកថោកទាប ចូរមក អ្នកថោកទាប ចូរទៅ រមែងហៅទាំងគ្រហស្ថ ទាំងបព្វជិតដោយវាទៈថា អ្នកថោកទាបទាំងអស់ ។

ថ្ងៃមួយ ភិក្ខុជាច្រើនក្រាបទូលដល់ព្រះសាស្ដាថា បពិត្រព្រះអង្គ ព្រះបិលិន្ទវច្ឆៈ រមែងហៅភិក្ខុទាំងឡាយដោយវាទៈថា ជនថោកទាប ។

ព្រះសាស្ដាឲ្យហៅព្រះថេរៈមកហើយ ត្រាស់សួរថា ម្នាលបិលិន្ទវច្ឆៈ បានឮថា អ្នកហៅភិក្ខុទាំងឡាយដោយវាទៈថា អ្នកថោកទាបឬ កាលព្រះថេរៈក្រាបទូលថា យ៉ាងនោះឯងព្រះអង្គ ទើបទ្រង់ធ្វើបុព្វេនិវាសរបស់ព្រះបិលិន្ទវច្ឆៈនោះក្នុងព្រះហឫទ័យហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំលើកទោសដល់ភិក្ខុឈ្មោះបិលិន្ទវច្ឆៈឡើយ ម្នាលភិក្ខុទាំងឡាយ វច្ឆៈមិនមានទោសខាងក្នុង ហៅភិក្ខុទាំងឡាយដោយពាក្យថា អ្នកថោកទាបឡើយ ម្នាលភិក្ខុទាំងឡាយ ជាតិទាំងឡាយ ៥០០ របស់ភិក្ខុឈ្មោះវច្ឆៈ មិនលាយឡំគ្នា ( គឺព្រាហ្មណ៍ ៥០០ ជាតិជាប់គ្នា ) ទាំងអស់នោះ កើតហើយក្នុងត្រកូលព្រាហ្មណ៍ ក្នុងកាលខាងក្រោយ វាទៈថោកទាបនោះ វច្ឆៈហៅមកហើយអស់កាលយូរ ជាពាក្យទ្រគោះបោះបោកជនដទៃ ជាពាក្យមិនពីរោះ ជាពាក្យគ្រោតគ្រាតនោះឯង ឈ្មោះថា មិនមានដល់ព្រះខីណាស្រព ព្រោះថាបុត្រ

របស់តថាគតពោលយ៉ាងនោះដោយអំណាចនៃការជ្ជាប់ កាលទ្រង់សម្តែងធម៌ ទើប ត្រាស់ព្រះគាថានេះថា

**អកក្កសំ វិញ្ញាបនឹ គិរំ សច្ចំ ឧទីរយេ**
**យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹង
សេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណាឲ្យ
ទាស់ចិត្ត តថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អកក្កសំ** បានដល់ ពាក្យមិនគ្រោតគ្រាត ។ បទថា **វិញ្ញាបនឹ** បានដល់ ឲ្យដឹងអត្ថគ្នាបាន ។ បទថា **សច្ចំ** បានដល់ ជាអត្ថដែលពិត ។ បទថា **នាភិសជេ** ជាដើម សេចក្តីថា បុគ្គលមិនគប្បីញ៉ាំងបុគ្គលដទៃឲ្យជាប់ជំពាក់ ដោយអំណាចនៃការឲ្យបុគ្គលនោះក្រោធ ដោយពាក្យណាមួយ ។ ធម្មតាព្រះខីណាស្រព គប្បីពោលពាក្យបែបនោះឯង ហេតុនោះទើបតថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ព្រះបិលិន្ទវច្ឆត្ថេរ ចប់**

# រឿង ភិក្ខុមួយរូប
## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **យោគ ឱយំ** ជាដើម ។

បានឮមកថា ព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់ក្នុងក្រុងសាវត្ថី ដោះសំពត់សាដក សម្រាប់ដណ្ដប់ដាក់ក្នុងចំណែកម្ខាង ព្រោះខ្វាចជំក្លិនខ្លួន អង្គុយបែរមុខចេញ មកខាងក្រៅទ្វារផ្ទះ ។

លំដាប់នោះ ព្រះខីណាស្រពមួយរូបធ្វើភត្តកិច្ចហើយ កំពុងដើរទៅកាន់ វិហារ ឃើញសំពត់សាដកនោះហើយ សម្លឹងមើលឆ្វេងស្ដាំ កាលមិនឃើញ បុគ្គលណាម្នាក់ ទើបគិតថា សំពត់សាដកនេះមិនមានម្ចាស់ ហើយអធិដ្ឋាន ជាសំពត់បង្សុកូល កាន់យកហើយ ។

ខណៈនោះ ព្រាហ្មណ៍ឃើញហើយ ជេរបណ្ដើរ ចូលទៅរកបណ្ដើរថា សមណៈត្រងោល លោកកាន់យកសំពត់សាដកខ្ញុំធ្វើអ្វី ព្រះខីណាស្រពពោល ថា ព្រាហ្មណ៍ នុ៎ះសំពត់សាដករបស់អ្នកឬ ព្រាហ្មណ៍ពោលថា អើសមណៈ ព្រះខីណាស្រពពោលថា អាត្មាមិនឃើញបុគ្គលណាម្នាក់ ទើបកាន់យកសំពត់ សាដកនោះ ដោយសម្គាល់ថា ជាសំពត់បង្សុកូល ចូរអ្នកទទួលយកសំពត់ សាដកនោះចុះ ឲ្យដល់ព្រាហ្មណ៍នោះហើយទៅកាន់វិហារ ប្រាប់សេចក្ដីនោះ ដល់ភិក្ខុទាំងឡាយ ។

លំដាប់នោះ ភិក្ខុទាំងឡាយស្ដាប់ពាក្យរបស់លោកហើយ ក៏ធ្វើនូវការ ចំអក ទើបពោលថា អាវុសោ សំពត់សាដកវែង ឬខ្លី គ្រោតគ្រាត ឬល្អិតហ្ន៎

ព្រះខីណាស្រពពោលថា អាវុសោទាំងឡាយ សំពត់សាដកវែង ឬខ្លី គ្រោត គ្រាត ឬល្អិតក៏ដោយចុះ ការអាល័យក្នុងសំពត់សាដកនោះរបស់ខ្ញុំមិនមាន ខ្ញុំកាន់យកដោយសម្គាល់ថា ជាសំពត់បង្សុកូលទេតើ ។

ភិក្ខុទាំងឡាយស្តាប់ពាក្យនោះហើយ ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុនោះពោលពាក្យមិនពិត ព្យាករអរហត្តផល ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះពោលពាក្យពិត ធម្មតាព្រះខីណាស្រពទាំងឡាយ មិនកាន់យករបស់អ្នកដទៃ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**យោធ ទីឃំ វ រស្សំ វា អណុំ ថូលំ សុភាសុភំ**
**លោកេ អទិន្នំ នាទិយតិ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនកាន់យករបស់វែង ឬខ្លី តូច ឬធំ ល្អ ឬ អាក្រក់ ដែលគេមិនបានឲ្យហើយ ក្នុងលោកនេះ តថាគត ហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះដូច្នេះថា បុគ្គលណា រមែងមិនកាន់យកទ្រព្យវែង ឬខ្លី បណ្តាវត្ថុទាំងឡាយ មានសំពត់សាដក និងគ្រឿងប្រដាប់ជាដើម តូច ឬធំ បណ្តាវត្ថុទាំងឡាយ មានកែវមណី និងកែវមុក្តាជាដើម ស្អាត ឬមិនស្អាត ដោយអំណាចនៃវត្ថុមានតម្លៃច្រើន និងមានតម្លៃតិច ដែលបុគ្គលដទៃហួងហែងហើយ ក្នុងលោកនេះ តថាគតហៅបុគ្គលនោះ ថាជា

ព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង ភិក្ខុមួយរូប ចប់**

# រឿង ព្រះសារីបុត្តត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អាសា យស្ស** ជាដើម ។

បានឮថា ព្រះថេរៈមានភិក្ខុ ៥០០ ជាបរិវារ ទៅកាន់វិហារមួយកន្លែងក្នុងជនបទ ហើយចាំវស្សា ។

មនុស្សទាំងឡាយ ឃើញព្រះថេរៈហើយ ត្រៀមសំពត់ចំណាំវស្សាជាច្រើន ។ ព្រះថេរៈបវារណាហើយ កាលសំពត់ចំណាំវស្សាទាំងពួងមិនទាន់ដល់ ( លំដាប់លោក ) នោះឯង កាលទៅកាន់សម្នាក់ព្រះសាស្តា ផ្តាំភិក្ខុទាំងឡាយថា បើសំពត់ចំណាំវស្សា ដែលមនុស្សទាំងឡាយនាំមកហើយដើម្បីភិក្ខុកំលោះ និងសាមណេរទាំងឡាយ ពួកលោកទទួល ហើយបញ្ជូនមក ឬរក្សាទុកហើយ គប្បីឲ្យដំណឹងមក ។ ព្រះថេរៈកាលពោលយ៉ាងនោះហើយ បានទៅកាន់សម្នាក់ព្រះសាស្តា ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា សូម្បីថ្ងៃនេះ តណ្ហារបស់ព្រះសារីបុត្តត្រេរប្រហែលជានៅមាន ពិតហើយ ព្រះថេរៈផ្តាំដល់ភិក្ខុទាំងឡាយថា កាលពួកមនុស្សប្រគេនសំពត់ចំណាំវស្សាហើយ ពួកលោកគប្បីបញ្ជូនសំពត់ចំណាំវស្សាមកដល់ពួកសទ្ធិវិហារិករបស់ខ្លួន ឬទុកដាក់ហើយ គប្បីឲ្យដំណឹងមកដូច្នេះហើយ ទើបចេញដំណើរមក ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តណ្ហារមែងមិនមានដល់បុត្រតថាគត តែសារីបុត្តពោលយ៉ាងនោះ ដោយគិតថាការវិនាសចាកបុណ្យរបស់ពួកមនុស្ស និងវិនាសចាកលាភ ដែលប្រកបដោយធម៌របស់ភិក្ខុកំលោះ និងសាមណេរទាំងឡាយ កុំបីមានឡើយដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អាសា យស្ស ន វិជ្ជន្តិ អស្មឹ លោកេ បរម្ហិ ច**
**និរាសយំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

អ្នកណា មិនមានសេចក្តីប្រាថ្នាក្នុងលោកនេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គលនោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះចាកកិលេស ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

តណ្ហា ឈ្មោះថា **អាសា** ក្នុងព្រះគាថានោះ ។ បទថា **និរាសាសំ**

បានដល់ មិនមានតណ្ហា ។ បទថា **វិសំយុត្តំ** សេចក្ដីថា តថាគតហៅបុគ្គល ដែលផុតស្រឡះបានហើយចាកកិលេសទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។៚

រឿង ព្រះសារីបុត្តត្ថេរ ចប់

# រឿង ព្រះមហាមោគ្គល្លានត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមោគ្គល្លាន ត្រាស់ព្រះធម្មទេសនានេះថា **យស្សាលយា** ជាដើម ។

រឿងដូចគ្នានឹងរឿងមុននោះឯង តែក្នុងរឿងនេះ ព្រះសាស្ដាត្រាស់ភាព ដែលព្រះមោគ្គល្លានត្ថេរ ជាបុគ្គលមិនមានតណ្ហា ហើយត្រាស់ព្រះគាថានេះថា

**យស្សាលយា ន វិជ្ជន្តិ　　អញ្ញាយ អកថង្កថី**
**អមតោគធំ អនុប្បត្តំ　　តមហំ ព្រូមិ ព្រាហ្មណំ ។**

អ្នកណា មិនមានសេចក្ដីអាល័យ គឺតណ្ហា មិនមានសេចក្ដី សង្ស័យក្នុងអ្វីសោះ ព្រោះដឹងច្បាស់ធម៌ តថាគតហៅ បុគ្គលនោះ ដែលមានចិត្តចុះស៊ប់កាន់ព្រះនិព្វាន ដែលមាន ព្រះអរហត្តផលដល់ហើយដោយលំដាប់ ថាជាព្រាហ្មណ៍ ។

# សេចក្តីអធិប្បាយ

តណ្ហា ឈ្មោះថា អាល័យ ក្នុងព្រះគាថានេះ ។

បាទព្រះគាថាថា **អញ្ញាយ អកថង្កថី** សេចក្តីថា បុគ្គលដឹងវត្ថុ ៨ តាមសេចក្តីពិតហើយ ជាអ្នកមិនមានសេចក្តីសង្ស័យ ដោយសេចក្តីសង្ស័យដែលមានវត្ថុ ៨ ។

បាទព្រះគាថាថា **អមតោគធំ អនុប្បត្តំ** សេចក្តីថា តថាគតហៅបុគ្គលនោះ ដែលចុះស៊ប់កាន់ព្រះនិព្វាន ឈ្មោះអមតៈ តាមសម្រេចហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿងព្រះមហាមោគ្គល្លានត្ថេរ ចប់**

# រឿង ព្រះរេវតត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងបុព្វារាម ទ្រង់ប្រារព្ធព្រះរេវតត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោធ បុញ្ញញ្ច** ជាដើម ។

រឿងខ្ញុំឲ្យពិស្ដារហើយ ក្នុងអដ្ឋកថានៃព្រះគាថាថា **គាមេ វា យទិ វា រញ្ញេ** ជាដើមហើយនោះឯង ។

ពិតហើយ ក្នុងរឿងនោះខ្ញុំពោលថា ស្អែកឡើងភិក្ខុទាំងឡាយសន្ទនាគ្នាថា គួរអស្ចារ្យ សាមណេរមានលាភ គួរអស្ចារ្យ សាមណេរមានបុណ្យមួយរូប សាងផ្ទះកំពូល ៥០០ ដើម្បីភិក្ខុ ៥០០ រូបបាន ។

ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុណ្យ រមែងមិនមានដល់បុត្ររបស់តថាគត បាប ក៏មិនមាន បុណ្យបាបទាំងពីរ ភិក្ខុនោះលះបង់ហើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**យោធ បុញ្ញញ្ច បាបញ្ច ឧភោ សង្គំ ឧបច្ចគា**
**អសោកំ វិរជំ សុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ និងបាបទាំងពីរ និងកិលេសជាគ្រឿងជំពាក់ ( មានរាគៈជាដើម ) ចេញហើយ តថាគតហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្ដីសោក មានធូលី គឺកិលេសអស់ហើយ ជាអ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧភោ** សេចក្តីថា លះបុណ្យ និងបាបទាំងពីរ ។

បទថា **សង្គំ** បានដល់ កិលេសជាគ្រឿងជាប់ជំពាក់ មានរាគៈជាដើម ។

បទថា **ឧបច្ចគា** បានដល់ ឈានកន្លងហើយ អធិប្បាយថា គថាគតហៅបុគ្គល ដែលឈ្មោះថាមិនមានសេចក្តីសោក ព្រោះមិនមានសេចក្តីសោកដែលមានវដ្តៈជាមូល ដែលឈ្មោះថាមានធូលីទៅប្រាសហើយ ព្រោះមិនមានធូលី គឺរាគៈជាដើមខាងក្នុង បុគ្គលឈ្មោះថាបរិសុទ្ធហើយ ព្រោះជាអ្នកមិនមានឧបក្កិលេសនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៙

**រឿង ព្រះរេវតត្ថេរ ចប់**

# រឿង ព្រះចន្ទាភត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះចន្ទាភត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ចន្ទំវ** ជាដើម ។

អនុបុព្វីកថាក្នុងរឿងរបស់ព្រះចន្ទាភត្ថេរដូចតទៅនេះថា បានឮថា ក្នុងអតីតកាល ឈ្មួញក្នុងក្រុងពារាណសីម្នាក់គិតថា អញទៅកាន់បច្ចន្តជនបទ ហើយនាំចន្ទន៍ក្រហមមក ជញ្ជូនយកវត្ថុជាច្រើនមានសំពត់ និងគ្រឿងអាភរណៈជាដើម ទៅកាន់បច្ចន្តជនបទដោយរទេះ ៥០០ កាន់យកទិសម្រាកក្នុងទីជិតទ្វារស្រុកហើយ សួរក្មេងឃ្វាលគោក្នុងព្រៃថា មនុស្សណាម្នាក់ក្នុងស្រុកនេះ ធ្វើការងារក្បែរជើងភ្នំមានដែរឬ ពួកក្មេងឃ្វាលគោពោលថា មាន ឈ្មួញពោលថា មនុស្សនោះឈ្មោះអ្វី ក្មេងឃ្វាលគោប្រាប់ថា មនុស្សនោះឈ្មោះនោះ ។

ឈ្មួញសួរថា ភរិយា ឬកូនរបស់គាត់ឈ្មោះអ្វី ពួកក្មេងឃ្វាលគោប្រាប់ថា គាត់មានឈ្មោះយ៉ាងនេះៗ ឈ្មួញពោលថា ផ្ទះរបស់គាត់នៅទីណា ពួកក្មេងឃ្វាលគោប្រាប់ថា ផ្ទះរបស់គាត់នៅក្នុងទីឈ្មោះនោះ ឈ្មួញនោះអង្គុយលើយានតូចដែលជាសប្បាយ ទៅកាន់ទ្វារផ្ទះរបស់បុរសនោះតាមសញ្ញាដែលពួកក្មេងទាំងនោះឲ្យហើយ ចុះអំពីយានចូលទៅកាន់ផ្ទះហើយ ហៅស្រីឈ្មោះនោះ ស្រីនោះគិតថា បុគ្គលនេះជាញាតិរបស់អញណាម្នាក់ ទើបមកដោយរហ័ស បានក្រាលអាសនៈ ។

ឈ្មួញនោះអង្គុយលើអាសនៈនោះហើយ ប្រារព្ធឈ្មោះសួរថា សម្លាញ់

របស់ខ្ញុំទៅណា ស្រីនោះឆ្លើយថា គាត់ទៅកាន់ព្រៃហើយ ឈ្មួញប្រារព្ធឈ្មោះរបស់មនុស្សទាំងពួងសួរថា កូនប្រុសរបស់ខ្ញុំឈ្មោះនោះ កូនស្រីរបស់ខ្ញុំឈ្មោះនោះទៅណា ដូច្នេះហើយ ពោលថា អ្នកគប្បីឲ្យសំពត់ និងគ្រឿងអាភរណៈទាំងនេះដល់ជនទាំងនោះ ក្នុងពេលដែលសម្លាញ់របស់ខ្ញុំត្រឡប់មកហើយអំពីព្រៃ នាងគប្បីឲ្យសំពត់ និងគ្រឿងអាភរណៈនេះ ហើយបានឲ្យវត្ថុទាំងនោះ ។ នាងធ្វើសក្ការៈក្រៃលែងដល់ឈ្មួញហើយ ក្នុងកាលដែលប្តីមក ទើបពោលថា នៃអ្នក បុគ្គលនេះតាំងអំពីគាត់ចូលមកហើយ ប្រារព្ធឈ្មោះរបស់ជនទាំងពួងហើយ ឲ្យវត្ថុនេះ និងវត្ថុនេះ ចំណែកប្តីរបស់ស្រីនោះ ក៏ធ្វើកិច្ចដែលគួរធ្វើដល់ឈ្មួញនោះ ។

ក្នុងពេលល្ងាច ឈ្មួញនោះអង្គុយលើទីដេកសួរថា សម្លាញ់ អ្នកត្រាច់ទៅត្រង់ជើងភ្នំ ធ្លាប់ឃើញអ្វីច្រើន បុរសម្ចាស់ផ្ទះពោលថា ខ្ញុំមិនបានឃើញអ្វីដទៃ ឃើញតែដើមឈើប្រភេទនេះ ដែលមានមែកពណ៌ក្រហមច្រើន ឈ្មួញពោលថា ដើមឈើប្រភេទនេះមានច្រើនឬ ម្ចាស់ទីកន្លែងពោលថា មានច្រើន ឈ្មួញពោលថា បើដូច្នោះ ចូរអ្នកបង្ហាញដើមឈើនោះដល់ខ្ញុំ ដូច្នេះហើយ ទៅជាមួយបុរសនោះ កាប់ចន្ទន៍ក្រហមផ្ទុកពេញរទេះ ៥០០ ហើយ ។ កាលធ្វើដំណើរមកពោលនឹងបុរសនោះថា សម្លាញ់ ផ្ទះរបស់ខ្ញុំនៅក្នុងទីឈ្មោះនោះក្នុងក្រុងពារាណសី អ្នកគប្បីមកកាន់សម្នាក់របស់ខ្ញុំ សព្វកាល តាមកាល ខ្ញុំមិនត្រូវការដោយគ្រឿងបណ្ណាការដទៃ អ្នកគប្បីនាំមកចំពោះតែដើមឈើមានមែកក្រហមប៉ុណ្ណោះ កាលបុរសនោះទទួលថា សាធុហើយ កាលមកកាន់

សម្លាញ់របស់ឈ្មួញនោះ សព្វកាល តាមកាល រមែងនាំមកតែដើមចន្ទន៍ក្រហមប៉ុណ្ណោះ សូម្បីឈ្មួញនោះ ក៏ឲ្យទ្រព្យច្រើនដល់បុរសនោះ ។

សម័យដទៃក្រោយមក កាលព្រះកស្សបទសពលបរិនិព្វានហើយ កាលព្រះស្តូបមាស គេបានប្រតិស្ឋានហើយ បុរសនោះ បានផ្ទុកចន្ទន៍ក្រហមជាច្រើន ទៅកាន់ក្រុងពារាណសី ។

កាលនោះ ឈ្មួញនោះជាសម្លាញ់របស់បុរសនោះ ឲ្យបុកដើមចន្ទន៍ជាច្រើនដាក់ពេញថាសហើយពោលថា សម្លាញ់ ចូរមកពួកយើងទៅកាន់ទីសាងចេតិយ ទម្រាំបាយឆ្អិនសឹមត្រឡប់ បាននាំបុរសនោះទៅក្នុងទីនោះ ធ្វើការបូជាដោយលម្អិតចន្ទន៍ហើយ ។

សម្លាញ់អ្នកបច្ចន្តជនបទរបស់បុរសនោះ បានសាងមណ្ឌលនៃព្រះចន្ទដោយខ្លឹមចន្ទន៍ ក្នុងបន្ទប់នៃចេតិយ បុព្វកម្មរបស់គាត់មានប្រមាណប៉ុណ្ណោះ ។

បុរសនោះចុតិអំពីអត្តភាពនោះហើយ កើតក្នុងទេវលោក ញុំាងពុទ្ធន្តរមួយឲ្យអស់ហើយក្នុងទេវលោកនោះ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាលក្នុងក្រុងរាជគ្រឹះ ។ រស្មីដូចគ្នានឹងមណ្ឌលព្រះចន្ទ តាំងឡើងអំពីផ្ចិតរបស់កុមារនោះ ព្រោះហេតុនោះ ទើបពួកញាតិដាក់ឈ្មោះថា ចន្ទាភៈ បានឮថា នុ៎ះជាផលនៃការធ្វើមណ្ឌលនៃព្រះចន្ទក្នុងព្រះចេតិយរបស់បុរសនោះ ។

ព្រាហ្មណ៍ទាំងឡាយគិតថា ពួកយើងអាចនាំយកព្រាហ្មណ៍នេះទៅរកស៊ីក្នុងលោកបាន ដូច្នេះហើយ ឲ្យគាត់អង្គុយលើយានតូច ដើរប្រកាសថា អ្នក

ណាយកដៃស្ទាបសរីរៈរបស់ចន្ទាភព្រាហ្មណ៍នេះ បុគ្គលនោះនឹងបានឥស្សរិយ-សម្បត្តិបែបនេះ ។ មនុស្សទាំងឡាយឲ្យទ្រព្យមួយរយខ្លះ មួយពាន់ខ្លះ មួយសែនខ្លះនោះឯង ទើបបានយកដៃស្ទាបសរីរៈរបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍ទាំងនោះត្រាច់ទៅរឿយៗ យ៉ាងនេះ ដល់ក្រុងសាវត្ថីដោយលំដាប់ កាន់យកទីសម្រាកត្រង់ចន្លោះនគរ និងវត្តជេតពនហើយ ។

អរិយសាវកប្រមាណ ៥ កោដិ ក្នុងក្រុងសាវត្ថីថ្វាយទានក្នុងកាលមុននៃភត្តហើយ ក្នុងកាលក្រោយភត្ត មានដៃកាន់គ្រឿងក្រអូប និងកម្រងផ្កាសំពត់ និងភេសជ្ជៈជាដើម ដើម្បីទៅស្តាប់ធម៌ ។ ព្រាហ្មណ៍ទាំងឡាយឃើញអរិយសាវកទាំងនោះហើយ សួរថា អ្នកទាំងឡាយនាំគ្នាទៅណា អរិយសាវកពោលថា ពួកយើងទៅកាន់សម្នាក់របស់ព្រះសាស្តាដើម្បីស្តាប់ធម៌ ។ ពួកព្រាហ្មណ៍ពោលថា មកអ្នកទាំងឡាយ អ្នកទៅក្នុងទីនោះហើយ នឹងធ្វើអ្វីអានុភាពដូចគ្នានឹងអានុភាពរបស់ចន្ទាភព្រាហ្មណ៍នៃពួកខ្ញុំ មិនមាន ព្រោះថាជនទាំងឡាយស្ទាបសរីរៈរបស់ចន្ទាភព្រាហ្មណ៍នោះ រមែងបានសម្បត្តិឈ្មោះនេះ ចូរអ្នកទាំងឡាយមក ចូរមើលចន្ទាភព្រាហ្មណ៍នោះ ។

អរិយសាវកទាំងនោះពោលថា ឈ្មោះថាអានុភាពរបស់ចន្ទាភព្រាហ្មណ៍របស់អ្នកទាំងឡាយដូចម្តេច ព្រះសាស្តារបស់ពួកយើងប៉ុណ្ណោះមានអានុភាពច្រើន ។ អរិយសាវក និងពួកព្រាហ្មណ៍ទាំងនោះ មិនអាចញ៉ាំងគ្នានិងគ្នាឲ្យយល់ព្រមបាន ទើបពោលថា ពួកយើងទៅវិហារហើយនឹងដឹងអានុភាពរបស់ចន្ទាភព្រាហ្មណ៍ ឬព្រះសាស្តារបស់ពួកយើង ដូច្នេះហើយ បាននាំចន្ទាភ-

ព្រាហ្មណ៍នោះទៅកាន់វិហារហើយ ។

ព្រះសាស្តា កាលចន្ទាកព្រាហ្មណ៍នោះ ចូលទៅកាន់សម្នាក់របស់ព្រះអង្គ ទ្រង់បានធ្វើរស្មីដូចព្រះចន្ទឲ្យបាត់ទៅ ចន្ទាកព្រាហ្មណ៍នោះដូចគ្នានឹងក្អែកដែលនៅក្នុងកញ្ជើផេះ ក្នុងសម្នាក់របស់ព្រះសាស្តា ។

គ្រានោះ ទើបព្រាហ្មណ៍ទាំងឡាយ នាំគាត់ទៅក្នុងចំណែកម្ខាង រស្មីក៏មានដូចមុន ព្រាហ្មណ៍ក៏នាំមកកាន់សម្នាក់ព្រះសាស្តាទៀត រស្មីក៏បាត់ទៅយ៉ាងនោះដូចគ្នា ចន្ទាកព្រាហ្មណ៍ទៅហើយយ៉ាងនោះអស់ ៣ ដង ឃើញរស្មីបាត់ទៅ ទើបគិតថា បុគ្គលនេះប្រហែលជាចេះមន្ត ធ្វើរស្មីឲ្យបាត់ទៅ ទើបទូលសួរព្រះសាស្តាថា ទ្រង់ចេះមន្តជាគ្រឿងបាត់ទៅនៃរស្មីឬហ្ន៎ ព្រះសាស្តាត្រាស់ថា អើ តថាគតចេះ ចន្ទាកៈទូលថា បើដូច្នោះ សូមទ្រង់ប្រទានដល់ខ្ញុំព្រះអង្គផង ព្រះសាស្តាត្រាស់ថា តថាគតមិនអាចឲ្យដល់បុគ្គលដែលមិនបួស ។ ចន្ទាកព្រាហ្មណ៍ពោលនឹងពួកព្រាហ្មណ៍ថា កាលខ្ញុំរៀនមន្តនោះហើយ ខ្ញុំនឹងជាបុគ្គលប្រសើរក្នុងជម្ពូទីបទាំងមូល ចូរពួកអ្នករង់ចាំក្នុងទីនេះសិន ខ្ញុំនឹងបួសរៀនមន្ត ២-៣ ថ្ងៃប៉ុណ្ណោះ ។

គាត់ទូលសូមបព្វជ្ជានឹងព្រះសាស្តា បានឧបសម្បទាហើយ ។ គ្រានោះទើបព្រះសាស្តាត្រាស់ប្រាប់អាការ ៣២ ដល់ចន្ទាកភិក្ខុនោះ ព្រះថេរៈទូលសួរថា នេះជាអ្វី ព្រះសាស្តាត្រាស់ថា នេះជាបរិកម្មនៃមន្ត អ្នកគួរស្វាធ្យាយ ។ ពួកព្រាហ្មណ៍ មកក្នុងចន្លោះៗ ហើយសួរថា លោកម្ចាស់រៀនមន្តបានហើយឬ ព្រះចន្ទាកៈពោលថា នៅទេ អាត្មាកំពុងរៀន ។ លោកសម្រេចអរហត្តក្នុង

កាល ២-៣ ថ្ងៃប៉ុណ្ណោះ ក្នុងពេលដែលពួកព្រាហ្មណ៍មកសួរហើយពោលថា អ្នកទាំងឡាយទៅចុះ ឥឡូវនេះ អាត្មាជាបុគ្គលមានធម៌ជា គ្រឿងមិនទៅហើយ ។

ភិក្ខុទាំងឡាយក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុនេះពោលពាក្យមិនពិត រមែងព្យាករអរហត្តផល ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ចន្ទាភៈបុត្ររបស់តថាគតមានអាសវៈអស់ហើយ រមែងពោលតែពាក្យពិតប៉ុណ្ណោះ ដូច្នេះហើយត្រាស់ព្រះគាថានេះថា

**ចន្ទំវ វិមលំ សុទ្ធំ វិប្បសន្នមនាវិលំ**
**នន្ទិភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅបុគ្គលដែលមិនមានសេចក្តីសៅហ្មង ដូចព្រះចន្ទប្រាសចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តថ្លា មិនកករល្អក់ អស់សេចក្តីត្រេកអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **វិមលំ** បានដល់ វៀរហើយចាកមន្ទិលមានពពកជាដើម ។ បទថា **សុទ្ធំ** បានដល់ មិនមានឧបក្កិលេស ។

បទថា **វិប្បសន្នំ** បានដល់ មានចិត្តថ្លាផង់ហើយ ។ បទថា **អនាវិលំ** បានដល់ វៀរហើយចាកមន្ទិល មានកិលេសជាដើម ។

បទថា **នន្ទិភវបរិក្ខីណំ** សេចក្តីថា តថាគតហៅបុគ្គលដែលមានតណ្ហា

ក្នុងភពទាំង ៣ អស់ហើយនោះថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។៙

រឿង ព្រះចន្ទាភត្ថេរ ចប់

# រឿង ព្រះសីវលិត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យនៅក្រុងកុណ្ឌិកោលិយនគរ ប្រថាប់ នៅក្នុងព្រៃ ឈ្មោះកុណ្ឌធាន ទ្រង់ប្រារព្ធព្រះសីវលិត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោមំ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ធីតារបស់កោលិយវង្ស ព្រះនាមថា សុប្បវាសា ព្រះនាងទ្រង់គភ៌អស់ ៧ ឆ្នាំ មានគភ៌វង្វេងអស់ ៧ ថ្ងៃ ត្រូវទុក្ខ វេទនាដ៏ខ្លាំងក្លា ក្តៅក្រហាយពាល់ត្រូវហើយ ព្រះនាងអត់ធន់ក្នុងទុក្ខនោះដោយ វិតក្ក ៣ គឺព្រះដ៏មានព្រះភាគអង្គណា ទ្រង់សម្តែងធម៌ដើម្បីលះទុក្ខនៃរូបនេះ ឯង ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងឯងដោយប្រពៃហ្ន៎ ១ ព្រះ សង្ឃសាវកណា បដិបត្តិដើម្បីលះទុក្ខនៃរូបនេះឯង ព្រះសង្ឃសាវកនោះរបស់ ព្រះដ៏មានព្រះភាគអង្គនោះ ជាអ្នកបដិបត្តិល្អហើយហ្ន៎ ១ ទុក្ខបែបនេះ មិនមាន ក្នុងព្រះនិព្វានណា ព្រះនិព្វាននោះជាសុខហ្ន៎ ១ ដូច្នេះហើយ ព្រះនាងបញ្ជូន

ស្វាមីទៅកាន់សម្នាក់ព្រះសាស្តា កាលព្រះស្វាមីនោះ ក្រាបទូលនូវការថ្វាយបង្គំដល់ព្រះសាស្តា តាមពាក្យរបស់ព្រះនាងហើយ ក្នុងខណៈដែលព្រះដ៏មានព្រះភាគត្រាស់ថា ព្រះធីតាកោលិយវង្ស ព្រះនាមសុប្បវាសា ចូរមានសេចក្តីសុខ កុំបីមានរោគ ប្រសូតឱរសដោយមិនមានរោគចុះ ដូច្នេះនោះឯងជាអ្នកសប្បាយ ប្រាសចាករោគ ប្រសូតព្រះឱរសមិនមានរោគហើយ ព្រះនាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបានថ្វាយមហាទានអស់ ៧ ថ្ងៃ ។

ឱរសរបស់ព្រះនាងកាន់យកធម្មក្រក ត្រងទឹកថ្វាយសង្ឃបាន ចាប់តាំងពីថ្ងៃដែលកើតហើយ ។ ក្នុងកាលតមក ព្រះឱរសនោះ ចេញបព្វជ្ជាហើយសម្រេចអរហត្ត ។

ថ្ងៃមួយ ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ចូរពួកលោកមើល ភិក្ខុដល់ព្រមដោយឧបនិស្ស័យនៃអរហត្តបែបនេះ គន់សោយទុក្ខក្នុងផ្ទៃមាតាអស់កាលមានប្រមាណប៉ុណ្ណោះ នឹងពោលថ្វីដល់ជនដទៃ ទុក្ខជាច្រើនហ្ន៎ ដែលភិក្ខុនេះដកចោលហើយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថាដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតផុតទុក្ខប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ ធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ហើយដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**យោមំ បលិបថំ ទុគ្គំ សំសារំ មោហមច្ចគា**
**តិណ្ណោ ចារគតោ ឈាយី អនេជោ អកថង្កថី**
**អនុបាទាយ និព្វុតោ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា កន្លងផ្លូវវាង គឺរាគៈ និងភក់ ដែលគេឆ្លងបាន ដោយកម្រ គឺកិលេស និងសង្សារវដ្ដ និងមោហៈទាំងនេះ បាន ជាអ្នកឆ្លងអន្លង់ទាំង ៤ បាន ដល់ត្រើយ គឺព្រះនិព្វាន ជាអ្នកមានឈាន មិនញាប់ញ័រដោយតណ្ហា មិនមានសេចក្ដី សង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគត ហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។*

## សេចក្ដីអធិប្បាយ

*គប្បីជ្រាបអត្ថនៃព្រះគាថានោះដូច្នេះថា ភិក្ខុណាកន្លងនូវផ្លូវ គឺរាគៈ ភក់ គឺកិលេស សង្សារវដ្ដ និងមោហៈ ដែលមិនឲ្យបាក់ធ្លុះអរិយសច្ច ៤ នេះទៅ ហើយ ជាអ្នកឆ្លងឱឃៈទាំង ៤ បាន ដល់ត្រើយហើយដោយលំដាប់ មាន ប្រក្រតីសម្លឹងឈាន ២ យ៉ាង ឈ្មោះថា មិនមានកិលេសជាគ្រឿងញាប់ញ័រ ព្រោះមិនមានតណ្ហា ។ ឈ្មោះថា មិនមានសេចក្ដីសង្ស័យជាហេតុនឹងពោល បាន ព្រោះមិនមានវាចាដើម្បីពោលថាដូចម្ដេច ឈ្មោះថា មិនប្រកាន់មាំ ហើយ ព្រោះមិនមានឧបាទាន ឈ្មោះថា រម្ងត់ហើយ ព្រោះការរលត់ទៅនៃ កិលេស តថាគតហៅភិក្ខុនោះ ថាជាព្រាហ្មណ៍ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

រឿង ព្រះសីវលិត្ថេរ ចប់

# រឿង ព្រះសុន្ទរសមុទ្ទត្ថេរ
## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសុន្ទរសមុទ្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោធ កាមេ** ជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី កុលបុត្រម្នាក់ឈ្មោះសុន្ទរសមុទ្ទកុមារ កើតក្នុងត្រកូលធំ មានសម្បត្តិ ៤០ កោដិ ។

ថ្ងៃមួយ ឃើញមហាជន មានគ្រឿងក្រអូប និងកម្រងផ្កាក្នុងដៃជាដើម ទៅកាន់វត្តជេតពនដើម្បីស្តាប់ធម៌ ក្នុងកាលខាងក្រោយកត្ត ទើបសួរថា ពួកលោកនាំគ្នាទៅណា កាលមហាជនទាំងនោះប្រាប់ថា ពួកយើងទៅកាន់សម្នាក់ព្រះសាស្តា ដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ ក៏ពោលថា ខ្ញុំក៏ទៅដែរ ហើយទៅជាមួយនឹងមហាជនទាំងនោះ អង្គុយខាងចុងបរិស័ទ ។

ព្រះសាស្តាទ្រង់ជ្រាបអាធ្យាស្រ័យរបស់កុមារ ទើបទ្រង់សម្តែងអនុបុព្វីកថា កុមារគិតថា បុគ្គលដែលគ្រប់គ្រងផ្ទះ មិនអាចប្រព្រឹត្តព្រហ្មចរិយៈឲ្យដូចជាស័ង្ខដែលគេខាត់ហើយបាន អាស្រ័យកថារបស់ព្រះសាស្តា មានឧស្សាហៈ

កើតហើយក្នុងបព្វជ្ជា កាលបរិស័ទចៀសចេញទៅហើយ ទើបទូលសូមបព្វជ្ជានឹងព្រះសាស្តា លុះបានឮថា ព្រះតថាគតទាំងឡាយមិនឲ្យកុលបុត្រដែលមាតាបិតាមិនទាន់អនុញ្ញាតបួស ទើបចូលទៅកាន់ផ្ទះ ញុំាងមាតាបិតាឲ្យអនុញ្ញាតដោយសេចក្ដីព្យាយាមច្រើន ដូចកុលបុត្រឈ្មោះរដ្ឋបាលជាដើម បានបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះសាស្ដាហើយ គិតថា ប្រយោជន៍អ្វីរបស់អញដោយការនៅក្នុងទីនេះ ទើបចេញអំពីក្រុងសាវត្ថី ទៅកាន់ក្រុងរាជគ្រឹះត្រាច់បិណ្ឌបាត ញុំាងកាលឲ្យកន្លងទៅហើយ ។

ថ្ងៃមួយ មាតាបិតារបស់ព្រះសុន្ទរសមុទ្ទត្ថេរនោះ ឃើញពួកកុមារដែលជាសម្លាញ់របស់លោក កំពុងលេងដោយសិរីសម្បត្តិដ៏ធំ ក្នុងថ្ងៃមហោស្រពមួយក្នុងក្រុងសាវត្ថី យំរៀបរាប់ថា ការលេងនេះ កូនរបស់អញបានដោយលំបាក ។

ក្នុងខណៈនោះ ស្រីពេស្យាម្នាក់ទៅកាន់ត្រកូលនោះ ឃើញមាតារបស់ព្រះសុន្ទរសមុទ្ទត្ថេរនោះកំពុងអង្គុយយំ ទើបសួរថា បពិត្រអ្នកម៉ែ ព្រោះហេតុអ្វីទើបអ្នកម៉ែយំ ម្ដាយរបស់ព្រះសុន្ទរសមុទ្ទត្ថេរពោលថា ខ្ញុំនឹកដល់កូនទើបយំ ស្រីពេស្យាពោលថា កូននោះនៅឯណា ស្រីនោះពោលថា បួសក្នុងសម្នាក់ភិក្ខុទាំងឡាយ ស្រីពេស្យាពោលថា បើឲ្យលោកសឹកមិនគួរឬ មាតាព្រះសុន្ទរសមុទ្ទត្ថេរនោះពោលថា គួរ តែលោកមិនប្រាថ្នាសឹក លោកចេញអំពីក្រុងសាវត្ថីនេះ ទៅកាន់ក្រុងរាជគ្រឹះ ។ ស្រីពេស្យាពោលថា បើខ្ញុំឲ្យលោកសឹកបាន អ្នកម៉ែគប្បីធ្វើដូចម្ដេចដល់ខ្ញុំ មាតាព្រះសុន្ទរសមុទ្ទត្ថេរនោះពោលថា

ខ្ញុំគប្បីឲ្យនាងជាម្ចាស់នៃទ្រព្យរបស់ត្រកូលនេះ ស្រីពេស្យាពោលថា បើដូច្នោះ សូមអ្នកម៉ែឲ្យឈ្នួលដល់ខ្ញុំ កាន់យកឈ្នួលហើយ ទៅកាន់ក្រុងរាជគ្រឹះដោយបរិវារធំ កំណត់វិថីដែលលោកត្រាច់បិណ្ឌបាតបានហើយ កាន់យកផ្ទះដែលជាទីសម្រាកមួយក្នុងទីនោះ ។ តាក់តែងអាហារដ៏ប្រណីតអំពីព្រលឹម ហើយថ្វាយភិក្ខា ក្នុងពេលព្រះថេរៈចូលទៅបិណ្ឌបាត ដោយកាលកន្លងទៅ ២-៣ ថ្ងៃ នាងក៏និមន្តថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់គង់ក្នុងទីនេះឯង ធ្វើភត្តកិច្ច ហើយទទួលយកបាត្រ លោកឲ្យបាត្រហើយ ។

គ្រានោះ ស្រីពេស្យានោះអង្គាសព្រះថេរៈដោយអាហារដ៏ប្រណីត ប្រាប់ថា បពិត្រលោកម្ចាស់ ការត្រាច់បិណ្ឌបាតក្នុងទីនេះឯងងាយស្រួលល្អ និមន្តឲ្យព្រះថេរៈគង់ឆាន់ត្រង់យ៉មុខ ២-៣ ថ្ងៃហើយ យកនំលួងលោមពួកក្មេងហើយពោលថា ពួកឯងចូរមកក្នុងពេលដែលព្រះថេរៈមកហើយ សូម្បីខ្ញុំហាម ឯងគប្បីមកក្នុងទីនេះ ហើយបាចធូលីឲ្យហុយឡើង ។

ស្អែកឡើង ពេលព្រះថេរៈឆាន់ ពួកក្មេងទាំងនោះ សូម្បីត្រូវស្រីនោះឃាត់ ក៏នៅតែបាចដីឲ្យហុយឡើង ។

ស្អែកឡើង ស្រីពេស្យាប្រាប់ថា ពួកក្មេងសូម្បីខ្ញុំឃាត់ក៏មិនស្តាប់ពាក្យរបស់ខ្ញុំ នៅតែបាចដីនោះឲ្យហុយឡើងក្នុងទីនេះបាន សូមលោកម្ចាស់គង់ខាងក្នុងផ្ទះចុះ ឲ្យលោកគង់ខាងក្នុងហើយ និមន្តឲ្យឆាន់ ២-៣ ថ្ងៃ នាងប្រមូលក្មេងមកទៀតពោលថា ពួកឯងសូម្បីខ្ញុំឃាត់ គប្បីធ្វើសំឡេងអឺងកងក្នុងពេលដែលព្រះថេរៈឆាន់ ក្មេងទាំងនោះធ្វើយ៉ាងនោះហើយ ។

ស្អែកឡើងនាងពោលថា បពិត្រលោកម្ចាស់ ក្នុងទីនេះសំឡេងអឺងកង ពន់ពេក ពួកក្មេងសូម្បីខ្ញុំហាម ក៏មិនស្តាប់ពាក្យរបស់ខ្ញុំ សូមលោកម្ចាស់គង់ ក្នុងប្រាសាទខាងលើចុះ ។ កាលព្រះថេរៈទទួលនិមន្តហើយ ធ្វើព្រះថេរៈទុក ខាងមុខ កាលឡើងទៅកាន់ប្រាសាទ បិទទ្វារទាំងឡាយបណ្តើរៗ ឡើងទៅ កាន់ប្រាសាទ ។

ព្រះថេរៈ សូម្បីជាអ្នកត្រាច់បិណ្ឌបាតតាមលំដាប់ប្រកដាវត្តយ៉ាងឧក្រិដ្ឋ ត្រូវចំណង់ក្នុងរសចងហើយ ទើបឡើងទៅកាន់ប្រាសាទជាន់ទី ៧ តាមពាក្យ របស់នាង ។

នាងឲ្យព្រះថេរៈគង់ហើយ សម្តែងមាយារបស់ស្រី លីលារបស់ស្រីដែល មកហើយយ៉ាងនេះថា ធ្វើមុខឲ្យស្រស់ថ្លា បានឮថា ស្រីរមែងទាក់បុរសដោយ ឋានៈ ៤០ គឺកាច់រាង ១ បន្ទន់ខ្លួន ១ កែក្រាយ ១ ក្រអឺមក្រអៀម ១ យកក្រចកផ្ទាត់ក្រចក ១ យកជើងជាន់ជើង ១ យកកំណាត់ឈើគូសផែនដី ១ លើកកូនក្មេងដោយខ្លួនឯង ១ ឲ្យកូនក្មេងលើកខ្លួនវិញ ១ លេងកូនក្មេង ដោយខ្លួនឯង ១ ញុំាងកូនក្មេងឲ្យលេង ១ ថើបកូនក្មេងដោយខ្លួនឯង ១ ញុំាងកូនក្មេងឲ្យថើបវិញ ១ ស៊ីខ្លួនឯង ១ ញុំាងកូនក្មេងឲ្យស៊ី ១ ឲ្យវត្ថុ ទៅកូនក្មេង ១ សុំលួងលោមយកមកវិញ ១ ធ្វើត្រាប់តាមក្មេងដែលវាធ្វើ ១ និយាយខ្លាំង ១ និយាយតិច ១ និយាយបើកចំហមាត់ ១ និយាយលាក់ លៀម ១ ធ្វើនូវនិមិត្តដោយការរាំ ច្រៀង ប្រគំ យំរាប់រៀប ម៉្រិកម្រក់ ស្អិត ស្អាង ១ សើចក្អាកក្អាយ ១ សម្លឹងសម្លក់ ១ ញាក់ចង្កេះ ១ ញុំាងទ្រព្យ

កំបាំងឲ្យកម្រើក ១ បើកបង្ហាញភ្លៅ ១ បិទភ្លៅទៅវិញ ១ បង្ហាញដោះ ១ បង្ហាញក្លៀក ១ បង្ហាញផ្ចិត ១ មិចភ្នែក ១ ញាក់ចញ្ចើម ១ ខាំបបូរមាត់ ១ លៀនអណ្តាត ១ ច្បូតសំពត់ ១ ស្លៀកសំពត់វិញ ១ រំសាយសក់ ១ បួងសក់វិញ ១ ឈរខាងមុខព្រះថេរៈនោះហើយ ពោលគាថានេះថា

ស្រីពេស្យា មានជើងជ្រលក់ហើយដោយទឹកល័ក្ត ពាក់ទ្រនាប់ជើង ពោលថា លោកម្ចាស់ជាកំលោះសម្រាប់ខ្ញុំ សូម្បីខ្ញុំជាក្រមុំសម្រាប់លោកម្ចាស់ សូម្បីយើងទាំងពីរចាស់ហើយ មានឈើច្រត់បោះទៅខាងមុខហើយ សឹមបួស ។

គ្រានោះ មហាសង្វេគកើតដល់ព្រះថេរៈថា ឱហ្ន៎ កម្មដែលអញមិនពិចារណាហើយធ្វើ ធ្ងន់ហ្ន៎ ខណៈនោះ ព្រះសាស្តាប្រថាប់គង់ក្នុងវត្តជេតពនចម្ងាយ ៤៥ យោជន៍នោះឯង ទ្រង់ឃើញហេតុនោះហើយ ទើបធ្វើការញញឹមឲ្យប្រាកដ ។

លំដាប់នោះ ព្រះអានន្ទត្ថេរទូលសួរថា បពិត្រព្រះអង្គ អ្វីហ្ន៎ ជាហេតុអ្វីហ្ន៎ ជាបច្ច័យនៃការធ្វើញញឹមឲ្យប្រាកដ ព្រះសាស្តាត្រាស់ អានន្ទ សង្គ្រាមរបស់ភិក្ខុឈ្មោះសុន្ទរសមុទ្ទ និងស្រីផ្កាមាសកំពុងប្រព្រឹត្តទៅលើប្រាសាទ ៧ ជាន់ ក្នុងក្រុងរាជគ្រឹះ ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គ ជ័យជម្នះនឹងមានដល់អ្នកណា បរាជ័យនឹងមានដល់អ្នកណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ការឈ្នះនឹងមានដល់សុន្ទរសមុទ្ទ ការចាញ់នឹងមានដល់ស្រីផ្កាមាស ដូច្នេះហើយ ទ្រង់ប្រកាសការឈ្នះរបស់ព្រះថេរៈ ប្រថាប់គង់ក្នុងវត្តជេតពន

នោះឯង ទ្រង់ផ្សាយព្រះរស្មីទៅត្រាស់ថា ម្នាលភិក្ខុ ចូរអ្នកអស់អាល័យ លះនូវកាមទាំងពីរចេញ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**យោធ កាមេ បហន្ត្វាន អនាគារោ បរិព្វជេ**
**កាមភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាមបាន តថាគតហៅបុគ្គលនោះ ដែលអស់កាមភពហើយ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះដូច្នេះថា បុគ្គលណា លះកាមទាំងពីរក្នុងលោកនេះហើយ ជាអ្នកមិនមានផ្ទះ វៀរចេញបានហើយ តថាគតហៅបុគ្គលនោះ ដែលមានកាមអស់ហើយ និងមានភពអស់ហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា ព្រះថេរៈសម្រេចអរហត្ត ហោះឡើងទៅក្នុងអាកាសដោយកម្លាំងនៃឫទ្ធិ ទម្លុះមណ្ឌលហោជាងចេញទៅហើយ សរសើរព្រះសរីរៈរបស់ព្រះសាស្តានោះឯង មកថ្វាយបង្គំព្រះសាស្តាហើយ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ព្រះសុន្ទរសមុទ្ទត្ថេរ អាស្រ័យរសដែលគប្បីដឹងដោយអណ្តាត ស្ទើរទើងខូចការណ៍ តែព្រះសាស្តាជាទីពឹងរបស់លោក ។

ព្រះសាស្តា ទ្រង់ស្តាប់កថានោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាទីពឹងរបស់សុន្ទរសមុទ្ទនោះ តែក្នុងឥឡូវនេះ ក៏មិនមែន សូម្បីក្នុង

កាលមុន តថាគតក៏ជាទីពឹងរបស់សុន្ទរសមុទ្ទនោះ ដែលជាប់ក្នុងរសតណ្ហា ហើយដូចគ្នា កាលភិក្ខុទាំងនោះអារាធនាហើយ ទ្រង់នាំអតីតនិទានមកដើម្បីប្រកាសសេចក្ដីនោះ ទ្រង់ញុំាងវាតមិគជាតកឲ្យពិស្ដារថា

ធម្មតាទ្រង់ថា ៖

ឆន្ទរាគៈដោយអាវាសទាំងឡាយ ឬដោយការស្និទ្ធស្នាល ទាំងឡាយ ជាសភាវៈលាមកជាងឆន្ទរាគៈ ដោយរសទាំង-ឡាយ មិនមានទេ ឧយ្យានបាលឈ្មោះសញ្ជ័យ បាននាំសត្វឈ្លូសដែលអាស្រ័យនៅ ព្រៃស្បាត មកកាន់អំណាច (របស់ខ្លួន) បាន ព្រោះតែរសទាំងឡាយ ។

ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ម្រឹគស្មាន់ក្នុងកាលណោះ បានមកជាសុន្ទរសមុទ្ទ ចំណែកមហាមាត្យរបស់ព្រះរាជា ដែលពោលគាថានេះហើយបានដោះលែងម្រឹគនោះទៅ គឺតថាគតនេះឯង ។ល។

## រឿងព្រះសុន្ទរសមុទ្ទត្ថេរ ចប់

---

-ក្នុងបិដកខ្មែរថា ព្រះរាជាជាអ្នកពោល ។

# រឿង ព្រះជោតិកត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះជោតិកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោធ តណ្ហំ** ជាដើម ។

អនុពីកថាក្នុងរឿងនោះ មានដូចតទៅនេះ ក្នុងអតីតកាល កុដុម្ពិកៈ ២ នាក់បងប្អូនក្នុងក្រុងពារាណសី ញុាំងជនឲ្យធ្វើចម្ការអំពៅជាច្រើន ។ ថ្ងៃមួយ ប្អូនប្រុសទៅចម្ការអំពៅ គិតថា អញនឹងឲ្យអំពៅមួយដើមដល់បងប្រុស មួយដើមជារបស់អញ ហើយចងអំពៅទាំងពីរក្នុងទីដែលកាប់ហើយ ដើម្បីកុំឲ្យរសហូរចេញ កាន់យកហើយ ។

បានឮថា ក្នុងកាលណោះ កិច្ចដោយការគាបអំពៅដោយគ្រឿងយន្ត មិនមាន ក្នុងពេលអំពៅដែលគេកាត់ត្រង់ចុង ឬគល់ហើយលើកឡើង រសរមែងហូរចេញឯង ដូចទឹកហូរចេញអំពីធម្មក្រក ដូច្នោះ ។ ក្នុងពេលដែលបុរសនោះកាន់អំពៅអំពីចម្ការដើរមក ព្រះបច្ចេកពុទ្ធនៅត្រង់ភ្នំគន្ធមាទន៍ ចេញអំពីសមាបត្តិហើយ ពិចារណាថា ថ្ងៃនេះ អាត្មានឹងធ្វើការអនុគ្រោះដល់អ្នកណាហ្ន៎ ឃើញបុរសនោះនៅក្នុងសំណាញ់ញាណ និងជ្រាបភាពដែលបុរសនោះ ជាអ្នកអាចធ្វើការសង្គ្រោះបាន ទើបកាន់យកបាត្រ និងចីវរ ហើយមកដោយឫទ្ធិ ឈរអំពីខាងមុខបុរសនោះ ។

បុរសនោះឃើញព្រះបច្ចេកពុទ្ធ មានចិត្តជ្រះថ្លា ទើបលាសំពត់ដណ្តប់លើប្រទេសដែលខ្ពស់ជាង ហើយនិមន្តឲ្យព្រះបច្ចេកពុទ្ធគង់ដោយពាក្យថា សូមនិមន្តគង់ទីនេះចុះ សូមលោកម្ចាស់បង្អោនបាត្រមកចុះ បានស្រាយចំណង

ដែលចងអំពៅ ដាក់លើបាត្រ រសហូរចេញពេញបាត្រហើយ កាលព្រះបច្ចេកពុទ្ធឆាន់រសនោះហើយ គាត់គិតថា ល្អហ្ន៎ លោកម្ចាស់របស់អញឆាន់រស បើបងប្រុសរបស់អញទារតម្លៃ អញនឹងឲ្យតម្លៃ បើឲ្យអញនាំចំណែកបុណ្យមក អញនឹងឲ្យចំណែកបុណ្យ ហើយពោលថា សូមលោកម្ចាស់បង្អោនបាត្រមកចុះ ហើយ ស្រាយអំពៅ ដើមទី ២ ប្រគេនរស ។

បុរសនោះគិតកន្លងមានប្រមាណប៉ុណ្ណេះថា បងប្រុសរបស់អញនឹងនាំអំពៅដទៃអំពីចម្ការមកទំពាស៊ី ។ ចំណែកព្រះបច្ចេកពុទ្ធ ប្រាថ្នានឹងចែករសនោះដល់ព្រះបច្ចេកពុទ្ធដទៃ ព្រោះលោកឆាន់រសអំពៅដើមដំបូងនោះ ទើបទទួលប៉ុណ្ណោះ ហើយគង់ស្ងៀម ។ បុរសនោះ ជ្រាបអាការរបស់លោកហើយ ទើបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន តាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់រសដ៏ប្រសើរនេះ ដែលខ្ញុំថ្វាយហើយ ដោយផលនៃរសដ៏ប្រសើរនេះ ខ្ញុំគប្បីសោយសម្បត្តិក្នុងទេវលោក និងមនុស្សលោក ក្នុងទីបំផុតគប្បីសម្រេចធម៌ដែលលោកម្ចាស់សម្រេចហើយនោះឯង ។ ព្រះបច្ចេកពុទ្ធក៏ពោលថា សេចក្តីប្រាថ្នាដែលអ្នកតម្កល់ទុកហើយ ចូរសម្រេចយ៉ាងនោះ ហើយធ្វើអនុមោទនាដោយគាថា ២ ថា **ឥច្ឆិតំ បត្ថិតំ តុយ្ហំ** ជាដើម ហើយអធិដ្ឋានដោយអាការដែលបុរសនោះឃើញបាន ហោះទៅកាន់ភ្នំគន្ធមាទន៍តាមអាកាស ហើយបានប្រគេនរសអំពៅដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ បុរសនោះឃើញបាដិហារ្យនោះហើយ ទៅកាន់សម្នាក់បងប្រុស កាលបងប្រុសសួរថា ឯងទៅណា ទើបប្រាប់ថា ខ្ញុំទៅមើលចម្ការអំពៅ ត្រូវបងប្រុសពោលថា ប្រយោជន៍អ្វីដោយ

បុគ្គលដូចឯងទៅចម្ការអំពៅ ឯងគួរកាន់យកអំពៅមួយដើម ឬពីរដើមមក មិនមែនឬ ក៏ឆ្លើយថា ខ្ញុំកាន់យកមកពីរដើម តែខ្ញុំឃើញព្រះបច្ចេកពុទ្ធមួយអង្គ ទើបប្រគេនអំពៅរបស់ខ្ញុំ ហើយប្រគេនទាំងអំពៅរបស់បង ដោយគិតថា អញនឹងឲ្យតម្លៃ ឬចំណែកបុណ្យ តែបងទទួលយកតម្លៃ ឬចំណែកបុណ្យ បងប្រុសពោលថា ព្រះបច្ចេកពុទ្ធធ្វើដូចម្តេច ប្អូនប្រុសពោលថា លោកឆាន់រសអំពៅខ្ញុំហើយ ក៏កាន់យករសអំពៅរបស់បង ទៅកាន់ភ្នំគន្ធមាទន៍តាមអាកាស ហើយចែកដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។

បងប្រុសនោះ កាលប្អូនកំពុងពោលនោះឯង មានសរីរៈដែលបីតិពាល់ត្រូវហើយ មិនមានចន្លោះ បានធ្វើសេចក្តីប្រាថ្នាថា ការសម្រេចធម៌ដែលព្រះបច្ចេកពុទ្ធនោះឃើញហើយនោះឯង គប្បីមានដល់អញ ប្អូនប្រុសប្រាថ្នាសម្បត្តិ ៣ យ៉ាង បងប្រុសប្រាថ្នាអរហត្ត ដោយប្រការដូច្នេះ នេះជាបុព្វកម្មរបស់ជនទាំងពីរ ។

ជនទាំងពីរនោះ តាំងនៅដល់អស់អាយុហើយ ចុតិចាកអត្តភាពនោះ កើតក្នុងទេវលោក ញុំាងពុទ្ធន្តរមួយឲ្យអស់ទៅ ក្នុងវេលាជនទាំងពីរនោះ ទៅកាន់ទេវលោកនោះឯង ព្រះសម្មាសម្ពុទ្ធព្រះនាមវិបស្សី កើតឡើងហើយ ក្នុងលោក ។

បងប្អូនទាំងពីរនោះ ឃ្លាតចាកទេវលោកហើយ បងប្រុសនៅតែជាបងប្រុស ប្អូនប្រុសនៅតែជាប្អូនប្រុស បដិសន្ធិក្នុងត្រកូលមួយនាពន្ធុមតីនគរ ។

បណ្តាក្មេងទាំងពីរនោះ មាតាបិតាបានដាក់ឈ្មោះកូនច្បងថា សេនៈ ប្អូន

ថា អបរាជិតៈ ។ កាលបងប្អូនទាំងពីរកំពុងប្រមូលកំណាប់ទ្រព្យ ក្នុងវេលាធំហើយ សេនកុដុម្ពិកៈ បានស្ដាប់សេចក្ដីប្រកាសក្នុងពន្ធមតីនគរ របស់ឧបាសកដែលឃោសនាថា ពុទ្ធរ័តន៍កើតឡើងហើយក្នុងលោក ធម្មរ័តន៍កើតឡើងហើយ ក្នុងលោក សង្ឃរ័តន៍កើតឡើងហើយ ក្នុងលោក ចូរពួកអ្នកឲ្យទាន ចូរធ្វើបុណ្យទាំងឡាយ ថ្ងៃនេះជាថ្ងៃតិថីទី ១៤ ថ្ងៃនេះជាតិថីទី ១៥ ចូរពួកអ្នកធ្វើឧបោសថ ចូរស្ដាប់ធម៌ ឃើញមហាជនថ្វាយទានក្នុងកាលមុនភត្តហើយ ទៅស្ដាប់ធម៌ក្នុងកាលក្រោយភត្ត ទើបសួរថា ពួកអ្នកទៅណា កាលមហាជនប្រាប់ថា ពួកយើងទៅកាន់សម្នាក់ព្រះសាស្ដា ដើម្បីស្ដាប់ធម៌ ទើបពោលថា ខ្ញុំក៏នឹងទៅ ហើយទៅព្រមជាមួយជនទាំងនោះ អង្គុយខាងចុងបរិស័ទ ។

ព្រះសាស្ដា ទ្រង់ជ្រាបអាធ្យាស្រ័យរបស់កុលបុត្រនោះ ទើបត្រាស់អនុបុព្វីកថា បុរសនោះស្ដាប់ធម៌របស់ព្រះសាស្ដាហើយ កើតឧស្សាហៈក្នុងបព្វជ្ជា ទើបទូលសូមបព្វជ្ជានឹងព្រះសាស្ដា ។

លំដាប់នោះ ព្រះសាស្ដាត្រាស់សួរថា ពួកញាតិដែលអ្នកគប្បីលាមានដែរឬទេ សេនកុដុម្ពិកៈពោលថា មានព្រះអង្គ ព្រះសាស្ដាត្រាស់ថា បើយ៉ាងនោះ ចូរអ្នកទៅលាហើយសឹមមក ។

កុមារទៅកាន់សម្នាក់របស់ប្អូនប្រុសហើយពោលថា ទ្រព្យសម្បត្តិណាមានក្នុងត្រកូលនេះ ទ្រព្យសម្បត្តិទាំងអស់នោះ ចូរជារបស់ឯងចុះ ប្អូនប្រុសពោលថា ចុះបងវិញ សេនកុដុម្ពិកៈពោលថា ខ្ញុំនឹងបួសក្នុងសម្នាក់របស់ព្រះ

សាស្តា ប្អូនប្រុសពោលថា បងនិយាយអ្វី ខ្ញុំកាលមាតាស្លាប់ហើយ ក៏បានបងដូចជាមាតា កាលបិតាស្លាប់ហើយ ក៏បានបងដូចជាបិតា ត្រកូលនេះមានភោគៈច្រើន បងតាំងនៅក្នុងផ្ទះនេះឯងក៏អាចធ្វើបុណ្យបាន បងកុំធ្វើយ៉ាងនោះ សេនកុដុម្ពិកៈពោលថា ខ្ញុំស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តាហើយ ខ្ញុំតាំងនៅក្នុងកណ្តាលផ្ទះមិនអាចបំពេញធម៌នោះបាន ខ្ញុំនឹងបួសឲ្យបាន ចូរឯងត្រឡប់ចុះ ។ សេនៈញ៉ាំងប្អូនប្រុសឲ្យត្រឡប់ដោយអាការយ៉ាងនោះហើយ បានចូលកាន់បព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះសាស្តាហើយ ក្នុងកាលមិនយូរប៉ុន្មានក៏សម្រេចអរហត្ត ។ ចំណែកប្អូនប្រុសគិតថា អញនឹងធ្វើសក្ការៈដល់បព្វជិតដែលជាបងប្រុស ទើបថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ថ្វាយបង្គំបងប្រុសហើយពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ធ្វើនូវការរលាស់ចេញចាកភពនៃខ្លួនបានហើយ ចំណែកខ្ញុំ ជាអ្នកជាប់ជំពាក់ដោយកាមគុណ ៥ មិនអាចចេញបួសបាន សូមលោកម្ចាស់ប្រាប់បុញ្ញកម្មដ៏ធំដែលសមគួរដល់ខ្ញុំដែលតាំងនៅក្នុងផ្ទះនេះឯង ។ លំដាប់នោះ ព្រះថេរៈពោលនឹងប្អូនប្រុសនោះថា សាធុ ឯងជាបណ្ឌិត ចូរឯងសាងព្រះគន្ធកុដិ សម្រាប់ព្រះសាស្តាចុះ ។

ប្អូនប្រុសនោះទទួលថា សាធុ ហើយញ៉ាំងជនឲ្យនាំឈើផ្សេងៗ មកហើយឲ្យចាំងដើម្បីប្រយោជន៍ដល់ទព្វសម្ភារៈទាំងឡាយ មានសសរជាដើម ឲ្យធ្វើសសរទាំងអស់ដាំដោយកែវ ៧ ប្រការ គឺមួយដើមដាំដោយមាស មួយដើមដាំដោយប្រាក់ មួយដើមដាំដោយកែវមណីជាដើម ហើយឲ្យសាងព្រះគន្ធកុដិ

ដោយសសរទាំងនោះ ឲ្យប្រក់ដោយក្បឿងសម្រាប់ប្រក់ រំលេចដោយកែវ ៧ ប្រការដូចគ្នា ។

ក្នុងពេលសាងព្រះគន្ធកុដិនោះឯង ក្មួយប្រុសឈ្មោះអបរាជិតៈ ដែលមានឈ្មោះដូចខ្លួននោះឯង ចូលទៅរកអបរាជិតកុដុម្ពិកៈនោះហើយ ពោលថា ខ្ញុំនឹងសាង សូមលោកឲ្យចំណែកបុណ្យដល់ខ្ញុំចុះ បុរសនោះពោលថា នែបា ខ្ញុំមិនឲ្យ ខ្ញុំនឹងសាងមិនឲ្យទូទៅដល់ជនដទៃ ។

ក្មួយប្រុសនោះ អង្វរជាច្រើន កាលមិនបានចំណែកបុណ្យ ទើបគិតថា ការដែលអញបានកុញ្ជរសាលាខាងមុខព្រះគន្ធកុដិ គួរ ដូច្នេះហើយ ទើបសាងកុញ្ជរសាលាដែលសម្រេចដោយកែវ ៩ ប្រការ ។ បុរសនោះបានមកជាមេណ្ឌកសេដ្ឋី ក្នុងពុទ្ធុប្បាទកាលនេះ ។

ក្នុងបន្ទុះបង្អួចធំ ៣ បន្ទុះដែលសម្រេចដោយកែវ ៧ ប្រការមានហើយ ក្នុងព្រះគន្ធកុដិ អបរាជិតគហបតី ឲ្យសាងស្រះបោក្ខរណី ៣ ដែលបូកលាបដោយបាយអខាងក្រោម ត្រង់សន្ទុះបង្អួចទាំងនោះឲ្យពេញដោយគន្ធជាតិ ៤ យ៉ាង ហើយឲ្យដាំដើមផ្កាដែលមានពណ៌ ៥ ឲ្យសំយុងបណ្តាកែវ ៧ ប្រការ កែវដែលគួរដល់ការសំយុង បានកាន់យកកែវក្រៅអំពីនេះ ទាំងអស់នោះឯង រោយជុំវិញព្រះគន្ធកុដិ ស្មើក្បាលជង្គង់ ញុំាងបរិវេណឲ្យពេញហើយ ។

គហបតីឈ្មោះអបរាជិតៈ ញុំាងព្រះគន្ធកុដិឲ្យសម្រេច ដោយអាការយ៉ាងនេះហើយ ទើបចូលទៅរកព្រះថេរៈដែលជាបងប្រុសសាកសួរថា បពិត្រលោកម្ចាស់ ព្រះគន្ធកុដិសម្រេចហើយ ខ្ញុំទន្ទឹងការប្រើប្រាស់ព្រះគន្ធកុដិនោះ

បានឮថា បុណ្យជាច្រើនរមែងមានព្រោះការប្រើប្រាស់ ។

ព្រះថេរៈនោះ ចូលទៅគាល់ព្រះសាស្ដាក្រាបទូលថា បពិត្រព្រះអង្គ បានឮថា កុដុម្ពិកៈនេះឲ្យសាងព្រះគន្ធកុដិដើម្បីព្រះអង្គ ឥឡូវនេះ កុដុម្ពិកៈនោះទន្ទឹងការប្រើប្រាស់ ។ ព្រះសាស្ដាក្រោកចាកអាសនៈហើយ យាងទៅកាន់ទីចំពោះមុខព្រះគន្ធកុដិ ទតគំនររតនៈដែលរោយជុំវិញព្រះគន្ធកុដិ បានប្រថាប់ឈរហើយត្រង់ខ្លោងទ្វារ កាលកុដុម្ពិកៈនោះក្រាបទូលថា បពិត្រព្រះអង្គ ការរក្សានឹងមានដល់ខ្ញុំព្រះអង្គឯង សូមទ្រង់យាងចូលចុះ ព្រះសាស្ដាបានយាងចូលហើយ ។

កុដុម្ពិកៈ ក៏តាំងការរក្សាដោយជុំវិញ បញ្ជាមនុស្សទាំងឡាយថា នែបាចូរពួកអ្នកហាមជនទាំងឡាយ ដែលកាន់យករតនៈដោយថ្នក់ ឬដោយល្អីនិងស្បោងជាដើមទៅ តែកុំហាមជនដែលកាន់យកដោយដៃ ខាងក្នុងនគរ ក៏ឲ្យប្រាប់ថា រតនៈ ៧ ប្រការ ខ្ញុំរោយហើយត្រង់បរិវេណព្រះគន្ធកុដិ មនុស្សក្រីក្រទាំងឡាយដែលស្ដាប់ធម៌ ក្នុងសម្នាក់ព្រះសាស្ដាហើយទៅ ចូរកាន់យកពេញដៃទាំងពីរ មនុស្សទាំងឡាយដល់នូវសេចក្ដីសុខហើយ ក៏ចូរកាន់យកដោយដៃនោះឯង ។

បានឮថា គាត់គិតយ៉ាងនេះថា ជនទាំងឡាយអ្នកមានសទ្ធា បំណងនឹងស្ដាប់ធម៌មុន ទើបទៅនោះឯង ចំណែកអ្នកមិនមានសទ្ធា ទៅដោយការចង់បានក្នុងទ្រព្យ ស្ដាប់ធម៌ហើយនឹងផុតចាកទុក្ខបាន ព្រោះហេតុនោះ ទើបគាត់ឲ្យប្រាប់យ៉ាងនោះ ដើម្បីសង្គ្រោះជន ។

មហាជនកាន់យករតនៈទាំងឡាយ តាមកំណត់ដែលគេប្រាប់ហើយនោះឯង កាលរតនៈដែលគេរោយមួងអស់ហើយ ទើបឲ្យរោយរឿយៗ ស្មើក្បាលជង្គង់អស់ ៣ ដង ។ មួយវិញទៀត គាត់ដាក់កែវមណីដែលមានតម្លៃមិនមានប្រមាណប៉ុនផ្លែឪឡឹក ទៀបបាទមូលរបស់ព្រះសាស្តា ។

បានឮថា គាត់បានគិតយ៉ាងនេះថា ឈ្មោះថាការឆ្អែតនឹងមិនមានដល់ជនទាំងឡាយ ដែលសម្លឹងមើលរស្មីនៃកែវមណី មួយអន្លើដោយរស្មីដែលមានពណ៌ដូចមាស ដែលផ្សាយចេញអំពីសរីរៈរបស់ព្រះសាស្តា ព្រោះដូច្នោះទើបគាត់ធ្វើយ៉ាងនោះ សូម្បីមហាជនក៏មើលមិនឆ្អែតឡើយ ។

សម័យថ្ងៃមួយ ព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់គិតថា បានឮថា កែវមណីមានតម្លៃច្រើន ដែលកុដុម្ពិកៈនោះដាក់ទៀបបាទមូលនៃព្រះសាស្តា អញនឹងលួចកែវមណីនោះ ទើបទៅកាន់វិហារ ចូលទៅចន្លោះមហាជនដែលមកហើយដើម្បីថ្វាយបង្គំព្រះសាស្តា ។ កុដុម្ពិកៈកំណត់បានថា ព្រាហ្មណ៍នេះមានបំណងនឹងកាន់យកកែវមណី ដោយអាការនៃការចូលទៅរបស់ព្រាហ្មណ៍នោះឯង ទើបគិតថា ឱហ្ន៎ ព្រាហ្មណ៍មិនគួរកាន់យក សូម្បីព្រាហ្មណ៍នោះ ដាក់ដៃទៀបបាទមូលហាក់ដូចថ្វាយបង្គំព្រះសាស្តា កាន់យកកែវមណីលាក់ក្នុងប្រមូរសំពត់ចៀសចេញទៅហើយ ។ កុដុម្ពិកៈមិនអាចញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រាហ្មណ៍នោះបាន ។ ក្នុងកាលចប់ធម្មកថា កុដុម្ពិកៈនោះចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ រតនៈ ៧ ប្រការ ខ្ញុំព្រះអង្គរោយជុំវិញព្រះគន្ធកុដិអស់ ៣ ដង ដោយជួរត្រឹមក្បាលជង្គង់ កាលជនទាំងឡាយកាន់យករតនៈទាំងនោះ

ឈ្មោះថាការអាឃាតមិនមានដល់ខ្ញុំព្រះអង្គឡើយ ចិត្តរឹងរឹតតែជ្រះថ្លារឿយៗ តែថ្ងៃនេះខ្ញុំព្រះអង្គគិតថា ឱហ្ន៎ ព្រាហ្មណ៍នេះមិនគួរកាន់យកកែវមណី កាលព្រាហ្មណ៍នោះ កាន់យកកែវមណីទៅហើយ ទើបមិនអាចញុាំងចិត្តឲ្យជ្រះថ្លាបាន ។

ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់កុដុម្ពិកៈនោះហើយត្រាស់ថា ឧបាសកអ្នកមិនអាចធ្វើរបស់មាននៃខ្លួន ឲ្យជារបស់ដែលជនដទៃ គប្បីនាំទៅមិនបានមិនមែនឬ ដូច្នេះហើយ ទ្រង់បានប្រទានន័យហើយ ។ កុដុម្ពិកៈនោះតាំងនៅក្នុងន័យដែលព្រះសាស្តាប្រទានហើយ ថ្វាយបង្គំព្រះសាស្តា បានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ព្រះរាជាក្តី ចោរក្តី ទោះបីរាប់រយ ឈ្មោះថាអាចកាន់យកកំណាប់នៃខ្ញុំព្រះអង្គ សូម្បីត្រឹមតែអំបោះជាយសំពត់ កុំបីមានតាំងអំពីថ្ងៃនេះជាដើមទៅ ភ្លើងក៏កុំឆេះទ្រព្យខ្ញុំព្រះអង្គឡើយ ទឹកក៏កុំលិច ។ ព្រះមានព្រះភាគទ្រង់ធ្វើអនុមោទនាដល់កុដុម្ពិកៈនោះថា សេចក្តីប្រាថ្នាដែលអ្នកប្រាថ្នាយ៉ាងនោះ ចូរសម្រេចចុះ ។ កុដុម្ពិកៈនោះ កាលធ្វើការឆ្លងព្រះគន្ធកុដិ ថ្វាយមហាទានដល់ភិក្ខុ ៦៨ សែនអង្គ ខាងក្នុងវិហារនោះឯង អស់កាល ៩ ខែក្នុងកាលជាទីបំផុត បានថ្វាយត្រៃចីវរដល់ភិក្ខុគ្រប់រូប ។ សំពត់សាដកសម្រាប់ចីវររបស់ភិក្ខុបួសថ្មីក្នុងសង្ឃ មានតម្លៃដល់មួយពាន់ ។

កុដុម្ពិកៈនោះ ធ្វើបុណ្យទាំងឡាយ ដរាបដល់អស់អាយុយ៉ាងនេះហើយ ចុតិចាកអត្តភាពនោះកើតក្នុងទេវលោក អន្ទោលទៅក្នុងទេវលោក និងមនុស្សលោក អស់កាលមានប្រមាណប៉ុណ្ណោះ ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុង

ត្រកូលសេដ្ឋីមួយក្នុងក្រុងរាជគ្រឹះ នៅក្នុងផ្ទៃមាតាអស់ ៩ ខែកន្លះ ។ ក្នុងថ្ងៃដែលកុដុម្ពិកៈកើត អាវុធទាំងឡាយក្នុងនគរទាំងមូលភ្លឺរុងរឿងហើយ អាភរណៈទាំងឡាយ ដែលពាក់ត្រង់កាយជនទាំងពួងភ្លឺរុងរឿងបញ្ចេញរស្មីហើយ ព្រះនគររុងរឿងជាសភាពតែមួយ សេដ្ឋីក៏បានទៅកាន់ទីបម្រើព្រះរាជាអំពីព្រលឹម កាលនោះ ព្រះរាជាត្រាស់សួរសេដ្ឋីនោះថា ថ្ងៃនេះសព្វាវុធទាំងឡាយ រុងរឿងហើយ ព្រះនគរក៏រុងរឿងតែមួយ អ្នកដឹងហេតុក្នុងរឿងនេះដែរឬទេ សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំដឹង ព្រះរាជាត្រាស់សួរថា តើដោយហេតុអ្វី សេដ្ឋីពោលថា ទាសៈរបស់ព្រះអង្គ កើតក្នុងផ្ទះរបស់ទូលបង្គំ ការរុងរឿងនោះ មានហើយដោយតេជះនៃបុណ្យរបស់ទារកនោះឯង ព្រះរាជាត្រាស់ថា ទារកនោះជាចោរទេដឹង សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព សេចក្តីនោះមិនមាន សត្វមានបុណ្យបានធ្វើអភិនីហារមកហើយ ។ ព្រះរាជាទ្រង់តាំងទ្រព្យថ្លៃចិញ្ចឹម មួយថ្ងៃមួយពាន់ ដោយព្រះតម្រាស់ថា បើដូច្នោះ អ្នកចិញ្ចឹមទារកនោះឲ្យល្អ ទើបគួរ នេះជាថ្លៃទឹកដោះសម្រាប់ទារកនោះ ក្នុងថ្ងៃតាំងឈ្មោះទើបជនទាំងឡាយឲ្យឈ្មោះថាជោតិកៈនោះឯង ព្រោះព្រះនគរទាំងមូលរុងរឿងតែមួយ ។

សម័យតមកក្នុងកាលដែលកុមារនោះធំហើយ កាលផ្ទៃដីដែលគេជម្រះដើម្បីសង់ផ្ទះ សក្កៈពិភពសម្តែងអាការក្តៅហើយ ។ សក្កៈទ្រង់ពិចារណាថាហេតុអ្វីហ្ន៎ ទ្រង់ជ្រាបថាជនទាំងឡាយកំពុងសាងផ្ទះដើម្បីជោតិកៈ ទ្រង់ត្រិះរិះថា ជោតិកៈនេះ នឹងមិននៅក្នុងផ្ទះដែលជនទាំងនោះធ្វើហើយ អញគួរទៅក្នុង

ទីនោះ ហើយទ្រង់យាងទៅទីនោះដោយភេទជាជាងឈើត្រាស់ថា ពួកអ្នកធ្វើអ្វី ពួកជនពោលថា ពួកខ្ញុំជម្រះទីដើម្បីសង់ផ្ទះសម្រាប់ជោតិកៈ សក្កទេវរាជត្រាស់ថា ចូរពួកអ្នកចៀសចេញទៅ ជោតិកៈនេះ មិននៅក្នុងផ្ទះដែលពួកអ្នកធ្វើ ហើយទ្រង់ទតមើលភូមិប្រទេសប្រមាណ ១៦ ករីស ភូមិប្រទេសនោះក្លាយជាផ្ទៃដីដែលស្មើក្នុងរំពេចនោះឯង ដូចមណ្ឌលកសិណ ហើយទ្រង់ត្រិះរិះទៀតថា ចូរប្រាសាទ ៧ ជាន់សម្រេចដោយកែវ ៧ ប្រការ ជ្រែកផែនដីផុសឡើងក្នុងទីនេះ ហើយទតមើលប្រាសាទ ឃើញប្រាសាទបែបនោះផុសឡើងក្នុងខណៈនោះឯង ។ សក្កទេវរាជត្រិះរិះទៀតថា ចូរកំពែង ៧ ជាន់សម្រេចដោយកែវ ៧ ប្រការ ផុសឡើងជុំវិញប្រាសាទនេះ ហើយទតមើលកំពែងបែបនោះផុសឡើងហើយ ។ កាលនោះ សក្កៈត្រិះរិះថា ចូរដើមកប្បព្រឹក្សទាំងឡាយ ផុសឡើងក្នុងទីបំផុតជុំវិញកំពែងទាំងនោះ ហើយទតមើលដើមកប្បព្រឹក្សទាំងឡាយបែបនោះ ផុសឡើងហើយ សក្កៈត្រិះរិះថា កំណាប់ទ្រព្យ ៤ រណ្តៅ ចូរផុសឡើងត្រង់ជ្រុងទាំង ៤ នៃប្រាសាទ ហើយទតមើលវត្ថុគ្រប់យ៉ាង មានយ៉ាងនោះដូចគ្នា ។

បណ្តាកំណាប់ទ្រព្យទាំងឡាយ កំណាប់មួយ មានប្រមាណមួយយោជន៍ កំណាប់មួយមានប្រមាណ ៣ គាវុត កំណាប់មួយ មានប្រមាណកន្លះយោជន៍ កំណាប់មួយមានប្រមាណ ១ គាវុត ។ ត្រង់ខ្លោងទ្វារទាំង ៧ យក្ខ ៧ នាក់ធ្វើការរក្សាហើយ ក្នុងខ្លោងទ្វារទីមួយ យក្ខឈ្មោះយមមោលី មួយអន្លើដោយយក្ខមួយពាន់ ជាបរិវាររបស់ខ្លួន ធ្វើការរក្សាហើយ ត្រង់ខ្លោងទ្វារទី ២

យក្ខឈ្មោះឧប្បល មួយអន្លើដោយយក្ខជាបរិវារ ២ ពាន់ធ្វើការរក្សាហើយ ត្រង់ខ្លោងទ្វារទី ៣ យក្ខឈ្មោះវជិរៈ មួយអន្លើដោយយក្ខដែលជាបរិវារ ៣ ពាន់ ធ្វើការរក្សាហើយ ត្រង់ខ្លោងទ្វារទី ៤ យក្ខឈ្មោះវជិរពាហុ មួយអន្លើ ដោយយក្ខជាបរិវារ ៤ ពាន់ ធ្វើការរក្សាហើយ ត្រង់ខ្លោងទ្វារទី ៥ យក្ខឈ្មោះសកដៈ មួយអន្លើដោយយក្ខជាបរិវារ ៥ ពាន់រក្សាហើយ ត្រង់ខ្លោងទ្វារទី ៦ យក្ខឈ្មោះសកដត្ថៈ មួយអន្លើដោយយក្ខដែលជាបរិវារ ៦ ពាន់ រក្សាហើយ ត្រង់ខ្លោងទ្វារទី ៧ យក្ខឈ្មោះទិសាមុខៈ មួយអន្លើដោយយក្ខជាបរិវារ ៧ ពាន់ រក្សាហើយ ។ ទាំងខាងក្នុង និងខាងក្រៅនៃប្រាសាទ មានការរក្សាយ៉ាងមាំទាំហើយ ដោយប្រការដូច្នេះ ។

ព្រះរាជាព្រះនាមពិម្ពិសារ ទ្រង់ឮថាប្រាសាទ ៧ ជាន់ សម្រេចដោយកែវ ៧ ប្រការ ផុសឡើងហើយដើម្បីជោតិកៈ កំពែង ៧ ជាន់ ខ្លោងទ្វារ ៧ កំណប់ទ្រព្យ ៤ ផុសឡើងហើយដូចគ្នា ទ្រង់បញ្ជូនឆត្រតំណែងសេដ្ឋីទៅឲ្យហើយ កុមារបានឈ្មោះថា ជោតិកសេដ្ឋី ស្រីដែលមានបុញ្ញកម្មបានធ្វើហើយជាមួយជោតិកសេដ្ឋីនោះ កើតហើយក្នុងឧត្តរកុរុទ្វីប ។

កាលនោះ ទេវតានាំនាងមកអំពីឧត្តរកុរុទ្វីបនោះហើយ ឲ្យអង្គុយក្នុងបន្ទប់ដ៏មានសិរី ។ ស្រីនោះកាលមក កាន់យកនាឡិអង្ករ ១ និងដុំថ្មដែលមានពន្លឺ ៣ ដុំមក ភត្តរបស់ជនទាំងពីរនោះ មានហើយដោយនាឡិអង្ករនោះឯងរហូតអស់ជីវិត ។

បានឮថា បើជនទាំងនោះបំណងនឹងញុំាងរទេះមួយរយ ឲ្យពេញដោយ

អង្ករ រទេះមួយរយក៏គង់ប្រាកដជានាឡិ ដែលពេញដោយអង្ករនោះឯង ក្នុងពេលចម្អិនកគ្គ ជនទាំងនោះដាក់អង្ករក្នុងឆ្នាំង ហើយដាក់ខាងលើដុំថ្មនោះ ដុំថ្មក៏ឆេះឡើងខណៈនោះឯង កាលកគ្គឆ្អិនហើយរមែងរលត់ទៅ ពួកជននោះដឹងថាកគ្គឆ្អិនហើយដោយសញ្ញានោះឯង ។ ក្នុងពេលស្លរបស់ដែលគួរស្លជាដើមក៏ន័យនេះដូចគ្នា ។ ជនទាំងពីររមែងចម្អិនអាហារដោយថ្មដែលឆេះឯងដោយអាការយ៉ាងនេះ ជនទាំងនោះ រមែងនៅដោយពន្លឺនៃកែវមណី មិនស្គាល់ពន្លឺរបស់ភ្លើង ឬប្រទីបឡើយ ។

បានឮថា សម្បត្តិរបស់ជោតិកសេដ្ឋីបែបនោះ បានប្រាកដពេញជម្ពូទ្វីបទាំងមូលហើយ មហាជនទឹមរទេះជាដើមមកដើម្បីមើល ។

ជោតិកសេដ្ឋី ឲ្យចម្អិនកគ្គដោយស្រូវសាលី ដែលនាំមកអំពីឧត្តរកុរុទ្វីបហើយឲ្យដល់ជនទាំងឡាយដែលមកហើយប្រាប់ថា ចូរជនទាំងឡាយកាន់យកសំពត់ ចូរកាន់យកគ្រឿងប្រដាប់អំពីដើមកប្បព្រឹក្សទាំងឡាយ ហើយឲ្យបើកមាត់រណ្ដៅទ្រព្យ មានប្រមាណ ១ គាវុត ហើយប្រាប់ថា ចូរជនទាំងឡាយកាន់យកទ្រព្យល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។ កាលជនទាំងឡាយនៅក្នុងជម្ពូទ្វីបទាំងមូលកាន់យកទ្រព្យទៅ មាត់នៃកំណាប់ទ្រព្យ មិនបានស្រកចុះសូម្បីត្រឹមមួយធ្នាប់ ។ បានឮថា នុ៎ះជាផលនៃរតនៈដែលគាត់រោយ ធ្វើឲ្យជាខ្សាច់ក្នុងបរិវេណព្រះគន្ធកុដិ ។

កាលមហាជនកាន់យកអាភរណៈ និងទ្រព្យតាមប្រាថ្នាទៅយ៉ាងនោះ ព្រះបាទពិម្ពិសារ មានបំណងនឹងទតប្រាសាទរបស់ជោតិកសេដ្ឋីនោះ កាលមហា-

ជនមក ទើបមិនបានឱកាស ។ ក្នុងកាលតមក កាលពួកមនុស្សថយចុះ ព្រោះកាន់យកវត្ថាភរណៈ និងទ្រព្យតាមសេចក្តីត្រូវការទៅហើយ ទើបព្រះរាជាត្រាស់នឹងបិតារបស់ជោតិកៈថា យើងមានបំណងនឹងទតប្រាសាទកូនរបស់អ្នក ឪពុកជោតិកៈនោះក្រាបទូលថា សាធុ ព្រះសម្មតិទេព ហើយទៅប្រាប់ដល់កូនថា នែបា ព្រះរាជាបំណងនឹងទតប្រាសាទរបស់ឯង ជោតិកៈពោលថា សាធុ លោកឪពុក សូមទ្រង់យាងមកចុះ ។

ព្រះរាជាបានយាងទៅក្នុងទីនោះ មួយអន្លើដោយរាជបរិវារជាច្រើន ។ ទាសីបោសសម្អាតសំរាមត្រង់ខ្លោងទ្វារទីមួយ បានថ្វាយដៃដល់ព្រះរាជា ព្រះរាជាទ្រង់ខ្មាសដោយសម្គាល់ថា ជាភរិយារបស់សេដ្ឋី ទ្រង់មិនដាក់ព្រះហស្តត្រង់ដៃរបស់នាង ។ ព្រះរាជាទ្រង់សម្គាល់ទាសីក្នុងខ្លោងទ្វារដ៏សេសទាំងឡាយថាជាភរិយារបស់សេដ្ឋីយ៉ាងនោះ ទើបទ្រង់មិនដាក់ព្រះហស្ត ត្រង់ដៃរបស់ទាសីទាំងនោះ ។

ជោតិកសេដ្ឋីមកទទួលព្រះរាជា ថ្វាយបង្គំហើយ នៅអំពីខាងខ្នងក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់យាងខាងមុខចុះ ផែនដីដែលប្រដាប់ដោយកែវមណី រមែងប្រាកដដល់ព្រះរាជា ដូចជ្រោះជម្រៅមួយរយជួរបុរស ព្រះរាជាសម្គាល់ថា ជោតិកៈនេះជីកអណ្តូង ដើម្បីចាប់ទ្រង់ ទើបមិនអាចយាងទៅបាន ។

ជោតិកៈក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះមិនមែនអណ្តូង សូមទ្រង់យាងមកខាងក្រោយទូលបង្គំចុះ ហើយនាំដំណើរព្រះរាជា ។

ព្រះរាជាទ្រង់ជាន់ក្នុងទីដែលជាតិក:នោះជាន់ហើយ ទ្រង់ទតប្រាសាទ តាំងអំពីជាន់ក្រោមរហូតដល់ជាន់លើ ។ ក្នុងកាលនោះ ព្រះរាជកុមារព្រះនាម អជាតសត្តុ ទ្រង់ចាប់អង្គុលីរបស់ព្រះបិតាយាងទៅ ទ្រង់ព្រះតម្រិះថា ឱ បិតារបស់អញជាអន្ធពាល គហបតីគង់នៅក្នុងប្រាសាទ ដែលធ្វើដោយកែវ ៧ ប្រការ បិតារបស់អញសូម្បីជាព្រះរាជា គង់ប្រថាប់នៅក្នុងព្រះរាជមន្ទីរ ដែលធ្វើដោយឈើ ឥឡូវនេះ បើអញបានជាព្រះរាជាហើយ នឹងមិនឲ្យគហបតី នេះ នៅក្នុងប្រាសាទនេះ ។ កាលព្រះរាជាកំពុងឡើងកាន់ប្រាសាទជាន់ខាង លើនោះឯង ជាពេលសោយព្រះក្រយាហារព្រឹក ព្រះរាជាត្រាស់ហៅសេដ្ឋីមក ត្រាស់ថា សេដ្ឋី ពួកយើងនឹងបរិភោគអាហារព្រឹកក្នុងទីនេះឯង សេដ្ឋីពោលថា បពិត្រព្រះសម្មតិទេព ទូលបង្គំក៏ជ្រាប ព្រះក្រយាហារសម្រាប់ព្រះសម្មតិ-ទេព ទូលបង្គំបានត្រៀមហើយ ។

ព្រះរាជាទ្រង់ស្រង់ដោយទឹកក្រអូប ១៦ ក្អម ហើយប្រថាប់គង់លើ បល្ល័ង្ក ដែលជាទីអង្គុយរបស់សេដ្ឋីនោះឯង ដែលគេតាក់តែងហើយក្នុង មណ្ឌប ជាទីអង្គុយរបស់សេដ្ឋី ដែលធ្វើដោយកែវ ។

គ្រានោះ ពួកបុរសថ្វាយទឹកសម្រាប់លាងព្រះហស្តដល់ព្រះរាជា ហើយ ដួសបាយសអំពីភាជន:នោះ ដែលមានតម្លៃមួយសែនដាក់ត្រង់ព្រះភក្ត្រ ព្រះ រាជាទ្រង់ផ្តើមនឹងសោយដោយសម្គាល់ថាជាភោជន សេដ្ឋីក្រាបទូលថា បពិត្រ ព្រះសម្មតិទេព នេះមិនមែនភោជន នេះជាបាយសសើម ពួកបុរសដួសភោជន ដាក់ភាជន:ដទៃ ហើយដាក់លើភាជន:មុន ។ បានឮថា ការបរិភោគភោជន

នោះ ដោយកម្តៅដែលផ្សាយឡើង អំពីកាជនៈបាយសសើមនោះ ជាហេតុនាំមកនូវការសប្បាយ ។ ព្រះរាជាកាលសោយភោជន ដែលមានរសឆ្ងាញ់ ទ្រង់មិនដឹងប្រមាណ ។ លំដាប់នោះ សេដ្ឋីថ្វាយបង្គំព្រះរាជាហើយ ផ្គងអញ្ជលី ក្រាបទូលថា បពិត្រព្រះអង្គ សោយប៉ុណ្ណេះល្មម ទ្រង់មិនអាចឲ្យភោជនដែលក្រៃលែងជាងនេះរលាយបានឡើយ ។ ពេលនោះ ព្រះរាជាត្រាស់ថា គហបតី អ្នកទើសទាល់ឬ ទើបនិយាយដល់កត្តរបស់ខ្លួន សេដ្ឋីទូលថា បពិត្រព្រះអង្គ មិនមែនដូច្នោះឡើយ ព្រោះភត្តដើម្បីពួកពលរបស់ព្រះអង្គទាំងអស់ ក៏បែបនេះឯង សម្ម ក៏សម្មនេះ តែខ្ញុំព្រះអង្គខ្លាចចំពោះការវិនាសយស ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី សេដ្ឋីទូលថា បើហេតុត្រឹមតែធ្ងន់នៃព្រះកាយ គប្បីមានដល់ព្រះសម្មតិទេពសោត ទូលបង្គំខ្លាចចំពោះពាក្យថា ម្សិលមិញនេះ ព្រះរាជាសោយក្នុងផ្ទះរបស់សេដ្ឋី សេដ្ឋីគង់នឹងធ្វើអ្វីមួយថ្វាយពិត ព្រះរាជាត្រាស់ថា បើយ៉ាងនោះ ចូរនាំភត្តទៅ ហើយយកទឹកមក ។ ក្នុងពេលស្រេចភត្តកិច្ចរបស់ព្រះរាជា រាជបរិវារទាំងអស់ក៏បរិភោគភត្តនោះឯង ។

ព្រះរាជាប្រថាប់គង់សន្ទនាប្រារព្ធដល់សេចក្តីសុខ ត្រាស់ហៅសេដ្ឋីមកហើយត្រាស់ថា ភរិយារបស់អ្នកក្នុងផ្ទះនេះមិនមានឬ សេដ្ឋីទូលថា បពិត្រព្រះអង្គ មាន ព្រះរាជាត្រាស់ថា នាងនៅឯណា សេដ្ឋីទូលថា នាងអង្គុយក្នុងបន្ទប់ដ៏មានសិរី មិនដឹងថា ព្រះសម្មតិទេពយាងមកទេ ។

ព្រះរាជា មួយអន្លើដោយរាជបរិវារ យាងមកអំពីព្រលឹមក៏ពិត តែនាងក៏មិនដឹងថា ទ្រង់យាងមក ។ លំដាប់នោះ សេដ្ឋីដឹងថា ព្រះរាជាមានបំណង

ទតកិរិយារបស់ខ្លួន ទើបចូលទៅកាន់សម្នាក់របស់នាងហើយប្រាប់ថា ព្រះរាជាយាងមកហើយ ការដែលនាងគាល់ព្រះរាជាមិនគួរឬ ។

កំពុងដេកនោះឯងនាងពោលថា នៃអ្នក ឈ្មោះថាព្រះរាជានោះដូចម្តេច កាលសេដ្ឋីប្រាប់ថា ជនដែលជាធំរបស់ពួកយើង ឈ្មោះថាព្រះរាជា ទើបប្រាប់ភាពដែលខ្លួនជាអ្នកមានចិត្តមិនត្រេកអរពោលថា ពួកយើងសូម្បីបុគ្គលជាធំឈ្មោះថា ធ្វើបុញ្ញកម្មទាំងឡាយមិនល្អហ្ន៎ ពួកយើងធ្វើបុញ្ញកម្មទាំងឡាយដោយមិនមានសទ្ធា ទើបដល់នូវសម្បត្តិកើតហើយក្នុងទីរបស់ជនដទៃ ដែលជាធំ ទានជារបស់ដែលយើងទាំងឡាយមិនជឿហើយឲ្យពិត នេះជាផលរបស់ទាននោះ ហើយពោលថា នៃអ្នក ឥឡូវនេះ ខ្ញុំនឹងធ្វើដូចម្តេច សេដ្ឋីពោលថា ចូរនាងកាន់យកផ្តិតស្លឹកត្នោត មកបក់ថ្វាយព្រះរាជា កាលនាងកាន់ផ្តិតស្លឹកត្នោតមកបក់ថ្វាយព្រះរាជា ខ្យល់ក្លិននៃព្រះភូសាសម្រាប់ជូតសីសៈរបស់ព្រះរាជា បានជួលមកបះភ្នែករបស់នាង ។ លំដាប់នោះ តំណក់នៃទឹកភ្នែកហូរចេញអំពីភ្នែករបស់នាង ព្រះរាជាទតឃើញអាការនោះ ទើបត្រាស់នឹងសេដ្ឋីថា មហាសេដ្ឋី ធម្មតាមាតុគ្រាមមានការដឹងតិច ប្រហែលជាយំព្រោះខ្លាចថា ព្រះរាជាគប្បីកាន់យកសម្បត្តិរបស់ប្តីអញ ចូរអ្នកលួងលោមនាង យើងមិនត្រូវការដោយសម្បត្តិរបស់អ្នកទេ សេដ្ឋីពោលថា បពិត្រព្រះសម្មតិទេព នាងមិនបានយំ ព្រះរាជាត្រាស់ថា បើដូច្នោះ នុ៎ះជាអ្វី សេដ្ឋីទូលថា ទឹកភ្នែករបស់នាងហូរចេញមកហើយ ព្រោះចំហាយក្លិននៃព្រះភូសាសម្រាប់ជូតរបស់ព្រះអង្គ ព្រោះថា កិរិយារបស់ទូលបង្គំនេះមិនធ្លាប់ឃើញ

ពន្លឺប្រទីប ពន្លឺភ្លើង រមែងបរិភោគ អន្ធយ និងដេក ដោយពន្លឺរបស់កែវមណី ប៉ុណ្ណោះ ចំណែកព្រះសម្មតិទេព នឹងប្រថាប់គង់ដោយពន្លឺនៃប្រទីប ព្រះរាជា ត្រាស់ថា ត្រូវហើយសេដ្ឋី សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព បើដូច្នោះ ចាប់ពីថ្ងៃនេះទៅ សូមទ្រង់ប្រថាប់គង់ ដោយពន្លឺនៃកែវមណី ហើយថ្វាយ កែវមណីដែលមានតម្លៃកាត់ថ្លៃមិនបាន ទំហំប្រមាណប៉ុនផ្លែឪឡឹក ។

ព្រះរាជាទតប្រាសាទហើយត្រាស់ថា សម្បត្តិរបស់ជោតិកៈ ច្រើនពិត ហើយយានត្រឡប់ទៅ នេះជារឿងកើតឡើងរបស់ជោតិកៈមានប្រមាណ ប៉ុណ្ណេះសិន ។

ឥឡូវនេះ គប្បីជ្រាបការកើតឡើងរបស់ព្រះថេរៈ ឈ្មោះជដិល

សេចក្ដីពិស្ដារថា ក្នុងក្រុងពារាណសី មានធីតារបស់សេដ្ឋីម្នាក់ មាន រូបស្អាត មាតាបិតាឲ្យស្រីបម្រើម្នាក់ដើម្បីរក្សាក្នុងពេលមានអាយុ ១៥-១៦ ឆ្នាំ ឲ្យនៅក្នុងបន្ទប់ដ៏មានសិរី លើប្រាសាទជាន់ទី ៧ ។

ថ្ងៃមួយ ពិទ្យាធរម្នាក់ កំពុងហោះទៅតាមអាកាស ឃើញនាងកំពុងបើក បង្អួចមើលមកខាងក្រៅ កើតសេចក្ដីស្នេហា ទើបចូលទៅតាមបង្អួច ហើយ ធ្វើសេចក្ដីស្និទ្ធស្នាលជាមួយនាង ។ អាស្រ័យការនៅរួមគ្នាជាមួយពិទ្យាធរនោះ គភ៌ក៏តាំងឡើងហើយក្នុងកាលមិនយូរឡើយ ។

លំដាប់នោះ ស្រីបម្រើនោះឃើញដូច្នោះហើយទើបពោលថា អ្នកនាង ម្ចាស់ តើនេះជាអ្វី នាងប្រាប់ថា សេចក្ដីនេះចូរលើកទុក នាងកុំប្រាប់ដល់អ្នក ណាឡើយ ទាសីនៅស្ងៀមព្រោះខ្លាច លុះកន្លងទៅ ១០ ខែ កាលនាងប្រសូត

បុត្រហើយ ឲ្យស្រីបម្រើនាំកាជនៈថ្មីមក ដាក់ក្មេងនោះដេកក្នុងកាជនៈហើយ បិទកាជនៈនោះ ដាក់កម្រងផ្កាខាងលើ ប្រាប់ស្រីអ្នកបម្រើថា ចូរនាងយកក្បាលទូលកាជនៈទៅបណ្តែតក្នុងស្ទឹងគង្គា បើត្រូវអ្នកណាសួរថា នេះអ្វី គប្បីប្រាប់ថា នេះជាពលីកម្មរបស់ម្ចាស់ខ្ញុំ ស្រីបម្រើនោះបានធ្វើយ៉ាងនោះ ។

ស្រីពីរនាក់កំពុងងូតទឹកខាងក្រោមខ្សែទឹក ឃើញកាជនៈនោះ ត្រូវទឹកបន្សាត់មក ស្រីម្នាក់ពោលថា កាជនៈនេះជារបស់ខ្ញុំ ស្រីម្នាក់ពោលថា វត្ថុដែលមានខាងក្នុងកាជនៈនោះជារបស់ខ្ញុំ កាលកាជនៈអណ្តែតមកដល់ហើយ ទើបចាប់កាជនៈនោះយកមកលើគោក បើកមើលឃើញទារក ស្រីម្នាក់ពោលថា ក្មេងជារបស់ខ្ញុំនោះឯង ព្រោះខ្ញុំពោលថា កាជនៈជារបស់ខ្ញុំ ស្រីម្នាក់ពោលថាក្មេងជារបស់ខ្ញុំ ព្រោះខ្ញុំពោលថា វត្ថុដែលនៅខាងក្នុងកាជនៈជារបស់ខ្ញុំ ។

ស្រីទាំងពីរប្រកែកគ្នា នាំគ្នាទៅកាន់សាលាវិនិច្ឆ័យហើយ ប្រាប់សេចក្តីនោះ កាលពួកអមាត្យវិនិច្ឆ័យមិនបាន ទើបបញ្ជូនទៅកាន់សម្នាក់ព្រះរាជា ។

ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ស្រីទាំងពីរនោះ ទើបត្រាស់ថា ចូរនាងយកក្មេង ចូរនាងយកកាជនៈ ។

ស្រីដែលបានក្មេង ជាឧបដ្ឋាយិការបស់ព្រះមហាកច្ចាយនត្ថេរ ព្រោះហេតុនោះ ទើបស្រីនោះចិញ្ចឹមទារកនោះ ដោយគិតថា នឹងឲ្យក្មេងនេះបួស ក្នុងសម្នាក់របស់ព្រះថេរៈ ។

សក់របស់ក្មេងនោះ បានរួញក្រញាញ់ ព្រោះមន្ទិលនៃគភ៌ដែលគេលាងមិនស្អាតក្នុងទីដែលក្មេងនោះកើត ព្រោះហេតុនោះ ទើបជនទាំងឡាយដាក់

ឈ្មោះថា ជដិលនោះឯង ។

ក្នុងកាលដែលកុមារដើរបាន ព្រះថេរៈចូលទៅកាន់ផ្ទះនោះដើម្បីបិណ្ឌបាត ឧបាសិកានិមន្តព្រះថេរៈឲ្យគង់ ហើយប្រគេនអាហារ ។ ព្រះថេរៈឃើញក្មេង ទើបសួរថា ឧបាសិកា នាងមានកូនឬ ឧបាសិកាប្រាប់ថា ករុណាលោកម្ចាស់ ខ្ញុំចិញ្ចឹមក្មេងនេះ ដោយបំណងថា នឹងឲ្យបួសក្នុងសម្នាក់របស់លោកម្ចាស់ សូមលោកម្ចាស់ឲ្យក្មេងនេះបួសចុះ ដូច្នេះ បានប្រគេនហើយ ព្រះថេរៈ ទទួលថា សាធុ ហើយនាំក្មេងនោះទៅ ប្រមើលមើលថា បុញ្ញកម្មដែលនឹង សោយសម្បត្តិរបស់គ្រហស្ថនៃក្មេងនេះមានឬហ្ន៎ ឃើញថា សត្វនេះមានបុណ្យ ច្រើន នឹងសោយសម្បត្តិធំ ក្មេងនេះនៅតូចពេក សូម្បីញាណក៏មិនទាន់ចាស់ ក្លាដោយជុំវិញ ទើបនាំក្មេងនោះទៅកាន់ផ្ទះរបស់ឧបដ្ឋាកម្នាក់ នៅក្នុងនគរ តក្កសិលា ឧបដ្ឋាកនោះ ថ្វាយបង្គំព្រះថេរៈហើយឈរ ឃើញក្មេងនោះហើយ សួរថា លោកម្ចាស់បានក្មេងឬ ព្រះថេរៈឆ្លើយថា អើឧបាសក កុមារនេះនឹង បួស តែនៅក្មេងពេក ចូរឲ្យនៅក្នុងសម្នាក់របស់អ្នកចុះ ។ ឧបាសកនោះ ទទួលថា សាធុ ហើយតាំងទុកក្នុងឋានៈជាកូន ថែរក្សាហើយ ។

ទំនិញក្នុងផ្ទះរបស់ឧបាសកនោះ ជារបស់ដែលសន្សំទុកហើយអស់ ១២ ឆ្នាំ គាត់ចូលកាន់ចន្លោះនៃស្រុក នាំយកទំនិញទាំងអស់ទៅកាន់ផ្សារ ឲ្យកុមារ នោះអង្គុយក្នុងផ្សារហើយ ប្រាប់តម្លៃទំនិញនោះៗ ហើយពោលថា អ្នកគប្បី កាន់យកទ្រព្យដែលមានប្រមាណប៉ុណ្ណេះហើយសឹមឲ្យវត្ថុនេះ និងវត្ថុនេះ ដូច្នេះ ហើយចៀសចេញទៅ ។ ក្នុងថ្ងៃនោះ ទេវតាអ្នករក្សានគរ ធ្វើឲ្យជនមានសេចក្តី

ត្រូវការដោយវត្ថុ ដោយហោចសូម្បីត្រឹមតែម្ទេស និងជីរ ឲ្យបែរមុខទៅកាន់ផ្សាររបស់ក្មេងប៉ុណ្ណោះ ក្មេងនោះលក់ទំនិញដែលសន្សំមកអស់ ១២ ឆ្នាំក្នុងមួយថ្ងៃប៉ុណ្ណោះ កុដុម្ពិកៈនោះមកមិនឃើញរបស់អ្វីមួយក្នុងផ្សារ ទើបពោលថា នែបា ទំនិញទាំងអស់ បាឲ្យវិនាសហើយឬ ។

កុមារឆ្លើយថា ខ្ញុំមិនបានឲ្យវិនាសឡើយ ខ្ញុំលក់ទំនិញទាំងអស់តាមន័យដែលពុកប្រាប់ហើយនោះឯង នេះជាថ្លៃរបស់ទំនិញឈ្មោះនោះ នេះជាតម្លៃរបស់ទំនិញឈ្មោះនោះ ។ កុដុម្ពិកៈត្រេកអរគិតថា បុរសដែលមានតម្លៃកាត់ថ្លៃមិនបាន នឹងរស់នៅក្នុងទីណាមួយបាន ទើបឲ្យកូនស្រីដែលចម្រើនវ័យហើយក្នុងផ្ទះរបស់ខ្លួនដល់កុមារនោះ ប្រាប់ពួកបុរសថា ចូរពួកអ្នកសាងផ្ទះដល់កូនយើង កាលផ្ទះធ្វើស្រេចហើយ ទើបប្រាប់ថា ចូរពួកអ្នកទៅ ចូរនៅក្នុងផ្ទះរបស់ខ្លួន ។

កាលនោះ ក្នុងពេលដែលជដិលកុមារនោះចូលទៅកាន់ផ្ទះ កាលធរណីទ្វារត្រូវកុមារជាន់ហើយដោយជើងម្ខាង ភ្នំមាសប្រមាណ ៨០ ហត្ថ បានជ្រែកផែនដីផុសឡើងខាងក្រោយផ្ទះ ។

ព្រះរាជាឮថា ភ្នំមាសជ្រែកផែនដីផុសឡើង ក្បែរផ្ទះរបស់ជដិលកុមារ ទើបបញ្ជូនឆត្រសម្រាប់សេដ្ឋី ទៅប្រទានដល់កុមារនោះ គាត់បានឈ្មោះថា ជដិលសេដ្ឋី ក្រោយមក គាត់មានកូនប្រុស ៣ នាក់ ។

គាត់ញុំាងចិត្តឲ្យកើតឡើងក្នុងការបួសក្នុងពេលដែលបុត្រទាំងនោះចម្រើនវ័យហើយ គិតថា បើត្រកូលសេដ្ឋីណាមានភោគៈស្មើអញសោត កូនទាំង-

ឡាយក៏នឹងឲ្យបួសបាន បើមិនមានសោត កូនទាំងឡាយនឹងមិនឲ្យ ក្នុងជម្ពូទ្វីប ត្រកូលដែលមានភោគៈ ស្មើនឹងយើងទាំងឡាយមានឬហ្ន៎ ទើបឲ្យជាងធ្វើឥដ្ឋ សម្រេចដោយមាស ជងជន្ទញដែលសម្រេចដោយមាស និងស្បែកជើងដែល សម្រេចដោយមាសដើម្បីពិសោធមើល ឲ្យក្នុងដៃរបស់បុរសទាំងឡាយហើយ បញ្ជូនទៅថា ចូរពួកអ្នកទៅ ចូរកាន់ឥដ្ឋដែលសម្រេចដោយមាសជាដើមនេះ ធ្វើដូចជាមើលអ្វីមួយនោះឯង ត្រាច់ទៅក្នុងជម្ពូទ្វីប ដឹងភាពដែលត្រកូលសេដ្ឋី មានភោគៈស្មើយើង មានឬមិនមានហើយចូរមក បុរសនោះត្រាច់ចារិកទៅដល់ ភទ្ទិយនគរ ។

គ្រានោះ មេណ្ឌកសេដ្ឋីឃើញបុរសទាំងនោះហើយសួរថា បាទាំងឡាយ ពួកអ្នកត្រាច់ទៅធ្វើអ្វី កាលពួកបុរសប្រាប់ថា ពួកខ្ញុំដើរមើលរបស់អ្វីមួយ ។ ដឹងថា កិច្ចដោយការកាន់ឥដ្ឋដែលសម្រេចដោយមាសជាដើម ទាំងនេះត្រាច់ ទៅដើម្បីមើលវត្ថុណាមួយនោះឯងរបស់បុរសទាំងនេះ រមែងមិនមាន បុរស ទាំងនេះដើរសើបមើលសេដ្ឋី ទើបពោលថា បាទាំងឡាយ ចូរពួកអ្នកទៅមើល ខាងក្រោយផ្ទះរបស់ខ្ញុំ ។

បុរសទាំងនោះ ឃើញពពែមាសទាំងឡាយមានប្រការដូចពោលហើយ ខាងដើមមានទំហំប៉ុនៗ ដំរី សេះ និងគោឧសភៈ យកខ្នងទាល់ខ្នង ជ្រែក ផែនដី ផុសឡើងក្នុងទីប្រមាណ ៨ ករីស ក្រោយផ្ទះនោះហើយ ត្រាច់ទៅ ក្នុងចន្លោះៗ ពពែទាំងនោះ ហើយចេញទៅ ។

លំដាប់នោះ សេដ្ឋីសួរបុរសទាំងនោះថា នែបាទាំងឡាយ ពួកអ្នកត្រាច់

ទៅមើលបុគ្គលណា បុគ្គលនោះពួកអ្នកឃើញហើយឬ កាលពួកបុរសពោលថា ឃើញហើយលោកម្ចាស់ ទើបបញ្ជូនទៅហើយពោលថា បើយ៉ាងនោះ ចូរពួកអ្នកទៅ ។

បុរសទាំងនោះ ទៅអំពីទីនោះហើយ កាលសេដ្ឋីរបស់ខ្លួនពោលថា បាទាំងឡាយ ត្រកូលសេដ្ឋីមានភោគៈស្មើយើងទាំងឡាយ ពួកអ្នកឃើញហើយឬ ជនទាំងនោះប្រាប់ថា លោកម្ចាស់មានអ្វីប៉ុណ្ណឹង សម្បត្តិបែបនេះ របស់មេណ្ឌកសេដ្ឋីមាន ក្នុងភទ្ទិយនគរ ហើយប្រាប់រឿងរ៉ាវទាំងអស់ ។

សេដ្ឋីស្តាប់ពាក្យនោះហើយ ជាអ្នកមានចិត្តត្រេកអរគិតថា ត្រកូលសេដ្ឋីអញបានដឹងមួយត្រកូលហើយ ត្រកូលសេដ្ឋីដទៃទៀតមានឬហ្ន៎ ហើយឲ្យសំពត់កម្ពលដែលមានតម្លៃមួយសែនបញ្ជូនទៅថា បាទាំងឡាយ ចូរពួកអ្នកទៅ ចូរស្វែងរកត្រកូលសេដ្ឋីដទៃ ។ ពួកបុរសទៅកាន់ក្រុងរាជគ្រឹះហើយ ធ្វើគំនរឧស ក្នុងទីមិនឆ្ងាយអំពីផ្ទះរបស់ជោតិកសេដ្ឋី ដុតភ្លើងហើយ ឈរ ។ ក្នុងពេលពួកជនសួរថា តើអ្នកធ្វើអ្វី ក៏ប្រាប់ថា កាលពួកខ្ញុំលក់សំពត់កម្ពលដែលមានតម្លៃច្រើននេះ មិនមានអ្នកទិញ ពួកខ្ញុំនឹងកាន់ដើរទៅក៏ខ្លាចចោរ ព្រោះហេតុនោះ ទើបពួកខ្ញុំដុតចោលហើយ សឹមទៅ ។

គ្រានោះ ជោតិកសេដ្ឋីឃើញជនទាំងនោះ សួរថា ពួកអ្នកធ្វើអ្វី ស្តាប់សេចក្តីនោះហើយ ឲ្យហៅមកសួរថា សំពត់កម្ពលមានតម្លៃប៉ុន្មាន កាលជនទាំងនោះប្រាប់ថា មានតម្លៃមួយសែន ទើបប្រាប់ថា ចូរពួកអ្នកឲ្យសំពត់នេះដល់ទាសីដែលបោសសំរាមត្រង់ខ្លោងទ្វារ ហើយបញ្ជូនឲ្យក្នុងដៃរបស់ពួក

ជននោះឯង ទាសីទទួលសំពត់កម្ពលហើយ ស្រែកយំ ទៅកាន់សម្នាក់របស់ម្ចាស់ប្រាប់ថា បពិត្រលោកម្ចាស់ បើកំហុសមាន សូមប្រហារខ្ញុំចុះ មិនគួរឬចុះហេតុអ្វី ទើបឲ្យសំពត់កម្ពលសាច់អន់យ៉ាងនេះដល់ខ្ញុំ ខ្ញុំនឹងស្លៀកឬដណ្តប់សំពត់កម្ពលនេះបានដូចម្តេច ។

ជោតិកសេដ្ឋីពោលថា យើងមិនមែនឲ្យនាងដើម្បីប្រយោជន៍ដល់ការស្លៀក ឬការដណ្តប់ឡើយ យើងបញ្ជូនសំពត់កម្ពលនេះទៅឲ្យនាង ដើម្បីឲ្យនាងបត់ ហើយដាក់ក្នុងជិតជំណោករបស់នាង ក្នុងកាលដេក ជូតជើងដែលលាងហើយ ដោយទឹកក្រអូបទេតើ នាងមិនអាចធ្វើកិច្ចនោះបានឬទាសីពោលថា បើដូច្នោះ ខ្ញុំអាចធ្វើកិច្ចនោះបាន ទើបទទួលយកទៅ ។

ចំណែកបុរសនោះ ឃើញហេតុនោះហើយ ទើបទៅកាន់សម្នាក់សេដ្ឋីរបស់ខ្លួន កាលសេដ្ឋីពោលថា បាទាំងឡាយ ត្រកូលនៃសេដ្ឋីពួកអ្នកឃើញហើយឬ ក៏ប្រាប់ថា បពិត្រលោកម្ចាស់ លោកម្ចាស់មានអ្វីប៉ុណ្ណឹង សម្បត្តិបែបនេះរបស់សេដ្ឋីឈ្មោះជោតិកៈ ក៏មានក្នុងក្រុងរាជគ្រឹះ ទើបប្រាប់សម្បត្តិក្នុងផ្ទះទាំងអស់ ហើយប្រាប់រឿងរ៉ាវនោះ ។

សេដ្ឋីស្តាប់ពាក្យរបស់បុរសទាំងនោះហើយ មានចិត្តត្រេកអរ គិតថាឥឡូវនេះ អញនឹងបានបួស ទើបទៅកាន់សម្នាក់ព្រះរាជាក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមានបំណងនឹងបួស ព្រះរាជាត្រាស់ថា សាធុ ចូរលោកសេដ្ឋីបួសចុះ ។

សេដ្ឋីនោះ ទៅកាន់ផ្ទះហើយ ហៅកូនទាំងឡាយមកហើយ ទុកដាក់ចប

ដែលមានដងជាមាស ផ្លែជាពេជ្រ ក្នុងដៃរបស់កូនច្បងហើយពោលថា នែបា ចូរបាជីកមាសអំពីភ្នំខាងក្រោយផ្ទះ កូនច្បងនោះ យកចបទៅកាប់ភ្នំមាស ពេលកាប់ភ្នំមាសនោះ ដូចកាប់ថ្មដា ដូច្នោះ ។ សេដ្ឋីទទួលចបអំពីដៃរបស់កូចប្រុសច្បងនោះ ឲ្យក្នុងដៃកូនកណ្តាល សូម្បីកូនកណ្តាលនោះកាប់ភ្នំមាស ពេលកាប់នោះ ដូចកាប់ថ្មដាដូច្នោះ ។ លំដាប់នោះ ទើបសេដ្ឋីបញ្ជូនចបនោះ ដាក់ក្នុងដៃកូនពៅ កាលកូនពៅនោះទទួលយកចបនោះកាប់ ពេលដែលកាប់នោះ ដូចកាប់ដីឥដ្ឋដែលគេគរ ដូច្នោះ ។

លំដាប់នោះ ទើបសេដ្ឋីពោលនឹងកូនប្រុសពៅថា មកបា ឪពុកនឹងឲ្យទ្រព្យប្រមាណប៉ុណ្ណេះ ហើយហៅកូនច្បងទាំងពីរមកប្រាប់ថា ភ្នំមាសនេះមិនកើតសម្រាប់ពួកឯង កើតដើម្បីឪពុក និងកូនពៅ ចូរពួកអ្នកប្រើប្រាស់រួមគ្នាជាមួយប្អូនប្រុសចុះ ។ សួរថា ព្រោះហេតុអ្វី ទើបភ្នំនោះកើតឡើងដើម្បីឪពុក និងកូនពៅប៉ុណ្ណោះ ព្រោះហេតុអ្វី ទើបជដិលសេដ្ឋី ត្រូវគេបណ្តែតក្នុងទឹក ក្នុងពេលដែលកើតហើយ ឆ្លើយថា ព្រោះកម្មដែលខ្លួនធ្វើហើយនោះឯង ។

សេចក្តីពិស្តារ កាលមហាជនកំពុងសាងព្រះចេតិយរបស់ព្រះកស្សបសម្មាសម្ពុទ្ធ ព្រះខីណាស្រពមួយអង្គ ទៅកាន់ចេតិយដ្ឋាន សម្លឹងមើលហើយ សួរថា បាទាំងឡាយ ព្រោះហេតុអ្វី ទើបមុខខាងទិសឧត្តរនៃចេតិយ មិនសាងឡើយ មហាជនពោលថា មាសមិនគ្រប់គ្រាន់ ព្រះខីណាស្រពពោលថា អាត្មានឹងចូលទៅខាងក្នុងស្រុកហើយបបួល ចូរពួកអ្នកធ្វើកម្មដោយអើពើចុះ ។ លោកពោលយ៉ាងនោះហើយ ចូលទៅកាន់ព្រះនគរ បបួល

មហាជនថា ញោមស្រី ញោមប្រុសទាំងឡាយ មាសត្រង់មុខនៃព្រះចេតិយរបស់ពួកយើង មិនគ្រប់គ្រាន់ ចូរពួកអ្នកជីងមាសចុះ បានទៅកាន់ត្រកូលនៃជាងមាសហើយ ចំណែកជាងមាស កំពុងឈ្លោះជាមួយកិរិយាក្នុងខណៈនោះឯង ។ គ្រានោះ ព្រះថេរៈពោលថា មាស សម្រាប់មុខព្រះចេតិយដែលអ្នកទាំងឡាយទទួល មិនគ្រប់គ្រាន់ ការដែលអ្នកជីងមាសនោះ គួរជាងមាសពោលដោយសេចក្តីក្រោធចំពោះភរិយាថា ចូរលោកបោះព្រះសាស្តារបស់លោក ចូលក្នុងទឹក ហើយទៅចុះ ។ លំដាប់នោះ ទើបនាងពោលថា អ្នកធ្វើកម្មដ៏រហ័សក្រៃលែង អ្នកខឹងនឹងខ្ញុំ គួរជេរ ឬគួរវាយខ្ញុំប៉ុណ្ណោះ ហេតុអ្វី ទើបធ្វើពៀរក្នុងព្រះពុទ្ធទាំងឡាយ ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្នទៅវិញ រំពេចនោះឯង ជាងមាសដល់នូវសេចក្តីសង្វេគហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់ទោសដល់ខ្ញុំ ហើយក្រាបចុះទៀបបាតជើងរបស់ព្រះថេរៈៗ ពោលថា នៃញោម ញោមមិនបានថាអ្វីជាមួយអាត្មាឡើយ ចូរញ៉ាំងព្រះសាស្តាឲ្យអត់ទោសចុះ ។

ជាងមាសពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងធ្វើដូចម្តេច ទើបឲ្យព្រះសាស្តាអត់ទោសបាន ព្រះថេរៈពោលថា ចូរអ្នកធ្វើផើងផ្កាមាស ៣ ផើងទុកខាងក្នុងទីបញ្ចុះព្រះធាតុ ហើយជាអ្នកមានសំពត់សើម មានសក់សើម ញ៉ាំងព្រះសាស្តាឲ្យអត់ទោសចុះ ជាងមាសទទួលថា សាធុ កាលធ្វើផើងផ្កាមាសបានហៅកូនច្បងក្នុងបណ្តាកូន ៣ នាក់មកហើយ ពោលថា មកបា ឪពុកបានពោលពាក្យនឹងព្រះសាស្តា ដោយពាក្យជាពៀរវេរា ព្រោះដូច្នោះ ឪពុក

នឹងធ្វើផ្កាទាំងនេះដាក់ក្នុងទីបញ្ចុះព្រះធាតុ ឲ្យព្រះសាស្តាអត់ទោស សូម្បីបាក៏ចូរជាសម្លាញ់របស់ឪពុក ។ កូនប្រុសច្បងប្រាប់ថា ខ្ញុំមិនបានឲ្យពុកពោលនូវពាក ដែលជាពៀរវេរាទេ សូមពុកធ្វើខ្លួនឯងចុះ ហើយមិនប្រាថ្នាធ្វើ ជាងមាសហៅកូនកណ្តាលមកហើយ ពោលដូចគ្នាយ៉ាងនោះ សូម្បីកូនកណ្តាលនោះ ក៏ពោលដូចគ្នាយ៉ាងនោះ ហើយមិនប្រាថ្នានឹងធ្វើ ទើបជាងមាសឲ្យហៅកូនពៅមកហើយ ពោលយ៉ាងនោះ កូនពៅគិតថា ធម្មតាកិច្ចដែលកើតឡើងដល់បិតា រមែងជាភារៈរបស់បុត្រ ទើបជាសម្លាញ់របស់បិតា បានធ្វើផ្កាទាំងឡាយហើយ ។ ជាងមាសញុំាងផើងផ្កាទំហំ ១ ចំអាម ៣ ផើងឲ្យសម្រេចហើយដាក់ក្នុងទីបញ្ចុះព្រះធាតុ មានសំពត់សើម មានសក់សើម ញុំាងព្រះសាស្តាឲ្យអត់ទោសហើយ ។ ជាងមាសត្រូវគេបោះក្នុងទឹកឲ្យអណ្តែតទៅអស់កាល ៧ ដងដោយប្រការដូច្នេះ ។

អត្តភាពរបស់គាត់ តាំងនៅហើយក្នុងទីបំផុតនេះ ក៏ត្រូវគេបោះទៅក្នុងទឹក ព្រោះផលរបស់កម្មនោះដូចគ្នា ។ ចំណែកបុត្ររបស់គាត់ ២ នាក់ មិនប្រាថ្នាជាសម្លាញ់ក្នុងកាលធ្វើផ្កាមាស ទើបភ្នំមាសមិនកើតសម្រាប់កូនទាំងពីរនោះ តែកើតសម្រាប់កូនពៅ ព្រោះភាពដែលគេធ្វើផ្កាមាសរួមគ្នានឹងឪពុក ។

សេដ្ឋីនោះទូន្មានបុត្រហើយ បួសក្នុងសម្នាក់ព្រះសាស្តា សម្រេចអរហត្តក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

សម័យដទៃក្រោយមក ព្រះសាស្តាត្រាច់ចារិកទៅដើម្បីបិណ្ឌបាត មួយអន្លើដោយភិក្ខុ ៥០០ រូប បានទៅកាន់ទ្វារផ្ទះកូនទាំងឡាយរបស់សេដ្ឋីនោះ

កូនទាំងនោះ បានថ្វាយភិក្ខាហារដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់កាលកន្លះខែ ភិក្ខុទាំងឡាយសន្ទនាក្នុងរោងធម្មសភាថា អាវុសោជដិល ក្នុងថ្ងៃនេះ ចំណង់ក្នុងភ្នំមាសប្រមាណ ៨០ ហត្ថ និងកូនទាំងឡាយរបស់លោកមានឬ ជដិលភិក្ខុពោលថា អាវុសោ តណ្ហា ឬមានះក្នុងភ្នំមាស និងកូនទាំងនោះរបស់ខ្ញុំមិនមាន ។ ទើបភិក្ខុទាំងនោះពោលថា ជដិលត្ថេរនេះ ពោលមិនពិត ព្យាករអរហត្តផល ។ ព្រះសាស្ដា ទ្រង់ស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តណ្ហា ឬមានះក្នុងភ្នំមាស និងបុត្រទាំងនោះរបស់បុត្រតថាគតមិនមាន ដូច្នេះហើយ កាលទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យោធ តណ្ហំ បហន្ត្វាន អនាគារោ បរិព្វជេ**
**តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន តថាគតហៅបុគ្គលដែលអស់តណ្ហា និងភពហើយនោះ ថាជាព្រាហ្មណ៍ ។

## សេចក្ដីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះថា បុគ្គលណាលះតណ្ហា ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ ក្នុងលោកនេះចេញបាន ជាអ្នកមិននៅគ្រប់គ្រងផ្ទះ ឈ្មោះថាជាអ្នកមិនមានផ្ទះ វៀរចេញបាន តថាគតហៅបុគ្គលឈ្មោះថា មានតណ្ហានិងភពអស់ហើយ ព្រោះភាពដែលតណ្ហា និងភព ជារបស់អស់ហើយនោះ

ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចំណែកព្រះបាទអជាតសត្តុកុមារ សេពគប់នឹងទេវទត្ត ផ្តាច់ព្រះជន្មព្រះបិតា តាំងនៅក្នុងរាជសម្បត្តិហើយ ទ្រង់ព្រះតម្រិះថា អញនឹងកាន់យកប្រាសាទរបស់ជោតិកសេដ្ឋី ទើបទ្រង់ត្រៀមការច្បាំង ហើយយាងចេញទៅ លុះទតឃើញព្រះឆាយា គឺស្រមោលរបស់ព្រះអង្គ មួយអន្លើដោយបរិវារត្រង់កំពែងកែវ យល់ថា គហបតី ជាអ្នកត្រៀមការច្បាំង ត្រៀមពលចេញមកហើយ ទើបទ្រង់មិនអាចយាងចូលបាន ។

ក្នុងថ្ងៃនោះ សេដ្ឋីជាអ្នករក្សាឧបោសថ បរិភោគអាហារអំពីព្រលឹមទៅកាន់វិហារ អង្គុយស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ។ ចំណែកយក្ខឈ្មោះយមមោលី ដែលរក្សាត្រង់ខ្លោងទ្វារទីមួយ ឃើញព្រះបាទអជាតសត្តុនោះទើបសួរថា ទ្រង់យាងទៅណា ហើយកម្ចាត់ព្រះបាទអជាតសត្តុ មួយអន្លើដោយរាជបរិវារ ដេញតាមទៅក្នុងទិសតូច និងទិសធំទាំងឡាយ ព្រះរាជាបានយាងទៅកាន់វិហារដូចគ្នា ។

គ្រានោះ សេដ្ឋីឃើញព្រះរាជាទើបទូលថា បពិត្រព្រះអង្គ តើមានរឿងអ្វី បានក្រោកចាកអាសនៈឈរហើយ ព្រះរាជាត្រាស់ថា គហបតី អ្នកបញ្ជាពួកបុរសរបស់អ្នកថា ចូរច្បាំងជាមួយយើង ហើយមកក្នុងទីនេះអង្គុយធ្វើដូចស្តាប់ធម៌ឬ សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព ទ្រង់យាងទៅដើម្បីដណ្តើម

យកផ្ទះរបស់ទូលបង្គំពិតមែនឬ ព្រះរាជាត្រាស់ថា អើ យើងទៅ សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព សូម្បីព្រះរាជារាប់ពាន់ ក៏មិនអាចដណ្តើមយកផ្ទះទូលបង្គំបាន ព្រោះទូលបង្គំមិនប្រាថ្នា ព្រះរាជាក្រោធថា អ្នកជាព្រះរាជាឬ សេដ្ឋីទូលថា ទូលបង្គំមិនជាព្រះរាជា តែព្រះរាជាក្តី ចោរក្តី មិនអាចកាន់យកសូម្បីអំបោះត្រង់ជាយសំពត់ដែលជារបស់ទូលបង្គំបានឡើយ បើទូលបង្គំមិនប្រាថ្នាឲ្យ ព្រះរាជាត្រាស់ថា យើងនឹងកាន់យកតាមគាប់ចិត្តរបស់អ្នកបានដូចម្តេច សេដ្ឋីទូលថា បពិត្រព្រះសម្មតិទេព បើយ៉ាងនោះ ចិញ្ចៀន ២០ វង់នេះ ដែលមានក្នុងម្រាមដៃទាំង ១០ របស់ទូលបង្គំ ទូលបង្គំមិនថ្វាយចិញ្ចៀនទាំងនេះដល់ទ្រង់ បើទ្រង់អាចសោត សូមទ្រង់កាន់យកចុះ ។ ព្រះរាជានោះប្រថាប់គង់ប្រហោងលើផែនដី កាលនឹងលោត រមែងលោតទៅកាន់ទី ១៨ ហត្ថ បើប្រថាប់ឈរ កាលនឹងលោត រមែងលោតទៅក្នុងទី ៨០ ហត្ថ ។ ព្រះរាជាទ្រង់មានកម្លាំងច្រើនយ៉ាងនេះ ទ្រង់លោតទៅមកខាងនោះខាងនេះ ក៏មិនអាចដោះនូវចិញ្ចៀនមួយបាន ។

លំដាប់នោះ សេដ្ឋីក្រាបទូលនឹងព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមទ្រង់លាសំពត់សាដក ហើយបានធ្វើម្រាមទាំងឡាយឲ្យត្រង់ ចិញ្ចៀនទាំង ២០ របូតចេញហើយ ។ លំដាប់នោះ សេដ្ឋីក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព បុគ្គលណាម្នាក់ មិនអាចកាន់យកសម្បត្តិ ដែលជារបស់ទូលបង្គំដោយអាការយ៉ាងនោះបាន បើទូលបង្គំមិនប្រាថ្នាឲ្យ ដូច្នេះហើយ កើតនូវសេចក្តីសង្វេគ ព្រោះកិរិយារបស់ព្រះរាជា ទើបក្រាបទូលថា បពិត្រព្រះ

សម្មតិទេព សូមទ្រង់អនុញ្ញាតដើម្បីការបួសដល់ទូលបង្គំ ព្រះរាជាទ្រង់ព្រះតម្រិះថា កាលសេដ្ឋីនេះបួសហើយ អញនឹងជណ្តើមប្រាសាទបានងាយ ទើបត្រាស់ថា ចូរបួសចុះ ដោយការត្រាស់ត្រឹមតែម្តងប៉ុណ្ណោះ សេដ្ឋីនោះ បួសក្នុងសម្នាក់ព្រះសាស្តាហើយ ក្នុងកាលមិនយូរ ក៏បានសម្រេចអរហត្តឈ្មោះថា ជោតិកត្ថេរ ។

ក្នុងខណៈដែលសម្រេចអរហត្តហើយនោះឯង សម្បត្តិទាំងអស់នោះក៏អន្តរធានទៅ ពួកទេវតាក៏នាំកិរិយារបស់សេដ្ឋីនោះ ដែលមានឈ្មោះថាសតុលកាយា ទៅកាន់ឧត្តរកុរុទ្វីបវិញ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយហៅជោតិកៈនោះមកហើយ សួរថា អាវុសោជោតិកៈ តណ្ហាក្នុងប្រាសាទ ឬក្នុងស្រីនោះរបស់លោក នៅមានឬ កាលលោកប្រាប់ថា មិនមានឡើយអាវុសោ ទើបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ជោតិកត្ថេរនេះពោលមិនពិត ព្យាករអរហត្តផល ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតមិនមានតណ្ហាក្នុងប្រាសាទ ឬក្នុងស្រីទាំងនោះឡើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

បុគ្គលណាក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះគេចចេញចាកតណ្ហាបាន តថាគតហៅបុគ្គលដែលអស់តណ្ហា និងភពហើយនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

# រឿង ភិក្ខុធ្លាប់ជាអ្នករបាំមួយរូប

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុមួយរូបធ្លាប់ជាអ្នករបាំ ត្រាស់ព្រះធម្មទេសនានេះថា* **ហិត្វា មានុសកំ** *ជាដើម ។*

*បានឮថា អ្នករបាំនោះត្រាច់លេងកីឡា គឺការរាំមួយប្រភេទ ស្តាប់ធម្មកថារបស់ព្រះសាស្តា បួសហើយសម្រេចអរហត្ត កាលភិក្ខុនោះកំពុងចូលទៅបិណ្ឌបាតជាមួយភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ភិក្ខុទាំងឡាយបានឃើញកូនរបស់អ្នករបាំម្នាក់កំពុងលេង ទើបសួរថា អាវុសោ បុត្ររបស់អ្នករបាំនោះលេងកីឡាដែលលោកលេងហើយ លោកមានការជាប់ជំពាក់ក្នុងកីឡាប្រភេទនេះដែរឬហ្ន៎ កាលភិក្ខុនោះឆ្លើយថា មិនមាន ទើបពោលថា អាវុសោ ភិក្ខុនេះពោលមិនពិត ព្យាករអរហត្តផល ។*

*ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតលះកន្លងកិលេស ជាគ្រឿងប្រកបទាំងពួងបានហើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា*

**ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា**
**សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា លះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្ស កន្លងកិលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វបានហើយ តថាគតហៅបុគ្គលដែលផុតស្រឡះចាកកិលេសជាគ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍ ។*

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ ពីរបទថា **មានុសកំ យោគំ** បានដល់ អាយុ និងកាមគុណទាំង ៥ ដែលជារបស់មនុស្ស ក្នុងកិលេសជាគ្រឿងប្រកបដែលជាទិព្វ ក៏ន័យនេះដូចគ្នា ។

បទថា **ឧបច្ចគា** ជាដើម សេចក្ដីថា បុគ្គលណាលះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្ស ឈានកន្លងកិលេសគ្រឿងប្រកបដែលជាទិព្វបានហើយ តថាគតហៅបុគ្គលនោះដែលផុតស្រឡះចាកកិលេស ជាគ្រឿងប្រកប ៤ យ៉ាងបានហើយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ភិក្ខុធ្លាប់ជាអ្នករាំម្នាក់រូប ចប់**

# រឿង ភិក្ខុធ្លាប់ជាអ្នករបាំមួយរូបទៀត

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុដែលធ្លាប់ជាអ្នករបាំ ដូចគ្នានឹងភិក្ខុរូបទីមួយ ទើបត្រាស់ព្រះធម្មទេសនានេះថា **ហិត្វា រតឹ** ជាដើម ។

រឿងដូចគ្នានឹងរឿងមុននោះឯង តែក្នុងរឿងនេះ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតលះសេចក្ដីត្រេកអរ និងមិនត្រេកអរបានហើយតាំងនៅ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ហិត្វា រតឹ អរតិញ្ច  សីតិភូតំ និរូបធឹ**
**សព្វលោកាភិភុំ វីរំ  តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគតហៅបុគ្គល ដែលលះបង់សេចក្ដីត្រេកអរក្នុងកាមគុណ និងមិនត្រេកអរក្នុងកិរិយានៅក្នុងព្រៃ ជាអ្នកមានចិត្តត្រជាក់ មិនមានឧបក្កិលេស គ្របសង្កត់លោកទាំងពួង មានសេចក្ដីព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **រតឹ** បានដល់ សេចក្ដីត្រេកអរក្នុងកាមគុណ ៥ ។

បទថា **អរតឹ** បានដល់ បុគ្គលមិនត្រេកអរក្នុងការនៅព្រៃ ។

បទថា **សីតិភូតំ** បានដល់ ជាអ្នករម្ងត់ហើយ ។

បទថា **និរូបធឹ** បានដល់ អ្នកមិនមានឧបធិ គឺកិលេស ។

បទថា **វីរំ** សេចក្តីថា តថាគតហៅបុគ្គលដែលគ្របសង្កត់ខន្ធលោក ទាំងអស់បានហើយ តាំងនៅ ជាអ្នកមានសេចក្តីក្លៀវក្លានោះ គឺបែបនោះ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង ភិក្ខុធ្លាប់ជាអ្នករបាំមួយរូបទៀត ចប់**

# រឿង ព្រះវង្គីសត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះវង្គីសត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ចុតឹ យោ វេទិ** ជាដើម ។

បានឮថា ព្រាហ្មណ៍ក្នុងក្រុងរាជគ្រឹះម្នាក់ឈ្មោះវង្គីសៈ ជាអ្នកគោះលលាដ៍ ក្បាលរបស់ពួកមនុស្សដែលស្លាប់ហើយដឹងបានថា នេះជាក្បាលរបស់បុគ្គល ដែលកើតក្នុងនរក នេះជាក្បាលរបស់បុគ្គលដែលកើតក្នុងកំណើតតិរច្ឆាន នេះ ជាក្បាលរបស់បុគ្គលដែលកើតក្នុងបិត្តិវិស័យ នេះជាក្បាលរបស់បុគ្គលដែល កើតក្នុងមនុស្សលោក នេះជាក្បាលរបស់បុគ្គលដែលកើតក្នុងទេវលោក ។

ពួកព្រាហ្មណ៍គិតថា ពួកយើងអាស្រ័យវង្គីសព្រាហ្មណ៍នេះ ក៏អាចរក ស៊ីក្នុងលោកបាន ទើបឲ្យស្លៀកសំពត់ក្រហម ២ ផ្ទាំង ហើយនាំត្រាច់ទៅក្នុង

ជនបទ ពោលនឹងពួកមនុស្សថា ព្រាហ្មណ៍ឈ្មោះវង្គីសៈ គោះលលាដ៍ក្បាលរបស់ពួកមនុស្សដែលស្លាប់ហើយក៏ដឹងទីកើត ចូរពួកអ្នកសួរដល់ទីដែលពួកញាតិរបស់ខ្លួនកើតហើយចុះ ។

ពួកមនុស្សឲ្យកហាបណៈ ១០ ខ្លះ ២០ ខ្លះ ១០០ ខ្លះ តាមកម្លាំងហើយទើបសួរដល់ពួកញាតិដែលកើតហើយ ។ ព្រាហ្មណ៍ទាំងនោះដល់ក្រុងសាវត្ថីដោយលំដាប់ហើយ កាន់យកទីសម្រាកក្នុងទីមិនឆ្ងាយអំពីវត្តជេតពន ពួកជនទាំងនោះឃើញមហាជនបរិភោគអាហារព្រឹកហើយ មានដៃកាន់គ្រឿងក្រអូបនិងកម្រងផ្កាជាដើម កំពុងដើរទៅដើម្បីស្តាប់ធម៌ ទើបសួរថា ពួកអ្នកទៅណា កាលមហាជនប្រាប់ថា ទៅកាន់វិហារដើម្បីស្តាប់ធម៌ ទើបពោលថា ពួកអ្នកទៅក្នុងទីនោះធ្វើអ្វី បុគ្គលដែលប្រៀបស្មើនឹងវង្គីសព្រាហ្មណ៍របស់ពួកយើង មិនមាន វង្គីសៈគោះលលាដ៍ក្បាលរបស់ពួកមនុស្សដែលស្លាប់ហើយដឹងទីកើតបាន ចូរពួកអ្នកសួរដល់ទីដែលពួកញាតិកើតចុះ ។

មនុស្សទាំងនោះពោលថា វង្គីសៈដឹងអ្វី បុគ្គលដែលប្រៀបផ្ទឹមនឹងព្រះសាស្តារបស់ពួកយើងមិនមាន ។ កាលពួកព្រាហ្មណ៍ក្រៅអំពីនេះពោលថា បុគ្គលដែលផ្ទឹមនឹងវង្គីសៈមិនមាន ក៏ប្រកែកគ្នាហើយពោលថា មក ឥឡូវនេះពួកយើងនឹងដឹងថា វង្គីសៈរបស់ពួកអ្នក ឬព្រះសាស្តារបស់ពួកយើង មានការដឹង ហើយបាននាំព្រាហ្មណ៍ទាំងនោះទៅកាន់វិហារ ។

ព្រះសាស្តាទ្រង់ជ្រាបថាជនទាំងនោះមក ទើបត្រាស់ឲ្យនាំលលាដ៍ក្បាល ៥ មក គឺលលាដ៍ក្បាលសត្វដែលកើតក្នុងឋានៈ ៤ គឺក្នុងនរក ក្នុងកំណើត

តិរច្ឆាន ក្នុងមនុស្សលោក ក្នុងទេវលោក និងលលាដ៍របស់ព្រះខីណាស្រព ត្រាស់ឲ្យតម្រៀបតាមលំដាប់ ។ ក្នុងពេលដែលវង្គីសៈមកហើយ ទើបត្រាស់សួរវង្គីសៈថា បានឮថា អ្នកគោះលលាដ៍ក្បាលហើយ ដឹងទីកើតរបស់សត្វទាំងឡាយដែលស្លាប់ហើយឬ វង្គីសៈទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គអាចដឹងបាន ព្រះសាស្តាត្រាស់ថា នេះលលាដ៍ក្បាលរបស់អ្នកណា វង្គីសៈគោះហើយ ទូលថា របស់សត្វដែលកើតក្នុងនរក ។ លំដាប់នោះ ព្រះសាស្តាប្រទានសាធុការថា សាធុ ទើបត្រាស់សួរដល់លលាដ៍ក្បាលទាំង ៣ ក្រៅអំពីនេះ ក្នុងខណៈដែលព្រាហ្មណ៍ក្រាបទូលហើយមិនខុស ក៏ប្រទានសាធុការយ៉ាងនោះ ទើបទ្រង់បង្ហាញលលាដ៍ក្បាលទី ៥ ត្រាស់សួរថា នេះលលាដ៍ក្បាលរបស់អ្នកណា ព្រាហ្មណ៍គោះហើយ មិនដឹងទីកើត ។ ពោលនោះព្រះសាស្តាត្រាស់នឹងព្រាហ្មណ៍ថា វង្គីសៈ អ្នកមិនដឹងឬ កាលព្រាហ្មណ៍ក្រាបទូលថា ខ្ញុំព្រះអង្គមិនដឹង ទើបត្រាស់ថា តថាគតដឹង វង្គីសៈពោលថា ទ្រង់ជ្រាបដោយអ្វី ព្រះសាស្តាត្រាស់ថា ជ្រាបដោយកម្លាំងមន្ត ។

លំដាប់នោះ វង្គីសៈទូលអង្វរថា សូមទ្រង់ប្រទានមន្តនេះដល់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា តថាគតមិនអាចឲ្យមន្តដល់បុគ្គលដែលមិនបានបួស ។

ព្រាហ្មណ៍គិតថា កាលអញរៀនមន្តនេះហើយ អញនឹងបានជាបុគ្គលប្រសើរក្នុងជម្ពូទ្វីបទាំងមូល ទើបបញ្ជូនព្រាហ្មណ៍ទាំងនោះទៅដោយពាក្យថា ចូរពួកអ្នកនៅក្នុងទីនេះឯងអស់ ២-៣ ថ្ងៃ ខ្ញុំនឹងបួស ហើយបានបំពេញបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះសាស្តា ជាអ្នកមានឈ្មោះថាវង្គីសត្ថេរ ។

លំដាប់នោះ ព្រះសាស្តាប្រទានកម្មដ្ឋាន មានអាការ ៣២ ជាអារម្មណ៍ ដល់លោកហើយ ត្រាស់ថា ចូរអ្នកស្វាធ្យាយបរិកម្មនៃមន្ត ។

វង្គីសត្ថេរកំពុងស្វាធ្យាយមន្ត ត្រូវពួកព្រាហ្មណ៍សួរក្នុងចន្លោះៗ ថា លោកម្ចាស់រៀនមន្តបានហើយឬ ទើបប្រាប់ថា ចូរពួកអ្នកបង្អង់សិន អាត្មាកំពុងរៀន ក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចអរហត្ត ។ ព្រាហ្មណ៍ទាំងឡាយសួរទៀត ទើបពោលថា អាវុសោ ឥឡូវនេះ ខ្ញុំមិនគួរទៅ ពួកភិក្ខុស្តាប់ពាក្យនោះហើយ ទើបក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ វង្គីសត្ថេរនេះ ព្យាករអរហត្តផល ដោយពាក្យមិនពិត ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំពោលយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ បុត្ររបស់តថាគតឈ្លាសក្នុងការចុតិ និងបដិសន្ធិហើយ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

**ចុតឹ យោ វេទិ សត្តានំ ឧបបត្តិញ្ច សព្វសោ**
**អសត្តំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**
**យស្ស គតឹ ន ជានន្តិ ទេវា គន្ធព្វមានុសា**
**ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ដឹងច្បាស់ចុតិ និងបដិសន្ធិរបស់ពួកសត្វ ដោយអាការទាំងពួងបាន តថាគតហៅបុគ្គល ដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមានដំណើរល្អ ដោយសេចក្តីប្រតិបត្តិ អ្នកត្រាស់ដឹងនូវសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។

ទេវតា គន្ធព្វ និងពួកមនុស្សទាំងឡាយ មិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្តនោះថា ជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **យោ វេទិ** ជាដើម សេចក្តីថា បុគ្គលណា ដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ដោយប្រការទាំងពួងយ៉ាងជាក់ច្បាស់ តថាគតហៅបុគ្គលនោះ ដែលឈ្មោះថា មិនជាប់ជំពាក់ ព្រោះភាពជាអ្នកមិនជាប់ជំពាក់ ឈ្មោះថា ទៅល្អហើយ ព្រោះភាពជាអ្នកទៅល្អហើយក្នុងកិច្ចបដិបត្តិ ឈ្មោះថា ជាអ្នកដឹងហើយ ព្រោះភាពជាអ្នកដឹងសច្ចៈទាំង ៤ ថាជាព្រាហ្មណ៍ ។

បទថា **យស្ស** ជាដើម សេចក្តីថា ទេវតាជាដើមនោះមិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គលដែលឈ្មោះថាមានអាសវៈអស់ហើយ ព្រោះភាពដែលអាសវៈទាំងឡាយអស់ហើយ ឈ្មោះថាជាអ្នកឆ្ងាយចាកកិលេស ព្រោះភាពជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿងព្រះវង្គីសត្ថេរ ចប់**

# រឿង ព្រះនាងធម្មទិន្នាថេរី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុនីឈ្មោះធម្មទិន្នាថេរី ត្រាស់ព្រះធម្មទេសនានេះថា **យស្ស បុរេ ច** ជាដើម ។

សេចក្ដីពិស្ដារថា ថ្ងៃមួយ ក្នុងកាលដែលនាងនៅជាគ្រហស្ថ វិសាខឧបាសកជាស្វាមី ស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា សម្រេចអនាគាមិផលហើយ គិតថា ការដែលអញឲ្យធម្មទិន្នាទទួលទ្រព្យសម្បត្តិទាំងពួង គួរក្នុងកាលមុនអំពីនោះ ឧបាសកនោះកាលមក ឃើញនាងធម្មទិន្នាកំពុងឈរមើលត្រង់មាត់បង្អួច រមែងធ្វើការញញឹម តែក្នុងថ្ងៃនោះ មិនសម្លឹងមើលនាង ដែលឈរត្រង់បង្អួចឡើយ បានទៅហើយ ។

នាងគិតថា តើមានរឿងអ្វីហ្ន៎ ហើយគិតទៀតថា សេចក្ដីនោះចូរលើកទុក អញនឹងដឹងក្នុងពេលបរិភោគ ហើយនាំភត្តចូលទៅក្នុងពេលបរិភោគ ។ ក្នុងថ្ងៃដទៃ ឧបាសកពោលថា មក យើងនឹងបរិភោគជាមួយគ្នា តែក្នុងថ្ងៃនោះ ជាអ្នកអង្គុយស្ងៀមបរិភោគហើយ នាងគិតថា ប្ដីគង់នឹងក្រោធដោយហេតុណាមួយពិតប្រាកដ ។

គ្រានោះ វិសាខឧបាសក ហៅនាងក្នុងពេលអង្គុយតាមសប្បាយមក ហើយពោលថា ធម្មទិន្នា ចូរនាងទទួលទ្រព្យសម្បត្តិទាំងពួងក្នុងផ្ទះនេះចុះ នាងគិតថា ធម្មតាមនុស្សទាំងឡាយដែលក្រោធហើយ រមែងមិនឲ្យអ្នកណាទទួលទ្រព្យសម្បត្តិ តើមានរឿងអ្វីហ្ន៎ ទើបពោលថា ចុះអ្នកវិញ ឧបាសកពោលថា ចាប់អំពីថ្ងៃនេះទៅ ខ្ញុំមិនចាត់ចែងការងារណាមួយ ធម្មទិន្នាពោលថា អ្នកណា

នឹងទទួលទឹកមាត់ដែលអ្នកស្តោះចោល កាលបើដូច្នោះ សូមអ្នកអនុញ្ញាតការបួសដល់ខ្ញុំចុះ ។

ឧបាសកទទួលថា សាធុ នាំនាងទៅកាន់សម្នាក់ភិក្ខុនីដោយសក្ការៈធំឲ្យបួសហើយ នាងបានឧបសម្បទាហើយ បានឈ្មោះថា ធម្មទិន្នាថេរី ។

នាងទៅកាន់ជនបទជាមួយភិក្ខុនីទាំងឡាយ ព្រោះជាអ្នកបំណាន់វិវេក កាលនៅក្នុងជនបទនោះ មិនយូរប៉ុន្មានក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ ដោយគិតថា ឥឡូវនេះ ពួកជនដែលជាញាតិអាស្រ័យអញហើយ នឹងធ្វើបុណ្យទាំងឡាយ ។

ឧបាសកបានជ្រាបភាពដែលព្រះថេរីមកហើយគិតថា ព្រះថេរីមកព្រោះហេតុអ្វីហ្ន៎ ទើបទៅកាន់សម្នាក់ភិក្ខុនី ថ្វាយបង្គំព្រះថេរីហើយអង្គុយក្នុងចំណែកម្ខាងគិតថា កាលដែលអញពោលថា បពិត្រអ្នកនាងម្ចាស់ នាងអផ្សុកឬ ដូច្នេះក៏ជាការមិនគួរ អញសួរបញ្ហាមួយ ជាមួយព្រះថេរីនោះ ហើយសួរបញ្ហាក្នុងសោតាបត្តិមគ្គ ព្រះថេរីឆ្លើយបញ្ហានោះបាន ឧបាសកសួរបញ្ហាក្នុងមគ្គដ៏សេសដោយឧបាយនោះឯង កាលព្រះថេរីនោះពោលក្នុងវេលាបញ្ហា ដែលឧបាសកនោះសួរឈានកន្លងវិស័យថា អាវុសោវិសាខៈ អ្នកកន្លងវិស័យទៅហើយ ហើយពោលថា បើអ្នកចង់ដឹងគប្បីចូលគាល់ព្រះសាស្តា ហើយទូលសួរបញ្ហានោះ ថ្វាយបង្គំព្រះថេរីហើយក្រោកចាកអាសនៈ ទៅកាន់សម្នាក់ព្រះសាស្តាក្រាបទូលការសន្ទនាប្រាស្រ័យទាំងអស់នោះ ដល់ព្រះដ៏មានព្រះភាគ ។

ព្រះសាស្តាត្រាស់ថា ធម្មទិន្នាធីតារបស់តថាគតពោលល្អហើយ ទោះបី

តថាគត កាលឆ្លើយបញ្ហានោះ ក៏គប្បីឆ្លើយយ៉ាងនោះដូចគ្នា ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ**
**អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនមានសេចក្តីកង្វល់ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្តាលផង តថាគតហៅបុគ្គលដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បុរេ** សេចក្តីថា ក្នុងខន្ធទាំងឡាយដែលជាអតីត ។ បទថា **បច្ឆា** គឺក្នុងខន្ធទាំងឡាយដែលជាអនាគត ។ បទថា **មជ្ឈេ** បានដល់ ខន្ធទាំងឡាយដែលជាបច្ចុប្បន្ន ។

ពីរបទថា **នត្ថិ កិញ្ចនំ** ជាដើម សេចក្តីថា ការកង្វល់ ពោល គឺការប្រកាន់ដោយតណ្ហាក្នុងឋានៈទាំង ៣ នោះរបស់បុគ្គលណាមាន តថាគតហៅបុគ្គលនោះ ដែលមិនមានសេចក្តីកង្វល់ដោយកិលេសជាគ្រឿងកង្វល់ គឺរាគៈជាដើម ដែលឈ្មោះថាមិនមានការប្រកាន់មាំ ព្រោះមិនមានការប្រកាន់មាំក្នុងអ្វីមួយ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

# រឿង ព្រះអង្គុលិមាលត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះអង្គុលិមាលត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧសភំ** ជាដើម ។

រឿងខ្ញុំបានពោលហើយ ក្នុងកាលពណ៌នាគាថាថា **ឆ ឞ កកនិយា គេវលោកំ វជន្តិ** ជាដើមនោះឯង ។

ពិតហើយ ក្នុងទីនោះ ខ្ញុំពោលថា ភិក្ខុទាំងឡាយសួរព្រះអង្គុលិមាលថា អាវុសោ លោកឃើញដំរីកាចឈរបាំងឆត្រហើយ មិនខ្លាចឬហ្ន៎ ព្រះអង្គុលិមាលឆ្លើយថា អាវុសោ ខ្ញុំមិនខ្លាចទេ ភិក្ខុទាំងនោះ ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះអង្គុលិមាលព្យាករព្រះអរហត្តដោយពាក្យមិនពិត ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អង្គុលិមាលបុត្ររបស់តថាគត មិនខ្លាច ព្រោះថា ភិក្ខុទាំងឡាយដូចគ្នានឹងបុត្ររបស់តថាគត ជាអ្នកអង់អាចបំផុត ក្នុងរវាងព្រះខីណាស្រពដែលអង់អាចទាំងឡាយ មិនខ្លាច ដូច្នេះហើយ ត្រាស់ព្រះគាថានេះ ក្នុងព្រាហ្មណវគ្គថា

**ឧសភំ បវរំ វីរំ មហេសឹ វិជិតាវិនំ**
**អនេជំ ន្ហាតកំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ ផ្ងូតលាងកិលេស ត្រាស់ដឹងសច្ចៈនោះថា ជាព្រាហ្មណ៍ ។

# សេចក្ដីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះថា តថាគតហៅបុគ្គលនោះ គឺបែបនោះ ដែលឈ្មោះថា **ឧសភំ** ព្រោះដូចគ្នានឹងគោឧសភៈ ដោយអត្ថថា ជាអ្នកមិនតក់ស្លុត ឈ្មោះថា **បវរំ** ព្រោះឧត្ដម ឈ្មោះថា **វីរំ** ព្រោះដល់ព្រមដោយភាពជាអ្នកក្លាហាន ឈ្មោះថា **មហេសឹ** ព្រោះភាពជាអ្នកស្វែងរកគុណដ៏ធំមានសីលក្ខន្ធជាដើម ឈ្មោះថា **វិជិតាវិនំ** ព្រោះភាពដែលមារទាំង ៣ ដែលខ្លួនឈ្នះហើយ ឈ្មោះថា **ន្ហាតកំ** ព្រោះភាពជាអ្នកមានកិលេសលាងហើយ ឈ្មោះថា **ពុទ្ធំ** ព្រោះភាពជាអ្នកដឹងសច្ចៈ ៤ ថាជាព្រាហ្មណ៍ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។l

**រឿងព្រះអង្គុលីមាលត្ថេរ ចប់**

# រឿង ទេវហិតព្រាហ្មណ៍

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ទេវហិតព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា **បុព្វេនិវាសំ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ព្រះសាស្តាទ្រង់អាពាធ ដោយព្រះវាយោកម្រើក ទ្រង់បញ្ជូនព្រះឧបវានត្ថេរ ទៅកាន់សម្នាក់របស់ទេវហិតព្រាហ្មណ៍ ដើម្បីទឹកក្តៅ ។ ព្រះថេរៈទៅប្រាប់ភាពដែលព្រះសាស្តាទ្រង់អាពាធ ហើយសូមទឹកក្តៅ ។

ព្រាហ្មណ៍ស្តាប់ពាក្យនោះហើយ ជាអ្នកមានចិត្តត្រេកអរគិតថា ការដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បញ្ជូនព្រះឧបវានត្ថេរមកកាន់សម្នាក់របស់អញ ដើម្បីទឹកក្តៅ ជាលាភរបស់អញហ្ន៎ ទើបឲ្យបុរសកាន់យកអម្រែកទឹកក្តៅ និងកញ្ចប់ស្ករអំពៅ ប្រគេនដល់ព្រះឧបវានត្ថេរ ។

ព្រះថេរៈ ឲ្យជនកាន់យកទឹកក្តៅជាដើមនោះទៅកាន់វិហារ ក្រាបទូលព្រះសាស្តាឲ្យទ្រង់ស្រង់ដោយទឹកក្តៅហើយ រំលាយស្ករអំពៅដោយទឹកក្តៅ ថ្វាយដល់ព្រះសាស្តា ។ ក្នុងខណៈនោះឯង អាពាធរបស់ព្រះសាស្តាក៏ស្ងប់រម្ងាប់ ។ ព្រាហ្មណ៍គិតថា ទេយ្យធម៌របស់អញ ឲ្យដល់អ្នកណាហ្ន៎ ទើបមានផលច្រើន អញនឹងទូលសួរព្រះសាស្តា ព្រាហ្មណ៍នោះ ទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគហើយ កាលនឹងទូលសួរសេចក្តីនោះ ទើបពោលគាថាថា

បុគ្គលគួរឲ្យទេយ្យធម៌ដល់បុគ្គលណា ទេយ្យវត្ថុដែលបុគ្គលឲ្យដល់បុគ្គលណា ទើបមានផលច្រើន ទក្ខិណារបស់បុគ្គលដែលបូជាដូចម្ដេច នឹងសម្រេចបានដូចម្ដេច ។

លំដាប់នោះ ព្រះសាស្ដាត្រាស់ថា ទេយ្យវត្ថុដែលបុគ្គលឲ្យហើយដល់ព្រាហ្មណ៍បែបនេះរមែងមានផលច្រើន ដូច្នេះហើយ កាលទ្រង់ប្រកាសបុគ្គលដែលជាព្រាហ្មណ៍ ដល់ព្រាហ្មណ៍នោះ ទើបត្រាស់ព្រះគាថានេះថា

**បុព្វេនិវាសំ យោ វេទិ សគ្គាបាយញ្ច បស្សតិ**
**អថោ ជាតិក្ខយំ បត្តោ អភិញ្ញា វោសិតោ មុនិ**
**សព្វវោសិតវោសានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ដឹងច្បាស់នូវខន្ធបញ្ចកៈ ដែលខ្ជួនធ្លាប់នៅអាស្រ័យក្នុងកាលមុនផង ឃើញច្បាស់ស្ថានសួគ៌ និងអបាយភូមិផង មួយទៀត បានសម្រេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញ ស្រេចកិច្ចហើយ ព្រោះអភិញ្ញា តថាគតហៅបុគ្គលដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ចប់សព្វគ្រប់ហើយនោះថាជាព្រាហ្មណ៍ ។

## សេចក្ដីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះថា បុគ្គលណាដឹងខន្ធដែលអាស្រ័យនៅពីមុនយ៉ាងជាក់ច្បាស់ ឃើញស្ថានសួគ៌ មានទេវលោក ២៦ ជាន់ និងអបាយ ៤ ដោយទិព្វចក្ខុ ម្យ៉ាងទៀត សម្រេចអរហត្ត ពោល គឺការអស់ទៅនៃជាតិ

*សម្រេចកិច្ចហើយ ព្រោះដឹងក្រៃលែងនូវធម៌ដែលគួរដឹងក្រៃលែង កំណត់ដឹងធម៌ដែលគួរកំណត់ដឹង លះធម៌ដែលគួរលះ ធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ គឺសម្រេចព្រះនិព្វាន ឬសម្រេចព្រហ្មចរិយៈដែលខ្ជូននៅចប់ហើយ ឈ្មោះថា ជាមុនី ជាអ្នកសម្រេចការៈនៃបុគ្គលអ្នកដឹងដោយបញ្ញាដែលជាហេតុអស់ទៅនៃអាសវៈ តថាគតហៅបុគ្គលនោះ ដែលឈ្មោះថាមានព្រហ្មចរិយៈនៅចប់ហើយ ព្រោះភាពជាអ្នកនៅចប់ព្រហ្មចរិយៈ ដែលជាទីបំផុតនៃកិលេសទាំងមូល គឺអរហត្តមគ្គញ្ញាណ ថាជាព្រាហ្មណ៍ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ចំណែកព្រាហ្មណ៍ មានចិត្តជ្រះថ្លាហើយ តាំងនៅក្នុងសរណៈទាំងឡាយ ប្រកាសភាពជាឧបាសកហើយ ដូច្នេះឯង ។៚*

**រឿងទេវហិតព្រាហ្មណ៍ ចប់**

**ព្រាហ្មណវគ្គ ចប់**

**វគ្គទី ២៦ ចប់**

## វគ្គដែលមានក្នុងគាថាធម្មបទ គឺ

យមកវគ្គ ១ អប្បមាទវគ្គ ១ ចិត្តវគ្គ ១ បុប្ផវគ្គ ១ ពាលវគ្គ ១ បណ្ឌិតវគ្គ ១ អរហន្តវគ្គ ១ សហស្សវគ្គ ១ បាបវគ្គ ១ ទណ្ឌវគ្គ ១ ជរាវគ្គ ១ អត្តវគ្គ ១ លោកវគ្គ ១ ពុទ្ធវគ្គ ១ សុខវគ្គ ១ បិយវគ្គ ១ កោធវគ្គ ១ មលវគ្គ ១ ធម្មដ្ឋវគ្គ ១ មគ្គវគ្គ ១ រួមជា ២០ វគ្គ បកិណ្ណកវគ្គ ១ និរយវគ្គ ១ នាគវគ្គ ១ តណ្ហាវគ្គ ១ ភិក្ខុវគ្គ ១ ព្រាហ្មណវគ្គ ១ រួមនឹង ២០ វគ្គខាងដើមជា ២៦ វគ្គ ដែលព្រះពុទ្ធទ្រង់មានផៅពង្សដូចព្រះអាទិត្យ ទ្រង់សម្តែងហើយក្នុងយមកវគ្គ មាន ២០ គាថា អប្បមាទវគ្គមាន ១២ គាថា ចិត្តវគ្គមាន ១១ គាថា បុប្ផវគ្គ មាន ១៦ គាថា ពាលវគ្គ មាន ១៧ គាថា បណ្ឌិតវគ្គ មាន ១៤ គាថា អរហន្តវគ្គ មាន ១០ គាថា សហស្សវគ្គ មាន ១៦ គាថា ក្នុងបាបវគ្គ មាន ១៣ គាថា ក្នុងទណ្ឌវគ្គ មាន ១៧ គាថា ក្នុងជរាវគ្គ មាន ១១ គាថា ក្នុងអត្តវគ្គ មាន ១២ គាថា ក្នុងលោកវគ្គ មាន ១២ គាថា ក្នុងពុទ្ធវគ្គ មាន ១៦ គាថា ក្នុងសុខវគ្គ និងបិយវគ្គ មួយវគ្គមាន ១២ គាថា ក្នុងកោធវគ្គ មាន ១៤ គាថា ក្នុងមលវគ្គ មាន ២១ គាថា ក្នុងធម្មដ្ឋវគ្គ មាន ១៧ គាថា ក្នុងមគ្គវគ្គ មាន ១៦ គាថា ក្នុងបកិណ្ណកវគ្គ មាន ១៦ គាថា ក្នុងនិរយវគ្គ និងនាគវគ្គ មួយវគ្គ មាន ១៤ គាថា ក្នុងតណ្ហាវគ្គ មាន ២២ គាថា ក្នុងភិក្ខុវគ្គ មាន ២៣ គាថា ក្នុងព្រាហ្មណវគ្គដែលជាវគ្គចុងក្រោយ មាន ៤០ គាថា ៤២៣ គាថា ដែលព្រះពុទ្ធមានផៅពង្សនៃព្រះអាទិត្យ ទ្រង់សម្តែងក្នុងនិបាតធម្មបទ ។

**គាថាធម្មបទ ចប់**

# សរុបរឿង

អដ្ឋកថានៃធម្មបទមានប្រមាណ ៧២ ភាណវារ ដែលខ្ញុំប្រកាស មានរឿង ២៩៩ រឿង គឺក្នុងយមកវគ្គ ដែលជាវគ្គដំបូងនៃវគ្គទាំងពួង មាន ១៤ រឿង ក្នុងអប្បមាទវគ្គ ៩ រឿង ក្នុងចិត្តវគ្គ ៩ រឿង ក្នុងបុប្ផវគ្គ ១២ រឿង ក្នុងពាលវគ្គ ១៥ រឿង ក្នុងបណ្ឌិតវគ្គ ១១ រឿង ក្នុងអរហន្តវគ្គ ១០ រឿង ក្នុងសហស្សវគ្គ ១៤ រឿង ក្នុងបាបវគ្គ ១២ រឿង ក្នុងទណ្ឌវគ្គ ១១ រឿង ក្នុងជរាវគ្គ ៩ រឿង ក្នុងអត្តវគ្គ ១០ រឿង ក្នុងលោកវគ្គ ១១ រឿង ក្នុងពុទ្ធវគ្គ ៩ រឿង ក្នុងសុខវគ្គ ៨ រឿង ក្នុងបិយវគ្គ ៩ រឿង ក្នុងកោធវគ្គ ៨ រឿង ក្នុងមលវគ្គ ១២ រឿង ក្នុងធម្មដ្ឋវគ្គ ១០ រឿង ក្នុងមគ្គវគ្គ ១០ រឿង ក្នុងបកិណ្ណកវគ្គ ៩ រឿង ក្នុងនិរយវគ្គ ៩ រឿង ក្នុងនាគវគ្គ ៨ រឿង ក្នុងតណ្ហាវគ្គ ១២ រឿង ក្នុងភិក្ខុវគ្គ ១២ រឿង ក្នុងព្រាហ្មណវគ្គ ៣៩ រឿង បានរចនាល្អមសមគួរដោយអំណាចមិនសង្ខេបពេក មិនពិស្តារពេក ចប់ហើយ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

**ធម្មបទដ្ឋកថា ចប់**

# ពាក្យឧទ្ទិស

ធម្មបទដ៏កំពូល ដែលព្រះដ៏មានព្រះភាគអង្គណា ដែលជាធម្មរាជាទ្រង់សម្រេចហើយ ព្រះគាថាពួកណាក្នុងព្រះធម្មបទ មានប្រមាណ ៤២៣ គាថា តាំងឡើងហើយក្នុងរឿង ២៩៩ រឿង ដែលព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ស្វែងរកគុណធំ ទ្រង់ញ៉ាំងសច្ចៈទាំង ៤ ឲ្យជាក់ច្បាស់ ទ្រង់ភាសិតហើយ ខ្ញុំជាអ្នកនៅក្នុងប្រាសាទរបស់ព្រះបាទសិរិកូដ ក្នុងវិហារអធិរាជ ដែលមានព្រះកតញ្ញូត្រាស់ឲ្យសាងហើយ រៀបរៀងអដ្ឋកថានេះ នៃព្រះគាថាទាំងនោះ ឲ្យដល់ព្រមដោយអត្ថ និងព្យញ្ជនៈ ឲ្យអស់មន្ទិលដោយល្អ តាមព្រះបាលីមានប្រមាណ ៧២ ភាណវារ ដើម្បីប្រយោជន៍ និងដើម្បីអនុគ្រោះដល់លោក ព្រោះភាពដែលខ្ញុំជាអ្នកប្រាថ្នាដើម្បីការតាំងមាំ នៃព្រះសទ្ធម្មរបស់ព្រះលោកនាថ បានសម្រេចកុសលណាហើយ ដោយអំណាចកុសលនោះ សូមតម្រិះដែលជាកុសលទាំងពួង ចូរឲ្យផលដែលគួរប្រាថ្នា សម្រេចដល់សត្វទាំងពួង ដោយប្រការដូច្នេះ ។

# គុណព្រះពុទ្ធឃោសាចារ្យ

ព្រះថេរៈទ្រទ្រង់នូវឈ្មោះ ដែលគ្រូទាំងឡាយឲ្យហើយថា **ពុទ្ធឃោសៈ** ជាអ្នកប្រដាប់ដោយសទ្ធា ប្រាជ្ញា និងសេចក្តីព្យាយាមបរិសុទ្ធក្រៃលែង មានគុណសមុទយៈ មានសីល អាចារ ភាពជាអ្នកស្មោះត្រង់ និងភាពជាអ្នកទន់ភ្លន់ជាដើមដល់ព្រមហើយ អាចឈមចុះក្នុងការកាន់យកលទ្ធិរបស់ខ្លួន និងលទ្ធិដទៃ ប្រកបដោយការឈ្លាសនៃបញ្ញា ប្រកាសញាណដែលមិនទើសទាក់ក្នុងសត្ថុសាសនៈ មានបរិយត្តិធម៌ គឺព្រះត្រៃបិដក មួយអន្លើដោយអដ្ឋកថា ជាអ្នកជំនាញក្នុងវេយ្យាករណ៍ ជាអ្នកប្រកបដោយគន្លងនៃពាក្យពីរោះក្រៃលែង ដែលបន្លឺចេញបានស្រួល ដែលញុំាងករណសម្បត្តិឲ្យកើត ជាអ្នកមានប្រក្រតីពោលត្រឹមត្រូវ ស្ទាត់ជំនាញ ប្រសើរក្នុងពាក្យពោល ជាមហាកវី ជាអ្នកប្រដាប់វង្សរបស់ព្រះថេរៈទាំងឡាយ ដែលនៅក្នុងមហាវិហារដោយប្រក្រតី ជាបុគ្គលប្រៀបដូចប្រទីបក្នុងវង្សរបស់ព្រះថេរៈ ដែលមានការដឹងមិនទើសទាក់ ក្នុងឧត្តរិមនុស្សធម្ម ដែលប្រដាប់ដោយគុណ មានអភិញ្ញា ៦ និងបដិសម្ភិទា ៤ ជាដើម មានការដឹងបរិបូណ៌ បរិសុទ្ធ រៀបរៀងអត្ថវណ្ណនានៃព្រះធម៌នេះហើយ ។

# ក្បាលទី - ៣៤
# សុត្តន្តបិដក បាលីប្រែ - ៥២
## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

### លោកវគ្គទី ១៣ ( ២ )


រឿងភិក្ខុកំលោះ ...... ...... ...... ...... ...... ៤
រឿងព្រះបាទសុទ្ធោទនៈ ...... ...... ...... ...... ...... ៧
រឿងភិក្ខុចម្រើនវិបស្សនា ...... ...... ...... ...... ...... ១១
រឿងអភ័យរាជកុមារ ...... ...... ...... ...... ...... ១៣
រឿងព្រះសម្មជ្ជនត្ថេរ ...... ...... ...... ...... ...... ១៥
រឿងអង្គុលិមាលត្ថេរ ...... ...... ...... ...... ...... ១៨
រឿងកូនស្រីជាងតម្បាញ ...... ...... ...... ...... ...... ២០
រឿងភិក្ខុ ៣០ រូប ...... ...... ...... ...... ...... ២៨
រឿងចិញ្ចមាណវិកា ...... ...... ...... ...... ...... ៣០
រឿងអសទិសទាន ...... ...... ...... ...... ...... ៣៧
រឿងកាឡៈកូនរបស់អនាថបិណ្ឌិកសេដ្ឋី ...... ...... ...... ...... ...... ៤៥


### ពុទ្ធវគ្គទី ១៤ ( ៥០ )


រឿងមារធីតា ...... ...... ...... ...... ...... ៥៣
រឿងយមកបា្បដិហារ្យ ...... ...... ...... ...... ...... ៦២
រឿងឯរកបត្តនាគរាជ ...... ...... ...... ...... ...... ៩៩
រឿងបញ្ហារបស់ព្រះអានន្ទត្ថេរ ...... ...... ...... ...... ...... ១០៦
រឿងភិក្ខុមិនត្រេកអរ ...... ...... ...... ...... ...... ១១១
រឿងអគ្គិទត្តបុរោហិត ...... ...... ...... ...... ...... ១១៥

រឿងបញ្ហារបស់ព្រះអានន្ទ ...... ...... ...... ...... ...... ១២៥
រឿងសម្ពហុលភិក្ខុ ...... ...... ...... ...... ...... ១២៧
រឿងព្រះចេតិយមាសរបស់ព្រះកស្សបទសពល ...... ...... ...... ...... ...... ១២៩

## សុខវគ្គទី ១៥ ( ១៣៤ )

រឿងរម្ងាប់ជម្លោះនៃពួកញាតិ ...... ...... ...... ...... ...... ១៣៦
រឿងមារ ...... ...... ...... ...... ...... ១៤១
រឿងបរាជ័យរបស់ព្រះបាទកោសល ...... ...... ...... ...... ...... ១៤៣
រឿងស្រីក្នុងត្រកូលណាមួយ ...... ...... ...... ...... ...... ១៤៥
រឿងឧបាសកម្នាក់ ...... ...... ...... ...... ...... ១៤៧
រឿងព្រះបាទបសេនទិកោសល ...... ...... ...... ...... ...... ១៥០
រឿងព្រះតិស្សត្ថេរ ...... ...... ...... ...... ...... ១៥៥
រឿងសក្កទេវរាជ ...... ...... ...... ...... ...... ១៥៧

## បិយវគ្គទី ១៦ ( ១៦៣ )

រឿងបព្វជិត ៣ រូប ...... ...... ...... ...... ...... ១៦៥
រឿងកុដុម្ពិកៈម្នាក់ ...... ...... ...... ...... ...... ១៧០
រឿងនាងវិសាខាឧបាសិកា ...... ...... ...... ...... ...... ១៧៤
រឿងស្តេចលិច្ឆវី ...... ...... ...... ...... ...... ១៧៦
រឿងអនិត្ថិគន្ធកុមារ ...... ...... ...... ...... ...... ១៧៨
រឿងព្រាហ្មណ៍ម្នាក់ ...... ...... ...... ...... ...... ១៨២
រឿងកុមារ ៥០០ ...... ...... ...... ...... ...... ១៨៥
រឿងព្រះអនាគាមិត្ថេរ ...... ...... ...... ...... ...... ១៨៩
រឿងនន្ទិយឧបាសក ...... ...... ...... ...... ...... ១៩២
សុត្តន្តបិដកកោធវគ្គទី ១៧ ...... ...... ...... ...... ...... ១៩៧
រឿងព្រះនាងរោហិណី ...... ...... ...... ...... ...... ១៩៩

រឿងភិក្ខុមួយរូប ...... ...... ...... ...... ...... ២០៥
រឿងឧត្តរាឧបាសិកា ...... ...... ...... ...... ...... ២០៨
រឿងបញ្ហារបស់ព្រះមោគ្គល្លានត្ថេរ ...... ...... ...... ...... ...... ២២១
រឿងបញ្ហាដែលភិក្ខុទូលសួរ ...... ...... ...... ...... ...... ២២៤
រឿងបុណ្ណាទាសី ...... ...... ...... ...... ...... ២៣០
រឿងអតុលឧបាសក ...... ...... ...... ...... ...... ២៣៥
រឿងឆព្វគ្គិយភិក្ខុ ...... ...... ...... ...... ...... ២៤០

## មលវគ្គទី ១៨ ( ២៤៣ )

រឿងកូនរបស់គោឃាតកៈ ...... ...... ...... ...... ...... ២៤៧
រឿងព្រាហ្មណ៍ម្នាក់ ...... ...... ...... ...... ...... ២៥៥
រឿងព្រះតិស្សត្ថេរ ...... ...... ...... ...... ...... ២៥៧
រឿងព្រះលោឡុទាយិត្ថេរ ...... ...... ...... ...... ...... ២៦២
រឿងកុលបុត្រម្នាក់ ...... ...... ...... ...... ...... ២៦៦
រឿងភិក្ខុឈ្មោះចូឡសារី ...... ...... ...... ...... ...... ២៧០
រឿងឧបាសក ៥ នាក់ ...... ...... ...... ...... ...... ២៧៥
រឿងភិក្ខុកំលោះឈ្មោះតិស្សៈ ...... ...... ...... ...... ...... ២៧៨
រឿងឧបាសក ៥ នាក់ ...... ...... ...... ...... ...... ២៨២
រឿង មេណ្ឌកសេដ្ឋី ...... ...... ...... ...... ...... ២៨៧
រឿងព្រះឧជ្ឈានសញ្ញិត្ថេរ ...... ...... ...... ...... ...... ៣០១
រឿងសុភទ្ទបរិញ្វាជក ...... ...... ...... ...... ...... ៣០២

## ធម្មដ្ឋវគ្គទី ១៩ ( ៣០៦ )

រឿងមហាមាត្យអ្នកវិនិច្ឆ័យក្តី ...... ...... ...... ...... ...... ៣០៩
រឿងឆព្វគ្គិយភិក្ខុ ...... ...... ...... ...... ...... ៣១២
រឿងព្រះឯកុទានត្ថេរ ...... ...... ...... ...... ...... ៣១៤

រឿងព្រះលកុណ្ឋកភទ្ទិយត្ថេរ ...... ...... ...... ...... ...... ៣១៧
រឿងភិក្ខុច្រើនរូប ...... ...... ...... ...... ...... ៣២០
រឿងភិក្ខុឈ្មោះហត្ថកៈ ...... ...... ...... ...... ...... ៣២២
រឿងព្រាហ្មណ៍ម្នាក់ ...... ...... ...... ...... ...... ៣២៤
រឿងតិរ្ថិយ ...... ...... ...... ...... ...... ៣២៦
រឿងព្រានសន្ទូចឈ្មោះអរិយៈ ...... ...... ...... ...... ...... ៣៣០
រឿងភិក្ខុច្រើនរូប ...... ...... ...... ...... ...... ៣៣២

## មគ្គវគ្គទី ២០ ( ៣៣៥ )

រឿងភិក្ខុ ៥០០ រូប ...... ...... ...... ...... ...... ៣៣៨
រឿងភិក្ខុ ៥០០ ដទៃទៀត ...... ...... ...... ...... ...... ៣៤៣
រឿងបធានកម្មិកតិស្សត្ថេរ ...... ...... ...... ...... ...... ៣៤៦
រឿងសូករប្រេត ...... ...... ...... ...... ...... ៣៥០
រឿងព្រះបោឋិលត្ថេរ ...... ...... ...... ...... ...... ៣៥៧
រឿងព្រះថេរៈចាស់ ...... ...... ...... ...... ...... ៣៦២
រឿងសទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ ...... ...... ...... ...... ...... ៣៦៦
រឿងឈ្មួញមានទ្រព្យច្រើន ...... ...... ...... ...... ...... ៣៧១
រឿងនាងកិសាគោតមី ...... ...... ...... ...... ...... ៣៧៤
រឿងនាងបដាចារ ...... ...... ...... ...... ...... ៣៧៦

## បកិណ្ណកវគ្គទី ២១ ( ៣៧៩ )

រឿងបុព្វកម្មព្រះសាស្តា ...... ...... ...... ...... ...... ៣៨២
រឿងកុមារិកាបរិភោគពងមាន់ ...... ...... ...... ...... ...... ៣៨៧
រឿងភិក្ខុអ្នកនគរភទ្ទិយៈ ...... ...... ...... ...... ...... ៣៨៩
រឿងលកុណ្ឋកភទ្ទិយត្ថេរ ...... ...... ...... ...... ...... ៤០៣
រឿងទារុសាកដិកៈ ...... ...... ...... ...... ...... ៤០៧

រឿងភិក្ខុវជ្ជីបុត្រ ...... ...... ...... ...... ...... ៤១៤
រឿងចិត្តគហបតី ...... ...... ...... ...... ...... ៤១៨
រឿងចូឡសុភទ្ទា ...... ...... ...... ...... ...... ៤២០
រឿងព្រះថេរៈឈ្មោះឯកវិហារី ...... ...... ...... ...... ...... ៤២៨

## និរយវគ្គទី ២២ ( ៤៣០ )

រឿងនាងបរិព្វាជិកាឈ្មោះសុន្ទរី ...... ...... ...... ...... ...... ៤៣៣
រឿងសត្វដែលត្រូវទុក្ខបៀតបៀន ...... ...... ...... ...... ...... ៤៣៨
រឿងភិក្ខុនៅត្រង់ច្រាំងស្ទឹងឈ្មោះវគ្គុមុទា ...... ...... ...... ...... ...... ៤៤០
រឿងសេដ្ឋីបុត្រឈ្មោះខេមកៈ ...... ...... ...... ...... ...... ៤៤២
រឿងភិក្ខុប្រដៅក្រ ...... ...... ...... ...... ...... ៤៤៥
រឿងស្រីច្នាស ...... ...... ...... ...... ...... ៤៤៨
រឿងអាគន្តុកភិក្ខុ ...... ...... ...... ...... ...... ៤៥០
រឿងនិគ្គណ្ឋ ...... ...... ...... ...... ...... ៤៥៣
រឿងសាវកតិត្ថិយ ...... ...... ...... ...... ...... ៤៥៦

## នាគវគ្គទី ២៣ ( ៤៦០ )

រឿងរបស់ព្រះសាស្តា ...... ...... ...... ...... ...... ៤៦៣
រឿងភិក្ខុធ្លាប់ជាហត្ថាចារ្យ ...... ...... ...... ...... ...... ៤៦៨
រឿងកូនរបស់ព្រាហ្មណ៍ចាស់ជរា ...... ...... ...... ...... ...... ៤៧០
រឿងព្រះបាទបសេនទិកោសល ...... ...... ...... ...... ...... ៤៧៨
រឿងសានុសាមណេរ ...... ...... ...... ...... ...... ៤៨១
រឿងដំរីឈ្មោះបាវេរកៈ ...... ...... ...... ...... ...... ៤៨៨
រឿងសម្ពហុលភិក្ខុ ...... ...... ...... ...... ...... ៤៩០
រឿងមារ ...... ...... ...... ...... ...... ៤៩៦

## តណ្ហាវគ្គទី ២៤ ( ៥០២ )


| | |
|---|---|
| រឿងកបិលមច្ឆៈ ...... ...... ...... ...... ...... | ៥០៧ |
| រឿងជ្រូកញី ...... ...... ...... ...... ...... | ៥១៧ |
| រឿងវិព្ភន្តកភិក្ខុ ...... ...... ...... ...... ...... | ៥២៦ |
| រឿងពន្ធនាគារ ...... ...... ...... ...... ...... | ៥២៩ |
| រឿងព្រះនាងខេមា ...... ...... ...... ...... ...... | ៥៣៤ |
| រឿងឧគ្គសេនសេដ្ឋីបុត្រ ...... ...... ...... ...... ...... | ៥៣៧ |
| រឿងចូឡធនុគ្គហបណ្ឌិត ...... ...... ...... ...... ...... | ៥៤៦ |
| រឿងមារ ...... ...... ...... ...... ...... | ៥៥២ |
| រឿងឧបកាជីវក ...... ...... ...... ...... ...... | ៥៥៦ |
| រឿងសក្កទេវរាជ ...... ...... ...... ...... ...... | ៥៥៨ |
| រឿងអបុត្តកសេដ្ឋី ...... ...... ...... ...... ...... | ៥៦៤ |
| រឿងអង្កុរទេវបុត្រ ...... ...... ...... ...... ...... | ៥៦៩ |


## ភិក្ខុវគ្គទី ២៥ ( ៥៧២ )


| | |
|---|---|
| រឿងភិក្ខុ ៥ រូប ...... ...... ...... ...... ...... | ៥៧៦ |
| រឿងភិក្ខុសម្លាប់ហង្ស ...... ...... ...... ...... ...... | ៥៨១ |
| រឿងកោកាលិកភិក្ខុ ...... ...... ...... ...... ...... | ៥៨៧ |
| រឿងព្រះធម្មារាមត្ថេរ ...... ...... ...... ...... ...... | ៥៩០ |
| រឿងភិក្ខុណាមួយ ...... ...... ...... ...... ...... | ៥៩៣ |
| រឿងបញ្ចគ្គទាយកព្រាហ្មណ៍ ...... ...... ...... ...... ...... | ៥៩៧ |
| រឿងសម្ពហុលភិក្ខុ ...... ...... ...... ...... ...... | ៦០២ |
| រឿងភិក្ខុ ៥០០ រូប ...... ...... ...... ...... ...... | ៦១៨ |
| រឿងព្រះសន្តកាយត្ថេរ ...... ...... ...... ...... ...... | ៦១៩ |

រឿងព្រះនង្គលកូដត្ថេរ ...... ...... ...... ...... ...... ៦២២

រឿងព្រះវក្កលិត្ថេរ ...... ...... ...... ...... ...... ៦២៦

រឿងសុមនសាមណេរ ...... ...... ...... ...... ...... ៦២៩


## ព្រាហ្មណវគ្គទី ២៦ ( ៦៤៩ )


រឿងព្រាហ្មណ៍មានសេចក្តីជ្រះថ្លាច្រើន ...... ...... ...... ...... ...... ៦៥៨

រឿងភិក្ខុច្រើនរូប ...... ...... ...... ...... ...... ៦៦១

រឿងមារ ...... ...... ...... ...... ...... ៦៦២

រឿងព្រាហ្មណ៍ម្នាក់ ...... ...... ...... ...... ...... ៦៦៤

រឿងព្រះអានន្ទត្ថេរ ...... ...... ...... ...... ...... ៦៦៥

រឿងបព្វជិតមួយរូប ...... ...... ...... ...... ...... ៦៦៨

រឿងព្រះសារីបុត្តត្ថេរ ...... ...... ...... ...... ...... ៦៧០

រឿងព្រះនាងមហាបជាបតិគោតមី ...... ...... ...... ...... ...... ៦៧៥

រឿងព្រះសារីបុត្តត្ថេរ ...... ...... ...... ...... ...... ៦៧៧

រឿងជដិលព្រាហ្មណ៍ ...... ...... ...... ...... ...... ៦៧៩

រឿងកុហកព្រាហ្មណ៍ ...... ...... ...... ...... ...... ៦៨០

រឿងកិសាគោតមី ...... ...... ...... ...... ...... ៦៨៥

រឿងព្រាហ្មណ៍ម្នាក់ ...... ...... ...... ...... ...... ៦៨៧

រឿងឧគ្គសេន ...... ...... ...... ...... ...... ៦៨៩

រឿងព្រាហ្មណ៍ពីរនាក់ ...... ...... ...... ...... ...... ៦៩០

រឿងអក្កោសកភារទ្វាជព្រាហ្មណ៍ ...... ...... ...... ...... ...... ៦៩៣

រឿងព្រះសារីបុត្តត្ថេរ ...... ...... ...... ...... ...... ៦៩៦

រឿងឧប្បលវណ្ណាថេរី ...... ...... ...... ...... ...... ៦៩៨

រឿងព្រាហ្មណ៍ម្នាក់ ...... ...... ...... ...... ...... ៧០០

រឿងខេមាភិក្ខុនី ...... ...... ...... ...... ...... ៧០១

| | |
|---|---|
| រឿងព្រះតិស្សត្ថេរអ្នកនៅក្នុងញកក្នុំ ...... ...... ...... ...... ...... | ៧០៣ |
| រឿងភិក្ខុមួយរូប ...... ...... ...... ...... ...... | ៧០៩ |
| រឿងសាមណេរ ...... ...... ...... ...... ...... | ៧១២ |
| រឿងព្រះមហាបន្ថកត្ថេរ ...... ...... ...... ...... ...... | ៧១៨ |
| រឿងព្រះបិលិន្ទវច្ឆត្ថេរ ...... ...... ...... ...... ...... | ៧២០ |
| រឿងភិក្ខុមួយរូប ...... ...... ...... ...... ...... | ៧២២ |
| រឿងព្រះសារីបុត្តត្ថេរ ...... ...... ...... ...... ...... | ៧២៤ |
| រឿងព្រះមហាមោគ្គល្លានត្ថេរ ...... ...... ...... ...... ...... | ៧២៦ |
| រឿងព្រះរេវតត្ថេរ ...... ...... ...... ...... ...... | ៧២៨ |
| រឿងព្រះចន្ទាភត្ថេរ ...... ...... ...... ...... ...... | ៧៣០ |
| រឿងព្រះសីវលិត្ថេរ ...... ...... ...... ...... ...... | ៧៣៦ |
| រឿងព្រះសុន្ទរសមុទ្ទត្ថេរ ...... ...... ...... ...... ...... | ៧៣៩ |
| រឿងព្រះជោតិកត្ថេរ ...... ...... ...... ...... ...... | ៧៤៦ |
| រឿងភិក្ខុធ្លាប់ជាអ្នករបាំមួយរូប ...... ...... ...... ...... ...... | ៧៧៧ |
| រឿងភិក្ខុធ្លាប់ជាអ្នករបាំមួយរូបទៀត ...... ...... ...... ...... ...... | ៧៧៩ |
| រឿងព្រះវង្គីសត្ថេរ ...... ...... ...... ...... ...... | ៧៨០ |
| រឿងព្រះនាងធម្មទិន្នាថេរី ...... ...... ...... ...... ...... | ៧៨៥ |
| រឿងព្រះអង្គុលិមាលត្ថេរ ...... ...... ...... ...... ...... | ៧៨៨ |
| រឿងទេវហិតព្រាហ្មណ៍ ...... ...... ...... ...... ...... | ៧៩០ |